# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៤៦

បាលីប្រែ ៥៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# ជាតកដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ជាតក

## សត្តមភាគ

# ៤៦

## បាលីប្រែ ៥៨



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី៤៦
# ខុទ្ទកនិកាយ ជាតក

## ទសកវគ្គ
## រាជោវាទជាតក

[ ១៥១ ] ( សារថីរបស់ព្រះបាទពល្លិកពោលថា ) ព្រះបាទពល្លិករមែងបោះនូវរបស់មាំ ដល់បុគ្គលអ្នកមាំ ឈ្នះនូវបុគ្គលទន់ ដោយកិរិយាទន់ ឈ្នះនូវសប្បុរសដោយសប្បុរស ឈ្នះនូវអសប្បុរសដោយអសប្បុរស ព្រះរាជានេះ ( មានសីលនិងអាចារៈ ) ប្រាកដដូច្នេះ ម្នាលសារថីអ្នកចូរចៀសចេញអំពីផ្លូវទៅ ។

[ ១៥២ ] ( សារថីរបស់ព្រះបាទពារាណសីពោលថា ) ព្រះរាជាគប្បីឈ្នះបុគ្គលអ្នកក្រោធ ដោយសេចក្តីមិនក្រោធ គប្បីឈ្នះអសប្បុរសដោយសប្បុរស គប្បីឈ្នះបុគ្គលកំណាញ់ ដោយការឲ្យ គប្បីឈ្នះបុគ្គលអ្នកពោលពាក្យកុហកដោយការពោលពាក្យពិត ព្រះរាជានេះ ( មានសីលនិងអាចារៈ ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ ។

**ចប់ រាជោវាទជាតកទី ១ ។**

## អដ្ឋកថា
## ខុទ្ទកនិកាយ ជាតកដ្ឋកថា
## ទុកនិបាត

# ទឡ្ហវគ្គ
## អដ្ឋកថា រាជោវាទជាតក

[ ១៥១-១៥២ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធឱវាទរបស់ព្រះរាជា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ទឡ្ហំ ទឡ្ហស្ស ខិបតិ** *ដូច្នេះជាដើម ។*

*ឱវាទរបស់ព្រះរាជានោះ មានជាក់ច្បាស់ក្នុងតេសកុណជាតក ។ ក្នុងថ្ងៃមួយ ព្រះបាទកោសលទ្រង់វិនិច្ឆ័យក្តីរឿងមួយដែលវិនិច្ឆ័យមិនល្អ មានអគតិស្រេចហើយ សោយព្រះក្រយាហារព្រឹក ទាំងដែលមានព្រះហស្តសើមទ្រង់ឡើងរាជរថដែលរៀបចំទុកហើយ ទ្រង់ចូលទៅគាល់ព្រះសាស្តា ទ្រង់ក្រាបចុះទៀបបាទាដ៏មានសិរីដូចផ្កាឈូករីក ថ្វាយបង្គំព្រះសាស្តា ប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាបានត្រាស់បដិសណ្ឋារៈជាមួយព្រះបាទកោសលថា មហាបពិត្រ ទ្រង់យាងមកអំពីណាទាំងកណ្តាលថ្ងៃ ព្រះបាទកោសលទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះខ្ញុំព្រះអង្គវិនិច្ឆ័យក្តីរឿងមួយដែលវិនិច្ឆ័យមិនល្អ ទើបមិនមានឱកាស ឥឡូវនេះពិចារណាក្តីនោះ*

ស្រេចហើយ ទើបបរិភោគអាហារទាំងដៃនៅសើមមកគាល់ព្រះអង្គនេះឯង ។ ព្រះសាស្តាត្រាស់ថា សូមថ្វាយព្រះពរ ការវិនិច្ឆ័យក្តីដោយទំនងគន្លងធម៌ជាការល្អ ជាផ្លូវនៃស្ថានសួគ៌ពិត ការដែលមហាបពិត្របានទូវឱវាទអំពីសម្នាក់របស់បុគ្គលដែលជាសព្វញ្ញូដូចតថាគត ទ្រង់វិនិច្ឆ័យក្តីដោយគន្លងធម៌នេះមិនអស្ចារ្យឡើយ ការដែលព្រះរាជាទាំងឡាយក្នុងកាលមុន ទ្រង់ស្តាប់ឱវាទរបស់ពួកបណ្ឌិតដែលមិនមែនជាសព្វញ្ញូហើយទ្រង់វិនិច្ឆ័យក្តីតាមគន្លងធម៌វៀរអគតិ ៤ យ៉ាង បំពេញទសពិធរាជធម៌មិនឲ្យសាបសូន្យ សោយរាជ្យដោយធម៌ បំពេញផ្លូវសួគ៌ យាងទៅហើយនេះឯងគួរអស្ចារ្យ ។ ព្រះបាទកោសលទូលអារាធនា ទើបទ្រង់នាំរឿងក្នុងអតីតមកនិទានថ្វាយថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យនៅក្នុងនគរពារាណសី ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះបានទទួលការបរិហារគភ៌យ៉ាងល្អ ទ្រង់ប្រសូតចាកផ្ទៃនៃព្រះមាតាដោយសួស្តី ។ ក្នុងថ្ងៃថ្វាយព្រះនាម ព្រះជនកជននីបានតាំងព្រះនាមរបស់ព្រះពោធិសត្វថា ព្រហ្មទត្តកុមារ ។

ព្រហ្មទត្តកុមារនោះបានចម្រើនវ័យឡើងដោយលំដាប់ កាលព្រះជន្មបាន ១៦ វស្សា យាងទៅនគរតក្កសិលា ទ្រង់សម្រេចសិប្បៈគ្រប់យ៉ាង កាលព្រះជនកសោយទិវង្គត ទ្រង់តាំងនៅក្នុងរាជសម្បត្តិ គ្រប់គ្រងរាជសម្បត្តិតាមគន្លងធម៌ ទ្រង់វិនិច្ឆ័យក្តីមិនលុះអគតិ មានឆន្ទាគតិជាដើម ។ កាលទ្រង់សោយរាជសម្បត្តិដោយធម៌យ៉ាងនេះ សូម្បីពួកអាមាត្យក៏នាំគ្នាវិនិច្ឆ័យក្តី ដោយធម៌

ដូចគ្នា ។ កាលក្តីទាំងឡាយបានទទួលការវិនិច្ឆ័យ ដោយធម៌ទើបមិនមានក្តីកោងកើតឡើងព្រោះមិនមានក្តីកោងទាំងនោះ ការស្រែកតវ៉ាជាទុក្ខក្នុងលានព្រះរាជវាំងដើម្បីឲ្យកើតក្តីក៏អស់ទៅ ។ ពួកអាមាត្យអង្គុយលើបល្ល័ង្កវិនិច្ឆ័យអស់មួយថ្ងៃមិនឃើញបុគ្គលណាម្នាក់មកឲ្យវិនិច្ឆ័យក្តី ក៏ក្រោកត្រឡប់ទៅ ។ ទីវិនិច្ឆ័យក្តីក៏ត្រូវទំនេរ ។

ព្រះពោធិសត្វទ្រង់ត្រិះរិះថា បើអញគ្រប់គ្រងរាជសម្បត្តិដោយធម៌ មិនមានបុគ្គលមកឲ្យវិនិច្ឆ័យក្តី មិនមានបុគ្គលមកតវ៉ា ទីវិនិច្ឆ័យក្តីក៏ត្រូវទំនេរឥឡូវនេះ អញគួរពិនិត្យមើលទោសរបស់ខ្លួន កាលអញដឹងថានេះជាទោសរបស់អញ នឹងលះទោសនោះចោលប្រព្រឹត្តក្នុងវត្ថុដែលជាគុណប៉ុណ្ណោះ ។ ចាប់តាំងអំពីនោះមកព្រះពោធិសត្វក៏ទ្រង់ពិនិត្យមើលថា តើមានបុគ្គលណាម្នាក់និយាយដល់ទោសរបស់អញដែរឬហ្ន៎ កាលទ្រង់មិនឃើញបុគ្គលណាមួយពោលដល់ទោសក្នុងរវាងខ្ញុំរាជការខាងក្នុង ទ្រង់ស្តាប់តែពាក្យសរសើរគុណរបស់ទ្រង់តែម្យ៉ាង ទ្រង់ព្រះតម្រិះថា ប្រហែលជាជនទាំងនេះខ្លាចអញទើបមិនពោលដល់ទោស ពោលតែគុណប៉ុណ្ណោះ ទើបទ្រង់ស៊ើបរាជបរិវារខាងក្រៅ សូម្បីក្នុងរាជបរិវារទាំងនោះ ក៏ទ្រង់មិនឃើញទើបទ្រង់សាកសួរអ្នកខាងក្នុងព្រះនគរ ទ្រង់សាកសួរអ្នកស្រុកត្រង់ទ្វារទាំង ៤ ខាងក្រៅព្រះនគរ ក្នុងទីនោះទ្រង់មិនបានឃើញបុគ្គលណាមួយពោលដល់ទោស ទ្រង់ស្តាប់តែពាក្យសរសើររបស់ព្រះអង្គតែម្យ៉ាង ទើបទ្រង់ព្រះតម្រិះថា អញនឹងស៊ើបតាមជនបទមើល ដូច្នេះទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ពួកអាមាត្យ ឡើងរថទៅជា

មួយសារថីប៉ុណ្ណោះ ទ្រង់ក្លែងភេទមិនឲ្យអ្នកណាស្គាល់ យាងចេញអំពីព្រះនគរ ព្យាយាមស៊ើបអ្នកជនបទរហូតដល់ជាយដែន ក៏មិនបានឃើញបុគ្គលណាម្នាក់ពោលដល់ទោស ទ្រង់ឮតែពាក្យសរសើរគុណទើបទ្រង់ត្រឡប់អំពីជាយដែនបែរព្រះភក្ត្រទៅកាន់ព្រះនគរតាមផ្លូវដែលមកអំពីជាយដែន ។

ក្នុងកាលនោះ ព្រះបាទកោសលព្រះនាមថាពល្លិក ក៏ទ្រង់គ្រប់គ្រងរាជ-សម្បត្តិដោយធម៌ ទ្រង់ស៊ើបរកទោសក្នុងបណ្តាខ្ញុំរាជការខាងក្នុងជាដើម មិនបានឃើញបុគ្គលណាម្នាក់ពោលដល់ទោសឡើយ ទ្រង់ឮតែពាក្យសរសើរគុណរបស់ទ្រង់ដូចគ្នាទើបទ្រង់ស៊ើបសួរអ្នកជនបទរហូតដល់ប្រទេសនោះ ។

ក្សត្រទាំង ២ អង្គបានជួបគ្នាត្រង់ផ្លូវរទេះមួយកន្លែងដែលមិនអាចចៀសគ្នាបាន សារថីរបស់ព្រះបាទពល្លិក និយាយនឹងសារថីរបស់ព្រះបាទពារាណសីថា ចូរចៀសរថរបស់អ្នក សារថីរបស់ព្រះបាទពារាណសីក៏ឆ្លើយថា ចូរអ្នកចៀសរថរបស់អ្នកចុះ លើរថនេះព្រះបាទព្រហ្មទត្តមហារាជ គ្រប់គ្រងរាជ-សម្បត្តិក្នុងក្រុងពារាណសីប្រថាប់គង់ សារថីម្ខាងទៀតក៏ពោលថា លើរថនេះព្រះបាទពល្លិកមហារាជ គ្រប់គ្រងរាជសម្បត្តិ ក្នុងដែនកោសលប្រថាប់គង់ចូរអ្នកចៀសរថរបស់អ្នក ហើយឲ្យឱកាសដល់រថព្រះរាជារបស់យើងចុះ ។

សារថីរបស់ព្រះបាទពារាណសីត្រិះរិះថា សូម្បីអ្នកដែលអង្គុយក្នុងរថនេះក៏ជាព្រះរាជាដូចគ្នា អញគួរធ្វើយ៉ាងណាល្អ ក៏គិតបានថា មានឧបាយមួយអញនឹងសួរដល់វ័យឲ្យរថរបស់ព្រះរាជាកំលោះចៀសចេញទៅ ហើយឲ្យព្រះរាជទានឱកាស ដល់ព្រះរាជាចាស់ លុះសម្រេចចិត្តហើយទើបសួរដល់វ័យ

របស់ព្រះបាទកោសលនឹងសារថី ហើយកំណត់ទុក កាលដឹងថាព្រះរាជាទាំង ២ មានវ័យស្មើគ្នាទើបសួរដល់ប្រមាណរាជសម្បត្តិ កម្លាំង ទ្រព្យ យស ជាតិ គោត្ត ត្រកូល ប្រទេស លុះដឹងថា ទាំង ២ ចំណែកជាអ្នកគ្រប់គ្រងរាជសីមាប្រមាណ ៣០០ យោជន៍ដូចគ្នាមានកម្លាំង ទ្រព្យ យស ជាតិ គោត្ត ត្រកូលនិងប្រទេសស្មើគ្នាហើយគិតទៀតថា យើងនឹងឲ្យឱកាសដល់ព្រះរាជាដែលមានសីលទើបសួរថា សីលនិងមារយាទ របស់ព្រះរាជារបស់អ្នកដូចម្តេច កាលប្រកាសវត្ថុដែលជាទោសនៃព្រះរាជារបស់ខ្លួន ដោយនឹកស្មានថាជាគុណ ទើបពោលគាថាដំបូងថា

> ព្រះបាទពល្លិក រមែងបោះនូវរបស់មាំដល់បុគ្គលអ្នកមាំ ឈ្នះនូវបុគ្គលទន់ដោយកិរិយាទន់ ឈ្នះនូវសប្បុរសដោយសប្បុរស ឈ្នះនូវអសប្បុរសដោយអសប្បុរស ព្រះរាជានេះ ( មានសីលនិងអាចារៈ ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទឡ្ហំ ទឡ្ហស្ស ខិបតិ** សេចក្តីថា សារថីនៃព្រះបាទពល្លិកប្រាប់ថា ព្រះបាទពល្លិករាជ ទ្រង់ឲ្យនូវការប្រហារឬព្រះវាចាគ្រោតគ្រាត ដែលទ្រង់គប្បីឈ្នះបានដោយការប្រហារ ឬដោយព្រះវាចាដែលគ្រោតគ្រាតមានកម្លាំងប៉ុណ្ណោះ ។ បទថា **ពល្លិកោ** ជាឈ្មោះនៃព្រះរាជាអង្គនោះ ។

បទថា **មុទុនា មុទុំ** សេចក្តីថា ព្រះបាទពល្លិកទ្រង់ជាអ្នកទន់ភ្លន់ទើប

ឈ្នះបុគ្គលដែលទន់ភ្លន់ដោយឧបាយដែលទន់ភ្លន់ពិត ។ បទថា **សាធុម្បិ សាធុនា ជេតិ អសាធុម្បិ អសាធុនា** សេចក្តីថា សារថីរបស់ព្រះបាទពល្លិកចន្លុលបង្ហាញតទៅថា ជនទាំងឡាយណាជាមនុស្សល្អ គឺជាសប្បុរស ទ្រង់ប្រើភាពល្អឈ្នះជនទាំងនោះ ដោយឧបាយដែលល្អ ។ ឯជនណាជាអសប្បុរស ទ្រង់ប្រើភាពមិនល្អ ឈ្នះជនទាំងនោះដោយឧបាយមិនល្អដូចគ្នា ។

បទថា **ឯតាទិសោ អយំ រាជា** សេចក្តីថា ព្រះបាទកោសលរបស់ពួកយើងទ្រង់ប្រកបដោយសីលនិងមារយាទបែបនេះ ។ បទថា **មគ្គា ឧយ្យាហិ សារថិ** សេចក្តីថា សារថីរបស់ព្រះបាទពល្លិកពោលថា ចូរអ្នកចៀសរថរបស់ខ្លួនអំពីផ្លូវ គឺចូរទៅខាងក្រៅផ្លូវ ឲ្យផ្លូវដល់ព្រះរាជារបស់ពួកយើង ។

សម័យនោះ សារថីរបស់ព្រះបាទពារាណសី ពោលនឹងសារថីរបស់ព្រះបាទពល្លិកថា អ្នកពោលដល់គុណរបស់ព្រះរាជានៃអ្នកឬ កាលសារថីនោះឆ្លើយថា ពិតហើយ ទើបសារថីរបស់ព្រះបាទពារាណសីពោលថា បើទាំងនេះជាគុណធម៌ដែលជាទោសតើដូចម្តេច សារថីរបស់ព្រះបាទពល្លិក ពោលថា ទាំងនេះជាទោសក៏ដោយចុះ តើព្រះរាជារបស់អ្នកមានព្រះគុណដូចម្តេច សារថីរបស់ព្រះបាទពារាណសីពោលថា បើដូច្នោះ ចូរអ្នកស្តាប់ រួចពោលគាថាទី ២ ថា

ព្រះរាជា គប្បីឈ្នះបុគ្គលអ្នកក្រោធ ដោយសេចក្តីមិនក្រោធ
គប្បីឈ្នះអសប្បុរសដោយសប្បុរស គប្បីឈ្នះបុគ្គលកំណាញ់
ដោយការឲ្យគប្បីឈ្នះបុគ្គលអ្នកពោលពាក្យកុហកដោយការ

ពោលពាក្យពិត ព្រះរាជានេះ ( មានសីលនិងអាចារៈ ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯតាទិសោ** សេចក្ដីថា ព្រះរាជាទ្រង់ប្រកបដោយគុណទាំងនេះ ដែលពោលទុកដោយន័យជាដើមថា គប្បីឈ្នះអ្នកក្រោធដោយការមិនក្រោធដូច្នេះ អធិប្បាយថា ព្រះរាជាអង្គនេះទ្រង់មិនក្រោធ ទ្រង់ឈ្នះបុគ្គលអ្នកក្រោធ ដោយការមិនក្រោធ ទ្រង់ជាសប្បុរស ទ្រង់ឈ្នះអសប្បុរសដោយសេចក្ដីល្អ ទ្រង់ជាអ្នកបរិច្ចាគ ទ្រង់ឈ្នះអ្នកកំណាញ់ ដោយបរិច្ចាគ ។ បទថា **សច្ចេនាលិកវាទិនំ** សេចក្ដីថា ទ្រង់ត្រាស់តែពាក្យពិត ទើបទ្រង់ឈ្នះអ្នកពោលឡេះឡោះដោយពាក្យពិត ។

បទថា **មគ្គា ឧយ្យាហិ សារថិ** សេចក្ដីថា សារថីរបស់ព្រះបាទពារាណសីពោលថា សារថីជាសម្លាញ់ ចូរចៀសផ្លូវឲ្យផ្លូវដល់ព្រះរាជារបស់ពួកយើងដែលប្រកបដោយគុណ គឺសីលនិងមារយាទយ៉ាងនេះ ព្រះរាជារបស់យើងសមគួរដល់ផ្លូវធ្វើដំណើរ ។

កាលសារថីរបស់ព្រះបាទពារាណសីពោលយ៉ាងនេះហើយព្រះបាទពល្លិកនិងសារថីទាំង ២ ក៏ចុះអំពីរថ ដោះសេះថយរថ ឲ្យផ្លូវដល់ព្រះបាទពារាណសី ។ ព្រះបាទពារាណសីថ្វាយឱវាទដល់ព្រះបាទពល្លិកថា ធម្មតាព្រះរាជាទ្រង់គួរធ្វើយ៉ាងនេះៗ ហើយយាងទៅក្រុងពារាណសី ទ្រង់ធ្វើបុណ្យមានទានជាដើម ទ្រង់ធ្វើផ្លូវទៅកាន់ស្ថានសួគ៌ឲ្យបរិបូណ៌ជរាបដល់អស់ព្រះជន្ម ។

ព្រះបាទពល្លិក ទ្រង់ទទួលឱវាទរបស់ព្រះបាទពារាណសី ទ្រង់ស៊ើបអ្នក

ជនបទ មិនឃើញមានបុគ្គលពោលទោស របស់ព្រះអង្គ ទ្រង់យាងទៅកាន់នគរធ្វើកុសលមានទានជាដើម ទ្រង់ធ្វើផ្លូវទៅកាន់ស្ថានសួគ៌ ឲ្យបរិបូណ៌ដរាបដល់អស់ព្រះជន្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមក ដើម្បីថ្វាយឱវាទដល់ព្រះបាទកោសល ហើយទ្រង់ប្រជុំជាតកថា សារថីរបស់ព្រះបាទពល្លិកក្នុងកាលនោះ បានមកជាមោគ្គល្លាន ព្រះបាទពល្លិកក្នុងកាលនោះ បានមកជាអានន្ទ សារថីរបស់ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាសារីបុត្ត ឯព្រះបាទពារាសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថារាជោវាទជាតក ចប់

## សិគាលជាតក

[ ១៥៣ ] ( រាជសីហ៍ពោធិសត្វពោលថា ) ការងារទាំងឡាយនោះ ញ៉ាំងបុគ្គលអ្នកមានការងារមិនបានពិចារណាដោយត្រឹមត្រូវ ឲ្យសម្រេចដោយរួសរាន់ ឲ្យក្តៅក្រហាយ ដូចជាវត្ថុក្តៅដែលបុគ្គលពមចូលទៅក្នុងមាត់ ។

[ ១៥៤ ] ( ព្រះសាស្តាត្រាស់ថា ) សីហៈញ៉ាំងភ្នំប្រាក់ឲ្យលាន់ឮខ្លាំងដោយសីហនាទ ចចកនៅក្នុងភ្នំប្រាក់បានឮសំឡេងគឹកកងនៃសត្វសីហៈហើយក៏ភ័យតក់ស្លុតបែកហឫទ័យស្លាប់ ។

**ចប់ សិគាលជាតកទី ២ ។**

## អដ្ឋកថា

## សិង្គាលជាតក

[ ១៥៣-១៥៤ ] ព្រះសាស្តាកាលគង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធបុត្តរបស់ជាងកោរកាត់ម្នាក់ ដែលនៅក្នុងក្រុងវេសាលី ហើយត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសមេក្ខិតកម្មន្តំ** ដូច្នេះជាដើម ។

បានឮថា បិតារបស់កុមារនោះជាអ្នកមានសទ្ធាជ្រះថ្លាដល់នូវត្រៃសរណគមន៍ សមាទានសីល ៥ ធ្វើកិច្ចគ្រប់យ៉ាងមានកោរព្រះមស្សុ កាត់ព្រះកេសា រៀបក្តារបាស្កាដល់ព្រះរាជា ព្រះមហេសី ព្រះរាជកុមារ និងព្រះរាជកុមារី ញ៉ាំងកាលឲ្យកន្លងទៅ ដោយការស្តាប់ធម៌របស់ព្រះសាស្តារឿយៗ ថ្ងៃមួយបិតាទៅធ្វើការក្នុងរាជនិវេសន៍ នាំកុមារនោះទៅដែរ កូននោះឃើញនាងកុមា

រិការបស់ស្តេចលិច្ឆវីមួយអង្គប្រដាប់តាក់តែង ដោយគ្រឿងអលង្ការប្រៀបដូចទេពអប្សរក្នុងរាជនិវេសន៍នោះ មានចិត្តប្រតិព័ទ្ធដោយអំណាចកិលេស កាលចេញអំពីព្រះរាជនិវេសន៍ជាមួយឪពុក គិតថាបើអញបានកុមារិកានេះទើបមានជីវិត បើមិនបានអញនឹងស្លាប់ក្នុងទីនេះឯង ទើបអត់អាហារដេកសុបសៅនៅលើគ្រែ ។

លំដាប់នោះ បិតាចូលទៅរកបុត្តនិយាយថា នែកូន កូនកុំធ្វើសេចក្តីពេញចិត្តក្នុងវត្ថុដែលមិនគួរឡើយ កូនជាមនុស្សមានកំណើតថោកទាប ជាកូនជាងកោរកាត់ ចំណែកកុមារិការបស់ស្តេចលិច្ឆវីជាធីតាក្សត្រ សម្បូរដោយជាតិ នាងមិនសមគួរដល់បាទេ ឪពុកនិងនាំកុមារិកាដទៃ ដែលសមដោយជាតិនិងគោត្តមកឲ្យកូន ។ កូននោះមិនបានស្តាប់ពាក្យរបស់ឪពុក តមក ញាតិមិត្តសម្លាញ់ គឺមាតា បងប្រុស ប្អូនស្រី មីងមា ទាំងអស់ប្រជុំគ្នាចង្អុលបង្ហាញក៏មិនអាចឲ្យយល់ព្រមបាន កុមារស្គមស្ងួកស្ងាំង ដេកស្លាប់នៅលើគ្រែនោះឯង ។ ឪពុករបស់កុមារនោះធ្វើឈាបនកិច្ចស្រេចហើយ កាលសេចក្តីសោកធូរស្បើយហើយគិតថា អញនឹងថ្វាយបង្គំព្រះសាស្តា ទើបកាន់គ្រឿងក្រអូបមានផ្កា ដែលមានក្លិនក្រអូបជាដើម ជាច្រើនទៅកាន់ព្រៃមហាវ័ន បូជាព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង កាលព្រះសាស្តាត្រាស់សួរថា ម្នាលឧបាសក ព្រោះហេតុអ្វី ទើបអ្នកមិនប្រាកដច្រើនថ្ងៃហើយ បុរសនោះក្រាបទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ព្រះសាស្តាត្រាស់ថាម្នាលឧបា-សក កូនរបស់អ្នកកើតការពេញចិត្តក្នុងវត្ថុ ដែលមិនសមគួរ ហើយដល់នូវ

សេចក្ដីវិនាស មិនមែនតែក្នុងឥឡូវនេះទេ សូម្បីក្នុងកាលមុនកូនរបស់អ្នកក៏ដល់នូវសេចក្ដីវិនាសមកហើយ កាលទូលអារាធនា ទើបទ្រង់នាំរឿងក្នុងអតីតមកថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតរាជសីហ៍ក្នុងព្រៃហិមពាន្ត ។ រាជសីហ៍នោះមានប្អូនប្រុស ៦ មានប្អូនស្រី ១ ។ រាជសីហ៍ទាំងនោះអាស្រ័យនៅក្នុងគុហាមាស ។ នៅឯវេជតបពិត មិនឆ្ងាយអំពីគុហានោះ មានគុហាកែវផលិកមួយ គុហាកែវផលិកនោះ មានចចកមួយអាស្រ័យនៅ ។ ចំណេរកាលតមក មេបារាជសីហ៍ទាំងឡាយក៏ស្លាប់ទៅ រាជសីហ៍ជាបងទាំងនោះ ឲ្យរាជសីហ៍ញីជាប្អូននៅក្នុងគុហា ហើយចេញទៅរកអាហារ នាំសាច់មកឲ្យប្អូនស្រី ចចកឃើញរាជសីហ៍ញីនោះ មានចិត្តប្រតិព័ទ្ធ តែកាលមេបារបស់រាជសីហ៍ញីមិនទាន់ស្លាប់ ទើបចចកមិនបានឱកាស ក្នុងកាលដែលរាជសីហ៍បងប្អូនទាំង ៧ ចេញទៅរកអាហារ ទើបចចកចុះពីគុហាកែវផលិក ទៅកាន់គុហាមាសពោលវាចាផ្ដេះផ្ដងដែល ប្រកបដោយលោកាមិស ចំពោះមុខរាជសីហ៍ញីថា នែនាងរាជសីហ៍តូច យើងមានជើង ៤ នាងក៏មានជើង ៤ ចូរនាងជាកិរិយារបស់យើងចុះ យើងជាប្ដីរបស់នាង យើងទាំង ២ នឹងរួមរក្សយ៉ាងរីករាយតាំងអំពីនេះទៅ ចូរនាងនៅរួមជាមួយយើងដោយអំណាចកិលេស ។ រាជសីហ៍ញីស្ដាប់ពាក្យចចកហើយគិតថា ចចកនេះជាសត្វថោកទាប គួរខ្ពើមដូចគ្នានឹងចណ្ឌាល ក្នុងរវាងសត្វជើង ៤ ទាំងឡាយ ពួកយើងដូចគ្នានឹងរាជ

ត្រកូល ចចកនេះនិយាយមិនល្អ មិនសមជាមួយអញ អញស្តាប់ពាក្យបែប នេះហើយ តើរស់នៅធ្វើអ្វី អញនឹងអត់ជន្ទើមឲ្យងាប់ តែរាជសីហ៍ញីគិតបាន ថា អញស្តាប់បែបនេះមិនសមគួរ រង់ចាំឲ្យបងរបស់អញត្រឡប់មកសិនអញ នឹងនិយាយរឿងនេះឲ្យបងស្តាប់ហើយសឹមស្លាប់ ។

ចំណែកចចក កាលមិនបានចម្លើយអំពីរាជសីហ៍ញី គិតថានាងមិនប្រតិ-ព័ទ្ធក្នុងអញហើយទោមនស្សត្រឡប់ទៅដេកក្នុងគុហាកែវផលិក ។ រាជសីហ៍មួយ សម្លាប់ក្របីនិងដំរីជាដើមណាមួយ ទំពាស៊ីសាច់និងនាំមួយចំណែកមកឲ្យរាជសីហ៍ញីជាប្អូនពោលថា ចូរនាងទំពាស៊ីសាច់នេះចុះ រាជសីហ៍ញីឆ្លើយថា ខ្ញុំមិនស៊ីទេ ខ្ញុំនឹងស្លាប់ ។ រាជសីហ៍សួរថា តើហេតុអ្វី ។ នាងបានតំណាលរឿងទាំងអស់ឲ្យរាជសីហ៍ជាបងស្តាប់ ។ រាជសីហ៍សួរថា ឥឡូវនេះចចកនោះនៅឯណា ។ រាជសីហ៍ញីសម្គាល់ចចកដែលដេកនៅក្នុងគុហាកែវផលិកស្មានថា ដេកកណ្តាលវាលទើបឆ្លើយថា បងមិនឃើញទេឬ ចចកនោះដេកកណ្តាលវាលក្បែររជតបព៌ត ។ កូនរាជសីហ៍មិនដឹងថា ចចកដេកក្នុងគុហាកែវផលិកសម្គាល់ថា ដេកកណ្តាលវាល គិតថា អញនឹងសម្លាប់ចចកចោល ទើបស្ទុះទៅដោយសម្ទុះដ៏រហ័សរបស់រាជសីហ៍បុកនឹងគុហាកែវផលិកបេះដូងរបស់កូនរាជសីហ៍នោះក៏បែកដល់នូវការស្លាប់ដួលចុះត្រង់ជើងភ្នំនោះឯង ។ បន្ទាប់មករាជសីហ៍មួយទៀតមកដល់ រាជសីហ៍ញី ក៏ប្រាប់រឿងនោះដល់រាជសីហ៍បងដូចមុន ។ រាជសីហ៍នោះ ក៏ធ្វើយ៉ាងនោះដូចគ្នាដល់នូវការស្លាប់ត្រង់ជើងភ្នំ ។ កាលបងទាំង ៦ ស្លាប់អស់ រាជសីហ៍ពោធិសត្វ

ត្រឡប់មកក្រោយគេ រាជសីហ៍ញី ក៏និទានរឿងឲ្យរាជសីហ៍ពោធិសត្វស្តាប់ កាលរាជសីហ៍ពោធិសត្វសួរថា ឥឡូវនេះចចកនោះនៅឯណា រាជសីហ៍ញី ប្រាប់ថា ចចកដេកកណ្តាលវាលក្បែរកំពូលរជតបពិត ។ រាជសីហ៍ពោធិសត្វ គិតថា ធម្មតាចចកទាំងឡាយមិនមានទីអាស្រ័យកណ្តាលវាល ចចកមុខជា ដេកក្នុងគុហាកែវផលិកដោយពិត ទើបរាជសីហ៍ពោធិសត្វដើរទៅកាន់ជើងភ្នំ ឃើញប្អូនទាំង ៦ ស្លាប់អស់ ទើបពោលថា រាជសីហ៍ទាំងនេះប្រហែលជា មិនដឹងថា ចចកដេកក្នុងគុហាកែវផលិក ព្រោះមិនមានបញ្ញាពិចារណាព្រោះ ភាពល្ងង់ខ្លៅទើបជល់គុហាស្លាប់ ឈ្មោះថាការងារដែលមិនពិចារណា ហើយ ប្រញាប់ប្រញាល់ធ្វើរមែងយ៉ាងនេះឯងហើយពោលគាថាទី ១ ថា

ការងារទាំងឡាយនោះ ញុំាងបុគ្គលអ្នកមានការងារមិនបានពិ-
ចារណាដោយត្រឹមត្រូវ ឲ្យសម្រេចដោយរួសរាន់ ឲ្យក្តៅក្រ-
ហាយដូចជាវត្ថុក្តៅដែលបុគ្គលពមចូលទៅក្នុងមាត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសមេក្ខិតកម្មន្តំ តុរិតាភិនិបាតិនំ** សេចក្តី ថា បុគ្គលណា បំណងនឹងធ្វើការងារណាមិនបានពិចារណា គឺមិនបានស្ទាប ស្ទង់ចំណែកដែលជាទោសក្នុងការងារនោះ ប្រញាប់ប្រញាល់សម្រេចរួសរាន់ ពេក បដិបត្តិដើម្បីប្រញាប់ធ្វើនូវការងារនោះ ការងារទាំងឡាយនោះតែងដុត រោលបុគ្គលនោះ ដែលមិនបានពិចារណាការងារ ប្រញាប់ធ្វើឲ្យសម្រេច គឺ ធ្វើឲ្យសោយសោក ធ្វើឲ្យលំបាក ។ សួរថា ដូចអ្វី ឆ្លើយថា ដូចរបស់ក្តៅ ដែលដាក់ក្នុងមាត់ដូច្នោះ អធិប្បាយថា ដូចបុគ្គលបរិភោគមិនបានពិចារណា

ថា របស់នេះត្រជាក់ របស់នេះក្តៅ ទម្លាក់ គឺដាក់របស់ដែលក្តៅចូលទៅក្នុង មាត់រមែងលោកមាត់ខ្លះ លោកកខ្លះ ពោះខ្លះ ធ្វើឲ្យសោក ធ្វើឲ្យលំបាក យ៉ាងណា ការងារទាំងឡាយនោះក៏ដូច្នោះ រមែងដុតបុគ្គលបែបនោះ ។

រាជសីពោធិសត្វនោះ កាលពោលគាថានេះហើយទើបពោលថា ប្អូនទាំងឡាយរបស់អញមិនឈ្លាសក្នុងឧបាយគិតថា នឹងសម្លាប់ចចក ប្រញាប់រួសរាន់ទើបខ្លួនឯងស្លាប់ ឯអញនឹងមិនធ្វើយ៉ាងនោះ នឹងហែកដើមទ្រូងចចកដែលដេកតក់ស្លុតក្នុងគុហាកែវផលិកឲ្យបាន រាជសីហ៍ពោធិសត្វសង្កេតផ្លូវឡើងចុះរបស់ចចកស្រេចហើយ ទើបបែរមុខទៅកាន់ផ្លូវនោះ បន្លឺសីហនាទ ៣ ដង អាកាសនិងផែនដីមានសំឡេងគឹកកងតែមួយ ។ បេះដូងចចកដែលដេកតក់ស្លុតក្នុងគុហាកែវផលិក ក៏បែកធ្លាយ ចចក ក៏ដល់នូវសេចក្តីស្លាប់ក្នុងទីនោះឯង ។

ព្រះសាស្តាត្រាស់ថា ចចកនោះបានឮរាជសីហ៍បន្លឺសំឡេងយ៉ាងនេះហើយដល់នូវការស្លាប់ កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់គាថាទី ២ ថា

> សីហៈញុំាងភ្នំប្រាក់ឲ្យលាន់ឮខ្ទាំងដោយសីហនាទ ចចកនៅក្នុង
> ភ្នំប្រាក់បានឮសំឡេងគឹកកងនៃសត្វសីហៈហើយ ក៏ភ័យតក់-
> ស្លុតបែកហឫទ័យស្លាប់ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សីហោ** បានដល់រាជសីហ៍ ៤ ពួក គឺតិណរាជសីហ៍ បណ្ឌុរាជសីហ៍ កាឡរាជសីហ៍ កេសររាជសីហ៍ ។ ក្នុងរាជសីហ៍ទាំងនោះ ក្នុងទីនេះបំណងយកកេសរសីហៈ ។

បទថា **ឧន្នទំ អភិនាទយិ** សេចក្តីថា កេសរសីហៈនោះបន្លឺសីហនាទគួរខ្លាចដូចសំឡេងអសនីបាតធ្លាក់ចុះ ១០០ ដង គឺបានធ្វើវជតបព៌តឲ្យមានសំ-ឡេងគឹកកងតែមួយ ។ បទថា **ឧន្នទេ រវំ** បានដល់ចចកដែលអាស្រ័យនៅក្នុងវជតបព៌តជាប់គ្នានឹងគុហាកែវផលិក ។ បទថា **ភីតោ សន្តាសមាបាទិ** សេចក្តីថា ចចកខ្លាចស្លាប់ដល់នូវការតក់ស្លុត ។ បទថា **ហទយញ្ចស្ស អប្ផលិ** សេចក្តីថា បេះដូងរបស់ចចកនោះបែកព្រោះការខ្លាច ។

រាជសីហ៍ពោធិសត្វ កាលឲ្យចចកដល់នូវការស្លាប់ហើយ ទើបគ្រប់គ្រងប្អូនៗទុកក្នុងទីមួយកន្លែង ហើយប្រាប់ការស្លាប់របស់រាជសីហ៍ទាំងនោះ ឲ្យរាជសីហ៍ញីជាប្អូនដឹង លួងលោមប្អូន អាស្រ័យនៅក្នុងគុហាជរាបដល់អស់ជីវិត ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចធម៌ ប្រជុំជាតក ។ ក្នុងកាលចប់សច្ចធម៌ ឧបាសកតាំងនៅក្នុងសោតា-បត្តិផល ចចកក្នុងកាលនោះបានមកជាកូនរបស់ជាងកោរកាត់ក្នុងកាលឥឡូវនេះ រាជសីហ៍ញីក្នុងកាលនោះ បានមកជាកុមារិការបស់ស្តេចលិច្ឆវី ប្អូនៗទាំង ៦ បានមកជាព្រះថេរៈរូបណាមួយ ឯរាជសីហ៍ដែលជាធំក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សិង្គាលជាតក ចប់

## សូករជាតក

[ ១៥៥ ] ( សូករពោលថា ) ម្នាលសំឡាញ់អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសំឡាញ់ អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសំឡាញ់ អ្នកចូរត្រឡប់មក អ្នកខ្លាចឬ បានជារត់ចេញ ។

[ ១៥៦ ] ( សីហពោធិសត្វពោលថា ) ម្នាលសូករ អ្នកមានកាយមិនស្អាត មានរោមប្រឡាក់ដោយវត្ថុស្អុយ មានក្លិនអាក្រក់បក់ទៅ បើអ្នកចង់ច្បាំងគ្នា ម្នាលសំឡាញ់ យើងឲ្យជ័យដល់អ្នកឯង ។

**ចប់ សូករជាតកទី ៣ ។**

## អដ្ឋកថា

## សូករជាតក

[១៥៥-១៥៦] ព្រះសាស្ដា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធព្រះថេរៈចាស់មួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ចតុប្ប-ទោ អហំ សម្ម** ដូច្នេះជាដើម ។

ក្នុងថ្ងៃមួយ កាលការស្ដាប់ធម៌នៅប្រព្រឹត្តទៅក្នុងពេលរាត្រី កាលព្រះ-សាស្ដាប្រថាប់ឈរនាផ្ទាំងថ្មកែវមណី ជិតទ្វារព្រះគន្ធកុដិ ប្រទានសុគតោវាទដល់ពួកភិក្ខុ ហើយចូលទៅកាន់ព្រះគន្ធកុដិ ព្រះធម្មសេនាបតីសារីបុត្រថ្វាយបង្គំព្រះសាស្ដា ហើយបានទៅកាន់បរិវេណរបស់ខ្លួន ។ ព្រះមហាមោគ្គល្លានក៏ទៅកាន់បរិវេណរបស់ខ្លួនដូចគ្នា ស្នាក់នៅមួយស្របក់ ទើបមករកព្រះថេរៈ

ហើយសួរបញ្ហា ។ ព្រះធម្មសេនាបតីបានឆ្លើយបញ្ហា ដែលព្រះមហាមោគ្គ-
ល្លានសួរហើយ បានធ្វើឲ្យជាក់ច្បាស់ដូចធ្វើព្រះចន្ទឲ្យប្រាកដលើលម្ហ ។ សូម្បី
បរិស័ទ ៤ ក៏អន្ទ្រយស្តាប់ធម៌ ។ ក្នុងទីនោះ ព្រះថេរៈចាស់មួយរូបគិតថា បើ
អញចូលទៅរកព្រះសារីបុត្រ សួរបញ្ហាក្នុងកណ្តាលបរិស័ទនេះ បរិស័ទនេះ
នឹងដឹងថា អញជាពហូសូត នឹងធ្វើសក្ការៈ លើកតម្កើង ទើបក្រោកឡើង
វាំងបរិស័ទ ចូលទៅរកព្រះថេរៈ ឈរក្នុងចំណែកម្ខាង ហើយពោលថា
អាវុសោសារីបុត្រ ខ្ញុំនឹងសួរបញ្ហាមួយជាមួយលោក សូមលោកឲ្យឱកាស
ដល់ខ្ញុំខ្លះ សូមលោកឲ្យនូវការវិនិច្ឆ័យដល់ខ្ញុំ ដោយអមក្តី ដោយត្រង់ក្តី ក្នុង
ការតិះដៀលក្តី ក្នុងការសរសើរក្តី ក្នុងការវិសេសក្តី ក្នុងការមិនវិសេសក្តី ។
ព្រះថេរៈ សម្លឹងមើលព្រះថេរៈចាស់នោះហើយគិតថា ព្រះថេរៈចាស់នេះតាំង
នៅក្នុងសេចក្តីប្រណែន ល្ងង់ខ្លៅមិនដឹងអ្វីឡើយ ទើបមិននិយាយជាមួយព្រះ
ថេរៈចាស់នោះ ព្រះថេរៈចាស់នោះមានការខ្មាស ដាក់ផ្ចិតវាលវីជនី ចុះអំពី
អាសនៈទៅកាន់បរិវេណ ។ សូម្បីព្រះមហាមោគ្គល្លានក៏ចូលទៅកាន់បរិវេណ
របស់ខ្លួនដូចគ្នា ។ ពួកមនុស្សនាំគ្នាក្រោកឡើង ប្រកាសថា ពួកអ្នកចូរចាប់
ព្រះថេរៈចាស់ចិត្តអាក្រក់នេះ មិនឲ្យពួកយើងបានស្តាប់ធម៌ដ៏ពីរោះ ហើយនាំ
គ្នាដេញតាមទៅ ព្រះថេរៈរត់គេចធ្លាក់ក្នុងរណ្តៅវច្ចកុដិ ពេញដោយលាមក
ដែលមានបន្ទះពុកផុយ ខាងចុងវិហារ ឡើងមកទាំងប្រឡាក់លាមក ។ ពួក
មនុស្សឃើញដូច្នោះ នាំគ្នារង្កៀស បានទៅគាល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ទតឃើញមនុស្សទាំងនោះ ទើបត្រាស់សួរថា ម្នាល

ឧបាសក ឧបាសិកាទាំងឡាយ ពួកអ្នកមកធ្វើអ្វី ខុសកាល ខុសវេលា ពួកមនុស្សនាំគ្នាក្រាបទូលសេចក្តីនោះ ឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសកឧបាសិកាទាំងឡាយ ភិក្ខុនេះតម្កើងខ្លួនមិនស្គាល់កម្លាំងរបស់ខ្លួនប្រៀបផ្ទឹមនឹងបុគ្គលដែលមានកម្លាំងច្រើន ហើយក៏ប្រឡាក់លាមក មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុចាស់នេះ ក៏ធ្លាប់លើកតម្កើងខ្លួន មិនដឹងកម្លាំងរបស់ខ្លួនប្រៀបផ្ទឹមនឹងអ្នកមានកម្លាំងច្រើន ហើយប្រឡាក់លាមក កាលឧបាសកឧបាសិកាទូលអារាធនា ទើបទ្រង់នាំរឿងអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិនៅក្នុងក្រុងពារាណសី ព្រះពោធិសត្វសោយព្រះជាតិជារាជសីហ៍ អាស្រ័យនៅក្នុងគុហាជិតហិមវន្តប្បទេស ។ ក្នុងទីមិនឆ្ងាយអំពីភ្នំនោះ មានជ្រូកជាច្រើនអាស្រ័យស្រះមួយកន្លែងរស់នៅ ។ តាបសទាំងឡាយ ក៏អាស្រ័យស្រះនោះធ្វើបណ្ណសាលារស់នៅ ។ ថ្ងៃមួយ រាជសីហ៍សម្លាប់សត្វមានក្របីនិងដំរីជាដើមណាមួយ ទំពាស៊ីស្កប់ស្កល់ ហើយចុះទៅកាន់ស្រះនោះផឹកទឹកហើយឡើងមក ។ ខណៈនោះ ជ្រូកធាត់មួយដើររកអាហារក្បែរស្រះនោះ រាជសីហ៍ឃើញជ្រូកធាត់នោះគិតថាថ្ងៃណាមួយ អញនឹងស៊ីជ្រូកនេះ តែជ្រូកនេះឃើញអញនឹងមិនមកទៀត ព្រោះខ្លាចជ្រូកមិនមក ទើបឡើងអំពីស្រះគេចទៅក្នុងចំណែកម្ខាង ជ្រូកឃើញរាជសីហ៍គិតថា រាជសីហ៍នេះគ្រាន់តែឃើញអញ មិនអាចចូលជិតអញបានព្រោះខ្លាចអញទើបគេចទៅ ថ្ងៃនេះអញត្រូវប្រយុទ្ធជាមួយរាជសីហ៍

នេះ ហើយអើតក្បាលស្រែកហៅរាជសីហ៍មកប្រយុទ្ធគ្នា ពោលគាថាទីមួយថា

ម្នាលសម្លាញ់អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសំឡាញ់
អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសំឡាញ់ អ្នកចូរត្រឡប់មក
អ្នកខ្លាចឬ បានជារត់ចេញដូច្នេះ ។

រាជសីហ៍ បានស្តាប់ពាក្យក្អេងក្អាងរបស់ជ្រូកនោះទើបពោលថា នែជ្រូកសម្លាញ់ថ្ងៃនេះយើងមិនប្រយុទ្ធជាមួយឯង បន្ទាប់អំពីនេះទៅ ៧ ថ្ងៃ ចូរឯងមកប្រយុទ្ធគ្នាក្នុងទីនេះ ហើយក៏ចៀសចេញទៅ ។ ជ្រូកសប្បាយចិត្តដោយគិតថា អញនឹងបានប្រយុទ្ធជាមួយរាជសីហ៍ ទើបនិយាយរឿងនោះ ឲ្យពួកញាតិស្តាប់ ពួកញាតិស្តាប់ហើយនាំគ្នាភ័យខ្លាចពោលថា ឯងនាំពួកយើងទាំងអស់ ឲ្យដល់នូវសេចក្តីវិនាសក្នុងគ្រានេះឯង ឯងមិនស្គាល់កម្លាំងរបស់ខ្លួនបំណងប្រយុទ្ធជាមួយរាជសីហ៍ រាជសីហ៍នឹងមកធ្វើឲ្យយើងទាំងឡាយដល់នូវសេចក្តីវិនាស ឯងកុំធ្វើកម្មធ្ងន់នេះឡើយ ជ្រូកកិតភ័យសួរថា ពេលនេះយើងធ្វើដូចម្តេចល្អ ពួកជ្រូកនាំគ្នាពោលថា នែសម្លាញ់ ចូរឯងទៅកាន់បង្គន់របស់ពួកតាបសទាំងនេះ ហើយបម្រះននៀលក្នុងលាមក រង់ចាំឲ្យស្ងួតខ្លួន ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ចូរធ្វើខ្លួនឲ្យសើមដោយទឹកសន្សើម ហើយមកមុនរាជសីហ៍ ចូរសង្កេតខ្យល់បក់ ហើយឈរលើខ្យល់ រាជសីហ៍ជាសត្វស្អាត បានធុំក្លិនខ្លួនសម្លាញ់ហើយ នឹងឲ្យឯងឈ្នះហើយត្រឡប់ទៅ ។ ជ្រូកជាត់បានធ្វើតាមនោះក្នុងថ្ងៃទី ៧ បានទៅឈររង់ចាំក្នុងទីនោះ ។ រាជសីហ៍ប៉ះនូវក្លិនខ្លួន ក៏ដឹងថា

ជ្រូកនេះប្រឡាក់លាមក ទើបពោលថា នែជ្រូកសម្លាញ់ ឯងគិតបានល្អ បើឯងមិនប្រឡាក់លាមក យើងនឹងសម្លាប់ឯងត្រង់នេះ តែឥឡូវនេះ យើងមិនអាចខាំខ្លួនឯងដោយមាត់ជាន់ឯងដោយជើងបាន យើងឲ្យឯងឈ្នះទៅចុះ ទើបពោលគាថាទីពីរថា

ម្នាលសូករ អ្នកមានកាយមិនស្អាត មានរោមប្រឡាក់ដោយ
វត្ថុស្អុយ មានក្លិនអាក្រក់បក់ទៅ បើអ្នកចង់ច្បាំងគ្នាម្នាលសំ-
ឡាញ់ យើងឲ្យជ័យដល់អ្នកឯង ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **បូតិលោមោសិ** បានដល់ រោមមានក្លិនស្អុយ ព្រោះប្រឡាក់លាមក ។ បទថា **ទុគ្គន្ធោ វាយសិ** បានដល់មានក្លិនបដិកូលផ្សាយទៅគួរខ្ពើមរអើមក្រៃពេក ។ បទថា **ជយំ សម្ម ទទាមិ តេ** បានដល់ យើងឲ្យឯងឈ្នះ ។

រាជសីហ៍កាលពោលថា ខ្ញុំចាញ់ហើយ ឯងឈ្នះចុះ ដូច្នេះហើយក៏ត្រឡប់អំពីទីនោះ ស្វែងរកអាហារ ផឹកទឹកក្នុងស្រះស្រេចហើយ ក៏ត្រឡប់ចូលគុហាវិញ ។ ជ្រូកក៏ប្រាប់ដល់ពួកញាតិថា យើងឈ្នះរាជសីហ៍ហើយ ។ ពួកជ្រូកទាំងនោះ នាំគ្នាភ័យខ្លាចក្រែងថ្ងៃណាមួយ រាជសីហ៍ត្រឡប់មកទៀតនឹងសម្លាប់ពួកខ្លួនស្លាប់អស់ទើបនាំគ្នាគេចទៅកាន់ទីដទៃ ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ជ្រូកក្នុងកាលនោះបានមកជាភិក្ខុចាស់ក្នុងកាលឥឡូវនេះ ចំណែករាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថាសូករជាតក ចប់

## ឧរគជាតក

[ ១៥៧ ] ( គ្រុឌពោលថា ) ស្តេចនាគដ៏ប្រសើរជាងពស់ទាំងឡាយ មានភេទដូចជាកែវ ដែលកើតអំពីថ្ម ប្រាថ្នាដើម្បីរួច បានចូលទៅក្នុងសំពត់សៀកនេះ ខ្ញុំកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ ខ្ញុំប្រាថ្នានឹងបរិភោគតែមិនអាចនឹងបរិភោគបាន ។

[ ១៥៨ ] ( តាបសពោធិសត្វពោលថា ) អ្នកមានបុគ្គលដ៏ប្រសើរគ្រប់គ្រងហើយ ចូររស់នៅអស់កាលយូរ អាហារជាទិព្វទាំងឡាយ ចូរកើតប្រាកដដល់អ្នក ( ព្រោះថា ) អ្នកកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរអ្នកប្រាថ្នានឹងបរិភោគ តែមិនអាចបរិភោគបាន ។

**ចប់ ឧរគជាតកទី ៤ ។**

## អដ្ឋកថា

## ឧរគជាតក

[ ១៥៧-១៥៨ ] ព្រះសាស្តា កាលគង់នៅក្នុងជេតពនមហាវិហារទ្រង់ប្រារព្ធការចងពៀររបស់បុគ្គលដែលមានពៀរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឥធូរគានំ បវរោ បវិដ្ឋោ** ដូច្នេះជាដើម ។

បានឮថា មហាមាត្យ ២ នាក់ជាមេទ័ព ជាសេវកៈរបស់ព្រះបាទកោសលឃើញគ្នានឹងគ្នា ហើយក៏ឈ្លោះគ្នា ការចងពៀររបស់ជនទាំង ២ ផ្សាយទៅពេញនគរ ។ ព្រះរាជា ញាតិមិត្រ មិនអាចធ្វើឲ្យជនទាំង ២ ស្រុះស្រួល

គ្នាបាន ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ព្រះសាស្តាប្រមើលមើលវេនេយ្យសត្វ ដែលគួរទូន្មានឲ្យត្រាស់ដឹង ទ្រង់ឃើញឧបនិស្ស័យ នៃសោតាបត្តិមគ្គរបស់ជនទាំង ២ ។ ស្អែកឡើង ទ្រង់យាងទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាតមួយព្រះអង្គប៉ុណ្ណោះ ឈរប្រថាប់ត្រង់ទ្វារផ្ទះ របស់អមាត្យម្នាក់ ។ បុរសនោះចេញមកទទួលបាត្រ ហើយនិមន្តព្រះសាស្តាឲ្យចូលទៅខាងក្នុងផ្ទះ ក្រាលអាសនៈឲ្យគង់ប្រថាប់ ព្រះសាស្តាគង់ប្រថាប់ហើយ ត្រាស់អានិសង្សនៃការចម្រើនមេត្តាដល់អាមាត្យនោះ ទ្រង់ជ្រាបថា មានចិត្តទន់ភ្លន់ហើយ ទើបទ្រង់ប្រកាសអរិយសច្ច កាលចប់អរិយសច្ច ក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាជ្រាបថា បុរសនោះតាំងនៅក្នុងសោតាហើយ ទ្រង់ឲ្យអាមាត្យនោះកាន់បាត្រ នាំទៅកាន់ទ្វារផ្ទះរបស់អាមាត្យម្នាក់ទៀត ។ អាមាត្យនោះ ក៏ចេញមកថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា សូមទ្រង់និមន្តចូលចុះ ហើយយាងព្រះសាស្តាចូលកាន់ផ្ទះ ឲ្យគង់ប្រថាប់ ។ អាមាត្យដែលកាន់បាត្រជូនដំណើរព្រះសាស្តាចូលទៅជាមួយព្រះសាស្តានោះឯង ព្រះសាស្តាត្រាស់ពណ៌នាអានិសង្សមេត្តា ១១ ប្រការ ទ្រង់ជ្រាបថា បុរសនោះមានចិត្តសមគួរហើយ ទើបទ្រង់ប្រកាសសច្ចធម៌ កាលចប់ហើយ អាមាត្យនោះក៏តាំងនៅក្នុងសោតាបត្តិផល អមាត្យទាំងពីរសម្រេចសោតាហើយ ក៏សម្តែងទោស ខមាទោសដល់គ្នានឹងគ្នា មានការសាមគ្គី ត្រេកអររកគ្នា មានអធ្យាស្រ័យរួមគ្នា ដោយប្រការដូច្នេះ ថ្ងៃនោះឯងជនទាំង ២ បរិភោគរួមគ្នាចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។

ព្រះសាស្តាសោយកត្តាហារស្រេចហើយ បានយាងត្រឡប់ទៅកាន់វិហារ

អាមាត្យទាំង ២ នោះ ក៏កាន់ផ្កា គ្រឿងក្រអូប សប្បិ ទឹកឃ្មុំ ទឹកអំពៅជាដើម ចេញទៅជាមួយព្រះសាស្តា កាលពួកភិក្ខុសម្តែងវត្តហើយ ព្រះសាស្តាទ្រង់ប្រទានសុគតោវាទ ហើយយាងចូលកាន់ព្រះគន្ធកុដិ ។

ក្នុងពេលល្ងាច ភិក្ខុទាំងឡាយប្រជុំគ្នាសន្ទនាដល់គុណកថារបស់ព្រះមុនី ក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់ទូន្មានបុគ្គលដែលទូន្មានមិនបាន ព្រះតថាគតទ្រង់ទូន្មានមហាមាត្យទាំង ២ ដែលទាស់ទែងគ្នាមកអស់កាលដ៏យូរ ព្រះរាជា ញាតិមិត្រជាដើម មិនអាចធ្វើឲ្យសាមគ្គីគ្នាបាន ក្នុងកាលត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានធ្វើឲ្យជនទាំង ២ នេះស្រុះស្រួលគ្នាតែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្វើឲ្យជនទាំងនេះសាមគ្គីគ្នាដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី កាលគេប្រកាសថា ក្នុងនគរពារាណសីមានមហោស្រព ក៏មានការប្រជុំធំ ។ ពួកមនុស្សជាច្រើនមួយអន្លើដោយទេវតា នាគ គ្រុឌជាដើម ប្រជុំគ្នាដើម្បីមើលមហោស្រពក្នុងនគរពារាណសីនោះ ស្តេចនាគចាំស្តេចគ្រុឌមិនបានទើបដាក់ដៃលើស្មារបស់ស្តេចគ្រុឌ ។ ស្តេចគ្រុឌនឹកក្នុងចិត្តថា អ្នកណាយកដៃដាក់លើស្មារបស់អញ ងាកមើលក៏ដឹងថា ស្តេចនាគ ។ ស្តេចនាគ

សម្ដឹងមើលស្គាល់ថាជាស្ដេចគ្រុឌ ទើបតក់ស្លុតចំពោះមរណភ័យ ចេញអំពីព្រះនគរគេចទៅតាមកំពង់ទឹក ស្ដេចគ្រុឌដេញតាមទៅដោយគិតថា នឹងចាប់ស្ដេចនាគនោះឲ្យបាន ។

សម័យនោះ ព្រះពោធិសត្វជាតាបសអាស្រ័យនៅក្នុងបណ្ណសាលាក្បែរឆ្នេរស្ទឹងនោះ ដើម្បីរម្ងាប់សេចក្ដីក្រវល់ក្រវាយក្នុងពេលថ្ងៃទើបស្លៀកសំពត់ឧទកសាដក ដាក់សំពត់សម្បកឈើត្រង់ឆ្នេរស្ទឹង ហើយចុះងូតទឹក ស្ដេចនាគគិតថា អញនឹងបានជីវិតព្រោះអាស្រ័យបព្វជិតនេះ ទើបកាឡាខ្លួនជាដុំកែវមណី ចូលទៅអាស្រ័យនៅក្នុងសំពត់សម្បកឈើនោះ ។ ស្ដេចគ្រុឌដេញតាមទៅ ឃើញស្ដេចនាគចូលទៅអាស្រ័យនៅក្នុងសំពត់សម្បកឈើនោះ ក៏មិនហ៊ានប៉ះពាល់សំពត់សម្បកឈើព្រោះសេចក្ដីគោរព ទើបនិយាយនឹងព្រះពោធិសត្វថា បពិត្រលោកម្ចាស់ខ្ញុំឃ្លាន សូមលោកម្ចាស់យកសំពត់សម្បកឈើរបស់លោកម្ចាស់ទៅ ខ្ញុំនឹងស៊ីស្ដេចនាគនេះ កាលប្រកាសសេចក្ដីនេះ ទើបពោលគាថាទីមួយថា

> ស្ដេចនាគដ៏ប្រសើរជាងពស់ទាំងឡាយ មានភេទដូចជាកែវ
> ដែលកើតអំពីថ្ម ប្រាថ្នាដើម្បីរួច បានចូលទៅក្នុងសំពត់ស្លៀក
> នេះ ខ្ញុំកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ ខ្ញុំប្រាថ្នានឹងបរិ-
> ភោគ តែមិនអាចនឹងបរិភោគបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥន្ទូរគានំ បវរោ បវិដ្ឋោ** សេចក្ដីថា ស្ដេចនាគដ៏ប្រសើរជាងពស់ទាំងឡាយ ចូលទៅអាស្រ័យសំពត់សម្បកឈើនេះ ។

បទថា **សេលស្ស វណ្ណេន** សេចក្តីថា ស្តេចនាគកាឡាខ្លួនជាដុំកែវមណី ចូលទៅអាស្រ័យសំពត់សម្បកឈើ ។ បទថា **បមោក្ខមិច្ឆំ** សេចក្តីថា ស្តេចនាគត្រូវការរួចផុតអំពីកណ្តាប់ដៃខ្ញុំ ។ បទថា **ព្រហ្មញ្ញ វណ្ណំ អបចាយ-មានោ** សេចក្តីថា ខ្ញុំបូជាគោរពចំពោះលោកម្ចាស់ដែលមានភេទដូចព្រហ្ម គឺមានភេទប្រសើរ ។ បទថា **ពុភុក្ខិតោ នោ វិសហាមិ ភោត្តុំ** សេចក្តីថា ទោះបីឃ្លាន ក៏ខ្ញុំមិនអាចស៊ីស្តេចនាគនោះ ដែលចូលទៅអាស្រ័យក្នុងសំពត់សម្បកឈើនោះបាន ។

ព្រះពោធិសត្វឈរនៅក្នុងទឹកនោះឯង បានសរសើរស្តេចគ្រុឌ ហើយពោលគាថាទីពីរថា

អ្នកមានបុគ្គលដ៏ប្រសើរគ្រប់គ្រងហើយ ចូររស់នៅអស់កាលយូរ អាហារជាទិព្វទាំងឡាយចូរកើតប្រាកដដល់អ្នក ( ព្រោះថា ) អ្នកកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ អ្នកប្រាថ្នានឹងបរិភោគ តែមិនអាចបរិភោគបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ ព្រហ្មគុត្តោ** សេចក្តីថា អ្នកជាបុគ្គលដែលព្រហ្មគ្រប់គ្រងរក្សាហើយ ។ បទថា **ទិព្យា ច តេ ពាតុភាវន្តុ ភក្ខា** សេចក្តីថា សូមអាហារទិព្វដែលគួរដល់ការបរិភោគនៃទេវតាទាំងឡាយ ប្រាកដដល់អ្នកចុះ អ្នកកុំធ្វើបាណាតិបាត បរិភោគសាច់នាគឡើយ ។

ព្រះពោធិសត្វ ទាំងដែលឈរនៅក្នុងទឹកធ្វើអនុមោទនាហើយ ឡើងអំពីស្រះស្លៀកសំពត់សម្បកឈើនាំសត្វទាំង ២ ទៅកាន់អាស្រមបទ សម្តែង

ដល់គុណនៃការចម្រើនមេត្តាហើយបានធ្វើសត្វទាំង ២ នោះឲ្យសាមគ្គីគ្នា ។

តាំងអំពីនោះមក សត្វទាំង ២ នោះ ក៏មានការស្រុះស្រួលគ្នា ត្រេកអរគ្នា រស់នៅរួមគ្នាដោយសេចក្ដីសុខ ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមក ហើយប្រជុំជាតកថា ស្ដេចនាគនិងស្ដេចគ្រុឌក្នុងកាលនោះបានមកជាមហាមាត្យទាំង ២ ក្នុងកាលឥឡូវនេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឧរគជាតក ចប់

## ភគ្គជាតក

[ ១៥៩ ] ( មាណពពោធិសត្វពោលថា ) បពិត្រភគ្គៈ សូមលោករស់នៅអស់ ១២០ ឆ្នាំ បិសាចទាំងឡាយចូរកុំទំពាស៊ីនូវខ្ញុំឡើយ សូមលោករស់នៅអស់ ១២០ ឆ្នាំ ។

[ ១៦០ ] ( បិតារបស់ពោធិសត្វពោលថា ) អ្នកចូររស់នៅអស់ ១២០ ឆ្នាំដែរ បិសាចទាំងឡាយចូរទំពាស៊ីនូវថ្នាំពិស អ្នកចូររស់នៅអស់ ១២០ ឆ្នាំ ។

**ចប់ ភគ្គជាតកទី ៥ ។**

## អដ្ឋកថា

## ភគ្គជាតក

[ ១៥៩-១៦០ ] ព្រះសាស្តា កាលគង់នៅក្នុងរាជការាម ដែលព្រះបាទបសេនទិកោសល ទ្រង់រៀបចំសាងថ្វាយជិតវត្តជេតពន ទ្រង់ប្រារព្ធការកណ្តាស់របស់ទ្រង់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ជីវ វស្ស-សតំ ភគ្គ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយព្រះសាស្តាគង់ក្នុងកណ្តាលបរិស័ទ ៤ ត្រង់រាជិការាម ខណៈសម្តែងធម៌ ទ្រង់ក៏កណ្តាស់ឡើង ។ ពួកភិក្ខុក៏ធ្វើសំឡេងគឹកកងយ៉ាងខ្លាំងថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគចម្រើនព្រះជន្មាយុរស់នៅ សូមព្រះសុគតចម្រើនព្រះជន្មាយុរស់នៅ ។ ធម្មកថាក៏ដាច់ពាក់កណ្តាលដោយសំឡេងនោះ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ហៅ

ភិក្ខុទាំងឡាយមកសួរថា ម្នាលភិក្ខុទាំងឡាយបុគ្គលដែលគេនិយាយថា អ្នកចូររស់នៅដូច្នេះ ក្នុងវេលាដែលកណ្តាស់ បុគ្គលនោះគួររស់នៅ ឬគួរស្លាប់ព្រោះហេតុប៉ុណ្ណោះដែរឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមែនទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកដទៃភិក្ខុមិនត្រូវពោលថា អ្នកចូររស់នៅក្នុងវេលាកណ្តាស់ ( ប៉ុណ្ណោះ ) ទេ ភិក្ខុណាពោលត្រូវអាបត្តិទុក្កដ ។

សម័យនោះឯង មនុស្សទាំងឡាយទៅនិយាយនឹងពួកភិក្ខុក្នុងវេលាដែលកណ្តាស់ថា បពិត្រលោកទាំងឡាយដ៏ចម្រើន ចូរលោករស់នៅ ។ ពួកភិក្ខុមានសេចក្តីរង្កៀសមិនហ៊ានពោលតបវិញ ។ មនុស្សទាំងឡាយពោលទោសតិះដៀលបន្តុះបង្អាប់ថា មិនសមបើសមណសក្យបុត្តិយ៍ទាំងនេះ កាលបើពួកយើងនិយាយថា បពិត្រលោកទាំងឡាយដ៏ចម្រើន ចូរលោករស់នៅដូច្នេះ ហើយលោកមិនពោលតបនឹងយើងសោះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាគ្រហស្ថទាំងឡាយ តែងត្រូវការដោយមង្គល ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលគ្រហស្ថទាំងឡាយនិយាយថា បពិត្រលោកដ៏ចម្រើន លោកចូររស់នៅដូច្នេះឲ្យនិយាយតបទៅវិញថា អ្នកចូររស់នៅអស់កាលយូរដូច្នេះបាន ដូច្នេះ ។

ភិក្ខុទាំងឡាយនាំគ្នាទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើនធម្មតាការពោលឆ្លើយថា សូមឲ្យអ្នកទាំងឡាយមានអាយុវែងចុះដូច្នេះ កើតឡើងអំពីកាលណា ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាការឆ្លើយ

ថា ចូររស់នៅចុះ កើតតាំងពីបុរាណកាល ហើយទ្រង់នាំរឿងក្នុងអតីតមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិនៅក្នុងនគរពារា-ណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍មួយក្នុងដែនកាសី ។ បិតារបស់ព្រះពោធិសត្វធ្វើនូវការលក់ដូរចិញ្ចឹមជីវិត បិតាឲ្យព្រះពោធិសត្វដែលមានអាយុ ១៦ ឆ្នាំរែកគ្រឿងកែវមណីធ្វើដំណើរទៅក្នុងស្រុកនិងនិគមជាដើម កាលដល់ក្រុងពារាណសី ឲ្យដាំបាយបរិភោគក្បែរផ្ទះរបស់អ្នកយាមទ្វារ កាលរកកន្លែងសម្រាកមិនបានទើបសួរថា បុគ្គលអ្នកមកខុសកាលស្នាក់នៅទីណា ។ កាលនោះពួកមនុស្សប្រាប់ថា ក្រៅព្រះនគរមានសាលាមួយ តែសាលានោះមានយក្ខគ្រប់គ្រង បើពួកអ្នកត្រូវការក៏ចូរនៅចុះ ព្រះពោធិសត្វពោលថា មកលោកឪពុកយើងនឹងទៅ កុំខ្លាចយក្ខឡើយ ខ្ញុំនឹងទូន្មានយក្ខនោះឲ្យក្រាបទៀបជើងរបស់លោកឪពុក ហើយក៏នាំបិតាទៅក្នុងទីនោះ ។ លំដាប់នោះ បិតារបស់ព្រះពោធិសត្វដេកលើបន្ទះក្តារ ព្រះពោធិសត្វអង្គុយច្របាច់ជើងឲ្យឪពុក ។ យក្ខដែលអាស្រ័យនៅត្រង់សាលានោះ បម្រើព្រះបាទវេស្សវ័ណអស់ ១២ ឆ្នាំកាលបានសាលានោះបានពរថា បណ្តាមនុស្សដែលចូលកាន់សាលានេះ បុគ្គលណាពោលក្នុងពេលដែលបុគ្គលណាម្នាក់កណ្តាស់ថា សូមលោករស់នៅចុះ ហើយបុគ្គលណាកាលគេពោលថា ចូររស់នៅចុះដូច្នេះហើយពោលឆ្លើយថា អ្នកក៏ដូចគ្នាចូររស់នៅចុះ វៀរបុគ្គលដែលពោលឆ្លើយនោះចេញជនដ៏សេសចូរបរិភោគចុះ យក្ខនោះអាស្រ័យត្រង់ធ្នឹមគិតថា

អញនឹងឲ្យបិតារបស់បុរសនេះកណ្តាស់ ទើបរោយលម្អិតដោយអានុភាព របស់ខ្លួន លម្អិតចូលទៅក្នុងប្រមុះ ទើបគាត់កណ្តាស់ឡើងទាំងដែលកំពុង ដេកលើបន្ទះក្តារនោះឯង ព្រះពោធិសត្វមិនបានពោលថា សូមលោករស់នៅ ចុះ ទើបយក្ខចុះអំពីធ្នឹមបំណាងមកស៊ីព្រះពោធិសត្វ ។ ព្រះពោធិសត្វឃើញ យក្ខចុះមកទើបគិតថា យក្ខនេះឯងធ្វើឲ្យឪពុកអញកណ្តាស់ យក្ខនេះពិតជា យក្ខស៊ីមនុស្សដែលមិនពោលថា សូមលោករស់នៅចុះក្នុងកាលដែលបុគ្គល ណាម្នាក់កណ្តាស់ទើបពោលគាថាទីមួយ ជាមួយបិតាថា

> បពិត្រគគ្គៈ សូមលោករស់នៅអស់ ១២០ ឆ្នាំ បិសាចទាំង
> ឡាយចូរកុំទំពាស៊ីនូវខ្ញុំឡើយ សូមលោករស់នៅអស់ ១២០
> ឆ្នាំ ដូច្នេះ ។

បណ្តាបទទាំងនោះ ព្រះពោធិសត្វហៅបិតាថា គគ្គៈ ។ បទថា **អបរា- ណិ ច វីសតិ** សេចក្តីថា សូមឲ្យលោករស់នៅ ១២០ ឆ្នាំចុះ ។ បទថា **មា មំ បិសាចា ខាទន្តុ** សេចក្តីថា បិសាចកុំទំពាស៊ីខ្ញុំឡើយ ។ បទថា **ជីវ ត្វំ សរទោសតំ** សេចក្តីថា សូមលោករស់នៅ ១២០ ឆ្នាំចុះ ។ សេចក្តីពិត ១២០ ឆ្នាំគ្រាន់តែជាការគិតដែលពិតត្រឹមតែ ១០០ ឆ្នាំប៉ុណ្ណោះ ។ ក្នុងទីនេះ លោកបំណាងយក ១០០ ឆ្នាំលើស ២០ ឆ្នាំ ។

យក្ខបានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយគិតថា អញមិនអាចស៊ី មាណពនេះបានព្រោះមាណពនេះពោលថា សូមលោករស់នៅចុះ តែអញនឹង ស៊ីបិតារបស់គេ គិតហើយក៏ទៅរកបិតា បិតាឃើញយក្ខចុះមកគិតថា យក្ខ

នេះពិតជាយក្ខស៊ីមនុស្សដែលមិនពោលតបថា សូមអ្នករស់នៅចុះ ព្រោះដូច្នោះអញនឹងពោលឆ្លើយទើបពោលគាថាទីពីរជាមួយបុត្តថា

អ្នកចូររស់នៅអស់ ១២០ ឆ្នាំដែរ បិសាចទាំងឡាយចូរទំពា
ស៊ីនូវថ្នាំពិស អ្នកចូររស់នៅអស់ ១២០ ឆ្នាំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិសំ បិសាចា ខាទន្តុ** បានដល់បិសាចចូរបរិភោគថ្នាំពិសដែលមានពិសខ្លាំងក្លា ។

យក្ខបានស្ដាប់ដូច្នោះគិតថា អញមិនអាចស៊ីជនទាំង ២ បានទើបថយក្រោយ ។ លំដាប់នោះព្រះពោធិសត្វសួរយក្ខនោះថា នែយក្ខព្រោះហេតុអ្វីទើបស៊ីមនុស្សដែលចូលកាន់សាលានេះ យក្ខឆ្លើយថា ព្រោះខ្ញុំឧបដ្ឋាកស្ដេចវេស្សវណអស់ ១២ ឆ្នាំ ហើយបានទទួលពរ ។ ព្រះពោធិសត្វសួរថា អ្នកស៊ីមនុស្សគ្រប់គ្នាឬ យក្ខឆ្លើយថា វៀរលែងតែជនដែលពោលថា សូមអ្នករស់នៅចុះ ជនក្រៅពីនោះយើងស៊ីទាំងអស់ ព្រះពោធិសត្វពោលថា នែយក្ខ អ្នកបានធ្វើអកុសលទុកក្នុងភពមុន ជាអ្នកកាចឃោរឃៅ ចូលចិត្តបៀតបៀនអ្នកដទៃ ឥឡូវនេះបើអ្នកនៅតែធ្វើកម្មនោះទៀតអ្នកឈ្មោះថា មកងងឹតទៅវិញក៏ងងឹត ព្រោះហេតុនោះ តាំងអំពីនេះទៅចូរអ្នកវៀរចាកបាណាតិបាតជាដើម ព្រះពោធិសត្វទូន្មានយក្ខនោះហើយប្រាប់ភ័យក្នុងនរក ឲ្យយក្ខតាំងនៅក្នុងសីល ៥ បានធ្វើយក្ខឲ្យដូចជាអ្នកបម្រើ ។

ស្អែកឡើងពួកអ្នកដំណើរឃើញយក្ខនោះដឹងថា ព្រះពោធិសត្វទូន្មានយក្ខបានទើបនាំគ្នាក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ មាណពម្នាក់ទូន្មាន

យក្ខនោះបាន ធ្វើឲ្យដូចជាអ្នកបម្រើ ។ ព្រះរាជាត្រាស់ឲ្យហៅព្រះពោធិសត្វ ហើយទ្រង់តាំងទុកក្នុងតំណែងជាសេនាបតី និងបានព្រះរាជទានយសធំដល់បិតាព្រះពោធិសត្វ ។ ព្រះរាជាទ្រង់ធ្វើយក្ខឲ្យបានទទួលពលិកម្ម តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យមានទានជាដើមបំពេញផ្លូវទៅកាន់ស្ថានសួគ៌ ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយត្រាស់ថា ពាក្យឆ្លើយថា ចូរអ្នករស់នៅចុះ បានកើតឡើងហើយក្នុងកាលនោះហើយទ្រង់ប្រជុំជាតកថា យក្ខក្នុងកាលនោះបានមកជាអង្គុលីមាលក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ បិតាក្នុងកាលនោះបានមកជាកស្សបៈ ឯបុត្ត គឺតថាគតនេះឯង ។

## អដ្ឋកថា គគ្គជាតក ចប់

## អលីនចិត្តជាតក

[ ១៦១ ] ( ព្រះសាស្តាត្រាស់ថា ) សេនាដ៏ច្រើនមានចិត្តរីករាយព្រោះអាស្រ័យនូវអលីនចិត្តរាជកុមារ បានញ៉ាំងដំរីឲ្យចាប់យកព្រះបាទកោសលទាំងរស់ ដែលមិនត្រេកអរហើយដោយរាជសម្បត្តិរបស់ខ្លួនយ៉ាងណាមិញ ។

[ ១៦២ ] ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ មានសេចក្តីព្យាយាមប្រារព្ធហើយ កាលចម្រើននូវកុសលធម៌ដើម្បីសម្រេចនូវព្រះនិព្វានជាទីក្សេមចាកយោគៈ គប្បីដល់នូវការអស់ទៅនៃសំយោជនៈទាំងពួងដោយលំដាប់ ក៏យ៉ាងនោះដែរ ។

**ចប់ អលីនចិត្តជាតកទី ៦ ។**

## អដ្ឋកថា
## អលីនចិត្តជាតក

[ ១៦១-១៦២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុលះបង់សេចក្តីព្យាយាមមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អលីនចិត្តំ និស្សាយ** ដូច្នេះជាដើម ។

រឿងមានច្បាស់ក្នុងសំវរជាតក ឯកាទសកនិបាតឯណោះ ។ ភិក្ខុនោះកាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុបានឮថា អ្នកបោះបង់សេចក្តីព្យាយាមពិតឬ ក៏ក្រាបទូលថា ករុណាព្រះអង្គពិតមែន ។

សម័យនោះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុកាលមុនអ្នកបាន

ធ្វើសេចក្តីព្យាយាមដណ្តើមរាជសម្បត្តិក្នុងនគរពារាណសី ប្រមាណ ១២ យោជន៍ ថ្វាយរាជកុមារដែលទើបនឹងកើតដូចគ្នានឹងដុំសាច់មិនមែនឬ ព្រោះហេតុអ្វីក្នុងកាលឥឡូវនេះអ្នកបួសក្នុងសាសនាបែបនេះបែរជាបោះបង់សេចក្តីព្យាយាម ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិនៅក្នុងនគរពារាណសី មានស្រុកជាងឈើនៅមិនឆ្ងាយអំពីនគរពារាណសីនោះ ។ ពួកជាងឈើ ៥០០ នាក់អាស្រ័យនៅក្នុងទីនោះ ពួកគេធ្វើដំណើរដោយទូក ហើយចូលទៅកាន់ព្រៃកាប់ឈើដើម្បីធ្វើប្រាសាទច្រើនប្រភេទមាន ប្រាសាទមួយជាន់ពីរជាន់ជាដើមក្នុងទីនោះឯង ហើយធ្វើគ្រឿងសម្គាល់ទុកក្នុងឈើគ្រប់ចម្រៀកតាំងអំពីសសរជាដើម ជញ្ជូនទៅកាន់ឆ្នេរស្ទឹងដាក់ទូកនាំមកកាន់ព្រះនគរតាមផ្លូវទឹក បុគ្គលណាត្រូវការផ្ទះប្រភេទណា ក៏សង់ផ្ទះប្រភេទនោះដល់បុគ្គលនោះ ហើយទទួលយកកហាបណៈត្រឡប់ទៅនាំគ្រឿងផ្ទះនោះមកទៀត ។ កាលជាងឈើចិញ្ចឹមជីវិតយ៉ាងនេះ សម័យមួយពួកជាងបោះជំរំកាប់ឈើក្នុងព្រៃ ក្នុងទីមិនឆ្ងាយប៉ុន្មានអំពីទីនោះដំរីមួយជាន់ជន្លត់គគីរ ជន្លត់បានជង់ជើងដំរី ដំរីមានការឈឺចាប់ជាកម្លាំង ជើងហើមពេញដោយខ្ទុះ ដំរីបានទទួលទុក្ខវេទនាដ៏ពន្ទឹក បានឮសំឡេងកាប់ឈើរបស់ជាងឈើទើបគិតថា អញនឹងមានសួស្តីព្រោះអាស្រ័យពួកជាងឈើនេះ ហើយដើរជើង ៣ ចូលមករកក្រាបចុះក្បែរៗ ជាងឈើឃើញដំរីហើមជើងទើបចូលទៅជិត ឃើញជន្លត់មុតត្រង់ជើង ហើយប្រើកាំបិតដែលមានមុខមុតលាក់ជន្លត់ ប្រើខ្សែចងទាញ

ជន្តត់ចេញមក ប្របាច់ខ្ទុះចេញ យកទឹកក្តៅលាង មិនយូរប៉ុន្មានមុខដំបៅក៏ជាសះស្បើយព្រោះប្រើថ្នាំដែលត្រឹមត្រូវ ។ ដំរីបាត់ឈឺចាប់ទើបគិតថា អញបានជីវិតព្រោះអាស្រ័យជាងឈើទាំងនេះ អញគួរតបគុណពួកគេ ។ តាំងអំពីនោះមក កាលជាងឈើនាំឈើមកចាំង មកបកសម្បក ដំរីក៏ជួយប្រមៀលជួយហុចគ្រឿងឧបករណ៍ មានកាំបិតជាដើមឲ្យដល់ជាងឈើ ។ ដំរីប្រើប្រមោយចាប់ចុងខ្សែបន្ទាត់ ។ ក្នុងកាលបរិភោគអាហារ ពួកជាងឈើក៏ឲ្យដុំបាយដល់ដំរីម្នាក់មួយពំនូត ( ទាំងអស់ ៥០០ ពំនូត ) ។ ដំរីនោះមានកូនដំរីជាអាជានេយ្យពណ៌សសុទ្ធ ព្រោះហេតុនោះទើបគិតថា ពេលនេះអញក៏ចាស់ អញគួរឲ្យកូនដំរីដល់ជាងឈើទាំងនេះ ដើម្បីធ្វើការងារជំនួសអញហើយចូលទៅព្រៃ ។ ដំរីនោះមិនបានប្រាប់ដល់ពួកជាងឈើ ចូលទៅកាន់ព្រៃនាំកូនដំរីមកពោលថា ដំរីតូចនេះជាកូនរបស់ខ្ញុំ ពួកលោកបានជួយជីវិតខ្ញុំ ខ្ញុំឲ្យកូនដំរីនេះជាគុណបំណាច់ដល់ពួកលោក តាំងអំពីនេះទៅកូនដំរីនេះនឹងធ្វើការឲ្យពួកលោក ។ ហើយទូន្មានកូនថា នែបា តាំងអំពីនេះទៅចូរបាធ្វើការងារជំនួសអញ កាលប្រគល់ឲ្យពួកជាងឈើហើយខ្លួនឯងក៏ចូលទៅកាន់ព្រៃ ។ តាំងអំពីនោះមកកូនដំរីនោះធ្វើតាមពាក្យរបស់ពួកជាងឈើ ជាសត្វស្លូតបូតប្រដៅងាយ ធ្វើកិច្ចការគ្រប់យ៉ាង ពួកជាងឈើក៏ចិញ្ចឹមកូនដំរីតូចដោយអាហារ ៥០០ ពំនូត កូនដំរីធ្វើការងារស្រេចហើយ ក៏ចុះកាន់ស្ទឹងងូតលេងហើយក៏ត្រឡប់ ។ កូនរបស់ជាងឈើក៏ចាប់កូនដំរីនោះត្រង់ប្រមោយជាដើមលេងជាមួយកូនដំរីទាំងក្នុងទឹកនិងលើគោក ។ ធម្មតាជាតិអាជានេយ្យ

ទាំងឡាយទោះជាដំរីក្តី សេះក្តី មនុស្សក្តី រមែងមិនបន្ទោបង់ឧច្ចារៈឬបស្សាវៈ ដាក់ក្នុងទឹកព្រោះដូច្នោះ ទើបកូនដំរីនោះមិនបន្ទោបង់ឧច្ចារៈឬបស្សាវៈក្នុងទឹក បន្ទោបង់ត្រង់ច្រាំងស្ទឹងខាងក្រៅប៉ុណ្ណោះ ។ ថ្ងៃមួយភ្លៀងធ្លាក់ចុះមក លាមកដំរីដែលស្ងួត ក៏ហូរទៅកាន់ស្ទឹងជាប់ត្រង់គុម្ពឈើមួយកន្លែងនាកំពង់ក្នុងនគរពារាណសី ។ គ្រានោះពួកហ្មដំរីរបស់ព្រះរាជានាំដំរី ៥០០ ទៅដោយបំណងនឹងងូតទឹក ។ ដំរីទាំងនោះប៉ះក្លិនលាមករបស់ដំរីអាជានេយ្យ ទើបមិនហ៊ានចុះកាន់ស្ទឹងសូម្បីតែមួយ លើកកន្ទុយនាំគ្នាគេចចេញទៅ ។ ពួកហ្មប្រាប់រឿងនោះដល់ហត្ថាចារ្យ ។ ពួកហត្ថាចារ្យគិតគ្នាថា ក្នុងទឹកពិតជាមានអន្តរាយទើបធ្វើការសម្អាតទឹក ឃើញលាមកដំរីអាជានេយ្យជាប់ត្រង់គុម្ពឈើ ក៏ដឹងថានេះឯងជាហេតុក្នុងរឿងនេះទើបឲ្យនាំថាសមក ដាក់ទឹកប្របាច់លាមកដំរីក្នុងថាសនោះហើយប្រោះលើខ្លួនដំរីទាំងឡាយ ខ្លួនដំរីក៏មានក្លិនក្រអូប ទើបដំរីទាំងនោះចុះងូតទឹកបាន ។ នាយហត្ថាចារ្យទូលរឿងនោះដល់ព្រះរាជាហើយក្រាបទូលថា សូមទ្រង់ស៊ើបរកដំរីអាជានេយ្យនោះនាំមកចុះ ។

ព្រះរាជាចុះកាន់ស្ទឹងដោយនាវា កាលនាវាទៅដល់ក្រសែទឹកខាងលើ ក៏ជួបលំនៅពួកជាងឈើ កូនដំរីកំពុងលេងទឹកបានឮសំឡេងស្គរ ទើបឡើងទៅឈរជាមួយពួកជាងឈើ ពួកជាងឈើថ្វាយការទទួលហើយក្រាបទូលថា បពិត្រព្រះអង្គ បើទ្រង់ត្រូវការដោយឈើ ហេតុអ្វីចាំបាច់យាងមក ទ្រង់បញ្ជូនមនុស្សមកជញ្ជូនយកទៅមិនគួរទេឬ ព្រះរាជាត្រាស់ថា អើអ្នក យើងមិនមែនមកត្រូវការឈើទេតែយើងមកត្រូវការដំរីនេះ ពួកជាងឈើក្រាបទូល

ថា សូមទ្រង់ឲ្យរាជបុរសនាំទៅចុះ ។ កូនដំរីមិនប្រាថ្នានឹងទៅ ព្រះរាជាត្រាស់សួរថា ដំរីឲ្យធ្វើដូចម្តេច ពួកជាងឈើក្រាបទូលថា បពិត្រព្រះអង្គដំរីចង់ឲ្យព្រះរាជទានតម្លៃចិញ្ចឹមដល់ពួកទូលបង្គំ ព្រះរាជាត្រាស់ថា សាធុ ហើយឲ្យដាក់កហាបណៈត្រង់ជើងទាំង ៤ ត្រង់ប្រមោយ ត្រង់កន្ទុយ មួយកន្លែងមួយសែនកហាបណៈ សូម្បីប៉ុណ្ណោះដំរីក៏មិនទៅ កាលព្រះរាជទានគូសំពត់ដល់ជាងឈើទាំងអស់ ព្រះរាជទានសំពត់សាដកសម្រាប់ស្លៀកដល់ភរិយាជាងឈើប៉ុណ្ណោះ ក៏មិនទៅ លុះតែព្រះរាជទានគ្រឿងបរិហារសម្រាប់ក្មេងដល់ក្មេងប្រុសស្រីដែលលេងជាមួយគ្នា ទើបកូនដំរីសម្លឹងមើលពួកជាង ពួកស្ត្រីនិងពួកកុមារ ហើយដើរទៅជាមួយព្រះរាជា ។ ព្រះរាជាទ្រង់នាំទៅដល់ព្រះនគរត្រាស់ឲ្យប្រដាប់ព្រះនគរនិងរោងដំរី ទ្រង់ឲ្យដំរីធ្វើប្រទក្សិណនគរហើយឲ្យចូលទៅកាន់រោងដំរី ទ្រង់ប្រដាប់ដំរីនោះដោយគ្រឿងអលង្ការទាំងពួង ទ្រង់ធ្វើការអភិសេក លើកឡើងជារាជពាហនៈ ទ្រង់តាំងទុកក្នុងឋានៈជាសម្លាញ់របស់ព្រះអង្គ ព្រះរាជទានសម្បត្តិពាក់កណ្តាលដល់ដំរី ទ្រង់ធ្វើការចិញ្ចឹមមើលថែស្មើនឹងព្រះអង្គដែរ ។ តាំងអំពីបានដំរីមក រាជសម្បត្តិក្នុងសកលជម្ពូទ្វីបបានធ្លាក់ក្នុងកណ្តាប់ព្រះហស្តព្រះរាជាទាំងអស់ ។

ក្នុងកាលកន្លងទៅយ៉ាងនេះ ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងផ្ទៃរបស់ព្រះអគ្គមហេសីនៃព្រះរាជាអង្គនោះ ក្នុងពេលព្រះនាងទ្រង់គភ៌គ្រប់ខែ ព្រះរាជាបានសោយទិវង្គតហើយ ។ បើស្តេចដំរីដឹងថា ព្រះរាជាសោយទិវង្គតហើយបេះដូងរបស់ស្តេចដំរីក៏នឹងត្រូវបែកធ្លាយទៅក្នុងទីនោះឯង ។ ដូច្នោះទើបពួក

ហ្មដំរីទំនុកបម្រុងមិនឲ្យស្តេចដំរីដឹងថា ព្រះរាជាបានសោយទិវង្គតហើយ ឯព្រះបាទកោសលដែលមានព្រះរាជាណាចក្រជិតខាង ទ្រង់ស្តាប់ដំណឹងថា ព្រះរាជាសោយទិវង្គតហើយ ទ្រង់ព្រះតម្រិះថា អញនឹងដណ្តើមរាជសម្បត្តិក្រុងពារាណសីដែលមិនមានអ្នកគ្រប់គ្រង ទើបលើកកងទ័ពធំព័ទ្ធព្រះនគរ ។ អ្នកនគរនាំគ្នាបិទទ្វារក្រុងបញ្ជូនសាសន៍ថ្វាយព្រះបាទកោសលថា អគ្គមហេសីរបស់ព្រះរាជាពួកខ្ញុំទ្រង់គភ៌ចាស់ពួកហោរាទាយថា បន្ទាប់អំពីនេះទៅ ៧ ថ្ងៃ អគ្គមហេសីនឹងប្រសូតព្រះឱរស ពួកខ្ញុំនឹងច្បាំងក្នុងថ្ងៃទី ៧ មិនប្រគល់រាជ-សម្បត្តិឲ្យឡើយ សូមទ្រង់រង់ចាំពេលមានប្រមាណប៉ុណ្ណោះ ។ ព្រះបាទកោសលទ្រង់ទទួលថា សាធុ កាលដល់ថ្ងៃទី ៧ ព្រះទេវីព្រះសូតព្រះរាជ-ឱរស ។ ក្នុងថ្ងៃថ្វាយព្រះនាមមហាជនបានថ្វាយព្រះនាមឱរសថា អលីនចិត្ត-រាជកុមារ ព្រោះព្រះឱរសបណ្តាលឲ្យចិត្តរួញរារបស់មហាជនមានភាពរឹងមាំឡើង ។ តាំងអំពីថ្ងៃដែលព្រះឱរសប្រសូត អ្នកនគររបស់ព្រះអង្គចូលច្បាំងជាមួយព្រះបាទកោសល ។ ព្រោះមិនមានអ្នកដឹកនាំសូម្បីមានកម្លាំងប្រយុទ្ធច្រើនប៉ុនណាកាលច្បាំងយូរទៅក៏ថមថយកម្លាំងបន្តិចម្តងៗ ពួកអាមាត្យក្រាបទូលសេចក្តីនោះចំពោះព្រះទេវីហើយទូលសួរថា បពិត្រព្រះនាងកម្លាំងទ័ពរលស់តិចចុះយ៉ាងនេះ ពួកទូលបង្គំខ្លាចក្រែងតែចាញ់សង្គ្រាម ។ មង្គលហត្ថីសម្លាញ់របស់ព្រះរាជាមិនដឹងថាព្រះរាជាសោយទិវង្គត ព្រះឱរសប្រសូតនិងព្រះបាទកោសលយាងមកធ្វើសង្គ្រាមឡើយ ពួកទូលបង្គំនឹងប្រាប់ឲ្យស្តេចដំរីដឹងតើគួរឬទេ ។ ព្រះទេវីត្រាស់ថា សាធុ ទើបតាក់តែងព្រះឱរសឲ្យផ្ទំ

លើអង្រឹងក្រាលដោយសំពត់សាច់ល្អ ចុះអំពីប្រាសាទមានពួកអាមាត្យចោមរោមយានដល់រោងដំរី ឲ្យព្រះពោធិសត្វផ្ទំក្បែរស្តេចដំរីហើយត្រាស់ថា នែមង្គលហត្ថី ព្រះរាជាសម្លាញ់របស់អ្នកសោយទិវង្គតហើយ ពួកយើងមិនបានប្រាប់ព្រោះខ្លាចក្រែងអ្នកបែកហទយៈ នេះគឺព្រះរាជឱរសនៃសម្លាញ់របស់អ្នក ព្រះបាទកោសលយាងមកព័ទ្ធព្រះនគរច្បាំងជាមួយព្រះឱរសរបស់អ្នក ពួករេហ៍ពលក៏ថមថយកម្លាំង អ្នកកុំឲ្យព្រះឱរសរបស់អ្នកស្លាប់ឡើយ ចូរទាញយករាជសម្បត្តិ ថ្វាយដល់ព្រះឱរសរបស់អ្នកចុះ ។ ខណៈនោះមង្គលហត្ថីក៏យកប្រមោយអង្អែលព្រះពោធិសត្វ ហើយលើកឡើងប្រតិស្ឋានលើពោង បន្លឺសំឡេងទើបដាក់ព្រះពោធិសត្វឲ្យផ្ទំលើព្រះហស្តព្រះទេវីហើយចេញអំពីរោងដំរីទៅបំណងនឹងចាប់ព្រះបាទកោសល ។ គ្រានោះទើបពួកអាមាត្យពាក់ក្រោះបំពាក់ក្រោះតាក់តែងស្តេចដំរី បើកទ្វារនគរនាំគ្នាចោមរោមស្តេចដំរីនោះចេញទៅ ។ ស្តេចមង្គលហត្ថីកាលចេញអំពីព្រះនគរហើយ ក៏បន្លឺកោញ្ចនាទញ៉ាំងមហាជនឲ្យតក់ស្លុត នាំគ្នាគេចទៅទម្លាយបន្ទាយសត្រូវចាប់ព្រះមោលីព្រះបាទកោសលទុក នាំមកឲ្យក្រាបទៀបបាទមូលនៃព្រះ-ពោធិសត្វ កាលពួកទាហានចូលចោមរោមសម្លាប់ព្រះបាទកោសល ស្តេចដំរីឃាត់ហើយថ្វាយឱវាទថា តាំងអំពីនេះទៅទ្រង់កុំប្រមាទ កុំសម្គាល់ថាកុមារនេះនៅតូច ហើយទើបឲ្យត្រឡប់ទៅ ។ តាំងអំពីនោះមករាជសម្បត្តិក្នុងសកលជម្ពូទ្វីបក៏ធ្លាក់ក្នុងកណ្តាប់ព្រះហស្តរបស់ព្រះពោធិសត្វ ។ ឈ្មោះថាសត្រូវឬបច្ចាមិត្រដទៃៗមិនអាចផ្ចាញ់បានឡើយ ។

ព្រះពោធិសត្វបានទទួលអភិសេកក្នុងកាលព្រះជន្មបាន ៧ វស្សាទ្រង់ព្រះនាមថា អលីនចិត្តរាជ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ទ្រង់បំពេញផ្លូវទៅកាន់ស្ថានសួគ៌រហូតដល់អវសាននៃជីវិត ។

ព្រះសាស្តាទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណបានត្រាស់ព្រះគាថាទាំងនេះថា

សេនាដ៏ច្រើនមានចិត្តរីករាយព្រោះអាស្រ័យនូវអលីនចិត្តរាជកុមារ បានញុំាងដំរីឲ្យចាប់យកព្រះបាទកោសលទាំងរស់ ដែលមិនត្រេកអរហើយដោយរាជសម្បត្តិរបស់ខ្លួនយ៉ាងណាមិញ ។

ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ មានសេចក្តីព្យាយាមប្រារព្ធហើយ កាលចម្រើននូវកុសលធម៌ដើម្បីសម្រេចនូវព្រះនិព្វានជាទីក្សេមចាកយោគៈ គប្បីដល់នូវការអស់ទៅនៃសំយោជនៈទាំងពួងដោយលំដាប់ ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលីនចិត្តំ និស្សាយ** បានដល់អាស្រ័យអលីនចិត្តរាជកុមារ ។ បទថា **បហដ្ឋា មហតី ចមូ** សេចក្តីថា មហាសេនានាំគ្នាត្រេកអរថា យើងបានរាជសម្បត្តិបន្តរាជបវេណីត្រឡប់មកវិញហើយ ។ បទថា **កោសលំ សេនាសន្តុដ្ឋំ** សេចក្តីថា ព្រះបាទកោសលទ្រង់មិនឆ្អែតដោយរាជសម្បត្តិរបស់ព្រះអង្គ យាងមកដោយចង់បានក្នុងរាជសម្បត្តិរបស់អ្នកដទៃ ។ បទថា **ជីវគ្គាហំ អគាហយិ** សេចក្តីថា សេនានោះសូមឲ្យ

ស្ដេចដើរចាប់ព្រះរាជាទាំងរស់កុំសម្លាប់ ។ បទថា **ឯវំ និស្សយសម្បន្នោ** សេចក្ដីថា សេនានោះយ៉ាងណា កុលបុត្តដទៃដែលបរិបូណ៌ដោយនិស្ស័យ បាននូវកល្យាណមិត្ត គឺព្រះពុទ្ធក្ដី សាវ័ករបស់ព្រះពុទ្ធក្ដី ព្រះបច្ចេកពុទ្ធក្ដីជាទីពឹងអាស្រ័យក៏ដូច្នោះ ។ បទថា **ភិក្ខុ** នេះជាឈ្មោះនៃអ្នកបរិសុទ្ធ ។ បទថា **អារទ្ធវីរិយោ** បានដល់ជាអ្នកផ្គងសេចក្ដីព្យាយាម គឺប្រកបដោយសេចក្ដីព្យាយាមដែលប្រាសចាកទោស ៤ ប្រការ ។ បទថា **ភាវយំ កុសលំ ធម្មំ** សេចក្ដីថា កាលចម្រើនធម៌ដែលជាកុសលដែលមិនមានអាល័យ គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ។ បទថា **យោគក្ខេមស្ស បត្តិយា** បានដល់ ចម្រើនធម៌នោះដើម្បីសម្រេចនិព្វានដែលក្សេមចាកយោគៈ ៤ ។ បទថា **ធាបុណោ អនុបុព្វេន សព្វសំយោជនក្ខយំ** សេចក្ដីថា ភិក្ខុដែលបរិបូណ៌ដោយឧបនិស្ស័យជាកល្យាណមិត្តនោះ កាលចម្រើនកុសលធម៌នេះ តាំងអំពីការឃើញច្បាស់យ៉ាងនេះ ក៏នឹងសម្រេចវិបស្សនាញាណនិងមគ្គផលខាងក្រោមដោយលំដាប់ក្នុងទីបំផុតរមែងសម្រេចអរហត្តពោលគឺ ការអស់សំយោជនៈទាំងពួងព្រោះជាធម៌ដែលកើតឡើងក្នុងទីបំផុតនៃការអស់ទៅរបស់សំយោជនៈ ១០ ។ ម្យ៉ាងទៀតព្រោះសំយោជនៈទាំងពួងអស់ទៅព្រោះអាស្រ័យព្រះនិព្វាន ហេតុនោះព្រះនិព្វានក៏ឈ្មោះថា អស់នូវសំយោជនៈទាំងពួងនោះឯង អធិប្បាយថា ភិក្ខុរមែងសម្រេចនូវការអស់ទៅនៃសំយោជនៈទាំងពួង បានដល់ព្រះនិព្វានដោយលំដាប់ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ប្រមូលកំពូលនៃព្រះធម្មទេសនាដោយអមតមហានិព្វាន ដោយប្រការដូច្នេះហើយទើបទ្រង់ប្រកាសសច្ចធម៌ឲ្យក្រៃលែងឡើង កាលចប់សច្ចធម៌ភិក្ខុអ្នកបោះបង់ការព្យាយាមបានសម្រេចអរហត្តហើយទើបទ្រង់ប្រជុំជាតកថា ព្រះមាតាក្នុងកាលនោះបានមកជាព្រះនាងមហាមាយាទេវីក្នុងកាលឥឡូវនេះ ព្រះបិតាក្នុងកាលនោះបានមកជាព្រះបាទសុទ្ធោទនមហារាជ ស្តេចដំរីដែលជួយឲ្យបានរាជសម្បត្តិក្នុងកាលនោះបានមកជាភិក្ខុដែលលះបង់សេចក្តីព្យាយាមរូបនេះ បារបស់ស្តេចដំរីក្នុងកាលនោះ បានមកជាសារីបុត្ត ព្រះបាទកោសលក្នុងកាលនោះបានមកជាមោគ្គល្លាន ឯអលីនចិត្តរាជកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អលីនចិត្តជាតក ចប់

## គុណជាតក

[ ១៦៣ ] ( ចចកពោលថា ) អ្នកមានកម្លាំងបណ្តេញ ( នូវបុគ្គលអ្នកសេពគប់នឹងខ្លួន ) តាមសេចក្តីប្រាថ្នាបាន បពិត្រស្តេចម្រឹគ ( នេះ ) ជាធម្មតានៃអ្នកមានកម្លាំង បពិត្រស្តេចម្រឹគអ្នកមានចង្កូមស្រួចលោកចូរដឹងចុះ មរណភ័យកើតហើយអំពីទីជាទីពឹង ( របស់យើង ) ។

[ ១៦៤ ] ( សីហៈពោធិសត្វពោលថា ) ប្រសិនបើមិត្តមានកម្លាំងខ្សោយតែតាំងនៅក្នុងមិត្តធម៌ទាំងឡាយ បុគ្គលនោះហៅថា ជាញាតិផង ជាផៅពង្សផង បុគ្គលនោះហៅថា មិត្តផង បុគ្គលនោះហៅថា សម្លាញ់របស់យើងផង ម្នាលមេម្រឹគមានចង្កូម នាងកុំមើលងាយចចកឈ្មោល និងចចកញីជាសំឡាញ់យើងឡើយ ព្រោះចចកជាអ្នកឲ្យជីវិតដល់យើង ។

**ចប់ គុណជាតកទី ៧ ។**

## អដ្ឋកថា

## គុណជាតក

[ ១៦៣-១៦៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពនវិហារ ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរបានសំពត់សាដក ១០០០ ផ្ទាំង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យេន កាមំ បណាមេតិ** ដូច្នេះជាដើម ។

រឿងព្រះថេរៈបង្រៀនធម៌ក្នុងព្រះរាជវាំងរបស់ព្រះបាទកោសល មានមកហើយក្នុងមហាសារជាតកខាងដើមនោះឯង ។

ព្រះថេរៈកាលបង្រៀនធម៌ខាងក្នុងព្រះរាជវាំងរបស់ព្រះរាជា មានអ្នកនាំសំពត់សាដក ១០០០ ផ្ទាំង ១ ផ្ទាំងតម្លៃ ១០០០ មកថ្វាយដល់ព្រះរាជា ព្រះរាជាបានព្រះរាជទានសំពត់សាដក ៥០០ ផ្ទាំងដល់ព្រះទេវី ៥០០ រូប ស្ត្រីទាំងនោះរក្សាសាដកទាំងនោះទុក ស្អែកឡើងបាននាំទៅប្រគេនព្រះអានន្ទ ខ្លួនឯងដណ្តប់សំពត់សាដកចាស់ចូលគាល់ព្រះរាជាក្នុងពេលព្រឹក ព្រះរាជាត្រាស់សួរថា យើងឲ្យសំពត់សាដកតម្លៃ ១០០០ ដល់ពួកនាងព្រោះហេតុអ្វីទើបពួកនាងមិនដណ្តប់សំពត់ទាំងនោះ ស្ត្រីទាំងនោះទូលថា បពិត្រព្រះអង្គ ពួកខ្ញុំម្ចាស់បានប្រគេនសំពត់ទាំងនោះដល់ព្រះថេរៈហើយ ។ ព្រះរាជាសួរថា ព្រះអានន្ទត្រូវទទួលទាំងអស់ឬ ស្ត្រីទាំងនោះទូលថា ទទួលទាំងអស់ ។ ព្រះរាជាទ្រង់ពិរោធនឹងព្រះថេរៈថា ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតត្រឹមចីវរ ៣ ព្រះអានន្ទត្រូវប្រហែលជាធ្វើអ្នកជំនួញសំពត់ទេដឹង ទើបទទួលសំពត់ច្រើនដល់ម៉្លេះ សោយព្រះក្រយាហារព្រឹកហើយទើបទៅកាន់វិហារដល់លំនៅរបស់ព្រះថេរៈ ទ្រង់នមស្ការព្រះថេរៈហើយប្រថាប់គង់ត្រាស់សួរថា បពិត្រលោកម្ចាស់ មេផ្ទះរបស់ខ្ញុំនៅស្តាប់ធម៌ រៀនធម៌ក្នុងសម្នាក់លោកម្ចាស់ឬ ព្រះអានន្ទពោលថា ថ្វាយព្រះពរ ស្រីទាំងនោះនៅស្តាប់ធម៌ រៀនធម៌ រៀនវត្ថុដែលគួររៀន ស្តាប់វត្ថុដែលគួរស្តាប់ ។ ព្រះរាជាសួរថា ពួកស្រីទាំងនោះគ្រាន់តែស្តាប់ប៉ុណ្ណោះឬប្រគេនសំពត់ដណ្តប់ដល់លោកម្ចាស់ដែរ ព្រះអានន្ទឆ្លើយថា សូមថ្វាយព្រះពរ ថ្ងៃនេះពួកស្រីទាំងនោះបានឲ្យសំពត់សាដកតម្លៃ ១០០០ ប្រមាណ ៥០០ ផ្ទាំង ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ទទួលទាំង

អស់ឬ ព្រះថេរៈឆ្លើយថា សូមថ្វាយព្រះពរអាត្មាទទួលទាំងអស់ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ព្រះសាស្តាទ្រង់អនុញ្ញាតចីវរ ៣ ផ្ទាំងប៉ុណ្ណោះមិនមែនឬ ព្រះអានន្ទទូលថា សូមថ្វាយព្រះពរ ត្រឹមត្រូវហើយព្រះមានព្រះភាគទ្រង់អនុញ្ញាតចីវរ ៣ ផ្ទាំងប៉ុណ្ណោះដល់ភិក្ខុមួយរូបសម្រាប់ប្រើប្រាស់ មិនមែនទ្រង់ហាមការទទួល ព្រោះហេតុនោះទើបអាត្មាទទួលសំពត់នោះទុកដើម្បីប្រគេនដល់ភិក្ខុដែលមានចីវរចាស់ដទៃ ។ ព្រះរាជាត្រាស់សួរថា ភិក្ខុទាំងនោះបានសំពត់អំពីលោកម្ចាស់ហើយចីវរចាស់អំពីមុនរបស់លោកយកទៅណា ព្រះអានន្ទទូលថា សូមថ្វាយព្រះពរ ចីវរចាស់ទាំងនោះទុកធ្វើសំពត់ដណ្តប់ ព្រះរាជាត្រាស់ថា សំពត់ដណ្តប់ចាស់យកទៅណា ព្រះថេរៈទូលថា ធ្វើជាសំពត់ស្បៀក ព្រះរាជាត្រាស់ថា សំពត់ស្បៀកចាស់យកទៅណា ព្រះអានន្ទទូលថា ធ្វើជាសំពត់កម្រាលដេក ព្រះរាជាត្រាស់ថា សំពត់ក្រាលដេកចាស់យកទៅណា ព្រះអានន្ទទូលថា ធ្វើជាសំពត់ក្រាលផ្ទៃកុដិ ព្រះរាជាត្រាស់ថា សំពត់ក្រាលផ្ទៃកុដិចាស់យកទៅណា ព្រះអានន្ទទូលថា ធ្វើជាសំពត់ជូតជើង ព្រះរាជាត្រាស់ថា សំពត់ជូតជើងចាស់យកទៅណា ព្រះអានន្ទទូលថា ធម្មតារបស់ដែលគេឲ្យដោយសទ្ធាធ្វើឲ្យវិនាសទៅមិនគួរព្រោះហេតុនោះភិក្ខុទាំងឡាយហែកសំពត់ជូតជើងចាស់ផ្សំជាមួយដីឥដ្ឋ បូកលាបជញ្ជាំងសេនាសនៈ ។ ព្រះរាជាត្រាស់ថា របស់ដែលប្រគេនហើយដល់លោកម្ចាស់ រមែងមិនដល់នូវការវិនាស ដោយហោចសូម្បីសំពត់ជូតជើង ព្រះថេរៈទូលថា សូមថ្វាយព្រះពរ ត្រឹមត្រូវហើយសំពត់ដែលឲ្យដល់អាត្មា

មិនវិនាសឡើយរមែងជារបស់ប្រើប្រាស់ទាំងអស់ ។ ព្រះរាជាទ្រង់សោម-នស្សក្រៃពេក ត្រាស់ឲ្យយកសំពត់ ៥០០ ផ្ទាំងដែលទុកក្នុងព្រះរាជដំណាក់មកប្រគេនព្រះថេរៈ កាលទ្រង់ស្តាប់អនុមោទនាហើយទើបទ្រង់នមស្ការព្រះថេរៈធ្វើប្រទក្សិណហើយត្រឡប់ទៅ ។

ព្រះថេរៈបានប្រគេនសំពត់សាដក ៥០០ ដែលបានលើកទី ១ ដល់ភិក្ខុដែលមានចីវរចាស់ ម្យ៉ាងទៀតព្រះថេរៈមានសទ្ធិវិហារិកប្រមាណ ៥០០ បណ្តាលោកទាំងនោះ ភិក្ខុកំលោះមួយរូបមានឧបការៈដល់ព្រះថេរៈច្រើនដូចជាបោសបរិវេណតម្កល់ទឹកប្រើប្រាស់ ទឹកឆាន់ ប្រគេនឈើស្ទន់ ទឹកលុបមុខ ទឹកស្រង់ លាងវច្ចកុដិ រៀបចំរោងភ្លើងនិងសេនាសនៈ ប្របាច់ដៃប្របាច់ជើង ប្របាច់ខ្នងជាដើម ។ ព្រះថេរៈបានប្រគេនសំពត់ ៥០០ ផ្ទាំងដែលបានលើកក្រោយទាំងអស់ដល់ភិក្ខុកំលោះនោះដោយឃើញថា សមគួរព្រោះភិក្ខុរូបនេះមានឧបការៈច្រើន ។ ភិក្ខុរូបនោះក៏បានចែកសំពត់ទាំងអស់នោះដល់ភិក្ខុដែលរួមឧបជ្ឈាយ៍របស់ខ្លួន ។

ភិក្ខុទាំងឡាយដែលបានសំពត់សាដកទាំងនោះ ក៏កាត់ជ្រលក់ស្បៀកនិងដណ្តប់សំពត់កាសាវពស្ត្រដែលមានពណ៌ដូចផ្កាកណិការ នាំគ្នាចូលទៅគាល់ព្រះសាស្តា អង្គុយក្នុងទីសមគួរនាចំណែកម្ខាងហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកថ្នាក់សោតាបន្ននៅមានការឲ្យដោយយល់មុខឬ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកឲ្យព្រោះយល់មុខមិនមាន ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏-

ចម្រើន ព្រះភណ្ឌាគារិកឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គទាំងឡាយឲ្យសំពត់សាដក ៥០០ តម្លៃ ១០០០ ដល់ភិក្ខុមួយរូបប៉ុណ្ណោះ ភិក្ខុកំលោះរូបនោះបានចែកសំពត់ដែលខ្លួនបានដល់ពួកខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទមិនមែនឲ្យដោយយល់មុខទេតែភិក្ខុរូបនោះមានឧបការៈច្រើនដល់អានន្ទ ព្រោះហេតុនោះអានន្ទគិតឃើញដោយអំណាចឧបការៈរបស់បុគ្គលដែលមានឧបការៈដល់ខ្លួនថា ឈ្មោះថាអ្នកមានឧបការៈ អាត្មាអញគួរធ្វើឧបការៈតបស្នង ដោយអំណាចគុណនិងដោយអំណាចការធ្វើសមគួរ ដូច្នេះទើបឲ្យដោយអំណាចកតញ្ញូកតវេទីដោយប្រការដូច្នេះ ។

សេចក្តីពិត បណ្ឌិតអំពីបុរាណក៏គង់ធ្វើឧបការៈតបដល់អ្នកមានឧបការៈដល់ខ្លួនដូចគ្នា កាលភិក្ខុទាំងនោះទូលអារាធនាទើបទ្រង់នាំយករឿងក្នុងអតីតមកត្រាស់ថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជារាជសីហ៍ អាស្រ័យនៅក្នុងគុហារលើភ្នំ ។ ថ្ងៃមួយរាជសីហ៍នោះចេញអំពីគុហាឈរលើកំពូលភ្នំសម្លឹងមើលមកជើងភ្នំ ។ មានស្រះធំព័ទ្ធជុំវិញជើងភ្នំនោះ ។ ក្នុងទីទួលមួយកន្លែងនៃស្រះនោះមានស្មៅខៀវខ្ចីកើតឡើងលើភក់ដែលរីងទឹកមួយកន្លែង ។ ម្រឹគតូចៗទាំងឡាយមានទន្សាយ ឆ្មានិងចចកជាដើមរត់លេងក្នុងស្មៅលើភក់ស្ងួតនោះ ។ ក្នុងថ្ងៃនោះម្រឹគមួយត្រាច់មកត្រង់ស្មៅនោះ រាជសីហ៍គិតថាអញនឹងចាប់ម្រឹគនោះបរិភោគ ទើបលោតពីលើកំពូលភ្នំស្ទុះទៅដោយកម្លាំងរបស់រាជសីហ៍ ។

ម្រឹគខ្លាចស្លាប់រត់ស្រែកគេចទៅ រាជសីហ៍មិនអាចទប់សម្ទុះដ៏រហ័សបាន ទើបលិចក្នុងភក់ស្អួតមិនអាចរើខ្លួនឡើងបាន បានឈរជោតជើង ៤ ដូចសសរ អត់អាហារអស់ ៧ ថ្ងៃ ។

គ្រានោះចចកមួយដើរស្វែងរកអាហារឃើញរាជសីហ៍ ទើបរត់ទៅដោយការភ័យខ្លាច ។ រាជសីហ៍ឃើញចចកទើបហៅហើយពោលថា នែចចកអ្នកកុំគេចឡើយ ខ្ញុំជាសត្វជាប់ភក់ សូមជួយខ្ញុំចុះ ទើបចចករត់ចូលទៅរករាជសីហ៍ហើយពោលថា ខ្ញុំនឹងជួយលើកលោកឡើងតែកាលខ្ញុំលើកលោកឡើងហើយក្រែងតែលោកស៊ីខ្ញុំ រាជសីហ៍ពោលថា កុំខ្លាចឡើយខ្ញុំមិនស៊ីអ្នកទេ ខ្ញុំនឹងតបគុណអ្នក ចូរអ្នករកឧបាយលើកខ្ញុំឡើងចុះ ចចកទទួលបេ្តជ្ញារបស់រាជសីហ៍ហើយទើបកាយភក់ជុំវិញជើងទាំង ៤ ធ្វើជាប្រឡាយ ៤ ក្បែរជើងទាំង ៤ ហើយធ្វើឲ្យទឹកហូរចូលមក ទឹកហូរចូលមកនោះធ្វើឲ្យភក់ទន់ ។ ខណៈនោះទើបចចកចូលទៅក្រោមពោះរបស់រាជសីហ៍ប្រាប់ថា សូមព្យាយាមចុះលោកហើយយកក្បាលទូលពោះ រាជសីហ៍បញ្ចេញកម្លាំងលោតឡើងអំពីភក់ដល់លើគោក ។

រាជសីហ៍សម្រាកមួយស្របក់ ទើបចុះទៅកាន់ស្រះងូតទឹកជម្រះភក់បន្ទោបង់សេចក្តីហត់នឿយហើយចាប់ក្របីបានមួយ យកចង្កូមហែកសាច់ដាក់ខាងមុខចចកព្រមទាំងពោលថា នែសម្លាញ់ ចូរអ្នកបរិភោគចុះ កាលចចកស៊ីស្រេចហើយ ទើបរាជសីហ៍ស៊ីតាមក្រោយ ចចកពាំដុំសាច់មួយដុំទុក រាជសីហ៍សួរថា នែសម្លាញ់ ធ្វើដូច្នេះអ្នកមានបំណងអ្វី ចចកឆ្លើយថា ទាសី

របស់ខ្ញុំមាន ដុំសាច់នេះជាចំណែករបស់នាង រាជសីហ៍ពោលថា យកចុះសម្លាញ់សូម្បីខ្លួនឯងក៏ពាំសាច់ទៅដើម្បីរាជសីហ៍ញីហើយពោលថា មកសម្លាញ់យើងនឹងទៅកាន់កំពូលភ្នំ ដែលជាលំនៅនៃស្ត្រីសម្លាញ់របស់យើង ហើយនាំគ្នាទៅក្នុងទីនោះ ឲ្យមេចចកស៊ីសាច់ហើយលួងលោមចចកនិងចចកញីថា តាំងអំពីនេះទៅខ្ញុំនឹងបដិបត្តិអ្នក ហើយនាំទៅកាន់លំនៅរបស់ខ្លួនឲ្យចចកទាំង ២ នៅក្នុងគុហាមួយក្បែរគុហាខ្លួន ។ តាំងអំពីនោះមកក៏ឲ្យមេរាជសីហ៍និងចចកញីនៅចាំគុហា ខ្លួនឯងនិងចចកចេញទៅរកអាហារ សម្លាប់ម្រឹគផ្សេងៗ សត្វទាំង ២ បរិភោគរួមគ្នាក្នុងទីនោះហើយនាំមកឲ្យរាជ-សីហ៍ញីនិងចចកញី ។ វេលាកន្លងទៅមេរាជសីហ៍កើតកូនបាន ២ ចចកញីក៏កើតកូនបាន ២ ដូចគ្នា សត្វទាំងអស់នៅជាមួយគ្នាយ៉ាងសុខសាន្ត ។ ថ្ងៃមួយរាជសីហ៍ញីមានចិត្តប្រចណ្ឌថា រាជសីហ៍នេះស្រឡាញ់ចចកញីនិងកូនចចកពន់ពេក ប្រហែលជារាជសីហ៍នេះស្នេហាចចកញីក៏ថាបានទើបស្រឡាញ់គ្នាយ៉ាងនេះ បើដូច្នោះអញនឹងបៀតបៀនគំរាមឲ្យមេចចកចេញអំពីទីនេះឲ្យបាន ។ លុះដល់ពេលរាជសីហ៍នាំចចកទៅរកអាហារ ទើបរាជសីហ៍ញីបៀតបៀនគំរាមចចកញីថា ហេតុអ្វីទើបនាងនៅក្នុងទីនេះមិនចេញទៅអំពីទីនេះសូម្បីកូនចចកក៏កូនរាជសីហ៍គំរាមដូចគ្នា ទើបចចកញីប្រាប់រឿងនោះដល់ចចកឈ្មោលហើយពោលថា យើងដឹងមិនបានថារាជសីហ៍ញីនេះបានធ្វើតាមពាក្យរបស់រាជសីហ៍ ( ឬក៏មិនធ្វើតាមទេ ) យើងរស់នៅទីនេះមកយូរហើយយើងត្រឡប់ទៅលំនៅរបស់យើងវិញចុះ ។

ចចកស្តាប់ពាក្យរបស់ចចកញីទើបចូលទៅរករាជសីហ៍ពោលថា បពិត្រលោកខ្ញុំនៅក្នុងសម្នាក់លោកយូរហើយ ធម្មតាការនៅយូររមែងមិនជាទីគាប់ចិត្តក្នុងពេលដែលយើងចេញទៅរកអាហារ រាជសីហ៍ញីបៀតបៀន សម្លុតចចកញីថា ហេតុអ្វីទើបនាងនៅក្នុងទីនេះមិនគេចចេញទៅសូម្បីកូនរាជសីហ៍ក៏គំរាមកូនខ្ញុំដែរ បុគ្គលណាមិនគាប់ចិត្តឲ្យបុគ្គលណានៅក្នុងសម្នាក់របស់ខ្លួន បុគ្គលនោះគប្បីបណ្តេញអ្នកដែលនៅក្នុងសំណាក់ខ្លួនថា ចូរអ្នកចៀសចេញទៅ ការបៀតបៀនគ្នា គំរាមគ្នានឹងមានប្រយោជន៍អ្វីហើយពោលគាថាទីមួយថា

អ្នកមានកម្លាំងបណ្តេញ ( នូវបុគ្គលអ្នកសេពគប់នឹងខ្លួន )
តាមសេចក្តីប្រាថ្នាបាន បពិត្រស្តេចម្រឹគ ( នេះ ) ជាធម្មតា
នៃអ្នកមានកម្លាំង បពិត្រស្តេចម្រឹគ អ្នកមានចង្កូមស្រួចលោក
ចូរដឹងចុះ មរណភ័យកើតហើយអំពីទីជាទីពឹង ( របស់
យើង ) ដូច្នេះ ។

រាជសីហ៍ស្តាប់ពាក្យរបស់ចចកហើយទើបពោលនឹងរាជសីហ៍ញីថា នែនាង ក្នុងកាលមួយនោះនាងរឭកបានទេថា យើងទៅរកអាហារអស់ ៧ ថ្ងៃបានមកជាមួយចចកនិងមេចចកនេះ រាជសីហ៍ញីពោលថា ចាំបាន រាជសីហ៍ឈ្មោលថា នាងដឹងដល់ហេតុដែលយើងមិនបានមកអស់ ៧ ថ្ងៃនោះដែរឬ រាជសីហ៍ញីពោលថា ខ្ញុំមិនដឹងទេ រាជសីហ៍ឈ្មោលពោលថា នែនាងយើងទៅដោយតាំងចិត្តថានឹងចាប់ម្រឹគមួយ ហើយធ្លាក់ទៅក្នុងភក់មិនអាចរើខ្លួន

ឡើងបានទើបឈរអត់អាហារ ៧ ថ្ងៃ យើងរួចជីវិតមកបានព្រោះអាស្រ័យចចកនេះ ។ ចចកនេះជាសម្លាញ់ជួយជីវិតយើង ។ ពិតហើយបុគ្គលដែលតាំងនៅក្នុងមិត្តធម៌ឈ្មោះថា មានកម្លាំងតិចមិនមានឡើយ តាំងអំពីនេះទៅនាងកុំមើលងាយចចកឈ្មោលចចកញីនិងកូនចចកជាសម្លាញ់យើងឡើយ ហើយទើបពោលគាថាទីពីរថា

ប្រសិនបើមិត្តមានកម្លាំងខ្សោយ តែតាំងនៅក្នុងមិត្តធម៌ទាំងឡាយ បុគ្គលនោះហៅថា ជាញាតិផង ជាផៅពង្សផង បុគ្គលនោះហៅថា មិត្តផង បុគ្គលនោះហៅថា សម្លាញ់របស់យើងផង ម្នាលមេម្រឹគមានចង្កូម នាងកុំមើលងាយចចកឈ្មោល និងចចកញីជាសំឡាញ់យើងឡើយ ព្រោះចចកជាអ្នកឲ្យជីវិតដល់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ ចេបិ** បានដល់ **អបិ** សព្ទមួយជាអនុគ្គហត្ថៈគឺ អត្ថអនុលោម **អបិ** សព្ទមួយទៀតជាសម្ភាវនត្ថៈគឺ អត្ថលើកតម្កើង ។ ក្នុងសព្ទនោះយោជនាថាខទុកថា បើបុគ្គលជាមិត្តសូម្បីមានកម្លាំងតិច តែតាំងនៅក្នុងមិត្តធម៌ គឺបើអាចតាំងនៅបាន បុគ្គលនោះឈ្មោះថា ជាញាតិផង បុគ្គលនោះឈ្មោះថាជាផៅពង្សផង បុគ្គលនោះឈ្មោះថាជាមិត្តផងព្រោះមានចិត្តមេត្តា និងឈ្មោះថាជាសម្លាញ់ព្រោះនៅរួមគ្នា ។ បទថា **ទាឋិនិ មាតិមញ្ញិត្ថោ** សេចក្តីថា នៃមេម្រឹគមានចង្កូមល្អ នាងកុំមើលងាយចចកឈ្មោល និងចចកញីជាសម្លាញ់យើងឡើយ ព្រោះចចកជាអ្នកឲ្យជីវិតដល់

យើង ។

រាជសីហ៍ញីស្តាប់ពាក្យរបស់រាជសីហ៍ហើយ ទើបសុំទោសចចក ចាប់តាំងអំពីនោះមកក៏នៅរួបរួមគ្នាជាមួយចចកញីនោះមួយអន្លើដោយកូនចចក សូម្បីកូនរាជសីហ៍ក៏ប្រឡែងលេងជាមួយកូនចចក សូម្បីមេបាក៏ពេញចិត្តដល់គ្នានឹងគ្នារហូតដល់ស្លាប់ក៏មិនទម្លាយមិត្តដល់គ្នានឹងគ្នា រស់នៅយ៉ាងសុខសប្បាយ ។

បានឮថា មេត្រីភាពរបស់សត្វទាំងនោះមិនបានបែកធ្លាយរហូតដល់ ៧ ជួរត្រកូល ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមក ហើយទ្រង់ប្រកាសអរិយសច្ច ក្នុងកាលចប់អរិយសច្ច ភិក្ខុពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាសកទាគាមី ពួកខ្លះបានជាអនាគាមី ពួកខ្លះបានជាព្រះអរហន្ត ហើយទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯរាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គុណជាតក ចប់

## សុហនុជាតក

[ ១៦៥ ] ( អាមាត្យពោធិសត្វពោលថា ) សេះឈ្មោះសុហនុ ធ្វើនូវសេចក្ដីស្រឡាញ់នេះជាមួយនឹងសេះឈ្មោះសោណៈ មិនមែនដោយមារយាទមិនស្មើគ្នាទេ សេចក្ដីប្រព្រឹត្តរបស់សេះឈ្មោះសោណៈយ៉ាងណា សេះឈ្មោះសុហនុ ក៏ប្រាកដយ៉ាងនោះដែរ ។

[ ១៦៦ ] អំពើរមែងស្មើគ្នាដោយការស្ទុះទៅនិងការឃ្នើសឃ្នងនិងការខាំកាត់នូវខ្សែជានិច្ច អំពើអាក្រក់ស្មើគ្នាដោយអំពើអាក្រក់ ការមិនរៀបរយស្មើគ្នាដោយការមិនរៀបរយ ។

**ចប់ សុហនុជាតកទី ៨ ។**

## អដ្ឋកថា

## សុហនុជាតក

[ ១៦៥-១៦៦ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុកាច ២ រូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **នយិទំ វិសមសីលេន** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា សម័យនោះភិក្ខុមួយរូបក្នុងជេតពនវិហារបានជាភិក្ខុកាចគ្រោតគ្រាតពន់ពេក ។ ក្នុងជនបទក្រៅ មានភិក្ខុមួយរូបក៏ជាអ្នកកាច ។ ថ្ងៃមួយ ភិក្ខុជនបទក្រៅបានមកកាន់វិហារជេតពន ដោយករណីយកិច្ចឯណានីមួយ ។ បណ្ដាសាមណេរនិងភិក្ខុកំលោះដឹងថា ភិក្ខុអ្នកជនបទរូបនោះជា

ភិក្ខុកាច ទើបបញ្ជូនភិក្ខុរូបនោះទៅកាន់លំនៅរបស់ភិក្ខុកាច ដែលនៅក្នុងវត្តជេតពនដោយគិតថា យើងនឹងឃើញភិក្ខុកាច ២ រូបនោះឈ្លោះគ្នា ។ ភិក្ខុទាំង ២ រូបនោះ កាលឃើញគ្នានឹងគ្នាហើយក៏សាមគ្គីគ្នា សរសើរគ្នានឹងគ្នាដោយសេចក្តីស្រឡាញ់បានធ្វើកិច្ចមានប្របាច់ដៃ ប្របាច់ជើង ប្របាច់ខ្នងឲ្យគ្នានឹងគ្នា ។

ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងរោងធម្មសភាថា អើ អាវុសោ ភិក្ខុកាច ២ រូប ជាអ្នកកាចគ្រោតគ្រាតពន់ពេកចំពោះអ្នកដទៃតែភិក្ខុទាំង ២ រូបនោះមានការសាមគ្គីគ្នា ស្រុះស្រួលគ្នា ដោយសេចក្តីស្រឡាញ់ដល់គ្នានឹងគ្នា ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបបង្គំទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយមិនមែនតែក្នុងកាលឥឡូវនេះទេសូម្បីក្នុងកាលមុនក៏ភិក្ខុ ២ រូប នេះកាចគ្រោតគ្រាតក្រៃពេកតែកាលឃើញគ្នានឹងគ្នាហើយក៏សាមគ្គីគ្នា សរសើរគ្នាដោយសេចក្តីស្រឡាញ់ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាអាមាត្យសម្រេចរាជការគ្រប់យ៉ាង ជាអ្នកថ្វាយអត្ថថ្វាយធម៌ដល់ព្រះរាជា ។ ឯព្រះរាជាអង្គនោះជាអ្នកមានប្រក្រតីលោភលន់ក្នុងព្រះរាជទ្រព្យ ទ្រង់មានសេះកាចមួយឈ្មោះមហាសោណៈ ។ ក្នុងកាល

នោះពួកឈ្មួញសេះអ្នកឧត្តរាបថនាំសេះ ៥០០ មក ពួកអាមាត្យក្រាបទូលដល់រឿងដែលសេះមកដល់ព្រះរាជាឲ្យទ្រង់ជ្រាប ។ ក្នុងកាលមុនព្រះពោធិ-សត្វវាយតម្លៃសេះឲ្យទ្រព្យមិនធ្វើតម្លៃឲ្យធ្លាក់ចុះ គឺមិនបន្ថោកតម្លៃ ។ ព្រះរាជាទ្រង់ឃើញព្រះពោធិសត្វមិនតថ្លៃឲ្យចុះ ទើបហៅអាមាត្យដទៃមកហើយត្រាស់ថា នែបា ចូរបាវាយតម្លៃសេះ កាលនឹងវាយតម្លៃ ចូរលែងសេះឈ្មោះមហាសោណៈ ឲ្យចូលទៅក្នុងរវាងសេះទាំងនោះសិន ឲ្យខាំសេះទាំងនោះធ្វើឲ្យមានរបួស លុះសេះពិការចូរវាយតម្លៃឲ្យទាប ។ អាមាត្យនោះទទួលព្រះរាជបញ្ជាបានធ្វើតាមព្រះរាជបំណង ។ ឈ្មួញសេះទាំងឡាយមិនពេញចិត្ត ទើបប្រាប់កិរិយាដែលអាមាត្យនោះធ្វើឲ្យព្រះពោធិសត្វជ្រាប ។ ព្រះពោធិសត្វសួរថា ក្នុងនគររបស់ពួកអ្នកមិនមានសេះកាចខ្លះទេឬ ឈ្មួញប្រាប់ថា មានសេះឈ្មោះសុហនុកាចក្រៃលែង ព្រះពោធិសត្វពោលថា បើដូច្នោះកាលអ្នកមកទៀតចូរនាំសេះនោះមកផងចុះ ។ ពួកឈ្មួញសេះទទួលពាក្យ កាលពួកឈ្មួញមកទៀតបាននាំសេះកាចនោះមកដែរ ។

ព្រះរាជាទ្រង់ឮថា ពួកឈ្មួញសេះមកត្រាស់ឲ្យបើកសីហបញ្ជរទតសេះទាំងឡាយហើយមានព្រះរាជបញ្ជាឲ្យលែងសេះឈ្មោះមហាសោណៈ ។ ពួកឈ្មួញសេះឃើញសេះមហាសេណៈមកក៏លែងសេះសុហនុទៅ ។ សេះទាំង ២ ជួបគ្នាក៏លិទ្ធរាងកាយគ្នានឹងគ្នាដោយសេចក្ដីស្និទ្ធស្នាល ។ ទើបព្រះរាជាត្រាស់សួរព្រះពោធិសត្វថា មើលចុះ សេះកាចនេះកាចក្រៃលែងចំពោះសេះដទៃខាំសេះដទៃឲ្យរបួស ឥឡូវនេះលិទ្ធរាងកាយគ្នានឹងគ្នាដោយសេចក្ដីស្និទ្ធ

ស្វាលតើមានរឿងអ្វីហ្ន៎ ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គ សេះនេះ មានប្រក្រតីមិនស្មើគ្នាក៏មិនមែន សេះនេះមានប្រក្រតីស្មើគ្នា មានធាតុស្មើគ្នា ហើយពោលគាថាទាំងពីរថា

សេះឈ្មោះសុហនុ ធ្វើនូវសេចក្តីស្រឡាញ់នេះជាមួយនិង
សេះឈ្មោះសោណៈ មិនមែនដោយមារយាទមិនស្មើគ្នាទេ
សេចក្តីប្រព្រឹត្តរបស់សេះឈ្មោះសោណៈ យ៉ាងណាសេះ
ឈ្មោះសុហនុក៏ប្រាកដយ៉ាងនោះដែរ ។

អំពើរមែងស្មើគ្នា ដោយការស្ទុះទៅនឹងការឃើញសឃ្មងនិង
ការខាំកាត់នូវខ្សែជានិច្ច អំពើអាក្រក់ស្មើគ្នាដោយអំពើអាក្រក់
ការមិនរៀបរយស្មើគ្នាដោយការមិនរៀបរយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នយិទំ វិសមសីលេន សោណេន សុហនូ សហ** សេចក្តីថា សុហនុសេះកាចធ្វើកិរិយាណាស្មើគ្នានិងសេះសោណៈ កិរិយានេះមិនមែនប្រព្រឹត្តទៅដោយប្រក្រតីមិនស្មើនឹងខ្លួនទេ ។ ដែលពិតរមែងមានមារយាទស្មើនឹងខ្លួន សត្វទាំង ២ នេះឈ្មោះថា មានប្រក្រតីស្មើគ្នា មានធាតុស្មើគ្នាព្រោះខ្លួនមានមារយាទអាក្រក់ មានប្រក្រតីមិនល្អ កាចសាហាវ ។ បទថា **សុហនុបិ តាទិសោ យេវ** សេចក្តីថា សេះសោណៈបែបណាសេះសុហនុក៏បែបនោះដូចគ្នា ។ បទថា **យោ សោណស្ស សគោចរោ** សេចក្តីថា សេះសោណៈមានអារម្មណ៍យ៉ាងណា សេះសុហនុក៏មានអារម្មណ៍យ៉ាងនោះដូចគ្នា ។ បើសេះសោណៈចូលចិត្តបៀតបៀនសេះដទៃ

ដើរខាំសេះដទៃយ៉ាងណា សូម្បីសេះសុហនុក៏យ៉ាងនោះ ។ ព្រះពោធិសត្វ សម្តែងប្រការដែលសេះទាំង ២ នោះមានអារម្មណ៍ស្មើគ្នាដោយបទនេះ ។ កាលសម្តែងដល់សេះទាំង ២ នោះមានមារយាទថោកទាបជាអារម្មណ៍ដូចគ្នា ទើបពោលពាក្យថា **បក្ខន្ទិនា** ប្រែថា ស្ទុះទៅជាដើម ។ បទថា **បក្ខន្ទិនា** បានដល់មានប្រក្រតីស្ទុះទៅ គឺមានប្រក្រតីស្ទុះទៅជាអារម្មណ៍លើសសេះទាំងឡាយ ។ បទថា **បគព្ភេន** បានដល់ មានប្រក្រតីអាក្រក់ប្រកបដោយការផ្តាំផ្គងកាយជាដើម ។ បទថា **និច្ចំ សន្ទានខាទិនា** បានដល់ មានប្រក្រតីខាំនិងចូលចិត្តខាំខ្សែដែលលាមខ្លួន ។ បទថា **សមេតិ បាបំ បាបេន** សេចក្តីថា ក្នុងសេះទាំង ២ នោះសេចក្តីអាក្រក់ គឺប្រក្រតីអាក្រក់របស់សេះមួយរមែងដូចគ្នានិងសេះមួយទៀត ។ បទថា **អសតាសតំ** សេចក្តីថា ការមិនល្អរបស់សេះម្ខាងទៀតដែលមិនស្ងប់រមែងចូលគ្នាបាន គឺដូចគ្នាមិនខុសប្លែកគ្នានិងសេះមួយទៀតដែលជាអ្នកមិនស្ងប់ គឺប្រកបដោយមារយាទថោកទាបដូចលាមកជាដើមចូលគ្នាបានជាមួយលាមកជាដើម ។

ព្រះពោធិសត្វ កាលក្រាបទូលយ៉ាងនេះហើយទើបថ្វាយឱវាទព្រះរាជាថា បពិត្រមហារាជ ធម្មតាព្រះរាជាមិនគួរលោភលន់ មិនគួរធ្វើសម្បត្តិអ្នកដទៃឲ្យវិនាសទេហើយទូលឲ្យវាយតម្លៃសេះតាមតម្លៃដែលពិត ។

ពួកឈ្មួញសេះបានតម្លៃតាមពិតក៏នាំគ្នាត្រេកអរត្រឡប់ទៅ ។ ព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វហើយទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

សេះទាំង ២ ក្នុងកាលនោះបានមកជាភិក្ខុកំណាចទាំង ២ រូបក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ ឯបណ្ឌិតាមាត្យក្នុងកាលនោះគឺតថាគតនេះឯង ។

## អដ្ឋកថា សុហនុជាតក ចប់

## មោរជាតក

[ ១៦៧ ] ( ក្ងោកពោធិសត្វពោលថា ) សុរិយទេវបុត្តណាជាឯករាជ មានចក្ខុមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដីកំពុងរះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់វេលាថ្ងៃក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណាសម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះរក្សានូវខ្ញុំ ការនមស្ការចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះធ្វើបរិត្តនេះរួចហើយទើបត្រាច់ទៅស្វែងរកអាហារ ។

[ ១៦៨ ] ( សុរិយទេវបុត្តណា ) ជាឯករាជមានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដីកំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណាសម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះរក្សានូវខ្ញុំ ការនមស្ការចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វធ្វើបរិត្តនេះរួចហើយទើបបានសម្រេចការនៅ ។

**ចប់ មោរជាតកទី ៩ ។**

## អដ្ឋកថា

## មោរជាតក

[ ១៦៧-១៦៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពនមហាវិហារទ្រង់ប្រារព្ធភិក្ខុអផ្សុក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧទេត-យញ្ចក្ខុមា ឯករាជា** ដូច្នេះជាដើម ។

ភិក្ខុទាំងឡាយនាំភិក្ខុនោះមកចូលគាល់ព្រះសាស្តា កាលទ្រង់សួរថា ម្នាលភិក្ខុ អ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គពិតមែន ។ ព្រះសាស្តាត្រាស់សួរថា អ្នកឃើញអ្វីទើបអផ្សុក ភិក្ខុនោះក្រាបទូលថា ឃើញមាតុគ្រាមម្នាក់ដែលប្រដាប់តាក់តែងកាយ ។ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ឈ្មោះថាមាតុគ្រាមរឿងអ្វីដែលថាមិនចាក់ដោតចិត្តមនុស្សអម្បាលអ្នក សូម្បីបណ្ឌិតក្នុងកាលមុនគ្រាន់តែបានឮសំឡេងមាតុ-គ្រាមកិលេសដែលស្ងប់អស់ ៧០០ ឆ្នាំ បានឱកាសកើតឡើងមួយរំពេច សត្វទាំងឡាយសូម្បីបរិសុទ្ធក៏គង់សៅហ្មងបាន សូម្បីសត្វដែលបរិបូណ៌ដោយយសខ្ពង់ខ្ពស់គង់ដល់នូវសេចក្តីវិនាសបាន នឹងពោលថ្វីដល់សត្វមិនបរិសុទ្ធ ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតក្ងោកនៅក្នុងស៊ុត ដែលមានសណ្ឋានមូលដូចផ្កាកណិការក្រពុំ កាលចោះសម្បកចេញមកហើយមានពណ៌ដូចមាសគួរពិតពិលរមិលមើល គួរជ្រះថ្លា មានឆ្នូតពណ៌ក្រហមនៅក្នុងចន្លោះស្លាប ក្ងោកនោះរក្សាជីវិតរបស់ខ្លួននៅអាស្រ័យត្រង់ភ្នំទណ្ឌកហិរញ្ញមួយកន្លែងក្បែរ

ជួរភ្នំ ទី ៤ ហួសជួរភ្នំទី ៣ ទៅ ។ ពេលព្រឹកព្រាងក្អោកមាសទំគ្រង់កំពូលភ្នំសម្លឹងមើលព្រះអាទិត្យដែលកំពុងរះឡើង កាលនឹងចងមន្តដ៏ប្រសើរដើម្បីការពារខ្លួនក្នុងបទេសដែលស្វែងរកអាហារទើបពោលគាថាទីមួយថា

សុរិយទេវបុត្តណា ជាឯករាជមានចក្ខុ មានសម្បុរដូចជាមាស
មានពន្លឺផ្សាយទៅលើផែនដីកំពុងរះឡើង ខ្ញុំសូមនមស្ការនូវ
សុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយ
ទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់វេលាថ្ងៃក្នុង
ថ្ងៃនេះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទេតិ** បានដល់ ព្រះអាទិត្យដែលរះឡើងអំពីទិសខាងកើត ។ បទថា **ចក្ខុមា** បានដល់ ភ្នែក ដោយភ្នែកដែលឲ្យដល់មហាជនព្រោះកម្ចាត់នូវងងឹត ធ្វើឲ្យអ្នកនៅក្នុងចក្កវាឡទាំងមូលបាននូវកែវភ្នែក ។ បទថា **ឯករាជា** សេចក្តីថា ឈ្មោះថាឯករាជ ព្រោះប្រសើរបំផុតក្នុងរវាងវត្ថុដែលធ្វើឲ្យលោកភ្លឺស្វាងក្នុងចក្កវាឡទាំងមូល ។ បទថា **ហរិស្សវណ្ណោ** គឺមានពណ៌ដូចមាស អធិប្បាយថា មានពណ៌ល្អក្រៃលែង ។ បទថា **បឋវិប្បភាសោ** គឺមានពន្លឺផ្សាយទៅលើផែនដី ។ បទថា **តំ តំ នមស្សាមិ** គឺ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តដ៏ចម្រើន នោះ ។ បទថា **តយជ្ជ គុត្តា វិហរេមុ ទិវសំ** បានដល់ ខ្ញុំសូមឲ្យលោករក្សាគ្រប់គ្រង ( ខ្ញុំ ) ក្នុងថ្ងៃនេះខ្ញុំគប្បីនៅជាសុខអស់ថ្ងៃនេះដោយការនៅក្នុងឥរិយាបថទាំង ៤ ។

ព្រះពោធិសត្វ កាលនមស្ការព្រះអាទិត្យដោយគាថានេះយ៉ាងនេះហើយ ទើបនមស្ការព្រះពុទ្ធដែលទ្រង់បរិនិព្វានទៅហើយក្នុងអតីតនិងព្រះគុណរបស់ព្រះពុទ្ធដោយគាទីពីរថា

ព្រាហ្មណ៍ទាំងឡាយណាសម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះរក្សានូវខ្ញុំ ការនមស្ការចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះធ្វើបរិត្តនេះរួចហើយទើបត្រាច់ទៅស្វែងរកអាហារដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យេ ព្រាហ្មណា** បានដល់ ព្រាហ្មណ៍ដែលបរិសុទ្ធ បន្សាត់នូវបាបហើយពួកណា ។ បទថា **វេទគូ** សេចក្តីថា ឈ្មោះថា ជាអ្នកដឹងត្រៃវេទព្រោះដល់នូវត្រើយនៃវេទ ម្យ៉ាងទៀតព្រោះដល់ត្រើយដោយវេទ ។ តែក្នុងទីនេះមានអធិប្បាយថា ព្រាហ្មណ៍ពួកណាធ្វើសង្ខតធម៌និងអសង្ខតធម៌ទាំងពួង ដែលខ្លួនដឹងហើយឲ្យប្រាកដ ទម្លាយកំពូលមារទាំង ៣ ញ៉ាំងម៉ឺនលោកធាតុឲ្យលាន់រំពង សម្រេចសម្មាសម្ពោធិញ្ញាណត្រង់មណ្ឌលពោធិព្រឹក្ស ជាអ្នកឆ្លងត្រើយសង្សារវដ្តបានហើយ ។ បទថា **តេ មេ នមោ** គឺ សូមព្រាហ្មណ៍ទាំងនោះទទួលនូវការថ្វាយបង្គំនេះរបស់ខ្ញុំ ។ បទថា **តេ ច មំ បាលយន្តុ** សេចក្តីថា ម្យ៉ាងទៀត សូមលោកដ៏ចម្រើនទាំងនោះ

ដែលខ្ញុំនមស្ការហើយយ៉ាងនេះ សូមរក្សា គឺឃុំគ្រងខ្ញុំ ។ បទថា **ឆមត្ថុ ពុទ្ធានំ ឆមត្ថុ ពោធិយា ឆមោ វិមុត្តានំ ឆមោ វិមុត្តិយា** សេចក្តីថា ការថ្វាយបង្គំរបស់ខ្ញុំនេះ ចូរមានដល់ព្រះពុទ្ធទាំងឡាយ ដែលទ្រង់បរិនិព្វាន កន្លងទៅហើយ ។ គឺសូមមានដល់បញ្ញាជាគ្រឿងត្រាស់ដឹងបានដល់ញាណ ក្នុងមគ្គ ៤ ផល ៤ របស់ព្រះពុទ្ធទាំងនោះ ម្យ៉ាងទៀតសូមមានដល់ព្រះអង្គ ដែលរួចផុតហើយដោយការរួចផុត គឺព្រះអរហត្តផលរបស់ព្រះអង្គនិងការ រួចផុត ៥ យ៉ាងរបស់ព្រះអង្គគឺ តទង្គវិមុត្តិ ១ វិក្ខម្ភនវិមុត្តិ ១ សមុច្ឆេទ-វិមុត្តិ ១ បដិបស្សទ្ធិវិមុត្តិ ១ និស្សរណវិមុត្តិ ១ ការថ្វាយបង្គំរបស់ខ្ញុំនេះ ចូរមានដល់ការរួចផុត ៥ យ៉ាងរបស់ព្រះអង្គនោះ ។

បទជាច្រើនថា **ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** នេះ ព្រះសាស្តាត្រាស់ក្នុងកាលបានសម្រេចអភិសម្ពោធិញ្ញាណហើយ ។ បទនេះ មានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយក្ងោកនោះកាលចម្រើនបរិត្តនេះគឺ ការ ការពារនេះហើយទើបត្រាច់ទៅស្វែងរកអាហារផ្សេងៗមានផ្កាឈើ ផ្លែឈើ ជាដើមក្នុងទីរកអាហាររបស់ខ្លួន ។

ក្ងោកនោះត្រាច់ទៅអស់ថ្ងៃយ៉ាងនេះហើយ ពេលល្ងាចក៏ទំត្រង់កំពូលភ្នំ សម្លឹងមើលព្រះអាទិត្យដែលកំពុងលិចរឭកដល់ព្រះពុទ្ធគុណ កាលនឹងចង មន្តដ៏ប្រសើរទៀតដើម្បីរក្សាក្នុងលំនៅទើបពោលពាក្យជាដើមថា **អបេតយំ** ដូច្នេះជាដើម ។

គាថានោះដូច្នេះថា

( សុរិយទេវបុត្តណា ) ជាឯករាជមានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដីកំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះរក្សានូវខ្ញុំ ការនមស្ការចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វធ្វើបរិត្តនេះរួចហើយទើបបានសម្រេចការនៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបេតិ** បានដល់ កន្លងទៅ គឺអស្តង្គតទៅ ។ សូម្បីបទថា **ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយិ** នេះព្រះសាស្តាក៏ត្រាស់កាលដែលព្រះអង្គបានសម្រេចអភិសម្ពោធិញ្ញាណហើយដែរ ។ បទនេះមានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក្ងោកនោះកាលចម្រើនព្រះបរិត្ត គឺគ្រឿងការពារនេះហើយទើបស្នាក់នៅក្នុងទីនោះ ។ ដោយអានុភាពនៃព្រះបរិត្តនេះក្ងោកមិនមានការខ្លាច ការភិតភ័យអស់រាត្រីក្នុងថ្ងៃនោះ ។

គ្រានោះព្រានអ្នកស្រុកនេសាទម្នាក់នៅមិនឆ្ងាយអំពីនគរពារាណសីត្រាច់ទៅក្នុងហិមវន្តប្បទេស ឃើញក្ងោកពោធិសត្វទំលើកំពូលភ្នំ ទណ្ឌកហិរញ្ញ

ក៏ត្រឡប់មកប្រាប់កូន ។ ថ្ងៃមួយព្រះនាងខេមា ជាទេវីរបស់ព្រះបាទពារា-ណសី ព្រះនាងសុបិនឃើញក្ងោកមាសសម្ដែងធម៌ តើនចាកព្រះបន្ទំក្រាបទូលសុបិនដល់ព្រះរាជាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ប្រាថ្នានឹងស្ដាប់ធម៌របស់ក្ងោកមាសទើបព្រះរាជាមានព្រះតម្រាស់សួរពួកអាមាត្យ ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ប្រហែលជាដឹង ពួកព្រា-ហ្មណ៍ស្ដាប់ព្រះរាជបុច្ឆាហើយទើបនាំគ្នាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនក្ងោកមាសមានពិត ព្រះរាជាត្រាស់សួរថា មាននៅទីណា ទើបក្រាបទូលថាពួកព្រានព្រៃនឹងជ្រាប ។ ព្រះរាជាឲ្យប្រជុំពួកព្រានទាំងអស់ហើយត្រាស់សួរ ។ កាលនោះកូនព្រាននោះក៏ក្រាបទូលថា បពិត្រមហារាជ ក្ងោកពណ៌មាសមានពិតអាស្រ័យនៅនាទណ្ឌកហិរញ្ញបព៌តឯណោះ ព្រះរាជាត្រាស់ថាបើដូច្នោះចូរឯងទៅចាប់ក្ងោកនោះមកទាំងរស់ ។ ទើបព្រានយកអន្ទាក់ទៅដាក់ក្នុងទីដែលក្ងោករកអាហារ ។ ក្នុងទីដែលក្ងោកជាន់អន្ទាក់ក៏មិនភ្ជាត់ ។ ព្រានមិនអាចចាប់ក្ងោកបានត្រាច់ទៅអស់ ៧ ឆ្នាំ ក៏ស្លាប់ក្នុងទីនោះឯង ។ ព្រះនាងខេមាទេវី កាលមិនបានសម្រេចបំណងក៏អស់ព្រះជន្ម ។ ព្រះរាជាទ្រង់ពិរោធថា ព្រះទេវីអស់ព្រះជន្មព្រោះអាស្រ័យក្ងោកទើបឲ្យចារឹកអក្សរទុកក្នុងក្រាំងមាសថា ក្នុងហិមវន្តប្បទេសមានភ្នំមួយឈ្មោះទណ្ឌកហិរញ្ញ ក្ងោកពណ៌មាសមួយអាស្រ័យនៅទីនោះ អ្នកណាបានស៊ីសាច់ក្ងោកនោះអ្នកនោះមិនចាស់មិនស្លាប់នឹងមានអាយុវែង ហើយដាក់ក្រាំងមាសក្នុងហិបមាស ។ កាលព្រះរាជាសោយទិវង្គតហើយ ព្រះរាជាអង្គដទៃគ្រងរាជសម្បត្តិ ទ្រង់អាន

សេចក្ដីក្នុងសុវណ្ណបដៈមានបំណងមិនចាស់មិនស្លាប់ ទើបបញ្ជូនព្រានដទៃទៅឲ្យដើរស្វែងរក ។ ព្រាននោះទៅដល់ទីនោះហើយក៏មិនអាចចាប់ព្រះពោធិសត្វបាន ក៏ស្លាប់ក្នុងទីនោះឯង ។ ដោយទំនងនេះព្រះរាជាសោយទិវង្គតទៅអស់ ៦ អង្គ លុះដល់អង្គទី ៧ គ្រងរាជសម្បត្តិក៏ទ្រង់បញ្ជូនព្រានម្នាក់ទៅ ព្រាននោះទៅដល់ហើយក៏ដឹងដល់ការៈដែលអន្ទាក់មិនក្ដាត់ក្នុងទីដែលក្ងោកព្រះពោធិសត្វជាន់ហើយនិងការដែលក្ងោកពោធិសត្វចម្រើនព្រះបរិត្តការពារខ្លួនជាមុនទើបហើរទៅរកអាហារ ទើបទៅកាន់បច្ចន្តជនបទ ចាប់ក្ងោកញីបានមួយ បង្ហាត់ឲ្យចេះរាំដោយសំឡេងទះដៃ និងឲ្យរងាវដោយសំឡេងផ្ទាត់ម្រាមដៃ កាលបង្ហាត់ក្ងោកញីជំនាញល្អហើយទើបនាំក្ងោកញីទៅ ។ កាលក្ងោកមាសមិនទាន់ចម្រើនព្រះបរិត្ត ដោតជង់អន្ទាក់ទុកក្នុងពេលព្រឹកឲ្យសញ្ញាដល់ក្ងោកញីរងាវ ក្ងោកមាសបានឮសំឡេងមាតុគ្រាម ដែលជាសត្រូវហើយក៏ក្ដៅក្រហាយដោយកិលេសមិនអាចចម្រើនព្រះបរិត្តបាន ទើបហើរមកជាប់អន្ទាក់ ព្រានក៏ចាប់ក្ងោកមាសទៅថ្វាយព្រះបាទពារាណសី ។ ព្រះរាជាទតឃើញរូបសម្បត្តិរបស់ក្ងោកមាស ក៏ទ្រង់ពេញព្រះរាជហឫទ័យ ព្រះរាជទានកន្លែងឲ្យទំ ។ ក្ងោកមាសពោធិសត្វទំលើបង្គង់ដែលគេរៀបចំឲ្យទូលសួរព្រះរាជាថា បពិត្រមហារាជ ព្រោះហេតុអ្វីទើបទ្រង់បញ្ជាឲ្យចាប់ទូលបង្គំ ព្រះរាជាត្រាស់ថា បានឮថាបុគ្គលណាបានស៊ីសាច់ឯង បុគ្គលនោះមិនចាស់មិនស្លាប់ ខ្ញុំត្រូវការស៊ីសាច់អ្នកនឹងមិនចាស់មិនស្លាប់ ទើបឲ្យចាប់អ្នកមក ។ ក្ងោកទូលថា បពិត្រមហារាជ មនុស្សទាំងឡាយស៊ីសាច់ទូលបង្គំមិនចាស់

មិនស្លាប់ក៏ដោយចុះ តើទូលបង្គំស្លាប់ឬមិនស្លាប់ ព្រះរាជាត្រាស់ថា អ្នកពិតជាស្លាប់ ក្អែកក្រាបទូលថា បពិត្រមហារាជ កាលទូលបង្គំត្រូវស្លាប់អ្នកដែលបរិភោគសាច់ទូលបង្គំហើយរឿងអ្វីដែលមិនស្លាប់នោះ ព្រះរាជាត្រាស់ថា អ្នកមានខ្លួនពណ៌មាសព្រោះហេតុនោះមានដំណឹងថា បុគ្គលដែលស៊ីសាច់អ្នកហើយនឹងមិនចាស់មិនស្លាប់ ក្អែកទូលថា បពិត្រមហារាជ ខ្ញុំមានពណ៌មាសព្រោះមិនមានហេតុក៏មិនមែន កាលមុនខ្ញុំជាស្តេចចក្កពត្តិក្នុងនគរនេះឯងខ្លួនឯងរក្សាសីល ៥ ផង ជនទាំងឡាយដទៃពេញចក្កវាលក៏ឲ្យរក្សាសីល ៥ ផង ខ្ញុំអស់ជីវិតហើយទៅកើតក្នុងឋានតាវត្តិង្ស តាំងនៅក្នុងកពនោះឯងដរាបដល់អស់អាយុចុតិអំពីនោះហើយ ទើបមកកើតក្នុងកំណើតក្អែកព្រោះផលនៃអកុសលកម្មដទៃ ម្យ៉ាងទៀតខ្លួនទូលបង្គំមានពណ៌ដូចមាសដោយអានុភាពនៃសីល ៥ ដែលរក្សាក្នុងកាលមុន ព្រះរាជាសួរថា ឯងពោលថាជាស្តេចចក្កពត្តិរក្សាសីល ៥ ខ្លួនមានពណ៌ដូចមាសព្រោះផលនៃសីលនោះសេចក្តីនេះយើងនឹងជឿឯងបានដូចម្តេច មាននរណាជាបន្ទាល់ ។ ក្អែកក្រាបទូលថា បពិត្រមហារាជ មាន ព្រះរាជាត្រាស់ថា តើជាអ្នកណា ទើបក្រាបទូលថា បពិត្រមហារាជ កាលទូលបង្គំជាស្តេចចក្កពត្តិទូលបង្គំអង្គុយក្នុងរថដែលសម្រេចដោយកែវ ៧ ប្រការត្រាច់ទៅក្នុងអាកាស រថរបស់ទូលបង្គំលិចចុះខាងក្រោមស្រះមង្គលបោក្ខរណី សូមទ្រង់លើករថនោះឡើងចាកស្រះមង្គលបោក្ខរណីចុះ រថនោះនឹងជាសាក្សីរបស់ខ្ញុំ ព្រះរាជាត្រាស់ថា សាធុហើយឲ្យបាចទឹកចេញអំពីស្រះបោក្ខរណី លើករថឡើងទើបទ្រង់ជឿពាក្យ

របស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វ សម្តែងធម៌ថ្វាយព្រះរាជាថា បពិត្រមហារាជ សង្ខតធម៌ទាំងអស់ក្រៅអំពីអមតមហានិព្វានមិនទៀង មានការអស់ទៅនិងសូន្យទៅជាធម្មតាព្រោះមានហើយទៅជាមិនមាន ដូច្នេះហើយឲ្យព្រះរាជាតាំងនៅក្នុងសីល ៥ ។ ព្រះរាជាទ្រង់ជ្រះថ្លា បូជាព្រះពោធិសត្វដោយរាជសម្បត្តិ ទ្រង់ធ្វើសក្ការៈជាច្រើន ។ ក្ងោកថ្វាយរាជសម្បត្តិដល់ព្រះរាជាវិញស្នាក់នៅ ២-៣ ថ្ងៃទើបថ្វាយឱវាទថា បពិត្រមហារាជសូមទ្រង់កុំប្រមាទហើយហើរឡើងទៅលើអាកាសទៅកាន់ភ្នំទណ្ឌកហិរញ្ញ ។ ឯព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វហើយទ្រង់បំពេញកុសលមានទានជាដើម ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ភិក្ខុអផ្សុកតាំងនៅក្នុងអរហត្តហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯក្ងោកមាសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មោរជាតក ចប់

# វិនីលកជាតក

[ ១៦៩ ] ( កូនក្អែកកាត់ហង្សពោលថា ) ហង្សទាំងឡាយ ( រមែងនាំយើង ) ឈ្មោះវិនីលកទៅបានយ៉ាងណាមិញសេះអាជានេយ្យទាំងឡាយនាំនូវព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាក៏យ៉ាងនោះដែរ ។

[ ១៧០ ] ( ហង្សពោធិសត្វជាបិតាពោលថា ) ម្នាលចៅវិនីលៈ អ្នកគប់រកនូវព្រៃភ្នំមានប្រកបផ្សៀត ម្នាលកូនអ្នកសេពនូវកន្លែងមិនមែនជាទីរបស់អ្នកៗចូរសេពនូវកន្លែងជាទីបំផុតនៃស្រុកចុះ ទីនោះជាលំនៅរបស់មាតាអ្នកហើយ ។

**ចប់ វិនីលកជាតកទី ១០ ។**

**ចប់ ទឡ្ហវគ្គទី ១ ។**

## ឧទ្ទាននៃទឡ្ហវគ្គនោះគឺ

និយាយអំពីព្រះបាទពល្លិកដ៏ប្រសើរ ១ ភ្នំប្រាក់ ១ សូករ ១ នាគប្រសើរជាងពស់ ១ បិតាឈ្មោះកគ្គ ១ ជាគម្រប់ ៥ សេនាធំ ១ ចចកប្រសើរ ១ សេះឈ្មោះសុហនុដ៏ឧត្តម ១ ក្ងោក ១ វិនីលក ១ ត្រូវជា១០ ។

# អដ្ឋកថា
# វិនីលជាតក

[ ១៦៩-១៧០ ] ព្រះសាស្តាកាលគង់នៅក្នុងវេឡុវ័នវិហារ ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ដែលយកលំនាំតាមព្រះសុគត ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ឯវមេវ ត្វំ រាជានំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កាលទេវទត្តដេកសម្តែងអាកប្បកិរិយាដូចព្រះសុគតដល់អគ្គសាវកទាំង ២ ដែលមកកាន់គយាសីសប្បទេស អគ្គសាវកទាំង ២ កាលសម្តែងធម៌ហើយ ក៏នាំនិស្សិតរបស់លោកមកកាន់វត្តវេឡុវ័ន ។ ព្រះសាស្តាត្រាស់សួរថា ម្នាលសារីបុត្ត ទេវទត្តឃើញអ្នកទាំង ២ ហើយធ្វើដូចម្តេច ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តធ្វើអាកប្បកិរិយាដូចព្រះអង្គ ហើយដល់នូវសេចក្តីវិនាសធំ ។ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ទេវទត្តយកលំនាំតថាគតដល់នូវសេចក្តីវិនាសធំមិនមែនក្នុងកាលឥឡូវនេះទេ ក្នុងកាលមុនក៏ដល់នូវសេចក្តីវិនាស កាលព្រះថេរៈអារាធនាទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទវិទេហៈ សោយរាជសម្បត្តិក្នុងនគរមិថិលាដែនវិទេហៈ ។ ព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃរបស់អគ្គមហេសីរបស់ព្រះបាទវិទេហៈនោះ កាលចម្រើនវ័យហើយទ្រង់សិក្សាសិល្បសាស្រ្តគ្រប់យ៉ាងក្នុងនគរតក្កសិលា កាលព្រះបិតាសោយទិវង្គតទ្រង់ក៏តាំងនៅក្នុងរាជសម្បត្តិ ។

ក្នុងកាលនោះ ហង្សមាសមួយ បាននៅរួមជាមួយក្អែកញីក្នុងទីស្វែងរកអាហារ ក្អែកញីកើតកូនមកជាកូនឈ្មោលមិនដូចមេមិនដូចបាទើបដាក់ឈ្មោះ

ថា វិនីលកៈ ព្រោះមានពណ៌សម្បុរស្ទើរខ្មៅបន្តិច ( ខៀវ ) ស្តេចហង្ស ទៅរកកូននោះរឿយៗ ។ មួយវិញទៀតស្តេចហង្សនោះមានកូនហង្សតូចៗ ២ ទៀត ។ ហង្សតូចឃើញឪពុកទៅដែនដីមនុស្សរឿយៗទើបសួរថា បពិត្រលោកឪពុក ហេតុអ្វីទើបលោកឪពុកទៅកាន់ដែនដីមនុស្សរឿយៗយ៉ាងនេះ ។ ស្តេចហង្សប្រាប់ថា អើកូនឪពុកស្រឡាញ់ក្អែកញីមួយបានកូនមួយឈ្មោះវិនី-លកៈ ឪពុកទៅសួរសុខទុក្ខកូននោះ ។ កូនហង្សសួរថា កូនរបស់ពុកនោះនៅឯណា ស្តេចហង្សប្រាប់ថា នៅលើចុងត្នោតមួយដើមក្នុងទីឈ្មោះនោះមិនឆ្ងាយអំពីក្រុងមិថិលាដែនវិទេហៈឡើយ ។ កូនហង្សពោលថា ពួកខ្ញុំនឹងទៅនាំកូនក្អែកនោះមក ស្តេចហង្សឃាត់ថា ឈ្មោះថាទឹកដីមនុស្សគួររង្កៀសមានភ័យជុំទិស កូនកុំទៅឡើយ ឪពុកនឹងទៅនាំមកឯង ។ កូនហង្សមិនស្តាប់ពាក្យឪពុកឡើយ ទើបនាំគ្នាទៅក្នុងទីនោះតាមសញ្ញាណដែលឪពុកប្រាប់ ឲ្យវិនីលកៈ ទំត្រង់កំណាត់ឈើមួយហើយនាំគ្នាយកចំពុះពាំចុងឈើទាំងសង ខាងហើរកាត់តាមក្រុងមិថិលា ។ ខណៈនោះព្រះបាទវិទេហៈប្រថាប់លើរថដែលទឹមដោយសេះសិន្ធពពណ៌ស ៤ ទ្រង់ធ្វើប្រទក្សិណព្រះនគរ ។ វិនី-លកៈ ឃើញដូច្នោះនឹកក្នុងចិត្តថា អញមិនខុសអ្វីពីព្រះបាទវិទេហៈ ព្រះបាទវិទេហៈប្រថាប់គង់លើរាជរថដែលទឹមដោយសេះសិន្ធពពណ៌ស ៤ ប្រទក្សិណព្រះនគរ អញអង្គុយក្នុងរថដែលទឹមដោយហង្ស ។ វិនីលកៈ កំពុងទៅតាមអាកាសបានពោលគាថាទីមួយថា

ហង្សទាំងឡាយ ( រមែងនាំយើង ) ឈ្មោះវិនីលកទៅបាន

យ៉ាងណាមិញ សេះអាជានេយ្យទាំងឡាយ នាំនូវព្រះបាទ
វិទេហៈអ្នកគ្រប់គ្រងក្រុងមិថិលាក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវមេវ** សេចក្ដីថា ក៏យ៉ាងនោះដែរ ។ បទថា **ន្ធូន** ជានិបាតចុះក្នុងបរិវិតក្ករមែងប្រព្រឹត្តទៅក្នុងចំណែកតែមួយ ។ បទថា **វេទេហំ** គឺជាធំក្នុងដែនវិទេហៈ ។ បទថា **មិថិលគ្គហំ** បានដល់គ្រប់គ្រងក្រុងមិថិលា គឺនគរមិថិលា ។ បទថា **អាជញ្ញា** បានដល់ សេះដែលដឹងហេតុនិងមិនមែនហេតុ ។ បទថា **យថា ហំសា វិធីលកំ** បានដល់ សេះអាជានេយ្យនាំព្រះបាទវិទេហៈទៅ ដូចហង្សទាំងនេះនាំអញឈ្មោះវិនីលកៈទៅដូច្នោះ ។

កូនហង្សស្ដាប់ពាក្យរបស់វិនីលកៈហើយ ក៏ក្រោធគិតទម្លាក់ចោលក្នុងទីនោះតែក្រែងត្រូវពាក្យតិះដៀលថា បើអញធ្វើយ៉ាងនេះ បារបស់អញនឹងតិះដៀលទើបនាំទៅជួបបាហើយនិយាយឲ្យបាស្ដាប់ដល់កិរិយាដែលវិនីលកៈធ្វើ ។ ស្ដេចហង្សក្រោធសម្ដុតថា ឯងវិសេសជាងកូនអញឬ ជិះកូនអញហើយប្រៀបធៀបកូនអញដូចសេះទឹមរថ ឯងមិនស្គាល់ប្រមាណខ្លួន ទីនេះមិនមែនទឹកដីរបស់ឯងទេ ចូរឯងទៅរកមេរបស់ឯងចុះហើយពោលគាថាទីពីរថា

ម្នាលចៅវិនីលៈអ្នកគប់រកនូវព្រៃភ្នំមានប្រកបផ្សៀត ម្នាលកូន
អ្នកសេពនូវកន្លែងមិនមែនជាទីរបស់អ្នកៗ ចូរសេពនូវកន្លែង
ជាទីបំផុតនៃស្រុកចុះ ទីនោះជាលំនៅរបស់មាតាអ្នកហើយ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិនីល** ជាពាក្យហៅក្អែកឈ្មោះវិនីលកៈ ។ បទថា **ទុគ្គំ ភជសិ** បានដល់ ឯងគប់រកតែញកភ្នំដែលជាលំនៅរបស់បក្សីទាំងនេះ ។ បទថា **អភូមឹ តាត សេវសិ** សេចក្ដីថា ឯងសេព គឺចូលទៅអាស្រ័យភ្នំ ញកភ្នំដែលមិនមែនជាទឹកដីរបស់ឯង ។ បទថា **ឯតំ មាតា-លយំ តុវំ** សេចក្ដីថា ទីចោលសំរាមនិងព្រៃខ្មោចក្បែរស្រុកនោះជាលំនៅគឺជាផ្ទះជាទីសម្រាករបស់មេឯង ឯងចូរទៅនៅក្នុងទីនោះចុះ ។ លុះស្ដេចហង្សគំរាមវិនីលកៈយ៉ាងនេះហើយក៏ប្រាប់កូនហង្សថា យកវាទៅលែងត្រង់ទីចាក់សំរាមនៃក្រុងមិថិលាចុះ កូនហង្សបានធ្វើតាមបញ្ជា ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា វិនីលកៈក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ កូនហង្សទាំង ២ ក្នុងកាលនោះបានមកជាអគ្គសាវកទាំង ២ បាហង្សក្នុងកាលនោះបានមកជាអានន្ទ ឯព្រះបាទវិទេហៈក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា វិនីលជាតក ចប់

ទឡ្ហវគ្គ ចប់

# សន្ថវវគ្គ

## ឥន្ទសមានគោត្តជាតក

[ ១៧១ ] ( តាបសពោធិសត្វពោលថា ) បុគ្គលកុំគប្បីធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងបុរសលាមក អរិយបុគ្គលដឹងច្បាស់នូវប្រយោជន៍ ( ក៏មិនគប្បីធ្វើនូវសេចក្តីស្និទ្ធស្នាល ) ជាមួយនឹងបុគ្គលមិនមែនជាអរិយៈ ( បុគ្គលមិនមែនជាអរិយៈ ) សូម្បីនៅជាមួយគ្នាអស់កាលយូរ រមែងធ្វើអំពើអាក្រក់ដូចជាដំរីកាលព្រេចនូវតាបសឈ្មោះឥន្ទសមានគោត្ត ។

[ ១៧២ ] បុគ្គលគប្បីដឹងនូវជនណាថា បុគ្គលនេះស្មើគ្នាដោយសីលផង បញ្ញាផង សុតៈផង របស់អញគប្បីធ្វើនូវមេត្រីជាមួយនឹងជននោះចុះ ( ព្រោះ ) ការគប់រកដោយសប្បុរសតែងនាំមកនូវសេចក្តីសុខដោយពិត ។

**ចប់ ឥន្ទសមានគោត្តជាតកទី ១ ។**

# សន្ថវវគ្គ

## អដ្ឋកថា ឥន្ទសមានគោត្ត ជាតក

[ ១៧១-១៧២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន សន្ថវំ កាបុរិសេន កយិរា** ដូច្នេះជាដើម ។

រឿងភិក្ខុប្រដៅក្រនោះមានច្បាស់ក្នុងគិជ្ឈជាតកនវកនិបាត ។

ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុកាលមុនអ្នកក៏មិនស្តាប់ពាក្យ

ទូន្មានរបស់បណ្ឌិតទាំងឡាយដែរ ព្រោះអ្នកជាបុគ្គលប្រដៅក្រទើបត្រូវបែកខ្ទេចខ្ទីព្រោះជើងដំរីចុះប្រេង ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ កាលចម្រើនវ័យហើយលះយកវាសចេញបួសជាឥសីជាសាស្តានៃពួកឥសី ៥០០ អាស្រ័យនៅក្នុងព្រៃហិមពាន្ត ក្នុងកាលនោះបណ្តាតាបសទាំងនោះមានតាបសមួយរូបឈ្មោះ ឥន្ទសមានគោត្ត ជាអ្នកប្រដៅក្រមិនស្តាប់ឱវាទរបស់គ្រូ តាបសនោះចិញ្ចឹមកូនដំរី ១ ព្រះពោធិសត្វដឹងដំណឹងទើបហៅតាបសនោះមកសួរថា បានឮថា អ្នកចិញ្ចឹមកូនដំរីមែនឬ តាបសឆ្លើយថា ពិតហើយលោកអាចារ្យ ខ្ញុំចិញ្ចឹមដំរីមួយទុកព្រោះមេវាស្លាប់ ។ ព្រះពោធិសត្វដាស់តឿនថា ឈ្មោះថា ដំរីកាលណាវាធំច្រើនសម្លាប់អ្នកចិញ្ចឹម អ្នកកុំចិញ្ចឹមកូនដំរីនោះឡើយ ។ តាបសពោលថា លោកអាចារ្យខ្ញុំមិនអាចបោះបង់វាបាន ។ ព្រះពោធិសត្វពោលថា បើដូច្នោះ អ្នកនឹងដឹងខ្លួនឯង ។ តាបសក៏នៅតែចិញ្ចឹមកូនដំរីនោះ ។ ចំណេរកាលតមកកូនដំរីក៏មានរាងកាយធំធាត់ ។ សម័យមួយពួកឥសីនាំគ្នាទៅក្នុងទីឆ្ងាយដើម្បីរកមើមឈើនិងផ្លែឈើក្នុងព្រៃហើយស្នាក់នៅក្នុងទីនោះ ២-៣ ថ្ងៃ ។

ដំរីក៏ចុះប្រេង រើបណ្ណសាលាចោលខ្ទាត់ខ្ទាយ បំបែកក្អមទឹកផឹក បោះដុំថ្មចោល ដកបន្ទះក្តារ ( ផ្តើរ ) គ្រវាត់ចោលហើយចូលទៅកាន់ទីលាក់ខ្លួនមួយកន្លែងឈររង់ចាំមើលការមករបស់តាបសដោយបំណងថានឹងសម្លាប់តាបស

ហើយទៅ ។ តាបសឥន្ទសមានគោត្តរកអាហារទុកឲ្យដំរី បានហើយដើរមកមុនតាបសទាំងឡាយ ឃើញដំរីនោះទើបចូលទៅរកតាមប្រក្រតី ដំរីចេញពីទីលាក់ខ្លួន យកប្រមោយចាប់តាបស បោកផ្ទប់នឹងផែនដី យកជើងជាន់ក្បាលឲ្យដល់នូវសេចក្តីស្លាប់ បន្លឺសំឡេងខ្លាំងហើយចូលកាន់ព្រៃ ។ ទើបពួកតាបសដ៏សេសប្រាប់ដំណឹងនោះដល់ព្រះពោធិសត្វ ព្រះពោធិសត្វពោលថា មិនគួរធ្វើសេចក្តីស្និទ្ធស្នាលជាមួយបុគ្គលអាក្រក់ហើយពោលគាថាទាំងនេះថា

បុគ្គលកុំគប្បីធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងបុរសលាមក អរិយបុគ្គលដឹងច្បាស់នូវប្រយោជន៍ ( ក៏មិនគប្បីធ្វើនូវសេចក្តីស្និទ្ធស្នាល ) ជាមួយនឹងបុគ្គលមិនមែនជាអរិយៈ ( បុគ្គលមិនមែនជាអរិយៈ ) សូម្បីនៅជាមួយគ្នាអស់កាលយូរមែងធ្វើអំពើអាក្រក់ ដូចជាដំរីកាលព្រេចនូវតាបសឈ្មោះឥន្ទសមានគោត្ត ។

បុគ្គលគប្បីដឹងនូវជនណាថា បុគ្គលនេះស្មើគ្នាដោយសីលផង បញ្ញាផង សុតៈផង របស់អញគប្បីធ្វើនូវមេត្រីជាមួយនឹងជននោះចុះ ( ព្រោះ ) ការគប់រកដោយសប្បុរសតែងនាំមកនូវសេចក្តីសុខដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន សន្ថវំ កាបុរិសេន កយិរា** សេចក្តីថា បុគ្គលមិនគប្បីធ្វើនូវការស្និទ្ធស្នាល ដោយអំណាចតណ្ហា ឬសេចក្តី

ស្និទ្ធស្នាលដោយអំណាចជាមិត្ត ជាមួយបុគ្គលដែលច្រើនដោយសេចក្ដីក្រោធ ដែលគួរខ្ពើម ។ បទថា **អរិយោ** ក្នុងបទថា **អរិយោនរិយេន បជានមត្ថំ** បានដល់ អរិយៈ ៤ ពួកគឺ អាចារអរិយៈ អរិយៈដោយមារយាទ ១ លិង្គអរិយៈ អរិយៈដោយភេទ ១ ទស្សនអរិយៈ អរិយៈក្នុងការឃើញ ១ បដិវេធអរិយៈ អរិយៈក្នុងការចាក់ធ្លុះ ១ ។ បណ្ដាអរិយៈទាំងនោះ អាចារអរិយៈលោកបំណងយកក្នុងទីនេះ អធិប្បាយថា បុគ្គលជាអរិយៈស្គាល់ប្រយោជន៍ គឺស្គាល់ផលឈ្លាសក្នុងប្រយោជន៍និងមិនមែនប្រយោជន៍ តាំងនៅក្នុងអាចារ មិនគប្បីធ្វើសេចក្ដីស្និទ្ធស្នាលដោយអំណាចតណ្ហា ឬសេចក្ដីស្និទ្ធស្នាលដោយអំណាចភាពជាមិត្តជាមួយបុគ្គលដែលមិនមែនអរិយៈ គឺបុគ្គលទ្រុស្តសីលមិនមានហិរិ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលមិនមែនអរិយៈនោះសូម្បីនៅរួមគ្នាយូរក៏មិនបានរឭកឃើញដល់ការនៅរួមគ្នានោះរមែងធ្វើកម្មអាក្រក់ គឺធ្វើកម្មលាមកប៉ុណ្ណោះ ។ សួរថា ដូចអ្វី ឆ្លើយថា ដូចដំរីសម្លាប់ឥន្ទសមានគោត្តតាបសដូច្នោះ ។ ក្នុងបទថា **យទេវ ជញ្ញា សទិសោ មមំ** សេចក្ដីថា គប្បីស្គាល់បុគ្គលណាថា បុគ្គលនេះស្មើអញដោយសីលជាដើម គប្បីធ្វើនៅមេត្រីជាមួយបុគ្គលនោះប៉ុណ្ណោះ ការសមាគមជាមួយសប្បុរសរមែងនាំសេចក្ដីសុខមកឲ្យ ។

ព្រះពោធិសត្វទូន្មានពួកឥសីថា ធម្មតាមនុស្សយើងមិនគួរជាអ្នកប្រដៅក្រ គួរសិក្សាឲ្យល្អ ហើយឲ្យរៀបចំការបូជាសពឥន្ទសមានគោត្តតាបស រួចនាំគ្នាចម្រើនព្រហ្មវិហារបានចូលដល់ព្រហ្មលោក ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយទ្រង់ប្រជុំជាតកថា ឥន្ទសមានគោត្តក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកគ្រូប្រចាំគណៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឥន្ទសមានគោត្តជាតក ចប់

## សន្តវជាតក

[ ១៧៣ ] ( តាបសពោធិសត្វពោលថា ) ការស្និទ្ធស្នាលណាជាមួយនឹងបុរសលាមក របស់ដទៃលាមកក្រៃលែងជាងការស្និទ្ធស្នាល ( នោះ ) មិនមានទេដូចជាភ្លើងដែលយើងឲ្យឆ្អែតដោយសប្បិនិងបាយាស នៅតែឆេះខ្ទមស្លឹកដែលយើងធ្វើហើយដោយលំបាក ។

[ ១៧៤ ] ការស្និទ្ធស្នាលណាជាមួយនឹងសប្បុរស របស់ដទៃប្រសើរក្រៃលែងជាងការស្និទ្ធស្នាល ( នោះ ) មិនមានទេដូចជាមេម្រឹគឈ្មោះសាមាលិទ្ធមាត់នៃស្តេចរាសីហ៍ផង ខ្លាធំផង ខ្លាដំបងផងព្រោះការស្និទ្ធស្នាល។

**ចប់ សន្តវជាតកទី ២ ។**

## អដ្ឋកថា

## សន្តវជាតក

[ ១៧៣-១៧៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពនមហាវិហារទ្រង់ប្រារព្ធការបូជាភ្លើង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯ សន្តវស្មា បរមត្ថិ ចាបិយោ** ដូច្នេះជាដើម ។

រឿងទាំងអស់ដូចរឿងដែលពោលទុកហើយក្នុងនង្គុដ្ឋជាតក ( ឯកនិបាត ) ខាងដើមនោះឯង ។

បានឮថា ភិក្ខុទាំងឡាយឃើញជដិលទាំងនោះបូជាភ្លើងទើបទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ជដិលទាំងឡាយប្រព្រឹត្តតបៈខុស

មានប្រការផ្សេងៗ សេចក្តីចម្រើនក្នុងការប្រព្រឹត្តតបៈនេះមានដែរឬហ្ន៎ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមានសេចក្តីចម្រើនណាមួយ ក្នុងការប្រព្រឹត្តតបៈដូច្នេះឡើយ សូម្បីបុរាណបណ្ឌិតសម្គាល់ថាមានសេចក្តីចម្រើនព្រោះការបូជាភ្លើងទើបបូជាភ្លើងអស់កាលយូរ លុះឃើញថាមិនមានសេចក្តីចម្រើនក្នុងការបូជាភ្លើងនោះទើបយកទឹកលត់ភ្លើង យកមែកឈើជាដើមវាយ មិនបានត្រឡប់មកមើលតទៅទៀតហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ។ មាតាបិតាដុតភ្លើងក្នុងថ្ងៃដែលព្រះពោធិសត្វប្រសូតរក្សាទុកហើយពោលនឹងព្រះពោធិសត្វក្នុងកាលមានអាយុ ១៦ ឆ្នាំថា កូនជាទីស្រឡាញ់ កូនទទួលយកភ្លើងក្នុងថ្ងៃដែលកូនកើតទៅបម្រើក្នុងព្រៃ ឬនឹងរៀនត្រៃវេទដើម្បីគ្រប់គ្រងសម្បត្តិជាឃរាវាស ព្រះពោធិសត្វឆ្លើយថា ខ្ញុំមិនត្រូវការនៅជាឃរាវាស ខ្ញុំនឹងបម្រើភ្លើងក្នុងព្រៃប្រាថ្នាព្រហ្មលោកហើយទើបទទួលយកភ្លើងកំណើត ថ្វាយបង្គំមាតាបិតា ចូលទៅក្នុងព្រៃអាស្រ័យនៅក្នុងបណ្ណសាលាបម្រើភ្លើង ។ ថ្ងៃមួយព្រះពោធិសត្វទៅកាន់ទីអញ្ជើញបានបាយាស និងសប្បិមកគិតថា អញនឹងថ្វាយបាយាសនេះដល់មហាព្រហ្មទើបនាំបាយាសនោះមកតាំងចិត្តថា អញនឹងបូជាភ្លើង ឲ្យព្រះអគ្គីជាម្ចាស់ ផឹកនូវបាយាសផ្សំដោយសប្បិមុន ហើយបាចបាយាសទៅក្នុងភ្លើង ។ បាយាសមានជាតិប្រេងច្រើនលុះដាក់ទៅក្នុងភ្លើង ភ្លើងក៏ឆេះមាន

អណ្តាតខ្ពស់ឡើងឆេះបណ្ណសាលា ។ ព្រះពោធិសត្វខ្វាចផង ភ័យផងរត់ទៅឈរខាងក្រៅកន្ទក់កន្ទេញថា មិនគួរធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងបុគ្គលអាក្រក់ ឥឡូវនេះបណ្ណសាលារបស់អញដែលធ្វើយ៉ាងលំបាកត្រូវភ្លើងឆេះហើយទើបពោលគាថាទីមួយថា

ការស្និទ្ធស្នាលណាជាមួយនឹងបុរសលាមក របស់ដទៃលាមក
ក្រៃលែងជាងការស្និទ្ធស្នាល ( នោះ ) មិនមានទេដូចជាភ្លើង
ដែលយើងឲ្យឆ្អែតដោយសប្បិនិងបាយាសនៅតែឆេះខ្ទមស្លឹក
ដែលយើងធ្វើហើយដោយលំបាក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន សន្ថវស្មា** សេចក្តីថា ការស្និទ្ធស្នាលមាន ២ យ៉ាងគឺ ស្និទ្ធស្នាលដោយអំណាចតណ្ហា ១ ស្និទ្ធស្នាលដោយភាពជាមិត្ត ១ មិនមានវត្ថុដទៃដែលអាក្រក់ក្រៃលែងជាងការស្និទ្ធស្នាល ២ យ៉ាងនោះ ។ បទថា **យោ សន្ថវោ កាបុរិសេន** សេចក្តីថា មិនមានការស្និទ្ធស្នាលដទៃដែលអាក្រក់ជាងការស្និទ្ធស្នាល ២ យ៉ាងនេះជាមួយបុរសអាក្រក់នេះឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភ្លើងដែលយើងឲ្យឆ្អែតហើយដោយសប្បិនិងបាយាសនៅតែឆេះបណ្ណសាលាដែលយើងសាងទុកដោយលំបាក ។

កាលព្រះពោធិសត្វពោលយ៉ាងនេះហើយក៏គិតថា អញមិនត្រូវការដោយរបស់ដែលទម្លាយមិត្តទើបយកទឹកលត់ភ្លើងនោះចោល យកមែកឈើវាយចូលទៅកាន់ព្រៃហិមពាន្ត ឃើញមេម្រឹគមួយឈ្មោះសាមាលិទ្ធមាត់រាជសីហ៍

ខ្លាធំនិងខ្លាដំបងទើបគិតថា មិនមានការប្រសើរដទៃអំពីការស្និទ្ធស្នាលជាមួយសប្បុរសឡើយទើបពោលគាថាទីពីរថា

ការស្និទ្ធស្នាលណាជាមួយនឹងសប្បុរស របស់ដទៃប្រសើរ
ក្រៃលែងជាងការស្និទ្ធស្នាល ( នោះ ) មិនមានទេដូចជាមេម្រឹគ
ឈ្មោះសាមាលិទ្ធមាត់នៃស្តេចរាសីហ៍ផង ខ្លាធំផង ខ្លាដំបងផង
ព្រោះការស្និទ្ធស្នាល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាមាមុខំ លេហតិ សន្ថវេន** សេចក្តីថា ម្រឹគញីឈ្មោះសាមា លិទ្ធមាត់សត្វទាំង ៣ នេះដោយសេចក្តីស្និទ្ធស្នាលគឺដោយសេចក្តីស្នេហា ។

កាលព្រះពោធិសត្វពោលយ៉ាងនេះ ហើយទើបចូលទៅខាងក្នុងព្រៃហិមពាន្តបួសជាឥសីញុំាងអភិញ្ញានិងសមាបត្តិឲ្យកើត លុះអស់ជីវិតក៏ចូលដល់ព្រហ្មលោក ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា តាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សន្ថវជាតក ចប់

# សុសីមជាតក

[ ១៧៥ ] ( ពោធិសត្វពោលថា ) បពិត្រព្រះរាជា ទ្រង់ព្រះនាមសុ-សីម ម្រឹគខ្មៅមានភ្លុកស ( ដំរី ) នេះរបស់ព្រះអង្គច្រើនជាងរយ បិទបាំងដោយបណ្ដាញមាស ព្រះអង្គទ្រង់រឭកនូវព្រះបិតានិងជីតា ( របស់ខ្ញុំព្រះ-អង្គ ) ទើបត្រាស់ថា អញនឹងឲ្យដំរីទាំងឡាយនោះដល់ព្រាហ្មណ៍ទាំងនោះមែនឬ ។

[ ១៧៦ ] ( ព្រះរាជាត្រាស់ថា ) ម្នាលមាណព ម្រឹគខ្មៅមានភ្លុកសនេះ របស់ខ្ញុំច្រើនជាងរយ បិទបាំងដោយបណ្ដាញមាស ខ្ញុំកាលរឭកនូវបិតានិងជីតាទើបពោលថា ខ្ញុំនឹងឲ្យនូវដំរីទាំងឡាយនោះ ដល់ព្រាហ្មណ៍ទាំងនោះមែន ។

**ចប់ សុសីមជាតកទី ៣ ។**

## អដ្ឋកថា

# សុសីមជាតក

[ ១៧៥-១៧៦ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការថ្វាយទានតាមគាប់ចិត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កាឡា មិគា សេតទន្តា តវីមេ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ក្នុងក្រុងសាវត្ថី ជួនកាលត្រកូលមួយប៉ុណ្ណោះថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ជួនកាលច្រើននាក់រួមគ្នាថ្វាយជា

គណៈ ជួនកាលថ្វាយតាមផ្លូវនៃវិថី ជួនកាលអ្នកក្រុងទាំងមូលរួមឆន្ទៈគ្នាថ្វាយទាន ។ តែក្នុងកាលនេះ អ្នកនគររួមឆន្ទៈគ្នាត្រៀមថ្វាយបរិក្ខារគ្រប់ប្រភេទ បែកគ្នាជា ២ ពួក ពួកមួយពោលថា ពួកយើងនឹងថ្វាយទានមួយអន្លើដោយបរិក្ខារគ្រប់ប្រភេទដល់អញ្ញតិត្ថិយ មួយពួកពោលថា នឹងថ្វាយដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ កាលការប្រកែកគ្នាប្រព្រឹត្តទៅរឿយៗយ៉ាងនេះ ពួកសាវកតិត្ថិយក៏ពោលថា នឹងឲ្យដល់តិត្ថិយប៉ុណ្ណោះ ពួកសាវករបស់ព្រះសម្ពុទ្ធក៏ពោលថា ថ្វាយដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានប៉ុណ្ណោះ កាលពាក្យដែលនិយាយថា យើងនឹងធ្វើមានច្រើន ជនដែលពោលថា យើងនឹងថ្វាយដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានមានច្រើន ជាធម្មតាពាក្យរបស់ជនទាំងនោះក៏ជាពាក្យតាំងមាំ ។ ពួកសាវករបស់តិត្ថិយមិនអាចធ្វើអន្តរាយដល់ទានដែលគួរថ្វាយដល់ព្រះពុទ្ធបាន ។ ទើបអ្នកក្រុងនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាននាំគ្នាបំពេញមហាទានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានថ្វាយគ្រឿងបរិក្ខារគ្រប់ប្រភេទ ព្រះសាស្ដាទ្រង់ធ្វើអនុមោទនា ឲ្យមហាជនភ្ញាក់ដោយមគ្គផលហើយទើបយាងទៅកាន់វត្តជេតពនមហាវិហារ ។ កាលភិក្ខុសង្ឃសម្ដែងវត្ត ទើបទ្រង់ប្រថាប់ឈរត្រង់យ៉មុខព្រះគន្ធកុដិ ប្រទានសុគតោវាទហើយចូលទៅកាន់ព្រះគន្ធកុដិ ។ ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយប្រជុំសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ពួកសាវករបស់តិត្ថិយសូម្បីព្យាយាមធ្វើអន្តរាយដល់ទានដែលគួរថ្វាយដល់ព្រះពុទ្ធ ក៏មិនអាចធ្វើអន្តរាយបាន ការថ្វាយគ្រឿងបរិក្ខារទាំងពួងនោះមកដល់បាទមូលរបស់ព្រះសម្ពុទ្ធ

ទាំងអស់ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សាវ័ករបស់តិរ្ថិយទាំងនេះបានព្យាយាមធ្វើឲ្យអន្តរាយដល់ទានដែលគួរដល់តថាគតមិនមែនតែក្នុងឥឡូវនេះទេសូម្បីក្នុងកាលមុនក៏ព្យាយាម ។ ម្យ៉ាងទៀតគ្រឿងបរិក្ខារនោះក៏មកដល់បាទដើងរបស់តថាគតគ្រប់ពេលហើយទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលក្នុងនគរពារាណសីព្រះរាជាព្រះនាមថា សុសីមៈ ។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃព្រាហ្មណីរបស់បុរោហិតនៃព្រះរាជា កាលព្រះពោធិសត្វមានអាយុ ១៦ ឆ្នាំ បិតាក៏អនិច្ចកម្ម ។ បុរោហិតនោះកាលនៅមានជីវិត បានជាអ្នកធ្វើមង្គលដល់ដំរីព្រះរាជា គាត់បានគ្រឿងឧបករណ៍និងគ្រឿងប្រដាប់ដំរីគ្រប់យ៉ាង ដែលមានអ្នកនាំមកក្នុងទីធ្វើមង្គលដល់ដំរីទាំងឡាយ ។ ក្នុងមង្គលម្តងៗទ្រព្យប្រមាណមួយកោដិកើតឡើងដល់បុរោហិតនោះ ។ កាលព្រាហ្មណ៍អនិច្ចកម្ម ហើយពិធីមហោស្រពក្នុងហត្ថិមង្គលបានមកដល់ ។ ពួកព្រាហ្មណ៍ដទៃៗចូលទៅគាល់ព្រះរាជាទូលថា បពិត្រមហារាជ មហោស្រពក្នុងមង្គលដំរីបានមកដល់ហើយ គួរប្រកបពិធីមង្គល តែកូនរបស់បុរោហិតនៅក្មេងពេកមិនចេះត្រៃវេទ មិនដឹងសូត្របំពេរដំរី ពួកទូលបង្គំនឹងធ្វើមង្គលដំរីដោយខ្លួនឯង ។ ព្រះរាជាទ្រង់ទទួលថា សាធុ ពួកព្រាហ្មណ៍ក៏នាំគ្នាត្រេកអរដើរទៅមកគិតថា ពួកយើងមិនឲ្យបុត្តបុរោហិត

ធ្វើមង្គលដ៏រីនឹងធ្វើឯងហើយនឹងបានទទួលទ្រព្យ កាលដល់ថ្ងៃទី ៤ នឹងមាន មង្គលដ៏រី មាតារបស់ព្រះពោធិសត្វដឹងដំណឹងនោះ ទើបសោយសោកកន្ទក់ កន្ទេញថា ឈ្មោះថាការធ្វើមង្គលដ៏រីជានាទីរបស់ពួកយើង ៧ ជួរត្រកូលមក ហើយ វង្សរបស់យើងនឹងវិនាស យើងនឹងវិនាសចាកទ្រព្យផងដែរ ។ ព្រះ ពោធិសត្វសួរថា ហេតុអ្វីទើបម៉ែយំ កាលបានស្តាប់ហេតុការណ៍នោះហើយ ទើបលួងលោមថា សូមម៉ែកុំសោយសោកឡើយកូននឹងធ្វើមង្គលឯង មាតា ពោលថា នែកូន កូនមិនចេះត្រៃវេទ មិនចេះសូត្របំពេរដ៏រី នឹងធ្វើហត្ថិ-មង្គលបានដូចម្តេច ព្រះពោធិសត្វសួរថា បពិត្រអ្នកម៉ែ តើថ្ងៃណាគេធ្វើមង្គល ដ៏រី មាតាឆ្លើយថា ក្នុងថ្ងៃទី ៤ បន្ទាប់អំពីថ្ងៃនេះឯង ។ ព្រះពោធិសត្វសួរថា អាចារ្យដែលជំនាញត្រៃវេទ ចេះសូត្របំពេរដ៏រីនៅទីណា មាតាប្រាប់ថា នែកូន អាចារ្យទិសាបាមោក្ខបែបនេះមាននៅក្នុងនគរតក្កសិលា ដែនគន្ធារៈ ក្នុងចម្ងាយផ្លូវពីនេះទៅ ១២០ យោជន៍ ។ ព្រះពោធិសត្វលួងលោមមាតាថា កូនមិនឲ្យវង្សរបស់យើងវិនាសទេ ស្អែកនេះកូននឹងទៅនគរតក្កសិលាធ្វើ ដំណើរមួយថ្ងៃក៏ដល់ រៀនត្រៃវេទនិងសូត្របំពេរដ៏រីមួយយប់ប៉ុណ្ណោះ ស្អែក ឡើងនឹងត្រឡប់មកធ្វើមង្គលដ៏រីក្នុងថ្ងៃទី ៤ ។ ស្អែកឡើងព្រះពោធិសត្វ បរិភោគអាហារពីព្រលឹម ធ្វើដំណើរម្នាក់ឯងត្រឹមតែមួយថ្ងៃ ក៏ដល់នគរតក្ក-សិលា ចូលទៅថ្វាយបង្គំអាចារ្យហើយអង្គុយក្នុងចំណែកម្ខាង ។ លំដាប់ នោះអាចារ្យសួរព្រះពោធិសត្វថា បាមកអំពីណា ព្រះពោធិសត្វប្រាប់ថា ខ្ញុំ មកពីនគរពារាណសី អាចារ្យពោលថា មកដើម្បីអ្វី ព្រះពោធិសត្វឆ្លើយថា

ដើម្បីរៀនត្រៃវេទនិងសូត្របំពេរដ៏រីក្នុងសម្នាក់របស់លោកអាចារ្យ អាចារ្យពោលថា សាធុ ចូរបារៀនចុះ ។ ព្រះពោធិសត្វពោលថា បពិត្រលោកអាចារ្យ ការងាររបស់ខ្ញុំប្រញាប់ប្រញាល់ពេកហើយក៏និយាយរឿងទាំងអស់ឲ្យជ្រាបហើយពោលថា ខ្ញុំមកអស់ចម្ងាយផ្លូវ ១២០ យោជន៍ត្រឹមមួយថ្ងៃប៉ុណ្ណោះ សូមលោកអាចារ្យឲ្យឱកាសដល់ខ្ញុំមួយយប់ចុះ ខ្ញុំមានឱកាសសម្រាប់រៀនតែមួយយប់ប៉ុណ្ណោះ ព្រោះថ្ងៃទី ៣ បន្ទាប់អំពីថ្ងៃនេះនឹងមានមង្គលដ៏រី ខ្ញុំសូមរៀនវិជ្ជាទាំងអស់ត្រឹមតែមាតិកាតែម្យ៉ាងប៉ុណ្ណោះ កាលអាចារ្យឲ្យឱកាសទើបលាងជើងអាចារ្យ ដាក់ថង់ទ្រព្យ ១០០០ ទុកខាងមុខថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាងផ្ដើមសិក្សា លុះអរុណរះឡើងក៏រៀនចប់ត្រៃវេទនិងសូត្របំពេរដ៏រីទើបសួរថា បពិត្រលោកអាចារ្យ នៅមានវិជ្ជាដទៃៗទៀតដែរឬទេ កាលអាចារ្យពោលថា មិនមានឡើយចប់អស់ហើយ ព្រះពោធិសត្វប្រាប់សិប្បៈឲ្យអាចារ្យស្ដាប់ថា បពិត្រលោកអាចារ្យ ក្នុងគម្ពីរនេះមានបទបាត់ទៅប៉ុណ្ណោះ ឃ្លៀងឃ្លាតព្រោះស្វាធ្យាយប៉ុណ្ណោះ តាំងអំពីនេះទៅលោកអាចារ្យគប្បីប្រាប់អន្តេវាសិកទាំងឡាយយ៉ាងនេះ ស្រេចហើយបរិភោគអាហារព្រឹក ថ្វាយបង្គំអាចារ្យត្រឡប់ទៅកាន់ក្រុងពារាណសីត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ថ្វាយបង្គំមាតា កាលមាតាសួរថា កូនរៀនសិប្បៈចប់ហើយឬ ព្រះពោធិសត្វឆ្លើយថា ចប់ហើយ ធ្វើមាតាឲ្យត្រេកអរ ។

ស្អែកឡើងពួកព្រាហ្មណ៍ត្រៀមធ្វើមង្គលដ៏រីយ៉ាងធំ ប្រជានុរាស្ត្ររៀបចំដ៏រីរៀងៗខ្លួន ពាក់គ្រឿងប្រដាប់ដែលធ្វើអំពីមាស ចងនូវទង់មាស ដណ្ដប់

ដោយបណ្ដាញមាស រៀបចំត្រង់លានព្រះរាជវាំង ពួកព្រាហ្មណ៍ក៏រៀបចំគ្រឿងអលង្ការដោយតាំងចិត្តថា ពួកយើងនឹងធ្វើមង្គលដំរី ។ ព្រះបាទសុសីមៈ ក៏ទ្រង់ប្ដើងយសឲ្យរៀបបរិវារកាន់គ្រឿងឧបករណ៍ យាងចូលកាន់មង្គលស្ថាន ។ ព្រះពោធិសត្វតាក់តែងរាងកាយដោយគ្រឿងអលង្ការដ៏ស្រស់ស្អាត មានបរិស័ទចោមរោមជាបរិវារទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលថា បពិត្រមហារាជ បានឮថា ទ្រង់ធ្វើវង្សរបស់ទូលបង្គំនិងវង្សរបស់ទ្រង់ឲ្យវិនាសទ្រង់បានត្រាស់ថា យើងឲ្យព្រាហ្មណ៍ដទៃធ្វើមង្គលដំរីហើយប្រគល់គ្រឿងអលង្ការដំរីនិងគ្រឿងឧបករណ៍ឲ្យ ( ព្រាហ្មណ៍ទាំងនោះ ) ពិតឬ ហើយពោលគាថាទីមួយថា

បពិត្រព្រះរាជាទ្រង់ព្រះនាមសុសីម ម្រឹគខ្មៅមានក្ដុកស ( ដំរី )
នេះរបស់ព្រះអង្គច្រើនជាងរយ បិទបាំងដោយបណ្ដាញមាស
ព្រះអង្គទ្រង់រឭកនូវព្រះបិតា និងជីតា[១]( របស់ខ្ញុំព្រះអង្គ )
ទើបត្រាស់ថា អញនឹងឲ្យដំរីទាំងឡាយនោះដល់ព្រាហ្មណ៍
ទាំងនោះមែនឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេ តេ ទទាមីតិ សុសីម ព្រូសិ** សេចក្ដីថា ខ្ញុំឲ្យដំរីទាំងនេះដល់ព្រាហ្មណ៍ទាំងនោះ គឺធ្វើឲ្យជារបស់ព្រាហ្មណ៍នោះ អធិប្បាយថា អញនឹងឲ្យដំរីដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ប្រមាណ ១០០ ដែលមានពណ៌ខ្មៅក្ដុក**ស**ដល់ព្រាហ្មណ៍ពួកដទៃ ។ បពិត្រព្រះរាជា

---

១-គួរប្រែថា បិតានិងជីតាទើបត្រូវតាមន័យរបស់អដ្ឋកថា ។

សុសីមៈ ទ្រង់ត្រាស់យ៉ាងនេះជាការពិតឬ ។ បទថា **អនុស្សរំ បេត្តិ-បិតាមហានំ** សេចក្តីថា ទ្រង់រឭកដល់ការធ្វើរបស់បិតានិងព្រះអយ្យកា រឿយ ៗ ក្នុងវង្សរបស់ទូលបង្គំនិងរបស់ព្រះអង្គ ។ សេចក្តីនេះលោកអធិប្បាយថា បពិត្រមហារាជ បិតានិងជីតារបស់ទូលបង្គំធ្វើមង្គលដំរីដល់ព្រះជនកនិងព្រះអយ្យការបស់ព្រះអង្គអស់ ៧ ជួរត្រកូល សូម្បីទ្រង់រឭកបានយ៉ាងនេះក៏នៅតែធ្វើវង្សរបស់ទូលបង្គំនិងវង្សរបស់ព្រះអង្គឲ្យវិនាស បានឮថា ទ្រង់ត្រាស់យ៉ាងនេះពិតឬ ។

ព្រះបាទសុសីមៈ ទ្រង់ស្តាប់ពាក្យរបស់ព្រះពោធិសត្វទើបត្រាស់គាថាទីពីរថា

ម្នាលមាណព ម្រឹគខ្មៅមានភ្លុកសនេះរបស់ខ្ញុំច្រើនជាងរយ
បិទបាំងដោយបណ្តាញមាស ខ្ញុំកាលរឭកនូវបិតា និងជីតា
ទើបពោលថា ខ្ញុំនឹងឲ្យនូវដំរីទាំងឡាយនោះដល់ព្រាហ្មណ៍
ទាំងនោះមែន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ តេ ទទាមិ** សេចក្តីថា នែមាណព ខ្ញុំនិយាយថា ខ្ញុំនឹងឲ្យដំរីទាំងនេះដល់ព្រាហ្មណ៍ទាំងឡាយជាការពិតនោះឯង អធិប្បាយថា ខ្ញុំបាននិយាយនឹងព្រាហ្មណ៍ទាំងនោះថា ខ្ញុំនឹងឲ្យដំរីទាំងឡាយនោះដល់ព្រាហ្មណ៍ទាំងនោះជាការពិត ។ បទថា **អនុស្សរំ** សេចក្តីថា ខ្ញុំនៅរឭកបាននូវកិរិយារបស់ព្រះបិតានិងជីតារបស់អ្នករឿយៗ មិនមែនមិនរឭកទេ ។ ព្រះរាជាត្រាស់យ៉ាងនោះដោយទ្រង់ចង្អុលបង្ហាញថា សូម្បីខ្ញុំក៏

វេកបានថា បិតានិងជីតារបស់អ្នកបានធ្វើពិធីមង្គលដល់ដំរីដល់ព្រះបិតានិង ព្រះអយ្យការបស់ខ្ញុំពិតមែន ។

លំដាប់នោះព្រះពោធិសត្វក្រាបទូលព្រះរាជាថា បពិត្រមហារាជ កាល ព្រះអង្គវេកដល់វង្សរបស់ព្រះអង្គនិងវង្សត្រកូលរបស់ទូលបង្គំបានព្រោះហេតុ អ្វីទើបទ្រង់ចោលទូលបង្គំហើយឲ្យអ្នកដទៃធ្វើមង្គលដំរីទៅវិញ ព្រះរាជាត្រាស់ ថា នែបា ពួកព្រាហ្មណ៍ប្រាប់ខ្ញុំថា បាមិនចេះត្រៃវេទនិងហត្ថិសូត្រព្រោះហេតុ នោះទើបខ្ញុំឲ្យពួកព្រាហ្មណ៍ដទៃធ្វើពិធីនេះជំនួស ។ ព្រះពោធិសត្វបន្លឺសីហ- នាទថា បពិត្រមហារាជ បណ្ដាព្រាហ្មណ៍ទាំងឡាយសូម្បីត្រឹមតែម្នាក់ដែល អាចចរចាជាមួយទូលព្រះបង្គំបានក្នុងវេទក្តី ក្នុងហត្ថិសូត្រក្តី បើមានចូរក្រោក ឡើង ព្រាហ្មណ៍ដទៃក្រៅអំពីទូលបង្គំឈ្មោះថា ចេះត្រៃវេទនិងហត្ថិសូត្រ មួយអន្លើដោយពិធីធ្វើមង្គលដំរីក្នុងជម្ពូទ្វីបមិនមានឡើយ ។ ព្រាហ្មណ៍សូម្បី តែម្នាក់ក៏មិនអាចក្រោកឡើងប្រកួតប្រជែងជាមួយព្រះពោធិសត្វបាន ។ ព្រះ ពោធិសត្វកាលតាំងវង្សត្រកូលរបស់ខ្លួនឲ្យមាំទាំហើយទើបធ្វើមង្គល កាន់ យកទ្រព្យជាច្រើនត្រឡប់ទៅកាន់លំនៅ ។

ព្រះសាស្ដានាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចធម៌ លុះចប់សច្ចធម៌ ជនពួកខ្លះបានជាសោតាបន្ន ជនពួកខ្លះបានជាសកទាគាមី ពួកខ្លះបានជាអនាគាមី ពួកខ្លះបានជាព្រះអរហន្ត ហើយទ្រង់ប្រជុំជាតកថា មាតាក្នុងកាលនោះបានមកជាព្រះនាងមហាមាយាទេវី ក្នុងកាលឥឡូវនេះ បិតាក្នុងកាលនោះបានមកជាព្រះបាទសុទ្ធោទនមហារាជ សុសីមរាជាក្នុងកាល

នោះបានមកជាអានន្ទ អាចារ្យទិសាបាមោក្ខក្នុងកាលនោះបានមកជាសារីបុត្ត ឯមាណពក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុសីមជាតក ចប់

## គិជ្ឈជាតក

[ ១៧៧ ] ( ព្រះរាជាពារាណសីត្រាស់ថា ) ត្មាតរមែងក្រឡេកមើលឃើញសាកសពចម្ងាយ ១០០ យោជន៍បាន ចុះហេតុអ្វីបានជាអ្នកហើរមកដល់បណ្ដាញនិងអន្ទាក់ហើយក៏នៅតែមិនភ្ញាក់ខ្លួន ។

[ ១៧៨ ] ( ត្មាតពោធិសត្វពោលថា ) សេចក្ដីវិនាសមានក្នុងវេលាណា សត្វមកដល់បណ្ដាញនិងអន្ទាក់ រមែងមិនបានភ្ញាក់ខ្លួនក្នុងការអស់ទៅនៃជីវិតក្នុងវេលានោះ ។

**ចប់ គិជ្ឈជាតកទី ៤ ។**

## អដ្ឋកថា

## គិជ្ឈជាតក

[ ១៧៧-១៧៨ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតាបិតាមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យន្នុ គិជ្ឈោ យោជនសតំ** ដូច្នេះជាដើម ។

រឿងមានជាក់ច្បាស់នៅក្នុងសុវណ្ណសាមជាតក ( មហានិបាត ) ឯណោះ ។ ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកចិញ្ចឹមគ្រហស្ថពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គទើបត្រាស់សួរថា គ្រហស្ថនោះជានរណា ភិក្ខុក្រាបទូលថា ជាមាតាបិតារបស់ខ្ញុំព្រះអង្គ ព្រះសាស្ដាឲ្យសាធុការថា សាធុ សាធុ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នក

កុំសម្លឹងទោសភិក្ខុនេះឡើយ សូម្បីបុរាណបណ្ឌិតទាំងឡាយក៏បានធ្វើឧបការៈដល់បុគ្គលមិនមែនញាតិដោយអំណាចគុណ ឯមាតាបិតារបស់ភិក្ខុនេះជាការៈពិតហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតត្មាតចិញ្ចឹមមាតាបិតាត្រង់គិជ្ឈបព៌ត ។ សម័យមួយមានព្យុះនិងភ្លៀងធំ ត្មាតទាំងឡាយ មិនអាចទ្រាំនឹងព្យុះភ្លៀងបានព្រោះខ្លាចរងា ទើបនាំគ្នាហើរគេចមកកាន់នគរពារាណសី ទំក្បែរកំពែងនិងប្រឡាយរងាញ័រចំប្រប់ ។ ក្នុងកាលនោះសេដ្ឋីក្រុងពារាណសីចេញអំពីក្រុងទៅងូតទឹកឃើញត្មាតទាំងនោះកំពុងលំបាក ទើបកៀងឲ្យមកប្រជុំគ្នាត្រង់ទីកំបាំងភ្លៀងមួយកន្លែង បង្កាត់ភ្លើងឲ្យអាំង ហើយបញ្ជូនទៅកាន់ព្រៃដែលបោលសាកសពគោ រកសាច់គោមកឲ្យពួកត្មាតរួចធ្វើការអភិរក្ស កាលព្យុះនិងភ្លៀងស្ងប់ហើយ ត្មាតទាំងឡាយមានរាងកាយស្រស់ស្រាយនាំគ្នាហើរត្រឡប់ទៅកាន់ភ្នំវិញ ។ ពួកត្មាតប្រជុំគ្នាប្រឹក្សាក្នុងទីនោះថា សេដ្ឋីក្រុងពារាណសីបានជួយសង្គ្រោះពួកយើងឲ្យបានមកកាន់ទីនេះវិញ ពួកយើងគួរជួយអ្វីដល់គាត់ ព្រោះដូច្នោះតាំងអំពីថ្ងៃនេះទៅបណ្ដាពួកយើងអ្នកណាបានសំពត់ឬគ្រឿងអលង្ការប្រភេទណា អ្នកនោះគប្បីពាំវត្ថុនោះទៅទម្លាក់ជិតផ្ទះរបស់សេដ្ឋីក្រុងពារាណសី ។ តាំងអំពីកាលនោះមកត្មាតទាំងឡាយឃ្លាំមើលការប្រហែសធ្វេសរបស់ពួកមនុស្សដែលហាលសំពត់ និងគ្រឿងអាករណៈទុកក្នុងទីដែលមានថ្ងៃក៏នាំគ្នាឆាបយកទៅដោយរហ័សដូចខ្លែងពាំដុំសាច់ ទៅទម្លាក់

ជិតផ្ទះរបស់សេដ្ឋីក្រុងពារាណសី ។ សេដ្ឋីដឹងថាជាគ្រឿងអាភរណៈរបស់ត្មាតទើបរក្សាគ្រឿងអាភរណៈទាំងអស់នោះទុកជាចំណែកៗ ។

មហាជននាំគ្នាទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ត្មាតទាំងឡាយប្លន់ក្រុង ព្រះរាជាត្រាស់ថា ពួកអ្នកចាប់ត្មាតបានមួយប៉ុណ្ណោះក៏នឹងបានរបស់ដែលបាត់ទាំងអស់ ហើយឲ្យដាក់អន្ទាក់និងសំណាញ់ក្នុងទីនោះៗ ។ ត្មាតដែលចិញ្ចឹមមាតាក៏ជាប់អន្ទាក់ ។ ជនទាំងឡាយក៏ចាប់ត្មាតនោះនាំទៅដោយគិតថានឹងថ្វាយព្រះរាជា ។ សេដ្ឋីក្រុងពារាណសីកំពុងដើរទៅគាល់ព្រះរាជាកាលឃើញមនុស្សទាំងនោះចាប់ត្មាតដើរទៅ ទើបបានទៅជាមួយដោយគិតថាមិនឲ្យអ្នកណាធ្វើបាបត្មាតមួយនេះ ។ ជនទាំងឡាយថ្វាយត្មាតដល់ព្រះរាជាព្រះរាជាត្រាស់ថា ពួកឯងប្លន់ក្រុងពាំសំពត់ជាដើមទៅឬ ។ ត្មាតក្រាបទូលថា បពិត្រមហារាជ សេចក្តីនេះពិតហើយ ព្រះរាជាត្រាស់ថា ពួកឯងយកទៅឲ្យអ្នកណា ត្មាតក្រាបទូលថា ឲ្យដល់សេដ្ឋីក្រុងពារាណសី ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ក៏ក្រាបទូលថា ព្រោះសេដ្ឋីនោះបានឲ្យជីវិតដល់ពួកខ្ញុំ ការធ្វើឧបការៈដល់អ្នកមានឧបការៈរមែងសមគួរព្រោះដូច្នេះទើបពួកខ្ញុំយកទៅឲ្យ ។ ព្រះរាជាត្រាស់សួរត្មាតថា បានឮថា ត្មាតទាំងឡាយមើលឃើញសាកសពក្នុងទី ១០០ យោជន៍ ព្រោះហេតុអ្វីទើបឯងមិនឃើញអន្ទាក់ដែលគេដាក់ចាប់ខ្លួនហើយត្រាស់គាថាទីមួយថា

ត្មាតរមែងក្រឡេកមើលឃើញសាកសពចម្ងាយ ១០០ យោជន៍
បាន ចុះហេតុអ្វីបានជាអ្នកហើរមកដល់បណ្តាញនិងអន្ទាក់

ហើយក៏នៅតែមិនភ្ញាក់ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ** ត្រឹមតែជានិបាត ។ បទថា **នុ** ត្រឹមតែជានាមត្ថនិបាត អធិប្បាយថា ធម្មតាត្មាតទាំងឡាយរមែងមើលឃើញសាកសពក្នុងទី ១០០ យោជន៍ ។ បទថា **អាសជ្ជាបិ** ប្រែថា ចូលជិត គឺមកដល់ ។ ព្រះរាជាត្រាស់សួរថា ឯងមកដល់សំណាញ់និងអន្ទាក់ដែលគេដាក់ដើម្បីចាប់ខ្លួនព្រោះហេតុអ្វីទើបមិនដឹង ។

ត្មាតស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយទើបពោលគាថាទីពីរថា

សេចក្ដីវិនាសមានក្នុងវេលាណា សត្វមកដល់បណ្ដាញនិង
អន្ទាក់ រមែងមិនបានភ្ញាក់ខ្លួន ក្នុងការអស់ទៅនៃជីវិតក្នុង
វេលានោះ[១]ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរាភវោ** គឺ សេចក្ដីវិនាស ។ បទថា **ពោសោ** គឺ សត្វ ។

ព្រះរាជាកាលទ្រង់ស្ដាប់ពាក្យរបស់ត្មាតហើយ ទើបត្រាស់សួរសេដ្ឋីថា នៃសេដ្ឋី ត្មាតទាំងឡាយនាំសំពត់ជាដើមមកត្រង់ផ្ទះរបស់លោកពិតឬ សេដ្ឋីទូលថា ពិតហើយព្រះអង្គ ព្រះរាជាត្រាស់ថា សំពត់ជាដើមនោះនៅឯណា សេដ្ឋីក្រាបទូលថា ទូលបង្គំចាត់ចែងសំពត់នោះទុកជាចំណែកៗ ទូលបង្គំនឹងឲ្យដល់ម្ចាស់គេវិញ សូមទ្រង់លែងត្មាតនេះចុះ ។ មហាសេដ្ឋីក្រាបទូលឲ្យ

---

១-ច្បាប់ស្យាមប្រទេសប្រែថា សេចក្ដីវិនាសនឹងមានក្នុងកាលណា សត្វជិតនឹងអស់ជីវិតក្នុងកាលណា ក្នុងកាលនោះទោះបីមកដល់បណ្ដាញនិងអន្ទាក់ក៏ដឹងមិនបាន ។

លែងត្មាតហើយសងសំពត់ជាដើមនោះទៅម្ចាស់គេវិញ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសអរិយសច្ច កាលចប់អរិយសច្ចកិក្ខុអ្នកចិញ្ចឹមមាតាតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ សេដ្ឋីក្រុងពារាណសីក្នុងកាលនោះបានមកជាសារីបុត្ត ឯត្មាតចិញ្ចឹមមាតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គិជ្ឈជាតក ចប់

## នកុលជាតក

[ ១៧៩ ] ( តាបសពោធិសត្វពោលថា ) ម្នាលស្កា ជាជលាពុជៈ អ្នកធ្វើនូវមិត្តភាព ដោយសត្រូវដែលជាអណ្ឌជៈកំណើត ហើយមកដេកបញ្ចេញចង្កូម តើសេចក្តីភ័យមានមកដល់អ្នកអំពីទីណា ។

[ ១៨០ ] ( ស្កាពោលថា ) បុគ្គលគប្បីរង្កៀសក្នុងសត្រូវ មិនគប្បីស្និទ្ធស្នាលសូម្បីក្នុងមិត្ត ភ័យដែលកើតឡើងអំពីជនដែលមិនគួរភ័យ រមែងកាត់នូវឫសគល់ទាំងឡាយបាន ។

**ចប់ នកុលជាតកទី ៥ ។**

## អដ្ឋកថា

## នកុលជាតក

[ ១៧៩-១៨០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការឈ្លោះគ្នារបស់អាមាត្យ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សន្ធឹ កត្វា អមិត្តេន** ដូច្នេះជាដើម ។

រឿងដូចគ្នាតាមដែលពោលទុកហើយក្នុងឧរគជាតកខាងដើមនោះឯង សូម្បីក្នុងរឿងនេះព្រះសាស្តាក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាមាត្យ ២ នាក់នេះ មិនមែនតថាគតធ្វើឲ្យសាមគ្គីគ្នាក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនតថាគតក៏បានធ្វើឲ្យជនទាំង ២ នេះសាមគ្គីគ្នាដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ក្នុងស្រុកមួយ កាលចម្រើនវ័យ បានរៀនសិប្បៈគ្រប់យ៉ាងក្នុងនគរតក្កសិលា លះបង់នូវឃរាវាសចេញបួស ជាឥសីញុំាងសមាបត្តិនិងអភិញ្ញាឲ្យកើត មានឫសឈើនិងផ្លែឈើក្នុងព្រៃជាអាហារ ដោយការត្រាច់ស្វែងរកស្នាក់នៅក្នុងហិមវន្តប្បទេសនោះ ។ ខាងចុងនៃទីចង្ក្រមរបស់តាបសពោធិសត្វមានដំបូកមួយជាទីអាស្រ័យនៅនៃសត្វស្កា ។ ក្បែរដំបូកមានពស់អាស្រ័យនៅត្រង់គល់ឈើមួយដើម ។ ពស់និងស្កាទាំង ២ ក៏ឈ្លោះគ្នាសព្វកាល ។ ព្រះពោធិសត្វពោលដល់ទោសក្នុងការឈ្លោះគ្នានិងអានិសង្សក្នុងការចម្រើនមេត្តាដល់សត្វទាំង ២ នោះហើយទូន្មានថា មិនគួរឈ្លោះគ្នាទេ គួរនៅដោយសាមគ្គី បានធ្វើសត្វទាំង ២ ឲ្យស្រុះស្រួលគ្នា ។ កាលដល់ពេលពស់ចេញទៅខាងក្រៅ ស្កាក៏ដេកហាមាត់ដាក់ក្បាលទៅខាងក្រៅដំបូកខាងចុងទីចង្ក្រម ដកដង្ហើមចេញចូលដេកលក់ទៅ ព្រះពោធិសត្វឃើញស្កានោះដេកលក់ កាលនឹងសួរថាភ័យអ្វីកើតឡើងដល់អ្នកទើបពោលគាថាទីមួយថា

> ម្នាលស្កា ជាជលាពុជៈ អ្នកធ្វើនូវមិត្តភាពដោយសត្រូវដែល
> ជាអណ្ឌជៈកំណើតហើយមកដេកបញ្ចេញចង្កូម តើសេចក្តី
> ភ័យមានមកដល់អ្នកអំពីទីណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្ធឹ កត្វា** គឺ ធ្វើនូវភាពជាមិត្តដល់គ្នានឹងគ្នា ។ បទថា **អណ្ឌជេន** បានដល់ ពស់ដែលកើតក្នុងស៊ុត ។ លោក

ហៅស្កាថា ជលាពុជៈ ដ្បិតថាស្កានោះហៅថា ជលាពុជៈព្រោះកើតក្នុងផ្ទៃ ។ បទថា **វិរិយេ** ប្រែថា ដេកហាមាត់ ។

ព្រះពោធិសត្វពោលយ៉ាងនេះហើយទើបស្កាប្រាប់ថា បពិត្រលោកម្ចាស់ ឈ្មោះថា សត្រូវមិនគួរមើលងាយគួរប្រយ័ត្នជានិច្ច ហើយពោលគាថាទីពីរថា

បុគ្គលគប្បីវង្វៀសក្នុងសត្រូវ មិនគប្បីស្និទ្ធស្នាលសូម្បីក្នុងមិត្ត
ភ័យដែលកើតឡើងអំពីជនដែលមិនគួរភ័យ រមែងកាត់នូវ
ឫសគល់ទាំងឡាយបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភយា ភយមុប្បន្នំ** បានដល់ ភ័យមិនកើតដល់អ្នកអំពីឱកាសនេះទេ ព្រោះហេតុនោះទើបឈ្មោះថា មិនមានភ័យ សួរថា បុគ្គលណាចាត់ថាជាមិត្ត ឆ្លើយថា បុគ្គលដែលមិនមានភ័យចាត់ថាជាមិត្ត ព្រោះដូច្នេះភ័យរមែងកើតឡើងអំពីមិត្តដែលស្និទ្ធស្នាលនោះ រមែងកាត់ឫសគល់នោះចោលអធិប្បាយថា រមែងប្រព្រឹត្តទៅព្រមដើម្បីកម្ចាត់ឫសគល់ព្រោះមិត្តដឹងចំណុចខ្សោយទាំងអស់ហើយ ។

លំដាប់នោះ ព្រះពោធិសត្វបានទូន្មានស្កានោះថា អ្នកកុំខ្លាចឡើយយើងបានធ្វើឲ្យពស់បៀតបៀនអ្នកមិនបានទៀតឡើយ តាំងអំពីនេះទៅអ្នកកុំរង្វៀសក្នុងពស់នោះឡើយ ហើយបង្រៀនឲ្យចម្រើនព្រហ្មវិហារ ៤ បែរមុខទៅកាន់ព្រហ្មលោក សូម្បីព្រះពោធិសត្វក៏ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំ

ជាតកថា ពស់និងស្កាទាំងនោះក្នុងកាលនោះបានមកជាមហាមាត្យទាំង ២ ក្នុងកាលឥឡូវនេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថានកុលជាតក ចប់

## ឧបសាឡ្ហកជាតក

[ ១៨១ ] ( តាបសពោធិសត្វពោលថា ) ពួកញាតិឈ្មោះឧបសាឡ្ហក ចំនួន ១៤០០០ នាក់ គេដុតហើយក្នុងប្រទេសនេះ ក្នុងលោករកទីដែលមិនមានគេស្លាប់មិនមានឡើយ ។

[ ១៨២ ] សច្ចៈ ១ ធម្មៈ ១ អហឹសា ១ សញ្ញមៈ ១ ទមៈ ១ មាននៅក្នុងបុគ្គលណា ព្រះអរិយទាំងឡាយរមែងសេពគប់នូវបុគ្គលនុ៎ះ គុណជាតនុ៎ះឈ្មោះថា មិនចេះស្លាប់ក្នុងលោក ។

**ចប់ ឧបសាឡ្ហកជាតកទី ៦ ។**

## អដ្ឋកថា

## ឧបសាឡ្ហកជាតក

[ ១៨១-១៨២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ដែលប្រកាន់ការបរិសុទ្ធរបស់ព្រៃខ្មោចឈ្មោះឧបសាឡ្ហកៈ ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ឧបសាឡ្ហកនាមានំ** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍នោះជាអ្នកស្តុកស្តម្ភដោយទ្រព្យតែព្រោះខ្លួនជាមិច្ឆាទិដ្ឋិទើបមិនបានធ្វើការសង្គ្រោះដល់ព្រះសម្ពុទ្ធ ដែលគង់នៅក្នុងព្រះវិហារក្បែរនោះ តែកូនរបស់ព្រាហ្មណ៍មានការឈ្លាសវៃ មាននូវបញ្ញា ។ ព្រាហ្មណ៍ផ្តាំកូនកាលដែលខ្លួនចាស់ជរាថា នែកូន ឯងកុំដុតអញក្នុងព្រៃខ្មោចដែលគេដុតមនុស្សល្មេងខ្មៅ តែគួរដុតអញក្នុងព្រៃខ្មោច ដែលមិនលាយឡំដោយបុគ្គល

ណាម្នាក់ត្រង់ទីណាមួយ ។ កូនពោលថា បពិត្រលោកឪពុក កូនមិនដឹងទីដែលគួរផុតលោកឪពុក យកល្អសូមពុកនាំកូនទៅប្រាប់ថា ចូរផុតត្រង់ទីនេះ ។ ព្រាហ្មណ៍ពោលថា សាធុ ហើយនាំកូនចេញអំពីនគរឡើងទៅកាន់កំពូលភ្នំគិជ្ឈកូដពោលថា នែកូន ត្រង់នេះឯងជាទីដែលមិនប្រឡូកប្រឡំ ជាទីមិនធ្លាប់ផុតមនុស្សល្ងង់ខ្លៅជទៃ កូនគួរផុតឪពុកត្រង់នេះហើយចុះអំពីភ្នំជាមួយកូន ។

ក្នុងថ្ងៃនោះពេលទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលផៅពង្សបុគ្គលដែលគួរប្រោស ទតឃើញឧបនិស្ស័យសោតាបត្តិមគ្គរបស់ឪពុកនិងកូននោះ ព្រោះដូច្នេះទើបទ្រង់កាន់យកផ្លូវនោះ យាងទៅកាន់ជើងភ្នំដូចព្រានព្រៃជំនាញក្នុងផ្លូវ គង់រង់ចាំឪពុកនិងកូនចុះអំពីកំពូលភ្នំ ។ ឪពុកនិងកូនចុះពីកំពូលភ្នំបានឃើញព្រះសាស្តា ព្រះសាស្តាធ្វើបដិសណ្ឋារៈត្រាស់សួរថា ម្នាលព្រាហ្មណ៍ តើអ្នកទៅណា មាណពប្រាប់សេចក្តីនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះមកយើងនឹងទៅកាន់ទីដែលបិតារបស់អ្នកប្រាប់ ទ្រង់នាំឪពុកនិងកូនឡើងលើកំពូលភ្នំត្រាស់សួរថា ទីត្រង់ណា មាណពក្រាបទូលថា បិតារបស់ខ្ញុំប្រាប់ថា ចន្លោះភ្នំទាំង ៣ នេះឯង ព្រះសាស្តាត្រាស់ថា ម្នាលមាណព បិតារបស់អ្នកមិនមែនប្រកាន់សេចក្តីបរិសុទ្ធនៃឈាបនដ្ឋានក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុនបិតារបស់អ្នកក៏កាន់យកសេចក្តីបរិសុទ្ធនៃព្រៃខ្មោច ម្យ៉ាងទៀតបិតារបស់អ្នកប្រាប់អ្នកថា ចូរផុតអញត្រង់នេះ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុនក៏ប្រាប់ទីសម្រាប់ផុតក្នុងទីនេះដូចគ្នា កាលមាណពទូលអារាធនាទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាលត្រង់នគររាជគ្រឹះនេះឯង មានព្រាហ្មណ៍ម្នាក់ឈ្មោះ ឧបសាឡ្ហកៈដូចគ្នានេះឯង កូនរបស់គាត់ក៏មានតែម្នាក់ដូចគ្នា ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ដែនមគធៈ កាលចប់សិល្បសាស្ត្រ ក៏បួសជាឥសីធ្វើអភិញ្ញា និងសមាបត្តិឲ្យកើតឡើង ត្រេកអរដោយការលេងឈាន អាស្រ័យនៅក្នុងហិមវន្តប្បទេសអស់កាលដ៏យូរ ក្រោយមកទើបទៅសម្រាកក្នុងបណ្ណសាលាជិតភ្នំគិជ្ឈកូដដើម្បីបរិភោគរសជូរប្រៃ ។ ក្នុងកាលនោះ ព្រាហ្មណ៍នោះបានប្រាប់ដល់កូនដោយទំនងដូចគ្នានេះឯង កាលកូនពោលថា សូមពុកប្រាប់ទីនោះដល់កូនចុះ ក៏ប្រាប់ទីនេះឯង ចុះទៅជាមួយកូនក៏បានឃើញព្រះពោធិសត្វ បានចូលទៅរកព្រះពោធិសត្វ ។ ព្រះពោធិសត្វសួរទំនងដូចគ្នានេះឯង កាលស្តាប់ពាក្យរបស់មាណពហើយទើបពោលថា មកចុះមាណពយើងនឹងដឹងថាទីដែលបិតារបស់អ្នកប្រាប់នោះមិនប្រឡូកប្រឡំឬប្រឡូកប្រឡំហើយនាំបិតានិងបុត្តឡើងទៅលើកំពូលភ្នំ កាលមាណពពោលថា ត្រង់ចន្លោះភ្នំទាំង ៣ នោះឯងជាទីដែលមិនប្រឡូកប្រឡំទើបព្រះពោធិសត្វប្រាប់ថា នែមាណព ក្នុងទីនេះឯងមិនមានប្រមាណនៃបុគ្គលដែលត្រូវដុត បិតារបស់អ្នក កើតក្នុងត្រកូលព្រាហ្មណ៍ក្រុងរាជគ្រឹះនេះឯងឈ្មោះឧបសាឡ្ហកៈតែម្យ៉ាង គ្រាន់តែដុតត្រង់ចន្លោះភ្នំនេះអស់ចំនួន ១៤០០០ ជាតិ ដែលពិតទីដែលមិនត្រូវដុតក្តី ទីដែលមិនមែនជាឈាបនដ្ឋានក្តី ទីដែលមិនធ្លាប់ដាក់ចុះនូវសាកសពក្តីមិនអាចរកបានលើផែនដីនេះ ហើយកំណត់ដោយបុព្វេនិវាសានុស្សតិញ្ញាណទើបពោលពីរគាថាថា

ពួកញាតិឈ្មោះឧបសាឡ្ហកចំនួន ១៤០០០ នាក់ គេដុត
ហើយក្នុងប្រទេសនេះ[១] ក្នុងលោករកទីដែលមិនមានគេស្លាប់
មិនមានឡើយ ។

សច្ចៈ ១ ធម្មៈ ១ អហឹសា ១ សញ្ញមៈ ១ ទមៈ ១ មាន
នៅក្នុងបុគ្គលណា ព្រះអរិយទាំងឡាយរមែងសេពគប់នូវ
បុគ្គលនុ៎ះ គុណជាតនុ៎ះឈ្មោះថា មិនចេះស្លាប់ក្នុងលោក
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អឆាមតំ** បានដល់ ពិតហើយទីដែលមិនស្លាប់លោកហៅថា អមតៈ ដោយការប្រៀបធៀបកាលបដិសេធសេចក្តីនោះ ទើបពោលថា **អឆាមតំ** ទីដែលមិនធ្លាប់ស្លាប់ ។ បាលីថា **អឆមតំ** ក៏មានអធិប្បាយថា ឈ្មោះថាទីដែលមិនមែនព្រៃខ្មោចជាទីដែលបុគ្គលណាម្នាក់មិនធ្លាប់ស្លាប់មិនមានក្នុងលោក ។ បទថា **យម្ហិ សច្ចញ្ច ធម្មោ ច** បានដល់ញាណគឺ សច្ចធម៌ដែលជាចំណែកខាងដើមមានអរិយសច្ច ៤ ជាបាទនិងលោកុត្តរធម៌មានក្នុងបុគ្គលណា ។ បទថា **អហឹសា** បានដល់ ការមិនបៀតបៀន កិរិយាដែលមិនបៀតបៀនចំពោះអ្នកដទៃ ។ បទថា **សញ្ញមោ** បានដល់ ការសង្រួមដោយសីល ។ បទថា **ទមោ** បានដល់ ការទូន្មាននូវ

---

១-គួរប្រែថា ព្រាហ្មណ៍ឈ្មោះឧបសាឡ្ហកចំនួន ១៤០០០ នាក់ពួកញាតិដុតហើយក្នុងប្រទេសនេះ ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

ឥន្ទ្រិយ ។ គុណជាតនេះឯងមានក្នុងបុគ្គលណា ។ បទថា **ឯតទរិយា សេ-វន្តិ** សេចក្ដីថា ព្រះអរិយៈទាំងឡាយ បានដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវករមែងសេពនូវឋានៈនេះ គឺរមែងចូលទៅរក រមែងសេពគប់បុគ្គលនោះ ។ បទថា **ឯតំ លោកេ អមតំ** បានដល់ គុណជាតនោះឈ្មោះថា អមតៈ ព្រោះសម្រេចនូវភាវៈមិនស្លាប់ក្នុងលោក ។ ព្រះពោធិសត្វសម្ដែងធម៌ដល់ឪពុកនិងកូនយ៉ាងនេះហើយចម្រើនព្រហ្មវិហារ ៤ បែរមុខចំពោះព្រហ្មលោក ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ឪពុកនិងកូនតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ឪពុកនិងកូនក្នុងកាលនោះបានមកជាឪពុកនិងកូនក្នុងកាលឥឡូវនេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឧបសាឡ្ហកជាតក ចប់

## សមិទ្ធិជាតក

[ ១៨៣ ] ( នាងទេពធីតាពោលប្រលោមថា ) បពិត្រភិក្ខុ លោកមិនទាន់បរិភោគកាមសិន ហើយត្រាច់ទៅដើម្បីភិក្ខុភាព បើលោកបរិភោគកាមរួចហើយសឹមត្រាច់ទៅដើម្បីភិក្ខាមិនបានឬ បពិត្រភិក្ខុ សូមលោកបរិភោគកាមសិនហើយសឹមត្រាច់ទៅដើម្បីភិក្ខាចុះ កុំឲ្យកាល ( ជាទីបរិភោគកាម ) កន្លងនូវលោកបានឡើយ ។

[ ១៨៤ ] ( តាបសពោធិសត្វពោលថា ) យើងមិនបានដឹងនូវមរណៈកាលដោយពិត មរណកាលកំបាំងមិនប្រាកដ ព្រោះហេតុនោះបានជាយើងមិនបរិភោគកាមហើយត្រាច់ទៅដើម្បីភិក្ខា កុំឲ្យកាល ( ធ្វើសមណធម៌ ) កន្លងនូវយើងបានឡើយ ។

**ចប់ សមិទ្ធិជាតកទី ៧ ។**

## អដ្ឋកថា
## សមិទ្ធិជាតក

[ ១៨៣-១៨៤ ] ព្រះសាស្តាកាលចូលទៅអាស្រ័យក្រុងរាជគ្រឹះ គង់ត្រង់ព្រះវិហារតបោទារាម ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះសមិទ្ធិ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អភុត្វា ភិក្ខសិ ភិក្ខុ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសមិទ្ធិត្ថេរតាំងសេចក្តីព្យាយាមមួយយប់ទល់ភ្លឺ លុះភ្លឺឡើងក៏ទៅងូតទឹកហើយស្លៀកស្បង់ឈរកាន់ចីវរដោយដៃម្ខាង

សំផិលកាយដែលមានពណ៌ដូចមាសឲ្យស្ងួត ។ ព្រះថេរៈមានឈ្មោះថា សមិទ្ធិ ព្រោះមានអត្តភាពដូចបដិមាមាស ដែលជាងមាសស្ងួសិតទុកយ៉ាងស្អាត ។ កាលនោះទេពធីតាមួយរូបឃើញលម្អនៃរាងកាយរបស់ព្រះថេរៈ មានចិត្តប្រតិព័ទ្ធពោលនឹងព្រះថេរៈយ៉ាងនេះថា បពិត្រភិក្ខុ លោកនៅក្មេង មានសក់ខ្មៅស្រិលប្រកបដោយវ័យកំលោះទាំងនៅចម្រើន មានរូបស្អាតគួរមើល គួរស្រឡាញ់ គួរជ្រះថ្លា លោកមានសភាពដូច្នេះមិនបរិភោគកាមប្រយោជន៍អ្វីដោយបព្វជ្ជារបស់លោកនោះ សូមបរិភោគកាមសិនចុះ ខាងក្រោយសឹមបួសបំពេញសមណធម៌ ។ កាលនោះព្រះថេរៈពោលនឹងទេពធីតាថា នែទេពធីតា អាត្មាមិនដឹងការស្លាប់របស់អាត្មាថា អាត្មានឹងស្លាប់ក្នុងថ្ងៃឈ្មោះនោះ អាត្មាកំណត់ពេលមិនបាន ព្រោះហេតុនោះអាត្មានឹងបំពេញសមណធម៌ទាន់នៅកំលោះហើយធ្វើនូវទីបំផុតទុក្ខ ។ ទេពធីតាកាលមិនបានការទទួលអំពីព្រះថេរៈក៏បាត់ទៅក្នុងទីនោះឯង ។ ព្រះថេរៈចូលទៅគាល់ព្រះសាស្តាហើយទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលសមិទ្ធិ ទេពធីតានោះប្រលោមអ្នកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនទេ សូម្បីក្នុងកាលមុនទេពធីតានេះក៏លួងលោមបណ្ឌិតបព្វជិតដូចគ្នា កាលព្រះថេរៈទូលអារាធនាទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាសិកគាមនាតំបន់មួយ កាលចម្រើនវ័យបានរៀនសិល្បសាស្ត្រគ្រប់យ៉ាងហើយបួសជាឥសី ញុំាងអភិញ្ញា

និងសមាបត្តិឲ្យកើត អាស្រ័យស្រះមួយនៅក្នុងហិមវន្តប្បទេស ។ តាបស នោះ បំពេញព្យាយាមមួយយប់ទល់ភ្លឺ ក្នុងពេលថ្ងៃរះឡើងងូតទឹកស្លៀកសំពត់សម្បកឈើមួយផ្ទាំង កាន់មួយផ្ទាំងឈរហាលសរីរៈឲ្យស្ងួតក្បែរស្រះ ។ ខណៈនោះ ទេពធីតាមួយអង្គសម្លឹងមើលអត្តភាពដ៏ល្អត្រកាលរបស់តាបសមានចិត្តប្រតិព័ទ្ធទើបលួងលោមព្រះពោធិសត្វពោលគាថាទីមួយថា

បពិត្រភិក្ខុ លោកមិនទាន់បរិភោគកាមសិន ហើយត្រាច់ទៅ
ដើម្បីភិក្ខុភាព បើលោកបរិភោគកាមរួចហើយ សឹមត្រាច់ទៅ
ដើម្បីភិក្ខាមិនបានឬ បពិត្រភិក្ខុ សូមលោកបរិភោគកាមសិន
ហើយសឹមត្រាច់ទៅដើម្បីភិក្ខាចុះ កុំឲ្យកាល ( ជាទីបរិភោគ
កាម ) កន្លងនូវលោកបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភុត្វា ភិក្ខសិ ភិក្ខុ** សេចក្តីថា បពិត្រភិក្ខុ លោកមិនទាន់បរិភោគវត្ថុកាមទាក់ទងដោយកិលេសកាម ក្នុងកាលនៅកំលោះហើយត្រាច់សូម ។ បទថា **ន ហិ ភុត្វាន ភិក្ខសិ** សេចក្តីថា លោកគួរបរិភោគកាមគុណ ៥ ហើយសឹមត្រាច់ទៅដើម្បីភិក្ខាមិនបានឬ លោកមិនទាន់បរិភោគកាម ហើយត្រាច់ទៅដើម្បីភិក្ខាយ៉ាងនេះមិនសមគួរឡើយ ។ បទថា **ភុត្វាន ភិក្ខុ ភិក្ខស្សុ** សេចក្តីថា បពិត្រភិក្ខុ សូមលោកបរិភោគកាមទាន់នៅជាកំលោះ ខាងក្រោយកាលចាស់ហើយសឹមត្រាច់ទៅដើម្បីភិក្ខាចុះ ។ បទថា **មា តំ កាលោ ឧបច្ចគា** សេចក្តីថា ពេលវេលាបរិភោគកាមនេះកុំបីកន្លងលោកក្នុងកាលនៅជាកំលោះឡើយ ។

ព្រះពោធិសត្វស្តាប់ពាក្យទេពធីតាហើយកាលប្រកាសអធ្យាស្រ័យរបស់ខ្លួន ទើបពោលគាថាទីពីរថា

យើងមិនបានដឹងនូវមរណៈកាលដោយពិត មរណកាលកំបាំង
មិនប្រាកដព្រោះហេតុនោះបានជាយើងមិនបរិភោគកាមហើយ
ត្រាច់ទៅដើម្បីភិក្ខា កុំឲ្យកាល ( ធ្វើសមណធម៌ ) កន្លងនូវ
យើងបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេ** ក្នុងបទថា **កាលំ វោហំ ន ជានាមិ** ត្រឹមតែជានិបាត សេចក្តីថា អាត្មាមិនដឹងពេលស្លាប់របស់ខ្លួនយ៉ាងនេះថា អញស្លាប់ក្នុងបឋមវ័យ ឬក្នុងមជ្ឈិមវ័យ ឬក្នុងបច្ឆិមវ័យ ។ ដូចលោកពោលទុក ( ក្នុងវិសុទ្ធិមគ្គ ) ថា

ធម៌ ៥ យ៉ាងគឺ ជីវិត ១ ព្យាធិ ១ កាល ១ ទីដាក់ចុះនៅ
សាកសព ១ គតិ ១ របស់សត្វទាំងឡាយក្នុងជីវលោកមិន
មាននិមិត្តដឹងបានឡើយ ដូច្នេះ ។

បទថា **ឆន្នោ កាលោ ន ទិស្សតិ** សេចក្តីថា ព្រោះអាត្មាមិនឃើញកាលដ៏កំបាំងនេះ គឺមិនប្រាកដ កាលដែលតាំងនៅដូចបិទបាំងថា អញគួរស្លាប់កាលដល់វ័យនោះឬក្នុងរដូវរងាជាដើម ។ បទថា **តស្មា អភុត្វា ភិក្ខាមិ** សេចក្តីថា ព្រោះហេតុនោះទើបអាត្មាមិនបរិភោគកាមគុណហើយសូម ។ បទថា **មា មំ កាលោ ឧបច្ចគា** សេចក្តីថា ពេលបំពេញសមណធម៌កុំបីកន្លងនូវអាត្មាឡើយ ព្រោះហេតុនោះ ទើបអាត្មាបួសបំពេញ

សមណធម៌ទាន់ខ្លួននៅក្មេង ។

ទេពធីតាស្តាប់ពាក្យព្រះពោធិសត្វហើយក៏អន្តរធានទៅក្នុងទីនោះឯង ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ទេពធីតាក្នុងកាលនោះបានមកជាទេពធីតាក្នុងកាលឥឡូវនេះ តាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សមិទ្ធិជាតក ចប់

# សកុណគ្ឃិជាតក

[ ១៨៥ ] ( ព្រះសាស្តាត្រាស់ថា ) សត្វខ្លែងបោះពួយចុះមក ដោយកម្លាំងរហ័សធាបនូវសត្វប្រចៀចដែលទំនៅលើ ( អាចម៍បំណះ ) ជាទីគោចរ ( របស់ខ្លួន ) ក៏ដល់នូវសេចក្តីស្លាប់ដោយហេតុនោះទៅ ។

[ ១៨៦ ] ( ប្រចៀចពោលថា ) ខ្ញុំនោះជាអ្នកបរិបូណ៌ដោយឧបាយ ត្រេកអរក្នុងទីគោចរជារបស់បិតា ឃើញនូវប្រយោជន៍របស់ខ្លួនហើយប្រាសចាកសត្រូវនៅរីករាយ ។

**ចប់ សកុណគ្ឃិជាតកទី ៨ ។**

# អដ្ឋកថា

# សកុណគ្ឃិជាតក

[ ១៨៥-១៨៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសកុណោវាទសូត្រដែលជាអធ្យាស្រ័យរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **សេនោ ពលសា បតមានោ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយព្រះសាស្តាត្រាស់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ព្រះសូត្រក្នុងសំយុត្តនិកាយមហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅក្នុងទីជាទីគោចរជាដែននៃបិតារបស់ខ្លួនចុះ ដូច្នេះហើយត្រាស់បន្តថា ពួកអ្នកចូរលើកទុកសិនចុះ ក្នុងកាលមុនសូម្បីតែសត្វតិរច្ឆានទាំងឡាយ ដែលលះវិស័យរបស់ខ្លួន ហើយត្រាច់ទៅក្នុងទីដែលជាអគោចរ

ធ្លាក់ក្នុងកណ្ដាប់ដៃរបស់សត្រូវ តែរួចចាកកណ្ដាប់ដៃនៃសត្រូវបានដោយការឈ្លាសក្នុងឧបាយ ព្រោះខ្លួនមានបញ្ញាជាសម្បត្តិ ហើយទ្រង់នាំយករឿងក្នុងអតីតមកថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសត្វប្រចៀច អាស្រ័យនៅតាមអាចម៍បំណះដែលគេភ្ជួរ ។ ថ្ងៃមួយសត្វប្រចៀចនោះលះទីដែលធ្លាប់រកស៊ីរបស់ខ្លួន ទៅខាងចុងព្រៃដោយគិតថា នឹងរកអាហារក្នុងទីដទៃ កាលនោះខ្លែងឃើញសត្វប្រចៀចកំពុងស្វែងរកអាហារទើបឆាបយកទៅ ។ កាលត្រូវខ្លែងឆាបយកទៅក៏ខ្សឹកខ្សួលយ៉ាងនេះថា អញគ្រោះអាក្រក់ណាស់ មានបុណ្យតិច ជាសត្វមិនមានលាភ អញត្រាច់ទៅក្នុងទីអគោចរដែលជាទីដទៃ បើថ្ងៃនេះអញត្រាច់ទៅក្នុងទីគោចរដែលជាទឹកដីបិតារបស់អញហើយខ្លែងនេះមិនមែនជាដៃគូអញក្នុងការប្រយុទ្ធទេ ។ ខ្លែងសួរថា នែប្រចៀច ទីស្វែងរកអាហារដែលជាទឹកដីបិតារបស់ឯងដូចម្ដេច សត្វប្រចៀចឆ្លើយថា គឺដុំដីអាចម៍បំណះទើបខ្លែងលែងសត្វប្រចៀចទៅដោយពោលថា ទៅចុះ ប្រចៀចឯងទៅក្នុងទីនោះក៏គង់មិនផុតពីអញ សត្វប្រចៀចហើរត្រឡប់ទៅក្នុងទីនោះបានឡើងទៅកាន់អាចម៍បំណះធំហើយឈរហៅថា មកឥឡូវនេះចុះអាខ្លែង ខ្លែងមិនបានបន្ថយកម្លាំង សម្ងបស្លាបទាំង ២ បោះពួយទៅយ៉ាងរហ័ស ឆាបនូវសត្វប្រចៀចដែលទំលើអាចម៍បំណះជាទីគោចររបស់ខ្លួន កាលសត្វប្រចៀចដឹងថា ខ្លែងនេះមកដល់អញដោយកម្លាំងខ្លាំង ទើបគេចចូលទៅក្រោមអាចម៍បំណះនោះ

ឯង ខ្ញុំមិនអាចទប់នូវសម្ទុះបានទើបបោកទ្រូងនឹងដុំដីក្នុងទីនោះឯងហើយក៏ដល់នូវការស្លាប់ក្នុងទីនោះឯង ។

ព្រះសាស្តាកាលទ្រង់សម្តែងរឿងក្នុងអតីតនេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីសត្វតិរច្ឆានត្រាច់ទៅក្នុងទីអគោចរយ៉ាងនេះក៏ធ្លាក់ក្នុងកណ្តាប់ដៃសត្រូវ តែកាលត្រាច់ទៅក្នុងទីរកអាហារដែលជាទីកដីបិតាខ្លួនក៏គ្របសង្កត់សត្រូវបាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះក្នុងសាសនានេះ អ្នកទាំងឡាយកុំត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែនរបស់បុគ្គលដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែនរបស់បុគ្គលដទៃ មាររមែងបាននូវចន្លោះ មាររមែងបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ចុះទីមិនមែនជាទីគោចររបស់ភិក្ខុ ជាដែននៃបុគ្គលដទៃ តើដូចម្តេច ។ គឺកាមគុណទាំង ៥ នេះឯង ។ កាមគុណទាំង ៥ តើដូចម្តេច ។ គឺរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាមគួរដល់តម្រេក ១ ។ សំឡេងទាំងឡាយដែលគប្បីដឹងដោយត្រចៀក ១ ។ ក្លិនទាំងឡាយដែលគប្បីដឹងដោយច្រមុះ ១ ។ រសទាំងឡាយដែលគប្បីដឹងដោយអណ្តាត ១ ។ ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាមគួរដល់តម្រេក ១ ។ ម្នាលភិក្ខុទាំងឡាយ នេះទីមិនមែនជាទីគោចររបស់ភិក្ខុ ជាដែនរបស់បុគ្គលដទៃ ។ កាលទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយ ទើបទ្រង់

ត្រាស់គាថាដំបូងថា

សត្វខ្លែងបោះពួយចុះមកដោយកម្លាំងរហ័ស ចាបនូវសត្វប្រ-
ចៀចដែលទំនៅលើ ( អាចម៍បំណះ ) ជាទីគោចរ ( របស់
ខ្លួន ) ក៏ដល់នូវសេចក្តីស្លាប់ដោយហេតុនោះទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពលសា បតមានោ** សេចក្តីថា ខ្លែងបោះពួយដោយកម្លាំង គឺដោយពេញកម្លាំងដោយគិតថា អញនឹងចាប់សត្វប្រ-ចៀច ។ បទថា **គោចរដ្ឋាយិយំ** សេចក្តីថា ខ្លែងចាបយកសត្វប្រចៀចដែលចេញអំពីដែនរបស់ខ្លួន ត្រាច់ទៅខាងចុងព្រៃដើម្បីរកអាហារ ។ បទថា **អជ្ឈ-ប្បត្តោ** បានដល់ បោះពួយ ។ បទថា **មរណំ តេនុបាគមិ** បានដល់ ខ្លែងដល់នូវសេចក្តីស្លាប់ដោយហេតុនោះ ។

កាលខ្លែងស្លាប់ ទើបសត្វប្រចៀចចេញមកឈរលើដើមទ្រូងរបស់ខ្លែង គិតថា អញឈ្នះសត្រូវហើយ កាលបន្លឺឧទានទើបពោលគាថាទីពីរថា

ខ្ញុំនោះជាអ្នកបរិបូណ៌ដោយឧបាយ ត្រេកអរក្នុងទីគោចរជា
របស់បិតា ឃើញនូវប្រយោជន៍របស់ខ្លួន ហើយប្រាសចាក
សត្រូវនៅរីករាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបាយេន** បានដល់ ឧបាយ ។ បទថា **អត្ត-មត្តនោ** បានដល់ សេចក្តីចម្រើនពោលគឺ ការផុតភ័យរបស់ខ្លួន ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ភិក្ខុជាច្រើនសម្រេចសោតាបត្តិផលជាដើម រួចទ្រង់ប្រជុំ

ជាតកថា ខ្ញុំក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកសត្វប្របចៀចក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាសកុណគ្ឃិជាតក ចប់

## អរកជាតក

[ ១៨៧ ] ( អរកសាស្តាពោលថា ) បុគ្គលណាសង្គ្រោះដល់សត្វលោកទាំងមូលដោយមេត្តាចិត្តក្នុងទិសខាងលើផង ទិសខាងក្រោមផង ទិសទទឹងផងដោយអាការទាំងពួងរកប្រមាណមិនបាន ។

[ ១៨៨ ] ចិត្តដែលប្រកបដោយប្រយោជន៍រកប្រមាណមិនបានឈ្មោះថា បុគ្គលបានចម្រើនបរិបូណ៌ហើយ អំពើណាដែលបុគ្គលបានធ្វើល្មមប្រមាណ អំពើនោះ រមែងមិនសល់នៅក្នុងចិត្តរបស់បុគ្គលអ្នកបានចម្រើននោះឡើយ ។

**ចប់ អរកជាតកទី ៩ ។**

## អដ្ឋកថា

## អរកជាតក

[ ១៨៧-១៨៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមេត្តសូត្រ ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **យោ វេ មេត្តេន ចិត្តេន** ដូច្នេះជាដើម ។

សម័យមួយព្រះសាស្តាហៅភិក្ខុទាំងឡាយមកហើយទ្រង់ត្រាស់ ( ក្នុងអង្គុត្តរនិកាយឯកាទសកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបានសេពគប់ បានចម្រើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន

បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្ស ១១ ប្រការរមែងកើតប្រាកដ ។ អានិសង្ស ១១ ប្រការ តើដូចម្តេច ។ គឺ មេត្តាវិហារិ បុគ្គលរមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនឃើញនូវសុបិនអាក្រក់ ១ ជាទីស្រឡាញ់របស់ពួកមនុស្ស ១ ជាទីស្រឡាញ់របស់ពួកអមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនចូលទៅក្នុងកាយរបស់មេត្តាវិហារិបុគ្គលនោះ ១ ចិត្តរមែងតាំងនៅមាំទាំ ១ សម្បុរមុខថ្លាស្រស់បស់ ១ ជាអ្នកមិនវង្វេងហើយធ្វើមរណកាល ១ កាលបើមិនទាន់ត្រាស់ដឹងនូវអរហត្តដ៏ក្រៃលែងជាងមេត្តាសមាបត្តិទេ រមែងបានទៅកើតក្នុងព្រហ្មលោក ១ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបានសេពគប់ បានចម្រើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្សទាំង ១១ ប្រការនេះរមែងកើតប្រាកដដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីចម្រើនមេត្តាភាវនាដែលគួរបាននូវអានិសង្ស ១១ ប្រការ គប្បីចម្រើនមេត្តាក្នុងសត្វគ្រប់ប្រភេទដោយចំពោះនិងមិនចំពោះ គប្បីមានចិត្តមេត្តាផ្សាយទៅកាន់សត្វដែលជាទីស្រឡាញ់ គប្បី

មានចិត្តមេត្តាផ្សាយទៅកាន់សត្វដែលមិនជាទីស្រឡាញ់ គប្បីមានចិត្តមេត្តាផ្សាយទៅកាន់សត្វដែលជាកណ្ដាល គប្បីចម្រើនមេត្តា ក្នុងសព្វសត្វដោយចំពោះនិងមិនចំពោះយ៉ាងនេះ គប្បីចម្រើនករុណា មុទិតា ឧបេក្ខា គប្បីបដិបត្តិក្នុងព្រហ្មវិហារ ៤ ព្រោះការធ្វើយ៉ាងនេះសូម្បីមិនបានមគ្គផលក៏គង់មានព្រហ្មលោកជាទីទៅខាងមុខ ។ សូម្បីបុរាណកបណ្ឌិតទាំងឡាយចម្រើនមេត្តាអស់ ៧ ឆ្នាំហើយស្ថិតនៅក្នុងព្រហ្មលោកនោះឯងអស់ ៧ សំវដ្តកប្បនិងវិវដ្តកប្ប ហើយទ្រង់នាំយករឿងក្នុងអតីតមកថា

ក្នុងអតីតកាល ក្នុងកប្បមួយព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ កាលចម្រើនវ័យទើបលះកាមសុខបួសជាឥសីបានជាគ្រូឈ្មោះអរកៈ ចម្រើននូវព្រហ្មវិហារ ៤ អាស្រ័យនៅក្នុងហិមវន្តប្បទេស ។ គ្រូឈ្មោះអរកៈនោះមានបរិវារច្រើន កាលទូន្មានឥសីទើបប្រកាសអានិសង្សមេត្តាថា ធម្មតាបព្វជិតគួរចម្រើន មេត្តា ករុណា មុទិតា ឧបេក្ខា ព្រោះចិត្តដែលប្រកបដោយមេត្តានេះកាលដល់ភាពជាចិត្តស្ទាត់ជំនាញហើយ រមែងឲ្យសម្រេចផ្លូវទៅកាន់ព្រហ្មលោកដូច្នេះហើយទើបពោលគាថាទាំងនេះថា

បុគ្គលណាសង្គ្រោះដល់សត្វលោកទាំងមូល ដោយមេត្តាចិត្តក្នុងទិសខាងលើផង ទិសខាងក្រោមផង ទិសទទឹងផង ដោយអាការទាំងពួងរកប្រមាណមិនបាន ។

ចិត្តដែលប្រកបដោយប្រយោជន៍រកប្រមាណមិនបានឈ្មោះថា បុគ្គលបានចម្រើនបរិបូណ៌ហើយ អំពើណាដែលបុគ្គល

បានធ្វើល្មមប្រមាណ អំពើនោះរមែងមិនសល់នៅក្នុងចិត្តរបស់

បុគ្គលអ្នកបានចម្រើននោះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យោ ច មេត្តេន ចិត្តេន សព្វលោកានុកម្បតិ** សេចក្ដីថា បណ្ដាក្សត្រជាដើម ឬសមណព្រាហ្មណ៍ណាមួយមានមេត្តាចិត្តយ៉ាងពិតប្រាកដ រមែងអនុគ្រោះសត្វលោកទូទៅ ។ បទថា **ឧទ្ធំ** គឺ ខាងលើចាប់អំពីផ្ទៃប្រឹថពីរហូតដល់ព្រហ្មលោកជាន់នេវសញ្ញានាសញ្ញាយតនៈ ។ បទថា **អធោ** គឺខាងក្រោមចាប់ពីផ្ទៃប្រឹថពី រហូតដល់ឧស្សទនរក ។ បទថា **តិរិយំ** គឺ ក្នុងមនុស្សលោកបានដល់ ក្នុងចក្កវាលទាំងអស់ អធិប្បាយថា ចម្រើនមេត្តាចិត្តយ៉ាងនេះថា ចូរសត្វទាំងឡាយទាំងពួងដែលកើតក្នុងទីមានប្រមាណប៉ុណ្ណោះ កុំបីមានពៀរ កុំបៀតបៀនគ្នា កុំមានសេចក្ដីចង្អៀតចង្អល់ ចូរមានសេចក្ដីសុខរក្សាខ្លួនចុះ ។ បទថា **អប្បមាណេន** គឺមិនមានប្រមាណព្រោះទាញយកសត្វមិនមានប្រមាណជាអារម្មណ៍ ។ បទថា **សព្វសោ** គឺ ដោយអាការទាំងពួង អធិប្បាយថា ដោយអំណាចនៃសុគតិនិងទុគ្គតិទាំងពួងយ៉ាងនេះគឺ ខាងលើ ខាងក្រោម និងខាងទទឹង ។ បទថា **អប្បមាណំ ហិតំ ចិត្តំ** បានដល់ ចិត្តអនុគ្រោះក្នុងសព្វសត្វដែលអប់រំធ្វើមិនឲ្យមានប្រមាណ ។ បទថា **បរិបុណ្ណំ** គឺ មិនខ្វះខាត ។ បទថា **សុភាវិតំ** គឺ ចម្រើនល្អហើយ ។ បទនេះជាឈ្មោះនៃចិត្តដែលមិនមានប្រមាណ ។ បទថា **យំ បមាណំ កតំ កម្មំ** សេចក្ដីថា កម្មណាគឺកម្មជាកាមាវចរដែលអប់រំហើយ ដោយអំណាចមេត្តា

ការនាមានអារម្មណ៍មិនមានប្រមាណនិងដោយអំណាចការដល់នូវភាពជាអ្នកជំនាញយ៉ាងនេះមានប្រមាណតិចបានដល់មានអារម្មណ៍ល្មមប្រមាណជារបស់តិចតួច ។ បទថា **ន តំ តត្រាវសិស្សតិ** សេចក្តីថា កម្មតិចតួចនោះគឺកម្មជារូបាវចរដែលរាប់ថា ចិត្តដែលមានមេត្តាមិនមានប្រមាណនោះមិនសេសសល់ក្នុងចិត្តនោះ អធិប្បាយថា ដូចទឹកតិចដែលត្រូវជំនន់ទឹកធំហូរចូលមកនិងត្រូវជំនន់ទឹកធំនោះគ្រប់ដណ្តប់មិនមានសេសសល់ គឺតាំងនៅមិនបានដែលពិតជំនន់ទឹកធំគ្របដណ្តប់ទឹកតូចនោះទុកយ៉ាងណា កម្មតិចតួចក៏យ៉ាងនោះមិនមានឱកាសនៃផលដែលកម្មជារបស់ធំកំណត់ទាញទុកបាន រមែងមិនសល់នៅ គឺមិនតាំងនៅ មិនអាចឲ្យផលរបស់ខ្លួនខាងក្នុងកម្មដែលជារបស់ធំនោះបានពិតណាស់ កម្មដែលជារបស់ធំប៉ុណ្ណោះរមែងហ៊ុំព័ទ្ធកម្មនោះ គឺឲ្យផល ។

ព្រះពោធិសត្វ កាលពោលដល់អានិសង្សមេត្តាភាវនាដល់អន្តេវាសិកទាំងឡាយយ៉ាងនេះហើយ ជាអ្នកមិនសាបសូន្យចាកឈាន ក៏ទៅកើតក្នុងព្រហ្មលោក មិនបានវិលត្រឡប់មកកាន់លោកនេះទៀតអស់ ៧ សំវដ្តកប្បនិងវិវដ្តកប្ប ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រជុំជាតកថា ពួកឥសីក្នុងកាលនោះបានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯគ្រូអរកៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា អរកជាតក ចប់**

## កកណ្ឌកជាតក

[ ១៨៩ ] ( ព្រះបាទវិទេហត្រាស់ថា ) កាលពីដើម បន្ទួយនេះនៅលើខ្លោងទ្វារមិនក្រអឺតក្រអោងទេ ម្នាលមហោសថ អ្នកចូរដឹងព្រោះហេតុអ្វីបានជាបន្ទួយត្រឡប់ទៅជារបឹងរឹងរូសវិញ ។

[ ១៩០ ] ( មហោសថពោធិសត្វពោលថា ) បន្ទួយបានរបស់ដែលមិនធ្លាប់បានចំនួនកន្ទះមាសក រមែងមើលងាយព្រះបាទវិទេហៈដែលសោយរាជ្យក្នុងនគរមិថិលា ។

**ចប់ កកណ្ឌកជាតកទី ១០ ។**

**ចប់ សន្ថវវគ្គទី ២ ។**

### ឧទ្ទាននៃសន្ថវវគ្គនោះគឺ

និយាយអំពីឥន្ទសមានតាបស ១ ខុមស្ទឹក ១ ព្រះរាជាសុសីម ១ ត្មាត ១ ស្លាជាជលាពុជៈ ១ ឧបសាឡ្ហកព្រាហ្មណ៍ ១ ភិក្ខុ ១ ប្រចៀចដ៏ប្រសើរ ១ មេត្តាដ៏ប្រសើរ ១ បន្ទួយក្រអើតក្រអោង ១ ត្រូវជា ១០ ។

# អដ្ឋកថា

## កកណ្ឌកជាតក

*[ ១៨៩-១៩០ ] កកណ្ឌកជាតកនេះ មានពាក្យផ្តើមថា* **ឆាយំ បុរេ ឧន្នមតិ** *ដូច្នេះជាដើម ។ ជាតកនេះ មានជាក់ច្បាស់ក្នុងមហាឧម្មគ្គជាតក[១]*

*អដ្ឋកថា កកណ្ឌកជាតក ចប់*

*សន្ថវវគ្គ ចប់*

១-មហោសធជាតក ។

# កល្យាណធម្មវគ្គ

## កល្យាណធម្មជាតក

[ ១៩១ ] ( សេដ្ឋីពោធិសត្វពោលថា ) បពិត្រព្រះអង្គជាធំជាងជន កាលណានរជនប្រកបដោយបញ្ញាដល់នូវសមញ្ញា ( ឈ្មោះ ) ថាជាអ្នកមានកល្យាណធម៌ក្នុងលោក ( កាលនោះ ) មិនគប្បីឲ្យសាបសូន្យចាកសមញ្ញានោះ សប្បុរសទាំងឡាយតែងកាន់យកនូវបព្វជ្ជាធុរៈដោយហិរិនិងឱត្តប្បៈ ។

[ ១៩២ ] បពិត្រព្រះអង្គជាធំជាងជនសមញ្ញានោះឯង ថាជាអ្នកមានកល្យាណធម៌ក្នុងលោកមកដល់ខ្ញុំក្នុងថ្ងៃនេះ ហើយខ្ញុំព្រះអង្គពិចារណាឃើញនូវសមញ្ញានោះនឹងបួសក្នុងថ្ងៃនេះ សេចក្ដីពេញចិត្តក្នុងការបរិភោគកាមក្នុងលោកនេះមិនមានដល់ខ្ញុំទេ ។

**ចប់ កល្យាណធម្មជាតកទី ១ ។**

# កល្យាណធម្មវគ្គ

## អដ្ឋកថា កល្យាណធម្មជាតក

[ ១៩១-១៩២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធម្តាយក្មេកត្រចៀកថ្លង់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កល្យាណធម្មោ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិកៈម្នាក់ជាអ្នកមានសទ្ធាជ្រះថ្លា ដល់នូវត្រៃសរណគមន៍ រក្សាសីល ៥ ។ ថ្ងៃមួយ គាត់កាន់កេសជ្ជៈមានសប្បិជាដើមជាច្រើន មួយអន្ទើដោយផ្កា និងគ្រឿងក្រអូបនិងសំពត់ជាដើម ទៅដោយគិតថានឹងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ក្នុងវត្តជេតពន ។ ក្នុងកាលកុដុម្ពិកៈទៅក្នុងទីនោះ ម្តាយក្មេកម្នាក់ត្រៀមរបស់ទំពា របស់បរិភោគ បំណងសួរសុខទុក្ខកូនស្រីបានទៅកាន់ផ្ទះនោះ ។ តែម្តាយក្មេកជាមនុស្សត្រចៀកថ្លង់ កាលបរិភោគជាមួយនឹងកូនស្រីឆ្អែតហើយ ទើបសួរកូនស្រីថា នែកូន ប្តីរបស់កូននៅដោយការស្រឡាញ់ត្រេកអរមិនឈ្លោះទាស់ទែងទេឬ កូនស្រីឆ្លើយថា ម៉ែនិយាយថ្វីយ៉ាងនោះ បុគ្គលដែលដល់ព្រមដោយសីលនិងមារយាទដូចកូនប្រសារបស់ម៉ែសូម្បីអ្នកបួសក៏គង់រកបានដោយលំបាក ។ ឧបាសិកាស្តាប់ពាក្យកូនស្រីមិនច្បាស់ កាន់យកតែបទថាបួសប៉ុណ្ណោះ ទើបគំហកឡើងថា ហេតុអ្វី ទើបប្តីរបស់នាងបួស ។ បណ្តាអ្នកនៅផ្ទះជិតខាងបានឮដូច្នោះនាំគ្នាពោលថា បានឮថា កុដុម្ពិកៈរបស់ពួកយើងបួសហើយ ។ បណ្តាបុគ្គលដែលដើរឆ្លងទៅមកតាមផ្លូវមុខផ្ទះបានឮសំឡេងរបស់មនុស្ស

ទាំងនោះទើបសួរថា តើមានរឿងអ្វី ជនទាំងនោះឆ្លើយថា បានឮថា កុដុម្ពិកៈក្នុងផ្ទះនេះបានបួសហើយ ។

ឯកុដុម្ពិកៈកាលស្តាប់ធម៌របស់ព្រះទសពលហើយ ក៏ចេញចាកវិហារត្រឡប់ចូលក្រុង ខណៈនោះបុរសម្នាក់ជួបក្នុងរវាងផ្លូវទើបពោលថា បានឮថាលោកបួស បុត្តកិរិយាបរិវារក្នុងផ្ទះរបស់អ្នកនាំគ្នាស្រែកយំ ។ ក្នុងនោះគាត់គិតថា ពិតហើយអញមិនបានបួសសោះជនទាំងនេះថាអញបួស សំឡេងល្អកើតឡើងហើយអញមិនគួរឲ្យបាត់ទៅ អញគួរបួសក្នុងថ្ងៃនេះឯងទើបត្រឡប់អំពីទីនោះទៅគាល់ព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា ម្នាលឧបាសក អ្នកធ្វើឧបដ្ឋាកទើបតែត្រឡប់ទៅអម្បាញ់មិញនេះឯង ហេតុអ្វីទើបត្រឡប់មកវិញ ទើបតំណាលរឿងនោះថ្វាយហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាសំឡេងល្អកើតឡើងហើយមិនគួរឲ្យបាត់ទៅឡើយព្រោះដូច្នោះខ្ញុំព្រះអង្គមានបំណងនឹងបួសទើបមក ។ កាលបុរសនោះឧបសម្បទាហើយជាអ្នកបដិបត្តិប្រពៃមិនយូរប៉ុន្មានក៏សម្រេចអរហត្ត បានឮថា ហេតុ-ការណ៍នេះប្រាកដល្បីខ្ទរខ្ទារទៅក្នុងគណៈសង្ឃ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ កុដុម្ពិកៈឈ្មោះនោះបានកើតការគិតឡើងថា សំឡេងល្អកើតឡើងហើយមិនគួរឲ្យបាត់ទៅឡើយទើបបព្វជ្ជាពេលនេះសម្រេចអរហត្តហើយ ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន

ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយសូម្បីបណ្ឌិត ក្នុងកាលមុនក៏មានការគិតថា សំឡេងល្អកើតឡើងហើយមិនគួរឲ្យបាត់ទៅ ហើយក៏ចេញបួស ហើយទ្រង់នាំរឿងក្នុងអតីតមកត្រាស់ថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី កាលចម្រើនវ័យហើយបិតាអនិច្ចកម្ម ទៅក៏បានទទួលតំណែងជាសេដ្ឋី ។ ថ្ងៃមួយ សេដ្ឋីចេញអំពីផ្ទះទៅប្រកប រាជកិច្ច ។ កាលនោះម្ដាយក្មេករបស់សេដ្ឋីបានទៅកាន់ផ្ទះនោះ ដោយគិតថា នឹងសួរសុខទុក្ខកូនស្រី ម៉ែក្មេកនោះជាមនុស្សត្រចៀកថ្លង់ ។ រឿងទាំងអស់ ដូចគ្នានឹងរឿងបច្ចុប្បន្ននេះឯង ។ បុរសម្នាក់ឃើញសេដ្ឋីប្រកបរាជកិច្ចស្រេច ហើយត្រឡប់មកផ្ទះ ទើបពោលថា ក្នុងផ្ទះរបស់លោកមានសំឡេងយំយ៉ាង ខ្លាំងព្រោះបានឮថា លោកបួសហើយ ព្រះពោធិសត្វបានទូវការគិតឡើងថា ធម្មតាសំឡេងល្អ ( សមញ្ញា ) កើតឡើងហើយមិនគួរឲ្យបាត់ទៅ ទើប ត្រឡប់មកអំពីនោះទៅគាល់ព្រះរាជា កាលព្រះរាជាសួរថា លោកសេដ្ឋីទើប តែទៅអម្បាញ់មិញនេះឯងហេតុអ្វីទើបត្រឡប់មកទៀតទើបទូលថា បពិត្រ ព្រះអង្គជាធំជាងជន ទូលបង្គំមិនបានបួសសោះ មនុស្សក្នុងផ្ទះកន្ទក់កន្ទេញ ពោលថា ទូលបង្គំបួសហើយ សំឡេងល្អបែបនេះកើតឡើងហើយមិនគួរឲ្យ បាត់ទៅ ទូលបង្គំនឹងបួសសូមទ្រង់ព្រះរាជានុញ្ញាតឲ្យទូលបង្គំបួសចុះ កាល នឹងប្រកាសអត្ថនេះទើបពោលគាថាទាំងឡាយថា

បពិត្រព្រះអង្គជាធំជាងជន កាលណានរជនប្រកបដោយ

បញ្ញាដល់នូវសមញ្ញា ( ឈ្មោះ ) ថាជាអ្នកមានកល្យាណធម៌ក្នុងលោក ( កាលនោះ ) មិនគប្បីឲ្យសាបសូន្យចាកសមញ្ញានោះ សប្បុរសទាំងឡាយតែងកាន់យកនូវបព្វជ្ជាធុរៈដោយហិរិនិងឱត្តប្បៈ ។

បពិត្រព្រះអង្គជាធំជាងជន សមញ្ញានោះឯងថាជាអ្នកមានកល្យាណធម៌ក្នុងលោកមកដល់ខ្ញុំក្នុងថ្ងៃនេះ ហើយខ្ញុំព្រះអង្គពិចារណាឃើញនូវសមញ្ញានោះ នឹងបួសក្នុងថ្ងៃនេះ សេចក្តីពេញចិត្តក្នុងការបរិភោគកាម ក្នុងលោកនេះមិនមានដល់ខ្ញុំទេដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កល្យាណធម្មោ** បានដល់ ធម៌ល្អ ។ បទថា **សមញ្ញំ អនុបាបុណាតិ** សេចក្តីថា ដល់នូវវោហារប្បញ្ញត្តិយ៉ាងនេះថាមានសីល មានកល្យាណធម៌បួសហើយ ។ ក្នុងបទថា **តស្មា ន ហិយ្យេថ** បានដល់ មិនគប្បីឲ្យសាបសូន្យចាកសមញ្ញានោះ ។ សប្បុរសទាំងឡាយរមែងទាញយកធុរៈទុកដោយហិរិថា បពិត្រមហារាជ ឈ្មោះថាសប្បុរសទាំងឡាយ តែងទាញយកនូវបព្វជ្ជាធុរៈ ដោយហិរិដែលកើតឡើង ដោយមានអារម្មណ៍ខាងក្នុងផង ដោយឱត្តប្បៈដែលកើតឡើង ដោយមានអារម្មណ៍ខាងក្រៅផង ។ បទថា **ឥធ មជ្ជ បត្តា** បានដល់ កល្យាណធម៌ក្នុងលោកនេះបានមកដល់ទូលព្រះបង្គំហើយក្នុងថ្ងៃនេះ ។ បទថា **តាហំ សមេក្ខំ** សេចក្តីថា ទូលបង្គំពិចារណាឃើញសមញ្ញាដែលបានហើយដោយគុណ ។

បទថា **ន ហិ មត្ថិ ជន្ទោ** កែជា **ន ហិ មេ អត្ថិ ជន្ទោ** ប្រែថា ទូលព្រះបង្គំមិនពេញចិត្តឡើយ ។ បទថា **៩៨ កាមភោគេ** គឺ ក្នុងការបរិភោគដោយកិលេសកាមនិងដោយវត្ថុកាមក្នុងលោកនេះ ។

ព្រះពោធិសត្វកាលក្រាបទូលយ៉ាងនេះហើយ ទើបសូមព្រះបរមរាជានុញ្ញាតដើម្បីបព្វជ្ជា ទៅកាន់ហិមវន្តប្បទេសបួសជាឥសី ញុំាងអភិញ្ញានិងសមាបត្តិឲ្យកើត មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯសេដ្ឋីនគរពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កល្យាណធម្មជាតក ចប់

## ទទ្ទរជាតក

[ ១៩៣ ] ( *កូនសីហៈសួរថា* ) *បពិត្រសីហរាជជាធំជាងម្រឹគ នរណាហ្ន៎ មានសំឡេងខ្លាំង ញុំាងភ្នំទទ្ទរៈឲ្យលាន់ឮ ពួកសីហៈមិនបន្ទឹតបទៅនឹងវាឡើយ សត្វដែលបន្លឺសំឡេងគឹកកងបាន នុ៎ះជាសត្វឈ្មោះអ្វី ។*

[ ១៩៤ ] ( *សីហពោធិសត្វពោលថា* ) *ម្នាលកូន ចចកជាសត្វថោកទាបជាងម្រឹគទាំងឡាយ វាបន្លឺឡើង ពួកសីហៈកាលខ្ពើមរអើមនូវជាតិរបស់វារមែងនាំគ្នាអង្គុយនៅស្ងៀម ។*

**ចប់ ទទ្ទរជាតក ទី ២ ។**

## អដ្ឋកថា

## ទទ្ទរជាតក

[ ១៩៣-១៩៤ ] *ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកោកាលិកភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **កោ នុ សទ្ទេន មហតា** *ដូច្នេះជាដើម ។*

*សេចក្ដីពិស្ដារថា ក្នុងកាលនោះពួកភិក្ខុជាពហុសូត អង្គុយត្រង់ផ្ទាំងថ្មពណ៌ក្រហម សូធ្យបទភាណវារក្នុងកណ្ដាលសង្ឃដូចរាជសីហ៍ជំទង់បន្លឺសីហនាទ ដូចទេវតាបណ្ដាលឲ្យអាកាសគង្គាធ្លាក់ចុះ កាលភិក្ខុទាំងនោះកំពុងសូធ្យបទភាណវារ កោកាលិកភិក្ខុមិនដឹងភាពល្ងង់ខ្លៅរបស់ខ្លួនក៏អួតអាងថា ខ្ញុំនឹងសូធ្យបទភាណវារដែរ ទើបចូលទៅក្នុងរវាងភិក្ខុទាំងឡាយ ដើរប្រកាសក្នុង*

ទីនោះៗ អាងភិក្ខុសង្ឃថា ពួកភិក្ខុមិនឲ្យឱកាសដល់ខ្ញុំពោលបទភាណវារ ខ្វះ បើឲ្យឱកាសដល់ខ្ញុំ ខ្ញុំនឹងពោលដែរ ។ វាចារបស់កោកាលិកភិក្ខុបាន ប្រាកដក្នុងពួកភិក្ខុ ពួកភិក្ខុគិតថា នឹងសាកល្បងកោកាលិកភិក្ខុមើល ទើប ពោលថា នែកោកាលិក ថ្ងៃនេះ ចូរលោកពោលបទភាណវារដល់សង្ឃចុះ កោកាលិកមិនដឹងសមត្ថភាពរបស់ខ្លួនទើបទទួលថា សាធុ ទើបឆាន់បបរ របស់ទំពាដែលជាទីសប្បាយរបស់ខ្លួនបរិភោគជាមួយស្ងោរដ៏ឆ្ងាញ់ ។ កាល ព្រះអាទិត្យលិចពួកជនប្រកាសវេលាស្តាប់ធម៌ ពួកភិក្ខុប្រជុំគ្នា ។ កោកា-លិកស្លៀកសំពត់កាសាវពស្ត្រមានពណ៌ដូចកក់ ដណ្តប់ចីវរមានពណ៌ដូចផ្កា កណិការចូលទៅកាន់ជំនុំសង្ឃ ថ្វាយបង្គំព្រះថេរៈ ឡើងកាន់ធម្មាសនៈដែល ប្រដាប់ទុកយ៉ាងល្អក្នុងរតនមណ្ឌប ចាប់ផ្ចិតវាលវីជនីដោយគិតថា អញនឹង ពោលបទភាណវារ ។ រំពេចនោះឯង ញើសក៏ហូរចេញអំពីរាងកាយរបស់ កោកាលិក ការភ័យខ្លាច ក៏គ្របសង្កត់ ។ កាលពោលបទដើមរបស់គាថា ដំបូងហើយក៏មិនឃើញបទខាងចុង ។ កោកាលិកភិក្ខុញ័រចំប្រប់ចុះអំពីធម្មា-សនៈដោយការខ្មាសអៀន បានចេញទៅអំពីជំនុំសង្ឃត្រឡប់ទៅកាន់ទីលំនៅ របស់ខ្លួន ។ ទើបភិក្ខុដែលជាពហូស្សូតដទៃពោលបទភាណវារតទៅ ។ តាំង អំពីនោះមកទើបភិក្ខុទាំងឡាយដឹងថា កោកាលិកភិក្ខុជាមនុស្សល្ងង់ ។

ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំង ឡាយ ភាពល្ងង់របស់កោកាលិកដំបូងដឹងបានលំបាកតែឥឡូវនេះបានប្រាកដ ច្បាស់ហើយ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ

អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កោកាលិកបើកបង្ហាញភាពល្ងង់ឲ្យប្រាកដនោះមិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ក៏បានបង្ហាញភាពល្ងង់ឲ្យប្រាកដហើយទើបទ្រង់នាំយកអតីតនិទានមកថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតរាជសីហ៍ ក្នុងហិមវន្តប្បទេស បានជាស្តេចនៃរាជសីហ៍ទាំងឡាយ ។ ស្តេចរាជសីហ៍នោះមានរាជសីហ៍ជាបរិវារមិនមែនតិចអាស្រ័យនៅក្នុងរតនគុហា ។ សូម្បីចចកក៏អាស្រ័យនៅក្នុងគុហាមួយកន្លែងមិនឆ្ងាយអំពីគុហានោះ ។ ថ្ងៃមួយភ្លៀងធ្លាក់ជាប់គ្រាប់ហើយពួករាជសីហ៍ទាំងអស់ ក៏នាំគ្នាមកប្រជុំត្រង់មុខគុហារបស់រាជសីហ៍ រាជសីហ៍នីមួយៗបន្លឺសីហនាទប្រឡែងគ្នា ។ ក្នុងខណៈដែលរាជសីហ៍ទាំងនោះបន្លឺសីហនាទប្រឡែងគ្នាយ៉ាងនេះ ចចកនោះក៏លូឡើង ពួករាជសីហ៍បានឮសំឡេងចចកក៏ខ្មើមរអើមនាំគ្នានៅស្ងៀមដោយគិតថា ចចកនេះលូប្រណាំងប្រជែងជាមួយពួកយើង ។ ក្នុងខណៈដែលរាជសីហ៍ទាំងនោះនៅស្ងៀម រាជសីហ៍តូចដែលជាកូនស្តេចរាជសីហ៍សួរបាថា បពិត្របិតា រាជសីហ៍ទាំងនេះបន្លឺសំឡេងប្រឡែងគ្នា កាលបានឮសំឡេងរបស់សត្វនោះនាំគ្នានៅស្ងៀមដោយការខ្មើមរអើមសត្វនោះឈ្មោះអ្វី អួតអាងដោយសំឡេងរបស់ខ្លួនទើបពោលគាថាទីមួយថា

បពិត្រសីហរាជជាធំជាងម្រឹគ នរណាហ្ន៎ មានសំឡេងខ្លាំង
ញុំាងភ្នំទទួរៈឲ្យលាន់ឮ ពួកសីហៈមិនបន្ទឺតបទៅនឹងវាឡើយ
សត្វដែលបន្ទឺសំឡេងគឹកកងបាន នុ៎ះជាសត្វឈ្មោះអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិនាទេតិ ទទ្ទរំ** សេចក្ដីថា នរណាហ្ន៎ ធ្វើទទួរបពិតឲ្យមានសំឡេងគឹកកងតែមួយ ។ កូនរាជសីហ៍ហៅបាថា **មិគា-ភិភូ** ក្នុងបទថា **មិគាភិភូ** នេះមានអធិប្បាយថា បពិត្រស្ដេចរាជសីហ៍ជាធំជាងម្រឹគ ខ្ញុំសូមសួរលោក តើសត្វនោះ ឈ្មោះ សត្វអ្វី ។

កាលបានស្ដាប់ពាក្យរបស់កូនរាជសីហ៍ហើយ ទើបពោលគាថាទីពីរថា

ម្នាលកូន ចចកជាសត្វថោកទាបជាងម្រឹគទាំងឡាយ វាបន្ទឺ
ឡើង ពួកសីហៈកាលខ្ពើមរអើមនូវជាតិរបស់វា រមែងនាំគ្នា
អង្គុយនៅស្ងៀម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សំ** ក្នុងបទថា **សមច្ឆរេ** ត្រឹមតែជាឧបសគ្គ សេចក្ដីថា នៅស្ងៀម ។ លោកអធិប្បាយទុកថា រាជសីហ៍ទាំងឡាយនៅស្ងៀម គឺនៅព្រងើយៗ ។ ក្នុងគម្ពីរទាំងឡាយកេចិអាចារ្យទាំងឡាយចារឹកទុកថា **សមច្ឆរេ** ក៏មាន ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កោកាលិកមិនបានបើកបង្ហាញភាពល្ងង់ខ្លៅរបស់ខ្លួនតែក្នុងកាលឥឡូវនេះទេ សូម្បីកាលមុនក៏បានបើកបង្ហាញហើយដូចគ្នា ហើយទ្រង់នាំយកព្រះធម្មទេសនានោះមកសម្ដែងហើយប្រជុំជាតកថា ចចកក្នុងកាលនោះបានមកជាកោកាលិក ក្នុងកាលឥឡូវនេះ

ឯកូនរាជសីហ៍ក្នុងកាលនោះ បានមកជារាហុល ស្តេចរាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទទ្ទរជាតក ចប់

## មក្កដជាតក

[ ១៩៥ ] ( តាបសជាកូនពោលថា ) បពិត្របិតា មាណពនុ៎ះបានឈរផ្អែកនឹងគល់ត្នោត រោងរបស់យើងនេះមាន បើដូច្នោះយើងនឹងប្រគល់រោងឲ្យទៅមាណពនោះចុះ ។

[ ១៩៦ ] ( តាបសពោធិសត្វពោលថា ) ម្នាលកូន អ្នកកុំហៅវាឡើយ វាគប្បីប្រទូស្តនូវរោងរបស់យើងមិនខាន មុខព្រាហ្មណ៍ដែលមានសីលធម៌ល្អ មិនមែនបែបយ៉ាងនេះទេ ។

**ចប់ មក្កដជាតកទី ៣ ។**

## អដ្ឋកថា

## មក្កដជាតក

[ ១៩៥-១៩៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនិយាយកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តាត មាណវកោ ឋសោ** ដូច្នេះជាដើម ។

រឿងនឹងមានច្បាស់ក្នុងឧទ្ទាលកជាតកក្នុងបកិណ្ណកនិបាតឯណោះ ។ ក្នុងកាលនោះព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមិនមែនកុហកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនកាលកើតជាស្វា ក៏ធ្លាប់កុហកព្រោះរឿងភ្លើងហើយទ្រង់នាំអតីតនិទានមកសាធកៈថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងដែនកាសី ចម្រើនវ័យហើយបាន សិក្សានូវសិល្បសាស្រ្តក្នុងនគរតក្កសិលាតម្កល់ខ្លួនជាឃរាវាស ។ ក្នុងគ្រាតមកព្រាហ្មណីភរិយារបស់ព្រហ្មណ៍នោះប្រសូតបុត្តម្នាក់ កាលបុត្តនោះវត់ទៅមកបាន ព្រាហ្មណីក៏ធ្វើកាលកិរិយា ។ ព្រះពោធិសត្វធ្វើឈាបនកិច្ចស្រេចហើយគិតថា អញនៅគ្រប់គ្រងផ្ទះធ្វើអ្វី ទើបលះញាតិមិត្តដែលនាំគ្នាទ្រហោយំ នាំកូនចូលកាន់ព្រៃហិមពាន្តបួសជាឥសី មានមើមឈើនិងផ្លែឈើក្នុងព្រៃជាអាហារ ។ ថ្ងៃមួយកាលភ្លៀងធ្លាក់ក្នុងរដូវភ្លៀងព្រះពោធិសត្វបង្កាត់ភ្លើងអាំងដេកនៅលើបន្ទះក្តារ សូម្បីបុត្តរបស់ឥសីក៏បួសជាតាបសកុមារអង្គុយច្របាច់ជើងបិតានោះឯង ។ ស្វាព្រៃមួយត្រូវរងាបៀតបៀនឃើញភ្លើងត្រង់បណ្ណសាលារបស់ព្រះពោធិសត្វគិតថា បើអញចូលទៅក្នុងបណ្ណសាលានេះ ឥសីនឹងស្រែកថា ស្វា ស្វា ហើយវាយអញនាំចេញទៅ អញនឹងមិនបានអាំងភ្លើង ណ្ហើយចុះឥឡូវនេះអញមានឧបាយមួយ អញនឹងក្លែងខ្លួនជាតាបសបញ្ឆោតឥសីនេះទើបស្លៀកសំពត់សម្បកឈើរបស់តាបសដែលស្លាប់ហើយម្នាក់ កាន់កំប្រោងតម្កក់និងឈើច្រត់អាស្រ័យត្នោតមួយដើមត្រង់ទីជិតបណ្ណសាលា ឈរញ័រចំប្រប់ ។ តាបសកុមារឃើញស្វាក៏មិនស្គាល់ថាជាស្វាទើបប្រាប់ដល់តាបសជាបិតាថា បពិត្របិតា មានតាបសចាស់មួយរូបត្រូវរងាបៀតបៀន គង់មករកភ្លើងអាំង យើងគួរឲ្យតាបសចាស់នោះចូលទៅអាំងភ្លើងក្នុងបណ្ណសាលាមួយខ្នង កាលពោលនឹងបិតាទើបពោលគាថាដំបូងថា

បពិត្របិតា មាណពនុ៎ះបានឈរផ្អែកនឹងគល់ត្នោត រោង
របស់យើងនេះមាន បើដូច្នោះយើងនឹងប្រគល់រោងឲ្យទៅ
មាណពនោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាណវកោ** ជាឈ្មោះរបស់សត្វ ។ លោកសម្ដែងថា បពិត្រលោកឪពុក នុ៎ះមាណព បានដល់ សត្វមួយប្រភេទ គឺ តាបសមួយរូប ។ បទថា **តាលមូលំ អបស្សិតោ** បានដល់ ឈរផ្អែកដើមត្នោត ។ បទថា **អគារកញ្ចិទំ អត្ថិ** បានដល់ យើងមានផ្ទះរបស់អ្នកបួសនេះ គឺសំដៅដល់បណ្ណសាលា ។ បទថា **ហន្ទ** ត្រឹមតែជានិបាត ចុះក្នុងអត្ថនៃការដាស់តឿន ។ បទថា **ទេមស្សគារកំ** សេចក្ដីថា យើងនឹងឲ្យផ្ទះតាបសនេះមួយចំណែក ។

ព្រះពោធិសត្វបានឮពាក្យរបស់បុត្ត ទើបក្រោកឡើងឈរត្រង់ទ្វារបណ្ណសាលា ( សម្លឹងមើល ) ដឹងថា សត្វនោះជាស្វាទើបប្រាប់កូនថា នៃកូនធម្មតាមុខមនុស្សមិនមែនបែបនេះទេ កូនមិនគួរហៅស្វាចូលមកក្នុងទីនេះ ទើបពោលគាថាទីពីរថា

ម្នាលកូន អ្នកកុំហៅវាឡើយ វាគប្បីប្រទូស្តនូវរោងរបស់
យើងមិនខាន មុខព្រាហ្មណ៍ដែលមានសីលធម៌ល្អ មិនមែន
បែបយ៉ាងនេះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទូសេយ្យ នោ អគារកំ** សេចក្ដីថា សត្វនេះចូលមកក្នុងរោងនឹងប្រទូសបណ្ណសាលា ដោយយកភ្លើងដុតបណ្ណសាលា

ដែលធ្វើបានដោយលំបាកនេះឬបន្ទោបង់ឧច្ចារៈជាក់ជាដើម ។ បទថា **ឆេ-តាធិសំ** បានដល់ មុខរបស់ព្រាហ្មណ៍ដែលមានសីលល្អមិនដូច្នេះឡើយ ។

ព្រះពោធិសត្វកាលប្រាប់ថា នុ៎ះជាស្វាដូច្នេះហើយ ទើបចាប់អង្កត់ភ្លើងមួយសម្គុតថា ឯងនៅទីនេះធ្វើអ្វីហើយគ្រវែងស្វានោះឲ្យចៀសចេញទៅ ស្វាក៏ចោលសំពត់សម្បកឈើរត់ឡើងដើមឈើចូលព្រៃទៅ ។

ព្រះពោធិសត្វចម្រើនព្រហ្មវិហារ ៤ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ស្វាក្នុងកាលនោះបានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ តាបសកុមារក្នុងកាលនោះបានមកជារាហុល ឯតាបសជាបិតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មក្កដជាតក ចប់

## ទុព្ភិយមក្កដជាតក

[ ១៩៧ ] ( ព្រាហ្មណ៍ពោធិសត្វពោលថា ) យើងបានឲ្យទឹកច្រើនដល់ឯងដែលត្រូវកម្ដៅថ្ងៃបៀតបៀនស្រេកហើយ ឥឡូវនេះឯងផឹកហើយធ្វើសំឡេងគំហកថា កិកិ ដូច្នេះការសេពគប់ដោយជនអាក្រក់មិនប្រសើរឡើយ ។

[ ១៩៨ ] ( ស្វាទេវទត្តពោលថា ) អ្នកឯងដែលបានឮឬបានឃើញថា ស្វាណាមានសីលធម៌ ឥឡូវនេះយើងបន្ទោបង់វច្ចៈលើក្បាលរបស់អ្នកឯង នេះជាធម្មតារបស់ពួកយើង ។

**ចប់ ទុព្ភិយមក្កដជាតកទី ៤ ។**

## អដ្ឋកថា

## ទុព្ភិយមក្កដជាតក

[ ១៩៧-១៩៨ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អទម្ហ តេ វារិ ពហុត្តរូបំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាអំពីភាពអកតញ្ញូនិងការទ្រុស្ដមិត្តរបស់ទេវទត្ត ។ ព្រះសាស្ដាត្រាស់ថា ទេវទត្តជាអកតញ្ញូទ្រុស្ដមិត្តមិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីកាលមុនក៏យ៉ាងនេះដូចគ្នា ហើយទ្រង់នាំរឿងក្នុងអតីតមកត្រាស់ថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍មួយក្នុងដែនកាសី ចម្រើនវ័យហើយ តម្កល់ខ្លួនជាឃរាវាស ។ សម័យនោះ មានអណ្តូងទឹកជ្រៅមួយនៅត្រង់ផ្លូវ ធំក្នុងដែនកាសី សត្វតិរច្ឆានទាំងឡាយចុះទៅមកមិនបាន ។ ពួកមនុស្ស ប្រាថ្នាបុណ្យដើរមកតាមផ្លូវនោះ ប្រើត្រឡោកមានខ្សែវែងដងទឹកដាក់ពេញ ស្នូកមួយឲ្យសត្វតិរច្ឆានផឹក នៅជុំវិញអណ្តូងនោះជាព្រៃធំ ស្វាជាច្រើន អាស្រ័យនៅក្នុងព្រៃនោះ ។ តមកតាមផ្លូវនោះមិនមានអ្នកដំណើរដើរទៅមក អស់ ២-៣ ថ្ងៃ ទើបសត្វតិរច្ឆានមិនបានទឹកផឹក ។

ក្នុងកាលនោះស្វាមួយស្រេកទឹកខ្លាំងដើររកទឹកផឹកក្បែរៗអណ្តូង ។ ព្រះ ពោធិសត្វធ្វើដំណើរតាមផ្លូវនោះដោយកិច្ចឯណានីមួយទើបដងទឹកក្នុងអណ្តូង នោះផឹក លាងដៃនិងជើងឃើញស្វានោះដឹងថា ស្រេកទឹកទើបដងទឹកដាក់ ស្នូកឲ្យផឹកស្រេចហើយគិតនឹងសម្រាក ទើបដេកក្រោមដើមឈើមួយដើម ។ ឯស្វានោះផឹកទឹកហើយអង្គុយមិនឆ្ងាយ ញាក់មុខញាក់មាត់ដាក់ព្រះពោធិសត្វ ព្រះពោធិសត្វឃើញកិរិយារបស់ស្វាទើបពោលថា នែស្វាចង្រៃ កាលឯង ស្រេកទឹក ហត់នឿយ មករកអញ អញឲ្យទឹកឯងផឹក ពេលនេះឯងគំហក អញថា កិកិទៅវិញ ការដែលជួយសត្វអាក្រក់មិនមានប្រយោជន៍ឡើយ ហើយពោលគាថាទីមួយថា

យើងបានឲ្យទឹកច្រើនដល់ឯង ដែលត្រូវកម្តៅថ្ងៃបៀតបៀន
ស្រេកហើយ ឥឡូវនេះឯងផឹកហើយធ្វើសំឡេងគំហកថា កិកិ

ដូច្នេះការសេពគប់ដោយជនអាក្រក់មិនប្រសើរឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោធានិ បិត្វាន កិកិកឹ ករោសិ** សេចក្ដីថា ឥឡូវនេះឯងផឹកទឹកដែលអញឲ្យហើយគងធ្វើមុខ ធ្វើមាត់បញ្ចេញសំឡេងកិកិដាក់អញទៅវិញ ។ បទថា **ន សង្គមោ ចាបជនេន សេយ្យោ** សេចក្ដីថា ការសេពគប់ជាមួយបុគ្គលអាក្រក់មិនល្អឡើយ មិនសេពគប់នោះឯងល្អជាង ស្វាដែលទ្រុស្តមិត្តនោះកាលបានឮដូច្នោះហើយទើបពោលថា អ្នកកុំសម្គាល់ថាខ្ញុំធ្វើប៉ុណ្ណោះហើយឈប់នោះ ឥឡូវនេះខ្ញុំនឹងជុះអាចម៍ដាក់ក្បាលអ្នកហើយសឹមទៅរួចពោលគាថាទីពីរថា

អ្នកឯងដែលបានឮឬបានឃើញថា ស្វាណាមានសីលធម៌
ឥឡូវនេះ យើងបន្ទោបង់វច្ចៈលើក្បាលរបស់អ្នកឯង នេះជា
ធម្មតារបស់ពួកយើង ដូច្នេះ ។

សេចក្ដីសង្ខេបក្នុងគាថានោះមានដូច្នេះថា នែព្រាហ្មណ៍ អ្នកឯងបានឮឬបានឃើញក្នុងទីណាថា ស្វាដឹងគុណមនុស្ស មានមារយាទ មានសីលនោះ ។ ខ្ញុំនឹងបន្ទោបង់លាមកដាក់ក្បាលអ្នកឥឡូវនេះឯងហើយសឹមទៅ នេះជាធម្មតាជាសភាវៈធម្មជាតិរបស់ពួកខ្ញុំ បុគ្គលឈ្មោះថាជាស្វា គឺបន្ទោបង់លាមកដាក់ក្បាលអ្នកមានឧបការៈ ។

ព្រះពោធិសត្វកាលបានឮដូច្នោះទើបត្រៀមនឹងក្រោកទៅ ខណៈនោះឯងស្វាលោតចាប់មែកឈើយោលទៅយោលមក បន្ទោបង់លាមក ដាក់ក្បាលព្រះពោធិសត្វ ស្រែកហើយក៏ចូលទៅកាន់ព្រៃ ព្រះពោធិសត្វងូតទឹកជម្រះ

កាយរូបទើបត្រឡប់ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនដឹងគុណតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏មិនដឹងគុណដែលតថាគតធ្វើដូចគ្នា ហើយទ្រង់នាំព្រះធម្មទេសនានេះមក ទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ឯព្រាហ្មណ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទុតិយមក្កដជាតក ចប់

# អាទិច្ចុបដ្ឋានជាតក

[ ១៩៩ ] ( ពួកមនុស្សពោលថា ) បានឮថា បណ្ដាពួកសត្វទាំងអស់ ( មានពួកសត្វខ្លះ ) ប្រកបដោយសីលធម៌ អ្នកចូរមើលស្វាដ៏លាមកដែលកំពុងឈរទមស្ការព្រះអាទិត្យ ។

[ ២០០ ] ( តាបសពោធិសត្វពោលថា ) អ្នកទាំងឡាយមិនបានដឹងច្បាស់នូវមារយាទរបស់ស្វានេះទេ  អ្នកទាំងឡាយពោលសរសើរស្វាព្រោះមិនដឹងស្វានោះដុតនូវរោងបូជាភ្លើងផង ទម្លាយនូវក្អមទឹកពីរផង ។

**ចប់ អាទិច្ចុបដ្ឋានជាតកទី ៥ ។**

## អដ្ឋកថា

## អាទិច្ចុបដ្ឋានជាតក

[ ១៩៩-២០០ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សព្វេសុ កិរ ភូតេសុ** ដូច្នេះជាដើម ។

រឿងដូចគ្នានឹងរឿងពោលហើយខាងដើម ។

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ដែនកាសី  ចម្រើនវ័យបានសិក្សាសិល្បៈក្នុងនគរតក្កសិលា បួសជាឥសីញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើត មានបរិវារច្រើន ជាគ្រូនៃគណៈអាស្រ័យនៅក្នុងព្រៃហិមពាន្ត ។ ព្រះពោធិសត្វ

នៅក្នុងព្រៃហិមពាន្តនោះអស់កាលយូរ ទើបចុះអំពីភ្នំ ដើម្បីបរិភោគរសជូរប្រៃ នៅអាស្រ័យស្រុកមួយក្នុងជាយដែន ស្នាក់នៅត្រង់បណ្ណសាលា ។ ខណៈនោះមានស្វាអន្តត់មួយ កាលគណៈឥសីទៅបិណ្ឌបាត ក៏មកកាន់អាស្រមបទ បោចស្បូវដែលប្រក់សាលា ចាក់ទឹកក្នុងក្អមចោល វាយបំបែកក្អមទឹក បន្ទោបង់លាមកដាក់រោងភ្លើង ។ តាបសទាំងឡាយនៅចាំវស្សាហើយត្រិះរិះថា ឥឡូវនេះព្រៃហិមពាន្តបរិបូណ៌ដោយផ្កានិងផ្លែឈើគួរជាទីត្រេកអរ ពួកយើងនឹងទៅក្នុងទីនោះទើបលាអ្នកស្រុកជាយដែន ។ ពួកមនុស្សពោលថា បពិត្រលោកម្ចាស់ ស្អែកនេះពួកខ្ញុំនឹងនាំកិក្ខាមកកាន់អាស្រមបទ លោកម្ចាស់ឆាន់អាហារហើយសឹមទៅ ។ ក្នុងថ្ងៃទី ២ ក៏នាំរបស់ទំពា របស់ឆាន់ជាច្រើនទៅក្នុងទីនោះទៀត ។ ស្វាអន្តត់ឃើញដូច្នោះគិតថា អញនឹងបោកបញ្ឆោតឲ្យមនុស្សជ្រះថ្លានាំរបស់ទំពា របស់បរិភោគមកឲ្យអញ ទើបធ្វើជាបំពេញតបៈនិងដូចរក្សាសីល ឈរនមស្ការព្រះអាទិត្យក្នុងទីមិនឆ្ងាយអំពីតាបសទាំងឡាយ ។ ពួកមនុស្សឃើញដូច្នោះហើយ ទើបនាំគ្នាពោលថា បុគ្គលដែលនៅក្បែរអ្នកមានសីល រមែងជាអ្នកមានសីលហើយពោលបឋមគាថាថា

> បានឮថា បណ្តាពួកសត្វទាំងអស់ ( មានពួកសត្វខ្លះ )
> ប្រកបដោយសីលធម៌ អ្នកចូរមើលស្វាដ៏លាមក ដែលកំពុង
> ឈរនមស្ការព្រះអាទិត្យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តិ សីលសមាហិតា** បានដល់ អ្នក

មានចិត្តតាំងមាំ គឺប្រកបដោយសីល អធិប្បាយថា ជាអ្នកមានសីលនិងមានចិត្តតាំងមាំមានអារម្មណ៍តែមួយ ។ បទថា **ជម្មំ** គឺ លាមក ។ បទថា **អាទិច្ចមុបតិដ្ឋតិ** សេចក្តីថា ស្វាឈរនមស្ការព្រះអាទិត្យ ។

ព្រះពោធិសត្វឃើញពួកមនុស្សទាំងនោះសរសើរគុណរបស់ស្វានោះ ក៏ពោលថា អ្នកទាំងឡាយមិនបានដឹងច្បាស់នូវសីលនិងមារយាទរបស់ស្វាអន្ធត់នេះទេហើយជ្រះថ្លាក្នុងវត្ថុដែលមិនមែនជាហេតុទើបពោលគាថាទីពីរថា

អ្នកទាំងឡាយ មិនបានដឹងច្បាស់នូវមារយាទរបស់ស្វានេះទេ
អ្នកទាំងឡាយពោលសរសើរស្វា ព្រោះមិនដឹងស្វានោះដុតនូវ
រោងបូជាភ្លើងផង ទម្លាយនូវក្អមទឹកពីរផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនញ្ញាយ** ប្រែថា មិនដឹង ។ បទថា **ឧហានំ** បានដល់ ការបន្តហេតុដែលស្វាអាក្រក់នេះធ្វើ ។ បទថា **កមណ្ឌលូ** បានដល់ ក្អមទឹក ។ ព្រះពោធិសត្វពោលទោសស្វាយ៉ាងនេះថា ស្វានេះវាយបំបែកក្អមទឹកអស់ពីរ ។

ពួកមនុស្សកាលដឹងថាជាស្វាបោកប្រាស់ ទើបទាញដុំដី និងដំបងដេញស្វានោះឲ្យរត់ទៅ ហើយប្រគេនភិក្ខាដល់ពួកឥសី ។ សូម្បីឥសីទាំងឡាយក៏នាំគ្នាទៅកាន់ព្រៃហិមពាន្ត ធ្វើឈានមិនឲ្យវិនាស មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមក ហើយទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះ បានមកជាភិក្ខុហាកនេះឯង ពួកឥសីក្នុងកាលនោះបានមកជាពុទ្ធ

បរិស័ទ ឯគ្រូប្រចាំគណៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អាទិច្ចុបដ្ឋានជាតក ចប់

## កន្ឡាយមុដ្ឋិជាតក

[ ២០១ ] ( អាមាត្យពោធិសត្វក្រាបទូលថា ) បពិត្រព្រះអង្គជាធំជាងជនស្វានេះល្ងង់ ប្រាជ្ញារបស់វាមិនមានទេ វាបានបាចសណ្តែកមួយកម្បង់ចោលអស់ទើបទៅស្វែងរកសណ្តែកមួយគ្រាប់ដែលជ្រុះទៅ ។

[ ២០២ ] បពិត្រព្រះរាជា យើងខ្ញុំទាំងឡាយក្តី ជនទាំងឡាយដទៃដែលល្មោភក្រៃលែងក្តី គប្បីលះបង់របស់ច្រើនព្រោះរបស់តិច ដូចជាស្វាកាលលះបង់សណ្តែកច្រើនព្រោះសណ្តែកតិចដូច្នោះឯង ។

**ចប់ កន្ឡាយមុដ្ឋិជាតកទី ៦ ។**

## អដ្ឋកថា

## កន្ឡាយមុដ្ឋិជាតក

[ ២០១-២០២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពាលោ វតាយំ ទុមសាខគោចរោ** ដូច្នេះជាដើម ។

រឿងពិស្តារថា សម័យមួយក្នុងរដូវភ្លៀងនៅឯជាយដែនរបស់ស្តេចកោសលមានការបះបោរ ពួកអ្នកចម្បាំងដែលនៅឯជាយដែននោះបានធ្វើការច្បាំងអស់វារៈ ២-៣ ដងក៏មិនអាចយកឈ្នះសត្រូវបានទើបថ្វាយដំណឹងឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាយាងចេញក្នុងរដូវភ្លៀងដែលមិនគួរដល់កាលវេលាទើបទ្រង់បោះព្រះពន្លាក្បែរវត្តជេតពនទ្រង់ត្រិះរិះថា អញចេញដំណើរ

ក្នុងកាលដែលមិនសមគួរ ញកក្ដីនិងជ្រោះជាដើមពេញដោយទឹក ផ្លូវធ្វើដំណើរក៏លំបាក អញនឹងចូលគាល់ព្រះសាស្ដាទ្រង់នឹងត្រាស់សួរអញថា មហាបពិត្រយាងទៅណា អញនឹងក្រាបទូលរឿងឲ្យទ្រង់ជ្រាប ព្រះសាស្ដាទ្រង់អនុគ្រោះដល់អញចំពោះប្រយោជន៍ខាងមុខប៉ុណ្ណោះក៏មិនមែនប្រយោជន៍ក្នុងបច្ចុប្បន្នក៏ទ្រង់អនុគ្រោះដូចគ្នា ព្រោះហេតុនោះប្រសិនបើអញទៅមិនចម្រើនទ្រង់នឹងត្រាស់ថា មហាបពិត្រ មិនទាន់ដល់កាលនឹងទ្រង់យាងទៅ បើមានសេចក្ដីចម្រើនទ្រង់នឹងនៅស្ងៀម ទើបចូលទៅកាន់វត្តជេតពនហើយថ្វាយបង្គំព្រះសាស្ដា ប្រថាប់គង់ក្នុងចំណែកម្ខាង ។ ព្រះសាស្ដា ទ្រង់ធ្វើបដិសណ្ឋារៈហើយត្រាស់សួរថា មហាបពិត្រ ទ្រង់យាងទៅណាទាំងកណ្ដាលថ្ងៃ ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចេញទៅបង្ក្រាបការបះបោរនៅឯជាយដែន មកនេះដោយគិតថានឹងថ្វាយបង្គំព្រះអង្គហើយទៅ ។ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ក្នុងកាលមុនព្រះរាជាទាំងឡាយកាលនឹងលើកទ័ពទៅបានស្ដាប់ពាក្យរបស់បណ្ឌិតហើយ ក៏មិនយាងទៅក្នុងកាលដែលមិនសមគួរ កាលព្រះរាជាអារាធនាទើបទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាអាមាត្យសម្រេចរាជកិច្ចទូទៅជាធម្មានុសាសកៈ គឺជាអ្នកបង្រៀនធម៌របស់ព្រះរាជាអង្គនោះ ។ កាលនោះជាយដែនរបស់ព្រះអង្គកើតនូវការបះបោរ ទាហានត្រង់ជាយដែនបញ្ជូនសាសន៍ឲ្យទ្រង់ជ្រាប ព្រះ

រាជាយាងចេញទៅក្នុងរជ្ជរភ្លៀង ប្រោះបន្ទាយក្នុងព្រះរាជឧទ្យាន ។ ព្រះពោធិសត្វនៅក្នុងទីជិតព្រះរាជា ។ ពួកទាហាននាំសណ្តែកខ្មៅដែលជាអាហាររបស់សេះមកដាក់ក្នុងស្នូក បណ្តាស្វាទាំងឡាយក្នុងព្រះរាជឧទ្យាន មានស្វាមួយ ចុះពីលើដើមឈើចក់យកសណ្តែកខ្មៅអំពីស្នូកនោះដាក់ក្នុងមាត់រហូតពេញហើយកើបយកមួយកម្សង់ទៀត លោតឡើងទៅអង្គុយលើដើមឈើចាប់ផ្តើមស៊ី កាលសណ្តែកខ្មៅមួយគ្រាប់ជ្រុះអំពីដៃលើផែនដី ស្វាចោលសណ្តែកទាំងអស់ដែលនៅក្នុងដៃ និងនៅក្នុងមាត់ ចុះអំពីដើមឈើស្វែងរកសណ្តែកមួយគ្រាប់ដែលជ្រុះទៅនោះ កាលរកមិនឃើញទើបឡើងដើមឈើអង្គុយស្ងប់សៅទោមនស្ស មានមុខស្រពោនលើមែកឈើដូចអ្នកចាញ់ក្តី ១០០០ ជង ។

ព្រះរាជាទតឃើញកិរិយារបស់ស្វាទើបហៅព្រះពោធិសត្វ ហើយត្រាស់សួរថា មើលចុះលោកអាចារ្យ ស្វានេះកំពុងធ្វើអ្វី ព្រះពោធិសត្វទូលថា បពិត្រមហារាជ បុគ្គលល្ងង់ខ្លៅអប្បឥតប្រាជ្ញាមិនមើលឃើញរបស់ច្រើន ឃើញតែរបស់តិចតួចរមែងធ្វើដូច្នេះឯងហើយពោលគាថាដំបូងថា

> បពិត្រព្រះអង្គជាធំជាងជន ស្វានេះល្ងង់ ប្រាជ្ញារបស់វាមិន
> មានទេ វាបានបាចសណ្តែកមួយកម្សង់ចោលអស់ ទើបទៅ
> ស្វែងរកសណ្តែកមួយគ្រាប់ដែលជ្រុះទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុមសាខគោចរោ** បានដល់ ស្វា ។ ព្រោះស្វានោះស្វែងរកអាហារលើមែកឈើ មែកឈើទាំងនោះជាគោចរ គឺជាទី

គ្រាប់ទៅមករបស់ស្វាព្រោះហេតុនោះទើបហៅថា **ឩមសាខគោចរោ** ។ ព្រះពោធិសត្វហៅព្រះរាជាថា **ជនិន្ទ** ព្រោះព្រះរាជាឈ្មោះថា ជាកំពូលនៃនរជនព្រោះភាពជាធំក្រៃលែង ។ បទថា **កឡាយមុដ្ឋិ** បានដល់ សណ្តែកមួយកម្បង់កេចិអាចារ្យពោលថា **កាឡរាជមាសមុដ្ឋិ** គឺ សណ្តែកខ្មៅ សណ្តែករាជមាសមួយកម្បង់ក៏មាន ។ បទថា **អវកិរិយ** បានដល់ បាចចោល ។ បទថា **កេវលំ** គឺ ទាំងអស់ ។ បទថា **គវេសតិ** គឺ ស្វែងរកសណ្តែកមួយគ្រាប់ដែលធ្លាក់លើផែនដី ។

កាលព្រះពោធិសត្វក្រាបទូលយ៉ាងនេះហើយ ទើបចូលទៅកាន់ទីនោះប្រាស្រ័យជាមួយព្រះរាជាហើយពោលគាថាទីពីរថា

បពិត្រព្រះរាជា យើងខ្ញុំទាំងឡាយក្តី ជនទាំងឡាយដទៃ
ដែលល្មោភក្រៃលែងក្តី គប្បីលះបង់របស់ច្រើន ព្រោះរបស់
តិចដូចជាស្វាកាលលះបង់សណ្តែកច្រើន ព្រោះសណ្តែកតិច
ដូច្នោះឯង ។

សេចក្តីសង្ខេបក្នុងគាថានោះមានដូច្នេះថា ព្រះពោធិសត្វថ្វាយឱវាទដល់ព្រះរាជាថា បពិត្រមហារាជ ពួកយើងក្តី ពួកជនដទៃដែលត្រូវលោភៈគ្របសង្កត់ក្តី ជនទាំងអស់នោះ រមែងសាបសូន្យចាករបស់ច្រើនព្រោះរបស់តិចដ្បិតថា ឥឡូវនេះពួកយើងធ្វើដំណើរទៅក្នុងផ្លូវវៀង មិនមែនជាកាលសមគួររមែងសាបសូន្យចាកប្រយោជន៍ច្រើនព្រោះប្រយោជន៍តូចតាច ។ បទថា **ក-ឡាយេនេវវានរោ** សេចក្តីថា ដូចស្វានេះ ស្វែងរកសណ្តែកមួយគ្រាប់

សាបសូន្យហើយចាកសំណ្តែកជាច្រើនព្រោះសំណ្តែកមួយគ្រាប់នោះយ៉ាងណា សូម្បីពួកយើងក្នុងឥឡូវនេះក៏យ៉ាងនោះ កំពុងទៅក្នុងទីដែលពេញដោយញកក្ដំនិងជ្រោះជាដើម ដោយមិនមែនកាលស្វែងរកប្រយោជន៍តិចតួចនឹងសាបសូន្យចាកពាហនៈមានដំរីនិងសេះជាដើមជាច្រើននិងពួកអ្នកចម្បាំង ព្រោះដូច្នោះមិនគួរទៅក្នុងកាលដែលមិនមែនជាកាល ។

ព្រះរាជាស្ដាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយយាងត្រឡប់អំពីទីនោះចូលកាន់ព្រះនគរពារាណសីក្នុងកាលនោះឯង ។ ពួកចោរបានដំណឹងថា ព្រះរាជាយាងចេញអំពីព្រះនគរដោយព្រះបំណងបង្រ្កាបពួកខ្លួន ទើបនាំគ្នាគេចចេញអំពីជាយដែននោះទៅ ។

ក្នុងបច្ចុប្បន្នពួកចោរបានឮថា ព្រះរាជាដែនកោសលយាងចេញ ទើបនាំគ្នាគេចទៅ ។ ព្រះរាជាស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ ទ្រង់ក្រោកចាកទីប្រថាប់ថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណ ត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញ ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯអាមាត្យជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កឡាយមុដ្ឋិជាតក ចប់

## តិន្ទុកជាតក

[ ២០៣ ] ( ពួកស្វាពោលថា ) យើងត្រូវពួកមនុស្សមានធ្នូនិងបំពង់ព្រួញក្នុងដៃ កាន់ដាវដ៏មុតព័ទ្ធជុំវិញហើយធ្វើម្ដេចនឹងរួចខ្លួនបាន ។

[ ២០៤ ] ( ស្វាពោធិសត្វពោលថា ) សេចក្ដីត្រូវការនីមួយ គប្បីកើតឡើងដល់ពួកមនុស្ស ដែលមានកិច្ចច្រើនដោយពិត ផ្លែឈើច្រើនយើងរើសប្រមូលមកហើយ អ្នកទាំងឡាយចូរនាំគ្នាស៊ីនូវផ្លែទន្ទាប់នោះចុះ ។

**ចប់ តិន្ទុកជាតកទី ៧ ។**

## អដ្ឋកថា

## តិន្ទុកជាតក

[ ២០៣-២០៤ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ធនុហត្ថកលាបេហិ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ព្រះសាស្ដាកាលទ្រង់ស្ដាប់វាចាពណ៌នាគុណនៃបញ្ញារបស់ព្រះអង្គដូចក្នុងមហាពោធិជាតកនិងឧម្មង្គជាតក ( មហោសធជាតក ) ហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមានបញ្ញាមិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុនក៏មានបញ្ញានិងឈ្លាសក្នុងឧបាយដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វកើតក្នុងកំណើតពានរ មានស្វា ៨០០០០ ជាបរិវារនៅអាស្រ័យក្នុងហិមវន្តប្បទេស ។ ក្បែរហិមវន្តប្បទេសនោះមានស្រុកជាយដែនមួយជួនកាលមានមនុស្សរស់នៅ ជួនកាលក៏មិនមានមនុស្សរស់នៅ ។ ត្រង់កណ្តាលស្រុកនោះមានដើមទន្លាប់មួយដើម មានមែកនិងប្រគាបបរិបូណ៌ផ្លែមានរសឆ្ងាញ់ ។ ហ្វូងស្វានាំគ្នាមកស៊ីផ្លែទន្លាប់នោះក្នុងកាលដែលមិនមានមនុស្សរស់នៅ ក្នុងកាលតមកក្នុងរដូវដែលមានផ្លែ ស្រុកនោះក៏មានមនុស្សរស់នៅ ផ្ទះនៃមនុស្សរៀង ៗ គ្នា ពួកមនុស្សប្រកបទ្វារធ្វើអំពីដើមបបុស ។ ដើមទន្លាប់នោះ ក៏ចេញផ្លែមែកក៏ទោរទន់ ។ ហ្វូងស្វាគិតថា ពីមុនយើងស៊ីផ្លែទន្លាប់ត្រង់ស្រុកនោះ ឥឡូវនេះ ទន្លាប់នោះមានផ្លែឬនៅហ្ន៎ ស្រុកនោះមានមនុស្សរស់នៅឬហ្ន៎ កាលគិតដូច្នេះហើយ ទើបបញ្ជូនស្វាមួយទៅប្រាប់ថា ឯងចូរទៅស៊ើបមើល ។ ស្វានោះ ទៅស៊ើបមើលដឹងថា ឈើនោះចេញផ្លែហើយមានមនុស្សរស់នៅ ទើបវិលមកប្រាប់ពួកស្វា ។ ពួកស្វាបានឮថា ដើមឈើនោះចេញផ្លែ កើតនូវឧស្សាហៈថានឹងស៊ីផ្លែទន្លាប់ដែលមានរសឆ្ងាញ់ ទើបប្រាប់សេចក្តីនោះដល់ស្តេចពានរ ។ ស្តេចស្វាសួរថា ស្រុកនោះមានមនុស្សរស់នៅឬ ស្វាប្រាប់ថា មានលោកម្ចាស់ ។ ស្តេចពានរប្រាប់ថា បើដូច្នោះកុំទៅ ព្រោះពួកមនុស្សមានល្បិចច្រើន ។ ពួកស្វាពោលថា បពិត្រលោកម្ចាស់ យើងនឹងស៊ីក្នុងពេលយប់ ក្នុងកាលដែលពួកមនុស្សដេកលក់ស៊ប់ លុះស្តេចពានរយល់ព្រមហើយទើបចេញអំពីព្រៃហិមពាន្ត ដេកលើផ្ទាំងថ្មធំមិនឆ្ងាយអំពីស្រុកនោះ រង់ចាំពេលដែលពួកមនុស្សដេកលក់ស៊ប់ ។ លុះ

មជ្ឈិមយាមចូលមកដល់ ពួកមនុស្សដេកលក់ស៊ប់ទើបនាំគ្នាឡើងដើមទទ្លាប់ហើយស៊ីផ្លែ ។ ពេលនោះបុរសម្នាក់ចេញអំពីផ្ទះទៅបន្ទោបង់ឧច្ចារៈ ដល់កណ្តាលស្រុកឃើញពួកស្វាក៏បន្លឺកប្រាប់ពួកមនុស្ស ពួកមនុស្សជាច្រើនទាញធ្នូនិងព្រួញ កាន់អាវុធផ្សេងៗ មួយអន្លើដោយដុំដីនិងដំបងជាដើមនាំគ្នាឈរព័ទ្ធដើមឈើដោយបំណងថានឹងចាប់ពួកស្វា ។

ហ្វូងស្វាទាំង ៨០០០០ ឃើញពួកមនុស្សកើតភ័យខ្លាចសេចក្តីស្លាប់នាំគ្នាទៅរកស្តេចពានរដោយគិតថា ក្រៅអំពីស្តេចពានរហើយមិនមានអ្នកដទៃជាទីពឹងរបស់ពួកយើងឡើយហើយពោលគាថាជំបូងថា

យើងត្រូវពួកមនុស្ស មានធ្នូ និងបំពង់ព្រួញក្នុងដៃកាន់ដាវដ៏មុតព័ទ្ធជុំវិញហើយ ធ្វើម្តេចនឹងរួចខ្លួនបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធនុហត្ថកលាបេហិ** សេចក្តីថា មានដៃកាន់ធ្នូនិងបំពង់ព្រួញ អធិប្បាយថា កាន់ធ្នូនិងបំពង់ព្រួញឈរព័ទ្ធជុំវិញ ។ បទថា **បរិកិណ្ណាម្ហា** បានដល់ ព័ទ្ធជុំវិញហើយ ។ បទថា **កថំ** បានដល់ ពួកយើងនឹងរួចផុតបានដោយឧបាយដូចម្តេចហ្ន៎ ។

ស្តេចពានរបានស្តាប់ពាក្យរបស់ស្វាទាំងនោះហើយលួងលោមពួកស្វាថា ពួកអ្នកកុំខ្លាចឡើយព្រោះថា ពួកមនុស្សមានការងារច្រើន ថ្ងៃនេះទើបតែមជ្ឈិមយាម ជួនកាលពួកមនុស្សឈរព័ទ្ធយើង ដោយគិតថានឹងសម្លាប់ពួកយើង កិច្ចដទៃដែលធ្វើឲ្យអន្តរាយដល់កិច្ចនេះគប្បីកើតឡើង រួចពោលគាថាទីពីរថា

សេចក្តីត្រូវការនីមួយ គប្បីកើតឡើងដល់ពួកមនុស្ស ដែល
មានកិច្ចច្រើនដោយពិត ផ្លែឈើច្រើន យើងរើសប្រមូលមក
ហើយ អ្នកទាំងឡាយចូរនាំគ្នាស៊ីនូវផ្លែទន្ទាប់នោះចុះ ដូច្នេះ ។

បទថា **ឆំ** ត្រឹមតែជានិបាត ។ ក្នុងបទនេះមានអធិប្បាយថា ជួនកាល សេចក្តីត្រូវការណាមួយដទៃ គប្បីកើតឡើងដល់ពួកមនុស្សដែលមានកិច្ចច្រើន ។ បទថា **អត្ថិ រុក្ខស្ស អច្ចិន្នំ** សេចក្តីថា មានឱកាសដែលដណ្តើមយកមកស៊ីបាន ដោយអំណាចនៃការប្រមូលយកផ្លែរបស់ឈើទាំងនេះ ។ បទថា **១៨ តញ្ចោវ តិន្ទុកំ** សេចក្តីថា ពួកអ្នកចូរស៊ីផ្លែទន្ទាប់នេះចុះ គឺពួកអ្នកមានសេចក្តីត្រូវការប៉ុនណា ចូរស៊ីប៉ុណ្ណោះចុះ យើងនឹងដឹងក្នុងកាលដែលគេប្រហារពួកយើង ។

ព្រះមហាសត្វលួងលោមពួកស្វាព្រោះថា កាលពួកស្វាមិនបានការលួងលោមដូច្នេះនឹងបែកបេះដូងស្លាប់ ។ មហាសត្វលួងលោមស្វាយ៉ាងនេះហើយពោលថា ពួកអ្នកចូររាប់ស្វាទាំងអស់មើល កាលពួកស្វារាប់ ក៏មិនឃើញស្វាឈ្មោះសេនកៈដែលជាក្មួយរបស់ស្តេចពានរ ទើបប្រាប់ថា សេនកៈមិនបានមក ។ ស្តេចពានរពោលថា បើសេនកៈមិនមកពួកអ្នកមិនបាច់ខ្លាចឡើយ សេនកៈនោះនឹងធ្វើនូវការផុតភ័យឲ្យដល់ពួកអ្នកក្នុងឥឡូវនេះ ។

សេនកៈដេកលក់ក្នុងពេលដែលហ្វូងស្វាមក ភ្ញាក់ឡើងមិនឃើញស្វាណាមួយ ទើបដើរតាមស្នាមជើងមកឃើញពួកមនុស្សទើបដឹងថា ភ័យកើតឡើងដល់ហ្វូងស្វាហើយ ទើបទៅរកស្រីចាស់ដែលដុតភ្លើងរវៃអំបោះនៅផ្ទះខាងចុង

គេមួយខ្នង ហើយធ្វើដូចជាក្មេងអ្នកស្រុកដើរទៅដើរមក ចាប់អង្កត់ឧស ដែលមានភ្លើងមួយរត់ទៅដុតផ្ទះដែលនៅខាងលើខ្យល់ ពួកមនុស្សនាំគ្នាចោល ពួកស្វាទៅលត់ភ្លើង ។ ស្វាទាំងឡាយក៏នាំគ្នាបេះផ្លែទន្ទាប់ម្នាក់មួយផ្លែដើម្បី យកទៅឲ្យសេនកៈហើយនាំគ្នាគេចចេញទៅ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សេនកៈក្នុយស្តេចពានរក្នុងកាលនោះ បានមកជាមហានាមសក្យៈក្នុងកាល ឥឡូវនេះ ពួកស្វាក្នុងកាលនោះបានមកជាពុទ្ធបរិស័ទ ស្តេចពានរក្នុងកាល នោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តិន្ទុកជាតក ចប់

## កច្ចបជាតក

[ ២០៥ ] ( *អណ្តើកនិយាយថា* ) *ខ្ញុំនៅក្នុងភក់ដោយគិតថា ខ្ញុំកើតហើយ ខ្ញុំចម្រើនហើយ ( ក្នុងទីនេះ ) ភក់បានកប់សង្កត់ខ្ញុំនោះធ្វើឲ្យទុព្វលភាព បពិត្រភគ្គវៈ ខ្ញុំសូមពោលនូវហេតុនោះនឹងអ្នក អ្នកចូរស្តាប់នូវពាក្យខ្ញុំចុះ ។*

[ ២០៦ ] *បុគ្គលបានសេចក្តីសុខក្នុងទីណា ទោះក្នុងស្រុកឬក្នុងព្រៃ ទីនោះហើយជាទីកើត ជាទីចម្រើនរបស់បុរសជាអ្នកដឹង ( នូវប្រយោជន៍និងមិនមែនប្រយោជន៍ ) បុគ្គលគប្បីរស់នៅក្នុងទីណា គប្បីទៅក្នុងទីនោះចុះ កុំគប្បីឲ្យទីដែលធ្លាប់នៅសម្លាប់ខ្លួនបានឡើយ ។*

**ចប់ កច្ចបជាតកទី ៨ ។**

## អដ្ឋកថា

## កច្ចបជាតក

[ ២០៥-២០៦ ] *ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នករួចចាកអហិវាតករោគម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ជនិតំ មេ ភវិតំ មេ** *ដូច្នេះជាដើម ។*

*បានឮថា ក្នុងក្រុងសាវត្ថីបានកើតអហិវាតករោគក្នុងត្រកូលមួយ ទើបមាតាបិតាប្រាប់ដល់កូនថា នែកូន ចូរកូនកុំនៅក្នុងផ្ទះនេះឡើយ ចូរទម្លាយជញ្ជាំងគេចទៅក្នុងទីណាមួយរក្សាជីវិត ខាងក្រោយសឹមត្រឡប់មកជីកទ្រព្យដែលមាតាបិតាកប់ទុកក្នុងទីនេះ ហើយរក្សាទ្រព្យចិញ្ចឹមជីវិតរស់នៅជាសុខចុះ*

កូននោះទទួលពាក្យរបស់មាតាបិតាហើយទម្លាយជញ្ជាំងផ្ទះរត់ទៅ កាលរោគរបស់ខ្លួនស្ងប់ល្អហើយ ទើបត្រឡប់មកជីកយកទ្រព្យដែលកប់ គ្រប់គ្រងផ្ទះជាសុខ ។ ថ្ងៃមួយបុរសនោះឲ្យមនុស្សកាន់សប្បិ ប្រេង សំពត់គ្រឿងស្លៀកដណ្ដប់ជាដើម ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្ដាហើយអង្គុយ ព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈហើយត្រាស់សួរថា បានឮថា អហិវាតករោគកើតឡើងក្នុងផ្ទះរបស់អ្នក អ្នកធ្វើដូចម្ដេចទើបរួចមកបាន បុរសនោះក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្ដាត្រាស់ថា ម្នាលឧបាសក ក្នុងកាលមុនជនទាំងឡាយណា កាលភ័យកើតឡើងធ្វើនូវសេចក្ដីអាល័យក្នុងលំនៅនៃខ្លួនមិនព្រមទៅកាន់ទីដទៃ ជនទាំងនោះដល់នូវការអស់ជីវិតតែជនទាំងឡាយណាមិនធ្វើសេចក្ដីអាល័យ មិនជាប់ជំពាក់ក្នុងលំនៅរបស់ខ្លួនទៅកាន់លំនៅដទៃ ជនទាំងនោះរួចជីវិតហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលស្មូនឆ្នាំងក្បែរភូមិមួយកន្លែង ធ្វើឆ្នាំងចិញ្ចឹមកូនប្រពន្ធ ។ ក្នុងកាលនោះក្បែរក្រុងពារាណសីមានស្រះធំជាប់នឹងស្ទឹងធំ ស្រះនោះមានទឹកហូរជាប់ជាមួយស្ទឹងនោះក្នុងកាលដែលមានទឹកច្រើន ។ កាលទឹកតិចក៏ដាច់អំពីគ្នា ។ ត្រីនិងអណ្ដើករមែងដឹងថា ឆ្នាំនេះភ្លៀងល្អ ឆ្នាំនេះភ្លៀងរាំង ។ ចំណោរតមកត្រីនិងអណ្ដើកដែលកើតក្នុងស្រះនោះដឹងថា ក្នុងឆ្នាំនេះអាកាសធាតុរាំងស្ងួត លុះដល់កាលទឹកហូរជាប់គ្នា ទើបនាំគ្នាចេញពីស្រះ

មកកាន់ស្ទឹងតែអណ្តើកមួយមិនព្រមទៅដោយគិតថា ទីនេះជាមាតុភូមិរបស់អញ ជាទីចម្រើនធំធាត់របស់អញ ជាទីដែលមេបារបស់អញធ្លាប់នៅ អញមិនអាចទៅអំពីទីនេះបានទេ ។ កាលនោះលុះដល់ពេលរាំងស្ងួតទឹកក៏រីងអស់ ។ អណ្តើកនោះ កាយដីចូលទៅក្នុងទីជញ្ជូនដីរបស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វបានទៅក្នុងទីនោះដោយបំណងថានឹងយកដី ទើបយកចបជំកាប់ដី កាប់ត្រូវអណ្តើកហើយយកចបគាស់ឡើងដូចដុំដីបោះទៅលើគោក អណ្តើកនោះទទួលទុក្ខវេទនាទើបសង្រេងសង្រែថា ខ្ញុំមិនអាចលះបង់ទីលំនៅបានទើបដល់នូវសេចក្តីវិនាសយ៉ាងនេះ ហើយបានពោលគាថាទាំងនេះថា

ខ្ញុំនៅក្នុងភក់ដោយគិតថា ខ្ញុំកើតហើយ ខ្ញុំចម្រើនហើយ ( ក្នុងទីនេះ ) ភក់បានកប់សង្កត់ខ្ញុំនោះធ្វើឲ្យទុព្វលភាព បពិត្រភគ្គវៈ ខ្ញុំសូមពោលនូវហេតុនោះនឹងអ្នក អ្នកចូរស្តាប់នូវពាក្យខ្ញុំចុះ ។

បុគ្គលបានសេចក្តីសុខក្នុងទីណា ទោះក្នុងស្រុកឬក្នុងព្រៃ ទីនោះហើយជាទីកើត ជាទីចម្រើនរបស់បុរសជាអ្នកដឹង ( នូវប្រយោជន៍និងមិនមែនប្រយោជន៍ ) បុគ្គលគប្បីរស់នៅក្នុងទីណា គប្បីទៅក្នុងទីនោះចុះ កុំគប្បីឲ្យទីដែលធ្លាប់នៅសម្លាប់ខ្លួនបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជនិតំ មេ ភវិតំ មេ** បានដល់ ទីនេះជាទីកើតរបស់ខ្ញុំ ជាទីចម្រើនរបស់ខ្ញុំ ។ បទថា **ឥតិ បង្កេ អវស្សយឹ** សេចក្តី

ថា ខ្ញុំអាស្រ័យ គឺដេក គឺសម្រេចការនៅក្នុងភក់នេះព្រោះហេតុនេះ ។ បទថា **អជ្ឈគា** បានដល់ គ្របសង្កត់ គឺឲ្យដល់សេចក្ដីវិនាស ។ លោកហៅស្មូនឆ្នាំងថា **ភគ្គវ** ភគ្គវនេះ ជានាមបញ្ញត្តិនិងគោត្តរបស់ស្មូនឆ្នាំង ។ បទថា **សុខំ** បានដល់ សេចក្ដីសុខកាយនិងសុខចិត្ត ។

បទថា **តំ ជនិតំ ភវិតញ្ច** បានដល់ នុ៎ះជាទីកើតនិងជាទីចម្រើនឡើង ។ បទថា **បជានតោ** បានដល់ បុគ្គលដឹងប្រយោជន៍និងមិនមែនប្រយោជន៍ គឺហេតុនិងមិនមែនហេតុ ។ បទថា **ន និកេតហតោ សិយា** បានដល់ ធ្វើនូវការអាល័យក្នុងលំនៅ ហើយមិនទៅកាន់ទីដទៃត្រូវលំនៅសម្លាប់ ។ មិនគួរឲ្យដល់មរណទុក្ខបែបនេះ ។

អណ្ដើកកាលពោលនឹងព្រះពោធិសត្វយ៉ាងនេះហើយក៏អស់ជីវិតទៅ ។ ព្រះពោធិសត្វរើសយកអណ្ដើកទៅហើយ ឲ្យអ្នកស្រុកទាំងអស់មកប្រជុំគ្នា កាលទូន្មានមនុស្សទាំងឡាយទើបពោលយ៉ាងនេះថា ពួកអ្នកចូរមើលអណ្ដើកនេះក្នុងខណៈដែលត្រីនិងអណ្ដើកដទៃៗទៅកាន់ស្ទឹងធំ អណ្ដើកនេះមិនអាចកាត់សេចក្ដីអាល័យក្នុងលំនៅរបស់ខ្លួនបានមិនទៅជាមួយសត្វទាំងនោះ ចូលទៅដេកក្នុងទីជញ្ជូនដីរបស់ខ្ញុំ កាលខ្ញុំជីកដីបានយកចបកាប់ចំខ្នងបោះទៅលើគោកដូចដុំដី អណ្ដើកនេះបានបើកបង្ហាញនូវអំពើដែលខ្លួនធ្វើខ្សឹកខ្សួលដោយគាថា ២ ហើយក៏ស្លាប់ ។ អណ្ដើនេះធ្វើនូវសេចក្ដីអាល័យក្នុងលំនៅរបស់ខ្លួនដល់នូវការអស់ជីវិត ពួកអ្នកកុំធ្វើដូចអណ្ដើកនេះ តាំងអំពីនេះទៅពួកអ្នកកុំប្រកាន់ដោយអំណាចតណ្ហា ដោយអំណាចគ្រឿងឧបភោគនិងបរិភោគ

ថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈរបស់អញ បុត្តរបស់អញ ធីតារបស់អញ ទាសីនិងទាសៈ ប្រាក់មាសជារបស់អញឡើយ សត្វម្នាក់ឯងប៉ុណ្ណោះត្រាច់រង្គាត់ក្នុងភព ៣ ។ ព្រះពោធិសត្វបានឲ្យឱវាទដល់មហាជនដោយពុទ្ធលីលាដោយប្រការដូច្នេះ ឱវាទនោះផ្សាយទៅពេញជម្ពូទ្វីប តាំងនៅអស់កាលប្រមាណ ៧០០០ ឆ្នាំ មហាជនតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វធ្វើកុសលមានទានជាដើម ធ្វើផ្លូវទៅកាន់ស្ថានសួគ៌ឲ្យបរិបូណ៌ក្នុងកាលអស់អាយុ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសអរិយសច្ច កាលចប់អរិយសច្ច កុលបុត្តនោះតាំងនៅក្នុងសោតាបត្តិផល ទ្រង់ប្រជុំជាតកថា អណ្ដើកក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯស្ដេចក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កច្ឆបជាតក ចប់

## សតធម្មជាតក

[ ២០៧ ] ( មាណពឈ្មោះសតធម្មៈពោលថា ) ( អាហារណាដែលបានបរិភោគហើយ ) បាយនោះជារបស់តិចផង សល់ដែលផង បុរសចណ្ឌាលបានឲ្យបាយនោះដល់យើងដោយសេចក្តីពិបាក យើងប្រកបដោយជាតិជាព្រាហ្មណ៍ អាហារណាដែលយើងបានបរិភោគហើយអាហារនោះឯងក៏ក្អួតចេញមក ។

[ ២០៨ ] ( ព្រះសាស្តាត្រាស់ថា ) ភិក្ខុណាលះបង់នូវធម៌ គឺអាជីវ-បារិសុទ្ធិសីលហើយចិញ្ចឹមជីវិតដោយខុសធម៌យ៉ាងនេះ ភិក្ខុនោះមិនត្រេកអរដោយលាភដែលខ្លួនបានហើយដូចជាសតធម្មមាណព ។

**ចប់ សតធម្មជាតកទី ៩ ។**

## អដ្ឋកថា

## សតធម្មជាតក

[ ២០៧-២០៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការស្វែងរកមិនប្រពៃ ២១ ប្រការ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តញ្ច អប្បញ្ច ឧច្ឆិដ្ឋំ** ដូច្នេះជាដើម ។

រឿងពិស្តារថា សម័យមួយភិក្ខុជាច្រើនសម្រេចជីវិតដោយការស្វែងរកមិនគួរ ២១ យ៉ាង មានការធ្វើគ្រូហ្ម ធ្វើជាទូតបញ្ជូនដំណឹង ទទួលបម្រើឲ្យឈើស្ទន់ ឲ្យឫស្សី ឲ្យផ្កា ឲ្យផ្លែឈើ ឲ្យលម្អិតសម្រាប់លាប ឲ្យគុរុកណ្ឋ

ឲ្យថ្នាំ ឲ្យបិណ្ឌបាត ។ អនេសនៈនោះមានច្បាស់ក្នុងសាកេតជាតក[១] ឯណោះ ។

ព្រះសាស្តាទ្រង់ជ្រាបការចិញ្ចឹមជីវិតរបស់ភិក្ខុទាំងនោះ ទ្រង់ព្រះតម្រិះថា ឥឡូវនេះភិក្ខុជាច្រើនញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដោយការស្វែងរកមិនប្រសើរ កាលសម្រេចជីវិតយ៉ាងនេះហើយនឹងមិនផុតភាពជាយក្ខ ជាប្រេត នឹងកើតជាគោអូសរទេះ នឹងកើតក្នុងនរក គួរ គថាគតគួរពោលធម្មទេសនាណាមួយ ដែលជាអធ្យាស្រ័យរបស់ខ្លួនដើម្បីឲ្យកើតបញ្ញា ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខរបស់ពួកភិក្ខុទាំងនោះ ហើយត្រាស់ឲ្យហៅពួកភិក្ខុប្រជុំគ្នាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនគួរឲ្យបច្ច័យកើតឡើងដោយការស្វែងរកមិនគួរ ២១ យ៉ាង ព្រោះបិណ្ឌបាតដែលកើតឡើងដោយការស្វែងរកមិនគួរដូចជាដុំលោហៈក្តៅ ថ្នាំពិសដែលមានពិសដ៏ពន្លឹក ពិតហើយការស្វែងរកមិនគួរនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងសាវ័ករបស់ព្រះពុទ្ធតិះដៀលជំទាស់ កាលភិក្ខុបរិភោគបិណ្ឌបាតដែលកើតឡើងដោយការស្វែងរកដែលមិនគួរ នឹងមិនមានការត្រេកអរឬសោមនស្សឡើយព្រោះថា បិណ្ឌបាតដែលកើតឡើងយ៉ាងនេះដូចគ្នានឹងអាហារសំណល់របស់មនុស្សចណ្ឌាល ។ ក្នុងសាសនាតថាគត ការបរិភោគបិណ្ឌបាតនោះរមែងដូចមាណពឈ្មោះសតធម្មបរិភោគអាហារសល់ដែល របស់មនុស្សចណ្ឌាលដូច្នោះ ហើយទ្រង់នាំយក

---

១-ក្នុងសាកេតជាតកមិនឃើញពោលអំពីអនេសនៈ ២១ ប្រហែលជានៅក្នុងជាតកឬសូត្រដទៃទេដឹងតែក្នុងបាលីរបស់អដ្ឋកថាលោកពោលទុកយ៉ាងនេះ ។

រឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងកំណើតមនុស្សចណ្ឌាល ចម្រើនវ័យដោយលំដាប់ ។ បានត្រៀមអង្ករជាស្បៀងនិងកញ្ចប់បាយធ្វើដំណើរទៅដោយករណីយកិច្ចឯណាទីមួយ ។ ក្នុងកាលនោះក្នុងនគរពារាណសីមានមាណពម្នាក់ឈ្មោះ សតធម្ម កើតក្នុងត្រកូលព្រាហ្មណមហាសាលឧទិច្ចគោត្ត ។ មាណពនោះមិនបានត្រៀមស្បៀងសម្រាប់ដើរផ្លូវទេ ធ្វើដំណើរទៅដោយកិច្ចឯណាទីមួយ ជនទាំង ២ បានជួបគ្នាក្នុងត្រង់ផ្លូវធំ ។ ទើបមាណពសួរព្រះពោធិសត្វថា អ្នកមានជាតិអ្វី មាណពប្រាប់ថា ខ្ញុំជាចណ្ឌាល ហើយសួរមាណពថា ចុះលោកជាជាតិអ្វី មាណពប្រាប់ថាជាព្រាហ្មណ៍ឧទិច្ចគោត្ត ។ ព្រះពោធិសត្វពោលថា ល្អហើយយើងនឹងទៅជាមួយគ្នា ជនទាំង ២ ក៏ធ្វើដំណើររួមគ្នាទៅ លុះដល់ពេលអាហារព្រឹក ព្រះពោធិសត្វអង្គុយក្នុងទីរកទឹកបានងាយ លាងដៃស្រាយកញ្ចប់បាយហើយពោលថា នែមាណព ចូរបរិភោគចុះ ។ មាណពនោះពោលថា នែអ្នកដ៏ចម្រើន ការដែលយើងត្រូវការអាហាររបស់មនុស្សចណ្ឌាលនោះមិនមានឡើយ ។ ព្រះពោធិសត្វក៏ពោលថា តាមចិត្តរបស់អ្នកចុះ ហើយរំលែកអាហារល្មមគ្រប់គ្រាន់សម្រាប់ខ្លួនដាក់លើស្លឹកឈើដទៃ មិនធ្វើអាហារក្នុងកញ្ចប់ឲ្យជារបស់សំណល់ វេចខ្ចប់ទុកក្នុងចំណែកម្ខាង បរិភោគ ផឹកទឹក លាងដៃលាងជើងកាន់យកអង្ករនិងអាហារដ៏សេសពោលថា នែមាណព យើងទៅជាមួយគ្នាចុះហើយធ្វើដំណើរតទៅ ។ ពួកគេនាំគ្នា

ធ្វើដំណើរអស់មួយថ្ងៃ លុះដល់វេលាល្ងាចជនទាំង ២ ចុះងូតទឹកក្នុងទីដែលទឹកសម្បូរមួយកន្លែង ស្រេចហើយក៏ឡើងមកវិញ ព្រះពោធិសត្វអង្គុយក្នុងទីផាសុក ហើយស្រាយកញ្ចប់អាហារមិនបានហៅមាណព ផ្ដើមបរិភោគ ។ មាណពអស់កម្លាំងព្រោះការធ្វើដំណើរអស់មួយថ្ងៃ កើតនូវការស្រេកឃ្លាន បានត្រឹមតែឈរសម្លឹងមើលដោយគិតថា បើបុរសនេះ ឲ្យអាហារដល់អញ អញក៏នឹងបរិភោគ ។ ឯព្រះពោធិសត្វក៏មិនបានពោលពាក្យណាមួយគិតតែបរិភោគតែម្យ៉ាង ។ មាណពនោះគិតថា បុរសចណ្ឌាលនេះមិនពោលជាមួយអញសោះ គង់បរិភោគទាល់តែអស់ អញគួរដណ្ដើមយកដុំបាយនេះទុកកៀរយកអាហារខាងលើចោលហើយបរិភោគចំណែកដែលសល់ មាណពបានធ្វើដូច្នោះហើយបរិភោគអាហារដែល ។ កាលបរិភោគស្រេចហើយប៉ុណ្ណោះក៏កើតនូវការក្ដៅក្រហាយចិត្តយ៉ាងខ្លាំងក្លាថា អញធ្វើកម្មដែលមិនសមគួរដល់ជាតិគោត្តត្រកូលនិងប្រទេសរបស់ខ្លួន អញបរិភោគអាហារដែលរបស់មនុស្សចណ្ឌាល ពេលនោះឯងអាហារលាយឡំដោយឈាមក៏រើចេញអំពីមាត់នៃមាណពនោះ ។ គាត់ខ្សឹកខ្សួលព្រោះសេចក្ដីសោកដ៏ធំឡើងថា អញធ្វើកម្មដែលមិនសមគួរព្រោះត្រឹមតែអាហារតិចតួច ហើយពោលគាថាទីមួយថា

( អាហារណាដែលបានបរិភោគហើយ ) បាយនោះជារបស់
តិចផង សល់ដែលផង បុរសចណ្ឌាលបានឲ្យបាយនោះដល់
យើងដោយសេចក្ដីពិបាក យើងប្រកបដោយជាតិជាព្រាហ្មណ៍

អាហារណាដែលយើងបានបរិភោគហើយ អាហារនោះឯងក៏

ក្អួតចេញមក ដូច្នេះ ។

ក្នុងគាថានោះមានសេចក្តីសង្ខេបដូចតទៅនេះថា អញបរិភោគអាហារណា អាហារនោះតិចផង ជាសំណល់ផង មនុស្សចណ្ឌាលនោះមិនបានឲ្យអាហារដល់អញដោយការពេញចិត្តរបស់ខ្លួន ដែលពិតត្រូវអញដណ្តើមទើបឲ្យដោយលំបាក គឺដោយការលំបាក អញជាព្រាហ្មណ៍មានជាតិបរិសុទ្ធដោយហេតុនោះអាហារដែលអញបរិភោគទើបរើចេញមកមួយអន្លើដោយឈាម ។

មាណពកន្ទក់កន្ទេញយ៉ាងនេះហើយទើបគិតថា អញធ្វើកម្មមិនសមគួរយ៉ាងនេះហើយតើរស់នៅធ្វើអ្វី ទើបចូលទៅកាន់ព្រៃ មិនបង្ហាញខ្លួនដល់បុគ្គលណាមួយដល់នូវការអស់ជីវិតដ៏គួរឲ្យអាសូរ ។

ព្រះសាស្តាទ្រង់សម្តែងរឿងក្នុងអតីតនេះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សតធម្មមាណព បរិភោគអាហារសំណល់របស់មនុស្សចណ្ឌាលជាការបរិភោគអាហារដែលមិនសមគួរដល់ខ្លួន ទើបមិនបានកើតសេចក្តីត្រេកអរយ៉ាងណា បុគ្គលណាបួសហើយក្នុងសាសនានេះក៏យ៉ាងនោះ ចិញ្ចឹមជីវិតដោយការស្វែងរកអាហារដែលមិនសមគួរ បរិភោគបច្ច័យតាមដែលបាន ( ដោយមិនសមគួរនោះ ) ការត្រេកអរមិនបានកើតដល់ភិក្ខុនោះព្រោះភិក្ខុនោះមានជីវិតរស់នៅដែលគួរតិះដៀល ដែលព្រះពុទ្ធអង្គទ្រង់ហាមឃាត់កាលទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយទើបត្រាស់គាថាទីពីរថា

ភិក្ខុណាលះបង់នូវធម៌ គឺអាជីវបារិសុទ្ធិសីល ហើយចិញ្ចឹម

*ជីវិតដោយខុសធម៌យ៉ាងនេះ ភិក្ខុនោះមិនត្រេកអរដោយលាភ*
*ដែលខ្លួនបានហើយដូចជាសតធម្មមាណព ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **ធម្មំ** *បានដល់ ធម៌ គឺអាជីវបារិសុទ្ធិសីល ។ បទថា* **និរង្កត្វា** *បានដល់ នាំទៅចោល ។ បទថា* **អធម្មេន** *បានដល់ មិច្ឆាជីវៈពោលគឺ ការស្វែងរកមិនសមគួរ ២១ យ៉ាងនេះ ។ បទថា* **សតធម្មោ** *ជាឈ្មោះរបស់មាណពនោះ ។ បាលីជា* **សុតធម្មោ** *ក៏មាន ។ បទថា* **ន នន្ទតិ** *សេចក្តីថា មាណពសតធម្មមិនត្រេកអរដោយលាភនោះថា អញបានអាហារដែលរបស់មនុស្សចណ្ឌាល យ៉ាងណាកុលបុត្តបួសក្នុងសាសនានេះក៏យ៉ាងនោះ បរិភោគលាភដែលបានមកដោយការស្វែងរកដែលមិនសមគួររមែងមិនរីករាយ មិនត្រេកអរតែងដល់នូវទោមនស្សថា អញរស់នៅដោយការចិញ្ចឹមជីវិតដែលព្រះពុទ្ធទ្រង់តិះដៀល ព្រោះដូច្នេះបុគ្គលដែលចិញ្ចឹមជីវិតដោយការស្វែងរក ដែលមិនសមគួរ គួរចូលព្រៃស្លាប់យ៉ាងអនាថា ល្អជាងដូចសតធម្មមាណពដូច្នោះ ។*

*ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសអរិយសច្ច កាលចប់អរិយសច្ច ភិក្ខុជាច្រើនសម្រេចសោតាបត្តិផលជាដើម ហើយទ្រង់ប្រជុំជាតកថា សតធម្មមាណពក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ កូនចណ្ឌាលក្នុងកាលនោះ គឺតថាគតនេះឯង ។*

**អដ្ឋកថា សតធម្មជាតក ចប់**

## ទុទ្ទុជាតក

[ ២០៩ ] ( តាបសពោធិសត្វពោលថា ) ពួកសប្បុរសកាលឲ្យនូវទាន ដែលគេឲ្យបានដោយកម្រ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ពួក អសប្បុរសធ្វើតាម ( នូវអំពើនោះ ) មិនបាន សភាពនៃសប្បុរសទាំងឡាយ គេដឹងបានដោយកម្រ ។

[ ២១០ ] ព្រោះហេតុនោះដំណើរអំពីលោកនេះរបស់សប្បុរសនិងអស-ប្បុរសរមែងបែកផ្សេងៗគ្នា ពួកអសប្បុរសរមែងទៅកាន់នរក ពួកសប្បុរស រមែងទៅកាន់ឋានសួគ៌ ។

**ចប់ ទុទ្ទុជាតកទី ១០ ។**

**ចប់ កល្យាណធម្មវគ្គទី ៣ ។**

**ឧទ្ទាននៃកល្យាណធម្មវគ្គនោះគឺ**

និយាយអំពីសមញ្ញាល្អ ១ មិគាធិកូឬសីហៈជាធំជាងម្រឹគ ១ មាណព ១ ទឹកច្រើន ១ សំពះព្រះអាទិត្យ ១ សណ្តែក ១ ផ្លែទន្លាប់ ១ ភក់ ១ មាណពឈ្មោះសតធម្មៈ ១ ទានដែល ឲ្យបានដោយក្រពេក ១ ត្រូវជា ១០ ។

# អដ្ឋកថា

# ធុន្ធជាតក

[ ២០៩-២១០ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការថ្វាយទានរបស់គណៈ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ធុន្ធធំធនមាឆាធំ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថីសម្លាញ់ពីរនាក់ជាបុត្តរបស់កុដុម្ពិកៈ រួមគ្នាឲ្យទានមានបរិក្ខារគ្រប់យ៉ាង និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានថ្វាយបរិក្ខារគ្រប់ប្រភេទ ។ ក្នុងជនទាំងនោះមនុស្សដែលជាប្រធានគណៈ ថ្វាយបង្គំព្រះសាស្ដា អង្គុយក្នុងទីសមគួរនាចំណែកម្ខាងហើយវេរថ្វាយថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងការថ្វាយទាននេះ មានទាំងអ្នកថ្វាយតិច មានទាំងអ្នកថ្វាយច្រើន សូមការថ្វាយនេះមានផលច្រើន ដល់ជនទាំងនោះគ្រប់គ្នាចុះ ។ ព្រះសាស្ដាត្រាស់ថា ឧបាសកឧបាសិកាទាំងឡាយ ពួកអ្នកថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយវេរយ៉ាងនេះជាការធ្វើដ៏ក្រៃលែងហើយ សូម្បីបុរាណកបណ្ឌិតទាំងឡាយក៏ថ្វាយទានវេរយ៉ាងនេះដូចគ្នា កាលជនទាំងនោះទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ដែនកាសី កាលចម្រើនវ័យហើយទៅកាន់នគរតក្កសិលាបានរៀនសិប្បៈគ្រប់យ៉ាង ស្រេចហើយលះឃរាវាស បួសជាឥសី បានជាគ្រូប្រចាំគណៈក្នុងហិមវន្តប្បទេសអស់កាលដ៏យូរ ត្រាច់

ចារិកទៅកាន់ជនបទដើម្បីសេពសេជូវនិងរសប្រៃបានទៅដល់នគរពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ព្រឹកឡើងទើបត្រាច់បិណ្ឌបាត មួយអន្លើដោយបរិស័ទតាមលំដាប់ផ្ទះ ។ ពួកមនុស្សនាំគ្នាថ្វាយកិក្ខា ។ ស្អែកឡើងត្រាច់បិណ្ឌបាត ក្នុងនគរពារាណសី ពួកមនុស្សនាំគ្នារីករាយត្រេកអរ កាលថ្វាយកិក្ខាហើយ ទើបរួមចិត្តគ្នាជាគណៈត្រៀមទានថ្វាយមហាទានដល់គណៈឥសី ។ កាលសម្រេចការថ្វាយ បុគ្គលជាប្រធានគណៈបានពោលដូចខាងដើមនោះឯង ។ ព្រះពោធិសត្វពោលថា អាវុសោ កាលមានចិត្តជ្រះថ្លាហើយទានឈ្មោះថា តិចតួចមិនមានទេ កាលធ្វើអនុមោទនា បានពោលគាថាទាំងនេះថា

ពួកសប្បុរសកាលឲ្យនូវទានដែលគេឲ្យបានដោយកម្រ ធ្វើនូវអំពើ ដែលគេធ្វើបានដោយកម្រ ពួកអសប្បុរសធ្វើតាម ( នូវអំពើនោះ ) មិនបាន សភាពនៃសប្បុរសទាំងឡាយគេដឹងបានដោយកម្រ ។

ព្រោះហេតុនោះ ដំណើរអំពីលោកនេះរបស់សប្បុរសនិងអសប្បុរសរមែងបែកផ្សេងៗគ្នា ពួកអសប្បុរសរមែងទៅកាន់នរក ពួកសប្បុរសរមែងទៅកាន់ឋានសួគ៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុទ្ទទំ** សេចក្ដីថា ឈ្មោះថា ទានដែលបុគ្គលមិនមែនបណ្ឌិតប្រកបដោយអំណាចទោសៈមានលោភៈជាដើមមិនអាចឲ្យបាន ព្រោះដូច្នេះទើបលោកពោលថា **ទុទ្ទទំ** ឲ្យវត្ថុដែលឲ្យបានលំបាក ។

បទថា **ទុក្ករំ កម្មកុព្វតំ** សេចក្តីថា កម្ម គឺការឲ្យនោះ ក៏ដូចគ្នាមិនអាចធ្វើបាន ។ បទថា **ទុក្ករំ** បានដល់ ធ្វើវត្ថុដែលធ្វើបានលំបាកនោះ ។ បទថា **អសន្តោ** បានដល់ ជនដែលមិនមែនបណ្ឌិត គឺបុគ្គលពាល ។ បទថា **នានុកុព្វន្តិ** សេចក្តីថា គឺធ្វើតាមកម្មនោះមិនបាន ។ បទថា **សតំ ធម្មោ** បានដល់ សភាវៈធម៌របស់បណ្ឌិតទាំងឡាយ នេះលោកសំដៅដល់ការឲ្យ ។ បទថា **ទុរន្នយោ** បានដល់ លំបាកនឹងដឹងដោយទាក់ទងនឹងផល លំបាកនឹងដឹកនាំ គឺលំបាកនឹងដឹងបានថា សភាពយ៉ាងនេះជាផលរបស់ទានប្រភេទនេះ ។ មួយប្រការទៀតបទថា **ទុរន្នយោ** បានដល់ លំបាកដែលនឹងចាក់ធ្លុះ អធិប្បាយថា ជនដែលមិនមែនបណ្ឌិតមិនឲ្យទានហើយមិនអាចនឹងបានផលនៃទាន ។ បទថា **នានា ហោតិ ឥតោ គតិ** បានដល់ បដិសន្ធិនោះរបស់សត្វដែលឃ្លាតចាកលោកនេះហើយ ទៅកាន់បរលោករមែងផ្សេងគ្នា ។ បទថា **អសន្តោ និរយំ យន្តិ** បានដល់ ជនដែលមិនមែនបណ្ឌិត ជាអ្នកទ្រុស្តសីលមិនឲ្យទាន មិនរក្សាសីលរមែងទៅកាន់នរក ។ បទថា **សន្តោ សគ្គបរាយនា** សេចក្តីថា ឯជនជាបណ្ឌិតឲ្យទានរក្សាសីល ធ្វើឧបោសថបំពេញសុចរិត ៣ រមែងមានឋានសួគ៌ជាទីទៅខាងមុខ គឺរមែងសោយសុខដែលធំក្រៃលែង ។

ព្រះពោធិសត្វកាលធ្វើអនុមោទនាយ៉ាងនេះហើយស្នាក់នៅក្នុងទីនោះអស់រដូវភ្លៀង កាលផុតរដូវភ្លៀងក៏ទៅកាន់ព្រៃហិមពាន្ត ញុំាងឈានឲ្យកើតមិនសាបសូន្យចាកឈានក៏បានចូលដល់ព្រហ្មលោក ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ពួកឥសីក្នុងកាលនោះបានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯគ្រូប្រចាំគណៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ទុទ្ទទជាតក ចប់**

**កល្យាណធម្មវគ្គ ចប់**

# អសទិសវគ្គ

## អសទិសជាតក

[ ២១១ ] ( ព្រះសាស្តាត្រាស់ថា ) ព្រះរាជបុត្តទ្រង់ព្រះនាមអសទិស ជាខ្មាន់ធ្នូមានកម្លាំងច្រើន បាញ់ធ្នូទៅក្នុងទីឆ្ងាយបាញ់ត្រង់ ទម្លាយនូវកងទ័ពធំបាន ។

[ ២១២ ] ព្រះរាជកុមារទ្រង់ច្បាំងនឹងសត្រូវទាំងពួងបាន តែមិនបានបៀតបៀននូវជនណាមួយឡើយ ធ្វើព្រះអនុជឲ្យសួស្តីហើយដល់នូវសេចក្តីសង្រួម គឺចូលទៅកាន់ផ្នួស ។

**ចប់ អសទិសជាតកទី ១ ។**

# អសទិសវគ្គ

## អដ្ឋកថា អសទិសជាតក

[ ២១១-២១២ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាភិនេស្រ្កមណ៍ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ធនុគ្គហោ អសទិសោ** ដូច្នេះជាដើម ។

រឿងពិស្ដារថា ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភាសរសើរមហានេក្ខម្មបារមីរបស់ព្រះមានព្រះភាគ ។ ព្រះសាស្ដាយាងមកកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញមហាភិនេស្រ្កមណ៍មិនមែនតែក្នុងឥឡូវនេះទេ សូម្បីក្នុងកាលមុនក៏តថាគតលះស្វេតច្ឆត្រចេញបួសដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងផ្ទៃអគ្គមហេសីរបស់ព្រះអង្គ ។ កាលព្រះរាជកុមារប្រសូតដោយសួស្ដី ក្នុងថ្ងៃថ្វាយព្រះនាម ព្រះជនកជននីថ្វាយព្រះនាមថា អសទិសកុមារ ។ កាលព្រះរាជឱរសរត់ទៅមកបាន សត្វមានបុណ្យដទៃក៏បដិសន្ធិក្នុងផ្ទៃរបស់ព្រះរាជទេវី ។ កាលព្រះរាជឱរសនោះប្រសូតដោយសួស្ដីក្នុងថ្ងៃថ្វាយព្រះនាមព្រះជនកជននីថ្វាយព្រះនាមថា ព្រហ្មទត្តកុមារ ។

បណ្តាព្រះរាជកុមារទាំង ២ អង្គ ព្រះពោធិសត្វកាលព្រះជន្មបាន ១៦ វស្សា ទ្រង់យាងទៅនគរតក្កសិលា ទ្រង់រៀននូវត្រៃវេទនិងសិល្បសាស្ត្រគ្រប់យ៉ាង ដែលជាបទដ្ឋានរបស់វិជ្ជា ១៨ ប្រការ មិនមានគូប្រៀបក្នុងសិប្បៈបាញ់ធ្នូហើយ ទ្រង់ត្រឡប់មកនគរពារាណសី ។

ព្រះរាជាកាលទ្រង់សោយទិវង្គត ទ្រង់មានព្រះរាជឱង្ការថា យើងត្រូវប្រគល់រាជសម្បត្តិដល់អសទិសកុមារ ឲ្យតំណែងឧបរាជដល់ព្រហ្មទត្តកុមារ រួចទ្រង់សោយទិវង្គត ។ កាលព្រះរាជាសោយទិវង្គតហើយ កាលគេប្រគល់រាជសម្បត្តិឲ្យព្រះពោធិសត្វទ្រង់បដិសេធថា ខ្ញុំមិនត្រូវការរាជសម្បត្តិ ទើបអភិសេកព្រហ្មទត្តរាជកុមារឲ្យគ្រប់គ្រងរាជសម្បត្តិ ។ ព្រះពោធិសត្វត្រាស់ថា ខ្ញុំមិនត្រូវការយស ទើបទ្រង់មិនប្រាថ្នាអ្វីៗទាំងអស់ កាលព្រះអនុជនៃទ្រង់គ្រងរាជសម្បត្តិ ព្រះពោធិសត្វ ក៏ទ្រង់ស្ថិតនៅដោយអាការដូចព្រះរាជាតាមប្រក្រតីនោះឯង ។ ពួកអ្នករាជការនាំគ្នាពោលបង្កាច់ព្រះពោធិសត្វក្នុងរាជសម្នាក់ថា អសទិសកុមារទ្រង់ប្រាថ្នារាជសម្បត្តិ ។ ព្រហ្មទត្តរាជាក៏ទ្រង់ជឿពាក្យរបស់ជនទាំងនោះ ទើបមានព្រះទ័យបែកបែរ ទ្រង់បញ្ជូនរាជបុរសទៅថា ពួកអ្នកចូរចាប់ព្រះជេដ្ឋារបស់យើង ។ កាលនោះមានជនបំណាច់ល្អចំពោះព្រះពោធិសត្វម្នាក់ប្រាប់ហេតុការណ៍នោះឲ្យទ្រង់ជ្រាប ។ ព្រះពោធិសត្វទ្រង់ព្រះពិរោធនឹងព្រះកនិដ្ឋភាតា ទ្រង់យាងទៅកាន់ដែនដទៃ ហើយឲ្យមនុស្សក្រាបទូលដល់ព្រះរាជានោះថា មានខ្មាន់ធ្នូម្នាក់មកឈរត្រង់ខ្លោងទ្វារព្រះរាជវាំង ព្រះរាជាត្រាស់ថា ប្រពៃហើយចូលមកចុះ ។ ព្រះរាជាត្រាស់

សួរព្រះពោធិសត្វដែលឈរក្នុងទីជិតថា ម្នាលអ្នកដ៏ចម្រើន អ្នកចេះបាញ់ធ្នូឬ ព្រះពោធិសត្វក្រាបទូលថា ករុណាថ្លៃពិសេស ព្រះរាជាត្រាស់សួរថា តើអ្នកត្រូវការថ្លៃឈ្នួលប៉ុន្មាន ព្រះពោធិសត្វក្រាបទូលថា ត្រូវការមួយឆ្នាំមួយសែន ។ ព្រះរាជាត្រាស់ថា សាធុ ចូរទទួលរាជកិច្ចចុះ ។ តាំងពីនោះមក ព្រះពោធិសត្វទទួលរាជការជាមួយព្រះរាជា ។ ពួកអ្នកបាញ់ធ្នូមុនៗឃើញតម្លៃដែលព្រះរាជាប្រទានដល់ព្រះពោធិសត្វ ទើបនាំគ្នាលើកទោសថា តម្លៃនេះច្រើនពេក ។

ថ្ងៃមួយ ព្រះរាជាយាងទៅព្រះរាជឧទ្យាន ប្រើឲ្យបាំងវាំងននក្បែរផ្ទាំងថ្មមង្គល ទ្រង់ផ្ទំលើរាជអាសនៈជាក្បែរដើមស្វាយទតខាងលើ ទ្រង់ឃើញផ្លែស្វាយមួយចង្កោមនៅខាងចុងបំផុត ទ្រង់ព្រះតម្រិះថា មិនមានអ្នកណាឡើងទៅយកផ្លែស្វាយនោះបាន ទ្រង់បញ្ជាឲ្យហៅពួកខ្មាន់ធ្នូមកត្រាស់ថា ពួកអ្នកអាចប្រើព្រួញបាញ់ចង្កោមស្វាយនោះឲ្យធ្លាក់បានដែរឬទេ ពួកនាយខ្មាន់ធ្នូក្រាបទូលថា បពិត្រព្រះអង្គ រឿងនេះមិនជាការលំបាកសម្រាប់ពួកទូលព្រះ-បង្គំទេ ទ្រង់ក៏ធ្លាប់ឃើញថ្វីដៃរបស់ពួកទូលព្រះបង្គំច្រើនដងហើយ តែនាយខ្មាន់ធ្នូដែលមកថ្មីបានតម្លៃច្រើនជាងពួកទូលព្រះបង្គំសូមទ្រង់ឲ្យគេបាញ់ចុះ ។ ព្រះរាជាត្រាស់ឲ្យហៅព្រះពោធិសត្វ ហើយត្រាស់សួរថា អ្នកអាចបាញ់ចង្កោមស្វាយនោះឲ្យធ្លាក់មកបានដែរឬទេ ព្រះពោធិសត្វក្រាបទូលថា បើបានទីទំនេរមួយកន្លែងទើបអាច ព្រះរាជាត្រាស់សួរថា ទីទំនេរត្រង់ណា ព្រះពោធិសត្វក្រាបទូលថា ខាងក្នុងទីបន្ទំរបស់ព្រះអង្គ ព្រះរាជាឲ្យប្តូរទីបន្ទំហើយព្រះរាជ

ទានទីទំនេរឲ្យ ។ ព្រះពោធិសត្វមិនមានធ្នូនៅក្នុងដៃទ្រង់លាក់ធ្នូទុកក្នុងរវាងព្រះកូសាត្រាច់ទៅព្រោះហេតុនោះទើបព្រះពោធិសត្វត្រាស់ថា គួរបានសំពត់និងវាំងននត្រឹមមួយផ្ទាំង ។ ព្រះរាជាត្រាស់ឲ្យនាំវាំងននមក ព្រះពោធិសត្វចូលទៅក្នុងវាំងនន ដោះសំពត់ខាងក្រៅចេញ ចងព្រះឧទរដោយសំពត់ក្រហមមួយផ្ទាំង ទ្រង់ចាប់យកព្រះខ័ន មួយអន្ទើដោយស្រោមចេញអំពីចង្កេះ ទ្រង់ចាប់ព្រះខ័នខាងឆ្វេង ពាក់អាវពណ៌មាស ស្ពាយបំពង់ព្រួញខាងក្រោយ ទ្រង់ទាញយកមេណ្ឌកមហាធ្នូ មួយអន្ទើដោយគ្រឿងប្រកប បំពាក់ខ្សែធ្នូពណ៌កែវប្រពាល ពាក់ព្រះឧណ្ហីស គ្រវីព្រួញដែលសម្រេចដោយក្រចកបើកវាំងននចេញទៅកាន់ទីថ្ងៃសរ ដូចនាគកុមារតាក់តែងកាយជ្រែកផែនដីមកដូច្នោះ ។ កាលផ្ទាប់ព្រួញហើយទើបក្រាបទូលព្រះរាជាថា បពិត្រមហារាជទ្រង់ចង់ឲ្យផ្លែស្វាយនោះធ្លាក់មកដោយព្រួញដែលបាញ់ឡើង ឬព្រួញដែលធ្លាក់ចុះមកវិញ ព្រះរាជាត្រាស់ថា មនុស្សជាច្រើនបាញ់ឲ្យធ្លាក់ក្នុងកាលដែលព្រួញឡើងទៅយើងធ្លាប់ឃើញតែបាញ់ដោយព្រួញធ្លាក់ចុះមក យើងមិនធ្លាប់ឃើញឡើយ ចូរបាញ់ឲ្យធ្លាក់ដោយព្រួញដែលធ្លាក់ចុះមកចុះ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ព្រួញនេះនឹងឡើងទៅឆ្ងាយរហូតដល់ពិភពចាតុម្មហារាជហើយត្រឡប់ចុះមកឯង សូមទ្រង់រង់ចាំទម្រាំព្រួញត្រឡប់មកវិញចុះ ព្រះរាជាត្រាស់ថា សាធុ ។ តមកទើបព្រះពោធិសត្វ ក្រាបទូលព្រះរាជាទៀតថា បពិត្រមហារាជ ព្រួញនេះកាលឡើងទៅ នឹងច្រៀកត្រង់កណ្តាលទងស្វាយ កាលឡើងទៅមិនវេទៅខាងនោះនិងខាងនេះត្រឹមមួយ

ចម្រៀកសក់នឹងធ្លាក់មកតាមគន្លងត្រូវផ្លែស្វាយនោះហើយទើបធ្លាក់ សូមព្រះអង្គទតចុះ ។ ទើបព្រះពោធិសត្វបញ្ចេញកម្លាំងបាញ់ទៅ ។ ព្រួញនោះទម្លុះទងស្វាយទៅ ។ ព្រះពោធិសត្វទ្រង់ជ្រាបថា ឥឡូវនេះព្រួញឡើងទៅដល់ពិភពចាតុម្មហារាជហើយ ទើបទ្រង់ប្រើកម្លាំងឲ្យខ្លាំងជាងមុន រួចបាញ់ព្រួញមួយទៀត ទើបព្រួញនោះហោះឡើងទៅប៉ះចុងព្រួញមុន ធ្វើឲ្យព្រួញត្រឡប់ហើយព្រួញទី ២ ក៏ដល់តាវត្តិង្សពិភព ។ ទេវតាទាំងឡាយ ក្នុងភពនោះបានចាប់ព្រួញនោះទុក ។ សំឡេងជ្រែកអាកាសរបស់ព្រួញដែលត្រឡប់ដូចគ្នានឹងសំឡេងរន្ទះ កាលមហាជនពោលថា នុ៎ះសំឡេងអ្វី ទើបព្រះពោធិសត្វប្រាប់ថា សំឡេងព្រួញត្រឡប់ ទើបលួងលោមមហាជនដែលខ្លាចព្រួញធ្លាក់ត្រូវរាងកាយរបស់ខ្លួនថា កុំខ្លាចឡើយ ហើយនិយាយថា ខ្ញុំនឹងមិនឲ្យព្រួញធ្លាក់ដល់ផែនដី ។ ព្រួញកាលធ្លាក់ចុះក៏មិនរេទៅខាងនោះខាងនេះធ្លាក់ចុះមកតាមគន្លងកាត់នូវចង្កោមស្វាយ ។ ព្រះពោធិសត្វមិនឲ្យស្វាយនិងព្រួញធ្លាក់ដល់ដី ទទួលក្នុងអាកាសដៃម្ខាងចាប់ស្វាយ ដៃម្ខាងចាប់ព្រួញ មហាជនឃើញភាពអស្ចារ្យនោះទើបនាំគ្នាពោលថា សភាពយ៉ាងនេះ ពួកយើងមិនធ្លាប់ឃើញឡើយនាំគ្នាសរសើរ បន្លឺសំឡេងទះដៃ ផ្ទាត់ម្រាមដៃ គ្រវីសំពត់រាប់ពាន់ ។ ទ្រព្យដែលរាជបរិស័ទគ្រេកអរប្រគល់ឲ្យព្រះពោធិសត្វប្រមាណមួយកោដិសូម្បីព្រះរាជាក៏បានព្រះរាជទានទ្រព្យជាច្រើន ព្រះរាជទានយសដ៏ធំក្រៃលែងដល់ព្រះពោធិសត្វ ដូចគ្នានឹងគ្រាប់ភ្លៀងដែលធ្លាក់ចុះមកដូច្នេះ ។ ធ្វើសក្ការៈគោរពរាប់អានព្រះពោធិសត្វដែលស្នាក់នៅក្នុងទីនោះយ៉ាងនេះ ។

ព្រះរាជា ៧ នគរទ្រង់ជ្រាបថា បានឮថា អសទិសកុមារមិនបាននៅក្នុង នគរពារាណសី ទើបនាំគ្នាលើករេហ៍ពលមកព័ទ្ធនគរពារាណសីហើយទ្រង់ បញ្ជូនសាសន៍ថ្វាយព្រះរាជាថា តើទ្រង់ប្រគល់រាជសម្បត្តិឲ្យ ឬច្បាំង ។ ព្រះរាជាទ្រង់ខ្លាចចំពោះមរណភ័យត្រាស់សួរថា ម្ចាស់បងរបស់យើងនៅទី ណា អាមាត្យក្រាបទូលថា ព្រះជេដ្ឋភាតានៅបម្រើស្តេចសាមន្តរាជមួយ អង្គ ទើបទ្រង់បញ្ជូនទូតទៅមួយអន្លើដោយព្រះរាជតម្រាស់ថា បើម្ចាស់ បងរបស់យើងមិនយាងត្រឡប់ទេយើងក៏មិនមានជីវិត ពួកអ្នកចូរទៅ ចូរថ្វាយ បង្គំទៀបបាទាហើយឲ្យទ្រង់អត់ទោសតាមពាក្យរបស់យើង យាងទ្រង់ត្រឡប់ មកចុះ ។ ពួករាជទូតនាំគ្នាទូលរឿងថ្វាយព្រះពោធិសត្វឲ្យទ្រង់ជ្រាប ។ ព្រះ ពោធិសត្វក្រាបថ្វាយបង្គំលាព្រះរាជាអង្គនោះត្រឡប់ទៅនគរពារាណសី ទ្រង់ លួងលោមព្រះរាជាថា កុំខ្លាចឡើយ ហើយទ្រង់ចារឹកអក្សរដាក់នឹងព្រួញ ដោយសេចក្តីថា យើងឈ្មោះអសទិសកុមារត្រឡប់មកហើយនឹងបាញ់ព្រួញ មួយទៀតដើម្បីជម្រះជីវិតពួកទ្រង់ទាំងឡាយ បុគ្គលអ្នកត្រូវការរួចជីវិត ចូរ ជៀសចេញទៅចុះ យើងមិនឲ្យមានឈាមត្រឹមមួយចម្អែតរុយ ហើយទ្រង់ ឈរប្រថាប់លើប៉មការពារបាញ់ព្រួញឲ្យធ្លាក់ចុះលើភាជន៍មាសប្រមាណមួយ ហត្ថ ខណៈដែលព្រះរាជា ៧ នគរកំពុងសោយ ។ ព្រះរាជាទាំងនោះទត ឃើញអក្សរត្រង់ចុងព្រួញហើយតក់ស្លុតខ្លាចចំពោះមរណភ័យ នាំគ្នារត់ទៅ ទាំងអស់ ។ ព្រះពោធិសត្វឲ្យព្រះរាជា ៧ អង្គរត់ទៅដោយមិនឲ្យមានឈាម ត្រឹមមួយចម្អែតរុយយ៉ាងនេះហើយទើបលាព្រះកនិដ្ឋភាតា លះកាមបួសជាឥសី

ញុាំងអភិញ្ញានិងសមាបត្តិឲ្យកើត កាលអស់ព្រះជន្មក៏ចូលដល់ព្រហ្មលោក ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អសទិសកុមារទ្រង់ឲ្យព្រះរាជា ៧ នគរគេចទៅ ទ្រង់មានជ័យជម្នះក្នុងសង្គ្រាមហើយទ្រង់បួសជាឥសីយ៉ាងនេះ កាលទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ហើយបានត្រាស់ព្រះគាថាទាំងនេះថា

ព្រះរាជបុត្តទ្រង់ព្រះនាមអសទិស ជាខ្មាន់ធ្នូមានកម្លាំងច្រើន
បាញ់ធ្នូទៅក្នុងទីឆ្ងាយបាញ់ត្រង់ ទម្លាយនូវកងទ័ពធំបាន ។
ព្រះរាជកុមារទ្រង់ច្បាំងនឹងសត្រូវទាំងពួងបាន តែមិនបាន
បៀតបៀននូវជនណាមួយឡើយ ធ្វើព្រះអនុជឲ្យសួស្តីហើយ
ដល់នូវសេចក្តីសង្រួម គឺចូលទៅកាន់ផ្នួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសទិសោ** សេចក្តីថា មិនមែនមិនស្មើដោយព្រះនាមប៉ុណ្ណោះទេ សូម្បីកម្លាំងវីរិយៈនិងបញ្ញាក៏មិនមានបុគ្គលស្មើ ។ បទថា **មហព្វលោ** សេចក្តីថា ទ្រទ្រង់នូវកម្លាំងកាយច្រើន ។ បទថា **ទូរេ បាតី** សេចក្តីថា ឈ្មោះថា **ទូរេ បាតី** ព្រោះអាចឲ្យព្រួញទៅដល់ឋានចាតុម្មហារាជិកា និងតាវត្តិង្សបាន ។ បទថា **អក្ខណវេធី** គឺ បាញ់មិនខុសបាញ់ត្រង់ ។ម្យ៉ាងទៀតផ្លេកបន្ទោរហៅថា អក្ខណៈ អធិប្បាយថា ក្នុងផ្លេកបន្ទោរម្តងបាញ់បាន ៧-៨ ដង ដោយពន្លឺនោះព្រោះហេតុនោះទើបហៅថា **អក្ខណវេធី** ។ បទថា **មហាកាយប្បទាលនោ** បានដល់ទម្លាយគំនរធំបាន ។ គំនរធំមាន ៧ យ៉ាងគឺ គំនរស្បែក ១ គំនរឈើ ១

គំនរលោហៈ ១ គំនរដែក ១ គំនរខ្សាច់ ១ គំនរទឹក ១ គំនរបន្ទះក្តារ ១ ក្នុងគំនរទាំងនោះអ្នកដទៃកាលទម្លាយគំនរស្បែក សូម្បីស្បែកក្របីក៏បាញ់ធ្លុះ តែព្រះពោធិសត្វនោះបាញ់ស្បែកក្របីដែលត្រួតគ្នា ១០០ ជាន់ឲ្យធ្លុះបាន ។ អ្នកដទៃបាញ់ក្តារល្វាកម្រាស់ ៨ ធ្នាប់ បាញ់ក្តារធ្នង់កម្រាស់ ៤ ធ្នាប់ ឲ្យធ្លុះបានតែព្រះពោធិសត្វបាញ់ក្តារទាំងនោះកម្រាស់ ១០០ ធ្នាប់ឲ្យធ្លុះបាន ទង់ដែងកម្រាស់ ២ ធ្នាប់ បន្ទះដែកកម្រាស់ ១ ធ្នាប់ក៏ដូចគ្នា រទេះផ្ទុកខ្សាច់ ផ្ទុកក្តារ ព្រះពោធិសត្វបាញ់ពីក្រោយឲ្យធ្លុះទៅខាងមុខ ។ តាមប្រក្រតីក្នុងទឹកព្រះពោធិសត្វបាញ់ព្រួញឲ្យជ្រែកទឹកទៅបាន ៤ ឧសភ ។ លើគោកចម្ងាយ ៨ ឧសភ ព្រះពោធិសត្វទម្លាយគំនរធំទាំងនោះបានទើបឈ្មោះថា **មហាកាយប្បទាលនោ** ដោយប្រការដូច្នេះ ។ បទថា **សព្វាមិត្តេ** បានដល់ សត្រូវទាំងអស់ ។ បទថា **រណំ កត្វា** បានដល់ ធ្វើការច្បាំង ឲ្យសត្រូវបរាជ័យ ។ បទថា **ន ច កិញ្ចិ វិហេឋយិ** គឺមិនបៀតបៀនបុគ្គលណាមួយឡើយ ។ តែទ្រង់ច្បាំងនឹងសត្រូវទាំងនោះដោយប្រើសរនោះឯង មិនឲ្យលំបាក ។ បទថា **សញ្ញមំ អជ្ឈុបាគមិ** បានដល់ ចូលដល់នូវការសង្រួមដោយសីលគឺបព្វជ្ជា ។

ព្រះសាស្តា កាលទ្រង់សម្តែងព្រះធម្មទេសនានេះយ៉ាងនេះហើយ ទ្រង់ប្រជុំជាតកថា ព្រះអកិដ្ឋភាតាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯអសទិសកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាអសទិសជាតក ចប់**

## សង្គាមាវចរជាតក

[ ២១៣ ] ( ទម័កដំរីពោធិសត្វពោលថា ) ម្នាលដំរី អ្នកល្បីថាជាសត្វចូលសង្គ្រាម មានកម្លាំងក្លៀវក្លា ហេតុអ្វីមកដល់ខ្លោងទ្វារហើយក៏ថយក្រោយទៅវិញ ។

[ ២១៤ ] ម្នាលដំរី អ្នកចូរញាំញីទម្លាយនូវសន្ទះទ្វារ ហើយដកភើចសសរខឿនចេញឲ្យឆាប់ ចូរញាំញីនូវខ្លោងទ្វារហើយចូលទៅយ៉ាងឆាប់ ។

**ចប់ សង្គាមាវចរជាតកទី ២ ។**

## អដ្ឋកថា

## សង្គាមាវចរជាតក

[ ២១៣-២១៤ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សង្គាមាវចរោ សូរោ** ដូច្នេះជាដើម ។

រឿងពិស្ដារថា កាលព្រះសាស្ដាយាងដល់នគរកបិលពស្ដុ ដោយយាងទៅគ្រាដំបូង ទ្រង់ឲ្យនន្ទកុមារព្រះកនិដ្ឋភាតាបួសហើយ ទ្រង់យាងចេញអំពីនគរកបិលពស្ដុទៅគង់នៅក្នុងនគរសាវត្ថីដោយលំដាប់ ព្រះនន្ទរឭកដល់វាចាដែលនាងជនបទកល្យាណីបានផ្ដាំក្នុងកាលដែលនន្ទកាន់បាត្រចេញអំពីព្រះរាជដំណាក់ជាមួយព្រះតថាគត ។ បានឮថា នន្ទកុមារយាងទៅជាមួយព្រះមុនីនាងជនបទកល្យាណីអើតតាមបង្អួចទាំងដែលបួងសក់បានពាក់កណ្ដាល ស្រែក

ឡើងថា បពិត្រអយ្យបុត្ត សូមអយ្យបុត្តប្រញាប់ត្រឡប់មក ទើបកើតអផ្សុក មិនមានសេចក្តីត្រេកអរ កើតនូវរោគស្គមលឿង មានព្រះកាយរវាមដោយសរសៃ ។

ព្រះសាស្តាទ្រង់ជ្រាបរឿងរបស់ព្រះនន្ទហើយទើបទ្រង់ព្រះតម្រិះថា បើដូច្នោះតថាគតនឹងឲ្យនន្ទតាំងនៅក្នុងអរហត្តផល ហើយទ្រង់យាងទៅលំនៅព្រះនន្ទ គង់លើអាសនៈដែលគេរៀបចំទុក ត្រាស់សួរថា ម្នាលនន្ទ អ្នកមិនត្រេកអរក្នុងសាសនានេះទេឬ ព្រះនន្ទក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមានចិត្តប្រតិព័ទ្ធនាងជនបទកល្យាណីទើបមិនត្រេកអរ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលនន្ទ អ្នកធ្លាប់ចារិកទៅព្រៃហិមពាន្តដែរឬទេ ព្រះនន្ទក្រាបទូលថា មិនធ្លាប់ទេព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលនន្ទ បើដូច្នោះយើងនឹងទៅ ។ ព្រះនន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមានឫទ្ធិនឹងទៅបានដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលនន្ទ តថាគតនាំអ្នកទៅដោយឫទ្ធិរបស់តថាគត ហើយទ្រង់ចាប់ដៃព្រះនន្ទហោះឡើងទៅកាន់អាកាស ទ្រង់បង្ហាញស្រែដែលត្រូវភ្លើងឆេះមួយកន្លែងក្នុងរវាងផ្លូវហើយទ្រង់បង្ហាញមេស្វាមួយដែលមានច្រមុះនិងកន្ទុយដាច់ មានរោមឆេះដោយភ្លើង មានស្បែករលាកស្គមនៅសល់តែស្បែកជណ្តប់ឆ្អឹង អង្គុយស្ងប់សៅលើជន្ទត់ឈើហើយត្រាស់សួរថា ម្នាលនន្ទ អ្នកឃើញស្វានោះដែរឬទេ ព្រះនន្ទក្រាបទូលថា ឃើញព្រះអង្គ ព្រះសាស្តាត្រាស់ថា ចូរអ្នកកំណត់ទុកឲ្យល្អហើយទ្រង់នាំនន្ទទៅឲ្យមើលផ្ទាំងមនោសិលាប្រមាណ ៦០ យោជន៍ ស្រះធំទាំង

៧ មានអនោតត្តស្រះជាដើម ស្ទឹងធំ ៥ ខ្សែនិងភ្នំហិមពាន្តដែលគួរត្រេកអរជាច្រើនរយកំពូលដែលវិចិត្រដោយភ្នំមាស ភ្នំប្រាក់និងភ្នំកែវមណី ហើយត្រាស់សួរថា ម្នាលនន្ទ អ្នកធ្លាប់ឃើញឋានតាវត្តិង្សដែរឬទេ ព្រះនន្ទក្រាបទូលថា មិនធ្លាប់ឃើញទេព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលនន្ទ មកតថាគតនឹងបង្ហាញឋានតាវត្តិង្សដល់អ្នក ហើយទ្រង់នាំទៅកាន់ស្ថានតាវត្តិង្ស គង់លើបណ្ឌុកម្ពលសិលាអាសនៈ សក្កទេវរាជ មួយអន្លើដោយពួកទេវតាក្នុងទេវលោកទាំង ២ ក៏នាំគ្នាមកថ្វាយបង្គំរួចអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ពួកទេពអប្សរប្រមាណ ៥០០ មានជើងពណ៌ដូចជើងព្រាបនិងស្រីបម្រើប្រមាណ ២ កោដិកន្ទះ[1]ក៏នាំគ្នាមកថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ។

ព្រះសាស្តាទ្រង់ឲ្យនន្ទមើលទេពអប្សរ ៥០០ នោះរឿយៗដោយអំណាចកិលេសត្រាស់សួរថា ម្នាលនន្ទ អ្នកឃើញទេពអប្សរ ដែលមានជើងពណ៌ដូចជើងព្រាបទាំងនេះដែរឬ ព្រះនន្ទក្រាបទូលថា ឃើញព្រះអង្គ ព្រះសាស្តាត្រាស់សួរថា ស្រីទេពអប្សរទាំងនេះស្អាត ឬនាងជនបទកល្យាណីស្អាត ព្រះនន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្វាញីដែលភ្លើងឆេះយ៉ាងណានាងជនបទកល្យាណីក៏យ៉ាងនោះ កាលប្រៀបធៀបនឹងស្រីទេពអប្សរទាំងនេះនាងជនបទកល្យាណីដូចជាមេស្វា ។ ព្រះសាស្តាត្រាស់សួរថា ម្នាលនន្ទឥឡូវនេះអ្នកនឹងធ្វើដូចម្តេច ព្រះនន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គធ្វើកម្មអ្វីទើបបានទេពអប្សរទាំងនេះ ព្រះសាស្តាត្រាស់ថា បំពេញ

---

១-ក្នុងទីខ្លះថា ២៥០ កោដិ ។

សមណធម៌ចុះ ។ ព្រះនន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើទ្រង់ធានាដើម្បីឲ្យបានស្រីទេពអប្សរទាំងនេះ ខ្ញុំព្រះអង្គនឹងបំពេញសមណធម៌ ។ ព្រះសាស្ដាត្រាស់ថា ម្នាលនន្ទចូរបំពេញសមណធម៌ចុះតថាគតនឹងធានាដល់អ្នក ។ ព្រះថេរៈកាន់យកព្រះតថាគតជាអ្នកធានាក្នុងកណ្ដាលពួកទេវតា ហើយទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គកុំធ្វើឲ្យយឺតយូរពេកសូមទ្រង់ត្រឡប់ចុះ ខ្ញុំព្រះអង្គនឹងបំពេញសមណធម៌ ។ ព្រះសាស្ដានាំនន្ទទៅកាន់វត្តជេតពនវិញ ។ ព្រះថេរៈផ្ដើមបំពេញសមណធម៌ ព្រះសាស្ដាហៅព្រះធម្មសេនាបតីមកហើយត្រាស់ថា ម្នាលសារីបុត្ត នន្ទប្អូនប្រុសរបស់តថាគតបានកាន់យកតថាគតជាអ្នកធានាព្រោះរឿងទេពអប្សរទាំងឡាយក្នុងកណ្ដាលពួកទេវតាជាន់តាវត្តិង្សទេវលោក ។ ដោយឧបាយនេះឯងទ្រង់ត្រាស់ដល់ភិក្ខុដ៏សេសដោយច្រើនដល់អសីតិមហាសាវកមានព្រះមោគ្គល្លានត្ថេរ ព្រះ-មហាកស្សបត្ថេរ ព្រះអនុរុទ្ធត្ថេរនិងព្រះអានន្ទដែលជាឃ្លាំងធម៌ជាដើម ។ ព្រះធម្មសេនាបតីសារីបុត្ត ចូលទៅរកព្រះនន្ទត្ថេរពោលថា អាវុសោនន្ទ ឮថាលោកឲ្យព្រះទសពល ជានាក្នុងកណ្ដាលពួកទេវតាជាន់តាវត្តិង្សទេវលោកថាបើបានទេពអប្សរនឹងបំពេញសមណធម៌ពិតឬហើយបញ្ជាក់ថា កាលបើយ៉ាងនេះការប្រព្រឹត្តព្រហ្មចរិយធម៌របស់លោកក៏ទាក់ទងដោយមាតុគ្រាម ទាក់ទងនឹងកិលេសមិនមែនឬ លោកមិនខុសអ្វីពីកម្មករស៊ីឈ្នួលធ្វើការងារដើម្បីស្រីទេធ្វើឲ្យព្រះថេរៈអស់នូវតេជៈមាននូវការខ្មាស ( ដល់នូវលជ្ជីធម៌ ) ។ ព្រះអសីតិមហាសាវកនិងភិក្ខុដ៏សេសបានធ្វើឲ្យព្រះនន្ទខ្មាសដោយឧបាយនេះ ។

ព្រះនន្ទពិចារណាថា អញធ្វើកម្មមិនសមគួរហ្ន៎ ហើយផ្គងសេចក្ដីព្យាយាម ឲ្យមាំទាំដោយហិរិនិងឱត្តប្បៈ ចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ចូលទៅគាល់ព្រះសាស្ដាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដកពាក្យធានារបស់ព្រះអង្គ ព្រះសាស្ដាត្រាស់ថា ម្នាលនន្ទ អ្នកសម្រេចអរហត្តក្នុងកាលណា កាលនោះ តថាគតក៏ផុតពាក្យធានា ។ ភិក្ខុទាំងឡាយកាលដឹងសេចក្ដីនេះហើយទើបប្រជុំគ្នាក្នុងធម្មសភាថា អាវុសោ ព្រះនន្ទរូបនេះអត់ធន់ចំពោះពាក្យប្រៀនប្រដៅ តាំងមាំក្នុងហិរិឱត្តប្បៈដោយឱវាទត្រឹមតែម្ដងប៉ុណ្ណោះហើយបំពេញសមណធម៌សម្រេចអរហត្ត ព្រះសាស្ដាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នន្ទអត់ធន់នឹងពាក្យប្រៀនប្រដៅតែក្នុងកាលឥឡូវនេះ ក៏មិនមែន សូម្បីក្នុងកាលមុនក៏អត់ធន់ចំពោះពាក្យប្រៀនប្រដៅដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលហ្មដំរី ចម្រើនវ័យសម្រេចសិប្បៈដំរីហើយទទួលរាជការជាមួយព្រះរាជាដែលជាសត្រូវរបស់ព្រះបាទពារាណសី ។ ព្រះពោធិសត្វបង្ហឹកដំរីមង្គលរបស់ព្រះរាជានោះទុកហើយយ៉ាងល្អ ព្រះរាជានោះទ្រង់ព្រះតម្រិះថានឹងដណ្ដើមរាជសម្បត្តិ ក្នុងនគរពារាណសី ទើបបបួលព្រះ

ពោធិសត្វឡើងដំរីមង្គលយាងទៅព័ទ្ធនគរពារាណសីដោយសេនាធំ ហើយទ្រង់បញ្ជូនរាជសាសន៍ដល់ព្រះបាទព្រហ្មទត្តថា តើលើករាជសម្បត្តិឲ្យ ឬច្បាំង ។ ព្រះបាទព្រហ្មទត្តតបថា យើងនឹងច្បាំង ហើយបញ្ជាឲ្យពលនិកាយត្រង់ទ្វារកំពែងនិងប៉មត្រៀមប្រយុទ្ធ ។ ព្រះរាជាជាសត្រូវយកក្រោះស្បែកពាក់ដំរីមង្គលសូម្បីព្រះអង្គក៏ពាក់ក្រោះស្បែកគង់លើកដំរីកាន់សស្ត្រាវុធ ទ្រង់បញ្ជាដំរីចូលកាន់ព្រះនគរដោយបំណងថានឹងទម្លាយព្រះនគរ បង្ក្រាបបច្ចាមិត្តឲ្យអស់ជីវិតដណ្តើមយករាជ្យឲ្យបាន ។ ដំរីមង្គលឃើញទាហានបាចខ្សាច់ដ៏ក្តៅជាដើម លែងនូវថ្មយន្តនិងគ្រឿងប្រហារផ្សេងៗច្រើនយ៉ាងក៏តក់ស្លុតចំពោះសេចក្តីស្លាប់មិនអាចចូលជិតបានទើបចៀសចេញទៅ ។ កាលនោះនាយហត្ថាចារ្យចូលទៅរកដំរីមង្គលនិយាយលួងលោមថា នែដំរី អ្នកល្បីថាជាសត្វក្លាហានក្នុងការចូលសង្គ្រាមឈ្មោះថា ការរាថយយ៉ាងនេះមិនសមគួរ កាលនឹងទូន្មានដំរីទើបពោលគាថាទាំងនេះថា

ម្នាលដំរី អ្នកល្បីថាជាសត្វចូលសង្គ្រាម មានកម្លាំងក្លៀវក្លា
ហេតុអ្វីមកដល់ខ្លោងទ្វារហើយក៏ថយក្រោយទៅវិញ ។
ម្នាលដំរី អ្នកចូរញាំញីទម្លាយនូវសន្ទះទ្វារ ហើយដកកើច
សសរខឿនចេញឲ្យឆាប់ ចូរញាំញីនូវខ្លោងទ្វារហើយចូលទៅ
យ៉ាងឆាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតិ វិស្សុតោ** សេចក្តីថា ជាអ្នកប្រាកដគឺដឹងទូទៅយ៉ាងនេះថា ឈ្មោះថា **សង្គាមាវចរោ** ព្រោះពេលចូលសង្គ្រាម

បានញាំញីប្រហារសត្រូវឈ្មោះថា **សូរោ** ព្រោះមានចិត្តអង់អាចនិងឈ្មោះថា **ពលវា** ព្រោះសម្បូរដោយកម្លាំង ។ បទថា **តោរណមាសជ្ជ** បានដល់មកដល់ខ្លោងទ្វារក្រុងហើយ ។ បទថា **បដិក្កមសិ** គឺ នាយហត្ថាចារ្យពោលថា ហេតុអ្វីទើបរាថយ គឺព្រោះហេតុអ្វីទើបត្រឡប់ ។ បទថា **ឱមទ្ទ** បានដល់ ចូរញាំញីទម្លាយនូវសន្ទះទ្វារចូលទៅ គឺចូររុលទៅមុខ ។ បទថា **ឯសិកានិ ច ឧព្យូហ** សេចក្តីថា សសរខឿនដែលគេកប់ទុកយ៉ាងមាំចូលទៅក្នុងផែនដី ១៦ ហត្ថឬ ៨ ហត្ថដែលនៅទីផទ្វារក្រុងមាន អ្នកចូរដក គឺចូរកើចសសរខឿននោះចេញឲ្យធាប់ចុះ នាយហត្ថាចារ្យបានប្រាប់ដូច្នេះ ។ បទថា **តោរណានិ ច មទ្ទិត្វា** គឺ ចូរទម្លាយសន្ទះទ្វារនគរ ។ បទថា **ខិប្បំ បវិស** គឺ ចូរប្រញាប់ចូលទ្វារនគរ ។ លោកហៅដំរីថា កុញ្ជរ ។

ដំរីមង្គលបានស្តាប់ដូច្នោះ ក៏បែរត្រឡប់ ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះពោធិសត្វត្រឹមតែម្តងប៉ុណ្ណោះ ហើយយកប្រមោយចាប់សសរខឿនដកឡើងដូចដកផ្សិតដូច្នោះ ហើយទម្លាយសសរបន្ទាយដកនូវនុកទ្វារ ទម្លាយទ្វារក្រុងចូលព្រះនគរ ដណ្តើមរាជសម្បត្តិថ្វាយព្រះរាជា ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ដំរីក្នុងកាលនោះ បានមកជានន្ទក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែកហត្ថាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាសង្គាមាវចរជាតក ចប់

## វារុណទូសកជាតក

[ ២១៥ ] ( ព្រះរាជាពារាណសីត្រាស់ថា ) សេចក្តីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលច្រោះដោយសម្បកក្រចៅ មានរសតិច ជារបស់ថោកទាប សេចក្តីស្រវឹងមិនកើតដល់ពួកសេះសិន្ធវៈ ព្រោះផឹកទឹកមានរសដ៏ឧត្តមនេះទេ ។

[ ២១៦ ] ( អាមាត្យពោធិសត្វក្រាបទូលថា ) បពិត្រព្រះអង្គជាធំជាងជន សត្វដែលមានជាតិថោកទាបផឹកទឹកមានរសតិចហើយ សត្វនោះត្រូវទឹកមានរសតិចពាល់ត្រូវហើយ រមែងស្រវឹង ចំណែកសត្វអ្នកនាំនូវធុរៈនឹងមានមារយាទកើតក្នុងត្រកូល ( ដ៏ខ្ពស់ ) បានផឹកទឹកមានរសដ៏ប្រសើររមែងមិនស្រវឹងទេ ។

**ចប់ វារុណទូសកជាតកទី ៣ ។**

## អដ្ឋកថា

## វារុណទូសកជាតក

[ ២១៥-២១៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នកស៊ីដែល ៥០០ នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វារុណទូសកំ អប្បរសំ និហីនំ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថីមានឧបាសក ៥០០ ប្រគល់នូវការគ្រប់គ្រងក្នុងផ្ទះឲ្យបុត្តកិរិយា ហើយធ្វើដំណើររួមគ្នាទៅស្តាប់ព្រះធម្មទេសនារបស់ព្រះ

សាស្តា ឧបាសកទាំងនោះពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះក៏បានជាព្រះអនាគាមីមិនមានបុថុជ្ជនសូម្បីតែម្នាក់ ។ មហាជន កាលនិមន្តព្រះសាស្តាក៏អញ្ជើញឧបាសកទាំងនោះរួមផងដែរ ។ តែអ្នកបម្រើ ៥០០ ធ្វើនាទីឲ្យឈើស្ទន់ ទឹកលុបមុខ សំពត់ គ្រឿងក្រអូបនិងផ្កាដល់ពួកគាត់ជាអ្នកស៊ីដែលនៅអាស្រ័យជាមួយអ្នកបម្រើទាំងនោះ បរិភោគអាហារព្រឹកហើយក៏នាំគ្នាចូលដេក លុះភ្ញាក់ឡើងនាំគ្នាទៅកាន់ស្ទឹងអចិរវតីស្រែកហ៊ោប្រទ្បេងគ្នាត្រង់ច្រាំងស្ទឹង ។ ឧបាសក ៥០០ នោះមានសំឡេងតិចមានការអ៊ូអរតិច ខ្វល់ខ្វាយក្នុងការពួនសម្ងំ ។ ព្រះសាស្តាទ្រង់ស្តាប់សំឡេងអឺងកងរបស់អ្នកស៊ីដែលទាំងនោះ ទើបត្រាស់សួរព្រះថេរៈថា ម្នាលអានន្ទ នុ៎ះសំឡេងអ្វី ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នោះជាសំឡេងអ្នកស៊ីដែល ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកស៊ីដែលទាំងនេះបរិភោគអាហារដែលជាសំណល់ហើយនាំគ្នាហ៊ោកញ្ជ្រៀវមិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុនជនទាំងនេះក៏ហ៊ោកញ្ជ្រៀវដូចគ្នា សូម្បីពួកឧបាសកទាំងនេះក៏នាំគ្នាស្ងប់មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ទោះក្នុងកាលមុនក៏នាំគ្នាស្ងប់ដូចគ្នា កាលព្រះថេរៈក្រាបទូលអារាធនាទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ កាលចម្រើនវ័យហើយក៏បានជាអ្នកថ្វាយអត្ថនិងធម៌ដល់ព្រះរាជា ។ សម័យមួយព្រះរាជាទ្រង់ជ្រាបថា នៅឯ

ជាយដែនកើតចលាចល ទើបត្រាស់ឲ្យត្រៀមសេះសិន្ធព ៥០០ ទ្រង់យាន ចេញ មួយអន្លើដោយចតុរង្គសេនា កាលបង្ក្រាបជាយដែនឲ្យរាបទាបហើយ ក៏យាងត្រឡប់មកនគរពារាណសីវិញមានព្រះរាជឱង្ការថា សេះសិន្ធពលំបាក ច្រើន ចូរពួកលោកឲ្យទឹកច័នស្រស់ដល់សេះទាំងនោះ ។ សេះទាំងនោះ កាលផឹកទឹកច័នក្រអូបហើយក៏ត្រឡប់ទៅកាន់រោងសេះសម្រាករៀងៗខ្លួន ។ កាកផ្លែច័ន៍ដែលប្រេបាច់ឲ្យសេះទាំងនោះមានទឹកជាប់នៅបន្តិចបន្តួច មនុស្ស ទាំងឡាយទូលសួរព្រះរាជាថា ឥឡូវនេះពួកទូលព្រះបង្គំ នឹងធ្វើដូចម្ដេច ព្រះរាជាត្រាស់ថា ចូរប្រេបាច់ជាមួយទឹកហើយត្រងដោយសំពត់សម្បកក្រចៅ រួចត្រាស់ថា អ្នកទាំងឡាយ ចូរឲ្យដល់លាដែលនាំអាហារមកឲ្យសេះសិន្ធព ។ លាទាំងឡាយផឹកទឹកសំណល់នោះហើយ ក៏ស្រវឹងដើរស្រែកជុំវិញលានព្រះ រាជវាំង ។ ព្រះរាជាទ្រង់បើកបង្អួចទតទៅកាន់លានព្រះរាជវាំងត្រាស់ហៅ ព្រះពោធិសត្វដែលគាល់នៅក្បែរសួរថា អ្នកដ៏ចម្រើន មើលចុះលាទាំងនេះ ផឹកទឹកកាកច័នដែលប្រោះដោយសម្បកក្រចៅស្រវឹងហើយនាំគ្នាស្រែកលោត ទៅលោតមក ឯសេះសិន្ធពកើតក្នុងត្រកូលសិន្ធព សូម្បីផឹកទឹកច័នក្រអូបក៏ មិនមានសំឡេង ជាសត្វស្ងប់ស្ងៀមមិនឡូឡាអ្វីជាហេតុហ្ន៎ ទើបត្រាស់គាថា ទីមួយថា

សេចក្ដីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលប្រោះ
ដោយសម្បកក្រចៅមានរសតិច ជារបស់ថោកទាប សេចក្ដី
ស្រវឹងមិនកើតដល់ពួកសេះសិន្ធវៈ ព្រោះផឹកទឹកមានរសដ៏ឧត្ដម

នេះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាលោទកំ** បានដល់ ទឹកដែលប្រោះដោយសម្បកក្រចៅ ។ បាឋៈថា **វាលុទកំ** ក៏មាន ។ បទថា **និហីនំ** គឺ ថោកទាបតាមសភាវៈរបស់ទឹកមានរសអាក្រក់ ។ បទថា **ន សញ្ញាយតិ** បានដល់ ការស្រវឹង រមែងមិនកើតដល់សេះសិន្ធពទាំងឡាយ ។ ព្រះរាជាត្រាស់សួរព្រះពោធិសត្វថា អ្វីជាហេតុហ្ន៎ ។ ព្រះពោធិសត្វកាលនឹងក្រាបទូលហេតុដល់ព្រះរាជាទើបពោលគាថាទីពីរថា

បពិត្រព្រះអង្គជាធំជាងជន សត្វដែលមានជាតិថោកទាប ផឹកទឹកមានរសតិចហើយ សត្វនោះត្រូវទឹកមានរសតិចពាល់ត្រូវហើយរមែងស្រវឹង ចំណែកសត្វអ្នកនាំនូវធុរៈនឹងមានមារយាទកើតក្នុងត្រកូល ( ដ៏ខ្ពស់ ) បានផឹកទឹកមានរសដ៏ប្រសើររមែងមិនស្រវឹងទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេន ជនិន្ទ ផុដ្ឋោ** សេចក្ដីថា បពិត្រព្រះអង្គជាធំជាងជន គឺបពិត្រក្សត្រដែលមានសក្តិធំ លានោះមានធាតុអាក្រក់ជាសភាវៈ កាលត្រូវភាពដែលមានធាតុអាក្រក់ពាល់ត្រូវរមែងស្រវឹង ។ បទថា **ធោរយ្ហសីលី** បានដល់ មានធុរៈឲ្យសម្រេច គឺសេះសិន្ធពដែលដល់ព្រមដោយមារយាទតែងនាំធុរៈទៅ ។ បទថា **អគ្គរសំ** សេចក្ដីថា សេះសិន្ធពសូម្បីផឹករសផ្លែច័ន្ទដែលត្រងដំបូងក៏មិនស្រវឹង ។

ព្រះរាជា ទ្រង់ស្ដាប់ពាក្យរបស់ព្រះពោធិសត្វហើយ ត្រាស់ឲ្យដេញលា

ចេញអំពីលានព្រះរាជវាំង ទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យមានទានជាដើមហើយទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា លា ៥០០ ក្នុងកាលនោះបានមកជាអ្នកស៊ីដែលក្នុងកាលឥឡូវនេះ សេះសិន្ធព ៥០០ ក្នុងកាលនោះបានមកជាឧបាសក ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ ចំណែកអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វាលោទកជាតក ចប់

# គិរិទត្តជាតក

[ ២១៧ ] ( អាមាត្យពោធិសត្វក្រាបទូលថា ) សេះឈ្មោះ បណ្ឌវៈ របស់ព្រះរាជាទ្រង់ព្រះនាមសាមៈ ដែលគង្វាលឈ្មោះគិរិទត្តប្រទូសរ៉ាយហើយ បានលះប្រក្រតីរបស់ខ្លួនពីដើមចេញ ហើយប្រព្រឹត្តតាមនាយគង្វាលនោះ ។

[ ២១៨ ] ជាបើបុរសមានជាតិដ៏សមគួរដល់សេះនោះ កាត់កោរសក់ និងពុកមាត់ដោយអាការៈដ៏ល្អ គប្បីកាន់សេះនោះត្រង់បង្ហៀរ ហើយដឹកក្រឡឹង ក្នុងមណ្ឌលក្រោល សេះនោះនឹងលះបង់នូវ ( អាការៈខ្វក់ចេញ ) ហើយធ្វើ តាមបុរសនោះវិញដោយឆាប់ ។

**ចប់ គិរិទត្តជាតកទី ៤ ។**

## អដ្ឋកថា

## គិរិទត្តជាតក

[ ២១៧-២១៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុ សេពគប់ខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទូសិតោ គិរិទត្តេន** ដូច្នេះជាដើម ។

រឿងបានពោលទុកហើយក្នុងមហិឡាមុខជាតក ( ឯកនិបាត ) ខាងដើម នោះឯង ។

តែក្នុងរឿងនេះព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះសេព គប់ខុស មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏សេព

គប់ខុសដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះរាជាព្រះនាមថាសាមៈ ទ្រង់គ្រងរាជសម្បត្តិ ក្នុងនគរពារាណសី កាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ ចម្រើនវ័យហើយក៏បានជាអ្នកបង្រៀនអត្ថនិងធម៌របស់ព្រះរាជា ។ ព្រះរាជាមានសេះមង្គលមួយឈ្មោះបណ្ឌវៈ ។ អ្នកគង្វាលសេះរបស់ព្រះរាជាអង្គនោះ ឈ្មោះគិរិទត្ត ។ គាត់មានជើងខ្ចក ។ សេះឃើញនាយគិរិទត្តកាន់បង្ហៀរដើរខាងមុខសម្គាល់ថា បុរសនេះបង្រៀនអញទើបរៀនតាមក៏ក្លាយជាសេះខ្ចកទៅ ។ ទើបគិរិទត្តក្រាបទូលអំពីអាការៈខ្ចករបស់សេះឲ្យព្រះរាជាទ្រង់ជ្រាប ។ ទើបព្រះរាជាទ្រង់បញ្ជូនពេទ្យទៅពិនិត្យមើលអាការៈ ។ ពួកពេទ្យទៅពិនិត្យមើលក៏មិនឃើញរោគក្នុងខ្លួនសេះ ទើបក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំទៅពិនិត្យ មិនឃើញមានរោគអ្វីក្នុងខ្លួនសេះទេ ។ ទើបព្រះរាជាទ្រង់បញ្ជូនព្រះពោធិសត្វទៅថា ចូរអ្នកទៅមើលហេតុការណ៍ របស់សេះ ។ ព្រះពោធិសត្វទៅពិនិត្យមើលក៏ដឹងថា សេះនោះខ្ចកព្រោះទាក់ទងនឹងគង្វាលសេះជើងខ្ចក ទើបក្រាបទូលរឿងនោះដល់ព្រះរាជា កាលសម្ដែងឲ្យឃើញហេតុនោះព្រោះទោសដែលទាក់ទងគ្នាទើបពោលគាថាទីមួយថា

សេះឈ្មោះបណ្ឌវៈ របស់ព្រះរាជាទ្រង់ព្រះនាមសាមៈ ដែល
គង្វាលឈ្មោះគិរិទត្តប្រទូសរ៉ាយហើយ បានលះប្រក្រតីរបស់
ខ្លួនពីដើមចេញ ហើយប្រព្រឹត្តតាមនាយគង្វាលនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហយោ សាមស្ស** បានដល់ សេះមង្គល

របស់ព្រះបាទសាមៈ ។ បទថា **ចោរាណំ បកតឹ ហិត្វា** បានដល់ លះប្រក្រតីដើមដែលជាសម្បត្តិរបស់ខ្លួន ។ បទថា **តស្សេវ អនុវិធិយ្យតិ** បានដល់ សិក្សាយកតម្រាប់ ។

លំដាប់នោះទើបព្រះរាជាត្រាស់សួរថា ឥឡូវនេះគួរធ្វើដូចម្តេចដល់សេះនោះ ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ បើបានអ្នកគង្វាលសេះដ៏ល្អសមគួរហើយសេះនឹងវិលត្រឡប់ដូចដើមវិញ ហើយពោលគាថាទីពីរថា

ថាបើបុរសមានជាតិដ៏សមគួរដល់សេះនោះ កាត់កោរសក់និង
ពុកមាត់ដោយអាការៈដ៏ល្អ គប្បីកាន់សេះនោះត្រង់បង្ហៀរ
ហើយដឹកក្រឡឹងក្នុងមណ្ឌលក្រោល សេះនោះនឹងលះបង់នូវ
( អាការៈខ្ចកចេញ ) ហើយធ្វើតាមបុរសនោះវិញដោយឆាប់
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តនុជោ** បានដល់ ជាអ្នកកើតតាម គឺសមគួរដល់សេះនោះ បុរសណាសមគួរដល់សេះនោះបុរសនោះឈ្មោះថាជាគំរូរបស់សេះនោះ ។ សេចក្តីនេះលោកអធិប្បាយទុកថា បពិត្រមហារាជ បើមានបុរសមានជាតិដ៏សមគួរដល់សេះដែលដល់ព្រមដោយមារយាទ គួរឲ្យស្រឡាញ់នោះឈ្មោះថា ដល់ព្រមដោយអាចារៈ ។ បទថា **សិង្គារាការ-កប្បិតោ** សេចក្តីថា បុរសនោះតាក់តែងសក់ និងពុកមាត់ដោយអាការដែលគួរស្រឡាញ់ គឺស្អាតគប្បីចាប់សេះនោះត្រង់បង្ហៀរដឹកដើរធ្វើលក្នុងមណ្ឌលក្រោល សេះនោះនឹងលះបង់កាពខ្ចកនេះក្នុងកាលមិនយូរនឹងយកតម្រាប់ គឺ

សិក្សាតាមបុរសនោះវិញ គឺនឹងតាំងនៅក្នុងភាពជាប្រក្រតី ដោយសម្គាល់ថា អ្នកគង្វាលសេះគួរស្រឡាញ់ដល់ព្រមដោយមារយាទនេះឲ្យអញយកតម្រាប់ ។

ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ សេះក៏តាំងនៅក្នុងភាពប្រក្រតី ។ ព្រះរាជាទ្រង់ត្រេកអរថា បុរសនេះដឹងអធ្យាស្រ័យសូម្បីរបស់សត្វតិរច្ឆាន ទើបទ្រង់ប្រទានយសធំដល់ព្រះពោធិសត្វ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា គិរិទត្តក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ សេះក្នុងកាលនោះ បានមកជាភិក្ខុដែលសេពគប់មិត្តខុស ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ ឯអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គិរិទត្តជាតក ចប់

## អនភិរតិជាតក

[ ២១៩ ] ( អាចារ្យទិសាបាមោក្ខពោលថា ) កាលបើទឹកល្អក់មិនថ្លា បុគ្គលរមែងមើលមិនឃើញនូវខ្យង ខ្ចៅនិងក្រួស ដីខ្សាច់ ហ្វូងត្រី យ៉ាងណាមិញកាលបើចិត្តល្អក់ហើយ បុគ្គលនោះក៏មើលមិនឃើញនូវប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃយ៉ាងនោះដែរ ។

[ ២២០ ] កាលបើទឹកថ្លាស្អាត បុគ្គលរមែងមើលឃើញនូវខ្យង ខ្ចៅនិងក្រួស ខ្សាច់ ហ្វូងត្រីបាន យ៉ាងណាមិញកាលបើចិត្តមិនល្អក់ហើយបុគ្គលនោះក៏មើលឃើញនូវប្រយោជន៍របស់ខ្លួននិងប្រយោជន៍អ្នកដទៃបានយ៉ាងនោះដែរ ។

**ចប់ អនភិរតិជាតកទី ៥ ។**

## អដ្ឋកថា
## អនភិរតិជាតក

[ ២១៩-២២០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថោ-ទកេ អាវិលេ អប្បសន្នេ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថីមានព្រាហ្មណកុមារម្នាក់រៀនចប់ត្រៃវេទ បង្រៀនមន្តពួកកុមារដែលជាក្សត្រនិងកុមារដែលជាព្រាហ្មណ៍ជាច្រើន ។ គ្រាតមកបុរសនោះនៅគ្រប់គ្រងផ្ទះ ធ្លាក់ក្នុងអំណាចរាគៈ ទោសៈ មោហៈ គិតតែរឿង

សំពត់គ្រឿងប្រដាប់ ទាសៈទាសី ស្រែចម្ការ គោក្របី បុត្តនិងភរិយាជាដើម ទើបមានចិត្តល្អក់កករមិនអាចពិនិត្យមន្តឲ្យដឹងខុសត្រូវតាមលំដាប់បាន មន្តទាំងឡាយក៏ស្រពិចស្រពិល ទាំងខាងដើមនិងខាងចុង ។ ថ្ងៃមួយបុរសនោះ ( កាន់យកគ្រឿងក្រអូបនិងផ្កាជាដើម ) ទៅកាន់វត្តជេតពនបូជាព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈត្រាស់សួរថា ម្នាលមាណព អ្នកនៅបង្រៀនមន្តឬ មន្តរបស់អ្នកស្ទាត់ជំនាញឬ បុរសនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុនមន្តរបស់ខ្ញុំព្រះអង្គស្ទាត់ជំនាញល្អ តាំងអំពីខ្ញុំព្រះអង្គគ្រប់គ្រងឃរាវាសចិត្តរបស់ខ្ញុំព្រះអង្គល្អក់កករ ដោយហេតុនោះទើបមន្តរបស់ខ្ញុំព្រះអង្គមិនប្រាកដច្បាស់ ។ លំដាប់នោះព្រះសាស្តាត្រាស់ថា ម្នាលមាណព មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន មន្តរបស់អ្នកប្រាកដច្បាស់ក្នុងកាលដែលចិត្តរបស់អ្នកមិនល្អក់កករ តែក្នុងកាលដែលចិត្តល្អក់កករ ដោយរាគៈជាដើម មន្តរបស់អ្នកក៏ស្រពិចស្រពិល កាលបុរសនោះទូលអារាធនាទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល កាលចម្រើនវ័យបានទៅរៀនមន្តក្នុងនគរតក្កសិលាបានជាអាចារ្យទិសាបាមោក្ខបង្រៀនមន្តដល់ខត្តិយកុមារនិងព្រាហ្មណកុមារជាច្រើនក្នុងនគរពារាណសី ។ ព្រាហ្មណ៍មាណពម្នាក់ក្នុងសម្នាក់របស់ព្រះពោធិសត្វនោះបានសិក្សាត្រៃវេទរហូតជំនាញ សូម្បី

តែបទមួយក៏មិនសង្ស័យបានជាអាចារ្យបង្រៀននូវមន្ត ។ តមកព្រាហ្មណ៍មាណពនោះនៅគ្រប់គ្រងផ្ទះមានចិត្តល្អក់កករ មិនអាចសូធ្យមន្តបានព្រោះគិតតែគ្រប់គ្រងផ្ទះ ។ កាលអាចារ្យសួរថា មាណព មន្តរបស់អ្នកនៅស្ទាត់ជំនាញឬ បុរសនោះឆ្លើយថា តាំងពីគ្រប់គ្រងផ្ទះចិត្តរបស់ខ្ញុំល្អក់កករ មិនអាចសាធ្យាយមន្តបាន ។

អាចារ្យពោលថា កាលចិត្តល្អក់កករហើយមន្តដែលរៀនសូម្បីជំនាញក៏រលុបរលាយបាន តែកាលចិត្តមិនល្អក់កករមន្តទាំងឡាយដែលសិក្សាហើយមិនភ្លេចភ្លាំងឡើយហើយពោលគាថាពីរថា

កាលបើទឹកល្អក់មិនថ្លា បុគ្គលរមែងមើលមិនឃើញនូវខ្យង ខ្ចៅនិងក្រួស ដីខ្សាច់ ហ្វូងត្រី យ៉ាងណាមិញកាលបើចិត្តល្អក់ហើយ បុគ្គលនោះក៏មើលមិនឃើញនូវប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃយ៉ាងនោះដែរ ។

កាលបើទឹកថ្លាស្អាត បុគ្គលរមែងមើលឃើញនូវខ្យង ខ្ចៅនិងក្រួស ខ្សាច់ ហ្វូងត្រីបាន យ៉ាងណាមិញកាលបើចិត្តមិនល្អក់ហើយ បុគ្គលនោះក៏មើលឃើញនូវប្រយោជន៍របស់ខ្លួននិងប្រយោជន៍អ្នកដទៃបានយ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាវិលេ** គឺ ល្អក់ដោយកក់ ។ បទថា **អប្បសន្នេ** គឺ មិនថ្លាព្រោះល្អក់នោះឯង ។ បទថា **សិប្បិកសម្ពុកញ្ច** បានដល់ ខ្យងផង ខ្ចៅផង ។ បទថា **មច្ឆគុម្ពំ** បានដល់ ហ្វូងត្រី ។ បទថា **ឃរំ**

**អាវិលម្ហិ** សេចក្តីថា កាលចិត្តល្អក់កករដោយរាគៈជាដើមក៏ដូច្នោះដូចគ្នា ។ បទថា **អត្តត្ថំ បរត្ថំ** បានដល់ មិនឃើញប្រយោជន៍ខ្លួន មិនឃើញប្រយោជន៍អ្នកដទៃ ។ បទថា **សោ បស្សតិ** សេចក្តីថា កាលចិត្តមិនល្អក់ បុគ្គលនោះរមែងឃើញប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃដូច្នោះដូចគ្នា ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសអរិយសច្ច កាលចប់អរិយសច្ច ព្រាហ្មណកុមារតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា មាណពក្នុងកាលនោះ បានមកជាមាណពក្នុងកាលឥឡូវនេះ ឯអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា អនភិរតិជាតក ចប់

## ទធិវាហនជាតក

[ ២២១ ] ( ព្រះបាទទធិវាហនត្រាស់សួរថា ) ក្នុងកាលមុនដើមស្វាយនេះប្រកបដោយពណ៌ក្លិននិងរស បាននូវគ្រឿងសក្ការបូជានោះដដែល ហេតុអ្វីស្វាយក៏មានផ្លែល្វីងទៅវិញ ។

[ ២២២ ] ( អាមាត្យពោធិសត្វពោលថា ) បពិត្រព្រះរាជាទ្រង់ព្រះនាមទធិវាហនៈ ស្វាយរបស់ព្រះអង្គ មានដើមស្ដៅជុះរួបរឹតជុំវិញ ឫសប្រទ្បំគ្នាដោយឫស មែកពាក់ព័ន្ធគ្នានឹងមែក ដោយការនៅជាមួយនឹងដើមស្ដៅ មិនមានរសផ្អែម ព្រោះហេតុនោះបានជាស្វាយត្រឡប់ជាមានផ្លែល្វីងទៅវិញ ។

**ចប់ ទធិវាហនជាតកទី ៦ ។**

## អដ្ឋកថា
## ទធិវាហនជាតក

[ ២២១-២២២ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុសេពគប់ខុស ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **វណ្ណគន្ធរសូបេតោ** ដូច្នេះជាដើម ។

រឿងខ្ញុំបានពោលទុកហើយខាងដើមនោះឯង ។

ក្នុងរឿងនេះព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការនៅរួមគ្នាជាមួយអសប្បុរសជារបស់ថោកទាបធ្វើតែសេចក្ដីវិនាស ។ ក្នុងការនៅរួមគ្នានោះមិនថាតែនៅរួមជាមួយបុគ្គលអាក្រក់ធ្វើតែសេចក្ដីវិនាសឲ្យដល់

មនុស្ស កាលមុនសូម្បីតែដើមស្វាយដែលមិនមានចិត្ត មានរសឆ្ងាញ់ប្រៀប ដូចរសទិព្វ អាស្រ័យនៅរួមជាមួយដើមស្ពោដែលមិនគួរពេញចិត្តមិនមានរស ឆ្ងាញ់គង់ល្វីងបាន ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅ នេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រាហ្មណ៍ ៤ នាក់បងប្អូន ក្នុងដែនកាសីបួសជាឥសី សាងបណ្ណសាលានៅ អាស្រ័យតាមលំដាប់គ្នា ក្នុងហិមវន្តប្បទេស ។ បងប្រុសច្បងរបស់ពួក ព្រាហ្មណ៍ស្លាប់ទៅកើតជាសក្កទេវរាជទ្រង់ជ្រាបហេតុការណ៍នោះ កន្លងទៅ ៧-៨ ថ្ងៃតាមលំដាប់ ទ្រង់យាងទៅមើលតាបសទាំងនោះ ។ ថ្ងៃមួយទ្រង់ទៅ នមស្ការតាបសបងប្រថាប់គង់ក្នុងចំណែកម្ខាងត្រាស់សួរថា លោកម្ចាស់ត្រូវ ការអ្វី តាបសនោះកើតរោគស្គមលឿងទើបថ្វាយព្រះពរថា អាត្មាត្រូវការភ្លើង ទើបសក្កទេវរាជប្រគេនកាំបិតធំ ។ កាំបិតមានដងប្រើជាកាំបិតក៏បាន ប្រើជា ពូថៅក៏បាន ឈ្មោះថា កាំបិតធំ ។ តាបសថ្វាយព្រះពរថា អ្នកណានឹងប្រើ កាំបិតនេះរកឧសមកឲ្យអាត្មាបាន ទើបសក្កៈត្រាស់នឹងតាបសនោះថា បើ លោកម្ចាស់ត្រូវការឧសក៏ចូរយកដៃទះកាំបិតធំនេះហើយប្រាប់ថា ចូររកឧស មកបង្កាត់ភ្លើងឲ្យយើង កាំបិតធំនេះនឹងរកឧសមកបង្កាត់ភ្លើងឲ្យ កាលសក្ក- ទេវរាជប្រទានកាំបិតធំដល់តាបសនោះហើយ ទើបចូលទៅរកតាបសទីពីរត្រាស់ សួរថា លោកម្ចាស់ត្រូវការអ្វី ។ ក្បែរបណ្ណសាលានៃតាបសនោះជាផ្លូវដើរ របស់ដំរី តាបសត្រូវដំរីបៀតបៀនទើបថ្វាយព្រះពរថា អាត្មាលំបាកព្រោះដំរី

សូមទ្រទ្រង់ដេញវាទៅចុះ ។ ទើបសក្កៈឲ្យស្គរមួយដល់តាបសនោះហើយប្រាប់ថា កាលលោកម្ចាស់វាយស្គរខាងនេះ សត្រូវនឹងគេចទៅ កាលលោកម្ចាស់វាយខាងនេះ សត្រូវនឹងមានមេត្តា ចោមរោមលោកម្ចាស់ដោយចតុរង្គសេនា កាលប្រគេនស្គរនោះហើយទើបយាងទៅកាន់សម្នាក់តាបសទី ៣ ត្រាស់សួរថា លោកម្ចាស់ត្រូវការអ្វី សូម្បីតាបសនោះ ក៏កើតរោគស្អមលឿងព្រោះហេតុនោះទើបថ្វាយព្រះពរថា អាត្មាត្រូវការទឹកដោះជូរ ទើបសក្កៈប្រគេនថ្នាំងទធិមួយដល់តាបសនោះហើយត្រាស់ថា បើលោកម្ចាស់ត្រូវការចូរផ្អៀងថ្នាំងនេះនឹងកើតជាស្ទឹងធំមានជំនន់ហូរទៅថែមទាំងអាចយករាជសម្បត្តិដល់លោកម្ចាស់បានលុះប្រាប់ហើយក៏យាងត្រឡប់ ។

តាំងអំពីកាលនោះមក កាំបិតធំក៏បន្ទាត់ភ្លើងឲ្យតាបសដែលជាបង គ្រាតាបសអង្គទី ២ វាយស្គរដំរីក៏គេចទៅ ។ តាបសជាប្អូនក៏ឆាន់ទឹកដោះជូរ ។ ក្នុងកាលនោះមានជ្រូកមួយត្រាច់ទៅកាន់ស្រុកដែលគេបោះបង់មួយកន្លែងបានជួបកែវមណីដែលទ្រទ្រង់នូវអានុភាព ទើបពាំកែវមណីនោះហោះទៅលើអាកាសដោយអានុភាពរបស់កែវមណី ទៅដល់កោះមួយកណ្ដាលសមុទ្ទ គិតថា ពេលនេះអញគួរនៅក្នុងទីនេះហើយចុះសម្រាកក្រោមដើមល្វាមួយដើមក្នុងទីដែលជាផាសុក ។ ថ្ងៃមួយជ្រូកដាក់កែវមណីទុកខាងមុខហើយដេកលក់ក្រោមដើមល្វានោះ ។

ក្នុងកាលនោះបុរសដែនកាសីម្នាក់ត្រូវមាតាបិតាបណ្ដេញចេញអំពីផ្ទះដោយគិតថា ក្មេងនេះមិនជួយធ្វើកិច្ចការអញឡើយទើបទៅដល់កំពង់មួយ

កន្លែងធ្វើជាកម្មករក្នុងសំពៅដោយសារសំពៅទៅ កាលសំពៅបែកធ្លាយកណ្តាលសមុទ្រទើបដេកលើបន្ទះក្តារអណ្តែតទៅដល់កោះមួយ ដើរស្វែងរកផ្លែឈើ កាលឃើញជ្រូកនោះដេកលក់ ទើបលបចូលទៅលួចយកកែវមណីហើយហោះទៅលើអាកាសដោយអានុភាពនៃកែវមណីនោះរួចត្រឡប់មកអង្គុយលើដើមល្វាគិតថា ប្រហែលជាជ្រូកនេះត្រាច់ទៅក្នុងអាកាសដោយអានុភាពនៃកែវមណីនេះហើយមកសម្រាកនៅក្នុងទីនេះ អញគួរសម្លាប់ជ្រូកនេះស៊ីសាច់សិនសឹមទៅក្នុងកាលជាក្រោយ ទើបបុរសនោះកាច់មែកឈើមួយទម្លាក់លើក្បាលជ្រូក ។ ជ្រូកក្រោកឡើងមិនឃើញកែវមណីទើបរសាប់រសល់ស្ទុះធ្លាទៅមក ។ បុរសអង្គុយលើដើមឈើសើច ជ្រូកងើយមើលឃើញបុរសនោះក៏យកក្បាលជល់ដើមឈើនោះស្លាប់មួយរំពេច ។ បុរសនោះចុះពីដើមឈើ បង្កាត់ភ្លើងអាំងសាច់ជ្រូកបរិភោគ ហើយហោះឡើងទៅលើអាកាសដល់ទីបំផុតនៃហិមវន្តប្បទេសឃើញអាស្រមតាបស ទើបចុះត្រង់អាស្រមតាបសដែលជាបងបានធ្វើវត្តបដិបត្តិតាបស ២-៣ ថ្ងៃនិងបានឃើញអានុភាពរបស់កាំបិតធំទើបបុរសនោះគិតថា អញគួរយកកាំបិតនេះឲ្យបានទើបអួតអានុភាពនៃកែវមណីដល់តាបសហើយពោលថា សូមលោកម្ចាស់យកកែវមណីនេះហើយឲ្យកាំបិតធំដល់ខ្ញុំចុះ ។ តាបសចង់ត្រាច់ទៅក្នុងអាកាសដែរទើបទទួលយកកែវមណីហើយឲ្យកាំបិតធំដល់បុរសនោះ ។ បុរសនោះកាលបានកាំបិតធំដើរទៅបានបន្តិចទើបទះកាំបិតធំប្រាប់ថា នែ កាំបិតធំចូរឯងកាត់ក្បាលតាបសហើយយកកែវមណីមកឲ្យយើង ។ កាំបិតធំក៏ទៅកាត់

ក្បាលតាបស ហើយនាំយកកែវមណីមកឲ្យ ។ បុរសនោះលាក់កាំបិតជំក្នុង ទីកំបាំងហើយដើរទៅរកតាបសទី ២ ស្នាក់នៅ ២-៣ ថ្ងៃក៏បានឃើញអានុភាព របស់ស្គរទើបដូរកែវមណីជាមួយស្គរ ហើយឲ្យកាំបិតជំកាត់ក្បាលតាបសរូប នោះដូចមុននោះឯងទើបចូលទៅរកតាបសចុងក្រោយ ក៏បានឃើញអានុភាព របស់ថ្នាំងទធិទើបយកកែវមណីដូរថ្នាំងទឹកដោះជូរនោះ ហើយឲ្យកាំបិតជំកាត់ ក្បាលតាបសនោះដោយន័យមុននោះឯង កាន់យកកែវមណី កាំបិតជំ ស្គរ ថ្នាំងទឹកដោះជូរហោះទៅតាមអាកាស ហើយចុះក្នុងទីមិនឆ្ងាយអំពីនគរពារា-ណសីឲ្យបុរសម្នាក់នាំសំបុត្រទៅថា ព្រះបាទពារាណសីច្បាំងជាមួយយើង ឬ ឲ្យរាជសម្បត្តិដល់យើង ព្រះរាជាស្តាប់សាសន៍ប៉ុណ្ណោះ ក៏យាងចេញបំណង ជានឹងចាប់ចោរ ទើបបុរសនោះវាយស្គរម្ខាងចតុរង្គសេនាក៏ចូលមកចោមរោម ។ បុរសនោះដឹងយ៉ាងពិតប្រាកដថា ព្រះរាជាធ្លាក់ក្នុងកណ្តាប់ដៃរបស់ខ្លួនហើយ ទើបផ្អៀងថ្នាំងទឹកដោះជូរកើតជាជំនន់ទឹកធំហូរទៅ មហាជនលិចក្នុងទឹកដោះ ជូរមិនអាចគេចទៅបានទើបប្រើកាំបិតជំថា ឯងចូរទៅកាត់ក្បាលព្រះរាជានាំ មក ។ កាំបិតជំក៏ទៅកាត់សីសៈព្រះរាជាមកទុកត្រង់ជើងរបស់បុរសនោះ សូម្បីអ្នកចម្បាំងម្នាក់ក៏មិនអាចងារអាវុធបាន ។ បុរសនោះចោមរោមដោយ ពលនិកាយធំ លើកកងទ័ពចូលកាន់នគរ ធ្វើពិធីរាជាភិសេកបានជាព្រះរាជា ព្រះនាមថា ទធិវាហនៈ គ្រប់គ្រងរាជសម្បត្តិដោយធម៌ ។

ថ្ងៃមួយកាលព្រះរាជាទធិវាហនៈទ្រង់ស្រង់ទឹកត្រង់ស្ទឹងធំខាងក្នុងសំណាញ់ ដែលបាំងជុំវិញ ស្វាយទុំមួយជារបស់ទេវតាអណ្តែតមកជាប់សំណាញ់នោះ

រាជបុរសទាំងឡាយលើកសំណាញ់ឡើង ក៏ឃើញស្វាយនោះទើបនាំទៅថ្វាយព្រះរាជា ។ ស្វាយនោះ មានផ្លែមូលប្រមាណប៉ុនក្អមធំ មានពណ៌ដូចមាស ។ ព្រះរាជាត្រាស់សួរព្រានព្រៃថា នេះផ្លែអ្វី ព្រានព្រៃប្រាប់ថាជាផ្លែស្វាយ ទើបត្រាស់ឲ្យដាំក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ហើយឲ្យស្រោចដោយទឹកដោះស្រស់ ។ ដើមស្វាយបានធំចម្រើនលូតលាស់ក្នុងឆ្នាំទី ៣ ក៏ចេញផ្លែ ។ ដើមស្វាយបានទទួលសក្ការៈ ( ការថែទាំ ) ជាច្រើន ។ ពួកបុរសស្រោចដោយទឹកដោះស្រស់ប្រោះព្រំដោយគ្រឿងប្រអូប ៥ ប្រភេទ សំយុងដោយកម្រងផ្កា អុជប្រទីបប្រេងក្រអូប បាំងដោយរាំងនន ជាស្វាយមានរសផ្អែម មានពណ៌ដូចមាស ។

ព្រះបាទទធិវាហនៈ ទ្រង់ផ្ញើផ្លែស្វាយទៅថ្វាយព្រះរាជាដទៃៗយកម្ជុលត្រីចាក់ទម្លុះពន្លកក្នុងគ្រាប់ហើយបញ្ជូនទៅ ព្រោះខ្លាចព្រះរាជាដទៃដាំឲ្យដុះឡើង ។ គ្រាប់ស្វាយដែលព្រះរាជាទាំងនោះសោយហើយឲ្យបណ្តុះក៏មិនដុះ ។ កាលព្រះរាជាទាំងនោះស៊ើបសួរថា អ្វីហ្ន៎ជាហេតុក្នុងរឿងនេះក៏មិនជ្រាបហេតុនោះ ។

ក្រោយមកព្រះរាជាមួយអង្គត្រាស់ឲ្យហៅអ្នកយាមឧទ្យានមកសួរថា ឯងអាចធ្វើរសស្វាយរបស់ព្រះបាទទធិវាហនៈឲ្យក្លាយទៅជាមានរសល្វីងបានដែរឬ កាលអ្នកយាមឧទ្យានក្រាបទូលថា បាន ទើបត្រាស់ថា បើដូច្នោះចូរអ្នកទៅហើយព្រះរាជទានទ្រព្យ ១០០០ ។ បុរសនោះ ទៅដល់នគរពារាណសីហើយឲ្យក្រាបទូលព្រះរាជាថា អ្នកយាមឧទ្យានម្នាក់មកសូមចូលគាល់ កាលព្រះរាជាត្រាស់ថា ឲ្យចូលមកចុះ ទើបបុរសនោះចូលទៅថ្វាយបង្គំព្រះរាជា

កាលព្រះរាជាត្រាស់សួរថា អ្នកជាអ្នកថែឧទ្យានឬ បុរសនោះក្រាបទូលថា ករុណាថ្ងៃវិសេសហើយក៏ពណ៌នាសមត្ថភាពរបស់ខ្លួន ព្រះរាជាត្រាស់ថា ចូរទៅនៅជាមួយអ្នករក្សាឧទ្យានរបស់យើងចុះ ។ តាំងអំពីកាលនោះមកជនទាំងពីរក៏នាំគ្នារក្សាព្រះឧទ្យាន អ្នករក្សាឧទ្យានមកថ្មីមិនបានប៉ុន្មានក៏ធ្វើដើមឈើឲ្យចេញផ្កាពុំដូកាល ឲ្យមានផ្លែពុំដូកាល ធ្វើឲ្យព្រះរាជឧទ្យានគួរជាទីត្រេកអរក្រៃលែង ព្រះរាជាទ្រង់ត្រេកអរនឹងបុរសនោះត្រាស់ឲ្យដកអ្នកយាមឧទ្យានចាស់ចោល បានព្រះរាជទាននាទីរក្សាឧទ្យាន ដល់បុរសនោះដោយចំពោះ ។ បុរសនោះត្រេកអរគិតថា ព្រះរាជឧទ្យានស្ថិតនៅក្នុងកណ្ដាប់ដៃរបស់អញហើយ ទើបដាំដើមស្ដៅនិងវល្លិបណ្ដូលពេចជុំវិញដើមស្វាយនោះ ដើមស្ដៅដុះឡើងដោយលំដាប់ ។ ឫសប្រទ្បំគ្នាដោយឫស មែកពាក់ព័ន្ធគ្នាដោយមែក ។ ព្រោះការសម្ពន្ធគ្នាជាមួយឈើដែលមិនគួរត្រេកអរនិងប្រាសចាករសនោះ ស្វាយដែលមានរសផ្អែមអំពីមុនក៏បែរជាមានរសល្វីង ទើបបុរសនោះគេចទៅ ។ ព្រះបាទទធិវាហនៈយាងទៅព្រះរាជឧទ្យានទ្រង់មិនអាចលេបស្វាយដែលធ្លាក់ចូលដល់ព្រះឱសបានដូចទឹកម្ចត់ធ្វើអំពីស្លឹកស្ដៅ ទ្រង់ស្ដោះព្រះខេឡ្ជៈចោល ។ កាលនោះព្រះពោធិសត្វបានជាអ្នកទូន្មានអត្ថនិងធម៌របស់ព្រះអង្គ ទើបព្រះរាជាប្រឹក្សានឹងព្រះពោធិសត្វថា នែបណ្ឌិតដើមស្វាយនេះ មិនមានការខ្វះខាតក្នុងការមើលថែមកអំពីមុនឡើយ កាលបើដូច្នោះផ្លែរបស់វាបែរជាល្វីងទៅបាន អ្វីហ្ន៎ជាហេតុក្នុងរឿងនេះ កាលទ្រង់ត្រាស់សួរទើបត្រាស់គាថាទីមួយថា

ក្នុងកាលមុនដើមស្វាយនេះប្រកបដោយពណ៌ក្លិននិងរស បាន
នូវគ្រឿងសក្ការបូជានោះដដែល ហេតុអ្វីស្វាយក៏មានផ្លែល្វីង
ទៅវិញ ដូច្នេះ ។

លំដាប់នោះព្រះពោធិសត្វកាលទូលប្រាប់ហេតុរបស់ស្វាយនោះ ទើប
ពោលថាទីពីរថា

បពិត្រព្រះរាជាទ្រង់ព្រះនាមទធិវាហនៈ ស្វាយរបស់ព្រះអង្គ
មានដើមស្ដៅជុះរួបរឹតជុំវិញ ឫសប្រទ្បុំគ្នាដោយឫស មែក
ពាក់ព័ន្ធគ្នានឹងមែក ដោយការនៅជាមួយនឹងដើមស្ដៅមិនមាន
រសផ្អែម ព្រោះហេតុនោះបានជាស្វាយត្រឡប់ជាមានផ្លែល្វីង
ទៅវិញ ដូច្នេះ ។

បទថា **បុចិមន្ទបរិវារោ** ប្រែថា ព័ទ្ធជុំវិញដោយដើមស្ដៅ ។ បទថា
**សាខា សាខំ និសេវរេ** គឺ មែកស្ដៅព័ទ្ធព័ន្ធមែកស្វាយ ។ បទថា **អសា-
តសន្និវាសេន** បានដល់ ព្រោះរួមគ្នាជាមួយស្ដៅដែលមានរសល្វីង ។ បទថា
**តេន** អធិប្បាយថា ព្រោះហេតុនោះទើបស្វាយនេះមានរសក្រាវ មានរសខារ
មានរសល្វីង ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រះពោធិសត្វហើយត្រាស់ឲ្យកាប់ដើមស្ដៅ
និងបណ្ដូលពេចចេញ ឲ្យដកឫសឡើង ជញ្ជូនដីដែលមិនមានរសទៅចោល
ឲ្យចាក់ដីដែលមានរសល្អឲ្យទំនុកបម្រុងដើមស្វាយដោយទឹកដោះ ស្ករ និង
គ្រឿងក្រអូប ។ ព្រោះការប្រឡូកប្រឡំដោយរសល្អទើបស្វាយមានរសដូច

ដើម ។ ព្រះរាជាប្រគល់រាជឧទ្យានដល់អ្នករក្សាឧទ្យានចាស់វិញ ។ ទ្រង់ស្ថិតនៅដរាបអស់ព្រះជន្ម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា អាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទធិវាហនជាតក ចប់

## ចតុមដ្ឋជាតក

[ ២២៣ ] ( ចចកពោលថា ) អ្នកទាំងឡាយ ឡើងទៅលើប្រគាបឈើដ៏ខ្ពស់ ហើយនិយាយគ្នាក្នុងទីស្ងាត់ អ្នកទាំងឡាយចូរចុះមកខាងក្រោម និយាយគ្នាវិញស្តេចម្រឹគនឹងស្តាប់ផង ។

[ ២២៤ ] ( រុក្ខទេវតាពោធិសត្វពោលថា ) ហង្សនិយាយគ្នានឹងហង្ស ទេវតានិយាយគ្នានឹងទេវតា ប្រយោជន៍អ្វីដល់ចចកជាសត្វទទេស្អាតចាកសម្បត្តិ ៤ ក្នុងរឿងនោះ ម្នាលសត្វលាមក ឯងចូរទៅកាន់រូងវិញទៅ។

**ចប់ ចតុមដ្ឋជាតកទី ៧ ។**

## អដ្ឋកថា

## ចតុមដ្ឋជាតក

[ ២២៣-២២៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧច្ចេ វិដភិមារុយ្ហ** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយកាលអគ្គសាវ័ក ២ រូប អង្គុយសន្ទនាប្រារព្ធការសួរនិងការឆ្លើយបញ្ហាដល់គ្នានឹងគ្នា ភិក្ខុចាស់មួយរូប ចូលទៅរកអគ្គសាវ័កទាំង ២ អង្គុយជាគម្រប់ ៣ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំសូមសួរបញ្ហាមួយ សូម្បីលោកក៏ចូរសួរបញ្ហាដែលលោកសង្ស័យជាមួយខ្ញុំចុះ ។ ព្រះថេរៈរង្កៀសចំពោះភិក្ខុចាស់នោះក្រោកឡើងចៀសចេញទៅ ។ ពួកបរិស័ទអង្គុយ

ដើម្បីស្តាប់ធម៌របស់ព្រះថេរៈ នាំគ្នាទៅគាល់ព្រះសាស្តា ក្នុងពេលដែលការប្រជុំរំសាយទៅ កាលព្រះសាស្តាត្រាស់សួរថា ហេតុអ្វីទើបពួកអ្នកមកខុសកាល ទើបក្រាបទូលហេតុនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តនិងមោគ្គល្លានវៀសភិក្ខុចាស់នោះ មិននិយាយហើយចៀសចេញទៅមិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុនក៏នាំគ្នាចៀសចេញទៅ រួចទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតរុក្ខទេវតានៅក្នុងដងព្រៃ ។ កាលនោះកូនហង្ស ២ ចេញអំពីភ្នំចិត្តកូដទំត្រង់ដើមឈើនោះហើយទៅរកអាហារ គ្រាហើរត្រឡប់ក៏មកសម្រាកត្រង់ដើមឈើនោះឯង ទើបត្រឡប់ទៅកាន់ភ្នំចិត្តកូដ ។ ពេលវេលាកន្លងទៅ ហង្សទាំង ២ ក៏មានសេចក្តីស្និទ្ធស្នាលជាមួយព្រះពោធិសត្វ ។ កាលហើរចូលទៅចូលមក ជនទាំង ៣ ក៏ត្រេកអរសន្ទនាធម៌ដល់គ្នានឹងគ្នាហើយចៀសចេញទៅ ។ ថ្ងៃមួយហង្សទាំង ២ ទំលើចុងឈើសន្ទនាជាមួយព្រះពោធិសត្វ ។ ចចកមួយឈរក្រោមដើមឈើនោះ កាលនឹងសន្ទនាជាមួយកូនហង្សទាំង ២ ទើបពោលគាថាទីមួយថា

> អ្នកទាំងឡាយឡើងទៅលើប្រគាបឈើដ៏ខ្ពស់ ហើយនិយាយ
> គ្នាក្នុងទីស្ងាត់ អ្នកទាំងឡាយ ចូរចុះមកខាងក្រោមនិយាយ
> គ្នាវិញស្តេចម្រឹគនឹងស្តាប់ផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧច្ចេ វិដភិមារុយ្ហ** សេចក្តីថា នាំគ្នាឡើង

ទៅលើប្រគាប ដែលខ្ពស់តាមប្រក្រតី គឺក្នុងទីដ៏ខ្ពស់លើដើមឈើនេះ ។ បទថា **មន្តយន្តោ** បានដល់ ប្រឹក្សាគ្នា គឺជជែកគ្នា ។ បទថា **ឆវេ ឱរុយ្ហ** បានដល់ អញ្ជើញចុះមកឈរប្រឹក្សាគ្នាខាងក្រោមវិញ ។ បទថា **មិគរាជាបិ សោស្សតិ** បានដល់ ចចកចេញវាចាលើកខ្លួនថាជាស្តេចម្រឹគ ។

កូនហង្សទាំង ២ រង្កៀសទើបនាំគ្នាហើរទៅកាន់ភ្នំចិត្តកូដ ក្នុងកាលដែលហង្សទាំង ២ ត្រឡប់ទៅ ទើបព្រះពោធិសត្វពោលគាថាទីពីរដល់ចចកថា

ហង្សនិយាយគ្នានឹងហង្ស ទេវតានិយាយគ្នានឹងទេវតា ប្រយោ-
ជន៍អ្វីដល់ចចកជាសត្វទេស្អាតចាកសម្បត្តិ ៤ ក្នុងរឿងនោះ
ម្នាលសត្វលាមក ឯងចូរទៅកាន់រូងវិញទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុបណ្ណោ** ប្រែថា សត្វដែលមានស្លាបល្អ ។ បទថា **សុបណ្ណេន** បានដល់ កូនហង្សទី ២ ។ បទថា **ទេវោ ទេវេន** បានដល់ សន្មតកូនហង្សទាំង ២ នោះជាទេវតាប្រឹក្សាគ្នា ។ បទថា **ចតុមដ្ឋស្ស** អធិប្បាយតាមតួអក្ខរៈថា ចចកជាសត្វអាក្រក់ គឺមិនបរិសុទ្ធដោយហេតុ ៤ យ៉ាងគឺ សរីរៈ ១ ជាតិ ១ សំឡេង ១ គុណ ១ ។ ព្រះពោធិសត្វកាលតិះដៀលពាក្យសរសើរមិនបរិសុទ្ធទើបពោលយ៉ាងនេះ ។ ក្នុងបទនេះមានអធិប្បាយដូច្នេះថា ចចកថោកទាប គឺលាមកដោយហេតុ ៤ ប្រការដូចម្តេច ។ បទថា **វិលំ បាវិស** គឺ ព្រះពោធិសត្វសម្តែងអារម្មណ៍ដែលគួរខ្លាច កាលនឹងដេញចចកឲ្យគេចទៅទើបពោលដូច្នេះ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំ

ជាតកថា ចបកក្នុងកាលនោះបានមកជាភិក្ខុចាស់ក្នុងកាលឥឡូវនេះ កូនហង្ស ទាំងគូក្នុងកាលនោះបានមកជាសារីបុត្តនិងមោគ្គល្លាន ឯរុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចតុមដ្ឋជាតក ចប់

# សីហកោត្ថុកជាតក

[ ២២៥ ] ( កូនសីហៈពោលថា ) សីហៈ ១ នោះមានម្រាមជើងជាសីហៈ មានក្រចកជាសីហៈ ឈរដោយជើងជាសីហៈ តែបន្លឺឡើងប្លែកម្នាក់ឯងក្នុងហ្វូងសីហៈ ។

[ ២២៦ ] ( សីហៈពោធិសត្វពោលថា ) ម្នាលកូនស្តេចសីហៈ អ្នកកុំបន្លឺឡើយ អ្នកចូរមានសំឡេងតិចនៅក្នុងព្រៃ ហ្វូងសត្វគប្បីស្គាល់អ្នកដោយសំឡេងព្រោះសំឡេងអ្នកមិនមែនកាត់បានមកខាងឪពុកឡើយ ។

**ចប់ សីហកោត្ថុកជាតកទី ៨ ។**

## អដ្ឋកថា

## សីហកោត្ថុកជាតក

[ ២២៥-២២៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវកោកាលិកភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សីហង្គុលី សីហនខោ** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយកោកាលិកភិក្ខុ កាលភិក្ខុជាពហូសូតច្រើនរូបកំពុងសន្ទនាធម៌បំណាងនឹងពោលដែរ ។ រឿងទាំងអស់ គប្បីឲ្យពិស្តារដោយន័យដែលពោលហើយខាងដើមនោះឯង ។

ព្រះសាស្តាកាលទ្រង់ស្តាប់រឿងនោះហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កោកាលិកបើកបង្ហាញដោយសំឡេងរបស់ខ្លួនមិនមែនតែក្នុងកាល

ឥឡូវនេះទេ សូម្បីក្នុងកាលមុនក៏បើកបង្ហាញដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី កាលនោះព្រះពោធិសត្វកើតក្នុងកំណើតរាជសីហ៍នៅអាស្រ័យក្នុងហិមវន្តប្បទេស ធ្វើសន្ធវៈជាមួយចចកញីមួយបានកូនមួយ ។ កូននោះកាត់ទៅបាដោយអាការទាំងនេះ គឺម្រាមក្រចក កេសរត្រង់ក ពណ៌និងសណ្ឋានតែសំឡេងកាត់ទៅមេ ។ ថ្ងៃមួយកាលភ្លៀងធ្លាក់ដាច់គ្រាប់ហើយពួករាជសីហ៍នាំគ្នាបន្លឺសីហនាទប្រឡែងគ្នា កូនចចកញីនោះត្រូវការបន្លឺសីហនាទក្នុងរវាងពួករាជសីហ៍ទាំងនោះដែរទើបបន្លឺសំឡេងដូចចចក ។ កាលនោះរាជសីហ៍ទាំងឡាយបានស្តាប់សំឡេងរបស់ចចកនោះទើបនាំគ្នាស្ងៀម ។ កូនរាជសីហ៍រួមកំណើតរបស់ព្រះពោធិសត្វមួយទៀតបានឮសំឡេងរបស់ចចក ទើបសួរបិតាថា បពិត្រលោកឪពុក រាជសីហ៍មួយនេះដូចយើងដោយពណ៌ជាដើមតែសំឡេងរបស់សត្វនេះមិនដូចពួកយើង បពិត្រលោកឪពុក សត្វនេះជាសត្វប្រភេទណាកាលនឹងសួរទើបពោលគាថាទីមួយថា

> សីហៈ ១ នោះមានម្រាមជើងជាសីហៈ មានក្រចកជាសីហៈ
> ឈរដោយជើងជាសីហៈ តែបន្លឺឡើងប្លែកម្នាក់ឯងក្នុងហ្វូង
> សីហៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីហានុប្បតិដ្ឋិតោ** បានដល់ ឈរដោយជើងរបស់រាជសីហ៍នោះឯង ។ បទថា **ឯកោ នទតិ អញ្ញថា** សេចក្តីថា

ម្នាក់ឯងប៉ុណ្ណោះបន្លឺសំឡេងដូចចចកមិនដូចពួករាជសីហ៍ដទៃឈ្មោះថា បន្លឺដោយសំឡេងម្យ៉ាងទៀត ។

ព្រះពោធិសត្វបានស្តាប់ពាក្យនេះហើយទើបពោលថា នែកូន សត្វនេះជាបងរបស់ឯង ជាកូនរបស់ចចកញីមានរូបដូចអញ មានសំឡេងដូចមេ ហើយទើបហៅកូនចចកមកទូន្មានថា នែកូន តាំងអំពីនេះទៅឯងចូរនៅក្នុងទីនេះ ចូរជាអ្នកមានសំឡេងតិច ៗ បើឯងបន្លឺសំឡេងទៀតរាជសីហ៍ទាំងឡាយនឹងដឹងថា ឯងជាចចកទើបពោលគាថាទីពីរថា

ម្នាលកូនស្តេចសីហៈ អ្នកកុំបន្លឺឡើយ អ្នកចូរមានសំឡេង
តិចនៅក្នុងព្រៃ ហ្វូងសត្វគប្បីស្គាល់អ្នកដោយសំឡេងព្រោះ
សំឡេងអ្នកមិនមែនកាត់បានមកខាងឪពុកឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាជបុត្ត** បានដល់ កូនស្តេចសីហៈ ។ កូនចចកនោះកាលស្តាប់ពាក្យទូន្មាននោះហើយ ក៏មិនហ៊ានបន្លឺសំឡេងតទៅទៀត ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះបានមកជាកោកាលិកក្នុងកាលឥឡូវនេះ កូនរាជសីហ៍ក្នុងកាលនោះបានមកជារាហុល ឯស្តេចសីហៈក្នុងកាលនោះគឺតថាគតនេះឯង ។

**អដ្ឋកថា សីហកោត្ថុកជាតក ចប់**

# សីហចម្មជាតក

[ ២២៧ ] ( អ្នកស្រែពោធិសត្វពោលថា ) នុ៎ះមិនមែនសម្រែកសីហៈ មិនមែនសម្រែកខ្លាធំ មិនមែនសម្រែកខ្លាដំបងទេ លាដ៏លាមកគេដណ្តប់គ្របដោយស្បែកសីហៈស្រែកទេតើ ។

[ ២២៨ ] ( ពាណិជពោលថា ) លាដណ្តប់ដោយស្បែកសីហៈស៊ីស្រូវសំទូងនោះអស់កាលជាយូរណាស់ហើយទាល់តែស្រែក ( ឲ្យគេដឹង ) បានជាប្រទូស្តខ្លួន ។

**ចប់ សីហចម្មជាតកទី ៩ ។**

## អដ្ឋកថា

## សីហចម្មជាតក

[ ២២៧-២២៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកោកាលិកភិក្ខុនោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នេតំ សីហស្ស នទិតំ** ដូច្នេះជាដើម ។

ក្នុងកាលនោះកោកាលិកភិក្ខុបំណងនឹងពោលសរភញ្ញ ។ ព្រះសាស្តាទ្រង់ស្តាប់រឿងនោះហើយទើបទ្រង់នាំរឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកស្រែ កាលចម្រើនវ័យចិញ្ចឹមជីវិតដោយកសិកម្មនោះឯង ។ ក្នុងកាលនោះមានឈ្មួញម្នាក់ដើរលក់ដូរដោយការដឹក

ទំនិញលើខ្នងលា ។ ឈ្មួញនោះលើកទំនិញចុះអំពីខ្នងលាក្នុងទីដែលទៅដល់ ហើយយកស្បែករាជសីហ៍ដណ្ដប់លា លែងឲ្យទៅរកស៊ីត្រង់ស្រែស្រូវសាលី និងស្រូវជំណើប ។ អ្នករក្សាស្រែឃើញហើយមិនអាចចូលជិត ដោយសម្គាល់ថាជារាជសីហ៍ ។ ថ្ងៃមួយឈ្មួញនោះស្នាក់នៅត្រង់ទ្វារស្រុកមួយកន្លែង ចម្អិនអាហារពេលព្រឹក បន្ទាប់មកយកស្បែករាជសីហ៍ដណ្ដប់ខ្នងលា លែងឲ្យទៅរកស៊ីក្នុងស្រែស្រូវជំណើប ។ ពួកអ្នកស្រែឃើញលានោះក៏មិនអាចចូលជិតបានដោយសម្គាល់ថាជារាជសីហ៍ទើបនាំគ្នាត្រឡប់ទៅផ្ទះ ។ ពួកអ្នកស្រុកទាំងអស់នាំគ្នាកាន់អាវុធ ផ្លុំស័ង្ខ វាយស្គរ ស្រែកហើយចូលមកជិត ។ លាខ្លាចស្លាប់ទើបបន្លឺសំឡេងជាលា កាលនោះព្រះពោធិសត្វដឹងថាជាសត្វលាទើបពោលគាថាទីមួយថា

> នុ៎ះមិនមែនសម្រែកសីហៈ មិនមែនសម្រែកខ្លាធំ មិនមែន
> សម្រែកខ្លាដំបងទេ លាដ៏លាមកគេដណ្ដប់គ្របដោយស្បែក
> សីហៈស្រែកទេតើ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជម្មោ** ប្រែថា លាមក ។ ពួកអ្នកស្រុកក៏ដឹងថា សត្វនោះជាលា នាំគ្នាសំពងឲ្យដួលចុះបាក់ឆ្អឹងហើយយកស្បែករាជ-សីហ៍ទៅ ។ កាលឈ្មួញនោះមកឃើញលាដល់នូវសេចក្ដីវិនាសទើបពោលគាថាទីពីរថា

> លាដណ្ដប់ដោយស្បែកសីហៈស៊ីស្រូវសំទូងនោះអស់កាលជា
> យូរណាស់ហើយ ទាល់តែស្រែក ( ឲ្យគេដឹង ) បានជា

ប្រទូស្តខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ** ត្រឹមតែជានិបាត អធិប្បាយថា លានេះមិនឲ្យគេដឹងថាខ្លួនជាលាដណ្តប់ដោយស្បែករាជសីហ៍ ស៊ីស្រូវជំណើបមកអស់កាលយូរ ។ បទថា **រវមានោវ ទូសយិ** សេចក្តីថា កាលស្រែកជាសំឡេងលាក៏ប្រទូស្តខ្លួនឯងមិនមែនជាកំហុសរបស់ស្បែករាជសីហ៍ទេ ។

លុះឈ្មួញនោះពោលយ៉ាងនេះស្រេចហើយ លាក៏ដេកស្លាប់ក្នុងទីនោះឯងសូម្បីឈ្មួញក៏បោះបង់លាត្រឡប់ទៅផ្ទះ ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ពាណិជក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ លាក្នុងកាលនោះបានមកជាកោកាលិកភិក្ខុ ឯអ្នកស្រែដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សីហចម្មជាតក ចប់

# សីលានិសំសជាតក

[ ២២៩ ] ( សមុទ្ទទេវតាពោធិសត្វពោលថា ) អ្នកចូរឃើញផលនៃសទ្ធា សីល ចាគៈ នាគនេះមានភេទដូចជាសំពៅនាំឧបាសកមានសទ្ធា ។

[ ២៣០ ] បុគ្គលគប្បីសេពគប់ជាមួយនឹងពួកសប្បុរស គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលជាមួយនឹងពួកសប្បុរស ដូចជាងផ្ចូតទឹកដល់នូវសួស្តីព្រោះនៅរួមជាមួយនឹងពួកសប្បុរស ។

**ចប់ សីលានិសំសជាតកទី ១០ ។**

**ចប់ អសទិសវគ្គទី ៤ ។**

## ឧទ្ទាននៃអសទិសវគ្គនោះគឺ

និយាយអំពីខ្លាន់ជ្ជួ ១ កុញ្ជរៈ ១ មានរសតិច ១ គន្ធាល សេះឈ្មោះគិរិទត្តៈ ១ ចិត្តថ្លាជាចិត្តប្រសើរ ១ ព្រះរាជាទធិវាហនៈ ១ ចចកជម្ពុកៈ ១ សត្វមានក្រចកជាសីហៈ ១ ស្រូវសំទូង ១ នាគដ៏ប្រសើរ ១ ត្រូវជា ១០ ។

## អដ្ឋកថា

## សីលានិសំសជាតក

[ ២២៩-២៣០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកមានសទ្ធាម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បស្ស សទ្ធាយ សីលស្ស** ដូច្នេះជាដើម ។

បានឮថា ឧបាសកនោះជាអរិយសាវកអ្នកមានសទ្ធាជ្រះថ្លា ថ្ងៃមួយដើរទៅកាន់វត្តជេតពនដល់ឆ្នេរស្ទឹងអចិរវតីក្នុងពេលល្ងាច កាលអ្នករត់ទូកចតទុកត្រង់ច្រាំងទៅស្តាប់ធម៌មិនអុំទូកត្រង់កំពង់ ទើបទាញយកបីតិមានព្រះពុទ្ធជាអារម្មណ៍ឲ្យមាំទាំចុះកាន់ស្ទឹង ជើងរបស់គាត់មិនលិចទៅក្នុងទឹកឡើយដូចគ្នានឹងដើរលើផែនដី គាត់ឃើញរលកក្នុងពេលដើរដល់កណ្តាលស្ទឹងបីតិមានព្រះពុទ្ធជាអារម្មណ៍របស់គាត់មានកម្លាំងខ្សោយ ជើងរបស់គាត់ក៏ផ្តើមលិចចុះទើបគាត់ផ្គងបីតិមានព្រះពុទ្ធជាអារម្មណ៍ឲ្យមាំ ដើរលើខ្នងទឹកដល់វត្តជេតពនថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងចំណែកម្ខាង ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយបុរសនោះត្រាស់សួរថា ម្នាលឧបាសក អ្នកធ្វើដំណើរមកហត់នឿយតិចតួចទេឬ កាលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាញយកបីតិមានព្រះពុទ្ធជាអារម្មណ៍ដើរលើផ្ទៃទឹកដូចលើផែនដីមក ទើបព្រះសាស្តាត្រាស់ថា ម្នាលឧបាសក មិនមែនតែអ្នកទេដែលរឭកដល់ពុទ្ធគុណហើយបាននូវទីពឹង សូម្បីតែក្នុងកាលមុន ឧបាសកទាំងឡាយកាលទូកលិចកណ្តាលសមុទ្រក៏រឭកដល់ពុទ្ធគុណបាននូវទីពឹងដូចគ្នា កាលឧបាសកទូលអារាធនាទើបទ្រង់នាំរឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងសាសនាព្រះកស្សបសម្ពុទ្ធ អរិយសាវកដែលជាសោតាបន្នមួយរូបធ្វើដំណើរតាមសំពៅទៅជាមួយកុដុម្ពិកៈដែលជាជាងកោរកាត់ម្នាក់ ភរិយារបស់ជាងកោរកាត់នោះផ្ញើជាងកោរកាត់ដល់ឧបាសកនោះថា នែអ្នក សុខទុក្ខរបស់ប្តីខ្ញុំសូមប្រគល់ឲ្យជាភារៈរបស់អ្នក ។ លុះដល់ថ្ងៃទី ៧ ទូករបស់ជាងកោរកាត់ក៏លិចកណ្តាលសមុទ្រ ជនទាំង ២ តោងបន្ទះក្តារមួយសន្ទឹកអណ្តែតមកដល់កោះមួយ ជាងកោរកាត់ក៏សម្លាប់បក្សីអាំងបរិភោគហើយឲ្យដល់ឧបាសក ។ ឧបាសកមិនព្រមបរិភោគដោយពោលថា កុំបន្សល់ទុកសម្រាប់ខ្ញុំឡើយ ។ ឧបាសកគិតថា ក្នុងទីនេះក្រៅអំពីព្រះរតនត្រ័យហើយមិនមានទីពឹងដទៃសម្រាប់អាត្មាអញឡើយ ទើបរឭកដល់គុណព្រះរតនត្រ័យ ។ លំដាប់នោះកាលបុរសនោះកំពុងរឭកដល់ព្រះរតនត្រ័យ ស្តេចនាគដែលកើតក្នុងកោះនោះក៏និម្មិតសរីរៈរបស់ខ្លួនជាសំពៅធំមានទេវតាប្រចាំសមុទ្រជាមាណពនៅលើសំពៅ ។ សំពៅនោះពេញទៅដោយរតនៈ ៧ ប្រការ ។ ក្តោងទាំង ៣ សម្រេចដោយកែវមណីពណ៌ឥន្ទនិល សំពៅសម្រេចដោយមាស ខ្សែសម្រេចដោយប្រាក់ ឈើចែវសម្រេចដោយមាស ។ ទេវតារក្សាសមុទ្រឈរលើសំពៅប្រកាសថា មានអ្នកណាចង់ទៅជម្ពូទ្វីបដែរឬទេ ឧបាសកឆ្លើយថា ពួកយើងចង់ទៅ ។ ទេវតាពោលថា បើដូច្នោះចូរឡើងសំពៅមក ។ ឧបាសកឡើងសំពៅហើយហៅជាងកោរកាត់ឲ្យឡើងដែរ ។ ទេវតារក្សាសមុទ្រពោលថា បានតែអ្នកប៉ុណ្ណោះ អ្នកនុ៎ះមិនបានឡើយ ។ ឧបាសកសួរថា ព្រោះហេតុអ្វី ទេវតារក្សាសមុទ្រឆ្លើយថា បុរស

នេះមិនមានគុណ គឺសីលនិងអាចារដូច្នោះទើបខ្ញុំនាំសំពៅមកដើម្បីអ្នកមិនមែនដើម្បីបុរសនោះទេ ។ ឧបាសកពោលថា ណ្ហើយចុះ ខ្ញុំនឹងឲ្យចំណែកបុណ្យដល់បុរសនេះ ដោយទានដែលខ្ញុំបានឲ្យហើយ ដោយសីលដែលខ្ញុំបានរក្សាហើយ ដោយការនាដែលខ្ញុំបានអប់រំហើយ ។ ជាងកោរកាត់ឆ្លើយថា ខ្ញុំសូមអនុមោទនា ។ ទេវតារក្សាសមុទ្ទពោលថា ខ្ញុំនឹងនាំទៅក្នុងកាលឥឡូវនេះហើយលើកជនទាំង ២ ដាក់សំពៅចេញអំពីសមុទ្ទទៅដល់ក្រុងពារាណសីតាមផ្លូវទឹក បណ្តាលឲ្យទ្រព្យនៅក្នុងផ្ទះរបស់ជនទាំង ២ ដោយអានុភាពរបស់ខ្លួន កាលពោលដល់គុណនៃការសេពគប់បណ្ឌិតថា គួរធ្វើសេចក្តីស្និទ្ធស្នាលជាមួយបណ្ឌិតទាំងឡាយ បើជាងកោរកាត់នេះមិនបានសេពគប់ជាមួយឧបាសកនេះនឹងវិនាសក្នុងកណ្តាលសមុទ្ទនោះឯង ទើបពោលគាថាទាំងនេះថា

អ្នកចូរឃើញផលនៃសទ្ធា សីល ចាគៈ នាគនេះមានភេទ
ដូចជាសំពៅនាំឧបាសកមានសទ្ធា ។
បុគ្គលគប្បីសេពគប់ជាមួយនឹងពួកសប្បុរស គប្បីធ្វើនូវ
សេចក្តីស្និទ្ធស្នាលជាមួយនឹងពួកសប្បុរស ដូចជាងផ្លូតទឹក
ដល់នូវសួស្តីព្រោះនៅរួមជាមួយនឹងពួកសប្បុរស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បស្ស** បានដល់ ( ទេវតា ) ហៅថា ចូរមើលចុះ មិនកំណត់បុគ្គលណាមួយ ។ បទថា **សទ្ធាយ** គឺ ដោយលោកិយសទ្ធានិងលោកុត្តរសទ្ធា ។ ក្នុងសីលក៏មានន័យនេះដូចគ្នា ។ បទថា **ចាគស្ស** បានដល់ បរិច្ចាគទេយ្យធម៌និងបរិច្ចាគកិលេស ។ បទថា **អយំ ផលំ**

បានដល់ នេះជាផល គឺជាគុណជាអានិសង្ស ។ម្យ៉ាងទៀតគប្បីឃើញសេចក្តីអធិប្បាយក្នុងបទនេះយ៉ាងនេះថា ចូរមើលផលនៃការបរិច្ចាគចុះ ស្តេចនាគនេះកាឡាខ្លួនជាសំពៅ ។ បទថា **នាវាយ វណ្ណេន** គឺ ដោយសណ្ឋានជាសំពៅ ។ បទថា **សទ្ធំ** គឺ សទ្ធាដែលតាំងនៅក្នុងព្រះរតនត្រ័យ ។ បទថា **សព្ភិរេវ** គឺ ពួកបណ្ឌិតនោះឯង ។ បទថា **សមាសេថ** បានដល់ ចូរមកនៅ គឺចូរមកនៅជាមួយគ្នា រស់នៅជាមួយគ្នា ។ បទថា **កុព្វេថ** បានដល់ គប្បីធ្វើ ។ បទថា **សន្ថវំ** បានដល់ ស្និទ្ធស្នាលក្នុងឋានៈជាមិត្ត ប៉ុន្តែមិនគួរធ្វើសេចក្តីស្និទ្ធស្នាលដោយតណ្ហាជាមួយបុគ្គលណាម្នាក់ទេ ។ បទថា **ន្ហាបិតោ** បានដល់ កុដុម្ពិកៈជាជាងកោរកាត់ ។ បាលីថា **នហាបិតោ** ក៏មាន ។ ទេវតាប្រចាំសមុទ្ទឈរនៅលើអាកាសសម្តែងធម៌ទូន្មានយ៉ាងនេះ ហើយទើបនាំស្តេចនាគទៅកាន់វិមានរបស់ខ្លួន ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងកាលចប់សច្ចធម៌ ឧបាសកនោះ តាំងនៅក្នុងសកទាគាមិផល ហើយទ្រង់ប្រជុំជាតកថា ឧបាសកដែលជាសោតាបន្នក្នុងកាលនោះ ចម្រើនមគ្គខ្ពស់ឡើងៗទៅក៏បរិនិព្វាន ស្តេចនាគក្នុងកាលនោះបានមកជាសារីបុត្ត ឯទេវតាប្រចាំសមុទ្ទក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា សីលានិសំសជាតក ចប់

អសទិសវគ្គ ចប់

# រុហកវគ្គ

## រុហកជាតក

[ ២៣១ ] ( ព្រះរាជាពោធិសត្វត្រាស់ថា ) ម្នាលរុហកព្រាហ្មណ៍ដ៏ចម្រើន ខ្សែប្រនោះធ្នូសូម្បីដាច់ហើយគេតឲ្យជាប់វិញ អ្នកចូរតភ្ជាប់ជាមួយនឹងនាងបូរាណីវិញចុះ កុំលុះក្នុងអំណាចនៃសេចក្ដីក្រោធឡើយ ។

[ ២៣២ ] ( រុហកបុរោហិតក្រាបទូលថា ) កាលបើសម្បកក្រចៅដែល ( ទន់ ) មានទាំងជនអ្នកធ្វើក៏មាន ទូលព្រះបង្គំនឹងធ្វើនូវខ្សែប្រនោះធ្នូដទៃ មិនគួរឡើយនឹងតភ្ជាប់ជាមួយនឹងនាងបូរាណីទេ ។

**ចប់ រុហកជាតកទី ១ ។**

# រុហកវគ្គ

## អដ្ឋកថា រុហកជាតក

[ ២៣១-២៣២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ភរិយាចាស់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អព្ភោ រុហក ឆិន្នាបិ** ដូច្នេះជាដើម ។

រឿងមានជាក់ច្បាស់ក្នុងឥន្ទ្រិយជាតកអដ្ឋកនិបាត ។

ក្នុងរឿងនេះព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្រីនេះធ្វើនូវការវិនាសឲ្យដល់អ្នកក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ស្រីនេះក៏បានធ្វើអាការឲ្យអ្នកខ្មាសក្នុងកណ្ដាលបរិស័ទមួយអន្លើដោយព្រះរាជា រួចចេញអំពីផ្ទះទៅទើបទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃនៃអគ្គមហេសីរបស់ព្រះរាជាអង្គនោះ កាលទ្រង់ចម្រើនវ័យ គ្រាព្រះជនកសោយទិវង្គតហើយទ្រង់តាំងនៅក្នុងរាជសម្បត្តិគ្រងរាជ្យដោយធម៌ ។ ព្រះអង្គមានបុរោហិតម្នាក់ឈ្មោះរុហក ។ ភរិយារបស់រុហកបុរោហិតនោះឈ្មោះថា បូរាណីព្រាហ្មណី ។ ព្រះរាជាព្រះទានសេះប្រដាប់ដោយគ្រឿងអលង្ការដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ជិះទៅធ្វើរាជការ ។ លំដាប់នោះមហាជនឈរក្នុងទីនោះៗ ឃើញបុរោហិតអង្គុយលើខ្នងសេះដែលប្រដាប់ហើយធ្វូងទៅមកទើបសរសើរសេះប៉ុណ្ណោះថា សេះនេះស្អាតពន់ពេក រុហកបុរោហិតមកដល់ផ្ទះ **ឡើងផ្ទះហៅភរិយាមកពោលថា** នៃនាង សេះ

របស់យើងស្អាតពន់ពេក មហាជនដែលឈរសងខាងផ្លូវសរសើរតែសេះរបស់យើងប៉ុណ្ណោះ ។ ឯព្រាហ្មណីនោះ ជាស្រីអ្នកលេងឡេះឡោះព្រោះហេតុនោះទើបនាងឆ្លើយយ៉ាងនេះថា នែអ្នក អ្នកមិនដឹងហេតុដែលធ្វើឲ្យសេះស្អាត សេះនេះស្អាតព្រោះអាស្រ័យគ្រឿងប្រដាប់ដែលពាក់ត្រង់ខ្លួន បើអ្នកប្រាថ្នានឹងស្អាតដូចសេះ ចូរយកគ្រឿងសេះមកពាក់ហើយទៅក្នុងចន្លោះផ្លូវហើយផាយជើងដូចជើងសេះទៅគាល់ព្រះរាជាចុះ ព្រះរាជាក៏នឹងសរសើរអ្នក សូម្បីពួកមនុស្សក៏សរសើរអ្នកប៉ុណ្ណោះ ។ រុហកបុរោហិតជាព្រាហ្មណ៍ល្ងីល្ងើមិនសូវគ្រប់ទឹក ស្តាប់ពាក្យរបស់ព្រាហ្មណីមិនដឹងថា ស្រីនោះនិយាយលេងនឹងខ្លួន គិតតែចង់ស្អាតប៉ុណ្ណោះទើបធ្វើតាមនោះ ។ ពួកមនុស្សដែលឃើញនាំគ្នាសើចចំអកថា លោកអាចារ្យស្អាត ឯព្រះរាជាត្រាស់នឹងអាចារ្យថា នែអាចារ្យចិត្តរបស់អ្នក មិនប្រក្រតីហើយឬ ឆ្កួតហើយឬ ហើយទ្រង់ធ្វើឲ្យបុរោហិតខ្មាស ។

ក្នុងកាលនោះព្រាហ្មណ៍ខ្មាសគិតក្នុងចិត្តថា អញធ្វើវត្ថុដែលមិនសមគួរទើបក្រោធនឹងព្រាហ្មណីថា អញត្រូវនាងធ្វើឲ្យខ្មាសក្នុងវាំងសេនា និងព្រះរាជានោះ អញនឹងវាយនាងហើយបណ្តេញចេញ ហើយត្រឡប់ទៅផ្ទះ ។ ព្រាហ្មណីអ្នកលេងដឹងថាប្តីក្រោធត្រឡប់មក ទើបចេញទៅតាមទ្វារតូចមុនហើយទៅកាន់ព្រះរាជវាំង ស្នាក់នៅក្នុងព្រះរាជវាំង ៤-៥ ថ្ងៃ ។ ព្រះរាជាទ្រង់ជ្រាបហេតុនោះទើបឲ្យហៅបុរោហិតនោះមកហើយត្រាស់ថា លោកអាចារ្យធម្មតាស្ត្រីរមែងមានកំហុសជាធម្មតាគួរលើកទោសឲ្យនាងចុះ ដើម្បីឲ្យបុរោ-

ហិតអត់ទោសទើបត្រាស់គាថាទីមួយថា

ម្នាលវុហកព្រាហ្មណ៍ដ៏ចម្រើន ខ្សែបន្ទោះធ្នូ សូម្បីដាច់ហើយ

គេតឲ្យជាប់វិញ អ្នកចូរតភ្ជាប់ជាមួយនឹងនាងបូរាណីវិញចុះ

កុំលុះក្នុងអំណាចនៃសេចក្ដីក្រោធឡើយ ដូច្នេះ ។

សេចក្ដីសង្ខេបក្នុងគាថានេះមានដូច្នេះថា វុហកដ៏ចម្រើន ខ្សែធ្នូសូម្បីដាច់ហើយក៏គង់កួចធ្វើឲ្យជាប់គ្នាបានមិនមែនឬ អ្នកក៏ដូចគ្នា គួរស្មគ្រស្មាគមជាមួយភរិយាចុះ កុំលុះក្នុងអំណាចនៃសេចក្ដីក្រោធឡើយ ។

វុហកបានស្ដាប់ព្រះរាជតម្រាស់ដូច្នោះទើបពោលគាថាទីពីរថា

កាលបើសម្បកក្រចៅដែល ( ទន់ ) មាន ទាំងជនអ្នកធ្វើក៏

មាន ទូលព្រះបង្គំនឹងធ្វើនូវខ្សែបន្ទោះធ្នូដទៃ មិនគួរឡើយនឹង

តភ្ជាប់ជាមួយនឹងនាងបូរាណីទេ ដូច្នេះ ។

ក្នុងអត្ថនៃគាថាទាំងនោះថា បពិត្រមហារាជ កាលសម្បកក្រចៅទន់នៅមាន ជាងអ្នកធ្វើក៏មាន ទូលបង្គំនឹងធ្វើខ្សែបន្ទោះធ្នូដទៃ មិនត្រូវការខ្សែបន្ទោះធ្នូចាស់ដែលដាច់ទៅហើយ ខ្សែបន្ទោះធ្នូដែលដាច់ហើយនោះ មិនមានប្រយោជន៍អ្វីសម្រាប់ទូលព្រះបង្គំ ។

កាលបុរោហិតក្រាបទូលយ៉ាងនេះហើយ ទើបបណ្ដេញព្រាហ្មណីចេញទៅ នាំព្រាហ្មណីដទៃមក ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចធម៌ លុះចប់សច្ចធម៌ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់

ប្រជុំជាតកថា ព្រាហ្មណីក្នុងកាលនោះ បានមកជាករិយាចាស់ក្នុងកាលឥឡូវនេះ រុហកព្រាហ្មណ៍ក្នុងកាលនោះបានមកជាភិក្ខុអផ្សុក ឯព្រះរាជាពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា រុហកជាតក ចប់

## សិរិកាឡកណ្ណិជាតក

[ ២៣៣ ] ( ព្រះបាទវិទេហរាជត្រាស់ថា ) ម្នាលមហោសធ ស្រ្តីដែលមានរូបល្អតែស្រ្តីនោះមានសីល បុរសមិនគប្បីប្រាថ្នាស្រ្តីនោះ អ្នកជឿឬទេ ។

[ ២៣៤ ] ( មហោសធក្រាបទូលថា ) បពិត្រមហារាជ ទូលព្រះបង្គំជឿ បុរសដែលថោកទាប ( មិនត្រូវការនឹងស្រ្តីនោះទេ ) ( ព្រោះ ) សិរីនឹងកាឡកណ្ណី រមែងមិនជួបប្រសព្វគ្នាក្នុងកាលណាម្តងឡើយ ។

**ចប់ សិរិកាឡកណ្ណិជាតកទី ២ ។**

## អដ្ឋកថា

## សិរិកាឡកណ្ណិជាតក

[ ២៣៣-២៣៤ ] សិរិកាឡកណ្ណិជាតកនេះ មានពាក្យផ្តើមថា **ឥត្ថី សិយា រូបវតី** ដូច្នេះជាដើម ។ នឹងមានច្បាស់ក្នុងមហាឧម្មង្គជាតក ។

**អដ្ឋកថា សិរិកាឡកណ្ណិជាតក ចប់**

## ចុល្លបទុមជាតក

[ ២៣៥ ] ( *ព្រះរាជាពោធិសត្វត្រាស់ថា* ) *ស្ត្រីទ្រុស្តសីលនោះ គឺមេនេះឯង បទុមកុមារនោះមិនមែនអ្នកដទៃឡើយ គឺអញនេះឯង ( ស្ត្រីនោះ ) និយាយចំពោះបុរសណាថាជាប្តីអំពីក្មេងរបស់អញ បុរសនោះមានដៃកំបុតមិនមែនអ្នកដទៃឡើយ គឺអាកំបុតនេះឯង ស្ត្រីទាំងឡាយត្រូវគេសម្លាប់ចោលព្រោះស្ត្រីទាំងឡាយមិនមានពាក្យសច្ចៈ ។*

[ ២៣៦ ] *អ្នកទាំងឡាយចូរសំពងបុរសលាមកអាក្រក់ប្រាកដស្មើដោយសាកសពដែលសេពនូវប្រពន្ធនៃបុគ្គលដទៃនេះដោយអង្រែផង ហើយកាត់ត្រចៀកនិងច្រមុះនៃស្ត្រីដែលរស់នៅគោរពប្តីអាក្រក់នេះផង ។*

**ចប់ ចុល្លបទុមជាតកជាទី ៣ ។**

## អដ្ឋកថា

## ចុល្លបទុមជាតក

[ ២៣៥-២៣៦ ] *ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អយមេវ សា អហម្បិ សោ អនញ្ញោ** *ដូច្នេះជាដើម ។*

*រឿងមានច្បាស់ក្នុងឧម្មាទន្តីជាតក ( បញ្ញាសនិបាត ) ឯណោះ ។*

*ក្នុងរឿងនេះភិក្ខុនោះកាលព្រះសាស្តាត្រាស់សួរថា បានឮថាអ្នកអផ្សុកពិតឬ ក៏ក្រាបទូលថា ករុណាព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរថា តើអ្នក*

អផ្សុកព្រោះហេតុអ្វី ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញមាតុគ្រាមម្នាក់តែងខ្លួនយ៉ាងស្អាត ហើយធ្លាក់នៅក្នុងអំណាចកិលេសទើបអផ្សុក ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ មាតុគ្រាមជាអកតញ្ញូទ្រុស្តមិត្តមានចិត្តរឹងត្អឹង សូម្បីបុរាណកបណ្ឌិតឲ្យផឹកឈាមក្បាលជង្គង់ស្តាំរបស់ខ្លួនឲ្យបាននូវជីវិតគង់ទាញចិត្តមាតុគ្រាមមិនបាន ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីព្រះពោធិសត្វ បដិសន្ធិក្នុងព្រះផ្ទៃរបស់អគ្គមហេសីរបស់ព្រះរាជាអង្គនោះ ក្នុងថ្ងៃថ្វាយព្រះនាមបានទទួលព្រះរាជទានព្រះនាមថា បទុមរាជកុមារ ។ បទុម-រាជកុមារមានបងប្អូន ៦ អង្គទៀត ។ ក្សត្រទាំង ៧ អង្គនោះចម្រើនព្រះជន្មឡើងដោយលំដាប់ គ្រប់គ្រងផ្ទះទ្រង់ប្រព្រឹត្តដូចព្រះរាជា ។ ថ្ងៃមួយព្រះរាជាទតត្រង់លានព្រះរាជវាំង ទ្រង់ឃើញព្រះរាជកុមារបងប្អូនទាំងនោះមានបរិវារច្រើននាំគ្នាមកបដិបត្តិរាជការ ទ្រង់កើតសេចក្តីសង្ស័យថា ព្រះរាជកុមារទាំងនេះគប្បីសម្លាប់អញហើយដណ្តើមយករាជសម្បត្តិ ទើបត្រាស់ហៅព្រះរាជ-កុមារទាំងនោះមកត្រាស់ថា នែបាទាំងឡាយ ពួកបានៅក្នុងនគរនេះមិនបានទេចូរទៅកាន់ទីដទៃចាំបិតាស្លាប់ហើយសឹមនាំគ្នាមកទទួលរាជសម្បត្តិជារបស់ត្រកូលចុះ ។

ព្រះរាជកុមារទាំងនោះទទួលព្រះតម្រាស់របស់ព្រះជនកហើយ ទ្រង់ព្រះកន្សែងយាងទៅកាន់ដំណាក់រៀងៗខ្លួនទ្រង់ពិចារណាថា ពួកយើងនឹងនាំព្រះ

ជាយាទៅចិញ្ចឹមជីវិតក្នុងទីណាមួយ ហើយយាងចេញអំពីព្រះនគរ ទ្រង់ធ្វើដំណើរដល់ផ្លូវកន្តារមួយកន្លែង កាលមិនបានបាយនិងទឹកមិនអាចអត់សង្កត់សេចក្តីស្រេកឃ្លានបាន ទើបដាច់ព្រះទ័យផ្តាច់ព្រះជន្មព្រះជាយារបស់ប្អូនដោយទ្រង់ព្រះតម្រិះថា កាលយើងនៅមានជីវិតក៏នឹងរកស្រីបាន ហើយចែកសាច់ជា ១៣ ចំណែកនាំគ្នាសោយ ។ ព្រះពោធិសត្វរក្សាទុកមួយចំណែកក្នុងចំណែកដែលខ្លួននិងព្រះជាយាបាន ទាំង ២ អង្គសោយតែមួយចំណែកប៉ុណ្ណោះ ព្រះរាជកុមារទាំងឡាយផ្តាច់ព្រះជន្មព្រះជាយាទាំង ៦ ហើយសោយសាច់បាន ៦ ថ្ងៃដោយប្រការដូច្នេះ ។

ឯព្រះពោធិសត្វទ្រង់បន្ទល់ទុកមួយចំណែកៗរាល់ថ្ងៃបាន ៦ ចំណែកក្នុងថ្ងៃទី ៧ កាលពោលថានឹងផ្តាច់ព្រះជន្មព្រះជាយារបស់ម្ចាស់បង ទើបព្រះ-ពោធិសត្វព្រះរាជទានសាច់ទាំង ៦ ចំណែកនោះដល់ប្អូនៗហើយត្រាស់ថា ថ្ងៃនេះពួកអ្នកចូរសោយសាច់ទាំង ៦ ចំណែកនេះសិនចុះ ស្អែកនេះសឹមដឹងគ្នា ក្នុងពេលដែលព្រះរាជកុមារជាប្អូនទាំងនោះសោយសាច់ហើយផ្ទំលក់ ព្រះពោធិសត្វនាំព្រះជាយាគេចទៅ ។ ព្រះជាយានោះ យាងទៅបានបន្តិចទូលថា បពិត្រព្រះភស្តា ខ្ញុំម្ចាស់មិនអាចដើរតទៅបានទេ ។ លំដាប់នោះទើបព្រះពោធិសត្វទ្រង់បញ្ចិកព្រះជាយាចេញអំពីផ្លូវកន្តាររហូតដល់អរុណរះ ។ លុះព្រះអាទិត្យរះឡើងព្រះនាងទូលថា ខ្ញុំម្ចាស់ស្រេកទឹកពន់ពេក ។ ព្រះពោធិសត្វត្រាស់ថា នែនាងដ៏ចម្រើនទឹកមិនមានទេ កាលព្រះនាងរំអុករឿយៗ ដោយសេចក្តីស្នេហាចំពោះព្រះនាងទើបយកព្រះខ័នធូតព្រះជានុ ( ជង្គង់ )

ខាងស្តាំហើយត្រាស់ថា ទឹកមិនមានឡើយ ចូរនាងអង្គុយចុះបីតឈាមត្រង់ក្បាលជង្គង់ស្តាំរបស់យើងចុះ ព្រះជាយាបានធ្វើតាមព្រះបំណាង ។ ក្សត្រទាំង ២ អង្គយាងដល់ស្ទឹងធំដោយលំដាប់ទ្រង់ផឹក ទ្រង់ងូត ទ្រង់សោយផលាផលស្នាក់នៅក្នុងទីដែលជាផាសុក ហើយទ្រង់សាងអាស្រមបទជិតស្ទឹងនោះ ។

ថ្ងៃមួយនៅផ្នែកខាងលើទឹក រាជបុរសដាក់ទោសចោរដែលខុសនឹងរាជ-អាជ្ញា កាត់ដៃជើង ត្រចៀកនិងច្រមុះឲ្យដេកក្នុងទូកកម្រោលមួយបណ្តែតទៅតាមខ្សែទឹក ចោរនោះស្រែកដោយសំឡេងគ្រលួចអណ្តែតមកដល់ទីនោះ ។ ព្រះពោធិសត្វ ទ្រង់ស្តាប់សំឡេងរោទ៍ដែលគួរឲ្យអាណិតរបស់ចោរនោះ ទ្រង់ព្រះតម្រិះថា បើអញនៅមានជីវិតសត្វដែលដល់នូវសេចក្តីទុក្ខកុំបីវិនាសឡើយ ទើបចូលទៅកាន់ស្ទឹង ស្រង់ឡើងអំពីទូកនាំមកកាន់អាស្រមបទ ។ ទ្រង់ព្យា-បាលរបួសដោយការលាងនិងការលាបដោយទឹកម្ចត់ ឯព្រះជាយារបស់ទ្រង់ជ្រាបថា ព្រះស្វាមីប្រណិប័តន៍មនុស្សកំបុតដែលអណ្តែតទឹកមកបែបនេះ ព្រះនាងរង្កៀសខ្ពើមរអើមមនុស្សអាក្រក់នោះសម្តែងនូវកិរិយារើសអើងទៅមក ។ កាលមុខរបួសចោរនោះជាស្រួលបួលហើយ ទើបព្រះពោធិសត្វ ឲ្យបុរសនោះនៅក្នុងអាស្រមបទជាមួយព្រះជាយា ទ្រង់ស្វែងរកផលាផលអំពីព្រៃមកចិញ្ចឹមចោរនិងព្រះជាយា ។ កាលជនទាំង ២ នៅជាមួយគ្នាយ៉ាងនេះស្រីនោះមានចិត្តប្រតិព័ទ្ធក្នុងបុរសអាក្រក់នោះ ប្រព្រឹត្តអនាចារជាមួយបុរសនោះ ត្រូវការសម្លាប់ព្រះពោធិសត្វដោយឧបាយណាមួយទើបក្រាបទូលយ៉ាងនេះថា កាលខ្ញុំអង្គុយលើស្មារបស់ព្រះអង្គចេញអំពីផ្ទៃកន្តារ សម្លឹងឃើញភ្នំមួយ ទើបបន់

ស្រន់ថា បពិត្រទេវតាដែលស្ថិតនៅលើកំពូលភ្នំ បើខ្ញុំនិងស្វាមីផុតអំពីសេចក្តីស្លាប់ខ្ញុំនឹងធ្វើពលីកម្មដល់លោក ឥឡូវនេះទេវតានោះធ្វើឲ្យខ្ញុំភ័យខ្លាច ខ្ញុំនឹងធ្វើពលីកម្មដល់ទេវតានោះ ។ ព្រះពោធិសត្វទ្រង់មិនដឹងមាយារបស់កិរិយាទើបទ្រង់ត្រាស់ថា សាធុ ហើយត្រៀមគ្រឿងពលីកម្មឲ្យព្រះជាយាកាន់កាជនៈដាក់គ្រឿងពលីកម្មឡើងកាន់កំពូលភ្នំ ។ ព្រះជាយាក្រាបទូលយ៉ាងនេះថា បពិត្រព្រះស្វាមី ទ្រង់ក៏ជាទេវតារបស់ខ្ញុំម្ចាស់ដែរ ឈ្មោះថាជាទេវតាដ៏ឧត្តមជាបឋមខ្ញុំម្ចាស់នឹងបូជាទ្រង់ដោយផ្កាក្នុងព្រៃ នឹងធ្វើប្រទក្សិណថ្វាយបង្គំរួចសឹមធ្វើពលីកម្មដល់ទេវតាក្នុងកាលជាក្រោយ ។ ព្រះនាងឲ្យព្រះពោធិសត្វបែរមុខទៅកាន់ជ្រោះបូជាដោយផ្កាក្នុងព្រៃ ធ្វើជាប្រាថ្នានឹងប្រទក្សិណថ្វាយបង្គំស្ថិតនៅពីក្រោយ ហើយប្រហារត្រង់ព្រះបិដ្ឋិ ប្រានទម្លាក់ក្នុងជ្រោះត្រេកអរថា អញឃើញខ្នងសត្រូវហើយទើបចុះអំពីភ្នំទៅរកបុរសអាក្រក់ ឯព្រះពោធិ-សត្វ ធ្លាក់អំពីភ្នំរមៀលចូលក្នុងជ្រោះជាប់ត្រង់គុម្ពឈើដែលមានស្លឹកក្រាស់មិនមានបន្លាមួយដើមដែលចាក់ស្រេះជាមួយដើមល្វា តែមិនអាចចុះកាន់ជើងភ្នំបាន ។ ទ្រង់សោយផ្លែល្វាប្រថាប់គង់វាង់មែក ។ គ្រានោះស្តេចទន្សោងធំមួយឡើងអំពីជើងភ្នំខាងក្រោមស៊ីផ្លែល្វាក្នុងទីនោះឃើញព្រះពោធិសត្វក្នុងថ្ងៃនោះទើបគេចទៅ ស្អែកឡើងមកស៊ីផ្លែឈើក្នុងទីម្ខាងទៀតហើយគេចទៅ ។ ស្តេចទន្សោងមករឿយៗយ៉ាងនេះក៏ស្និទ្ធស្នាលនឹងព្រះពោធិសត្វ សួរព្រះពោធិ-សត្វថា លោកមកទីនេះបានដូចម្តេច កាលព្រះពោធិសត្វប្រាប់ឲ្យដឹងហើយទើបពោលថា បើដូច្នោះអ្នកកុំខ្លាចឡើយ ឲ្យព្រះពោធិសត្វដេកលើខ្នងរបស់

ខ្លួន ប្រវាចុះអំពីភ្នំ នាំព្រះពោធិសត្វចេញអំពីព្រៃយកទៅដាក់នឹងផ្លូវធំហើយបញ្ជូនទៅដោយពាក្យថា សូមលោកទៅតាមផ្លូវនេះចុះ ហើយចូលទៅកាន់ព្រៃ ។ ព្រះពោធិសត្វទៅដល់ស្រុកមួយ កាលអាស្រ័យនៅក្នុងស្រុកនោះក៏បានដំណឹងថា ព្រះជនកសោយទិវង្គតហើយទើបទៅកាន់នគរពារាណសី ទ្រង់តាំងនៅក្នុងរាជសម្បត្តិជារបស់ត្រកូលព្រះនាមថា បទុមរាជា ទ្រង់គ្រប់គ្រងរាជ្យដោយធម៌មិនឲ្យរាជធម៌កម្រើក ឲ្យសាងរោងទាន ៦ កន្លែងត្រង់ទ្វារនគរទាំង ៤ កណ្តាលនគរនិងត្រង់ទ្វារព្រះរាជនិវេសន៍ ទ្រង់បរិច្ចាគទ្រព្យបំពេញមហាទានមួយថ្ងៃ ៦ សែន ។

ស្រីអាក្រក់នោះ ក៏ឲ្យបុរសអាក្រក់អង្គុយលើក ចេញអំពីព្រៃដើរសូមទានក្នុងផ្លូវដែលមានមនុស្សជួបជុំគ្នា ប្រមូលបាយបបរនិងកត្ត ចិញ្ចឹមបុរសអាក្រក់នោះ កាលមានមនុស្សសួរថា បុរសនេះត្រូវជាអ្វីនឹងនាង ក៏ប្រាប់ថា ខ្ញុំជាកូនស្រីរបស់អ៊ំប្រុសនៃបុរសនេះ គាត់ជាកូនរបស់ឪពុកមារ ពុកម៉ែខ្ញុំបានលើកខ្ញុំឲ្យបុរសនេះ ។ ខ្ញុំត្រូវបញ្ជិះកស្វាមីដែលត្រូវទោសត្រាច់សូមទានចិញ្ចឹមគាត់ ពួកមនុស្សនាំគ្នាពោលថា ស្រីនេះប្រណិប័តន៍ប្តីល្អពិត តាំងអំពីនោះមកក៏នាំគ្នាឲ្យបាយ បបរនិងកត្តក្រៃលែងឡើង ។ បុរសមួយពួកទៀតពោលថា បានឮថា នាងកុំត្រាច់ទៅយ៉ាងនេះឡើយ ព្រះបាទបទុមរាជសោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់បរិច្ចាគទានល្បីពេញជម្ពូទ្វីប ព្រះបាទបទុមរាជទ្រង់ឃើញហើយនឹងត្រេកអរព្រះរាជទានទ្រព្យជាច្រើន ចូរនាងនាំស្វាមីរបស់នាងទៅកាន់ទីនោះចុះ ហើយឲ្យកញ្ជើផ្តៅមួយទៅ ។ នាងប្រាស

ចាកហិរិឲ្យបុរសនោះអង្គុយក្នុងកញ្ជើ ហើយទូលចូលទៅកាន់នគរពារាណសី បរិភោគអាហារក្នុងរោងទាន ។

ព្រះពោធិសត្វប្រថាប់លើកដីរីដែលតាក់តែងដោយគ្រឿងអលង្ការ យាង ដល់រោងទាន ទ្រង់បរិច្ចាគដោយព្រះហស្តឯងដល់បុគ្គលដែលមកសុំ ៨ នាក់ ខ្លះ ១០ នាក់ខ្លះហើយយាងត្រឡប់ ។ ស្រីមិនមានខ្មាស់នោះឲ្យបុរសអាក្រក់ អង្គុយក្នុងកញ្ជើហើយទូលដើរទៅតាមផ្លូវដែលព្រះរាជាយាង ។ ព្រះរាជាទត ឃើញដូច្នោះទើបត្រាស់សួរថា នុ៎ះជានរណា រាជបុរសទាំងឡាយក្រាបទូល ថា បពិត្រព្រះសម្មតិទេព ស្រីបដិបត្តិប្តីម្នាក់ ។ លំដាប់នោះព្រះរាជាត្រាស់ ឲ្យហៅនាងមកទ្រង់ស្គាល់ ទើបបញ្ជាឲ្យលើកបុរសអាក្រក់ចេញអំពីកញ្ជើ ហើយត្រាស់សួរថា បុរសនេះជាអ្វីនឹងនាង ។ នាងក្រាបទូលថា បពិត្រ ព្រះសម្មតិទេព បុរសនេះជាកូនរបស់ឪពុកមាខ្ញុំម្ចាស់នោះឯង ជាប្តីដែលឪពុក ម្តាយទុកដាក់ ។ ពួកមនុស្សមិនដឹងរឿងនោះនាំគ្នាសរសើរស្រីឥតខ្មាសនោះ ថា គួរអស្ចារ្យហ្ន៎ នាងជាស្រីបដិបត្តិល្អក្នុងស្វាមី ។ ព្រះរាជាត្រាស់សួរថា បុរសនេះជាប្តីពេញច្បាប់របស់នាងឬ នាងចាំព្រះរាជាមិនបាន ទើបក្រាបទូលថា ព្រះមេខ្ញុំម្ចាស់ ទើបព្រះរាជាត្រាស់ថា បុរសនេះ ជាឱរសរបស់ព្រះបាទពារា- ណសីឬ នាងជាធីតារបស់ព្រះរាជាអង្គនោះមានឈ្មោះយ៉ាងនេះ ជាជាយា របស់បទុមរាជកុមារ ផឹកឈាមក្បាលជង្គង់របស់អញ ហើយមានចិត្តប្រតិព័ទ្ធ ក្នុងបុរសអាក្រក់នេះ ច្រានអញឲ្យធ្លាក់ក្នុងជ្រោះ ឥឡូវនេះនាងបែរមុខមក រកសេចក្តីស្លាប់សម្គាល់ថា អញស្លាប់ទៅហើយឬទើបមកក្នុងទីនេះ អញនៅ

មានជីវិតមិនមែនឬ ហើយត្រាស់ហៅអាមាត្យទាំងឡាយថា លោកអាមាត្យទាំងឡាយ ពួកលោកសួរយើង យើងបានប្រាប់ពួកលោកទុកយ៉ាងនេះថា ប្អូនប្រុស ៦ អង្គរបស់យើងសម្លាប់ស្រី ៦ នាក់ បរិភោគសាច់មិនមែនឬ ។ តែយើងបានជួយជាយារបស់យើងឲ្យផុតភ័យ នាំទៅកាន់ច្រាំងស្ទឹងគង្គា អាស្រ័យនៅក្នុងអាស្រមបទបានជួបបុរសអាក្រក់ម្នាក់ដែលត្រូវរាជទណ្ឌយកមកចិញ្ចឹម ។ ស្រីនេះមានចិត្តប្រតិព័ទ្ធបុរសអាក្រក់នោះ ប្រានយើងឲ្យធ្លាក់ក្នុងជ្រោះភ្នំ យើងរួចជីវិតមកព្រោះមានចិត្តមេត្តា ស្រីដែលប្រានយើងធ្លាក់អំពីភ្នំមិនមែនស្រីដទៃ គឺស្រីអាក្រក់នេះឯង បុរសអាក្រក់ដែលត្រូវរាជអាជ្ញាក៏មិនមែនអ្នកដទៃ គឺបុរសកំបុតនេះឯង ហើយត្រាស់គាថាទាំងនេះថា

ស្ត្រីទ្រុស្តសីលនោះ គឺមេនេះឯង បទុមកុមារនោះមិនមែនអ្នកដទៃឡើយ គឺអញនេះឯង ( ស្ត្រីនោះ ) និយាយចំពោះបុរសណាថាជាប្តីអំពីក្មេងរបស់អញ បុរសនោះមានដៃកំបុតមិនមែនអ្នកដទៃឡើយ គឺអាកំបុតនេះឯង ស្ត្រីទាំងឡាយត្រូវគេសម្លាប់ចោល ព្រោះស្ត្រីទាំងឡាយមិនមានពាក្យសច្ចៈ ។

អ្នកទាំងឡាយ ចូរសំពងបុរសលាមកអាក្រក់ ប្រាកដស្មើដោយសាកសព ដែលសេពនូវប្រពន្ធនៃបុគ្គលដទៃនេះដោយអង្រែផង ហើយកាត់ត្រចៀកនិងច្រមុះនៃស្ត្រីដែលរស់នៅគោរពប្តីអាក្រក់នេះផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យមាហា កោមារិបតិកោ មមន្តិ** សេចក្តី

ថា ស្រីនេះពោលថា បុរសនេះជាប្ដីរបស់នាងតាំងអំពីក្មេង គឺជាប្ដីរៀបការ បុរសនេះឯងគឺ បុរស ( ដែលត្រូវកាត់ដៃ ) នោះមិនមែនអ្នកដទៃ ។ បាលីថា **យមាហុ កោមារបតិ** ក៏មាន ។ ព្រោះលោករចនាបទនេះទុកក្នុងគម្ពីរទាំងឡាយសេចក្ដីក៏តែមួយ ។ តែក្នុងបទនេះគប្បីជ្រាបការឃ្លៀងឃ្លាតនៃពាក្យព្រះរាជាត្រាស់ពាក្យណាទុកពាក្យនោះឯងមកហើយក្នុងទីនេះ ។ បទថា **វជ្ឈិត្ថិយោ** សេចក្ដីថា ឈ្មោះថា ស្រីទាំងឡាយគួរសម្លាប់ឲ្យអស់ ។

បទថា **នត្ថិ ឥត្ថីសុ សច្ចំ** បានដល់ ឈ្មោះថា សច្ចៈក្នុងស្រីទាំងនេះមិនមានសូម្បីត្រឹមតែមួយ ។ បទថា **ឥមញ្ច ជម្មំ** ជាដើម លោកពោលដោយការដាក់ទោសបុរសទាំងនោះ ។ ក្នុងបទទាំងនោះបទថា **ជម្មំ** គឺអាក្រក់ ។ បទថា **មុសលេន ហន្ត្វា** បានដល់ យកអង្រែវាយធ្វើឲ្យឆ្អឹងបាក់ជាកំណាត់ៗ ។ បទថា **លុទ្ទំ** គឺ គ្រោតគ្រាត ។ បទថា **ឆវំ** បានដល់ប្រាកដស្មើដោយសាកសពព្រោះមិនមានគុណធម៌ ។ បទថា **ឆំ** ក្នុងបទថា **ឥមិស្សា ច ឆំ** នេះត្រឹមតែជានិបាត អធិប្បាយថា អ្នកទាំងឡាយចូរកាត់ត្រចៀកនិងច្រមុះរបស់ស្រីនេះដែលប្រណិប័តន៍ប្ដីអាក្រក់ មិនមានកេរ្ដិ៍ឈ្មោះជាស្រីទ្រុស្តសីលទាំងដែលនៅរស់ ។

ព្រះពោធិសត្វ កាលទ្រង់មិនអាចអត់ធន់នឹងសេចក្ដីក្រោធបានហើយត្រាស់ឲ្យដាក់អាជ្ញាដល់ជនទាំង ២ យ៉ាងនេះ ក៏ទ្រង់មិនបានឲ្យធ្វើយ៉ាងនោះទ្រង់បានបន្ទោបង់សេចក្ដីក្រោធឲ្យធូរស្រាល ហើយទ្រង់ឲ្យចងកញ្ជើជាប់នឹងក្បាលយ៉ាងណែនដោយធ្វើឲ្យនាងមិនអាចលើកចេញអំពីក្បាល បានដាក់បុរស

អាក្រក់នោះទុកក្នុងកញ្ជើឲ្យនាងទូលដល់អស់ជីវិត ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ភិក្ខុអផ្សុកបានសម្រេចសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា បងប្អូនទាំង ៦ ក្នុងកាលនោះបានមកជាព្រះថេរៈណាមួយក្នុងកាលឥឡូវនេះ ព្រះជាយាអាក្រក់ក្នុងកាលនោះបានមកជា នាងចិញ្ចមាណវិកា បុរសអាក្រក់ក្នុងកាលនោះ បានមកជាទេវទត្ត ស្តេចទន្សងក្នុងកាលនោះបានមកជាអានន្ទ ឯបទុមរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចូឡបទុមជាតក ចប់

## មណិចោរជាតក

[ ២៣៧ ] ( នាងសុជាតាពោលថា ) ពួកទេវតា ( ជាអ្នករមិលមើលពួកជនអ្នកមានសីលក្នុងលោកនេះ ) មិនមាន រមែងប្រាសខ្ចាត់ខ្ចាយដោយពិត ( ពួកសមណព្រាហ្មណ៍ ) ដែលគេសន្មតថាជាលោកបាលក្នុងលោកនេះ ក៏មិនមានដោយពិត ទាំងពួកជនអ្នកហាមឃាត់នូវជនទាំងឡាយអ្នកមិនសង្រួមធ្វើតែអំពើដ៏សហ័ស ( អាក្រក់ ) ក៏មិនមានដោយពិត ។

[ ២៣៨ ] ( ព្រះឥន្ទ្រត្រាស់ថា ) ក្នុងរាជ្យនៃស្តេចមិនប្រកបដោយធម៌នោះ ភ្លៀងរមែងបង្អុរចុះក្នុងកាលមិនគួរ មិនបង្អុរចុះក្នុងកាលដែលគួរ ឯស្តេចមិនប្រកបដោយធម៌នោះ រមែងច្យុតចាកឋានសួគ៌ត្រូវគេសម្លាប់ចោលដោយហេតុត្រឹមប៉ុណ្ណេះដោយពិត ។

**ចប់ មណិចោរជាតកទី ៤ ។**

## អដ្ឋកថា
## មណិចោរជាតក

[ ២៣៧-២៣៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តដែលព្យាយាមផ្តាច់ព្រះជន្ម ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន សន្តិ ទេវា បវសន្តិ នូន** ដូច្នេះជាដើម ។

ព្រះសាស្តាទ្រង់ព្រះសណ្តាប់ថា ទេវទត្តព្យាយាមផ្តាច់ព្រះជន្មទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តព្យាយាមសម្លាប់តថាគតមិនមែនតែក្នុងកាល

ឥឡូវនេះទេវសូម្បីក្នុងកាលមុនក៏ព្យាយាមសម្លាប់តថាគតដូចគ្នា តែទោះជាព្យាយាមក៏មិនអាចសម្លាប់តថាគតបាន ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលគហបតី ត្រង់ស្រុកមួយមិនឆ្ងាយអំពីនគរពារា-ណសី ។ កាលចម្រើនវ័យទើបមាតាបិតានាំកុលធីតាមកអំពីនគរពារាណសី ។ នាងជាទីស្រឡាញ់ មានរូបស្អាតគួរមើលដូចទេពអប្សរ ដូចបុប្ផលតានិងដូចកិន្នរីយាងយាស បដិបត្តិស្វាមីល្អដល់ព្រមដោយសីលាចារវត្តមានឈ្មោះថាសុជាតា ។ ការបដិបត្តិស្វាមីក្តី ម្តាយក្មេកក្តី ឪពុកក្មេកក្តីស្រីនេះធ្វើទាល់តែសម្រេចអស់ អស់កាលជានិច្ចទើបនាងជាទីស្រឡាញ់ ជាទីត្រេកអររបស់ព្រះពោធិសត្វ ។ ប្តីប្រពន្ធទាំង ២ មានចិត្តត្រេកអររួមគ្នាតែមួយរស់នៅដោយស្រុះស្រួលគ្នា ។

ថ្ងៃមួយនាងសុជាតាប្រាប់ដល់ព្រះពោធិសត្វថាចង់ទៅសួរសុខទុក្ខមាតាបិតា ។ ព្រះពោធិសត្វពោលថា សាធុ ចូរត្រៀមស្បៀងឲ្យគ្រប់គ្រាន់ឲ្យចៀនរបស់ទំពាច្រើនប្រភេទ ហើយផ្ទុករបស់ទំពាជាដើមលើយានតូច អង្គុយខាងមុខយានបរទៅ ឯនាងអង្គុយខាងក្រោយ ព្រះពោធិសត្វនិងកិរិយាទៅជិតដល់នគរទើបដោះយាន ងូតទឹក បរិភោគអាហារ ។ ស្រេចហើយព្រះពោធិសត្វក៏ទឹមយានអង្គុយខាងមុខ នាងសុជាតាផ្លាស់សំពត់តាក់តែងរាងកាយអង្គុយខាងក្រោយ ។

ក្នុងកាលដែលយានចូលទៅក្នុងព្រះនគរ ព្រះបាទពារាណសីប្រថាប់លើកដីរដ៏ប្រសើរធ្វើប្រទក្សិណព្រះនគរបានយាងមកដល់ទីនោះ នាងសុជាតាចុះដើរដោយជើងខាងក្រោយយាន ព្រះរាជាទតឃើញនាងត្រូវរូបរបស់នាងចាក់ដោតព្រះហឫទ័យមានចិត្តប្រតិព័ទ្ធ បញ្ជូនអាមាត្យម្នាក់ទៅដោយព្រះតម្រាស់ថា ចូរអ្នកទៅចុះ ចូរដឹងថា ស្រីនោះមានប្តីឬមិនមាន ។ កាលអាមាត្យទៅក៏ដឹងថា នាងមានប្តីហើយទើបក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព នាងមានប្តីហើយ បុរសអង្គុយលើយាននោះជាប្តីរបស់នាង ។ ព្រះរាជាមិនអាចអត់សង្កត់ព្រះហឫទ័យដែលប្រតិព័ទ្ធបាន ទ្រង់ក្តៅក្រហាយដោយកិលេសទ្រង់ត្រិះរិះថា អញនឹងសម្លាប់បុរសនេះដោយឧបាយណាមួយហើយដណ្តើមយកស្រីនេះមក ទ្រង់ហៅបុរសម្នាក់មកហើយត្រាស់ថា អ្នកចូរទៅចូរយកចូឡាមណី ( ស្នៀតសក់ ) នេះទៅ ធ្វើដូចជាអ្នកដំណើរលាក់ទុកក្នុងយានរបស់បុរសនោះហើយត្រឡប់មក ទ្រង់បញ្ជូនចូឡាមណីទៅឲ្យ ។ បុរសនោះទទួលព្រះរាជតម្រាស់ថា សាធុ កាន់យកចូឡាមណីនោះទៅទុកក្នុងយានហើយត្រឡប់មកក្រាបទូលថា ទូលព្រះបង្គំធ្វើស្រេចហើយ ។ ព្រះរាជាត្រាស់ថា ចូឡាមណីរបស់យើងបាត់ទៅ ។ ពួកមនុស្សក៏នាំគ្នាជ្រួលច្របល់ជាកោ-លាហល ។ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយចូរបិទទ្វារគ្រប់ទិស ផ្តាច់នូវការសញ្ចរទៅមកដើម្បីចាប់ចោរ ។ ពួករាជបុរសបានធ្វើតាមព្រះរាជឱង្ការ ។ ព្រះនគរកោលាហលគ្រប់ទីកន្លែង ។ បុរសម្នាក់ ( ដែលយកចូឡាមណីទៅលាក់ក្នុងរទេះព្រះពោធិសត្វ ) នាំពួករាជបុរសទៅរកព្រះពោធិសត្វពោលថា

ចូរឈប់យានតូចសិន ចូឡាមណីរបស់ព្រះរាជាបាត់ទៅយើងនឹងឆែកឆេរមើលយាន កាលពិនិត្យមើលយានឃើញចូឡាមណីដែលខ្លួនលាក់ទុក ចាប់ព្រះពោធិសត្វវាយដោយដៃនិងជើងពោលថា ចោរលួចចូឡាមណីហើយចងដៃទៅក្រោយនាំទៅប្រគល់ដល់ព្រះរាជាក្រាបទូលថា បុរសនេះជាចោរលួចចូឡាមណី ព្រះរាជាមានរាជបញ្ជាថា ចូរកាត់ក្បាលវាចុះ ។ ពួករាជបុរសយកផ្តៅវាយព្រះពោធិសត្វម្តង ៤ ដើមៗនាំចេញអំពីព្រះនគរតាមទ្វារទិសខាងត្បូង ។ នាងសុជាតាក៏បោះបង់យានផ្គងដើមដៃដើរយំរៀបរាប់តាមទៅអំពីខាងក្រោយថា បពិត្រស្វាមី អ្នកបានទទួលទុក្ខនេះព្រោះអាស្រ័យខ្ញុំ ។ ពួករាជបុរសឲ្យព្រះពោធិសត្វដេកផ្ងារ ដោយបំណងថានឹងកាត់ក្បាលរបស់ព្រះពោធិសត្វ ។ នាងសុជាតាឃើញដូច្នោះទើបរឭកដល់គុណនៃសីលរបស់ខ្លួនពោលថា ឈ្មោះថា ទេវតាអ្នកអាចហាមឃាត់មនុស្សអាក្រក់មាននិស្ស័យដ៏ថោកទាប ដែលបៀតបៀនអ្នកមានសីលទាំងឡាយក្នុងលោកនេះ ប្រហែលជាមិនមានក្នុងលោកនេះហ្ន៎ទើបពោលគាថាទីមួយថា

ពួកទេវតា ( ជាអ្នករមិលមើលពួកជនអ្នកមានសីលក្នុងលោកនេះ ) មិនមានរមែងប្រាសខ្ចាត់ខ្ចាយដោយពិត ( ពួកសមណព្រាហ្មណ៍ ) ដែលគេសន្មតថាជាលោកបាលក្នុងលោកនេះក៏មិនមានដោយពិត ទាំងពួកជនអ្នកហាមឃាត់នូវជនទាំងឡាយអ្នកមិនសង្រួមធ្វើតែអំពើដ៏សហ័ស ( អាក្រក់ ) ក៏មិនមានដោយពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន សន្តិ ទេវា** សេចក្ដីថា ទេវតាទាំងឡាយ ដែលមើលថែអ្នកមានសីលនិងហាមមនុស្សអាក្រក់មិនមានក្នុងលោកនេះពិត ។ បទថា **បវសន្តិ នូន** សេចក្ដីថា កាលកិច្ចបែបនេះកើតឡើង ទេវតាទាំងឡាយក៏នាំគ្នាទៅស្នាក់នៅ គឺទៅក្នុងទីដទៃអស់ពិត ។ បទថា **នត្ថិ លោកេ** សេចក្ដីថា សូម្បីសមណព្រាហ្មណ៍ទាំងឡាយ ដែលមានសីល ដែលអនុគ្រោះ ដែលគេសន្មតថាជាអ្នករក្សាលោកមិនមានក្នុងលោកនេះដោយពិត ។ បទថា **សហសា ករោន្តានមសញ្ញតានំ** បានដល់ បុគ្គលទ្រុស្តសីលមិនពិនិត្យពិចារណាធ្វើកម្មដ៏សហ័ស គឺកម្មអាក្រក់ ។ បទថា **បដិសេធិតា ភោ** គឺឃាត់ថា អ្នកទាំងឡាយ ចូរកុំធ្វើកម្មបែបនេះ ធ្វើបែបនេះមិនបានយ៉ាងនេះមិនមានឡើយ ។

កាលស្រីសម្បូរដោយសីលរៀបរាប់យ៉ាងនេះ អាសនៈរបស់សក្កទេវរាជក៏មានអាការក្ដៅ ។ សក្កទេវរាជពិចារណាថា នរណាហ្ន៎ បំណងឲ្យអញឃ្លាតចាកតំណែងជាសក្កទេវរាជទ្រង់ក៏ជ្រាបហេតុនេះថា ស្ដេចពារាណសីធ្វើកម្មគ្រោតគ្រាតក្រៃលែង ធ្វើឲ្យនាងសុជាតាដែលបរិបូរដោយសីលលំបាកអញគួរទៅក្នុងឥឡូវនេះ ទើបចុះអំពីទេវលោក បណ្ដាលឲ្យព្រះរាជាអាក្រក់ដែលប្រថាប់គង់លើកដីរចុះអំពីកដីរឲ្យដេកលើជ្រញ់សម្រាប់ស្លាប់ហើយទ្រង់ត្រកងពោធិសត្វ ឲ្យទ្រង់គ្រឿងអលង្ការសព្វយ៉ាង ទ្រង់កេទដូចជាព្រះរាជាគង់ប្រថាប់លើកដីរ ពេជ្ឈឃាដនាពូថៅកាត់ក្បាល ក៏កាត់ក្បាលព្រះរាជារបស់ខ្លួនឯង ក្នុងកាលក្បាលដាច់នោះឯងទើបដឹងថាជាសីសៈព្រះរាជា ។ សក្កទេវរាជ

ទ្រង់សម្តែងព្រះកាយឲ្យប្រាកដចូលទៅរកព្រះពោធិសត្វ ទ្រង់អភិសេកថ្វាយព្រះមហាសត្វ ទ្រង់តាំងតំណែងអគ្គមហេសីដល់នាងសុជាតា ។

ពួកអាមាត្យ ព្រាហ្មណ៍និងគហបតីជាដើមឃើញសក្កទេវរាជហើយក្រែក-អរថា ព្រះរាជាប្រាសចាកធម៌អស់ព្រះជន្មហើយ ឥឡូវនេះពួកយើងបានព្រះរាជាអ្នកទ្រទ្រង់ធម៌ដែលសក្កទេវរាជទ្រង់ប្រទាន ។ សក្កទេវរាជប្រថាប់នៅក្នុងអាកាសទ្រង់ត្រាស់ដល់បរិស័ទទាំងឡាយថា ពួកអ្នកបានព្រះរាជាអង្គនេះដែល ( យើង ) សក្កទេវរាជឲ្យហើយនិងមានទេវតម្រាស់តទៅថា បពិត្រមហារាជ តាំងអំពីនេះទៅសូមទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ចុះ បើព្រះរាជាមិនប្រកបដោយធម៌ភ្លៀងក៏ធ្លាក់មិនត្រូវតាមរដូវកាល ភ័យ ៣ យ៉ាងគឺ ភ័យកើតអំពីការអត់ឃ្លាន ១ ភ័យកើតអំពីរោគ ១ ភ័យកើតអំពីសស្ត្រា ១ នឹងកើតឡើង កាលនឹងថ្វាយឱវាទទើបត្រាស់គាថាទីពីរថា

ក្នុងរាជ្យនៃស្តេចមិនប្រកបដោយធម៌នោះ ភ្លៀងរមែងបង្អុរចុះ
ក្នុងកាលមិនគួរ មិនបង្អុរចុះក្នុងកាលដែលគួរ ឯស្តេចមិន
ប្រកបដោយធម៌នោះ រមែងច្យុតចាកឋានសួគ៌ ត្រូវគេសម្លាប់
ចោលដោយហេតុត្រឹមប៉ុណ្ណោះដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អកាលេ** សេចក្តីថា ក្នុងរជ្ជសម័យរបស់ព្រះបាទអធម្មិករាជ ភ្លៀងរមែងធ្លាក់ក្នុងកាលដែលមិនគួរ គឺក្នុងកាលដែលស្រូវទុំខ្លះ ក្នុងកាលដែលច្រូតខ្លះ ក្នុងកាលបោកបែនជាដើមខ្លះ ។ បទថា **កាលេ** សេចក្តីថា តែមិនធ្លាក់ក្នុងកាលត្រូវប្រកបការងារ និងពេលខ្វល់ខ្វាយ

ក្នុងការងារក្នុងកាលសាបព្រោះ ក្នុងកាលដកស្ទូង ក្នុងកាលស្រូវមានដង្ហើមជាដើមឡើយ ។ បទថា **សគ្គា ច ចវតិ ឋានា** សេចក្ដីថា ឃ្លាតចាកឋានៈបានដល់ស្ថានសួគ៌ គឺចាកទេវលោកពិតហើយ ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ឈ្មោះថា ឃ្លាតចាកទេវលោកព្រោះមិនបានលាភឬការគ្រងរាជ-សម្បត្តិនៅក្នុងស្ថានសួគ៌ក៏ឈ្មោះថា ឃ្លាតចាកស្ថានសួគ៌នោះ ។ បទថា **ឆន្ទុសោ តាវតា ហតោ** សេចក្ដីថា ព្រះរាជាមិនតាំងនៅក្នុងអរិយធម៌នឹងត្រូវកម្ចាត់ដោយហេតុត្រឹមប៉ុណ្ណេះដោយពិត ។ម្យ៉ាងទៀតនឹងក្ដៅក្រហាយក្នុងមហានរក ៨ រណ្ដៅនិងក្នុងឧស្សទនរក ១៦ រណ្ដៅនេះជាអធិប្បាយក្នុងសេចក្ដីនេះ ។

សក្កទេវរាជប្រទានឱវាទដល់មហាជនយ៉ាងនេះហើយ បានយាងត្រឡប់ទៅកាន់ទេវស្ថានរបស់ព្រះអង្គសូម្បីព្រះពោធិសត្វក៏គ្រងរាជសម្បត្តិដោយធម៌ទ្រង់បំពេញផ្លូវទៅស្ថានសួគ៌ឲ្យបរិបូណ៌ ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយទ្រង់ប្រជុំជាតកថា ព្រះរាជាមិនតាំងនៅក្នុងធម៌ក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ សក្កទេវរាជក្នុងកាលនោះបានមកជាអនុរុទ្ធ នាងសុជាតាក្នុងកាលនោះបានមកជារាហុលមាតា ឯព្រះរាជាដែលសក្កៈប្រទានក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មណិចោរជាតក ចប់

## បញ្ចុត្តរជាតក

[ ២៣៩ ] ( ព្រះបាទព្រហ្មទត្តត្រាស់ថា ) ស្រះបោក្ខរណីដ៏ត្រជាក់កើតហើយក្បែរជើងភ្នំជាទីរីករាយ ចចកកាលដឹងថា ស្រះបោក្ខរណីនោះសីហៈរក្សាហើយក៏នៅតែផឹក ( ទឹកក្នុងស្រះនោះ ) ។

[ ២៤០ ] ( អមាត្យពោធិសត្វពោលថា ) បពិត្រមហារាជ ( មិនត្រឹមតែចចកប៉ុណ្ណោះទេ ) ពួកសត្វដែលមានជើង រមែងនាំគ្នាចុះផឹកទឹកស្ទឹងធំដែរ ( តែស្ទឹងធំនោះ ) នឹងក្លាយទៅជាមិនមែនស្ទឹងដោយហេតុនោះក៏ទេ បើ ( ស្ត្រីនោះ ) ជាទីស្រឡាញ់របស់ព្រះអង្គហើយ សូមព្រះអង្គអត់ទោសចុះ ។

**ចប់ បញ្ចុត្តរជាតក ទី ៥ ។**

## អដ្ឋកថា

## បញ្ចុត្តរជាតក

[ ២៣៩-២៤០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បញ្ចុត្តរេ រម្មេ** ដូច្នេះជាដើម ។

បានឮថា អាមាត្យម្នាក់របស់ព្រះបាទកោសលបង្កនូវការប្រទូស្តខាងក្នុងព្រះរាជវាំង ( ប្រទូស្តស្រីស្នំ ) ព្រះរាជាទ្រង់ស៊ើបដឹងរឿងនោះជាក់ច្បាស់ហើយ ទើបយាងទៅកាន់វត្តជេតពនដោយទ្រង់ព្រះតម្រិះថានឹងក្រាបទូលព្រះសាស្តា ថ្វាយបង្គំព្រះសាស្តា ហើយត្រាស់សួរថា បពិត្រព្រះអង្គដ៏ចម្រើន

អាមាត្យម្នាក់ ប្រទូស្តខាងក្នុងព្រះរាជវាំងរបស់ខ្ញុំព្រះអង្គ គួរធ្វើដូចម្តេចដល់អាមាត្យនោះ ព្រះសាស្តាត្រាស់សួរព្រះរាជាថា មហាបពិត្រ អាមាត្យនោះមានឧបការៈចំពោះព្រះអង្គឬ ហើយស្រីនោះជាទីស្រឡាញ់របស់ព្រះអង្គឬ ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដូច្នោះពិតមែនអាមាត្យនោះមានឧបការៈក្រៃលែងជួយការងារក្នុងរាជត្រកូលគ្រប់យ៉ាងផង ស្រីនោះក៏ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គផងទើបព្រះសាស្តាមានព្រះតម្រាស់ថា មហាបពិត្រទ្រង់មិនគួរដាក់ទោសក្នុងសេវកៈ ដែលមានឧបការៈនិងក្នុងស្រីដែលជាទីស្រឡាញ់របស់ព្រះអង្គឡើយ សូម្បីក្នុងកាលមុនព្រះរាជាទាំងឡាយស្តាប់ពាក្យរបស់ពួកបណ្ឌិតក៏ទ្រង់ដាក់ព្រះទ័យជាកណ្តាល កាលព្រះរាជាទូលអារាធនាទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ កាលចម្រើនវ័យក៏បាននាទីក្នុងការថ្វាយអត្ថនិងធម៌ដល់ព្រះរាជាអង្គនោះ ។ កាលនោះអាមាត្យម្នាក់របស់ព្រះរាជាបង្កហេតុប្រទូស្តខាងក្នុងព្រះរាជវាំង ព្រះរាជាទ្រង់ជ្រាបរឿងនោះពិតប្រាកដទើបត្រិះរិះថា អាមាត្យនេះក៏មានឧបការៈច្រើនដល់អញ ស្រីនេះក៏ជាទីស្រឡាញ់របស់អញ នឹងទម្លាយជនទាំងពីរមិនបាន អញនឹងសួរបញ្ហាចំពោះអាមាត្យដែលជាបណ្ឌិត បើគួរអត់ទោសបានអញគួរអត់ទោស បើអត់ទោសមិនបានអញនឹងមិនអត់ទោស ទើបត្រាស់ហៅអាមាត្យពោធិសត្វមកឲ្យអាសនៈហើយត្រាស់ថា នែបណ្ឌិត យើងនឹងសួរបញ្ហាចំពោះអ្នក កាលព្រះពោធិសត្វ

ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់សួរមកចុះទូលព្រះបង្គំនឹងឆ្លើយ កាលត្រាស់សួរបញ្ហាទើបពោលគាថាទីមួយថា

ស្រះបោក្ខរណីដ៏ត្រជាក់ កើតហើយក្បែរជើងភ្នំ ជាទីរីករាយ
ចចកកាលដឹងថា ស្រះបោក្ខរណីនោះ សីហៈរក្សាហើយក៏
នៅតែផឹក ( ទឹកក្នុងស្រះនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បព្វតូបត្ថរេ រម្មេ** គឺ ក្នុងទីទួលដែលលាតសន្ធឹងត្រង់ជើងភ្នំហិមពាន្ត ។ បទថា **ជាតា បោក្ខរណី សិវា** គឺ ស្រះបោក្ខរណីមានទឹកត្រជាក់កើតហើយ ។ម្យ៉ាងទៀតសូម្បីស្ទឹងដែលដេរដាសដោយផ្កាឈូក ក៏ឈ្មោះថា ស្រះបោក្ខរណីដូចគ្នា ។ **អប** សព្ទក្នុងបទថា **អបាបាសិ** ជាឧបសគ្គ សេចក្តីថា បានផឹកហើយ ។ បទថា **ជានំ សីហេន រក្ខិតំ** សេចក្តីថា ស្រះបោក្ខរណីនោះ សម្រាប់ជាទីបរិភោគរបស់រាជសីហ៍ដែលរាជសីហ៍រក្សា ។ ចចកនោះ ទាំងដែលដឹងថា ស្រះបោក្ខរណីនេះរាជ-សីហ៍រក្សាក៏ផឹក អ្នកយល់ដូចម្តេច ចចកនោះមិនខ្លាចរាជសីហ៍ឬទើបផឹកទឹកក្នុងស្រះបោក្ខរណីបែបនេះ នេះជាសេចក្តីអធិប្បាយក្នុងគាថានេះ ។

ព្រះពោធិសត្វគិតថា ប្រហែលមានអាមាត្យណាមួយបង្កហេតុអាក្រក់ក្នុងស្រីស្នំរបស់ព្រះរាជាអង្គនេះទើបពោលគាថាទីពីរថា

បពិត្រមហារាជ ( មិនត្រឹមតែចចកប៉ុណ្ណោះទេ ) ពួកសត្វ
ដែលមានជើង រមែងនាំគ្នាចុះផឹកទឹកស្ទឹងធំដែរ ( តែស្ទឹងធំ
នោះ ) នឹងក្លាយទៅជាមិនមែនស្ទឹងដោយហេតុនោះក៏ទេ បើ

( ស្ត្រីនោះ ) ជាទីស្រឡាញ់របស់ព្រះអង្គហើយ សូមព្រះអង្គអត់ទោសចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាបទានិ** បានដល់ មិនមែនចចកតែមួយមុខប៉ុណ្ណោះទេ សត្វមានជើង ៤ ទាំងអស់មានក្ដែ សេះ ធ្មានិងម្រឹគក៏រមែងចុះផឹក ។ សត្វទាំងឡាយរមែងចុះផឹកទឹកក្នុងស្ទឹងដែលមានឈ្មោះថា បោក្ខរណី ព្រោះដេរដាសទៅដោយផ្កាឈូក ។ បទថា **ន តេន អនទី ហោតិ** សេចក្ដីថា សត្វគ្រប់ប្រភេទក៏ស្រេកទឹកទាំងសត្វជើង ២ ជើង ៤ ពស់និងត្រីតែងចុះផឹកទឹកក្នុងស្ទឹង ។ ស្ទឹងនោះនឹងឈ្មោះថា មិនមែនជាស្ទឹងដោយហេតុនោះក៏មិនមែនទាំងឈ្មោះថាជាស្ទឹងសំណល់ក៏មិនមែនសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជារបស់សាធារណៈដល់សត្វទូទៅ ម្យ៉ាងទៀតស្ទឹងដែលបុគ្គលណាមួយផឹករមែងមិនវិនាសយ៉ាងណាស្រីក៏យ៉ាងនោះ ក្បត់ស្វាមីដោយអំណាចកិលេសទៅនៅជាមួយប្រុសដទៃឈ្មោះថា មិនមែនស្រីក៏ទេ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជារបស់សាធារណៈដល់មនុស្សទូទៅ ។ ទាំងមិនឈ្មោះថាជាស្រីដែលសល់ពីគេ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពជាបុគ្គលបរិសុទ្ធប្រៀបដូចជាទឹក ។ បទថា **ខមស្សុ យទិ តេ បិយា** សេចក្ដីថា បើស្រីនោះជាទីស្រឡាញ់របស់ទ្រង់ផង អាមាត្យនោះជាអ្នកមានឧបការៈច្រើនដល់ព្រះអង្គផង សូមទ្រង់អត់ទោសដល់ជនទាំង ២ ចុះ គឺទ្រង់ដាក់ខ្លួនជាកណ្ដាល ។

ព្រះមហាសត្វ បានថ្វាយឱវាទដល់ព្រះរាជាយ៉ាងនេះ ព្រះរាជាទ្រង់តាំង

នៅក្នុងឱវាទរបស់ព្រះមហាសត្វហើយមានព្រះតម្រាស់អត់ទោសដល់ជនទាំង ២ ថា តាំងអំពីនេះទៅឯងទាំង ២ កុំធ្វើកម្មអាក្រក់បែបនេះទៀត ។ ព្រះរាជាទ្រង់ធ្វើបុណ្យមានទានជាដើម កាលអស់ព្រះជន្មទ្រង់បំពេញផ្លូវទៅកាន់ស្ថានសួគ៌ឲ្យបរិបូណ៌ ។

ព្រះរាជាកោសលបានស្តាប់ព្រះធម្មទេសនានេះហើយ ទ្រង់ក៏លើកលែងទោសដល់ជនទាំង ២ នោះ ដាក់ព្រះអង្គជាកណ្តាល ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ អាមាត្យជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បព្វតូបត្ថរជាតក ចប់

## វលាហកជាតក

[ ២៨១ ] ( ព្រះសាស្តាត្រាស់ថា ) ពួកនរជនណាមិនធ្វើតាមឱវាទដែលព្រះពុទ្ធសម្តែងហើយ ពួកនរជននោះនឹងដល់នូវសេចក្តីវិនាសដូចពួកឈ្មួញដែលអារក្ខទឹកទាំងឡាយ ( លួងលោមហើយ ) ។

[ ២៨២ ]ម្យ៉ាងទៀតពួកនរជនណាធ្វើតាមឱវាទដែលព្រះពុទ្ធសម្តែងហើយ ពួកនរជននោះនឹងដល់នូវត្រើយ គឺព្រះនិព្វានដោយសួស្តីដូចពួកឈ្មួញ ( ធ្វើតាមពាក្យ ) ដែលស្តេចវលាហកៈ ( ពោលហើយ ) ។

**ចប់ វលាហកជាតកទី ៦ ។**

## អដ្ឋកថា

## វលាហកជាតក

[ ២៨១-២៨២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យេ ន កាហន្តិ ឱវាទំ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបមានដូច្នេះថា ភិក្ខុនោះកាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុអ្នកអផ្សុកពិតឬ ក៏ក្រាបទូលថា ករុណាព្រះអង្គពិតមែន ព្រះសាស្តាត្រាស់សួរថា ព្រោះហេតុអ្វី ទើបក្រាបទូលថា ព្រោះឃើញមាតុគ្រាមតែងខ្លួនយ៉ាងស្អាតម្នាក់ទើបអផ្សុកដោយកិលេស ។ លំដាប់នោះព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុធម្មតាស្រីទាំងនេះលួងលោមបុរសដោយរូប សំឡេង ក្លិន រស

ផោដ្ឋព្វៈនិងដោយមាយាស្រ្តី ធ្វើឲ្យនៅក្នុងអំណាចរបស់ខ្លួនគេហៅថា យក្ខិនី ព្រោះលួងលោមបុរសដោយភាពញៀងញ៉ង កាលដឹងថា បុរសនោះធ្លាក់នៅក្នុងអំណាចហើយ ក៏ឲ្យដល់នូវការវិនាសនៃសីលនិងការវិនាសនៃផ្ទត់បវេណីពិតហើយ ក្នុងកាលមុនពួកយក្ខិនីចូលទៅរកពួកបុរសមួយក្រុមដោយមាយាស្រ្តីហើយលួងលោមពួកឈ្មួញឲ្យធ្លាក់នៅក្នុងអំណាចរបស់ខ្លួន លុះមានប្រុសដទៃមកទៀតក៏សម្លាប់ពួកឈ្មួញទាំងអស់ឲ្យដល់នូវការស្លាប់ ហើយទំពាស៊ីទាំងដែលមានឈាមហូរតាមថ្គាមទាំងសងខាង ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលត្រង់កោះតម្ពបណ្ណិមាននគរយក្ខឈ្មោះសិរិសវត្ថុ ។ ពួកយក្ខិនីនៅអាស្រ័យក្នុងនគរនោះ ។ ក្នុងកាលដែលពួកឈ្មួញសំពៅលិចសំពៅយក្ខិនីទាំងនោះក៏នាំគ្នាប្រដាប់តាក់តែងរាងកាយកាន់របស់ទំពា របស់បរិភោគមានពួកទាសីចោមរោមបីទារកចូលទៅរកពួកឈ្មួញដើម្បីឲ្យមនុស្សទាំងនោះដឹងថា ពួកយើងក៏មកដល់ទីលំនៅរបស់មនុស្ស ទើបបង្ហាញកិច្ចជាដើមថា ពួកមនុស្ស ហ្វូងគោ ឆ្កែ កំពុងធ្វើកសិកម្ម គោរក្ខកម្មជាដើមក្នុងទីនោះៗ ហើយចូលទៅរកពួកឈ្មួញពោលថា អញ្ជើញបរិភោគបបរ អញ្ជើញបរិភោគអាហារ អញ្ជើញទំពារបស់នេះ ពួកឈ្មួញបាត់បង់ភាពឈ្លាសវៃ បរិភោគអាហារដែលយក្ខិនីទាំងនោះឲ្យហើយ ។ កាលដល់ពេលដែលពួកជនទាំងនោះទំពាបរិភោគស្រេចហើយសម្រាកទើបយក្ខិនីសួរថា ពួកលោកនៅឯណាមកអំពីណាទៅណា មកទីនេះធ្វើអ្វី កាលពួកឈ្មួញឆ្លើយថា ពួកខ្ញុំលិចសំពៅ

ទើបមកទីនេះ យក្ខិនីពោលថា សាធុ ប្តីរបស់ពួកខ្ញុំក៏ចេញសំពៅទៅអស់ ៣ ឆ្នាំហើយប្រហែលជាស្លាប់អស់ ពួកអ្នកក៏ជាឈ្មួញដូចគ្នា ពួកខ្ញុំនឹងជាស្រីបម្រើពួកលោក ហើយលួងលោមឈ្មួញទាំងនោះដោយមាយាមានសើចនិងចរិតរបស់ស្ត្រីនាំទៅនគរយក្ខ បើមានពួកមនុស្សដែលចាប់ទុកអំពីមុនក៏ចងមនុស្សទាំងនោះដោយច្រវាក់កាយសិទ្ធិ ទុកក្នុងបន្ទប់ឃុំឃាំង ធ្វើមនុស្សដែលចាប់បានខាងក្រោយឲ្យជាប្តីរបស់ខ្លួន តែកាលមិនបានមនុស្សដែលត្រូវសំពៅលិចមកទេ ក៏ត្រាច់ទៅតាមឆ្នេរសមុទ្ទ ដែលមានកោះកល្យាណីជាត្រើយនាយមានកោះនាគជាត្រើយអាយ[១] ។

ថ្ងៃមួយឈ្មួញដែលលិចសំពៅ ៥០០ នាក់នាំគ្នាឡើងទៅជិតនគរយក្ខិនីទើបយក្ខិនីទាំងនោះ ទៅរកពួកឈ្មួញលួងលោមហើយនាំមកនគរយក្ខ ចងពួកមនុស្សដែលចាប់ក្នុងកាលមុន ដោយច្រវាក់ យកទៅដាក់ក្នុងបន្ទប់ឃុំឃាំង ប្រធានយក្ខិនីក៏យកប្រធានឈ្មួញជាប្តី យក្ខិនីដ៏សេសក៏យកឈ្មួញដទៃជាប្តី យក្ខិនី ៥០០ បានធ្វើឈ្មួញ ៥០០ ឲ្យជាប្តីរបស់ខ្លួនដោយប្រការដូច្នេះ ។

តមកយក្ខិនីជាប្រធាននោះក្នុងកណ្តាលរាត្រីកាលឈ្មួញដេកលក់ ទើបក្រោកឡើងទៅសម្លាប់មនុស្សទាំងឡាយក្នុងទីឃុំឃាំងស៊ីសាច់ស្រេចហើយក៏ត្រឡប់មក ។ យក្ខិនីដ៏សេសក៏ធ្វើយ៉ាងនោះដូចគ្នា ។ ក្នុងកាលដែលប្រធាន

---

១-ក្នុងទីនេះពាក្យថា កល្យាណី ព្រោះមានដើមក្លៅនាងដុះប្រចាំកោះ ឯពាក្យថា នាគសំដៅដល់កោះដែលមានដើមខ្លឹងតែក្នុងចរិយាបិដកពាក្យថា នាគ លោកប្រែថា កោះពស់ដែលអកិត្តិតាបសពោធិសត្វអាស្រ័យនៅ ឆាន់ស្លឹកតង្កៀបក្តាមក្នុងទីនោះ ។

យក្ខិនីស៊ីមនុស្សហើយត្រឡប់មកវាងកាយក៏ត្រជាក់ ឈ្មួញដែលជាប្រធានក៏ឃ្លាំសង្កេតមើល លុះដឹងថាជាយក្ខិនីក៏ពិចារណាថា ស្រី ៥០០ ប្រហែលជាយក្ខិនី ពួកយើងគួរគេចទៅ ព្រឹកឡើងដើរទៅដើម្បីលុបមុខទើបប្រាប់ដល់ពួកឈ្មួញដទៃថា ស្រីទាំងនេះជាយក្ខិនីមិនមែនស្រីមនុស្ស ក្នុងពេលដែលពួកឈ្មួញលិចសំពៅមកពួកយក្ខិនីនឹងធ្វើឈ្មួញទាំងនោះឲ្យជាប្តី ហើយស៊ីពួកយើង មកពួកយើងនាំគ្នាគេចទៅ ។ បណ្តាពួកឈ្មួញទាំងនោះឈ្មួញ ២៥០ពោលថា ខ្ញុំមិនអាចបោះបង់ស្រីទាំងនេះទៅបានទេ ពួកលោកទៅចុះ ពួកយើងមិនគេចទៅឡើយ ប្រធានឈ្មួញក៏នាំឈ្មួញ ២៥០ នាក់ដែលស្តាប់ពាក្យរបស់ខ្លួនខ្លាចយក្ខិនីទាំងនោះគេចទៅ ក្នុងកាលនោះព្រះពោធិសត្វកើតក្នុងកំណើតសេះវលាហក សេះនោះមានពណ៌សសុទ្ធ មានក្បាលដូចក្អែកសក់ជាសំណុំមានឫទ្ធិអាចហោះបាន ។ សេះនោះហោះមកអំពីព្រៃហិមពាន្តទៅកាន់កោះតម្ពបណ្ណិ ស៊ីស្រូវសាលីដែលកើតឯងលើកក់ជិតស្រះតម្ពបណ្ណិនោះហើយត្រឡប់ទៅ ។ម្យ៉ាងទៀតកាលហោះទៅនោះពោលជាកាសាមនុស្សដែលបានអប់រំមកដោយសេចក្តីករុណា ៣ ដងថា មានបុគ្គលណាបំណងទៅជនបទដែរឬទេ មានបុគ្គលណាបំណងទៅជនបទដែរឬទេ មានបុគ្គលណាបំណងទៅជនបទដែរឬទេ ។ ពួកឈ្មួញទាំងនោះបានឮពាក្យរបស់សេះនោះទើបផ្គងអញ្ជលីចូលទៅរកពោលថា បពិត្រលោកម្ចាស់ ខ្ញុំចង់ទៅកាន់ជនបទ ។ សេះប្រាប់ថា បើដូច្នោះចូរឡើងលើខ្នងមកចុះ ។ ហើយឈ្មួញពួកខ្លះក៏ឡើងលើខ្នង ពួកខ្លះចាប់ត្រង់កន្ទុយ ពួកខ្លះឈរផ្គងអញ្ជលី ។ ព្រះពោធិសត្វនាំ

ឈ្មួញទាំងអស់ដោយហោចពួកជនដែលឈរផ្គងអញ្ជលីទៅកាន់ជនបទដោយអានុភាពរបស់ខ្លួនឲ្យជនទាំងនោះនៅក្នុងលំនៅរៀងៗខ្លួនហើយទៅកាន់លំនៅរបស់ខ្លួន ។ យក្ខិនីទាំងនោះក្នុងកាលដែលអ្នកសំពៅដទៃមកដល់ក៏សម្លាប់មនុស្ស ២៥០ ដែលនៅក្នុងទីនោះស៊ីជាអាហារ ។

ព្រះសាស្តាហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកឈ្មួញដែលធ្លាក់ក្នុងអំណាចនៃយក្ខិនីបានអស់ជីវិត ពួកជនដែលជឿពាក្យស្តេចសេះវលាហកក៏ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនដោយសួស្តីយ៉ាងណា ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលមិនធ្វើតាមឱវាទរបស់ព្រះពុទ្ធទាំងឡាយក៏យ៉ាងនោះដូចគ្នា រមែងដល់នូវសេចក្តីទុក្ខធំក្នុងអបាយភូមិ ៤ ចំណង ៥ ប្រការនិងគ្រឿងកម្មករណៈជាដើម ឯបុគ្គលដែលស្តាប់ឱវាទ រមែងសម្រេចឋានៈទាំងនេះគឺ កុសលសម្បត្តិ ៣ ស្ថានសួគ៌ជាន់កាមាវចរ ៦ ព្រហ្មលោក ២០ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតមហានិព្វានសោយសុខជាអនេក កាលទ្រង់ត្រាស់ដឹងអភិសម្ពោធិញ្ញាណហើយទើបត្រាស់គាថាទាំងនេះថា

ពួកនរជនណាមិនធ្វើតាមឱវាទ ដែលព្រះពុទ្ធសម្តែងហើយ
ពួកនរជននោះនឹងដល់នូវសេចក្តីវិនាសដូចពួកឈ្មួញដែល
អារក្ខទឹកទាំងឡាយ ( លួងលោមហើយ ) ។

ម្យ៉ាងទៀតពួកនរជនណា ធ្វើតាមឱវាទដែលព្រះពុទ្ធសម្តែង
ហើយ ពួកនរជននោះនឹងដល់នូវត្រើយ គឺព្រះនិព្វានដោយ
សួស្តីដូចពួកឈ្មួញ ( ធ្វើតាមពាក្យ ) ដែលស្តេចវលាហកៈ

( ពោលហើយ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ ន កាហន្តិ ឱវាទំ** គឺ នរជនទាំងឡាយណាមិនជឿពាក្យប្រៀនប្រដៅ ។ បទថា **ព្យសនំ តេ គមិស្សន្តិ** បានដល់ នរជនទាំងនោះនឹងដល់មហាវិនាស ។ បទថា **រក្ខសីហិវ វា-ណិជា** បានដល់ ដូចពួកឈ្មួញដែលត្រូវយក្ខិនីលួងលោមដូច្នោះ ។ បទថា **សោត្ថិ ចារំ គមិស្សន្តិ** បានដល់ នឹងដល់នូវត្រើយ គឺព្រះនិព្វានដោយសួស្តី ។ បទថា **វលាហកេនវ វាណិជា** បានដល់ ដូចឈ្មួញដែលសេះវលាហកពោលថា មកចុះក៏ជឿសេះនោះ ។

ព្រះសាស្ដាទ្រង់កាន់យកកំពូលនៃព្រះធម្មទេសនាដោយអមតមហានិព្វានថា ជនទាំងឡាយដែលធ្វើតាមពាក្យរបស់ព្រះពុទ្ធទាំងឡាយ រមែងដល់នូវនិព្វានដែលជាត្រើយនៃសង្សារដូចឈ្មួញទាំងនោះទៅដល់ច្រាំងនៃមហាសមុទ្រក៏បានទៅកាន់លំនៅរៀងៗខ្លួន ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចធម៌ លុះចប់សច្ចធម៌ភិក្ខុអ្នកអផ្សុកតាំងនៅក្នុងសោតាបត្តិផល ភិក្ខុដទៃច្រើនរូបសម្រេចសោតាបត្តិផល សកទាគាមិផល អនាគាមិផល និងអរ-ហត្តផលហើយទ្រង់ប្រជុំជាតកថា ឈ្មួញ ២៥០ ដែលជឿពាក្យរបស់ស្ដេចសេះវលាហកក្នុងកាលនោះបានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯស្ដេចសេះវលាហកក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វលាហកជាតក ចប់**

# មិត្តាមិត្តជាតក

[ ២៨៣ ] ( ព្រះពោធិសត្វពោលថា ) បុគ្គលឃើញបុគ្គលនោះហើយ មិនញញឹមផង មិនរីករាយតបនឹងបុគ្គលនោះផង មិនឲ្យភ្នែកចំពោះបុគ្គលនោះ គឺមិនសំឡឹងចំភ្នែកនិងភ្នែកផង ប្រព្រឹត្តខ្ទាំងសត្រូវ (ចំពោះបុគ្គលនោះផង) ។

[ ២៨៤ ] បុគ្គលជាបណ្ឌិតឃើញហើយ ឮហើយគប្បីស្គាល់នូវបុគ្គលមិនមែនជាមិត្តដោយអាការៈទាំងឡាយណា អាការៈទាំងឡាយនុ៎ះរមែងមានតាំងនៅក្នុងបុគ្គលមិនមែនជាមិត្ត ។

**ចប់ មិត្តាមិត្តជាតក ទី ៧ ។**

## អដ្ឋកថា
## មិត្តាមិត្តជាតក

[ ២៨៣-២៨៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆ ធំ ឱម្ហាយតេ ធិស្វា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុមួយរូបកាន់យកសេសសំពត់មួយផ្ទាំង ដោយវិសាសៈដែលព្រះឧបជ្ឈាយ៍ទុកដោយគិតថា កាលអញកាន់យកហើយព្រះឧបជ្ឈាយ៍របស់អញនឹងមិនក្រោធ ហើយធ្វើជាថង់ដាក់ស្បែកជើង ខាងក្រោយទើបប្រាប់ឧបជ្ឈាយ៍ ។ កាលឧបជ្ឈាយ៍សួរភិក្ខុនោះថា ព្រោះហេតុអ្វីទើបលោកកាន់យកសំពត់របស់ខ្ញុំ ភិក្ខុនោះឆ្លើយថា ខ្ញុំកាន់យករបស់លោកម្ចាស់ដោយស្និទ្ធ

ស្ពាលព្រោះគិតថា កាលអាត្មាអញកាន់យកហើយ ព្រះឧបជ្ឈាយ៍នឹងមិនក្រោធ ទើបឧបជ្ឈាយ៍ពោលថា ឈ្មោះថា វិសាសៈរបស់អ្នកនិងខ្ញុំដូចម្ដេចហើយ ខឹងក្រោធ ។ ការធ្វើរបស់ឧបជ្ឈាយ៍នោះបានប្រាកដក្នុងពួកភិក្ខុ ។

ថ្ងៃមួយភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ភិក្ខុកំលោះរូបនោះបានកាន់យកសេសសំពត់របស់ឧបជ្ឈាយ៍ដោយវិសា-សៈ ហើយធ្វើជាថង់ដាក់ស្បែកជើងតែឧបជ្ឈាយ៍បែរជាក្រោធខឹងហើយសួរថា ឈ្មោះថា វិសាសៈរបស់អ្នកនិងខ្ញុំដូចម្ដេច ព្រះសាស្ដាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានវិសាសៈនឹងសទ្ធិវិហារិករបស់ខ្លួនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏មិនមានវិសាសៈដូចគ្នា ហើយទ្រង់នាំយករឿងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងដែនកាសី កាលចម្រើនវ័យហើយចេញបួសជាឥសី ញុំាងអភិញ្ញានិងសមាបត្តិឲ្យកើត បានជាគ្រូប្រចាំគណៈអាស្រ័យនៅក្នុងហិមវន្តប្បទេស ។ ក្នុងពួកឥសីនោះមានតាបសមួយរូបមិនជឿពាក្យព្រះពោធិសត្វ ចិញ្ចឹមកូនដំរីកំព្រាមួយ ។ កាលកូនដំរីធំឡើងបានសម្លាប់តាបសនោះហើយគេចចូលព្រៃ ។ ពួកឥសីកាលធ្វើឈាបនកិច្ចសព

របស់តាបសនោះស្រេចហើយ ទើបចូលទៅចោមរោម សួរព្រះពោធិសត្វថា បពិត្រលោកម្ចាស់ ភាពជាមិត្តឬជាសត្រូវអាចដឹងបានដោយហេតុដូចម្ដេច កាលព្រះពោធិសត្វប្រាប់ថា ដោយហេតុនេះៗទើបពោលគាថាទាំងនេះថា

បុគ្គលឃើញបុគ្គលនោះហើយមិនញញឹមផង មិនរីករាយ
តបនឹងបុគ្គលនោះផង មិនឲ្យភ្នែកចំពោះបុគ្គលនោះ គឺមិន
សំឡឹងចំភ្នែកនិងភ្នែកផង ប្រព្រឹត្តខ្វាំងសត្រូវ ( ចំពោះបុគ្គល
នោះផង ) ។

បុគ្គលជាបណ្ឌិតឃើញហើយ ឮហើយគប្បីស្គាល់នូវបុគ្គល
មិនមែនជាមិត្តដោយអាការៈទាំងឡាយណា អាការៈទាំងឡាយ
នុ៎ះរមែងមានតាំងនៅក្នុងបុគ្គលមិនមែនជាមិត្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន នំ ឧម្ហយតេ ទិស្វា** សេចក្ដីថា ជនជាសត្រូវនៃបុគ្គលណា ជននោះបានឃើញអ្នកនោះហើយរមែងមិនញញឹម គឺមិនសើច មិនសម្ដែងអាការត្រេកអរ ។ បទថា **ន ច នំ បដិនន្ទតិ** បានដល់ សូម្បីបានឮពាក្យរបស់ជននោះរមែងមិនសរសើរបុគ្គលនោះ គឺមិនត្រេកអរតាមថា ពាក្យរបស់បុគ្គលនោះល្អជាសុភាសិត ។ បទថា **ចក្ខូនិ ចស្ស ន ទទាតិ** បានដល់ ភ្នែកនិងភ្នែកប៉ះគ្នាហើយដាក់មុខចុះមិនសម្លឹងមើល គឺបែរមុខទៅកាន់ទីដទៃ ។ បទថា **បដិលោមញ្ច វត្តតិ** បានដល់ មិនពេញចិត្តការប្រព្រឹត្តតាមកាយ តាមវាចារបស់បុគ្គលនោះ គឺកាន់យកផ្ទុយគ្នា សម្ដែងកិរិយាជាសត្រូវ ។ បទថា **អាការា** បានដល់ ហេតុ ។

បទថា **យេហិ អមិត្តំ** សេចក្ដីថា ហេតុដែលបុគ្គលជាបណ្ឌិតឃើញនិងឮ ហើយគប្បីដឹងបានថា បុគ្គលនេះជាសត្រូវនឹងអញ ។ ឯភាពជាមិត្តគប្បីដឹងបានដោយអាការផ្ទុយគ្នានឹងសត្រូវនោះ ។

ព្រះពោធិសត្វកាលប្រាប់ហេតុនៃភាពជាមិត្តនិងជាសត្រូវយ៉ាងនេះហើយ ចម្រើនព្រហ្មវិហារចូលដល់ព្រហ្មលោក ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា តាបសចិញ្ចឹមកូនដំរីក្នុងកាលនោះបានមកជាសទ្ធិវិហារិកក្នុងកាលឥឡូវនេះ ដំរីក្នុងកាលនោះបានមកជាឧបជ្ឈាយ៍ គណៈឥសីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯគ្រូប្របាំគណៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មិត្តាមិត្តជាតក ចប់

## រាធជាតក

[ ២៨៥ ] ( ព្រាហ្មណ៍ពោលថា ) ម្នាលអ្នក អញមកអំពីទីព្រាត់ប្រាសហើយ ទើបនឹងមកដល់ក្នុងកាលអម្បាញ់មិញនេះ ម្នាលអ្នក ចុះមាតារបស់អ្នកមិនចូលទៅសេពនឹងបុរសដទៃខ្លះទេឬ ។

[ ២៨៦ ] ( សេកឈ្មោះរាធៈពោលថា ) បុគ្គលកាលពោលវាចាដែលប្រកបដោយសច្ចនេះតែមិនល្អ គប្បីដេកដូចជាសេកឈ្មោះបោដ្ឋបាទត្រូវនាងព្រាហ្មណីដុតក្នុងជើងក្រានដូច្នោះ ។

**ចប់ រាធជាតកទី ៨ ។**

## អដ្ឋកថា

## រាធជាតក

[ ២៨៥-២៨៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ អផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បវាសា អាគតោ តាត** ដូច្នេះជាដើម ។

បានឮថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ព្រះមានព្រះភាគត្រាស់សួរថា ព្រោះហេតុអ្វីទើបអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ព្រោះឃើញស្ត្រីរូបស្អាតមួយរូប ទើបអផ្សុកដោយអំណាចកិលេស ។ លំដាប់នោះព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ធម្មតាមាតុគ្រាមបុគ្គលណា

មួយក៏មិនអាចរក្សាបានសូម្បីក្នុងកាលមុនគេដាក់អ្នកយាមទ្វាររក្សាទុក នៅតែមិនអាចរក្សាបាន អ្នកត្រូវការមាតុគ្រាមធ្វើអ្វី សូម្បីបានហើយក៏មិនអាចរក្សាបាន ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសេកឈ្មោះរាធៈ ។ សេកនោះមានប្អូនឈ្មោះ បោដ្ឋបាទ ព្រាហ្មណ៍ម្នាក់ចាប់សេក ២ នាក់បងប្អូនក្នុងកាលនៅជាកូនតូច ឲ្យដល់ព្រាហ្មណ៍ម្នាក់ក្នុងក្រុងពារាណសី ។ ព្រាហ្មណ៍នោះចិញ្ចឹមសេកទុកក្នុងឋានៈជាកូន តែព្រាហ្មណីរបស់ព្រាហ្មណ៍ជាស្រីមិនរក្សាខ្លួន ជាស្រីទ្រុស្តសីល ។ កាលព្រាហ្មណ៍ទៅធ្វើការលក់ដូរបានហៅកូនសេកនោះមកប្រាប់ថា នែបា ឪពុកទៅធ្វើការជួញដូរចូរឯងទាំង ២ មើលការធ្វើរបស់ម្តាយឯងទាំងក្នុងពេលថ្ងៃទាំងក្នុងពេលយប់គប្បីពិនិត្យមើលថា មានប្រុសដទៃមកឬអត់ កាលប្រគល់នាងព្រាហ្មណីនឹងកូនសេកហើយចេញទៅ ។ ព្រាហ្មណីតាំងពីព្រាហ្មណ៍ចេញទៅក៏ប្រព្រឹត្តអនាចារ មនុស្សដែលទៅនិងមកទាំងពេលយប់ពេលថ្ងៃច្រើនពន់ពេក ។ បោដ្ឋបាទឃើញដូច្នោះសួររាធៈថា ព្រាហ្មណ៍បានប្រគល់ព្រាហ្មណីនេះដល់ពួកយើងហើយទើបទៅ ឥឡូវនេះព្រាហ្មណីនេះធ្វើនូវការផិតក្បត់ យើងនឹងជាស់តឿនល្អដែរឬទេ រាធៈឆ្លើយថា កុំឡើយ បោដ្ឋបាទ ។ បោដ្ឋបាទមិនជឿពាក្យរបស់រាធៈ ទើបទៅជាស់តឿនព្រាហ្មណីថា បពិត្រមាតា ព្រោះហេតុអ្វីទើបមាតាផិតក្បត់យ៉ាងនេះ ។ ព្រាហ្មណីចង់សម្លាប់បោដ្ឋបាទពុតធ្វើជាស្រឡាញ់ហៅមកពោលថា នែកូន ឯងជាទីស្រ-

ឡាញ់របស់ម៉ែ តាំងអំពីនេះទៅម៉ែឈប់ធ្វើកម្មនោះទៀតហើយ មកកូន លុះបោដ្ឋបាទមកក៏ចាប់ហើយកំហែងថា ឯងទូន្មានអញ ឯងមិនស្គាល់ប្រមាណខ្លួនហើយមួលករហូតដល់អស់ជីវិតបោះទៅក្នុងជើងក្រាន ។ ព្រាហ្មណ៍មកដល់សម្រាកបន្តិចហើយសួរព្រះពោធិសត្វថា នែរាជៈ ម្ដាយរបស់ឯងធ្វើអនាចារដែរឬទេទើបពោលគាថាទីមួយថា

ម្នាលអ្នក អញមកអំពីទីព្រាត់ប្រាសហើយទើបនឹងមកដល់ក្នុង
កាលអម្បាញ់មិញនេះ ម្នាលអ្នក ចុះមាតារបស់អ្នកមិនចូល
ទៅសេពនឹងបុរសដទៃខ្លះទេឬ ដូច្នេះ ។

អធិប្បាយសេចក្ដីនៃគាថានោះថា នែបារាជៈ ឪពុកត្រឡប់មកអំពីទីព្រាត់ប្រាសទើបតែមកដល់អម្បាញ់មិញនេះឯងមកមិនយូរប៉ុន្មាន ដោយហេតុនោះឪពុកមិនដឹងរឿងសុំសួរបា នែកូន ម៉ែរបស់ឯងមិនចូលទៅសេពបុរសដទៃទេឬ ។

រាជៈឆ្លើយថា បពិត្រលោកឪពុក ធម្មតាបណ្ឌិតទាំងឡាយរមែងមិនពោលពាក្យពិតឬមិនពិតដែលមិនធ្វើឲ្យផុតទុក្ខបាន កាលនឹងប្រាប់ឲ្យព្រាហ្មណ៍ដឹងទើបពោលគាថាទីពីរថា

បុគ្គលកាលពោលវាចាដែលប្រកបដោយសច្ចនេះ តែមិនល្អ
គប្បីដេកដូចជាសេកឈ្មោះបោដ្ឋបាទ ត្រូវនាងព្រាហ្មណីដុត
ក្នុងជើងក្រានដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **គិរំ** គឺ វាចា ។ ពិតហើយវាចាលោកហៅ

ថា គិរៈ ដូចវាចាដែលបន្លឺចេញក្នុងពេលនេះ ។ កូនសេកនោះមិនបានគិតដល់ភេទ ទើបពោលយ៉ាងនោះ ។ អធិប្បាយសេចក្ដីក្នុងគាថានេះដូច្នេះថា បពិត្រលោកឪពុក ធម្មតាបណ្ឌិត មិនពោលសូម្បីពាក្យដែលប្រកបដោយសច្ចៈ គឺសភាពដែលពិតនិងប្រកបដោយប្រយោជន៍ តែមិនធ្វើឲ្យផុតទុក្ខនិងសេចក្ដីពិតដែលមិនល្អ គឺមិនធ្វើឲ្យផុតទុក្ខ ។ បទថា **សយេថ ពោដ្ឋបាទោ មុម្មុរេ ឧបក្កសិតោ** សេចក្ដីថា ដូចសេកឈ្មោះពោដ្ឋបាទដេកដេកនៅក្នុងរងើកភ្លើងដូច្នោះ ។ បាលីថា **ឧបកុដ្ឋិតោ** ក៏មានឯសេចក្ដីក៏ដូចគ្នា ។

រាធៈសម្ដែងធម៌ដល់ព្រាហ្មណ៍យ៉ាងនេះហើយ ទើបពោលថា ខ្ញុំមិនអាចនៅក្នុងទីនេះបានទេ ក៏លាព្រាហ្មណ៍ហើយហើរចូលទៅកាន់ព្រៃ ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា សេកឈ្មោះពោដ្ឋបាទក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ សេកឈ្មោះរាធៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថារាធជាតក ចប់**

## គហបតិជាតក

[ ២៤៧ ] ( គហគតីពោធិសត្វពោលថា ) ហេតុទាំង ២ យ៉ាង មិនគួរដល់យើង ហេតុទាំង ២ យ៉ាង យើងមិនពេញចិត្តទេ ស្រីនេះចុះកាន់ជង្រុក ហើយនិយាយថា ខ្ញុំមិនសងដូច្នេះ ។

[ ២៤៨ ] ម្នាលម្ចាស់ស្រុក ព្រោះហេតុនោះបានជាយើងនិយាយនឹងអ្នក កាលបើជីវិតលំបាកតិច ( ប្រព្រឹត្តទៅយ៉ាងនេះកាលយើងកាន់យក ) នូវសាច់អ្នក ( បានឲ្យ ) នូវគោចាស់ស្គមហើយធ្វើនូវការកំណត់ ២ ខែ ឥឡូវនេះមកតឿនទារក្នុងកាលដែលមិនទាន់ដល់កំណត់ ក៏អំពើនោះយើងមិនពេញចិត្តឡើយ ។

**ចប់ គហបតិជាតកទី ៩ ។**

## អដ្ឋកថា
## គហបតិជាតក

[ ២៤៧-២៤៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកដូចគ្នា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧភយំ មេ ន ខមតិ** ដូច្នេះជាដើម ។

ព្រះសាស្តាកាលត្រាស់ទើបត្រាស់ថា ឈ្មោះថា មាតុគ្រាមរក្សាមិនបាន ធ្វើនូវកម្មអាក្រក់ហើយរមែងបោកប្តីដោយឧបាយណាមួយ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលគហបតីនាដែនកាសី កាលចម្រើនវ័យបានគ្រប់គ្រងឃរាវាស ។ ភរិយារបស់ព្រះពោធិសត្វនោះជាស្រីទ្រុស្តសីល ប្រព្រឹត្តអនាចារជាមួយមេស្រុក ។ ព្រះពោធិសត្វជ្រាបអាកប្បកិរិយាទើបចាំឃ្លាំមើល ។ ក្នុងកាលនោះជារដូវភ្លៀង កាលស្រូវមិនទាន់ទុំក៏កើតការអត់ឃ្លានលុះដល់ស្រូវផើមអ្នកស្រុកទាំងអស់មូលមិត្តគ្នាខ្ចីគោចាស់មួយរបស់មេស្រុកមកបរិភោគសាច់ដោយសន្យាថា ពីរខែទៀតប្រូតកាត់ហើយនឹងឲ្យស្រូវ ។

ថ្ងៃមួយមេស្រុកបានឱកាស ទើបចូលទៅកាន់ផ្ទះក្នុងកាលដែលព្រះពោធិសត្វចេញទៅខាងក្រៅ ។ ក្នុងខណៈជនទាំង ២ ដេកជាសុខនោះឯង ព្រះពោធិសត្វក៏ចូលទៅតាមខ្លោងទ្វារបែរមុខទៅក្នុងផ្ទះ ។ ស្រីនោះងាកមកតាមទ្វារឃើញព្រះពោធិសត្វគិតថា អ្នកណាហ្នុ៎ ទើបឈរមើលត្រង់ធរណីទ្វារកាលដឹងថាព្រះពោធិសត្វនោះឯងទើបប្រាប់ដល់មេស្រុក មេស្រុកមានខ្លួនញ័រចំប្រប់ ។ ស្រីនោះប្រាប់ដល់មេស្រុកថា កុំខ្លាច កុំខ្លាច ខ្ញុំមានឧបាយមួយពួកយើងខ្ចីគោរបស់លោកមកស៊ីសាច់ សូមលោកធ្វើជាអ្នកទារថ្លៃសាច់ ខ្ញុំនឹងឡើងទៅកាន់ជង្រុកស្រូវហើយឈរត្រង់ទ្វារប្រាប់លោកថា ស្រូវមិនមានលោកឈរត្រង់កណ្តាលផ្ទះ ហើយទាររឿយៗថា ពួកក្មេងក្នុងផ្ទះរបស់យើងឃ្លានចូរនាងឲ្យថ្លៃសាច់ចុះ ថាហើយនាងក៏ឡើងទៅកាន់ជង្រុកស្រូវអង្គុយត្រង់ទ្វារជង្រុក ឯមេស្រុកឈរត្រង់កណ្តាលផ្ទះស្រែកថា ចូរឲ្យថ្លៃសាច់ដល់យើងនាងអង្គុយត្រង់ទ្វារជង្រុកពោលថា ក្នុងជង្រុកមិនមានស្រូវប្រូតកាត់ហើយខ្ញុំ

នឹងឲ្យសូមលោកទៅសិនចុះ ។

ព្រះពោធិសត្វចូលទៅកាន់ផ្ទះឃើញកិរិយារបស់ជនទាំង ២ ក៏ដឹងថា នេះជាឧបាយរបស់ស្រីអាក្រក់នេះ ទើបហៅមេស្រុកមកពោលថា នែលោក កាលខ្ញុំបរិភោគសាច់គោចាស់របស់លោកក៏បរិភោគដោយសន្យាថា អំពីនេះទៅពីរខែខ្ញុំនឹងឲ្យស្រូវ មិនទាន់ដល់កន្លះខែផង ព្រោះហេតុអ្វីទើបលោកមកទារក្នុងពេលនេះលោកមិនបានមកដោយហេតុនេះប្រហែលជាមកដោយហេតុដទៃទេដឹង ខ្ញុំមិនពេញចិត្តក្នុងកិរិយារបស់លោកឡើយ សូម្បីស្រីនេះក៏លាមកដឹងថា ជង្រុកមិនមានស្រូវក៏ឡើងជង្រុកប្រាប់ថា ស្រូវមិនមាន សូម្បីលោកក៏ទារថា ចូរឲ្យខ្ញុំ ខ្ញុំមិនគាប់ចិត្តការធ្វើរបស់អ្នកទាំងពីរឡើយ កាលប្រកាសសេចក្តីនេះទើបពោលគាថាទាំងនេះថា

ហេតុទាំង ២ យ៉ាងមិនគួរដល់យើង ហេតុទាំង ២ យ៉ាង
យើងមិនចេញចិត្តទេ ស្រីនេះចុះកាន់ជង្រុកហើយនិយាយថា
ខ្ញុំមិនសងដូច្នេះ ។

ម្នាលម្ចាស់ស្រុក ព្រោះហេតុនោះបានជាយើងនិយាយនឹង
អ្នក កាលបើជីវិតលំបាកតិច[1] ( ប្រព្រឹត្តទៅយ៉ាងនេះកាល
យើងកាន់យក ) នូវសាច់អ្នក ( បានឲ្យ ) នូវគោចាស់ស្គម
ហើយធ្វើនូវការកំណត់ ២ ខែ ឥឡូវនេះមកតឿនទារក្នុងកាល
ដែលមិនទាន់ដល់កំណត់ ក៏អំពើនោះយើងមិនពេញចិត្តឡើយ

---

១-លំបាកផងតិចផង ។

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តំ តំ គាមបតិ ព្រូមិ** សេចក្ដីថា លោកជាអ្នកជំក្នុងស្រុក ខ្ញុំនិយាយនឹងលោកដោយហេតុនោះ ។ បទថា **កទរេ អប្បស្មិំ ជីវិតេ** សេចក្ដីថា ឈ្មោះថាជីវិតរបស់ខ្ញុំក្រីក្រ គឺខ្វះខាតសៅហ្មង មិនគ្រប់គ្រាន់ កម្លាំងតិច ស្ដាំងស្ដម កាលជីវិតរបស់ខ្ញុំដល់នូវសភាពបែបនេះ ។ បទថា **ទ្វេ មាសេ សង្គរំ កត្វា មំសំ ជរគ្គវំ កិសំ** សេចក្ដីថា កាលពួកយើងទទួលសាច់លោកក៏ឲ្យគោចាស់ គឺគោជរា ស្គម ទុព្វលភាពរូបសន្យា គឺកំណត់ពេល ២ ខែ យ៉ាងនេះថា ពីរខែកន្លងហើយអ្នកគួរជម្រះតម្លៃសាច់ ។ បទថា **អប្បត្តកាលេ ចោទេសិ** សេចក្ដីថា កាលមិនដល់ពេលនោះលោកក៏មកតឿនទារហើយ ។ បទថា **តម្បិ មយ្ហំ ន រុច្ចតិ** សេចក្ដីថា ស្រីអាក្រក់ទ្រុស្ដសីលនេះដឹងថា ខាងក្នុងជង្រុកមិនមានស្រូវធ្វើដូចជាមិនដឹងចុះកាន់ជង្រុកឈរត្រង់ទ្វារជង្រុកពោលថា ខ្ញុំមិនទាន់ឲ្យបំណុលបាន ម្យ៉ាងទៀតលោកក៏មកទារមិនទាន់ដល់កាល ហេតុទាំង ២ យ៉ាងនេះ ខ្ញុំមិនគាប់ចិត្តទេ ។

កាលព្រះពោធិសត្វពោលគំរាមយ៉ាងនេះក៏ក្របួចសក់ម្ចាស់ស្រុកទាញឲ្យដួលត្រង់កណ្ដាលផ្ទះហើយជេរដោយពាក្យជាដើមថា ឯងប្រទូស្ដរបស់ដែលអ្នកដទៃហួងហែងរក្សាដោយអាងថា អញជាមេស្រុក ហើយវាយរហូតទ្រមចាប់កប្រានចេញអំពីផ្ទះ ហើយចាប់សក់ស្រីអាក្រក់នោះឲ្យចុះមកអំពីជង្រុកវាយសម្លុតថា បើហែងធ្វើបែបនេះទៀតនឹងដឹងគ្នា ។ តាំងពីកាលនោះមក

មេស្រុកក៏មិនហ៊ានសម្លឹងមើលផ្ទះនោះ សូម្បីស្រីនោះក៏មិនអាចប្រព្រឹត្តក្រៅចិត្តទៀត ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា មេស្រុកក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ គហបតីដែលដាក់ទោសមេស្រុកក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គហបតិជាតក ចប់

## សាធុសីលជាតក

[ ២៤៩ ] ( ព្រាហ្មណ៍សួរថា ) ភាពនៃបុគ្គលមានសរីរៈល្អ ភាពនៃបុគ្គលចាស់ ភាពនៃបុគ្គលមានជាតិល្អ ភាពនៃបុគ្គលមានសីលល្អ យើងសូមសួរអ្នកជាព្រាហ្មណ៍ថា បណ្ដាបុគ្គលទាំង ៤ នាក់នោះតើយើងប្រាថ្នានូវបុគ្គលណា ។

[ ២៥០ ] ( អាចារ្យពោធិសត្វពោលថា ) សេចក្ដីចម្រើនរមែងមានក្នុងបុគ្គលមានសរីរៈល្អ យើងសូមធ្វើមនស្ការចំពោះបុគ្គលចាស់ សេចក្ដីចម្រើនរមែងមានក្នុងបុគ្គលដែលមានជាតិល្អតែសីលរមែងពេញចិត្តដល់យើងទាំងឡាយ ។

**ចប់ សាធុសីលជាតកទី ១០ ។**

**ចប់រុហកវគ្គទី ៥ ។**

### ឧទ្ទាននៃរុហកវគ្គនោះគឺ

និយាយអំពីរុហកព្រាហ្មណ៍ ១ ស្រីមានរូបល្អ ១ បុរសដែលគេប្រហារដោយអង្រែ ១ ទេវតាព្រាត់ប្រាស ១ ស្រះបោក្ខរណី ១ ជាគម្រប់ ៥ តពីនោះមកពួកឈ្មួញរួចពីអារក្សទឹក ១ ញញឹម ១ ការមកអស់កាលដ៏យូរ ១ ជង្រុក ១ សរីរៈ ១ ត្រូវជា ១០ ជាតក ។

# អដ្ឋកថា
# សាធុសីលជាតក

[ ២៤៩-២៥០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សរីរឲព្យំ វុឌ្ឍព្យំ** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍នោះមានកូនក្រមុំ ៤ នាក់ មានបុរស ៤ នាក់ត្រូវការកូនក្រមុំទាំងនោះ ។ ក្នុងបុរស ៤ នាក់នោះបុរសម្នាក់រូបស្អាតដល់ព្រមដោយសរីរៈ បុរសម្នាក់ទៀតអាយុច្រើនជាមនុស្សចាស់ បុរសម្នាក់ទៀតដល់ព្រមដោយជាតិ បុរសម្នាក់ទៀតដល់ព្រមដោយសីល ។ ព្រាហ្មណ៍គិតថា កាលរៀបចំកូនស្រីគួរឲ្យដល់នរណាហ្ន៎ គួរឲ្យដល់អ្នករូបស្អាត អ្នកមានអាយុច្រើន អ្នកសម្បូរដោយជាតិ ឬអ្នកមានសីលណាមួយល្អ ។ សូម្បីគាត់ព្យាយាមគិតក៏មិនដឹងទើបគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់នឹងជ្រាបហេតុនេះ អញនឹងទូលសួរព្រះអង្គ ហើយលើកកូនស្រីឲ្យដល់បុគ្គលដែលសមគួរក្នុងរវាងមនុស្សទាំងនោះ ទើបកាន់យកគ្រឿងក្រអូប ផ្កាកម្រងជាដើមទៅវិហារថ្វាយបង្គំព្រះសាស្តា អង្គុយនាចំណែកម្ខាង ក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន គួរឲ្យដល់នរណាក្នុងបុរសទាំង ៤ នាក់នេះ ។ ព្រះសាស្តាត្រាស់ថា ក្នុងកាលមុនបណ្ឌិតទាំងឡាយក៏សួរបញ្ហានេះដល់តថាគតតែព្រោះអន្តរនៃភពទើបមិនអាចចាំបាន កាលព្រាហ្មណ៍ទូលអារាធនា ទើបទ្រង់នាំយករឿងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ រៀនសិប្បៈក្នុងនគរតក្កសិលាហើយ បានជាអាចារ្យទិសាបាមោក្ខក្នុងនគរតក្កសិលា ។ កាលនោះព្រាហ្មណ៍ម្នាក់ មានកូនក្រមុំ ៤ នាក់ មានបុរស ៤ នាក់ត្រូវការកូនស្រីទាំងនោះ ។ ព្រាហ្មណ៍គិតថា គួរឲ្យដល់នរណា កាលមិនជាក់ច្បាស់ក្នុងចិត្តទើបគិតថា អញត្រូវសួរអាចារ្យ ហើយឲ្យដល់អ្នកដែលគួរឲ្យ ទើបចូលទៅរកអាចារ្យសួរ រឿងនោះហើយពោលគាថាទីមួយថា

*ភាពនៃបុគ្គលមានសរីរៈល្អ ភាពនៃបុគ្គលចាស់ ភាពនៃ បុគ្គលមានជាតិល្អ ភាពនៃបុគ្គលមានសីលល្អ យើងសូមសួរ អ្នកជាព្រាហ្មណ៍ថា បណ្ដាបុគ្គលទាំង ៤ នាក់នោះតើយើង ប្រាថ្នានូវបុគ្គលណា ដូច្នេះ ។*

ក្នុងបទទាំងនោះ ព្រាហ្មណ៍ប្រកាសគុណដែលមានក្នុងខ្លួនបុរសទាំង ៤ នាក់នោះ ។ ក្នុងគាថានេះមានអធិប្បាយដូច្នេះថា បុរស ៤ នាក់ត្រូវការកូន ស្រី ៤ នាក់របស់ខ្ញុំ ក្នុងបុរស ៤ នាក់នោះបុរសម្នាក់មានរូបស្អាតដល់ព្រម ដោយរាងកាយសណ្ឋារ បុរសម្នាក់អាយុច្រើន គឺជាមនុស្សចាស់ចម្រើនដោយ វ័យ បុរសម្នាក់មានជាតិខ្ពស់ គឺដល់ព្រមដោយជាតិព្រោះកើតមកល្អ បុរស ម្នាក់មានសីល គឺស្អាតស្អំដោយសីល ដល់ព្រមដោយសីល ។ បទថា **ព្រាហ្មណានំ បុច្ឆាម** សេចក្ដីថា ខ្ញុំមិនដឹងថានឹងឲ្យកូនទាំងនេះដល់បុរស ណាមួយក្នុងចំណោម ៤ នាក់នោះទើបមកសូមសួរលោក ។ បទថា **កិន្នុ**

**តេសំ វណិម្ហសេ** សេចក្តីថា បុរសទាំង ៤ នាក់នោះខ្ញុំនឹងជ្រើសរើស គឺត្រូវការអ្នកណាល្អ ។ ព្រាហ្មណ៍សួរអាចារ្យថា ខ្ញុំនឹងឲ្យកូនស្រីទាំងនោះដល់អ្នកណា ។

អាចារ្យស្តាប់ព្រាហ្មណ៍នោះហើយទើបឆ្លើយថា បុគ្គលមានសីលវិបត្តិហើយទោះបីមានរូបសម្បត្តិក៏គួរតិះដៀល ព្រោះហេតុនោះ រូបសម្បត្តិមិនជាប្រមាណឡើយ ខ្ញុំពេញចិត្តភាពជាអ្នកមានសីល កាលប្រកាសសេចក្តីនេះទើបពោលគាថាទីពីរថា

សេចក្តីចម្រើន រមែងមានក្នុងបុគ្គលមានសរីរៈល្អ យើងសូមធ្វើមនស្ការចំពោះបុគ្គលចាស់ សេចក្តីចម្រើន រមែងមានក្នុងបុគ្គលដែលមានជាតិល្អតែសីលរមែងពេញចិត្តដល់យើងទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថោ អត្ថិ សរីរស្មឹ** សេចក្តីថា សេចក្តីត្រូវការ គឺភាពវិសេសសេចក្តីចម្រើនក្នុងរាងកាយដែលសម្បូរដោយរូបមានដូចគ្នាមិនមែនខ្ញុំថាមិនមាន ។ បទថា **វុឌ្ឍព្យស្ស នមោករេ** សេចក្តីថា តែខ្ញុំធ្វើការឱនលំទោនដល់អ្នកចម្រើនដោយវ័យ ព្រោះអ្នកចម្រើនដោយវ័យរមែងបាននូវការសំពះគោរពរាប់អាន ។ បទថា **អត្ថោ អត្ថិ សុជាតស្មឹ** សេចក្តីថា ការចម្រើនរមែងមានដល់បុគ្គលដែលមានជាតិល្អ ព្រោះជាតិសម្បត្តិក៏គួរប្រាថ្នាដូចគ្នាដែរ ។ បទថា **សីលំ អស្មាក រុច្ចតិ** បានដល់តែខ្ញុំគាប់ចិត្តក្នុងសីលប៉ុណ្ណោះ ព្រោះអ្នកមានសីលសម្បូរដោយមារយាទ សូម្បី

មិនមានសិរីសម្បត្តិក៏គួរបូជា គួរសរសើរ ។

ព្រាហ្មណ៍ស្តាប់ពាក្យរបស់អាចារ្យហើយ ក៏លើកកូនស្រីឲ្យដល់អ្នកមានសីលនោះឯង ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ព្រាហ្មណ៍តាំងនៅក្នុងសោតាបត្តិផល ។ ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាព្រាហ្មណ៍ក្នុងកាលឥឡូវនេះ ឯអាចារ្យទិសាបាមោក្ខក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា សាធុសីលជាតក ចប់

រុហកវគ្គ ចប់

# ឆត្តំទន្សវគ្គ

## ពន្ធនាគារជាតក

[ ២៥១ ] ( តាបសពោធិសត្វពោលថា ) ចំណងណាកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅជំណោកទន្សាយក្តី ចំណងនោះអ្នកប្រាជ្ញទាំងឡាយមិនហៅថា ចំណងមាំឡើយ ជនទាំងឡាយ មានសេចក្តីត្រេកអរដ៏ក្រៃលែងក្នុងកែវមណី និងកុណ្ឌលទាំងឡាយផង សេចក្តីអាឡោះអាល័យក្នុងកូន និងប្រពន្ធទាំងឡាយផង ។

[ ២៥២ ] អ្នកប្រាជ្ញទាំងឡាយពោលថា ចំណងនុ៎ះមាំ អាចទាញសត្វទម្លាក់ចុះក្នុងអបាយ ជាចំណងដ៏ធូរតែបុគ្គលស្រាយបានដោយក្រ ចំណែកខាងអ្នកប្រាជ្ញទាំងឡាយបានកាត់នូវចំណង គឺកិលេសនេះហើយមិនមានសេចក្តីអាឡោះអាល័យ បានលះបង់នូវសេចក្តីសុខក្នុងកាម ចៀសចេញទៅ ។

**ចប់ ពន្ធនាគារជាតកទី ១ ។**

# ឆតំឧឡ្ទវគ្គ

## អដ្ឋកថា ពន្ធនាគារជាតក

[ ២៥១-២៥២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពន្ធនាគារ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆ តំ ឧឡ្ទំ ពន្ធនមាហុ ធីរា** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ពួករាជបុរសចាប់បានពួកចោរ ដែលកាត់ទីតសម្លាប់មនុស្សតាមផ្លូវ សម្លាប់អ្នកស្រុកជាច្រើន នាំមកថ្វាយព្រះបាទកោសលព្រះរាជាត្រាស់ឲ្យចងពួកចោរទាំងនោះដោយចំណង គឺឃ្នាង ខ្សែនិងច្រវាក់ ភិក្ខុអ្នកជនបទប្រមាណ ៣០ រូប បំណងនឹងគាល់ព្រះសាស្តាទើបនាំគ្នាមកគាល់ ថ្វាយបង្គំ ព្រឹកឡើងចេញបិណ្ឌបាត ធ្វងកាត់គុកឃើញពួកចោរទាំងនោះ ត្រឡប់ពីបិណ្ឌបាត វេលាល្ងាចចូលគាល់ព្រះតថាគតទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំព្រះអង្គចេញបិណ្ឌបាត បានឃើញពួកចោរជាច្រើនត្រង់ពន្ធនាគារត្រូវជាប់ដោយឃ្នាងនិងខ្សែជាដើម សោយទុក្ខធំក្រៃ ពួកចោរទាំងនោះ មិនអាចកាត់ចំណងទាំងនោះគេចទៅបានឡើយ បពិត្រព្រះអង្គ-ដ៏ចម្រើន តើមានចំណងដទៃដែលមាំទាំជាងចំណងនោះទៀតដែរឬទេ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចំណងទាំងនោះ មិនឈ្មោះថាជាចំណងមាំទេ ចំណែកចំណងគឺ កិលេសបានដល់ការប្រាថ្នាក្នុងទ្រព្យ ក្នុងស្រូវអង្ករក្នុងបុត្តកិរិយាជាដើមនេះឯង ទើបជាចំណងដ៏មាំជាងចំណងទាំងនោះរាប់រយរាប់ពាន់ដង តែចំណងនេះ សូម្បីធំកាត់បានលំបាកយ៉ាងនេះ បណ្ឌិតកាលមុន

គង់កាត់បានហើយចូលកាន់ព្រៃហិមពាន្តបួស ហើយទើបទ្រង់នាំយកអតីតនិទាន មកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលគហបតីក្រីក្រមួយ កាលចម្រើនវ័យហើយបិតាក៏ធ្វើកាលកិរិយា ។ ព្រះពោធិសត្វបានធ្វើការស៊ីឈ្នួលចិញ្ចឹមមាតា ។ កាលនោះ ទើបមាតាបានទៅសូមធីតាក្នុងត្រកូលមួយ មកជាភរិយារបស់ព្រះពោធិសត្វទាំងដែលព្រះពោធិសត្វមិនត្រូវការហើយមាតានោះក៏អនិច្ចកម្មទៅ ។

ចំណែកភរិយារបស់ព្រះពោធិសត្វក៏តាំងគភ៌ ។ ព្រះពោធិសត្វមិនដឹងថានាងតាំងគភ៌ទើបប្រាប់ថា ម្នាលនាងដ៏ចម្រើន ចូរនាងស៊ីឈ្នួលគេចិញ្ចឹមជីវិតចុះខ្ញុំនឹងបួស ទើបនាងពោលថា បពិត្រអ្នកជាម្ចាស់ ខ្ញុំមានទម្ងន់ ចាំខ្ញុំប្រសូតហើយ អ្នកឃើញកូនហើយសឹមបួសចុះ ។ ព្រះពោធិសត្វ ក៏ទទួលថា សាធុ លុះនាងប្រសូតហើយទើបពោលថា នាងប្រសូតស្រេចបាច់ហើយខ្ញុំនឹងបួស ទើបនាងពោលថា សូមរង់ចាំឲ្យកូនដាច់ដោះសិនហើយក៏មានទម្ងន់ទៀត ព្រះពោធិសត្វត្រិះរិះថា អញមិនអាចឲ្យនាងយល់ព្រមបានឡើយ អញនឹងមិនប្រាប់ដល់នាងហើយគេចទៅ ។ ព្រះពោធិសត្វមិនបានប្រាប់នាង លុះដល់កណ្ដាលយប់ក៏ក្រោករត់ទៅ ។ កាលនោះអ្នកយាមទ្វារនគរបានចាប់ព្រះពោធិសត្វទុក ។ ទើបព្រះពោធិសត្វប្រាប់ថា នែអ្នក ខ្ញុំជាអ្នកចិញ្ចឹមមាតា សូមអ្នកលែងខ្ញុំចុះ កាលឲ្យគេលែងហើយក៏ទៅអាស្រ័យក្នុងទីមួយកន្លែង ចេញតាមទ្វារធំនោះឯងចូលព្រៃហិមពាន្តបួសជាឥសីញុំាង

អភិញ្ញានិងសមាបត្តិឲ្យកើត ត្រេកអរដោយឈាន ឥសីពោធិសត្វកាលនៅក្នុងទីនោះក៏បន្លឺឧទានថា អញបានកាត់ចំណង គឺបុត្តភរិយា ចំណង គឺកិលេសដែលកាត់បានដោយលំបាកនេះហើយបានពោលគាថាទាំងនេះថា

ចំណងណាកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅ
ជំណោកទន្សាយក្តី ចំណងនោះអ្នកប្រាជ្ញទាំងឡាយមិនហៅថា
ចំណងមាំឡើយ ជនទាំងឡាយមានសេចក្តីត្រេកអរដ៏ក្រៃលែង
ក្នុងកែវមណីនិងកុណ្ឌលទាំងឡាយផង សេចក្តីអាឡោះអា-
ល័យក្នុងកូននិងប្រពន្ធទាំងឡាយផង ។

អ្នកប្រាជ្ញទាំងឡាយពោលថា ចំណងនុ៎ះមាំ អាចទាញសត្វ
ទម្លាក់ចុះក្នុងអបាយ ជាចំណងដ៏ធូរ តែបុគ្គលស្រាយបាន
ដោយក្រ ចំណែកខាងអ្នកប្រាជ្ញទាំងឡាយបានកាត់នូវចំណង
គឺកិលេសនេះហើយ មិនមានសេចក្តីអាឡោះអាល័យបានលះ
បង់នូវសេចក្តីសុខក្នុងកាមចៀសចេញទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធីរា** សេចក្តីថា ឈ្មោះថា **ធីរា** ព្រោះមានបញ្ញា ព្រោះប្រាសចាកបាប ។ មួយវិញទៀតឈ្មោះថា **ធីរា** ព្រោះជាអ្នកប្រកបដោយបញ្ញានោះបានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវ័ករបស់ព្រះពុទ្ធនិងព្រះពោធិសត្វ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **យទាយសំ** ជាដើមថា អ្នកប្រាជ្ញទាំងឡាយរមែងមិនហៅចំណងដែលធ្វើដោយដែកបានដល់ ប្រវាក់ ចំណងដែលធ្វើដោយឈើបានដល់ ឃ្នាង ចំណងដែលធ្វើដោយខ្សែបានដល់

ខ្សែដែលវេញដោយស្មៅជំណោកទន្សាយ ឬវត្ថុដទៃមានក្រចៅជាដើមថាជាចំណងដ៏មាំទាំ ចំណងក្រាស់ឡើយ ។ បទថា **សារត្តរត្តា** បានដល់ ការត្រេកអរ គឺត្រេកអរដោយតម្រេកខ្លាំង ។ បទថា **មណិកុណ្ឌលេសុ** បានដល់ ក្នុងកែវមណីនិងកុណ្ឌលឬក្នុងកុណ្ឌលដែលប្រកបដោយកែវមណី ។ បទថា **ឯតំ ទឡ្ហំ** សេចក្តីថា អ្នកប្រាជ្ញទាំងឡាយពោលថា ចំណង គឺកិលេសនៃបុគ្គលដែលត្រេកអរក្នុងកែវមណីនិងកុណ្ឌលនិងចំណងរបស់បុគ្គលដែលអាឡោះអាល័យក្នុងបុត្តនិងភរិយាថា ជាគ្រឿងចងដ៏មាំទាំពិតប្រាកដ ។ បទថា **ឱហារិនំ** សេចក្តីថា ឈ្មោះថា **ឱហារិនំ** ព្រោះនាំចុះទៅកាន់ទីទាបទម្លាក់ក្នុងអបាយ ៤ ។ បទថា **សិថិលំ** សេចក្តីថា ឈ្មោះថា **សិថិលំ** ព្រោះមិនមុតស្បែកនិងសាច់ មិនធ្វើឲ្យមានឈាម មិនឲ្យដឹងថាជាចំណងទៀតផង រមែងឲ្យធ្វើនូវការងារទាំងផ្លូវគោកនិងផ្លូវទឹកជាដើម ។ បទថា **ទុប្បមុញ្ចំ** សេចក្តីថា ឈ្មោះថា **ទុប្បមុញ្ចំ** ព្រោះចំណង គឺកិលេសកើតឡើងម្តងដោយអំណាចតណ្ហានិងលោភៈ រមែងស្រាយឲ្យរបូតបានដោយក្រ ដូចអណ្តើកផុតចាកចំណងបានដោយក្រ ។ បទថា **ឯតម្បិ ឆេត្វាន** សេចក្តីថា អ្នកប្រាជ្ញទាំងឡាយកាត់ចំណង គឺកិលេសនោះសូម្បីមាំទាំយ៉ាងនេះដោយព្រះខ័ន គឺញាណ កាត់ទន្លីងដែកដូចដំរីចុះប្រេង ដូចរាជសីហ៍ជំទង់ទម្លាយទ្រុងដែក រង្កៀសវត្ថុកាមនិងកិលេសកាមដូចទីចាក់សំរាម មិនមានអាឡោះអាល័យលះកាមសុខចៀសចេញទៅហើយចូលព្រៃហិមពាន្តបួសជាឥសី ញ៉ាំងកាលឲ្យកន្លងទៅដោយសុខដែលកើតអំពីឈាន ។

ព្រះពោធិសត្វកាលបន្ទឹឧទានយ៉ាងនេះហើយមានឈានមិនវិនាស មាន ព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ភិក្ខុពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ពួកខ្លះបានជាព្រះអរហន្ត ហើយទ្រង់ប្រជុំជាតកថា មាតាក្នុងកាលនោះ បានមកជាព្រះនាងមហាមាយាទេវីក្នុងកាលឥឡូវនេះ បិតាក្នុងកាលនោះ បានមកជាព្រះបាទសុទ្ធោទនមហារាជ ភរិយាក្នុងកាលនោះ បានមកជារាហុលមាតា បុត្តក្នុងកាលនោះបានមកជារាហុល ឯបុរសដែលលះបុត្តនិងភរិយាចេញបួសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ពន្ធនាគារជាតក ចប់

# កោឡិសីលជាតក

[ ២៥៣ ] ( ព្រះសាស្តាត្រាស់ថា ) ហង្សទាំងឡាយក្តី ក្រៀលទាំងឡាយក្តី ក្ងោកទាំងឡាយក្តី ដំរីទាំងឡាយក្តី ពួកម្រឹគពិសេសក្តី សត្វទាំងអស់រមែងខ្លាចសត្វសីហៈ ( ព្រោះ ) ការប្រៀបផ្ទឹមក្នុងកាយមិនមានឡើយ។

[ ២៥៤ ] បណ្តាមនុស្សទាំងឡាយ ( មនុស្សណា ) បើទុកជាខ្ជួននៅក្មេងតែមានប្រាជ្ញាវាងវៃ មនុស្សនោះទើបឈ្មោះថា ធំក្នុងពួកមនុស្សនោះ មនុស្សល្ងង់ខ្លៅសូម្បីមានសរីរៈ ( ធាត់ធំ ) ក៏មិនឈ្មោះថាធំឡើយ ។

**ចប់ កោឡិសីលជាតកទី ២ ។**

# អដ្ឋកថា
# កោឡិសីលជាតក

[ ២៥៣-២៥៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលកុណ្ឌកភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ហំសា កោញ្ចា មយូរា ច** ដូច្នេះជាដើម ។

បានឮថា ព្រះលកុណ្ឌកភទ្ទិយត្ថេរជាអ្នកប្រាកដឈ្មោះបោះសំឡេងក្នុងព្រះពុទ្ធសាសនាមានសំឡេងពីរោះ ជាអ្នកសម្តែងធម៌ពីរោះ ជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទាក្នុងចំណោមព្រះមហាថេរ ៨០ អង្គតែលោកមានរាងកាយតូចទាប ដូចគ្នានឹងសាមណេរដែលត្រូវគេលេង ។ ថ្ងៃមួយលោកថ្វាយបង្គំព្រះតថាគតហើយទៅកាន់ខ្លោងទ្វារវត្តជេតពន ភិក្ខុអ្នកជនបទ

ប្រមាណ ៣០ រូបទៅកាន់វត្តជេតពនដោយគិតថានឹងថ្វាយបង្គំព្រះតថាគត ឃើញព្រះថេរៈត្រង់ខ្លោងទ្វារវិហារដោយការរពឹសដៃ ទើបនាំគ្នាចាប់ព្រះថេរៈត្រង់ជាយចីវរ ត្រង់ដៃ ត្រង់ក្បាល ត្រង់ច្រមុះ ត្រង់ត្រចៀក អង្រួនដោយសម្គាល់ថា សាមណេរ កាលទុកបាត្រចីវរហើយក៏នាំគ្នាចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយ កាលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈដោយព្រះតម្រាស់ដ៏ពីរោះទើបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះថេរៈមួយអង្គឈ្មោះលកុណ្ដកភទ្ទិយត្តេរជាសាវ័ករបស់ព្រះអង្គសម្ដែងធម៌ពីរោះ ឥឡូវនេះព្រះថេរៈរូបនោះគង់នៅឯណា ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រាថ្នានឹងឃើញភិក្ខុរូបនោះឬ ក៏ក្រាបទូលថា ខ្ញុំព្រះអង្គទាំងឡាយប្រាថ្នានឹងឃើញ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលពួកអ្នកឃើញត្រង់ខ្លោងទ្វារហើយពួកអ្នកគ្នាំគ្នងដៃចាប់ត្រង់ជាយចីវរជាដើម ភិក្ខុរូបនោះឯងគឺ លកុណ្ដកភទ្ទិយៈ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សាវ័កដែលដល់ព្រមដោយអភិនីហារ បានតាំងសេចក្តីប្រាថ្នាទុកបែបនេះ ព្រោះហេតុអ្វីទើបមានសក្តិតូចយ៉ាងនេះ ។ ព្រះសាស្តាត្រាស់ថា ព្រោះអាស្រ័យកម្មដែលខ្លួនធ្វើទុក កាលភិក្ខុទាំងនោះទូលអារាធនាទើបទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិជាសក្កទេវរាជ ។ ក្នុងកាលនោះបុគ្គលណាក៏មិនអាចឲ្យព្រះបាទព្រហ្មទត្តបានឃើញដំរី សេះឬគោដែលចាស់ជរា ទ្រង់ចូលចិត្ត

លេងសប្បាយ កាលទ្រង់ទតឃើញសត្វបែបនោះត្រាស់ឲ្យពួករាជបុរសកៀងសត្វទាំងនោះឲ្យជល់គ្នា ឃើញរទេះចាស់ៗក៏បញ្ជាឲ្យប្រណាំងគ្នារហូតទាល់តែបាក់ ឃើញស្ត្រីចាស់ត្រាស់ឲ្យហៅមកដាក់ត្រង់ពោះឲ្យដួលហើយចាប់ឲ្យក្រោកឡើងឲ្យរាំច្រៀង ឃើញបុរសចាស់ៗបានឲ្យហក់លោតដាំដូងជាដើមលើផែនដីដូចអ្នកកីឡា ទោះបីទ្រង់មិនបានឃើញគ្រាន់តែឮដំណឹងថា មនុស្សចាស់មានត្រង់ស្រុកនោះក៏ត្រាស់ឲ្យហៅមកហើយបញ្ជាឲ្យលេង ពួកមនុស្សក៏ខ្មាស បញ្ជូនមាតាបិតារបស់ខ្លួនទៅកាន់នគរដទៃ មិនបានទំនុកបម្រុងមាតាបិតា ។ ពួកសេវកៈក៏ពេញចិត្តក្នុងការលេង ។ ជនដែលស្លាប់ទៅក៏នាំគ្នាកើតពេញអបាយភូមិ ៤ ទេវបរិស័ទទាំងឡាយក៏ថយចុះ ។ សក្កទេវរាជទ្រង់មិនឃើញទេវបុត្តថ្មីៗមកកើត ទើបទ្រង់ពិចារណាថា ហេតុអ្វីហ្ន៎ កាលទ្រង់ជ្រាបហេតុនោះហើយទើបត្រិះរិះថា អញនឹងទូន្មានស្តេចព្រហ្មទត្ត ទើបកាឡាខ្លួនជាមនុស្សចាស់ដាក់ពាងតក្កៈ ២ ក្នុងរទេះចាស់ទឹមគោចាស់ ២ ក្នុងថ្ងៃមហោស្រពមួយ កាលព្រះបាទព្រហ្មទត្តគង់លើដំរីដែលជាព្រះទីន័ងតាក់តែងដោយគ្រឿងអលង្ការប្រទក្សិណនគរដែលតាក់តែងហើយ សក្កទេវរាជស្លៀកសំពត់ចាស់បរយានទៅក្នុងទីចំពោះមុខព្រះរាជា ។ ព្រះរាជាទតឃើញរទេះចាស់ទឹមដោយគោចាស់ទើបត្រាស់ថា ចូរនាំយាននោះមក ពួករាជបុរសនាំគ្នាទូលថា បពិត្រព្រះសម្មតិទេព យាននោះនៅឯណា ពួកទូលព្រះបង្គំមើលមិនឃើញ សក្កទេវរាជទ្រង់សម្តែងឲ្យព្រះរាជាប៉ុណ្ណោះឃើញដោយអានុភាពរបស់សក្កៈ ។

លំដាប់នោះកាលរទេះទៅដល់កណ្តាលមហាជនហើយ ទើបសក្កៈទ្រង់បររទេះនោះទៅខាងលើបំបែកពាងតក្កៈមួយ ស្រោចលើសីសៈរបស់ព្រះរាជាហើយត្រឡប់មកវាយបំបែកពាងទី ២ ។ កាលនោះតក្កៈហូរចុះប្រឡាក់ព្រះរាជាតាំងពីសីសៈចុះមក ព្រះរាជាទ្រង់ខ្មាសអៀនជាខ្លាំងទ្រង់រកកល់ចង្កួត ។ កាលសក្កៈជ្រាបថា ព្រះរាជាទោមនស្ស ទ្រង់បររទេះចេញទៅហើយនិម្មិតព្រះកាយជាសក្កៈកាន់វជិរាវុធដោយដៃឈរលើអាកាសគំរាមថា នែអធម្មិក-រាជ ទ្រង់មិនចាស់ទេឬ ជរាមិនកើតមានដល់សរីរៈរបស់ទ្រង់ទេឬ ទ្រង់ចូលចិត្តបៀតបៀនដល់មនុស្សចាស់ជាច្រើន ព្រោះអាស្រ័យទ្រង់តែម្នាក់ អ្នកដែលស្លាប់ទៅព្រោះធ្វើកម្មនេះទើបពេញក្នុងអបាយ ពួកមនុស្សមិនបានបម្រើមាតាបិតា បើទ្រង់មិនវៀរកម្មនេះទេ យើងនឹងបំបែកក្បាលរបស់ទ្រង់ដោយដំបងពេជ្រនេះ តាំងអំពីនេះទៅកុំធ្វើកម្មនេះទៀតឡើយ ហើយត្រាស់ដល់គុណរបស់មាតាបិតា ចង្អុលអានិសង្សនៃការគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ កាលទូន្មានហើយក៏យាងទៅកាន់វិមានរបស់ព្រះអង្គ ។ តាំងអំពីនោះមកព្រះរាជា ក៏មិនបានសូម្បីត្រឹមតែគិតដើម្បីធ្វើកម្មនោះទៀត ។ ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយបានត្រាស់គាថាទាំងនេះថា

ហង្សទាំងឡាយក្តី ក្រៀលទាំងឡាយក្តី ក្ងោកទាំងឡាយក្តី ដំរីទាំងឡាយក្តី ពួកម្រឹគពិសេសក្តី សត្វទាំងអស់រមែងខ្លាចសត្វសីហៈ ( ព្រោះ ) ការប្រៀបផ្ទឹមក្នុងកាយមិនមានឡើយ ។

បណ្តាមនុស្សទាំងឡាយ ( មនុស្សណា ) បើទុកជាខ្លួន
នៅក្មេងតែមានប្រាជ្ញាវាងវៃ មនុស្សនោះទើបឈ្មោះថា ធំក្នុង
ពួកមនុស្សនោះ មនុស្សល្ងង់ខ្លៅសូម្បីមានសរីរៈ ( ជាត់ធំ )
ក៏មិនឈ្មោះថា ធំឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បសទា មិគា** បានដល់ សត្វរមាំង ( ម្រឹគពិសេស ) អធិប្បាយថា រមាំងក្តី ម្រឹគដ៏សេសក្តី ។ បាលីថា **បសទមិគា** ក៏មាន បានដល់ រមាំងនោះឯង ។ បទថា **នត្ថិ កាយស្មិ តុល្យតា** សេចក្តីថា ទំហំរាងកាយមិនសំខាន់ បើសំខាន់សោតពួកដំរីនិងរមាំងដែលមានរាងកាយធំក៏គប្បីសម្លាប់រាជសីហ៍បាន រាជសីហ៍ក៏គប្បីសម្លាប់បានតែសត្វតូចៗប៉ុណ្ណោះដូចជាហង្សទ្រនិងក្ងោកជាដើម ។ កាលបើដូច្នោះ សត្វតូចៗប៉ុណ្ណោះគប្បីខ្លាចរាជសីហ៍តែសត្វធំៗមិនខ្លាច ។ តែព្រោះសេចក្តីនេះប្រព្រឹត្តទៅមិនបានដូច្នោះទើបសត្វទាំងអស់ខ្លាចរាជសីហ៍ ។ បទថា **សរីរវា** បានដល់ មនុស្សល្ងង់សូម្បីរាងកាយធំក៏មិនឈ្មោះថា ធំ ព្រោះដូច្នោះលកុណ្តកភទ្ទិយត្ថេរសូម្បីមានរាងកាយតូចក៏កុំយល់ថា តូចដោយញាណឡើយ ។

ព្រះសាស្តា ទ្រង់នាំមកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ បណ្តាភិក្ខុទាំងនោះ ពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ពួកខ្លះបានជាព្រះអរហន្តហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាលកុណ្តកភទ្ទិយត្ថេរ ដែលជាទីឡកឡឺយរបស់ជនដទៃព្រោះបាបកម្មដែលខ្លួន

ពេញចិត្តយកអ្នកដទៃមកលេងសើចក្នុងកាលឥឡូវនេះ ឯសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កេឡិសីលជាតក ចប់

# ខន្ធបរិត្តជាតក

[ ២៥៥ ] ( តាបសពោធិសត្វពោលថា ) ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ វិរូបក្ខៈទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ ឯរាបថៈទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ ឆព្យាបុត្តទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ កណ្ហាគោតមកៈទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វឥតជើងទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វជើង ២ ទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វជើង ៤ ទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វជើងច្រើនទាំងឡាយផង សត្វឥតជើងកុំបៀតបៀនអាត្មាអញឡើយ សត្វជើង ២ កុំបៀតបៀនអាត្មាអញឡើយ សត្វជើង ៤ កុំបៀតបៀនអាត្មាអញឡើយ សត្វជើងច្រើនកុំបៀតបៀនអាត្មាអញឡើយ សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផងទាំងអស់គ្នា សូមសព្វសត្វ ( ទាំងនោះ ) ឃើញនូវសេចក្តីចម្រើនទាំងឡាយ សេចក្តីលាមកអាក្រក់តិចតួចកុំមកដល់ឡើយ គឺថាកុំកើតមានដល់សត្វទាំងនោះឡើយ ។

[ ២៥៦ ] ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូនឬសត្វវារទាំងឡាយគឺ ពស់ ខ្យូង ក្អែប ពីងពាង តុកកែនិងកណ្តុរសុទ្ធតែមានប្រមាណ

( មិនច្រើនដូចគុណព្រះរតនៈត្រៃ ) កិរិយារក្សា អាត្មាអញបានធ្វើហើយ កិរិយាការពារអាត្មាអញបានធ្វើហើយ ពួកសត្វ ( កាច ) ទាំងឡាយ ចូរចៀសចេញទៅ អាត្មាអញ ( ធ្វើ ) នូវនមស្ការចំពោះព្រះមានព្រះភាគ នមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ ។

**ចប់ ខន្ធបរិត្តជាតកទី ៣ ។**

# អដ្ឋកថា

# ខន្ធបរិត្តជាតក

[ ២៥៥-២៥៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វិរូបក្ខេហិ មេ មេត្តំ** ដូច្នេះជាដើម ។

បានឮថា កាលភិក្ខុនោះកំពុងពុះឧសក្នុងរោងភ្លើង ពស់មួយលូនចេញមកអំពីចន្លោះឈើពុកបានខាំភិក្ខុត្រង់ម្រាមជើង ។ ភិក្ខុនោះមរណភាពក្នុងទីនោះមួយរំពេច ។ រឿងដែលភិក្ខុនោះមរណភាពបានប្រាកដទៅពេញវត្ត ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា បានឮថា ភិក្ខុរូបនោះកំពុងពុះឧសត្រង់រោងភ្លើងត្រូវពស់ចឹករហូតអស់ជីវិតក្លាមនោះឯង ។ ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រ

ព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុរូបនោះបានចម្រើនមេត្តាផ្សាយដល់ត្រកូលស្តេចពស់ទាំង ៤ ហើយពស់ក៏មិនចឹកភិក្ខុនោះ ។ តាបសទាំងឡាយដែលជាបណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើង ក៏បានចម្រើនមេត្តាផ្សាយទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ផុតភ័យដែលកើតព្រោះអាស្រ័យត្រកូលស្តេចពស់ទាំងនោះហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងដែនកាសី កាលចម្រើនវ័យលះកាមសុខចេញបួសជាឥសីញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើត សាងអាស្រមបទត្រង់ច្នេរស្ទឹងមួយកន្លែងក្នុងហិមវន្តប្បទេស ត្រេកអរក្នុងឈាន ជាគ្រូប្រចាំគណៈ មានពួកឥសីចោមរោមរស់នៅយ៉ាងសុខស្ងប់ ។

កាលនោះត្រង់ច្រាំងស្ទឹងគង្គាមានពស់ច្រើនប្រភេទ ធ្វើអន្តរាយដល់ពួកឥសី ពួកឥសីដោយច្រើនទទួលអនិច្ចកម្ម ។ ទើបតាបសប្រាប់រឿងនោះដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វឲ្យតាបសទាំងអស់ប្រជុំគ្នា ហើយពោលថា បើអ្នកទាំងឡាយចម្រើនមេត្តាផ្សាយទៅកាន់ក្នុងត្រកូលស្តេចពស់ទាំង ៤ ពស់ទាំងឡាយនឹងមិនចឹកពួកអ្នកព្រោះហេតុនោះ តាំងពីនេះទៅអ្នកទាំងឡាយចូរចម្រើនមេត្តាផ្សាយទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ហើយទើបត្រាស់គាថាទីមួយថា

ភាវៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូល

ស្តេចនាគឈ្មោះ វិរូបក្ខៈទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ ឯរាបថៈទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ ឆព្យាបុត្តទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងត្រកូលស្តេចនាគឈ្មោះ កណ្ហាគោតមកៈទាំងឡាយផងដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិរូបក្ខេហិ មេ មេត្តំ** សេចក្តីថា ការៈជាមិត្តរបស់អាត្មាអញ ចូរមានជាមួយនឹងត្រកូលស្តេចពស់ឈ្មោះ **វិរូបក្ខ** ។ ក្នុងបទថា **ឯរាបថេ** ក៏មានន័យនេះឯង ។ ត្រកូលស្តេចពស់ទាំងនោះមាន ៣ ត្រកូលទៀតគឺ ស្តេចពស់ឈ្មោះឯរាបថៈ ១ ស្តេចពស់ឈ្មោះឆព្យាបុត្ត ១ ស្តេចពស់ឈ្មោះកណ្ហាគោតមកៈ ១ ក៏សុទ្ធតែជាត្រកូលស្តេចពស់នោះឯង ។

ព្រះពោធិសត្វកាលសម្តែងត្រកូលស្តេចពស់ទាំង ៤ យ៉ាងនេះហើយ ទើបពោលថា បើពួកលោកចម្រើនមេត្តាក្នុងត្រកូលស្តេចពស់ទាំង ៤ នោះ ពស់ទាំងឡាយក៏មិនបៀតបៀនពួកលោកហើយពោលគាថាទីពីរថា

ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វឥតជើងទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វជើង ២ ទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វជើង ៤ ទាំងឡាយ

ផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមានជាមួយ ) នឹងសត្វ
ជើងច្រើនទាំងឡាយផង ដូច្នេះ ។

បណ្ដាបទទាំងនោះ មេត្តាភាវនាលោកបានសម្ដែងហើយ ក្នុងសត្វមិនមានជើងទាំងអស់ដូចជាពស់ និងត្រីជាដើម ព្រោះលោកបំភ្លឺហើយដោយចំពោះក្នុងបទទាំងឡាយនោះដោយបទទីមួយ ។ លោកបានសម្ដែងមេត្តាភាវនាក្នុងមនុស្សទាំងឡាយផង ក្នុងបក្សីជាតិទាំងឡាយផងដោយបទទីពីរ ។ លោកបានសម្ដែងមេត្តាភាវនាក្នុងសត្វជើង ៤ ទាំងឡាយមានដំរីនិងសេះជាដើមដោយបទទី ៣ លោកបានសម្ដែងមេត្តាភាវនាក្នុងសត្វដែលមានជើងច្រើនទាំងឡាយមាន ខ្ទួយ ក្អែប ដង្កូវមាស់និងពីងពាងជាដើមដោយបទទី ៤ ។

ព្រះពោធិសត្វ កាលសម្ដែងមេត្តាភាវនាដោយសរុបយ៉ាងនេះហើយ ឥឡូវនេះកាលនឹងសម្ដែងដោយការសូមអង្វរទើបពោលគាថានេះថា

សត្វឥតជើងកុំបៀតបៀនអាត្មាអញឡើយ សត្វជើង ២ កុំ
បៀតបៀនអាត្មាអញឡើយ សត្វជើង ៤ កុំបៀតបៀនអាត្មា
អញឡើយ សត្វជើងច្រើន កុំបៀតបៀនអាត្មាអញឡើយ
ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មា មំ** ព្រះពោធិសត្វពោលថា អ្នកទាំងឡាយកាលសូមយ៉ាងនេះថា បណ្ដាសត្វទាំងឡាយ មានសត្វឥតជើងជាដើមនោះសត្វឯណានីមួយ ចូរកុំបៀតបៀន ចូរកុំប្រទូស្តខ្ញុំឡើយ គប្បីចម្រើនមេត្តាដូច្នេះ ។

ព្រះពោធិសត្វ កាលនឹងសម្តែងនូវការចម្រើនមេត្តាដោយមិនចំពោះទើប ពោលគាថានេះថា

សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូត ទាំងឡាយផង ទាំងអស់គ្នា សូមសព្វសត្វ ( ទាំងនោះ ) ឃើញនូវសេចក្តីចម្រើនទាំងឡាយ សេចក្តីលាមកអាក្រក់តិច តួចកុំមកដល់ឡើយ គឺថាកុំកើតមានដល់សត្វទាំងនោះឡើយ ដូច្នេះ ។

សេចក្តីពិសេសក្នុងបទទាំងឡាយនោះគប្បីជ្រាបយ៉ាងនេះថា ឈ្មោះថា **សត្តា** ព្រោះជាអ្នកជាប់ចំពាក់ ជាប់ស្អិត ពាក់ព័ន្ធក្នុងខន្ធ ៥ ក្នុងវដ្តដោយអំណាចតណ្ហានិងទិដ្ឋិ ។ ឈ្មោះថា **ចាណា** ដោយអំណាចនៃការរស់នៅពោលគឺ ការប្រព្រឹត្តទៅនៃខ្យល់ដង្ហើមចូលចេញ ។ ឈ្មោះថា **ភូតា** ដោយអំណាចនៃការកើតប្រាកដកើតឡើង ។ តែដោយការមិនពិសេស បទទាំងអស់នេះជាការសង្គ្រោះហើយដោយសព្វសត្វតែម្យ៉ាងប៉ុណ្ណោះ ។

បទថា **កេវលា** បានដល់ ទាំងអស់ ។ បទថា **កេវលា** នេះជាពាក្យបរិយាយនៃសត្វទាំងពួងនោះឯង ។ បទថា **ភទ្រានិ បស្សន្តុ** សេចក្តីថា សត្វទាំងឡាយទាំងពួងនោះ សូមជួបនូវសេចក្តីចម្រើន សេចក្តីល្អ សេចក្តីស្អាតប៉ុណ្ណោះ ។

បទថា **មា កិញ្ចិ ចាបមាគមា** សេចក្តីថា បាបគ្រោះដ៏លាមកកុំបីមក កុំបីពាល់ត្រូវដល់សត្វឯណានីមួយបណ្តាសត្វទាំងនោះឡើយ សត្វទាំង

ពួងកុំបីមានពៀរ កុំបីបៀតបៀន ចូរជាអ្នកមានសេចក្តីសុខ ប្រាសចាកទុក្ខចុះ ។

ព្រះពោធិសត្វពោលថា ពួកអ្នកចូរចម្រើនមេត្តាមិនចំពោះ ក្នុងសព្វសត្វយ៉ាងនេះ ដើម្បីឲ្យរឭកដល់គុណរបស់ព្រះរតនត្រ័យទៀតទើបពោលថា

ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូនឬសត្វវារទាំងឡាយគឺ ពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ និងកណ្តុរ សុទ្ធតែមានប្រមាណ ( មិនច្រើនដូចគុណព្រះរតនៈត្រៃ ) ដូច្នេះ ។

ក្នុងបទទាំងនោះ ពុទ្ធរតនៈប្រមាណមិនបានព្រោះការមិនមាននៃកិលេសជាទីធ្វើប្រមាណនិងព្រោះមិនមានប្រមាណនៃព្រះគុណទាំងឡាយ ។ បទថា **ធម្មោ** សេចក្តីថា លោកុត្តរធម៌ ៩ ឈ្មោះថា ប្រមាណមិនបានព្រោះបុគ្គលណាមួយ មិនអាចធ្វើប្រមាណក្នុងលោកុត្តរធម៌នោះបាន ឯព្រះសង្ឃក៏ប្រមាណមិនបានព្រោះព្រះសង្ឃប្រកបដោយធម៌ដែលប្រមាណមិនបាននោះ ។

ព្រះពោធិសត្វពោលថា អ្នកទាំងឡាយ ចូររឭកដល់គុណរបស់ព្រះរតនត្រ័យនេះ កាលសម្តែងភាពដែលព្រះរតនត្រ័យ មានព្រះគុណប្រមាណមិនបានដើម្បីសម្តែងពួកសត្វដែលមានប្រមាណទើបពោលថា សត្វលូនឬសត្វវារទាំងឡាយគឺ ពស់ ខ្ទួយ ក្អែប ពីងពាង តុកកែនិងកណ្តុរសុទ្ធតែមានប្រមាណ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សិរីសបានិ** ជាឈ្មោះរបស់សត្វទីឃជាតិទាំងពួងដ្បិតថា សត្វទាំងនោះកាលប្រាថ្នានឹងទៅក៏លូនទៅដោយក្បាល ព្រោះហេតុនោះទើបពោលថា **សិរីសបា** ។ បទថា **អហិ** ជាដើម ជាពាក្យសម្តែងសត្វទាំងនោះដោយសរុប ។ ក្នុងបទទាំងនោះ បទថា **ឧណ្ណានាភី** ប្រែថា ពីងពាងពិតហើយ សរសៃដូចគ្នានឹងរោមទន់មានពណ៌សចេញអំពីផ្ចិតរបស់ពីងពាងនោះ ទើបលោកហៅថា **ឧណ្ណានាភី** ។ បទថា **សរពូ** ( តុកកែ ) បានដល់ សត្វលូនវារអាស្រ័យផ្ទះ ។

ព្រះពោធិសត្វសម្តែងថា ព្រោះធម៌ទាំងឡាយដែលធ្វើប្រមាណមានរាគៈខាងក្នុងរបស់សត្វទាំងនោះនៅមាន ដូច្នេះទើបសត្វលូនវារទាំងនោះឈ្មោះថាមានប្រមាណដូច្នេះហើយពោលថា អ្នកទាំងឡាយចូររឭកដល់គុណព្រះរតនត្រ័យយ៉ាងនេះថា ដោយអានុភាពរបស់ព្រះរតនត្រ័យដែលមិនមានប្រមាណសូមសត្វទាំងឡាយ ដែលមានប្រមាណប៉ុណ្ណោះ ចូរធ្វើនូវការរក្សាពួកយើងទាំងឡាយទាំងយប់ទាំងថ្ងៃចុះ ដើម្បីសម្តែងកម្មដែលគួរធ្វើឲ្យក្រៃលែងឡើងជាងនោះទើបពោលគាថានេះថា

> កិរិយារក្សា អាត្មាអញបានធ្វើហើយ កិរិយាការពារ អាត្មាអញ
> បានធ្វើហើយ ពួកសត្វ ( កាច ) ទាំងឡាយចូរចៀសចេញ
> ទៅ អាត្មាអញ ( ធ្វើ ) នូវនមស្ការចំពោះព្រះមានព្រះភាគ
> នមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កតា មេ រក្ខា** សេចក្តីថា ខ្ញុំរឭកដល់

ព្រះគុណរបស់ព្រះរតនត្រ័យធ្វើការរក្សា គឺគ្រប់គ្រងខ្ញុំហើយ ។ បទថា **កតា មេ បរិត្តា** សេចក្ដីថា ខ្ញុំធ្វើការការពារខ្លួនហើយ ។ បទថា **បដិក្កមន្តុ ភូតានិ** សេចក្ដីថា សត្វទាំងឡាយដែលមានអធ្យាស្រ័យមិនអនុគ្រោះក្នុងខ្ញុំ ចូរគេចចេញទៅ គឺចូរចៀសចេញទៅ ។ បទថា **សោហំ នមោ ភគវតោ** សេចក្ដីថា ខ្ញុំនោះធ្វើនូវបរិត្តហើយយ៉ាងនេះ ទើបនមស្ការដល់ព្រះមានព្រះភាគដែលទ្រង់ត្រាស់ដឹងហើយក្នុងអតីត បរិនិព្វានហើយទាំងពួង ។ បទថា **នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ** សេចក្ដីថា ខ្ញុំសូមធ្វើនមស្ការព្រះសម្ពុទ្ធក្នុងអតីតទាំង ៧ អង្គ ដែលបរិនិព្វានហើយដោយលំដាប់ អធិប្បាយថា អ្នកទាំងឡាយ កាលនមស្ការយ៉ាងនេះហើយ ចូររឭកដល់ព្រះសម្មាសម្ពុទ្ធទាំងពួងចុះ ។

ព្រះពោធិសត្វចងព្រះបរិត្តនេះឲ្យដល់គណៈឥសី ។ ឯបរិត្តនេះគប្បីជ្រាបថា លោកពោលទុកក្នុងជាតកនេះដោយគាថាទាំងឡាយខាងដើម ព្រោះសម្ដែងមេត្តាក្នុងត្រកូលស្ដេចពស់ទាំង ៤ ឬព្រោះសម្ដែងមេត្តាភាវនាទាំង ២ គឺ ដោយចំពោះនិងមិនចំពោះដូច្នេះ ។ គួរពិចារណារកហេតុដទៃតទៅ ។

តាំងអំពីនោះគណៈឥសី តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ចម្រើនមេត្តារឭកដល់ព្រះពុទ្ធគុណ កាលឥសីរឭកដល់ព្រះពុទ្ធគុណយ៉ាងនេះបណ្ដាពស់ទាំងឡាយក៏នាំគ្នាចៀសចេញទៅ ព្រះពោធិសត្វចម្រើនព្រហ្មវិហារមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំ

ជាតកថា គណៈឥសីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯគ្រូប្រចាំគណៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ខន្ធបរិត្តជាតក ចប់

# វិរកជាតក

[ ២៥៧ ] ( ប្រពន្ធរបស់ក្អែកគោកសួរថា ) នែក្អែកទឹកឈ្មោះវិរកៈ អ្នកឃើញសត្វស្វាបដែលពោលពាក្យពីរោះ មានផ្នួតកដូចជាផ្នួតកនៃក្ងោក ជាក្អែកគោកឈ្មោះសវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ ។

[ ២៥៨ ] ( ក្អែកទឹកពោធិសត្វពោលថា ) ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្វាបអ្នកត្រាច់ទៅក្នុងទឹកនិងលើគោក បានបរិភោគត្រីស្រស់ជានិច្ច នោះត្រូវសារាយព័ន្ធព័ទ្ធស្លាប់ទៅហើយ ។

**ចប់ វិរកជាតកទី ៤ ។**

## អដ្ឋកថា

## វិរកជាតក

[ ២៥៧-២៥៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការធ្វើត្រាប់ព្រះសុគត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អបិ វិរក បស្សេសិ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលព្រះថេរៈទាំងឡាយនាំបរិស័ទរបស់ទេវទត្តមកគាល់ព្រះសាស្តា ទ្រង់ត្រាស់សួរថា ម្នាលសារីបុត្ត ទេវទត្តឃើញពួកអ្នកហើយបានធ្វើដូចម្តេច ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តត្រាប់តាមបែបព្រះសុគត ទើបទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ទេវទត្តធ្វើត្រាប់តាមតថាគតដល់នូវសេចក្តីវិនាស មិនតែក្នុងឥឡូវនេះទេ សូម្បីក្នុង

កាលមុនក៏ដល់នូវសេចក្តីវិនាសមកហើយ ព្រះថេរៈទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតក្អែកទឹក ក្នុងហិមវន្តប្បទេស អាស្រ័យស្រះមួយរស់នៅមានឈ្មោះថា វីរកៈ ។ គ្រានោះក្នុងដែនកាសី ស្រូវអង្ករកបានដោយលំបាកឡើងថ្លៃ ពួកមនុស្សមិនអាចឲ្យអាហារក្អែកឬធ្វើពលីកម្មដល់យក្ខនិងនាគបាន ។ ទើបក្អែកទាំងឡាយចេញអំពីទីអត់ឃ្លានចូលព្រៃដោយច្រើន ។ ក្នុងក្អែកទាំងនោះមានក្អែកមួយឈ្មោះសវិដ្ឋកៈ នៅក្នុងក្រុងពារាណសីនាំក្អែកញីទៅកាន់លំនៅរបស់ក្អែកឈ្មោះវីរកៈ អាស្រ័យស្រះនោះរស់នៅត្រង់ចំណែកមួយ ។ ថ្ងៃមួយក្អែកឈ្មោះសវិដ្ឋកៈរកចំណីក្នុងស្រះនោះឃើញក្អែកវីរកៈចាបត្រីក្នុងទឹករួចឡើងមកសំងិលខ្លួនឲ្យស្ងួត ទើបគិតថា អញអាស្រ័យក្អែកនេះហើយអាចរកត្រីបានច្រើន អញនឹងប្រណិប័តន៍ក្អែកនេះហើយចូលទៅរកក្អែកវីរកៈនោះ កាលក្អែកវីរកៈសួរថា មានការអ្វីសម្លាញ់ ។ ក្អែកសវិដ្ឋកៈឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំចង់បម្រើលោក ក្អែកវីរកៈទទួលថា សាធុ តាំងអំពីនោះមកក្អែកសវិដ្ឋកៈក៏ប្រណិប័តន៍ក្អែកវីរកៈ ។

ឯក្អែកវីរកៈស៊ីត្រីឆ្អែតសម្រាប់ខ្លួនហើយ ក៏ពាំត្រីមកឲ្យដល់ក្អែកសវិដ្ឋកៈ ចំណែកក្អែកសវិដ្ឋកៈស៊ីឆ្អែតសម្រាប់ខ្លួនហើយក៏ឲ្យត្រីដ៏សេសដល់ក្អែកញី ។ ក្នុងកាលតមក ក្អែកសវិដ្ឋកៈកើតមានៈថា ក្អែកទឹកនេះក៏ជាក្អែកខ្មៅ អញក៏ជាក្អែកខ្មៅ ភ្នែកចំពុះនិងជើងរបស់ក្អែកវីរកៈនោះនិងភ្នែកជាដើមរបស់អញក៏

មិនខុសគ្នា តាំងអំពីនេះទៅអញមិនត្រូវការត្រីដែលក្អែកនេះចាប់មកឲ្យអញ អញនឹងចាប់ឯង ។ ទើបក្អែកសវិដ្ឋកៈ ចូលទៅរកក្អែកវីរកៈនោះពោលថា នែសម្លាញ់ ចាប់ពីថ្ងៃនេះទៅខ្ញុំនឹងចុះកាន់ស្រះចាប់ត្រីស៊ីឯង កាលក្អែកវីរកៈ ឃាត់ថា នែសម្លាញ់ អ្នកមិនកើតក្នុងត្រកូលក្អែកដែលចុះទឹកចាប់ត្រីស៊ីទេ អ្នកកុំវិនាសឡើយ ។ ក្អែកសវិដ្ឋកៈនោះក៏មិនបានជឿ មិនស្តាប់ពាក្យទូន្មាន របស់ក្អែកវីរកៈ ចុះកាន់ស្រះមុជទឹកហើយក៏ផុសឡើង មិនអាចញែកសារាយ ចេញមកបានជាប់ខាងក្នុងសារាយផុសតែចុងចំពុះមកប៉ុណ្ណោះ ក្អែកសវិដ្ឋកៈ ដកដង្ហើមមិនបាន ក៏អស់ជីវិតក្នុងទឹកនោះឯង កាលនោះក្អែកញីប្រពន្ធរបស់ ក្អែកសវិដ្ឋកៈមិនឃើញប្តីត្រឡប់មក ទើបទៅរកក្អែកវីរកៈ ដើម្បីដឹងការប្រព្រឹត្ត ទៅកាលនឹងសួរថា បពិត្រលោកម្ចាស់ ក្អែកសវិដ្ឋកៈមិនប្រាកដតើក្អែកនោះ បាត់ទៅណា ទើបពោលគាថាទីមួយថា

> នែក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្វាបដែលពោលពាក្យ
> ពីរោះ មានផ្នួតកដូចជាផ្នួតកនៃក្ងោក ជាក្អែកគោកឈ្មោះ
> សវិដ្ឋកៈជាប្តីរបស់ខ្ញុំដែរឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ វីរក បស្សេសិ** សេចក្តីថា បពិត្រ វីរកៈ លោកម្ចាស់ឃើញដែរឬទេ ។ បទថា **មញ្ជុភាណកំ** សេចក្តីថា បក្សី ដែលបន្លឺសម្លេងពីរោះ ។ ពិតហើយក្អែកញីនោះសម្គាល់ថា ប្តីរបស់ខ្លួនមាន សម្លេងពីរោះព្រោះអំណាចរាគៈ ព្រោះហេតុនោះ ទើបពោលយ៉ាងនេះ ។ បទ ថា **មយូរគីវសង្កាសំ** សេចក្តីថា មានពណ៌ផ្នួតកដូចផ្នួតកក្ងោក ។

ក្អែកវីរកៈស្តាប់ដូច្នោះហើយទើបពោលថា ខ្ញុំដឹងទីដែលប្តីរបស់នាងទៅ ហើយពោលគាថាទីពីរថា

ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្លាបអ្នកត្រាច់ទៅក្នុងទឹកនិង
លើគោក បានបរិភោគត្រីស្រស់ជានិច្ចនោះត្រូវសារាយព័ន្ធព័ទ្ធ
ស្លាប់ទៅហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧភយចរស្ស** បានដល់ ជាអ្នកអាចត្រាច់ទៅបានទាំងក្នុងទឹកនិងលើគោក ។ បទថា **បក្ខិនោ** នេះព្រះពោធិសត្វពោលសំដៅដល់ខ្លួនឯង ។ បទថា **តស្សានុករំ** សេចក្តីថា កាលធ្វើតាមកិរិយារបស់ក្អែកទឹកនោះ ។ បទថា **សេវាលេហិ បលិគុណ្ឋិតោ មតោ** សេចក្តីថា ក្អែកសវិដ្ឋកៈមុជចុះទៅក្នុងទឹកហើយ កាលមិនអាចញែកសារាយចេញមកបាន ត្រូវសារាយព័ទ្ធព័ន្ធស្លាប់ក្នុងទឹកនោះឯង ចូរមើលចុះឃើញត្រឹមតែចំពុះប៉ុណ្ណោះ ។

ក្អែកញីបានស្តាប់ដូច្នោះ សោយសោកដល់នូវទោមនស្ស ត្រឡប់ទៅក្រុងពារាណសីវិញ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ក្អែកសវិដ្ឋកៈក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ក្អែកវីរកៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វីរកជាតក ចប់**

# គង្គេយ្យជាតក

[ ២៥៩ ] ( អណ្តើកពោលថា ) ត្រីទាំងឡាយនៅក្នុងទន្លេគង្គាក៏ល្អ ត្រីទាំងឡាយនៅក្នុងទន្លេយមុនាក៏ល្អ តែបុរសមានជើង ៤ នេះមានបរិមណ្ឌល ដូចដើមជ្រៃផង មានកវែងដូចចន្ទោលនៃរថផង ល្អរុងរឿង លើសអ្នកទាំងឡាយរាល់គ្នាទៅទៀត ។

[ ២៦០ ] ( ត្រីទាំងឡាយពោលថា ) យើងសួរហេតុណា មិនប្រាប់ហេតុនោះ យើងសួរហើយត្រឡប់ប្រាប់ហេតុដទៃវិញ សត្វសរសើរតែខ្លួនឯងនេះមិនគាប់ចិត្តយើងទេ ។

**ចប់ គង្គេយ្យជាតកទី ៥ ។**

## អដ្ឋកថា

## គង្គេយ្យជាតក

[ ២៥៩-២៦០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុជាសម្លាញ់ ២ រូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សោភន្តិ មច្ឆា គង្គេយ្យា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុទាំង ២ នោះ ជាកុលបុត្តអ្នកក្រុងសាវត្ថីបួសក្នុងសាសនា ហើយមិនបានបំពេញអសុភភាវនា ពេញចិត្តក្នុងការសរសើររូប ដើរអួតអាងតែរឿងរូប ។ ថ្ងៃមួយភិក្ខុទាំង ២ នោះកើតនូវការជជែកគ្នាក្នុងរឿងរូបថា លោកស្អាត ខ្ញុំក៏ស្អាត ឃើញព្រះថេរៈមួយរូបអង្គុយនៅមិនឆ្ងាយពោលថា

ព្រះថេរៈរូបនេះនឹងដឹងយើងថា ស្អាតឬមិនស្អាត ទើបចូលទៅរកសួរថា បពិត្រលោកម្ចាស់ ខ្ញុំទាំង ២ នេះអ្នកណាស្អាតជាងអ្នកណា ព្រះថេរៈឆ្លើយថា ខ្ញុំនេះឯងស្អាតជាងពួកលោក ។ ភិក្ខុកំលោះទាំង ២ រូបគិតថា ព្រះថេរៈចាស់នេះ មិនឆ្លើយពាក្យដែលអញសួរ បែរជាឆ្លើយពាក្យដែលអញមិនសួរ ទើបជេរហើយចៀសចេញទៅ ។ កិរិយារបស់ភិក្ខុ ២ រូបនោះបានប្រាកដក្នុងចំណោមសង្ឃ ។

ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា បានឮថា ព្រះថេរៈចាស់បានធ្វើឲ្យភិក្ខុកំលោះដែលអួតរឿងរូបសម្បត្តិទាំង ២ នោះដល់នូវការខ្មាស ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកំលោះ ២ រូបនេះមិនមែនប្រណាំងប្រជែងរូបតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុនភិក្ខុទាំង ២ ក៏ត្រាច់សរសើររូបដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតា អាស្រ័យនៅត្រង់ឆ្នេរស្ទឹងគង្គា ។ ក្នុងកាលនោះមានត្រី ២ មួយនៅក្នុងស្ទឹងគង្គា មួយនៅក្នុងស្ទឹងយមុនាបានប្រកែកគ្នារឿងរូបត្រង់ស្ទឹងគង្គានិងស្ទឹងយមុនាដែលប្រសព្វមុខគ្នាថា ខ្ញុំស្អាត អ្នកមិនស្អាត ឃើញអណ្តើកត្រង់ស្ទឹងគង្គាមិនឆ្ងាយអំពីទីនោះប៉ុន្មានគិតគ្នាថា អណ្តើក

នេះគង់ដឹងថា ខ្ញុំស្អាតឬអ្នកស្អាត ទើបចូលទៅរកអណ្តើកនោះហើយសួរថា អណ្តើកសម្លាញ់ ត្រីដែលនៅក្នុងស្ទឹងគង្គាស្អាតឬត្រីដែលនៅក្នុងស្ទឹងយមុនាស្អាត អណ្តើកឆ្លើយថា ត្រីដែលនៅក្នុងស្ទឹងគង្គាក៏ស្អាត ត្រីដែលនៅក្នុងស្ទឹងយមុនាក៏ស្អាតតែខ្ញុំស្អាតជាងអ្នកទាំង ២ ទៅទៀត កាលទឹងប្រកាសសេចក្តីនេះទើបពោលគាថាទីមួយថា

ត្រីទាំងឡាយនៅក្នុងទន្លេគង្គាក៏ល្អ ត្រីទាំងឡាយនៅក្នុងទន្លេ
យមុនាក៏ល្អតែបុរសមានជើង ៤ នេះមានបរិមណ្ឌលដូចដើម
ជ្រៃផង មានកវែងដូចចន្ទោលនៃរថផង ល្អរុងរឿងលើសអ្នក
ទាំងឡាយរាល់គ្នាទៅទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុប្បាទាយំ** នេះអណ្តើកពោលសំដៅដល់ខ្លួនឯងថា បុរសអ្នកមានជើង ៤ ។ បទថា **និគ្រោធបរិមណ្ឌលោ** គឺមានបរិមណ្ឌលដូចដើមជ្រៃដែលដុះឡើងល្អហើយ ។ បទថា **ឦសកាយត-គីវោ** គឺ មានកវែងដូចចន្ទោលរថ ។ បទថា **សព្វេ វ អតិរោចតិ** សេចក្តីថា អណ្តើកដែលបរិបូរណ៌ដោយទ្រង់ទ្រាយពោលថា ខ្ញុំនេះរមែងរុងរឿងជាងអ្នកទាំងឡាយ គឺខ្ញុំនេះឯងស្អាតជាងពួកអ្នកទាំងឡាយ ។

ត្រីស្តាប់ពាក្យអណ្តើកហើយពោលថា នែអណ្តើកអាក្រក់ អួតខ្លួនល្អឯងមិនឆ្លើយពាក្យដែលអញសួរបែរជាឆ្លើយពាក្យដទៃ ហើយពោលគាថាទីពីរថា

យើងសួរហេតុណាមិនប្រាប់ហេតុនោះ យើងសួរហើយត្រឡប់

ប្រាប់ហេតុដទៃវិញ សត្វសរសើរតែខ្លួនឯងនេះ មិនគាប់ចិត្ត
យើងទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្តប្បសំសកោ** បានដល់ បុគ្គលចូលចិត្តសរសើរខ្លួនឯង គឺលើកតម្កើងខ្លួន ។ បទថា **ឆាយំ អស្មាក រុច្ចតិ** សេចក្តីថា អណ្តើកអាក្រក់នេះមិនគាប់ចិត្ត គឺមិនពេញចិត្តយើងទេ ។ ត្រីទាំង ២ ព្រួសទឹកដាក់អណ្តើកហើយក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ត្រីទាំង ២ ក្នុងកាលនោះបានមកជាភិក្ខុកំលោះ ២ រូបក្នុងកាលឥឡូវនេះ អណ្តើកក្នុងកាលនោះបានមកជាភិក្ខុចាស់ ឯរុក្ខទេវតាដែលកើតត្រង់ច្នេះស្ទឹងគង្គា អ្នកឃើញហេតុការណ៍ដោយសព្វគ្រប់ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គន្ធេយ្យជាតក ចប់

## កុរុង្គមិគជាតក

[ ២៦១ ] ( សត្វចចាតពោលថា ) ម្នាលអណ្តើក សូមអ្នកកាត់នូវអន្ទាក់ព្រ័ត្រដោយធ្មេញចុះ យើងនឹងធ្វើព្រានមិនឲ្យមកបាន ។

[ ២៦២ ] ( ព្រះសាស្តាត្រាស់ថា ) អណ្តើកចូលទៅកាន់ទឹក សត្វប្រើសក៏ចូលទៅព្រៃ ឯសត្វចចាតបាននាំកូនទាំងឡាយអំពីចុងឈើទៅក្នុងទីឆ្ងាយ ។

**ចប់ កុរុង្គមិគជាតកទី ៦ ។**

## អដ្ឋកថា
## កុរុង្គមិគជាតក

[ ២៦១-២៦២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឥង្ឃ វទ្ធមយំ បាសំ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា ក្នុងកាលនោះព្រះសាស្តាទ្រង់ស្តាប់ថា ទេវទត្តព្យាយាមផ្តាច់ព្រះជន្មព្រះអង្គទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តព្យាយាមផ្តាច់ជីវិតរបស់តថាគតមិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុនក៏ព្យាយាមដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វយោនយកកំណើតជាប្រើស អាស្រ័យនៅត្រង់ព្រៃល្បោះមួយ កន្លែងមិនឆ្ងាយអំពីទីនោះ មានស្រះមួយនៅក្នុងព្រៃ មិនឆ្ងាយអំពីស្រះនោះមាន ចចាតមួយឈ្មោះសតបត្ត អាស្រ័យនៅត្រង់ចុងឈើមួយដើម ។ ក្នុងស្រះ នោះមានអណ្តើកមួយនៅអាស្រ័យ ។ សត្វទាំង ៣ នោះជាសម្លាញ់នឹងគ្នា នៅរួមគ្នាដោយសេចក្តីស្រឡាញ់ ។ កាលនោះ ព្រានម្នាក់ត្រាច់ទៅក្នុងព្រៃជួប ស្នាមជើងប្រើសត្រង់កំពង់ដែលចុះផឹកទឹកទើបដាក់អន្ទាក់ព្រ័ត្រដ៏រឹងដូចច្រវាក់ ដែកហើយត្រឡប់ទៅ ។ ព្រះពោធិសត្វមកផឹកទឹកជាប់អន្ទាក់តាំងពីបឋមយាម ទើបស្រែកឲ្យដឹងថាខ្លួនជាប់អន្ទាក់ ហើយសត្វចចាតឮសំឡេងព្រះពោធិសត្វ ទើបចុះអំពីដើមឈើ អណ្តើកក៏ឡើងអំពីទឹកប្រឹក្សាគ្នាថា គួរធ្វើដូចម្តេចល្អ សត្វចចាតប្រាប់អណ្តើកថា នែសម្លាញ់ អ្នកមានធ្មេញចូរកកេរអន្ទាក់នេះចុះ ខ្ញុំនឹងទៅពាំងមិនឲ្យព្រានមកបាន ដោយសេចក្តីព្យាយាមដែលយើងទាំងពីរ ធ្វើនេះសម្លាញ់របស់យើងនឹងរួចជីវិត កាលនឹងប្រកាសអត្ថនេះ ទើបពោល គាថាទីមួយថា

ម្នាលអណ្តើក សូមអ្នកកាត់នូវអន្ទាក់ព្រ័ត្រដោយធ្មេញចុះ
យើងនឹងធ្វើព្រានមិនឲ្យមកបាន ដូច្នេះ ។

ទើបអណ្តើកផ្តើមកកេរខ្សែស្បែក សត្វចចាតក៏ទំត្រង់ដើមឈើមិនឆ្ងាយ អំពីផ្ទះរបស់នាយព្រាន ។ ព្រានកាន់លំពែងចេញអំពីផ្ទះ ក្នុងពេលទៀបភ្លឺ ។ សត្វចចាតដឹងថាព្រានចេញអំពីផ្ទះក៏សម្រុបស្លាបយកចំពុះចឹកព្រានដែលចេញ តាមទ្វារមុខ ។ ព្រានគិតថា អញត្រូវសត្វកាឡកណ្ណីប្រាស់ហើយទើបត្រឡប់

ទៅដេកមួយសន្ទុះហើយក្រោកឡើង កាន់លំពែងចេញទៅទៀត សត្វចចាតគិតថា កាលមុន ព្រាននេះចេញទៅតាមទ្វារខាងមុខ ឥឡូវនេះគង់នឹងចេញទៅតាមទ្វារខាងក្រោយទើបទៅទំចាំត្រង់ទ្វារខាងក្រោយ នាយព្រានគិតថា កាលអញចេញតាមទ្វារមុខក៏ជួបសត្វកាឡកណ្ណី ឥឡូវនេះ អញនឹងចេញតាមទ្វារក្រោយទើបចេញទៅតាមទ្វារក្រោយ សត្វចចាតក៏បោះពួយ យកចំពុះចឹកទៀត ព្រានគិតថា អញត្រូវសត្វកាឡកណ្ណីចឹកទៀត ឥឡូវនេះសត្វនេះគង់មិនឲ្យអញចេញទៅ ដេករង់ចាំដល់ថ្ងៃរះសឹមទៅចុះ ។ លុះថ្ងៃរះឡើងទើបកាន់លំពែងចេញទៅ ។ សត្វចចាតប្រញាប់ទៅប្រាប់ដល់ព្រះពោធិសត្វថា ព្រានកំពុងដើរមក ក្នុងខណៈនោះ អណ្តើកខាំខ្សែដាច់នៅសល់ត្រឹមតែមួយធ្នុងទៀត តែធ្មេញរបស់អណ្តើកក៏ជ្រុះស្ទើរអស់ មាត់ក៏ហើមប្រឡាក់ដោយឈាម ។ ព្រះពោធិសត្វឃើញព្រានកាន់លំពែងដើរមករហ័សដូចផ្គេកបន្ទោរ ទើបខាំអន្ទាក់មួយសរសៃនោះដាច់ហើយរត់ចូលព្រៃ សត្វចចាតទំត្រង់ចុងឈើតែអណ្តើកដេកក្នុងទីនោះឯងព្រោះមានរបួសធ្ងន់ ព្រានឃើញអណ្តើកទើបចាប់ដាក់កំប្រោងព្យួរទុកត្រង់ដើមឈើមួយកន្លែង ។ ព្រះពោធិសត្វត្រឡប់មកមើលដឹងថា អណ្តើកត្រូវចាប់ទើបគិតថា អញនឹងជួយជីវិតសម្លាញ់ទើបធ្វើហាក់ដូចជាអស់កម្លាំងបង្ហាញខ្លួនឲ្យព្រានឃើញ ព្រានគិតថា ម្រឹគនេះអស់កម្លាំងអញនឹងសម្លាប់វាហើយកាន់លំពែងដេញតាមទៅ ។ ព្រះពោធិសត្វទៅមិនឆ្ងាយមិនជិតពេកបញ្ឆោតព្រានឲ្យចូលព្រៃ កាលដឹងថាព្រានទៅឆ្ងាយហើយទើបជាន់ស្នាមជើងបញ្ឆោតហើយគេចទៅផ្លូវដទៃដោយសន្ទុះដ៏រហ័សដូចខ្យល់

ព្យុះ យកស្នែងលើកកំប្រោងឡើងទម្លាក់លើផែនដី វែងឲ្យរហែកនាំអណ្តើក ចេញមកបាន សត្វចចាតក៏ចុះអំពីដើមឈើ ។ ព្រះពោធិសត្វ កាលនឹងឲ្យ ឱវាទដល់សត្វទាំង ២ ទើបពោលថា ខ្ញុំបានជីវិតក៏ព្រោះអាស្រ័យពួកអ្នក កិច្ច ដែលគួរធ្វើដល់សម្លាញ់ពួកអ្នកក៏បានធ្វើដល់ខ្ញុំហើយ ឥឡូវនេះព្រាននឹងមក ចាប់ពួកយើងទៀត ព្រោះដូច្នោះចចាតសម្លាញ់សូមអ្នកនាំកូនតូចៗរបស់អ្នក ទៅកាន់ទីដទៃចុះ អណ្តើកសម្លាញ់សូមឰអ្នកក៏ចូរចុះក្នុងទឹក សត្វទាំង ២ បាន ធ្វើតាម ។

ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយត្រាស់គាថាទីពីរថា

អណ្តើកចូលទៅកាន់ទឹក សត្វប្រើសក៏ចូលទៅព្រៃ ឯសត្វ
ចចាតបាននាំកូនទាំងឡាយអំពីចុងឈើទៅក្នុងទីឆ្ងាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អចានយិ** សេចក្តីថា បានទៅហើយ គឺ នាំកូនទៅហើយ ។

ចំណែកព្រានមកកាន់ទីនោះមិនឃើញសត្វណាមួយ ចាប់កំប្រោងដែល រហែកលើកឡើងហើយ អាក់អន់ចិត្តត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន សត្វដែលជា សម្លាញ់ទាំង ៣ រូបផុតអំពីអន្ទាក់ក៏មិនបានកាត់សេចក្តីស្និទ្ធស្នាលនឹងគ្នាដរាប ដល់អស់ជីវិត ហើយក៏ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំ ជាតកថា ព្រានក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ សត្វចចាត ក្នុងកាលនោះបានមកជាសារីបុត្ត អណ្តើកក្នុងកាលនោះបានមកជាមោគ្គល្លាន

ឯប្រើសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កុរុង្គមិគជាតក ចប់

## អស្សកជាតក

[ ២៦៣ ] ( សត្វកំពោងញីពោលថាកាលពីដើម ) ឧយ្យានប្រទេសនេះ ខ្ញុំបានត្រាច់ទៅជាមួយនឹងស្តេចអស្សកៈជាប្តី ជាទីស្រឡាញ់ដែលខ្ញុំប្រាថ្នាគេៗប្រាថ្នានូវខ្ញុំ ។

[ ២៦៤ ] សេចក្តីសុខនិងទុក្ខថ្មីតែងបិទបាំងនូវសុខ និងទុក្ខចាស់ ព្រោះហេតុនោះ សត្វកំពោងឈ្មោលជាទីស្រឡាញ់របស់ខ្ញុំ ជាងស្តេចអស្សកទៅទៀត ។

### ចប់ អស្សកជាតកទី ៧ ។

## អដ្ឋកថា

## អស្សកជាតក

[ ២៦៣-២៦៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់បុរាណទុតិយិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អយមស្សករាជេន** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា ភិក្ខុនោះកាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតមែនឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ពិតមែន ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វីទើបអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា ព្រោះអតីតករិយារបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ស្រីនោះមានសេចក្តីស្រឡាញ់ក្នុងអ្នកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន

សូម្បីក្នុងកាលមុនអ្នកក៏បានទទួលទុក្ខធំព្រោះអាស្រ័យស្រីនោះដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះរាជាព្រះនាមអស្សកៈ គ្រងរាជសម្បត្តិក្នុងនគរឈ្មោះបាដលិក្នុងដែនកាសី ។ ទ្រង់មានអគ្គមហេសីព្រះនាមថា ឧព្វរី ជាទីស្រឡាញ់គាប់ព្រះទ័យរបស់ព្រះអង្គ មានរូបឆោមស្អាតគួរពិតពិលរមិលមើល មានព្រះឆវីក្រៃលែងជាងមនុស្សតែមិនដល់ពណ៌សម្បុរជាទិព្វ ។ ព្រះនាងអស់ព្រះជន្មទាំងដែលរូបនៅស្អាត ។ ព្រះរាជាទ្រង់សោកាសោយទុក្ខទោមនស្សពន់ពេកព្រោះការអស់ព្រះជន្មរបស់ព្រះនាងនោះ ។ ព្រះរាជាឲ្យលើកសពរបស់ព្រះនាង ដាក់មឈូសហើយចាក់ប្រេងពេញរក្សាទុក លើកទៅតម្កល់ក្រោមព្រះទែនសយនា ទ្រង់អត់ព្រះក្រយាហារ ផ្ទំព្រះកន្សែងបរិទេវនាការ ។ ព្រះរាជមាតាបិតា ព្រះញាតិមិត្តនិងអាមាត្យ ព្រាហ្មណ៍ គហបតីជាដើមនាំគ្នាលួងលោមថា បពិត្រព្រះសម្មតិទេពសូមទ្រង់កុំសោយសោកឡើយ សង្ខារទាំងឡាយជារបស់មិនទៀង ក៏មិនអាចឲ្យទ្រង់ត្រេកអរបាន ។ ទ្រង់យំរៀបរាប់ដូច្នោះអស់ ៧ ថ្ងៃ ។ កាលនោះព្រះពោធិសត្វជាតាបសសម្រេចអភិញ្ញា ៥ និងសមាបត្តិ ៨ នៅក្នុងហិមវន្តប្បទេស ចម្រើនអាលោកកសិណពិនិត្យមើលជម្ពូទ្វីបដោយទិព្វចក្ខុ ឃើញព្រះរាជាបរិទេវនាការយ៉ាងនោះត្រិះរិះថា អញគួរជាទីពឹងរបស់ព្រះរាជាអង្គនោះ ទើបហោះមកតាមអាកាសដោយឥទ្ធានុភាពរួចចុះទៅក្នុងព្រះរាជឧទ្យានអង្គុយលើផ្ទាំងមង្គលសិលាដូចបដិមាមាស ។

គ្រានោះព្រាហ្មណមាណពអ្នកនគរបាដលិម្នាក់ទៅកាន់ព្រះរាជឧទ្យាន

ឃើញព្រះពោធិសត្វ ទើបអង្គុយចុះហើយថ្វាយបង្គំ ។ ព្រះពោធិសត្វធ្វើបដិសណ្ឋារៈជាមួយមាណពនោះហើយសួរថា នែមាណព ព្រះរាជាទ្រង់តាំងនៅក្នុងធម៌ឬ មាណពឆ្លើយថា បពិត្រលោកម្ចាស់ ព្រះរាជាតាំងនៅក្នុងធម៌ តែព្រះមហេសីរបស់ទ្រង់អស់ព្រះជន្មហើយ ទ្រង់តម្កល់សពព្រះនាងទុកក្នុងមឈូសហើយទ្រង់ផ្ទំព្រះកន្សែងរៀបរាប់ ថ្ងៃនេះជាថ្ងៃទី ៧ លោកម្ចាស់មិនជួយព្រះរាជាឲ្យផុតទុក្ខទេឬ កាលមានអ្នកមានសីលដូចលោកម្ចាស់សមគួរឲ្យព្រះរាជាសោយទុក្ខដូច្នោះឬ ។ ព្រះពោធិសត្វពោលថា នែមាណព អាត្មាមិនស្គាល់ព្រះរាជា បើព្រះរាជាយាងមកសួរអាត្មា អាត្មានេះឯងនឹងប្រាប់ទីដែលព្រះមហេសីទៅកើត នឹងឲ្យព្រះនាងត្រាស់សន្ទនាជាមួយព្រះរាជានោះឯង ។ មាណពនោះពោលថា បពិត្រលោកម្ចាស់ បើដូច្នោះសូមលោកម្ចាស់អង្គុយរង់ចាំទីនេះសិនទម្រាំខ្ញុំទូលព្រះរាជាយាងមក ។ មាណពទទួលប្តេជ្ញារបស់ព្រះពោធិសត្វហើយទៅគាល់ព្រះរាជាក្រាបទូលសេចក្តីនោះ ហើយទូលបន្តថា បពិត្រព្រះសម្មតិទេព ទ្រង់គួរយាងទៅកាន់សម្នាក់របស់លោកអ្នកមានទិព្វចក្ខុ ។ ព្រះរាជាទ្រង់ត្រេកអរដោយទ្រង់បានឮថានឹងបានឃើញនាងឧព្វរី ទ្រង់ឡើងកាន់រថ ទៅកាន់ព្រះរាជឧទ្យាន ថ្វាយបង្គំព្រះពោធិសត្វហើយគង់ក្នុងចំណែកម្ខាងត្រាស់សួរថា បពិត្រលោកម្ចាស់ បានឮថា លោកម្ចាស់ដឹងទីកើតរបស់ព្រះនាងឧព្វរីពិតឬ ព្រះពោធិសត្វទូលថា ពិតហើយព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា នាងកើតក្នុងទីណា ព្រះពោធិសត្វទូលថា បពិត្រមហារាជ ព្រះនាងស្រវឹងក្នុងរូបអាស្រ័យការស្រវឹងមិនធ្វើកុសលកម្មទើបទៅកើត

ក្នុងកំណើតសត្វកំពោង ។ ព្រះរាជាត្រាស់ថា ខ្ញុំមិនជឿឡើយ ។ ឥសីទូលថា បើដូច្នោះ អាត្មានឹងបង្ហាញដល់ព្រះអង្គហើយឲ្យសត្វនោះនិយាយ ។ ព្រះរាជាត្រាស់ថា សាធុ សូមឲ្យព្រះនាងពោលចុះ ។ ព្រះពោធិសត្វបានធ្វើឲ្យសត្វកំពោង ២ មកដោយអានុភាពរបស់ខ្លួនដោយអធិដ្ឋានថា សូមសត្វកំពោង ២ ជ្រែកអាចម៍គោចេញមកចំពោះព្រះភក្ត្ររបស់ព្រះរាជាចុះ សត្វកំពោង ២ ក៏ចេញមកតាមការអធិដ្ឋាននោះ ព្រះពោធិសត្វ កាលបង្ហាញព្រះទេវីទើបក្រាបទូលថា បពិត្រមហារាជ ព្រះទេវីឧព្វរីបែកពីទ្រង់ទៅហើយពេលនេះកំពុងតែដើរតាមក្រោយកំពោងឈ្មោលមក សូមទ្រង់ទតចុះ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំមិនជឿថាសត្វដែលកើតក្នុងកំណើតកំពោងជានាងឧព្វរីឡើយ ព្រះពោធិសត្វទូលថា មហាបពិត្រ អាត្មានឹងឲ្យកំពោងនោះពោល ។ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ឲ្យពោលចុះ ។

ព្រះពោធិសត្វកាលនឹងឲ្យកំពោងពោលដោយអានុភាពរបស់ខ្លួនទើបហៅថា នែនាងឧព្វរី ។ កំពោងញីពោលជាភាសាមនុស្សថា ករុណាលោកម្ចាស់ ព្រះពោធិសត្វសួរថា ក្នុងអត្តភាពដែលកន្លងទៅហើយនាងជាអ្នកណា កំពោងញីឆ្លើយថា ខ្ញុំជាអគ្គមហេសីរបស់ស្តេចអស្សកៈ ឈ្មោះឧព្វរី ឥសីសួរថា ឥឡូវនេះព្រះរាជាអស្សកៈនៅជាទីស្រឡាញ់របស់នាងឬ ឬកំពោងឈ្មោលជាទីស្រឡាញ់របស់នាង សត្វកំពោងញីឆ្លើយថា បពិត្រលោកម្ចាស់ ព្រះរាជាជាស្វាមីរបស់ខ្ញុំក្នុងជាតិមុន កាលនោះខ្ញុំត្រាច់សរសើររូប សំឡេង ក្លិនរស ផោដ្ឋព្វៈ ជាមួយព្រះរាជានោះក្នុងឧទ្យាននេះតែឥឡូវនេះតាំងពីខ្ញុំបែកកត

គ្នាហើយ ព្រះរាជាអស្សកៈគ្មានជាអ្វីនឹងខ្ញុំឡើយ ឥឡូវនេះខ្ញុំនឹងសម្លាប់ស្តេចអស្សកៈ យកឈាមក្នុងបំពង់ករបស់ទ្រង់មកលាងជើងកំពោងឈ្មោលជាប្តីរបស់ខ្ញុំ ហើយបានពោលគាថានេះដោយភាសាមនុស្សក្នុងកណ្តាលបរិស័ទថា

ឧយ្យានប្រទេសនេះ ខ្ញុំបានត្រាច់ទៅជាមួយនឹងស្តេចអស្សកៈជាប្តីជាទីស្រឡាញ់ដែលខ្ញុំប្រាថ្នាគេ ៗ ប្រាថ្នានូវខ្ញុំ ។

សេចក្តីសុខនិងទុក្ខថ្មីតែងបិទបាំងនូវសុខនិងទុក្ខចាស់ ព្រោះហេតុនោះសត្វកំពោងឈ្មោលជាទីស្រឡាញ់របស់ខ្ញុំជាងស្តេចអស្សកទៅទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយមស្សករាជេន ទេសោ វិចរិតោ មយា** សេចក្តីថា ឧទ្យានបទេសដែលគួរត្រេកអរនេះខ្ញុំធ្លាប់ត្រាច់ទៅជាមួយស្តេចអស្សកៈ ។ ពាក្យថា **អនុ** ក្នុងបទថា **អនុកាមយកាមេន** ត្រឹមតែជានិបាត សេចក្តីថា ខ្ញុំមានសេចក្តីប្រាថ្នាចំពោះស្តេចអស្សកៈនោះបានត្រាច់លេងជាមួយស្តេចអស្សកៈដែលប្រាថ្នាចំពោះខ្ញុំ ។ បទថា **បិយេន** បានដល់ជាទីស្រឡាញ់ក្នុងអត្តភាពនោះ ។ បទថា **នវេន សុខទុក្ខេន បោរាណំ អបិធិយ្យតិ** សេចក្តីថា កំពោងញីពោលថា បពិត្រលោកម្ចាស់ សុខចាស់ត្រូវសុខថ្មីបិទបាំង ទុក្ខចាស់ត្រូវទុក្ខថ្មីបិទបាំងនេះជាធម្មតានៃលោក ។ បទថា **តស្មា អស្សករញ្ញាវ កីដោ បិយតរោ មមំ** សេចក្តីថា ព្រោះសុខទុក្ខចាស់ត្រូវសុខទុក្ខថ្មីបិទបាំង ដូច្នោះទើបកំពោងឈ្មោលជាទីស្រឡាញ់របស់ខ្ញុំក្រៃលែងជាងស្តេចអស្សកៈរាប់រយរាប់ពាន់ដង ។

ព្រះបាទអស្សកៈបានស្តាប់ដូច្នោះហើយ ទ្រង់មានវិប្បដិសារីប្រថាប់ក្នុងទីនោះឯងឲ្យនាំសពព្រះទេវីចេញទៅ ទ្រង់ស្រង់ព្រះសីសៈហើយថ្វាយបង្គំព្រះពោធិសត្វយាងចូលព្រះនគរ ទ្រង់អភិសេកស្ត្រីដទៃជាអគ្គមហេសី ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ។ ព្រះពោធិសត្វថ្វាយឱវាទព្រះរាជាឲ្យទ្រង់ប្រាសចាកសេចក្តីសោកហើយក៏ត្រឡប់ទៅកាន់ព្រៃហិមពាន្ត ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះទេវីឧព្វរីក្នុងកាលនោះ បានមកជាភរិយាចាស់របស់ភិក្ខុនោះក្នុងកាលឥឡូវនេះ ព្រះបាទអស្សកៈក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក មាណពក្នុងកាលនោះ បានមកជាសារបុត្ត ឯតាបសក្នុងកាលនោះគឺតថាគតនេះឯង ។

## អដ្ឋកថា អស្សកជាតក ចប់

## សុំសុមារជាតក

[ ២៦៥ ] ( ស្វាពោធិសត្វពោលថា ) ផ្លៃឈើទាំងឡាយណា ( ដែលអ្នកឃើញហើយ ) នាត្រើយសមុទ្រខាងនាយ ផ្លៃឈើទាំងនោះគឺ ផ្លៃស្វាយក្តី ផ្លៃព្រីងក្តី ផ្លៃខ្នុរក្តីមិនគួរដល់យើងឡើយ ដើមល្វា ( នេះឯង ) ជាឈើដ៏ប្រសើររបស់យើង ។

[ ២៦៦ ] សរីរៈរបស់អ្នកធំមែន ប៉ុន្តែប្រាជ្ញាសមគួរនឹងសរីរៈនោះមិនមាន នែក្រពើ ឯងត្រូវអញបញ្ឆោតហើយឥឡូវចូរឯងទៅតាមស្រួលចុះ ។

**ចប់ សុំសុមារជាតក ទី ៨ ។**

## អដ្ឋកថា

## សុំសុមារជាតក

[ ២៦៥-២៦៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្តដែលព្យាយាមផ្តាច់ព្រះជន្មព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អលមេតេហិ អម្ពេហិ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបដូច្នេះថា ក្នុងកាលនោះព្រះសាស្តាទ្រង់បានឮថា ទេវទត្តព្យាយាមសម្លាប់ព្រះអង្គទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តព្យាយាមសម្លាប់តថាគតមិនមែនតែក្នុងកាលឥឡូវនេះទេសូម្បីក្នុងកាលមុនក៏ព្យាយាមដូចគ្នា តែមិនអាចធ្វើសូម្បីត្រឹមតែការតក់ស្លុតឲ្យកើតដល់តថាគតបានឡើយ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតពានរ ក្នុងហិមវន្តប្បទេស មានកម្លាំងដូចដំរីសា សម្បុរជោយសម្ផុះ មានរាងកាយធំដល់ព្រមដោយលម្អ អាស្រ័យនៅក្នុង ដងព្រៃត្រង់ស្ទឹងបត់ ។ ក្នុងកាលនោះក្រពើមួយអាស្រ័យក្នុងស្ទឹងគង្គា ប្រពន្ធ របស់ប្រពើឃើញកាយរបស់ព្រះពោធិសត្វហើយ កើតចាញ់ផ្ទៃចង់ស៊ីសាច់ បេះដូងរបស់ព្រះពោធិសត្វ ទើបប្រាប់ក្រពើជាប្ដីថា បពិត្រអ្នក ខ្ញុំចង់ស៊ីសាច់ បេះដូងរបស់ស្ដេចស្វា ។ ក្រពើជាប្ដីប្រាប់ថា នែនាង យើងជាសត្វត្រាច់ ទៅក្នុងទឹក ស្វាជាសត្វត្រាច់ទៅលើគោក យើងនឹងចាប់ស្វានោះបានដូចម្ដេច ក្រពើញីប្រាប់ថា សូមអ្នករកឧបាយចាប់ស្វានោះឲ្យបានបើចាប់មិនបានខ្ញុំនឹង ស្លាប់ ។ ក្រពើឈ្មោលលួងលោមថា កុំគិតច្រើនឡើយ មានឧបាយមួយខ្ញុំ យកបេះដូងស្ដេចពានរនោះឲ្យនាងស៊ីទាល់តែបាន ទើបចូលទៅរកព្រះពោធិ-សត្វ ក្នុងកាលដែលព្រះពោធិសត្វមកផឹកទឹកក្នុងស្ទឹងគង្គាហើយអង្គុយសម្រាក ត្រង់ច្រាំងស្ទឹងពោលយ៉ាងនេះថា បពិត្រស្ដេចពានរ អ្នកតែម្នាក់ឯងស៊ីផ្លែចេក ក្នុងទឹកដីនេះត្រាច់ទៅក្នុងទីដែលធ្លាប់ទៅតែម្យ៉ាងប៉ុណ្ណោះ ត្រង់ត្រើយស្ទឹងគង្គា ត្រើយនាយមានផ្លែឈើដែលមានរសឆ្ងាញ់ជាច្រើនមានស្វាយ ព្រីងជាដើម អ្នកមិនទៅទំពាស៊ីផ្លែឈើត្រង់ត្រើយនាយទេឬ ស្ដេចពានរឆ្លើយថា នែស្ដេច កុម្ភីលៈ ស្ទឹងគង្គាមានទឹកច្រើនផង ធំផង ខ្ញុំនឹងឆ្លងទៅបានដូចម្ដេច ។ ក្រពើ ពោលថា បើអ្នកចង់ទៅខ្ញុំនឹងឲ្យអ្នកជិះលើខ្នងខ្ញុំទៅ ស្ដេចពានរជឿទើបយល់ ព្រម កាលក្រពើពោលថា បើដូច្នោះចូរអ្នកឡើងលើខ្នងខ្ញុំទើបស្ដេចពានរ

ឡើងលើខ្នងក្រពើ ក្រពើទៅបានបន្តិចក៏មុជចុះក្នុងទឹក ព្រះពោធិសត្វសួរថា នែសម្លាញ់ អ្នកក្លែងធ្វើឲ្យខ្ញុំលិចទឹកតើមានរឿងអ្វី ក្រពើឆ្លើយថា ខ្ញុំមិនបាននាំអ្នកទៅតាមធម្មតាទេ តែប្រពន្ធរបស់ខ្ញុំចាញ់ផ្ទៃចង់ស៊ីបេះដូងរបស់អ្នក ខ្ញុំបំណងនឹងឲ្យប្រពន្ធរបស់ខ្ញុំស៊ីសាច់បេះដូងរបស់អ្នកទេតើ ។ ស្តេចពានរពោលថា សម្លាញ់ អ្នកបានប្រាប់ខ្ញុំល្អហើយបើបេះដូងនៅក្នុងផ្ទៃរបស់ខ្ញុំ កាលខ្ញុំលោតទៅតាមចុងឈើបេះដូងគប្បីបែកអស់ ក្រពើសួរថា បើដូច្នោះអ្នកយកបេះដូងទៅទុកឯណា ព្រះពោធិសត្វចង្អុលឲ្យមើលដើមល្វាមួយដើមមិនឆ្ងាយអំពីទីនោះ មានផ្លែទុំជាចង្កោមរួចពោលថា ចូរអ្នកមើលបេះដូងរបស់ខ្ញុំដែលព្យួរទុកត្រង់ដើមល្វានោះ ក្រពើពោលថា បើអ្នកឲ្យបេះដូងដល់ខ្ញុំ ខ្ញុំមិនសម្លាប់អ្នកទេ ស្តេចស្វាពោលថា បើដូច្នោះ ចូរអ្នកនាំខ្ញុំទៅទីនោះចុះ ខ្ញុំនឹងឲ្យបេះដូងដែលព្យួរលើដើមល្វានោះដល់អ្នក ទើបក្រពើនាំស្តេចពានរទៅក្នុងទីនោះ ។ ព្រះពោធិសត្វលោតអំពីខ្នងប្រពើទៅអង្គុយលើដើមល្វា ពោលថា សម្លាញ់ក្រពើល្ងង់ខ្លៅ ឯងយល់ថា ធម្មតាបេះដូងរបស់សត្វទាំងឡាយនៅលើចុងឈើឬ ឯងជាសត្វល្ងង់ទើបយើងកន្លងឯងបាន ផ្លែឈើរបស់អ្នកក៏ចូរជារបស់អ្នកចុះ អ្នកធំតែខ្លួនប៉ុណ្ណោះតែមិនមានបញ្ញាឡើយកាលនឹងប្រកាសសេចក្តីនេះបានពោលគាថាទាំងនេះថា

ផ្លែឈើទាំងឡាយណា ( ដែលអ្នកឃើញហើយ ) នា
ត្រើយសមុទ្រខាងនាយ ផ្លែឈើទាំងនោះគឺ ផ្លែស្វាយក្តី ផ្លែព្រីង
ក្តី ផ្លែខ្នុរក្តីមិនគួរដល់យើងឡើយ ដើមល្វា ( នេះឯង ) ជា

ឈើដ៏ប្រសើររបស់យើង ។

សរីរៈរបស់អ្នកធំមែន ប៉ុន្តែប្រាជ្ញាសមគួរនឹងសរីរៈនោះមិនមាន នៃក្រពើ ឯងត្រូវអញបញ្ឆោតហើយ ឥឡូវចូរឯងទៅតាមស្រួលចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អលមេតេហិ** សេចក្ដីថា ខ្ញុំមិនត្រូវការផ្លែឈើដែលអ្នកឃើញនៅលើកោះនោះទេ ។ បទថា **វរំ មយ្ហំ ឧទុម្ពរោ** គឺផ្លែល្វាដើមនេះរបស់យើងប្រសើរជាង ។ បទថា **តនុបិកា** សេចក្ដីថា អ្នកមានបញ្ញាតិចតួចមិនសមនឹងរាងកាយរបស់អ្នកឡើយ ។ បទថា **គច្ឆទានិ យថាសុខំ** សេចក្ដីថា ចូរអ្នកទៅតាមសប្បាយចុះ អធិប្បាយថា ឧបាយដែលអ្នកនឹងបានបេះដូងរបស់យើងមិនមានឡើយ ។

ក្រពើទាមទនស្ស សុបសៅដូចចាញ់ក្លាល់រាប់ពាន់បានត្រឡប់ទៅលំនៅរបស់ខ្លួនវិញ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ក្រពើឈ្មោលក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ក្រពើញីក្នុងកាលនោះ បានមកជាចិញ្ចមាណវិកា ឯស្ដេចពានរក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុំសុមារជាតក ចប់

## កក្ការជាតក

[ ២៦៧ ] ( មាន់ព្រៃពោលថា ) ដើមត្រចៀកប្រើសនិងដើមសម៉ ពិភេទក៏ទាំងឡាយដុះក្នុងព្រៃ យើងធ្លាប់ឃើញហើយ អ្នកអាចឈានដើរទៅកាន់ដើមឈើបានយ៉ាងណា ឯឈើទាំងនោះមិនអាចឈានដើរទៅបានយ៉ាងនោះទេ ។

[ ២៦៨ ] ( ព្រានពោលថា ) មាន់ព្រៃចាស់នេះ ទម្លាយនូវទ្រុងចេញមកហើយ ជាសត្វឈ្លាសក្នុងអន្ទាក់ដែលធ្វើដោយរោមកន្ទុយ ក៏បានចេញទៅផងនិយាយផង ។

**ចប់ កក្ការជាតកទី ៩ ។**

## អដ្ឋកថា

## កក្ការជាតក

[ ២៦៧-២៦៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះ ដែលជាសទ្ធិវិហារិករបស់ព្រះធម្មសេនាបតីសារីបុត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទិដ្ឋា មយា វនេ រុក្ខា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុកំលោះរូបនោះជាអ្នកឈ្លាសក្នុងការរក្សារាងកាយរបស់ខ្លួន មិនឆាន់របស់ត្រជាក់ពេក ក្តៅពេក ព្រោះក្រែងរាងកាយមិនសប្បាយ មិនចេញទៅខាងក្រៅ ព្រោះខ្លាចរាងកាយប៉ះរងានិងក្តៅ មិនឆាន់ចង្ហាន់ដែលស្អែង ព្រោះភិក្ខុរូបនោះជាអ្នកឈ្លាសក្នុងការរក្សារាងកាយ ទើបប្រាកដទៅក្នុងកណ្តាល

សង្ឃ ។ ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ភិក្ខុកំលោះរូបនោះជាអ្នកឈ្លាសក្នុងការរក្សារាងកាយរបស់ខ្លួន ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកំលោះរូបនេះមិនមែនឈ្លាសក្នុងការរក្សារាងកាយតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ជាអ្នកឈ្លាសដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតាក្នុងដងព្រៃធំ ។ កាលនោះមានព្រានបក្សីម្នាក់ បីមាន់ធ្លាក់មួយកាន់អន្ទាក់និងដងទៅដាក់មាន់ក្នុងព្រៃ ផ្តើមនឹងទាក់មាន់របស់ខ្លួនដែលរួចចូលព្រៃអំពីមុននោះ ។ មាន់នោះព្រោះដឹងក្នុងអន្ទាក់ទើបមិនព្រមចូលទៅជិតចេះតែថយរឿយៗ ទើបនាយព្រានយកមែកឈើនិងស្លឹកឈើបិទបាំងខ្លួន រំកិលអន្ទាក់និងដងតាមរឿយៗទៅ ។ ឯមាន់ចង់ឲ្យព្រានខ្មាសទើបពោលភាសាមនុស្សជាគាថាទីមួយថា

> ដើមត្រចៀកប្រើសនិងដើមសម៉ពិភេទក៏ទាំងឡាយ ដុះក្នុងព្រៃ
> យើងធ្លាប់ឃើញហើយ អ្នកអាចឈានដើរទៅកាន់ដើមឈើ
> បានយ៉ាងណា ឯឈើទាំងនោះ មិនអាចឈានដើរទៅបានយ៉ាង
> នោះទេ ដូច្នេះ ។

គាថានោះមានអធិប្បាយថា នៃព្រានសម្លាញ់ ខ្ញុំធ្លាប់ឃើញដើមត្រចៀក ប្រើសនិងដើមសម៉ាភិភេកជាច្រើនកើតក្នុងព្រៃនេះ ដើមឈើទាំងនោះមិនរំកិលទៅមុខ មិនឈាន មិនដើរ ដូចអ្នកឈានទៅខាងនោះខាងនេះបាននោះទេ ។

កាលមាន់នោះពោលយ៉ាងនេះហើយទើបគេចទៅកាន់ទីដទៃ ក្នុងកាលដែលគេចទៅទើបនាយព្រានពោលគាថាទីពីរថា

មាន់ព្រៃចាស់នេះទម្លាយនូវទ្រុងចេញមកហើយ ជាសត្វឈ្លាសក្នុងអន្ទាក់ដែលធ្វើដោយរោមកន្ទុយក៏បានចេញទៅផង និយាយផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុសលោ វាលបាសានំ** សេចក្ដីថា មាន់ឈ្លាសក្នុងអន្ទាក់រោមសត្វ មិនឲ្យចាប់ខ្លួនបាន រមែងគេចទៅនិងចំអកឲ្យទៀតផង កាលចំអកហើយមាន់ក៏គេចទៅ ។

កាលពោលយ៉ាងនេះហើយ ព្រានក៏ត្រាច់ទៅចាប់មាន់តាមដែលជាប់អន្ទាក់ត្រឡប់ទៅ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ព្រានក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ មាន់ក្នុងកាលនោះ បានមកជាភិក្ខុកំលោះអ្នកឈ្លាសក្នុងការរក្សារាងកាយ ចំណែករុក្ខទេវតាអ្នកឃើញហេតុការណ៍យ៉ាងប្រចក្ស ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កក្ករជជាតក ចប់**

## កន្ទគលកជាតក

[ ២៦៩ ] ( សត្វត្រសេះឈ្មោះកន្ទគលកៈពោលថា ) ម្នាលត្រសេះឈ្មោះខទិរវនិយៈដ៏ចម្រើន អំបែងក្បាលបែកហើយដោយការប្រហារតែម្តងពួដ៏ដើមឈើណា ដើមឈើនេះ មានស្លឹកល្អិតប្រកបដោយបន្លា តើជាឈើឈ្មោះអ្វី ។

[ ២៧០ ] ( ខទិរនិយពោលថា ) ឱហ្ន៎ ត្រសេះនេះកាលចោះនូវឈើក្នុងព្រៃទាំងឡាយបានហើរទៅក្នុងពួកឈើមិនមានខ្លឹម ជាចំណែកនៃឈើស្ងួតក្នុងកាលជាខាងក្រោយមកត្រសេះ ( នេះ ) បានហើរមកទម្លាយអំបែងក្បាល ( របស់ខ្លួន ) នឹងដើមសង្កែជាឈើមានខ្លឹមអំពីកំណើត ។

**ចប់ កន្ទគលកជាតកទី ១០ ។**

**ចប់ នតំទឡ្ហវគ្គទី ៦ ។**

### ឧទ្ទាននៃនតំទឡ្ហវគ្គនោះគឺ

និយាយអំពីចំណងមាំ ១ ហង្សប្រសើរ ១ ស្តេចនាគឈ្មោះវិរូបក្ខៈ ១ ក្អែកគោកឈ្មោះសរិទ្ធកៈ ១ ត្រីដ៏ប្រសើរ ១ ប្រើស ១ ស្តេចឈ្មោះអស្សកៈ ១ ផ្លែស្វាយដ៏ប្រសើរ ១ មាន់ ១ ត្រសេះ ១ ត្រូវជា ១០ ។

# អដ្ឋកថា

# កន្ទុគលកជាតក

[ ២៦៩-២៧០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្តដែលត្រាប់លំនាំព្រះសុគត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អម្ភោ កោ ឆាមយំ រុក្ខោ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ក្នុងកាលនោះព្រះសាស្តាទ្រង់ឮថា ទេវទត្តយកលំនាំព្រះសុគតទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តយកលំនាំតថាគតដល់នូវសេចក្ដីវិនាសមិនមែនតែក្នុងកាលឥឡូវនេះទេសូម្បីក្នុងកាលមុនក៏បានដល់នូវសេចក្ដីវិនាសមកហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសត្វត្រសេះក្នុងហិមវន្តប្បទេស ។ ត្រសេះនោះមានឈ្មោះថា ខទិរវនិយៈ ត្រាច់រកអាហារក្នុងព្រៃគគីរ ។ បក្សីនោះមានសម្លាញ់មួយឈ្មោះកន្ទុគលកៈ ។ កន្ទុគលកៈស្វែងរកស៊ីក្នុងព្រៃល្ហុសផ្អុង ថ្ងៃមួយត្រសេះឈ្មោះកន្ទុគលកៈបានទៅរកបក្សីឈ្មោះខទិរវនិយៈ ។ ខទិរវនិយៈត្រេកអរពោលថា សម្លាញ់របស់អញមកហើយទើបនាំកន្ទុគលកៈចូលទៅកាន់ព្រៃគគីរ ប្រើចំពុះចោះដើមគគីរបានសត្វល្អិតអំពីដើមឈើនោះមកឲ្យកន្ទុគលកៈស៊ីសត្វល្អិតដែលសម្លាញ់ឲ្យហើយដូចនំដ៏ឆ្ងាញ់ កាលកន្ទុគលកៈកំពុងស៊ីនោះ ទើបកើតមានះឡើងថា ខទិរវនិយៈនេះកើតក្នុងកំណើតត្រសេះ

សូម្បីអញក៏កើតក្នុងកំណើតដូចគ្នា រឿងអ្វីដែលអញត្រូវអាស្រ័យចំណីដែលគេឲ្យ អញនឹងរកចំណីក្នុងព្រៃគគីរឯង ។

កន្ទុគលកៈពោលនឹងខទិរវនិយៈថា នែសម្លាញ់ ចូរអ្នកកុំលំបាកឡើយ ខ្ញុំនេះឯងនឹងរកស៊ីក្នុងព្រៃគគីរ ។ លំដាប់នោះទើបខទិរវនិយៈពោលថា នែសម្លាញ់ អ្នកធ្លាប់រស់នៅដោយការរកស៊ីក្នុងព្រៃឈើមិនមានខ្លឹមដូចជាដើមរកានិងដើមរលួសផ្អុងជាដើម ចំណែកដើមគគីរជាឈើមានខ្លឹម បើអ្នកធ្វើយ៉ាងនោះមិនគាប់ចិត្តខ្ញុំឡើយ ។ កន្ទុគលកៈពោលថា ខ្ញុំមិនកើតក្នុងកំណើតត្រសេះទេឬ មិនជឿពាក្យរបស់ខទិរវនិយៈរូតរះទៅ យកចំពុះចោះដើមគគីរ រំពេចនោះឯងចំពុះរបស់កន្ទុគលកៈបាក់មួយរំពេច ភ្នែកបញ្ឈរ ក្បាលបែក មិនអាចទំលើចុងឈើនោះបានធ្លាក់ចុះលើផែនដីពោលគាថាទីមួយថា

ម្នាលត្រសេះឈ្មោះ ខទិរវនិយៈដ៏ចម្រើន អំបែងក្បាលបែកហើយដោយការប្រហារតែម្តង ឮដ៏ដើមឈើណា ដើមឈើនេះមានស្លឹកល្អិត ប្រកបដោយបន្លា តើជាឈើឈ្មោះអ្វីដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អម្ភោ កោ ឆាមយំ រុក្ខោ** សេចក្តីថា នែខទិរវនិយៈដ៏ចម្រើន ដើមឈើនេះឈ្មោះអ្វី ។ បាលីថា **កោឆាមសោ** ដូច្នេះក៏មាន ។ បទថា **សិន្នបត្តោ** គឺ មានស្លឹកល្អិត ។ បទថា **យត្ថ ឯកប្បហារេន** បានដល់ ដោយការចោះត្រឹមតែម្តងត្រង់ដើមឈើ ។ បទថា **ឧត្តមង្គំ វិសាជិតំ** បានដល់ អំបែងក្បាលបែកមិនត្រឹមតែបែកប៉ុណ្ណោះ

សូម្បីចំពុះក៏បាក់កន្ទុគលកៈមិនស្គាល់ដើមគគីរថាជាដើមអ្វីព្រោះឈើចាប់ខ្លាំង បានទទួលទុក្ខវេទនាទើបកន្ទុក់កន្ទេញដោយគាថានេះ ។

ខទិរវនិយៈស្តាប់ពាក្យរៀបរាប់របស់កន្ទុគលកៈហើយ ទើបពោលគាថាទីពីរថា

ឱហ្ន៎ ត្រសេះនេះកាលចោះនូវឈើក្នុងព្រៃទាំងឡាយ បានហើរ

ទៅក្នុងពួកឈើមិនមានខ្លឹមជាចំណែកនៃឈើស្ងួត ក្នុងកាលជា

ខាងក្រោយមកត្រសេះ ( នេះ ) បានហើរមកទម្លាយអំបែង

ក្បាល ( របស់ខ្លួន ) នឹងដើមសង្កែជាឈើមានខ្លឹមអំពី

កំណើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អចារិ វតាយំ** បានដល់ កន្ទុគលកៈនេះ បានត្រាច់ទៅ ។ បទថា **វិតុទំ វនានិ** សេចក្តីថា ចោះ គឺចឹកឈើមិនមានខ្លឹមដូចជាដើមរកា ដើមល្ហុសផ្អុងជាដើម ។ បទថា **កដ្ឋង្គរុក្ខេសុ** បានដល់ ឈើស្ងួត ។ បទថា **អសារកេសុ** បានដល់ ជាឈើមិនមានខ្លឹម មានដើមល្ហុសផ្អុងនិងដើមរកាជាដើម ។

បទថា **អថាសទា ខទិរំ ជាតសារំ** សេចក្តីថា ខាងក្រោយមកជួបដើមគគីរមានខ្លឹមតាំងពីនៅតូច ។ បទថា **យត្ថព្ភិទា** ក្នុងបទថា **យត្ថព្ភិទា គរុឡោ ឧត្តមង្គំ** បានដល់ ចោះ គឺចឹកដើមឈើណា ។

ខទិរវនិយៈពោលនឹងកន្ទុគលកៈនោះថា នែកន្ទុគលកៈ ដើមគគីរនេះជាឈើខ្លឹមដែលធ្វើឲ្យខួរក្បាលចេញមក ។ កន្ទុគលកៈបានដល់នូវការស្លាប់ក្នុង

ទីនោះឯង ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កន្ទុគលកៈក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកខទិរវនិយៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កន្ទុគលកជាតក ចប់**

**នតំទឡ្ហវគ្គ ចប់**

# ពីរណាគ្គម្ភកវគ្គ

## សោមទត្តជាតក

[ ២៧១ ] ( ពោធិសត្វពោលថាបពិត្រលោកអាពុក ) លោកមិនមានសេចក្តីធ្វេសប្រហែសជានិច្ច បានធ្វើសេចក្តីព្យាយាមក្នុងព្រៃស្មសានដ៏ដេរដាសដោយគុម្ពនៃស្បូវរណ្តាសអស់ ១ ឆ្នាំ ( កាលបើដូច្នេះ ) លោកចូរទៅកាន់បរិសទ្យហើយធ្វើ ( នូវហេតុនោះ ) ឲ្យទៅជាហេតុដទៃវិញ សេចក្តីព្យាយាមរមែងមិនរក្សានូវបុគ្គលដែលឥតប្រាជ្ញាឡើយ ។

[ ២៧២ ] ( ព្រាហ្មណ៍ពោលថា ) ម្នាលសោមទត្តជាកូន ធម្មតាជនអ្នកសូមគេរមែងដល់នូវហេតុ ២ យ៉ាង គឺមិនបាននូវទ្រព្យ ១ បាននូវទ្រព្យ ១ ព្រោះថា ការសូមគេរមែងមានសភាពយ៉ាងនេះជាធម្មតា ។

**ចប់ សោមទត្តជាតកទី ១ ។**

# ពីរណាចម្ភវគ្គ

## អដ្ឋកថា សោមទត្តជាតក

[ ២៧១-២៧២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោឡុទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អកាសិ យោគ្គំ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ព្រះលោឡុទាយិត្ថេរនោះមិនអាចនឹងពោលពាក្យសូម្បីតែមួយឲ្យសម្រេចក្នុងរវាងជន ២-៣ នាក់ ជាអ្នកខ្មាស់ខ្មោះគិតនឹង

និយាយពាក្យមួយត្រឡប់ទៅជាពោលពាក្យដទៃទៅវិញ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាដល់រឿងរបស់ព្រះថេរៈនោះ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡុទាយីនេះមិនមែនជាមនុស្សឡេះឡោះតែក្នុងកាលឥឡូវនេះទេសូម្បីក្នុងកាលមុនក៏ជាអ្នកឡេះឡោះដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍មួយក្នុងដែនកាសី កាលចម្រើនវ័យរៀនសិប្បៈក្នុងនគរតក្កសិលា កាលសម្រេចហើយទើបត្រឡប់មកផ្ទះដឹងថាមាតាបិតាក្រីក្រគិតថា អញនឹងលើកស្ទួយត្រកូលដែលទាបទើបលាមាតាបិតាទៅទទួលរាជការក្នុងក្រុងពារាណសី ព្រះពោធិសត្វ ជាទីពេញព្រះហឫទ័យរបស់ព្រះរាជា ។ កាលនោះឪពុករបស់ព្រះពោធិសត្វគួរស្រែចិញ្ចឹមជីវិតដោយគោ ២ គោ ១ ក៏ស្លាប់ទៅ ។ ទើបបិតាចូលទៅរកព្រះពោធិសត្វហើយពោលថា នែកូន គោស្លាប់ ១ ហើយធ្វើកសិកម្មមិនបាន ចូរកូនសូមគោអំពីព្រះរាជា ១ ចុះ ព្រះពោធិសត្វពោលថា បពិត្រលោកឪពុក កូនទើបតែទទួលរាជការបើទូលសូមគោមិនសមគួរ សូមលោកឪពុកទូលសូមឯងចុះ ។ ព្រាហ្មណ៍ពោលថា នែកូន កូនមិនដឹងថាឪពុកជាមនុស្សល្ងង់ខ្លៅទេឬ ក្នុងទីចំពោះមុខជន ២-៣ នាក់ឪពុកមិនអាចពោលបានត្រឹមត្រូវទេ បើឪពុកទៅ

គាល់ព្រះរាជាទូលសូមគោឪពុកនឹងថ្វាយគោនេះក៏ថាបាន ។ ព្រះពោធិសត្វពោលថា តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនអាចទូលសូមគោបានឡើយណ្ហើយចុះ ខ្ញុំនឹងបង្រៀនលោកឪពុក ។ ព្រាហ្មណ៍ពោលថា បើដូច្នោះចូរកូនបង្រៀនពុកឲ្យល្អក៏ជាការស្រេច ។ ព្រះពោធិសត្វនាំឪពុកទៅកាន់ព្រៃខ្មោចឈ្មោះពីរណត្ថម្ភកៈ ក្ដួចស្បូវរណ្ដាសទុកតាមកន្លែងសន្មតឈ្មោះប្រាប់ឪពុកតាមលំដាប់ថា នេះព្រះរាជា នេះឧបរាជ នេះសេនាបតី ហើយពោលថាបពិត្រលោកឪពុក កាលលោកទៅគាល់ព្រះរាជា ចូរក្រាបថ្វាយបង្គំរួចថ្វាយព្រះពរថា សូមទ្រង់មានជ័យជម្នះចុះ ហើយសឹមពោលគាថានេះដើម្បីសូមគោ ។ ព្រះមហាសត្វឲ្យបិតារៀនគាថាដូច្នេះថា

បពិត្រមហារាជ ទូលព្រះបង្គំមានគោសម្រាប់ភ្ជួរ ២ បណ្ដា
គោទាំងនោះគោ ១ ស្លាប់ហើយសូមទ្រង់ព្រះរាជទានគោឲ្យ
បានជាគម្រប់ ២ ដូច្នេះ ។

ព្រាហ្មណ៍រៀនគាថានេះបានស្ទាត់ជំនាញអស់កាលមួយឆ្នាំហើយទើបប្រាប់ព្រះពោធិសត្វថា សោមទត្តកូន ឪពុកចាំគាថាបានស្ទាត់ហើយ ឥឡូវនេះពុកអាចពោលបានមិនថាក្នុងសម្នាក់បុគ្គលណាម្នាក់ ចូរកូននាំឪពុកទៅគាល់ព្រះរាជាចុះ ព្រះពោធិសត្វទទួលថា សាធុ ទើបឲ្យរៀបចំគ្រឿងបណ្ណាការនាំឪពុកទៅគាល់ព្រះរាជា ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់មានជ័យជម្នះ ហើយទូលថ្វាយគ្រឿងបណ្ណាការ ។ ព្រះរាជាត្រាស់ថានែសោមទត្ត ព្រាហ្មណ៍នេះជាអ្វីនឹងអ្នក ព្រះពោធិសត្វទូលថា បពិត្រព្រះ

សម្មតិទេព ព្រាហ្មណ៍នេះជាឪពុករបស់ទូលព្រះបង្គំ ។ ព្រះរាជាត្រាស់សួរថា មកមានការអ្វី ខណៈនោះព្រាហ្មណ៍ទូលសូមគោថា

បពិត្រមហារាជ ទូលព្រះបង្គំមានគោសម្រាប់ភ្ជួរ ២ ក្នុងគោ ២ នោះគោ ១ ស្លាប់ហើយសូមទ្រង់ទទួលយកគោទី ២ ទៅចុះ ដូច្នេះ ។

ព្រះរាជាទ្រង់ជ្រាបថា ព្រាហ្មណ៍និយាយខុស ទ្រង់ព្រះសំណើចត្រាស់សួរថា សោមទត្តក្នុងផ្ទះរបស់អ្នកប្រហែលជាមានគោច្រើនឬ សោមទត្តក្រាបទូលថា បពិត្រមហារាជ ទ្រង់ព្រះរាជទានហើយទើបមានច្រើន ។ ព្រះរាជាប្រោសប្រាណព្រះពោធិសត្វព្រះរាជទានគោ ១៦ និងគ្រឿងប្រដាប់និងផ្ទះសម្រាប់នៅជារង្វាន់ផងដែរ ហើយទ្រង់បញ្ជូនព្រាហ្មណ៍ទៅដោយយសធំ ព្រាហ្មណ៍ឡើងរថទឹមដោយសេះពណ៌សសុទ្ធ បានទៅព្រមដោយបរិវារធំ ។ ព្រះពោធិសត្វអង្គុយក្នុងរថជាមួយបិតាពោលថា បពិត្រលោកឪពុក ខ្ញុំបង្រៀនមកអស់កាលមួយឆ្នាំ តែលោកឪពុក កាលពោលមែនទែនបែរជាទូលថ្វាយគោដល់ព្រះរាជាហើយពោលគាថាទីមួយថា

បពិត្រលោកអាពុក លោកមិនមានសេចក្ដីធ្វេសប្រហែសជានិច្ច បានធ្វើសេចក្ដីព្យាយាមក្នុងព្រៃស្មសាន ដ៏ដេរដាសដោយគុម្ពនៃស្បូវរណ្ដាសអស់ ១ ឆ្នាំ ( កាលបើដូច្នេះ ) លោកចូរទៅកាន់បរិសទ្យហើយធ្វើ ( នូវហេតុនោះ ) ឲ្យទៅជាហេតុដទៃវិញ សេចក្ដីព្យាយាមរមែងមិនរក្សានូវបុគ្គលដែល

ឥតប្រាជ្ញាឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អកាសិ យោគ្គំ ធុវមប្បមត្តោ សំវច្ឆរំ ពីរណត្ថម្ភកស្មឹ** សេចក្តីថា បពិត្រលោកឪពុក ពុកមិនប្រមាទជានិច្ចបាន ធ្វើនូវការសិក្សាក្នុងព្រៃខ្មោចឈ្មោះពីរណត្ថម្ភកៈអស់មួយឆ្នាំ ។ បទថា **ព្យាកាសិ អញ្ញំ បរិសំ វិគយ្ហ** កាលឪពុកចូលជំនុំបរិស័ទ បានធ្វើនូវហេតុនោះឲ្យទៅជាហេតុដទៃវិញ គឺធ្វើខុសបានដល់ប្តូរទៅជាដទៃ ។ បទថា **ន និយ្យមោ តាយតិ អប្បបញ្ញំ** សេចក្តីថា សេចក្តីព្យាយាម រមែងមិនការពារ គឺមិនរក្សាបុគ្គលដែលអប្បឥតប្រាជ្ញាឡើយ ។ ព្រាហ្មណ៍ស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយទើបពោលគាថាទីពីរថា

ម្នាលសោមទត្តជាកូន ធម្មតាជនអ្នកសូមគេ រមែងដល់នូវហេតុ
២ យ៉ាងគឺ មិនបាននូវទ្រព្យ ១ បាននូវទ្រព្យ ១ ព្រោះថា
ការសូមគេរមែងមានសភាពយ៉ាងនេះជាធម្មតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវំ ធម្មា ហិ យាចនា** បានដល់ ព្រោះការសូមគេមានសភាពយ៉ាងនេះជាធម្មតា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡុទាយីមិនមែនឡេះឡោះក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ជាអ្នកឡេះឡោះដូចគ្នា ។

ព្រះសាស្តាលុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា បិតារបស់សោមទត្តក្នុងកាលនោះ បានមកជាលោឡុទាយីក្នុងកាលឥឡូវនេះ ចំណែកសោមទត្តក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាសោមទត្តជាតក ចប់**

# ឧច្ឆិដ្ឋភត្តជាតក

*[ ២៧៣ ] ( ព្រាហ្មណ៍ពោលថា ) អាការខាងលើដទៃ អាការខាងក្រោមដទៃ ម្នាលនាងព្រាហ្មណី អញសួរចំពោះនាងថា បាយខាងក្រោមតើដូចម្តេច បាយខាងលើតើដូចម្តេច ។*

*[ ២៧៤ ] ( កូនអ្នករបាំពោធិសត្វពោលថា ) ម្នាលអ្នកដ៏ចម្រើន ខ្ញុំអ្នករបាំ ជាអ្នកសូម មកដល់ក្នុងទីនេះ ឯសហាយរបស់នាងព្រាហ្មណីនេះ ចុះទៅហើយកាន់ជង្រុក អ្នកស្វែងរកនូវបុរសណា បុរសនោះនេះឯង ។*

***ចប់ ឧច្ឆិដ្ឋភត្តជាតកទី ២ ។***

## អដ្ឋកថា

## ឧច្ឆិដ្ឋភត្តជាតក

*[ ២៧៣-២៧៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់បុរាណទុតិយិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អញ្ញោ ឧបរិមោវណ្ណោ** *ដូច្នេះជាដើម ។*

*មានសេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គ ព្រះសាស្តាត្រាស់សួរថា អ្នកណាធ្វើឲ្យអ្នកអផ្សុក ទើបក្រាបទូលថា អតីតកិរិយារបស់ខ្ញុំព្រះអង្គ លំដាប់នោះព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្រីនេះជាអ្នកធ្វើនូវសេចក្តីវិនាសឲ្យដល់អ្នក តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន*

ទេសូម្បីក្នុងកាលមុនបានឲ្យអ្នកបរិភោគអាហាររបស់ប្រុសសហាយ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលអ្នករបាំក្រីក្រ ត្រាច់សូមអាហារដើម្បីចិញ្ចឹមជីវិតក្នុងត្រកូលមួយ ។ កាលចម្រើនធំធាត់ជាអ្នកក្រីក្រ រូបអាក្រក់ដើរសូមភិក្ខាចិញ្ចឹមជីវិត ។ ក្នុងកាលនោះ ព្រាហ្មណីរបស់ព្រាហ្មណ៍ម្នាក់ក្នុងដែនកាសីជាស្រីទ្រុស្តសីល លាមក ប្រព្រឹត្តក្រៅចិត្តប្តី ។

ថ្ងៃមួយកាលព្រាហ្មណ៍ទៅធ្វើការងារក្រៅផ្ទះ ប្រុសកំណាន់របស់ព្រាហ្មណីបានឱកាសទើបចូលទៅកាន់ផ្ទះនោះ ។ នាងប្រព្រឹត្តក្រៅចិត្តជាមួយប្រុសកំណាន់ហើយពោលថា អញ្ជើញបរិភោគអាហារបន្តិចសិនសឹមទៅ រៀបចំអាហារក្តៅៗ មួយអន្ទើដោយសូបព្យញ្ជនៈ ( សម្ល ទឹកនិងសម្លគោក ) ឲ្យសហាយនោះបរិភោគហើយនាងឈរត្រង់ទ្វារចាំមើលព្រាហ្មណ៍ត្រឡប់មក ។ ព្រះពោធិសត្វឈររង់ចាំសូមបាយដែលប្រុសកំណាន់របស់ព្រាហ្មណីបរិភោគ ។ គ្រានោះព្រាហ្មណ៍ដើរតម្រង់មកផ្ទះព្រាហ្មណីឃើញព្រាហ្មណ៍មកទើបប្រញាប់ទៅប្រាប់ថា ក្រោកឡើងព្រាហ្មណ៍កំពុងមកហើយឲ្យសហាយចូលក្នុងជង្រុកស្រូវ ។ នៅពេលដែលព្រាហ្មណ៍ចូលទៅអង្គុយហើយទើបនាងយកបន្ទះក្តារទៅឲ្យ ឲ្យទឹកលាងដៃ ដួសបាយក្តៅដាក់ពីលើបាយដែលត្រជាក់ដែលសល់ពីសហាយបរិភោគដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍លូកដៃក្នុងបាយឃើញបាយខាងលើក្តៅខាងក្រោមត្រជាក់ទើបគិតថា ប្រហែលជាបាយដែលសល់អំពី

មនុស្សដទៃ ព្រាហ្មណ៍កាលសួរព្រាហ្មណីទើបពោលគាថាទីមួយថា

អាការខាងលើដទៃ អាការខាងក្រោមដទៃ ម្នាលនាងព្រាហ្មណី អញសួរចំពោះនាងថា បាយខាងក្រោមតើដូចម្ដេច បាយខាង លើតើដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វណ្ណោ** គឺ អាការព្រោះព្រាហ្មណ៍កាលនឹងសួរភាពដែលបាយខាងលើក្ដៅ ខាងក្រោមត្រជាក់ ទើបពោលយ៉ាងនេះ ។ បទថា **កឹ ហេដ្ឋា កិញ្ច ឧបរិ** សេចក្ដីថា នៃនាង ធម្មតាបាយដែលដួសខាងលើគួរតែត្រជាក់ ខាងក្រោមគួរតែក្ដៅ តែនេះមិនដូច្នោះឡើយ ព្រោះហេតុនោះទើបអញសួរនាង ព្រោះហេតុអ្វីទើបបាយខាងលើក្ដៅ បាយខាងក្រោមត្រជាក់ ។

ព្រាហ្មណីកាលព្រាហ្មណ៍សួររឿយៗ ក៏នៅស្ងៀម ព្រោះក្រែងខ្លាចកម្មដែលខ្លួនធ្វើប្រាកដឡើង ។ ក្នុងខណៈនោះ កូនអ្នករបាំគិតថា បុរសដែលស្រីនេះឲ្យទៅអង្គុយក្នុងជង្រុកប្រហែលជាសហាយ បុរសនេះគង់ជាម្ចាស់ផ្ទះ ព្រាហ្មណីមិនពោលពាក្យណាមួយ ព្រោះខ្លាចកម្មដែលខ្លួនធ្វើប្រាកដ ណ្ហើយចុះ អញនឹងប្រកាសកម្មរបស់ស្រីនេះនិងប្រាប់ដល់ភាពដែលប្រុសកំណាន់ពួនក្នុងជង្រុកដល់ព្រាហ្មណ៍ទើបកូនអ្នករបាំប្រាប់ព្រឹត្តិកម្មទាំងអស់តាំងអំពីព្រាហ្មណ៍ចេញអំពីផ្ទះទៅ ប្រុសកំណាន់ចូលទៅក្នុងផ្ទះប្រព្រឹត្តកន្លង បរិភោគអាហារយ៉ាងសប្បាយ ព្រាហ្មណីឈរមើលត្រង់ទ្វារ រហូតដល់ប្រុសកំណាន់ត្រូវចូលក្នុងជង្រុកហើយពោលគាថាទីពីរថា

ម្នាលអ្នកដ៏ចម្រើន ខ្ញុំអ្នករបាំ ជាអ្នកសូម មកដល់ក្នុងទីនេះ
ឯសហាយរបស់នាងព្រាហ្មណីនេះ ចុះទៅហើយកាន់ជង្រុក
អ្នកស្វែងរកនូវបុរសណា បុរសនោះនេះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហំ ឆដោស្មិ ភទ្ទន្តេ** សេចក្តីថា បពិត្រលោកម្ចាស់ ខ្ញុំជាអ្នករបាំកំព្រា ។ បទថា **ភិក្ខកោស្មិ ឥធាគតោ** សេចក្តីថា ខ្ញុំត្រាច់សូមមកដល់ទីនេះ ។ បទថា **អយំ ហិ កោដ្ឋមោតិណ្ណោ** សេចក្តីថា ប្រុសកំណាន់របស់ស្រីនេះកំពុងបរិភោគអាហារ ចុះទៅពួនក្នុងជង្រុកព្រោះខ្លាចលោក ។ បទថា **អយំ សោ យំ គវេសសិ** សេចក្តីថា បុរសនោះឯង គឺបុរសដែលលោកត្រិះរិះថា បាយសល់ដែលនេះជារបស់អ្នកណាហ្ន៎ ។ សូមលោកចាប់ផ្នួងសក់ប្រុសកំណាន់នោះហើយវាយនាំចេញអំពីជង្រុក ទូន្មានកុំឲ្យធ្វើយ៉ាងនេះទៀត ព្រះពោធិសត្វពោលហើយក៏ចៀសចេញទៅ ។ ព្រាហ្មណ៍ទូន្មានជនទាំង ២ កុំឲ្យធ្វើអំពើអាក្រក់បែបនេះទៀតដោយការសម្លុតនិងការវាយ ។ លុះអស់អាយុក៏ទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណីក្នុងកាលនោះ បានមកជាភរិយាចាស់ក្នុងកាលឥឡូវនេះ ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក ចំណែកកូនអ្នករបាំក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ឧច្ចិដ្ឋភត្តជាតក ចប់**

## ភរុរាជជាតក

[ ២៧៥ ] ( ព្រះសាស្តាត្រាស់ថា ) តថាគតបានឮដូច្នេះថា ស្តេចនៅក្នុងដែនភរុបានធ្វើនូវទោសដល់ពួកឥសី ស្តេចនោះ ( ដល់នូវឆន្ទាគតិ ) ក៏ដាច់សូន្យព្រមទាំងដែនដល់នូវសេចក្តីវិនាស ។

[ ២៧៦ ] ព្រោះហេតុនោះអ្នកប្រាជ្ញទាំងឡាយ តែងមិនសរសើរនូវការលុះក្នុងឆន្ទាគតិ ( បុគ្គល ) មានចិត្ត គឺកិលេសមិនប្រទូស្តហើយគប្បីពោលនូវវាចាដែលប្រកបដោយសច្ចៈ ។

**ចប់ ភរុរាជជាតកទី ៣ ។**

## អដ្ឋកថា

## ភរុជាតក

[ ២៧៥-២៧៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្តេចកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឥសីនមន្តរំ កត្វា** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា លាភនិងសក្ការៈបានកើតឡើងជាច្រើនដល់ព្រះដ៏មានព្រះភាគនិងភិក្ខុសង្ឃ ។ ដូចព្រះធម្មសង្គាហកាចារ្យពោលទុក ( ក្នុងខុទ្ទកនិកាយឧទាន ) ថា សម័យនោះឯងព្រះមានព្រះភាគ គេធ្វើសក្ការៈគោរពរាប់អានបូជាកោតក្រែង បានចីវរបិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប្រក្រតី ។ សូម្បីភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈគោរពរាប់អានបូជា

កោតក្រែង បានចីវរបិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារដែរ ។ ចំណែកពួកបរិព្វាជកអន្យតិ្ថិយគេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរបិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប្រក្រតីឡើយ ដូច្នេះ ។

ពួកបរិព្វាជកទាំងនោះសាបសូន្យចាកលាភនិងសក្ការៈយ៉ាងនេះ ទើបប្រជុំប្រឹក្សាគ្នាទាំងពេលថ្ងៃ និងពេលយប់ថា តាំងអំពីព្រះសមណគោតមកើតឡើងមក ពួកយើងសាបសូន្យចាកលាភនិងសក្ការៈ ព្រះសមណគោតមបែរជាបានលាភនិងយសដ៏លើសលន់ សម្បត្តិនេះ កើតដល់ព្រះសមណគោតមដោយហេតុអ្វីហ្ន៎ ក្នុងពួកបរិព្វាជកទាំងនោះពួកខ្លះពោលយ៉ាងនេះថា ព្រះសមណគោតមបានធ្វើវត្ថុស្អាតល្អជាទីរីករាយនៃអ្នកជម្ពូទ្វីបទាំងមូល ហេតុនោះទើបលាភសក្ការៈកើតដល់សមណគោតម ។ ពួកដ៏សេសពោលថា នុ៎ះក៏មានហេតុផល សូម្បីពួកយើង បើធ្វើអារាមតិត្ថិយខាងក្រោយវត្តជេតពនមហាវិហារ ក៏គង់មានលាភយ៉ាងនោះដែរ ។ ពួកបរិព្វាជកទាំងអស់យល់ឃើញថានឹងធ្វើយ៉ាងនោះទើបសម្រេចថា បើពួកយើងមិនក្រាបទូលព្រះរាជាជាមុន សាងអារាមពួកភិក្ខុនឹងរាំងបាន ធម្មតាអ្នកបានសំណូកហើយ នឹងផាករមិនមាន ព្រោះហេតុនោះ យើងនឹងថ្វាយសំណូកដល់ព្រះរាជាហើយនឹងសូមធ្វើអារាម ទើបសំណូមពរពួកឧបដ្ឋាកទាំងឡាយ រួបរួមទ្រព្យបានមួយសែន ថ្វាយដល់ព្រះរាជាហើយក្រាបទូលថា មហាបពិត្រ អាត្មាភាពទាំងឡាយនឹងសាងអារាមតិត្ថិយខាងក្រោយវត្តជេតពនមហាវិហារ បើពួកភិក្ខុមកថ្វាយព្រះពរដល់ទ្រង់

ថា មិនព្រមឲ្យធ្វើ សូមមហាបពិត្រ កុំឲ្យពាក្យធ្វើយដល់ភិក្ខុទាំងនោះ ។

ព្រះរាជាទ្រង់ទទួលពាក្យព្រោះចំណង់ក្នុងសំណូក ពួកតិរ្ថិយកាលថ្វាយសំណូកព្រះរាជាហើយទើបហៅជាងមកផ្តើមធ្វើការកសាង មានសំឡេងអឺងកងឡើង ។

សាស្តាត្រាស់សួរថា អានន្ទ នុ៎ះសំឡេងអ្វី គឹកកងគោឡោ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយឲ្យសាងអារាមតិរ្ថិយ ខាងក្រោយវត្តជេតពនទើបមានសំឡេងខ្លាំងក្នុងទីនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ទីនោះមិនសមគួរដល់អារាមតិរ្ថិយឡើយ ពួកតិរ្ថិយ ចូលចិត្តសំឡេងអូអរ ភិក្ខុសង្ឃមិនអាចនៅរួមជាមួយតិរ្ថិយទាំងនោះបានទើបឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទូលព្រះរាជាឲ្យទ្រង់បញ្ឈប់ការសាងអារាមតិរ្ថិយ ។ ភិក្ខុសង្ឃទទួលព្រះពុទ្ធតម្រាស់ ហើយទៅឈរត្រង់ទ្វារព្រះរាជវាំង ព្រះរាជាទ្រង់ជ្រាបថាសង្ឃមកទ្រង់ត្រិះរិះថា ពួកភិក្ខុគង់មកព្រោះរឿងអារាមតិរ្ថិយ ព្រោះទ្រង់ទទួលសំណូកទើបឲ្យរាជបុរសទៅប្រាប់ថា ព្រះរាជាមិនប្រថាប់នៅក្នុងវាំង ទើបភិក្ខុទាំងនោះទៅក្រាបទូលដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ព្រះរាជាទ្រង់ធ្វើយ៉ាងនេះព្រោះទ្រង់ទទួលសំណូកទើបបញ្ជូនអគ្គសាវកទាំង ២ ទៅ ។ ព្រះរាជាទ្រង់ឮថា អគ្គសាវកទាំង ២ រូបមកទើបឲ្យរាជបុរសទៅប្រាប់យ៉ាងនោះដូចគ្នា អគ្គសាវកទាំង ២ មកក្រាបទូលព្រះសាស្តា ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្តពេលនេះព្រះរាជានឹងមិនបានប្រថាប់គង់ក្នុងព្រះរាជវាំងទេ ទ្រង់នឹងចេញទៅ

ខាងក្រៅ ។ ស្អែកឡើងក្នុងវេលាព្រឹកព្រះសាស្តាស្លៀកស្បង់កាន់បាត្រចីវរ យាងទៅកាន់ទ្វារព្រះរាជវាំងជាមួយភិក្ខុ ៥០០ រូប ព្រះរាជាទ្រង់បានស្តាប់ប៉ុណ្ណោះក៏ចុះចាកប្រាសាទទទួលបាត្រនិមន្តព្រះសាស្តាឲ្យយាងចូលទៅហើយ ទ្រង់ថ្វាយយាគូនិងភត្ត ថ្វាយបង្គំព្រះសាស្តា គង់ប្រថាប់ក្នុងចំណែកម្ខាង ។ ព្រះមុនី ទ្រង់នាំព្រះធម្មទេសនា ដោយបរិយាយមួយមកសម្តែងដល់ព្រះរាជាថា មហាបពិត្រ ព្រះរាជាក្នុងកាលមុនក៏ទទួលសំណូក ហើយធ្វើអ្នកមានសីលទាំងឡាយឲ្យឈ្លោះគ្នា មិនជាម្ចាស់នៃដែនរបស់ខ្លួនបានដល់នូវសេចក្តីវិនាសធំ ព្រះរាជាក្រាបទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលមានព្រះរាជាព្រះនាមថា កុរុរាជ សោយរាជសម្បត្តិក្នុងដែនកុរុ កាលនោះព្រះពោធិសត្វជាតាបស ជាគ្រូប្រចាំគណៈបានអភិញ្ញា ៥ និងសមាបត្តិ ៨ ចោមរោមទៅដោយតាបស ៥០០ នៅក្នុងហិមវន្តប្បទេសអស់កាលដ៏យូរ ។ ចេញអំពីហិមវន្តប្បទេសដើម្បីបរិភោគរសជូរប្រៃ បានទៅដល់កុរុនគរដោយលំដាប់ និមន្តបិណ្ឌបាតក្នុងនគរនោះហើយ ចេញអំពីនគរអង្គុយត្រង់គល់ជ្រៃដែលសម្បូរដោយមែកនិងប្រគាប ត្រង់ខ្លោងទ្វារទិសខាងជើង ធ្វើភត្តកិច្ចស្រេចហើយអាស្រ័យនៅត្រង់គល់ឈើនោះឯង ។ លុះគណៈឥសីនោះនៅក្នុងទីនោះកន្លងទៅបានកន្លះខែ គ្រូប្រចាំគណៈម្នាក់ទៀតមានបរិវារ ៥០០ មកត្រាច់ភិក្ខាក្នុងនគរនោះដែរ ។ កាលចេញអំពីនគរហើយ អង្គុយត្រង់គល់ជ្រៃដូចគ្នាដែលស្ថិតនៅត្រង់ខ្លោងទ្វារទិសខាងត្បូង ធ្វើភត្តកិច្ច

ស្រេចហើយនៅអាស្រ័យក្នុងទីនោះឯង ។ គណៈឥសីទាំង ២ នោះស្នាក់នៅតាមគាប់ចិត្តក្នុងទីនោះហើយក៏ត្រឡប់ចូលទៅកាន់ហិមវន្តប្បទេសវិញ ។ កាលគណៈឥសីទាំងនោះទៅហើយដើមជ្រៃទិសខាងត្បូងក៏ស្វិតស្រពោន កាលឥសីទាំងនោះមកម្តងទៀត ឥសីដែលតែងសម្រាកត្រង់ដើមជ្រៃទិសខាងត្បូងមកដល់មុនដឹងថាដើមឈើរបស់ខ្លួនងាប់ ត្រាច់បិណ្ឌបាត ចេញអំពីនគរមកត្រង់គល់ឈើនាទិសឧត្តរ ធ្វើកត្តកិច្ចស្រេចហើយស្នាក់នៅក្នុងទីនោះឯង ។ ឯឥសីមួយពួកទៀតមកដល់ឯក្រោយ ត្រាច់ភិក្ខាក្នុងនគរហើយទៅកាន់គល់ឈើរបស់ខ្លួនធ្វើកត្តកិច្ចស្រេចហើយក៏សម្រាក ពួកឥសីទាំង ២ គណៈឈ្លោះគ្នាព្រោះដើមឈើថា ដើមឈើរបស់យើង ដើមឈើរបស់យើង ក៏កើតនូវជម្លោះយ៉ាងធំ ឥសីមួយពួកពោលថា ពួកអ្នកយកទីលំនៅរបស់យើងដែលធ្លាប់នៅពីមុនមិនបាន ។ ឥសីមួយពួកទៀតពោលថា ពួកយើងមកដល់ទីនេះមុន ពួកអ្នកយកមិនបាន ឥសីទាំងនោះក៏ប្រកែកគ្នាថា ពួកយើងជាម្ចាស់ ពួកយើងជាម្ចាស់ដូច្នេះហើយនាំគ្នាទៅកាន់រាជត្រកូលដើម្បីត្រូវការគល់ឈើ ។ ព្រះរាជាទ្រង់កាត់ឲ្យគណៈឥសី ដែលមកមុនជាម្ចាស់ ចំណែកឥសីមួយពួកទៀតគិតថា ពួកយើងមិនព្រមឲ្យអ្នកណាពោលថា ពួកយើងត្រូវពួកឥសីទាំងនេះឲ្យចាញ់បានទើបប្រមើលដោយទិព្វចក្ខុ ឃើញបន្ទុំរថមួយសម្រាប់ស្តេចចក្រពត្តិទ្រង់ប្រើប្រាស់ ទើបនាំមកថ្វាយជាសំណូកដល់ព្រះរាជា នាំគ្នាថ្វាយព្រះពរថា បពិត្រមហារាជ សូមទ្រង់កាត់ក្តីឲ្យពួកអាត្មាជាម្ចាស់ផងចុះ ព្រះរាជាទ្រង់ទទួលសំណូកហើយទ្រង់កាត់ឲ្យឥសីទាំង ២ គណៈថា ចូរនៅ

រួមគ្នាទាំង ២ គណៈចុះ ។ ឥសីមួយពួកទៀតនាំខ្នងកង់របស់រថនោះមក ថ្វាយជាសំណូកហើយទូលថា បពិត្រមហារាជ សូមទ្រង់កាត់សម្រេចឲ្យពួកអាត្មាជាម្ចាស់របស់ចុះ ។ ព្រះរាជាទ្រង់ធ្វើតាមនោះ ។ គណៈឥសីមានការក្តៅក្រហាយចិត្តថា ពួកយើងលះវត្ថុកាមនិងកិលេសកាមចេញបួស ឈ្លោះគ្នាព្រោះដើមឈើជាហេតុ ជាការមិនសមគួរ ទើបប្រញាប់គេចទៅកាន់ហិមវន្តប្បទេស ។ ទេវតាដែលអាស្រ័យនៅក្នុងកុរុរដ្ឋទាំងមូលរួមគ្នាក្រោធខឹងនឹងព្រះបាទកុរុថា ព្រះរាជាធ្វើឲ្យអ្នកមានសីលឈ្លោះគ្នាជាការមិនសមគួរ ទើបបណ្តាលឲ្យដែនកុរុរដ្ឋដែលមានទំហំ ៣០០ យោជន៍ក្លាយជាមហាសមុទ្ទដល់នូវសេចក្តីវិនាស ។ អ្នកដែនទាំងមូលដល់នូវសេចក្តីវិនាស ព្រោះអាស្រ័យព្រះបាទកុរុរាជមួយអង្គដោយប្រការដូច្នេះ ។

ព្រះសាស្តា ទ្រង់នាំយករឿងក្នុងអតីតមក ទ្រង់ត្រាស់ដឹងហើយបានត្រាស់គាថាទាំងនេះថា

តថាគតបានឮដូច្នេះថា ស្តេចនៅក្នុងដែនកុរុបានធ្វើនូវ
ទោសដល់ពួកឥសី ស្តេចនោះ ( ដល់នូវឆន្ទាគតិ ) ក៏ដាច់
សូន្យព្រមទាំងដែនដល់នូវសេចក្តីវិនាស ។

ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយតែងមិនសរសើរនូវ
ការលុះក្នុងឆន្ទាគតិ ( បុគ្គល ) មានចិត្ត គឺកិលេសមិន
ប្រទូស្តហើយគប្បីពោលនូវវាចាដែលប្រកបដោយសច្ចៈដូច្នេះ។

បណ្តាបទទាំងនោះ បទថា **ឥសីនមន្តរំ កត្វា** សេចក្តីថា បើកឱកាស

ឲ្យដោយអំណាចឆន្ទាគតិ ។ បទថា **កុរុរាជា** គឺ ព្រះរាជាដែនកុរុ ។ បទថា **ឥតិ មេ សុតំ** សេចក្តីថា តថាគតបានឮរឿងនេះមកពីមុនហើយ ។ បទថា **តស្មា ហិ ឆន្ទាគមនំ** សេចក្តីថា ព្រោះព្រះបាទកុរុរាជ ទ្រង់ដល់នូវឆន្ទាគតិ ទើបវិបត្តិព្រមទាំងដែន ដូច្នោះទើបបណ្ឌិតទាំងឡាយមិនសរសើរការដល់នូវឆន្ទាគតិ ។ បទថា **អទុដ្ឋចិត្តោ** សេចក្តីថា បុគ្គលមិនគួរមានចិត្តប្រទូស្តដោយកិលេស គួរពោលពាក្យពិត ។ បទថា **សច្ចូបសញ្ហិតំ** សេចក្តីថា គួរពោលពាក្យដែលអាស្រ័យសភាវៈគឺ អាស្រ័យហេតុ អាស្រ័យផលប៉ុណ្ណោះ ។ ក្នុងជនទាំងនោះជនពួកណាដែលពោលជំទាស់ថា ស្តេចកុរុ-រាជទ្រង់ទទួលសំណូក នេះជាការធ្វើមិនសមគួរឈ្មោះថា ពោលពាក្យដែលអាស្រ័យការពិត ទីកន្លែងសម្រាប់ជនទាំងនោះរស់នៅបានប្រាកដឡើងជាកោះ ១០០០ ក្នុងនាលិកេរទ្វីបរហូតដល់សព្វថ្ងៃនេះ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែង ហើយត្រាស់ថា មហាបពិត្រ មិនគួរលំអៀងដោយឆន្ទាគតិ មិនគួរធ្វើឲ្យបព្វជិតទាំង ២ គណៈឈ្លោះគ្នាហើយទ្រង់ប្រជុំជាតកថា តថាគតបានជាប្រធានគណៈឥសីសម័យនោះ ។ ព្រះរាជាក្នុងកាលដែលព្រះតថាគតសោយភត្តាហារស្រេចហើយយាងត្រឡប់ទៅ បានបញ្ជូនពួករាជបុរសឲ្យទៅរើអាពាមតិត្ថិយ ពួកតិត្ថិយក៏ធ្វើមិនបានដូច្នេះ ។

**អដ្ឋកថា ករុជាតក ចប់**

## បុណ្ណនទីជាតក

[ ២៧៧ ] ( ព្រះរាជាទ្រង់លិខិតក្នុងព្រះរាជសាសន៍ថា ) ជនទាំងឡាយពោលនូវស្ទឹង ដែលល្មមសត្វណាផឹកបាន ថាជាស្ទឹងពេញហើយផង ជនទាំងឡាយពោលនូវសន្ទូង ដែលល្មមសត្វណាពួនបាន ថាជាសន្ទូងកើតហើយផង ជនទាំងឡាយហៅរកនូវបុគ្គលដែលទៅហើយកាន់ទីឆ្ងាយដោយសត្វណាផង សត្វនោះយើងនាំមកហើយដើម្បីអ្នក ម្នាលព្រាហ្មណ៍ចូរអ្នកបរិភោគ ( នូវសាច់ក្អែកនេះ ) ចុះ ។

[ ២៧៨ ] ( ពោធិសត្វពោលថា ) កាលណាស្តេចរព្រកអញសូម្បីតែសាច់ក្អែកក៏ផ្ញើមក ( កាលស្តេចបាន ) ហង្សក្តី ក្រៀលក្តី ក្ងោកក្តី ( ហេតុអ្វីក៏មិនរព្រក ) ការមិនរព្រកនេះឯងជាសេចក្តីលាមកបំផុត ( ក្នុងលោក ) ។

**ចប់ បុណ្ណនទីជាតកទី ៤ ។**

## អដ្ឋកថា

## បុណ្ណនទីជាតក

[ ២៧៧-២៧៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបញ្ញាបារមី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បុណ្ណំ នទី** ដូច្នេះជាដើម ។

សេចក្តីសង្ខេបដូច្នេះថា ថ្ងៃមួយភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាប្រារព្ធបញ្ញាបារមីរបស់ព្រះតថាគតក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសម្មាសម្ពុទ្ធ

មានព្រះបញ្ញាធំ មានព្រះបញ្ញាដ៏ក្រាស់ មានព្រះបញ្ញានាំឲ្យរីករាយ មានព្រះបញ្ញាជាគ្រឿងស្ទុះទៅ មានព្រះបញ្ញាដ៏មុត មានព្រះបញ្ញាដ៏ជ្រាលជ្រៅ មានព្រះបញ្ញាជាគ្រឿងទម្លុះទម្លាយ ។ ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏មានបញ្ញាឈ្លាសក្នុងឧបាយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលបុរោហិត កាលចម្រើនវ័យហើយ រៀនសិប្បៈសម្រេចគ្រប់យ៉ាងក្នុងនគរតក្កសិលា កាលឪពុកស្លាប់ទៅបានតំណែងជាបុរោហិតជាអ្នកទូន្មានអត្ថនិងធម៌ដល់ព្រះបាទពារាណសី ។ ក្នុងកាលតមកព្រះរាជាទ្រង់ជឿពាក្យរបស់អ្នកញុះញង់ ទ្រង់ពិរោធបណ្តេញព្រះពោធិសត្វចេញពីក្រុងពារាណសី ដោយព្រះតម្រាស់ថា អ្នកកុំនៅជិតយើងទៀតឡើយ ។ ព្រះពោធិសត្វនាំបុត្តភរិយាទៅអាស្រ័យក្នុងស្រុកមួយកន្លែងក្នុងដែនកាសី ។ តមកព្រះរាជាទ្រង់រឭកដល់គុណរបស់ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ការដែលអញបញ្ជូនអ្នកណាម្នាក់ទៅហៅអាចារ្យមិនសមគួរ តែអញគួរចងគាថាមួយរចនាអក្សរ ឲ្យស្ងោរសាច់ក្អែកហើយខ្ចប់សំបុត្រនិងសាច់ក្អែកដោយកំណាត់ស ប្រថាប់ត្រាផ្ញើទៅឲ្យ បើបុរោហិតជាអ្នកឈ្លាសអានសំបុត្រ

ហើយដឹងថា សាច់ក្អែកក៏នឹងត្រឡប់មក បើមិនដឹងក៏មិនត្រឡប់ ទ្រង់របនាគាថាមានពាក្យផ្ដើមថា **បុណ្ណំ នទឹ** ជាដើមក្នុងស៊ីករឹតថា

ជនទាំងឡាយពោលនូវស្ទឹងដែលល្មមសត្វណាផឹកបាន ថាជាស្ទឹងពេញហើយផង ជនទាំងឡាយពោលនូវសន្ទូងដែលល្មមសត្វណាពួនបាន ថាជាសន្ទូងកើតហើយផង ជនទាំងឡាយហៅរកនូវបុគ្គលដែលទៅហើយកាន់ទីឆ្ងាយ ដោយសត្វណាផង សត្វនោះយើងនាំមកហើយដើម្បីអ្នក ម្នាលព្រាហ្មណ៍ចូរអ្នកបរិភោគ ( នូវសាច់ក្អែកនេះ ) ចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុណ្ណំ នទឹ យេន ច បេយ្យមាហុ** សេចក្ដីថា ជនទាំងឡាយពោលស្ទឹង ដែលក្អែកផឹកបាន គឺពោលដល់ស្ទឹងដែលពេញហើយក្អែកអាចផឹកបាន ព្រោះស្ទឹងដែលមិនពេញមិនហៅថាល្មមក្អែកផឹកបានទេ កាលណាក្អែកឈរត្រង់ច្រាំងស្ទឹងអាចឱនកផឹកបាន កាលនោះលោកហៅស្ទឹងនោះថា ក្អែកផឹកបាន ។ ពាក្យថា **យវំ** ក្នុងបទថា **ជាតំ យវំ យេវ ច គុយ្ហមាហុ** នេះ ត្រឹមតែជាទេសនាតែក្នុងទីនេះសំដៅយកសន្ទូងខ្ចីដែលកើតដុះជាលសម្បូរគ្រប់ប្រភេទ ។ ព្រោះថា សន្ទូងនោះកាលណាអាចបិទបាំងក្អែកដែលចូលទៅខាងក្នុងបានកាលនោះឈ្មោះថា ក្អែកពួនបាន ។ បទថា **ទូរំ គតំ យេន ច អវ្ហយំ** សេចក្ដីថា បុគ្គលជាទីស្រឡាញ់ទៅឆ្ងាយអស់កាលយូរមែងរឭកដល់គ្នា ព្រោះបានឃើញក្អែកមកទំឬឮសំឡេងក្អែកបួលថា កាកា ក៏និយាយយ៉ាងនេះថា បុគ្គលឈ្មោះនេះគង់

នឹងមកព្រោះក្អែកបួល ។ បទថា **សោ ត្យាភតោ** សេចក្តីថា សត្វនោះ យើងនាំមកហើយដើម្បីអ្នក ។ បទថា **ហន្ទ ច ភុញ្ជ ព្រាហ្មណ** សេចក្តីថា ម្នាលព្រាហ្មណ៍ អញ្ជើញទទួលយកទៅបរិភោគចុះ គឺបរិភោគសាច់ក្អែកនេះចុះ ។

ព្រះរាជាទ្រង់វចនាគាថានេះក្នុងស្លឹករឹត ហើយបញ្ជូនទៅឲ្យព្រះពោធិសត្វ ព្រះពោធិសត្វអានសំបុត្រហើយក៏ជ្រាបថា ព្រះរាជាទ្រង់ត្រូវការជួបអញទើបពោលគាថាទីពីរថា

> កាលណាស្តេចរឭកអញ សូម្បីតែសាច់ក្អែកក៏ផ្ញើមក ( កាលស្តេចបាន ) ហង្សក្តី ក្រៀលក្តី ក្ងោកក្តី ( ហេតុអ្វីក៏មិនរឭក ) ការមិនរឭកនេះឯងជាសេចក្តីលាមកបំផុត ( ក្នុងលោក ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យតោ មំ សរតី រាជា វាយសម្បិ បហេតវេ** សេចក្តីថា កាលណាព្រះរាជាទ្រង់បានសាច់ក្អែករមែងរឭកដល់អញទើបបញ្ជូនសាច់ក្អែកនោះមកឲ្យ ។ បទថា **ហំសា កោញ្ចា មយូរា ច** សេចក្តីថា ក្នុងកាលណាគេនាំសាច់ហង្សជាដើមមកថ្វាយ ទ្រង់បានសាច់ហង្សជាដើមនោះ កាលនោះរឿងអ្វីដែលថាទ្រង់មិនរឭកដល់អញ ។ បទថា **អសតិយេវ បាបិយា** សេចក្តីថា ការបានសាច់អ្វីក៏ដោយហើយរឭកដល់អញនោះជាការប្រពៃ តែមិនរឭកដល់សោះជាអំពើអាក្រក់ក្នុងលោក ព្រោះការមិនរឭកដល់នោះជាអំពើថោកទាប ប៉ុន្តែហេតុនោះមិនបានកើតចំពោះព្រះ

រាជារបស់អញឡើយ ព្រះរាជានៅរឭកដល់អញ ទ្រង់ទន្ទឹងដល់ការគ្រឡប់របស់អញ ព្រោះហេតុនោះអញនឹងទៅ ។

ព្រះពោធិសត្វ បានទឹមយានទៅគាល់ព្រះរាជា ព្រះរាជាសប្បាយព្រះហឫទ័យ តែងតាំងឲ្យជាបុរោហិតវិញ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បុណ្ណនទីជាតក ចប់

## កច្ឆបជាតក

[ ២៧៩ ] ( អាមាត្យពោធិសត្វពោលថា ) អណ្តើកកាលបើឈ្មើខ្លួន ពាំស៊ីប់ហើយហានិយាយសម្លាប់នូវខ្លួនឯង ឈ្មោះថាសម្លាប់ដោយវាចារបស់ខ្លួន ។

[ ២៨០ ] បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងជន ( ឯបណ្ឌិតបុរស ) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចាជាកុសលឲ្យហួសវេលា ព្រះអង្គគង់នឹងទតឃើញអណ្តើកដែលដល់នូវសេចក្តីវិនាសព្រោះតែនិយាយច្រើន ។

**ចប់ កច្ឆបជាតកទី ៥ ។**

## អដ្ឋកថា

## កច្ឆបជាតក

[ ២៧៩-២៨០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកោកាលិកភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អវធិ វត អត្តានំ** ដូច្នេះជាដើម ។

រឿងមានច្បាស់ក្នុងមហាតក្ការិយជាតក ។ ក្នុងគ្រានោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កោកាលិកមិនមែនសម្លាប់ខ្លួនឯងព្រោះតែវាចាក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ កាលមុនក៏សម្លាប់ខ្លួនដោយវាចាដូចគ្នា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ កាលចម្រើនវ័យបានជាអ្នកទូន្មានអត្ថនិងធម៌របស់ព្រះរាជាអង្គនោះ តែព្រះរាជាចូលចិត្តនិយាយច្រើន កាលទ្រង់និយាយ អ្នកដទៃមិនមានឱកាសពោលបានឡើយ ។ ព្រះពោធិសត្វបំណងនឹងឃាត់នូវការនិយាយច្រើនរបស់ព្រះរាជាអង្គនោះ ទើបគិតរកឧបាយណាមួយ ។ ក្នុងកាលនោះមានអណ្តើកមួយអាស្រ័យនៅក្នុងស្រះមួយនាហិមវន្ត-ប្បទេស មានកូនហង្ស ២ រកស៊ីរហូតស្និទ្ធស្នាលជាមួយនឹងអណ្តើក ។ កូនហង្សទាំង ២ នោះស្និទ្ធស្នាលហើយ ថ្ងៃមួយទើបនិយាយនឹងអណ្តើកថា អណ្តើកសម្លាញ់ ត្រង់គុហាមាសលើភ្នំចិត្តកូដនាព្រៃហិមពាន្តរបស់ពួកយើងជាប្រទេសគួររីករាយ ឯងទៅជាមួយខ្ញុំឬទេ អណ្តើកសួរថា ខ្ញុំនឹងទៅបានដូចម្តេច កូនហង្សពោលថា ខ្ញុំនឹងនាំឯងទៅបើឯងរក្សាមាត់បាន ឯងមិនត្រូវនិយាយអ្វីជាមួយបុគ្គលណាឡើយ ។ អណ្តើកឆ្លើយថា បានពួកឯងនាំខ្ញុំទៅចុះ ទើបកូនហង្សទាំង ២ ឲ្យអណ្តើកខាំកំណាត់ឈើមួយ ខ្លួនឯងពាំចុងទាំងសងខាងហើរទៅក្នុងអាកាស ។ ពួកក្មេងអ្នកស្រុកឃើញហង្សនាំអណ្តើកទៅដូច្នោះក៏បន្លឺកឡើងថា ហង្ស ២ នាំអណ្តើកទៅដោយកំណាត់ឈើ អណ្តើកចង់ពោលថា នែក្មេងថោកទាប សម្លាញ់របស់យើងនាំយើងទៅយ៉ាងនេះទើសអ្វីដល់ពួកឯង ទើបលែងកំណាត់ឈើដែលខាំទុកក្នុងកាលដែលដល់ខាងលើព្រះរាជនិវេសន៍ ក្នុងនគរពារាណសី ព្រោះហង្សនាំទៅរហ័សទើបធ្លាក់ពីលើអាកាសបែកជា ២ បំណែកកើតនូវការផ្អើលឆោឡោឡើងថា អណ្តើក

ធ្លាក់អំពីអាកាសបែកជា ២ ។

ព្រះរាជាមានពួកអាមាត្យហែហមទ្រង់នាំព្រះពោធិសត្វទៅ ទ្រង់ដល់ទីនោះ ទតឃើញអណ្ដើកទើបត្រាស់សួរព្រះពោធិសត្វថា នែបណ្ឌិត ហេតុអ្វីទើបអណ្ដើកធ្លាក់មក ។ ព្រះពោធិសត្វគិតថា អញទន្ទឹងមកយូរហើយប្រាថ្នានឹងឲ្យឱវាទដល់ព្រះរាជា កំពុងត្រិះរិះរកឧបាយ អណ្ដើកនេះគង់ស្និទ្ធស្នាលនឹងហង្សទាំង ២ នេះទើបហង្សទាំង ២ ឲ្យអណ្ដើកខាំកំណាត់ឈើដោយបំណងថានឹងនាំទៅកាន់ព្រៃហិមពាន្ត ទើបហើរទៅក្នុងអាកាស អណ្ដើកនេះបានឮពាក្យរបស់អ្នកណាមួយចង់និយាយឆ្លើយឆ្លងបន្តិចបន្តួច ព្រោះខ្លួនមិនបានរក្សាមាត់ទើបលែងកំណាត់ឈើធ្លាក់អំពីអាកាសដល់នូវការស្លាប់ ទើបក្រាបទូលថា បពិត្រមហារាជ ធម្មតាមនុស្សមាត់ច្រើននិយាយមិនចេះចប់រមែងបានទទួលទុក្ខបែបនេះឯងហើយបានពោលគាថាទាំងនេះថា

អណ្ដើកកាលបើឈើខ្លួនពាំស៊ប់ហើយ ហានិយាយសម្លាប់
នូវខ្លួនឯង ឈ្មោះថាសម្លាប់ដោយវាចារបស់ខ្លួន ។
បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងជន ( ឯបណ្ឌិត
បុរស ) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចាជា
កុសលឲ្យហួសវេលា ព្រះអង្គគង់នឹងទតឃើញអណ្ដើកដែល
ដល់នូវសេចក្ដីវិនាសព្រោះតែនិយាយច្រើន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អវធិ វត** បានដល់ បានសម្លាប់ហើយហ្ន៎ ។ បទថា **បព្យាហារំ** បានដល់ ហាមាត់ប្រុងនឹងពោល ។ បទថា **សុគ្គ-**

**ហិតស្មឹ កដ្ឋស្មឹ** សេចក្តីថា កាលកំណាត់ឈើដែលខ្លួនពាំទុកល្អហើយ ។ បទថា **វាចាយ សកិយា វធិ** សេចក្តីថា អណ្តើកកាលបន្ទឺវាចាក្នុងកាលមិនគួរព្រោះភាពដែលខ្លួនចូលចិត្តនិយាយច្រើនទើបលែងឈើដែលពាំឈ្មោះថា សម្លាប់ខ្លួនឯងដោយវាចារបស់ខ្លួន ។ អណ្តើកដល់នូវសេចក្តីស្លាប់ដោយហេតុនេះ មិនមែនហេតុដទៃទេ ។ បទថា **ឯតម្បិ ទិស្វា** គឺ ឃើញហេតុនេះឯង ។ បទថា **ឆវីរសេដ្ឋ** សេចក្តីថា បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងពួកជន ជាព្រះរាជាប្រសើរដោយសេចក្តីព្យាយាមក្នុងនរជនទាំងឡាយ ។ បទថា **វាចំ បមុញ្ចេ កុសលំ នាតិវេលំ** សេចក្តីថា បុរសដែលជាបណ្ឌិតគប្បីបន្ទឺវាចាដែលជាកុសលតែម្យ៉ាងប្រកបដោយសច្ចៈជាដើម គឺគប្បីពោលវាចាដែលជាប្រយោជន៍ប្រកបដោយកាល មិនគប្បីពោលវាចាហួសកាល ហួសពេលមិនចេះចប់ ។ បទថា **បស្សសិ** សេចក្តីថា ទ្រង់ទតឃើញអណ្តើកប្រេចក្បហើយមិនមែនឬ ។ បទថា **ពហុភាណេន** ប្រែថា ព្រោះនិយាយច្រើន ។ បទថា **កច្ឆបំ ព្យសនំ គតំ** គឺ អណ្តើកដល់នូវការស្លាប់យ៉ាងនេះ ។

ព្រះរាជាទ្រង់ជ្រាបថា ព្រះពោធិសត្វពោលសំដៅដល់ទ្រង់ទើបត្រាស់ថា អ្នកពោលសំដៅដល់យើងតើមែនឬទេ ព្រះពោធិសត្វក្រាបទូលឲ្យជាក់ច្បាស់ថា បពិត្រមហារាជ មិនថាជាព្រះអង្គឬក៏បុគ្គលណាមួយទេ កាលពោលហួសប្រមាណរមែងដល់នូវសេចក្តីវិនាសយ៉ាងនេះ ព្រះរាជាតាំងអំពីនោះមកក៏ទ្រង់វៀរចាកការត្រាស់ច្រើនត្រាស់តែពាក្យតិចតួច ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា អណ្តើកក្នុងកាលនោះបានមកជាកោកាលិកភិក្ខុក្នុងកាលឥឡូវនេះ កូនហង្សទាំង ២ ក្នុងកាលនោះបានមកជាមហាថេរៈទាំង ២ រូប ( អគ្គសាវក ) ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាកច្ឆបជាតក ចប់

## មច្ចជាតក

[ ២៨១ ] ( ត្រីឈ្មោលពោលថា ) ភ្លើងនេះអញមិនក្តៅ ឈើស្រួច ដែលគេបិតសម្រួចល្អហើយក៏អញមិនឈឺ អញឈឺតែត្រង់មេត្រីសម្គាល់អញ ថាទៅត្រេកអរនឹងមេត្រីដទៃនោះ ។

[ ២៨២ ] ភ្លើងគឺ រាគៈនោះរលាកនូវអញផង ចិត្ត ( ដ៏សម្បយុត្តដោយរាគៈ ) ក៏ញុំាងអញឲ្យក្តៅផង បពិត្រព្រានសំណាញ់ទាំងឡាយ សូមអ្នកទាំងឡាយលែងខ្ញុំទៅ ( សត្វដែលបិតនៅ ) ក្នុងកាម អ្នកទាំងឡាយកុំបៀតបៀនក្នុងហេតុនីមួយ ។

**ចប់ មច្ចជាតកទី ៦ ។**

## អដ្ឋកថា

## មច្ចជាតក

[ ២៨១-២៨២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ភរិយាចាស់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន មាយមគ្គិ តបតិ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ព្រះសាស្តាសួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថាអ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គ ព្រះសាស្តាត្រាស់សួរថា អ្នកណាធ្វើឲ្យអ្នកអផ្សុកក៏ក្រាបទូលថា ភរិយាចាស់របស់ខ្ញុំព្រះអង្គ ។ លំដាប់នោះព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្រីនេះធ្វើនូវសេចក្តី

វិនាសឲ្យដល់អ្នកយ៉ាងនេះមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនអ្នកអាស្រ័យស្រីនេះស្ទើរតែនឹងត្រូវជោតដោយឈើអណ្តាត អាំងលើរងើកភ្លើង ត្រូវបរិភោគសាច់ អាស្រ័យបណ្ឌិតទើបរួចជីវិតមកបានហើយ ទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាបុរោហិតរបស់ព្រះរាជា ។ ថ្ងៃមួយអ្នកប្រមង់បោះត្រីដែលជាប់សំណាញ់មួយមកលើធ្នេរខ្សាច់ដ៏ក្តៅ សម្រួចឈើអណ្តាតដោយគិតថា អញនឹងអាំងត្រីនេះលើរងើកភ្លើងហើយទំពាស៊ី ។ ត្រីកន្ទក់កន្ទេញដល់ត្រីញីបានពោលគាថាទាំងនេះថា

ភ្លើងនេះអញមិនក្តៅ ឈើស្រួចដែលគេបិតសម្រួចល្អហើយ
ក៏អញមិនឈឺ អញឈឺតែត្រង់មេត្រីសម្គាល់អញថាទៅត្រេក-
អរនឹងមេត្រីដទៃនោះ ។

ភ្លើងគឺ រាគៈនោះរលាកនូវអញផង ចិត្ត ( ដ៏សម្បយុត្ត
ដោយរាគៈ ) ក៏ញុំាងអញឲ្យក្តៅផង បពិត្រព្រានសំណាញ់
ទាំងឡាយ សូមអ្នកទាំងឡាយលែងខ្ញុំទៅ ( សត្វដែលបិត
នៅ ) ក្នុងកាម អ្នកទាំងឡាយកុំបៀតបៀនក្នុងហេតុនីមួយ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន មាយមគ្គិ** សេចក្តីថា ភ្លើងនេះមែងមិនដុតអញ គឺមិនធ្វើឲ្យអញក្តៅ មិនធ្វើឲ្យអញសោយសោក ។ បទថា **ន**

**សូលោ** គឺ សូម្បីឈើសូលដែលព្រានសម្រួចទុកយ៉ាងល្អ ក៏មិនដុតអញ គឺមិនញ៉ាំងសេចក្ដីសោកឲ្យកើតដល់អញ ។ បទថា **យញ្ច មំ មញ្ញតេ មច្ឆី** សេចក្ដីថា តែត្រីញីនោះសម្គាល់ថា អញទៅត្រេកអរនឹងត្រីញីដទៃ ដោយការត្រេកអរក្នុងកាមគុណ ៥ នោះឯងធ្វើឲ្យអញក្ដៅក្រហាយ ធ្វើឲ្យអញសោយសោកដុតរោលអញ ។ បទថា **សោ មំ ឧហតិ** សេចក្ដីថា ភ្លើង គឺ រាគៈនោះរមែងដុតអញ ។ បទថា **ចិត្តញ្ចុបតបេតិ មំ** សេចក្ដីថា ចិត្តរបស់អញប្រកបដោយរាគៈនោះធ្វើឲ្យអញក្ដៅក្រហាយលំបាក ។ បទថា **ជាលិនោ** ជាពាក្យសម្រាប់ហៅអ្នកប្រមង់ព្រោះថា អ្នកប្រមង់ទាំងនោះលោកហៅថា **ជាលិនោ** ព្រោះមានសំណាញ់ ។ បទថា **មុញ្ចយិរា មំ** បានដល់ ត្រីអង្វរថា បពិត្រលោកម្ចាស់ សូមលែងខ្ញុំចុះ ។ បទថា **ឧ កាមេ ហញ្ញតេ ក្វចិ** សេចក្ដីថា សត្វដែលតាំងនៅក្នុងកាមត្រូវកាមនាំទៅមិនគួរសម្លាប់ដោយពិត ។ ត្រីខ្សឹកខ្សួលថា មនុស្សដូចអ្នកមិនគួរសម្លាប់ត្រីនោះឡើយ ។ ម្យ៉ាងទៀតត្រីហែលតាមត្រីញីព្រោះហេតុកាមជនដូចអ្នកមិនគួរសម្លាប់ដោយពិត ។

ខណៈនោះព្រះពោធិសត្វទៅដល់មាត់ស្ទឹង បានឮត្រីនេះយំរៀបរាប់ទើបចូលទៅសុំអ្នកប្រមង់យកត្រីនោះទៅលែង ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងកាលចប់សច្ចធម៌ ភិក្ខុអផ្សុកនោះតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ត្រីញីក្នុងកាលនោះបានមកជាករិយាចាស់ក្នុងកាលឥឡូវនេះ

ត្រីឈ្មោលក្នុងកាលនោះបានមកជាភិក្ខុអផ្សុក ចំណែកបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាមច្ឆជាតក ចប់

## សេគ្គុជាតក

[ ២៨៣ ] ( បិតាពោលថា ) សត្វលោកទាំងអស់ជាអ្នកមានចិត្តរីករាយ ( ដោយការសេពកាម ) នាងសេគ្គុជាស្រីមិនឈ្លាសក្នុងធម៌របស់អ្នកស្រុក នាងដែលយើងចាប់ហើយយំក្នុងព្រៃដោយធម្មតាណា ធម្មតានោះរបស់នាងឈ្មោះថា នៅក្មេងទេឬ ។

[ ២៨៤ ] ( នាងសេគ្គុកុមារិកាពោលថា ) ជនណាគប្បីជាទីពឹងរបស់ខ្ញុំដែលទុក្ខពាល់ត្រូវហើយ ជននោះជាបិតារបស់ខ្ញុំបានប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញចំពោះអ្នកណាក្នុងកណ្តាលព្រៃ បិតាណាជាអ្នកការពារ បិតានោះធ្វើនូវកម្មដ៏សាហស ។

**ចប់ សេគ្គុជាតកទី ៧ ។**

## អដ្ឋកថា

## សេគ្គុជាតក

[ ២៨៣-២៨៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកលក់បន្លែម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វោ លោកោ** ដូច្នេះជាដើម ។

រឿងមានពិស្តារក្នុងឯកនិបាតនោះហើយ ។

ក្នុងទុកនិបាតនេះ ព្រះសាស្តាត្រាស់សួរឧបាសកនោះថា ឧបាសកហេតុអ្វីទើបអ្នកបាត់យូរម្ល៉េះ ឧបាសកទូលថា បពិត្រព្រះអង្គដ៏ចម្រើន កូនស្រី

របស់ខ្ញុំព្រះអង្គមានមុខញញឹមញញែមជានិច្ច ខ្ញុំព្រះអង្គសាកល្បងហើយ ទើបលើកឲ្យទៅកំលោះក្នុងត្រកូលមួយព្រោះវល់ចាត់ចែងរឿងនោះ ទើបខក ខានមកគាល់ព្រះអង្គ ។ លំដាប់នោះព្រះសាស្តាត្រាស់នឹងឧបាសកនោះថា ម្នាលឧបាសក កូនស្រីរបស់អ្នក មិនមែនជាអ្នកមានសីលតែក្នុងកាលឥឡូវ នេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ជាអ្នកមានសីលហើយអ្នកក៏ធ្លាប់ពិសោធ ហើយដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជារុក្ខទេវតា ។ ក្នុងកាលនោះ ឧបាសកអ្នកលក់បន្លែនេះឯង គិតនឹងសាកល្បងកូនស្រី ទើបនាំទៅព្រៃហើយធ្វើជាចាប់ដៃដូចត្រូវការដោយ អំណាចកិលេសហើយពោលនឹងកូនស្រីដែលកំពុងយំដោយគាថាទីមួយថា

សត្វលោកទាំងអស់ជាអ្នកមានចិត្តរីករាយ ( ដោយការសេព
កាម ) នាងសេគ្គុជាស្រីមិនឈ្លាសក្នុងធម៌របស់អ្នកស្រុក
នាងដែលយើងចាប់ហើយយំក្នុងព្រៃដោយធម្មតា ណាធម្មតា
នោះរបស់នាងឈ្មោះថា នៅក្មេងទេឬដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វោ លោកោ អត្តមនោ អហោសិ** សេចក្តីថា នែនាង សត្វលោកទាំងអស់ពេញចិត្តក្នុងការសេពកាម ។ បទ ថា **សេគ្គុ** នេះជាឈ្មោះរបស់កុមារិកានោះ ។ នែនាងសេគ្គុ នាងមិនឈ្លាស ក្នុងធម៌របស់អ្នកស្រុក ។ លោកអធិប្បាយថា នាងមិនឈ្លាសក្នុងធម៌របស់ អ្នកស្រុក គឺមិនឈ្លាសក្នុងធម៌របស់មនុស្សថោកទាប ។ បទថា **កោមារិ-**

**កោ ឆាម គវជ្ជ ធម្មោ** សេចក្តីថា នែនាង សភាពរបស់នាងដូចម្តេចក្នុងថ្ងៃនេះ ។ បទថា **យំ ត្វំ គហិតា បវនេ បវោធសិ** សេចក្តីថា ឧបាសកសួរថា នាងត្រូវអញចាប់ដៃដោយសេចក្តីត្រេកអរក្នុងព្រៃនេះ នាងកន្ទក់កន្ទេញ គឺមិនព្រម សភាពរបស់នាងនេះគឺអ្វី នាងនៅក្មេងឬ ។

កុមារីស្តាប់ពាក្យនោះហើយពោលថា ពិតហើយខ្ញុំនៅជាកុមារី ហើយយំពោលគាថាទីពីរថា

ជនណាគប្បីជាទីពឹងរបស់ខ្ញុំដែលទុក្ខពាល់ត្រូវហើយ ជននោះជាបិតារបស់ខ្ញុំ បានប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញចំពោះអ្នកណាក្នុងកណ្តាលព្រៃ បិតាណាជាអ្នកការពារ បិតានោះធ្វើនូវកម្មដ៏សហ័ស ដូច្នេះ ។

ឧបាសកលក់បន្លែនោះ សាកល្បងចិត្តកូនស្រីក្នុងកាលនោះដោយប្រការដូច្នេះ ហើយទើបនាំទៅផ្ទះលើកឲ្យកំលោះក្នុងត្រកូលមួយ ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងកាលចប់សច្ចធម៌ ឧបាសកអ្នកលក់បន្លែតាំងនៅក្នុងសោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា កូនស្រីក្នុងកាលនោះបានមកជាកូនស្រីក្នុងកាលឥឡូវនេះ បិតាក្នុងកាលនោះបានមកជាឧបាសកអ្នកលក់បន្លែ ឯរុក្ខទេវតាអ្នកធ្វើហេតុនោះឲ្យប្រចក្សក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សេគ្គុជាតក ចប់**

## កូដវាណិជជាតក

[ ២៨៥ ] ( វិនិច្ឆយាមាត្យពោធិសត្វពោលថា ) កលបញ្ឆោតតប ចំពោះបុគ្គលអ្នកមានកលបញ្ឆោត អ្នកគិតល្អហើយ ការកោងតបចំពោះបុគ្គលអ្នកកោង អ្នកបានតទល់ ( ល្អ ) ហើយ ថាបើកណ្តុរទាំងឡាយគប្បីស៊ីនូវផាលមែនហេតុអ្វីក៏សត្វខ្លែងទាំងឡាយនាំក្មេងទៅមិនបាន ។

[ ២៨៦ ] ព្រោះថា បុគ្គលកោងតបទាំងឡាយរមែងមានចំពោះបុគ្គលអ្នកកោង បុគ្គលអ្នកបោកប្រាស់ដទៃអំពីបុគ្គលអ្នកបោកប្រាស់ រមែងមាន ( ដល់ ) បុគ្គលអ្នកបោកប្រាស់ ម្នាលបុរសអ្នកបាត់កូនអ្នកចូរឲ្យនូវផាលដល់បុរសអ្នកបាត់ផាល កុំឲ្យអ្នកបាត់ផាលលួចកូនអ្នកទៅឡើយ ។

**ចប់ កូដពាណិជជាតកទី ៨ ។**

## អដ្ឋកថា

## កូដវាណិជជាតក

[ ២៨៥-២៨៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញកោងម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សឋស្ស សាឋេយ្យមិទំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ជន ២ នាក់គឺ ឈ្មួញកោងនិងឈ្មួញដែលជាបណ្ឌិតអ្នកក្រុងសាវត្ថីធ្វើដំណើរទៅជាមួយគ្នាផ្ទុកទំនិញពេញរទេះ ៥០០ ធ្វើនូវការលក់ដូរ ចេញអំពីទិសខាងកើតទៅកាន់ទិសផ្សេងៗ កាលបានចំណេញច្រើន

ក៏ត្រឡប់មកក្រុងសាវត្ថី ឈ្មួញដែលជាបណ្ឌិតបានពោលនឹងឈ្មួញកោងថា នែសម្លាញ់ មកយើងចែកទំនិញគ្នា ឈ្មួញកោងគិតថា ឈ្មួញនេះលំបាកដោយការដេក ការបរិភោគដែលខ្វះខាតមកអស់កាលយូរ កាលបរិភោគអាហារដែលមានរសប្រសើរផ្សេងៗក្នុងផ្ទះរបស់ខ្លួននឹងស្លាប់ព្រោះអាហារមិនរលាយ ពេលនោះទ្រព្យទាំងអស់នឹងជារបស់អញតែម្នាក់ទើបពោលថា ឫក្សនិងថ្ងៃមិនទាន់ល្អ ស្អែកនេះ ខានស្អែកនេះសឹមដឹង ពន្យាពេលឲ្យកន្លងទៅ ។ ឈ្មួញជាបណ្ឌិតទារឲ្យចែកទាល់តែបាន កាន់យកផ្កាកម្រងនិងគ្រឿងក្រអូបទៅគាល់ព្រះសាស្តា បូជាព្រះសាស្តា ថ្វាយបង្គំហើយអង្គុយនៅក្នុងចំណែកម្ខាង ។ ព្រះសាស្តាត្រាស់សួរថា ម្នាលឧបាសក អ្នកមកដល់ពីអន្លើ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកបានប្រមាណកន្លះខែ ព្រះសាស្តាត្រាស់សួរថា ព្រោះហេតុអ្វីទើបយឺតយូរយ៉ាងនេះ មិនមកកាន់ទីឧបដ្ឋាក ឧបាសកក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនឈ្មួញនេះក៏កោងដូចគ្នា ឧបាសកទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ កាលចម្រើនវ័យបានជាអាមាត្យវិនិច្ឆ័យក្តីរបស់ព្រះរាជា ក្នុងកាលនោះមានឈ្មួញ ២ នាក់គឺ ឈ្មួញជនបទនិងឈ្មួញអ្នកក្រុងជាមិត្តនឹងគ្នា ។ ឈ្មួញជនបទផ្ញើផាល ៥០០ ទុកនឹងឈ្មួញ

អ្នកក្រុង ឈ្មួញអ្នកក្រុងលក់ផាលទាំងនោះហើយយកប្រាក់ទុក ហើយយកអាចម៍កណ្តុរមករោយទុកក្នុងទីរក្សាផាល លុះឈ្មួញជនបទមករកពោលថា ចូរអ្នកឲ្យផាលខ្ញុំចុះ ឈ្មួញកោងពោលថា ផាលរបស់អ្នកត្រូវកណ្តុរស៊ីអស់ហើយទើបចង្អុលឲ្យមើលអាចម៍កណ្តុរ ។ ឈ្មួញស្រុកក្រៅពោលថា កណ្តុរស៊ីហើយក៏ស៊ីទៅចុះ កាលកណ្តុរស៊ីហើយនឹងធ្វើដូចម្តេចបាន ។ ទើបនាំបុត្ររបស់ឈ្មួញកោងនោះទៅងូតទឹក ឲ្យក្មេងនោះអង្គុយខាងក្នុងបន្ទប់ផ្ទះសម្លាញ់ម្នាក់ហើយប្រាប់ថា កុំឲ្យទារកនេះដល់អ្នកណាដាច់ខាត ហើយខ្លួនឯងក៏ងូតទឹក ត្រឡប់ទៅកាន់ផ្ទះរបស់ឈ្មួញកោង ឈ្មួញកោងសួរថា ឯណាកូនរបស់ខ្ញុំ ឈ្មួញស្រុកក្រៅប្រាប់ថា ខណៈដែលខ្ញុំដាក់កូនរបស់អ្នកទុកត្រង់មាត់ច្រាំងហើយចុះងូតទឹក សត្វខ្លែងមួយហើរមកយកក្រចកចាបកូនរបស់អ្នករួចហើរទៅកាន់អាកាស សូម្បីខ្ញុំព្យាយាមទះដៃស្រែកក៏មិនអាចឲ្យវាលែងបានឈ្មួញកោងពោលថា ឯងនិយាយកុហក សត្វខ្លែងមិនអាចនាំក្មេងទៅបានទេ ឈ្មួញស្រុកក្រៅពោលថា នែសម្លាញ់ អ្នកថាយ៉ាងនេះក៏ថាបានតើខ្ញុំនឹងធ្វើដូចម្តេច ( ប៉ុន្តែ ) សត្វខ្លែងចាបយកកូនរបស់អ្នកពិតមែន ។ ឈ្មួញកោងគំរាមឈ្មួញស្រុកក្រៅថា ឯងជាចោរចិត្តកាចសម្លាប់មនុស្ស ពេលនេះអញនឹងទៅសាលាវិនិច្ឆ័យឲ្យចៅក្រមដាក់ទោសឯងហើយចេញទៅ ។ ឈ្មួញស្រុកក្រៅពោលថា ធ្វើតាមគាប់ចិត្តរបស់ឯងចុះហើយទៅជាមួយឈ្មួញកោងនោះ ។

ឈ្មួញកោងពោលនឹងព្រះពោធិសត្វថា បពិត្រលោកម្ចាស់ ឈ្មួញនេះនាំកូនរបស់ខ្ញុំទៅងូតទឹកមិននាំកូនរបស់ខ្ញុំមកវិញ កាលខ្ញុំសួរថា កូនរបស់ខ្ញុំ

ទៅណាក៏ប្រាប់ថា សត្វខ្លែងជាបយកទៅ សូមលោកមេត្តាវិនិច្ឆ័យក្តីដល់ខ្ញុំផង ចុះ ព្រះពោធិសត្វសួរឈ្មួញស្រុកក្រៅថា អ្នកនិយាយពិតឬ ឈ្មួញជនបទពោលថា ខ្ញុំនាំក្មេងនោះទៅពិត ព្រះពោធិសត្វសួរថា សត្វខ្លែងនាំក្មេងទៅពិតឬ ឈ្មួញជនបទពោលថា ពិតលោកម្ចាស់ ព្រះពោធិសត្វសួរថា ក្នុងលោកនេះធម្មតាសត្វខ្លែងនាំក្មេងទៅបានឬ ។ ឈ្មួញស្រុកក្រៅពោលថា បពិត្រលោកម្ចាស់ ខ្ញុំសូមសួរលោកថា សត្វខ្លែងមិនអាចនាំក្មេងទៅក្នុងអាកាសបានតែកណ្តុរទំពាស៊ីផាលដែកបានឬ ។ ព្រះពោធិសត្វសួរថា តើរឿងនេះដូចម្តេច ។ ឈ្មួញជនបទពោលថា បពិត្រលោកម្ចាស់ ខ្ញុំផ្ញើផាល ៥០០ ក្នុងផ្ទះរបស់ឈ្មួញនេះ ឈ្មួញនេះប្រាប់ថា ផាលរបស់អ្នកត្រូវកណ្តុរស៊ីហើយចង្អុលបង្ហាញអាចម៍កណ្តុរថា នេះគឺអាចម៍របស់កណ្តុរដែលស៊ីផាលរបស់អ្នក បពិត្រលោកម្ចាស់ បើកណ្តុរស៊ីផាលបានសូម្បីសត្វខ្លែងក៏នាំយកក្មេងទៅបាន បើកណ្តុរស៊ីមិនបានសត្វខ្លែងក៏នាំក្មេងនោះទៅមិនបាន ឈ្មួញនេះពោលថា កណ្តុរស៊ីផាលអស់ហើយសូមលោកជ្រាបចុះថា ផាលទាំងនោះកណ្តុរស៊ីពិតដែរឬទេ សូមលោកពិចារណាក្តីរបស់ខ្ញុំចុះ ។ ព្រះពោធិ-សត្វដឹងថា ឈ្មួញស្រុកក្រៅនេះគិតកោងតបយកឈ្នះមនុស្សកោង ទើបពោលថា អ្នកគិតល្អហើយបានពោលគាថាទាំងនេះថា

កលបញ្ឆោតតប ចំពោះបុគ្គលអ្នកមានកលបញ្ឆោត អ្នក
គិតល្អហើយ ការកោងតបចំពោះបុគ្គលអ្នកកោង អ្នកបាន
តទល់ ( ល្អ ) ហើយ ថាបើកណ្តុរទាំងឡាយគប្បីស៊ីនូវផាល

មែន ហេតុអ្វីក៏សត្វខ្លែងទាំងឡាយនាំក្មេងទៅមិនបាន ។
ព្រោះថា បុគ្គលកោងតបទាំងឡាយរមែងមានចំពោះបុគ្គលអ្នកកោង បុគ្គលអ្នកបោកប្រាស់ដទៃអំពីបុគ្គលអ្នកបោកប្រាស់រមែងមាន ( ដល់ ) បុគ្គលអ្នកបោកប្រាស់ ម្នាលបុរសអ្នកបាត់កូន អ្នកចូរឲ្យនូវផាលដល់បុរសអ្នកបាត់ផាល កុំឲ្យអ្នកបាត់ផាលលួចកូនអ្នកទៅឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សឋស្ស** សេចក្តីថា ឈ្មោះថា បុគ្គលកោងព្រោះគិតថា អញគួរធ្វើឧបាយឯណានីមួយដោយកលល្បិចហើយយកទ្រព្យអ្នកដទៃ ។ បទថា **សាធេយ្យមិទំ សុចិន្តិតំ** បានដល់ សេចក្តីកោងនេះអ្នកគិតល្អហើយ ។ បទថា **បច្ចោឌ្ឌិតំ បដិកូដស្ស កូដំ** សេចក្តីថា ការកោងតបចំពោះបុគ្គលកោងអ្នកចាត់ការល្អហើយ អធិប្បាយថា ធ្វើផ្ទញ់ផ្ទាល់ត្រឹមត្រូវដែលគួរធ្វើហើយ ។ បទថា **ផាលំ ចេ ខាទេយ្យុំ មូសិកា** សេចក្តីថា បើពួកកណ្តុរស៊ីផាលបាន ហេតុអ្វីសត្វខ្លែងនាំក្មេងទៅមិនបាន ព្រោះដូច្នោះកាលកណ្តុរស៊ីផាលបាន រឿងអ្វីដែលខ្លែងនាំក្មេងទៅមិនបាន ។ បទថា **កូដស្ស ហិ សន្តិ កូដកូដា** សេចក្តីថា អ្នកយល់ថា ខ្ញុំត្រូវបុរសដែលឲ្យកណ្តុរស៊ីផាលបោកប្រាស់ ឯការផ្ទញ់ផ្ទាល់បុគ្គលដែលកោងដូច្នេះនៅមានច្រើនទៀតក្នុងលោកនេះ គឺការកោងតបចំពោះបុគ្គលកោងនៅមាន ។ បទថា **ភវតិ បរោ ឆិកតិនោ ឆិកត្យា** សេចក្តីថា បុគ្គលដែលផ្ទញ់ផ្ទាល់ចំពោះអ្នកធ្វើការបោកបញ្ឆោតនៅមានទៀតនោះឯង នៃបុរស

បាត់កូន អ្នកចូរសងផាលឲ្យដល់បុរសដែលបាត់ផាលនេះចុះ បើអ្នកមិនឲ្យផាលគេនឹងនាំកូនរបស់អ្នកទៅ តែបុរសនេះមិនលួចកូនរបស់អ្នក អ្នកត្រូវឲ្យផាលដល់គេ ។ ឈ្មួញកោងពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងសងផាលបើបុរសនេះឲ្យកូនដល់ខ្ញុំ ។ ឈ្មួញបណ្ឌិតពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងឲ្យកូនបើបុរសនេះសងផាលខ្ញុំ ។ ឈ្មួញដែលបាត់កូនក៏បានកូន ឈ្មួញដែលបាត់ផាលក៏បានផាល ជនទាំង ២ ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជតកថា ឈ្មួញកោងក្នុងកាលនោះ បានមកជាឈ្មួញកោងក្នុងកាលឥឡូវនេះ ឈ្មួញជាបណ្ឌិតក្នុងកាលនោះបានមកជាឈ្មួញបណ្ឌិតនេះឯង ឯអាមាត្យអ្នកវិនិច្ឆ័យក្តីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាកូដវាណិជជាតក ចប់

## គរហិតជាតក

[ ២៨៧ ] ( ពានរពោធិសត្វពោលថា ) វាចាដែលពោលថា ប្រាក់របស់អញ មាសរបស់អញអស់យប់នឹងថ្ងៃនេះ ជាវាចារបស់មនុស្សទាំងឡាយអ្នកឥតប្រាជ្ញាមិនឃើញអរិយធម៌ ។

[ ២៨៨ ] ក្នុងផ្ទះ ១ មានម្ចាស់ផ្ទះពីរៗនាក់ បណ្ដាម្ចាស់ផ្ទះពីរនាក់នោះ ម្ចាស់ផ្ទះម្នាក់មិនមានពុកមាត់ មានដោះយាចុះ មានផ្នួងសក់បួងហើយមានត្រចៀកចោះប្រដាប់ហើយ ដែលគេទិញដោយទ្រព្យដ៏ច្រើន ម្ចាស់ផ្ទះនោះតែងពោលចាក់ដោតនូវជននោះ ។

**ចប់ គរហិតជាតកទី ៩ ។**

## អដ្ឋកថា

## គរហិតជាតក

[ ២៨៧-២៨៨ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកព្រោះមិនត្រេកអរមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ហិរញ្ញំ មេ សុវណ្ណំ មេ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ភិក្ខុនោះមិនមានឯកគ្គតារម្មណ៍ឡើយ ។ ភិក្ខុទាំងឡាយនាំភិក្ខុដែលមិនត្រេកអរនោះទៅគាល់ព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា ពិតព្រះអង្គ ។ ព្រះសាស្ដាត្រាស់សួរថា ព្រោះហេតុអ្វី ភិក្ខុនោះក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន ព្រោះអំណាចកិលេស ។ លំដាប់នោះព្រះសាស្តា ត្រាស់ថា ម្នាលភិក្ខុ ធម្មតាកិលេសសូម្បីតែសត្វតិរច្ឆានទាំងឡាយក្នុងកាលមុនក៏តិះដៀលដែរ អ្នកបួសហើយក្នុងសាសនាបែបនេះ ហេតុអ្វីទើបអផ្សុកដោយអំណាចកិលេសដែលសូម្បីតែសត្វតិរច្ឆានក៏តិះដៀលដែរនោះ ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាពានរក្នុងហិមវន្តប្បទេស ។ ថ្មើរព្រៃម្នាក់ចាប់ពានរនោះមកថ្វាយព្រះរាជា ។ ពានរនោះកាលនៅក្នុងព្រះរាជវាំងអស់កាលយូរបានក្លាយជាសត្វសុភាពរាបសារ ដឹងកិរិយាការប្រព្រឹត្តក្នុងពួកមនុស្សជាច្រើន ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងចរិយាវត្តរបស់ពានរនោះឲ្យហៅព្រានព្រៃមកត្រាស់ថា ចូរលែងស្វានេះក្នុងទីដែលចាប់បាន ។ ព្រានបានធ្វើតាមព្រះរាជបញ្ជា ។ ហ្វូងស្វាដឹងថាព្រះពោធិសត្វមក កាលឃើញព្រះពោធិសត្វទើបប្រជុំគ្នាត្រង់ផ្ទាំងថ្មមួយជុំសរសើរព្រះពោធិសត្វហើយសួរថា នែសម្លាញ់ឯងទៅណាមិនឃើញអស់កាលយូរ ព្រះពោធិសត្វឆ្លើយថា ខ្ញុំនៅក្នុងព្រះរាជនិវេសន៍ក្នុងក្រុងពារាណសី ។ ពួកស្វាសួរថា បើដូច្នោះតើអ្នករួចមកបានដូចម្តេច ។ ព្រះពោធិសត្វពោលថា ព្រះរាជាធ្វើខ្ញុំឲ្យជាស្វាសម្រាប់លេងហើយទ្រង់ជ្រះថ្លាក្នុងវត្តរបស់ខ្ញុំទើបទ្រង់ដោះលែង ។ លំដាប់នោះពានរទាំងឡាយពោលនឹងព្រះពោធិសត្វថា អ្នកចេះកិរិយាការប្រព្រឹត្តរបស់មនុស្សលោក សូមអ្នកប្រាប់ដល់ពួកយើងខ្លះពួកយើងចង់ស្តាប់ ព្រះពោធិ-

សត្វពោលថា អ្នកកុំសួរដល់កិរិយារបស់មនុស្សជាមួយខ្ញុំឡើយ ។ ពានរពោលថា ប្រាប់មកសម្លាញ់ពួកយើងចង់ស្តាប់ ព្រះពោធិសត្វពោលថា ឈ្មោះថា មនុស្សទោះក្សត្រក្តី ព្រាហ្មណ៍ក្តី សុទ្ធតែពោលថា របស់អញ របស់អញ មិនដឹងដល់ការមិនទៀងនិងការអស់ទៅ សូន្យទៅ ឥឡូវនេះពួកអ្នកចូរស្តាប់ការធ្វើរបស់អន្ធពាលទាំងនោះហើយពោលគាថាទាំងនេះថា

> វាចាដែលពោលថា ប្រាក់របស់អញ មាសរបស់អញ
> អស់យប់និងថ្ងៃនេះ ជាវាចារបស់មនុស្សទាំងឡាយ អ្នកឥត
> ប្រាជ្ញាមិនឃើញអរិយធម៌ ។
>
> ក្នុងផ្ទះ ១ មានម្ចាស់ផ្ទះពីរៗនាក់ បណ្តាម្ចាស់ផ្ទះពីរនាក់
> នោះ ម្ចាស់ផ្ទះម្នាក់មិនមានពុកមាត់ មានជោះយាចុះ មានផ្នួង
> សក់បួងហើយមានត្រចៀកចោះប្រដាប់ហើយ ដែលគេទិញ
> ដោយទ្រព្យដ៏ច្រើន ម្ចាស់ផ្ទះនោះតែងពោលចាក់ដោតនូវជន
> នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិរញ្ញំ មេ សុវណ្ណំ មេ** នេះត្រឹមតែជាមាតិកានៃទេសនា ។ ដោយបទទាំង ២ នេះ ក៏សង្គ្រោះយករតនៈ ១០ ប្រការ បុព្វន្នជាតិ អបរណ្ណជាតិ ស្រែចម្ការនិងសត្វជើង ២ ជើង ៤ សព្វយ៉ាងហើយពោលថា នេះរបស់អញ នេះរបស់អញ ។ បទថា **ឯសា រត្តិន្ទិវា គាថា** សេចក្តីថា ពួកមនុស្សនិយាយគ្នាជានិច្ច ទាំងពេលថ្ងៃនិងពេលយប់មិនបានដឹងយ៉ាងដទៃថា បញ្ចក្ខន្ធមិនទៀងឬមាន ហើយទៅជាមិន

មានវិញ ដើរពោល ដើរនិយាយតែយ៉ាងនេះឯង ។ បទថា **ឧម្មេធានំ** គឺ មានបញ្ញាថោកថយ ។ បទថា **អរិយធម្មំ អបស្សន្តំ** សេចក្តីថា មិនឃើញធម៌របស់អរិយៈ មានព្រះពុទ្ធជាដើម ឬលោកុត្តរធម៌ ៩ ដ៏ប្រសើរ មិនមានទោស មនុស្សមិនមានការពោលដទៃថា មិនទៀងជាទុក្ខ ។ បទថា **គហាបតយោ** បានដល់ ជាធំក្នុងផ្ទះ ។ បទថា **ឃរេកោ តត្ថ** បានដល់ ក្នុងម្ចាស់នៃផ្ទះ ២ នាក់នោះ លោកពោលសំដៅដល់មាតុគ្រាមតែម្នាក់ ។ បទថា **វេណិករោ** គឺ ផ្នួងសក់ អធិប្បាយថា មានផ្នួងសក់ទ្រង់ទ្រាយផ្សេងៗ ។ បទថា **អថោ អង្គិតកណ្ណកោ** បានដល់ ចោះត្រចៀក គឺ ត្រចៀកមានស្នាមចោះ លោកពោលសំដៅដល់មានត្រចៀកយារ ។ បទថា **កីតោ ធនេន ពហុនា** សេចក្តីថា បុគ្គលដែលមិនមានពុកមាត់ មានដោះយារចុះ មានផ្នួងសក់ ចោះត្រចៀក គេឲ្យដ៏ទ្រព្យច្រើនដល់មាតាបិតា គឺទិញយកមកប្រដាប់តាក់តែងឲ្យ លើកឡើងកាន់យាននាំទៅកាន់ផ្ទះ ( ខាងប្រុស ) ដោយបរិវារធំ ។ បទថា **សោ តំ វិតុទតេ ជនំ** សេចក្តីថា ម្ចាស់ផ្ទះនោះតាំងអំពីមកក៏ប្រើលំពែង គឺមាត់ចាក់ដោតមនុស្សក្នុងផ្ទះមានទាសៈនិងកម្មករជាដើម ត្រង់ផ្ទះនោះថា អាទាសៈថោកទាប មេទាសីថោកទាប ឯងធ្វើវត្ថុនេះមិនធ្វើវត្ថុនេះ ឯងចូរត្រួតត្រាពួកមនុស្សធ្វើដូចចៅហ្វាយនាយ ។ ពានរពោធិសត្វតិះដៀលពួកមនុស្សថា ពួកមនុស្សមិនសមគួរយ៉ាងក្រៃលែងដោយប្រការដូច្នេះ ។

ស្វាទាំងអស់ បានស្តាប់ដូច្នោះ យកដៃបិទត្រចៀកយ៉ាងណែនពោលថា

អ្នកកុំពោលឡើយ ពួកយើងឮវត្ថុដែលមិនគួរឮ តិះដៀលថា ពួកយើងស្ដាប់វត្ថុដែលមិនគួរស្ដាប់ក្នុងទីនេះហើយនាំគ្នាទៅកាន់ទីដទៃ ។ បានឮថា ថ្មដានោះបានឈ្មោះថា គរហិតបិដ្ឋិបាសាណ គឺផ្ទាំងថ្មដែលត្រូវតិះដៀល ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ទ្រង់ប្រជុំជាតកថា ហ្វូងពានរក្នុងកាលនោះបានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ពានរជាធំក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គរហិតជាតក ចប់

## ធម្មទ្ធជជាតក

[ ២៨៩ ] ( សក្កទេវរាជពោលថា ) អ្នកមានសភាពរស់នៅជាសុខ ចេញចាកដែន ហើយមកកាន់ព្រៃដ៏ស្ងាត់ អ្នកនោះតែម្នាក់ឯងអន្ទយសញ្ជប់សញ្ជឹងនៅជិតគល់ឈើ ( ក្នុងព្រៃ ) ដូចជាមនុស្សកំព្រា ។

[ ២៩០ ] ( បុរោហិតពោធិសត្វពោលថា ) ខ្ញុំមានសភាពរស់នៅជាសុខ ចេញចាកដែនហើយមកកាន់ព្រៃស្ងាត់ ខ្ញុំនោះតែម្នាក់ឯង ការរឭកធម៌របស់សប្បុរស អន្ទយសញ្ជប់សញ្ជឹងជិតគល់ឈើ ( ក្នុងព្រៃ ) ដូចជាមនុស្សកំព្រា ។

**ចប់ ធម្មទ្ធជជាតកទី ១០ ។**

**ចប់ ពីរណត្ថម្ភកវគ្គទី ៧ ។**

### ឧទ្ទាននៃពីរណត្ថម្ភកវគ្គនោះគឺ

និយាយអំពីគុម្ពស្មៅរណ្ដាសដ៏ប្រសើរ ១ អ្នករបាំ ១ ស្ដេចកុរុដ៏ឧត្ដមប្រសើរ ១ ស្ទឹងពេញដោយទឹក ១ បុគ្គលនិយាយច្រើន ១ ភ្លើង ១ ព្រៃធំ ១ សត្វកណ្ដុរ ១ មនុស្សដោះយារ ១ មនុស្សកំព្រា ១ ត្រូវជា ១០ ។

## អដ្ឋកថា

## ធម្មទ្ធជជាតក

[ ២៨៩-២៩០ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តព្យាយាមផ្ដាច់ព្រះជន្មព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សុខំ ជីវិតរូបោសិ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តព្យាយាមសម្លាប់តថាគតក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ព្យាយាមសម្លាប់តថាគតដូចគ្នា តែមិនអាចធ្វើត្រឹមតែការព្រឺរោមឲ្យកើតដល់តថាគតទើបទ្រង់នាំយករឿងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះរាជាព្រះនាមថា យសបាណី សោយរាជសម្បត្តិក្នុងនគរពារាណសី ។ មានសេនាបតីឈ្មោះកាឡកៈ កាលនោះព្រះពោធិសត្វបានជាបុរោហិតរបស់ព្រះបាទយសបាណីឈ្មោះ ធម្មទ្ធជៈ ឯអ្នកកោរកាត់របស់ព្រះរាជាអង្គនោះឈ្មោះឆត្តបាណិ ។ ព្រះរាជាទ្រង់គ្រប់គ្រងរាជដោយធម៌ ។ តែសេនាបតីរបស់ព្រះអង្គកាលនឹងវិនិច្ឆ័យក្ដីរមែងស៊ីសំណូក ទទួលសំណូកហើយធ្វើអ្នកដែលមិនមែនម្ចាស់របស់ឲ្យជាម្ចាស់របស់ ដូចមនុស្សប្រាំស៊ីសាច់ខ្នងនៃអ្នកដទៃ ។

ថ្ងៃមួយមនុស្សម្នាក់ត្រូវកាត់ក្ដីឲ្យចាញ់ត្រង់សាលាវិនិច្ឆ័យ ផ្គងដើមដៃទ្រហោយំចេញអំពីសាលា ឃើញព្រះពោធិសត្វកំពុងទៅធ្វើរាជកិច្ច ទើបក្រាបចុះទៀបបាទជើងព្រះពោធិសត្វនិយាយរឿងដែលខ្លួនចាញ់ក្ដីថា បពិត្រលោកម្ចាស់ កាលមនុស្សដូចលោកម្ចាស់ថ្វាយអត្ថនិងថ្វាយធម៌ដល់ព្រះរាជានៅមាន

កាឡកសេនាបតីទទួលសំណូក ធ្វើបុគ្គលដែលមិនមែនម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យនោះមិនសមគួរឡើយ ។ ព្រះពោធិសត្វ កើតសេចក្តីករុណាពោលថា មកចុះអ្នកកំលោះ ខ្ញុំនឹងវិនិច្ឆ័យក្តីរបស់អ្នកដោយខ្លួនឯង ហើយនាំបុរសនោះទៅកាន់សាលាវិនិច្ឆ័យ មហាជនប្រជុំគ្នា ។ ព្រះពោធិសត្វ កាត់ក្តីឲ្យម្ចាស់ទ្រព្យនោះឯងបានជាម្ចាស់ទ្រព្យ មហាជនស្រែកឲ្យសាធុការ ។ សំឡេងនោះបានខ្ទរខ្ទារទៅពេញព្រះនគរ ព្រះរាជាទ្រង់ស្តាប់សំឡេងនោះ ត្រាស់សួរថា នុ៎ះជាសំឡេងអ្វី រាជបុរសទូលថា បពិត្រព្រះសម្មតិទេព ធម្មទ្ធជបណ្ឌិតកាត់ក្តីដែលកាឡកសេនាបតីកាត់ខុស ឲ្យត្រូវវិញ នុ៎ះជាសំឡេងស្រែកឲ្យសាធុការក្នុងទីនោះ ។ ព្រះរាជាទ្រង់សោមនស្សត្រាស់ឲ្យហៅព្រះពោធិសត្វមកសួរថា លោកអាចារ្យ បានឮថា លោកកាត់ក្តីឬ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ពិតហើយ កាឡកសេនាបតីកាត់ក្តីមិនល្អទើបទូលព្រះបង្គំវិនិច្ឆ័យជាថ្មីទើបព្រះរាជាត្រាស់ថា តាំងអំពីនេះទៅ ចូរអ្នកជាអ្នកកាត់ក្តីចុះ យើងនឹងបានឮសំឡេងដែលល្អផង ប្រជានុរាស្ត្រនឹងមានទូវសេចក្តីត្រេកអរផង ហើយទ្រង់ប្រកាសថា ចូរអ្នកអង្គុយត្រង់ទីកាត់ក្តីដើម្បីអនុគ្រោះចំពោះមហាជនចុះ សូម្បីព្រះពោធិសត្វមិនប្រាថ្នាក៏បានធ្វើតាមព្រះរាជបំណាង ។ តាំងអំពីនោះមកព្រះពោធិសត្វក៏អង្គុយក្នុងទីកាត់ក្តី ។ ធ្វើបុគ្គលដែលជាម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យ ។ កាឡកសេនាបតីកាលមិនបានទទួលសំណូក តាំងពីនោះមកក៏វិនាសចាកលាភទើបទូលកុហកព្រះរាជាឲ្យទ្រង់ស្អប់ព្រះពោធិសត្វថា បពិត្រមហារាជ ធម្មទ្ធជបណ្ឌិតប្រាថ្នារាជសម្បត្តិរបស់ព្រះអង្គ ។ ព្រះរាជាទ្រង់

មិនជឿទ្រង់យាត់ថា អ្នកកុំពោលយ៉ាងនោះ កាឡកសេនាបតីក្រាបទូលទៀត ថា បើទ្រង់មិនជឿសូមទ្រង់ចាំទតតាមបង្អួចក្នុងពេលដែលធម្មទ្ធជបណ្ឌិតមក ចុះ ពេលនោះទ្រង់ឃើញព្រះនគរទាំងមូលត្រូវធម្មទ្ធជបណ្ឌិតធ្វើទុកក្នុងកណ្ដាប់ ដៃរបស់ខ្លួន ព្រះរាជាទតក្បួនពួកកូនក្តីរបស់ធម្មទ្ធជបណ្ឌិតទ្រង់យល់ថាជា បរិវារធម្មទ្ធជបណ្ឌិតទាំងអស់ ទ្រង់សង្ស័យក្នុងព្រះហឫទ័យត្រាស់សួរថា នែ សេនាបតី យើងនឹងធ្វើដូចម្ដេច សេនាបតីនោះក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់គួរសម្លាប់ធម្មទ្ធជបណ្ឌិតនោះចោល ។ ព្រះរាជាត្រាស់ថា យើងមិន ឃើញទោសខ្លាំងក្លានឹងសម្លាប់គេបានដូចម្ដេច ទើបក្រាបទូលថា បពិត្រព្រះ អង្គ មានឧបាយមួយ ។ ព្រះរាជាត្រាស់សួរថា ឧបាយដូចម្ដេច កាឡក-សេនាបតីក្រាបទូលថា សូមទ្រង់ដាក់កម្មដែលហួសវិស័យឲ្យដល់ធម្មទ្ធជ-បណ្ឌិតនោះរួចសម្លាប់គេដែលមិនអាចធ្វើកម្មនោះបានដោយកំហុសនោះចុះ ។ ព្រះរាជាត្រាស់ថា កម្មដែលហួសវិស័យរបស់ធម្មទ្ធជបណ្ឌិតដូចម្ដេចក៏ក្រាប ទូលថា បពិត្រព្រះអង្គ ធម្មតាឧទ្យានដែលដាំក្នុងផែនដីរឹង ទំនុកបម្រុងនឹង ឲ្យផលក្នុង ៣-៤ ឆ្នាំសូមទ្រង់ត្រាស់ហៅធម្មទ្ធជបណ្ឌិតនោះមកហើយត្រាស់ ថា នែបណ្ឌិត យើងប្រពាតឧទ្យានចាស់មកយូរហើយ ឥឡូវនេះបំណងនឹង ប្រពាតឧទ្យានថ្មី ស្អែកនេះ យើងនឹងប្រពាតឧទ្យាន ចូរអ្នកសាងឧទ្យានថ្មី ឲ្យយើងចុះ ធម្មទ្ធជបណ្ឌិតនោះគង់សាងមិនបានដោយពិត ពេលនោះឯង ព្រះអង្គនឹងកាត់ទោសធម្មទ្ធជបណ្ឌិតបាន ។ ព្រះរាជាត្រាស់ហៅព្រះពោធិសត្វ មកត្រាស់តាមឧបាយដែលកាឡកសេនាបតីប្រាប់គ្រប់ប្រការ ។

ព្រះពោធិសត្វជ្រាបថា ព្រះរាជាត្រូវកាឡកសេនាបតីដែលមិនបានទទួលសំណូកញុះញង់ហើយទើបក្រាបទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំអាចដឹងឯង ត្រឡប់ទៅផ្ទះបរិភោគភោជនយ៉ាងល្អដេកគិតត្រង់ដំណេក ពិភពរបស់សក្កៈបានសម្តែងអាការៈក្តៅ ព្រះឥន្ទ្រពិនិត្យមើលក៏ដឹងថា ជាការគិតរបស់ព្រះពោធិសត្វ ប្រញាប់យាងមកចូលក្នុងបន្ទប់ដ៏មានសិរី ប្រថាប់ឈរលើអាកាសត្រាស់សួរថា នែបណ្ឌិត អ្នកកំពុងគិតអ្វី ព្រះពោធិសត្វសួរថា អ្នកជានរណា សក្កទេវរាជឆ្លើយថា យើងជាសក្កៈ ទើបព្រះពោធិសត្វប្រាប់ថា ព្រះរាជាឲ្យខ្ញុំសាងឧទ្យានថ្មី ខ្ញុំគិតថានឹងសាងបានដូចម្តេច សក្កទេវរាជត្រាស់ថា នែបណ្ឌិត អ្នកកុំគិតថ្វីឡើយយើងនឹងនិម្មិតឧទ្យានដូចគ្នានឹងនន្ទនវ័ននិងចិត្តលតាវ័នឲ្យអ្នក អ្នកឲ្យសាងក្នុងទីណា ។ ព្រះពោធិសត្វទូលថា សាងក្នុងទីនោះចុះ ។ សក្កទេវរាជនិម្មិតហើយត្រឡប់ទៅកាន់ទេវនគរ ។ ស្អែកឡើងព្រះពោធិសត្វឃើញឧទ្យានដោយប្រចក្សហើយ ទើបទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ឧទ្យានសម្រាប់ទ្រង់សម្រេចហើយ សូមទ្រង់ប្រពាតចុះ ។ ព្រះរាជាយាងទៅទតឃើញឧទ្យានព័ទ្ធដោយកំពែងមានពណ៌ដូចមនោសិលាកម្ពស់ ១៨ ហត្ថ មានទ្វារបរិបូណ៌លម្អដោយរុក្ខជាតិច្រើនពណ៌ចេញផ្លែពាសពេញ ត្រាស់សួរកាឡកសេនាបតីថា បណ្ឌិតបានធ្វើតាមពាក្យរបស់យើងហើយ ពេលនេះយើងនឹងធ្វើដូចម្តេចទៀត ។ កាឡកសេនាបតីក្រាបទូលថា បពិត្រព្រះសម្មតិទេព បណ្ឌិតអាចសាងឧទ្យានបានដោយប្រើពេលតែមួយយប់ មិនអាចដណ្តើមរាជសម្បត្តិបានឬ ព្រះរាជាត្រាស់សួរថា

ឥឡូវនេះយើងត្រូវធ្វើដូចម្ដេច កាឡកសេនាបតីក្រាបទូលថា យើងនឹងធ្វើកម្មហួសវិស័យដទៃ ព្រះរាជាត្រាស់សួរថា កម្មអ្វី កាឡកសេនាបតីក្រាបទូលថា សូមទ្រង់ឲ្យសាងស្រះបោក្ខរណីដែលសម្រេចដោយកែវ ៧ ប្រការ ព្រះរាជាទទួលថា សាធុ ឲ្យហៅព្រះពោធិសត្វមកត្រាស់ថា អាចារ្យ ឧទ្យានលោកបានសាងស្រេចហើយ ចូរលោកសាងស្រះបោក្ខរណីដែលសម្រេចដោយកែវ ៧ ប្រការដ៏សមគួរដល់ឧទ្យាននេះចុះ បើមិនអាចសាងបានទេ ជីវិតរបស់អ្នកក៏មិនមាន ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំអាចសាងថ្វាយបាន ។ លំដាប់នោះទើបសក្កទេវរាជនិម្មិតស្រះបោក្ខរណីដែលស្អាតក្រៃលែងមានកំពង់ ១០១ មានជណ្ដើរ ១០០០ ដេរដាសទៅដោយផ្កាបទុមដែលមានពណ៌ ៥ ដូចគ្នានឹងនន្ទនបោក្ខរណី ។ ស្អែកឡើងព្រះពោធិសត្វ បានធ្វើស្រះនោះឲ្យប្រចក្សហើយ ទើបទៅក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ទូលព្រះបង្គំសាងស្រះបោក្ខរណីស្រេចហើយ ។ ព្រះរាជាទតឃើញស្រះបោក្ខរណីនោះទើបត្រាស់សួរកាឡកសេនាបតីថា តើយើងធ្វើដូចម្ដេចទៀត កាឡកសេនាបតីក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យសាងផ្ទះធំដែលសមគួរដល់ឧទ្យាននោះចុះ ។ ព្រះរាជាត្រាស់ថា លោកអាចារ្យឥឡូវនេះចូរលោកសាងផ្ទះធំដែលសម្រេចដោយភ្លុកដំរីសមគួរដល់ឧទ្យាននិងស្រះបោក្ខរណីនេះចុះ បើសាងមិនបានជីវិតរបស់អ្នកមិនមានឡើយ ។ កាលនោះសក្កទេវរាជក៏និម្មិតផ្ទះធំឲ្យដល់ព្រះពោធិសត្វ ។ ស្អែកឡើងព្រះពោធិសត្វធ្វើផ្ទះធំនោះឲ្យប្រចក្សហើយ ក្រាបទូលដល់ព្រះរាជា ព្រះរាជាទតផ្ទះធំនោះ

ហើយទើបត្រាស់សួរកាឡកសេនាបតីថា ឥឡូវនេះតើធ្វើដូចម្ដេចទៀត កាឡកសេនាបតីនោះទូលថា បពិត្រមហារាជ សូមទ្រង់ត្រាស់ឲ្យសាងកែវមណី ដែលសមគួរដល់ផ្ទះធំនោះចុះ ។ ព្រះរាជាឲ្យហៅព្រះពោធិសត្វមកហើយ ត្រាស់ថា នែបណ្ឌិត អ្នកចូរសាងកែវមណីដែលសមគួរដល់ផ្ទះធំដែល សម្រេចដោយក្លុកដ៏រនេះចុះ យើងនឹងត្រាច់ទៅដោយពន្លឺនៃកែវមណី បើអ្នក ធ្វើមិនបានជីវិតរបស់អ្នកក៏មិនមានឡើយ ។ គ្រានោះសក្កៈនិម្មិតកែវមណីឲ្យ ព្រះពោធិសត្វ ។ ស្អែកឡើងព្រះពោធិសត្វធ្វើកែវមណីនោះឲ្យប្រចក្សហើយ ក្រាបទូលដល់ព្រះរាជា ព្រះរាជាទតឃើញកែវមណីនោះ ត្រាស់សួរកាឡកសេនាបតីថា ឥឡូវនេះតើយើងគិតធ្វើអ្វីទៀត ។ កាឡកសេនាបតីក្រាប ទូលថា បពិត្រមហារាជ ប្រហែលជាមានទេវតាចាំនិម្មិតវត្ថុឲ្យតាមប្រាថ្នាដល់ ធម្មទ្ធជព្រាហ្មណ៍ដោយពិត ពេលនេះវត្ថុណាសូម្បីតែទេវតាក៏មិនអាចនិម្មិត បានសូមទ្រង់ត្រាស់ឲ្យធ្វើវត្ថុនោះចុះ ទេវតាក៏មិនអាចនិម្មិតមនុស្ស ដែលប្រកប ដោយអង្គ ៤ បាន ព្រោះហេតុនោះ សូមទ្រង់ត្រាស់ឲ្យធម្មទ្ធជបណ្ឌិតសាង មនុស្សរក្សាឧទ្យានប្រកបដោយអង្គ ៤ ចុះ ។ ព្រះរាជាឲ្យព្រះពោធិសត្វមក ត្រាស់ថា នែអាចារ្យ ឧទ្យាន ស្រះបោក្ខរណី ប្រាសាទដែលសម្រេចដោយ ក្លុក កែវមណីសម្រាប់ឲ្យភ្លឺដល់ប្រាសាទ អ្នកសាងឲ្យដល់យើងស្រេចហើយ ឥឡូវនេះចូរអ្នកសាងមនុស្សរក្សាឧទ្យានប្រកបដោយអង្គ ៤ ធ្វើនាទីរក្សា ឧទ្យានដល់យើងចុះ បើអ្នកសាងមិនបានជីវិតនឹងមិនមាន ។ ព្រះពោធិសត្វ ក្រាបទូលថា សូមទុកជាភារៈរបស់ទូលព្រះបង្គំចុះ កាលទូលបង្គំសាងបាន

នឹងដឹងទើបត្រឡប់ទៅផ្ទះ បរិភោគអាហារយ៉ាងល្អហើយភ្ញាក់ឡើងក្នុងពេលមុនអរុណអង្គុយគិតលើដំណេកថា សក្កទេវរាជអាចនិម្មិតតែវត្ថុដែលខ្លួននិម្មិតបានតែគង់មិនអាចនិម្មិតអ្នកយាមឧទ្យានប្រកបដោយអង្គ ៤ បាន កាលបើដូច្នោះការស្លាប់យ៉ាងអនាថាក្នុងព្រៃនោះឯង ល្អជាងការស្លាប់ក្នុងកណ្ដាប់ដៃរបស់អ្នកដទៃ ។ ព្រះពោធិសត្វមិនបានប្រាប់ដល់បុគ្គលណាម្នាក់ ចុះអំពីផ្ទះ ចេញអំពីព្រះនគរតាមទ្វារធំចូលព្រៃ អង្គុយពិចារណាដល់ធម៌របស់សប្បុរសត្រង់គល់ឈើមួយដើម ។ សក្កទេវរាជជ្រាបហេតុនោះទើបកាឡាខ្លួនជាព្រានព្រៃចូលទៅរកព្រះពោធិសត្វ កាលត្រាស់សួរសេចក្ដីនេះថា នែព្រាហ្មណ៍ អ្នកជាបុគ្គលធ្លាប់មានសេចក្ដីសុខមិនធ្លាប់ជួបប្រសព្វនឹងសេចក្ដីទុក្ខចូលមកកាន់ព្រៃអង្គុយធ្វើអ្វីទើបពោលគាថាទីមួយថា

អ្នកមានសភាពរស់នៅជាសុខ ចេញចាកដែនហើយមកកាន់
ព្រៃដ៏ស្ងាត់ អ្នកនោះតែម្នាក់ឯងអង្គុយសញ្ជប់សញ្ជឹងនៅជិត
គល់ឈើ ( ក្នុងព្រៃ ) ដូចជាមនុស្សកំព្រា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុខំ ជីវិតរូបោសិ** សេចក្ដីថា អ្នកតាំងនៅក្នុងសេចក្ដីសុខ មានជីវិតនៅដោយសេចក្ដីសុខ គឺដូចបរិហារឲ្យមានសេចក្ដីសុខ ។ បទថា **រដ្ឋា** គឺ ចេញចាកដែនដែលច្រឡូកច្រឡំដោយមនុស្ស ។ បទថា **វិវនមាគតោ** គឺ ចូលកាន់ព្រៃស្ងាត់ដែលជាទីមិនមានទឹក ។ បទថា **រុក្ខមូលេ** គឺ ជិតគល់ឈើ ។ បទថា **កបណោ វិយ ឈាយសិ** សេចក្ដីថា អ្នកអង្គុយសុបសៅម្នាក់ឯង ដូចមនុស្សកំព្រា ។

សក្កទេវរាជត្រាស់សួរថា អ្នកគិតអ្វី ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបពោលគាថាទីពីរថា

ខ្ញុំមានសភាពរស់នៅជាសុខ ចេញចាកដែនហើយមកកាន់ព្រៃស្ងាត់ ខ្ញុំនោះតែម្នាក់ឯង ការរឭកធម៌របស់សប្បុរស អង្គុយសញ្ជប់សញ្ជឹងជិតគល់ឈើ ( ក្នុងព្រៃ ) ដូចជាមនុស្សកំព្រាដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតំ ធម្មំ អនុស្សរំ** សេចក្តីថា នែសម្លាញ់ នោះជាសេចក្តីពិត ខ្ញុំនៅជាសុខហើយបានចេញអំពីដែនមកកាន់ព្រៃស្ងាត់ ខ្ញុំម្នាក់ឯងប៉ុណ្ណោះ អង្គុយជិតគល់ឈើក្នុងព្រៃនេះរមែងស្ងប់ស្ងៀម ដូចមនុស្សកំព្រា អ្នកបានសួរថា អ្នកគិតអ្វី ខ្ញុំសូមប្រាប់ដល់អ្នក ។ បទថា **សតំ ធម្មំ** សេចក្តីថា ខ្ញុំអង្គុយក្នុងទីនេះជញ្ជឹងគិតដល់ធម៌របស់អ្នកស្ងប់ ធម៌របស់បណ្ឌិតគឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះសាវកទាំងឡាយ ពិតហើយលោកធម៌ ៨ ប្រការនេះគឺ មានលាភ អត់លាភ មានយស អត់យស សរសើរ និន្ទា សុខ ទុក្ខ តែសប្បុរសទាំងឡាយទោះលោកធម៌ ៨ នេះពាល់ត្រូវហើយ រមែងមិនញាប់ញ័រ មិនកម្រើក ធម៌របស់សប្បុរសបានដល់ការមិនញាប់ញ័រ ក្នុងលោកធម៌ ៨ នេះ ខ្ញុំអង្គុយរឭកដល់ធម៌នេះដោយប្រការដូច្នេះ ។

លំដាប់នោះទើបសក្កៈត្រាស់សួរថា នែព្រាហ្មណ៍ កាលបើដូច្នោះហេតុដូចម្តេចទើបអ្នកអង្គុយក្នុងទីនេះ ព្រះពោធិសត្វឆ្លើយថា ព្រះរាជាត្រាស់ឲ្យខ្ញុំសាងមនុស្សរក្សាឧទ្យាន ដែលប្រកបដោយអង្គ ៤ តែខ្ញុំមិនអាចសាង

បុគ្គលបែបនោះបានទើបគិតថា មានប្រយោជន៍អ្វីដោយការស្លាប់ក្នុងកណ្តាប់ដៃរបស់អ្នកដទៃ អញនឹងទៅព្រៃស្លាប់យ៉ាងអនាថាទើបមកអង្គុយក្នុងទីនេះ ។ សក្កទេវរាជត្រាស់ថា នែព្រាហ្មណ៍ ខ្ញុំគឺសក្កទេវរាជ ខ្ញុំនិម្មិតឧទ្យានឲ្យអ្នកហើយតែមិនអាចនិម្មិតអ្នករក្សាឧទ្យានដែលប្រកបដោយអង្គ ៤ បាន ។ ជាងកោរកាត់របស់ព្រះរាជាឈ្មោះឆត្តបាណិជាមនុស្សប្រកបដោយអង្គ ៤ បើអ្នកត្រូវការអ្នករក្សាឧទ្យានចូរក្រាបទូលឲ្យទ្រង់តែងតាំងជាងកោរកាត់នោះជាអ្នករក្សាឧទ្យានចុះ ។ សក្កទេវរាជប្រទានឱវាទដល់ព្រះពោធិសត្វហើយ ទ្រង់លួងលោមថា កុំខ្លាចឡើយ ។ ហើយទ្រង់យាងទៅកាន់ទេវបុរីវិញ ។ ព្រះពោធិសត្វទៅផ្ទះបរិភោគអាហារហើយ ទៅដល់ខ្លោងទ្វារព្រះរាជវាំងជួបឆត្តបាណិត្រង់ទ្វារព្រះរាជវាំងនោះ ចាប់ដៃឆត្តបាណិហើយសួរថា ឆត្តបាណិសម្លាញ់ បានឮថា អ្នកប្រកបដោយអង្គ ៤ ឬ ឆត្តបាណិសួរថា អ្នកណាប្រាប់លោកថាខ្ញុំប្រកបដោយ អង្គ ៤ ព្រះពោធិសត្វឆ្លើយថា សក្កទេវរាជ ។ ឆត្តបាណិសួរថា ហេតុអ្វីទើបប្រាប់ ទើបព្រះពោធិសត្វដំណាលរឿងទាំងអស់ហើយពោលថា ប្រាប់ដោយហេតុឈ្មោះនេះ ។ ឆត្តបាណិពោលថា ត្រូវហើយខ្ញុំជាមនុស្សប្រកបដោយអង្គ ៤ ។ លំដាប់នោះ ទើបព្រះពោធិសត្វយកដៃចាប់ដៃឆត្តបាណិទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ ឆត្តបាណិនេះជាបុគ្គលប្រកបដោយអង្គ ៤ ។ បើទ្រង់ត្រូវការអ្នករក្សាឧទ្យាន សូមទ្រង់តាំងឆត្តបាណិនេះឲ្យជាអ្នករក្សាឧទ្យានចុះ ។ លំដាប់នោះព្រះរាជាត្រាស់សួរឆត្តបាណិថា បានឮថា អ្នកជាបុគ្គលប្រកបដោយអង្គ ៤ ឬ ឆត្តបាណិក្រាប

ទូលថា បពិត្រព្រះសម្មតិទេព ពិតហើយ ។ ព្រះរាជាត្រាស់សួរថាអ្នកប្រកបដោយអង្គ ៤ គឺអ្វីខ្លះ ឆត្តបាណិទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលព្រះបង្គំមិនប្រណែន ជាអ្នកមិនផឹកនូវទឹកស្រវឹង ជាអ្នកមិនជាប់ក្នុងសេចក្តីស្រឡាញ់ ជាអ្នកតាំងមាំក្នុងការមិនក្រោធ ។

បពិត្រមហារាជ ឈ្មោះថា សេចក្តីប្រណែនមិនមានដល់ទូលព្រះបង្គំ ទឹកស្រវឹងទូលព្រះបង្គំមិនធ្លាប់ផឹក ការស្រឡាញ់ក្តី សេចក្តីក្រោធក្តីក្នុងអ្នកដទៃមិនធ្លាប់មានក្នុងទូលព្រះបង្គំឡើយ ទូលព្រះបង្គំប្រកបដោយអង្គទាំង ៤ នេះ ។

លំដាប់នោះព្រះរាជាត្រាស់សួរថា នែឆត្តបាណិ អ្នកមិនប្រណែនឬ ឆត្តបាណិក្រាបទូល បពិត្រព្រះអង្គ ពិតហើយទូលព្រះបង្គំជាអ្នកមិនប្រណែន ។ ព្រះរាជាត្រាស់ថា អ្នកឃើញហេតុអ្វីទើបមិនប្រណែន ឆត្តបាណិក្រាបទូលថា សូមទ្រង់ស្តាប់ចុះ កាលនឹងពោលដល់ហេតុនៃការមិនប្រណែនទើបពោលគាថានេះថា

បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំបានឲ្យគេចងបុរោហិតព្រោះ
ស្រីជាហេតុ បុរោហិតនោះឲ្យទូលព្រះបង្គំតាំងនៅក្នុងប្រយោជន៍
ហើយ ព្រោះហេតុនោះទើបទូលព្រះបង្គំមិនប្រណែនដូច្នេះ ។

សេចក្តីអធិប្បាយនៃគាថានោះថា ទូលព្រះបង្គំនេះឯង កាលមុនជាព្រះរាជាក្នុងក្រុងពារាណសីនោះឯងដូចគ្នានឹងព្រះអង្គ ឲ្យចងនូវបុរោហិតព្រោះស្រីជាហេតុ គឺក្នុងកាលនោះ ជាងកោរកាត់ឆត្តបាណិនេះជាព្រះរាជាត្រូវព្រះទេវី

ផិតក្បត់ជាមួយពួកបាទមូល ៦៤ នាក់ ព្រះទេវីនោះប្រាថ្នានឹងធ្វើព្រះពោធិ-សត្វដែលមិនស្រឡាញ់ខ្លួនឲ្យវិនាស ទូលញុះញង់ឲ្យព្រះរាជាចាប់ចងតាមន័យដែលមកហើយក្នុង ( ពន្ធនមុខ ) ជាតកនេះថា

ជនពាលទាំងឡាយពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់
រមែងជាប់នៅក្នុងទីនោះ អ្នកប្រាជ្ញទាំងឡាយពោលក្នុងទីណា
ពួកជនសូម្បីជាប់ហើយរមែងរួចក្នុងទីនោះ ដូច្នេះ ។

ក្នុងកាលនោះព្រះពោធិសត្វត្រូវចងនាំទៅគាល់ ទើបក្រាបទូលទោសរបស់ព្រះទេវីតាមសេចក្តីពិត បានរួចផុតចំណង បានទូលឲ្យដោះលែងពួកបាទមូលដែលចងទាំងអស់នោះថ្វាយឱវាទថា បពិត្រមហារាជ សូមទ្រង់លើកលែងទោសឲ្យដល់ពួកបាទមូលទាំងនោះនិងព្រះទេវីផងចុះ ។ រឿងទាំងអស់គប្បីជ្រាបដោយពិស្តារតាមន័យដែលពោលហើយខាងដើមនោះឯង ។

ឆត្តបាណិសំដៅដល់សេចក្តីនោះទើបពោលថា

បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំបានឲ្យគេចងបុរោហិតព្រោះ
ស្រីជាហេតុ បុរោហិតនោះឲ្យទូលបង្គំតាំងនៅក្នុងប្រយោជន៍
ហើយព្រោះហេតុនោះទើបទូលព្រះបង្គំមិនប្រណែន ដូច្នេះ ។

ក្នុងកាលនោះព្រះរាជា ( ឆត្តបាណិ ) នោះគិតថា អញលះបង់ស្នំ ១៦០០០ នាក់ ស្នេហស្ម័គ្រតែព្រះទេវីមួយអង្គប៉ុណ្ណោះ ដោយអំណាចកិលេសគង់មិនអាចឲ្យនាងឆ្អែតបានឈ្មោះថា ការក្រោធចំពោះស្រីទាំងឡាយដែលបំពេញបានដោយក្រយ៉ាងនេះ ក៏ដូចគ្នានឹងការក្រោធខឹងនឹងសំពត់ស្លៀកដែល

សៅហ្មងថា ហេតុអ្វីទើបសៅហ្មង និងដូចគ្នានឹងការក្រោធខឹងចំពោះអាហារ ដែលបរិភោគហើយ ដែលក្លាយទៅជាករីសថា ហេតុអ្វីទើបក្លាយទៅជាលាមក ដូច្នេះ ។ តាំងអំពីនោះមក ទូលព្រះបង្គំអធិដ្ឋានថា បើមិនអាចសម្រេចអរហត្ត ដរាបណាឥស្សា គឺសេចក្តីប្រណែនកុំកើតមានដល់ទូលព្រះបង្គំព្រោះអាស្រ័យ កិលេសដរាបនោះ តាំងអំពីនោះមកព្រះរាជាអង្គនោះមិនប្រណែនឡើយ ឆត្តបាណិជាងកោរកាត់ពោលថា ព្រោះហេតុនោះទើបទូលព្រះបង្គំមិនប្រណែន សំដៅដល់រឿងនេះឯង ។

លំដាប់នោះព្រះរាជាត្រាស់សួរថា នែឆត្តបាណិ អ្នកឃើញអារម្មណ៍ដូចម្តេចទើបមិនផឹកទឹកស្រវឹង ឆត្តបាណិកាលក្រាបទូលហេតុនោះទើបពោលគាថា នេះថា

បពិត្រមហារាជ ទូលព្រះបង្គំស្រវឹងហើយទើបស៊ីនូវសាច់កូន
ឯង ទូលព្រះបង្គំត្រូវសេចក្តីសោកដល់បុត្តនោះពាល់ត្រូវ
ហើយទើបវៀរនូវការផឹកទឹកស្រវឹង ដូច្នេះ ។

សេចក្តីអធិប្បាយក្នុងគាថានោះថា បពិត្រមហារាជ ក្នុងកាលមុនទូលព្រះបង្គំជាស្តេចពារាណសីដូចទ្រង់ដែរ បើអត់ទឹកស្រវឹងមិនអាចតម្កល់ជីវិតឲ្យប្រព្រឹត្តទៅបានសូម្បីអាហារដែលមិនមានសាច់ ក៏មិនអាចបរិភោគបាន ។ ក្នុងនគរមិនមានអ្នកសម្លាប់សត្វក្នុងថ្ងៃឧបោសថ អ្នកពិសេសទិញសាច់មកទុកតាំងពីថ្ងៃ ១៣ នៃបក្ខ សាច់នោះទុកមិនល្អត្រូវឆ្កែស៊ីអស់ អ្នកពិសេសរកសាច់ក្នុងថ្ងៃឧបោសថមិនបាន ទើបចម្អិនអាហារមានរសប្រសើរផ្សេងៗសម្រាប់

ព្រះរាជា លើកឡើងទៅលើប្រាសាទតែមិនអាចនាំចូលទៅបាន ទើបចូលទៅគាល់ព្រះទេវីក្រាបទូលថា បពិត្រព្រះទេវី ថ្ងៃនេះទូលព្រះបង្គំរកសាច់មិនបាន ទើបមិនអាចនាំព្រះក្រយាហារដែលមិនមានសាច់ចូលទៅថ្វាយបាន ទូលព្រះបង្គំនឹងធ្វើដូចម្ដេច ព្រះទេវីត្រាស់ថា នេះឱរសរបស់យើង ជាទីស្រឡាញ់ប្រោសប្រាណរបស់ព្រះរាជា ព្រះរាជាទ្រង់ឃើញឱរសរបស់យើងហើយក៏ទ្រង់ឱបថើបឱរសនោះរហូតទ្រង់មិនជ្រាបថា សាច់មានឬមិនមានសម្រាប់ព្រះអង្គ ។ យើងនឹងតែងខ្លួនឲ្យព្រះឱរសហើយឲ្យអង្គុយលើភ្លៅរបស់ព្រះរាជា កាលទ្រង់លេងជាមួយព្រះឱរសសឹមអ្នកនាំព្រះក្រយាហារចូលទៅថ្វាយ ព្រះទេវីមានព្រះសវនីយ៍ដូច្នោះហើយ ទើបតាក់តែងព្រះរាជកុមារនាំទៅឲ្យអង្គុយលើភ្លៅរបស់ព្រះរាជា ។ ក្នុងពេលដែលព្រះរាជាទ្រង់លេងជាមួយព្រះឱរស ទើបអ្នកពិសេសនាំព្រះក្រយាហារចូលទៅថ្វាយ ព្រះរាជាទ្រង់ស្រវឹងស្រា ទ្រង់មិនឃើញសាច់ក្នុងថាសទើបត្រាស់សួរថា សាច់នៅឯណា ទើបអ្នកពិសេសក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំរកសាច់មិនបាន ព្រោះថ្ងៃនេះជាថ្ងៃឧបោសថ មិនមានការសម្លាប់សត្វទើបព្រះរាជាត្រាស់សួរថា ឈ្មោះថាសាច់សម្រាប់យើងរកបានលំបាកណាស់ឬ ទើបទ្រង់កាច់កព្រះឱរស ដែលអង្គុយលើភ្លៅរហូតអស់ជីវិតបោះទៅខាងមុខអ្នកពិសេសត្រាស់ថា ចូរចម្អិនឲ្យឆាប់ ។ អ្នកពិសេសបានធ្វើតាមរាជបញ្ជា ។ ព្រះរាជាសោយព្រះក្រយាហារដែលចម្អិនដោយសាច់បុត្ត ហើយមិនមានអ្នកណាយំឲ្យព្រះរាជាឃើញសូម្បីតែម្នាក់ព្រោះខ្លាចព្រះរាជា ។ ព្រះរាជាកាលសោយស្រេចហើយយាង

ចូលព្រះបន្ទំ ទ្រង់តើនឡើងក្នុងពេលទៀបភ្លឺ ទ្រង់ស្វាងស្រាហើយត្រាស់ថា ចូរនាំឱរសរបស់យើងមក ។ ក្នុងកាលនោះព្រះទេវីទ្រង់ព្រះកន្សែងទៀបបាទា កាលព្រះរាជាត្រាស់សួរថា តើនាងយំរឿងអ្វីក៏ក្រាបទូលថា បពិត្រព្រះអង្គ ម្សិលមិញនេះទ្រង់សម្លាប់ព្រះឱរសរួចហើយសោយសាច់ ។ ព្រះរាជាទ្រង់ខ្សឹកខ្សួលដល់ព្រះឱរស ទ្រង់ឃើញទោសក្នុងការផឹកទឹកស្រវឹងថា ទុក្ខនេះកើតឡើងដល់អញព្រោះអាស្រ័យការផឹកទឹកស្រវឹង ហើយទ្រង់ក្រោកឡើងក្តាប់ធូលីយកមកលាបមុខ ទ្រង់អធិដ្ឋានថា តាំងអំពីថ្ងៃនេះទៅបើមិនទាន់សម្រេចអរហត្តដរាបណា អញនឹងមិនផឹកស្រាដែលធ្វើនូវសេចក្តីវិនាសបែបនេះដរាបនោះ ។

តាំងពីកាលនោះមក ទ្រង់មិនបានផឹកទឹកស្រវឹងទៀតឡើយ ឆត្តបាណិជាងកោរកាត់ពោលគាថានេះថា **មត្តោ អហំ មហារាជ** បពិត្រមហារាជ ទូលព្រះបង្គំស្រវឹងហើយ គឺសំដៅដល់រឿងនេះ ។

លំដាប់នោះព្រះរាជាត្រាស់សួរថា នែឆត្តបាណិ អ្នកឃើញអារម្មណ៍ដូចម្តេចទើបមិនមានសេចក្តីស្រឡាញ់ ។ ឆត្តបាណិកាលទូលហេតុនោះ ទើបពោលគាថានេះថា

ទូលព្រះបង្គំជាព្រះរាជាឈ្មោះថា កិតវាស ឱរសរបស់ទូលព្រះបង្គំបំបែកបាត្ររបស់ព្រះបច្ចេកពុទ្ធហើយដល់នូវការអស់ជីវិត ទូលព្រះបង្គំមិនមានសេចក្តីស្រឡាញ់ព្រោះឱរសនោះជាហេតុ ដូច្នេះ ។

សេចក្ដីក្នុងគាថានេះថា បពិត្រមហារាជ កាលមុនទូលព្រះបង្គំជាព្រះរាជាឈ្មោះកិតវាសក្នុងក្រុងពារាណសី ។ ឱរសរបស់ទូលព្រះបង្គំបានប្រសូតលុះប្រសូតហើយ ហោរាឃើញលក្ខណៈព្រះឱរសហើយទាយថា បពិត្រមហារាជ ព្រះឱរសនេះនឹងអស់ព្រះជន្មដោយការមិនមានទឹក ។ ព្រះជនកព្រះជននីថ្វាយព្រះនាមឱរសនោះថា ទុដ្ឋកុមារ ។ កុមារនោះកាលចម្រើនវ័យហើយបានតំណែងជាឧបរាជ ។ ព្រះរាជាឲ្យព្រះរាជកុមារយាងតាមទ្រង់ពីមុខខ្លះ ពីក្រោយខ្លះជានិច្ចព្រោះខ្លាចឱរសអត់ទឹកអស់ព្រះជន្ម ទើបឲ្យជីកស្រះបោក្ខរណីទុកក្នុងទីនោះៗខាងក្នុងព្រះនគរ ក្បែរទ្វារទាំង ៤ ឲ្យសាងមណ្ឌបទុកតាមផ្លូវបែកជា ៤ ជាដើមហើយឲ្យតម្កល់ពាងទឹកទុក ។ ថ្ងៃមួយព្រះរាជកុមារតែងព្រះកាយយាងប្រពាតឧទ្យានអំពីព្រលឹម ជួបព្រះបច្ចេកពុទ្ធក្នុងចន្លោះផ្លូវ ។ មហាជនឃើញព្រះបច្ចេកពុទ្ធហើយក៏ក្រាបថ្វាយបង្គំ សរសើរនិងផ្គងអញ្ជលីដល់ព្រះបច្ចេកពុទ្ធនោះ ។ ព្រះរាជកុមារនោះគិតថា ជនដែលទៅជាមួយនិងមនុស្សដូចអញនាំគ្នាក្រាបថ្វាយបង្គំ ផ្គងអញ្ជលីសរសើរដល់សមណៈត្រងោលនេះ ទ្រង់ពិរោធចុះអំពីកដំរីចូលទៅរកព្រះបច្ចេកពុទ្ធត្រាស់សួរថា សមណៈលោកបានភត្តាហារដែរឬ ព្រះបច្ចេកពុទ្ធប្រាប់ថា បានហើយព្រះរាជកុមារ ។ ទើបព្រះរាជកុមារដណ្ដើមបាត្រអំពីដៃព្រះបច្ចេកពុទ្ធបោកលើផែនដី ជាន់ភត្តាហារឲ្យបែកទៅ ព្រះបច្ចេកពុទ្ធសម្លឹងមើលព្រះភក្ត្ររាជកុមារគិតថា សត្វនេះដល់នូវសេចក្ដីវិនាសហើយហ្ន៎ ។ រាជកុមារត្រាស់ថា នែសមណៈ យើងជាកូនរបស់ព្រះបាទកិតវាសឈ្មោះ ទុដ្ឋកុមារ លោកខឹងនឹង

យើង សម្លឹងមើលមុខយើងនឹងធ្វើអ្វីយើងបាន ។ ព្រះបច្ចេកពុទ្ធកាលបាត្រ បែកហើយក៏ហោះទៅកាន់អាកាសឆ្ពោះទៅកាន់ភ្នំនន្ទមូលកៈ ក្នុងហិមវន្តប្បទេស នាទិសឧត្តរ ។ ខណៈនោះឯងកម្មអាក្រក់របស់ព្រះរាជកុមារបានឲ្យផលជា ទិដ្ឋធម្មវេទនីយកម្ម ។ ព្រះរាជកុមារមានព្រះវរកាយក្តៅក្រហាយស្រែកថា ក្តៅណាស់ ក្តៅណាស់ ដួលចុះក្នុងទីនោះឯង ទឹកទាំងអស់ដែលមានក្នុង ទីនោះៗក៏រីងស្ងួតទៅ ស្រះទាំងឡាយក៏ខះអស់ ព្រះរាជកុមារអស់ជីវិតក្នុង ទីនោះឯងទៅកើតក្នុងអវីចីនរក ។

ព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ ត្រូវសេចក្តីសោកដល់ព្រះឱរសគ្រប សង្កត់ទ្រង់ត្រិះរិះថា សេចក្តីសោករបស់អញកើតអំពីវត្ថុដែលជាទីស្រឡាញ់ បើអញមិនមានសេចក្តីស្រឡាញ់ហើយ សេចក្តីសោកនឹងមិនកើតឡើង តាំង អំពីនេះជាដើមទៅឈ្មោះថា សេចក្តីស្រឡាញ់ក្នុងវត្ថុណាមួយ ទោះមាន វិញ្ញាណឬមិនមានវិញ្ញាណកុំកើតឡើងដល់អញឡើយ ទ្រង់អធិដ្ឋានដូច្នេះ ហើយ តាំងអំពីនោះមកក៏មិនមានសេចក្តីស្រឡាញ់ឡើយ ឆត្តបាណិពោល គាថាជាដើមថា **កិតវាសោ ឆាមាហំ** ទូលព្រះបង្គំជាព្រះរាជាឈ្មោះថា កិតវាស គឺសំដៅដល់រឿងនេះ ។

លំដាប់នោះព្រះរាជាត្រាស់សួរឆត្តបាណិថា នែឆត្តបាណិ អ្នកឃើញ អារម្មណ៍ដូចម្តេចទើបជាបុគ្គលមិនក្រោធ ។ ឆត្តបាណិកាលទូលសេចក្តីនោះ ទើបពោលគាថានេះថា

ទូលព្រះបង្គំជាតាបសឈ្មោះថា អរកៈ ចម្រើនមេត្តាចិត្តអស់

៧ ឆ្នាំ ទៅនៅក្នុងព្រហ្មលោកអស់ ៧ កប្ប ព្រោះដូច្នោះ
ទើបជាអ្នកមិនក្រោធ ដូច្នេះ ។

សេចក្តីក្នុងគាថានោះថា បពិត្រមហារាជ ទូលព្រះបង្គំជាតាបសឈ្មោះអរកៈ ចម្រើនមេត្តាចិត្តអស់ ៧ ឆ្នាំហើយទៅកាន់ព្រហ្មលោក ៧ សំវដ្ដ-វិវដ្ដកប្ប ទើបទូលព្រះបង្គំនោះជាអ្នកមិនក្រោធព្រោះសន្សំមេត្តាភាវនាអស់កាលយូរ ។

កាលធត្តបាណិក្រាបទូលអង្គ ៤ របស់ខ្លួនយ៉ាងនេះហើយព្រះរាជាទ្រង់ឲ្យសញ្ញាដល់បរិស័ទ រំពេចនោះឯងពួកអាមាត្យមានព្រាហ្មណ៍និងគហបតីជាដើមក្រោកឡើងពោលថា នែចោរស៊ីសំណូក ឯងជាចោរកាច មិនបានស៊ីសំណូកហើយគិតនឹងសម្លាប់បណ្ឌិត នាំគ្នាចាប់ដៃនិងជើងកាឡកសេនាបតីនាំចុះអំពីព្រះរាជនិវេសន៍ គប់ក្បាលដោយដុំថ្មនិងកំណាត់ឈើម្នាក់មួយដុំវាយម្នាក់មួយដៃរហូតដល់ស្លាប់ ទើបចាប់ជើងអូសទៅចោលត្រង់គំនរសំរាម ។ តាំងអំពីកាលនោះ ព្រះរាជាទ្រង់គ្រងរាជសម្បត្តិដោយធម៌ កាលសោយទិវង្គតហើយក៏យាងទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយទ្រង់ប្រជុំជាតកថា កាឡក-សេនាបតីក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ធត្តបាណិក្នុងកាលនោះបានមកជាអានន្ទ[១] សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ

---

១-ក្នុងបាលីអដ្ឋកថាជាព្រះសារីបុត្ត តែក្នុងពន្ធនមោក្ខជាតកព្រះរាជាដែលបញ្ជាឲ្យចងព្រះពោធិសត្វនោះជាតួអង្គព្រះអានន្ទ ទើបយើងលើកយកព្រះអានន្ទមកដាក់ក្នុងទីនេះបណ្ឌិតគប្បីបិចារណា ។

ចំណែកធម្មទ្ធជបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ធម្មទ្ធជជាតក ចប់

## ពីរណថម្ភវគ្គ ចប់

# កាសាវវគ្គ

## កាសាវជាតក

[ ២៩១ ] ( ដំរីពោធិសត្វពោលថា ) បុគ្គលណាមានទឹកចត់ គឺកិលេស មិនទាន់លះចេញហើយ ជាអ្នកប្រាសចាកទមៈ ( ការទូន្មាននូវឥន្ទ្រិយ ) និងសច្ចៈ នឹងស្លៀកដណ្ដប់នូវសំពត់ដែលជ្រលក់ដោយទឹកចត់ បុគ្គលនោះមិនគួរនឹងស្លៀកដណ្ដប់នូវសំពត់ជ្រលក់ដោយទឹកចត់ឡើយ ។

[ ២៩២ ] ចំណែកខាងបុគ្គលណាមានទឹកចត់ គឺកិលេសខ្ជាក់ចោលហើយ មានចិត្តតាំងមាំល្អក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយទមៈនិងសច្ចៈ បុគ្គលនោះឯងទើបគួរនឹងស្លៀកដណ្ដប់នូវសំពត់ជ្រលក់ដោយទឹកចត់បាន ។

**ចប់ កាសាវជាតកទី ១ ។**

# កាសាវវគ្គ

## អដ្ឋកថា កាសាវជាតក

[ ២៩១-២៩២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អនិក្កសាវោ កាសាវំ** ដូច្នេះជាដើម ។

ប៉ុន្តែរឿងកើតឡើងក្នុងនគររាជគ្រឹះ ។

សម័យមួយព្រះធម្មសេនាបតី គង់ក្នុងវត្តវេឡុវនមហាវិហារជាមួយភិក្ខុ ៥០០ រូប ។ កាលនោះទេវទត្តចោមរោមទៅដោយបរិស័ទដែលទ្រុស្តសីល សមគួរដល់ខ្លួនក្នុងគយាសីសប្បទេស សម័យនោះអ្នកក្រុងរាជគ្រឹះផ្តួចផ្តើមត្រៀមនូវទាន ។ កាលនោះមានឈ្មួញដើរលក់ដូរម្នាក់បានឲ្យសំពត់កាសាវៈមានក្លិនក្រអូបមានតម្លៃច្រើនដោយពោលថា សូមអ្នកទាំងឡាយចាត់ចែងសំពត់នេះហើយឲ្យខ្ញុំមានចំណែកបុណ្យរួមផងចុះ ។ អ្នកនគរថ្វាយទានសន្ធឹកសន្ធាប់ វត្ថុទានគ្រប់យ៉ាងដែលរួបរួមគ្នារៀបចំស្រេចបាច់ហើយដោយកហាបណៈទាំងនោះ ។ សំពត់សាដកនោះនៅសល់ ។ មហាជនប្រជុំគ្នាថា សំពត់សាដកមានក្លិនក្រអូបមួយផ្ទាំងនេះជារបស់ប្រសើរ យើងនឹងប្រគេនសំពត់ផ្ទាំងនេះដល់លោកម្ចាស់អង្គណា នឹងប្រគេនដល់ព្រះសារីបុត្ត ឬព្រះទេវទត្តហ្ន៎ ។ ក្នុងមនុស្សទាំងនោះពួកខ្លះពោលថា នឹងប្រគេនដល់ព្រះសារីបុត្តត្រូវពួកខ្លះទៀតពោលថា ព្រះសារីបុត្តលោកនៅ ២-៣ ថ្ងៃ ក៏នឹងចៀសចេញទៅតាមគាប់ចិត្ត ចំណែកលោកម្ចាស់ទេវទត្ត អាស្រ័យនគររបស់យើងជាប្រចាំ

លោកម្ចាស់អង្គនេះឯងបានជាទីពឹងរបស់យើងទាំងឡាយ ក្នុងការងារមង្គលផង និងការងារអវមង្គលផង ពួកយើងនឹងប្រគេនដល់លោកម្ចាស់ទេវទត្ត ។

ជនដែលពោលទាំងនោះជនដែលពោលថា នឹងប្រគេនដល់លោកម្ចាស់ទេវទត្តមានច្រើនជាងទើបមហាជនប្រគេនដល់ទេវទត្តភិក្ខុ ។ ទេវទត្តឲ្យជាងកាត់សំពត់កាសាវៈមានក្លិនក្រអូបនោះហើយឲ្យដេរជា ២ ជាន់ ឲ្យជ្រលក់រហូតមានពណ៌ដូចជំបារមាស ។

ក្នុងកាលនោះភិក្ខុប្រមាណ ៣០០ រូប ចេញអំពីក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថី ថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ បានទូលឲ្យទ្រង់ជ្រាបរឿងថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តស្លៀកដណ្តប់កាសាវៈដែលជាទង់ជ័យអរហត្តមិនសមគួរដល់ខ្លួនយ៉ាងនេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តស្លៀកដណ្តប់សំពត់កាសាវៈដែលជាទង់អរហត្តមិនសមគួរដល់ខ្លួនក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនទេវទត្តក៏ស្លៀកដណ្តប់ហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតក្នុងត្រកូលដំរីក្នុងហិមវន្តប្បទេស លុះធំចម្រើនវ័យហើយបានជាមេហ្វូងមានដំរី ៨៤០០០ ជាបរិវារអាស្រ័យក្នុងដងព្រៃ ។ កាលនោះមានមនុស្សទុគ៌តម្នាក់អាស្រ័យនៅនគរពារាណសីឃើញជាងធ្វាក់ភ្លុកត្រង់ដងវិថីនៃពួកជាងភ្លុក កំពុងធ្វាក់ភ្លុកផ្សេងៗមានកងដៃភ្លុកជា

ដើមទើបសួរថា បើបានក្អកដីរហើយអ្នកទិញដែរឬទេ ។ ពួកជាងក្អកឆ្លើយថា យើងទិញ ។ បុរសនោះទុគ៌តនោះទទួលថា ប្រពៃហើយទើបកាន់អាវុធស្លៀកដណ្តប់សំពត់ជ្រលក់ដោយទឹកចត់ធ្វើដូចជាព្រះបច្ចេកពុទ្ធ ទទូរក្បាលឈរត្រង់ទីដីរធ្វេងកាត់ ប្រើអាវុធសម្លាប់ដីរហើយយកក្អកមកលក់ឯនគរពារាណសីចិញ្ចឹមជីវិត ។ តមកមនុស្សក្រីក្រនោះបានសម្លាប់ដីរបរិវាររបស់ព្រះពោធិសត្វដែលដើរក្រោយគេ កាលដីររលស់ទៅរាល់ថ្ងៃទើបពួកដីរប្រាប់ដល់ព្រះពោធិ-សត្វថា ដីរបាត់ទៅដោយហេតុអ្វីហ្ន៎ ព្រះពោធិសត្វសង្កេតមើលក៏ដឹងថា បុរសម្នាក់កាន់យកភេទដូចព្រះបច្ចេកពុទ្ធឈរត្រង់ផ្លូវដីរធ្វេងកាត់ បុរសនោះទេដឹងសម្លាប់ដីរ អញនឹងចាំចាប់បុរសនោះ ។ ថ្ងៃមួយទើបឲ្យពួកដីរដើរទៅខាងមុខ ខ្លួនឯងដើរឯក្រោយ ។ បុរសនោះឃើញព្រះពោធិសត្វ ទើបផ្ងារអាវុធតម្រង់ចូលទៅ ។ ព្រះពោធិសត្វថយត្រឡប់មកឈរគិតថានឹងចាប់បោកលើផែនដីឲ្យស្លាប់ទើបបួងដោយប្រមោយឃើញសំពត់កាសាវៈដែលមនុស្សនោះដណ្តប់គិតថា សំពត់កាសាវៈជាទង់របស់ព្រះអរហន្តនេះអញគួរធ្វើការគោរពទើបលែងវិញហើយពោលថា នែបុរស សំពត់ដែលជាទង់របស់ព្រះអរហន្តនេះមិនសមគួរដល់អ្នកមិនមែនឬ ហេតុអ្វីទើបអ្នកដណ្តប់សំពត់នោះ ហើយពោលគាថាទាំងនេះថា

បុគ្គលណាមានទឹកចត់ គឺកិលេសមិនទាន់លះចេញហើយ
ជាអ្នកប្រាសចាកទមៈ ( ការទូន្មាននូវឥន្ទ្រិយ ) និងសច្ច
នឹងស្លៀកដណ្តប់នូវសំពត់ដែលជ្រលក់ដោយទឹកចត់ បុគ្គល

នោះមិនគួរនឹងស្លៀកដណ្តប់នូវសំពត់ជ្រលក់ ដោយទឹកចត់ឡើយ ។

ចំណែកខាងបុគ្គលណាមានទឹកចត់ គឺកិលេសខ្ជាក់ចោលហើយ មានចិត្តតាំងមាំល្អក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយទមៈនិងសច្ច បុគ្គលនោះឯងទើបគួរនឹងស្លៀកដណ្តប់នូវសំពត់ជ្រលក់ដោយទឹកចត់បាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនិក្កសាវោ** សេចក្តីថា កិលេសដូចទឹកម្ចត់នោះបានដល់ រាគៈ ទោសៈ មោហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ អកុសលធម៌ទាំងអស់ ទុច្ចរិតទាំងអស់ កម្មដែលនាំទៅកាន់ភពទាំងអស់ កិលេស ១៥០០ នេះឈ្មោះថា កសាវកិលេស គឺកិលេសដូចទឹកម្ចត់ ។

កិលេសដូចទឹកម្ចត់នោះបុគ្គលណាមិនទាន់លះបាននៅអាស្រ័យនៅឡើយ មិនទាន់លះចេញអំពីសន្តានរបស់បុគ្គលណា បុគ្គលនោះឈ្មោះថា មានកិលេសដូចទឹកម្ចត់ដែលមិនទាន់ខ្ជាក់ចេញ ។ បទថា **កាសាវំ** បានដល់សំពត់មានពណ៌លឿងជារសរបស់ទឹកម្ចត់ ជាទង់ជ័យរបស់ព្រះអរហន្ត ។ បទថា **យោ វត្ថំ បរិទហិស្សតិ** សេចក្តីថា បុគ្គលណាមានសភាពយ៉ាងនេះមិនគួរប្រើប្រាស់ គឺស្លៀកដណ្តប់សំពត់បែបនេះឡើយ ។ បទថា **អបេ–តោ ទមសច្ចេន** សេចក្តីថា បុគ្គលនោះជាអ្នកប្រាសចាក គឺឆ្ងាយចាកទមៈដែលបានដល់ការទូន្មានឥន្ទ្រិយនិងបរមត្ថសច្ច ដែលបានដល់ព្រះនិព្វាន ។

បទថា **ន សោ កាសាវមរហតិ** សេចក្តីថា បុគ្គលនោះមិនគួរដល់កាសាវៈ ដែលជាទង់របស់ព្រះអរហន្ត ព្រោះនៅមានកិលេសដូចទឹកម្ចត់មិនទាន់ខ្ជាក់ចេញបានទើបមិនសមគួរដល់សំពត់កាសាវៈនោះ ។ បទថា **យោ ច វន្ត-កសាវស្ស** សេចក្តីថា ឯបុគ្គលណាឈ្មោះថាជាអ្នកមានកិលេសដូចទឹកម្ចត់ខ្ជាក់ចោលហើយ ព្រោះកិលេសដូចទឹកម្ចត់តាមដែលពោលហើយនោះខ្ជាក់ចេញអស់ហើយ ។ បទថា **សីលេសុ សុសមាហិតោ** សេចក្តីថា ជាអ្នកមាំទាំដោយល្អក្នុងមគ្គសីលនិងផលសីល គឺតាំងមាំក្នុងមគ្គសីលនិងផលសីលទាំងនោះដូចដងទឹកមកតម្កល់ទុក ។ បទថា **ឧបេតោ** បានដល់ ដល់ព្រម គឺប្រកបព្រម ។ បទថា **ទមសច្ចេន** គឺ ដោយទមៈនិងសច្ចៈមានប្រការដូចពោលហើយ ។ បទថា **ស វេ កាសាវមរហតិ** សេចក្តីថា បុគ្គលបែបនេះរមែងគួរដល់សំពត់កាសាវៈដែលជាទង់ជ័យនៃព្រះអរហន្តនោះ ។

ព្រះពោធិសត្វពោលហេតុនេះដល់បុរសនោះយ៉ាងនេះ ហើយសម្លុតថា តាំងអំពីថ្ងៃនេះទៅកុំមកទីនេះទៀតដាច់ខាត បើឯងមកឯងនឹងស្លាប់ ហើយដេញទៅ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា បុរសសម្លាប់ដំរីក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ឯដំរីដែលជាមេហ្វូងក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កាសាវជាតក ចប់**

## ចុល្លនន្ទិយជាតក

[ ២៩៣ ] ( នាយព្រានពោលថា ) បារាសរិយព្រាហ្មណ៍បានពោលនូវពាក្យណាថា បាបកម្មណាដែលធ្វើហើយ ញុំាំងអ្នកឲ្យក្តៅក្រហាយក្នុងកាលជាខាងក្រោយ អ្នកកុំធ្វើបាបកម្មនោះឡើយ នេះជាពាក្យរបស់អាចារ្យ ។

[ ២៩៤ ] បុរសធ្វើនូវអំពើទាំងឡាយណា រមែងឃើញនូវអំពើទាំងឡាយនោះ ចំពោះខ្លួនបុរសអ្នកធ្វើអំពើល្អរមែងទទួលផលល្អ ចំណែកខាងបុរសអ្នកធ្វើអំពើអាក្រក់រមែងទទួលផលអាក្រក់ បុគ្គលសាបព្រោះនូវពូជបែបណារមែងបាននូវផ្លែបែបនោះ ។

**ចប់ ចុល្លនន្ទិយជាតកទី ២ ។**

## អដ្ឋកថា

## ចុល្លនន្ទិយជាតក

[ ២៩៣-២៩៤ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឥទំ តទាចរិយវចោ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបមានដូច្នេះថា ថ្ងៃមួយពួកភិក្ខុប្រជុំសន្ទនាគ្នា ក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តជាមនុស្សគ្រោតគ្រាតមានវាចាអាក្រក់ ជាអ្នកមានកម្មធ្ងន់ ចង់ផ្ដាច់ព្រះជន្មព្រះសម្មាសម្ពុទ្ធបានប្រមៀលថ្ម លែងនូវដំរីនាឡាគិរី មិនមានសូម្បីតែខន្តី មេត្តានិងសេចក្ដីករុណាក្នុងព្រះតថាគតឡើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តរឹងត្អឹង គ្រោតគ្រាត គ្មានករុណាតែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុនទេវទត្តក៏រឹងរូស គ្រោតគ្រាត ឥតករុណាដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសំដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាពានរឈ្មោះនន្ទិយៈនៅក្នុងហិមវន្តប្បទេស មានប្អូនប្រុសឈ្មោះចុល្លនន្ទិយៈ ២ នាក់បងប្អូនមានស្វា ៨៤០០០ ជាបរិវារ ប្រណិប័តន៍មេដែលខ្វាក់ភ្នែកអាស្រ័យក្នុងហិមវន្តប្បទេស ។ ពានរ ២ នាក់បងប្អូនឲ្យមេសម្រាកត្រង់គុម្ពឈើ ចូលទៅរកផ្លែឈើដែលមានរសឆ្ងាញ់បានហើយផ្ញើមកឲ្យមេ ។ ស្វាដែលនាំមកមិនបានឲ្យដល់មេ មេស្វាត្រូវសេចក្តីឃ្លានគ្របសង្កត់ស្គមសល់តែស្បែកជណ្តប់ឆ្អឹង ។ កាលនោះទើបព្រះពោធិ-សត្វសួរមេថា បពិត្រអ្នកមេ កូនបញ្ជូនផ្លែឈើមានរសឆ្ងាញ់មកឲ្យមេ ហេតុអ្វីទើបមេស្គមស្គាំងម៉្លេះ មេឆ្លើយថា នែកូន មេមិនធ្លាប់បានទេ ព្រះពោធិសត្វគិតថា បើអញនៅគ្រប់គ្រងហ្វូងមេរបស់អញគង់ស្លាប់ពិត អញលះហ្វូងពានរទៅប្រណិប័តន៍មេប៉ុណ្ណោះ ។ ទើបព្រះពោធិសត្វហៅចុល្លនន្ទិយៈមកពោលថា នែប្អូនចុល្លនន្ទិយៈ ចូរប្អូនគ្រប់គ្រងហ្វូងស្វាចុះបងនឹងប្រណិប័តន៍មេឯង ។ ឯចុល្លនន្ទិយៈពោលថា បពិត្របង ខ្ញុំមិនត្រូវការគ្រប់គ្រងហ្វូងស្វា

ខ្ញុំក៏ចង់ប្រណិប័តន៍មេដែរ ។ បងប្អូនទាំង ២ នោះមានធនូតែមួយដូច្នេះ ហើយទើបលះហ្វូងពានរនាំមេចេញពីហិមវន្តប្បទេស អាស្រ័យត្រង់គល់ជ្រៃជាយដែនប្រណិប័តន៍មេ ។

គ្រានោះមានព្រាហ្មណមាណពអ្នកក្រុងពារាណសីម្នាក់ រៀនចប់សិប្បៈគ្រប់ប្រការក្នុងសម្នាក់អាចារ្យទិសាបាមោក្ខក្នុងនគរតក្កសិលា លាអាចារ្យថា ខ្ញុំនឹងទៅ ឯអាចារ្យក៏ដឹងដោយអានុភាពវិជ្ជាមើលអវយវៈថា មាណពនេះជាមនុស្សរឹងត្អឹង គ្រោតគ្រាត មានកម្មសាហ័សទូន្មានថា នែបា បាជាមនុស្សរឹងត្អឹង គ្រោតគ្រាត មានកម្មសាហ័ស បើបានៅតែគ្រោតគ្រាតយ៉ាងនេះនឹងមិនបានទទួលផលល្អទេរមែងជួបនូវសេចក្តីវិនាស ជួបនូវទុក្ខដ៏ធំ អ្នកកុំជាបុគ្គលរឹងត្អឹងគ្រោតគ្រាត កុំធ្វើកម្មដែលឲ្យក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ផ្តាំដូច្នេះហើយទើបបញ្ជូនទៅ ។ ព្រាហ្មណមាណពនោះថ្វាយបង្គំអាចារ្យហើយទៅកាន់នគរពារាណសីមានករិយាហើយ កាលមិនអាចចិញ្ចឹមជីវិតដោយសិប្បៈដទៃទើបគិតថា អញនឹងកាន់យកធ្នូជាទីពឹងចិញ្ចឹមជីវិត គឺធ្វើជាព្រានព្រៃ ចេញអំពីនគរពារាណសីទៅកាន់តំបន់ជាយដែន ចងបន្ទោះធ្នូនិងធ្វើផ្លែព្រួញស្រេចហើយចូលព្រៃបាញ់ម្រឹគច្រើនប្រភេទ ចិញ្ចឹមជីវិតដោយការលក់សាច់ ។ ថ្ងៃមួយបុរសនោះរកសត្វក្នុងព្រៃមិនបានដើរត្រឡប់មកវិញជួបដើមជ្រៃត្រង់ទួលគិតថា គួរតែមានអ្វីនៅលើដើមជ្រៃនេះខ្លះទើបដើរតម្រង់ទៅកាន់ដើមជ្រៃ ។ ខណៈនោះពានរ ២ នាក់បងប្អូនអង្គុយត្រង់ចន្លោះប្រគាបឲ្យមេបរិភោគផ្លែឈើនៅខាងមុខ ឃើញព្រាហ្មណមាណពដើរមកគិតថា ទោះ

បីមាណពនេះឃើញមេអញ គង់មិនធ្វើអ្វីឡើយ ទើបពួនក្នុងចន្លោះមែកឈើ ឯបុរសអាក្រក់នោះមកដល់ដើមឈើនោះហើយ ឃើញមេរបស់ពានរនោះចាស់ ទុព្វលភាពខ្វាក់ភ្នែកគិតថា អញត្រឡប់ទៅដៃទទេធ្វើអ្វី អញនឹងបាញ់មេស្វា នេះយកទៅផង ទើបឃឹតធ្នូបំណងនឹងបាញ់មេស្វាចាស់នោះ ។ ព្រះពោធិសត្វ ឃើញដូច្នោះពោលថា នែចុល្លនន្ទិយៈ បុរសនេះនឹងបាញ់មេរបស់យើងបង នឹងលះបង់ជីវិតជំនួសមេ កាលបងស្លាប់ទៅហើយចូរប្អូនចិញ្ចឹមមេចុះ ទើប ចេញអំពីទីពួនមកពោលថា នែលោក សូមលោកកុំបាញ់មេរបស់ខ្ញុំឡើយ មេរបស់ខ្ញុំភ្នែកខ្វាក់ ទុព្វលភាព ខ្ញុំនឹងលះបង់ជីវិតជំនួសមេ សូមលោកកុំ សម្លាប់មេខ្ញុំឡើយ សូមសម្លាប់ខ្ញុំចុះ ទទួលបេ្តជ្ញារបស់បុរសនោះហើយទើប អង្គុយក្នុងទីជិតព្រួញ ។ បុរសនោះប្រាសចាកសេចក្តីករុណា បាញ់ព្រះពោធិ-សត្វធ្លាក់ចុះ ហើយឃឹតធ្នូទៀតដើម្បីបាញ់មេរបស់ព្រះពោធិសត្វទៀត ចុល្ល-នន្ទិយៈឃើញដូច្នោះគិតថា បុរសនេះប្រាថ្នានឹងបាញ់មេរបស់អញ មេរបស់ អញទោះបីមានជីវិតមួយថ្ងៃក៏គង់ឈ្មោះថា បានរួចជីវិតហើយ អញនឹងលះ បង់ជីវិតជំនួសមេទើបចេញអំពីចន្លោះមែកឈើពោលថា នែអ្នក អ្នកកុំបាញ់ មេរបស់ខ្ញុំឡើយ ខ្ញុំនឹងលះបង់ជីវិតជំនួសមេខ្ញុំ អ្នកបាញ់ខ្ញុំហើយយកខ្ញុំ ២ នាក់បងប្អូនទៅ សូមទុកជីវិតដល់មេរបស់ខ្ញុំចុះ ទទួលបេ្តជ្ញារបស់បុរសនោះ ហើយអង្គុយក្នុងទីជិតព្រួញ ។ ទើបបុរសនោះ បាញ់ចុល្លនន្ទិយៈឲ្យធ្លាក់ចុះ ហើយគិតថានឹងយកទៅផ្ញើកូនៗឯផ្ទះ ទើបបាញ់មេរបស់ស្វាទាំង ២ ឲ្យធ្លាក់ ចុះ រែកស្វាទាំង ៣ តម្រង់ទៅផ្ទះ ។ គ្រានោះរន្ទះបានធ្លាក់ចុះត្រង់ផ្ទះរបស់

បុរសអាក្រក់នោះឆេះភរិយានិងកូនទាំង ២ មួយអន្លើដោយផ្ទះសល់ត្រឹមតែសសរនិងធ្នឹម ។

ខណៈនោះ បុរសម្នាក់ជួបបុរសអាក្រក់នោះត្រង់ទ្វារស្រុកនោះឯង ទើបជំណាលការប្រព្រឹត្តទៅឲ្យស្តាប់ ។ បុរសអាក្រក់នោះត្រូវសេចក្តីសោកដល់បុត្តនិងភរិយាគ្របសង្កត់ ចោលអម្រែកស្វានិងធ្នូមួយអន្លើដោយបំពង់ព្រួញទុកត្រង់នោះឯង ដោះសំពត់អាក្រាតកាយ ផ្គងដើមដៃ យំចូលទៅកាន់ផ្ទះ ខណៈនោះ ធ្នឹមក៏បាក់ធ្លាក់មកត្រូវក្បាលបែក ផែនដីបើកចន្លោះអណ្តាតភ្លើងលៀនមកអំពីអវីចីនរក ។ បុរសអាក្រក់នោះ កំពុងត្រូវផែនដីស្រូប រឭកដល់ឱវាទរបស់អាចារ្យគិតថា បារាសរិយព្រាហ្មណ៍ឃើញហេតុនេះ ទើបបានឲ្យឱវាទដល់អញដូច្នេះហើយកន្ទក់កន្ទេញពោលគាថាពីរថា

> បារាសរិយព្រាហ្មណ៍បានពោលនូវពាក្យណាថា បាបកម្ម
> ណាដែលធ្វើហើយ ញុំាងអ្នកឲ្យក្តៅក្រហាយក្នុងកាលជាខាង
> ក្រោយ អ្នកកុំធ្វើបាបកម្មនោះឡើយ នេះជាពាក្យរបស់
> អាចារ្យ ។
>
> បុរសធ្វើនូវអំពើទាំងឡាយណា រមែងឃើញនូវអំពើទាំង
> ឡាយនោះចំពោះខ្លួន បុរសអ្នកធ្វើអំពើល្អរមែងទទួលផលល្អ
> ចំណែកខាងបុរសអ្នកធ្វើអំពើអាក្រក់រមែងទទួលផលអាក្រក់
> បុគ្គលសាបព្រោះនូវពូជបែបណា រមែងបាននូវផ្លែបែបនោះ
> ដូច្នេះ ។

អធិប្បាយនៃគាថានេះដូច្នេះថា បារាសរិយព្រាហ្មណ៍បានពោលពាក្យណាទុកថា អ្នកកុំធ្វើបាប បាបណាដែលអ្នកធ្វើទុកបាបនោះនឹងដុតបំផ្លាញអ្នកក្នុងកាលជាខាងក្រោយ នេះជាពាក្យរបស់អាចារ្យ បុរសធ្វើកម្មណាទុកតាមកាយទ្វារ វចីទ្វារនិងមនោទ្វារ កាលបុគ្គលនោះត្រឡប់បានផលនៃកម្មនោះរមែងជួបនូវកម្មនោះឯងចំពោះខ្លួន បុគ្គលធ្វើកម្មល្អ រមែងសោយផលល្អ បុគ្គលធ្វើកម្មអាក្រក់ រមែងសោយផលអាក្រក់ដែលមិនគួរប្រាថ្នា ពិតហើយ សូម្បីក្នុងផ្លូវលោកបុគ្គលព្រោះពូជបែបណាទុករមែងនាំទៅនូវពូជនោះ គឺរមែងឲ្យផល បានទទួលផល សោយផលដែលសមគួរដល់ពូជនោះឯង ។

បុរសអាក្រក់នោះសង្រេងសង្រែយ៉ាងនោះឯង ចូលទៅកាន់ផែនដីកើតក្នុងអវិចីមហានរក ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តរឹងត្អឹង គ្រោតគ្រាតមិនមានករុណាមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏រឹងត្អឹង គ្រោតគ្រាត គ្មានករុណាដូចគ្នា ។

ព្រះសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា បុរសព្រានអាក្រក់ក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ អាចារ្យទិសាបាមោក្ខក្នុងកាលនោះ បានមកជាសារីបុត្ត ចុល្លនន្ទិយពានរក្នុងកាលនោះបានមកជាអានន្ទ មេពានរក្នុងកាលនោះ បានមកជាមហាបជាបតិគោតមី ចំណែកមហានន្ទិយពានរក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ចុល្លនន្ទិយជាតក ចប់**

## កុដកត្ថជាតក

[ ២៩៥ ] ( អាមាត្យពោធិសត្វពោលថា ) បុគ្គលគប្បីឱនលំទោនតបចំពោះបុគ្គលអ្នកឱនលំទោនខ្លួន គប្បីគប់រកនូវបុគ្គលអ្នកគប់រកខ្លួន គប្បីធ្វើកិច្ចតបចំពោះបុគ្គលអ្នកធ្វើនូវកិច្ចដល់ខ្លួន កុំគប្បីធ្វើប្រយោជន៍ដល់បុគ្គលអ្នកប្រាថ្នានូវសេចក្តីវិនាសដល់ខ្លួន មិនគប្បីរាប់រកនូវបុគ្គលអ្នកមិនរាប់រកខ្លួន ។

[ ២៩៦ ] បុគ្គលគប្បីលះនូវបុគ្គលអ្នកលះបង់នូវខ្លួន មិនគប្បីធ្វើនូវឈើដែលតាំងនៅក្នុងព្រៃ គឺសេចក្តីប៉ុនប៉ងក្នុងបុគ្គលនោះ មិនគប្បីសមាគមជាមួយនឹងបុគ្គលដែលមានចិត្តវិបល្លាស សត្វស្លាបដឹងនូវឈើដែលមានផ្លែអស់ហើយ រមែងសម្លឹងរកនូវដើមឈើឯទៀតដែលមានផ្លែយ៉ាងណា ( បុគ្គលគប្បីគប់រកបុគ្គលដទៃយ៉ាងនោះដែរ ) ព្រោះថា លោកសន្និវាសនៅធំទូលាយណាស់ ។

**ចប់ កុដកត្ថជាតកទី ៣ ។**

## អដ្ឋកថា

## កុដកត្ថជាតក

[ ២៩៥-២៩៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆមេ ឆមន្តស្ស** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈអ្នកនគរសាវត្ថីម្នាក់បានធ្វើការជួញដូរជាមួយកុដុម្ពិកៈអ្នកជនបទម្នាក់ កុដុម្ពិកៈអ្នកក្រុងនោះនាំភរិយារបស់ខ្លួនទៅរកអ្នកទុកដាក់ប្រាក់របស់កុដុម្ពិកៈអ្នកជនបទនោះ ។ អ្នកទុកដាក់ប្រាក់ប្រាប់ថា ខ្ញុំមិនអាចនឹងឲ្យបានទើបមិនឲ្យអ្វីទៅកុដុម្ពិកៈនោះ ។ កុដុម្ពិកៈអ្នកក្រុងក្រោធមិនព្រមបរិភោគអាហារឡើយហើយដើរចេញទៅ គ្រានោះបុរសអ្នកដំណើរទាំងឡាយឃើញកុដុម្ពិកៈអ្នកក្រុងស្រេកឃ្លានក្នុងរវាងផ្លូវ ទើបឲ្យកញ្ចប់បាយដោយប្រាប់ថា ចូរអ្នកចែកឲ្យភរិយាផងហើយបរិភោគចុះ ។ កុដុម្ពិកៈអ្នកក្រុងទទួលកញ្ចប់បាយហើយមិនចង់ចែកឲ្យភរិយាទើបពោលថា នែនាង ត្រង់នេះជាទីកដីចោរ ចូរនាងទៅមុនចុះ បញ្ជូនភរិយាទៅហើយទើបបរិភោគអាហារទាល់តែអស់ហើយយកកញ្ចប់ទទេមកបង្ហាញពោលថា នែនាង ពួកបុរសអ្នកធ្វើដំណើរឲ្យកញ្ចប់ទទេមិនមានបាយឡើយចូរនាងមើល ។ ភរិយាដឹងថាស្វាមីបរិភោគម្នាក់ឯងមានការតូចចិត្ត ។ ពីរនាក់ស្វាមីភរិយាធ្វើដំណើរទៅដល់ក្រោយវត្តជេតពនមហាវិហារ ទើបចៀងចូលទៅវត្តជេតពនមហាវិហារដោយគិតថានឹងផឹកទឹក ។ ព្រះសាស្តា ទ្រង់គង់ទន្ទឹងការមករបស់ប្តីប្រពន្ធនោះត្រង់មុខព្រះគន្ធកុដិ ដូចព្រានស្ទាក់ចាំម្រឹគដូច្នោះ ។ ស្វាមីភរិយាជួបព្រះសាស្តាហើយទើបចូលទៅថ្វាយបង្គំ អង្គុយហើយ ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយស្វាមីភរិយានោះត្រាស់សួរថា ឧបាសិកាប្តីនាងយកចិត្តទុកដាក់ល្អនឹងនាងឬ ។ ភរិយាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់មានការជាប់ជំពាក់ចំពោះប្តីតែប្តីមិនមានសេចក្តីអាឡោះអាល័យចំពោះខ្ញុំម្ចាស់

ឡើយ ថ្ងៃដទៃលើកទុកចុះ ថ្ងៃនេះឯងប្តីរបស់ខ្ញុំម្ចាស់បានបាយមួយកញ្ចប់ក្នុងរវាងផ្លូវមិនចែករំលែកដល់ខ្ញុំម្ចាស់ បរិភោគម្នាក់ឯង ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសិកា នាងជាអ្នកយកចិត្តទុកដាក់នឹងប្តីជានិច្ចមក ប្តីរបស់នាងមិនយកចិត្តទុកដាក់នឹងនាងឡើយតែដឹងគុណរបស់នាង ព្រោះអាស្រ័យបណ្ឌិតកាលនោះទើបប្រគល់កាពជាធំទាំងពួងឲ្យ កាលនាងអារាធនាថា បពិត្រព្រះអង្គសូមទ្រង់សម្តែងរឿងនោះទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ កាលចម្រើនវ័យហើយបានជាអ្នកបង្រៀនអត្ថនិងធម៌របស់ព្រះរាជាព្រហ្មទត្តនោះ កាលនោះព្រះរាជាទ្រង់សង្ស័យឱរសរបស់ទ្រង់ថានឹងក្បត់ចំពោះព្រះអង្គ ទើបទ្រង់និទ្ទេសចេញអំពីអាណាចក្រនោះ ។ ព្រះឱរសនោះនាំព្រះជាយារបស់ខ្លួនចេញអំពីនគរទៅអាស្រ័យក្នុងដែនកាសីត្រង់ស្រុកមួយ ។ ក្នុងកាលតមកព្រះឱរសនោះជ្រាបថា បិតាសោយទិវង្គតហើយគិតថា អញនឹងទៅគ្រប់គ្រងរាជសម្បត្តិដែលជាសម្បត្តិរបស់ត្រកូលទើបត្រឡប់មកកាន់នគរពារាណសី បានបាយកញ្ចប់ក្នុងរវាងផ្លូវដែលអ្នកឲ្យប្រាប់ថា ចូរចែកកិរិយាផងហើយបរិភោគចុះ មិនព្រមឲ្យព្រះជាយានោះ បរិភោគម្នាក់ឯងទាំងអស់ នាងទោមនស្សថា បុរសនេះចិត្តអាក្រក់ពិតហ្ន៎ ។

ព្រះឱរសនោះគ្រងរាជសម្បត្តិក្នុងនគរពារាណសីហើយ តាំងនាងទុកក្នុង

តាំណែងអគ្គមហេសីមិនបានប្រទានគ្រឿងសក្ការៈនិងការលើកតម្កើងអ្វីដទៃទេ ដោយយល់ឃើញថា ប៉ុណ្ណោះក៏គ្រប់គ្រាន់ហើយសម្រាប់នាងសូម្បីតែពាក្យសួរថា នាងសុខសប្បាយទេឬក៏មិនដែលសួរឡើយ ។ ព្រះពោធិសត្វគិតថា ព្រះទេវីនេះមានឧបការៈច្រើន មានសេចក្ដីស្រឡាញ់ភក្ដីចំពោះព្រះរាជាក្រៃលែង តែព្រះរាជាមិនអើពើដល់ព្រះនាង សូម្បីតែតិចតួច អញនឹងឲ្យទ្រង់ប្រទានគ្រឿងសក្ការៈនិងលើកតម្កើងដល់ព្រះនាង ទើបចូលទៅគាល់ព្រះទេវីមិនឆ្ងាយពេកមិនជិតពេក ហើយឈរក្នុងចំណែកម្ខាង កាលព្រះនាងត្រាស់សួរថា តើមានរឿងអ្វី ទើបទូលចំពោះរឿងឡើងថា បពិត្រព្រះទេវី ទូលព្រះបង្គំទទួលរាជការ ព្រះនាងឲ្យកំណាត់សំពត់ឬដុំបាយដល់ទូលព្រះបង្គំដែលមានមាតាបិតាចាស់ជរាខ្ចះមិនគួរឬ ។ ព្រះទេវីត្រាស់ថា សូម្បីតែខ្លួនខ្ញុំឯងក៏មិនបានអ្វីផងនឹងបានអ្វីឲ្យលោកនោះ ក្នុងកាលដែលខ្ញុំបាន ខ្ញុំនឹងឲ្យលោក ប៉ុន្តែពេលនេះ ព្រះរាជាមិនបានព្រះរាជទានអ្វីឲ្យខ្ញុំឡើយ ការដែលព្រះរាជាព្រះរាជទានអ្វីដទៃ ចូរលើកទុកចុះ សូម្បីកាលធ្វើដំណើរមកដើម្បីទទួលរាជសម្បត្តិបានបាយមួយកញ្ចប់ក្នុងរវាងផ្លូវ មិនបានប្រទានសូម្បីតែអាហារដល់ខ្ញុំ ទ្រង់សោយមួយអង្គឯងប៉ុណ្ណោះ ។ ព្រះពោធិសត្វទូលសួរថា បពិត្រព្រះនាង ព្រះនាងអាចពោលយ៉ាងនេះ ក្នុងសម្នាក់ព្រះរាជាដែរឬ ទើបព្រះនាងឆ្លើយថា ខ្ញុំអាច ។ ព្រះពោធិសត្វទូលថា បើដូច្នោះក្នុងពេលដែលទូលព្រះបង្គំកំពុងគាល់ក្នុងព្រះរាជសម្នាក់ថ្ងៃនេះឯង កាលទូលព្រះបង្គំទូលសួរ សូមព្រះនាងត្រាស់យ៉ាងនេះក្នុងថ្ងៃនេះឯង ទូលព្រះបង្គំនឹងឲ្យព្រះរាជា

រឭកគុណរបស់ព្រះនាង ។ កាលពោលយ៉ាងនេះហើយ ទើបព្រះពោធិសត្វទៅមុនឈរគាល់ព្រះរាជា ឯព្រះទេវីក៏ទៅឈរគាល់ព្រះរាជាដូចគ្នា ។

សម័យនោះព្រះពោធិសត្វទូលសួរព្រះទេវីថា បពិត្រព្រះនាង ព្រះនាងមានព្រះហឫទ័យគ្រោតគ្រាត ការដែលព្រះនាងឲ្យកំណាត់សំពត់ ឬត្រឹមតែដុំបាយដល់មាតាបិតា ( របស់ទូលព្រះបង្គំ ) មិនសមគួរឬ ព្រះទេវីត្រាស់ថា ខ្ញុំផ្ទាល់មិនបានអ្វីអំពីព្រះរាជានឹងយកអ្វីឲ្យលោក ។ ព្រះពោធិសត្វទូលសួរថា ព្រះនាងបានតំណែងអគ្គមហេសីមិនមែនឬ ទើបត្រាស់ថា នែលោក បើមិនមានការលើកតម្កើងតំណែងអគ្គមហេសីមានប្រយោជន៍អ្វី ព្រះរាជារបស់លោកនឹងព្រះរាជទានអ្វីដល់ខ្ញុំក្នុងកាលឥឡូវនេះ ទ្រង់បានកញ្ចប់បាយវាំងផ្លូវគង់មិនព្រះរាជទានឲ្យត្រឹមតែតិចតួច ទ្រង់សោយតែមួយអង្គឯង ។ ព្រះពោធិសត្វទូលសួរថា បពិត្រមហារាជ បានឮថាសេចក្ដីនោះយ៉ាងនេះឬ ។ ព្រះរាជាទ្រង់ទទួលថា ពិតមែន ព្រះពោធិសត្វជ្រាបថា ព្រះរាជាទ្រង់ទទួលហើយទើបទូលថា បពិត្រព្រះនាង បើដូច្នោះប្រយោជន៍អ្វីដោយការប្រថាប់នៅក្នុងទីនេះ តាំងអំពីកាលមិនជាទីស្រឡាញ់របស់ព្រះរាជា ព្រោះការនៅរួមនឹងបុគ្គលមិនជាទីស្រឡាញ់ជាទុក្ខក្នុងលោក កាលព្រះនាងគង់នៅក្នុងទីនេះ ការនៅរួមនឹងការមិនជាទីស្រឡាញ់នៃព្រះរាជានោះជាទុក្ខ ធម្មតាសត្វទាំងនេះរមែងគប់រកបុគ្គលដែលគប់រកខ្លួន ដឹងបុគ្គលដែលមិនគប់រកថា គេមិនចង់គប់រកក៏ទៅកាន់ទីដទៃ ដ្បិតថាទីអាស្រ័យ គឺលោកសន្និវាសធំទូលាយណាស់ ហើយបានពោលគាថាទាំងនេះថា

បុគ្គលគប្បីឱនលំទោនតប ចំពោះបុគ្គលអ្នកឱនលំទោនខ្លួន គប្បីគប់រកនូវបុគ្គលអ្នកគប់រកខ្លួន គប្បីធ្វើកិច្ចតបចំពោះបុគ្គលអ្នកធ្វើនូវកិច្ចដល់ខ្លួន កុំគប្បីធ្វើប្រយោជន៍ដល់បុគ្គលអ្នកប្រាថ្នានូវសេចក្តីវិនាសដល់ខ្លួន មិនគប្បីរាប់រកនូវបុគ្គលអ្នកមិនរាប់រកខ្លួន ។

បុគ្គលគប្បីលះនូវបុគ្គលអ្នកលះបង់នូវខ្លួន មិនគប្បីធ្វើនូវឈើដែលតាំងនៅក្នុងព្រៃ គឺសេចក្តីប៉ុនប៉ងក្នុងបុគ្គលនោះ មិនគប្បីសមាគមជាមួយនឹងបុគ្គល ដែលមានចិត្តវិបល្លាស សត្វស្លាបដឹងនូវឈើដែលមានផ្លែអស់ហើយ រមែងសម្លឹងរកនូវដើមឈើឯទៀតដែលមានផ្លែយ៉ាងណា ( បុគ្គលគប្បីគប់រកបុគ្គលដទៃយ៉ាងនោះដែរ ) ព្រោះថា លោកសន្និវាសនៅធំទូលាយណាស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆមេ ឆមន្តស្ស ភជេ ភជន្តំ** សេចក្តីថា បុគ្គលគួរឱនលំទោនតបចំពោះបុគ្គលដែលឱនលំទោន គឺគួរគប់រកបុគ្គលដែលគប់រកខ្លួនប៉ុណ្ណោះ ។ បទថា **កិច្ចានុកុព្វស្ស ករេយ្យ កិច្ចំ** សេចក្តីថា បុគ្គលគួរជួយធ្វើកិច្ចដែលកើតឡើងដល់បុគ្គលដែលជួយធ្វើកិច្ចដែលកើតឡើងដល់ខ្លួនប៉ុណ្ណោះ ។ បទថា **ចជេ ចជន្តំ វនថំ ន កយិរា** បានដល់ គួរលះបង់ជនដែលលះបង់ខ្លួនមិនគួរធ្វើនូវសេចក្តីអាល័យពោលគឺ អាឡោះអាល័យក្នុងបុគ្គលនោះសូម្បីតែតិចតួច ។ បទថា **អបេតចិត្តេន** បានដល់

ជាអ្នកមានចិត្តអណ្តែតអណ្តូងវិបល្លាស ។ បទថា **ឆ សម្ភជេយ្យ** គឺ មិនគួរសមាគមជាមួយបុគ្គលបែបនោះ ។ បទថា **ធិជោ ទុមំ** បានដល់ ដូចបក្សីដឹងនូវឈើដែលមានផ្លែអស់ហើយ លះបង់ដើមឈើនោះទៅរកដើមឈើដទៃយ៉ាងណាបុគ្គលគប្បីគប់រកបុគ្គលដទៃយ៉ាងនោះដែរព្រោះថា ព្រោះលោកសន្និវាសនេះធំទូលាយ ព្រះនាងនឹងបានបុរសម្នាក់ ដែលមានសេចក្តីស្នេហាក្នុងព្រះនាងដោយពិត ។

ព្រះបាទពារាណសីទ្រង់ស្តាប់ដូច្នោះហើយទ្រង់បានព្រះរាជទានឥស្សរិយ-យសទាំងពួងដល់ព្រះទេវី តាំងអំពីនោះមកក៏នៅព្រមព្រៀងត្រេកអរកគ្នា ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ស្វាមីភរិយាតាំងនៅក្នុងសោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា ព្រះរាជានិងព្រះជាយាក្នុងកាលនោះបានមកជាស្វាមីភរិយាក្នុងកាលឥឡូវនេះ ឯអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បុដកត្តជាតក ចប់

## កុម្ភីលជាតក

[ ២៩៧ ] ( ក្រពើបាននិយាយថា ) បុគ្គលណាមានធម៌ ៤ យ៉ាងគឺ សច្ចៈ ១ សុចរិតធម៌ ១ សេចក្ដីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចម្រើនក្រៃលែង បុគ្គលនោះរមែងកន្លងនូវសត្រូវបាន ។

[ ២៩៨ ] ចំណែកបុគ្គលណាមិនមានធម៌ ៤ យ៉ាងនេះគឺ សច្ចៈ ១ សុចរិតធម៌ ១ សេចក្ដីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចម្រើនក្រៃលែង បុគ្គលនោះរមែងមិនកន្លងនូវសត្រូវបានទេ ។

**ចប់ កុម្ភីលជាតកទី ៤ ។**

## អដ្ឋកថា

## កុម្ភិលជាតក

[ ២៩៧-២៩៨ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យស្សេតេ ចតុរោ ធម្មា** ដូច្នេះជាដើម ។

ព្រះពោធិសត្វបានពោលគាថាទាំងនេះថា

បុគ្គលណាមានធម៌ ៤ យ៉ាងគឺ សច្ចៈ ១ សុចរិតធម៌ ១
សេចក្ដីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចម្រើនក្រៃលែង
បុគ្គលនោះរមែងកន្លងនូវសត្រូវបាន ។

ចំណែកបុគ្គលណាមិនមានធម៌ ៤ យ៉ាងនេះគឺ សច្ចៈ ១

សុចរិតធម៌ ១ សេចក្ដីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចម្រើនក្រៃលែង បុគ្គលនោះ រមែងមិនកន្លងនូវសត្រូវបានទេដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គុណា បរមកន្តកា** សេចក្ដីថា បុគ្គលណាមិនមានគុណធម៌ដ៏ចម្រើនទាំង ៤ ប្រការនេះដោយភាពជាពួក ជាក្រុមទេ បុគ្គលនោះរមែងមិនកន្លងនូវសត្រូវបានឡើយ ។ សេចក្ដីដ៏សេសទាំងអស់ក្នុងជាតកនេះនិងការប្រជុំជាតកមានន័យដូចពោលហើយក្នុងកុម្ភិលជាតក ( វានរិន្ទជាតក ) ខាងដើមនោះឯង ។

## អដ្ឋកថា កុម្ភិលជាតក ចប់

## ខន្តិវណ្ណជាតក

[ ២៩៩ ] ( អាមាត្យបានក្រាបទូលថា ) បពិត្រព្រះសម្មតិទេព មានបុរសរបស់ទូលព្រះបង្គំម្នាក់ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចការទាំងពួង តែបុរសនោះមានកំហុសមួយ ព្រះអង្គទ្រង់សម្គាល់ក្នុងកំហុសរបស់បុរសនោះថា គួរនឹងធ្វើដូចម្តេច ។

[ ៣០០ ] ( ព្រះរាជាពោធិសត្វមានព្រះបន្ទូលថា ) បុរស ( ជាអ្នកប្រទូស្ត ) ក្នុងផ្ទះរបស់យើងមានដែរ ឯបុរសបែបនេះ ( ឥឡូវនេះ ) មានក្នុងទីនេះ តែបុរសអ្នកប្រកបដោយចំណែកនៃគុណ គេរកបានដោយកម្របានជាយើងចូលចិត្តអត់ធន់ ។

**ចប់ ខន្តិវណ្ណជាតក ទី ៥ ។**

## អដ្ឋកថា

## ខន្តិវណ្ណជាតក

[ ២៩៩-៣០០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្តេចកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អត្ថិ មេ បុរិសោ ទេវ** ដូច្នេះជាដើម ។

បានឮថា អាមាត្យរបស់ស្តេចកោសលម្នាក់មានឧបការៈច្រើនបានលបលួចធ្វើសហាយស្មន់ជាមួយស្រីស្នំ ។ ព្រះរាជាទ្រង់ជ្រាបក៏ទ្រង់អត់សង្កត់នៅស្ងៀមដោយគិតថាជាអ្នកមានឧបការៈដល់អញ បានក្រាបទូលដល់ព្រះសាស្តា

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ សូម្បីព្រះរាជាក្នុងកាលមុនក៏អត់សង្កត់យ៉ាងនេះដូចគ្នា កាលព្រះបាទកោសលទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី អាមាត្យម្នាក់បានលបលួចផិតក្បត់នឹងស្នំព្រះរាជា សូម្បីអ្នកបម្រើរបស់អាមាត្យនោះក៏លបលួចផិតក្បត់នឹងភរិយារបស់អាមាត្យនោះដូចគ្នា អាមាត្យនោះមិនអាចអត់ធន់នឹងកំហុសរបស់អ្នកបម្រើនោះបាន ទើបនាំខ្លួនទៅគាល់ព្រះរាជាដើម្បីសួរថា បពិត្រព្រះសម្មតិទេព អ្នកបម្រើរបស់ទូលព្រះបង្គំម្នាក់ជាអ្នកធ្វើកិច្ចការទាំងពួង បានផិតក្បត់ជាមួយភរិយារបស់ទូលព្រះបង្គំ ទូលព្រះបង្គំគួរធ្វើដូចម្តេចដល់បុរសនេះទើបពោលគាថាទីមួយថា

> បពិត្រព្រះសម្មតិទេព មានបុរសរបស់ទូលព្រះបង្គំម្នាក់ ជាអ្នក
> ខ្វល់ខ្វាយក្នុងកិច្ចការទាំងពួង តែបុរសនោះ មានកំហុសមួយ
> ព្រះអង្គទ្រង់សម្គាល់ក្នុងកំហុសរបស់បុរសនោះថា គួរនឹងធ្វើ
> ដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្ស ចេកោ បរាធត្ថិ** សេចក្តីថា បុរសនោះមានកំហុសមួយ ។ បទថា **តត្ថ ត្វំ កិន្តិ មញ្ញសិ** សេចក្តីថា ព្រះអង្គទ្រង់ព្រះតម្រិះក្នុងកំហុសរបស់បុរសនោះថា គួរនឹងធ្វើដូចម្តេច សូមទ្រង់ដាក់ទោសបុរសនោះតាមសមគួរដល់កំហុសរបស់គេចុះ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយទើបពោលគាថាទីពីរថា

បុរស ( ជាអ្នកប្រទូស្ត ) ក្នុងផ្ទះរបស់យើងមានដែរ ឯបុរស
បែបនេះ ( ឥឡូវនេះ ) មានក្នុងទីនេះ តែបុរសអ្នកប្រកបដោយ
ចំណែកនៃគុណ គេរកបានដោយកម្រ បានជាយើងចូលចិត្ត
អត់ធន់ ដូច្នេះ ។

អធិប្បាយនៃគាថានោះថា បុរសដែលប្រទូស្តបែបនេះ គឺមានឧបការៈច្រើន មានក្នុងដំណាក់របស់យើងដែលជាព្រះរាជាជាសប្បុរស ឥឡូវនេះ បុរសបែបនោះមានក្នុងទីនេះ សូម្បីយើងដែលជាព្រះរាជាក៏គង់អត់ធន់ព្រោះបុរសនោះ ជាអ្នកមានឧបការៈច្រើន ។ បទថា **អង្គសម្បន្នោ** សេចក្តីថា ឈ្មោះថា បុរសដែលប្រកបដោយចំណែកនៃគុណធម៌ទាំងពួងរកបានលំបាក ដោយហេតុនោះទើបយើងអត់សង្កត់ក្នុងឋានៈបែបនេះ ។

អាមាត្យដឹងថា ព្រះរាជាត្រាស់សំដៅដល់ខ្លួន តាំងអំពីកាលនោះមកក៏មិនហ៊ានផិតក្បត់នឹងស្នំទៀត ។ សូម្បីតែអ្នកបម្រើរបស់អាមាត្យនោះក៏ដឹងថា ព្រះរាជាទ្រង់ពោលដល់ខ្លួន តាំងអំពីនោះមកក៏មិនហ៊ានធ្វើកម្មបែបនោះទៀត ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង អាមាត្យនោះដឹងថាព្រះរាជាក្រាបទូលដល់ព្រះសាស្តា តាំងអំពីនោះមក ក៏មិនហ៊ានធ្វើកម្មនោះ ។

## អដ្ឋកថា ខន្តិវណ្ណជាតក ចប់

## កោសិយជាតក

[ ៣០១ ] ( អាមាត្យពោធិសត្វពោលថា ) ការចេញទៅក្នុងកាលគួរជាការប្រពៃ ការចេញទៅក្នុងកាលមិនគួរមិនជាការប្រពៃទេព្រោះថា ( ជនណាមួយ ) ចេញទៅក្នុងកាលមិនគួររមែងមិនញុំាងប្រយោជន៍តិចតួចឲ្យកើតបាន ជនជាសត្រូវដ៏ច្រើននឹងចោមចាប់នូវបុរសតែម្នាក់ឯង ( ដែលចេញទៅក្នុងកាលមិនគួរហើយឲ្យដល់នូវសេចក្តីវិនាសដ៏ធំ ) ដូចសេនាក្អែក ( ចោមចឹក ) នូវសត្វមៀម ( ដែលចេញទៅក្នុងកាលមិនគួរ ) ។

[ ៣០២ ] អ្នកប្រាជ្ញដឹងនូវរបៀបនិងការចាត់ចែង ដឹងនូវទោសរបស់ជនទាំងឡាយដទៃ បានធ្វើនូវមិត្តទាំងអស់ឲ្យលុះក្នុងអំណាចរបស់ខ្លួន គប្បីបាននូវសេចក្តីសុខដូចសត្វមៀម ( មានប្រាជ្ញាចឹកក្បាលក្អែកឲ្យដាច់ស្លាប់ ) បានសេចក្តីសុខដូច្នោះ ។

**ចប់ កោសិយជាតកទី ៦ ។**

## អដ្ឋកថា

## កោសិយជាតក

[ ៣០១-៣០២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្តេចកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាលេ និក្ខមនា សាធុ** ដូច្នេះជាដើម ។

ព្រះបាទកោសលយាងទៅដើម្បីបង្ក្រាបជាយដែនក្នុងកាលដែលមិនសម

គួរ រឿងមានន័យដូចពោលហើយខាងដើមទាំងអស់នោះឯង ។ ឯព្រះសាស្តា ទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទពារាណសី ស្តេចលើករេហ៍ពលចេញទៅក្នុងកាលមិនសមគួរ ទ្រង់បញ្ឈប់កងទ័ពត្រង់ឧទ្យាន ក្នុងកាលនោះមានសត្វមៀមមួយចូលទៅពួនក្នុងគុម្ពឫស្សី ។ ហ្វូងក្អែកនាំគ្នាមកចោមរោមដោយគិតថា នឹងចាប់ពេលដែលសត្វមៀមចេញមក ។ សត្វមៀមមិនរង់ចាំដល់ព្រះអាទិត្យលិចចេញទៅក្នុងកាលមិនសមគួរគិតនឹងហើរគេច ។ ពេលនោះទើបក្អែកទាំងឡាយចោមរោមចឹករហូតធ្លាក់ចុះ ។ ព្រះរាជាហៅព្រះពោធិសត្វមកហើយត្រាស់សួរថា នែបណ្ឌិត ពួកក្អែកទាំងនេះចឹកមៀមឲ្យធ្លាក់ចុះដោយហេតុអ្វីហ្ន៎ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ មៀមចេញពីលំនៅរបស់ខ្លួនក្នុងកាលមិនសមគួរទើបទទួលទុក្ខបែបនេះព្រោះដូច្នោះ ទើបមិនគួរចេញអំពីលំនៅរបស់ខ្លួន ក្នុងកាលដែលមិនសមគួរ ។ កាលនឹងប្រកាសសេចក្តីនេះទើបពោលគាថាទាំងនេះថា

ការចេញទៅក្នុងកាលគួរជាការប្រពៃ ការចេញទៅក្នុងកាល
មិនគួរមិនជាការប្រពៃទេព្រោះថា ( ជនណាមួយ ) ចេញទៅ
ក្នុងកាលមិនគួរ រមែងមិនញុំាងប្រយោជន៍តិចតួចឲ្យកើតបាន
ជនជាសត្រូវដ៏ច្រើននឹងចោមចាប់នូវបុរសតែម្នាក់ឯង ( ដែល
ចេញទៅក្នុងកាលមិនគួរហើយឲ្យដល់នូវសេចក្តីវិនាសដ៏ធំ )
ដូចសេនាក្អែក ( ចោមចឹក ) នូវសត្វមៀម ( ដែលចេញទៅ

ក្នុងកាលមិនគួរ ) ។

អ្នកប្រាជ្ញដឹងនូវរបៀបនិងការចាត់ចែង ដឹងនូវទោសរបស់ជនទាំងឡាយដទៃ បានធ្វើនូវមិត្តទាំងអស់ឲ្យលុះក្នុងអំណាចរបស់ខ្លួន គប្បីបាននូវសេចក្ដីសុខដូចសត្វមៀម ( មានប្រាជ្ញាចឹកក្បាលក្អែកឲ្យដាច់ស្លាប់ ) បានសេចក្ដីសុខដូច្នោះដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាលេ និក្ខមនា សាធុ** សេចក្ដីថា ការចេញទៅក្ដី ការឈានទៅក្ដីឈ្មោះថា ការចេញទៅ ការចេញទៅក្នុងកាលដែលសមគួរជាការប្រពៃ ការចេញទៅក្នុងកាលមិនសមគួរមិនប្រពៃ ព្រោះហេតុនោះការចេញទៅក្ដី ការឈានទៅក្ដី ដើម្បីទឹងទៅក្នុងទីដទៃចាកលំនៅនៃខ្លួនក្នុងកាលមិនគួរមិនប្រពៃឡើយ ។ ក្នុងបទថា **អកាលេន ហិ** ជាដើម គប្បីប្រកបបទទី ៣ ជាមួយបទទី ១ បទទី ៤ ជាមួយបទទី ២ ហើយគប្បីជ្រាបសេចក្ដីយ៉ាងនេះ ។ ដោយពិតមហាជន គឺជនដែលជាសត្រូវដ៏ច្រើនឡោមព័ទ្ធមនុស្សម្នាក់ ដែលចេញទៅឬឈានទៅក្នុងកាលដែលមិនគួរញុំាងបុគ្គលម្នាក់ឯងឲ្យដល់នូវសេចក្ដីវិនាសប្រៀបដូចហ្វូងក្អែកចឹកមៀមដែលចេញទៅឬហើរទៅក្នុងកាលដែលមិនសមគួរ ឲ្យដល់នូវសេចក្ដីវិនាសដូច្នោះ ។ ព្រោះហេតុនោះ ចូរមើលសត្វតិរច្ឆានជាដើមជាគំរូ បុគ្គលណាមួយមិនគួរចេញទៅ មិនគួរឈានទៅចាកលំនៅរបស់ខ្លួនក្នុងកាលដែលមិនសមគួរ ។ បទថា **ធីរោ** ក្នុងគាថាទី ២ បានដល់ បណ្ឌិត ។ បទថា **វិធិ** បានដល់ ប្រពៃណីដែលបណ្ឌិតអំពីមុនបានចងក្រងទុក ។ បទថា **វិធានំ** បានដល់ ចំណែក

ឬការរៀបចំ ។ បទថា **វិវរានុគូ** បានដល់ ដើរតាម គឺដឹង ។ បទថា **សព្វាមិត្តេ** បានដល់ សត្រូវទាំងអស់ ។ បទថា **វសីករិត្វា** បានដល់ ធ្វើឲ្យនៅក្នុងអំណាចរបស់ខ្លួន ។ បទថា **កោសិយោវ** គឺ ដូចសត្វមៀម ដែលឈ្លាសជាងសត្វមៀមដែលល្ងង់នោះ ។

លោកអធិប្បាយទុកថា បុគ្គលណាជាបណ្ឌិត រមែងដឹងវិធីការដែលជាចំណែកនៃវិធីពោលគឺ ប្រពៃណីដែលបុរាណកបណ្ឌិតរៀបចំទុកថា ក្នុងកាលនេះគួរចេញទៅ គួរឈានទៅ ក្នុងកាលនេះមិនគួរចេញទៅ មិនគួរឈានទៅ ឬការចាត់ចែងវិធីនោះ ។ បុគ្គលនោះឈ្មោះថា ចេះវិធីការផ្សេងៗដឹងចន្លោះប្រហោងនៃអ្នកដទៃ គឺសត្រូវរបស់ខ្លួន ដូចសត្វមៀមដែលឈ្លាសចេញនិងឈានទៅក្នុងកាលសមគួររបស់ខ្លួន គឺក្នុងពេលយប់ចឹកក្បាលក្អែកដែលកំពុងដេកក្នុងទីនោះៗ ធ្វើក្អែកទាំងនោះឲ្យនៅក្នុងអំណាចរបស់ខ្លួនគប្បីនៅជាសុខយ៉ាងណាបណ្ឌិតចេញទៅ ឈានទៅក្នុងកាលដែលសមគួរក៏យ៉ាងនោះ ធ្វើសត្រូវរបស់ខ្លួនឲ្យនៅក្នុងអំណាច គប្បីមានសេចក្តីសុខ មិនមានទុក្ខដូច្នោះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយយាងត្រឡប់ ។ ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កោសិយជាតក ចប់**

## គូថបាណកជាតក

[ ៣០៣ ] ( សត្វកំពោងពោលថា ) អ្នកជាសត្វក្លៀវក្លាមកជួបប្រទះនឹងយើងជាអ្នកក្លៀវក្លាមានសេចក្តីប្រឹងប្រែង អាចប្រហារគ្នាបាន នែដំរីអ្នកចូរមក អ្នកចូរត្រឡប់មក អ្នកខ្លាចឬបានជារត់ទៅ អ្នកស្រុកអង្គៈនិងមគធៈទាំងឡាយចូរមើលសេចក្តីព្យាយាមរបស់យើងនិងអ្នក ។

[ ៣០៤ ] ( ដំរីពោលថា ) យើងនឹងមិនសម្លាប់អ្នកដោយជើង មិនសម្លាប់ដោយភ្លុក មិនសម្លាប់ដោយប្រមោយទេ យើងនឹងសម្លាប់អ្នកដោយអាចម៍ សត្វស្អុយចូរវិនាសដោយរបស់ស្អុយ ។

**ចប់ គូថបាណកជាតកទី ៧ ។**

## អដ្ឋកថា

## គូថបាណជាតក

[ ៣០៣-៣០៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សូរោ សូរេន សង្គម្ម** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះមានភូមិក្នុងស្រុកមួយ ចម្ងាយអំពីវត្តជេតពនមហាវិហារប្រមាណមួយយោជន៍និងមួយគាវុត ។ ត្រង់ស្រុកនោះមានសលាកភត្តនិងបក្ខិកភត្តជាច្រើន ។ មានបុរសកំបុតម្នាក់ចូលចិត្តសាកសួរបញ្ហាក្នុងភូមិនោះ ។ បុរសនោះសួរបញ្ហាជាមួយភិក្ខុកំលោះនិងសាមណេរដែលទៅ

ទទួលសលាកភត្តនិងបក្ខិកភត្តថា ជនពួកណាផឹក ជនពួកណាទំពាស៊ី ជនពួកណាបរិភោគ ធ្វើឲ្យភិក្ខុកំលោះនិងសាមណេរទាំងនោះមិនអាចឆ្លើយបញ្ហាបានខ្មាសហើយ ។ ទើបភិក្ខុនិងសាមណេរទាំងឡាយ មិនទៅកាន់ភូមិនោះដើម្បីទទួលសលាកភត្តនិងបក្ខិកភត្ត ព្រោះខ្លាចអាបុរសកំបុតនោះ ។ ថ្ងៃមួយភិក្ខុមួយរូបទៅកាន់រោងស្លាកសួរថា បពិត្រលោកម្ចាស់ សលាកភត្តឬបក្ខិកភត្តត្រង់ភូមិនោះនៅមានឬ កាលភិក្ខុដែលជាភត្តុទ្ទេសកៈពោលថា នៅមានតែភូមិនោះមានបុរសកំបុតម្នាក់សួរបញ្ហា ជេរភិក្ខុសាមណេរដែលមិនអាចឆ្លើយបញ្ហាបានទើបមិនមាននរណាចង់ទៅព្រោះញញើតបុរសកំបុតនោះ ភិក្ខុនោះពោលថា អាវុសោ ចូរឲ្យភត្តត្រង់ភូមិនោះដល់ខ្ញុំចុះ ខ្ញុំនឹងទូន្មានបុរសនោះ ធ្វើឲ្យអស់ព្យសន៍ និងធ្វើឲ្យគេចទៅព្រោះឃើញខ្ញុំ ។ ភិក្ខុទាំងឡាយទទួលថា សាធុ ហើយឲ្យភត្តត្រង់ភូមិនោះដល់ភិក្ខុនោះទើបភិក្ខុនោះទៅកាន់ភូមិនោះដណ្តប់ចីវរត្រង់ទ្វារស្រុក ។ បុរសកំបុតឃើញភិក្ខុនោះ ក៏ប្រញាប់ចូលទៅរកដូចពពែកាចហើយពោលថា មើលសមណៈ សូមឆ្លើយបញ្ហារបស់ខ្ញុំចុះ ។ ភិក្ខុនោះពោលថា ឧបាសក ចាំអាត្មាបិណ្ឌបាតក្នុងភូមិទទួលបបរមកសាលាអង្គុយសម្រាកសិនចុះ ។ កាលភិក្ខុនោះទទួលបបរហើយមកកាន់សាលាអង្គុយសម្រាកបុរសកំបុតនោះក៏បានពោល យ៉ាងនោះទៀតភិក្ខុនោះក៏ពន្យាថា ចាំអាត្មាឆាន់បបរសិន ចាំអាត្មាបោសសាលាអង្គុយសម្រាកសិន ចាំអាត្មាទទួលសលាកភត្តសិន កាលទទួលសលាកភត្តហើយទើបឲ្យបុរសនោះកាន់បាត្រពោលថា តាមអាត្មាមកចុះ អាត្មានឹងឆ្លើយបញ្ហារបស់

អ្នក នាំទៅខាងក្រៅស្រុក ទើបដោះចីវរពាក់លើស្មាទទួលបាត្រអំពីដៃរបស់បុរសនោះហើយឈរ ។ បុរសនោះពោលតៀនថា សមណៈ សូមឆ្លើយបញ្ហារបស់ខ្ញុំ ភិក្ខុនោះពោលថា អាត្មានឹងឆ្លើយបញ្ហារបស់អ្នកហើយប្រានឲ្យដួលចុះ វាយហាក់បីដូចធ្វើធ្មឹងឲ្យល្អិត យកលាមកញាត់មាត់សម្តុតថា តាំងពីពេលនេះទៅអាត្មាចាំស៊ើបមើលឲ្យដឹងក្នុងពេលដែលអ្នកសួរបញ្ហាណាមួយនឹងភិក្ខុដែលមកកាន់ភូមិនេះ ។ តាំងពីពេលនោះមកបុរសកំបុតឃើញភិក្ខុអំពីចម្ងាយហើយក៏គេចទៅ ។ ក្នុងកាលតមកការធ្វើនៃភិក្ខុនោះបានប្រាកដឡើងក្នុងជំនុំសង្ឃ ។ ទើបភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ បានឮថា ភិក្ខុរូបនោះយកលាមកញាត់មាត់បុរសកំបុតហើយក៏ទៅ ។ ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបៀតបៀតបុរសកំបុតដោយលាមក ក្នុងកាលឥឡូវនេះក៏មិនមែនសូម្បីក្នុងកាលមុនក៏បានបៀតបៀនហើយដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល អ្នកអង្គៈនិងមគធៈទាំងឡាយតែងទៅមករកគ្នា ។ ថ្ងៃមួយចូលទៅអាស្រ័យផ្ទះមួយត្រង់ព្រំដែននៃរដ្ឋទាំង ២ ផឹកស្រា ស៊ីត្រីនិងសាច់ហើយក៏ទឹមយានធ្វើដំណើរអំពីព្រលឹម ក្នុងកាលដែលជនទាំងនោះទៅហើយ កំពោងស៊ីលាមកមួយធុំក្លិនលាមកទើបមកឃើញសុរាដែលគេចោល

ត្រង់ទីអន្លុយទើបផឹកដោយការស្រែកទឹកក៏ស្រវឹង វារឡើងទៅទំលើដុំលាមក កាលកំពោងស្រវាឡើងទៅនោះលាមកស្រស់ៗក៏ស្រុតចុះបន្តិច កំពោងក៏ស្រែកឡើងថា ផែនដីទ្រទម្ងន់ខ្ញុំរបស់យើងមិនបាន ។ គ្រានោះដំរីចុះប្រេងមួយមកដល់ដុំក្លិនលាមកខ្ពើមហើយចៀសចេញទៅ កំពោងឃើញដំរីនោះហើយយល់ថា ដំរីនេះខ្លាចអញទើបរត់ អញគួរធ្វើសង្គ្រាមជាមួយដំរីនេះ ទើបស្រែកហៅដំរីនោះមកដោយគាថាទីមួយថា

អ្នកជាសត្វក្លៀវក្លា មកជួបប្រទះនឹងយើងជាអ្នកក្លៀវក្លា មានសេចក្តីប្រឹងប្រែង អាចប្រហារគ្នាបាន នៃដំរី អ្នកចូរមក អ្នកចូរត្រឡប់មក អ្នកខ្លាចឬបានជារត់ទៅ អ្នកស្រុកអង្គៈនិងមគធៈទាំងឡាយ ចូរមើលសេចក្តីព្យាយាមរបស់យើង និងអ្នកដូច្នេះ ។

អត្ថនៃព្រះគាថានេះថា អ្នកក៏ជាអ្នកក្លាហានមកជួបយើងដែលជាអ្នកក្លាហានមិនរួញរាក្នុងសេចក្តីព្យាយាម ប្រឹងប្រែង ជាអ្នកចម្បាំងព្រោះអាចក្នុងការច្បាំង ហេតុអ្វីទើបគេចទៅ មិនបំណងការប្រយុទ្ធទេឬ ការប្រហារគ្នាត្រឹមតែម្តង ក៏គួរធ្វើមិនមែនឬ ព្រោះហេតុនោះ នៃដំរីមកចុះ ចូរត្រឡប់មក អ្នកខ្លាចស្លាប់ដោយហេតុត្រឹមប៉ុណ្ណោះគេចទៅឬ អ្នកអង្គៈនិងអ្នកមគធៈទាំងឡាយដែលនៅត្រង់ព្រំដែននេះ ចូរមើលសេចក្តីក្លៀវក្លា ការប្រហារ ការតទល់របស់ខ្ញុំនិងអ្នក ។ ដំរីនោះបានស្តាប់ពាក្យកំពោងនោះហើយក៏បន្លឺសំឡេងទើបត្រឡប់មករកកំពោង កាលនឹងបៀតបៀនបានពោលគាថាទីពីរថា

យើងនឹងមិនសម្លាប់អ្នកដោយជើង មិនសម្លាប់ដោយក្ពុក មិន
សម្លាប់ដោយប្រមោយទេ យើងនឹងសម្លាប់អ្នកដោយអាចម៍
សត្វស្អុយចូរវិនាសដោយរបស់ស្អុយ ដូច្នេះ ។

អត្ថនៃគាថានោះថា យើងនឹងមិនសម្លាប់អ្នកដោយជើងជាដើម តែយើងសម្លាប់អ្នកដោយលាមកទើបសមគួរដល់អ្នក កាលដំរីពោលយ៉ាងនេះហើយទើបពោលថា សត្វស៊ីរបស់ស្អុយគួរស្លាប់ដោយរបស់ស្អុយ ។

ដំរីក៏បន្ទោបង់លាមកដាក់លើក្បាលកំពោងនោះ ហើយបន្ទោបង់បស្សាវៈស្រោច ញុំាងកំពោងឲ្យដល់នូវការស្លាប់ក្នុងទីនោះឯង បន្លឺសំឡេងចូលទៅកាន់ព្រៃ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា សត្វកំពោងក្នុងកាលនោះបានមកជាបុរសកំបុតក្នុងកាលឥឡូវនេះ ដំរីក្នុងកាលនោះ បានមកជាភិក្ខុរូបនោះ ឯទេវតាដែលនៅក្នុងដងព្រៃនោះឃើញហេតុនោះដោយប្របចក្សក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គូថបាណជាតក ចប់

## កាមនីតជាតក

[ ៣០៥ ] ( ព្រះបាទពារាណសីត្រាស់ថា ) យើងប្រាថ្នានូវដែនជាចន្លោះនៃក្រុងទាំង ៣ គឺ ដែនបញ្ចាល ១ កុរុ ១ កេកកៈ ១ ម្នាលព្រាហ្មណ៍ យើងត្រូវការរាជសម្បត្តិក្នុងក្រុងទាំង ៣ នោះក្រៃលែងជាងរាជសម្បត្តិក្នុងក្រុងពារាណសីនោះទៅទៀត ម្នាលព្រាហ្មណ៍ អ្នកចូររក្សានូវយើងដែលកាមនាំទៅហើយ ។

[ ៣០៦ ] ( សក្កទេវរាជពោធិសត្វត្រាស់ថា ) ពេទ្យពួកខ្លះ រមែងធ្វើ ( នូវការរក្សា ) ចំពោះបុគ្គលដែលពស់ចឹកហើយ បណ្ឌិតទាំងឡាយតែងធ្វើ ( នូវការរក្សា ) ចំពោះបុគ្គលដែលខ្មោចចូលហើយ បុគ្គលនីមួយ ( ក្រៅពីបណ្ឌិត ) រមែងមិនធ្វើនូវការរក្សាចំពោះបុគ្គលដែលកាមនាំទៅហើយព្រោះថា ការរក្សាដូចម្តេចចំពោះបុគ្គលដែលមានធម៌សជាក់ចុះហើយ ។

**ចប់ កាមនីតជាតកទី ៨ ។**

## អដ្ឋកថា
## កាមនីតជាតក

[ ៣០៥-៣០៦ ] ព្រះបរមសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះកាមនីត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តយោគិរី** ដូច្នេះជាដើម ។

រឿងទាំងបច្ចុប្បន្ននិងអតីត នឹងមានច្បាស់ក្នុងកាមជាតកក្នុងទ្វាទសកនិ-

បាត ។

ព្រះរាជបុត្តទាំង ២ អង្គនោះបុត្តច្បងបានត្រឡប់មកជាព្រះរាជាក្នុងនគរពារាណសី ព្រះរាជបុត្តប្អូនបានមកជាឧបរាជ ។ ព្រះរាជា ២ អង្គនោះព្រះរាជបុត្តច្បងជាអ្នកមិនឆ្អែតដោយវត្ថុកាមនិងកិលេសកាម មានព្រះហឫទ័យលោភក្នុងទ្រព្យសម្បត្តិ ។ ក្នុងគ្រានោះព្រះពោធិសត្វជាសក្កទេវរាជប្រមើលមើលជម្ពូទ្វីបទ្រង់ជ្រាបថា ព្រះរាជាអង្គនេះមិនចេះឆ្អែតក្នុងកាមទាំង ២ យ៉ាងទ្រង់ត្រិះរិះថានឹងទៅសង្កត់សង្កិនព្រះរាជានេះឲ្យខ្មាស ទើបទ្រង់កាឡាខ្លួនជាព្រាហ្មណមាណពចូលគាល់ព្រះរាជា កាលព្រះរាជាត្រាស់សួរថា នែមាណពអ្នកមកដោយបំណងដូចម្ដេច ក៏ក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំឃើញនគរ ៣ ដែលគួរជាទីរីករាយ មានកិក្ខាហារសម្បូរដល់ព្រមដោយដំរីសេះ រថ ពលនិករនិងមាសប្រាក់ គ្រឿងអលង្ការ តែទ្រង់អាចដណ្ដើមនគរទាំង ៣ នោះដោយកម្លាំងតិចតួចប៉ុណ្ណោះទើបទូលព្រះបង្គំមកដើម្បីជួយច្បាំងយកនគរទាំង ៣ ថ្វាយព្រះអង្គ កាលព្រះរាជាត្រាស់សួរថា នែមាណពយើងគួរទៅក្នុងកាលណា មាណពក្រាបទូលថា បពិត្រមហារាជ យើងនឹងទៅក្នុងថ្ងៃស្អែកនេះ ។ ព្រះរាជាត្រាស់ថា បើដូច្នោះយើងទៅជាមួយគ្នា ចូរអ្នកមកពីព្រឹកបន្តិច ។ សក្កទេវរាជត្រាស់ថា សាធុ សូមទ្រង់ត្រៀមពលទុកដោយរហ័សហើយត្រឡប់ទៅវិមានរបស់ព្រះអង្គ ។

ស្អែកឡើងព្រះរាជាត្រាស់ឲ្យវាយស្គរប្រជុំពួកពលឲ្យអាមាត្យទាំងឡាយមកហើយត្រាស់ថា ម្សិលមិញនេះមានព្រាហ្មណ៍កំលោះម្នាក់មកជួយវាយ

ដណ្តើមនគរទាំង ៣ យករាជសម្បត្តិថ្វាយ គឺនគរឧត្តរបញ្ចាលៈ ១ នគរឥន្ទបត្ត ១ នគរកេកកៈ ១ យើងនឹងនាំមាណពនោះទៅវាយដណ្តើមយករាជសម្បត្តិក្នុងនគរទាំង ៣ នោះ ពួកអ្នកចូរទៅតាមមាណពនោះមកដោយរហ័ស ។ ពួកអាមាត្យទូលសួរថា បពិត្រព្រះអង្គ ទ្រង់ព្រះរាជទានទីសម្រាកឲ្យមាណពនោះក្នុងទីណា ។ ព្រះរាជាត្រាស់ថា យើងមិនបានឲ្យទីសម្រាកដល់មាណពនោះទេ ពួកអាមាត្យក្រាបទូលសួរថា តើទ្រង់បានព្រះរាជទានស្បៀងអាហារដល់មាណពនោះដែរឬទេ ព្រះរាជាត្រាស់ថា ស្បៀងអាហារក៏មិនបានប្រទាន ជនទាំងនោះទូលសួរថា ទូលព្រះបង្គំនឹងទៅរកក្នុងទីណា ព្រះរាជាត្រាស់ថា ពួកអ្នកចូរដើររកតាមវិថីក្នុងព្រះនគរចុះ ។ ពួកអាមាត្យត្រាច់មើលហើយមិនជួបទើបទូលថា បពិត្រព្រះអង្គ មិនជួបឡើយ កាលព្រះរាជាមិនបានមាណពក៏កើតទោមនស្សថា អញវិនាសចាកឥស្សរិយ-សម្បត្តិដ៏ធំយ៉ាងនេះហើយ ព្រះហឫទ័យក៏ក្តៅក្រហាយ ឈាមក្នុងបេះដូងក៏កម្រើករហូតដល់ក្អួតឈាមចេញមក ។ បណ្តាពេទ្យទាំងឡាយ ក៏មិនអាចព្យាបាលបាន ។ បន្ទាប់អំពីនោះមក ៣-៤ ថ្ងៃ សក្កទេវរាជទ្រង់ប្រមើលមើលដឹងការប្រឈួនរបស់ព្រះរាជាទ្រង់ព្រះតម្រិះថានឹងជួយព្យាបាល ទើបកាឡាខ្លួនជាព្រាហ្មណ៍មកកាន់ទ្វារព្រះរាជវាំងឲ្យក្រាបទូលថា មានព្រាហ្មណ៍ជាពេទ្យមករក្សាព្រះអង្គ ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះត្រាស់ថា ពេទ្យហ្លួងសុទ្ធតែជំនាញគង់ព្យាបាលយើងមិនបាននឹងពោលទៅថ្វីដល់ព្រាហ្មណ៍ ចូរឲ្យគេត្រឡប់ចុះ ។ សក្កទេវរាជបានស្តាប់ពាក្យអាមាត្យដែលមកប្រាប់ហើយ

ទើបត្រាស់ថា ខ្ញុំមិនត្រូវការទីសម្រាកនិងតម្លៃជំនឺឬរង្វាន់អ្វីឡើយ ខ្ញុំសូមព្យាបាលព្រះរាជា ។ សូមព្រះរាជាឲ្យខ្ញុំគាល់ចុះ ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយត្រាស់ថា បើដូច្នោះចូលមកចុះ សក្កទេវរាជចូលទៅហើយថ្វាយបង្គំឈរក្នុងចំណែកម្ខាង ។ ព្រះរាជាត្រាស់សួរថា អ្នកព្យាបាលយើងឬ ក៏ក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ព្រះរាជាត្រាស់ថា បើដូច្នោះចូរព្យាបាលចុះ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ សូមព្រះរាជទានវរោកាស សូមទ្រង់ប្រាប់លក្ខណៈរបស់រោគដល់ទូលព្រះបង្គំថា កើតព្រោះហេតុអ្វី កើតព្រោះសោយអ្វីឬបានទតបានស្តាប់អ្វី ព្រះរាជាត្រាស់ថា នែបា រោគរបស់យើងកើតព្រោះបានស្តាប់ដំណឹង ព្រាហ្មណ៍ទូលសួរថា ទ្រង់ស្តាប់អ្វី ព្រះរាជាត្រាស់ថា នែបា មានមាណពម្នាក់មកប្រាប់ថានឹងជួយដណ្តើមរាជសម្បត្តិក្នុងនគរទាំង ៣ ឲ្យយើង យើងមិនបានឲ្យទីសម្រាកឬតម្លៃអាហារដល់មាណពនោះ ប្រហែលជាគេក្រោធនឹងយើង ទើបទៅគាល់ព្រះរាជាអង្គដទៃ កាលបើដូច្នោះ យើងនៅតែគិតថា អញសាបសូន្យចាកឥស្សរិយសម្បត្តិដ៏ធំ ដូច្នេះទើបកើតរោគ បើអ្នកអាចក៏ចូរព្យាបាលរោគដែលកើតព្រោះចិត្តប្រាថ្នារបស់យើងកាលប្រកាសសេចក្តីនេះបានពោលគាថាទីមួយថា

យើងប្រាថ្នានូវដែនជាចន្លោះនៃក្រុងទាំង ៣ គឺ ដែនបញ្ចាល ១ កុរុ ១ កេកកៈ ១ ម្នាលព្រាហ្មណ៍ យើងត្រូវការរាជសម្បត្តិក្នុងក្រុងទាំង ៣ នោះក្រៃលែងជាងរាជសម្បត្តិក្នុងក្រុងពារាណសីនោះទៅទៀត ម្នាលព្រាហ្មណ៍ អ្នកចូររក្សានូវយើង

ដែលកាមនាំទៅហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តយោ គិរី** គឺ នគរទាំង ៣ ។ ដូច សុទស្សនទេវនគរលោកហៅថា សុទស្សគិរីព្រោះនឹងច្បាំងដណ្ដើមយកបាន ដោយលំបាក ធ្វើឲ្យញាប់ញ័របានដោយលំបាក ដូចក្នុងប្រយោគនេះថា **សុ-ទស្សនគិរិនោ ទ្វារំ ឃោតំ បកាសតិ** ។ ព្រោះហេតុនោះក្នុងគាថានេះ ទើបមានអត្ថដូច្នេះថា យើងត្រូវការនគរទាំង ៣ និងដែនទាំង ៣ ដែលនៅ ត្រង់ចន្លោះនគរទាំង ៣ នោះ ។ យើងត្រូវការរាជសម្បត្តិក្នុងនគរទាំង ៣ នោះនិងដែនទាំង ៣ នោះគឺ ដែនឧត្តរបញ្ចាលៈមាននគរឈ្មោះកបិល ដែន ១ ទៀតមានឈ្មោះថា កុរុយៈដែលមាននគរឈ្មោះថា ឥន្ទបត្ត ដែន ១ ទៀតមានឈ្មោះថា កេកកៈមាននគរឈ្មោះកេកករាជធានី ។ យើងប្រាថ្នា រាជសម្បត្តិក្នុងដែនទាំង ៣ នោះក្រៃលែងជាងរាជសម្បត្តិក្នុងក្រុងពារាណសី ដែលយើងគ្រប់គ្រងនេះទៅទៀត ។ បទថា **តិកិច្ឆ មំ ព្រាហ្មណា កាម-និតំ** សេចក្ដីថា នែព្រាហ្មណ៍ យើងត្រូវវត្ថុកាមនិងកិលេសកាមទាំងនោះ នាំទៅហើយ ត្រូវកាមទាំងនោះបៀតបៀនធ្វើឲ្យអន្ទះអន្ទែងហើយ បើអ្នកអាច ក៏ចូរព្យាបាលចុះ ។

លំដាប់នោះទើបសក្កទេវរាជត្រាស់នឹងព្រះរាជាថា បពិត្រមហារាជ ទ្រង់ ព្យាបាលដោយឱសថ គឺឫសឈើជាដើមមិនជាឡើយ ត្រូវព្យាបាលដោយ ឱសថ គឺបញ្ញាតែម្យ៉ាងទើបពោលគាថាទីពីរថា

ពេទ្យពួកខ្លះរមែងធ្វើ ( នូវការរក្សា ) ចំពោះបុគ្គលដែលពស់

ចឹកហើយ បណ្ឌិតទាំងឡាយតែងធ្វើ ( នូវការរក្សា ) ចំពោះ
បុគ្គលដែលខ្មោចចូលហើយ បុគ្គលទីមួយ ( ក្រៅពីបណ្ឌិត )
រមែងមិនធ្វើនូវការរក្សាចំពោះបុគ្គល ដែលកាមនាំទៅហើយ
ព្រោះថា ការរក្សាដូចម្តេចចំពោះបុគ្គលដែលមានធម៌សជាក់
ចុះហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កណ្ហាហិ ទដ្ឋស្ស ករោន្តិ ហេកេ** សេចក្តីថា សេចក្តីពិត កាលបុគ្គលត្រូវពស់វែកមានពិសដ៏ពន្លឹកចឹក គ្រូខ្លះក៏រក្សាដោយមន្ត និងដោយឱសថឲ្យជាបាន ។ បទថា **អមនុស្សវិដ្ឋស្ស ករោន្តិ បណ្ឌិតា** សេចក្តីថា គ្រូខ្មោចដែលឈ្លាសពួកខ្លះ កាលមនុស្សត្រូវអមនុស្សមានខ្មោច និងយក្ខជាដើមចូលសណ្ឋិតហើយ រមែងធ្វើការរក្សាបានដោយវិធីផ្សេងៗ មានការបួងសួង សូត្រព្រះបរិត្តនិងដាក់ថ្នាំជាដើម ឲ្យសះស្បើយបាន ។ បទថា **ន កាមនីតស្ស ករោតិ កោចិ** សេចក្តីថា តែបុគ្គលដែលត្រូវកាមនាំទៅហើយ គឺនៅក្នុងអំណាចរបស់កាម វៀរបណ្ឌិតចេញបុគ្គលណាមួយក៏ធ្វើការរក្សាមិនបាន សូម្បីរក្សាក៏មិនអាចរក្សាឲ្យជាបាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលដែលឈានកន្លង ព្រំដែនសុក្កធម៌ គឺកុសលធម៌ តាំងនៅក្នុងអកុសលធម៌ហើយ នឹងមិនព្យាបាលដោយមន្តឬឱសថជាដើម យ៉ាងណាក៏ដោយឡើងវិញ មិនអាចព្យាបាលបានដោយមន្តនិងឱសថជាដើមនោះឡើយ ។

ព្រះមហាសត្វសម្តែងហេតុនេះដល់ព្រះរាជាដូច្នេះហើយបានពោលឲ្យ

ក្រៃលែងយ៉ាងនេះថា បពិត្រមហារាជ បើទ្រង់នឹងបានរាជសម្បត្តិក្នុងនគរទាំង ៣ នោះ តើទ្រង់សោយរាជ្យទាំង ៤ នគរ ដណ្តប់ដោយសាដក ៤ ផ្ទាំងក្នុងពេលតែមួយឬដូចម្តេច នឹងសោយទាំង ៤ ថាសមាស ផ្ទំលើគ្រែ ៤ តែម្តងបានដូចម្តេច បពិត្រមហារាជ ទ្រង់មិនគប្បីប្រព្រឹត្តទៅតាមអំណាចតណ្ហា ព្រោះថា តណ្ហានេះជាឫសគល់នៃសេចក្តីវិនាស កាលចម្រើនឡើងដល់បុគ្គលណារមែងទាញបុគ្គលនោះទម្លាក់ក្នុងនរក ៨ រណ្តៅ ឧស្សទនរក ១៦ រណ្តៅនិងអបាយភូមិដ៏សេសមានប្រភេទច្រើនប្រការ ។ ព្រះមហាសត្វសម្តែងធម៌ឲ្យព្រះរាជាតក់ស្លុត ដោយលើកភ័យក្នុងនរកជាដើមយ៉ាងនេះ ឯព្រះរាជាស្តាប់ធម៌របស់មហាសត្វហើយក៏ស្វាងនូវសេចក្តីសោក ជាព្រះរោគក្នុងវេលានោះឯង ។ សក្កទេវរាជប្រទានឱវាទដល់ព្រះរាជា ឲ្យតាំងនៅក្នុងសីលហើយយាងត្រឡប់ទៅកាន់ទេវលោក ។ ឯព្រះរាជា តាំងអំពីនោះមក ទ្រង់បំពេញបុណ្យមានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានជាព្រាហ្មណ៍ឈ្មោះកាមនីតក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កាមនីតជាតក ចប់

## បលាយិជាតក

[ ៣០៧ ] ( ព្រះបាទព្រហ្មទត្តទ្រង់ត្រាស់ថា ) ក្រុងតក្កសិលា យើងឡោមព័ទ្ធជុំវិញហើយដោយពពក គឺពលដំរីស្រែកសំទារដ៏ប្រសើរ ដោយកម្រងផ្កា គឺពលសេះដ៏ប្រសើរ ដោយរលកទឹក គឺពលរថ ដោយភ្លៀងខ្លាំង គឺសរដោយខ្នាន់ខ្នាប់ជាអ្នកលបចាំប្រហារមាំ ។

[ ៣០៨ ] អ្នកទាំងឡាយចូរស្ទុះទៅផង ចូរលោតផ្លោះទៅផង ចូរស្រែកដោយសំឡេងផ្សេងៗ ( មួយអន្លើ ) ដោយពលដំរីទាំងឡាយ សំឡេងគឹកកងដ៏ខ្លាំង ( ប្រាកដស្មើដោយសំឡេងនៃរន្ទះ ) ចូរប្រព្រឹត្តទៅក្នុងថ្ងៃនេះ ដូចជាផ្លេកបន្ទោរដែលចេញផុតចាកមេឃកាលគ្រហឹមដូច្នោះ ។

**ចប់ បលាយិជាតក ទី ៩ ។**

## អដ្ឋកថា
## បលាយិតជាតក

[ ៣០៧-៣០៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបលាយិបរិព្វាជក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **គជគ្គមេ-ឃេភិ** ដូច្នេះជាដើម ។

បានឮថា បរិព្វាជកនោះត្រាច់ទៅពេញជម្ពូទ្វីបដើម្បីលើកវាទៈ មិនបានទទួលការតបវាទៈហើយរហូតដល់ក្រុងសាវត្ថីដោយលំដាប់ សួរមនុស្សទាំងឡាយថា បុគ្គលណាមួយអាចនឹងឆ្លើយវាទៈជាមួយយើងមានខ្លះទេ ។ ពួក

មនុស្សនាំគ្នាសរសើរព្រះពុទ្ធអង្គថា ព្រះមហាគោតម ទ្រង់ជាសព្វញ្ញូជាងសត្វជើង ២ ទាំងឡាយ ជាអ្នកធំដោយធម៌ ញាំញីវាទៈនៃអ្នកដទៃ ជាអ្នកអាចនឹងឆ្លើយវាទៈជាមួយមនុស្សដូចអ្នកសូម្បីរាប់ពាន់អ្នកប្រាជ្ញខាងវាទៈដែលកើតឡើងក្នុងជម្ពូទ្វីប សូម្បីទាំងមូល ដែលអាចកន្លងព្រះដ៏មានព្រះភាគអង្គនោះបានមិនមាន ។ បណ្ដាវាទៈទាំងពួងមកដល់បាទមូលរបស់ព្រះអង្គក៏ខ្ចាត់ខ្ចាយទៅដូចរលកសមុទ្ទខ្ទប់ប្រាំងដូច្នោះ ។ បលាយិបរិព្វាជកសួរថា ឥឡូវនេះទ្រង់គង់នៅឯណា បានដំណឹងថា គង់ត្រង់វត្តជេតពនទើបពោលថា អញនឹងទៅលើកវាទៈជាមួយព្រះអង្គ ក្នុងកាលឥឡូវនេះ ហោមរោមដោយមហាជនទៅកាន់វត្តជេតពន លុះឃើញខ្លោងទ្វារវត្តជេតពនដែលព្រះរាជកុមារឈ្មោះថាជេតទ្រង់លះទ្រព្យ ៩ កោដិសាង ។ សួរថា នេះគឺប្រាសាទជាទីគង់របស់ព្រះគោតមឬ បានឮថា នេះគឺខ្លោងទ្វារក៏ពោលថា ខ្លោងទ្វារគង់សម្បើមដល់ម៉្លេះ ត្រឹះហាសនៈ គឺទីគង់ដូចម្ដេចហ្ន៎ កាលមហាជនពោលថា ឈ្មោះថាព្រះគន្ធកុដិប្រមាណមិនបានទើបពោលថា អ្នកណានឹងលើកវាទៈជាមួយព្រះគោតមដែលមានសភាពបែបនេះបានទើបគេចទៅអំពីទីនោះឯង ។ មនុស្សទាំងឡាយនាំគ្នាកុះករចូលទៅកាន់វត្តជេតពន ព្រះសាស្ដាត្រាស់សួរថា ហេតុអ្វីទើបអ្នកទាំងឡាយមកខុសកាល ខុសវេលា ពួកមនុស្សទាំងនោះក្រាបទូលការប្រព្រឹត្តទៅឲ្យទ្រង់ជ្រាប ។ ព្រះសាស្ដាត្រាស់ថា ម្នាលឧបាសកទាំងឡាយបលាយិបរិព្វាជកនេះឃើញខ្លោងទ្វាររបស់តថាគត គេចទៅតែក្នុងឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុនក៏គេចទៅហើយដូចគ្នា កាលពួកមនុស្សទូល

អាពាធនាទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះពោធិសត្វសោយរាជសម្បត្តិក្នុងនគរតក្កសិលា ក្នុងដែនគន្ធារៈ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះបាទព្រហ្មទត្តទ្រង់ព្រះតម្រិះថានឹងដណ្តើមយកនគរតក្កសិលា ទើបលើកពលនិកាយធំទៅ បោះបន្ទាយមិនឆ្ងាយអំពីនគរតក្កសិលា ទ្រង់បញ្ជាសេនាថា ចូរបញ្ជូនដំរីទៅច្រកនេះ សេះទៅច្រកនេះ ពលរថទៅច្រកនេះ ពលថ្មើរជើងទៅច្រកនេះ កាលសម្រុកចូលទៅយ៉ាងនេះហើយ ចូរប្រើអាវុធទាំងឡាយ ចូរប្រើភ្លៀងព្រួញឲ្យធ្លាក់ដូចវលាហកបាចសាចដូចព្រិលដូច្នោះ ដោយប្រការដូច្នេះបានត្រាស់គាថាពីរថា

ក្រុងតក្កសិលា យើងឡោមព័ទ្ធជុំវិញហើយ ដោយពពកគឺពលដំរីស្រែកសំទារដ៏ប្រសើរ ដោយកម្រងផ្កា គឺពលសេះដ៏ប្រសើរ ដោយរលកទឹក គឺពលរថ ដោយភ្លៀងខ្លាំង គឺសរដោយខ្មាន់ធ្នូជាអ្នកលបបចាំប្រហារមាំ ។

អ្នកទាំងឡាយចូរស្ទុះទៅផង ចូរលោតផ្លោះទៅផង ចូរស្រែកដោយសំឡេងផ្សេងៗ ( មួយអន្លើ ) ដោយពលដំរីទាំងឡាយ សំឡេងគឹកកងដ៏ខ្លាំង ( ប្រាកដស្មើដោយសំឡេងនៃរន្ទះ ) ចូរប្រព្រឹត្តទៅក្នុងថ្ងៃនេះ ដូចជាផ្លេកបន្ទោរដែលចេញផុតចាកមេឃកាលគ្រហឹមដូច្នោះ ។

ព្រះបាទព្រហ្មទត្តទ្រង់ត្រួតពល លើកទឹកចិត្តសេនាឲ្យអង់អាចដូច្នេះហើយ

លើកទ័ពទៅដល់ខ្លោងទ្វារ ឃើញខ្លោងទ្វារហើយត្រាស់សួរថា នេះគឺវាំងស្តេចឬ កាលពួកសេនាក្រាបទូលថា នេះគឺខ្លោងទ្វារនគរ ព្រះរាជាត្រាស់ថា ខ្លោងទ្វារនគរដល់ម្ល៉េះ ព្រះរាជវាំងដូចម្តេចហ្ន៎ ទ្រង់បានឮថា ដូចគ្នានឹងវេជ្ជយន្តប្រាសាទ ត្រាស់ថា យើងមិនអាចច្បាំងជាមួយព្រះរាជាដែលដល់ព្រមដោយយសយ៉ាងនេះ បានទតខ្លោងទ្វារហើយ ទ្រង់គេចទៅកាន់នគរ ពារាណសី ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាបលាយិបរិព្វាជកក្នុងកាលឥឡូវនេះ ឯព្រះរាជានគរតក្កសិលាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បលាយិតជាតក ចប់

# ទុតិយបលាយិជាតក

[ ៣០៩ ] ( ព្រះរាជាគន្ធារៈទ្រង់ត្រាស់ថា ) ទង់សម្រាប់រថប្រមាណមិនបាន ពលពាហនៈមានត្រើយមិនមានទីបំផុត ( រាប់មិនបាន ) ពួកសត្រូវគ្របសង្កត់បានដោយក្រដូចជាសមុទ្រសាគរដែលហ្វូងក្អែក ( គ្របសង្កត់បានដោយក្រ ) ( ពួកពលរបស់យើងនេះ ) ពួកពលដទៃគ្របសង្កត់បានដោយក្រដូចជាភ្នំដែលខ្យល់គ្របសង្កត់បានដោយក្រ ក្នុងថ្ងៃនេះអាត្មាអញប្រកបដោយពលប្រាកដដូច្នោះ កម្រអ្នកណានឹងគ្របសង្កត់បាន ។

[ ៣១០ ] ( ព្រះរាជាពារាណសីពោធិសត្វពោលថា ) ព្រះអង្គកុំនិយាយនូវអំពើពាលឡើយ ព្រោះបុគ្គលប្រហែលដូចព្រះអង្គមិន ( អាចយករាជសម្បត្តិបានទេ ) ព្រះអង្គក្តៅអន្ទះអន្ទែង ( ដោយភ្លើង គឺរាគៈ ទោសៈ មោហៈ និងមានះតែប៉ុណ្ណោះ ) ដ្បិតថាព្រះអង្គរមែងមិនបាននូវបុគ្គលប្រាកដស្មើដោយខ្ញុំ ដែលជាអ្នកកំចាត់បង់ទេ ដំរីណានឹងគក់បោកនូវព្រះអង្គដូចជាជាន់ឈ្លីនូវដើមបបុសដោយជើង ព្រះអង្គដូចជាដំរី ( ចុះប្រេង ) ចូលទៅរក ត្រាច់ទៅតែម្នាក់ឯងនោះ ។

**ចប់ ទុតិយបលាយិជាតក ទី ១០ ។**

**ចប់ កាសាវវគ្គ ទី ៨ ។**

## ឧទ្ទាននៃកាសាវនោះគឺ

និយាយអំពីសំពត់ដ៏ប្រសើរ ១ ពាក្យរបស់អាចារ្យ ១ ផ្លែឈើអស់ហើយ ១ ធម៌ដ៏ប្រសើរ ៤ យ៉ាង ១ បុរសដ៏ខ្ពង់ខ្ពស់ ១ សត្វក្អែក ១ ពួកជនក្នុងដែនមគធៈ ១ ដែន ៣ កន្លែង ១ ដំរីដ៏ប្រសើរស្រែកសំទារ ១ ទង់ដ៏ប្រសើរ ១ ត្រូវជា ១០ ។

## អដ្ឋកថា

## ទុតិយបលាយិតជាតក

[ ៣០៩-៣១០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបលាយិបរិព្វាជក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ធជមបរិមិតំ** ដូច្នេះជាដើម ។

តែក្នុងរឿងនេះ បរិព្វាជកនោះ ចូលទៅកាន់វត្តជេតពន ។ ខណៈនោះព្រះសាស្តាចោមរោមដោយមហាជន គង់លើធម្មាសនៈដែលប្រដាប់តាក់តែងហើយសម្តែងធម៌ ដូចសីហៈបន្លឺសីហនាទលើផ្ទាំងមនោសិលា បរិព្វាជកឃើញរូបរបស់ព្រះទសពល មានចំណែកដ៏ស្អាតដូចរូបព្រហ្ម ព្រះភក្ត្រមានសិរីដូចព្រះចន្ទពេញវង់និងព្រះនលាដដូចដំបារមាសក៏ពោលថា អ្នកណាអាចយកឈ្នះឧត្តមបុរសមានរូបយ៉ាងនេះ បានបែរត្រឡប់មិនបានចូលក្នុងពួកបរិស័ទគេចទៅ ។ មហាជនដេញតាមបរិព្វាជកហើយត្រឡប់មកក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា បរិព្វាជកនោះឃើញព្រះភក្ត្រមានឆវីវណ្ណដូចមាសរបស់តថាគត គេចទៅហើយក្នុងកាលឥឡូវនេះក៏មិនមែនសូម្បីក្នុងកាលមុនក៏គេចទៅហើយដូចគ្នា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះពោធិសត្វសោយរាជសម្បត្តិនៅក្នុងនគរពារាណសីព្រះបាទគន្ធារៈមួយអង្គសោយសម្បត្តិក្នុងក្រុងតក្កសិលា ព្រះបាទគន្ធារៈនោះត្រិះរិះថា នឹងទៅវាយដណ្តើមនគរពារាណសី ដល់ព្រមដោយចតុរង្គសេនា

លើកទ័ពមកព័ទ្ធនគរពារាណសី ប្រថាប់ឈរក្បែរខ្លោងទ្វារនគរទតមើលពលពាហនៈរបស់ព្រះអង្គគិតថា អ្នកណាអាចយកឈ្នះពលពាហនៈប្រមាណប៉ុណ្ណោះបានបានពោលគាថាទីមួយសរសើរកងទ័ពរបស់ព្រះអង្គថា

ទង់សម្រាប់រថប្រមាណមិនបាន ពលពាហនៈមានត្រើយមិនមានទីបំផុត ( រាប់មិនបាន ) ពួកសត្រូវគ្របសង្កត់បានដោយក្រដូចជាសមុទ្រសាគរដែលហ្វូងក្អែក ( គ្របសង្កត់បានដោយក្រ ) ( ពួកពលរបស់យើងនេះ ) ពួកពលដទៃគ្របសង្កត់បានដោយក្រដូចជាភ្នំដែលខ្យល់គ្របសង្កត់បានដោយក្រ ក្នុងថ្ងៃនេះអាត្មាអញប្រកបដោយពលប្រាកដដូច្នោះ កម្រអ្នកណានឹងគ្របសង្កត់បាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធជមបរិមិតំ** សេចក្តីថា ចំពោះទង់ដែលដោតទុកត្រង់ចន្ទោលរថរបស់យើងនេះប៉ុណ្ណោះ ក៏រាប់មិនអស់សន្ធឹកសន្ធាប់ច្រើនរយ ។ បទថា **អនន្តបារំ** សេចក្តីថា សូម្បីពលពាហនៈរបស់យើងមើលដាច់កន្ទុយភ្នែក ដែលគណនារាប់មិនបានថា ពលដំរីមានប៉ុណ្ណោះ ពលសេះមានប៉ុណ្ណោះ ពលរថមានប៉ុណ្ណោះ ពលថ្មើរជើងមានប៉ុណ្ណោះ ។ បទថា **ទុប្បសហំ** បានដល់ សត្រូវទាំងឡាយមិនអាចគ្របសង្កត់បាន ។ សួរថា ដូចអ្វី ឆ្លើយថា ដូចសមុទ្រសាគរដែលក្អែកទាំងឡាយសូម្បីច្រើនលំបាកយកឈ្នះបានដោយការប្រណាំងដោយសម្ទុះ គឺការហើរឆ្លងដូច្នោះ ។ បទថា **គិរិមិវ អនិលេន ទុប្បសហោ** សេចក្តីថាម្យ៉ាងទៀតពលនិកាយរបស់

យើងនេះ ពលនិកាយដទៃលំបាកនឹងគ្របសង្កត់បានដូចក្អំដែលខ្យល់ផាត់ឲ្យកម្រើកមិនបានដូច្នោះ ។ បទថា **ឧប្បសហោ អហាមជ្ជ តានិសេន** សេចក្ដីថា យើងដល់ព្រមដោយពលបែបនេះសត្រូវលំបាកដណ្ដើមជ័យជម្នះបានក្នុងថ្ងៃនេះ ព្រះបាទគន្ធារៈត្រាស់សំដៅ ( កំញើញ ) ដល់ព្រះពោធិសត្វដែលប្រថាប់ឈរលើប៉ម ។

លំដាប់នោះព្រះពោធិសត្វបង្ហាញព្រះភក្ត្ររបស់ព្រះអង្គ ដែលទ្រទ្រង់នូវសិរីដូចព្រះចន្ទពេញវង់ដល់ព្រះបាទគន្ធារៈនោះទ្រង់សម្ដុតថា នែស្ដេចពាលទ្រង់កុំនិយាយនូវអំពើពាលឡើយ ឥឡូវនេះយើងនឹងកម្ទេចពលពាហនៈរបស់ទ្រង់ឲ្យដូចជាដំរីចុះប្រេងជាន់ដើមបបុសដូច្នេះ ទើបពោលគាថាទីពីរថា

ព្រះអង្គកុំនិយាយនូវអំពើពាលឡើយ ព្រោះបុគ្គលប្រហែល
ដូចព្រះអង្គមិន ( អាចយករាជសម្បត្តិបានទេ ) ព្រះអង្គក្ដៅ
អន្ទះអន្ទែង ( ដោយភ្លើង គឺរាគៈ ទោសៈ មោហៈនិងមានៈ
តែប៉ុណ្ណោះ ) ដ្បិតថាព្រះអង្គរមែងមិនបាននូវបុគ្គលប្រាកដ
ស្មើដោយខ្ញុំដែលជាអ្នកកំចាត់បង់ទេ ដំរីណានឹងគក់បោកនូវ
ព្រះអង្គដូចជាជាន់ឈ្លីនូវដើមបបុសដោយជើង ព្រះអង្គដូចជា
ដំរី ( ចុះប្រេង ) ចូលទៅរក ត្រាច់ទៅតែម្នាក់ឯងនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មា ពាលិយំ វិប្បលបិ** សេចក្ដីថា ព្រះអង្គកុំរវើរវាយតាមភាពដែលខ្លួនជាបុគ្គលពាលឡើយ ។ បទថា **ន ហិស្ស តាទិសំ** បាលីថា **ន ហិស្ស តាទីសោ** ក៏មានសេចក្ដីថា ព្រោះមិនមាន

បុគ្គលដែលគិតថា ពាហនៈរបស់យើងផុតកន្ទុយក្អែកអាចនឹងដណ្តើមរាជ-សម្បត្តិបានដូចទ្រង់ ។ បទថា **វិឧឃ្ឃសេ** សេចក្តីថា ទ្រង់ត្រូវកាពក្តៅក្រហាយ គឺរាគៈ ទោសៈ មោហៈនិងមានះដុតរោលជានិច្ច ។ បទថា **ឧ ហិ លកសេ ធិសេធកំ** សេចក្តីថា ទ្រង់មិនបានការសម្ងុតគ្របសង្កត់បុគ្គលដូចយើងបានឡើយ ថ្ងៃនេះយើងនឹងឲ្យទ្រង់រត់ទៅតាមផ្លូវដែលមកនោះឯង ។ បទថា **អាសជ្ជសិ** បានដល់ ចូលទៅជិត ។ បទថា **គជមិវ ឯកចារិនំ** បានដល់ ដូចដំរីចុះប្រេងដែលត្រាច់ទៅតែឯង ។ បទថា **យោ តំ បទា ឧឡមិវ ចោជយិស្សតិ** សេចក្តីថា កងទ័ពរបស់យើងនឹងកម្ទេចទ្រង់ឲ្យខ្ទេចខ្ទីដូចដំរីចុះប្រេងបែនដើមបបុសដោយជើងដូច្នោះ ។

ឯព្រះបាទគន្ធារៈ បានស្តាប់ពាក្យរបស់ព្រះពោធិសត្វសម្តុតដូច្នេះហើយ ទតមើលឃើញព្រះនលាដដូចដំបារមាស ខ្វាចត្រូវចាប់ ទើបបែរត្រឡប់ទៅកាន់នគររបស់ទ្រង់ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទគន្ធារៈក្នុងកាលនោះ បានមកជាបលាយិបរិព្វាជកក្នុងកាលឥឡូវនេះ ឯព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ទុតិយបលាយិតជាតក ចប់**

**កាសាវវគ្គ ចប់**

# ឧបាហនវគ្គ

## ឧបាហនជាតក

[ ៣១១ ] ( ទម្ម័កជីវិតពោធិសត្វពោលថា ) ស្បែកជើងដែលបុរសទិញហើយ ដើម្បីប្រយោជន៍ដោយសេចក្ដីសុខ ជាស្បែកជើងក្ដៅហើយដោយកម្ដៅថ្ងៃ បៀតបៀនផ្ទៃជើងគប្បីនាំមកនូវសេចក្ដីទុក្ខ គប្បីស៊ីនូវជើងនៃបុរសនោះឯងមានឧបមាយ៉ាងណា ។

[ ៣១២ ] បុគ្គលណាកើតក្នុងត្រកូលអាក្រក់ ជាអ្នកមិនប្រសើរ បានរៀនវិជ្ជានិងសូត្រ ( អំពីសំណាក់ ) នៃអ្នកទាំងឡាយ ( អាចារ្យ ) ហើយ រមែងស៊ីនូវខ្លួននោះឯង ព្រោះវិជ្ជានិងសូត្រដែលខ្លួនរៀនហើយ ក្នុងសំណាក់នៃអាចារ្យនោះ បុគ្គលនោះ ( បណ្ឌិតពោលថា ) ជាមនុស្សមិនប្រសើរមានឧបមាដោយស្បែកជើងដែលធ្វើមិនល្អហើយយ៉ាងនោះដែរ ។

**ចប់ ឧបាហនជាតកទី ១ ។**

# ឧបាហនវគ្គ

## អដ្ឋកថា ឧបាហនជាតក

[ ៣១១-៣១២ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យថាបិ កីតា** ដូច្នេះជាដើម ។

មានសេចក្ដីសង្ខេបថា ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា

អាវុសោទាំងឡាយ ទេវទត្តភិក្ខុទ្រុស្តអាចារ្យ ក្លាយជាសត្រូវចំពោះព្រះតថាគត ដល់នូវសេចក្តីវិនាសធំ ។ ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនទ្រុស្តអាចារ្យ ជាអ្នកបដិបក្ខចំពោះតថាគត ដល់នូវសេចក្តីវិនាសធំតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនក៏ជាបដិបក្ខចំពោះតថាគតដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលនាយហត្ថាចារ្យ កាលចម្រើនវ័យហើយ ក៏សម្រេចហត្ថិសិប្បៈ កាលនោះមានមាណពអ្នកស្រុកកាសិគាមម្នាក់មករៀនសិប្បៈក្នុងសម្នាក់របស់ព្រះពោធិសត្វ ។ ធម្មតាព្រះពោធិសត្វទាំងឡាយកាលនឹងបង្រៀនសិប្បៈរមែងមិនលាក់វិជ្ជា ឲ្យសិក្សាតាមដែលខ្លួនចេះមកមិនមានសេសសល់ ។ ព្រោះហេតុនោះទើបមាណពនោះរៀនសិប្បៈរបស់ព្រះពោធិ-សត្វទាល់តែអស់ ហើយពោលនឹងព្រះពោធិសត្វថា បពិត្រលោកអាចារ្យ ខ្ញុំនឹងទទួលរាជការ ព្រះពោធិសត្វពោលថា ប្រពៃហើយបា ទើបទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព សិស្សរបស់ទូលព្រះបង្គំ ប្រាថ្នានឹងទទួលរាជការ ។ ព្រះរាជាត្រាស់ថា សាធុ ចូរទទួលរាជការចុះ ។ ព្រះពោធិសត្វក្រាបទូលថា បើដូច្នោះសូមទ្រង់តាំងបៀវត្សដល់គេចុះ ។ ព្រះរាជាត្រាស់

ថា សិស្សរបស់អ្នកបានបៀវត្សស្មើនឹងអ្នកមិនបាន បើអ្នកបាន ១០០ គេត្រូវបាន ៥០ បើអ្នកបាន ២០០ គេត្រូវបាន ១០០ ។ ព្រះពោធិសត្វត្រឡប់មកផ្ទះប្រាប់រឿងនោះដល់កូនសិស្ស កូនសិស្សពោលថា បពិត្រលោកអាចារ្យ ខ្ញុំចេះសិប្បៈស្មើលោកបើបានបៀវត្សស្មើគ្នានឹងលោក ខ្ញុំនឹងទទួលរាជការ បើមិនបានខ្ញុំមិនទទួលឡើយ ។ ព្រះពោធិសត្វក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា បើគេស្មើនឹងអ្នកគ្រប់ប្រការអាចសម្តែងសិប្បៈស្មើនឹងអ្នកនោះឯងក៏នឹងបានបៀវត្សស្មើគ្នា ។ ទើបព្រះ-ពោធិសត្វ ប្រាប់រឿងនោះដល់កូនសិស្ស កាលកូនសិស្សទទួលថា សាធុ ខ្ញុំនឹងសម្តែងទើបទៅក្រាបទូលដល់ព្រះរាជា ព្រះរាជាត្រាស់ថា បើដូច្នោះចូរសម្តែងសិប្បៈក្នុងថ្ងៃស្អែកចុះ ។ ព្រះពោធិសត្វក្រាបទូលថា សាធុទូលព្រះបង្គំនឹងសម្តែង សូមទ្រង់ឲ្យមនុស្សវាយស្គរប្រកាសចុះ ។ ព្រះរាជាបានឲ្យវាយស្គរប្រកាសថា ស្អែកនេះអាចារ្យនិងសិស្សទាំង ២ នាក់នឹងសម្តែងសិប្បៈដំរី អ្នកបំណងមើលចូរនាំគ្នាមកមើលត្រង់លានព្រះរាជវាំង ។ អាចារ្យគិតថា កូនសិស្សរបស់អញមិនទាន់ឈ្លាសក្នុងឧបាយ ទើបចាប់ដំរីមួយមកបង្ហាត់ឲ្យចាំដោយការធ្វើផ្ទុយក្នុងមួយយប់ប៉ុណ្ណោះ ។ អាចារ្យឲ្យដំរីសិក្សាយ៉ាងនេះគឺ បើប្រាប់ឲ្យដើរទៅមុខក៏ដើរថយក្រោយ បើប្រាប់ឲ្យដើរថយក្រោយក៏ដើរទៅមុខ ប្រាប់ឲ្យក្រាបក៏ក្រោក ប្រាប់ឲ្យក្រោកក៏ក្រាប កាលប្រាប់ឲ្យចាប់ក៏ដាក់ កាលប្រាប់ឲ្យដាក់ក៏ចាប់ ។

ស្អែកឡើង ទើបជិះដំរីនោះទៅកាន់លានព្រះរាជវាំង ឯកូនសិស្សក៏ឡើង

ដំរីដែលខ្លួនពេញចិត្តមួយទៅ ។ មហាជនប្រជុំគ្នាហើយទាំង ២ នាក់បាន សម្តែងសិប្បៈស្មើៗគ្នា ។ ព្រះពោធិសត្វឲ្យដំរីរបស់ខ្លួនធ្វើកិច្ចដែលផ្ទុយគ្នា ។ ដំរីនោះកាលប្រាប់ថា ចូរទៅមុខក៏ថយក្រោយ កាលប្រាប់ថា ចូរថយក្រោយ ក៏បែរជារត់ទៅមុខ កាលប្រាប់ថា ចូរឈរក៏ក្រាបចុះ កាលប្រាប់ថា ចូរ ក្រាបចុះក៏ក្រោកឡើង កាលប្រាប់ថា ចូរកាន់យកក៏គ្រវែងចោល កាល ប្រាប់ថា ចូរគ្រវែងចោលក៏កាន់យក ។ មហាជនពោលថា នែសិស្សអាក្រក់ អ្នកធ្វើការប្រណាំងជាមួយអាចារ្យមិនស្គាល់ប្រមាណខ្លួនយល់ថា ខ្លួនចេះស្មើ នឹងអាចារ្យ នាំគ្នាកាន់យកដុំដីនិងអង្កត់ឧសជាដើម ប្រហារឲ្យដល់នូវការស្លាប់ ក្នុងទីនោះឯង ។ ព្រះពោធិសត្វចុះអំពីដំរី ចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព ឈ្មោះថា សិប្បៈបុគ្គលរមែងរៀនដើម្បីសេចក្តីសុខ ដល់ខ្លួន តែសិប្បៈដែលបុគ្គលខ្លះរៀនហើយបែរជានាំសេចក្តីវិនាសមកឲ្យដូច ស្បែកជើងដែលធ្វើមិនល្អដូច្នោះទើបពោលគាថា ២ ថា

ស្បែកជើងដែលបុរសទិញហើយដើម្បីប្រយោជន៍ដោយ
សេចក្តីសុខ ជាស្បែកជើងក្តៅហើយដោយកម្តៅថ្ងៃ បៀត
បៀនផ្ទៃជើង គប្បីនាំមកនូវសេចក្តីទុក្ខ គប្បីស៊ីនូវជើងនៃបុរស
នោះឯងមានឧបមាយ៉ាងណា ។

បុគ្គលណាកើតក្នុងត្រកូលអាក្រក់ជាអ្នកមិនប្រសើរ បាន
រៀនវិជ្ជានិងសូត្រ ( អំពីសំណាក់ ) នៃអ្នកទាំងឡាយ
( អាចារ្យ ) ហើយរមែងស៊ីនូវខ្លួននោះឯងព្រោះវិជ្ជានិងសូត្រ

ដែលខ្លួនរៀនហើយក្នុងសំណាក់នៃអាចារ្យនោះ បុគ្គលនោះ
( បណ្ឌិតពោលថា ) ជាមនុស្សមិនប្រសើរមានឧបមាដោយ
ស្បែកជើងដែលធ្វើមិនល្អហើយយ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទព្យហោ** គឺ នាំមក ។ បទថា **យម្មាភិ-តត្តាតលសារ បីឡិតា** បានដល់ ស្បែកជើងនោះត្រូវកម្ដៅថ្ងៃធ្វើឲ្យក្ដៅផង ត្រូវបាទជើងបៀតបៀនផង ។ បទថា **តស្សេវ** សេចក្ដីថា ស្បែកជើងដែលធ្វើមិនល្អ ដែលគេទិញមកពាក់ដើម្បីជាសុខដល់ជើង កាលត្រូវកម្ដៅថ្ងៃបៀតបៀន ត្រូវផ្ទៃជើងបៀតបៀនហើយ រមែងមុតជើងក្លាយជារបួស ។ បទថា **ទុក្កុលិនោ** បានដល់ បុគ្គលដែលមានជាតិថោកទាប មិនមែនកូនរបស់អ្នកមានត្រកូលទេ ។ បទថា **អនរិយោ** គឺជាអសប្បុរស មិនមានហិរិឱត្តប្បៈ ។ បទថា **វិជ្ជញ្ច** បានដល់ រៀនយកនូវសិល្បសាស្ត្រទាំង ១៨ ប្រការណាមួយ ។ បទថា **សុតំ** បានដល់ សុតៈ គឺបរិយត្តិណាមួយ រមែងបៀតបៀនខ្លួនឯងដោយសូត្រក្នុងសម្នាក់អាចារ្យនោះ ។ បទថា **សោ** សេចក្ដីថា បុគ្គលណាកើតក្នុងត្រកូលអាក្រក់ មិនមានអរិយធម៌រៀនវិជ្ជានិងសូត្រអំពីអាចារ្យ បុគ្គលនោះរមែងបៀតបៀនខ្លួនឯងដោយសុតៈក្នុងសម្នាក់អាចារ្យនោះដូច្នោះ ។ បទថា **អនរិយោ វុច្ចតុបាហនូបមោ** បណ្ឌិតហៅថា ជាអ្នកមិនមានអរិយធម៌ដូចស្បែកជើងដែលធ្វើមិនល្អ ។ ព្រះរាជាទ្រង់ប្រោសប្រទានយសធំដល់ព្រះពោធិសត្វ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំ

ជាតកថា កូនសិស្សក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ឯអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាឧបាហនជាតក ចប់

# វិណាថូណជាតក

[ ៣១៣ ] ( សេដ្ឋីពោធិសត្វពោលថា ) ប្រយោជន៍នេះ នាងគិតតែម្នាក់ឯង បុរសពាលនាំនាងទៅមិនបាន ម្នាលនាងដ៏ចម្រើនព្រោះថា នាងមិនគួរដើម្បីទៅជាមួយនឹងបុរសគមតឿឡើយ ។

[ ៣១៤ ] ( សេដ្ឋីធីតាពោលថា ) ខ្ញុំសំគាល់បុរសគមជាបុរសឧសភៈបានប្រាថ្នាហើយ បុរសគមនេះដេករួញអង្កុញដូចជាពិណាដែលមានខ្សែដាច់ ។

**ចប់ វិណាថូណជាតកទី ២ ។**

## អដ្ឋកថា

## វិណាថូណជាតក

[ ៣១៣-៣១៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកាម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯកចិន្តិតោ អយមត្ថោ** ដូច្នេះជាដើម ។

បានឮថា កុមារិកានោះជាធីតារបស់សេដ្ឋីម្នាក់ក្នុងក្រុងសាវត្ថី ឃើញគ្រឿងសក្ការៈដែលគេធ្វើដល់គោឧសភរាជក្នុងផ្ទះរបស់ខ្លួន ទើបសួរមេដោះថា បពិត្រអ្នកម៉ែ នុ៎ះជាអ្វីទើបបានគ្រឿងសក្ការៈយ៉ាងនេះ មេដោះឆ្លើយថា នោះជាគោឧសភរាជ ។ ថ្ងៃមួយនាងឈរត្រង់បង្អួចក្រឡេកមើលវិថីឃើញបុរសគមម្នាក់គិតថា គោដែលជាធំក្នុងហ្វូងគោ រមែងមានបូកត្រង់ខ្នង មនុស្សជាធំក៏គង់មានបូកត្រង់ខ្នងដូចគ្នា បុរសនេះគង់ជាបុរសឧសភរាជពិត អញគួរជា

បាទបរិចារិកាបរបស់បុរសនេះ ។ ទើបនាងឲ្យទាសីទៅប្រាប់ដល់បុរសគមថា សេដ្ឋីធីតាចង់ទៅជាមួយអ្នក ចូរអ្នកបង្អង់ក្នុងទីឈ្មោះនោះហើយកាន់យកវត្ថុមានតម្លៃ ក្លែងខ្លួនមិនឲ្យអ្នកណាស្គាល់ចុះអំពីប្រាសាទគេចទៅជាមួយបុរសគមនោះ ។ ក្រោយមកការធ្វើរបស់សេដ្ឋីធីតានោះបានប្រាកដក្នុងនគរនិងពួកភិក្ខុ ។ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា សេដ្ឋីធីតាឈ្មោះនោះរត់ទៅជាមួយបុរសគម ។ ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេដ្ឋីធីតានេះមិនមែនប្រាថ្នាបុរសគមតែក្នុងកាលឥឡូវប៉ុណ្ណោះនេះទេ សូម្បីក្នុងកាលមុនក៏ប្រាថ្នាបុរសគមដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែង ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលសេដ្ឋីនាតំបន់មួយ លុះចម្រើនវ័យហើយមានក្រុមគ្រួសារចម្រើនដោយបុត្តធីតាទាំងឡាយ ទើបទៅដណ្តឹងធីតារបស់សេដ្ឋីនគរពារាណសីឲ្យដល់បុត្តរបស់ខ្លួន កំណត់ថ្ងៃហើយ ។ សេដ្ឋីធីតាឃើញគ្រឿងសក្ការៈរបស់គោឧសភរាជត្រង់ផ្ទះរបស់ខ្លួនទើបសួរមេដោះថា បពិត្រអ្នកម៉ែ សត្វនេះមានឈ្មោះអ្វី បានស្តាប់ថា គោឧសភរាជ កាលឃើញបុរសគមដើរតាមផ្លូវក៏គិតថា បុរសនេះគង់ជាបុរសឧសភរាជទើបកាន់បង្វេច

វត្ថុមានតម្លៃ គេចទៅជាមួយបុរសគមនោះ ។ ឯព្រះពោធិសត្វគិតថានឹងនាំសេដ្ឋីធីតាមកផ្ទះទើបទៅកាន់នគរពារាណសីជាមួយបរិវារដ៏ច្រើន ធ្វើដំណើរទៅតាមផ្លូវនោះដូចគ្នា ឯបុរសគមនិងសេដ្ឋីធីតាទាំងគូនោះ ធ្វើដំណើរដល់យប់ គ្រានោះបុរសគមត្រូវរោគបៀនបៀនមួយយប់ ទើបរោគខ្យល់កម្រើកក្នុងរាងកាយ លុះអរុណរះឡើងដល់នូវទុក្ខវេទនាដ៏ខ្លាំងក្លា ទើបចៀសចេញអំពីផ្លូវ ដើម្បីអត់សង្កត់នូវទុក្ខវេទនា ដេកផ្អែកដូចពិណដាច់ខ្សែ ។ ឯសេដ្ឋីធីតាក៏អង្គុយក្បែរជើងរបស់បុរសនោះ ។ ព្រះពោធិសត្វឃើញសេដ្ឋីធីតានោះអង្គុយក្នុងទីក្បែរជើងបុរសគមចាំបានទើបចូលទៅរក កាលនឹងសន្ទនាក៏ពោលគាថាទីមួយថា

> ប្រយោជន៍នេះ នាងគិតតែម្នាក់ឯង បុរសពាលនាំនាងទៅមិន
> បាន ម្នាលនាងដ៏ចម្រើនព្រោះថា នាងមិនគួរដើម្បីទៅជាមួយ
> នឹងបុរសគមតៀទ្បើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯកចិន្តិតោ អយមត្ថោ** សេចក្តីថា នែនាង នាងគិតប្រយោជន៍ឯណាទើបគេចមកជាមួយបុរសគមនេះ ប្រយោជន៍នោះនាងគិតតែម្នាក់ឯង ។ បទថា **ពាលោ អបរិណាយកោ** សេចក្តីថា ព្រោះថា បុរសគមជាបុគ្គលពាលនេះជាបុរសមិនមានបញ្ញា ទោះបីចាស់ក៏ល្ងង់ ទោះបីកាលមិនមានអ្នកដទៃនាំទៅក៏មិនអាចទៅបាន នែនាងដ៏ចម្រើន នាងកើតក្នុងត្រកូលធំ មានរូបស្អាត គួរអាណិត មិនគួរទៅជាមួយបុរសគមដែលថោកទាបនិងជាមនុស្សគៀនេះឡើយ ។ គ្រានោះសេដ្ឋីធីតាស្តាប់ពាក្យ

ព្រះពោធិសត្វហើយពោលគាថាទីពីរថា

ខ្ញុំសំគាល់បុរសគមជាបុរសឧសភៈ បានប្រាថ្នាហើយ បុរសគមនេះដេករួញអង្កុញ ដូចជាពិណាដែលមានខ្សែដាច់ដូច្នេះ ។

អត្ថនៃគាថានោះដូច្នេះថា បពិត្រលោកម្ចាស់ ខ្ញុំឃើញគោឧសភរាជមួយគិតថា គោដែលជាធំជាងគោទាំងឡាយមានបូកត្រង់ខ្នង សូម្បីបុរសនេះក៏មានបូកគង់ជាបុរសឧសភរាជ ខ្ញុំយល់បុរសគមថាជាបុរសឧសភរាជទើបស្រឡាញ់បុរសគមនោះដែលដេករួញអង្កុញខ្លួន ដូចពិណាដែលមានខ្សែដាច់សល់តែស្នូកដូច្នោះ ។

ព្រះពោធិសត្វជ្រាបថា នាងបន្ទំខ្លួនគេចទើបឲ្យស្រួចទឹកគាក់តែងខ្លួនឲ្យឡើងកាន់វេចរមកកាន់ផ្ទះរបស់ខ្លួន ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា សេដ្ឋីធីតាក្នុងកាលនោះបានមកជាសេដ្ឋីធីតាក្នុងកាលឥឡូវនេះ ឯពារាណសីសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វីណាថូណជាតក ចប់

## វិកណ្ណកជាតក

[ ៣១៥ ] ( បុរសអ្នកឲ្យបាយត្រីពោលថា ) ឯងប្រាថ្នាក្នុងទីណា ប្រាកដចូលទៅក្នុងទីនោះចុះ ឯងត្រូវច្បូកមុតហើយត្រង់ទីជាទីស្លាប់ ឯងជាសត្វរលោភរលាំដេញតាមចាប់នូវត្រីទាំងឡាយត្រូវគេសម្លាប់ហើយដោយបាយព្រមទាំងគ្រឿងប្រគំ ។

[ ៣១៦ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) បុគ្គលកាលប្រព្រឹត្តទៅតាមលោកាមិសៈ ជាអ្នកលុះក្នុងអំណាចនៃចិត្ត រមែងក្តៅក្រហាយ បុគ្គលនោះរមែងក្តៅក្រហាយក្នុងកណ្តាលពួកញាតិ និងសម្លាញ់ បុគ្គលនោះដូចក្រពើដេញតាមនូវត្រីដូច្នោះ ។

**ចប់ វិកណ្ណកជាតកទី ៣ ។**

## អដ្ឋកថា

## វិកណ្ណកជាតក

[ ៣១៥-៣១៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាមំ យហឹ ឥច្ឆសិ តេន គច្ឆ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា ភិក្ខុនោះត្រូវនាំទៅកាន់ធម្មសភា ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ក៏ក្រាបទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់សួរថា អ្នកអផ្សុកព្រោះហេតុអ្វី ភិក្ខុនោះក្រាប

ទូលថា ព្រោះកាមគុណ ។ លំដាប់នោះទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា កាមគុណនេះដូចគ្នានឹងច្បូក កាលតាំងនៅក្នុងបេះដូងម្តងហើយ តែងឲ្យដល់នូវសេចក្តីស្លាប់បាននោះឯង ដូចច្បូកដែលដោតចូលទៅហើយ គង់ញាំងក្រពើឲ្យដល់នូវសេចក្តីស្លាប់ដូច្នេះហើយ ទ្រង់នាំយកអតីតនិទានមកសំដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះពោធិសត្វសោយរាជសម្បត្តិក្នុងនគរពារាណសីដោយធម៌ ។ ថ្ងៃមួយប្រពាតឧទ្យានយាងដល់ច្រាំងស្រះបោក្ខរណី អ្នកជំនាញក្នុងការរាំច្រៀងជាដើម ក៏ប្រកបការរាំច្រៀងថ្វាយ ។ ត្រីនិងអណ្តើកទាំងឡាយត្រង់ស្រះបោក្ខរណីក៏មកប្រមូលគ្នាព្រោះមានចិត្តចង់ស្តាប់ក្នុងសំឡេងច្រៀងហែលទឹកតាមព្រះរាជាទៅ ។ ព្រះរាជាទតឃើញហ្វូងត្រីប្រមាណប៉ុនដើមត្នោតត្រាស់សួរអាមាត្យទាំងឡាយថា នែអ្នកទាំងឡាយ ហេតុអ្វីហ្ន៎ទើបពួកត្រីទាំងនេះហែលតាមយើង ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ត្រីទាំងនេះរង់ចាំបម្រើព្រះអង្គ ព្រះរាជាទ្រង់ពេញព្រះហឫទ័យថា ត្រីទាំងនេះគង់រង់ចាំបម្រើអញទើបទ្រង់ប្រទានអាហារប្រចាំថ្ងៃដល់ត្រីទាំងនោះ ។ ភ្នាក់ងារបានដាំអង្ករមួយអម្ពណៈ ( នាឡិ ) រាល់ៗថ្ងៃ ។ តមកត្រីទាំងឡាយដល់ពេលឲ្យអាហារពួកខ្លះមក ពួកខ្លះក៏មិនមក អាហារក៏ខូចទើបបុរសនោះក្រាបទូលសេចក្តីនោះដល់ព្រះរាជា ព្រះរាជាត្រាស់ថា តាំងអំពីនេះទៅ ចូរវាយស្គរប្រកាសពេលអាហារ ។ កាលពួកត្រីមកជុំគ្នាតាមសំឡេងស្គរហើយ ចូរឲ្យអាហារចុះ ។ តាំងអំពីនោះមកភ្នាក់ងារអ្នកចាត់ចែងអាហារបានវាយស្គរ

ហើយឲ្យអាហារដល់ពួកត្រីដែលមកជួបជុំគ្នា សូម្បីពួកត្រីទាំងនោះក៏មកជួបជុំគ្នាស៊ីអាហារតាមសញ្ញាស្គរ កាលពួកត្រីជួបជុំគ្នាស៊ីអាហារយ៉ាងនេះ មានក្រពើមួយមកស៊ីត្រី ទើបក្អាក់ងារក្រាបទូលរឿងនោះដល់ព្រះរាជា ព្រះរាជាស្ដាប់ដូច្នោះទើបត្រាស់ថា ចូរអ្នកយកច្បូកចាក់ក្រពើនោះ ដែលចូលមកក្នុងពេលស៊ីត្រីហើយចាប់ខ្លួនវាឲ្យបាន បុរសនោះទទួលព្រះរាជឱង្ការហើយត្រឡប់ទៅចុះទូករង់ចាំមើលបានប្រើច្បូកចាក់ក្រពើ ។ ច្បូកទម្លុះខ្នងក្រពើនោះក្រពើទទួលទុក្ខវេទនា ទើបគេចនាំយកច្បូកទៅផង ។ ក្អាក់ងារដឹងថាចាក់ត្រូវក្រពើហើយ កាលពោលនឹងក្រពើនោះទើបពោលគាថាទីមួយថា

ឯងប្រាថ្នាក្នុងទីណាប្រាកដចូលទៅក្នុងទីនោះចុះ ឯងត្រូវច្បូកមុតហើយត្រង់ទីជាទីស្លាប់ ឯងជាសត្វលោភលាំដេញតាមចាប់នូវត្រីទាំងឡាយ ត្រូវគេសម្លាប់ហើយដោយបាយ ព្រមទាំងគ្រឿងប្រគំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាមំ** គឺ ដោយចំណែកមួយ ។ បទថា **យហឹ ឥច្ឆសិ តេន គច្ឆ** សេចក្ដីថា អ្នកប្រាថ្នាក្នុងទីណា ក៏ចូរទៅក្នុងទីនោះចុះ ។ បទថា **មម្មម្ហិ** គឺ ក្នុងទីរបស់យើង ។ បទថា **អនុពន្ធមានោ** សេចក្ដីថា កាលអ្នកគេឲ្យអាហារដោយសញ្ញាស្គរក៏ជាសត្វល្មោភដេញតាមត្រីបំណងនឹងស៊ី ក៏ត្រូវអាហារមានសំឡេងស្គរជាសញ្ញាកម្មាត់ហើយ ។ ក្នុងទីដែលអ្នកទៅអ្នកក៏មិនមានជីវិត ក្រពើនោះទៅដល់លំនៅរបស់ខ្លួនហើយក៏ស្លាប់ ។

ព្រះសាស្តាកាលទ្រង់សម្តែងជាតកនេះហើយ ត្រាស់ដឹងហើយបានត្រាស់គាថាទីពីរថា

បុគ្គលកាលប្រព្រឹត្តទៅតាមលោកាមិសៈ ជាអ្នកលុះក្នុងអំណាចនៃចិត្តរមែងក្តៅក្រហាយ បុគ្គលនោះ រមែងក្តៅក្រហាយក្នុងកណ្តាលពួកញាតិនិងសម្លាញ់ បុគ្គលនោះដូចក្រពើដេញតាមនូវត្រីដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **លោកាមិសំ** បានដល់ កាមគុណ ៥ ព្រោះកាមគុណ ៥ នោះ សត្វលោកសម្គាល់ថាជារបស់គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ព្រោះហេតុនោះទើបហៅថា លោកាមិស ។ បទថា **ឱបតន្តោ** សេចក្តីថា បុគ្គលប្រព្រឹត្តទៅតាមលោកាមិសនោះ ជាអ្នកលុះក្នុងអំណាចនៃចិត្តដោយអំណាចកិលេសរមែងក្តៅក្រហាយ លំបាក ដល់នូវសេចក្តីវិនាស ។ បទថា **សោ ហញ្ញតិ** សេចក្តីថា បុគ្គលប្រកាន់កាមគុណ ៥ ថាជាទីពឹងជាទីពេញចិត្តហើយរមែងដល់នូវសេចក្តីក្តៅក្រហាយ លំបាក ដល់នូវសេចក្តីវិនាសក្នុងកណ្តាលញាតិនិងសម្លាញ់ទាំងឡាយដូចក្រពើ ដែលដេញតាមត្រីត្រូវចាក់ដោយច្បូកដូច្នោះ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា ក្រពើក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ត្រីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯព្រះបាទពារាណសីក្នុងកាល

នោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វិកណ្ណកជាតក ចប់

# អសិតាភុជាតក

[ ៣១៧ ] ( នាងអសិតាភូពោលថា ) ( ខ្ញុំ ) អស់សេចក្តីស្រឡាញ់ចំពោះអ្នកព្រោះអំពើណា អ្នកបានធ្វើអំពើនេះ ក្នុងកាលឥឡូវនេះសេចក្តីស្រឡាញ់នោះមិនតជាប់វិញទេ ដូចជាភ្លុកដំរីដែលគេកាត់ដោយរណារដូច្នោះ ។

[ ៣១៨ ] ( ព្រហ្មទត្តរាជកុមារមានទទួលថា ) បុគ្គលមានសេចក្តីប្រាថ្នាលើសលុប រមែងសាបសូន្យចាកប្រយោជន៍ ព្រោះលោភហួសហេតុផង ព្រោះសេចក្តីស្រវឹងក្នុងការចង់បានហួសហេតុផង ដូចយើងសាបសូន្យចាករាជធីតាឈ្មោះអសិតាភូ ។

**ចប់ អសិតាភុជាតកទី ៤ ។**

## អដ្ឋកថា

# អសិតាភុជាតក

[ ៣១៧-៣១៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ត្វមេវទានិមការិ** ដូច្នេះជាដើម ។

បានឮថា ក្នុងត្រកូលឧបដ្ឋាកមួយរបស់អគ្គសាវកទាំង ២ ក្នុងក្រុងសាវត្ថី មានកុមារីម្នាក់មានរូបស្អាតដល់ព្រមដោយលម្អដ៏លើស ។ នាងចម្រើនវ័យក៏បានទៅកាន់ត្រកូលដែលមានជាតិស្មើគ្នា ស្វាមីរបស់នាងមិនពេញចិត្តដោយប្រការណាមួយទើបត្រាច់ទៅក្នុងទីដទៃតាមគាប់ចិត្ត នាងក៏មិនយកចិត្ត

ទុកដាក់ក្នុងការដែលស្វាមីមិនត្រេកអរនឹងខ្លួននោះ និមន្តអគ្គសាវកទាំង ២ មកថ្វាយទាន ស្ដាប់ធម៌ តាំងនៅក្នុងសោតាបត្តិផល ។ តាំងអំពីនោះមកនាងឲ្យពេលវេលាកន្លងទៅ ដោយសេចក្ដីសុខក្នុងមគ្គ និងផលគិតថា ប្ដីក៏មិនត្រេកអរក្នុងអញ អញក៏មិនមានការជាក្នុងផ្ទះយាវាស អញនឹងបួសទើបលាមាតាបិតាចេញបួស ក៏សម្រេចអរហត្ត ។ ការធ្វើរបស់នាងបានប្រាកដក្នុងពួកភិក្ខុ ។ ថ្ងៃមួយភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយធីតារបស់ត្រកូលនោះជាស្រីស្វែងរកប្រយោជន៍ដឹងថា ប្ដីមិនត្រេកអរបានស្ដាប់ធម៌របស់អគ្គសាវកតាំងនៅក្នុងសោតាបត្តិផលហើយលាមាតាបិតាចេញបួសទៀតសម្រេចអរហត្តហើយ អាវុសោទាំងឡាយ កុមារិកានោះជាអ្នកស្វែងរកប្រយោជន៍យ៉ាងនេះ ។ ព្រះសាស្ដាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុមារិកានោះជាអ្នកស្វែងរកប្រយោជន៍ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនជាអ្នកស្វែងប្រយោជន៍ដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបួសជាឥសីញុំាងអភិញ្ញានិងសមាបត្តិឲ្យកើតហើយ អាស្រ័យនៅក្នុងហិមវន្តប្បទេស ។ កាលនោះព្រះបាទពារាណសីឃើញការដល់ព្រមនៃបរិវាររបស់ព្រហ្មទត្តកុមារដែលជាឱរសរបស់ព្រះអង្គ កើតនូវសេចក្ដី

សន្សំយក្នុងព្រះហឫទ័យទើបនិទ្ទេសព្រះរាជឱរសចេញអំពីដែន ។ ព្រហ្មទត្តកុមារទ្រង់នាំព្រះទេវីរបស់ទ្រង់ព្រះនាមថា អសិតាភូចូលទៅកាន់ព្រៃហិមពាន្តសោយត្រី សាច់និងផ្លែឈើស្នាក់នៅក្នុងបណ្ណសាលា ។ ព្រហ្មទត្តកុមារនោះឃើញកិន្នរីមួយ មានចិត្តប្រតិព័ទ្ធគិតថានឹងយកកិន្នរីនេះជាភរិយា ទើបដើរតាមស្នាមជើងកិន្នរីនោះទៅមិនបាននឹកនាដល់ព្រះនាងអសិតាភូឡើយ ។ ព្រះនាងអសិតាភូ ឃើញព្រហ្មទត្តកុមារតាមកិន្នរីទៅត្រិះរិះថា ព្រហ្មទត្តកុមារនេះតាមកិន្នរីទៅមិនបាននឹកនាដល់អញ អញត្រូវការអ្វីដោយព្រហ្មទត្តកុមារនេះមានព្រះហឫទ័យប្រាសចាកសេចក្តីស្រឡាញ់ ទើបចូលទៅរកព្រះពោធិសត្វនមស្ការហើយ ។ ព្រះពោធិសត្វប្រាប់នូវការបរិកម្មកសិណដល់នាង នាងសម្លឹងកសិណ ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើត នមស្ការព្រះពោធិសត្វហើយត្រឡប់មកឈរត្រង់ទ្វារបណ្ណសាលារបស់ខ្លួន ។ ព្រហ្មទត្តកុមារដើរតាមកិន្នរីទៅ ទោះបីស្វែងរកក៏មិនបានជួបផ្លូវដែលកិន្នរីនោះទៅ អស់សង្ឃឹមទើបត្រឡប់បែរមុខមកកាន់បណ្ណសាលា ។ ព្រះនាងអសិតាភូឃើញព្រហ្មទត្តកុមារត្រឡប់មក ក៏បណ្តែតខ្លួនទៅកាន់វេហាឈរលើអាកាស មានពណ៌ដូចកែវមណីមានព្រះសវនីយ៍ថា បពិត្រអយ្យបុត្ត ខ្ញុំបានឈានសុខនេះព្រោះអាស្រ័យទ្រង់ហើយបានពោលគាថាទីមួយថា

( ខ្ញុំ ) អស់សេចក្តីស្រឡាញ់ចំពោះអ្នក ព្រោះអំពើណា
អ្នកបានធ្វើអំពើនេះ ក្នុងកាលឥឡូវនេះសេចក្តីស្រឡាញ់នោះ
មិនតជាប់វិញទេ ដូចជាភ្លុកដំរីដែលគេកាត់ដោយរណាដូច្នោះ

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ត្វមេវ ធាសិមករិ** សេចក្ដីថា បពិត្រអយ្យបុត្ត ទ្រង់នោះឯងលះបង់ខ្ញុំតាមកិន្នរី បានធ្វើហេតុនេះក្នុងឥឡូវនេះ ។ បទថា **យំ កាមោ ព្យគមា តយិ** លោកសម្ដែងថា ហេតុដែលធ្វើឲ្យសេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះទ្រង់បានរសាយទៅហើយ គឺលះបានដោយវិក្ខម្ភនប្បហាន ខ្ញុំដល់នូវសេចក្ដីវិសេសបែបនេះក៏ព្រោះលះសេចក្ដីស្រឡាញ់បានហើយ ។ បទថា **សោ យំ អប្បដិសន្ធិកោ** សេចក្ដីថា សេចក្ដីស្រឡាញ់នោះនឹងត្រឡប់តជាប់វិញទៀតមិនបាន គឺមិនអាចតបានក្នុងឥឡូវនេះ ។ បទថា **ខរា ឆិន្នំវ រេណុកំ** សេចក្ដីថា ប្រៀបដូចក្អកដីរ ដែលត្រូវរណារកាត់ដាច់ហើយនឹងតវិញមិនបាន គឺនឹងតជាប់ឲ្យជិតស្និទ្ធដូចដើមទៀតមិនបានយ៉ាងណា ការតភ្ជាប់ចិត្តរបស់ខ្ញុំជាមួយទ្រង់ទៀតរមែងមិនបានក៏យ៉ាងនោះ ។ កាលនាងពោលដូច្នេះហើយ បានត្រាច់ទៅកាន់ទីដទៃដោយអាកាសទាំងដែលព្រហ្មទត្តកុមារកំពុងមើលនោះឯង ។

ព្រហ្មទត្តកុមារកាលនាងអសិតាភូទៅហើយក៏សោកសង្រេងពោលគាថាទីពីរថា

បុគ្គលមានសេចក្ដីប្រាថ្នាលើសលុប រមែងសាបសូន្យចាក
ប្រយោជន៍ ព្រោះលោភហួសហេតុផង ព្រោះសេចក្ដីស្រវឹង
ក្នុងការចង់បានហួសហេតុផង ដូចយើងសាបសូន្យចាករាជ-
ធីតាឈ្មោះអសិតាភូ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អច្ចិដ្ឋា អតិលោភេន** សេចក្ដីថា ការចង់បានរកទីបំផុតមិនមានពោលគឺ ការប្រាថ្នាក្នុងរបស់នោះៗហៅថា **អច្ចិដ្ឋា** សេចក្ដីលោភដែលប្រព្រឹត្តទៅហួសប្រមាណហៅថា **អតិលោភេន** ។ បទថា **អតិលោភមទេន** ច បានដល់ សេចក្ដីស្រវឹងដោយលោភៈដ៏ខ្លាំងក្លាព្រោះជាហេតុឲ្យកើតសេចក្ដីស្រវឹងរបស់បុរស ។ បទនេះលោកអធិប្បាយថា បុគ្គលដែលប្រាថ្នាក្នុងវត្ថុនោះៗ ដោយសេចក្ដីប្រាថ្នាច្រើន រមែងវិនាសចាកប្រយោជន៍ ព្រោះការលោភខ្លាំងក្លា និងព្រោះការស្រវឹងដោយអតិលោភដូចខ្ញុំវិនាសហើយចាករាជធីតាឈ្មោះអសិតាភូដូច្នោះ ។

ព្រហ្មទត្តកុមារទ្រង់សម្រេងសម្រែដោយគាថានេះហើយ ប្រថាប់គង់មួយអន្លើឯងក្នុងព្រៃ កាលបិតាសោយទិវង្គតហើយទើបយាងទៅគ្រងរាជសម្បត្តិ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា រាជបុត្តនិងរាជធីតាក្នុងកាលនោះ បានមកជាជនទាំង ២ ក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា អសិតាភូជាតក ចប់**

## វច្ឆនខជាតក

[ ៣១៩ ] ( ពារាណសីសេដ្ឋីពោលថា ) បពិត្រវច្ឆនខតាបស លោកជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយគប្បីបរិភោគផង ផឹកផង ហើយដេកក្នុងផ្ទះទាំងឡាយណា ផ្ទះទាំងឡាយនោះប្រកបដោយប្រាក់និងមាស ប្រកបដោយភោជនជាសុខ ( យ៉ាងក្រៃលែង ) ។

[ ៣២០ ] ( វច្ឆនខតាបសពោលថា ) ការគ្រប់គ្រងផ្ទះមិនមានដល់បុគ្គលឥតព្យាយាម ការគ្រប់គ្រងផ្ទះមិនមានដល់បុគ្គលមិននិយាយពាក្យកុហក ការគ្រប់គ្រងផ្ទះមិនមានដល់បុគ្គលមិនកាន់យកនូវអាជ្ញា មិនធ្វើទោសដល់ជនទាំងឡាយដទៃ បុគ្គលណានឹងគ្រប់គ្រងផ្ទះដែលធ្លុះបំពេញបានដោយកម្រយ៉ាងនេះ ។

**ចប់ វច្ឆនខជាតក ទី ៥ ។**

## អដ្ឋកថា

## វច្ឆនខជាតក

[ ៣១៩-៣២០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នកប្រដាល់ឈ្មោះរោជៈ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សុខា ឃរា វច្ឆនខ** ដូច្នេះជាដើម ។

បានឮថា អ្នកប្រដាល់ឈ្មោះរោជៈជាសម្លាញ់របស់ព្រះអានន្ទ ។ ថ្ងៃមួយគាត់បញ្ជូនដំណឹងទៅដល់ព្រះថេរៈដើម្បីនិមន្តព្រះថេរៈមក ។ ព្រះថេរៈក៏

ក្រាបទូលព្រះសាស្តាហើយទៅ ។ បុរសនោះ និមន្តព្រះថេរៈឲ្យឆាន់អាហារ ដែលមានរសប្រសើរផ្សេងៗហើយអង្គុយក្នុងចំណែកម្ខាង គាត់ធ្វើបដិសណ្ឋារៈជាមួយព្រះថេរៈនិមន្តព្រះថេរៈដោយកាមគុណដែលជាគោគៈរបស់គ្រហស្ថថា បពិត្រលោកម្ចាស់អានន្ទ រតនៈមានវិញ្ញាណក្តី មិនមានវិញ្ញាណក្តី ក្នុងផ្ទះខ្ញុំមានច្រើន ខ្ញុំនឹងចែកឲ្យលោកម្ចាស់ពាក់កណ្តាល សូមលោកម្ចាស់មកចុះយើងនឹងគ្រប់គ្រងផ្ទះជាមួយគ្នា ។ ព្រះថេរៈសម្តែងទោសកាមគុណដល់បុរសនោះ ចុះអំពីអាសនៈត្រឡប់ទៅកាន់វិហារ ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ អ្នកជួបនឹងរោជៈហើយឬ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានជួបហើយ ព្រះសាស្តាត្រាស់សួរថា អ្នកនិយាយអ្វីជាមួយរោជៈ ក៏ក្រាបទូលថា រោជៈនិមន្តខ្ញុំព្រះអង្គឲ្យទៅគ្រប់គ្រងផ្ទះទើបខ្ញុំព្រះអង្គសម្តែងដល់ទោសក្នុងការគ្រប់គ្រងផ្ទះនិងទោសនៃកាមគុណដល់រោជៈ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកប្រជាល់ឈ្មោះរោជៈមិនមែនបបួលអ្នកបួសឲ្យគ្រប់គ្រងផ្ទះក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏បានបបួលហើយដូចគ្នា កាលព្រះអានន្ទទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់មួយ លុះចម្រើនវ័យហើយចេញបួសជាឥសីក្នុងហិមវន្តប្បទេសអស់កាលដ៏យូរ បានទៅកាន់នគរពារាណសីដើម្បីសេពរសជូរប្រៃ ស្នាក់នៅត្រង់ព្រះរាជឧទ្យាន ស្អែកឡើងចូល

ទៅកាន់ក្រុងពារាណសី កាលនោះសេដ្ឋីក្រុងពារាណសីជ្រះថ្លាក្នុងចរិយាវត្ត របស់ព្រះពោធិសត្វ ទើបនាំទៅកាន់ផ្ទះឲ្យឆាន់ហើយ ទទួលយកការប្តេជ្ញាដើម្បី នៅក្នុងឧទ្យានជានិច្ច ។ ជនទាំង ២ មានសេចក្តីស្រឡាញ់ចំពោះគ្នានឹងគ្នា ។ ថ្ងៃមួយ សេដ្ឋីក្រុងពារាណសីបានគិតយ៉ាងនេះ ដោយសេចក្តីស្រឡាញ់និង សេចក្តីស្និទ្ធស្នាលក្នុងព្រះពោធិសត្វថា ឈ្មោះថាការបួសជាទុក្ខ អញនឹងឲ្យ បរិព្វាជកឈ្មោះវច្ឆនខជាសម្លាញ់របស់អញសឹក ហើយចែកសម្បត្តិឲ្យពាក់ កណ្តាលដល់វច្ឆនខបរិព្វាជកនោះ យើងទាំង ២ នឹងរស់នៅប្រហាក់ប្រហែល គ្នា ។ ថ្ងៃមួយសេដ្ឋីនោះក្នុងកាលសម្រេចភត្តកិច្ច បានធ្វើបដិសណ្ឋារៈយ៉ាង ទន់ភ្លន់ជាមួយវច្ឆនខបរិព្វាជកហើយពោលថា បពិត្រលោកម្ចាស់វច្ឆនខ ឈ្មោះថា ការបួសជាទុក្ខ ឃរាវាសជាសុខ មកយើងទាំង ២ រួមគ្នាបរិភោគ កាមចុះហើយពោលគាថាទីមួយថា

> បពិត្រវច្ឆនខតាបស លោកជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ
> គប្បីបរិភោគផង ផឹកផង ហើយដេកក្នុងផ្ទះទាំងឡាយណា
> ផ្ទះទាំងឡាយនោះប្រកបដោយប្រាក់និងមាស ប្រកបដោយ
> ភោជនជាសុខ ( យ៉ាងក្រៃលែង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សហិរញ្ញា** គឺ ដល់ព្រមដោយរតនៈ ៧ ប្រការ ។ បទថា **សភោជនា** គឺ មានរបស់ទំពាររបស់បរិភោគច្រើន ។ បទថា **យត្ថ ភុត្វា បិវិត្វា ច** បានដល់ បរិភោគភោជនមានរសប្រសើរ ផ្សេងៗនិងផឹកនូវរបស់ផឹកផ្សេងៗក្នុងផ្ទះដែលមានទាំងប្រាក់ទាំងរបស់បរិភោគ។

បទថា **សយេយ្យាសិ អនុស្សុកោ** សេចក្តីថា លោកម្ចាស់មិនចាំបាច់ខ្វល់ខ្វាយក៏បានដេកលើដំណេកដ៏មានសិរី ដែលខ្ញុំតាក់តែងទុកហើយ ។ ដោយហេតុនោះទើបឈ្មោះថា ការនៅគ្រប់គ្រងផ្ទះជាសុខយ៉ាងក្រៃលែង ។

លំដាប់នោះ ព្រះពោធិសត្វ ស្តាប់ពាក្យរបស់សេដ្ឋីហើយទើបពោលថា លោកសេដ្ឋី អ្នកជាបុគ្គលជាប់ក្នុងកាម ពោលគុណរបស់យរាវាសនិងទោសរបស់បព្វជ្ជាក៏ព្រោះការមិនដឹង អាត្មានឹងពោលទោសរបស់យរាវាសដល់អ្នក អ្នកចូរស្តាប់ក្នុងកាលឥឡូវនេះចុះ ហើយពោលគាថាទីពីរថា

ការគ្រប់គ្រងផ្ទះមិនមានដល់បុគ្គលឥតព្យាយាម ការគ្រប់គ្រង
ផ្ទះមិនមានដល់បុគ្គលមិននិយាយពាក្យកុហក ការគ្រប់គ្រង
ផ្ទះមិនមានដល់បុគ្គលមិនកាន់យកនូវអាជ្ញា មិនធ្វើទោសដល់
ជនទាំងឡាយដទៃ បុគ្គលណានឹងគ្រប់គ្រងផ្ទះដែលធ្លុះបំពេញ
បានដោយកម្រយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃរា នានីហមានស្ស** សេចក្តីថា ឈ្មោះថា ធម្មតាយរាវាសអ្នកគ្មានមានះ មិនព្យាយាមធ្វើការដាំដុះនិងចិញ្ចឹមសត្វជាដើម សព្វកាលមិនមាន អធិប្បាយថា ឈ្មោះថា ការនៅគ្រប់គ្រងផ្ទះនឹងតាំងនៅមិនបាន ។ បទថា **ឃរា នាភណតោ មុសា** សេចក្តីថា ឈ្មោះថា ផ្ទះនឹងតាំងនៅមិនបាន សូម្បីមិនព្រមពោលកុហកដើម្បីប្រយោជន៍ដល់ស្រែចម្ការ មាសប្រាក់ជាដើម ។ បទថា **ឃរា នាទិន្នទណ្ឌស្ស បរេសំ អនិ-កុព្វតោ** សេចក្តីថា បុគ្គលមិនកាន់ដំបង ដាក់ដំបងចុះហើយមិនសម្លុតអ្នក

ដទៃផ្ទះក៏តាំងនៅមិនបាន ចំណែកបុគ្គលណាមានដៃកាន់ដំបងដាក់ទោសអ្នកដទៃមានទាសនិងកម្មករជាដើម ដោយការសម្លាប់ ការចង កាត់អវយវៈនិងវាយជាដើម តាមសមគួរដល់កំហុសនោះៗ ការគ្រប់គ្រងផ្ទះរបស់បុគ្គលនោះទើបតាំងនៅបាន ។ បទថា **ឃរំ ធិត្តំ ទុរភិសម្ភវំ កោ ឃរំ បដិបជ្ជតិ** សេចក្តីថា កាលមិនមានការកុហកជាដើម កាលដែលបើកឱកាសដល់សេចក្តីវិនាសនោះៗ ( សេចក្តីវិនាសមកដល់ ) ត្រូវធ្វើជានិច្ចនូវកិច្ចនៃឃរាវាសឲ្យគ្រប់គ្រាន់បានដោយលំបាក ធ្វើឲ្យកើតសេចក្តីត្រេកអរបានដោយកម្រព្រោះត្រូវធ្វើជានិច្ចនោះឯង ។ អាត្មាក៏អស់នូវចំណាង់គិតនឹងគ្រប់គ្រងផ្ទះដែលបំពេញបានដោយកម្រយ៉ាងក្រៃលែងឲ្យបរិបូណ៌បានដោយលំបាកនោះ ដោយហេតុនោះអ្នកណានឹងទៅគ្រប់គ្រងផ្ទះនោះបាន ។

ព្រះមហាសត្វពោលទោសរបស់ឃរាវាសយ៉ាងនេះហើយ បានត្រឡប់ទៅកាន់ព្រះរាជឧទ្យានវិញ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ពារាណសីសេដ្ឋីក្នុងកាលនោះ បានមកជាអ្នកប្រដាល់ឈ្មោះរាជៈក្នុងកាលឥឡូវនេះ ចំណែកវច្ឆនខបរិព្វាជកក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វច្ឆនខជាតក ចប់**

## ពកជាតក

[ ៣២១ ] ( ពួកត្រីពោលថា ) សត្វស្លាបនេះស្រួលបួលពេក ដូចផ្កាកុមុទៈ មានស្លាបទាំងពីរសម្ងំហើយ ឈរសំកុកហាក់ដូចជាមានកម្លាំងខ្សោយ ។

[ ៣២២ ] ( ត្រីពោធិសត្វពោលថា ) អ្នកទាំងឡាយមិនដឹងច្បាស់នូវសីលរបស់កុកនោះទេ អ្នកទាំងឡាយមិនដឹងហើយនាំគ្នាសរសើរ សត្វស្លាបមិនមែនរក្សានូវយើងឡើយ ព្រោះហេតុនោះទើបសត្វស្លាប ( នេះ ) មិនកម្រើកខ្លួន ។

**ចប់ ពកជាតកទី ៦ ។**

## អដ្ឋកថា

## ពកជាតក

[ ៣២១-៣២២ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ភទ្ទកោ វតាយំ បក្ខី** ដូច្នេះជាដើម ។

មានសេចក្ដីសង្ខេបថា ព្រះសាស្ដាទ្រង់ឃើញភិក្ខុកុហកមួយរូបដែលត្រូវនាំខ្លួនមកគាល់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរូបនេះមិនមែនកុហកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន ក៏កុហកដូចគ្នាហើយទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិជាត្រីមាន បរិវារច្រើនអាស្រ័យនៅក្នុងស្រះមួយកន្លែងក្នុងហិមវន្តប្បទេស ។ កាលនោះមានកុកមួយគិតថា អញនឹងស៊ីត្រី ទើបឈរឱនក្បាល សម្ងបស្លាបធ្វើស្លុះៗសម្លឹងមើលត្រីក្នុងទីក្បែរស្រះចាំមើលត្រីដែលភ្លេចខ្លួន ។ ខណៈនោះ ព្រះពោធិសត្វចោមរោមដោយហ្វូងត្រីត្រាច់រកចំណីទៅដល់ទីនោះ ។ ហ្វូងត្រីឃើញកុកនោះទើបពោលគាថាទីមួយថា

សត្វស្លាបនេះស្រួលបួលពេកដូចផ្កាកុមុទៈ មានស្លាបទាំងពីរ
សម្ងបហើយ ឈរសំកុកហាក់ដូចជាមានកម្លាំងខ្សោយដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មន្ទមន្ទោវ ឈាយតិ** បានដល់ កុកឈរសំកុកហាក់ដូចជាអស់កម្លាំង ធ្វើមិនដឹងមិនឮក្នុងរឿងអ្វីទាំងអស់ ។

លំដាប់នោះព្រះពោធិសត្វសម្លឹងមើលកុកនោះពោលគាថាទីពីរថា

អ្នកទាំងឡាយមិនដឹងច្បាស់នូវសីលរបស់កុកនោះទេ អ្នកទាំង
ឡាយមិនដឹងហើយនាំគ្នាសរសើរ សត្វស្លាបមិនមែនរក្សានូវ
យើងឡើយព្រោះហេតុនោះទើបសត្វស្លាប ( នេះ ) មិនកម្រើក
ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនញ្ញាយ** ប្រែថា មិនដឹងច្បាស់ ។ បទថា **អម្ហេ ទិជោ ន បាលេតិ** សេចក្ដីថា បក្សីនេះមិនរក្សា មិនគ្រប់គ្រងពួកយើងឡើយតែជញ្ជឹងគិតថា ក្នុងត្រីទាំងនេះអញនឹងចឹកមួយណាហ្ន៎ ។ បទថា **តេន បក្ខី ន ផន្ទតិ** សេចក្ដីថា ដោយហេតុនោះ ទើបបក្សីនេះមិនកម្រើក

ខ្ជួន ។

កាលព្រះពោធិសត្វពោលយ៉ាងនេះ ហ្លួងត្រីក៏ព្រួសទឹកឲ្យកុករត់ទៅ ។ ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា កុកក្នុងកាលនោះបានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ ឯស្តេចត្រីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ពកជាតក ចប់

## សាកេតជាតក

[ ៣២៣ ] ( ពួកភិក្ខុពោលថា ) បពិត្រព្រះមានព្រះភាគ ហេតុអ្វីហ្ន៎ បច្ច័យត្រជាក់យ៉ាងក្រៃលែងទាំងចិត្តក៏ជ្រះថ្លាក្នុងបុគ្គលពួកខ្លះក្នុងលោកនេះ ។

[ ៣២៤ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) សេចក្តីស្រឡាញ់នោះរមែងកើតដោយហេតុពីរយ៉ាងគឺ ដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹកដោយហេតុ ២ យ៉ាង គឺ ទឹក ១ ភក់ ១ ។

**ចប់ សាកេតជាតកទី ៧ ។**

## អដ្ឋកថា

## សាកេតជាតក

[ ៣២៣-៣២៤ ] ព្រះសាស្តាកាលគង់នៅក្នុងក្រុងសាកេត ទ្រង់ប្រារព្ធសាកេតព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោ នុ ខោ ភគវា ហេតុ** ដូច្នេះជាដើម ។

ចំណែករឿងក្នុងជាតកនេះអតីតក្តី បច្ចុប្បន្នក្តីពោលទុកក្នុងឯកនិបាតខាងដើមនោះឯង ។

កាលដែលព្រះតថាគតយាងចូលកាន់វិហារ ភិក្ខុទាំងឡាយទូលសួរថា បពិត្រដ៏ចម្រើនឈ្មោះថា ការស្រឡាញ់នេះតាំងនៅបានដូចម្តេចហើយពោលគាថាទីមួយថា

បពិត្រព្រះមានព្រះភាគ ហេតុអ្វីហ្ន៎ ហឫទ័យត្រជាក់យ៉ាងក្រៃ
លែងទាំងចិត្តក៏ជ្រះថ្លាក្នុងបុគ្គលពួកខ្លះក្នុងលោកនេះ ដូច្នេះ ។

អត្ថនៃគាថានោះថា អ្វីហ្ន៎ជាហេតុឲ្យបុគ្គលពួកខ្លះក្នុងលោកនេះ គ្រាន់តែឃើញគ្នាប៉ុណ្ណោះចិត្តក៏ស្ងប់ គឺត្រជាក់ដូចយកទឹកក្រអូប ១០០០ ក្អម មកស្រោច បុគ្គលខ្លះមិនស្ងប់ បុគ្គលខ្លះគ្រាន់តែឃើញប៉ុណ្ណោះក៏មានចិត្តជ្រះថ្លាទន់ភ្លន់ជាប់ជំពាក់ចំពោះគ្នាដោយអំណាចសេចក្តីស្រឡាញ់ ពួកខ្លះក៏មិនជាប់ជំពាក់ចំពោះគ្នា ។

លំដាប់នោះ ព្រះសាស្តាកាលទ្រង់សម្តែងហេតុនៃសេចក្តីស្រឡាញ់ដល់ភិក្ខុទាំងនោះទើបត្រាស់គាថាទីពីរថា

សេចក្តីស្រឡាញ់នោះរមែងកើតដោយហេតុពីរយ៉ាងគឺ ដោយ
ធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុង
បច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹកដោយហេតុ ២
យ៉ាងគឺ ទឹក ១ ភក់ ១ ដូច្នេះ ។

អត្ថនៃគាថានោះថា ម្នាលភិក្ខុទាំងឡាយ ធម្មតាសេចក្តីស្រឡាញ់នេះរមែងកើតដោយហេតុ ២ ប្រការ គឺធ្លាប់ជាមាតាបិតា បុត្តធីតា បងប្អូនប្រុស បងប្អូនស្រី ស្វាមីភរិយាឬមិត្តសម្លាញ់នឹងគ្នាក្នុងភពមុនធ្លាប់នៅរួមគ្នាមក ការស្រឡាញ់នោះរមែងមិនលះបង់គន់ជាប់តាមសូម្បីក្នុងភពដទៃព្រោះការនៅរួមគ្នាក្នុងកាលមុន ១ ម្យ៉ាងទៀតសេចក្តីស្រឡាញ់នោះ កើតព្រោះការឧបការៈ គឺធ្វើប្រយោជន៍ដល់គ្នានឹងគ្នាក្នុងបច្ចុប្បន្នដែលបានធ្វើក្នុងអត្តភាពនេះ ១ ។

សេចក្តីស្រឡាញ់នោះរមែងកើតឡើងដោយហេតុ ២ ប្រការដូច្នេះប្រៀបដូចឧប្បលដែលដុះក្នុងទឹកដូច្នោះ គឺដូចឧប្បលនិងបុប្ផជាតិផ្សេងៗ ដែលកើតក្នុងទឹក ដុះក្នុងទឹកក៏បានដោយហេតុ ២ យ៉ាង គឺទឹកនិងភក់យ៉ាងណា សេចក្តីស្រឡាញ់នោះក៏កើតដោយហេតុ ២ ប្រការយ៉ាងនោះ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍និងព្រាហ្មណីក្នុងកាលនោះ បានមកជាជនទាំង ២ នាក់ក្នុងកាលឥឡូវនេះ ចំណែកកូនក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សាកេតជាតក ចប់

## ឯកបទជាតក

[ ៣២៥ ] ( កុមារជាកូននៃព្រះពោធិសត្វពោលថា ) បពិត្របិតា យើងញុំាងប្រយោជន៍ឲ្យសម្រេចដោយបទណា សូមអញ្ជើញលោកប្រាប់នូវបទនោះតែមួយ ដែលអាស្រ័យនូវបទជាប្រយោជន៍ច្រើន ដែលសង្គ្រោះ ( រួមចូល ) តែមួយ ។

[ ៣២៦ ] ( បិតាប្រាប់ថា ) នៃកូន សេចក្ដីឧស្សាហ៍ ( ប្រកបដោយញាណ ) ជាបទតែមួយដែលអាស្រ័យនូវបទជាប្រយោជន៍ច្រើន តែសេចក្ដីឧស្សាហ៍នោះប្រកបដោយសីល ប្រកបដោយខន្តិធម៌ អាចញុំាងពួកមិត្តឲ្យសុខឬដើម្បីសេចក្ដីទុក្ខដល់ពួកបុគ្គលមិនមែនជាមិត្ត ។

**ចប់ ឯកបទជាតកទី ៨ ។**

## អដ្ឋកថា

## ឯកបទជាតក

[ ៣២៥-៣២៦ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឥង្ឃ ឯកបទំ តាត** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈម្នាក់ក្នុងក្រុងសាវត្ថី ថ្ងៃមួយកូនរបស់គាត់អង្គុយលើភ្លៅសួរបញ្ហាឈ្មោះថា អត្ថទ្វារ គឺទ្វារនៃប្រយោជន៍ ។ បុរសនោះគិតថា បញ្ហានេះជាពុទ្ធវិស័យ អ្នកដទៃមិនអាចឆ្លើយប្រស្នានេះបាន ទើបនាំកូនទៅកាន់

វត្តជេតពនថ្វាយបង្គំព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទារកនេះអង្គុយលើភ្លៅនៃខ្ញុំព្រះអង្គបានសួរបញ្ហាឈ្មោះអត្ថទ្វារ ខ្ញុំព្រះអង្គមិនជ្រាបបញ្ហានោះទើបមកក្នុងទីនេះ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ត្រាស់បញ្ហានេះនឹងខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក ទារកនេះស្វែងរកប្រយោជន៍ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន កាលមុនក៏ជាអ្នកស្វែងរកប្រយោជន៍បានសួរបញ្ហានេះនឹងបណ្ឌិត ។ បុរាណកបណ្ឌិតក៏ប្រាប់ដល់ទារកនោះហើយតែទារកចាំមិនបានព្រោះអន្តរនៃភព ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី ។ កាលនោះ កុមារតូចជាកូនរបស់ព្រះពោធិសត្វអង្គុយលើភ្លៅសួរថា បពិត្រលោកឪពុក សូមលោកឪពុកប្រាប់បទមួយ គឺហេតុមួយដែលជាផ្លូវឲ្យដល់នូវប្រយោជន៍មិនមែនតិចដល់ខ្ញុំហើយពោលគាថាទីមួយថា

> បពិត្របិតា យើងញុំាងប្រយោជន៍ឲ្យសម្រេច ដោយបទណា
> សូមអញ្ជើញលោកប្រាប់នូវបទនោះតែមួយ ដែលអាស្រ័យ
> នូវបទជាប្រយោជន៍ច្រើនដែលសង្គ្រោះ ( រួមចូល ) តែមួយ
> ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥង្ឃ** ជានិបាតចុះក្នុងអត្ថថា អង្វរឬក្រើនរំឭក ។ បទថា **ឯកបទំ** សេចក្តីថា បទគឺហេតុមួយ ឬបទគឺព្យញ្ជនៈ

ដែលលោកសង្គ្រោះចូលជាមួយហេតុមួយ ។ បទថា **អនេកត្ថបទស្សិតំ** សេចក្ដីថា ដែលប្រយោជន៍ច្រើនយ៉ាងអាស្រ័យបទ គឺហេតុ ។ បទថា **កិញ្ចិ សង្គហិតំ ព្រូហិ** សេចក្ដីថា ចូរប្រាប់បទមួយដែលរួមបទ ( ប្រយោជន៍ ) ទុកជាច្រើន ។ ព្រះបាលីក៏យ៉ាងនោះឯង ។ បទថា **យេនត្ថេ សាធយេមសេ** សេចក្ដីថា ខ្ញុំគប្បីញុំាងសេចក្ដីចម្រើនឲ្យសម្រេចដល់ខ្លួនដោយបទណាមួយនូវប្រយោជន៍ច្រើនដែលអាស្រ័យ ( បទនោះ ) សូមប្រាប់បទនោះដល់ខ្ញុំ ។

លំដាប់នោះបិតាកាលនឹងប្រាប់ដល់កុមារតូចនោះបានពោលគាថាទីពីរថា

នែកូន សេចក្ដីឧស្សាហ៍ ( ប្រកបដោយញាណ ) ជាបទតែមួយ ដែលអាស្រ័យនូវបទជាប្រយោជន៍ច្រើន តែសេចក្ដីឧស្សាហ៍នោះប្រកបដោយសីល ប្រកបដោយខន្តិធម៌អាចញុំាងពួកមិត្តឲ្យសុខ ឬដើម្បីសេចក្ដីទុក្ខ ដល់ពួកបុគ្គលមិនមែនជាមិត្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកបទំ តាត** សេចក្ដីថា បទមួយបទ គឺសេចក្ដីព្យាយាម ។ សេចក្ដីព្យាយាមដែលប្រកបដោយញាណនៃបុគ្គលអ្នកឈ្លាស ដែលញុំាងលាភឲ្យកើតឡើងឈ្មោះថា សេចក្ដីព្យាយាម ។ បទថា **អនេកត្ថបទស្សិតំ** សេចក្ដីថា សេចក្ដីព្យាយាមមានប្រការដូចពោលហើយយ៉ាងនេះ ដែលប្រយោជន៍ច្រើនយ៉ាងអាស្រ័យ ។ សួរថា ប្រកបដោយបទអ្វី ឆ្លើយថា ប្រកបដោយបទមានសីលជាដើម ព្រោះហេតុ

នោះឯងទើបលោកពោលថា **តញ្ច សីលេន សំយុត្តំ** ជាដើម ។ អធិប្បាយសេចក្តីនោះថា សេចក្តីព្យាយាមនោះប្រកបដោយអាចារនិងសីលដល់ព្រមដោយអធិវាសនខន្តី អាច គឺមានសមត្ថភាពដើម្បីញ៉ាំងមិត្តទាំងឡាយឲ្យនៅជាសុខបាន ឲ្យកើតសេចក្តីទុក្ខដល់សត្រូវទាំងឡាយបាន បុគ្គលប្រកបដោយកុសលនិងវិរិយៈដែលប្រកបដោយញាណ ដែលញ៉ាំងលាភឲ្យកើតដល់ព្រមដោយអាចារនិងខន្តិធម៌ រឿងអ្វីមិនអាចញ៉ាំងមិត្តឲ្យនៅជាសុខ ឬញ៉ាំងសត្រូវឲ្យនៅជាទុក្ខបាននោះ ។

ព្រះពោធិសត្វពោលឆ្លើយបញ្ហាដល់បុត្តដូច្នេះ ។ បុត្តនោះបានញ៉ាំងនូវប្រយោជន៍របស់ខ្លួនឲ្យសម្រេចតាមន័យដែលបិតាប្រាប់ តម្កល់ជីវិតទៅតាមយថាកម្មហើយ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌បិតានិងបុត្តតាំងនៅក្នុងសោតាបត្តិផល ទ្រង់ប្រជុំជាតកថា កូនក្នុងកាលនោះ បានមកជាកូនក្នុងកាលឥឡូវនេះឯង ឯសេដ្ឋីក្រុងពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឯកបទជាតក ចប់

## ហរិតមាតជាតក

[ ៣២៧ ] ( សត្វពស់សួរថា ) ម្នាលអ្នកជាកូននៃហរិតមណ្ឌុកមាតាត្រីទាំងឡាយ ស៊ីនូវយើងដែលជាសត្វមានពិស ដែលចូលទៅកាន់មាត់លប ដោយហេតុណា ហេតុនេះពេញចិត្ត ( ដល់អ្នកដែរឬ ) ។

[ ៣២៨ ] ( នីលមណ្ឌុកពោធិសត្វពោលថា ) ( ឥស្សរភាព ) របស់បុរសនោះបានប្រព្រឹត្តទៅដរាបណា បុរស ( នោះ ) រមែងរឹបជាន់ ( ជនដទៃដរាបនោះ ) លុះពួកជនដទៃ ( បានឥស្សរភាព ) រមែងរឹបជាន់វិញក្នុងកាលណា បុរសអ្នករឹបជាន់នោះត្រូវពួកជនដទៃរឹបជាន់វិញក្នុងកាលនោះ ។

**ចប់ ហរិតមាតជាតកទី ៩ ។**

## អដ្ឋកថា

## ហរិតមាតជាតក

[ ៣២៧-៣២៨ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះបាទអជាតសត្តុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អាសីវិសម្បិ មំ សន្តំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ព្រះបាទមហាកោសលជាព្រះបិតារបស់ព្រះបាទកោសល ព្រះរាជទានធីតាដល់ព្រះបាទពិម្ពិសារ បានប្រទានស្រុកកាសីជាតម្លៃសម្រាប់ងូតដល់ព្រះធីតា ។ ព្រះទេវីនោះកាលព្រះបាទអជាតសត្តុធ្វើបិតុឃាតកម្ម ក៏បានអស់ព្រះជន្មព្រោះសេចក្ដីស្នេហាចំពោះព្រះរាជាក្នុងកាល

មិនយូរឡើយ ។ ព្រះបាទអជាតសត្តុកាលព្រះជននីអស់ព្រះជន្មហើយនៅគ្រប់គ្រងស្រុកនោះដដែល ព្រះបាទបសេនទិកោសលត្រិះរិះថា អញនឹងមិនឲ្យស្រុកដែលជារបស់ត្រកូលដល់ចោរសម្លាប់បិតា ទើបច្បាំងជាមួយព្រះបាទអជាតសត្តុ ជួនកាលព្រះមាតុលាឈ្នះ ជួនកាលម្ចាស់ក្មួយឈ្នះ តែកាលណាព្រះបាទអជាតសត្តុឈ្នះ កាលនោះទ្រង់ក៏សោមនស្សលើកទង់ជ័យលើរថចូលព្រះនគរដោយយសធំ ។ កាលណាទ្រង់បរាជ័យ កាលនោះទ្រង់ក៏ទោមនស្សមិនឲ្យបុគ្គលណាមួយដឹងឡើយ យាងចូលព្រះនគរ ។ ថ្ងៃមួយភិក្ខុទាំងឡាយសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះបាទអជាតសត្តុទ្រង់ឈ្នះព្រះមាតុលាហើយក៏ទ្រង់ត្រេកអរ ទ្រង់បរាជ័យក៏ទោមនស្ស ។

ព្រះសាស្តាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនព្រះបាទអជាតសត្តុនោះទ្រង់ឈ្នះហើយក៏សប្បាយព្រះហឫទ័យ ទ្រង់បរាជ័យក៏ទោមនស្សដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតកង្កែបខៀវ ។ គ្រានោះមនុស្សទាំងឡាយបានដាក់លបដើម្បីចាប់ត្រី ក្នុងស្ទឹងនិងជ្រោះជាដើម ។ ត្រីជាច្រើនចូលទៅជាប់លបមួយ ។ កាលនោះមានពស់ទឹកមួយចង់ស៊ីត្រី ទើបចូលកាន់លបនោះ

ត្រីជាច្រើនមកចោមរោមចឹកពស់នោះរហូតហូរឈាម ។ ពស់ទឹកមិនឃើញទីពឹង ខ្លាចស្លាប់ទើបគេចទៅតាមច្រើសលបបានដល់នូវសេចក្ដីឈឺចាប់ដេកនៅលើផ្ទៃទឹក ។ ក្នុងខណៈនោះកន្ធែបខៀវលោតទៅទំលើខ្នងលប ពស់កាលមិនបាននូវទីពឹងឃើញកន្ធែបខៀវដេកលើខ្នងលបនោះ កាលនឹងសួរថា នែកន្ធែបសម្លាញ់ កិរិយារបស់ពួកត្រីទាំងនេះពេញចិត្តដល់អ្នកដែរឬទេ ទើបពោលគាថាទីមួយថា

ម្នាលអ្នកជាកូននៃហរិតមណ្ឌុកមាតា ត្រីទាំងឡាយស៊ីនូវយើង

ដែលជាសត្វមានពិស ដែលចូលទៅកាន់មាត់លបដោយហេតុ

ណាហេតុនេះពេញចិត្ត ( ដល់អ្នកដែរឬ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាសីវិសម្បិ មំ សន្តំ** បានដល់ នូវខ្ញុំដែលជាសត្វមានពិស ។ បទថា **រុច្ចតេ ហរិតាមាតា យំ មំ ខាទន្តិ មច្ឆកា** សេចក្ដីថា ពស់ពោលថា អ្នកជាបុត្តកន្ធែបខៀវ អ្នកគាប់ចិត្តក្នុងហេតុនោះឬ ។

លំដាប់នោះទើបកន្ធែបខៀវពោលនឹងពស់ថា នែសម្លាញ់ ត្រឹមត្រូវហើយខ្ញុំគាប់ចិត្តសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះប្រសិនបើហ្វូងត្រីមកដល់កន្លែងរបស់អ្នក អ្នកក៏រមែងស៊ីត្រីនោះ ឯហ្វូងត្រីក៏រមែងស៊ីអ្នកដែលទៅកាន់កន្លែងរបស់ខ្លួន ការខ្សោយកម្លាំងក្នុងកន្លែងរកស៊ីក្នុងទីដែលជាដែនរបស់ខ្លួនរមែងមិនមានបានពោលគាថាទីពីរថា

( ឥស្សរភាព ) របស់បុរសនោះបានប្រព្រឹត្តទៅដរាបណា

បុរស ( នោះ ) រមែងរិបជាន់ ( ជនដទៃដរាបនោះ ) លុះពួក
ជនដទៃ ( បានឥស្សរភាព ) រមែងរិបជាន់វិញក្នុងកាលណា
បុរសអ្នករិបជាន់នោះត្រូវពួកជនដទៃរិបជាន់វិញក្នុងកាលនោះ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិលុម្បតេវ បុរិសោ យាវស្ស ឧបកប្បតិ** សេចក្ដីថា ភាពជាធំរមែងសម្រេច រមែងប្រព្រឹត្តទៅដល់បុរសដរាបណា បុគ្គលរមែងញាំញីអ្នកដទៃបានដរាបនោះ ។ បាលីថា **យាវ សោ ឧបកប្បតិ** ក៏មាន អធិប្បាយថា បុរសនោះអាចញាំញីបានសព្វកាល ។ បទថា **យទា ចញ្ញេ វិលុម្បន្តិ** គឺ អ្នកដទៃដែលជាធំ រមែងញាំញីកាលណា ។ បទថា **សោ វិលុត្តោ វិលុម្បតិ** សេចក្ដីថា គ្រានោះអ្នកញាំញីនោះរមែងត្រូវអ្នកដទៃញាំញី ។ បាលីថា **វិលុម្បតេ** ដូច្នេះក៏មាន សេចក្ដីនេះក៏មានអត្ថដូចគ្នា ។ អាចារ្យពួកខ្លះសូធ្យថា **វិលុម្បន្តិ** ដូច្នេះក៏មាន តែសេចក្ដីមិនដូចគ្នា គឺបុគ្គលញាំញីយ៉ាងនេះរមែងត្រឡប់បាននូវការញាំញីវិញ ។

ព្រះពោធិសត្វកាលវិនិច្ឆ័យក្ដីហើយ ហ្វូងត្រីដឹងថា ពស់ខ្សាយកម្លាំងទើបគិតថានឹងចាប់សត្រូវ ទើបរុលចេញតាមប្រើសលបធ្វើឲ្យពស់ស្លាប់ក្នុងទីនោះឯងហើយក៏ចៀសចេញទៅ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ពស់ទឹកក្នុងកាលនោះបានមកជាព្រះបាទអជាតសត្តុក្នុងកាលឥឡូវនេះ ចំណែកកង្កែបខៀវក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ហរិតមាតជាតក ចប់**

# មហាបិង្គលជាតក

[ ៣២៩ ] ( ព្រះពោធិសត្វពោលថា ) ជនទាំងអស់ត្រូវស្តេចបិង្គលបៀតបៀនហើយ កាលស្តេចនោះសោយទិវង្គតហើយ ជនទាំងឡាយរមែងបាននូវសេចក្តីត្រេកអរ ម្នាលទ្វារបាល ស្តេចអកណ្ហនេត្រ ជាទីស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វីបានជាអ្នកយំ ។

[ ៣៣០ ] ( ទ្វារបាលបុរសពោលថា ) ស្តេចអកណ្ហនេត្រមិនមែនជាទីស្រឡាញ់របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ ( ព្រោះស្តេចនោះ ) ទៅអំពីមនុស្សលោកនេះគប្បីបៀតបៀននូវមច្ចុរាជ មច្ចុរាជនោះក្រែងត្រូវស្តេចបិង្គលៈបៀតបៀនហើយ គប្បីនាំមកទុកក្នុងមនុស្សលោកនេះវិញ ។

[ ៣៣១ ] ( ព្រះពោធិសត្វពោលថា ) ព្រះបាទបិង្គលៈនោះគេដុតដោយឧស ១ ពាន់ដឹក គេស្រោចដោយទឹក ១ រយក្អម ឯទីសម្រាប់ដុតគេបិទបាំងជុំវិញហើយ អ្នកកុំភ័យឡើយស្តេចបិង្គលៈនោះនឹងមិនមកវិញបានទេ ។

**ចប់ មហាបិង្គលជាតកទី ១០ ។**

**ចប់ ឧបាហនវគ្គទី ៩ ។**

## ឧទ្ទាននៃឧបាហនវគ្គនោះគឺ

និយាយអំពីស្បែកជើងប្រសើរ ១ បុរសគម ១ ក្រពើត្រូវចាប់ត្រីមុត ១ ព្រះរាជធីតាឈ្មោះអសិតាភូ ១ វច្ឆនខតាបស ១ សត្វកុក ១ សេចក្ដីស្រឡាញ់ដ៏ប្រសើរឧត្តម ១ បទតែមួយ ១ មាត់ លប ១ ស្ដេចឈ្មោះបិង្គលៈ ១ ត្រូវជា ១០ ។

# អដ្ឋកថា

# មហាបិង្គលជាតក

[ ៣២៩-៣៣១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វោ ជនោ** ដូច្នេះជាដើម ។

កាលទេវទត្តចងអាឃាតជាមួយព្រះសាស្តា លិចចូលក្នុងផែនដីជិតខ្លោងទ្វារវត្តជេតពនបាន ៩ ខែ អ្នកក្រុងសាវត្ថីនិងអ្នកដែនទាំងមូលត្រេកអរថា ទេវទត្តជាបច្ចាមិត្តរបស់ព្រះពុទ្ធអង្គត្រូវផែនដីស្រូបហើយ ឥឡូវនេះព្រះសម្មាសម្ពុទ្ធទ្រង់កម្ចាត់សត្រូវបានហើយ ។ អ្នកជម្ពូទ្វីបទាំងមូល ពួកយក្ខ ភូតនិងទេវតាទាំងឡាយក៏នាំគ្នាសប្បាយត្រេកអរពោលយ៉ាងនោះដូចគ្នា ។

ថ្ងៃមួយភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ កាលទេវទត្តលិចចូលក្នុងផែនដី មហាជនត្រេកអរថា ទេវទត្តជាចម្រូងចម្រាស់របស់ព្រះពុទ្ធអង្គត្រូវផែនដីលេបហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលទេវទត្តស្លាប់មហាជនសប្បាយត្រេកអរមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីតែក្នុងកាលមុនក៏មហាជនត្រេកអរដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលមានព្រះរាជាព្រះនាមថា មហាបិង្គល សោយរាជសម្បត្តិ

នៅក្នុងនគរពារាណសីដោយអធម៌ដែលជាធម៌មិនរាបស្មើ ធ្វើបាបកម្មដោយអគតិ មានឆន្ទាគតិជាដើម បៀតបៀនមហាជនដោយអាជ្ញា ដោយពន្ធអាករ រឹបអូសយកប្រាក់មាសជាដើមដូចកំណាត់អំពៅដែលគ្រឿងយន្តគាបដូច្នោះ ។ ព្រះបាទមហាបិង្គលនោះជាស្តេចរឹងរូស គ្រោតគ្រាត ឃោរឃៅ ។ មិនមានសូម្បីត្រឹមតែការអាណិតក្នុងអ្នកដទៃឡើយ ។ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តនៃពួកស្ត្រី បុត្តធីតាក្នុងព្រះរាជវាំង អាមាត្យ ព្រាហ្មណ៍និងគហបតីជាដើមប្រៀបដូចធូលីក្នុងភ្នែក ដូចដុំក្រួសក្នុងដុំបាយនិងដូចបន្លាមុតកែងជើងដូច្នោះ កាលនោះព្រះពោធិសត្វបដិសន្ធិជាឱរសរបស់ព្រះបាទមហាបិង្គល ។ ព្រះបាទមហាបិង្គលសោយរាជសម្បត្តិមកយូរហើយក៏សោយទិវង្គត ។ កាលព្រះបាទមហាបិង្គលសោយទិវង្គតហើយ អ្នកនគរពារាណសីទាំងមូលត្រេកអរញញឹមញញែមដាក់គ្នាបូជាសពព្រះបាទមហាបិង្គលដោយឧស ១០០០ រទេះរំលត់ជើងថ្ករដោយទឹកច្រើនពាន់ក្អម ហើយអភិសេកព្រះពោធិសត្វឲ្យសោយរាជ្យត្រេកអរថា យើងបានព្រះរាជាដែលតាំងនៅក្នុងធម៌ហើយ ត្រាច់វាយស្គរគគ្រឹកគគ្រេង តាក់តែងព្រះនគរដោយទង់ផ្សេងៗ ធ្វើបារាំតាមទ្វារស្រុកគ្រប់ទ្វារ អង្គុយស៊ីលៀងត្រង់បារាំដែលបានតាក់តែងហើយ មានផ្ទៃដីរាយរាយដោយលាជនិងផ្កា ព្រះពោធិសត្វក៏ប្រថាប់គង់ទ្រង់យសជំកែលែងត្រង់បល្ល័ង្កដែលបាំងដោយស្វេតច្ឆត្រ ត្រង់ផ្ទៃប្រាសាទដែលប្រដាប់តាក់តែងហើយ ។ ពួកអាមាត្យ ព្រាហ្មណ៍ គហបតី អ្នករក្សានគរនិងអ្នកយាមទ្វារជាដើមក៏ឈរចោមរោមព្រះរាជា លំដាប់នោះមានអ្នកយាមទ្វារម្នាក់ឈរក្នុងទីមិនឆ្ងាយ

បានស្រែកទ្រហោយំ ព្រះពោធិសត្វទតឃើញអ្នកយាមទ្វារនោះ ទើបសួរថា នែអ្នកយាមទ្វារ កាលព្រះបិតារបស់យើងសោយទិវង្គតហើយ មហាជនទាំងពួងក៏សប្បាយត្រេកអរលេងនូវមហោស្រព ចំណែកអ្នកបែរជាឈរយំបិតារបស់យើងជាទីគាប់ចិត្តរបស់អ្នកឬ ទើបពោលគាថាទីមួយថា

ជនទាំងអស់ត្រូវស្តេចបិង្គលបៀតបៀនហើយ កាលស្តេចនោះ
សោយទិវង្គតហើយ ជនទាំងឡាយរមែងបាននូវសេចក្តីត្រេកអរ
ម្នាលទ្វារបាល ស្តេចអកណ្ហនេត្រ ជាទីស្រឡាញ់របស់អ្នកឬ
ព្រោះហេតុអ្វីបានជាអ្នកយំ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ហឹសិតោ** បានដល់ ត្រូវព្រះបាទបិង្គលៈបៀតបៀនដោយអាជ្ញានិងពន្ធអាករច្រើនប្រការ ។ បទថា **បិង្គលេន** បានដល់ មានភ្នែកលឿង បានឮថា ព្រះបាទបិង្គលៈនោះមានព្រះនេត្រទាំង ២ លឿងគួរខ្លាចមានពណ៌ដូចភ្នែកឆ្មាទើបមានឈ្មោះថា បិង្គលៈ ។ បទថា **បច្ចយំ វេទយន្តិ** គឺ នាំគ្នាត្រេកអរ ។ បទថា **អកណ្ហនេត្តោ** គឺ មានភ្នែកលឿង ។ បទថា **កស្មា នុ តុំ** គឺ អ្នកយំធ្វើអ្វី ។ ក្នុងអដ្ឋកថាមានបាលីថា **កស្មា តុវំ** ដូច្នេះ ។

នាយទ្វារបាលនោះស្តាប់ពាក្យរបស់ព្រះពោធិសត្វ ទើបក្រាបទូលថា ទូលព្រះបង្គំមិនមែនយំព្រោះព្រះបាទមហាបិង្គលសោយទិវង្គតទេ តែយំព្រោះខ្លាចក្បាលរបស់ទូលព្រះបង្គំបានសុខហើយ ព្រោះព្រះបាទបិង្គលៈ កាលយាងឡើងប្រាសាទទ្រង់ខោកក្បាលទូលព្រះបង្គំម្តង ៨ ក្រញរដូចដំដោយញញួរ

ជានមាសដូច្នោះ ទ្រង់យានទៅកាន់បរលោកហើយនឹងខោកក្បាលពួកនិរយបាលខ្វះ ស្តេចយមរាជខ្វះ ដូចខោកក្បាលទូលព្រះបង្គំ ពេលនោះនិរយបាលគិតថា ព្រះបាទបិង្គលៈនេះបៀតបៀនពួកយើងពន់ពេកទើបនាំមកដោះលែងក្នុងទីនេះទៀត កាលបើដូច្នោះទ្រង់ក៏គប្បីខោកក្បាលទូលព្រះបង្គំទៀត កាលប្រកាសសេចក្តីនេះទើបពោលគាថាទីពីរថា

ស្តេចអកណ្ហនេត្រ មិនមែនជាទីស្រឡាញ់របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ ( ព្រោះស្តេចនោះ ) ទៅអំពីមនុស្សលោកនេះគប្បីបៀតបៀនទូវមច្ចុរាជ មច្ចុរាជនោះក្រែងត្រូវស្តេចបិង្គលៈបៀតបៀនហើយគប្បីនាំមកទុកក្នុងមនុស្សលោកនេះវិញ ដូច្នេះ ។

លំដាប់នោះព្រះពោធិសត្វ កាលនឹងត្រាស់លួងលោមនាយទ្វារបាលនោះទើបត្រាស់ថា ព្រះរាជាអង្គនោះត្រូវដុតដោយឧស ១០០០ រទេះ លត់ដោយទឹករាប់រយក្អមសូម្បីឈាបនដ្ឋានរបស់ព្រះរាជាក៏ព័ទ្ធរបងជុំវិញហើយ តាមប្រក្រតីបុគ្គលទៅកាន់បរលោកហើយក៏ទៅទីដទៃនោះឯង ទ្រង់មិនត្រឡប់មកដោយរាងកាយនោះទៀតទេ អ្នកកុំខ្លាចឡើយទើបពោលគាថានេះថា

ព្រះបាទបិង្គលៈនោះគេដុតដោយឧស ១ ពាន់ដឹក គេស្រោចដោយទឹក ១ រយក្អម ឯទីសម្រាប់ដុតគេបិទបាំងជុំវិញហើយ អ្នកកុំភ័យឡើយ ស្តេចបិង្គលៈនោះនឹងមិនមកវិញបានទេ ដូច្នេះ ។

បន្ទាប់អំពីនោះនាយទ្វារបាលក៏ទទួលនូវការជូរស្បើយចិត្ត ។ ព្រះពោធិសត្វសោយរាជសម្បត្តិប្រកបដោយធម៌ ទ្រង់បំពេញបុណ្យ មានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទមហាបិង្គលៈក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកព្រះឱរសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មហាបិង្គលជាតក ចប់**

**ឧបាហនវគ្គ ចប់**

# សិគាលវគ្គ

## សព្វទាឋិជាតក

[ ៣៣២ ] ( ព្រះសាស្ដា ទ្រង់ត្រាស់ថា ) ចចករីងត្អឹងដោយមានះ ត្រូវការដោយបរិវារ ( ច្រើន ) ក៏ដល់ភូមិសម្បត្តិដ៏ធំបានជាស្ដេចនៃពួកសត្វ មានចង្កូមទាំងពួង ។

[ ៣៣៣ ] បណ្ដាមនុស្សទាំងឡាយមនុស្សណាជាអ្នកមានបរិវារ មនុស្សនោះឈ្មោះថាជាធំក្នុងពួកបរិវារនោះ ដូចជាចចក ( បានជាធំ ) ជាងសត្វមានចង្កូមទាំងឡាយដូច្នោះឯង ។

**ចប់ សព្វទាឋិជាតកទី ១ ។**

# សិង្គាលវគ្គ

## អដ្ឋកថា សព្វទាឋិជាតក

[ ៣៣២-៣៣៣ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សិគាលោ មានត្ថទ្ធោ** ច ដូច្នេះជាដើម ។

ទេវទត្តញុំាងព្រះបាទអជាតសត្តុឲ្យជ្រះថ្លាហើយ ក៏មិនអាចធ្វើលាភសក្ការៈដែលកើតឡើងហើយឲ្យតាំងនៅបានយូរ ។ លាភសក្ការៈរបស់ភិក្ខុទេវទត្តបានអស់ទៅ តាំងអំពីកាលដែលបានឃើញបាដិហារ្យក្នុងការលែងដំរីនាឡាគិរីហើយ ។ ថ្ងៃមួយភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា

អាវុសោទាំងឡាយ ទេវទត្តញុំាងលាភសក្ការៈឲ្យកើតឡើងហើយក៏មិនអាចឲ្យតាំងនៅបានយូរ ។ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនធ្វើលាភសក្ការៈដែលកើតដល់ខ្លួនឲ្យអស់ទៅក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏បានធ្វើលាភសក្ការៈឲ្យអស់ទៅហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីត មកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាបុរោហិតនៃព្រះរាជាអង្គនោះ ជាអ្នកចប់ត្រៃវេទនិងសិល្បសាស្ត្រ ១៨ ប្រការ ចេះនូវបឋវីវិជយមន្ត ។ ដែលហៅថា បឋវីវិជយមន្តនោះគឺ មន្តត្រឡប់ចិត្តឲ្យវង្វេង ។ ថ្ងៃមួយព្រះពោធិសត្វគិតថានឹងស្វាធ្យាយមន្តនោះទើបអង្គុយធ្វើការស្វាធ្យាយលើថ្មដាត្រង់ទួលមួយកន្លែង ។ បានឮថា មន្តនោះបុគ្គលមានចិត្តប្របូកប្របល់ ការទ្រទ្រង់ចាំមិនល្អមិនអាចឲ្យសម្រេចបាន ។ ព្រោះដូច្នោះទើបបុរោហិតអង្គុយស្វាធ្យាយក្នុងទីនោះ ។ ក្នុងកាលដែលបុរោហិតធ្វើនូវការស្វាធ្យាយមានចចកមួយដេកក្នុងព្រៃឈើមួយកន្លែងបានឮមន្តនោះដូចគ្នា បានទន្ទេញចាំរហូតស្ទាត់ជំនាញ បានឮថា ចចកនោះក្នុងអត្តភាពមុននោះកើតជាព្រាហ្មណ៍ម្នាក់ដែលស្ទាត់ជំនាញក្នុងបឋវីវិជយមន្ត ។ ព្រះពោធិសត្វធ្វើការស្វាធ្យាយហើយក្រោកទៅពោលថា មន្តរបស់អញនេះស្ទាត់ជំនាញហ្ន៎ ចចកចេញមកអំពីព្រៃឈើពោលថា នៃព្រាហ្មណ៍ដ៏ចម្រើន

មន្តនេះស្ទាត់ជំនាញដល់អញជាងអ្នកទៅទៀតហើយរត់គេចទៅ ។ ព្រះពោធិ-សត្វគិតថា ចចកនេះនឹងធ្វើអកុសលកម្មធំកន្លងទើបស្រែកឡើងថា ចាប់ៗ ហើយដេញតាមទៅបានបន្តិចចចកក៏គេចចូលព្រៃទៅ ។

ចចកទៅខាំចចកញីមួយ កាលចចកញីសួរថា មានរឿងអ្វី ក៏ពោលថា នាងស្គាល់យើង ឬមិនស្គាល់ ចចកញីឆ្លើយថា ខ្ញុំស្គាល់ ។ ចចកនោះរាយបឋវីវិជយមន្តបង្ក្រាបចចករាប់រយឲ្យនៅក្នុងអំណាច ធ្វើសត្វជើង ៤ មានដំរី សេះ សីហៈ ខ្លា ទន្សាយ ជ្រូកនិងម្រឹគជាដើមទុកក្នុងសម្នាក់របស់ខ្លួនទាំងអស់ ហើយបានជាស្តេចសត្វឈ្មោះថា សព្វទាឋៈ ។ ចចកញីមួយបានជាអគ្គមហេសី ។ ស្តេចចចកសព្វទាឋៈឲ្យរាជសីហ៍ឈរលើខ្នងដំរី ២ ស្តេចចចកអង្គុយលើខ្នងរាជសីហ៍ជាមួយចចកញីដែលជាអគ្គមហេសីជាយសដ៏ធំក្រៃលែង ។ ស្តេចចចកស្រវឹងដោយយសដ៏ធំកើតនូវមានះគិតដណ្តើមរាជសម្បត្តិក្នុងនគរពារាណសី ចោមរោមដោយសត្វចតុប្បាទទាំងពួងលើកទៅព័ទ្ធនគរពារាណសីដោយបរិវារប្រមាណ ១២ យោជន៍ ។ ស្តេចចចកតាំងនៅមិនឆ្ងាយប៉ុន្មានបញ្ជូនសាសន៍ដល់ព្រះរាជាថា តើព្រមប្រគល់រាជសម្បត្តិឬច្បាំង ។ អ្នកនគរពារាណសីនាំគ្នាតក់ស្លុតបិទទ្វារព្រះនគរយ៉ាងមាំ ។ ព្រះពោធិសត្វចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំខ្លាចឡើយ ការតស៊ូដោយចម្បាំងនឹងចចកសព្វទាឋៈជាភារៈទូលព្រះបង្គំឯងរៀរទូលព្រះបង្គំ មិនមានអ្នកអាចច្បាំងជាមួយចចកបានទេ លួងលោមព្រះរាជានិងមហាជនហើយគិតថា សព្វទាឋៈដណ្តើមរាជសម្បត្តិដោយវិធីណា អញ

នឹងសាកសួរមើលសិន ទើបឡើងលើប៉មត្រង់ទ្វារនគរសួរថា នែសព្វទាឋៈ សម្លាញ់អ្នកដណ្តើមយករាជសម្បត្តិនេះបានដោយប្រការដូចម្តេច ។ សព្វទាឋៈឆ្លើយថា យើងនឹងឲ្យរាជសីហ៍បន្លឺសីហនាទ ធ្វើឲ្យមហាជនតក់ស្លុតក្នុងសំឡេងហើយដណ្តើមយករាជសម្បត្តិព្រះពោធិសត្វដឹងថា មានមធ្យោបាយដោះស្រាយទើបចុះអំពីប៉ម ឲ្យវាយស្គរប្រកាសថា អ្នកនគរពារាណសីទាំងអស់ ១២ យោជន៍ចូរយកម្សៅសណ្តែករាជមាសចុកត្រចៀក ។ មហាជនស្តាប់សំឡេងប្រកាស នាំគ្នាយកម្សៅសណ្តែករាជមាសចុករន្ធត្រចៀករបស់ខ្លួននិងសត្វជើង ៤ ទាំងអស់សូម្បីតែឆ្មាមិនឲ្យឮសំឡេងរបស់អ្នកដទៃ ។ កាលនោះព្រះពោធិសត្វឡើងកាន់ប៉មស្រែកហៅទៀតថា នែសព្វទាឋៈ ។ ស្តេចចចកសួរថា មានការអ្វីព្រាហ្មណ៍ ព្រះពោធិសត្វក៏ពោលថា អ្នកនឹងធ្វើដូចម្តេចទៀតទើបដណ្តើមយករាជសម្បត្តិនេះបាន ចចកឆ្លើយថា យើងនឹងឲ្យរាជសីហ៍បន្លឺសីហនាទឲ្យពួកមនុស្សតក់ស្លុតដល់នូវការស្លាប់ ហើយដណ្តើមយករាជសម្បត្តិ ។ ព្រះពោធិសត្វពោលថា ឯងមិនអាចឲ្យរាជសីហ៍បន្លឺសីហនាទបានទេ ព្រោះកេសរសីហរាជមានជើងមុខជើងក្រោយក្រហមល្អសម្បូរដោយជាតិ នឹងមិនធ្វើតាមពាក្យរបស់ចចកចាស់ដូចឯង ។ ចចកជាសត្វរឹងត្អឹងមានអំនួតពោលថា រាជសីហ៍ទាំងឡាយដទៃចូរនៅឲ្យស្ងៀមយើងអង្គុយលើខ្នងរាជសីហ៍ណា នឹងឲ្យរាជសីហ៍នោះបន្លឺសំឡេង ព្រះពោធិសត្វពោលថា បើដូច្នោះ ចូរឲ្យបន្លឺសំឡេងចុះបើឯងអាច ។ ទើបស្តេចចចកឲ្យសញ្ញាដោយជើងដល់រាជសីហ៍ដែលខ្លួនអង្គុយលើខ្នងថា ចូរបន្លឺសំឡេង ។

ទើបរាជសីហ៍បើកមាត់បន្លឺសីហនាទលើក្បាលដំរី ៣ ដង ដែលមិនធ្លាប់បន្លឺមក ដំរីទាំងឡាយតក់ស្លុតរលាស់ចចកឲ្យធ្លាក់ត្រង់ជើងក៏ក្ចាត់ជើងជាន់ក្បាលចចកនោះបែកទៅ សព្វទាឋៈដល់នូវការស្លាប់ក្នុងទីនោះឯង ។ ដំរីនោះបានឮសំឡេងរាជសីហ៍ហើយក៏តក់ស្លុតនឹងសេចក្ដីស្លាប់ ទើបរត់ជាន់គ្នាស្លាប់ក្នុងទីនោះឯង ។ សត្វជើង ៤ ទាំងអស់ម្រឹគនិងជ្រូកជាដើមមានទន្សាយនិងឆ្មាជាទីបំផុត វៀរលែងតែរាជសីហ៍ចេញដល់នូវការស្លាប់ក្នុងទីនោះឯង រាជសីហ៍ទាំងឡាយក៏គេចចូលព្រៃទៅ ។ គំនរសាច់សត្វដេរដាសក្នុងទី ១២ យោជន៍ ។ ព្រះពោធិសត្វចុះពីលើប៉មហើយបានបើកទ្វារនគរឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា អ្នកនគរទាំងអស់ចូរយកម្សៅចេញពីត្រចៀក បើមានសេចក្ដីត្រូវការដោយសាច់ក៏ចូរទៅយកមក មនុស្សទាំងឡាយបានបរិភោគសាច់ស្រស់សាច់ដែលសល់ក៏ហាលឲ្យក្រៀមធ្វើជាសាច់ងៀត ។ មានតំណាលថា ការធ្វើសាច់ងៀតបានកើតឡើងតាំងពីកាលនោះឯង ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា

ចចករឹងត្អឹងដោយមានះ ត្រូវការដោយបរិវារ ( ច្រើន ) ក៏
ដល់ភូមិសម្បត្តិដ៏ធំបានជាស្ដេចនៃពួកសត្វមានចង្កូមទាំងពួង ។
បណ្ដាមនុស្សទាំងឡាយ មនុស្សណាជាអ្នកមានបរិវារ
មនុស្សនោះឈ្មោះថាជាធំក្នុងពួកបរិវារនោះដូចជាចចក ( បាន
ជាធំ ) ជាងសត្វមានចង្កូមទាំងឡាយដូច្នោះឯង ។

បណ្ដាបទទាំងនោះ បទថា **មានជនេ្មា** សេចក្ដីថា ចចករីងត្អឹងដោយមានះកើតឡើងព្រោះអាស្រ័យបរិវារ ។ បទថា **បរិវារេន អត្ថិកោ** គឺ មានសេចក្ដីត្រូវការដោយបរិវារដែលក្រៃលែងឡើង ។ បទថា **មហតី ភូមី** បានដល់ សម្បត្តិជាច្រើន ។ បទថា **រាជាសិ សព្វទាឋិនំ** គឺ បានជាស្ដេចនៃសត្វដែលមានចង្កូមនិងភ្លុកទាំងអស់ ។ បទថា **សោ ហិ តត្ថ មហា ហោតិ** សេចក្ដីថា បុរសដែលដល់ព្រមដោយបរិវារនោះឈ្មោះថាជាធំក្នុងបរិវារទាំងនោះ ។ បទថា **សិគាលោ វិយ ទាឋិនំ** បានដល់ ជាធំដូចចចកដែលបានជាធំជាងសត្វមានចង្កូមនិងភ្លុកដូច្នោះ ពេលនោះសត្វនោះដល់នូវសេចក្ដីប្រមាទ ក៏រមែងដល់នូវសេចក្ដីវិនាសព្រោះអាស្រ័យបរិវារនោះដូចចចកដូច្នោះ ។

ព្រះសាស្ដាទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះបានមកជាសារីបុត្ត ឯបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សព្វទាឋិជាតក ចប់

## សុណខជាតក

[ ៣៣៤ ] ( ព្រះពោធិសត្វពោលថា ) ឆ្កែណាមិនស៊ីព្រ័ត្រ ឆ្កែនុ៎ះពេញជាល្ងង់ ម្យ៉ាងទៀតឆ្កែគួរដោះខ្លួនអំពីចំណង ស៊ីព្រ័ត្រឆ្អែតហើយគប្បីទៅកាន់ផ្ទះ ( របស់ខ្លួន ) ។

[ ៣៣៥ ] ( ឆ្កែពោលថា ពាក្យរបស់អ្នក ) ខ្ញុំបានតាំងទុកក្នុងចិត្តខ្ញុំហើយ ម្យ៉ាងទៀតខ្ញុំបានធ្វើទុកក្នុងហឫទ័យខ្ញុំហើយ ជនដេកលក់ស៊ប់ដរាបណាខ្ញុំរង់ចាំនូវកាលដរាបនោះ ។

**ចប់ សុនខជាតកទី ២ ។**

## អដ្ឋកថា

## សុណខជាតក

[ ៣៣៤-៣៣៥ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឆ្កែស៊ីអាហារត្រង់សាលាសម្នាក់ក្បែរប្រឡាយទឹក ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្ដើមថា **ពាលោ វតាយំ សុណខោ** ដូច្នេះជាដើម ។

បានឮថា ពួកអ្នកដងទឹកនាំឆ្កែនោះមកចិញ្ចឹមក្នុងទីនោះតាំងពីតូច ក្នុងកាលតមកឆ្កែនោះបានស៊ីអាហារក្នុងទីនោះរហូតមានរាងកាយធំធាត់ ។ ថ្ងៃមួយមានបុរសអ្នកស្រុកម្នាក់មកដល់ទីនោះឃើញឆ្កែនោះទើបឲ្យសំពត់សាដកសាច់ល្អនិងប្រាក់ដល់អ្នកដងទឹក ហើយយកច្រវាក់ចងនាំឆ្កែនោះទៅ ។ ឆ្កែនោះត្រូវគេនាំទៅក៏មិនរើបម្រះ បរិភោគអាហារដែលគេឲ្យ ដើរតាមទៅអំពី

ក្រោយ ។ បុរសនោះគិតថា ឥឡូវនេះឆ្កែនេះស្រឡាញ់អញ ទើបស្រាយប្រវាក់ចេញ ឆ្កែគ្រាន់តែស្រាយប៉ុណ្ណោះក៏រត់ដោយរហ័សដល់សាលាសម្នាក់វិញ ភិក្ខុទាំងឡាយឃើញឆ្កែនោះជ្រាបហេតុដែលឆ្កែធ្វើទើបសន្ទនាគ្នាក្នុងធម្មសភានាពេលល្ងាចថា អាវុសោទាំងឡាយ ឆ្កែត្រង់សាលាសម្នាក់ឈ្លាសក្នុងការធ្វើឲ្យផុតចំណង គ្រាន់តែគេលែងប៉ុណ្ណោះក៏គេចមកបាន ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឆ្កែនោះមិនមែនឈ្លាសក្នុងការធ្វើឲ្យផុតចំណង ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ឈ្លាសក្នុងការធ្វើឲ្យផុតចំណងដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកមានសម្បត្តិច្រើនក្នុងដែនកាសី លុះចម្រើនវ័យបានគ្រប់គ្រងឃរាវាស ។ កាលនោះមនុស្សម្នាក់ក្នុងក្រុងពារាណសីមានឆ្កែមួយ ។ ឆ្កែនោះបានជុំបាយស៊ីរហូតជាត់ ។ អ្នកស្រុកម្នាក់មកកាន់ក្រុងពារាណសី ឃើញឆ្កែនោះទើបឲ្យសំពត់សាដកសាច់ម៉ដ្ឋនិងប្រាក់ដល់អ្នកនោះ ហើយយកឆ្កែនោះ យកព្រ័ត្រចងកាន់ចុងព្រ័ត្រដឹកដើរទៅ ទើបចូលទៅកាន់សាលាដើមបបុសមួយកន្ទែងក្បែរមាត់ព្រៃចងឆ្កែនោះទុក ដេកលក់លើបន្ទះក្តារ ។ ក្នុងកាលនោះ ព្រះពោធិសត្វដើរច្នងព្រៃដោយធុរៈឯណាទីមួយឃើញ

ឆ្កែនោះត្រូវលាមទុក ទើបពោលគាថាទីមួយថា

ឆ្កែណាមិនស៊ីព្រ័ត្រ ឆ្កែនុ៎ះពេញជាល្ងង់ ម្យ៉ាងទៀតឆ្កែគួរដោះខ្លួនអំពីចំណង ស៊ីព្រ័ត្រឆ្អែតហើយគប្បីទៅកាន់ផ្ទះ ( របស់ខ្លួន ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បមោចយេ្យ** សេចក្ដីថា គប្បីដោះ ។ ព្រះបាលីក៏យ៉ាងនេះ ។ បទថា **អសិតោវ យាំ វជេ** សេចក្ដីថា គប្បីជាអ្នកទំពាស៊ីឲ្យឆ្អែតហើយទៅកាន់លំនៅរបស់ខ្លួន ។

ឆ្កែបានស្ដាប់ពាក្យនោះ ទើបពោលគាថាទីពីរថា

( ពាក្យរបស់អ្នក ) ខ្ញុំបានតាំងទុកក្នុងចិត្តខ្ញុំហើយ ម្យ៉ាងទៀតខ្ញុំបានធ្វើទុកក្នុងហឫទ័យខ្ញុំហើយ ជនដេកលក់ស៊ប់ដរាបណាខ្ញុំរង់ចាំនូវកាលដរាបនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋិតំ មេ មនស្មឹ មេ** សេចក្ដីថា អ្នកពោលពាក្យណាពាក្យនោះខ្ញុំតាំងចិត្តទុកហើយ គឺរក្សាទុកហើយក្នុងចិត្តរបស់ខ្ញុំ ។ បទថា **អថោ មេ ហទយេ កតំ** គឺ ពាក្យរបស់អ្នកខ្ញុំក៏រក្សាទុកក្នុងចិត្តនោះឯង ។ បទថា **កាលញ្ច បដិកង្ខាមិ** គឺ ខ្ញុំកំពុងរង់ចាំកាល ។ បទថា **យាវ បសុបតុជ្ជនោ** សេចក្ដីថា ខ្ញុំរង់ចាំកាលទម្រាំមហាជនដេកលក់ ។ ក្រៅអំពីនេះឆ្កែគិតថា ការប្រាថ្នារបស់ខ្លួនកើតឡើងថានឹងគេច ព្រោះហេតុនោះក្នុងពេលយប់កាលមនុស្សដេកលក់អស់ អញនឹងខាំខ្សែគេចទៅ ។

ឆ្កែកាលពោលយ៉ាងនេះហើយ កាលមហាជននាំគ្នាដេកលក់ទើបខាំខ្សែ

ស៊ីផ្អែតហើយគេចទៅកាន់ផ្ទះរបស់ម្ចាស់ខ្លួនវិញ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ឆ្កែក្នុងកាលនោះ បានមកជាឆ្កែក្នុងកាលឥឡូវនេះ ឯបុរសបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុនខជាតក ចប់

## គុត្តិលជាតក

[ ៣៣៦ ] ( ព្រះពោធិសត្វពោលថា ) បពិត្រព្រះឥន្ទ្រកោសិយៈ ខ្ញុំបាន ( ញុំាងសិស្សឈ្មោះ មុសិលៈ ) ឲ្យរៀននូវពិណមានខ្សែ ៧ មានសំឡេងពីរោះជាទីរីករាយនៃចិត្ត ( ឥឡូវនេះ ) សិស្សឈ្មោះមុសិលៈនោះហៅខ្ញុំក្នុងកណ្ដាលរង្គមណ្ឌល ( កន្លែងរាំ ) សូមព្រះអង្គជាទីពឹងនៃខ្ញុំ ។

[ ៣៣៧ ] ( សក្កទេវរាជទ្រង់មានព្រះបន្ទូលថា ) ម្នាលសំឡាញ់ ខ្ញុំនឹងជាទីពឹងរបស់អ្នក ខ្ញុំជាអ្នកបូជានូវអាចារ្យ សិស្សនឹងមិនឈ្នះអ្នក បពិត្រអាចារ្យ អ្នកនឹងឈ្នះនូវសិស្សវិញ ។

**ចប់ គុត្តិលជាតកទី ៣ ។**

## អដ្ឋកថា

## គុត្តិលជាតក

[ ៣៣៦-៣៣៧ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សត្តតន្តឹ សុមធុរំ** ដូច្នេះជាដើម ។

មានសេចក្ដីសង្ខេបថា ក្នុងកាលនោះភិក្ខុទាំងឡាយពោលនឹងទេវទត្តថា នែអាវុសោទេវទត្ត ព្រះសម្មាសម្ពុទ្ធជាអាចារ្យរបស់លោក លោកអាស្រ័យព្រះសម្មាសម្ពុទ្ធ រៀនព្រះត្រៃបិដកញុំាងឈាន ៤ ឲ្យកើតឡើង ការដែលលោកធ្វើខ្លួនឲ្យជាសត្រូវចំពោះបុគ្គលជាអាចារ្យមិនសមគួរឡើយ ។ ទេវទត្ត

ពោលថា អាវុសោទាំងឡាយ ព្រះសមណគោតមជាអាចារ្យរបស់ខ្ញុំឬ ព្រះត្រៃបិដកខ្ញុំរៀនដោយកម្លាំងរបស់ខ្លួនឯងមិនមែនឬ ឈានទាំង ៤ ខ្ញុំធ្វើឲ្យកើតដោយកម្លាំងរបស់ខ្លួនទាំងអស់មិនមែនឬ ។ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តរមិលគុណអាចារ្យហើយក្លាយជាសត្រូវចំពោះព្រះសម្មាសម្ពុទ្ធ ដល់នូវសេចក្ដីវិនាសហើយ ។ ព្រះសាស្ដាយាងមកកាន់ធម្មសភាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនរមិលគុណអាចារ្យ ជាសត្រូវចំពោះតថាគតហើយដល់នូវសេចក្ដីវិនាសតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុនក៏ដល់នូវសេចក្ដីវិនាសហើយដូចគ្នាទើបទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នករបាំ មាតាបិតាឲ្យឈ្មោះថា គុត្តិលកុមារ ។ គុត្តិលកុមារនោះកាលចម្រើនវ័យ សម្រេចសិប្បៈខាងការប្រគំ ជាអ្នកប្រគំដ៏កំពូលក្នុងជម្ពូទ្វីបទាំងមូលឈ្មោះថា គុត្តិលគន្ធព្វ គុត្តិលមាណពមិនមានភរិយាចិញ្ចឹមមាតាបិតាដែលខ្វាក់ភ្នែក ។ ក្នុងកាលនោះឈ្មួញអ្នកក្រុងពារាណសីទៅធ្វើការជួញដូរក្នុងក្រុងឧជ្ជេនី កាលគេប្រកាសថាមានមហោស្រពទើបនាំគ្នារកផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងទំពា គ្រឿងបរិភោគជាដើមជាច្រើនប្រជុំគ្នាក្នុងលានកីឡាឲ្យថ្លៃឈ្នួលហើយពោលថា ពួកអ្នកចូរនាំ

អ្នកចម្រៀងម្នាក់មកចុះ ។

សម័យនោះក្នុងក្រុងឧជ្ជេនីមានអ្នកចម្រៀងដ៏កំពូលម្នាក់ឈ្មោះ មុសិលៈ ទើបពួកឈ្នួញហៅបុរសនោះមកឲ្យសម្តែងការច្រៀង ។ មុសិលៈកាលនឹងដេញពិណ បានតម្លើងខ្សែឯកដេញហើយ ការដេញរបស់មុសិលៈនោះបានប្រាកដដូចសំឡេងអេះកន្ទេលផែងដល់ពួកឈ្នួញទាំងនោះ ព្រោះពួកឈ្នួញទាំងនោះជាអ្នកធ្លាប់ត្រចៀកក្នុងការស្តាប់សំឡេងពិណរបស់គុត្តិលគន្ធព្វ ទើបមិនបានសម្តែងអាការពេញចិត្តសូម្បីត្រឹមតែម្នាក់ ។ មុសិលៈកាលពួកឈ្នួញទាំងនោះមិនសម្តែងអាការពេញចិត្តគិតថា អញប្រហែលជាដេញពិណតឹងពេក ទើបបន្ថយសំឡេងជាខ្សែកណ្តាលដេញ ដោយសំឡេងជាកណ្តាលពួកឈ្នួញទាំងនោះក៏នៅស្ងៀមក្នុងសំឡេងពិណនោះ ។ លំដាប់នោះគាត់គិតថា ពួកឈ្នួញទាំងនេះមិនដឹងអ្វីទើបធ្វើជាមិនដឹងរឿងហើយដេញពិណខ្សែធូរ ។ ពួកឈ្នួញក៏មិនថាអ្វីទើបមុសិលៈពោលថា នែឈ្នួញដ៏ចម្រើន កាលខ្ញុំដេញពិណលោកមិនពេញចិត្តឬ ពួកឈ្នួញពោលថា អ្នកដេញពិណអ្វីពួកយើងមិនបានយល់ថា អ្នកតម្លើងសំឡេងពិណដេញទេ មុសិលៈសួរថា លោកស្គាល់អាចារ្យដែលពូកែជាងខ្ញុំឬ ឬមិនធ្លាប់ត្រេកអរព្រោះខ្លួនមិនធ្លាប់ស្តាប់ ។ ពួកឈ្នួញពោលថា យើងធ្លាប់ស្តាប់សំឡេងពិណគុត្តិលគន្ធព្វឯក្រុងពារាណសី សំឡេងពិណរបស់គាត់ដូចស្រីបំពេកូន ។ មុសិលៈពោលថា បើដូច្នោះសូមលោកយកតម្លៃរបស់លោកទៅវិញចុះ ខ្ញុំមិនត្រូវការតម្លៃនោះតែកាលលោកទៅកាន់ក្រុងពារាណសី ជួយនាំខ្ញុំទៅផង ពួកឈ្នួញពោលថា សាធុ ក្នុង

កាលត្រឡប់បានទាំបុរសនោះទៅកាន់ក្រុងពារាណសីប្រាប់មុសិលៈថា នុ៎ះគឺ ផ្ទះគុត្តិលគន្ធព្វ ហើយទៅកាន់ទីលំនៅនៃខ្លួន ។ មុសិលៈចូលទៅកាន់ផ្ទះ ព្រះពោធិសត្វឃើញពិណរបស់ព្រះពោធិសត្វទើបយកមកដេញ ។ លំដាប់ នោះមាតាបិតារបស់ព្រះពោធិសត្វ មើលមិនឃើញមុសិលៈ ព្រោះភ្នែកខ្វាក់ យល់ថា ប្រហែលជាកណ្តុរមកកាត់ពិណទើបពោលថា កណ្តុរកាត់ខ្សែពិណ ។ មុសិលៈដាក់ពិណចុះថ្វាយបង្គំមាតាបិតារបស់ព្រះពោធិសត្វ កាលមាតាបិតា របស់ព្រះពោធិសត្វសួរថា អ្នកមកអំពីណា ទើបពោលថា ខ្ញុំមកពីក្រុងឧជ្ជេនី ដើម្បីសូមរៀនសិប្បៈក្នុងសម្នាក់របស់លោកអាចារ្យ ។ កាលមាតាបិតាព្រះ ពោធិសត្វទទួលថា សាធុ ហើយទើបសួរថា លោកអាចារ្យទៅណា មាតា បិតានោះពោលថា មិននៅទេអ្នកថ្ងៃនេះនឹងត្រឡប់មក ទើបអង្គុយក្នុងទីនោះ កាលព្រះពោធិសត្វត្រឡប់មក បានទទួលបដិសណ្ឋារៈហើយ ក៏ប្រាប់ហេតុ ដែលខ្លួនមក ។ ព្រះពោធិសត្វស្គាល់អង្គនៃវិជ្ជាទាយលក្ខណៈដឹងថា មុសិលៈ ជាអសប្បុរសបានបណ្តេញទៅថា ទៅចុះបា សិប្បៈមិនសម្រេចដល់អ្នកទេ មុសិលៈចាប់ជើងមាតាបិតាព្រះពោធិសត្វប្រចាប់ថ្នមៗ ឲ្យអាណិតខ្លួនហើយ អង្វរថា សូមលោកជួយឲ្យលោកអាចារ្យបង្រៀនសិប្បៈដល់ខ្ញុំផងចុះ ។ ព្រះ ពោធិសត្វត្រូវមាតាបិតានិយាយអង្វររឿយៗក៏មិនអាចជំទាស់បាន ទើបព្រម បង្រៀនសិប្បៈ ។ មុសិលៈទៅរាជនិវេសន៍ជាមួយព្រះពោធិសត្វ ។ ព្រះរាជា ទតឃើញត្រាស់សួរថា បុរសនេះជានរណាលោកអាចារ្យ ។ ព្រះពោធិសត្វ ក្រាបទូលថា បពិត្រមហារាជ បុរសនេះគឺអន្តេវាសិករបស់ទូលព្រះបង្គំ ។

មុសិលៈស្និទ្ធស្នាលជាមួយព្រះរាជាដោយលំដាប់ ។ ព្រះពោធិសត្វមិនបាន បិទបាំងឲ្យសិក្សាវិជ្ជាតាមដែលខ្លួនរៀនចប់មកហើយពោលថា នែបា អ្នករៀន សិប្បៈចប់ហើយ ។ មុសិលៈគិតថា សិប្បៈអញក៏ជំនាញហើយ ទាំងក្រុង ពារាណសីនេះក៏ជានគរដ៏ប្រសើរក្នុងជម្ពូទ្វីបទាំងមូល ។ បើអាចារ្យរបស់អញ ចាស់ អញគួរនៅក្នុងនគរពារាណសីនេះឯង ។ ទើបមុសិលៈប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំនឹងទទួលរាជការ ។ អាចារ្យពោលថា សាធុ យើង នឹងក្រាបទូលព្រះរាជាទើបនាំទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ អន្តេវាសិករបស់ទូលព្រះបង្គំប្រាថ្នាទទួលរាជការបម្រើព្រះអង្គ សូមទ្រង់ ពិចារណាបៀវត្សរ៍សម្រាប់គេចុះ ។ កាលព្រះរាជាត្រាស់ថា បុរសនេះ បានពាក់កណ្ដាលចំណែកដែលអ្នកបាន ទើបប្រាប់រឿងនោះដល់មុសិលៈ មុសិលៈពោលថា បើខ្ញុំបានបៀវត្សរ៍ស្មើលោកអាចារ្យទើបទទួលរាជការ ព្រះ ពោធិសត្វសួរថា ព្រោះហេតុអ្វី មុសិលៈឆ្លើយថា ខ្ញុំចេះសិប្បៈដែលលោក អាចារ្យចេះទាំងអស់មិនមែនឬ ។ ព្រះពោធិសត្វពោលថា ត្រូវហើយអ្នកចេះ ទាំងអស់ មុសិលៈពោលថា បើដូច្នោះហេតុអ្វីទើបព្រះរាជាព្រះរាជទាន បៀវត្សរ៍ដល់ខ្ញុំត្រឹមតែពាក់កណ្ដាលទើបព្រះពោធិសត្វក្រាបទូលដល់ព្រះរាជា ព្រះរាជាត្រាស់ថា បើអន្តេវាសិករបស់អ្នកអាចសម្ដែងសិប្បៈស្មើនឹងអ្នក ក៏ នឹងបានស្មើគ្នា ។ ព្រះពោធិសត្វស្ដាប់ព្រះតម្រាស់នោះ ទើបប្រាប់ដល់ មុសិលៈ កាលមុសិលៈពោលថា សាធុ ខ្ញុំនឹងសម្ដែង ទើបក្រាបទូលដល់ ព្រះរាជា ។ ព្រះរាជាត្រាស់ថា សាធុ ចូរសម្ដែងចុះ នឹងសម្ដែងប្រកួតគ្នាក្នុង

ថ្ងៃណា ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ សូមប្រកួតគ្នាក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ។ ព្រះរាជាហៅមុសិលៈមកត្រាស់សួរថា បានឮថា អ្នកប្រកួតប្រជែងជាមួយអាចារ្យឬ មុសិលៈក្រាបទូលថា ករុណាថ្លៃវិសេស ។ សូម្បីព្រះរាជាទ្រង់ហាមឃាត់ថា ការប្រកួតប្រជែងនឹងអាចារ្យមិនសមគួរឡើយ មុសិលៈក៏នៅតែក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ឲ្យទូលព្រះបង្គំប្រកួតប្រជែងនឹងអាចារ្យក្នុងថ្ងៃទី ៧ ចុះនឹងបានដឹងថា អ្នកណាឈ្នះ ។ ព្រះរាជាត្រាស់ថា សាធុ ឲ្យត្រាច់វាយស្គរប្រកាសថា ក្នុងថ្ងៃទី ៧ បន្ទាប់ពីថ្ងៃនេះ អាចារ្យនិងសិស្សសម្ដែងសិប្បៈប្រកួតគ្នាត្រង់ខ្លោងទ្វារព្រះរាជវាំង ចូរមហាជនមកប្រជុំគ្នាមើលការប្រឡងប្រណាំងចុះ ។ ព្រះពោធិសត្វគិតថា មុសិលៈនេះនៅកំលោះមានកម្លាំងរឹងមាំ អញចាស់ថមថយកម្លាំងហើយ ធម្មតាកិរិយារបស់មនុស្សចាស់មិនរឹងប៉ឹង រហ័សរហួន ម្យ៉ាងទៀតធម្មតាកូនសិស្សទោះបីចាញ់ក៏មិនជាការអ្វី តែបើសិស្សឈ្នះអញស្លាប់ក្នុងព្រៃប្រសើរជាងការខ្មាសដែលគប្បីបានទទួល ។ ទើបព្រះពោធិសត្វចូលទៅកាន់ព្រៃ ហើយត្រឡប់មកវិញព្រោះខ្លាចស្លាប់ ហើយត្រឡប់ទៅទៀតព្រោះខ្លាចខ្មាសគេ ។ ព្រះពោធិសត្វត្រឡប់ទៅត្រឡប់មកយ៉ាងនេះអស់ ៦ ថ្ងៃ ស្មៅទាំងឡាយរាបកើតជាគន្លងជើងហើយ ។ ខណៈនោះពិភពរបស់សក្កៈសម្ដែងអាការៈក្ដៅ សក្កទេវរាជទ្រង់ប្រមើលមើលហេតុការណ៍នោះទ្រង់ព្រះតម្រិះថា គុត្តិលគន្ធព្វបានទទួលទុក្ខធំក្នុងព្រៃព្រោះខ្លាចអន្តេវាសិក អញគួរជាទីពឹងរបស់បុរសនេះក៏រូតរះទៅឈរអំពីខាងមុខ ត្រាស់សួរថា លោកអាចារ្យចូលទៅក្នុងព្រៃ

ធ្វើអ្វី កាលព្រះពោធិសត្វសួរថា អ្នកជានរណា សក្កទេវរាជក៏ត្រាស់ថា ខ្ញុំជាសក្កទេវរាជ ។ លំដាប់នោះទើបព្រះពោធិសត្វទូលសក្កទេវរាជថា បពិត្រទេវរាជ ខ្ញុំចូលព្រៃព្រោះខ្លាចចាញ់អន្តេវាសិក ហើយពោលគាថាទីមួយថា

បពិត្រព្រះឥន្ទ្រកោសិយៈ ខ្ញុំបាន ( ញុំាងសិស្សឈ្មោះមុ-
សិលៈ ) ឲ្យរៀននូវពិណមានខ្សែ ៧ មានសំឡេងពីរោះ
ជាទីរីករាយនៃចិត្ត ( ឥឡូវនេះ ) សិស្សឈ្មោះមុសិលៈនោះ
ហៅខ្ញុំក្នុងកណ្ដាលរង្គមណ្ឌល ( កន្លែងរាំ ) សូមព្រះអង្គជាទី
ពឹងនៃខ្ញុំ ដូច្នេះ ។

សក្កទេវរាជស្ដាប់ពាក្យរបស់ព្រះពោធិសត្វហើយពោលថា កុំខ្លាចឡើយ ខ្ញុំនឹងជួយតតាំងការពារអ្នកបានពោលគាថាទីពីរថា

ម្នាលសម្លាញ់ ខ្ញុំនឹងជាទីពឹងរបស់អ្នក ខ្ញុំជាអ្នកបូជានូវ
អាចារ្យ សិស្សនឹងមិនឈ្នះអ្នក បពិត្រអាចារ្យអ្នកនឹងឈ្នះនូវ
សិស្សវិញ ដូច្នេះ ។

សក្កទេវរាជត្រាស់ថា កាលអ្នកដេញពិណ ចូរផ្ដាច់ខ្សែ ១ ដេញខ្សែ ៦ សំឡេងពិណរបស់អ្នកនឹងដូចដើម ឯមុសិលៈក៏នឹងផ្ដាច់ខ្សែពិណតែសំឡេងពិណរបស់គេនឹងមិនដូចដើម ខណៈនោះគេនឹងដល់នូវភាពបរាជ័យ កាលដឹងថា គេដល់នូវភាពបរាជ័យហើយអ្នកគប្បីផ្ដាច់ខ្សែទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ទី ៧ ដេញតែដងទទេ សំឡេងនឹងចេញអំពីកំណួចខ្សែពិណដែលផ្ដាច់ចោលឮខ្ទាំងពេញក្រុងពារាណសីទាំង ១២ យោជន៍ ។ សក្កទេវរាជ

ត្រាស់យ៉ាងនេះហើយ ទើបប្រទានចិញ្ចៀន ៣ វង់ឲ្យព្រះពោធិសត្វត្រាស់ថា កាលសំឡេងពិណរបស់អ្នកឮពេញព្រះនគរហើយ ចូរអ្នកបោះចិញ្ចៀននេះ ១ ទៅក្នុងអាកាស លំដាប់នោះទេពអប្សរ ៣០០ នឹងចុះមករាំខាងមុខអ្នក ក្នុងកាលដែលទេពអប្សរទាំងនោះរាំអ្នកគប្បីបោះចិញ្ចៀនទី ២ ទៅ លំដាប់នោះទេពអប្សរ ៣០០ ទៀតនឹងចុះមករាំខាងមុខពិណរបស់អ្នក បន្ទាប់ពីនោះបោះចិញ្ចៀនទី ៣ ទៅ លំដាប់នោះទេពអប្សរ ៣០០ ទៀតនឹងចុះមករាំត្រង់លានសម្រាប់រាំ ឯខ្ញុំក៏នឹងមករកអ្នក ទៅចុះកុំខ្លាចឡើយ ។

ព្រះពោធិសត្វបានត្រឡប់ទៅផ្ទះក្នុងពេលព្រឹក ។ ពួកអ្នកក្រុងធ្វើមណ្ឌបក្បែរខាងទ្វារព្រះរាជវាំង តាក់តែងទីប្រថាប់សម្រាប់ព្រះរាជា ។ ព្រះរាជាយាងចុះមកអំពីប្រាសាទហើយប្រថាប់គង់លើបល្ល័ង្ក ក្នុងរង្គមណ្ឌលដែលប្រដាប់ហើយ ។ ស្ត្រីតាក់តែងហើយមួយម៉ឺន អាមាត្យ ព្រាហ្មណ៍ អ្នកដែនជាដើមនាំគ្នាគាល់ច្រើនសន្ធឹកសន្ធាប់ ។ អ្នកនគរក៏ប្រជុំគ្នាក្នុងលានព្រះរាជវាំងយករថត្រួតលើរថ យកគ្រែត្រួតលើគ្រែ ព្រះពោធិសត្វស្ងួតទឹកជម្រះកាយហើយបរិភោគអាហារមានរសផ្សេងៗ កាន់ពិណទៅអង្គុយលើអាសនៈសម្រាប់ខ្លួន ។ សក្កទេវរាជមកឋិតនៅលើអាកាសដោយមិនប្រាកដកាយ ។ ព្រះពោធិសត្វប៉ុណ្ណោះឃើញសក្កទេវរាជ ។ ឯមុសិលៈមកអង្គុយលើអាសនៈរបស់ខ្លួន មហាជនចោមរោមហើយជនទាំង ២ ក៏ដេញពិណចាប់ផ្ដើមស្មើគ្នា មហាជនចាប់ផ្ដើមហ៊ោកញ្ជ្រៀវត្រេកអរ ដោយការដេញពិណនៃជនទាំង ២ ទេវរាជ ស្ថិតនៅលើអាកាសប្រាប់ឲ្យឮតែព្រះពោធិសត្វប៉ុណ្ណោះថា ចូរអ្នកផ្ដាច់

ខ្សែទី ១ ។ ព្រះពោធិសត្វផ្ដាច់ខ្សែទី ១ ចោលហើយសំឡេងក៏នៅតែចេញអំពីកំណួចដែលដាច់ហើយដូចសំឡេងពិណរបស់ទេវគន្ធព្វដូច្នោះ ។ ចំណែកមុសិលៈ ( ឃើញដូច្នោះ ) ក៏ផ្ដាច់ខ្សែពិណដែរតែសំឡេងមិនឮចេញមក ។ អាចារ្យផ្ដាច់ខ្សែទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ទី ៧ ។ កាលដេញតែដងពិណទទេសំឡេងក៏លាន់ពេញព្រះនគរ ។ សំឡេងហ៊ោកញ្ជ្រៀវនិងទង់បក់បោកច្រើនពាន់បានប្រព្រឹត្តទៅហើយ ។ ព្រះពោធិសត្វបានបោះចំពៀនទី ១ ទៅក្នុងអាកាសគ្រានោះទេពអប្សរ ៣០០ ចុះមករាំ កាលបោះចំពៀនទី ២ ទី ៣ ទៅហើយទេពអប្សរ ៩០០ បានចុះមករាំតាមន័យដែលពោលហើយ ។ ខណៈនោះ ព្រះរាជាបានឲ្យសញ្ញាដល់មហាជន មហាជនក៏នាំគ្នាក្រោកឡើងគំរាមមុសិលៈថា ឯងប្រណាំងប្រជែងជាមួយអាចារ្យ ព្យាយាមវាយឫកស្មើនឹងអាចារ្យ មិនស្គាល់ប្រមាណខ្លួន គប់ដោយដុំដី ដុំថ្មនិងដំបងជាដើមតាមដែលចាប់យកមកបានឲ្យដល់នូវសេចក្ដីស្លាប់ ចាប់ជើងអូសទៅចោលត្រង់គំនរសំរាម ។ ព្រះរាជាមានព្រះហឫទ័យត្រេកអរព្រះរាជទានទ្រព្យជាច្រើនដល់ព្រះពោធិសត្វដូចព្រិលធ្លាក់ចុះមក ។ អ្នកនគរក៏ឲ្យយ៉ាងនោះដូចគ្នា ។ សក្កទេវរាជទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រះពោធិសត្វថា នែបណ្ឌិត ខ្ញុំនឹងឲ្យមាតលិសារថី យករថទឹមដោយសេះអាជានេយ្យ ១០០០ មកទទួលអ្នកក្នុងកាលជាក្រោយ អ្នកគប្បីឡើងកាន់វេជយន្តរថដែលទឹមដោយសេះ ១០០០ ទៅកាន់ទេវលោកចុះ ហើយយាងត្រឡប់ ។ កាលនោះទេពធីតាទាំងឡាយបានទូលសួរសក្កទេវរាជដែលយាងមកដល់ប្រថាប់គង់លើបណ្ឌុកម្ពលសិលា

អាសនៈថា បពិត្រទេវរាជ ទ្រង់យាងមកអំពីទីណា សក្កៈត្រាស់ហេតុនោះ ដល់ពួកទេពធីតាដោយពិស្តារហើយ ពណ៌នាសីលនិងគុណរបស់ព្រះពោធិ-សត្វ ។ ពួកទេពធីតាក្រាបទូលថា បពិត្រទេវរាជ ពួកខ្ញុំក៏ប្រាថ្នានឹងឃើញលោកអាចារ្យ សូមទ្រង់នាំមកទីនេះចុះ សក្កទេវរាជហៅមាតលិទេវបុត្តមកត្រាស់ថា នែបា ទេពអប្សរប្រាថ្នាឃើញគុត្តិលគន្ធព្វ ចូរអ្នកឲ្យគុត្តិលគន្ធព្វអង្គុយលើវេជយន្តរថនាំមកចុះ ។ មាតលិទេវបុត្តទទួលទេវឱង្ការទៅនាំព្រះពោធិសត្វមកហើយ ។ សក្កទេវរាជ ទ្រង់ត្រេកអរជាមួយព្រះពោធិសត្វត្រាស់ថា លោកអាចារ្យ ពួកទេពកញ្ញាប្រាថ្នានឹងស្តាប់ការលេងភ្លេងរបស់អ្នក ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រទេវរាជ ខ្ញុំឈ្មោះថាជាគន្ធព្វអាស្រ័យសិប្បៈចិញ្ចឹមជីវិត ទាល់តែបានទ្រនឹបទើបលេង ។ សក្កទេវរាជត្រាស់ថា ចូរលេងពិណាចុះ ខ្ញុំនឹងឲ្យទ្រនឹបដល់អ្នក ។ ព្រះពោធិសត្វក្រាបទូលថា ខ្ញុំមិនត្រូវការទ្រនឹបដទៃ តែសូមទេពធីតាទាំងនេះប្រាប់កល្យាណកម្មរបស់ខ្លួនដល់ខ្ញុំចុះ បើយ៉ាងនេះខ្ញុំនឹងលេង ។ លំដាប់នោះទេពធីតាទាំងឡាយពោលនឹងព្រះពោធិសត្វថា ពួកខ្ញុំនឹងប្រាប់កល្យាណកម្មដែលធ្វើទុកដល់អ្នកក្នុងកាលជាក្រោយ សូមលោកអាចារ្យលេងពិណាសិនចុះ ។ ព្រះពោធិសត្វលេងភ្លេងដល់ទេវតាទាំងឡាយអស់ ៧ ថ្ងៃ សំឡេងពិណានោះពីរោះក្រៃលែងជាងពិណាទិព្វរបស់គន្ធព្វ ។ លុះគ្រប់ ៧ ថ្ងៃទើបព្រះពោធិសត្វសួរទេពធីតាទាំងឡាយដល់កល្យាណកម្ម ។

ទេពធីតាមួយរូបបានប្រគេនសំពត់យ៉ាងល្អ ដល់ភិក្ខុមួយរូប ក្នុងសាសនា

របស់ព្រះកស្សបសម្ពុទ្ធ បានកើតមកជាបាទបរិចារិការបស់សក្កទេវរាជមានទេពអប្សរ ១០០០ ជាបរិវារ ។ ទើបព្រះពោធិសត្វសួរទេពកញ្ញាដែលទ្រទ្រង់ពស្ត្រាភរណៈដ៏ប្រសើរថា ក្នុងភពមុននាងធ្វើកម្មអ្វីទុក ។ អាការដែលព្រះពោធិសត្វសួរនិងទេពកញ្ញាឆ្លើយនោះមានក្នុងវិមានវត្ថុនោះឯង ។ សេចក្តីក្នុងវិមានវត្ថុនោះព្រះពោធិសត្វសួរថា

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួង
ឲ្យភ្លឺដូចផ្កាយព្រឹក សម្បុររបស់នាងបែបនោះ តើសម្រេច
ដោយបុណ្យដូចម្តេច ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈ
ទាំងឡាយណានីមួយជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង
ដល់នាងផង តើដោយហេតុដូចម្តេច ។

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលកើតជាមនុស្សតើបានធ្វើបុណ្យដូចម្តេច នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់
សព្វទិស តើដោយបុណ្យដូចម្តេច ។

ទេពធីតានោះឆ្លើយថា

នារីឲ្យនូវសំពត់ដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រី
ទាំងឡាយ នារីនោះជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់
ទើបទៅកាន់ឋានមានវិមានជាដើម បាននូវរបស់ទិព្វជាទីគាប់
ចិត្តយ៉ាងនេះ សូមលោករមិលមើលនូវវិមានរបស់ខ្ញុំនោះចុះ

ខ្ញុំជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ ។

ព្រោះហេតុនោះបានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ ក៏ភ្លឺច្បាស់សព្វទិស ដូច្នេះ ។

ទេពធីតាមួយអង្គទៀត បានឲ្យនូវផ្កាដ៏ឧត្តមចំពោះភិក្ខុ អ្នកត្រាច់បិណ្ឌបាតជាវត្តមួយរូប ។ ទេពធីតាមួយអង្គទៀតកាលគេប្រាប់ថា សូមអ្នកទាំងឡាយប្រគេនគ្រឿងក្រអូបសម្រាប់ប្រោះព្រំចេតិយចុះ បានប្រគេនគ្រឿងក្រអូបដ៏ឧត្តម ។ ទេពធីតាមួយអង្គទៀតបានប្រគេនផ្លែឈើមានរសដ៏ឧត្តម ។ ទេពធីតាមួយអង្គទៀត បានប្រគេនអាហារមានរសដ៏ឧត្តម ។ ទេពធីតាមួយអង្គទៀតបានប្រគេនគ្រឿងប្រោះព្រំមានក្លិនក្រអូបលើស្តូបនៃព្រះមានព្រះភាគទ្រង់ព្រះនាមកស្សបៈ ។ ទេពធីតាមួយអង្គទៀត បានឃើញនូវពួកភិក្ខុនិងពួកភិក្ខុនីដើរទៅកាន់ផ្លូវបានស្តាប់ធម៌របស់ភិក្ខុនិងភិក្ខុនីទាំងឡាយនោះហើយរក្សាឧបោសថអស់មួយថ្ងៃ ។ ទេពធីតាមួយអង្គទៀត ឈរក្នុងទឹកមានចិត្តជ្រះថ្លាបានប្រគេនទឹកដល់ភិក្ខុអ្នកឆាន់ចង្ហាន់ក្នុងទូក ។ ទេពធីតាមួយអង្គទៀត កាលនៅគ្រប់គ្រងផ្ទះ មិនច្រើនទៅដោយសេចក្តីក្រោធ ។ ទេពធីតាមួយអង្គទៀត មិនមានសេចក្តីប្រណែន បានបម្រើម្តាយក្មេក និងឪពុកក្មេកដែលកាចផង ខឹងច្រើនផង អាក្រក់ផង បែងចំណែកដែលខ្លួនបានចេញចែកចាយជាមុនទើបបរិភោគទាំងជាអ្នកមិនប្រមាទក្នុងសីលរបស់ខ្លួន ។ ទេពធីតាមួយអង្គទៀត

ជាទាសីធ្វើការបម្រើជនដទៃ ជាអ្នកមិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ជាស្ត្រីមិនមានសេចក្តីក្រោធ មិនមើលងាយគេ ជាអ្នកចែករំលែកនូវចំណែករបស់ខ្លួនដល់ជនអ្នកត្រូវការ ទើបបានមកកើតជាបាទបរិចារិកានៃសក្កទេវរាជ ។ សេចក្តីទាំងអស់នេះមានក្នុងគុត្តិលវិមានវត្ថុ ។ ទេពធីតា ៣៧ អង្គបានធ្វើកម្មណាទុកទើបបានមកកើតក្នុងទេវលោកទាំងអស់ ព្រះពោធិសត្វសាកសួរបានពោលគាថាទាំងឡាយ សម្តែងកម្មដែលខ្លួនបានធ្វើទុក ព្រះពោធិសត្វបានស្តាប់ពាក្យនោះហើយពោលថា ជាលាភរបស់អញហ្ន៎ អញបានល្អហើយហ្ន៎ អញមកនេះបានស្តាប់សម្បត្តិដែលបានមកដោយកម្មមានប្រមាណតិច តាំងអំពីនេះទៅអញត្រឡប់ទៅកាន់មនុស្សលោកហើយនឹងធ្វើតែកុសលកម្មមានទានជាដើមប៉ុណ្ណោះបានបន្លឺឧទានដូច្នេះថា

ឱហ្ន៎ ដំណើរមកនៃអញក្នុងថ្ងៃនេះជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អណាស់ ការក្រោកឡើងអំពីដំណេកល្អណាស់ ព្រោះអញបានឃើញពួកទេវតាជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា អាត្មាអញនោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ នឹងបានធ្វើកុសលច្រើនដោយការឲ្យទានផង ដោយការប្រព្រឹត្តិស្មើផង ដោយការសង្រួមផង ដោយការទូន្មានផង អ្នកផងទៅក្នុងទីណាហើយមិនសោយសោក អាត្មាអញនោះនឹងទៅក្នុងទីនោះដែរ[១]ដូច្នេះ ។

---

១-បិ.៥៥ ទំ.៧១ ។

លុះគ្រប់ ៧ ថ្ងៃ សក្កទេវរាជទ្រង់ត្រាស់ឲ្យមាតលិទេវសារថីនាំព្រះ-ពោធិសត្វដែលអង្គុយលើរថមកកាន់នគរពារាណសីវិញ ។ ព្រះពោធិសត្វកាលត្រឡប់មកដល់នគរពារាណសីហើយ បានតំណាលដល់ហេតុការណ៍ដែលខ្លួនបានឃើញ ក្នុងទេវលោកឲ្យពួកមនុស្សស្តាប់ តាំងអំពីនោះមកពួកមនុស្សទាំងនោះក៏ដល់នូវភាពឧស្សាហ៍ធ្វើនូវបុណ្យ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា មុសិលៈក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ សក្ក-ទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ ចំណែកគុត្តិលគន្ធព្វក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គុត្តិលជាតក ចប់

## វិគតិច្ឆជាតក

[ ៣៣៨ ] ( តាបសពោធិសត្វពោលថា ) បុគ្គលឃើញនូវរបស់ណា មិនប្រាថ្នានូវរបស់នោះ មួយទៀតមិនឃើញនូវរបស់ណាចង់បានរបស់នោះ យើងសំគាល់ថា បុគ្គលនោះនឹងត្រាច់ទៅ ( ក្នុងសង្សារ ) អស់កាលយូរ ព្រោះថា បុគ្គលនោះប្រាថ្នារបស់ណាមិនបាននូវរបស់នោះ ។

[ ៣៣៩ ] ( បុគ្គលបាននូវរបស់ណា ) មិនត្រេកអរនឹងរបស់នោះ ប្រាថ្នាសម្បត្តិណាមើលងាយនូវសម្បត្តិដែលបានហើយនោះព្រោះថា សេចក្តីប្រាថ្នាជាជំណើររកទីបំផុតគ្មាន យើងសូមធ្វើនមស្ការចំពោះពួកបណ្ឌិតដែលមានសេចក្តីប្រាថ្នាទៅប្រាសហើយ ។

**ចប់ វិគតិច្ឆជាតកទី ៤ ។**

## អដ្ឋកថា
## វិគតិច្ឆជាតក

[ ៣៣៨-៣៣៩ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបលាយិបរិព្វាជកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យំ បស្សតិ ន តំ ឥច្ឆតិ** ដូច្នេះជាដើម ។

បានឮថា បរិព្វាជកនោះមិនបាននូវចម្លើយក្នុងសកលជម្ពូទ្វីប ទើបមកកាន់ក្រុងសាវត្ថីសួរថា អ្នកណាហ៊ានលើកវាទៈជាមួយយើង បានឮថា ព្រះសម្មាសម្ពុទ្ធទ្រង់អាចទើបចោមរោមដោយមហាជន នាំគ្នាទៅកាន់វត្តជេតពន

ទូលសួរបញ្ហានឹងព្រះសាស្តាដែលកំពុងសម្តែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ។ លំដាប់នោះព្រះសាស្តាទ្រង់ឆ្លើយបញ្ហាដល់បរិព្វាជកនោះ ហើយត្រាស់សួរថា អ្វីឈ្មោះថា ១ បរិព្វាជកនោះមិនអាចឆ្លើយបានទើបក្រោកគេចទៅ បរិស័ទដែលអង្គុយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បរិព្វាជកត្រូវទ្រង់សង្កត់សង្កិនដោយបញ្ហា ១ ប៉ុណ្ណោះ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសកឧបាសិកាទាំងឡាយ តថាគតមិនមែនញាំញីបរិព្វាជកដោយបញ្ហា ១ ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនតថាគតក៏សង្កត់សង្កិនបានដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងដែនកាសី កាលចម្រើនវ័យហើយលះកាមចេញបួសជាឥសីក្នុងហិមវន្តប្បទេសអស់កាលដ៏យូរ ។ តមកព្រះ-ពោធិសត្វចុះអំពីភ្នំ អាស្រ័យភូមិមួយ ស្នាក់នៅក្នុងបណ្ណសាលាក្បែរស្ទឹងដែលមានទឹកវល់ ។

សម័យនោះបរិព្វាជកម្នាក់មិនបានទូវការលើកវាទៈក្នុងសកលជម្ពូទ្វីប ទើបទៅដល់តំបន់នោះសួរថា មាននរណាហ្នឹងដែលអាចលើកវាទៈជាមួយនឹងយើងបាន ដឹងថាមាន ព្រោះបានស្តាប់ដល់ភាពអង់អាចរបស់ព្រះពោធិសត្វ ទើបចោមរោមដោយមហាជនទៅកាន់លំនៅរបស់ព្រះពោធិសត្វនោះ ធ្វើបដិ-សណ្ឋារៈហើយអង្គុយ ។ គ្រានោះ ព្រះពោធិសត្វសួរបរិព្វាជកនោះថា អ្នកនឹងផឹកទឹកស្ទឹងគង្គាមានពណ៌និងក្លិនដែលគួរឲ្យចង់ផឹកដែរឬទេ បរិព្វាជកកាល

នឹងលេងវោហារទើបពោលថា អ្វីគឺគន្ធា គន្ធាខ្សាច់ គន្ធាទឹក គន្ធាត្រើយអាយ ឬគន្ធាត្រើយនាយ ។ ព្រះពោធិសត្វពោលថា នែបរិព្វាជក អ្នកញែកទឹកជាមួយខ្សាច់និងត្រើយអាយ ត្រើយនាយចេញហើយនឹងបានគន្ធាអំពីទីណា ។ បរិព្វាជកអស់បដិភាណក្រោកគេចទៅ ។ កាលបរិព្វាជកគេចទៅព្រះពោធិ-សត្វកាលនឹងសម្តែងធម៌ដល់បរិស័ទដែលអង្គុយ បានពោលគាថាទាំងនេះថា

បុគ្គលឃើញនូវរបស់ណាមិនប្រាថ្នានូវរបស់នោះ មួយទៀត
មិនឃើញនូវរបស់ណាចង់បានរបស់នោះ យើងសំគាល់ថា
បុគ្គលនោះនឹងត្រាច់ទៅ ( ក្នុងសង្សារ ) អស់កាលយូរព្រោះ
ថា បុគ្គលនោះប្រាថ្នារបស់ណាមិនបាននូវរបស់នោះ ។

( បុគ្គលបាននូវរបស់ណា ) មិនត្រេកអរនឹងរបស់នោះ
ប្រាថ្នាសម្បត្តិណាមើលងាយនូវសម្បត្តិ ដែលបានហើយនោះ
ព្រោះថា សេចក្តីប្រាថ្នាជាដំណើររកទីបំផុតគ្មាន យើងសូមធ្វើ
នមស្ការចំពោះពួកបណ្ឌិត ដែលមានសេចក្តីប្រាថ្នាទៅប្រាស
ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ បស្សតិ** សេចក្តីថា បុគ្គលឃើញទឹកជាដើមក៏មិនប្រាថ្នាទឹកនោះថាជាគន្ធា ។ បទថា **យញ្ច ន បស្សតិ** សេចក្តីថា បុគ្គលមិនឃើញគន្ធាដែលមិនមានទឹកជាដើម សេចក្តីថា នៅប្រាថ្នាគន្ធានោះ ។ បទថា **មញ្ញាមិ ចិរំ ចរិស្សតិ** សេចក្តីថា ខ្ញុំយល់យ៉ាងនេះថា បរិព្វាជកនេះ ស្វែងរកគន្ធាបែបនេះនឹងត្រាច់ទៅទៀតអស់កាលយូរ ឬម្យ៉ាង

ទៀតការស្វែងរកខ្លួនដែលផុតអំពីរូបជាដើមដូចស្វែងរកគន្លាដែលមិនមានទឹកជាដើមដូច្នោះ នឹងត្រាច់ទៅក្នុងសង្សារអស់កាលយូរ ។ បទថា **ន ហិ តំ លច្ឆតិ** សេចក្តីថា សូម្បីត្រាច់ទៅអស់កាលយូរក៏មិនបានគន្លាឬខ្លួនតាមប្រាថ្នា ។ បទថា **យំ លភតិ** សេចក្តីថា កាលបានទឹកជាដើម ឬរូបជាដើមក៏រមែងមិនពេញចិត្ត ( ក្នុង ) ទឹកឬរូបនោះ ។ បទថា **យំ បត្ថេតិ លទ្ធំ ហីលេតិ** សេចក្តីថា កាលមិនពេញចិត្តក្នុងវត្ថុដែលបានយ៉ាងនេះប្រាថ្នាសម្បត្តិណាមួយ លុះបានហើយរមែងមើលងាយ មើលថោកដោយគិតថានឹងមានប្រយោជន៍អ្វីដោយសម្បត្តិនេះ ។ បទថា **ឥច្ឆា ហិ អនន្តគោចរា** សេចក្តីថា តណ្ហាដែលឈ្មោះថា ការប្រាថ្នានេះមានអារម្មណ៍មិនមានទីបំផុតព្រោះត្រូវមើលងាយក្នុងវត្ថុដែលបានហើយ ទៅប្រាថ្នាអារម្មណ៍ដទៃៗ ។ បទថា **វិគតិច្ឆានំ នមោ ករោមសេ** សេចក្តីថា ហេតុនោះបណ្ឌិតពួកណាមានព្រះពុទ្ធជាដើម ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា យើងទាំងឡាយសូមធ្វើនូវការគោរព ឱនលំទោនលោកអ្នកដែលជាបណ្ឌិតទាំងនោះដូច្នេះ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា បរិព្វាជកក្នុងកាលនោះបានមកជាបរិព្វាជកក្នុងកាលឥឡូវនេះចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

### អដ្ឋកថា វិគតិច្ឆជាតក ចប់

# មូលបរិយាយជាតក

[ ៣៨០ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វសួរថា ) កាលរមែងស៊ីនូវពួកសត្វទាំងអស់ព្រមទាំងខ្លួនឯង ចំណែកសត្វណាជាអ្នកស៊ីនូវកាល សត្វនោះឈ្មោះថា ដុតនូវតណ្ហាដែលជាធម្មជាតិដុតសត្វ ។

[ ៣៨១ ] ( ព្រះពោធិសត្វតិះដៀលថា ) ក្បាលនរជនទាំងឡាយដ៏ច្រើន ក្បាលទាំងនោះមានរោមផង ធំផង គ្របនៅលើក បណ្ដាមនុស្សទាំងអម្បាលនេះគង់មានមនុស្សណាមួយដែលមានប្រាជ្ញាមិនខាន ។

**ចប់ មូលបរិយាយជាតក ទី ៥ ។**

## អដ្ឋកថា
## មូលបរិយាយជាតក

[ ៣៨០-៣៨១ ] ព្រះសាស្ដាកាលគង់នៅក្នុងសុភគវ័ន អាស្រ័យឧក្កដ្ឋជានី ទ្រង់ប្រារព្ធមូលបរិយាយសូត្រ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កាលោ ឃសតិ ភូតានិ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះមានព្រាហ្មណ៍ ៥០០ ចប់ត្រៃវេទហើយចេញបួសក្នុងសាសានា រៀនព្រះត្រៃបិដក ជាអ្នកស្រវឹងដោយមានះគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់ចេះព្រះត្រៃបិដក សូម្បីយើងក៏ចេះព្រះត្រៃបិដក កាលបើដូច្នេះ យើងនឹងព្រះសម្មាសម្ពុទ្ធនឹងផ្សេងគ្នាដូចម្ដេច ដូច្នេះទើបមិនទៅគាល់ព្រះសម្ពុទ្ធតាំងខ្លួនជាបដិបក្ខ ។ ថ្ងៃមួយព្រះសាស្ដាកាលភិក្ខុទាំងនោះប្រជុំគ្នា

ក្នុងសម្នាក់របស់ព្រះអង្គ ត្រាស់មូលបរិយាយសូត្រប្រដាប់ដោយភូមិ ៨ ភិក្ខុទាំងនោះកំណត់អ្វីមិនបានទើបមានការគិតថា ពួកយើងតម្កើងខ្លួនថា មិនមាននរណាឈ្លាសស្មើពួកយើងតែឥឡូវនេះពួកយើងមិនដឹងអ្វីសោះឈ្មោះថាអ្នកឈ្លាសដូចព្រះសម្ពុទ្ធមិនមាន ឈ្មោះថាពុទ្ធគុណគួរអស្ចារ្យពេក ។ តាំងអំពីនោះមកភិក្ខុទាំងនោះក៏អស់នូវមានះអស់នូវការវង្វេង ដូចពស់ពិសដែលដកចង្កូមហើយដូច្នោះ ។

ព្រះសាស្តាគង់នៅក្នុងឧក្កដ្ឋជានីតាមផាសុក ហើយយាងទៅកាន់ក្រុងវេសាលី ត្រាស់គោតមកសូត្រត្រង់គោតមចេតិយ ។ លោកធាតុមួយម៉ឺនញាប់ញ័រហើយភិក្ខុទាំងនោះស្តាប់គោតមសូត្រនោះហើយបានសម្រេចអរហត្ត ។ កាលចប់មូលបរិយាយសូត្រ ព្រះសាស្តានៅគង់នៅក្នុងឧក្កដ្ឋជានីនោះឯង ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ពុទ្ធានុភាពគួរអស្ចារ្យពេក ព្រះមានព្រះភាគទ្រង់ធ្វើឲ្យភិក្ខុទាំងនោះដែលជាព្រាហ្មណ៍ចេញបួស ស្រវឹងដោយការតម្កើងខ្លួនយ៉ាងនេះអស់នូវការតម្កើងខ្លួន ដោយមូលបរិយាយទេសនា ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន តថាគតក៏បានធ្វើភិក្ខុទាំងនោះដែលមានក្បាលរឹងដោយការតម្កើងខ្លួនឲ្យអស់មានះ ហើយទ្រង់

នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ កាលចម្រើនវ័យសម្រេចត្រៃវេទបាន ជាអាចារ្យទិសាបាមោក្ខ បង្រៀនមន្តដល់មាណព ៥០០ ។ មាណព ៥០០ នោះរៀនចប់សិប្បៈ ធ្ងន់នូវការប្រឡងក្នុងសិប្បៈទាំងឡាយហើយ កើតនូវមានះ តម្កើងខ្លួនថា ពួកយើងដឹងប៉ុនណា អាចារ្យក៏ដឹងប៉ុណ្ណោះដូចគ្នា មិនមានការ ពិសេសជាងគ្នា ដូច្នេះមិនទៅកាន់សម្នាក់អាចារ្យមិនធ្វើវត្តបដិបត្តិ ។ ថ្ងៃមួយ កាលអាចារ្យអង្គុយត្រង់ដើមពុទ្រា ពួកមាណពទាំងនោះ បំណងនឹងមើលងាយ អាចារ្យទើបយកក្រចកគោះដើមពុទ្រាពោលថា ដើមឈើនេះមិនមានខ្លឹម ព្រះពោធិសត្វដឹងថាត្រូវមើលងាយ ទើបពោលនឹងអន្តេវាសិកថា ខ្ញុំនឹងសួរ បញ្ហាមួយដល់ពួកអ្នក ។ មាណពទាំងនោះត្រេកអរពោលថា សូមសួរមក ចុះ ពួកខ្ញុំនឹងដោះកាលអាចារ្យសួរបញ្ហាបានពោលគាថាទីមួយថា

> កាលរមែងស៊ីនូវពួកសត្វទាំងអស់ ព្រមទាំងខ្លួនឯង ចំណែក
> សត្វណាជាអ្នកស៊ីនូវកាលសត្វនោះឈ្មោះថា ដុតនូវតណ្ហា
> ដែលជាធម្មជាតិដុតសត្វ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាលោ** បានដល់ ពេលជាដើមដូចជាពេល មុនអាហារ ក្រោយអាហារ ។ បទថា **ភូតានិ** នេះជាឈ្មោះរបស់សត្វ កាលមិនបានដកស្បែកនិងសាច់ជាដើមរបស់សត្វទៅស៊ីតែញ៉ាំងអាយុ ពណ៌ សម្បុរនិងកម្លាំងរបស់សត្វទាំងនោះឲ្យអស់ទៅ ញ៉ាំញីវ័យកំលោះក្រមុំធ្វើនូវ

ការមិនមានរោគឲ្យវិនាសហៅថា ស៊ីសត្វ គឺទំពាស៊ីសត្វ ។ កាលដែលស៊ីសត្វយ៉ាងនេះ មិនមានវៀរបុគ្គលណាមួយរមែងស៊ីទាំងអស់ ។ ម្យ៉ាងទៀត មិនមែនស៊ីតែសត្វទាំងឡាយប៉ុណ្ណោះទេ រមែងស៊ីខ្លួនឯងដោយកាលមុនអាហារ រមែងមិនសល់ពេលក្រោយអាហារ ។ ក្នុងរឿងកាលក្រោយអាហារជាដើម ក៏ន័យដូចគ្នា ។ បទថា **យោ ច កាលឃសោ ភូតោ** ជាពាក្យហៅព្រះខីណាស្រព ។ ពិតហើយ ព្រះខីណាស្រពនោះ ហៅថាជាអ្នកស៊ីកាល ព្រោះញ៉ាំងកាលបដិសន្ធិឲ្យអស់ដោយអរិយមគ្គ ។ បទថា **ស ភូតបចនឹ បចិ** សេចក្តីថា ព្រះខីណាស្រពនោះដុត គឺធ្វើឲ្យឆេះជាផេះនូវតណ្ហាដែលដុតសត្វក្នុងអបាយដោយភ្លើង គឺញាណ ព្រោះហេតុនោះទើបលោកហៅថា ឈ្មោះថា ដុតនូវតណ្ហាដែលជាធម្មជាតិដុតសត្វដូច្នេះ ។ បាលីថា **បជនឹ** ក៏មាន ។ អធិប្បាយថា សត្វដែលកើតហើយ គឺកើតឡើងហើយ ។

ពួកមាណពទាំងនោះស្តាប់បញ្ហានេះហើយមិនមានអ្នកអាចដឹងបាន សូម្បីតែម្នាក់ ។ លំដាប់នោះទើបព្រះពោធិសត្វពោលនឹងមាណពទាំងនោះថា ពួកអ្នកកុំយល់ថា បញ្ហានេះមាននៅក្នុងត្រៃវេទ ពួកអ្នកសម្គាល់ថា អាចារ្យដឹងវត្ថុណាអញក៏ដឹងវត្ថុទាំងអស់នោះទើបប្រៀបយើងដូចគ្នានឹងដើមពុទ្រា ពួកអ្នកមិនបានដឹងថា យើងដឹងវត្ថុដែលពួកអ្នកមិនដឹងជាច្រើនទៀត ទៅចុះយើងឲ្យពេល ៧ ថ្ងៃ ចូរនាំគ្នាគិតបញ្ហានេះតាមកាលកំណត់ ។ មាណពទាំងនោះថ្វាយបង្គំព្រះពោធិសត្វហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួន សូម្បីនាំគ្នាគិតអស់ ៧ ថ្ងៃ ក៏មិនបានឃើញទីបំផុតមិនបានឃើញកំណួចនៃបញ្ហា ។ ក្នុងថ្ងៃ

ទី ៧ ទើបនាំគ្នាមករកអាចារ្យ ថ្វាយបង្គំហើយអង្គុយ កាលអាចារ្យសួរថា ពួកអ្នកមានមុខរីករាយដឹងបញ្ហានេះឬ ក៏ពោលថា មិនទាន់ដឹងទេ ។ ព្រះពោធិសត្វកាលតិះដៀលមាណពទាំងនោះទើបពោលគាថាទីពីរថា

ក្បាលនរជនទាំងឡាយដ៏ច្រើន ក្បាលទាំងនោះមានរោមផង
ធំផង គ្របនៅលើក បណ្ដាមនុស្សទាំងអម្បាលនេះគង់មាន
មនុស្សណាមួយដែលមានប្រាជ្ញាមិនខាន ដូច្នេះ ។

សេចក្ដីរបស់គាថានោះថា ក្បាលប្រាកដមានច្រើន ក្បាលទាំងនោះមានសក់ខ្មៅគ្របដល់ក យកដៃចាប់មើលមិនដូចផ្លែត្នោត បុគ្គលទាំងនោះមិនប្លែកគ្នាដោយធម៌ទាំងនោះឡើយ ។ ពាក្យថា **កោចិ នេវេត្ថ កណ្ណវា** នេះ ព្រះពោធិសត្វពោលសំដៅយកខ្លួន ។ បទថា **កណ្ណវា** គឺ អ្នកមានបញ្ញា ។ ឯរន្ធត្រចៀកមិនមានដល់បុគ្គលណាមួយក៏មិនមែន ។

ព្រះពោធិសត្វតិះដៀលពួកមាណពទាំងនោះថា ពួកអ្នកជាបុគ្គលល្ងង់មានតែរន្ធត្រចៀកប៉ុណ្ណោះមិនមានបញ្ញាដូច្នេះហើយទើបឆ្លើយបញ្ហា ។ មាណពទាំងនោះស្ដាប់ហើយពោលថា ធម្មតាអាចារ្យជាបុគ្គលធំក្រៃលែង គួរអស្ចារ្យ សូមខមាទោសអាចារ្យហើយក៏អស់នូវការតម្កើងខ្លួន ប្រណិប័តន៍ព្រះពោធិសត្វវិញ ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា មាណពទាំង ៥០០ ក្នុងកាលនោះបានមកជាភិក្ខុទាំងនេះក្នុងកាលឥឡូវនេះ ឯអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មូលបរិយាយជាតក ចប់**

## ពាលោវាទជាតក

[ ៣៤២ ] ( កុដុម្ពិកម្នាក់ពោលថា ) បុគ្គលអ្នកមិនសង្រួមប្រហារសត្វផង ធ្វើសត្វឲ្យលំបាកផង ធ្វើសត្វឲ្យស្លាប់ផង ហើយឲ្យទាន ( ដល់សមណៈណា ) សមណៈនោះកាលបរិភោគនូវភត្តបែបនេះឈ្មោះថា ប្រឡាក់ដោយបាបដែរ ។

[ ៣៤៣ ] ( ព្រះពោធិសត្វតបថា ) ប្រសិនបើបុគ្គលអ្នកមិនសង្រួមសូម្បីសម្លាប់នូវកូននិងប្រពន្ធហើយឲ្យទាន ( ដល់សមណៈណា ) សមណៈនោះជាអ្នកប្រកបដោយប្រាជ្ញា ទុកជាកាលបរិភោគ ក៏មិនប្រឡាក់ដោយបាបឡើយ ។

**ចប់ ពាលោវាទជាតក ទី ៦ ។**

## អដ្ឋកថា

## ពាលោវាទជាតក

[ ៣៤២-៣៤៣ ] ព្រះសាស្ដាកាលគង់នៅកូដាគារសាលា ទ្រង់យាងចូលទៅអាស្រ័យក្រុងវេសាលីទ្រង់ប្រារព្ធសីហសេនាបតី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ហន្ត្វា ឃត្វា វធិត្វា** ច ដូច្នេះជាដើម ។

មានសេចក្ដីសង្ខេបថា សីហសេនាបតីនោះ ដល់នូវព្រះមានព្រះភាគជាទីពឹងហើយនិមន្តទៅថ្វាយភត្តាហារ ចម្អិនដោយសាច់ ។ ពួកនិគ្រន្ថស្ដាប់ដំណឹងហើយមិនពេញចិត្ត ប្រាថ្នានឹងបៀតបៀនព្រះតថាគតទើបលើកទោស

ថា ព្រះសមណគោតមសោយសាច់ដែលគេឧទ្ទិសទាំងដឹងខ្លួន ។ ភិក្ខុទាំង ឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ និគណ្ឋនាដបុត្តនិង បរិស័ទដើរនិយាយផ្ទេសផ្តាសថា ព្រះសមណគោតម សោយសាច់ដែលគេ ឧទ្ទិសចំពោះទាំងដឹងខ្លួន ។ ព្រះសាស្តា ស្តាប់រឿងនោះហើយត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ និគណ្ឋនាដបុត្តនិន្ទាតថាគតព្រោះបរិភោគសាច់ដែលគេឧទ្ទិស ថ្វាយតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនសូម្បីក្នុងកាលមុនក៏បានតិះដៀល ហើយដូចគ្នា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ កាលចម្រើនវ័យហើយចេញបព្វជ្ជា ជាឥសី មកអំពីព្រៃហិមពាន្ត ដើម្បីសេពរសជូរប្រៃក្នុងនគរពារាណសី ។ ស្អែកឡើង ទើបត្រាច់ភិក្ខាចារក្នុងព្រះនគរ ។ កាលនោះកុដុម្ពិកៈម្នាក់គិតថា អញនឹងធ្វើតាបសឲ្យក្តៅក្រហាយទើបនិមន្តឲ្យចូលទៅកាន់ផ្ទះ និមន្តឲ្យអង្គុយ លើអាសនៈដែលក្រាលទុកហើយ អង្គាសដោយត្រីនិងសាច់ កាលស្រេច ភត្តកិច្ចហើយអង្គុយក្នុងចំណែកម្ខាងត្រាស់ថា សាច់នេះខ្ញុំសម្លាប់ចម្អិនជា អាហារចំពោះលោកម្ចាស់ដោយត្រង់ សូមអកុសលនេះ កុំមានដល់ខ្ញុំឡើយ សូមធ្លាក់ជារបស់លោកម្ចាស់ចុះហើយពោលគាថាទីមួយថា

បុគ្គលអ្នកមិនសង្រួម ប្រហារសត្វផង ធ្វើសត្វឲ្យលំបាកផង
ធ្វើសត្វឲ្យស្លាប់ផង ហើយឲ្យទាន ( ដល់សមណៈណា )
សមណៈនោះកាលបរិភោគនូវភត្តបែបនេះឈ្មោះថា ប្រឡាក់

ដោយបាបដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហន្ត្វា** សេចក្តីថា ប្រហារហើយ ។ បទថា **ឃត្វា** សេចក្តីថា ធ្វើឲ្យលំបាក ។ បទថា **វធិត្វា** សេចក្តីថា ធ្វើឲ្យស្លាប់ ។ បទថា **ទេតិ ទានំ អសញ្ញតោ** សេចក្តីថា ជាអ្នកមិនសង្រួមទ្រុស្តសីល ធ្វើយ៉ាងនេះហើយឲ្យទាន ។ បទថា **ឯទិសំ ភត្តំ ភុញ្ជមានោ សបាប-មុបលិម្បតិ** សេចក្តីថា សមណៈនោះបរិភោគភត្តដែលខ្ញុំធ្វើចំពោះលោកបែបនេះរមែងចូលទៅជាប់ក្នុងបាប គឺប្រកបដោយបាប ។

ព្រះពោធិសត្វស្តាប់ហើយទើបពោលគាថាទីពីរថា

ប្រសិនបើបុគ្គលអ្នកមិនសង្រួម សូម្បីសម្លាប់នូវកូននិងប្រពន្ធ
ហើយឲ្យទាន ( ដល់សមណៈណា ) សមណៈនោះជាអ្នក
ប្រកបដោយប្រាជ្ញា ទុកជាកាលបរិភោគក៏មិនប្រឡាក់ដោយ
បាបឡើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភុញ្ជមានោបិ សប្បញ្ញោ** សេចក្តីថា សាច់របស់អ្នកដទៃចូរលើកទុក លោកអ្នកមានបញ្ញាជាអ្នកដល់ព្រមដោយគុណមានខន្តិនិងមេត្តាជាដើមសូម្បីបរិភោគសាច់ ដែលបុគ្គលទ្រុស្តសីលសូម្បីសម្លាប់បុត្តភរិយាឲ្យ ( ទាន ) ហើយនោះរមែងមិនប្រឡាក់ដោយបាប ។

ព្រះពោធិសត្វកាលសម្តែងធម៌ដល់កុដុម្ពិកៈយ៉ាងនោះហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់

ប្រជុំជាតកថា កុដុម្ពិកៈក្នុងកាលនោះបានមកជានិគណ្ឋនាដបុត្តក្នុងកាលឥឡូវ
នេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ពាលោវាទជាតក ចប់

## ចានញ្ញលិជាតក

[ ៣៤៤ ] ( អាមាត្យពោធិសត្វសរសើរថា ) ព្រះរាជកុមារព្រះនាម បាទញ្ជលី រុងរឿងកន្លងនូវពួកយើងទាំងអស់គ្នាដោយប្រាជ្ញាពិតមែន ដូច្នោះ បានជាទ្រង់ពេបព្រះឱស្ឋ ទ្រង់ទតឃើញនូវហេតុដ៏ក្រៃលែងដោយពិត ។

[ ៣៤៥ ] ( ព្រះពោធិសត្វជៀលថា ) ព្រះរាជកុមារព្រះនាមបាទញ្ជលី នេះមិនទ្រង់ជ្រាបនូវសភាពជាធម៌ និងសភាពមិនមែនជាធម៌ផង នូវប្រយោជន៍ និងមិនមែនជាប្រយោជន៍ផង ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះ វៀរលែង តែការពេបនូវព្រះឱស្ឋចេញហើយទ្រង់មិនជ្រាបនូវហេតុតិចតួចឡើយ។

**ចប់ បាទញ្ជលិជាតក ទី ៧ ។**

## អដ្ឋកថា

## ចានញ្ញលិជាតក

[ ៣៤៤-៣៤៥ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ លោឡុយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អទ្ធា ចានញ្ញលី សព្វេ** ដូច្នេះជាដើម ។

ថ្ងៃមួយព្រះមហាសាវកទាំង ២ វិនិច្ឆ័យបញ្ហា ។ ភិក្ខុទាំងឡាយស្តាប់ បញ្ហាក៏សរសើរព្រះថេរៈទាំង ២ ។ ព្រះលោឡុទាយិត្ថេរអង្គុយក្នុងចន្លោះបរិ- ស័ទលូកមាត់ឡើងថា ព្រះមហាសាវកទាំងនេះ ចេះដឹងអ្វីបើប្រៀបធៀបនឹង យើង ព្រះថេរៈទាំង ២ ឃើញលោឡុទាយិត្ថេរនោះហើយក្រោកចាកអាសនៈ

ចៀសចេញទៅ ។ បរិស័ទក៏បែកខ្ញែកគ្នា ។ ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ លោទុ្បទាយីលួកមាត់ឡើងតិះដៀលអគ្គសាវ័កទាំង ២ ។ ព្រះសាស្ដាយាងមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនលោកទុ្បទាយីក៏មិនចេះដឹងអ្វីក្រៃលែងជាងនោះក្រៅអំពីជំទាស់ប៉ុណ្ណោះ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាអាមាត្យអ្នកទូន្មានអត្ថនិងធម៌របស់ព្រះអង្គ ។ ព្រះរាជានោះមានព្រះឱរសព្រះនាមថា បាទញ្ជលី មានព្រះហឫទ័យឡេះឡោះ ច្បិចច្បើម តមកព្រះរាជាក៏សោយទិវង្គត ពួកអាមាត្យរៀបចំថ្វាយព្រះភ្លើងហើយប្រឹក្សាគ្នាថា ពួកយើងនឹងអភិសេកបាទញ្ជលីរាជបុត្តឲ្យគ្រងរាជសម្បត្តិ ។ តែព្រះពោធិសត្វពោលថា ព្រះរាជកុមារនេះមានព្រះហឫទ័យឡេះឡោះមិនស៊ប់សួន ពួកយើងគួរសាកល្បងមើលសិនហើយសឹមអភិសេកព្រះរាជកុមារនោះ ។ ទើបពួកអាមាត្យត្រៀមនូវការកាត់ក្ដី ឲ្យព្រះរាជកុមារប្រថាប់គង់ក្នុងទីជិតការកាត់ក្ដី ក៏ធ្វើជាកាត់មិនត្រឹមត្រូវកាត់ឲ្យបុគ្គលដែលមិនមែនម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យហើយទូលព្រះរាជកុមារថា បពិត្រព្រះរាជកុមារ ពួកទូលព្រះបង្គំកាត់សេចក្ដីត្រឹមត្រូវតាមធម៌ដែរឬទេ ព្រះរាជកុមារពេបព្រះឱស្ឋ ព្រះពោធិសត្វសម្គាល់ថា ប្រហែលជាព្រះរាជកុមារទ្រង់ឆ្លៀវឆ្លាសទ្រង់ប្រហែលជាជ្រាបថា កាត់សេចក្ដីមិនត្រឹមត្រូវទើបពោលគាថាទីមួយថា

ព្រះរាជកុមារព្រះនាមបាទញ្ជលី រុងរឿងកន្លងនូវពួកយើងទាំង
អស់គ្នាដោយប្រាជ្ញាពិតមែន ដូច្នោះបានជាទ្រង់ពេបព្រះឱស្ឋ
ទ្រង់ទតឃើញនូវហេតុដ៏ក្រៃលែងដោយពិត ដូច្នេះ ។

អធិប្បាយក្នុងគាថានោះថា បាទញ្ជលិរាជកុមារ រមែងរុងរឿងជាងយើង ទាំងអស់ដោយបញ្ញាពិតប្រាកដ កាលបើដូច្នោះរឿងអ្វីទ្រង់មិនពេបព្រះឱស្ឋ ទ្រង់ឃើញហេតុដទៃក្រៃលែងជាងនេះដោយពិត ។ ក្នុងថ្ងៃដទៃពួកអាមាត្យ ទាំងនោះត្រៀមនូវការកាត់សេចក្តី ហើយកាត់រឿងមួយទៀតប្រកបដោយធម៌ ហើយទូលសួរថា បពិត្រព្រះរាជកុមារ ទូលព្រះបង្គំ កាត់ក្តីត្រឹមត្រូវដែរឬទេ ព្រះរាជកុមារទ្រង់ពេបព្រះឱស្ឋដូចមុន ។ លំដាប់នោះទើបព្រះពោធិសត្វ ជ្រាបថា ព្រះរាជកុមារនេះល្ងង់ខ្លៅ ហើយពោលគាថាទីពីរថា

ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះមិនទ្រង់ជ្រាបនូវសភាពជា
ធម៌និងសភាពមិនមែនជាធម៌ផង នូវប្រយោជន៍និងមិនមែនជា
ប្រយោជន៍ផង ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះ វៀរលែង
តែការពេបនូវព្រះឱស្ឋចេញហើយ ទ្រង់មិនជ្រាបនូវហេតុតិច
តួចឡើយ ដូច្នេះ ។

ពួកអាមាត្យដឹងថា បាទញ្ជលិរាជកុមារទ្រង់ល្ងង់ខ្លៅ ទើបអភិសេកព្រះ ពោធិសត្វឲ្យឡើងគ្រងរាជសម្បត្តិ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំ ជាតកថា បាទញ្ជលិរាជកុមារក្នុងកាលនោះ បានមកជាលោឡុទាយីក្នុងកាល

ឥឡូវនេះ ឯអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បាទញ្ជលិជាតក ចប់

# កឹំសុកោបមជាតក

[ ៣៤៦ ] ( ព្រះរាជាពោលថា ) ដើមចារអ្នករាល់គ្នាបានឃើញហើយ អ្នកទាំងឡាយនៅសង្ស័យក្នុងដើមចានោះថាដូចម្តេចហ្ន៎ ដ្បិតអ្នកទាំងឡាយមិនបានសាកសួរនាយសារថីក្នុងទីទាំងពួងសោះ ។

[ ៣៤៧ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ធម៌ទាំងឡាយដែលពួកជនណាមិនបានដឹងហើយ ដោយញាណទាំងឡាយទាំងពួងយ៉ាងនេះ ពួកជននោះឯងរមែងសង្ស័យក្នុងធម៌ទាំងឡាយដូចជា ( ព្រះរាជបុត្តទាំង ៤ ព្រះអង្គ ) ជាបងប្អូននឹងគ្នាសង្ស័យក្នុងដើមចារដូច្នោះ ។

**ចប់ កឹំសុកោបមជាតក ទី ៨ ។**

## អដ្ឋកថា

## កឹំសុកោបមជាតក

[ ៣៤៦-៣៤៧ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកឹំសុកោបមសូត្រ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វេហិ កឹំសុកោ ទិដ្ឋោ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុ ៤ រូបចូលគាល់ព្រះតថាគតទូលសូមកម្មដ្ឋាន ព្រះសាស្តាទ្រង់ប្រាប់កម្មដ្ឋានដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះរៀនកម្មដ្ឋាន ទៅកាន់ទីសម្រាកពេលយប់និងពេលថ្ងៃ ។ ក្នុងភិក្ខុទាំងនោះភិក្ខុមួយរូបកំណត់ផស្សាយតនៈ ៦ សម្រេចអរហត្តហើយ ។ មួយរូបកំណត់ខន្ធ ៥ មួយរូបកំណត់

មហាភូតរូប ៤ មួយរូបកំណត់ធាតុ ១៨ ។ ភិក្ខុទាំងនោះក្រាបទូលគុណវិសេសដែលខ្លួនបានដល់ព្រះសាស្តា ។ បណ្តាភិក្ខុទាំងនោះមានភិក្ខុមួយរូបកើតបរិវិតក្កថា កម្មដ្ឋានទាំងនោះមានការប្លែកផ្សេងគ្នាតែភិក្ខុទាំងនោះដល់នូវព្រះនិព្វានដូចគ្នា ភិក្ខុទាំងអស់សម្រេចអរហត្តបានដូចម្តេចទើបទូលសួរព្រះសាស្តា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកក៏មិនខុសគ្នានឹងបងប្អូន ៤ នាក់ដែលឃើញដើមចារ ភិក្ខុទាំងឡាយទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់សម្តែងហេតុនេះដល់ខ្ញុំព្រះអង្គចុះ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីទ្រង់មានឱរស ៤ អង្គ ថ្ងៃមួយឱរស ៤ អង្គហៅសារថីមកត្រាស់ថា នែសម្លាញ់ ពួកយើងចង់ឃើញដើមចារចូរអ្នកបង្ហាញដើមចារឲ្យយើងមើលចុះ ។ សារថីទូលថា សាធុ ទូលព្រះបង្គំនឹងបង្ហាញតែមិនបង្ហាញដល់រាជបុត្តទាំង ៤ ព្រមគ្នា ឲ្យរាជបុត្តមួយអង្គប្រថាប់គង់លើរថទៅមុននាំទៅព្រៃហើយចង្អុលឲ្យមើលដើមចារក្នុងកាលជ្រុះស្លឹកថានេះគឺ ដើមចារ មួយអង្គទៀតឲ្យមើលក្នុងពេលដើមចារលាស់ត្រួយខ្ចី មួយអង្គទៀតឲ្យមើលក្នុងពេលចេញផ្កា មួយអង្គទៀតឲ្យមើលក្នុងពេលចេញផ្លែ ។ តមករាជបុត្តទាំង ៤ អង្គអង្គុយជួបជុំគ្នាទើបសាកសួរគ្នាថា ឈ្មោះថា ដើមចារដូចម្តេច មួយអង្គត្រាស់ថា ដូចដង្គត់ឈើភ្លើងឆេះ អង្គទី ២ ត្រាស់ថា ដូចដើមជ្រៃ អង្គទី ៣ ត្រាស់ថា ដូចដុំសាច់ អង្គទី ៤ ត្រាស់ថា ដូចដើមប្រេស ។ ទាំង ៤ អង្គមិនស្រប

តាមពាក្យនៃគ្នានឹងគ្នាទើបទៅគាល់ព្រះបិតាទូលសួរថា បពិត្របិតា ឈ្មោះថា ដើមចារដូចម្តេច កាលព្រះរាជាត្រាស់ថា ពួកអ្នកឃើញដូចម្តេចទើបក្រាបទូលព្រះរាជាតាមដែលប្រកែកគ្នា ។ ព្រះរាជាត្រាស់ថា ពួកបាទាំង ៤ មិនបានឃើញដើមចារស្រេចតែសារថីបង្ហាញដើមចារ ។ ពួកអ្នកមិនបានសាកសួរដើមចារក្នុងកាលនេះដើមចារដូចម្តេច ដោយហេតុនោះទើបសេចក្តីសង្ស័យកើតឡើងដល់បាហើយត្រាស់គាថាទីមួយថា

ដើមចារ អ្នករាល់គ្នាបានឃើញហើយ អ្នកទាំងឡាយនៅ
សង្ស័យក្នុងដើមចានោះថាដូចម្តេចហ្ន៎ ដ្បិតអ្នកទាំងឡាយមិន
បានសាកសួរនាយសារថីក្នុងទីទាំងពួងសោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ហិ សព្វេសុ ឋានេសុ សារថី បរិ-បុច្ឆិតោ** សេចក្តីថា ពួកអ្នកទាំងឡាយបានឃើញដើមចារហើយឬ ពួកអ្នកវិនិច្ឆ័យក្នុងដើមចារនោះហើយឬ ក្នុងទីដទៃដើមចារដូចម្តេច ពួកអ្នកមិនសាកសួរនាយសារថីក្នុងទីដទៃៗ ដោយហេតុនោះ ទើបសេចក្តីសង្ស័យកើតឡើងដល់ពួកអ្នក ។

ព្រះសាស្តាទ្រង់សម្តែងហេតុនេះហើយត្រាស់ថា នែភិក្ខុ ដូចបងប្អូនទាំង ៤ កើតសេចក្តីសង្ស័យក្នុងដើមចារព្រោះមិនបានសាកសួរឲ្យជិតដល់ យ៉ាងណា សូម្បីអ្នកញុំាងការសង្ស័យឲ្យកើតឡើងក្នុងធម៌នេះ ក៏យ៉ាងនោះ ដូចគ្នា ទ្រង់ត្រាស់ដឹងក្រៃលែងហើយបានត្រាស់គាថាទីពីរថា

ធម៌ទាំងឡាយដែលពួកជនណាមិនបានដឹងហើយដោយញាណ

ទាំងឡាយទាំងពួងយ៉ាងនេះ ពួកជននោះឯងរមែងសង្ស័យក្នុង
ធម៌ទាំងឡាយដូចជា ( ព្រះរាជបុត្តទាំង ៤ ព្រះអង្គ ) ជាបង
ប្អូននឹងគ្នាសង្ស័យក្នុងដើមចារដូច្នោះ ដូច្នេះ ។

អត្ថនៃគាថានោះថា ដូចបងប្អូនទាំងនោះសង្ស័យហើយ ព្រោះមិនឃើញដើមចារគ្រប់ឋានៈយ៉ាងណា ធម៌ទាំងពួងចែកប្រភេទជាផស្សៈ ៦ អាយតនៈ ១២ ( មហា ) ភូតនិងធាតុ ។ ជនពួកណាមិនបានឲ្យកើតដោយវិបស្សនាញាណទាំងពួង គឺមិនបានចាក់ធ្លុះព្រោះមិនទាន់បានសម្រេចសោតាបត្តិមគ្គ ជនទាំងនោះរមែងសង្ស័យក្នុងធម៌មានផស្សៈ ៦ និងអាយតនៈជាដើមដូចបងប្អូនទាំង ៤ សង្ស័យក្នុងដើមចារតែមួយដូច្នោះ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទក្រុងពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កឹសុកោបមជាតក ចប់

## សាលកជាតក

[ ៣៤៨ ] ( ហ្លួងពោលថា ) នែសាលកភទ្រៈ អ្នកជាក់ជាកូនប្រុសតែមួយ ( នៃយើង ) មួយទៀតអ្នកនឹងបានជាធំក្នុងត្រកូលរបស់យើង ចូរអ្នកចុះអំពីដើមឈើមកយើងនឹងទៅផ្ទះក្នុងកាលឥឡូវនេះ ។

[ ៣៤៩ ] ( ស្វាពោលតបថា ) ក្រែងអ្នកសម្គាល់ខ្ញុំថាជាសត្វមានហឫទ័យល្អ តែអ្នកបៀតបៀនខ្ញុំដោយបន្ទះឫស្សី ខ្ញុំត្រេកអរក្នុងព្រៃស្វាយដែលមានផ្លែទុំ អ្នកចូរទៅផ្ទះតាមសប្បាយចុះ ។

**ចប់ សាលកជាតក ទី ៩ ។**

## អដ្ឋកថា

## សាលកជាតក

[ ៣៤៨-៣៤៩ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាថេរៈមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឯកបុត្តកោ ភវិស្សសិ** ដូច្នេះជាដើម ។

បានឮថា ព្រះមហាថេរៈនោះបានឲ្យកុមារតូចបព្វជ្ជាហើយ ធ្វើឲ្យលំបាកក្នុងវត្តជេតពននោះ ។ សាមណេរនោះមិនអាចអត់ធន់សេចក្ដីលំបាកបានទើបសឹក ។ ព្រះថេរៈទៅលួងលោមកុមារតូចនោះថា នែកុមារតូច ចីវររបស់អ្នកគង់ជារបស់អ្នកដូចមុន បាត្រគង់ជារបស់អ្នក បាត្រនិងចីវរគង់ជារបស់អ្នក ចូរមកបព្វជ្ជាចុះ ។ កុមារតូចនោះសូម្បីពោលថា ខ្ញុំមិនបព្វជ្ជា ត្រូវព្រះ

ថេរៈល្អួងលោមរឿយៗក៏បួស កាលនោះ ព្រះថេរៈបានធ្វើឲ្យសាមណេរនោះលំបាកទៀត តាំងពីថ្ងៃដែលបួសមកសាមណេរអត់ធន់នឹងសេចក្តីលំបាកមិនបានទើបសឹកទៀត សូម្បីព្រះថេរៈល្អួងលោមច្រើនដង ច្រើនគ្រាក៏មិនព្រមបួសដោយពោលថា លោកឪមិនឃើញចិត្តខ្ញុំ លោកឪអត់ខ្ញុំមិនអាចរស់នៅបានឬ ទៅចុះលោកឪខ្ញុំមិនបួសទេ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភាថាអាវុសោទាំងឡាយ ទារកនោះចិត្តល្អពិតហ្ន៎ ជាប់អធ្យាស្រ័យរបស់ព្រះមហា-ថេរៈហើយទើបមិនបួស ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថាម្នាលភិក្ខុទាំងឡាយ ទារកនោះមិនមែនមានចិត្តល្អតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនក៏ចិត្តល្អ ឃើញទោសរបស់ព្រះថេរៈនោះតែម្តងប៉ុណ្ណោះមិនព្រមចូលជិតទៀត ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលកុដុម្ពិកៈ កាលចម្រើនវ័យហើយចិញ្ចឹមជីវិតដោយការជួញដូរស្រូវ មានគ្រូពស់ម្នាក់បង្ហាត់ស្វាមួយឲ្យកាន់ថ្នាំ ហើយឲ្យពស់សម្តែងកីឡាជាមួយស្វានោះចិញ្ចឹមជីវិត កាលមានការឃោសនាសម្តែងមហោស្រពត្រង់ក្រុងពារាណសី គ្រូពស់នោះបំណងនឹងមើលមហោស្រពទើបប្រគល់ស្វានោះទុកជាមួយឈ្មួញស្រូវនោះប្រាប់ថា អ្នកកុំប្រហែសក្នុងស្វានេះ កាលមើលមហោស្រពហើយក្នុងថ្ងៃទី ៧ ទើបទៅរកឈ្មួញសួរថា ស្វា

នៅឯណា ស្វាគ្រាន់តែឮសំឡេងម្ចាស់ប្រញាប់ចេញអំពីពានលក់ស្រូវ ។ លំដាប់នោះគ្រូពស់យកបន្ទះឫស្សីវាយខ្នងស្វា នាំទៅចងទុកក្នុងចំណែកម្ខាង ហើយត្រឡប់ទៅ ។ ស្វាដឹងថា ម្ចាស់ដេកលក់ទើបស្រាយខ្សែត្រង់ករត់ឡើងដើមស្វាយ ស៊ីផ្លែស្វាយទុំហើយចោលគ្រាប់ត្រង់ក្បាលគ្រូពស់ ។ គ្រូពស់ភ្ញាក់ឡើងឃើញស្វានោះហើយគិតថា អញនឹងលួងលោមស្វានោះដោយពាក្យពីរោះ ឲ្យវាចុះពីលើដើមឈើហើយចាប់វា កាលលួងលោមស្វានោះបានពោលគាថាទីមួយថា

នែសាលកវានរៈ អ្នកជាក់ជាកូនប្រុសតែមួយ ( នៃយើង )
មួយទៀតអ្នកនឹងបានជាធំក្នុងត្រកូលរបស់យើង ចូរអ្នកចុះអំពី
ដើមឈើមក យើងនឹងទៅផ្ទះក្នុងកាលឥឡូវនេះ ដូច្នេះ ។

អធិប្បាយសេចក្ដីគាថានោះថា អ្នកជាកូនតែមួយរបស់យើង អ្នកនឹងបានគ្រប់គ្រងសម្បត្តិក្នុងត្រកូលរបស់យើងចូរអ្នកចុះអំពីដើមឈើនោះមកយើងនាំគ្នាទៅកាន់ផ្ទះរបស់យើង ។ ស្វាបានស្ដាប់ដូច្នោះទើបពោលគាថាទីពីរថា

ក្រែងអ្នកសម្គាល់ខ្ញុំថាជាសត្វមានហឫទ័យល្អ តែអ្នកបៀតបៀន
ខ្ញុំដោយបន្ទះឫស្សី ខ្ញុំត្រេកអរក្នុងព្រៃស្វាយដែលមានផ្លែទុំ
អ្នកចូរទៅផ្ទះតាមសប្បាយចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆន្នុ មំ សុហទយោតិ មញ្ញសិ** សេចក្ដីថា អ្នកសម្គាល់ថាខ្ញុំជាសត្វមានចិត្តល្អមិនមែនឬ អធិប្បាយថា អ្នកសម្គាល់ថាស្វានេះជាសត្វចិត្តល្អ ។ បទថា **យញ្ច មំ ហនសិ វេឡុយដ្ឋិយា**

សេចក្តីថា លោកសម្តែងទុកដូច្នេះថា អ្នកមើលងាយខ្ញុំដោយហេតុណា អ្នកវាយខ្ញុំដោយចម្រៀកឫស្សីដោយហេតុណា ហេតុនោះទើបខ្ញុំមិនត្រឡប់ទៅ ។ កាលបើដូច្នោះ ទើបខ្ញុំពេញចិត្តក្នុងព្រៃស្ងាយនេះ សូមអ្នកត្រឡប់ទៅផ្ទះតាមសប្បាយចុះ ហើយលោតចូលព្រៃទៅ ។ គ្រូពស់មិនសប្បាយចិត្តបានត្រឡប់ទៅផ្ទះរបស់ខ្លួន ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះបានមកជាសាមណេរក្នុងកាលឥឡូវនេះ គ្រូពស់ក្នុងកាលនោះបានមកជាមហាថេរៈ ឯឈ្លួញលក់ស្រូវក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សាលកជាតក ចប់

# កបិជាតក

[ ៣៥០ ] ( តាបសកុមារពោលថា ) ឥសីអន្ធនេះត្រេកអរក្នុងការស្ងប់និងការសង្រួម លោកត្រូវភ័យអំពីរងាបៀតបៀនហើយ សូមឲ្យតាបសនេះចូលមកកាន់ផ្ទះនេះ ដើម្បីបន្ទោបង់នូវត្រជាក់និងសេចក្តីក្រវល់ក្រវាយចេញកុំឲ្យមានសេសសល់ឡើយ ។

[ ៣៥១ ] ( ពោធិសត្វពោលថា ) អ្នកនេះមិនមែនជាឥសី អ្នកត្រេកអរក្នុងការស្ងប់និងការសង្រួមទេ អ្នកនេះជាសត្វស្វា ជាសត្វគោចរនៅលើមែកឈ្មោ ស្វានោះជាសត្វខឹងប្រទូស្តមានសន្តានចិត្តដ៏លាមក បើវាចូលមកមុខតែប្រទូស្តផ្ទះនេះមិនខាន ។

**ចប់ កបិជាតក ទី ១០ ។**

**ចប់ សិគាលវគ្គ ទី ១០ ។**

## ឧទ្ទាននៃសិគាលវគ្គនោះគឺ

និយាយអំពីស្តេចចចក ១ សុនខ ១ ព្រះឥន្ទ្រកោសិយ ១ បុគ្គលប្រាថ្នា ១ បុគ្គលអ្នកស៊ីនូវកាល ១ ទានដ៏ប្រសើរ ១ ព្រះរាជកុមារពេបព្រះឱស្ឋ ១ នាយសារថី ១ ព្រៃស្វាយ ១ ស្វារអា ១ ត្រូវជា ១០ ។

## ឧទ្ទាននៃវគ្គគឺ

និយាយអំពីទឡ្ហវគ្គ ១ សន្ថវវគ្គដទៃ ១ កល្យាណវគ្គ ១ អសទិសវគ្គ ១ រុហកវគ្គ ១ នតំទឡ្ហវគ្គ ១ ពីរណត្ថម្ភកវគ្គ ១ កាសាវវគ្គ ១ ឧបាហនវគ្គ ១ សិគាលវគ្គ ១ ត្រូវជា ១០ ។

## ចប់ ទុកនិបាត ។

# អដ្ឋកថា

# កបិជាតក

[ ៣៥០-៣៥១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អយំ ឥសិ ឧបសមសញ្ញមេ រតោ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះជាអ្នកបោកបញ្ឆោតបានប្រាកដក្នុងពួកភិក្ខុ ។ ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុនោះបួសក្នុងព្រះពុទ្ធសាសនាដែលនាំសត្វចេញចាកទុក្ខនៅតែបំពេញវត្តបោកបញ្ឆោតទៀត ព្រះសាស្តា យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមែនកុហកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ កាលមុនក៏ធ្លាប់កុហកដូចគ្នា កាលកើតជាស្វាបានធ្វើការកុហកព្រោះហេតុត្រឹមតែភ្លើងប៉ុណ្ណោះ ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងដែនកាសី កាលចម្រើនវ័យហើយ ក្នុងកាលដែលបុត្តរត់លេងបាន ព្រាហ្មណីក៏អនិច្ចកម្ម ទើបលើកកូនដាក់លើចង្កេះទៅកាន់ព្រៃហិមពាន្តបួសជាឥសី ឲ្យបុត្តបួសជាតាបសកុមារអាស្រ័យក្នុងបណ្ណសាលា លុះរដូវវស្សាភ្លៀងធ្លាក់មិនដាច់ស្វាមួយត្រូវរងាញៀតញៀនដើរញ័រខ្លួនរណ្តំធ្មេញ ។ ព្រះពោធិសត្វរកឧសធំៗមកបង្កាត់ភ្លើងហើយដេក

លើគ្រែ ឯកូនប្រុសអង្គុយប្របាច់ជើង ។ ស្វានោះ ដណ្តប់សំពត់សម្បកឈើរបស់តាបសដែលស្លាប់មួយរូប ដណ្តប់ស្បែកខ្លាធំ កាន់អម្រែកនិងឃ្លោកបន្ទំខ្លួនជាឥសីមកឈរបោកបញ្ឆោតត្រង់ទ្វារបណ្ណសាលាព្រោះត្រូវការភ្លើង ។ តាបសកុមារឃើញស្វានោះទើបអង្វរបិតាថា បពិត្រលោកឪពុកតាបសម្នាក់ត្រូវរងាបៀតបៀន ឈរញ័រចំប្រប់ សូមលោកឪពុកហៅតាបសនោះចូលមកក្នុងទីនេះចុះ តាបសនឹងបានអាំងភ្លើង បានពោលគាថាទីមួយថា

ឥសីអង្គនេះ ត្រេកអរក្នុងការស្ងប់និងការសង្រួម លោកត្រូវភ័យអំពីរងាបៀតបៀនហើយ សូមឲ្យតាបសនេះចូលមកកាន់ផ្ទះនេះដើម្បីបន្ទោបង់នូវត្រជាក់និងសេចក្តីក្រវល់ក្រវាយចេញកុំឲ្យមានសេសសល់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបសមសញ្ញមេ រតោ** គឺ ត្រេកអរក្នុងការស្ងប់ចាកកិលេសមានរាគៈជាដើម និងក្នុងការសង្រួមដោយសីល ។ បទថា **ស តិដ្ឋតិ** ប្រែថា លោកមកឈរ ។ បទថា **សិសិរភយេន** បានដល់ព្រោះខ្លាចរងាដែលកើតអំពីខ្យល់និងភ្លៀង ។ បទថា **អដ្ដិតោ** សេចក្តីថាត្រូវភ័យ គឺរងាបៀតបៀនហើយ ។ បទថា **បាវិសតុមំ** កាត់បទជា **បាវិសតុ ឥមំ** គឺ អញ្ជើញចូលមកកាន់បណ្ណសាលានេះ ។ បទថា **កេវលំ** បានដល់ទាំងមូល គឺមិនមានសេសសល់ ។

ព្រះពោធិសត្វស្តាប់ពាក្យរបស់បុត្ត ទើបក្រោកឡើង សម្លឹងមើលដឹងថាជាស្វាទើបពោលគាថាទីពីរថា

អ្នកនេះមិនមែនជាឥសី អ្នកត្រេកអរក្នុងការស្ងប់និងការសង្រួម
ទេ អ្នកនេះជាសត្វស្វា ជាសត្វគោចរនៅលើមែកឈើ ស្វានោះ
ជាសត្វវិងប្រទូស្តមានសន្តានចិត្តដ៏លាមក បើវាចូលមកមុខ
តែប្រទូស្តផ្ទះនេះមិនខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុមវសាខគោចរោ** បានដល់ ត្រាច់ទៅតាម
មែកឈើ ។ បទថា **សោ ទូសកោ រោសកោ ចាបិ ជម្មោ** សេចក្តីថា
ឈ្មោះថា **ទូសកោ** ព្រោះប្រទូស្តទីដែលវាទៅហើយ ឈ្មោះថា **រោសកោ**
ព្រោះទ្រគោះបោះបោក ឈ្មោះថា **ជម្មោ** ព្រោះជាសត្វលាមក ។ បទថា
**សចេ វជេ** សេចក្តីថា បើស្វានោះចូលមកកាន់បណ្ណសាលានេះគប្បីប្រទូស្ត
បណ្ណសាលាទាំងអស់ ដោយការបន្ទោបង់ឧច្ចារបស្សាវៈនិងដោយការដុត ។

ព្រះពោធិសត្វកាលពោលយ៉ាងនេះហើយ ទើបស្រវាអង្កត់ឧសដែលមាន
ភ្លើង ចេញមកសម្លុតឲ្យស្វាភិតភ័យ ហើយគេចទៅ ។ ស្វាលោតគេចទៅ
ចូលព្រៃមិនបានមកទីនោះទៀត ។ ព្រះពោធិសត្វញុំាងអភិញ្ញានិងសមាបត្តិ
ឲ្យកើត បង្រៀនការបរិកម្មកសិណដល់តាបសកុមារ ។ តាបសកុមារធ្វើ
អភិញ្ញានិងសមាបត្តិឲ្យកើតឡើងហើយ តាបសទាំង ២ មានឈានមិនវិនាស
មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ថា
ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាល
មុនភិក្ខុនេះក៏ជាអ្នកកុហកដូចគ្នា ហើយទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ច

ធម៌ ភិក្ខុពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ។ ហើយទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះ បានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ បុត្តក្នុងកាលនោះ បានមកជារាហុល ឯបិតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាកបិជាតក ចប់**

**សិង្គាលវគ្គ ចប់**

**ទុកនិបាត ចប់**

# តិកនិបាតជាតក

# សង្កប្បវគ្គ

## សង្កប្បរាគជាតក

[ ៣៥២ ] ( តាបសពោធិសត្វពោលថា ) អាត្មាត្រូវ ( សរគឺកិលេស ) ដែលលាងដោយទឹក គឺសង្កប្បរាគៈ ( រាគៈប្រកបដោយកាមវិតក្កៈ ) ផង ដែលសំលៀងដោយថ្ម គឺកាមវិតក្កៈផងមិនបានចម្រើនដោយគ្រឿងតាក់តែងផង ( មិនមែន ) ជាងសរធ្វើហើយផង ។

[ ៣៥៣ ] មិនមែនទាញមកនូវគុម្ពត្រចៀកហើយលែងទៅវិញផង ទាំងមិនជាប់ដោយស្លាបក្ងោកផង ជាសរអាចដុតអវយវៈទាំងអស់ឲ្យក្តៅនោះ បានមុតហើយត្រង់ហឫទ័យ ។

[ ៣៥៤ ] ឈាមគប្បីហូរចេញចាកមុខរបួសដែលសរណាមុតហើយ អាត្មាមើលមិនឃើញមុខរបួសដែលសរនោះមុតហើយទេ ចិត្ត ( របស់អាត្មាត្រូវសរមុតជាប់ហើយ ) ព្រោះខុសទំនង អាត្មានាំមកនូវសេចក្តីទុក្ខដោយខ្លួនឯង ។

**ចប់ សង្កប្បរាគជាតកទី ១ ។**

# តិកនិបាត

# សង្កប្បវគ្គ

## អដ្ឋកថា សង្កប្បរាគជាតក

[ ៣៥២-៣៥៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកអផ្សុក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សង្កប្ប-រាគធោតេន** ដូច្នេះជាដើម ។

បានឮថា មានកុលបុត្តអ្នកនគរសាវត្ថីម្នាក់ បួសថ្វាយជីវិតក្នុងសាសនារបស់ព្រះសាស្តា ។ ថ្ងៃមួយត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថីបានឃើញស្ត្រីម្នាក់តាក់តែងរាងកាយស្រស់ស្អាត កើតសេចក្តីស្រឡាញ់ មិនត្រេកអរប្រព្រឹត្តព្រហ្មចរិយត្រាច់ទៅ ។ អាចារ្យនិងឧបជ្ឈាយ៍ជាដើមបានឃើញអាការដូច្នោះទើបសួរដល់ហេតុដែលមិនត្រេកអរ ក្នុងការប្រព្រឹត្តព្រហ្មចរិយ កាលជ្រាបថាលោកមានសេចក្តីប្រាថ្នានឹងសឹកទើបនាំគ្នាពោលថា នែលោក ធម្មតាថាព្រះបរមសាស្តាទ្រង់លះបង់កិលេសមានរាគៈជាដើម ទ្រង់ទូន្មានហើយប្រកាសអរិយសច្ចៈ ប្រទានសោតាបត្តិផលជាដើម មកចុះលោក ពួកយើងនឹងទៅគាល់ព្រះសាស្តា ហើយបាននាំទៅ ។ កាលព្រះបរមសាស្តាត្រាស់សួរថាម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុដែលមិនប្រាថ្នាមកធ្វើអ្វី ទើបនាំគ្នាក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះបរមសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលលោកក្រាបទូលថា ពិតហើយព្រះអង្គ ទើបត្រាស់សួរថា ព្រោះហេតុអ្វី ភិក្ខុនោះក៏ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។

លំដាប់នោះទើបព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុ ធម្មតាស្ត្រីទាំងឡាយនេះធ្លាប់ធ្វើសេចក្ដីសៅហ្មងឲ្យកើតដល់សត្វដែលបរិសុទ្ធទាំងឡាយ ដែលសង្កត់កិលេសបានដោយកម្លាំងឈានរឿងអ្វីនឹងមិនធ្វើបុគ្គលគ្មានគុណសម្បត្តិដូចអ្នកឲ្យសៅហ្មង អ្នកបរិសុទ្ធគង់សៅហ្មងបាន ទាំងលោកអ្នកព្រមព្រៀងដោយឧត្តមយស ក៏គង់ដល់នូវការវិនាសយសបាន នឹងពោលថ្វីដល់បុគ្គលដែលមិនបរិសុទ្ធនោះ ខ្យល់ដែលបក់ភ្នំសិនេរុឲ្យញាប់ញ័រ ហេតុអ្វីនឹងមិនបក់សំរាមស្លឹកឈើចាស់ឲ្យខ្ចាត់ខ្ចាយទៅបាន កិលេសនេះបៀតបៀនសត្វដែលអង្គុយនៅត្រង់គល់ពោធិព្រឹក្សនឹងត្រាស់ដឹងបាន រឿងអ្វីមិនបៀតបៀនមនុស្សដូចអ្នក កាលភិក្ខុទាំងឡាយទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ បានកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល មានទ្រព្យសម្បត្តិ ៨០ កោដិ កាលចម្រើនវ័យហើយទៅរៀនសិល្បៈទាំងពួងនៅក្នុងនគរតក្កសិលា កាលរៀនចប់ហើយក៏ត្រឡប់មកកាន់នគរពារាណសី នៅគ្រប់គ្រងផ្ទះមានបុត្តភរិយា កាលមាតាបិតាស្លាប់ទៅហើយក៏បានធ្វើកិច្ចទាក់ទងជាមួយនឹងការស្លាប់របស់មាតាបិតា កាលត្រួតពិនិត្យប្រាក់ទើបពិចារណាថា ទ្រព្យដែលមាតាបិតាប្រមូលទុកនៅប្រាកដ តែមាតាបិតាមិនប្រាកដ ដូច្នេះហើយទើបមានសេចក្ដីសង្វេគ ញើសហូរចេញអំពីរាងកាយ ។ ព្រះពោធិសត្វនៅគ្រប់គ្រងផ្ទះអស់កាលយូរ បានឲ្យទានច្រើន លះកាមទាំងឡាយ លះពួក

ញាតិដែលមានមុខជោគដោយទឹកភ្នែក ចូលទៅកាន់ព្រៃហិមពាន្តសាងបណ្ណ-សាលានៅក្នុងទីដ៏ទីគួររីករាយ ត្រាច់ស្វែងរកឫសឈើនិងផ្លែឈើក្នុងព្រៃចិញ្ចឹមជីវិត មិនយូរប៉ុន្មានក៏បានធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតឡើង លេងឈានមកអស់កាលយូរទើបគិតថា អាត្មាអញទៅកាន់ដែនដីមនុស្សនឹងបានសេពរសជូរប្រៃ កាលបើដូច្នោះរាងកាយរបស់អាត្មាអញនឹងរឹងមាំ នឹងបានជាការសម្រាករបស់អញផង ទាំងជនពួកណានឹងឲ្យភិក្ខាឬនឹងធ្វើការអភិវាទជាដើមដល់បុគ្គលដែលមានសីលដូចអាត្មាអញ ជនទាំងនោះនឹងបានទៅកើតក្នុងស្ថានសួគ៌ ។ កាលគិតហើយទើបចេញអំពីព្រៃហិមពាន្តត្រាច់ចារិកទៅតាមលំដាប់រហូតដល់នគរពារាណសីក្នុងវេលាព្រលប់ ទើបត្រាច់ស្វែងរកទីស្នាក់អាស្រ័យនៅឃើញព្រះរាជឧទ្យានទើបគិតថា ទីនេះសមគួរដល់ការពួនសម្ងំ អាត្មាអញនឹងនៅក្នុងទីនេះ កាលគិតហើយទើបចូលទៅកាន់ព្រះរាជ-ឧទ្យាន អង្គុយត្រង់គល់ឈើមួយដើម ធ្វើរាត្រីឲ្យអស់ទៅដោយសេចក្តីសុខក្នុងឈាន ព្រឹកឡើងជម្រះសរីរៈកាយហើយចាត់ចែងចងជដា ដណ្តប់ស្បែកខ្លានិងដណ្តប់សំពត់សម្បកឈើកាន់ភាជនៈសម្រាប់ភិក្ខាចារ សង្រួមឥន្ទ្រិយ៍ស្ងប់រម្ងាប់ បរិបូណ៌ដោយឥរិយាបថ ក្រឡេកមើលមួយជួរនឹមមានរូបសិរីរបស់ខ្លួនបរិបូណ៌ដោយអាការទាំងពួង អាចទាញយកក្រខ្សែភ្នែករបស់មហាជនឲ្យសម្លឹងមើល ដើរចូលព្រះនគរ ត្រាច់ភិក្ខាចារទៅរហូតដល់ទ្វារព្រះរាជ-និវេសន៍ ។ ព្រះរាជាកំពុងយាងលើផ្ទៃប្រាសាទទតឃើញព្រះពោធិសត្វតាមសីហបញ្ជរ ទ្រង់ជ្រះថ្លាក្នុងឥរិយាបថរបស់ពោធិសត្វទ្រង់ត្រិះរិះថា បើធម៌ដ៏

ស្ងប់រម្ងាប់មានក៏គង់នឹងមានក្នុងខាងក្នុងចិត្តរបស់អ្នកមានសភាពដូច្នេះ ដូច្នេះហើយទើបត្រាស់បញ្ជាអាមាត្យម្នាក់ថា ចូរអ្នកទៅនាំតាបសនោះមក ។ អាមាត្យនោះទៅថ្វាយបង្គំហើយសូមទទួលយកភាជនៈសម្រាប់កិច្ចាចារ ហើយពោលថា បពិត្រលោកម្ចាស់ ព្រះរាជាត្រាស់ឲ្យនិមន្តលោកម្ចាស់ ។ ព្រះពោធិសត្វពោលថា នែអ្នកមានបុណ្យច្រើន ព្រះរាជាទ្រង់មិនស្គាល់អាត្មា ។ អាមាត្យពោលថា បើដូច្នោះសូមនិមន្តលោកម្ចាស់ឈប់ត្រង់នេះ ទម្រាំខ្ញុំត្រឡប់មកហើយទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ត្រាស់ថា តាបសរូបដទៃដែលចូលមកកាន់រាជត្រកូលរបស់យើងមិនមាន ចូរអ្នកទៅនិមន្តតាបសនោះមក ។ ចំណែកព្រះអង្គក៏ទ្រង់លាព្រះហស្តថ្វាយបង្គំតាមបង្អួចត្រាស់ថា បពិត្រលោកម្ចាស់ សូមនិមន្តមកកាន់ព្រះរាជនិវេសន៍នេះចុះ ។ ទើបព្រះពោធិសត្វប្រគល់ភាជនៈសម្រាប់កិច្ចាចារឲ្យអាមាត្យកាន់ទៅហើយ ក៏ដើរឡើងកាន់ផ្ទៃប្រាសាទ ។ លំដាប់នោះព្រះរាជាទ្រង់ថ្វាយបង្គំព្រះពោធិសត្វនោះហើយនិមន្តឲ្យគង់លើរាជបល្ល័ង្ក អង្គាសដោយយាគូ របស់ទំពានិងភត្តាហារដែលគ្នាក់ងារចាត់ចែងទុកសម្រាប់ព្រះអង្គ ។ ព្រះពោធិសត្វឆាន់ស្រេចហើយទើបត្រាស់សួរបញ្ហា ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងការព្យាករបញ្ហារបស់ព្រះពោធិសត្វក្រៃលែងទើបថ្វាយបង្គំហើយត្រាស់សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់គង់នៅក្នុងទីណា នឹងមកអំពីទីណា កាលព្រះពោធិសត្វទូលថា មហាបពិត្រ អាត្មានៅក្នុងព្រៃហិមពាន្ត នឹងមកអំពីព្រៃហិមពាន្ត ទើបត្រាស់សួរទៀតថា មកព្រោះហេតុអ្វី កាលព្រះពោធិសត្វទូលថា មហាបពិត្រ

ក្នុងវដ្តវត្តៀងគួរនឹងបានការស្នាក់នៅជាប្រចាំ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ សូមនិមន្តលោកម្ចាស់ស្នាក់នៅក្នុងព្រះរាជឧទ្យាន លោកម្ចាស់នឹងមិនលំបាកដោយបច្ច័យទាំង ៤ ញោមក៏បានបុណ្យដែលនឹងនាំខ្លួនទៅកើតក្នុងស្ថានសួគ៌ ។ កាលទ្រង់កាន់យកប្ដេជ្ញាហើយសោយព្រះក្រយាហើយ បានយាងទៅកាន់ព្រះរាជឧទ្យានមួយអន្លើដោយព្រះពោធិសត្វ ត្រាស់ឲ្យសាងបណ្ណសាលា សាងទីចង្រ្កម រៀបចំសេនាសនៈ ទីសម្រាកពេលយប់និងទីសម្រាកពេលថ្ងៃជាដើម ស្រេចបាច់ហើយប្រគេនបព្វជិតបរិក្ខារហើយត្រាស់ថា សូមលោកម្ចាស់នៅដោយសេចក្ដីសុខចុះ ប្រគល់នាយឧទ្យានបាលឲ្យរក្សា ។ តាំងអំពីនោះមកព្រះពោធិសត្វបាននៅក្នុងព្រះរាជឧទ្យាននោះអស់ ១២ ឆ្នាំ ។ តមកខាងក្រោយប្រទេសជាយដែនរបស់ព្រះរាជាកើតនូវការបះបោរ ។ ព្រះរាជាមានបំណងយាងទៅរម្ងាប់ហេតុការណ៍នោះ ទើបហៅព្រះទេវីមក ហើយត្រាស់ថា នែនាងដ៏ចម្រើន នាងគួរសម្ងំនៅក្នុងព្រះនគរ ។ ព្រះទេវីទូលថា បពិត្រព្រះសម្មតិទេព ព្រោះអាស្រ័យហេតុអ្វីទើបទ្រង់ត្រាស់យ៉ាងនេះ ព្រះរាជាត្រាស់ថា ព្រោះអាស្រ័យតាបសអ្នកមានសីល ព្រះទេវីទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់នឹងមិនប្រមាទ ក្នុងតាបសនោះ ការប្រណិប័តន៍លោកម្ចាស់របស់ពួកយើងជាភារៈរបស់ខ្ញុំម្ចាស់ សូមព្រះអង្គទ្រង់កុំកង្វល់ចូរស្ដេចយាងទៅចុះ ។ ទើបព្រះរាជាចេញទៅ ។ ចំណែកព្រះទេវីក៏តាំងចិត្តឧបដ្ឋាកព្រះពោធិសត្វដូចដើម ។ ចំណែកព្រះពោធិសត្វ ក្រោយអំពីព្រះរាជាស្ដេចយាងទៅហើយក៏មិនបានទៅតាមវេលាដែលធ្លាប់មក បានទៅកាន់ព្រះរាជនិ-

វេសន៍ ធ្វើកត្តកិច្ចតាមវេលាដែលខ្លួនពេញចិត្ត ។ តមកថ្ងៃមួយ កាលព្រះពោធិសត្វយឺតយូរក្នុងការមក ព្រះរាជទេវីចាត់ចែងខាទនីយភោជនីយាហារគ្រប់យ៉ាងស្រេចហើយទើបព្រះនាងស្រពស្រង់ព្រះកាយ ហើយប្រដាប់ព្រះវរកាយ ឲ្យក្នាក់ងារតាក់តែងគ្រែតូចផ្ទំរង់ចាំការមករបស់ព្រះពោធិសត្វដោយស្លៀកព្រះភូសាសាច់ម៉ដ្ឋ ។ ចំណែកព្រះពោធិសត្វកំណត់ថា ដល់វេលាហើយក៏កាន់យកកិក្ខាភាជនះហោះមកដល់មាត់បង្អួច ។ ព្រះទេវីបានស្តាប់សំឡេងសំពត់សម្បកឈើរបស់ព្រះពោធិសត្វ ព្រះនាងក៏ក្រោកឡើងដោយរហ័ស ។ ព្រះភូសាសាច់ម៉ដ្ឋដែលព្រះនាងដណ្តប់នោះក៏របូតមួយរំពេច ។ ព្រះពោធិសត្វបានឃើញវិសភាគារម្មណ៍មិនបានសង្រួមឥន្ទ្រិយ៍ សម្លឹងមើលដោយអំណាចនៃសុភនិមិត្ត ។ លំដាប់នោះកិលេសរបស់ព្រះពោធិសត្វ ដែលស្ងប់ដោយកម្លាំងឈានក៏កម្រើកឡើងដូចអាសិរពិសដែលដាក់ក្នុងទ្រុង លុះចេញចាកទ្រុងបានក៏បើកពពារឡើងដូច្នោះ ។ ព្រះពោធិសត្វបានជាអ្នកមានអាការដូចវេលាត្រូវមុតដោយកាំបិតដូច្នោះ ។ អង្គឈានទាំងឡាយ វិនាសទៅដំណាលគ្នានិងកិលេសដែលកើតឡើង ។ ឥន្ទ្រិយ៍ទាំងឡាយក៏មិនបរិបូណ៌ ។ ខ្លួនឯងមានសភាពដូចក្អែកបាក់ស្លាបដូច្នោះ ។ ព្រះពោធិសត្វនោះមិនអាចអង្គុយធ្វើកត្តកិច្ចដូចកាលមុនបាន ។ សូម្បីព្រះទេវីត្រាស់ប្រាប់ឲ្យអង្គុយ ក៏មិនព្រមអង្គុយ ។ លំដាប់នោះព្រះទេវីដាក់ខាទនីយៈភោជនីយាហារគ្រប់យ៉ាងក្នុងកិក្ខាភាជនះរបស់ព្រះពោធិសត្វ ។ ថ្ងៃនោះព្រះពោធិសត្វមិនអាចទៅដូចសព្វមួយដងដែលធ្វើកត្តស្រេចហើយក៏ហោះចេញទៅតាមសីហបញ្ជរ បានតែ

ទទួលកត្តាហារហើយដើរចុះតាមជណ្តើរធំទៅកាន់ព្រះរាជឧទ្យាន ។ ព្រះទេវីក៏ជ្រាបថា តាបសមានចិត្តប្រតិព័ទ្ធក្នុងព្រះនាង ។ ព្រះពោធិសត្វនោះ ទៅដល់ព្រះរាជឧទ្យានហើយមិនបរិភោគកត្តាហារឡើយទុកក្រោមគ្រែ ដេករវើរវាយថា ព្រះហស្តបែបនេះរបស់ព្រះទេវីស្អាត ព្រះបាទក៏ស្អាតទីបំផុតនៃចង្កេះស្អាតបែបនេះ លក្ខណៈរបស់ព្រះឧរុបែបនេះ ដូច្នេះជាដើម ដេករវើរវាយអស់ ៧ ថ្ងៃ ។ កត្តាហារក៏ផ្អូមមានពួករុយខៀវចោមរោម ។ ចំណែកព្រះរាជាទ្រង់ញ៉ាំងបច្ចន្តជនបទឲ្យស្ងប់រម្ងាប់ហើយក៏យាងត្រឡប់មក ទ្រង់ប្រទក្សិណព្រះនគរ ដែលអ្នកនគរតាក់តែងទទួលព្រះរាជា តែទ្រង់យាងទៅកាន់ព្រះរាជឧទ្យានមិនយាងទៅកាន់និវេសន៍ ។ ស្តេចយាងទៅកាន់ព្រះរាជឧទ្យានដោយបំណងថានឹងសួរសុខទុក្ខព្រះពោធិសត្វ ដូច្នេះហើយ បានទតឃើញអាស្រមបទស្អេកស្កះដោយសំរាមទ្រង់សំគាល់ថា តាបសជៀសចេញទៅហើយ ដូច្នេះហើយ ទើបទ្រង់បើកទ្វារបណ្ណសាលាយាងចូលទៅខាងក្នុងទតឃើញតាបសនោះដេកទើបទ្រង់ព្រះតម្រិះថា ប្រហែលជាមានការមិនសប្បាយប្រការណាមួយដូច្នេះហើយទើបត្រាស់ឲ្យយកកត្តាហារផ្អូមទៅចោលជម្រះសម្អាតបណ្ណសាលាហើយត្រាស់សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនសប្បាយឬ តាបសទូលថា មហាបពិត្រ អាត្មាភាពត្រូវព្រួញមុត ។ ព្រះរាជាគិតថា ប្រហែលពួកមិច្ឆាមិត្តរបស់យើងមិនបានឱកាសក្នុងយើងទើបមកបាញ់តាបសនេះ ដោយគិតថានឹងធ្វើឋានៈដែលជាទីស្រឡាញ់របស់ព្រះរាជានោះឲ្យទុព្វលភាព ដូច្នេះហើយទើបទ្រង់ចាប់ប្រែរាងកាយពិនិត្យមើលស្នាម

ដែលត្រូវបាញ់ក៏មិនឃើញស្នាមដែលត្រូវបាញ់ទើបត្រាស់សួរថា លោកម្ចាស់ត្រូវគេបាញ់ត្រង់ណា ព្រះពោធិសត្វពោលថា មហាបពិត្រ អាត្មាភាពមិនបានត្រូវអ្នកដទៃបាញ់ឡើយតែអាត្មាភាពបាញ់ខ្លួនឯងត្រង់បេះដូង កាលទូលហើយទើបក្រោកឡើងអង្គុយពោលគាថាទាំងនេះថា

អាត្មាត្រូវ ( សរគឺកិលេស ) ដែលលាងដោយទឹក គឺសង្កប្បរាគៈ ( រាគៈប្រកបដោយកាមវិតក្កៈ ) ផង ដែលសំលៀងដោយថ្ម គឺកាមវិតក្កៈផង មិនបានចម្រើនដោយគ្រឿងតាក់តែងផង ( មិនមែន ) ជាងសរធ្វើហើយផង ។

មិនមែនទាញមកនូវគុម្ពត្រចៀកហើយលែងទៅវិញផង ទាំងមិនជាប់ដោយស្លាបក្ងោកផង ជាសរអាចដុតអវយវៈទាំងអស់ឲ្យក្ដៅនោះបានមុតហើយត្រង់ហឫទ័យ ។

ឈាមគប្បីហូរចេញចាកមុខរបួសដែលសរណាមុតហើយ អាត្មាមើលមិនឃើញមុខរបួសដែលសរនោះមុតហើយទេ ចិត្ត ( របស់អាត្មាត្រូវសរមុតជាប់ហើយ ) ព្រោះខុសទំនង អាត្មានាំមកនូវសេចក្ដីទុក្ខដោយខ្លួនឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សង្កប្បរាគធោតេន** សេចក្ដីថា លាបដោយរាគៈដែលប្រកបព្រមដោយសេចក្ដីត្រិះរិះក្នុងកាម ។ បទថា **វិតក្កនិសិតេន** សេចក្ដីថា ដែលសំលៀងដោយថ្ម គឺសេចក្ដីត្រិះរិះដោយទឹក គឺរាគៈនោះឯង ។ បទថា **នេវាលង្កតភទ្រេន** សេចក្ដីថា ដែលជាងមិនបាន

ធ្វើឲ្យរលោង ។ បទថា **ឧសុការកតេន ច** សេចក្តីថា សូម្បីជាងសរទាំងឡាយក៏មិនបានពត់ ។ បទថា **ន កណ្ណាយតមុត្តេន** សេចក្តីថា មិនបានទាញខ្សែមកឲ្យផុតគុម្ពត្រចៀកខាងស្តាំជាកំណត់ ។ បទថា **នបិ មោរុប-សេវិនា** សេចក្តីថា មិនបានធ្វើការភ្ជាប់រោមស្លាបក្ងោកនិងរោមកន្ទុយស្លាបត្មាតជាដើម ។ បទថា **តេនម្ហិ ហទយេ វិទ្ធោ** សេចក្តីថា ត្រូវកូនសរគឺកិលេសនោះចាក់ដោតត្រង់ហទយៈ ។ ដោយបទថា **សព្វង្គបរិទាហិនា** នេះលោកសម្តែងថា មហាបពិត្រ អាត្មាភាពត្រូវចាក់ដោតត្រង់បេះដូង ដោយកូនសរ គឺកិលេសនោះដែលអាចធ្វើឲ្យអវយវៈទាំងពួងក្តៅក្រហាយ តាំងអំពីវេលាដែលអាត្មាភាពត្រូវកូនសរនោះមុតហើយអវយវៈគ្រប់ចំណែករបស់អាត្មាភាពក្តៅដូចភ្លើងឆេះពេញរាងកាយដូច្នោះ ។ បទថា **អាវេធញ្ច ន បស្សាមិ** សេចក្តីថា អាត្មាភាពមិនឃើញទីដែលកូនសរចាក់ដោត ។ បទថា **យតោ រុហិរមស្សវេ** សេចក្តីថា ឈាមរបស់អាត្មាភាពហូរចេញចាកមុខរបួសណាអាត្មាភាពមិនឃើញមុខរបួសនោះ ។ សព្ទថា **យាវ** ក្នុងបទថា **យាវ អយោនិសោ ចិត្តំ** នេះជានិបាតប្រើក្នុងអត្ថថា មាំទាំ អធិប្បាយថា កូនសរចាក់ដោតចិត្តដែលគិតមិនត្រូវទំនងយ៉ាងនោះខ្លាំងក្លា ។ បទថា **សយំ មេ ទុក្ខមាភតំ** សេចក្តីថា អាត្មាភាពនាំទុក្ខមកឲ្យដល់ខ្លួនដោយខ្លួនឯង ។

ព្រះពោធិសត្វកាលសម្តែងធម៌ដល់ព្រះរាជាដោយគាថា ៣ គាថានេះ យ៉ាងនេះហើយ ទើបទូលឲ្យព្រះរាជាស្តេចយាងចេញប្រថាប់ខាងក្រៅបណ្ណ-សាលា ហើយធ្វើកសិណបរិកម្មធ្វើឈានដែលវិនាសឲ្យកើតឡើង ហើយ

ចេញចាកបណ្ណសាលាហោះឡើងទៅអង្គុយកណ្ដាលអាកាស ទូន្មានព្រះរាជាហើយទូលថា មហាបពិត្រ អាត្មាភាពនឹងទៅកាន់ព្រៃហិមពាន្តវិញ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ កុំនិមន្តទៅឡើយ ព្រះពោធិសត្វក៏ទូលថា មហាបពិត្រ ព្រោះអាត្មានៅក្នុងទីនេះទើបបានទទួលអាការដែលខុសបែបនេះឥឡូវនេះមិនអាចនៅក្នុងទីនេះបាន ទាំងដែលព្រះរាជទ្រង់អង្វរហើយនោះឯង ក៏ហោះទៅកាន់ព្រៃហិមពាន្តតាំងនៅជរាបដល់អស់ជីវិត ក្នុងវេលាអស់ជីវិតក៏បានទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុអ្នកអផ្សុក ក៏តាំងនៅក្នុងអរហត្ត ជនពួកខ្លះបានជាសោតាបន្ន ពួកខ្លះបានជាសកទាគាមី ពួកខ្លះជាអនាគាមីហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សន្ថវជាត ចប់

# តិលមុដ្ឋិជាតក

[ ៣៥៥ ] ( ព្រះបាទព្រហ្មទត្តពោលថា ) អ្នកចាប់យើងត្រង់ដើមដៃ ហើយវាយយើងដោយរំពាត់ព្រោះហេតុតែល្ងមួយក្តាប់ ការវាយនោះប្រាកដក្នុងចិត្តរបស់យើងដរាបដល់ថ្ងៃនេះ ។

[ ៣៥៦ ] ម្នាលព្រាហ្មណ៍ អ្នកមកដោយហេតុណា អ្នកមិនត្រេកអរក្នុងជីវិតដោយហេតុនោះទេឬ ព្រោះអ្នកចាប់យើងត្រង់ដើមដៃហើយវាយអស់វារៈបីដង ។

[ ៣៥៧ ] ( ព្រាហ្មណ៍ពោលថា ) អរិយជនណាហាមឃាត់នូវបុគ្គលមិនប្រសើរ កាលធ្វើនូវអំពើអាក្រក់ដោយអាជ្ញា ការហាមឃាត់របស់អរិយជននោះរាប់ថាជាពាក្យប្រៀនប្រដៅ ការហាមឃាត់អរិយជននោះ មិនមែនជាពៀរឡើយ បណ្ឌិតទាំងឡាយរមែងដឹងនូវហេតុនោះដូច្នេះឯង ។

**ចប់ តិលមុដ្ឋិជាតកទី ២ ។**

## អដ្ឋកថា

## តិលមុដ្ឋិជាតក

[ ៣៥៥-៣៥៧ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលច្រើនដោយសេចក្តីក្រោធមួយរូបទើបត្រាស់ធម្មទេសនានេះ មានពាក្យផ្តើមថា **អជ្ជាបិ មេ តំ មនសិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុមួយរូបជាអ្នកច្រើនដោយសេចក្តីក្រោធ ច្រើនដោយការ

បង្អៀតបង្អល់ចិត្ត ត្រូវបុគ្គលណាមួយស្តីថា សូម្បីមានប្រមាណតិចតួចក៏ក្រោធ អន់ចិត្ត ធ្វើសេចក្តីក្រោធ ការប្រទូស្តនិងទោមនស្សឲ្យប្រាកដ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុរូបនោះជាអ្នកក្រោធងាយច្រើនទៅដោយសេចក្តីបង្អៀតបង្អល់ ត្រាច់ធ្វើសំឡេងតដះ តដះ ដូចអំបិលដែលគេដាក់ក្នុងជើងក្រាន ជាអ្នកបួសក្នុងសាសនាដែលទូន្មានមិនឲ្យក្រោធបែបនេះ សេចក្តីក្រោធប៉ុណ្ណោះក៏មិនអាចសង្កត់សង្កិនបាន ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះទើបទ្រង់បញ្ជូនភិក្ខុមួយរូបទៅហៅភិក្ខុនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកច្រើនទៅដោយសេចក្តីក្រោធពិតឬ កាលភិក្ខុនោះទទួលពាក្យថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនភិក្ខុនេះក៏បានជាអ្នកច្រើនទៅដោយសេចក្តីក្រោធដូចគ្នា កាលភិក្ខុទាំងឡាយទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ឱរសរបស់ព្រះបាទព្រហ្មទត្តនោះមាននាមថា ព្រហ្មទត្តកុមារ ។ ពិតហើយព្រះរាជាក្នុងកាលមុនសូម្បីមានអាចារ្យទិសាបាមោក្ខក្នុងនគររបស់ខ្លួនក៏រមែងបញ្ជូនព្រះរាជឱរសរបស់ខ្លួនទៅរៀនសិល្បៈខាងក្រៅដែនក្នុងទីឆ្ងាយ ដោយសង្ឃឹមថា កាលធ្វើយ៉ាងនេះព្រះរាជឱរសនោះនឹងជាអ្នកកំចាត់សេចក្តីប្រកាន់ខ្លួនដោយមានះ ១ នឹងជាអ្នកអត់ធន់ចំពោះរងានិងក្តៅ ១ នឹងបានដឹងចារិត

ប្រពៃណីរបស់មនុស្សលោក ១ ព្រោះហេតុនោះទើបព្រះរាជាអង្គនោះមាន ព្រះរាជឱង្ការឲ្យហៅព្រះរាជឱរសដែលមានព្រះជន្មាយុ ១៦ វស្សាមក ហើយ ព្រះរាជទានស្បែកជើងមួយជាន់មួយគូ ឆត្រស្លឹកឈើមួយនិងទ្រព្យ ១០០០ កហាបណៈហើយត្រាស់ថា នែកូន ចូរបាទៅកាន់នគរតក្កសិលារៀនយក សិប្បៈមកហើយទ្រង់បញ្ជូនទៅ ។ ព្រះរាជឱរសទទួលព្រះរាជឱង្ការហើយ ថ្វាយបង្គំព្រះជនកជននីហើយស្តេចចេញទៅ ត្រាច់ទៅរហូតដល់នគរតក្កសិលា ដោយលំដាប់បានទៅសួររកស្រុកអាចារ្យ ។ ក៏ក្នុងវេលានោះឯងអាចារ្យ បង្រៀនសិល្បៈដល់ពួកមាណពស្រេចហើយ ក្រោកឡើងមកអង្គុយក្នុងទី សមគួរនាចំណែកម្ខាងត្រង់ទ្វារផ្ទះ ។ ព្រះរាជឱរសនោះទៅត្រង់ផ្ទះអាចារ្យនោះ បានឃើញអាចារ្យអង្គុយក្នុងទីនោះ កាលឃើញហើយ ទើបដោះស្បែកជើង ត្រង់ទីនោះ គម្លោះឆត្រថ្វាយបង្គំអាចារ្យហើយឈរ ។ អាចារ្យនោះដឹងថា ព្រះរាជឱរសនោះធ្វើដំណើរមកហត់នឿយទើបធ្វើអាគន្តុកសង្គហៈ ។ ព្រះរាជ កុមារសោយព្រះក្រយាស្រេចហើយ សម្រាកមួយស្របក់ទើបចូលទៅរក អាចារ្យ ថ្វាយបង្គំហើយឈរ កាលអាចារ្យទិសាបាមោក្ខសួរថា អ្នកមកអំពី ណា ទើបឆ្លើយថា មកអំពីនគរពារាណសី ។ អាចារ្យសួរថា អ្នកជាកូន នរណា ព្រះរាជឱរសឆ្លើយថា ជាឱរសរបស់ព្រះបាទពារាណសី ។ អាចារ្យ សួរថា ទ្រង់យាងមកដោយបំណងអ្វី ព្រះរាជឱរសឆ្លើយថា បពិត្រលោក អាចារ្យ ខ្ញុំមកដើម្បីរៀនសិល្បៈ ។ អាចារ្យសួរថា ទ្រង់នាំទ្រព្យដែលជា ចំណែករបស់អាចារ្យមកដែរឬ ឬទ្រង់បំណងជាធម្មន្តេវាសិក ព្រះរាជកុមារ

នោះពោលថា ទ្រព្យដែលជាចំណែករបស់អាចារ្យខ្ញុំនាំមកហើយ ពោលហើយក៏ដាក់ថង់ទ្រព្យ ១០០០ កហាបណៈទៀបជើងរបស់អាចារ្យហើយថ្វាយបង្គំ ។ ធម្មតាសិស្សដែលជាធម្មន្តេវាសិក វេលាថ្ងៃត្រូវធ្វើការងារឲ្យអាចារ្យ វេលាយប់ទើបបានរៀន ។ សិស្សដែលឲ្យទ្រព្យជាចំណែករបស់លោកអាចារ្យដូចជាបុត្តច្បងក្នុងផ្ទះរៀនតែសិល្បៈប៉ុណ្ណោះ ។ ព្រោះហេតុនោះអាចារ្យនោះលុះបានឫក្សល្អហើយទើបផ្តើមបង្រៀនសិល្បៈដល់ព្រះរាជកុមារ ។ ចំណែកព្រះរាជកុមារក៏រៀនយកសិល្បៈ ។ ថ្ងៃមួយបានទៅងូតទឹកព្រមជាមួយអាចារ្យ ។ កាលនោះមានស្រ្តីជរាម្នាក់បកល្ងឲ្យអស់សម្បកហើយយកមកហាល អង្គុយយាម ។ ព្រះរាជកុមារឃើញគ្រាប់ល្ងដែលហាលក៏ប្រាថ្នានឹងសោយទើបចាប់យកល្ងមួយក្តាប់ហើយសោយ ។ ស្រ្តីជរាគិតថា មាណពនេះគង់ប្រាថ្នាបរិភោគ ដូច្នេះហើយទើបអង្គុយស្ងៀមមិនបានពោលដោយប្រការណា ។ សូម្បីក្នុងថ្ងៃស្អែកឡើងព្រះរាជកុមារនោះក៏បានធ្វើយ៉ាងនោះដូចគ្នាក្នុងវេលានោះ ។ សូម្បីស្រ្តីជរានោះក៏មិនបានពោលអ្វីចំពោះព្រះរាជកុមារនោះ ។ ក្នុងថ្ងៃទី ៣ ព្រះរាជកុមារក៏បានធ្វើយ៉ាងនោះដូចគ្នាទៀត ។ គ្រានោះស្រ្តីជរាឃើញព្រះរាជកុមារទើបផ្គងដើមដៃទាំង ២ យំខ្សឹកខ្សួលថា អាចារ្យទិសាបាមោក្ខម្តេចឲ្យសិស្សរបស់ខ្លួនប្លន់យើង ។ អាចារ្យត្រឡប់មកសួរថា នេះមានរឿងអ្វី ស្រ្តីជរាពោលថា បពិត្រលោកម្ចាស់ សិស្សរបស់លោកទំពាស៊ីគ្រាប់ល្ងដែលខ្ញុំហាល ថ្ងៃនេះមួយក្តាប់ ម្សិលមិញមួយក្តាប់ ម្សិលម៉្ងៃមួយក្តាប់ កាលសិស្សរបស់លោកទំពាស៊ីយ៉ាងនេះ ល្ងដែលមានរបស់ខ្ញុំក៏នឹងអស់ទៅមិនមែនឬ

អាចារ្យទិសាបាមោក្ខពោលថា អ្នកម៉ែកុំយំឡើយខ្ញុំនឹងសងថ្លៃដល់អ្នកម៉ែ ។ ស្ត្រីជរាពោលថា ខ្ញុំមិនត្រូវការតម្លៃរបស់លោកទេ ខ្ញុំសូមឲ្យលោកទូន្មានដោយកុំឲ្យកុមារនេះ ធ្វើយ៉ាងនេះតទៅទៀត ។ អាចារ្យពោលថា បើយ៉ាងនោះ សូមអ្នកម៉ែចាំមើលចុះ ។ ហើយឲ្យមាណព ២ នាក់ចាប់ព្រះរាជកុមារនោះត្រង់ដើមដៃទាំង ២ ទើបយកបន្ទះឫស្សីមកវាយត្រង់កណ្តាលខ្នង ៣ រំពាត់ព្រមជាមួយការទូន្មានថា អ្នកកុំធ្វើយ៉ាងនេះតទៅទៀតឡើយ ។ ព្រះរាជកុមារក្រោធខឹងជាមួយអាចារ្យ មានភ្នែកក្រហមសម្លឹងមើលតាំងអំពីខ្នងជើងរហូតដល់ចុងសក់ ។ សូម្បីអាចារ្យនោះក៏ដឹងថា ព្រះរាជកុមារនោះសម្លឹងមើលព្រោះសេចក្តីក្រោធ ។ ព្រះរាជកុមាររៀនសិល្បៈចប់ហើយធ្វើនូវការប្រឡងប្រជែង រក្សាទោសដែលអាចារ្យនោះធ្វើទុកក្នុងហឫទ័យដោយអាឃាតថា អញនឹងសម្លាប់អាចារ្យនេះ ដូច្នេះហើយកាលវេលានឹងទៅទើបថ្វាយបង្គំអាចារ្យធ្វើហាក់ដូចជាមានសេចក្តីស្រឡាញ់យ៉ាងខ្លាំង ហើយឲ្យអាចារ្យទទួលប្តេជ្ញាថា បពិត្រលោកអាចារ្យ កាលណាខ្ញុំបានរាជសម្បត្តិក្នុងនគរពារាណសីហើយបញ្ជូនដំណឹងមកដល់លោក កាលនោះសូមលោកមករកខ្ញុំ ។ ពោលដូច្នេះហើយក៏ចៀសចេញទៅ ។ ព្រះរាជកុមារនោះកាលទៅដល់នគរពារា-ណសីហើយថ្វាយបង្គំព្រះជនកព្រះជននីហើយសម្តែងសិល្បៈឲ្យឃើញ ។ ព្រះរាជាត្រាស់ថា យើងចង់ឃើញបុត្ររបស់យើងសោយរាជសម្បត្តិនិងឃើញសិរីក្នុងរាជសម្បត្តិនៃបុត្ររបស់យើងក្នុងពេលមានជីវិតនោះឯង ទើបទ្រង់ស្ថាបនាព្រះរាជឱរសទុកក្នុងរាជសម្បត្តិ ។ កាលព្រះរាជឱរសបានគ្រប់គ្រង

សិរីរាជសម្បត្តិរឭកដល់ទោសដែលអាចារ្យបានធ្វើទុកក៏ទ្រង់ពិរោធ ទើបទ្រង់បញ្ជូនទូតទៅដល់អាចារ្យដើម្បីឲ្យមកគាល់ដោយតាំងព្រះហឫទ័យថា យើងនឹងសម្លាប់អាចារ្យនោះ ។ លោកអាចារ្យគិតថា ក្នុងវេលាដែលព្រះរាជកុមារនៅក្មេង អញមិនអាចឲ្យព្រះរាជានោះយល់បាន ហេតុនោះហើយទើបមិនបានទៅ ក្នុងវេលាដែលព្រះរាជានោះកន្លងមជ្ឈិមវ័យគិតថា ឥឡូវនេះអញអាចឲ្យព្រះរាជានោះយល់បាន ហេតុនោះហើយទើបធ្វើដំណើរទៅឈរត្រង់ទ្វារព្រះរាជវាំងឲ្យក្រាបទូលថា អាចារ្យនៅក្នុងនគរតក្កសិលាមកហើយ ។ ព្រះរាជាទ្រង់សោមនស្សត្រាស់ឲ្យហៅអាចារ្យមក លុះឃើញអាចារ្យនោះមកគាល់ព្រះអង្គប៉ុណ្ណោះ ទ្រង់ពិរោធរហូតដល់ព្រះនេត្រទាំង ២ ក្រហម ។ ត្រាស់ហៅអាមាត្យទាំងឡាយមកថា នែអ្នកដ៏ចម្រើន ទីដែលអាចារ្យវាយចាក់ដោតយើងនៅរហូតដល់សព្វថ្ងៃ អាចារ្យនាំយកសេចក្តីស្លាប់មកដោយមិនដឹងថា សេចក្តីស្លាប់នឹងមកដល់អញក្នុងថ្ងៃនេះ អាចារ្យនេះនឹងមិនមានជីវិតហើយត្រាស់គាថា ២ ជាបឋមថា

អ្នកចាប់យើងត្រង់ដើមដៃហើយវាយយើងដោយរំពាត់ ព្រោះហេតុតែល្ងមួយក្តាប់ ការវាយនោះប្រាកដក្នុងចិត្តរបស់យើងដរាបដល់ថ្ងៃនេះ ។

ម្នាលព្រាហ្មណ៍ អ្នកមកដោយហេតុណា អ្នកមិនត្រេកអរក្នុងជីវិតដោយហេតុនោះទេឬ ព្រោះអ្នកចាប់យើងត្រង់ដើមដៃហើយវាយអស់វារៈបីដង ដូច្នេះ ។

ទុតិយាវិកត្តិក្នុងពាក្យទាំង ២ ថា **យំ មំ** និង **ពាហាយំ មំ** ក្នុងគាថានោះសម្ដែងដល់ការវាយនិងការចាប់ ។ ក្នុងបទនេះមានសេចក្ដីអធិប្បាយដូច្នេះថា ការដែលលោកវាយខ្ញុំព្រោះលូមួយក្ដាប់និងកាលវាយបានចាប់ដៃយើងហើយវាយនោះនៅកប់ក្នុងចិត្តយើងដល់សព្វថ្ងៃនេះ ។ បទថា **នន្ុ ជីវិតេ ន រមសិ** សេចក្ដីថា លោកប្រហែលជាមិនត្រេកអរក្នុងជីវិតរបស់ខ្លួន ។ បទថា **យេនាសិ ព្រាហ្មណាគតោ** សេចក្ដីថា នែព្រាហ្មណ៍ ព្រោះហេតុដែលលោកមករកយើងក្នុងទីនេះ ។ បទថា **យំ មំ ពាហា គហេត្វាន** សេចក្ដីថា ការដែលចាប់ដើមដៃទាំង ២ របស់យើង អធិប្បាយថា ចាប់ត្រង់ដៃយើងដូច្នេះក៏មាន ។ បទថា **តិក្ខត្តុំ អនុតាលយិ** សេចក្ដីថា លោកវាយយើងដោយបន្ទះឫស្សីអស់វារៈ ៣ ដង ។ ថ្ងៃនេះលោកនឹងបានទទួលផលនៃការវាយយើងនោះ ។ ព្រះរាជាយកសេចក្ដីស្លាប់មកគំរាមអាចារ្យដូច្នេះទើបពោលយ៉ាងនោះ ។ អាចារ្យបានស្ដាប់ពាក្យដូច្នោះទើបពោលគាថាទី ៣ ថា

> អរិយជនណាហាមឃាត់នូវបុគ្គលមិនប្រសើរ កាលធ្វើនូវអំពើអាក្រក់ដោយអាជ្ញា ការហាមឃាត់របស់អរិយជននោះរាប់ថាជាពាក្យប្រៀនប្រដៅ ការហាមឃាត់អរិយជននោះមិនមែនជាពៀរឡើយ បណ្ឌិតទាំងឡាយរមែងដឹងនូវហេតុនោះដូច្នេះឯង ដូច្នេះ ។

បទថា **អរិយោ** ក្នុងគាថានោះជាឈ្មោះរបស់បុគ្គលដែលទូន្មាន ។ ក៏

អរិយៈនោះមាន ៤ ប្រភេទ គឺអាចារអរិយជន ( អរិយជនដែលមានអាចារៈ ) ១ ទស្សនអរិយជន ( អរិយជនដែលគួរមើល ) ១ លិង្គអរិយជន ( អរិយជនដែលកាន់យកភេទ ) ១ បដិវេធអរិយជន ( អរិយជនដែលចាក់ធ្លុះ ) ១ ។ ក្នុងអរិយជន ៤ ប្រភេទនោះ អរិយជនដែលតាំងនៅក្នុងមារយាទដ៏ប្រសើរទើងជាមនុស្សឬជាសត្វតិរច្ឆានក៏ដោយឈ្មោះថា អាចារអរិយជន ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមហាហង្សជាតក ) ថា

ម្នាលសត្វហង្ស អ្នកណាបានគោរពដុំអាហារ ( ដែលបាន
អំពីម្ចាស់ ) អ្នកនោះឈ្មោះថា ប្រព្រឹត្តធម៌ដ៏ប្រសើរ យើង
នឹងលែងនូវម្ចាស់របស់អ្នកនោះ អ្នកទាំង ២ ចូរទៅតាមស្រួល
ចុះ ដូច្នេះ ។

ចំណែកអរិយជនដែលប្រកបដោយរូបនិងឥរិយាបថដែលគួរជ្រះថ្លា គួរមើលឈ្មោះថា ទស្សនអរិយជន ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងសង្ខបាលជាតក ) ថា

លោកជាអ្នកមានឱកាសនៃសរីរៈដ៏ប្រសើរ មានព្រះនេត្រថ្លា
ខ្ញុំសម្គាល់ថា លោកដ៏ចម្រើនជាអ្នកចេញចាកត្រកូលហើយបួស
ចុះលោកអ្នកមានប្រាជ្ញា លះបង់នូវទ្រព្យនិងភោគៈទាំងឡាយ
ចេញចាកផ្ទះហើយបួស តើដោយហេតុដូចម្តេចដូច្នេះ ។

អរិយជនដូចគ្នានិងសមណៈដោយកាន់យកភេទដោយការស្លៀកដណ្តប់ត្រាច់ទៅ សូម្បីជាបុគ្គលទ្រុស្តសីល ក៏ឈ្មោះថាលិង្គអរិយជន ដែលលោក

ពោលទុក ( ក្នុងខុទ្ទកនិកាយសុត្តនិបាត ) ថា

សមណៈណាធ្វើនូវភេទរបស់ពួកអ្នកមានវត្តល្អ ឲ្យជាគ្រឿងបិទបាំង ជាអ្នកស្ទុះស្ទា អ្នកទ្រុស្តត្រកូល មានឫកពាឃ្នើសឃ្នង មានកលមាយាមិនសង្រួម ពោលពាក្យឡេះឡោះប្រព្រឹត្តបន្ទំ សមណៈនោះឈ្មោះថាជាអ្នកទ្រុស្តនូវមគ្គ ដូច្នេះ ។

ចំណែកព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើមឈ្មោះថា បដិវេធ-អរិយជន ។ ដោយហេតុនោះ ទើបលោកពោលថា ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងពុទ្ធសាវកទាំងឡាយហៅថា ព្រះអរិយៈ ។ បណ្ដាអរិយជនទាំងនោះក្នុងទីនេះ ព្រាហ្មណ៍បំណងយកអាចារអរិយជននោះឯង ។ បទថា **អនរិយំ** បានដល់ បុគ្គលទ្រុស្តសីលមានធម៌ដ៏លាមក ។ បទថា **កុរុំ** បានដល់ អ្នកធ្វើកម្មរបស់បុគ្គលដែលទ្រុស្តសីល ៥ យ៉ាង មានបាណាតិបាតជាដើម ។ម្យ៉ាងទៀតអត្ថនេះមានសេចក្ដីថា បុគ្គលដែលធ្វើកម្មដែលជាពៀរនិងភ័យ ៥ដែលមិនប្រសើរ គឺអាក្រក់លាមក ។ បទថា **យោ** សេចក្ដីថា បណ្ដាក្សត្រជាដើម បុគ្គលណាមួយ ។ បទថា **ទណ្ឌេន** សេចក្ដីថា ដោយគ្រឿងប្រហារណាមួយ ។ បទថា **និសេធតិ** សេចក្ដីថា វាយហាមប្រាមថា កុំធ្វើកម្មបែបនេះតទៅទៀត ។ បទថា **អាសនំ តំ ន តំ វេរំ** សេចក្ដីថាបពិត្រមហារាជឈ្មោះថា ការវាយបុត្តធីតាឬសិស្ស ដែលធ្វើវត្តមិនគួរធ្វើដោយអាការយ៉ាងនេះជាការទូន្មានក្នុងលោកនេះ គឺការប្រៀនប្រដៅ ជាឱវាទមិនមែនជាពៀរឡើយ ។ បទថា **ឥតិ នំ បណ្ឌិតា វិទូ** សេចក្ដីថា បណ្ឌិត

ទាំងឡាយដឹងច្បាស់នូវសេចក្តីនោះយ៉ាងនេះឯង ។ បពិត្រមហារាជ ព្រោះហេតុនោះសូម្បីព្រះអង្គក៏សូមទ្រង់ជ្រាបយ៉ាងនេះ ព្រះអង្គមិនគួរបងពៀរក្នុងឋានៈបែបនេះ បើទូលព្រះបង្គំមិនឲ្យទ្រង់សិក្សាយ៉ាងនេះហើយតទៅខាងមុខព្រះអង្គលួចទំ ស្ករក្រាមនិងផ្លែឈើជាដើម ជាប់នៅក្នុងចោរកម្មទាំងឡាយនិងធ្វើការកាត់ទីតសម្លាប់មនុស្សក្នុងផ្លូវនិងសម្លាប់អ្នកស្រុកជាដើម ដោយលំដាប់ត្រូវចាប់ព្រមទាំងភ័ស្តុតាងថា ចោរធ្វើខុសចំពោះព្រះរាជា ដូច្នេះហើយបង្ហាញចំពោះព្រះរាជានឹងបានទទួលភ័យ គឺអាជ្ញាដោយព្រះតម្រាស់ថាពួកលោកចូរទៅដាក់អាជ្ញាដែលសមគួរដល់ទោសរបស់ចោរនេះ ដូច្នេះហើយសម្បត្តិបែបនេះនឹងមានដល់ព្រះអង្គអំពីណា ព្រះអង្គបានភាពជាធំដោយល្អព្រោះអាស្រ័យទូលព្រះបង្គំ មិនមែនឬ អាចារ្យបានធ្វើឲ្យព្រះរាជាទ្រង់យល់ព្រមដោយប្រការដូចពោលមកនេះ ។

ចំណែកអាមាត្យទាំងឡាយដែលឈរចោមរោមបានស្តាប់ពាក្យរបស់អាចារ្យនោះហើយទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ពាក្យដែលអាចារ្យពោលនោះជាពាក្យពិត ភាពជាធំនេះគួរដល់អាចារ្យរបស់ព្រះអង្គ ។ ខណៈនោះព្រះរាជាទ្រង់កំណត់បានដល់គុណរបស់អាចារ្យទើបពោលថា លោកអាចារ្យ ខ្ញុំឲ្យភាពជាធំនេះដល់លោក សូមលោកទទួលយករាជសម្បត្តិចុះ ។ អាចារ្យបដិសេធថា ទូលព្រះបង្គំមិនត្រូវការរាជសម្បត្តិ ។ ព្រះរាជាទ្រង់បញ្ជូនដំណឹងទៅកាន់នគរតក្កសិលាឲ្យនាំបុត្តនិងភរិយារបស់អាចារ្យមក ហើយប្រទានឥស្សរិយយសធំ ទ្រង់តាំងអាចារ្យនោះឯងឲ្យជាបុរោហិត ហើយតាំង

ទុកក្នុងឋានៈជាបិតា ទ្រង់តាំងនៅក្នុងឱវាទរបស់អាចារ្យនោះ ទ្រង់បំពេញបុណ្យទាំងឡាយមានទានជាដើម មានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈភិក្ខុដែលច្រើនដោយសេចក្តីក្រោធ តាំងនៅក្នុងអនាគាមិផល ជនដទៃៗបានជាព្រះសោតាបន្នខ្លះ ជាសកទាគាមីខ្លះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាភិក្ខុអ្នកច្រើនដោយសេចក្តីក្រោធក្នុងកាលឥឡូវនេះ ចំណែកអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តិលមុដ្ឋិជាតក ចប់

## មណិកណ្ឋជាតក

[ ៣៥៨ ] ( មណិកណ្ឋនាគរាជពោលថា ) បាយនិងទឹកកើតដល់ខ្ញុំច្រើនពេកក្រៃព្រោះហេតុនៃកែវមណីនេះ ខ្ញុំនឹងមិនឲ្យកែវមណីនោះដល់លោក លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងមិនមកកាន់អាស្រមរបស់លោកទេ ។

[ ៣៥៩ ] លោកកាលសូមកែវមណីដែលកើតអំពីថ្ម នាំឲ្យខ្ញុំតក់ស្លុតដូចមនុស្សកំលោះមានដៃកាន់ដាវសំលៀងហើយដោយថ្ម មកញាំងខ្ញុំឲ្យតក់ស្លុត ដូច្នោះខ្ញុំមិនឲ្យកែវមណីនោះដល់លោកទេ ( ព្រោះ ) លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងលែងមកកាន់អាស្រមរបស់លោកហើយ ។

[ ៣៦០ ] ( តាបសពោធិសត្វជាបងពោលថា ) បុគ្គលដឹងនូវវត្ថុណា ថា ជាទីស្រឡាញ់របស់គេ មិនត្រូវសូមវត្ថុនោះទេ សេចក្តីស្អប់រមែងមានព្រោះការសូមជ្រុលពេក ដូចស្តេចនាគដែលត្រូវព្រាហ្មណ៍សូមកែវមណីទៅកាន់ទីលែងមើលឃើញតាំងអំពីកាលនោះ ។

**ចប់ មណិកណ្ឋជាតកទី ៣ ។**

## អដ្ឋកថា

## មណិកណ្ឋជាតក

[ ៣៥៨-៣៦០ ] ព្រះសាស្តាកាលទ្រង់អាស្រ័យនៅក្នុងនគរអាឡវី ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយ ទ្រង់ប្រារព្ធកុដិការសិក្ខាបទ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មមន្នបានំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុក្រុងអាឡវីនាំគ្នាសាងកុដិដោយការត្រាច់សូមច្រើន ដោយការសូមច្រើន ដោយការធ្វើវិញ្ញត្តិពោលពាក្យជាដើមថា អ្នកទាំងឡាយចូរឲ្យមនុស្ស អ្នកទាំងឡាយចូរឲ្យមេការ ។ ពួកមនុស្សត្រូវបៀតបៀនដោយការសូម ត្រូវបៀតបៀនដោយការអង្វរ ឃើញភិក្ខុក៏ភ័យខ្លាចរត់គេចជៀសចេញទៅ ។ កាលនោះព្រះមហាកស្សបៈទៅរហូតដល់នគរអាឡវីហើយចូលទៅបិណ្ឌបាត ។ ពួកមនុស្សឃើញសូម្បីព្រះថេរៈក៏នាំគ្នារត់ពួនយ៉ាងនោះ ។ ព្រះថេរៈត្រឡប់អំពីបិណ្ឌបាត ខាងក្រោយអំពីភត្តាហារហើយ ទើបហៅភិក្ខុទាំងឡាយមកសួរថា អ្នកមានអាយុទាំងឡាយ កាលមុនក្រុងអាឡវីនេះរកភិក្ខាបានងាយព្រោះហេតុអ្វីឥឡូវនេះទើបរកភិក្ខាបានលំបាក កាលបានស្ដាប់ហេតុការណ៍នោះ ទើបចូលទៅគាល់ព្រះមានព្រះភាគកាលព្រះសាស្ដាយាងមកដល់ក្រុងអាឡវីគង់ត្រង់អគ្គាឡវចេតិយ ហើយក្រាបទូលសេចក្ដីនោះឲ្យទ្រង់ជ្រាប ។ ព្រោះហេតុនោះទើបព្រះសាស្ដាទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយទ្រង់សាកសួរភិក្ខុក្នុងក្រុងអាឡវីថា ពិតឬដែលបានឮថា ពួកអ្នកឲ្យគេធ្វើកុដិដោយការត្រាច់សូម កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា ពិតហើយព្រះអង្គ ទើបទ្រង់តិះដៀលភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថា ការសូមនេះ រមែងមិនជាទីពេញចិត្ត សូម្បីរបស់ពួកនាគទាំងពួងដែលនៅក្នុងនាគពិភពដែលបរិបូណ៌ដោយរតនៈ ៧ ប្រការ នឹងបាច់ពោលថ្វីដល់ពួកមនុស្សដែលធ្វើទ្រព្យឲ្យកើតឡើងត្រឹមតែ ១ កហាបណៈក៏លំបាកដូចធ្វើសាច់ឲ្យកើតឡើងអំពីថ្ម ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈ

ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ដែលមានសម្បត្តិច្រើន ។ ក្នុងវេលាដែលព្រះពោធិសត្វនោះរត់លេងបាន សត្វដែលមានបុណ្យដទៃទៀត ក៏បានកើតក្នុងផ្ទៃមាតារបស់ព្រះពោធិសត្វនោះ ។ បងប្អូនទាំង ២ នោះចម្រើនវ័យហើយ កាលមាតាបិតាធ្វើកាលកិរិយាហើយ ទើបមានសេចក្ដីសង្វេគនាំគ្នាបួសជាឥសី សាងបណ្ណសាលានៅត្រង់ច្រាំងស្ទឹងគង្គា ។ បណ្ដាឥសីទាំង ២ នោះបណ្ណសាលារបស់ឥសីដែលជាបងនៅខាងលើទឹកនៃស្ទឹងគង្គា ។ បណ្ណ-សាលារបស់ឥសីដែលជាប្អូននៅក្រោមខ្សែទឹកនៃស្ទឹងគង្គា ។ ថ្ងៃមួយស្ដេចនាគឈ្មោះថា មណិកណ្ឋៈចេញចាកនាគពិភព និម្មិតខ្លួនជាមាណពត្រាច់ទៅតាមច្រាំងស្ទឹងគង្គា ទៅដល់អាស្រមរបស់ឥសីដែលជាប្អូនទើបថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ជនទាំង ២ ធ្វើសម្មោទនីយ-កថា បានជាអ្នកស្និទ្ធស្នាលគ្នាមិនអាចឃ្លាតអំពីគ្នាបាន ។ មណិកណ្ឋៈនាគមកកាន់សម្នាក់របស់តាបសដែលជាប្អូនហើយអង្គុយសន្ទនា ប្រាស្រ័យគ្នាកាលវេលាកន្លងទៅ ហើយដោយការស្និទ្ធស្នាលរបស់តាបសទើបប្ដូរអត្តភាពហើយយករង្វេលព័ទ្ធជុំវិញតាបស ហើយបើកពពារធំនៅលើសីសៈ ដេកសម្រាកមួយស្របក់ល្មមបន្ទោបង់សេចក្ដីស្រឡាញ់នោះហើយ ទើបប្ដូររាងកាយជាមាណពវិញ ថ្វាយបង្គំតាបសហើយត្រឡប់ទៅកាន់នាគភិកពរបស់ខ្លួនវិញ ។ ព្រោះការខ្លាចស្ដេចនាគនោះតាបសទើបស្គមស្គាំង សៅហ្មង ពណ៌

សម្បុរមិនផូរផង់ កើតជារោគស្គមលឿង មានខ្លួនរវាមទៅដោយសរសៃ ។ ថ្ងៃមួយតាបសដែលជាប្អូននោះ ក៏ទៅរកតាបសដែលជាបង ។ លំដាប់នោះ តាបសដែលជាបងក៏សាកសួរតាបសដែលជាប្អូននោះថា អ្នកដ៏ចម្រើនព្រោះហេតុអ្វីទើបលោកស្គមស្គាំង សៅហ្មង មានពណ៌សម្បុរអាក្រក់ កើតរោគស្គមលឿង មានខ្លួនរវាមដោយសរសៃ តាបសដែលជាប្អូនទើបប្រាប់រឿងទាំងនោះដល់តាបសដែលជាបងហើយតាបសដែលជាបងសួរថា អ្នកដ៏ចម្រើនលោកត្រូវការឬមិនត្រូវការឲ្យស្តេចនាគនោះមក ទើបឆ្លើយថា មិនត្រូវការ កាលតាបសដែលជាបងពោលថា ស្តេចនាគនោះកាលមកកាន់សម្នាក់របស់លោកប្រដាប់ដោយគ្រឿងអលង្ការអ្វី ក៏ឆ្លើយថា ប្រដាប់ដោយកែវមណី ។ តាបសដែលជាបងពោលថា បើយ៉ាងនោះបើស្តេចនាគនោះមកថ្វាយបង្គំលោកហើយមិនទាន់អង្គុយ ចូរប្រញាប់សូមថា លោកចូរឲ្យកែវមណី កាលសូមយ៉ាងនោះស្តេចនាគនោះនឹងមិនរឹតលោកដោយរង្វេលឡើយនឹងទៅមួយរំពេចនោះឯង ព្រឹកឡើងស្តេចនាគនាះមកឈរត្រង់ទ្វារអាស្រមបទនៅមិនទាន់បានចូលទៅ លោកគប្បីសូម ក្នុងថ្ងៃទី ៣ លោកចូរទៅឈរនៅត្រង់ប្រាំងស្ទឹងគង្គា លុះស្តេចនាគនោះផុសឡើងអំពីទឹកគប្បីសូមមួយរំពេច កាលបើយ៉ាងនេះស្តេចនាគនោះនឹងមិនមករកលោកតទៅទៀតឡើយ ។ តាបសទទួលពាក្យហើយត្រឡប់ទៅកាន់បណ្ណសាលារបស់ខ្លួន ស្អែកឡើងគ្រាន់តែស្តេចនាគមកឈរប៉ុណ្ណោះក៏សូមថា អ្នកចូរឲ្យកែវមណីដែលជាគ្រឿងប្រដាប់នោះដល់យើងចុះ ។ ស្តេចនាគនោះមិនអង្គុយជៀសចេញទៅហើយ ។ ថ្ងៃទី

២ ស្តេចនាគនោះមកឈរនៅត្រង់ទ្វារអាស្រមបទប៉ុណ្ណោះក៏ពោលថា ម្សិល មិញលោកនៅមិនទាន់បានឲ្យកែវមណីដល់យើង ថ្ងៃនេះលោកក៏ចូរឲ្យកែវ-មណីដល់យើងក្នុងកាលឥឡូវនេះចុះ ។ កាលបើយ៉ាងនោះស្តេចនាគនោះក៏មិនបានចូលទៅកាន់អាស្រមបទប្រញាប់ជៀសចេញទៅ ។ ក្នុងថ្ងៃទី ៣ គ្រាន់តែស្តេចនាគនោះផុសឡើងអំពីទឹកប៉ុណ្ណោះ តាបសក៏ពោលថា កាលយើងសូមថ្ងៃនេះជាថ្ងៃទី ៣ ហើយ ឥឡូវនេះចូលោកឲ្យកែវមណីនោះដល់យើងចុះ ។ ស្តេចនាគនៅក្នុងទឹកនោះឯង កាលនឹងហាមតាបសនោះមិនឲ្យសូមទើបពោលគាថា ២ នេះថា

*បាយនិងទឹកកើតដល់ខ្ញុំច្រើនពេកក្រៃ ព្រោះហេតុនៃកែវមណីនេះ ខ្ញុំនឹងមិនឲ្យកែវមណីនោះដល់លោក លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងមិនមកកាន់អាស្រមរបស់លោកទេ ។*

*លោកកាលសូមកែវមណីដែលកើតអំពីថ្ម នាំឲ្យខ្ញុំតក់ស្លុតដូចមនុស្សកំលោះមានដៃកាន់ដាវសំលៀងហើយដោយថ្ម មកញាំងខ្ញុំឲ្យតក់ស្លុត ដូច្នោះខ្ញុំមិនឲ្យកែវមណីនោះដល់លោកទេ ( ព្រោះ ) លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងលែងមកកាន់អាស្រមរបស់លោកហើយ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **មមន្នបានំ** បានដល់ ភោជនដែលជាទិព្វមានបបរនិងកត្តជាដើមនិងទឹកផឹកដែលជាទិព្វមានទឹកបាន: ៨ ប្រភេទរមែងកើតឡើងដល់ខ្ញុំ ។ បទថា **វិបុលំ** បានដល់ ច្រើន ។ បទថា **ឧឡារំ** បាន

ដល់ ប្រសើរ គឺប្រណីត ។ បទថា **តន្តេ** បានដល់ យើងនឹងមិនឲ្យកែវមណី នោះដល់លោក ។ បទថា **អតិយាចកោសិ** សេចក្តីថា លោកសូមកែវ-មណីដែលជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំអស់ ៣ ថ្ងៃរហូតដល់ថ្ងៃនេះកន្លងកាលនិងកន្លងកំណត់ប្រមាណឈ្មោះថាជាអ្នកសូមហួសហេតុ ។ បទថា **ន ចាបិ តេ** សេចក្តីថា យើងនឹងមិនឲ្យតែម្យ៉ាងប៉ុណ្ណោះក៏មិនមែនសូម្បីអាស្រមរបស់លោកយើងក៏មិនមក ។ បទថា **សុសូ យថា** បានដល់ ដូចបុរសកំលោះ ។ បទថា **សក្ខរធោតបាណី** បានដល់ អ្នកមានបាតដៃលាងហើយដោយទឹកស្អរក្រោម អធិប្បាយថា មានដៃកាន់ដាវដែលសំលៀងហើយត្រង់ថ្មដែលលាបដោយប្រេង ។ បទថា **តាសេសិមំ សេលំ យាចមានោ** សេចក្តីថា លោកកាលសូមកែវមណីនេះធ្វើឲ្យពុញទ្រាន់ដូចបុរសកំលោះផាដាវមានដងធ្វើដោយមាស ហើយពោលសម្តុតថា អញនឹងកាត់ក្បាលអា ។ ស្តេចនាគនោះកាលពោលយ៉ាងនេះហើយទើបមុជទឹកទៅកាន់នាគភិកពខណៈនោះឯងហើយមិនត្រឡប់មកទៀតឡើយ ។

តមកតាបសនោះ ត្រឡប់ជាអ្នកស្គមស្គាំង សៅហ្មង ពណ៌សម្បុរមិនស្អាត កើតជារោគស្គមលឿង មានខ្នួរវាមដោយសរសៃក្រៃលែងជាងមុន ព្រោះមិនបានឃើញស្តេចនាគដែលគួរមើលនោះ ។ ចំណែកតាបសដែលជាបងគិតថានឹងដឹងរឿងរបស់តាបសដែលជាប្អូនដូច្នេះហើយទើបទៅកាន់សម្នាក់របស់តាបសនោះ បានឃើញតាបសដែលជាប្អូននោះមានរោគស្គមលឿងខ្លាំងជាងមុនទើបពោលថា អ្នកដ៏ចម្រើន ព្រោះហេតុអ្វីលោកទើបកើតរោគស្គម

លឿនក្រៃលែងជាងមុន កាលបានស្តាប់ថាព្រោះមិនបានជួបស្តេចនាគដែលគួរមើលនោះទើបកំណត់បានថា តាបសនេះមិនអាចឃើញស្តេចនាគបានដូច្នេះហើយទើបពោលគាថាទី ៣ ថា

បុគ្គលដឹងនូវវត្ថុណាថាជាទីស្រឡាញ់របស់គេ មិនត្រូវសូមវត្ថុនោះទេ សេចក្តីស្អប់រមែងមានព្រោះការសូមជ្រុលពេក ដូចស្តេចនាគដែលត្រូវព្រាហ្មណ៍សូមកែវមណី ទៅកាន់ទីលែងមើលឃើញតាំងអំពីកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន តំ យាចេ** សេចក្តីថា មិនគប្បីសូមវត្ថុនោះ ។ បទថា **យស្ស បិយំ ជិគីសេ** សេចក្តីថា គប្បីដឹងថា វត្ថុណាដែលជាទីស្រឡាញ់របស់បុគ្គលនោះ ។ បទថា **ទេស្សោ ហោតិ** បានដល់ រមែងមិនជាទីស្រឡាញ់ ។ បទថា **អតិយាចនាយ** បានដល់ កាលសូមវត្ថុលើសប្រមាណនោះឯងឈ្មោះថា ព្រោះសូមហួសប្រមាណនោះ ។ បទថា **អទស្សនំ-យេវ តទជ្ឈគមា** បានដល់ បន្ទាប់អំពីនោះមកក៏មិនទៅឲ្យឃើញទៀតឡើយ ។

តាបសដែលជាបងកាលពោលចំពោះតាបសដែលប្អូនយ៉ាងនេះហើយទើបលួងលោមថា អ្នកដ៏ចម្រើន តាំងអំពីនេះទៅលោកកុំសោកសៅឡើយ ហើយត្រឡប់ទៅកាន់អាស្រមរបស់ខ្លួន ។ ក្នុងកាលតមកតាបសដែលជាបងប្អូនទាំង ២ នោះធ្វើឈាននិងសមាបត្តិឲ្យកើតឡើងហើយមានព្រហ្មលោកជាទីទៅខាងមុខ ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថា ការសូមមិនជាទីពេញចិត្តសូម្បីពួកនាគដែលនៅក្នុងនាគភិភព ដែលបរិ-

បូណ៌ដោយរតនៈទាំង ៧ ប្រការយ៉ាងនេះ នឹងបាច់ពោលថ្វីដល់មនុស្សទាំងឡាយ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា តាបសដែលជាប្អូនក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកតាបសដែលជាបងក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មណិកណ្ឋជាតក ចប់

# កុណ្ឌកកុច្ឆិសិន្ធវជាតក

[ ៣៦១ ] ( ឈ្មួញសេះពោធិសត្វពោលថា ) អ្នកធ្លាប់បរិភោគស្មៅដ៏សល់ដែល ធ្លាប់បរិភោគបាយក្តាំងនិងកុណ្ឌកមកហើយ នេះជាភោជនរបស់អ្នក ឥឡូវនេះហេតុអ្វីក៏អ្នកមិនបរិភោគ ។

[ ៣៦២ ] ( កូនសេះសិន្ធវៈពោលថា ) បពិត្រមហាព្រហ្ម ជនទាំងឡាយមិនស្គាល់សត្វដែលគួរចិញ្ចឹមដោយជាតិឬដោយមារយាទដែលគួរទូន្មានក្នុងទីណា ក្នុងទីនោះប្ញីក៏ខ្ញុំមិនបរិភោគបាយក្តាំងនិងកុណ្ឌកច្រើន ។

[ ៣៦៣ ] ចំណែកខាងលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះឧត្តមយ៉ាងណាៗ ខ្ញុំកាលដឹងព្រោះអាស្រ័យអ្នកជាអ្នកដឹងទើបមិនបរិភោគនូវកុណ្ឌករបស់អ្នក ។

**ចប់ កុណ្ឌកកុច្ឆិសិន្ធវជាតក ទី ៤ ។**

## អដ្ឋកថា

## កុណ្ឌកកុច្ឆិសិន្ធវជាតក

[ ៣៦១-៣៦៣ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ភុត្វា តិណបរិឃាសំ** ដូច្នេះជាដើម ។

បានឮថា សម័យមួយព្រះសម្មាសម្ពុទ្ធគង់នៅក្នុងនគរសាវត្ថី ចេញវស្សាហើយស្តេចចារិកហើយស្តេចយាងត្រឡប់មកទៀត ។ ជនទាំងឡាយគិតគ្នា

ថានឹងធ្វើអាគន្តុកសក្ការៈ ដូច្នេះហើយទើបថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាននាំគ្នាតាំងភិក្ខុដែលប្រកាសធម៌មួយរូបទុកក្នុងវិហារ ទាយកណាៗ ដែលមកត្រូវការភិក្ខុប្រមាណប៉ុនណា ភិក្ខុនោះចាត់ភិក្ខុឲ្យដល់ទាយកតាមចំនួនដែលត្រូវការ ។ គ្រានោះមានស្ត្រីចាស់ក្រីក្រម្នាក់បានចាត់ចែងចំណែកទានវត្ថុទុកមួយចំណែកនោះឯង កាលព្រះធម្មឃោសកភិក្ខុចាត់ភិក្ខុឲ្យដល់ជនទាំងនោះហើយក្នុងវេលាយឺតយូរជាងគេ នាងទើបទៅកាន់សម្នាក់របស់ព្រះធម្មឃោសកៈ ហើយពោលថា សូមលោកម្ចាស់ចាត់ភិក្ខុឲ្យដល់ខ្ញុំមួយរូបចុះ ។ ព្រះធម្មឃោសកៈពោលថា អាត្មាចាត់ភិក្ខុឲ្យទៅអស់ហើយ តែព្រះសារីបុត្តត្ថេរនៅក្នុងវិហារ ចូរនាងប្រគេនភិក្ខាហារដល់លោកចុះ ។ ស្ត្រីជរានោះត្រេកអរពោលថា សាធុ ឈរត្រង់ខ្លោងទ្វារវត្តជេតពនក្នុងវេលាព្រះថេរៈមក ទើបថ្វាយបង្គំហើយទទួលបាត្រអំពីដៃនាំទៅផ្ទះហើយនិមន្តឲ្យគង់ក្នុងផ្ទះ ។ ពួកត្រកូលដែលមានសទ្ធាដ៏ច្រើនបានឮថា ស្ត្រីជរាម្នាក់និមន្តព្រះធម្មសេនាបតីឲ្យគង់ក្នុងផ្ទះរបស់ខ្លួន ។ បណ្តាជនទាំងនោះព្រះបាទបសេនទិ-កោសលទ្រង់បានស្តាប់ហេតុនោះ ទើបទ្រង់បញ្ជូនកត្តនិងកាជនៈមួយអន្លើដោយសំពត់សាដកនិងថង់ទ្រព្យ ១០០០ ទៅឲ្យស្ត្រីជរានោះដោយព្រះតម្រាស់ថា ស្ត្រីជរាកាលនឹងអង្គាស លោកម្ចាស់របស់យើងចូរស្លៀកសំពត់សាដកនេះហើយចំណាយកហាបណៈទាំងនេះអង្គាសព្រះថេរៈចុះ ។ អនាថបិណ្ឌិកសេដ្ឋីចូឡអនាថបិណ្ឌិកសេដ្ឋី សុប្បវាសាវិសាខាមហាឧបាសិកាក៏បញ្ជូនទៅដូចដែលព្រះរាជាទ្រង់បញ្ជូនទៅ ។ ត្រកូលដទៃៗក៏បញ្ជូនកហាបណៈទៅតាមសមគួរ

ដល់កម្លាំងរៀងៗខ្លួនម្នាក់ ១០០ កហាបណខ្លះ ២០០ កហាបណៈខ្លះជាដើម ។ ដោយវិធីយ៉ាងនេះស្ត្រីជរានោះបានទ្រព្យប្រមាណ ១០០០០០ កហាបណៈ ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ។ ចំណែកព្រះថេរៈឆាន់យាគូចំពោះតែស្ត្រីជរានោះ ថ្វាយនិងឆាន់របស់ទំពានិងកត្តដែលចម្អិនហើយដែលស្ត្រីជរានោះធ្វើ ហើយពោលអនុមោទនា ឲ្យស្ត្រីជរានោះតាំងនៅក្នុងសោតាបត្តិផលរួចបានទៅកាន់វិហារនោះឯង ។ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាដល់គុណរបស់ព្រះថេរៈក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះធម្មសេនាបតីបានជាទីពឹង ជួយដោះស្ត្រីជរាដែលជាមេផ្ទះ ឲ្យផុតចាកភាពក្រីក្រ មិនរង្កៀសក្នុងអាហារដែលនាងប្រគេនយ៉ាងណា ។ ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តជាទីពឹងអាស្រ័យរបស់ស្ត្រីជរានេះតែក្នុងកាលឥឡូវនេះក៏មិនមែន ទាំងមិនរង្កៀសបរិភោគអាហារដែលនាងឲ្យក្នុងកាលឥឡូវនេះក៏មិនមែនសូម្បីក្នុងកាលមុនក៏បានបរិភោគដូចគ្នា ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលពាណិជក្នុងឧត្តរាបថជនបទ ។ ឈ្មួញសេះ ៥០០ នាក់ចេញអំពីឧត្តរាបថជនបទ នាំសេះមកលក់នៅក្នុងនគរពារាណសី ។ ឈ្មួញសេះម្នាក់ទៀតនាំសេះ ៥០០ ធ្វើដំណើរទៅកាន់នគរពារាណសី ( ដូច

គ្នា ) ។ ក្នុងចន្លោះផ្លូវមាននិគមមួយនៅក្នុងទីមិនឆ្ងាយអំពីនគរពារាណសី ។ កាលមុនមានសេដ្ឋីអ្នកមានទ្រព្យសម្បត្តិច្រើននៅក្នុងនិគមនោះនិវេសន៍របស់សេដ្ឋីនោះធំ ។ តែត្រកូលនោះ បានដល់នូវការវិនាសទៅដោយលំដាប់ ។ សល់តែស្ត្រីជរាម្នាក់ប៉ុណ្ណោះ ។ ស្ត្រីជរានោះអាស្រ័យនៅក្នុងនិវេសន៍នោះ ។ កាលនោះឈ្មួញសេះនោះទៅដល់និគមនោះហើយ និយាយចំពោះស្ត្រីជរាថា ខ្ញុំនឹងឲ្យឈ្នួលដល់នាងហើយស្នាក់អាស្រ័យនៅក្នុងនិវេសន៍របស់ស្ត្រីជរានោះ សូម្បីសេះក៏ចងទុកក្នុងទីបំផុតនាចំណែកម្ខាង ។ ក្នុងថ្ងៃនោះឯងមេសេះអាជានេយ្យមួយរបស់ឈ្មួញនោះកើតកូន ។ ឈ្មួញនោះស្នាក់នៅក្នុងទីនោះ ២-៣ ថ្ងៃល្មមឲ្យសេះទាំងឡាយមានកម្លាំងទើបពោលថា ខ្ញុំនឹងទៅគាល់ព្រះរាជា ទើបនាំសេះទាំងឡាយទៅ ។ លំដាប់នោះស្ត្រីជរាបាននិយាយជាមួយឈ្មួញនោះថា អ្នកចូរឲ្យឈ្នួលផ្ទះ ។ កាលឈ្មួញពោលថា សាធុ អ្នកម៉ែខ្ញុំនឹងឲ្យទើបនាងពោលថា នែបា កាលអ្នកឲ្យឈ្នួលផ្ទះដល់ខ្ញុំ ចូរឲ្យកូនសេះមួយនេះដោយកាត់ថ្លៃជាមួយឈ្នួលផ្ទះនោះ ។ ឈ្មួញនោះបានធ្វើយ៉ាងនោះហើយក៏ជៀសចេញទៅ ។ ស្ត្រីជរានោះចូលទៅតាំងសេចក្តីស្រឡាញ់ក្នុងកូនសេះនោះដូចជាបុត្ត កាលបើយ៉ាងនោះបានឲ្យកត្តដែលជាបាយក្តាំងនិងស្មៅដែលជាសំណល់ដល់កូនសេះនោះហើយប្រណិប័តន៍ ។ កាលក្រោយមកព្រះពោធិសត្វនាំសេះ ៥០០ ទៅស្នាក់អាស្រ័យនៅក្នុងផ្ទះនោះ ។ លុះបានក្លិនអំពីទីកូនសេះសិន្ធពបរិភោគកន្ទក់ សូម្បីសេះត្រឹមតែមួយក៏មិនអាចចូលទៅកាន់លានរបស់ផ្ទះនោះ ។ ទើបព្រះពោធិសត្វសួរស្ត្រីជរានោះថា បពិត្រ

អ្នកម៉ែក្នុងផ្ទះនេះមានសេះខ្វះដែរទេ ស្ត្រីជរាពោលថា នែបាឈ្មោះថា សេះដទៃមិនមានតែខ្ញុំប្រណិប័តន៍កូនសេះមួយដូចជាកូន កូនសេះនោះមាននៅក្នុងផ្ទះនេះ ។

ឈ្មួញពោលថា បពិត្រអ្នកម៉ែ កូនសេះនោះនៅឯណា ស្ត្រីជរាឆ្លើយថាត្រាច់ទៅរកស៊ីហើយបា ។ ឈ្មួញពោលថា វេលាណានឹងមក ។ ស្ត្រីជរាឆ្លើយថា ក្នុងពេលព្រលប់នោះឯងទើបមក ។ ព្រះពោធិសត្វកាលនឹងរង់ចាំការមករបស់កូនសេះសន្ធពនោះ ទើបចងសេះទាំងឡាយទុកខាងក្រៅហើយអង្គុយ ។ ចំណែកកូនសេះសន្ធពត្រាច់រកស៊ីហើយ លុះពេលព្រលប់ទើបត្រឡប់មក ។ ព្រះពោធិសត្វឃើញកូនសេះសន្ធពមានពោះប្រឡាក់កន្ទក់ពិចារណាលក្ខណៈទាំងឡាយហើយគិតថា សេះសន្ធពនេះមានតម្លៃច្រើន អញនឹងឲ្យតម្លៃដល់ស្ត្រីជរាហើយកាន់យកកូនសេះសិន្ធពទើបគួរ ។ ចំណែកកូនសេះសិន្ធពក៏ចូលផ្ទះឈរនៅក្នុងលំនៅរបស់ខ្លួនប៉ុណ្ណោះ ។ ខណៈនោះទើបសេះទាំងនោះអាចចូលទៅកាន់ផ្ទះបាន ។ ព្រះពោធិសត្វស្នាក់នៅ ២-៣ ថ្ងៃឲ្យស្មៅសេះទាំងឡាយឆ្អែតស្កប់ស្កល់ហើយកាលនឹងទៅទើបពោលថា បពិត្រអ្នកម៉ែ សូមកាន់យកតម្លៃហើយឲ្យកូនសេះនេះដល់ខ្ញុំ ។ ស្ត្រីជរាពោលថា នែបា អ្នកនិយាយអ្វីឈ្មោះថា បុគ្គលនឹងលក់បុត្ររមែងមិនមាន ឈ្មួញសួរថា បពិត្រអ្នកម៉ែ តើអ្នកម៉ែប្រណិប័តន៍សេះនេះដោយឲ្យស៊ីអ្វី ស្ត្រីជរាពោលថា នែបា ខ្ញុំឲ្យស៊ីបាយចុងអង្ករ បាយក្ដាំងនិងស្មៅដែលជារបស់សល់ដែលនិងឲ្យផឹកទឹកបបរដែលស្ងោរដោយកន្ទក់ប្រណិប័តន៍ ។ ឈ្មួញពោលថា

បពិត្រអ្នកម៉ែ បើខ្ញុំបានកូនសេះនេះហើយនឹងឲ្យបរិភោគភោជនមានរសឆ្ងាញ់ទាំងពុំហើយចងពិដានសំពត់ត្រង់ទីដែលសេះនេះឈរ ហើយឲ្យឈរលើតាំងដែលក្រាលទុក ។ ស្ត្រីជរាពោលថា នែបា កាលបើយ៉ាងនោះបុត្ររបស់យើងចូរសោយសុខដែលកើតអំពីភោគៈ ចូរបានាំយកទៅចុះ ។ លំដាប់នោះព្រះពោធិសត្វក៏ដាក់ថង់ទ្រព្យ ៦០០០ កហាបណៈជាតម្លៃត្រង់ជើងទាំង ៤ កន្ទុយនិងក្បាលរបស់កូនសេះនោះមួយកន្លែង ១០០០ កហាបណៈហើយឲ្យស្ត្រីជរាស្លៀកដណ្តប់សំពត់ថ្មីតាក់តែងហើយ ឲ្យឈរនៅខាងមុខកូនសេះសិន្ធព ។ កូនសេះសិន្ធពបើកភ្នែកមើលមាតាហើយសម្រក់ទឹកភ្នែក ។ ចំណែកស្ត្រីជរាអង្អែលខ្នងកូនសេះអាជានេយ្យនោះហើយពោលថា ម៉ែបានធ្វើការចិញ្ចឹមឯងដូចជាកូន ចូរកូនទៅចុះ ។ ខណៈនោះកូនសេះសិន្ធពនោះបានទៅហើយ ។ ថ្ងៃស្អែកឡើងព្រះពោធិសត្វចាត់ចែងភោជនមានរសសម្រាប់កូនសេះនោះគិតថា អញនឹងសាកល្បងកូនសេះនោះ កូនសេះនោះនឹងដឹងកម្លាំងរបស់ខ្លួនឬទេ ដូច្នេះហើយទើបឲ្យចាក់បបរដែលដាំដោយកន្ទក់ក្នុងស្នូកហើយឲ្យបរិភោគ ។ កូនសេះសិន្ធពនោះគិតថា អញនឹងមិនបរិភោគភោជននេះ ដូច្នេះហើយទើបមិនប្រាថ្នានឹងបរិភោគបបរនោះ ។ ព្រះពោធិសត្វកាលនឹងសាកល្បងសេះសិន្ធពនោះទើបពោលគាថាទី ១ ថា

អ្នកធ្លាប់បរិភោគស្មៅដ៏សល់ដែល ធ្លាប់បរិភោគបាយក្តាំងនិងកុណ្ឌកមកហើយ នេះជាភោជនរបស់អ្នក ឥឡូវនេះហេតុអ្វីក៏អ្នកមិនបរិភោគ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភុត្វា តិណបរិឃាសំ** សេចក្តីថា កាលមុនអ្នកធ្លាប់បរិភោគស្មៅដែលជារបស់សំណល់ គឺស្មៅដែលសល់អំពីសេះទាំងឡាយនោះៗ ដែលស្រ្តីជរាឲ្យរហូតដល់ធំធាត់ឡើង ។ ក្នុងបទថា **ភុត្វា អាចាមកុណ្ឌកំ** នេះ បាយបុងក្រោយដែលជាប់ត្រង់បាតឆ្នាំងហៅថា **អាចាម** ( បាយក្តាំង ) កន្ទក់នោះឯងហៅថា **កុណ្ឌក** ។ លោកសម្តែងថា អ្នកបរិភោគបាយក្តាំងនិងកុណ្ឌកនោះរហូតដល់ធំ ។ បទថា **ឯតំ តេ** សេចក្តីថា បាយក្តាំងនិងកុណ្ឌកនោះជាភោជនរបស់អ្នកក្នុងកាលមុន ។ បទថា **កស្មា-ទានិ ន ភុញ្ជសិ** សេចក្តីថា ព្រោះហេតុអ្វីឥឡូវនេះ ទើបអ្នកមិនបរិភោគបាយក្តាំងនិងកុណ្ឌកនោះ ។

កូនសេះសិន្ធពបានស្តាប់ដូច្នោះទើបបានពោលគាថា ២ ក្រៅអំពីនេះថា

បពិត្រមហាព្រហ្ម ជនទាំងឡាយ មិនស្គាល់សត្វដែលគួរចិញ្ចឹមដោយជាតិ ឬដោយមារយាទដែលគួរទូន្មាន ក្នុងទីណា ក្នុងទីនោះ ប្រាក៏ខ្ញុំមិនបរិភោគបាយក្តាំងនិងកុណ្ឌកច្រើន ។

ចំណែកខាងលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះឧត្តមយ៉ាងណាៗខ្ញុំកាលដឹងព្រោះអាស្រ័យអ្នកជាអ្នកដឹងទើបមិនបរិភោគនូវកុណ្ឌករបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យត្ថ** បានដល់ ក្នុងទីណា ។ បទថា **ពោសំ** បានដល់ សត្វ ។ បទថា **ជាតិយា វិនយេន វា** សេចក្តីថា ជនទាំងឡាយរមែងដឹងយ៉ាងនេះថា សេះនេះបរិបូណ៌ដោយជាតិឬទេ ឬថាប្រកបដោយ

មារយាទឬទេ ។ សេះសិន្ធពកាលនឹងហៅទើបពោលការហៅយ៉ាងគោរពថា បពិត្រមហាព្រហ្ម ( ព្រាហ្មណ៍ ) ។ បទថា **យានិសោយំ** កាត់បទជា **យានិសោ អយំ** ប្រែថា សេះនេះជាសេះយ៉ាងណា ។ សេះសិន្ធពពោលសំដៅដល់ខ្លួន ។ បទថា **ជានន្តោ ជានមាគម្ម** សេចក្តីថា ខ្ញុំដឹងកម្លាំងរបស់ខ្លួន ព្រោះអាស្រ័យបុគ្គលអ្នកដឹងនោះឯង តើនឹងបរិភោគកន្ទក់ក្នុងសម្នាក់របស់អ្នកដូចម្តេចកើត ឯអ្នកឲ្យទ្រព្យ ៦០០០ ហើយនាំយកខ្ញុំមកព្រោះប្រាថ្នានឹងឲ្យបរិភោគកន្ទក់ក៏មិនមែន ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបលួងលោមកូនសេះសិន្ធពនោះថា ខ្ញុំធ្វើដូច្នោះដើម្បីនឹងសាកល្បង អ្នកកុំក្រោធឡើយ ។ ហើយឲ្យបរិភោគភោជនល្អនាំទៅកាន់លានព្រះរាជវាំងចងសេះ ៥០០ ទុកក្នុងចំណែកម្ខាង ចំណែកម្ខាងទៀតព័ទ្ធដោយវាំងននដ៏វិចិត្រក្រាលកម្រាលខាងក្រោមខាងលើចងពិដានសំពត់ឲ្យកូនសេះសិន្ធពឈរក្នុងទីនោះ ។ ព្រះរាជាយាងមកទតមើលហ្វូងសេះត្រាស់សួរថា ហេតុដូចម្តេចទើបសេះនេះទុកដោយឡែក ទ្រង់បានស្តាប់ថា សេះនេះជាសេះសិន្ធព បើមិនបំបែក ( ពីគេ ) សេះទាំងនេះនឹងដាច់រត់ទៅដូច្នេះហើយទើបត្រាស់សួរថា នែបាដ៏ចម្រើន សេះសិន្ធពស្រស់ស្អាតវាងវៃឬ ព្រះពោធិសត្វក្រាបទូលថា ស្រស់ស្អាតវាងវៃព្រះអង្គ កាលព្រះរាជាត្រាស់ថា បើយ៉ាងនោះយើងនឹងមើលការវាងវៃរបស់សេះសិន្ធព្វនេះ ទើបចងសេះនោះហើយឡើងជិះក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទតហើយឲ្យពួកមនុស្សជៀសចេញទៅហើយបំផាយសេះទៅក្នុងលានព្រះរាជ

វាំង ។ លានព្រះរាជវាំងទាំងមូលមានស្រមោលសេះជាប់តគ្នាតែមួយ ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទតសន្ទុះរបស់កូនសេះសិន្ធពហើយដេញចេញទៅទៀត ។ សូម្បីមនុស្សត្រឹមតែម្នាក់ក៏មើលមិនឃើញកូនសេះសិន្ធពនោះ ។ ព្រះពោធិសត្វ ទើបយកផ្ទាំងសំពត់ក្រហមចងត្រង់ពោះហើយលែងចេញទៅទៀត ។ ពួកមហាជនឃើញតែផ្ទាំងសំពត់ក្រហមដែលគេចងត្រង់ពោះរបស់កូនសេះសិន្ធពនោះប៉ុណ្ណោះ ។ លំដាប់នោះព្រះពោធិសត្វក៏លែងសេះសិន្ធពនោះខាងលើស្រះទឹកបោក្ខរណីមួយកន្លែងក្នុងឧទ្យានខាងក្នុងព្រះនគរ ។ កាលសេះសិន្ធពនោះរត់ទៅលើខ្នងទឹកស្រះបោក្ខរណីនោះសូម្បីតែចុងក្រចកក៏មិនសើម ។ កាលរត់ទៅលើស្លឹកឈូកម្តងទៀត ស្លឹកឈូកត្រឹមតែមួយក៏មិនបានលិចទៅក្នុងទឹក ។ ព្រះពោធិសត្វកាលសម្តែងសម្បត្តិនៃភាពរហ័សរបស់កូនសេះសិន្ធពនោះយ៉ាងនេះហើយទើបចុះអំពីសេះទះដៃហើយលាដៃចូលទៅ សេះលោតឡើងទៅឈរលើបាតដៃ ធ្វើជើងទាំង ៤ ឲ្យប្រជុំនៅក្នុងកន្លែងតែមួយ ។ លំដាប់នោះព្រះមហាសត្វក្រាបទូលព្រះរាជាថា បពិត្រមហារាជ កាលទូលព្រះបង្គំសម្តែងកម្លាំងរបស់អស្សបោតកៈនេះដោយអាការគ្រប់យ៉ាង កាលទ្រង់រក្សាទុកក្នុងដែនដែលមានសមុទ្ទជាព្រំប្រទល់ ក៏រមែងមិនល្មមនឹងរក្សាទុកបាន ។ ព្រះរាជាទ្រង់ពេញព្រះហឫទ័យបានប្រទានតំណែងឧបរាជដល់ព្រះមហាសត្វ បានអភិសេកកូនសេះសិន្ធពហើយតាំងឲ្យជាសេះមង្គល ។ កូនសេះសិន្ធពនោះបានជាទីស្រឡាញ់ប្រោសប្រាណរបស់ព្រះរាជា ។ សូម្បីសក្ការៈក៏បានកើតមានច្រើនដល់កូនសេះសិន្ធព

នោះ ៗ ទីលំនៅរបស់កូនសេះសិន្ធពនោះដូចផ្ទះដែលអប់ដោយក្លិនដែលព្រះរាជាទ្រង់ប្រដាប់តាក់តែងទុកបានធ្វើការបូកលាបដោយគន្ធជាតិ ៤ ប្រការឲ្យសំយុងផ្កាកម្រងនិងគ្រឿងក្រអូបអំពីខាងលើ មានពិដានសំពត់វិចិត្រដោយផ្កាយមាស បានចងវាំងននដ៏វិចិត្រទុកជុំវិញពិដាន តាំងប្រទីបប្រេងគ្រឿងក្រអូបទុកជានិច្ចឲ្យតម្កល់ផើងមាសទុកក្នុងទីដែលកូនសេះសិន្ធពនោះបន្ទោបង់ឧច្ចារៈនិងបស្សាវៈ បរិភោគភោជនដែលជាព្រះស្ងោយសម្រាប់ព្រះរាជា ជានិច្ចនោះឯង ៗ ចាប់តាំងអំពីកូនសេះសិន្ធពនោះមករាជសម្បត្តិក្នុងសកលជម្ពូទ្វីបបានតាំងនៅក្នុងកណ្ដាប់ព្រះហស្ដរបស់ព្រះរាជាទាំងអស់ ៗ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វទ្រង់បំពេញបុណ្យទាំងឡាយមានទានជាដើមមានស្ថានសួគ៌ជាទីទៅខាងមុខ ៗ

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ មហាជនបានជាសោតាបន្នសកទាគាមី អនាគាមីនិងព្រះអរហត្តហើយទ្រង់ប្រជុំជាតកថា ស្ដ្រីជរាក្នុងកាលនោះបានមកជាស្ដ្រីជរានេះក្នុងកាលឥឡូវនេះ សេះសិន្ធពក្នុងកាលនោះបានមកជាព្រះសារីបុត្ត ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ ចំណែកឈ្មួញសេះក្នុងកាលនោះ គឺតថាគតនេះឯង ៗ

## អដ្ឋកថា កុណ្ឌកកុច្ឆិសិន្ធវជាតក ចប់

# សុកជាតក

[ ៣៦៤ ] ( ព្រះសាស្តាត្រាស់ថា ) សត្វហើរ គឺសេកនោះដឹងប្រមាណក្នុងភោជនដរាបណា ក៏បានដល់នូវអាយុវែងផង បានចិញ្ចឹមមាតាផងដរាបនោះ ។

[ ៣៦៥ ] មួយទៀត សេកនោះបរិភោគនូវភោជនដ៏ច្រើនលើសលុបក្នុងកាលណា ក៏លិចចុះក្នុងសមុទ្រនោះឯងក្នុងកាលនោះ ព្រោះសេកនោះមិនស្គាល់ប្រមាណ ។

[ ៣៦៦ ] ព្រោះហេតុនោះការដឹងប្រមាណ មិនល្មោភក្នុងភោជនជាការប្រពៃព្រោះពួកជនដែលមិនដឹងប្រមាណរមែងលិច ពួកជនដែលដឹងប្រមាណរមែងមិនលិចទេ ។

**ចប់ សុកជាតក ទី ៥ ។**

# អដ្ឋកថា

# សុកជាតក

[ ៣៦៤-៣៦៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូបដែលមរណភាពព្រោះឆាន់ច្រើនពេក រហូតដល់អាហារមិនរលាយទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យាវ សោ មត្តមញ្ញាសិ** ដូច្នេះជាដើម ។

បានឮថា កាលភិក្ខុនោះមរណភាពទៅយ៉ាងនេះហើយ ភិក្ខុទាំងឡាយ

អន្តុយសន្ទនាគ្នាដល់ទោសដែលមិនមែនជាគុណរបស់ភិក្ខុរូបនោះ ក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុឈ្មោះនោះមិនដឹងប្រមាណផ្ទៃរបស់ខ្លួន បរិភោគហួសប្រមាណមិនអាចធ្វើអាហារឲ្យរលាយទើបមរណភាព ។ ព្រះសាស្តាទ្រង់យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនភិក្ខុនេះក៏ស្លាប់ព្រោះបរិភោគហួសប្រមាណជាបច្ច័យ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសត្វសេកក្នុងព្រៃហិមពាន្ត បានជាស្តេចរបស់សេកច្រើនពាន់នៅក្នុងហិមវន្តប្បទេសដែលលាតសន្ធឹងទៅតាមសមុទ្ទ ។ ព្រះពោធិសត្វនោះមានកូនមួយ កាលកូននោះចម្រើនវ័យហើយព្រះពោធិសត្វក៏មានចក្ខុទុព្វល ។ បានឮថា សេកទាំងឡាយមានសន្ទុះរហ័សដោយហេតុនោះក្នុងវេលាដែលសេកទាំងនោះចាស់ចក្ខុនោះទើបទុព្វលមុន ។ កូនសេកនោះឲ្យមាតាបិតានៅក្នុងសម្បុកហើយនាំយកអាហារមកចិញ្ចឹម ។ ថ្ងៃមួយកូនសេកនោះបានទៅកាន់ទីរកស៊ីហើយទំលើកំពូលភ្នំសម្លឹងមើលសមុទ្ទ បានឃើញកោះមួយ ។ត្រង់កោះនោះមានព្រៃស្វាយមានផ្លែផ្អែមមានពណ៌ដូចមាស ។ ស្អែកឡើងដល់វេលារកស៊ីកូនសេកនោះហើរទៅចុះត្រង់ព្រៃស្វាយនោះ ផឹក

រសស្វាយហើយបានពាំយកផ្លែស្វាយទុំមកឲ្យមាតាបិតា ។ ព្រះពោធិសត្វបរិភោគផ្លែស្វាយនោះហើយចាំរសបានទើបពោលថា នែកូន នេះជាផ្លែស្វាយទុំក្នុងកោះនោះមិនមែនឬ កាលកូនសេកទទួលថា មែនហើយលោកពុក ទើបពោលថា នែកូន ពួកសេកដែលទៅកាន់កោះនោះឈ្មោះថា រក្សាអាយុឲ្យយឺនយូរបានមិនមានឡើយបាកុំទៅកោះនោះទៀតឡើយ ។ កូនសេកនោះមិនជឿពាក្យរបស់ព្រះពោធិសត្វនោះនៅតែទៅទៀត ។ ថ្ងៃមួយកូនសេកផឹករសស្វាយជាច្រើនហើយពាំយកស្វាយទុំមកដើម្បីមាតាបិតា កាលហើរដល់កណ្តាលសមុទ្រព្រោះហើរលឿនពេកកាយក៏អស់កម្លាំងត្រូវការងោកងុយគ្របសង្កត់ទាំងដែលដេកលក់ក៏នៅតែហើរមកនោះឯង ។ ចំណែកស្វាយទុំដែលពាំមកដោយចំពុះក៏ជ្រុះទៅ ។ កូនសេកនាះបានលះផ្លូវដែលធ្លាប់មកដោយលំដាប់ទើបធ្លាក់ទៅក្នុងទឹក ។ កូនសេកនោះអណ្តែតមកតាមខ្សែទឹកទើបលិចទៅក្នុងទឹក ។ ពេលនោះត្រីមួយពាំកូនសេកនោះយកទៅស៊ី ។ កាលកូនសេកនោះមិនមកតាមកាលដែលធ្លាក់មកព្រះពោធិសត្វក៏ដឹងបានថា ( កូនរបស់យើង ) ប្រហែលជាធ្លាក់ក្នុងសមុទ្រស្លាប់ហើយ ។ កាលនោះមាតាបិតារបស់កូនសេកនោះកាលមិនបានអាហារក៏ស្គមស្លាប់ទៅ ។

ព្រះសាស្តាកាលទ្រង់នាំយករឿងក្នុងអតីតមកសាធកៈហើយ ទើបត្រាស់ព្រះគាថាដែលជាអភិសម្ពោធិគាថាទាំងនេះថា

សត្វហើរ គឺសេកនោះដឹងប្រមាណក្នុងភោជនដរាបណាក៏
បានដល់នូវអាយុវែងផង បានចិញ្ចឹមមាតាផងដរាបនោះ ។

មួយទៀត សេកនោះបរិភោគនូវភោជនដ៏ច្រើនលើសលុប ក្នុងកាលណាក៏លិចចុះក្នុងសមុទ្រនោះឯងក្នុងកាលនោះ ព្រោះសេកនោះមិនស្គាល់ប្រមាណ ។

ព្រោះហេតុនោះការដឹងប្រមាណ មិនល្មោភក្នុងភោជនជាការប្រពៃព្រោះពួកជនដែលមិនដឹងប្រមាណរមែងលិច ពួកជនដែលដឹងប្រមាណរមែងមិនលិចទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យាវ សោ** សេចក្ដីថា បក្សីនោះបានដឹងប្រមាណក្នុងភោជនដរាបណា ។ បទថា **តាវ អទ្ធានមាបាទិ** សេចក្ដីថា ឲ្យដល់ភាពជាអ្នករស់នៅបានយូរ គឺបាននូវអាយុអស់កាលដរាបនោះ ។ បទថា **មាតរញ្ច** នេះត្រឹមតែជាមាតិកានៃទេសនា អធិប្បាយថា បានចិញ្ចឹមមាតាបិតា ។ បទថា **យតោ ច ខោ** បានដល់ ក្នុងកាលណា ។ បទថា **ភោជនំ អជ្ឈវាហរិ** សេចក្ដីថា បរិភោគសេស្វាយ ។ បទថា **តតោ** បានដល់ ក្នុងកាលនោះ ។ បទថា **តត្ថេវ សំសីទិ** សេចក្ដីថា លិចចុះ គឺលិចចុះក្នុងសមុទ្រនោះឯង ដល់នូវភាពជាអាហាររបស់ត្រី ។ បទថា **តស្មា មត្ត-ញ្ញុតា សាធុ** សេចក្ដីថា ព្រោះហេតុដែលសេកមិនដឹងប្រមាណក្នុងភោជនទើបធ្លាក់ចុះក្នុងសមុទ្រស្លាប់ ព្រោះហេតុនោះ ភាពជាអ្នកដឹងប្រមាណ ពោលគឺភាពជាអ្នកមិនជាប់នៅក្នុងភោជនជាការល្អ អធិប្បាយថា ការដឹងប្រមាណជាការល្អ ។ម្យ៉ាងទៀតសូម្បីភាពជាអ្នកដឹងប្រមាណក៏ជាការល្អ ដែលលោកពណ៌នាទុកយ៉ាងនេះថា ភិក្ខុពិចារណាដោយឧបាយហើយ បរិភោគ

អាហារមិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង ។បេ។ ការនៅយ៉ាងផាសុក និងពុទ្ធដីកាក្នុង ( សំយុត្តនិកាយសគាថវគ្គនិងខុទ្ទកនិកាយថេរគាថា ) ថា

ភិក្ខុកាលបរិភោគនូវអាហារស្រស់ឬក្រៀម មិនគប្បីឲ្យឆ្អែតជ្រុលទេ គប្បីជាអ្នកមានពោះធូរ មានអាហារដ៏ល្មម មានស្មារតីវៀរចេញ ។ ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត ) ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខនៃភិក្ខុអ្នកមានចិត្តស្ងួតទៅរក ( ព្រះនិព្វាន ) ដូច្នេះ ។

សូម្បីភាពជាអ្នកដឹងប្រមាណក្នុងភោជនក៏ជាការល្អ ដែលលោកពណ៌នាទុកយ៉ាងនេះថា

មនុស្សមានស្មារតីសព្វកាល ដឹងប្រមាណក្នុងភោជនដែលខ្លួនបានហើយ រមែងមានវេទនាស្រាល អាហារនោះតែងរក្សាអាយុជ្រួតជ្រាបបន្តិចម្តងៗ ដូច្នេះ ។

សូម្បីភាពជាបុគ្គលមិនជាប់ចំពាក់ក៏ជាការល្អ ដែលលោកពោលទុក ( ក្នុងវិសុទ្ធិមគ្គ ) ថា

បុគ្គលមិនជាប់ក្នុងរស រមែងបរិភោគអាហារដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដូចបុគ្គលបរិភោគសាច់កូនក្នុងផ្លូវកន្តារនិងដូចបុគ្គលប្រើតំណក់ប្រេងបន្តក់ក្លៀវរថដូច្នោះ ។

តែក្នុងព្រះបាលីលោករចនាទុកថា **អតិត្ថិជា** បាឋៈក្នុងអដ្ឋកថានេះពីព្រោះ

ជាងបាលីនោះ ។ បទថា **អមត្តញ្ញូហិ សីទន្តិ** សេចក្ដីថា ដ្បិតថា បុគ្គល ដែលមិនដឹងប្រមាណក្នុងភោជនធ្វើកម្មដ៏លាមក ដោយអំណាចសេចក្ដីប្រាថ្នាក្នុង រសរមែងលិចចុះក្នុងអបាយទាំង ៤ ។ បទថា **មត្តញ្ញូ ច សីទរេ** សេចក្ដី ថា ចំណែកជនពួកណារមែងស្គាល់ប្រមាណក្នុងភោជន ជនទាំងនោះរមែង មិនលិចចុះទាំងក្នុងទិដ្ឋធម៌ទាំងក្នុងសម្បរាយិកភព ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ មហាជនបានសោតាបន្នខ្លះ សកទាគាមីខ្លះ អនាគាមីខ្លះ អរហត្តខ្លះ ។ ហើយទ្រង់ប្រជុំជាតកថា កូន សេករបស់ស្ដេចសេកក្នុងកាលនោះ បានមកជាភិក្ខុអ្នកមិនដឹងប្រមាណក្នុង ភោជនក្នុងកាលឥឡូវនេះ ចំណែកស្ដេចសេកក្នុងកាលនោះ គឺតថាគតនេះ ឯង ។

## អដ្ឋកថាសុកជាតក ចប់

## ជរូទបានជាតក

[ ៣៦៧ ] ( ព្រះសាស្តាត្រាស់ថា ) ពួកឈ្មួញអ្នកត្រូវការដោយទឹក កាលជីកអណ្តូងចាស់ ក៏បាននូវដែកនឹងទង់ដែងផង នូវសំណរកក់ផង នូវកែវមណីទាំងឡាយផង នូវប្រាក់នឹងមាសផង នូវកែវមុក្តានិងកែវពៃទូរ្យទាំងឡាយផងដ៏ច្រើន ។

[ ៣៦៨ ] តែពួកឈ្មួញទាំងនោះមិនសន្តោសដោយទ្រព្យនោះ រឹងរឹតតែជីកចុះទៅទៀត សត្វមានពិសដ៏ក្លៀវក្លា មានតេជះក៏សម្លាប់នូវពួកឈ្មួញទាំងនោះដោយតេជះ ( នៃពិស ) ក្នុងអណ្តូងទឹកនោះឯង ។

[ ៣៦៩ ] ព្រោះហេតុនោះបុគ្គលគប្បីជីក តែកុំជីកឲ្យជ្រៅហួសពេក ព្រោះការជីកអណ្តូងជ្រៅហួសពេកជាការលាមក ទ្រព្យ ( ដែលពួកឈ្មួញ ) បានហើយដោយការជីកក៏វិនាសអស់ព្រោះតែការជីកជ្រៅហួសពេក ។

**ចប់ ជរូទបានជាតក ទី ៦ ។**

## អដ្ឋកថា

## ជរូទបានជាតក

[ ៣៦៧-៣៦៩ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញអ្នកនគរសាវត្ថី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ជរូទបានំ ខណមានា** ដូច្នេះជាដើម ។

បានឮថា ឈ្មួញទាំងនោះទិញទំនិញក្នុងនគរសាវត្ថីដាក់រទេះ ក្នុងវេលា

នឹងទៅដើម្បីត្រូវការលក់ បាននិមន្តព្រះសាស្តាមកហើយថ្វាយមហាទានទទួលសរណៈតាំងនៅក្នុងសីល ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គទាំងឡាយនឹងធ្វើដំណើរផ្លូវឆ្ងាយដើម្បីលក់ទំនិញ កាលលក់ទំនិញអស់ បានធ្វើដំណើរត្រឡប់មកដោយផុតភ័យនឹងថ្វាយបង្គំព្រះអង្គទៀត កាលក្រាបទូលហើយក៏ធ្វើដំណើរទៅ ។ ឈ្មួញទាំងនោះបានជួបអណ្តូងទឹកបុរាណក្នុងផ្លូវកន្តារទើបពោលថា ក្នុងអណ្តូងនេះមិនមានទឹកផឹក ពួកយើងក៏ស្រេកទឹកនឹងជីកអណ្តូងនោះពោលហើយក៏នាំគ្នាជីក បានដែក ។បេ។ កែវពិទូរ្យដ៏ច្រើនតាមលំដាប់ ។ ឈ្មួញទាំងនោះជាអ្នកសន្តោសដោយទ្រព្យទាំងនោះ យករតនៈទាំងនោះដាក់ពេញរទេះត្រឡប់មកកាន់នគរសាវត្ថីដោយផុតភ័យ ។ ឈ្មួញទាំងនោះទុកដាក់ទ្រព្យដែលបានមកហើយគិតគ្នាថា ពួកយើងដើរផ្លូវផុតភ័យហើយនឹងថ្វាយទាន ដូច្នេះហើយទើបនិមន្តព្រះសាស្តាថ្វាយទាន ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលដល់ហេតុការណ៍ដែលខ្លួនបានទ្រព្យដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយជាឧបាសក សន្តោសដោយទ្រព្យនោះទើបបាននូវទ្រព្យនិងជីវិតព្រោះភាពជាអ្នកដឹងប្រមាណ ចំណែកមនុស្សអំពីមុនជាអ្នកមិនសន្តោស មិនស្គាល់ប្រមាណ មិនធ្វើតាមពាក្យរបស់បណ្ឌិតទាំងឡាយទើបដល់នូវការអស់ជីវិត កាលឈ្មួញទាំងនោះអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វកើតក្នុងត្រកូលឈ្មួញក្នុងនគរពារាណសី លុះចម្រើនវ័យហើយ បានជាប្រធានឈ្មួញរទេះ ។ ព្រះពោធិសត្វនោះទិញទំនិញក្នុងនគរពារាណសី ដាក់ពេញរទេះនាំពួកឈ្មួញដ៏ច្រើនដើរទៅកាន់ផ្លូវកន្តារនោះដូចគ្នា បានឃើញអណ្តូងទឹកដូចគ្នា ។ ក្នុងទីនោះឈ្មួញទាំងនោះនិយាយគ្នាថានឹងជីកទឹកទើបជីកអណ្តូងនោះបានទ្រព្យមានដែកជាដើមច្រើនដោយលំដាប់ ។ ឈ្មួញទាំងនោះបានរតនៈច្រើនក៏មិនសន្តោស គឺត្រេកអរតាមដែលបានរតនៈនោះនាំគ្នាជីកអណ្តូងនោះក្រៃលែងឡើងដោយបំណងថា ក្នុងអណ្តូងនេះនឹងមានវត្ថុដទៃដែលល្អជាងរតនៈនេះ ។ លំដាប់នោះព្រះពោធិសត្វក៏ពោលនឹងឈ្មួញទាំងនោះថា នៃឈ្មួញទាំងឡាយដ៏ចម្រើនដែលឈ្មោះថា សេចក្តីលោភនេះជាឫសគល់នៃសេចក្តីវិនាស ពួកអ្នកបានទ្រព្យច្រើនហើយ ចូរសន្តោសដោយទ្រព្យមានប្រមាណប៉ុណ្ណេះចុះ កុំជីកជ្រៅជាងនេះតទៅទៀតឡើយ ។ ឈ្មួញទាំងនោះសូម្បីត្រូវព្រះពោធិសត្វហាមក៏នៅតែជីកនោះឯង ។ អណ្តូងនោះមាននាគហួងហែង ។ លំដាប់នោះស្តេចនាគដែលនៅខាងក្រោមអណ្តូងនោះ កាលវិមានរបស់ខ្លួនត្រូវទម្លាយ កាលដុំដីនិងធូលីធ្លាក់លើក៏ក្រោធប្រើខ្យល់ច្រមុះផ្លុំឈ្មួញទាំងអស់ឲ្យដល់នូវការអស់ជីវិតមិនមានសេសសល់ឡើយ វៀរតែព្រះពោធិសត្វហើយចេញចាកនាគពិភព ឲ្យទឹមរទេះដាក់រតនៈទាំងឡាយរហូតពេញ ឲ្យព្រះពោធិសត្វអង្គុយក្នុងយានតូចដ៏សប្បាយ ។ ពួកនាគមាណពបររទេះនាំព្រះពោធិសត្វទៅកាន់នគរពារាណសី ចូលទៅកាន់ផ្ទះរក្សាទ្រព្យហើយក៏ទៅកាន់នាគពិភពរបស់ខ្លួនវិញ ។ ព្រះពោធិសត្វចាយទ្រព្យនោះធ្វើ

ឲ្យជម្ពូទ្វីបទាំងមូលឲ្យមាននន្ទ័លលើកឡើងហើយឲ្យទានសមាទានសីល រក្សាឧបោសថ ក្នុងកាលអស់ជីវិតបានទៅកើតក្នុងស្ថានសួគ៌ ។

ព្រះសាស្តាកាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ដឹងក្រៃលែងហើយទើបត្រាស់គាថាទាំងនេះថា

ពួកឈ្មួញអ្នកត្រូវការដោយទឹក កាលជីកអណ្តូងចាស់ក៏បាននូវដែកនិងទង់ដែងផង នូវសំណរកក់ផង នូវកែវមណីទាំងឡាយផង នូវប្រាក់និងមាសផង នូវកែវមុក្តានិងកែវពៃទូរ្យទាំងឡាយផងដ៏ច្រើន ។

តែពួកឈ្មួញទាំងនោះមិនសន្តោសដោយទ្រព្យនោះ រឹងរឹតតែជីកចុះទៅទៀត សត្វមានពិសដ៏ក្លៀវក្លា មានតេជះក៏សម្លាប់នូវពួកឈ្មួញទាំងនោះដោយតេជះ ( នៃពិស ) ក្នុងអណ្តូងទឹកនោះឯង ។

ព្រោះហេតុនោះបុគ្គលគប្បីជីក តែកុំជីកឲ្យជ្រៅហួសពេក ព្រោះការជីកអណ្តូងជ្រៅហួសពេកជាការលាមក ទ្រព្យ ( ដែលពួកឈ្មួញ ) បានហើយដោយការជីកក៏វិនាសអស់ ព្រោះតែការជីកជ្រៅហួសពេក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយំ** បានដល់ លោហៈពណ៌ខ្មៅ ។ បទថា **លោហំ** បានដល់ លោហៈពណ៌ក្រហម ។ បទថា **មុត្តា** បានដល់ កែវមុក្តាជាដើម ។ បទថា **តេ ច តេន អសន្តុដ្ឋា** សេចក្តីថា ឈ្មួញ

ទាំងនោះមិនបានត្រេកអរដោយទ្រព្យនោះ ។ បទថា **តេ តត្ថ** បានដល់ ឈ្មួញទាំងនោះក្នុងអណ្តូងនោះ ។ បទថា **តេជសី** បានដល់ ជាអ្នកប្រកបដោយតេជះនៃពិស ។ បទថា **តេជសា ហនិ** បានដល់ សម្លាប់ដោយតេជះនៃពិស ។ បទថា **អតិក្ខាតេន ឆាសិតំ** សេចក្តីថា ព្រោះជីកជ្រៅពេកទើបទ្រព្យនិងជីវិតនោះវិនាសទៅ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ស្តេចនាគក្នុងកាលនោះបានមកជាសារីបុត្តក្នុងកាលឥឡូវនេះ ចំណែកប្រធានឈ្មួញក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ជវូទបានជាតក ចប់**

# គាមណិចណ្ឌជាតក

[ ៣៧០ ] ( ព្រះរាជកុមារពោធិសត្វពោលថា ) សត្វនេះជាសត្វមិនឈ្លាស ( ក្នុងការធ្វើ ) នូវផ្ទះទាំងឡាយ សត្វនេះជាសត្វខិលខូច មានមុខជ្រួញ បានតែខាងប្រទូស្តចំពោះកិច្ចការដែលគេធ្វើហើយៗ ត្រកូលនេះជាធម្មតាយ៉ាងនេះឯង ។

[ ៣៧១ ] រោមនេះមិនមែនជារោមនៃសត្វមានចិត្ត ( សម្បយុត្តដោយបញ្ញាជាគ្រឿងពិចារណា ) ទេ ម្រឹគ គឺស្វានេះមិនអាចធ្វើគេឲ្យចូលចិត្តបានទេ ក្បួនខ្នាតព្រះរាជបិតារបស់ខ្ញុំទ្រង់ព្រះនាមជនសន្ធៈ ( បានត្រាស់ហើយ ) ថា ស្វានេះមិនដឹងនូវហេតុតិចតួចឡើយ ។

[ ៣៧២ ] បុរសប្រាកដដូច្នោះមិនគប្បីចិញ្ចឹមនូវមាតាបិតា បងប្អូនប្រុសនិងបងប្អូនស្រីរបស់ខ្លួនបានទេ ព្រះបាទទសរថ ( ជាព្រះបិតា ) បានប្រៀនប្រដៅខ្ញុំ ( យ៉ាងនេះ ) ។

**ចប់ គាមណិចន្ទជាតក ទី ៧ ។**

## អដ្ឋកថា

## គាមណិចណ្ឌជាតក

[ ៣៧០-៣៧២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសរសើរបញ្ញា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆាយំ យវានំ កុសលោ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុទាំងឡាយអង្គុយសរសើរបញ្ញារបស់ព្រះទសពលក្នុងធម្ម-សភាថា អាវុសោទាំងឡាយ ព្រះតថាគតទ្រង់មានព្រះបញ្ញាជាធំ មានព្រះបញ្ញាដ៏ក្រាស់ មានព្រះបញ្ញានាំឲ្យរីករាយ មានព្រះបញ្ញាជាគ្រឿងស្ទុះទៅ មានព្រះបញ្ញាដ៏មុត មានព្រះបញ្ញាជាគ្រឿងទម្លុះទម្លាយឈានកន្លងលោកនេះព្រមទាំងទេវលោកដោយព្រះបញ្ញា ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនតថាគតក៏មានបញ្ញាដូចគ្នា ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះរាជាព្រះនាមថា ជនសន្ធៈសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះពោធិសត្វកើតក្នុងព្រះឧទរនៃព្រះអគ្គមហេសីរបស់ព្រះរាជានោះ ។ មុខរបស់ព្រះពោធិសត្វនោះស្រស់ស្អាត បរិសុទ្ធដូចកញ្ចក់មាសដល់នូវលម្អដ៏ក្រៃលែង ។ ដោយហេតុនោះក្នុងថ្ងៃដាក់ឈ្មោះ ញាតិទាំងឡាយទើបដាក់ឈ្មោះរបស់ព្រះពោធិសត្វនោះថា **អាទាសមុខកុមារ** ។ ខាងក្នុង ៧ ឆ្នាំប៉ុណ្ណោះព្រះជនកឲ្យកុមារនោះសិក្សាគម្ពីរវេទទាំង ៣ និងវត្ថុទាំងពួងដែលគប្បីធ្វើក្នុងលោក ហើយបានសោយទិវង្គតក្នុងពេលដែលព្រះរាជកុមារនោះមានអាយុ ៧ ឆ្នាំ ។ អាមាត្យទាំងឡាយបានថ្វាយព្រះភ្លើងព្រះសពរបស់ព្រះរាជាដោយបរិវារធំហើយថ្វាយទានសម្រាប់មនុស្សស្លាប់ ក្នុងថ្ងៃទី ៧ ប្រជុំ

គ្នាត្រង់លានព្រះរាជវាំងពិភាក្សាគ្នាថា ព្រះរាជកុមារនៅក្មេងពេកមិនអាចអភិសេកឲ្យគ្រងរាជបាន ពួកយើងនឹងសាកល្បងព្រះរាជកុមារនោះសិនសឹមអភិសេក ។ ថ្ងៃមួយអាមាត្យទាំងនោះឲ្យតាក់តែងព្រះនគរ រៀបចំទីវិនិច្ឆ័យឲ្យតាក់តែងបល្ល័ង្កហើយទៅគាល់ព្រះរាជកុមារទូលថា បពិត្រព្រះសម្មតិទេពព្រះអង្គគួរយាងទៅកាន់ទីសម្រាប់វិនិច្ឆ័យ ។ ព្រះរាជកុមារទទួលពាក្យថាសាធុ ហើយក៏យាងទៅដោយបរិវារដ៏ច្រើនគង់លើបល្ល័ង្ក ។ ក្នុងវេលាដែលព្រះរាជកុមារនោះគង់ហើយ អាមាត្យទាំងនោះឲ្យយកស្វាមួយដែលដើរជើង ២ បាន ឲ្យតាក់តែងជាភេទអាចារ្យដែលមានវិជ្ជាមើលទឹកដីហើយនាំទៅកាន់ទីសម្រាប់វិនិច្ឆ័យក្តីទូលថា បពិត្រព្រះសម្មតិទេព បុរសនេះជាអាចារ្យដឹងវិជ្ជាមើលទឹកដីក្នុងសម័យរបស់ព្រះជនកមហារាជ គាត់រមែងដឹងគុណទោសក្នុងទីដែលមានរតនៈ ៧ ប្រការ ខាងក្នុងផែនដីដោយវិទ្យាដ៏ស្ទាត់ជំនាញស្ថានទីសាងព្រះរាជវាំងរបស់រាជត្រកូល បុរសនេះឯងជាអ្នកទស្សន៍ទាយ សូមព្រះអង្គសង្គ្រោះបុរសនេះ សូមស្ថាបនាទុកក្នុងតំណែងចុះ ។ ព្រះរាជកុមារមើលស្វានោះទាំងខាងក្រោមទាំងខាងលើ ក៏ទ្រង់ជ្រាបថា បុគ្គលនេះមិនមែនជាបុរស បុគ្គលនេះជាស្វាដូច្នេះហើយទើបទ្រង់ត្រិះរិះថា ធម្មតាស្វារមែងដឹងតែបំផ្លាញវត្ថុដែលគេធ្វើទុក មិនចេះធ្វើឬចាត់ចែងវត្ថុដែលគេមិនទាន់បានធ្វើដូច្នេះហើយទើបពោលគាថាជំបូងដល់ពួកអាមាត្យថា

សត្វនេះជាសត្វមិនឈ្លាស ( ក្នុងការធ្វើ ) នូវផ្ទះទាំងឡាយ
សត្វនេះជាសត្វវិលវូច មានមុខជ្រួញ បានតែខាងប្រទូស្ត

ចំពោះកិច្ចការដែលគេធ្វើហើយ ៗ ត្រកូលនេះជាធម្មតាយ៉ាងនេះ

ឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆាយំ យវានំ កុសលោ** សេចក្ដីថា សត្វនេះមិនឈ្លាសក្នុងរឿងផ្ទះ គឺមិនឈ្លាសវៃដើម្បីនឹងរៀបចំឬធ្វើផ្ទះ ។ បទថា **លោលោ** បានដល់ មានកំណើតឡេះឡោះ ។ បទថា **វលីមុខោ** សេចក្ដីថា ឈ្មោះថា **វលីមុខោ** ព្រោះមានស្នាមជ្រួញត្រង់មុខ ។ បទថា **ឯវំធម្មមិទំ កុលំ** សេចក្ដីថា ធម្មតាត្រកូលស្វានេះមានសភាពយ៉ាងនេះ គឺប្រទូស្តវត្ថុដែលគេធ្វើទុកឲ្យវិនាស ។

អាមាត្យទាំងឡាយទូលថា បពិត្រមហារាជ ដូចជាព្រះតម្រាស់យ៉ាងនោះហើយនាំស្វានោះចេញទៅ កន្លងទៅបាន ២-៣ ថ្ងៃ ក៏តាក់តែងស្វានោះទៀតហើយនាំទៅកាន់ទីវិនិច្ឆ័យក្ដីក្រាបទូលថា បពិត្រព្រះសម្មតិទេព បុគ្គលនេះជាអាមាត្យអ្នកវិនិច្ឆ័យក្ដីក្នុងកាលព្រះជនកមហារាជ ក្បួនច្បាប់វិនិច្ឆ័យរបស់បុរសនេះប្រព្រឹត្តទៅល្អ គួរព្រះអង្គទ្រង់អនុគ្រោះបុរសនេះឲ្យធ្វើនាទីវិនិច្ឆ័យក្ដីតទៅ ។ ព្រះរាជកុមារសម្លឹងមើលស្វានោះហើយដឹងថា បុគ្គលដែលជាមនុស្សបរិបូណ៌មានការគិតរមែងមិនមានរោមបែបនេះ បុគ្គលនេះក៏គង់ជាស្វាដែលមិនមានការគិតមិនអាចធ្វើកិច្ចក្នុងការវិនិច្ឆ័យក្ដីបានដូច្នេះហើយ ទើបត្រាស់គាថាទី ២ ថា

រោមនេះមិនមែនជារោមនៃសត្វមានចិត្ត ( សម្បយុត្តដោយ

បញ្ញាជាគ្រឿងពិចារណា ) ទេ ម្រឹគ គឺស្វានេះមិនអាចធ្វើ

គេឲ្យចូលចិត្តបានទេ ក្បួនខ្នាតព្រះរាជបិតារបស់ខ្ញុំទ្រង់ព្រះនាម ជនសន្ធៈ ( បានត្រាស់ហើយ ) ថា ស្វានេះមិនដឹងនូវហេតុ តិចតួចឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆវិធំ ចិត្តវតោ លោមំ** សេចក្ដីថា រោម គ្រោតគ្រាតក្នុងសរីរៈរបស់សត្វនេះ មិនមានដល់បុគ្គលដែលមានការគិតដែល ប្រកបដោយបញ្ញាជាគ្រឿងពិចារណា ធម្មតាសត្វតិរច្ឆានឈ្មោះថា មិនមាន ការគិត ដោយការគិតតាមប្រក្រតី រមែងមិនមាន ។ បទថា **ឆាយំ អស្សា-សិកោ** សេចក្ដីថា សត្វនេះឈ្មោះថា ធ្វើឲ្យអ្នកដទៃត្រេកអរមិនបាន ព្រោះ មិនអាចជាទីពឹងអាស្រ័យ ឬធ្វើការទូន្មានឲ្យអ្នកដទៃធូរស្រាលចិត្តបាន ។ បទ ថា **មិគោ** បានដល់ ស្វា ។ ដោយបទថា **សត្ថំ មេ ជនសន្ធេន** នេះ ព្រះ ពោធិសត្វសម្ដែងថា សេចក្ដីនេះព្រះបាទជនសន្ធៈ ដែលជាព្រះជនករបស់ យើងទូន្មានទុក គឺត្រាស់ទុក បានដល់ ប្រទានអនុសាសនីទុកយ៉ាងនេះថា ធម្មតាស្វារមែងមិនដឹងហេតុនិងមិនមែនហេតុ ។ បទថា **ឆាយំ កិញ្ចិ វិជានាតិ** សេចក្ដីថា ព្រោះហេតុនោះ ក្នុងសេចក្ដីនេះគប្បីសម្រេចបានថា ធម្មតា ពានរនេះ រមែងមិនដឹងហេតុការណ៍អ្វីឡើយ ។ តែក្នុងបាលីសរសេរទុកថា **ឆាយំ កិញ្ចិ ន ទូសយេ** ប្រែថា ស្វានេះមិនគប្បីប្រទូស្តវត្ថុណាមួយមិនមាន ។ ពាក្យនោះមិនមានក្នុងអដ្ឋកថា ។

អាមាត្យទាំងឡាយបានស្ដាប់ព្រះតម្រាស់នេះហើយក្រាបទូលថា បពិត្រ ព្រះសម្មតិទេព សេចក្ដីនេះយ៉ាងនេះឯង ហើយនាំស្វានោះចេញទៅ ។ ថ្ងៃ

មួយតាក់តែងស្វានោះឯងហើយនាំមកកាន់ទីវិនិច្ឆ័យក្តីទៀតក្រាបទូលថា បពិត្រព្រះសម្មតិទេព ក្នុងសម័យព្រះជនកមហារាជ ( បិតារបស់ព្រះអង្គ ) បុរសនេះបានបំពេញនាទីទំនុកបម្រុងមាតាបិតា ជាអ្នកធ្វើសេចក្តីគោរពចំពោះរៀមច្បងក្នុងត្រកូល ព្រះអង្គសមគួរអនុគ្រោះបុរសនេះ ។ ព្រះរាជកុមារសម្លឹងមើលស្វានោះហើយព្រះតម្រិះថា ធម្មតាស្វាទាំងឡាយមានចិត្តឡេះឡោះមិនអាចធ្វើការងារបែបនេះបានដូច្នេះហើយទើបពោលគាថាទី ៣ ថា

បុរសប្រាកដដូច្នោះ មិនគប្បីចិញ្ចឹមនូវមាតាបិតា បងប្អូនប្រុស
និងបងប្អូនស្រីរបស់ខ្លួនបានទេ ព្រះបាទទសរថ ( ជាព្រះបិតា )
បានប្រៀនប្រដៅខ្ញុំ ( យ៉ាងនេះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាតរំ ភគិនឹ សកំ** បានដល់ បងប្រុសឬបងស្រីរបស់ខ្លួន ។ តែក្នុងបាលីរចនាទុកថា **សខំ** ពាក្យនោះក្នុងអដ្ឋកថាលោកវិនិច្ឆ័យទុកថា កាលពោលថា **សកំ** រមែងស៊ីសេចក្តីដល់បងប្រុសនិងបងស្រីរបស់ខ្លួន កាលពោលថា **សខំ** បានសំដៅយកចំពោះសំឡាញ់ ។ បទថា **ភរេយ្យ** បានដល់ គប្បីចិញ្ចឹម ។ បទថា **តាទិសោ ចោសោ** សេចក្តីថា ធម្មជាតិស្វាដែលមានសភាពបែបនោះគប្បីចិញ្ចឹម ( អ្នកដទៃ ) មិនបាន ។ បទថា **សិដ្ឋំ ទសរថេន មេ** សេចក្តីថា ព្រះជនករបស់យើងទ្រង់ទូន្មានទុកយ៉ាងនេះ ។ ពិតហើយព្រះជនករបស់ព្រះរាជកុមារនោះគេហៅថា ព្រះបាទជនសន្ធ: ព្រោះទ្រង់សង្គ្រោះជនដោយសង្គហៈវត្ថុ ៤ ប្រការ ហៅថា ព្រះបាទទសរថ ព្រោះទ្រង់ធ្វើកិច្ចដែលនឹងគប្បីធ្វើដោយរថ ១០

គ្រឿង ដោយរថរបស់ព្រះអង្គត្រឹមមួយគ្រឿងប៉ុណ្ណោះ ។ ព្រោះបានស្តាប់ឱវាទបែបនោះអំពីសម្នាក់របស់ព្រះជនកអង្គនោះ ទើបព្រះរាជកុមារត្រាស់យ៉ាងនេះ ។

អាមាត្យទាំងឡាយក្រាបទូលថា សេចក្តីនោះពិតយ៉ាងនោះឯង ហើយនាំស្វានោះចេញទៅ បានព្រមព្រៀងគ្នាថា ព្រះរាជកុមារជាបណ្ឌិតអាចគ្រប់គ្រងរាជសម្បត្តិបានហើយបានអភិសេកព្រះពោធិសត្វឲ្យគ្រប់គ្រងរាជសម្បត្តិហើយឲ្យត្រាច់ប្រកាសវាយស្គរទូទៅក្នុងព្រះនគរថាជាអាណាចក្ករបស់ព្រះបាទអាទាសមុខហើយ ។ ចាប់តាំងអំពីនោះមកព្រះពោធិសត្វទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ដោយប្រពៃ ។ ភាពដែលព្រះបាទអាទាសមុខនោះជាបណ្ឌិតឈ្មោសវៃក៏ផ្សាយទៅពេញជម្ពូទ្វីប ។ ដើម្បីនឹងសម្តែងភាពដែលព្រះអង្គជាបណ្ឌិត លោកបាននាំយករឿង ១៤ នេះមកពោលទុកគឺ

រឿងគោ ១ រឿងបុត្ត ១ រឿងសេះ ១ រឿងជាងផែង ១ រឿងមេស្រុក ១ រឿងស្រីពេស្យា ១ រឿងស្រីក្មេង ១ រឿងពស់ ១ រឿងម្រឹគ ១ រឿងសត្វទទា ១ រឿងរុក្ខទេវតា ១ រឿងស្តេចនាគ ១ រឿងតាបសមានតបៈ ១ រឿងព្រាហ្មណមាណព ១ ។

ក្នុងនិទាន ១៤ រឿងនោះ មានរឿងតាមលំដាប់ដូចតទៅនេះថា

កាលព្រះពោធិសត្វអភិសេកនៅក្នុងរាជសម្បត្តិនោះ បុរសម្នាក់ឈ្មោះថាគាមណិចន្ទ ដែលធ្លាប់ជាបាទមូលិការបស់ព្រះបាទជនសន្ធៈគិតយ៉ាងនេះថា

ធម្មតាថា ភាពជាព្រះរាជានេះ រមែងសមជាមួយបុគ្គលដែលមានវ័យស្មើគ្នា ចំណែកអញជាមនុស្សចាស់មិនសមគួរបម្រើព្រះរាជកុមារ ដែលទ្រង់នៅក្មេង អញនឹងធ្វើកសិកម្មចិញ្ចឹមជីវិតនៅក្នុងជនបទ ។ បុរសនោះក៏ចេញចាកព្រះនគរទៅកាន់ទីឆ្ងាយប្រមាណ ៣ យោជន៍ សម្រេចការនៅក្នុងស្រុកមួយកន្លែង ។ តែគាត់មិនមានសូម្បីតែគោសម្រាប់ធ្វើកសិកម្ម ។ កាលភ្លៀងធ្លាក់ ទើបគាត់ខ្ចីគោ ២ ជាមួយសម្លាញ់ម្នាក់ ភ្ជួរស្រែពេញមួយថ្ងៃឲ្យគោស៊ីស្មៅ ហើយបានទៅកាន់ផ្ទះដើម្បីប្រគល់គោទាំង ២ ឲ្យដល់ម្ចាស់គេវិញ ។ ខណៈនោះម្ចាស់របស់គោ កំពុងអង្គុយបរិភោគអាហារនៅកណ្ដាលផ្ទះមួយអន្លើដោយភរិយា ។ ចំណែកគោទាំង ២ ក៏ចូលទៅកាន់ផ្ទះដោយភាពស្និទ្ធស្នាល ។ កាលគោទាំងនោះចូលទៅស្វាមីលើកថាស ។ ភរិយាកាន់ថាសចេញទៅ ។ នាយគាមណិចន្ទសម្លឹងមើលដោយគិតថា ស្វាមីភរិយាទាំងពីរនេះនឹងហៅអញឲ្យស៊ីបាយ ដូច្នេះហើយទើបមិនប្រគល់គោឲ្យប្រញាប់ជៀសចេញទៅ ។ ក្នុងវេលាយប់ពួកចោរកាត់ក្រោលគោលួចគោទាំងនោះទៅ ។ ម្ចាស់គោចូលទៅកាន់ក្រោលគោអំពីព្រលឹមមិនឃើញគោទាំងនោះ ទោះបីដឹងថាត្រូវចោរលួចទៅ ក៏ចូលទៅរកនាយគាមណិចន្ទនោះដោយគិតថានឹងពិន័យដល់គាមណិ-ចន្ទដូច្នេះហើយពោលថា អ្នកដ៏ចម្រើន ចូរអ្នកប្រគល់គោទាំង ២ ឲ្យខ្ញុំ ។ នាយគាមណិចន្ទពោលថា គោចូលទៅកាន់ផ្ទះហើយមិនមែនឬ ម្ចាស់របស់គោពោលថា អ្នកប្រគល់គោទាំងនោះឲ្យដល់ខ្ញុំហើយឬ នាយគាមណិចន្ទពោលថា មិនទាន់បានប្រគល់ ។ ម្ចាស់គោពោលថា បើយ៉ាងនោះរឿងនេះ

ជាអាជ្ញាសម្រាប់អ្នក ចូរអ្នកមក ។ ពិតហើយក្នុងជនបទទាំងនោះកាលបុគ្គលណាមួយលើកវត្ថុឯណានីមួយជាដុំគ្រួសក្តី អំបែងក្តីហើយពោលថា នេះជាអាជ្ញាសម្រាប់អ្នក ចូរអ្នកមក ។ បុគ្គលណាមិនទៅក៏រមែងដាក់អាជ្ញាដល់បុគ្គលនោះព្រោះហេតុនោះនាយគាមណិចន្ទនោះលុះបានស្តាប់ថាជាអាជ្ញាដូច្នេះហើយក៏ចេញទៅមួយរំពេច ។ ចូលទៅកាន់រាជត្រកូលជាមួយម្ចាស់គោនោះទៅដល់ស្រុកដែលជាទីលំនៅរបស់សំឡាញ់ម្នាក់ទើបពោលថា អ្នកដ៏ចម្រើនខ្ញុំឃ្លានណាស់ ចូរអ្នកបង្អង់នៅក្នុងទីនេះ ទម្រាំខ្ញុំចូលទៅកាន់ផ្ទះបរិភោគអាហារហើយត្រឡប់មក ពោលហើយក៏បានទៅកាន់ផ្ទះរបស់សំឡាញ់ ។ ចំណែកសំឡាញ់របស់គាមណិចន្ទមិនបាននៅផ្ទះ ។ ស្រ្តីជាសំឡាញ់ឃើញគាត់ក៏ពោលថា នែអ្នកអាហារដែលឆ្អិនមិនមាន ចូរអ្នករង់ចាំបន្តិចខ្ញុំនឹងចម្អិនឲ្យអ្នកឥឡូវនេះឯងហើយប្រញាប់ឡើងជង្រុកអង្ករតាមបង្អោង ទើបរអិលធ្លាក់ចុះកាន់ផែនដី ។ គភ៌របស់នាងបាន ៧ ខែ ក៏រលូតទៅក្នុងខណៈនោះឯង ។ ខណៈនោះស្វាមីរបស់នាងត្រឡប់មកឃើញដូច្នោះទើបពោលថា អ្នកប្រហារភរិយារបស់ខ្ញុំធ្វើឲ្យគភ៌រលូតនេះជាអាជ្ញារបស់អ្នក ចូរអ្នកមកហើយនាំនាយគាមណិចន្ទនោះចេញទៅ ។ ចាប់តាំងអំពីនោះមកជនទាំង ២ ដើរទៅឲ្យនាយគាមណិចន្ទនៅកណ្តាល ។ កាលនោះត្រង់ទ្វារស្រុកមួយកន្លែងអ្នកចិញ្ចឹមសេះម្នាក់មិនអាចកៀងសេះឲ្យត្រឡប់បាន ។ ចំណែកសេះក៏ដើរទៅក្នុងសម្នាក់របស់មនុស្សទាំងនោះ អ្នកចិញ្ចឹមសេះឃើញនាយគាមណិចន្ទ ទើបពោលថា នែអ៊ំគាមណិចន្ទ សូមអ៊ំជួយយករបស់ណាមួយគប់សេះនេះឲ្យ

ត្រឡប់ផងចុះ ។ ទើបនាយគាមណិចន្ទយកថ្មមួយដុំគ្រវែងទៅ ។ ដុំថ្មនោះត្រូវសេះបាក់ជើងដូចដើមល្ហុងខ្វៃរដូច្នោះ ។ លំដាប់នោះអ្នកចិញ្ចឹមសេះបានពោលនឹងនាយគាមណិចន្ទថា អ្នកធ្វើសេះរបស់ខ្ញុំឲ្យបាក់ជើងនេះជាអាជ្ញាសម្រាប់អ្នកហើយនាំខ្លួនទៅ ។ ចំណែកនាយគាមណិចន្ទកាលត្រូវជនទាំង ៣ នាំទៅទើបគិតថា ជនទាំងនេះនឹងបង្ហាញអញដល់ព្រះរាជាសូម្បីតម្លៃសម្រាប់ថ្លៃគោ អញក៏មិនអាចឲ្យបាននឹងពោលថ្វីដល់អាជ្ញាដែលធ្វើឲ្យគកិច្ចាក់ អញនឹងបានតម្លៃសេះមកអំពីណា អញស្លាប់ប្រសើរជាង ។ នាយគាមណិចន្ទដើរទៅបានឃើញភ្នំមួយ ដែលមានមុខចោទក្នុងទីមិនឆ្ងាយអំពីផ្លូវក្នុងព្រៃក្នុងរវាងផ្លូវ ។ ជាងផែង ២ នាក់ឪពុកនិងកូនត្បាញកន្ទេលផែងនៅក្នុងស្រមោលភ្នំនោះ ។ នាយគាមណិចន្ទពោលថា ខ្ញុំត្រូវការបន្ទោបង់ឧច្ចារៈ អ្នកទាំងឡាយ ចូររង់ចាំនៅទីនេះមួយអន្ទាំស្លាសិនទម្រាំខ្ញុំមកហើយឡើងទៅកាន់ភ្នំនោះ ក៏លោតចុះទៅត្រង់មុខដែលចោទធ្លាក់ទៅលើខ្នងជាងផែងដែលជាឪពុក ។ ជាងផែងដែលជាឪពុកនោះស្លាប់មួយរំពេច ។ នាយគាមណិចន្ទមិនស្លាប់ក្រោកឡើងបានក៏ដើរទៅ ។ ជាងផែងដែលជាកូនពោលថា អ្នកជាចោរសម្លាប់ឪពុកខ្ញុំនេះជាអាជ្ញាសម្រាប់អ្នក ហើយចាប់ដៃនាយគាមណិចន្ទអូសចេញអំពីគុម្ពឈើ កាលនាយគាមណិចន្ទនិយាយថា តើមានរឿងអ្វីទើបពោលថា អ្នកជាចោរសម្លាប់ឪពុកខ្ញុំ ។ តាំងអំពីនោះមកជនទាំង ៤ នាក់ឲ្យនាយគាមណិចន្ទនៅកណ្ដាលដើរអមទៅ ។

កាលដល់ទ្វារស្រុកមួយកន្លែងមេស្រុកម្នាក់ឃើញនាយគាមណិចន្ទ ទើប

ពោលថា អ៊ឹគាមណិចន្ទ អ៊ឹទៅណា កាលនាយគាមណិចន្ទពោលថា ទៅគាល់ព្រះរាជា ។ ទើបពោលថា អ្នកទៅគាល់ព្រះរាជាពិតហើយ ខ្ញុំបំណាំងនឹងផ្ញើសាសន៍ដល់ព្រះរាជាអ្នកនឹងនាំសាសន៍ទៅបានឬទេ នាយគាមណិចន្ទពោលថា បានខ្ញុំនឹងនាំទៅឲ្យ ។ មេស្រុកពោលថា កាលមុនតាមប្រក្រតីខ្ញុំមានរូបស្អាត មានទ្រព្យបរិបូណ៌ដោយយសស័ក្តិ មិនមានរោគតែក្នុងកាលឥឡូវនេះខ្ញុំជាមនុស្សក្រីក្រ កើតរោគស្គមលឿង ចូរអ្នកទូលសួរព្រះរាជាថាក្នុងរឿងនោះព្រោះហេតុអ្វី បានឮថា ព្រះរាជាអ្នកឈ្លាសវៃព្រះអង្គនឹងត្រាស់ប្រាប់ដល់អ្នក អ្នកចូរប្រាប់ព្រះតម្រាស់របស់ទ្រង់ដល់ខ្ញុំផងចុះ ។ នាយគាម-ណិចន្ទពោលថា សាធុ ។ លំដាប់នោះស្ត្រីគណិកាម្នាក់នៅត្រង់ទ្វារស្រុកមួយកន្លែងខាងមុខ ឃើញនាយគាមណិចន្ទនោះទើបពោលថា នែអ៊ឹគាមណិចន្ទតើអ៊ឹទៅណា កាលនាយគាមណិចន្ទប្រាប់ថា ទៅគាល់ព្រះរាជា ទើបពោលថា បានឮថា ព្រះរាជាជាបណ្ឌិតឈ្លាសវៃ ចូរអ្នកនាំសាសន៍របស់ខ្ញុំទៅផងហើយពោលយ៉ាងនេះថា កាលមុនខ្ញុំបានថ្លៃឈ្នួលច្រើនតែក្នុងកាលឥឡូវនេះមិនបានសូម្បីតែស្លាម្លូ បុគ្គលណាមួយមកកាន់សម្នាក់របស់ខ្ញុំមិនមានឡើយចូរអ្នកទូលសួរព្រះរាជាថា ក្នុងរឿងនោះព្រោះហេតុអ្វីហើយគប្បីត្រឡប់មកប្រាប់ដល់ខ្ញុំ ។ លំដាប់នោះស្រីម្នាក់ដែលនៅត្រង់ទ្វារស្រុកមួយកន្លែងខាងមុខឃើញនាយគាមណិចន្ទនោះហើយបានសួរយ៉ាងនោះដូចគ្នា ហើយពោលថាខ្ញុំមិនអាចនៅក្នុងផ្ទះរបស់ស្វាមី ទាំងមិនអាចនៅក្នុងផ្ទះរបស់ត្រកូល ចូរអ្នកទូលសួរព្រះរាជាថា ក្នុងរឿងនោះព្រោះហេតុអ្វី ហើយគប្បីត្រឡប់មកប្រាប់

ដល់ខ្ញុំ ។ ក្នុងកាលតអំពីនោះមកមានពស់នៅក្នុងដំបូកមួយកន្លែងជិតផ្លូវធំ ឃើញនាយគាមណិចន្ទនោះទើបសួរថា នែអ៊ំគាមណិចន្ទ តើអ៊ំទៅណា កាលគាមណិចន្ទប្រាប់ថា ខ្ញុំទៅគាល់ព្រះរាជាទើបពោលថា បានឮថា ព្រះរាជាជាបណ្ឌិត ចូរអ្នកនាំសាសន៍របស់ខ្ញុំទៅផង ។ ហើយពោលបន្តថា ក្នុងវេលាទៅរកស៊ីខ្ញុំត្រូវសេចក្តីស្រេកឃ្លានជុតរោលមានរាងកាយក្រៀមស្វិត កាលចេញអំពីដំបូករាងកាយពេញរន្ធលូនចេញទៅបានដោយលំបាកតែកាលត្រាច់រកស៊ីហើយត្រឡប់មក ជាអ្នកឆ្អែតស្កប់ស្កល់មានរាងកាយធាត់ កាលលូនចូលទៅមិនប៉ះជញ្ជាំងរន្ធជុំវិញឡើយ ចូលទៅបានយ៉ាងងាយ ចូរអ្នកទូលសួរព្រះរាជាថា ក្នុងរឿងនោះព្រោះហេតុអ្វីហើយគប្បីប្រាប់ដល់ខ្ញុំ ។ លំដាប់នោះ ម្រឹគមួយនៅខាងមុខឃើញនាយគាមណិចន្ទនោះ ទើបសួរដូចគ្នាយ៉ាងនោះហើយពោលថា ខ្ញុំមិនអាចទៅស៊ីស្មៅក្នុងទីដទៃបាន អាចស៊ីស្មៅបានតែត្រង់គល់ឈើមួយកន្លែងប៉ុណ្ណោះ អ្នកគប្បីទូលសួរព្រះរាជាថា ក្នុងរឿងនោះព្រោះហេតុអ្វីដូច្នេះ ។ ក្នុងកាលតមកមានសត្វទទាមួយនៅខាងមុខឃើញនាយគាមណិចន្ទនោះហើយក៏ពោលថា ខ្ញុំទំត្រង់ជើងដំបូកមួយកន្លែងប៉ុណ្ណោះ អាចនៅបានយ៉ាងសប្បាយទំក្នុងទីដទៃមិនអាចនៅបាន អ្នកគប្បីទូលសួរព្រះរាជាថា ក្នុងរឿងនោះព្រោះហេតុអ្វីដូច្នេះ ។ លំដាប់នោះ រុក្ខទេវតាមួយអង្គនៅខាងមុខឃើញនាយគាមណិចន្ទនោះទើបសួរថា នែគាមណិចន្ទ តើអ្នកទៅណា កាលគាមណិចន្ទប្រាប់ថាទៅគាល់ព្រះរាជាទើបពោលថា បានឮល្បីថា ព្រះរាជាជាអ្នកឈ្លាសវៃ ក្នុងកាលមុនខ្ញុំបានសក្ការៈ តែក្នុងកាលឥឡូវនេះ

សូម្បីត្រឹមតែអន្ទក់មួយក្តាប់ក៏មិនបាន អ្នកជួយទូលសួរព្រះរាជាថា ក្នុងរឿងនោះព្រោះហេតុអ្វីដូច្នេះ ។ ក្នុងកាលបន្ទាប់អំពីនោះស្តេចនាគមួយបានឃើញនាយគាមណិចន្ទទើបសួរដូចគ្នាយ៉ាងនោះហើយពោលថា បានឮថា ព្រះរាជាជាបណ្ឌិត ក្នុងកាលមុនទឹកក្នុងស្រះនេះថ្លាមានពណ៌ដូចកែវមណីតែក្នុងកាលឥឡូវនេះល្អក់មានចកគ្របដណ្តប់ ចូរអ្នកទូលសួរព្រះរាជាថា ក្នុងរឿងនេះព្រោះហេតុអ្វីដូច្នេះ ។ ពេលនោះតាបសទាំងឡាយដែលនៅក្នុងអារាមមួយកន្លែងខាងមុខក្នុងទីជិតព្រះនគរ ឃើញនាយគាមណិចន្ទនោះ ទើបសួរដូចគ្នាយ៉ាងនោះហើយពោលថា បានឮថា ព្រះរាជាជាបណ្ឌិត ក្នុងកាលមុនផលាផលទាំងឡាយក្នុងអារាមនេះឆ្ងាញ់ តែក្នុងកាលឥឡូវនេះប្រហាតមិនមានរសអ្នកជួយទូលសួរព្រះរាជាថា ក្នុងរឿងនេះព្រោះហេតុអ្វីដូច្នេះ ។ ខាងមុខអំពីនោះទៅមានព្រាហ្មណមាណពនៅក្នុងសាលាមួយកន្លែងក្នុងទីជិតទ្វារព្រះនគរ ឃើញនាយគាមណិចន្ទនោះ ទើបពោលថា នែគាមណិចន្ទ តើអ្នកទៅណាកាលគាមណិចន្ទឆ្លើយថា ខ្ញុំទៅគាល់ព្រះរាជា ទើបនាំគ្នាពោលថា បើយ៉ាងនោះអ្នកជួយកាន់យកដំណឹងរបស់ពួកខ្ញុំទៅផង ដ្បិតថា ក្នុងកាលមុនទីដែលពួកខ្ញុំរៀនហើយរមែងប្រាកដតែក្នុងកាលឥឡូវនេះមិនទ្រទ្រង់ចាំទុកមិនប្រាកដដូចទឹកក្នុងឆ្នាំងធ្លុះរមែងប្រាកដដូចជាងងឹត អ្នកគប្បីទូលសួរព្រះរាជាថា ក្នុងរឿងនេះព្រោះហេតុអ្វីដូច្នេះ ។ នាយគាមណិចន្ទទទួលយកដំណឹងទាំង ១០ចំណុចនេះហើយបានទៅគាល់ព្រះរាជា ។ ព្រះរាជាបានប្រថាប់គង់នៅក្នុងទីវិនិច្ឆ័យក្តី ។

ម្ចាស់គោបាននាំនាយគាមណិចន្ទចូលគាល់ព្រះរាជា ។ ព្រះរាជាលុះទ្រង់ឃើញគាមណិចន្ទ ក៏ចាំបានទ្រង់ព្រះតម្រិះថា នាយគាមណិចន្ទជាឧបដ្ឋាកនៃព្រះជនករបស់យើងលុះលើកអញឡើងសោយរាជ្យហើយក៏ជៀសចេញទៅអស់កាលប្រមាណប៉ុណ្ណេះ គាត់នៅទីណាហ្ន៎ ដូច្នេះហើយទើបត្រាស់សួរថា នៃគាមណិចន្ទដ៏ចម្រើន អស់កាលមានប្រមាណប៉ុណ្ណេះអ្នកនៅទីណា អស់កាលយូរហើយអ្នកមិនប្រាកដ អ្នកមកដោយត្រូវការអ្វី នាយគាមណិចន្ទក្រាបទូលថា បពិត្រមហារាជ ចាប់តាំងអំពីព្រះជនករបស់ព្រះអង្គសោយទិវង្គតហើយទូលព្រះបង្គំទៅកាន់ជនបទធ្វើកសិកម្មចិញ្ចឹមជីវិត បន្ទាប់អំពីនោះបុរសនេះបានសម្តែងអាជ្ញាព្រោះហេតុទាក់ទងនឹងក្តីរឿងគោ ទើបនាំខ្ញុំទូលព្រះបង្គំមកគាល់ព្រះអង្គ ។ ព្រះរាជាត្រាស់ថា អ្នកបើគេមិនចាប់មកក៏គង់មិនមកព្រោះហេតុនោះការដែលត្រូវគេចាប់មកនេះឯងជាការល្អ ឥឡូវនេះយើងនឹងឃើញបុរសនោះ បុរសនោះនៅឯណានាយគាមណិចន្ទក្រាបទូលថា មនុស្សនេះព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា នៃអ្នកដ៏ចម្រើន បានឮថា អ្នកដាក់អាជ្ញាដល់នាយគាមណិចន្ទរបស់យើងពិតឬ ម្ចាស់គោទូលថា ពិតហើយព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ម្ចាស់គោទូលថា ព្រោះនាយគាមណិចន្ទនេះមិនសងគោ ២ ដល់ទូលព្រះបង្គំ ។ ព្រះរាជាត្រាស់សួរថា គេថាពិតឬចន្ទៈ នាយគាមណិចន្ទទូលថា បពិត្រមហារាជ បើយ៉ាងនោះសូមព្រះអង្គស្តាប់ទូលព្រះបង្គំចុះ ហើយក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់បានស្តាប់ដូច្នោះទើបត្រាស់សួរម្ចាស់គោថា អ្នកដ៏

ចម្រើន កាលគោចូលទៅកាន់ផ្ទះរបស់អ្នក អ្នកឃើញឬទេ ម្ចាស់គោទូលថា មិនឃើញទេព្រះអង្គ ។ ព្រះរាជាត្រាស់ថា លោកមិនធ្លាប់បានឮមនុស្ស និយាយដល់យើងថា ព្រះរាជាព្រះនាមថាអាទាសមុខខ្លះទេឬ អ្នកកុំខ្លាច ឡើយ ចូរប្រាប់មកចុះ ។ ម្ចាស់គោទូលថា បានឃើញព្រះអង្គ ។ ព្រះរាជា ត្រាស់ថា គាមណិចន្ទដ៏ចម្រើន ព្រោះអ្នកមិនប្រគល់គោឲ្យម្ចាស់របស់គោ តម្លៃជាសំណងសម្រាប់អ្នកតែបុរសនេះទាំងដែលឃើញនិយាយមុសាវាទទាំង ដឹងខ្លួនថា មិនឃើញ ព្រោះដូច្នោះអ្នកនោះឯងជាអ្នកប្រកបនូវការខ្វេះគ្រាប់ ភ្នែកទាំង ២ របស់បុរសនេះនិងកិរិយារបស់បុរសនេះផង ចំណែកខ្លួនឯង ឲ្យកហាបណៈ ២៤ ជាការសងថ្លៃសម្រាប់គោ ។ កាលព្រះរាជាត្រាស់យ៉ាង នេះហើយ ក្នក់ងារក៏នាំខ្លួនម្ចាស់របស់គោចេញទៅខាងក្រៅ ។ ម្ចាស់របស់ គោនោះគិតថា កាលគេខ្វេះគ្រាប់ភ្នែកចេញហើយ យើងនឹងយកកហាបណៈ ២៤ ទៅធ្វើអ្វី ដូច្នេះហើយទើបក្រាបទៀបបាទជើងរបស់នាយគាមណិចន្ទ ហើយពោលថា នែនាយគាមណិចន្ទ កហាបណៈដែលជាតម្លៃសម្រាប់គោ ចូរជារបស់អ្នកចុះនិងចូរកាន់យកកហាបណៈទាំងនេះផង ។ ហើយឲ្យកហា- បណៈទាំងឡាយដទៃៗ ហើយចៀសចេញទៅ ។

លំដាប់នោះបុរសទី ២ ទូលថា បពិត្រមហារាជ នាយគាមណិចន្ទនេះ ប្រហារកិរិយារបស់ទូលព្រះបង្គំធ្វើឲ្យគភ៌រលូតទៅ ។ ព្រះរាជាត្រាស់សួរថា ពិតឬចន្ទៈ នាយគាមណិចន្ទក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ស្តាប់ ហើយក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាបដោយពិស្តារ ។ លំដាប់នោះព្រះ

រាជាត្រាស់សួរនាយគាមណិចន្ទនោះថា អ្នកប្រហារកិរិយារបស់បុរសនេះធ្វើគភ៌ឲ្យធ្លាក់ទៅឬ នាយគាមណិចន្ទក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំមិនបានធ្វើឲ្យគភ៌រលូតទៅទេ ។ ព្រះរាជាត្រាស់សួរបុរសនោះថា អ្នកដ៏ចម្រើនការដែលនាយគាមណិចន្ទនេះប្រហារហើយធ្វើគភ៌ឲ្យធ្លាក់ទៅ អ្នកអាចឲ្យកើតឡើងបានដែរឬទេ បុរសនោះទូលថា មិនអាចទេព្រះអង្គ ។ ព្រះរាជាត្រាស់សួរបុរសនោះថា ឥឡូវនេះអ្នកនឹងធ្វើដូចម្តេច បុរសនោះក្រាបទូលថា ទូលព្រះបង្គំគួរបានបុត្តមកវិញព្រះអង្គ ។ ព្រះរាជាត្រាស់ថា នែចន្ទៈដ៏ចម្រើនបើយ៉ាងនោះអ្នកយកកិរិយារបស់បុរសនេះទៅទុកក្នុងផ្ទះរបស់អ្នក ក្នុងកាលដែលនាងប្រសូតបុត្ត ចូរនាំបុត្តនោះមកឲ្យបុរសនេះ ។ ចំណែកបុរសនោះក្រាបទៀបជើងរបស់នាយគាមណិចន្ទហើយពោលថា នែអ្នកកុំទម្លាយផ្ទះរបស់ខ្ញុំឡើយ បានឲ្យកហាបណៈហើយជៀសចេញទៅ ។

លំដាប់នោះបុរសទី ៣ មកក្រាបទូលព្រះរាជាថា បពិត្រមហារាជនាយគាមណិចន្ទនេះប្រហារជើងសេះរបស់ទូលព្រះបង្គំបាក់ ។ ព្រះរាជាត្រាស់សួរថា គេជាពិតឬចន្ទៈ នាយគាមណិចន្ទក្រាបទូលថា បពិត្រមហារាជសូមព្រះអង្គទ្រង់ស្តាប់ហើយក្រាបទូលព្រឹត្តិការណ៍នោះដោយពិស្តារ ។ ព្រះរាជាទ្រង់បានស្តាប់ដូច្នោះ ទើបត្រាស់សួរអ្នកចិញ្ចឹមសេះថា បានឮថា អ្នកពោលថា ចូរគប់សេះឲ្យត្រឡប់ ពិតមែនឬ អ្នកចិញ្ចឹមសេះនោះទូលថា បពិត្រមហារាជ ទូលបង្គំមិនបាននិយាយ គេត្រូវត្រាស់សួរជដែលទើបក្រាបទូលថា បពិត្រព្រះអង្គទូលបង្គំនិយាយ ។ ព្រះរាជាត្រាស់ហៅគាមណិចន្ទ

ថា នែចន្ទៈដ៏ចម្រើន បុរសនេះនិយាយហើយត្រឡប់ពោលមុសាវាទថាមិនបាននិយាយ ចូរអ្នកកាត់អណ្តាតរបស់បុរសនេះហើយយករបស់ដែលយើងមានឲ្យជាតម្លៃសេះ ១០០០ កហាបណៈ ។ បុរសចិញ្ចឹមសេះត្រឡប់ឲ្យកហាបណៈដទៃទៀតហើយជៀសចេញទៅ ។

លំដាប់នោះបុត្តរបស់ជាងផែងក្រាបទូលថា បពិត្រមហារាជ នាយគាមណិចន្ទនេះជាចោរសម្លាប់បិតារបស់ទូលព្រះបង្គំ ។ ព្រះរាជាត្រាស់សួរថា គេថាពិតមែនឬចន្ទៈ នាយគាមណិចន្ទក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ស្តាប់ហើយក្រាបទូលហេតុនោះឲ្យទ្រង់ជ្រាបដោយពិស្តារ ។ ព្រះរាជាត្រាស់នឹងបុត្តជាងផែងថា ឥឡូវនេះអ្នកនឹងធ្វើដូចម្តេច បុត្តជាងផែងក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំសូមបិតារបស់ទូលព្រះបង្គំមកវិញ ។ ព្រះរាជាត្រាស់ថា នែចន្ទៈដ៏ចម្រើន ការបានបិតារបស់ជាងផែងនេះមកវិញទើបគួរ ឯមនុស្សស្លាប់ហើយមិនអាចដើម្បីនឹងនាំមកវិញបាន ចូរអ្នកនាំមាតារបស់ជាងផែងនេះមកទុកក្នុងផ្ទះអ្នក ហើយខ្លួនអ្នក ចូរធ្វើជាបិតារបស់ជាងផែងនេះ ។ បុត្តរបស់ជាងផែងពោលថា នែអ្នក សូមអ្នកកុំទម្លាយផ្ទះនៃបិតាដែលស្លាប់ហើយរបស់ខ្ញុំឡើយ បានឲ្យកហាបណៈដល់នាយគាមណិចន្ទហើយជៀសចេញទៅ ។

នាយគាមណិចន្ទបានជ័យជម្នះក្នុងថ្ងៃនេះមានចិត្តត្រេកអរ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ មានបុគ្គលខ្លះ បញ្ជូនសាសន៍មកដល់ព្រះអង្គ ទូលព្រះបង្គំសូមក្រាបទូលសាសន៍នោះដល់ព្រះអង្គ ។ ព្រះរាជាត្រាស់ថា

ចូរប្រាប់មកចុះចន្ទ: នាយគាមណិចន្ទក្រាបទូលរឿងនីមួយៗបញ្ជាក់លំដាប់ ចាប់តាំងអំពីសាសន៍របស់ពួកព្រាហ្មណមាណពជាដើម ។ ព្រះរាជាទ្រង់បាន ឆ្លើយទៅតាមលំដាប់ ។ ព្រះរាជាទ្រង់ឆ្លើយដូចម្តេច គឺជាបឋមព្រះរាជាទ្រង់ ស្តាប់សាសន៍ទី ១ បានត្រាស់ថា ក្នុងកាលមុនមានមាន់ដែលរងាវត្រូវកាល នៅក្នុងលំនៅរបស់ពួកព្រាហ្មណមាណពនោះ កាលព្រាហ្មណមាណពនោះ ក្រោកឡើងតាមសំឡេងរបស់មាន់នោះ ហើយរៀនមន្តធ្វើការស្វាធ្យាយរហូត អារុណរះឡើង ដោយហេតុនោះមន្តដែលពួកព្រាហ្មណមាណពទាំងនោះរៀន មកហើយក៏មិនវិនាសតែក្នុងកាលឥឡូវនេះមានមាន់រងាវមិនត្រូវកាលនៅក្នុង លំនៅរបស់ព្រាហ្មណមាណពទាំងនោះ មាន់នោះរងាវយប់ពេកខ្លះ រងាវភ្លឺ ពេកខ្លះ ពួកព្រាហ្មណមាណពក្រោកឡើងតាមសំឡេងរបស់មាន់នោះដែល រងាវយប់ពេករៀនមន្តហើយក៏ងងុយដេក កំពុងធ្វើការស្វាធ្យាយក៏ដេកលក់ ទៅ កាលក្រោកឡើងតាមសំឡេងរងាវរបស់មាន់ក្នុងកាលភ្លឺពេកក៏ស្វាធ្យាយ មិនបាន ដោយហេតុនោះ មន្តដែលពួកព្រាហ្មណមាណពទាំងនោះរៀនទុកក៏ មិនប្រាកដ ។

សូម្បីរឿងទី ២ ព្រះរាជាកាលទ្រង់បានស្តាប់ហើយទើបត្រាស់ថា ក្នុង កាលមុនតាបសទាំងនោះនាំគ្នាធ្វើសមណធម៌ បានជាអ្នកខ្វល់ខ្វាយប្រកបការ បរិកម្មកសិណតែក្នុងកាលឥឡូវនេះនាំគ្នាលះបង់សមណធម៌ខ្វល់ខ្វាយប្រកប ក្នុងកិច្ចដែលមិនគួរធ្វើ ឲ្យផលាផលដែលកើតឡើងក្នុងអារាម ដល់ពួកឧបដ្ឋាក សម្រេចការចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ដោយការទទួលដុំបាយនិងឲ្យដុំបាយ

តបស្នង ដោយហេតុនោះទើបផលាផលទាំងឡាយរបស់តាបសទាំងនោះមិនមានរសឆ្ងាញ់ ប្រសិនបើតាបសទាំងនោះជាអ្នកខ្វល់ខ្វាយប្រកបសមណធម៌ទៀតដូចក្នុងកាលមុន ផ្លែឈើទាំងឡាយរបស់តាបសទាំងនោះនឹងត្រឡប់មានរសឆ្ងាញ់វិញ តាបសទាំងនោះរមែងមិនដឹងថារាជត្រកូលជាបណ្ឌិត ចូរអ្នកប្រាប់ឲ្យតាបសទាំងនោះធ្វើសមណធម៌ចុះ ។

ព្រះរាជាកាលទ្រង់ស្តាប់រឿងទី ៣ ទើបត្រាស់ថា ស្តេចនាគទាំងនោះធ្វើការឈ្លោះទាស់ទែងគ្នានឹងគ្នា ដោយហេតុនោះទឹកនោះទើបល្អក់ បើស្តេចនាគទាំងនោះសាមគ្គីគ្នាដូចក្នុងកាលមុនទឹកនឹងត្រឡប់ជាថ្លាវិញ ។

ព្រះរាជាកាលទ្រង់ស្តាប់រឿងទី ៤ ទើបត្រាស់ថា ក្នុងកាលមុនរុក្ខទេវតានោះរក្សាពួកមនុស្សដែលធ្វើដំណើរក្នុងព្រៃ ព្រោះហេតុនោះទើបបានពលិកម្មមានប្រការផ្សេងៗ តែក្នុងកាលឥឡូវនេះរុក្ខទេវតានោះមិនធ្វើនូវការរក្សាព្រោះហេតុនោះទើបមិនបានពលិកម្ម បើធ្វើការរក្សាដូចក្នុងកាលមុនក៏នឹងជាអ្នកបានលាភដ៏ប្រសើរវិញ ទេវតានោះមិនដឹងថា ព្រះរាជាជាបណ្ឌិតព្រោះហេតុនោះ ចូរអ្នកប្រាប់ឲ្យទេវតានោះរក្សាពួកមនុស្សដែលដើរក្នុងព្រៃចុះ ។

ព្រះរាជាកាលទ្រង់ស្តាប់រឿងទី ៥ ទើបត្រាស់ថា សត្វទានោះទំត្រង់ជើងដំបូកនោះ ទើបរងាវយ៉ាងស្អប់ស្អល់ ដ្បិតខាងក្រោមដំបូកនោះមានឆ្នាំងកំណប់ទ្រព្យធំ ចូរអ្នកជីកដំបូកយកទ្រព្យនោះចុះ ។

ព្រះរាជាកាលទ្រង់ស្តាប់រឿងទី ៦ ទើបត្រាស់ថា ម្រឹគនោះអាចស៊ីស្មៅត្រង់គល់ឈើដើមណា ខាងលើដើមឈើនោះមានសំបុកឃ្មុំធំ ម្រឹគនោះជាប់

ចិត្តនឹងស្មៅដែលប្រឡាក់ដោយទឹកឃ្មុំនោះ ទើបមិនអាចទំពាស៊ីស្មៅដទៃ ចូរអ្នកនាំសំបុកឃ្មុំនោះទៅ ហើយបញ្ជូនរសផ្អែមមកឲ្យយើង សេសសល់អំពីនោះអ្នកទុកបរិភោគប្រើប្រាស់ខ្លួនឯងចុះ ។

ព្រះរាជាកាលទ្រង់ស្តាប់រឿងទី ៧ ទើបត្រាស់ថា ខាងក្រោមដំបូកដែលពស់នៅនោះមានកំណប់ទ្រព្យធ្នាំងធំ ពស់នោះរក្សាកំណប់ទ្រព្យនោះ ក្នុងវេលាចេញព្រោះសេចក្តីលោភក្នុងទ្រព្យ ទើបធ្វើសរីរៈឲ្យធូរប៉ះត្រង់នោះប៉ះត្រង់នេះចេញទៅ កាលបានចំណីហើយមិនជាប់ចំពាក់ឡើយប្រញាប់ចូលទៅដោយរហ័សព្រោះសេចក្តីជាប់ចិត្តក្នុងទ្រព្យ ចូរអ្នកជីកយកទ្រព្យនោះចុះ ។

ព្រះរាជាកាលទ្រង់ស្តាប់រឿងទី ៨ ទើបត្រាស់ថា ក្នុងរវាងស្រុកជាទីលំនៅរបស់ស្វាមីនិងមាតាបិតារបស់ស្រីក្មេងនោះមានប្រុសសាហាយនៅក្នុងស្រុកមួយ នាងរឭកដល់សាហាយនោះ ព្រោះសេចក្តីស្នេហាក្នុងសាហាយនោះ ទើបមិនអាចនៅក្នុងផ្ទះស្វាមីពោលថា ខ្ញុំនឹងទៅសួរសុខទុក្ខមាតាបិតាហើយក៏ទៅនៅក្នុងផ្ទះសាហាយ ២-៣ ថ្ងៃ ហើយទើបទៅផ្ទះរបស់មាតាបិតានៅក្នុងផ្ទះរបស់មាតាបិតានោះ ២-៣ ថ្ងៃ នឹកដល់សាហាយនោះទៀតទើបពោលថា ខ្ញុំនឹងទៅផ្ទះស្វាមីក៏ចៀងចូលទៅកាន់ផ្ទះរបស់សាហាយនោះឯងទៀត ចូរអ្នកប្រាប់ស្រីនោះថា ព្រះរាជាមានច្បាប់ ហើយចូរពោលដល់ស្រីនោះថា នាងចូរនៅតែក្នុងផ្ទះរបស់ស្វាមីប៉ុណ្ណោះ បើព្រះរាជាត្រាស់ឲ្យចាប់នាង ជីវិតរបស់នាងមិនមាន គួរធ្វើសេចក្តីមិនប្រមាទដូច្នេះ ។

ព្រះរាជាកាលស្តាប់រឿងទី ៩ ទើបត្រាស់ថា ក្នុងកាលមុនស្ត្រីគណិកា

នោះទទួលយកតម្លៃអំពីដៃរបស់បុរសម្នាក់ហើយក៏នៅប្រចាំជាមួយបុរសនោះ មិនទទួលយកតម្លៃអំពីដៃរបស់បុរសដទៃទៀត ដោយហេតុនោះក្នុងកាលមុន តម្លៃទើបកើតឡើងដល់ស្ត្រីគណិកានោះយ៉ាងច្រើន តែក្នុងកាលឥឡូវនេះស្ត្រីគណិកានោះលះបង់ធម្មតារបស់ខ្លួនចេញ មិនជម្រះតម្លៃដែលខ្លួនទទួលអំពីដៃរបស់បុរសម្នាក់ឲ្យសម្រេចសិនទៅទទួលអំពីដៃរបស់បុរសដទៃ មិនឲ្យឱកាសដល់បុរសដំបូងត្រឡប់ឲ្យឱកាសដល់បុរសខាងក្រោយ ដោយហេតុនោះតម្លៃក៏មិនកើតដល់ស្ត្រីគណិកានោះ បុគ្គលណាមួយក៏មិនទៅរកស្ត្រីគណិកានោះ ប្រសិនបើនាងតាំងនៅក្នុងធម្មតារបស់ខ្លួន តម្លៃនឹងមានដូចកាលមុននោះឯង ចូរអ្នកប្រាប់ស្ត្រីគណិកានោះឲ្យតាំងនៅក្នុងធម្មតារបស់ខ្លួន ។

ព្រះរាជា កាលទ្រង់ស្តាប់រឿងទី ១០ ទើបត្រាស់ថា មេស្រុកនោះក្នុងកាលមុនវិនិច្ឆ័យក្តីដោយធម៌ ដោយស្មើ ដោយហេតុនោះទើបជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ពួកមនុស្សជាទីស្រឡាញ់ក៏នាំបណ្ណាការដ៏ច្រើនមកឲ្យដល់មេស្រុកនោះ ដោយហេតុនោះទើបមេស្រុកនោះជាអ្នកមានរូបស្អាត មានទ្រព្យច្រើនបរិបូណ៌ដោយយស តែក្នុងកាលឥឡូវនេះជាអ្នកឃើញតែសំណូក ហើយវិនិច្ឆ័យក្តីមិនប្រកបដោយធម៌ ដោយហេតុនោះទើបមេស្រុកនោះក្លាយជាមនុស្សកំព្រា ក្រីក្រ ត្រូវរោគស្គមលឿងគ្របសង្កត់ បើមេស្រុកនោះវិនិច្ឆ័យក្តីដោយធម៌ដូចក្នុងកាលមុន គេនឹងត្រឡប់បាននូវវត្ថុសព្វយ៉ាងដូចក្នុងកាលមុន មេស្រុកនោះមិនដឹងថាមានព្រះរាជាជាបណ្ឌិត ចូរអ្នកប្រាប់ឲ្យគេវិនិច្ឆ័យក្តីដោយធម៌ចុះ ។ នាយគាមណិចន្ទបានក្រាបទូលសាសន៍

មានប្រមាណប៉ុណ្ណោះឲ្យព្រះរាជាទ្រង់ជ្រាបដោយប្រការដូច្នេះ ។ ព្រះរាជាក៏ទ្រង់ព្យាករបញ្ហាទាំងអស់នោះ ដោយបញ្ញារបស់ព្រះអង្គដូចសព្វញ្ញុពុទ្ធ ព្រះរាជទានទ្រព្យជាច្រើន ដល់នាយគាមណិចន្ទ ទ្រង់ធ្វើលំនៅរបស់គាមណិចន្ទឲ្យជាព្រហ្មទេយ្យ ( របស់ដែលព្រះរាជាប្រទាន ) ព្រះរាជទានចំពោះគាមណិចន្ទប៉ុណ្ណោះ ហើយបញ្ជូនត្រឡប់ទៅ ។

នាយគាមណិចន្ទនោះ ចេញអំពីព្រះនគរ ហើយប្រាប់ដំណឹងទាំងអស់នោះដែលព្រះពោធិសត្វប្រទានមកហើយដល់ព្រាហ្មណមាណព តាបស ស្តេចនាគនិងរុក្ខទេវតាស្រេចហើយកាន់យកកំណប់ទ្រព្យអំពីលំនៅរបស់សត្វទានោះ ហើយទៅយកទឹកឃ្មុំអំពីដើមឈើក្នុងទីដែលម្រឹគស៊ីស្មៅ បញ្ជូនទឹកឃ្មុំទៅថ្វាយព្រះរាជាហើយទៅជីកជំបូកក្នុងលំនៅរបស់ពស់យកកំណប់ទ្រព្យមកហើយប្រាប់ដំណឹងតាមទំនងដែលព្រះរាជាទ្រង់ត្រាស់នោះឯង ដល់ស្រីក្មេងស្ត្រីគណិកានិងមេស្រុកស្រេចហើយ ទៅកាន់ផ្ទះរបស់ខ្លួនដោយយសស័ក្តិធំក្រៃលែងតាំងនៅដរាបដល់អស់អាយុក៏ទៅតាមយថាកម្ម ។ ចំណែកព្រះបាទអាទាសមុខទ្រង់បំពេញបុណ្យទាំងឡាយមានទានជាដើម ក្នុងវេលាអស់ព្រះជន្មាយុ ទ្រង់បំពេញផ្លូវសួគ៌ឲ្យពេញហើយស្តេចយាងទៅ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមានបញ្ញាច្រើនក្នុងកាលឥឡូវនេះក៏មិនមែនសូម្បីក្នុងកាលមុនក៏មានបញ្ញាច្រើនដូចគ្នា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយក្នុងវេលាចប់សច្ចៈ មហាជនបានជាសោតាបន្នខ្លះ សកទាគាមីខ្លះ អនា-

គាមិខ្ចះ អរហន្តខ្ចះហើយទ្រង់ប្រជុំជាតកថា នាយគាមណិចន្ទក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកព្រះបាទអាទាសមុខក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាគាមណិចន្ទជាតក ចប់

## មន្ធាតុរាជជាតក

[ ៣៧៣ ] ( ព្រះសាស្តាត្រាស់ថា ) ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ( ដើរក្រឡឹង ) ភ្លឺសិនេរុ ទិសទាំងឡាយភ្លឺរុងរឿងរហូតទីមានកំណត់ត្រឹមណា សត្វទាំងឡាយណាដែលអាស្រ័យលើផែនដី សត្វទាំងអស់នោះជាទាសៈរបស់ស្តេចមន្ធាតុរហូតទីមានកំណត់ត្រឹមណោះ ។

[ ៣៧៤ ] ការផ្អែតក្នុងកាមទាំងឡាយ រមែងមិនមានដោយភ្លៀងកហាបណៈទេ បណ្ឌិតបានដឹងថា កាមទាំងឡាយមានសេចក្ដីសុខតិចមានសេចក្ដីទុក្ខ ( ច្រើន ) ។

[ ៣៧៥ ] ព្រោះហេតុនោះ សាវកនៃព្រះសម្មាសម្ពុទ្ធនោះមិនបានត្រេកអរក្នុងកាមទាំងឡាយសូម្បីជាទិព្វ ជាអ្នកត្រេកអរតែក្នុងធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ។

**ចប់ មន្ធាតុរាជជាតកទី ៨ ។**

## អដ្ឋកថា

## មន្ធាតុរាជជាតក

[ ៣៧៣-៣៧៥ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យាវតា ចន្ទិមសុរិយា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុរូបនោះត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី ឃើញស្ត្រីម្នាក់តាក់

តែងគ្រឿងអលង្ការស្រស់ស្អាត ទើបកើតសេចក្ដីអផ្សុក ។ លំដាប់នោះភិក្ខុទាំងឡាយ ទើបនាំភិក្ខុរូបនោះមកកាន់ធម្មសភាហើយបង្ហាញដល់ព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុរូបនេះអផ្សុកប្រាថ្នានឹងសឹក ។ ព្រះសាស្ដាត្រាស់សួរថា បានឮថា អ្នកអផ្សុកពិតមែនឬ កាលភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គទើបព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ កាលអ្នកគ្រប់គ្រងផ្ទះនឹងអាចធ្វើតណ្ហាឲ្យពេញបានដូចម្ដេច ព្រោះដែលឈ្មោះថា កាមតណ្ហានេះពេញបានដោយលំបាកដូចមហាសមុទ្រដ្បិតថាបុរាណកបណ្ឌិតទាំងឡាយគ្រងរាជសម្បត្តិជាស្ដេចចក្កពត្តិក្នុងមហាទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារ បានគ្រប់គ្រងរាជសម្បត្តិក្នុងទេវលោកជាន់ចតុម្មហារាជិកាមានមនុស្សជាបរិវារប៉ុណ្ណោះ ទាំងគ្រប់គ្រងរាជសម្បត្តិក្នុងស្ថានទីប្រថាប់នៅរបស់សក្កទេវរាជ ៣៦ អង្គ ក្នុងទេវលោកជាន់តាវតឹង្សមិនអាចដើម្បីនឹងធ្វើកាមតណ្ហារបស់ខ្លួនឲ្យពេញក៏បានធ្វើកាលកិរិយាទៅ ឯអ្នកសោតកាលណាអាចធ្វើកាមតណ្ហានោះឲ្យពេញបាន ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលគ្រាបឋមកប្បមានព្រះរាជាព្រះនាមថា ព្រះបាទមហាសម្មតរាជ ។ ឱរសរបស់ព្រះរាជាព្រះនាមថា រោជៈ ឱរសរបស់ព្រះបាទរោជៈព្រះនាមថា វររោជៈ ។ ឱរសរបស់ព្រះបាទវររោជៈព្រះនាមថា កល្យាណៈ ។ ឱរសរបស់ព្រះបាទកល្យាណៈព្រះនាមថា វរកល្យាណៈ ។ ឱរសរបស់ព្រះបាទវរកល្យាណៈព្រះនាមថា ឧបោសថ ។ ឱរសរបស់ព្រះបាទឧបោសថ

ព្រះនាមថា មន្ធាតុ ។ ព្រះបាទមន្ធាតុនោះទ្រង់ប្រកបដោយរតនៈ ៧ និង ឥទ្ធិឫទ្ធិ ៤ គ្រប់គ្រងរាជសម្បត្តិជាស្តេចចក្កពត្តិ ។ ក្នុងវេលាដែលព្រះអង្គលាព្រះហស្តឆ្វេងទះដោយព្រះហស្តស្តាំភ្លៀងរតនៈ ៧ ក៏ធ្លាក់ចុះមកប្រមាណត្រឹមជង្គង់ដូចភ្លៀងទិព្វក្នុងអាកាស ។ ព្រះបាទមន្ធាតុបានជាមនុស្សអស្ចារ្យបែបនេះ ។ ព្រះបាទមន្ធាតុនោះទ្រង់នៅលេងជាកុមារ ៨៤០០០ ឆ្នាំ ទ្រង់គ្រប់គ្រងភាពជាឧបរាជ ៨៤០០០ ឆ្នាំ ទ្រង់គ្រប់គ្រងរាជ្យជាស្តេចចក្កពត្តិ ៨៤០០០ ឆ្នាំ ។ ព្រះបាទមន្ធាតុទ្រង់មានព្រះជន្មាយុ ១ អសង្ខេយ្យឆ្នាំ ។ ថ្ងៃមួយព្រះបាទមន្ធាតុនោះមិនអាចធ្វើកាមតណ្ហាឲ្យពេញបានទើបទ្រង់សម្តែងអាការអផ្សុកក្នុងព្រះហឫទ័យ ។ អាមាត្យទាំងឡាយទូលសួរថា បពិត្រព្រះសម្មតិទេព ព្រះអង្គទ្រង់អផ្សុកព្រោះហេតុអ្វី ព្រះបាទមន្ធាតុត្រាស់ថា កាលយើងឃើញកម្លាំងបុណ្យរបស់យើង រាជសម្បត្តិនេះនឹងធ្វើអ្វីបាន ទីណាហ្ន៎ ទើបគួររីករាយ ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ ទេវលោកគួររីករាយ ។ ទើបទ្រង់បង្វិលចក្ករតនៈទៅកាន់ទេវលោកជាន់ចតុម្មហារាជិកាមួយអន្ទើដោយបរិស័ទ ។ លំដាប់នោះមហារាជទាំង ៤ ទ្រង់កាន់ផ្កានិងគ្រឿងក្រអូបដែលជាទិព្វហែហមដោយពួកទេវតា ធ្វើការទទួលនាំព្រះបាទមន្ធាតុនោះទៅកាន់ទេវលោកជាន់ចាតុម្មហារាជិកា បានថ្វាយរាជសម្បត្តិក្នុងទេវលោក ។ កាលព្រះបាទមន្ធាតុនោះហែហមដោយបរិស័ទរបស់ព្រះអង្គគ្រប់គ្រងរាជសម្បត្តិនៅក្នុងជាន់ចាតុម្មហារាជិកានោះពេលវេលាកន្លងទៅអស់កាលដ៏យូរ ។ ព្រះអង្គមិនអាចធ្វើតណ្ហាឲ្យពេញក្នុងជាន់ចាតុម្មហារាជិកានោះ

បាន ទើបទ្រង់សម្ដែងអាការៈអផ្សុក ។ មហារាជទាំង ៤ ទើបទូលសួរថា បពិត្រមហារាជ ព្រះអង្គទ្រង់អផ្សុកព្រោះអ្វីហ្ន៎ ព្រះបាទមន្ធាតុត្រាស់ថា ក្រៅអំពីទេវលោកនេះទីណាហ្ន៎គួររីករាយជាង មហារាជទាំង ៤ ទូលថា បពិត្រមហារាជ ពួកទូលព្រះបង្គំជាបរិស័ទរង់ចាំឧបដ្ឋាកអ្នកដទៃ ដែលឈ្មោះថាទេវលោកជាន់តាវត្តិង្សគួររត្រេកអរ ។ ព្រះបាទមន្ធាតុបង្វិលចក្ករតនៈចេញទៅ ហែហមដោយបរិស័ទរបស់ព្រះអង្គ មានមុខឆ្ពោះទៅកាន់ភពតាវត្តិង្ស ។ លំដាប់នោះសក្កទេវរាជទ្រង់កាន់ផ្កានិងគ្រឿងក្រអូបដែលជាទិព្វហែហមដោយពួកទេវតាទ្រង់ធ្វើការទទួលព្រះបាទមន្ធាតុនោះ ទ្រង់ចាប់ព្រះអង្គដោយព្រះហស្ត ហើយត្រាស់ថា បពិត្រមហារាជ សូមព្រះអង្គយាងមកផ្លូវនេះ ។ ក្នុងវេលាដែលព្រះរាជាដែលមានទេវតាហែហមយាងទៅ បរិនាយកកែវនាំចក្កកែវមកកាន់មនុស្សលោកមួយអន្លើដោយបរិស័ទចូលទៅកាន់នគររៀងៗខ្លួន ។ សក្កទេវរាជទ្រង់នាំព្រះបាទមន្ធាតុទៅភពតាវត្តិង្ស ទ្រង់ធ្វើទេវតាឲ្យជា ២ ចំណែក ទ្រង់បែងចែកទេវរាជសម្បត្តិរបស់ព្រះអង្គពាក់កណ្ដាលថ្វាយព្រះបាទមន្ធាតុ ។ តាំងអំពីនោះមកព្រះរាជា ២ អង្គទ្រង់គ្រប់គ្រងរាជសម្បត្តិ ( ក្នុងភពតាវត្តិង្សនោះ ) ។ កាលវេលាកន្លងទៅដោយប្រការយ៉ាងនេះ សក្កទេវរាជទ្រង់ឲ្យព្រះជន្មាយុអស់ទៅ ៣ កោដិ ៦០ សែនឆ្នាំក៏ចុតិ ។ សក្កទេវរាជអង្គដទៃក៏មកកើតជំនួស ។ សូម្បីសក្កទេវរាជអង្គនោះក៏គ្រប់គ្រងរាជសម្បត្តិក្នុងទេវលោកហើយក៏ចុតិទៅដោយអស់ព្រះជន្មាយុ ។ ដោយឧបាយនេះសក្កទេវរាជដល់ទៅ ៣៦ អង្គចុតិទៅហើយ ។ ចំណែកព្រះបាទមន្ធាតុនៅគ្រប់គ្រង

រាជសម្បត្តិក្នុងទេវលោកដោយរាងកាយរបស់មនុស្សនោះឯង ។ កាលវេលាកន្លងទៅដោយប្រការយ៉ាងនេះកាមតណ្ហាក៏នៅកើតឡើងដល់ព្រះអង្គដ៏លើសប្រមាណក្រៃលែងឡើង ។ ទើបទ្រង់ព្រះតម្រិះថា អញនឹងបានប្រយោជន៍អ្វីដោយរាជសម្បត្តិ ក្នុងទេវលោកពាក់កណ្តាល អញនឹងសម្លាប់សក្កទេវរាជគ្រងរាជសម្បត្តិក្នុងទេវលោកម្នាក់ឯងចុះ ។ ព្រះបាទមន្ធាតុ មិនអាចសម្លាប់សក្កទេវរាជបាន ។ តណ្ហាគឺសេចក្តីប្រាថ្នានេះជាឫសគល់នៃសេចក្តីវិនាស ។ ដោយហេតុនោះអាយុសង្ខាររបស់ព្រះបាទមន្ធាតុក៏វិនាសទៅ ។ ភាពជរាក៏បៀតបៀនព្រះអង្គ ។ ធម្មតារាងកាយរបស់មនុស្សរមែងមិនបែកធ្លាយនៅក្នុងទេវលោក ។ លំដាប់នោះព្រះបាទមន្ធាតុនោះក៏ធ្លាក់អំពីទេវលោកចុះមកក្នុងព្រះរាជឧទ្យាន ។ ក្មាក់ងារដែលរក្សាព្រះរាជឧទ្យានក៏ក្រាបទូលភាពដែលព្រះបាទមន្ធាតុនោះយាងមកឲ្យរាជត្រកូលជ្រាប ។ រាជត្រកូលយាងមកនាំគ្នាក្រាលទីផ្ទំក្នុងព្រះរាជឧទ្យាននោះឯង ។ ព្រះរាជាទ្រង់ផ្ទំដោយអនុដ្ឋានសេយ្យាសន៍ ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេពទូលព្រះបង្គំនឹងពោលយ៉ាងណាចំពោះព្រះភក្ត្ររបស់ព្រះអង្គ ព្រះបាទមន្ធាតុត្រាស់ថា អ្នកទាំងឡាយគប្បីប្រាប់ដំណឹងនេះដល់មហាជនថា ព្រះបាទមន្ធាតុមហារាជគ្រប់គ្រងរាជសម្បត្តិជាស្តេចចក្កពត្តិក្នុងមហាទ្វីបទាំង ៤ ដែលមានទ្វីបតូច ២០០០ ជាបរិវារគ្រប់គ្រងរាជសម្បត្តិនៅក្នុងទេវលោកជាន់ចាតុម្មហារាជិកាអស់កាលដ៏យូរ ហើយបានគ្រប់គ្រងរាជសម្បត្តិនៅក្នុងទេវលោកតាមប្រមាណព្រះជន្មាយុរបស់សក្កទេវរាជរហូតដល់ទៅ ៣៦ អង្គ គង់ធ្វើ

តណ្ហា គឺសេចក្តីប្រាថ្នាឲ្យពេញមិនបានឡើយបានសោយទិវង្គតទៅហើយ ដូច្នេះ ។ កាលព្រះអង្គត្រាស់យ៉ាងនេះហើយក៏សោយទិវង្គតទៅតាមយ-ថាកម្ម ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ដឹងក្រៃលែងហើយទើបត្រាស់គាថាទាំងនេះថា

ព្រះចន្ទ្រនិងព្រះអាទិត្យទាំងឡាយ ( ដើរក្រឡឹង ) ភ្នំសិនេរុ ទិសទាំងឡាយភ្លឺរុងរឿងរហូតទីមានកំណត់ត្រឹមណា សត្វទាំងឡាយណា ដែលអាស្រ័យលើផែនដី សត្វទាំងអស់នោះជាទាសៈរបស់ស្តេចមន្ធាតុរហូតទីមានកំណត់ត្រឹមណោះ ។

ការឆ្អែតក្នុងកាមទាំងឡាយ រមែងមិនមានដោយភ្លៀងកហាបណៈទេ បណ្ឌិតបានដឹងថា កាមទាំងឡាយមានសេចក្តីសុខតិចមានសេចក្តីទុក្ខ ( ច្រើន ) ។

ព្រោះហេតុនោះ សាវ័កនៃព្រះសម្មាសម្ពុទ្ធនោះមិនបានត្រេកអរក្នុងកាមទាំងឡាយសូម្បីជាទិព្វ ជាអ្នកត្រេកអរតែក្នុងធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវតា** ជាពាក្យពោលដល់កំណត់ខេត្ត ។ បទថា **បរិហរន្តិ** សេចក្តីថា រមែងវិលជុំវិញភ្នំសិនេរុដោយកំណត់មានប្រមាណប៉ុណ្ណោ ។ បទថា **ទិសា ភន្តិ** សេចក្តីថា រមែងភ្លឺស្វាងក្នុងទិសទាំង ១០ ។ បទថា **វិរោចនា** សេចក្តីថា ឈ្មោះថា មានសភាពភ្លឺស្វាង

ព្រោះធ្វើនូវពន្ធ ។ បទថា **សព្វេ ទាសា មន្ធាតុ យេ ចាណាបថាវិស្សិតា** សេចក្តីថា សត្វទាំងឡាយ គឺពួកមនុស្សអ្នកជនបទពួកណា ដែលអាស្រ័យផែនដីនៅក្នុងប្រទេសមានប្រមាណប៉ុណ្ណោះ សត្វទាំងអស់នោះ កាលចូលទៅគាល់ដោយគិតយ៉ាងនេះថា ពួកយើងជាទាសរបស់ព្រះបាទមន្ធាតុ ព្រះបាទមន្ធាតុជាជីតារបស់ពួកយើងដូច្នេះ សូម្បីមិនមែនជាទាសក៏ឈ្មោះថាជាទាសដូច គ្នា ។ ក្នុងបទថា **ឆ កហាបណវស្សេន** នេះ ព្រះបាទមន្ធាតុទ្រង់ទះព្រះហស្តធ្វើឲ្យភ្លៀងគឺរតនៈ ៧ ប្រការធ្លាក់ចុះមកដើម្បីទ្រង់អនុគ្រោះពួកមនុស្សដែលជាទាសទាំងនោះ ។ ភ្លៀងគឺរតនៈ ៧ ប្រការ នោះលោកហៅថាភ្លៀងគឺកហាបណៈក្នុងគាថានេះ ។ បទថា **តិត្តិ កាមេសុ** សេចក្តីថា ដែលឈ្មោះថា ការឆ្អែតក្នុងវត្ថុកាម និងកិលេសទាំងឡាយ ព្រោះភ្លៀងគឺកហាបណៈនោះរមែងមិនមាន តណ្ហានោះធ្វើឲ្យពេញបានលំបាកយ៉ាងនេះ ។ បទថា **អប្បស្សាទា ទុខា កាមា** សេចក្តីថា ដែលឈ្មោះថា កាមទាំងឡាយដែលប្រៀបដូចជាការយល់សប្តិ មានសេចក្តីត្រេកអរតិច គឺមានសេចក្តីសុខតិចក៏ក្នុងកាមនេះមានតែទុក្ខប៉ុណ្ណោះច្រើន ទុក្ខនោះគប្បីសម្តែងដោយទុក្ខក្ខន្ធសូត្រ ។ បទថា **ឥតិ វិញ្ញាយ** បានដល់ កំណត់ដឹងយ៉ាងនេះ ។ បទថា **ទិព្វេសុ** បានដល់ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ដែលជាគ្រឿងបរិភោគរបស់ទេវតាទាំងឡាយ ។ បទថា **រតឹ សោ** សេចក្តីថា ភិក្ខុឃើញច្បាស់នោះ សូម្បីត្រូវអញ្ជើញដោយកាមទាំងឡាយដែលជាទិព្វក៏រមែងមិនដល់នូវការត្រេកអរក្នុងកាមទាំងនោះដូចព្រះសមិទ្ធិ ។ បទថា **តណ្ហក្ខយរតោ**

បានដល់ ដែលត្រេកអរហើយក្នុងព្រះនិព្វាន ។ ពិតហើយ តណ្ហាមកដល់ព្រះនិព្វាន រមែងអស់ទៅ ព្រោះហេតុនោះ ទើបព្រះនិព្វាននោះលោកហៅថា តណ្ហក្ខយៈ ជាអ្នកត្រេកអរហើយ ត្រេកអរក្រៃលែងហើយក្នុងធម៌ជាទីអស់ទៅនៃតណ្ហានោះ ។ បទថា **សម្មាសម្ពុទ្ធសាវកោ** សេចក្ដីថា ឈ្មោះថា សម្មា-សម្ពុទ្ធ ព្រោះត្រាស់ដឹងសច្ចៈដោយប្រពៃ ដោយព្រះអង្គឯង ដែលឈ្មោះថា សាវក ព្រោះកើតក្នុងទីបំផុតនៃការស្ដាប់ គឺជាយោគាវចរបុគ្គលដែលបានស្ដាប់ច្រើន ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលអផ្សុក តាំងនៅក្នុងសោតាបត្តិផល មហាជនក៏បានសម្រេចសោតាបត្តិផលជាដើម ហើយទ្រង់ប្រជុំជាតកថា ព្រះបាទមន្ធាតុមហារាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មន្ធាតុរាជជាតក ចប់

# តិរីតិវច្ឆជាតក

[ ៣៧៦ ] ( ឧបរាជទូលសួរព្រះរាជាថា ) កម្មតិចតួចដែលសម្រេចដោយវិជ្ជារបស់តាបសនេះមិនមានឡើយ មួយទៀតតាបសនេះមិនមែនជាផៅពង្ស ទាំងមិនមែនជាសម្លាញ់របស់ព្រះអង្គទេ កាលបើយ៉ាងនេះ ហេតុអ្វីបានជាតាបសឈ្មោះតិរីតិវច្ឆៈ កាន់ឈើច្រត់មានចំពាម ៣ បរិភោគនូវដុំបាយមានរសដ៏ប្រសើរ ។

[ ៣៧៧ ] ( ព្រះរាជាត្រាស់ថា ) ក្នុងគ្រាមានអន្តរាយ កាលអញច្បាំងចាញ់គេ ( តាបសនេះ ) បានធ្វើ ( នូវសេចក្តីអនុគ្រោះ ) ដល់អញម្នាក់ឯងក្នុងព្រៃគួរខ្លាចដ៏ពន្លឹក បានលានូវដៃ ( យោងអញ ) ដែលដល់នូវសេចក្តីលំបាក ( ក្នុងអណ្តូង ) ព្រោះហេតុនោះ អញដែលត្រូវសេចក្តីទុក្ខគ្របសង្កត់ទើបបានឡើងរួចមក ។

[ ៣៧៨ ] អញ ( ឋិតនៅ ) ក្នុងជីវលោក ( នេះដល់ ) នូវវិស័យនៃសេចក្តីស្លាប់ទៅហើយតែមកក្នុងទីនេះបាន ព្រោះសេចក្តីលំបាកនៃតាបសនេះ ម្នាលកូន រីតិរីតិវច្ឆៈតាបសជាបុគ្គលគួរដល់លាភ អ្នកទាំងឡាយចូរឲ្យនូវគ្រឿងបរិភោគផង ចូរបូជានូវវត្ថុដែលគួរបូជាផងដល់លោក ។

**ចប់ តិរីតិវច្ឆជាតក ទី ៩ ។**

# អដ្ឋកថា

# តិរិតិវច្ឆជាតក

[ ៣៧៦-៣៧៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការដែលព្រះអានន្ទបានសំពត់ ១០០០ ផ្ទាំង គឺបានមកអំពីដៃស្រីស្នំរបស់ព្រះបាទកោសល ៥០០ ផ្ទាំង បានអំពីព្រះហស្តរបស់ព្រះរាជា ៥០០ ផ្ទាំង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆយិមស្ស រិដ្ឋា** ដូច្នេះជាដើម ។

រឿងលោកពោលទុកពិស្តារហើយក្នុងគុណជាតកទុកនិបាត ខាងដើមនោះឯង ។ ( ក្នុងទីនេះ ) ព្រះសាស្តាទ្រង់នាំយករឿងក្នុងអតីតមកសាធក: ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែនកាសី ក្នុងថ្ងៃដាក់ឈ្មោះពួកញាតិបានដាក់ឈ្មោះថា តិរិតិវច្ឆកុមារ ។ ព្រះពោធិសត្វនោះបានដល់នូវភាពចម្រើនវ័យដោយលំដាប់ បានរៀនសិល្បសាស្ត្រគ្រប់យ៉ាងក្នុងនគរតក្កសិលាហើយនៅគ្រប់គ្រងផ្ទះ កាលមាតាបិតាធ្វើកាលកិរិយាទៅហើយមានចិត្តសង្វេគទើបចេញបួសជាឥសី មានឫសឈើនិងផ្លែឈើក្នុងព្រៃជាអាហារ សម្រេចការនៅក្នុងដងព្រៃ ។ កាលព្រះពោធិសត្វនៅក្នុងដងព្រៃនោះ អាណាខេត្តជាយដែនរបស់ព្រះបាទពារាណសីកើតនូវការបះបោរ ។ ព្រះអង្គយាងទៅកាន់ជាយដែននោះ ទ្រង់ចាញ់ក្នុងការច្បាំង ទ្រង់ខ្លាចចំពោះមរណភ័យយាងឡើងកាន់កដីរីដ៏ប្រសើរប៉ុណ្ណោះស្តេចភាសខ្លួនយាងទៅក្នុងព្រៃ លុះដល់វេលាព្រឹក

ជាវេលាដែលតិរីតិវច្ឆតាបសចេញទៅដើម្បីរកផលាផល ទើបស្តេចចូលទៅកាន់អាស្រមរបស់តិរីតិវច្ឆតាបសនោះ ។ ព្រះរាជានោះទ្រង់ជ្រាបថា ជាស្ថានទីនៅរបស់តាបសដូច្នេះហើយទើបស្តេចចុះអំពីកដំរី ទ្រង់នឿយហត់ព្រោះខ្យល់និងកម្តៅថ្ងៃទើបទ្រង់ស្រេកទឹក សម្លឹងរកក្អមទឹកក៏ទ្រង់មិនឃើញក្នុងទីណាឡើយ តែទ្រង់បានឃើញអណ្តូងទឹកនៅខាងចុងទីចង្រ្កម ។ ព្រះរាជាអង្គនោះ កាលត្រាច់រកខ្សែនិងក្អមដើម្បីដងទឹក ក៏មិនបានឃើញ កាលទ្រង់មិនអាចនឹងអត់សង្កត់ចំពោះសេចក្តីស្រេកឃ្លានបាន ទើបយកខ្សែ ដែលចងត្រង់ពោះដំរីមកឲ្យដំរីឈរក្នុងទីជិតមាត់អណ្តូងទឹក យកខ្សែចងត្រង់ជើងដំរី ហើយតោងខ្សែចុះទៅក្នុងអណ្តូងទឹក កាលខ្សែមិនគ្រប់គ្រាន់ទើបស្តេចឡើងមកជាថ្មី ទ្រង់យកសំពត់សាដកសម្រាប់ដណ្តប់ចងជាមួយចុងខ្សែ ហើយស្តេចចុះទៅទៀត ។ សូម្បីយ៉ាងនោះ ខ្សែក៏នៅមិនគ្រប់គ្រាន់ ។ ព្រះអង្គទ្រង់យកចុងព្រះបាទទាំង ២ ប៉ះទឹកទ្រង់កាន់តែស្រេកទឹកខ្លាំងឡើងបន្ទោបង់សេចក្តីស្រេកមិនបានទើបទ្រង់ព្រះតម្រិះថា ទោះបីស្លាប់ក៏ស្លាប់ទៅចុះ ដូច្នេះហើយទើបលែងខ្សែទម្លាក់ខ្លួនទៅក្នុងអណ្តូងទឹកសោយរហូតគ្រប់គ្រាន់ដល់សេចក្តីត្រូវការ កាលមិនអាចឡើងបានទើបឈរក្នុងអណ្តូងទឹកនោះឯង ។ ដំរីក៏មិនទៅក្នុងទីដទៃឈរយាមព្រះរាជា ក្នុងទីនោះឯង ព្រោះជាដំរីដែលបានទទួលការសិក្សាមកល្អហើយ ក្នុងវេលាល្ងាចព្រះពោធិសត្វនាំយកផលាផលទាំងឡាយមក ឃើញដំរីទើបគិតថា ព្រះរាជាគង់នឹងយាងមកទើបដំរីប្រាកដ តើមានហេតុអ្វីហ្ន៎ ដូច្នេះហើយទើបចូលទៅជិតដំរី ។ ចំណែកដំរីដឹងថាព្រះពោធិសត្វនេះចូលមករក

ទើបឈរស្ងៀមក្នុងចំណែកម្ខាង ។ ព្រះពោធិសត្វដើរទៅកាន់មាត់អណ្តូង ឃើញព្រះរាជាទើបលួងលោមថា បពិត្រមហារាជ សូមទ្រង់កុំខ្លាចឡើយ ហើយចងបង្អោងឲ្យព្រះរាជាឡើង គក់ប្របាច់ព្រះវរកាយរបស់ព្រះរាជាលាបដោយប្រេង រកទឹកមកឲ្យស្រពស្រង់ ឲ្យសោយផ្លែឈើតូចធំហើយស្រាយគ្រឿងចងដីរ ។ ព្រះរាជាទ្រង់ស្នាក់នៅ ២-៣ ថ្ងៃ ទ្រង់កាន់យកប្តេជ្ញាដើម្បីឲ្យព្រះពោធិសត្វមកកាន់សម្នាក់របស់ព្រះអង្គហើយយាងទៅ ។ ពលនិកាយរបស់ព្រះរាជាបោះជំរុំមិនឆ្ងាយអំពីព្រះនគរឃើញព្រះរាជាយាងមកទើបនាំគ្នាហែហម ។ ព្រះរាជាយាងចូលកាន់ព្រះនគរ ។ ចំណែកព្រះពោធិសត្វលុះកន្លងទៅបានកន្លះខែ ក៏ទៅកាន់នគរពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យានស្អែកឡើងត្រាច់កិក្ខាចារទៅដល់ទ្វារព្រះរាជវាំង ។ ព្រះរាជាទ្រង់បើកមហាសីហបញ្ជរទតលានព្រះរាជវាំងទ្រង់ឃើញព្រះពោធិសត្វក៏ចាំបាន ទើបយាងចុះមកអំពីប្រាសាទ ថ្វាយបង្គំហើយទ្រង់នាំឡើងកាន់ប្រាសាទ ឲ្យគង់លើរាជបល្ល័ង្ក ដែលលើកស្វេតច្ឆត្រ ឲ្យឆាន់អាហារដែលគេចាត់ចែងទុកសម្រាប់ព្រះអង្គ សូម្បីព្រះអង្គឯងក៏សោយស្រេចហើយនាំទៅកាន់ព្រះរាជឧទ្យានឲ្យសាងលំនៅប្រកបដោយទីចង្ក្រមជាដើមដល់ព្រះពោធិសត្វក្នុងព្រះរាជឧទ្យាននោះហើយប្រគេនបព្វជិតបរិក្ខារសព្វយ៉ាង ទ្រង់ប្រគល់ឲ្យនាយឧទ្យានបាលដាក់វេនថែរក្សា ថ្វាយបង្គំហើយយាងចេញទៅ ។ ចាប់តាំងអំពីនោះព្រះពោធិសត្វបរិភោគចំពោះក្នុងរាជនិវេសន៍មានសក្ការៈនិងការរាប់អានច្រើន ។ អាមាត្យទាំងឡាយអត់ធន់នឹងការធ្វើនោះមិនបាននាំគ្នាពោលថា សក្ការៈបែប

នេះទាហានម្នាក់ ( ក៏មិន ) បាន គួរធ្វើដូចម្តេច ហើយនាំគ្នាចូលទៅគាល់ឧបរាជធ្វើសេចក្តីគោរពហើយទូលថា បពិត្រព្រះរាជកុមារ ព្រះរាជារបស់ទូលព្រះបង្គំកាន់យកតាបសមួយរូបថាជារបស់អញយ៉ាងខ្ជាប់ខ្ជួន គុណអ្វីដែលព្រះរាជានោះ ទ្រង់បានឃើញក្នុងតាបសនោះ សូមព្រះអង្គប្រឹក្សាជាមួយព្រះរាជា ។ ឧបរាជទទួលពាក្យហើយចូលទៅគល់ព្រះរាជាមួយអន្លើជាមួយអាមាត្យ ថ្វាយបង្គំហើយពោលគាថាទី ១ ថា

កម្មតិចតួចដែលសម្រេចដោយវិជ្ជារបស់តាបសនេះ មិនមានឡើយ មួយទៀតតាបសនេះ មិនមែនជាផៅពង្សទាំងមិនមែនជាសំឡាញ់របស់ព្រះអង្គទេ កាលបើយ៉ាងនេះហេតុអ្វីបានជាតាបសឈ្មោះតិរិតិវច្ឆៈ កាន់ឈើច្រត់មានចំពាម ៣ បរិភោគនូវដុំបាយមានរសដ៏ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នយិមស្ស វិជ្ជាមយមត្ថិ កិញ្ចិ** សេចក្តីថា ការងារណាមួយដែលសម្រេចដោយវិជ្ជារបស់តាបសនេះមិនមាន ។ បទថា **ន ពន្ធវោ** សេចក្តីថា បណ្តាផៅពង្សខាងឱរស ផៅពង្សខាងសិប្បៈផៅពង្សខាងគោត្តនិងផៅពង្សខាងញាតិ សូម្បីផៅពង្សខាងណាមួយក៏មិនមាន ។ បទថា **នោ បន តេ សហាយោ** សេចក្តីថា ទាំងមិនបានជាសម្លាញ់ដែលលេងធូលីជាមួយព្រះអង្គ ។ បទថា **កេន វណ្ណេន** បានដល់ ព្រោះហេតុអ្វី ។ បទថា **តិរីតិវច្ឆោ** ជាឈ្មោះរបស់តាបសនោះ ។ បទថា **តេទណ្ឌិកោ** សេចក្តីថា កាន់ឈើច្រត់ចំពាម ៣ ដើម្បីព្យួរកុណ្ឌី

ទឹកត្រាច់ទៅ ។ បទថា **អគ្គបិណ្ឌំ** សេចក្ដីថា រមែងបរិភោគភោជនដ៏ប្រសើរបរិបូណ៌ដោយរសដែលគួរដល់ព្រះរាជា ។

ព្រះរាជាទ្រង់បានស្ដាប់ដូច្នោះ ទើបត្រាស់ហៅព្រះឱរសមកហើយត្រាស់ថា នែបា បុត្តរឮកបានដល់កាលដែលឪពុកទៅប្រទេសជាយដែនច្បាំងចាញ់ហើយមិនបានមកអស់កាល ២-៣ ថ្ងៃដែរឬ កាលព្រះរាជឱរសទូលថា រឮកបានព្រះអង្គ ទើបព្រះរាជាត្រាស់ថា ក្នុងកាលនោះ ឪពុកអាស្រ័យតាបសនេះទើបបានជីវិតមក ។ ដូច្នេះហើយទើបត្រាស់ប្រាប់រឿងទាំងអស់ហើយត្រាស់បន្ថថា នែបា កាលបុគ្គលឲ្យជីវិតដល់យើងមកកាន់សម្នាក់របស់យើង ទោះឲ្យរាជសម្បត្តិ យើងក៏មិនអាចធ្វើឲ្យសមគួរដល់គុណ ដែលតាបសនេះបានធ្វើទុកដូច្នេះហើយទើបត្រាស់គាថា ២ ថា

ក្នុងគ្រាមានអន្តរាយ កាលអញច្បាំងចាញ់គេ ( តាបសនេះ ) បានធ្វើ ( នូវសេចក្ដីអនុគ្រោះ ) ដល់អញម្នាក់ឯងក្នុងព្រៃគួរខ្លាចដ៏ពន្លឹក បានលានូវដៃ ( យោងអញ ) ដែលដល់នូវសេចក្ដីលំបាក ( ក្នុងអណ្ដូង ) ព្រោះហេតុនោះអញដែលត្រូវសេចក្ដីទុក្ខគ្របសង្កត់ទើបបានឡើងរួចមក ។

អញ ( បិតនៅ ) ក្នុងជីវលោក ( នេះដល់ ) នូវវិស័យនៃសេចក្ដីស្លាប់ទៅហើយ តែមកក្នុងទីនេះបាន ព្រោះសេចក្ដីលំបាកនៃតាបសនេះ ម្នាលកូន រីតិរិតិវច្ឆៈតាបសជាបុគ្គលគួរដល់លាភ អ្នកទាំងឡាយ ចូរឲ្យនូវគ្រឿងបរិភោគ

ផង ចូរបូជានូវវត្ថុដែលគួរបូជាផងដល់លោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាចាសុ** បានដល់ ក្នុងអន្តរាយទាំងឡាយ ។ បទថា **ឯកស្ស** បានដល់ មិនមានសម្លាញ់ ។ បទថា **កត្វា** បានដល់ ធ្វើសេចក្ដីនូវអនុគ្រោះ គឺធ្វើនូវសេចក្ដីស្រឡាញ់ឲ្យកើតឡើង ។ បទថា **ឋិរឌស្មិ** បានដល់ ក្នុងព្រៃដែលរៀបចាកទឹកផឹក ។ បទថា **ឃោរេ** បានដល់ គួរខ្លាច ។ បទថា **បសារយិ កិច្ចគតស្ស បាណឹ** សេចក្ដីថា តិរិតិវច្ចតាបសចងបង្អោនលាដៃ ដែលប្រកបដោយសេចក្ដីព្យាយាមដើម្បីជួយបិតាចេញអំពីអណ្ដូងបានទទួលសេចក្ដីទុក្ខឲ្យឡើងអំពីអណ្ដូង ។ បទថា **តេនុទ្ធតោរឹ ឧក្ខុសម្បរេតោ** សេចក្ដីថា ព្រោះហេតុនោះ សូម្បីយើងក៏នឹងត្រូវសេចក្ដីទុក្ខគ្របសង្កត់ក៏ឡើងអំពីអណ្ដូងនោះបាន ។ បទថា **ឯតស្ស កិច្ចេន ឥធានុបត្តោ** សេចក្ដីថា បិតាមកដល់នគរនេះបានដោយសេចក្ដីលំបាករបស់តាបសនេះ គឺដោយអានុភាពនៃសេចក្ដីលំបាកដែលតាបសនេះធ្វើ ។ បទថា **វេយ្យាសិនោ វិសយា** សេចក្ដីថា ស្ដេចយម ហៅថា **វេយ្យាសិ** ។ វិស័យនៃស្ដេចយមនោះ ។ បទថា **ជីវលោកេ** បានដល់ ក្នុងមនុស្សលោក ។ លោកពោលអធិប្បាយទុកថា ដ្បិតថា បិតាតាំងនៅក្នុងមនុស្សលោកនេះឯង តែក៏បានឈ្មោះថាទៅកាន់បរលោកដែលជាវិស័យនៃស្ដេចយម គឺជាវិស័យនៃមច្ចុរាជ បិតានោះឈានកន្លងវិស័យរបស់ស្ដេចយមមកកាន់នគរនេះបានទៀត ព្រោះហេតុនៃតាបសនេះ ដូច្នេះ ។ បទថា **លាភារហោ** បានដល់ ជាអ្នកគួរដល់លាភ គឺជាអ្នកសមគួរបានចតុប្បច្ច័យ ។

បទថា **ទេថស្ស ភោគំ** សេចក្តីថា អ្នកទាំងឡាយចូរឲ្យគ្រឿងបរិភោគ ពោលគឺ សមណបរិក្ខារដែលជាបច្ច័យ ៤ ដែលតាបសនេះគប្បីប្រើប្រាស់ ដល់តាបសនេះ ។ បទថា **យជិតញ្ច យញ្ញំ** សេចក្តីថា អ្នកទាំងឡាយ គឺ បុត្តពួកអាមាត្យនិងអ្នកនគរ ចូរឲ្យគ្រឿងបរិភោគនិងបូជាដល់តាបសនេះ ដ្បិតថា ទេយ្យធម៌ដែលលោកទាំងឡាយឲ្យដល់តាបសនោះ រមែងឈ្មោះថា ជាគ្រឿងបរិភោគព្រោះជារបស់ដែលតាបសនោះដែលត្រូវបរិភោគប្រើប្រាស់ និងឈ្មោះថាជាយញ្ញព្រោះជាយញ្ញគឺ ទានរបស់បុគ្គលក្រៅអំពីនេះ ដោយហេតុនោះទើបលោកពោលថា អ្នកទាំងឡាយ ចូរឲ្យនូវគ្រឿងបរិភោគផង ចូរបូជានូវវត្ថុដែលគួរបូជាផងដល់លោកដូច្នេះ ។

កាលព្រះរាជា ទ្រង់ប្រកាសគុណរបស់ព្រះពោធិសត្វ ដូចធ្វើព្រះចន្ទឲ្យអណ្តែតឡើងក្នុងលម្ហមេឃ ដោយប្រការយ៉ាងនេះគុណរបស់តិរិតិវច្ឆតាបសនោះក៏កើតប្រាកដមានប្រយោជន៍ក្នុងទីគ្រប់ស្ថាននោះឯង ។ លាភសក្ការៈដ៏ច្រើនក្រៃលែង ក៏កើតឡើងដល់តិរិតិវច្ឆតាបសនោះ ។ ចាប់អំពីនោះបុគ្គលណាមួយទោះជាឧបរាជ ពួកអាមាត្យឬជនដទៃក្តី រមែងមិនអាចពោលពាក្យណាមួយនឹងព្រះរាជាបាន ។ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ បំពេញបុណ្យទាំងឡាយមានទានជាដើម ទ្រង់ធ្វើស្ថានសួគ៌ឲ្យពេញបរិបូណ៌ ។ ចំណែកព្រះពោធិសត្វក៏ធ្វើអភិញ្ញានិងសមាបត្តិទាំងឡាយឲ្យកើតឡើង មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់

ត្រាស់ថា បុរាណកបណ្ឌិតទាំងឡាយក៏ធ្វើឧបការៈ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាព្រះអានន្ទក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តិរីតិវច្ឆជាតក ចប់

# ទូតជាតក

[ ៣៧៩ ] ( លោលបុរសពោលថា ) សត្វទាំងឡាយមកកាន់ប្រទេសឆ្ងាយដើម្បីសូមនូវវត្ថុនឹងបុគ្គលសូម្បីជាសត្រូវ ដើម្បីប្រយោជន៍ដល់ផ្ទៃណា ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។

[ ៣៨០ ] មាណពទាំងឡាយលុះអំណាចនៃផ្ទៃណា ទាំងថ្ងៃទាំងយប់ ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។

[ ៣៨១ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) ម្នាលព្រាហ្មណ៍យើងឲ្យនូវគោសម្បុរក្រហម ១ ពាន់ព្រមទាំងគោបាដល់អ្នកព្រោះយើងជាទូត ( របស់ផ្ទៃ ) នឹងមិនឲ្យដល់អ្នកជាទូត ( របស់ផ្ទៃដែរ ) ដូចម្តេចកើត យើងទាំងឡាយសុទ្ធតែជាទូតរបស់ផ្ទៃដូចគ្នា ។

**ចប់ ទូតជាតកទី ១០ ។**

**ចប់ សង្កប្បវគ្គទី ១ ។**

## ឧទ្ទាននៃសង្កប្បវគ្គនោះគឺ

និយាយអំពីជាតិសេរប្រសើរ ១ លូមួយក្តាប់ ១ កែវមណី ១ ស្តេចសេះ ១ សត្វហើរឡើងអាកាស ១ ពស់មានពិសដ៏ក្លៀវក្លា ១ ស្តេចទ្រង់ព្រះនាមជនសន្ធៈ ១ ក្មេងកហាបណៈ ១ តាបសឈ្មោះតិរិតិវច្ឆៈ ១ ទូតរបស់ផ្ទៃ ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ទូតជាតក

[ ៣៧៩-៣៨១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឡេះឡោះមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យស្សត្ថា ទូរមាយន្តិ** ដូច្នេះជាដើម ។

រឿងនឹងមានជាក់ច្បាស់ក្នុងចក្កវាកជាតកនវកនិបាត ។ ព្រះសាស្តាហៅភិក្ខុរូបនោះមកត្រាស់ថា ម្នាលភិក្ខុ អ្នកជាបុគ្គលឡេះឡោះចំពោះក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនអ្នកក៏ជាបុគ្គលឡេះឡោះក៏ព្រោះភាពជាបុគ្គលឡេះឡោះអ្នករិះត្រូវកាត់ក្បាលដោយដាវ ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាឱរសរបស់ព្រះបាទព្រហ្មទត្តនោះ ក្នុងកាលចម្រើនវ័យក៏បានរៀនសិល្បសាស្ត្រទាំងពួងក្នុងនគរតក្កសិលា កាលព្រះជនកសោយទិវង្គតហើយក៏បានតាំងនៅក្នុងរាជសម្បត្តិបានសោយភោជនដ៏បរិសុទ្ធ ។ ដោយហេតុនោះទើបព្រះអង្គមានព្រះនាមថា ព្រះបាទភោជនសុទ្ធិករាជ ។ បានឮថា ព្រះអង្គទ្រង់តាំងនៅក្នុងឋានៈបែបនោះ សោយព្រះក្រយាហារដែលមានភាជនៈមួយមានតម្លៃមួយសែនកហាបណៈ មួយវិញទៀតកាលសោយក៏មិនសោយខាងក្នុងព្រះរាជសម្នាក់ ព្រោះមានបំណងនឹងឲ្យមហាជនបានឃើញវិធីសោយរបស់ព្រះអង្គដែលបានធ្វើបុណ្យទើបឲ្យសាងរតនៈមណ្ឌបត្រង់ទ្វារព្រះរាជវាំងវេលាសោយក៏ឲ្យតាក់តែងរតនមណ្ឌបនោះហើយប្រថាប់លើរាជបល្ល័ង្ក ដែល

សម្រេចដោយមាសខាងក្រោមស្វេតច្ឆត្រ ចោមរោមដោយខត្តិយកញ្ញាទាំងឡាយ ទើបសោយព្រះក្រយាហារដែលមានរសដែលមានតម្លៃ ១០០០០០ កហាបណៈ ដោយភាជនៈមាសដែលមានតម្លៃ ១០០០០០ កហាបណៈ ។

គ្រានោះមានបុរសឡេះឡោះម្នាក់ បានឃើញវិធីសោយព្រះក្រយាហាររបស់ព្រះរាជានោះ ចង់បរិភោគភោជននោះ កាលមិនអាចនឹងអត់សង្កត់ចំណង់បានគិតថា មានឧបាយមួយដូច្នេះហើយទើបស្លៀកសំពត់យ៉ាងខ្ជាប់ខ្ជួនហើយលើកដៃម្ខាងឡើងស្រែកខ្លាំងៗថា លោកដ៏ចម្រើនទាំងឡាយ ខ្ញុំជាទូត លោកដ៏ចម្រើនទាំងឡាយ ខ្ញុំជាទូត ហើយចូលទៅគាល់ព្រះរាជា ។ សម័យនោះក្នុងជនបទនោះបុគ្គលណាមួយ រមែងមិនឃាត់មនុស្សដែលពោលថា ខ្ញុំជាទូត ព្រោះហេតុនោះទើបមហាជនញែកជា ២ ចំណែកឲ្យឱកាស ។ បុរសនោះប្រញាប់ទៅចាប់យកដុំភត្តមួយដុំអំពីភាជនៈមាសរបស់ព្រះរាជា ដាក់ក្នុងមាត់ ។ លំដាប់នោះទាហានដាវហូតដាវដោយបំណងថានឹងកាត់ក្បាលរបស់បុរសនោះ ។ ព្រះរាជាឃាត់ថា កុំប្រហារហើយត្រាស់បន្ថថា អ្នកកុំខ្លាចចូរបរិភោគចុះ ។ ហើយទ្រង់លាងព្រះហស្តប្រថាប់គង់ ។ ក្នុងវេលាស្រេចការបរិភោគ ព្រះរាជាឲ្យប្រទានទឹកផឹកនិងម្លូរបស់ព្រះអង្គដល់បុរសនោះហើយត្រាស់សួរថា នៃបុរសដ៏ចម្រើន អ្នកពោលថាជាទូត អ្នកជាទូតរបស់អ្នកណា ។ បុរសនោះក្រាបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គជាទូតរបស់តណ្ហា តណ្ហាតាំងទូលព្រះបង្គំឲ្យជាទូតហើយបញ្ជូនមកថា ចូរអ្នកទៅដូច្នេះហើយបានពោលគាថា ២ ជាបឋមថា

សត្វទាំងឡាយមកកាន់ប្រទេសឆ្ងាយ ដើម្បីសូមនូវវត្ថុនឹងបុគ្គលសូម្បីជាសត្រូវដើម្បីប្រយោជន៍ដល់ផ្ទៃណា ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។

មាណពទាំងឡាយលុះអំណាចនៃផ្ទៃណា ទាំងថ្ងៃទាំងយប់ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្សត្ថា ទូរមាយន្តិ** សេចក្ដីថា សត្វទាំងនេះជាអ្នកនៅក្នុងអំណាចរបស់តណ្ហា រមែងទៅសូម្បីទៅក្នុងទីឆ្ងាយដើម្បីប្រយោជន៍ដល់ផ្ទៃណា ។ បទថា **រថេសភ** បានដល់ បពិត្រព្រះអង្គជាធំជាងពលរថ ។

ព្រះរាជាទ្រង់បានស្ដាប់ពាក្យរបស់បុរសនោះហើយ ទ្រង់ព្រះតម្រិះថា សេចក្ដីនេះពិត សត្វទាំងនេះជាទូតរបស់ផ្ទៃត្រាច់ទៅដោយអំណាចនៃតណ្ហា តណ្ហាក៏រមែងចាត់ចែងសត្វទាំងនេះ បុរសនេះពោលពាក្យជាទីពេញចិត្តអញក្រៃលែង ដូច្នេះហើយទើបទ្រង់ត្រេកអរក្នុងបុរសនោះត្រាស់គាថាទី ៣ ថា

ម្នាលព្រាហ្មណ៍យើងឲ្យនូវគោសម្បុរក្រហម ១ ពាន់ ព្រមទាំងគោបាដល់អ្នក ព្រោះយើងជាទូត ( របស់ផ្ទៃ ) នឹងមិនឲ្យដល់អ្នកជាទូត ( របស់ផ្ទៃដែរ ) ដូចម្ដេចកើត យើងទាំងឡាយសុទ្ធតែជាទូតរបស់ផ្ទៃដូចគ្នា ដូច្នេះ ។

បទថា **ព្រាហ្មណា** នេះ ក្នុងគាថានោះត្រឹមតែជាពាក្យហៅ ។ បទថា **រោហិណីធំ** បានដល់ មានពណ៌ក្រហម ។ បទថា **សហ បុង្គវេន** បានដល់ មួយអន្លើដោយគោដែលជាបរិនាយកដែលការពារអន្តរាយឲ្យ ។ បទថា **មយម្បិ** សេចក្តីថា យើងនិងសត្វទាំងពួងដ៏សេសរមែងជាទូតរបស់ផ្ទៃនោះដូចគ្នា ព្រោះហេតុនោះយើងជាទូតរបស់ផ្ទៃស្មើគ្នា ព្រោះហេតុអ្វីទើបមិនឲ្យដល់អ្នកជាទូតរបស់ផ្ទៃនោះ ។

ព្រះរាជា កាលត្រាស់យ៉ាងនេះហើយ ទ្រង់មានព្រះហឫទ័យត្រេកអរថា បុរសនោះឯងឲ្យយើងបានស្តាប់ហេតុដែលមិនធ្លាប់បានស្តាប់ដូច្នេះហើយទើបបានប្រទានយសធំដល់បុរសនោះ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈភិក្ខុល្មោភល្មោះតាំងនៅក្នុងអនាគាមិផល មហាជនបានជាសោតាបន្នជាដើមហើយទ្រង់ប្រជុំជាតកថា បុរសដែលល្មោភល្មោះក្នុងកាលនោះ បានមកជាភិក្ខុល្មោភល្មោះក្នុងកាលឥឡូវនេះ ចំណែកព្រះបាទភោជនសុទ្ធិកព្រះរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ទូតជាតក ចប់**

**សង្កប្បវគ្គ ចប់**

# បទុមវគ្គ

## បទុមជាតក

[ ៣៨២ ] ( សេដ្ឋីបុត្តទី ១ ពោលថា ) សក់ក្តី ពុកមាត់ក្តីដែលគេកោរកាត់ចោលហើយរមែងដុះឡើងវិញយ៉ាងណា សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញយ៉ាងនោះដែរ យើងសូមផ្កាឈូកហើយអ្នកចូរឲ្យ ។

[ ៣៨៣ ] ( សេដ្ឋីបុត្តទី ២ ពោលថា ) ពូជក្នុងសរទកាល ( រដូវរំហើយ ) ដែលគេព្រោះក្នុងស្រែរមែងលូតលាស់យ៉ាងណាមិញ សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញ យ៉ាងនោះដែរ យើងសូមផ្កាឈូកហើយអ្នកចូរឲ្យ ។

[ ៣៨៤ ] ( សេដ្ឋីបុត្តពោធិសត្វទី ៣ ពោលថា ) ជនទាំងពីរនាក់នេះនិយាយកុហកដោយគិតថា ធ្វើដូចម្តេចហ្ន៎ ( បុរសនេះ ) នឹងឲ្យផ្កាឈូកទាំងឡាយខ្លះ ទោះជនទាំងពីរនាក់នោះពោលក្តីមិនពោលក្តី ការដុះឡើងនៃច្រមុះគ្មានទេ ម្នាលសំឡាញ់សូមអ្នកឲ្យផ្កាឈូកទាំងឡាយ យើងសូមហើយសូមអ្នកឲ្យផ្កាឈូកទាំងឡាយ ។

**ចប់ បទុមជាតក ទី ១ ។**

# បទុមវគ្គ

## អដ្ឋកថា បទុមជាតក

[ ៣៨២-៣៨៤ ] ព្រះសាស្តាកាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុទាំងឡាយដែលធ្វើការបូជាដោយផ្កាត្រង់ដើមអានន្ទពោធិ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា កេសា ច មស្សុ ច** ដូច្នេះជាដើម ។ រឿងនេះមានច្បាស់នៅក្នុងកាលិង្គពោធិជាតក ។

ដើមពោធិនោះឈ្មោះថា អានន្ទពោធិ ព្រោះជាដើមពោធិដែលព្រះអានន្ទត្ថេរដាំទុក ។ ពិតហើយការដែលព្រះថេរៈដាំដើមពោធិទុកត្រង់ខ្លោងទ្វារវត្តជេតពនបានផ្សព្វផ្សាយទូទាំងជម្ពូទ្វីប ។ គ្រានោះភិក្ខុអ្នកជនបទពួកខ្លះនាំគ្នាគិតថា ពួកយើងនឹងធ្វើការបូជាដោយកម្រងផ្កាត្រង់អានន្ទពោធិ ដូច្នេះហើយទើបទៅកាន់វិហារជេតពនថ្វាយបង្គំព្រះសាស្តា ស្អែកឡើងចូលទៅកាន់នគរសាវត្ថីទៅកាន់ផ្លូវដែលមានលក់ផ្កាឧប្បល មិនបានផ្កា ទើបត្រឡប់មកប្រាប់ដល់ព្រះអានន្ទត្ថេរថា អាវុសោ ពួកខ្ញុំគិតគ្នាថានឹងធ្វើការបូជាដោយផ្កាត្រង់ដើមពោធិទើបទៅកាន់ផ្លូវដែលមានលក់ផ្កាឧប្បល ក៏មិនបានផ្កាសូម្បីត្រឹមតែមួយទង ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ខ្ញុំនឹងនាំមកឲ្យលោក ។ ហើយដើរទៅកាន់ផ្លូវដែលមានលក់ផ្កាឧប្បល ឲ្យគេយកបាច់ផ្កាឧប្បលខៀវដ៏ច្រើនហើយបញ្ជូនទៅប្រគេនដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះកាន់យកផ្កាឧប្បលខៀវទាំងនោះទៅបូជាត្រង់ដើមពោធិ ។ ភិក្ខុទាំងឡាយដឹងរឿងទាំងនោះទើបអង្គុយសន្ទនាគ្នាដល់គុណរបស់ព្រះថេរៈក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុអ្នកជនបទមានបុណ្យតិច ទៅកាន់ផ្លូវដែលមានលក់ផ្កា

ឧប្បលក៏មិនបានផ្កា ចំណែកព្រះថេរៈ ទៅតែមួយស្របក់ក៏បានផ្កាមកហើយ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឈ្លាសក្នុងការពោល ឈ្លាសក្នុងវាចា រមែងបានផ្កាតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនសូម្បីក្នុងកាលមុនបុគ្គលឈ្លាសក៏បានហើយដូចគ្នា ។ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាបុត្តសេដ្ឋី ។ ខាងក្នុងព្រះនគរនោះ ក្នុងស្រះមួយកន្លែងឈូកកំពុងចេញផ្កា ។ បុរសច្រមុះក្រហតម្នាក់រក្សាស្រះនោះ ។ ថ្ងៃមួយកាលគេប្រកាសការសម្តែងមហោស្រពក្នុងនគរពារាណសី បុត្តរបស់សេដ្ឋី ៣ នាក់មានសេចក្តីប្រាថ្នានឹងប្រដាប់ផ្កាលេងមហោស្រព ទើបគិតថានឹងពណ៌នាគុណរបស់បុរសច្រមុះក្រហតដោយពាក្យមិនពិតហើយនឹងសូមផ្កា ។ សេដ្ឋីបុត្តទាំងនោះកាលគិតគ្នាហើយ ក្នុងវេលាដែលបុរសច្រមុះក្រហតនោះកាច់ផ្កាឈូកទើបចូលទៅជិតស្រះ បានឈរក្នុងទីសមគួរនាចំណែកម្ខាង ។ បណ្តាសេដ្ឋីបុត្តទាំង ៣ នាក់នោះ សេដ្ឋីបុត្តម្នាក់ហៅបុរសច្រមុះក្រហតនោះមកហើយពោលគាថាទី ១ ថា

សក់ក្តី ពុកមាត់ក្តីដែលគេកោរកាត់ចោលហើយ រមែងដុះ
ឡើងវិញយ៉ាងណា សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញយ៉ាង

នោះដែរ យើងសូមផ្កាឈូកហើយអ្នកចូរឲ្យ ដូច្នេះ ។

បុរសប្រមុះក្រហតនោះក្រោធចំពោះសេដ្ឋីបុត្តនោះទើបមិនឲ្យផ្កាឈូក ។ លំដាប់នោះសេដ្ឋីបុត្តទី ២ បានពោលគាថាទី ២ ចំពោះបុរសនោះថា

ពូជក្នុងសរទកាល ( រដូវរំហើយ ) ដែលគេព្រោះក្នុងស្រែ
រមែងលូតលាស់យ៉ាងណាមិញ សូមឲ្យប្រមុះរបស់អ្នកដុះឡើង
វិញយ៉ាងនោះដែរ យើងសូមផ្កាឈូកហើយអ្នកចូរឲ្យ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សារទិកំ** បានដល់ ពូជដែលបរិបូណ៌ដោយសាច់ ដែលបុគ្គលកាន់យកក្នុងសរទកាលហើយរក្សាទុក ។

បុរសប្រមុះក្រហតនោះក្រោធចំពោះសេដ្ឋីបុត្តនោះ ក៏មិនឲ្យផ្កាឈូក ។ លំដាប់នោះសេដ្ឋីបុត្តទី ៣ ពោលគាថាទី ៣ ចំពោះបុរសនោះថា

ជនទាំងពីរនាក់នេះ និយាយកុហកដោយគិតថា ធ្វើដូចម្ដេចហ្ន៎
( បុរសនេះ ) នឹងឲ្យផ្កាឈូកទាំងឡាយខ្លះ ទោះជនទាំងពីរ
នាក់នោះពោលក្ដី មិនពោលក្ដី ការដុះឡើងនៃប្រមុះគ្មានទេ
ម្នាលសំឡាញ់ សូមអ្នកឲ្យផ្កាឈូកទាំងឡាយ យើងសូម
ហើយសូមអ្នកឲ្យផ្កាឈូកទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧភោបិ វិលបន្តេ តេ** សេចក្ដីថា ជនទាំង ២ នោះនិយាយកុហក ។ បទថា **អបិ បទ្មានិ** សេចក្ដីថា ជនទាំង ២ នោះគិតថា បុរសប្រមុះក្រហតនឹងឲ្យផ្កាឈូកដល់ពួកយើងខ្លះ ដូច្នេះហើយទើបពោលយ៉ាងនោះ ។ បទថា **វជ្ជុំ វា តេ ន វា វជ្ជុំ** សេចក្ដីថា

ជនទាំងនេះ គប្បីពោលឬមិនគប្បីពោលយ៉ាងនេះថា ប្រមុះរបស់អ្នកចូរដុះឡើង ឈ្មោះថា ពាក្យរបស់ជនទាំងនោះ មិនជាប្រមាណ ប្រមុះរមែងមិនដុះឡើង ដោយប្រការទាំងពួង ចំណែកខ្ញុំមិនពោលអាស្រ័យដល់ប្រមុះរបស់អ្នក សូមតែម្យ៉ាង នែសម្លាញ់ អ្នកកាលខ្ញុំសូម ចូរឲ្យផ្កាឈូកនោះដល់ខ្ញុំ ។

បុរសអ្នកយាមស្រះឈូកបានស្តាប់ដូច្នោះ ទើបពោលថា ជនទាំង ២ នេះធ្វើមុសាវាទ ចំណែកអ្នកពោលតាមសភាវៈ ( ពិត ) ផ្កាឈូកទាំងឡាយសមគួរដល់អ្នក ។ ហើយកាន់យកផ្កាឈូកមួយបាច់ធំមកឲ្យដល់សេដ្ឋីបុត្តទី ៣ នោះ ហើយត្រឡប់ទៅកាន់ស្រះឈូករបស់ខ្លួនវិញ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា សេដ្ឋីបុត្តដែលបានផ្កាឈូកក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បទុមជាតក ចប់

## មុទុបាណិជាតក

[ ៣៨៥ ] ( ព្រះរាជធីតាពោលថា ) បើចូឡុបដ្ឋាកមានដៃដ៏ទន់ ១ ដីដែលព្រះអង្គបង្អាត់រាបសាហើយ ១ ពេលងងឹតសូន្យឈឹង ១ ភ្ញៀងបន្អុរចុះ ១ គប្បីមានក្នុងកាលណា សេចក្តីប៉ងក្នុងព្រះរាជហឫទ័យរបស់ព្រះអង្គគង់នឹងសម្រេចក្នុងកាលនោះមិនខាន ។

[ ៣៨៦ ] ( ព្រះរាជាពោធិសត្វជាបិតាពោលថា ) ស្រីទាំងឡាយនោះ បុគ្គលមិនគួរនិយាយដោយពាក្យទន់ភ្លន់ឡើយ ជាស្រីដែលបំពេញបានដោយកម្រ ប្រាកដស្មើដោយស្ទឹងរមែងលិចចុះ ( ក្នុងអបាយ ៤ ) បណ្ឌិតបុរសដឹងច្បាស់ហើយគួរគេចចេញអំពីចម្ងាយ ។

[ ៣៨៧ ] ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណាដោយសេចក្តីពេញចិត្តក្តី ដោយទ្រព្យក្តីតែងដុតបំផ្លាញបុរសនោះ ( ឲ្យវិនាស ) យ៉ាងធាប់ដូចភ្លើង ( ដែលឆេះ ) នូវទីនៅរបស់ខ្លួន ។

**ចប់ មុទុបាណិជាតកទី ២ ។**

## អដ្ឋកថា

## មុទុបាណិជាតក

[ ៣៨៥-៣៨៧ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បាណិ ចេ មុទុកោ ចស្ស** ដូច្នេះជាដើម ។

បានឮថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះដែលត្រូវនាំមកកាន់ធម្មសភាថា ម្នាលភិក្ខុ បានឮថា អ្នកជាអ្នកអផ្សុកពិតមែនឬ កាលភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា ស្ត្រីទាំងឡាយនេះ បុគ្គលណាមួយមិនអាចរក្សាព្រោះទៅតាមអំណាចរបស់កិលេស សូម្បីបុរាណកបណ្ឌិតទាំងឡាយទាំង ដែលចាប់ដៃធីតារបស់ខ្លួនរក្សា ក៏មិនអាចរក្សាបាន ធីតាឈរចាប់ដៃបិតាមិនឲ្យបិតាដឹងខ្លួនឡើយគេចទៅជាមួយបុរសដោយអំណាចកិលេស ។ ទើបទ្រង់នាំយករឿងក្នុងអតីត មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទព្រហ្មទត្តនោះ លុះទ្រង់ចម្រើនវ័យក៏រៀនសិល្បសាស្ត្រគ្រប់យ៉ាងក្នុងនគរតក្កសិលា កាលព្រះរាជបិតាសោយទិវង្គតហើយក៏តាំងនៅក្នុងរាជសម្បត្តិ ទ្រង់គ្រងរាជដោយធម៌ ទ្រង់ចិញ្ចឹមជនទាំង ២ គឺ ព្រះរាជធីតានិងព្រះរាជភាគិនេយ្យទុកក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ ។ ថ្ងៃមួយ ប្រថាប់ជាមួយពួកអាមាត្យត្រាស់ថា កាលយើងស្លាប់ទៅ ក្មួយរបស់យើងនឹងបានជាព្រះរាជា ចំណែកធីតារបស់យើងនឹងបានជាអគ្គមហេសីរបស់ព្រះរាជានោះ ។ ក្នុងកាលតមក ក្នុងវេលាដែលព្រះធីតានិងព្រះភាគិនេយ្យនោះចម្រើនវ័យ ប្រថាប់ជាមួយពួកអាមាត្យម្តងទៀតត្រាស់ថា យើងនឹងនាំធីតារបស់ព្រះរាជាដទៃមកឲ្យក្មួយយើង នឹងឲ្យធីតារបស់យើងក្នុងរាជត្រកូលដទៃ កាលធ្វើយ៉ាងនេះញាតិទាំងឡាយរបស់យើងនឹង

មានច្រើនឡើង ។ អាមាត្យទាំងនោះក៏ទទួលបញ្ជា ។ លំដាប់នោះទើបព្រះរាជាត្រាស់ឲ្យប្រទានវាំងខាងក្រៅដល់ភាគិនេយ្យហាមមិនឲ្យចូលខាងក្នុងព្រះរាជនិវេសន៍ តែជនទាំង ២ នោះមានចិត្តប្រតិព័ទ្ធដល់គ្នានឹងគ្នា ។ ព្រះរាជកុមារគិតថា ដោយឧបាយដូចម្តេចទើបនាំព្រះរាជធីតាមកទុកខាងក្រៅបាន ដូច្នេះហើយទ្រង់គិតថាមានឧបាយដូច្នេះ ទើបឲ្យតម្លៃដល់មេដោះ កាលស្រីមេដោះក្រាបទូលថា បពិត្រអយ្យបុត្ត ទ្រង់មានកិច្ចអ្វី ទើបព្រះរាជកុមារត្រាស់ថា បពិត្រអ្នកម៉ែ ដោយឧបាយដូចម្តេចទើបព្រះរាជធីតាបានឱកាសចេញមកខាងក្រៅព្រះរាជវាំង ។ មេដោះទូលថា ខ្ញុំម្ចាស់និយាយជាមួយព្រះរាជធីតាហើយនឹងដឹងបាន ។ ព្រះរាជកុមារត្រាស់ថា សាធុ ។ មេដោះនោះទៅហើយទូលថា មកព្រះនាងខ្ញុំម្ចាស់នឹងចាប់ចៃលើសីសៈ ហើយឲ្យព្រះរាជធីតានោះគង់លើតាំងតូចខាងក្រោម ខ្លួនឯងនៅលើតាំងតូចខ្ពស់ជាង ឲ្យសីសៈរបស់ព្រះរាជធីតានោះនៅត្រង់ចន្លោះភ្លៅទាំង ២ របស់ខ្លួន ចាប់ចៃទើបយកក្រចករបស់ខ្លួនឆ្កឹះសីសៈរបស់ព្រះរាជធីតា ។ ព្រះរាជធីតាទ្រង់ជ្រាបថា មេដោះនេះរមែងមិនយកក្រចករបស់ខ្លួនឆ្កឹះអញតែយកក្រចកគឺ ការគិតរបស់ព្រះរាជកុមារដែលជាឱរសរបស់ព្រះបិតុច្ឆារបស់យើងឆ្កឹះ ដូច្នេះហើយទើបត្រាស់សួរថា អ្នកម៉ែបានទៅគាល់ព្រះរាជកុមារឬ មេដោះទូលថា ព្រះមេខ្ញុំម្ចាស់ទើបតែមក ។ ព្រះរាជធីតាត្រាស់ថា ព្រះរាជកុមារប្រាប់ដំណឹងអ្វីមកឬ មេដោះទូលថា ព្រះរាជកុមារសួរដល់ឧបាយដែលព្រះនាងបានយាងចេញទៅខាងក្រៅ ព្រះរាជធីតាគិតថា ព្រះរាជកុមារជាបណ្ឌិតមានបញ្ញាក៏

នឹងដឹង ដូច្នេះហើយទើបត្រាស់ថា បពិត្រអ្នកម៉ែ សូមអ្នកម៉ែរៀនយកគាថា នេះទៅប្រាប់ដល់ព្រះរាជកុមារចុះហើយទើបត្រាស់គាថាទី ១ ថា

បើចូឡូបដ្ឋាកមានដៃដ៏ទន់ ១ ដំរីដែលព្រះអង្គបង្ហាត់រាបសា
ហើយ ១ ពេលងងឹតសូន្យឈឹង ១ ភ្លៀងបង្អុរចុះ ១ គប្បី
មានក្នុងកាលណា សេចក្តីប៉ងក្នុងព្រះរាជហឫទ័យរបស់ព្រះ
អង្គគង់នឹងសម្រេចក្នុងកាលនោះមិនខាន ដូច្នេះ ។

មេដោះនោះរៀនគាថានោះហើយទៅគាល់ព្រះរាជកុមារ កាលព្រះរាជកុមារត្រាស់ថា បពិត្រអ្នកម៉ែ ព្រះរាជធីតាត្រាស់អ្វី ទើបទូលថា បពិត្រអយ្យបុត្ត ព្រះរាជធីតាមិនបានត្រាស់ពាក្យណាមួយដទៃឡើយបញ្ជូនតែគាថានេះមក ។ ហើយលើកគាថានោះឡើងមក ។ ចំណែកព្រះរាជកុមារទ្រង់ជ្រាបសេចក្តីរបស់គាថានោះ ទើបបញ្ជូនមេដោះនោះទៅដោយព្រះតម្រាស់ថា បពិត្រអ្នកម៉ែ ទៅចុះ ។ គាថានោះមានសេចក្តីថា បើអ្នកបម្រើម្នាក់របស់ព្រះអង្គមានដៃទន់ដូចដៃរបស់ខ្ញុំ ១ បើដំរីមួយរបស់ព្រះអង្គប្ងូន្ទានឲ្យធ្វើហេតុនៃការមិនញាប់ញ័របានយ៉ាងល្អ ១ ថ្ងៃនោះមានងងឹតប្រកបដោយអង្គបួន ១ ភ្លៀងធ្លាក់ ១ កាលបើមានហេតុយ៉ាងនោះ សេចក្តីប្រាថ្នារបស់ទ្រង់នឹងសមតាមបំណងក្នុងកាលនោះពិត អធិប្បាយថា ព្រោះអាស្រ័យបច្ច័យ ៤ ប្រការនេះ មនោរថរបស់ទ្រង់ក៏នឹងដល់ទីបំផុតដោយពិតប្រាកដក្នុងកាលនោះ ។

ព្រះរាជកុមារទ្រង់ជ្រាបសេចក្តីនោះដោយពិត ទើបទ្រង់ធ្វើការត្រៀមអ្នកបម្រើម្នាក់មានរូបស្អាតមានដៃទន់ ឲ្យថ្ងៃឈ្នួលដល់នាយហត្ថាចារ្យដែលរក្សា

មង្គលហត្ថី ឲ្យហ្វឹកហាត់ដំរីធ្វើអាការមិនឲ្យញាប់ញ័រ ហើយទ្រង់រង់ចាំកាល ។ ក្នុងថ្ងៃឧបោសថខាងរនោច មេឃខ្មៅភ្លៀងធ្លាក់ចុះមកក្នុងវេលាមជ្ឈិមយាម ។ ព្រះរាជកុមារនោះទ្រង់កំណត់ថាថ្ងៃនេះជាថ្ងៃដែលព្រះរាជធីតាកំណត់ ( ណាត់ ) ទុក ដូច្នេះហើយទើបឡើងកាន់កដំរី ឲ្យអ្នកបម្រើដៃទន់នោះអង្គុយលើខ្នងដំរី យាងទៅប្រថាប់ត្រង់ទីទួលទំនេរនៃព្រះរាជនិវេសន៍ ឲ្យដំរីអែបខ្លួនជាប់នឹងជញ្ជាំងប្រថាប់ហាលភ្លៀងក្នុងទីមិនឆ្ងាយអំពីបង្អួច ។ ចំណែកព្រះរាជាកាលនឹងរក្សាព្រះរាជធីតាទើបមិនឲ្យផ្ទំក្នុងទីដទៃឲ្យផ្ទំនៅលើទីបន្ទំតូចជិតព្រះអង្គ ។ ចំណែកព្រះរាជធីតាដឹងថា ថ្ងៃនេះព្រះរាជកុមារយាងមក ដូច្នេះហើយក៏ផ្ទំមិនលក់ឡើយទូលថា បពិត្រព្រះរាជបិតា ខ្ញុំម្ចាស់ចង់ងូតទឹក ។ ព្រះរាជាត្រាស់ថា មកចុះកូន ហើយចាប់ដៃព្រះរាជធីតានាំទៅក្បែរបង្អួចត្រាស់ថា ងូតចុះកូន ។ ហើយលើកឡើងឲ្យឈរត្រង់រានហាលខាងក្រៅបង្អួចប្រថាប់ឈរចាប់ដៃម្ខាង ។ ព្រះរាជធីតានោះកំពុងងូតទឹកក៏លាដៃឲ្យដល់ព្រះរាជកុមារ ព្រះរាជកុមារដោះគ្រឿងអាភរណៈអំពីដៃរបស់ព្រះរាជធីតានោះហើយពាក់ត្រង់ដៃរបស់អ្នកបម្រើនោះ ហើយលើកអ្នកបម្រើនោះឡើង ឲ្យឈរត្រង់រានហាលក្បែរព្រះរាជធីតា ។ ព្រះរាជធីតានោះចាប់ដៃអ្នកបម្រើនោះដាក់ត្រង់ដៃរបស់ព្រះបិតា ។ ព្រះរាជាចាប់ដៃម្ខាងរបស់អ្នកបម្រើនោះហើយលែងដៃម្ខាងរបស់ព្រះរាជធីតា ។ ព្រះរាជធីតានោះ ដោះគ្រឿងអាភរណៈអំពីដៃម្ខាងទៀតពាក់ត្រង់ដៃទីពីររបស់អ្នកបម្រើនោះហើយដាក់ត្រង់ដៃរបស់ព្រះបិតា ខ្លួនឯងទៅជាមួយព្រះរាជកុមារ ។ ព្រះរាជាទ្រង់សម្គាល់ថា នេះជាធីតារបស់អញ ដូច្នេះ

ហើយទើបឲ្យទារកនោះដេកនៅក្នុងបន្ទប់ដ៏មានសិរី ក្នុងវេលាចប់ការផ្ងូតទឹក បិទទ្វារដាក់គន្លឹះធ្វើនូវការរក្សាហើយយាងទៅកាន់ទីផ្ទុំរបស់ព្រះអង្គ ។ កាលរាត្រីអស់ហើយ ព្រះរាជានោះទ្រង់បើកទ្វារឃើញទារកនោះទើបត្រាស់សួរថា នេះមានរឿងអ្វី ទារកនោះ ក្រាបទូលភាពដែលព្រះរាជធីតានោះយាងទៅជាមួយព្រះរាជកុមារ ។ ព្រះរាជាទ្រង់ក្តៅក្រហាយព្រះតម្រិះថា អញចាប់ដៃត្រាច់ទៅក៏មិនអាចរក្សាមាតុគ្រាមបាន ឈ្មោះថាស្រីទាំងឡាយ បុគ្គលណាមួយរក្សាមិនបានយ៉ាងនេះ ដូច្នេះហើយទើបត្រាស់គាថា ២ ក្រៅនេះថា

ស្រីទាំងឡាយនោះ បុគ្គលមិនគួរនិយាយដោយពាក្យទន់ភ្លន់ឡើយ ជាស្រីដែលបំពេញបានដោយកម្រប្រាកដស្មើដោយស្ទឹង រមែងលិចចុះ ( ក្នុងអបាយ ៤ ) បណ្ឌិតបុរសដឹងច្បាស់ហើយគួរគេចចេញអំពីចម្ងាយ ។

ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណាដោយសេចក្តីពេញចិត្តក្តី ដោយទ្រព្យក្តីតែងដុតបំផ្លាញបុរសនោះ ( ឲ្យវិនាស ) យ៉ាងឆាប់ដូចភ្លើង ( ដែលឆេះ ) នូវទីនៅរបស់ខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អឈលា មុទុសម្ភាសា** សេចក្តីថា បុរសទាំងឡាយមិនអាច គឺមិនអាចហួងហែងបានសូម្បីដោយពាក្យដ៏ពីរោះទន់ភ្លន់ ។ ម្យ៉ាងទៀតឈ្មោះថា មិនអាចរក្សាបានព្រោះបុរសទាំងឡាយមិនអាចរក្សាស្ត្រីទាំងនេះ ។ បទថា **មុទុសម្ភាសា** សេចក្តីថា ឈ្មោះថា **មុទុសម្ភាសា** ព្រោះកាលបេះដូងរឹងត្អឹង ក៏មានពាក្យសម្តីទន់ភ្លន់ ។ បទថា **ទុប្បូរា តា**

**ធនិសមា** សេចក្តីថា ឈ្មោះថា **ធុប្បុរា** ព្រោះមិនឆ្អែតដោយមេថុនជាដើមដែលសេពហើយរឿយៗ ដូចស្ទឹងដែលបំពេញបានដោយក្រព្រោះទឹកហូរទៅមក ។ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមរមែងមិនឆ្អែត មិនទ្រាន់ចំពោះធម៌ ៣ យ៉ាងរហូតដល់មរណកាល ។ ធម៌ ៣ យ៉ាងនេះ តើដូចម្តេច ។ គឺមេថុនធម្មសមាបត្តិ ១ ប្រសូតបុត្ត ១ ការប្រដាប់តាក់តែងខ្លួន ១ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមរមែងមិនឆ្អែត មិនទ្រាន់ចំពោះធម៌ ៣ យ៉ាងនេះរហូតដល់មរណកាល ដូច្នេះ ។

បទថា **សីទន្តិ** សេចក្តីថា រមែងលិច គឺលិចក្នុងមហានរក ៨ និងឧស្សទនរក ១៦ ។ បទថា **ធំ** ត្រឹមតែជានិបាត ។ បទថា **វិទិត្វាន** ប្រែថា ដឹងច្បាស់ហើយយ៉ាងនេះ ។ បទថា **អារកា បរិវជ្ជយេ** នេះ លោកសម្តែងថា បុរសដែលជាបណ្ឌិតដឹងយ៉ាងនេះថា ធម្មតាស្ត្រីទាំងនេះមិនឆ្អែតក្នុងមេថុនធម្មជាដើម ស្លាប់ហើយរមែងលិចចុះក្នុងនរកទាំងនេះ កាលខ្លួនលិចចុះយ៉ាងនេះហើយនឹងកើតមានសេចក្តីសុខដល់អ្នកដទៃ ( ដូចម្តេចកើត ) ដូច្នេះហើយគប្បីវៀរស្រីទាំងនេះចេញអំពីចម្ងាយ ។ បទថា **ឆន្ទសា វា ធនេន វា** សេចក្តីថា ស្ត្រីទាំងនេះរមែងចូលទៅសេពគប់ គឺគប់រកបុរស

---

១-គាថានេះមានក្នុងអង្គុត្តរនិកាយទុកនិបាត ក្នុងទីនោះមិនមានការប្រដាប់តាក់តែងខ្លួន ឯក្នុងតិកនិបាតយើងរកពុំជួបឡើយ ។

ណាព្រោះសេចក្តីពេញចិត្ត គឺសេចក្តីពេញចិត្ត សេចក្តីស្រឡាញ់របស់ខ្លួន ឬព្រោះទ្រព្យដែលបានមកដោយការជួល ។ បទថា **ជាតវេទោ** បានដល់ភ្លើង ។ ពិតហើយភ្លើងនោះឈ្មោះថា **ជាតវេទោ** ព្រោះគ្រាន់តែកើតប៉ុណ្ណោះក៏ដឹងបានជាសភាពដែលដឹង គឺប្រាកដ ។ ភ្លើងនោះរមែងឆេះទីកន្លែង គឺហេតុ បានដល់ទីរបស់ខ្លួនយ៉ាងណាស្រីទាំងនោះក៏យ៉ាងនោះដូចគ្នា សេពគប់ជាមួយបុរសណារមែងឆេះ គឺដុតមួយរំពេចនូវបុរសនោះសូម្បីដែលប្រកបដោយទ្រព្យ យស សីលនិងបញ្ញា ធ្វើឲ្យសម្បត្តិនោះមិនគួរកើតឡើងទៀតដោយធ្វើទ្រព្យជាដើមទាំងនោះឲ្យវិនាសទៅ ។ សមពិតដូចលោកពោលទុកថា

ជនដែលធ្លាក់នៅក្នុងអំណាចរបស់មាតុគ្រាម ទោះបីមានកម្លាំង
ក៏ទៅជាអ្នកខ្សោយកម្លាំង ទោះបីជាអ្នកមានថាមពលក៏វិនាស
ថមថយទៅ ទោះបីមានភ្នែកក៏ក្លាយជាមនុស្សខ្វាក់ ។ ជនអ្នក
ធ្លាក់ក្នុងអំណាចរបស់មាតុគ្រាម ទោះបីមានគុណក៏អស់នូវ
គុណ ទោះបីមានបញ្ញាក៏សាបសូន្យចាកបញ្ញា ជាបុគ្គល
ប្រមាទជាប់ក្នុងអន្ទាក់ មាតុគ្រាមរមែងបំផ្លាញនូវការសិក្សារៀន
សូត្រ តបៈ សីល សច្ចៈ ចាគៈ សតិនិងមតិវិជ្ជារបស់
បុគ្គលអ្នកប្រមាទ ដូចពួកចោរចាំស្កាត់ផ្លូវ រមែងធ្វើយស
កិត្តិយស ធិតិ សេចក្តីក្លាហាន ភាពជាពហុស្សូត ការចេះ
ដឹងរបស់បុគ្គលប្រមាទឲ្យវិនាសទៅដូចភ្លើងធ្វើគំនរឧសឲ្យអស់

ទៅដូច្នោះ ដូច្នេះ ។

ព្រះមហាសត្វកាលពោលយ៉ាងនេះហើយទ្រង់ត្រិះរិះថា ក្មួយយើងក៏ត្រូវចិញ្ចឹម ធីតារបស់យើងក៏ត្រូវចិញ្ចឹមដូច្នេះហើយទើបព្រះរាជទានព្រះរាជធីតាឲ្យដល់ព្រះភាគិនេយ្យនោះឯងដោយសក្ការៈធំ ហើយទ្រង់តាំងព្រះភាគិនេយ្យនោះឲ្យតាំងនៅក្នុងតំណែងឧបរាជ ។ កាលព្រះរាជាដែលជាអំសោយទិវង្គត ឧបរាជនោះក៏តាំងនៅក្នុងរាជសម្បត្តិ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលអផ្សុក តាំងនៅក្នុងសោតាបត្តិផលហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មុទុបាណិជាតក ចប់

## ចុល្លបលោភនជាតក

[ ៣៨៨ ] ( ព្រះរាជបុត្តពោធិសត្វពោលថា ) លោកមក ( តាមអាកាស ) ដោយខ្លួនឯង លើទឹកមិនបែករលកដោយអំណាចនៃឫទ្ធិ លុះទៅប្រឡូកប្រឡំដោយស្រីក៏លិចចុះក្នុងសមុទ្ទធំ ។

[ ៣៨៩ ] ធម្មតាស្រីទាំងឡាយរមែងញុំាងបុរសឲ្យវិលវល់ មានមាយាច្រើន ញុំាងព្រហ្មចរិយធម៌ឲ្យកម្រើករមែងលិចចុះ ( ក្នុងអបាយ ៤ ) បណ្ឌិតបុរសដឹងច្បាស់ហើយគប្បីចៀសវាងអំពីចម្ងាយ ។

[ ៣៩០ ] ស្ត្រីទាំងឡាយនុ៎ះ ចូលទៅគប់រកបុរសណា ដោយសេចក្តីពេញចិត្តក្តី ដោយទ្រព្យក្តីតែងដុតបំផ្លាញបុរសនោះ ( ឲ្យវិនាស ) យ៉ាងឆាប់ដូចភ្លើង ( ដែលឆេះ ) នូវលំនៅរបស់ខ្លួន ។

**ចប់ ចុល្លបលោភនជាតក ទី ៣ ។**

## អដ្ឋកថា

## ចុល្លបលោភនជាតក

[ ៣៨៨-៣៩០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលអផ្សុកដូចគ្នាមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អភិជ្ជមានេ វារិស្មឹ** ដូច្នេះជាដើម ។

បានឮថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះដែលត្រូវនាំមកកាន់ធម្មសភាថា ម្នាលភិក្ខុ បានឮថា អ្នកជាអ្នកអផ្សុកពិតហ្ន៎ កាលភិក្ខុនោះក្រាបទូលថា

ពិតហើយព្រះអង្គទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថាស្រីទាំងនេះសូម្បីសត្វដែលបរិសុទ្ធ ដែលមានក្នុងកាលមុន ក៏ធ្វើឲ្យសៅហ្មងដូចគ្នា កាលភិក្ខុទាំងនោះទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ជាអ្នកមិនមានព្រះឱរសទើបត្រាស់នឹងស្រីស្នំរបស់ព្រះអង្គថា នាងទាំងឡាយចូរធ្វើសេចក្តីប្រាថ្នាដើម្បីឲ្យបានបុត្ត ។ ទើបស្រីស្នំទាំងនោះនាំគ្នាប្រាថ្នាបុត្ត ។ កាលវេលាកន្លងទៅដោយអាការយ៉ាងនេះ ព្រះពោធិសត្វចុតិអំពីព្រហ្មលោកកើតក្នុងព្រះឧទររបស់អគ្គមហេសី ។ ព្រះពោធិសត្វនោះគ្រាន់តែប្រសូតព្រះជនកព្រះជននីឲ្យស្រេពស្រង់ហើយបានប្រទានដល់ស្រីស្នំដើម្បីឲ្យបៅដោះ ។ ព្រះពោធិសត្វនោះត្រូវស្រីស្នំទាំងឡាយឲ្យបៅទឹកដោះ ក៏ទ្រង់ស្រែកយំ ។ លំដាប់នោះព្រះជនកព្រះជននីក៏ប្រទានឲ្យព្រះពោធិសត្វនោះឲ្យដល់ស្រីស្នំដទៃ ។ ក្នុងដៃរបស់មាតុគ្រាមព្រះពោធិសត្វទ្រង់មិននៅស្ងៀមឡើយ ។ លំដាប់នោះព្រះជនកព្រះជននីក៏ប្រទានព្រះពោធិសត្វនោះដល់បុរសម្នាក់ដែលជាបាទមូលិកា ។ គ្រាន់តែបាទមូលិកានោះទទួលប៉ុណ្ណោះ ព្រះពោធិសត្វក៏នៅស្ងៀម ។ តាំងអំពីនោះមកបុរសប៉ុណ្ណោះនាំព្រះរាជកុមារនោះត្រាច់ទៅ កាលបៅដោះបិទមុខនិងទទួរឲ្យបៅ ឬដាក់ដោះក្នុងព្រះឱស្ឋតាមចន្លោះវាំងនន ។ ព្រោះហេតុនោះទើបព្រះពោធិសត្វមានព្រះឈ្មោះថា អនិត្ថិគន្ធកុមារ ។ កាលព្រះរាជកុមារចេះរត់លេងទៅមក បុគ្គលណាមួយ មិនអាចបង្ហាញមាតុគ្រាម

ឲ្យឃើញ ។ ដោយហេតុនោះទើបព្រះរាជាឲ្យសាងស្ពានទីប្រថាប់គង់ជាដើម ទុកក្នុងទីទទេនិងឲ្យសាងឈានាគារទុកខាងក្រៅ ដើម្បីព្រះរាជកុមារនោះ ។ ក្នុងវេលាព្រះរាជកុមារនោះមានព្រះជន្ម ១៦ វស្សា ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិនមានឱរសដទៃទៀត ចំណែកព្រះរាជកុមារនេះមិនបរិភោគកាមសុម្បីរាជសម្បត្តិក៏មិនប្រាថ្នា អញបានព្រះរាជឱរសលំបាកពិតហ្ន៎ ។

កាលនោះមានស្រីរបាំវ័យក្មេងម្នាក់ ឈ្លាសក្នុងការរាំ ការច្រៀងនិងការប្រគំអាចលួងលោមបុរសឲ្យធ្លាក់នៅក្នុងអំណាចរបស់ខ្លួន បានចូលទៅគាល់ព្រះរាជាហើយក្រាបទូលថា បពិត្រមហារាជ ព្រះអង្គទ្រង់ព្រះតម្រិះរឿងអ្វី ។ ចំណែកព្រះរាជាទ្រង់ត្រាស់ប្រាប់ហេតុនោះ ។ ស្រីរបាំនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន រឿងនោះលើកទុកសិនចុះ ខ្ញុំម្ចាស់នឹងលួងលោមព្រះរាជកុមារនោះឲ្យស្គាល់កាមរស ។ ព្រះរាជាត្រាស់ថា បើនាងអាចលួងលោមអនិត្ថិគន្ធកុមារដែលជាឱរសរបស់យើងបាន សោតព្រះរាជកុមារនោះនឹងជាព្រះរាជា នាងនឹងជាអគ្គមហេសី ។ ស្រីរបាំក្រាបទូលថា បពិត្រព្រះអង្គការលួងលោមជាភារៈរបស់ខ្ញុំម្ចាស់ ព្រះអង្គទ្រង់កុំបរិវិតក្កៈឡើយ ។ ហើយចូលទៅរកអ្នកយាមពោលថា ក្នុងវេលាជិតភ្លឺខ្ញុំនឹងមកឈរត្រង់ក្រឡាបន្ទំរបស់ព្រះអយ្យបុត្តខាងក្រៅឈានាគាហើយនឹងច្រៀង បើព្រះរាជកុមារទ្រង់ខ្ញាល់ពួកអ្នកគប្បីប្រាប់ខ្ញុំ ខ្ញុំនឹងគេចចេញទៅ បើទ្រង់ស្តាប់ពួកអ្នកចូរប្រាប់ដល់ខ្ញុំដូចគ្នា ។ ក្នាក់ងារអ្នករក្សាទាំងឡាយនាំគ្នាទទួលពាក្យនាងថា សាធុ ។ ចំណែកស្រីរបាំនោះក្នុងវេលាទៀបភ្លឺ បានទៅឈរត្រង់ប្រទេសនោះហើយច្រៀង

ជាមួយនឹងសំឡេងពិណ ដេញពិណឲ្យស៊ីជាមួយនឹងសំឡេងច្រៀងដោយសំឡេងដ៏ពីរោះ ។ ព្រះរាជកុមារទ្រង់ផ្ទំស្តាប់ ។ ស្អែកឡើងព្រះរាជកុមារទ្រង់ត្រាស់ឲ្យនាងឈរច្រៀងក្នុងទីជិត ស្អែកឡើង ត្រាស់ឲ្យឈរច្រៀងក្នុងឈាននាគា ស្អែកឡើង ត្រាស់ឲ្យឈរច្រៀងក្នុងទីជិតព្រះអង្គ ដោយវិធីយ៉ាងនេះព្រះអង្គទ្រង់ធ្វើតណ្ហាឲ្យកើតឡើងដោយលំដាប់រហូតដល់សេពលោកធម៌បានដឹងកាមរសហើយមានព្រះវាចាថា ឈ្មោះថា មាតុគ្រាម អញមិនឲ្យដល់បុរសដទៃ កាន់ដាវយាងចុះកាន់ផ្លូវដេញតាមបុរសទាំងឡាយ ។

លំដាប់នោះព្រះរាជាត្រាស់ឲ្យចាប់ព្រះរាជកុមារនោះហើយឲ្យនាំចេញទៅចាកព្រះនគរ មួយអន្លើដោយកុមារិកានោះ ។ ចំណែកព្រះរាជកុមារនិងព្រះជាយាទាំង ២ ស្តេចចូលទៅកាន់ដងព្រៃនៅខាងក្រោមខ្សែទឹកស្ទឹងគង្គាសាងអាស្រមនៅក្នុងចន្លោះស្ទឹងគង្គានិងមហាសមុទ្រ ដោយមានស្ទឹងគង្គានៅម្ខាងនិងមហាសមុទ្រនៅម្ខាងសម្រេចការនៅក្នុងទីនោះ ។ ចំណែកកុមារិកាអង្គុយនៅក្នុងបណ្ណសាលាកំពុងស្ងោរមើមឈើមានមើមដំឡូងជាដើម ។ ព្រះពោធិ-សត្វនាំយកផលាផលទាំងឡាយមកអំពីព្រៃ ។ ថ្ងៃមួយកាលព្រះពោធិសត្វនោះទៅដើម្បីត្រូវការផ្លែនិងឫសឈើ មានតាបសមួយរូបអាស្រ័យនៅត្រង់កោះក្នុងមហាសមុទ្រហោះមកតាមអាកាសក្នុងវេលាភិក្ខាចារ ឃើញផ្សែងនោះទើបចុះមកកាន់អាស្រម ។ លំដាប់នោះកុមារិកានោះនិមន្តតាបសនោះឲ្យគង់ដោយពោលថា សូមលោកម្ចាស់គង់រង់ចាំទម្រាំខ្ញុំស្ងោរឆ្អិនហើយលួងលោមដោយមាយារបស់ស្ត្រីឲ្យវិនាសចាកឈាន ធ្វើព្រហ្មចារ្យរបស់តាបសនោះឲ្យអន្តរធាន

ទៅ ។ តាបសនោះដូចជាក្អែកបាក់ស្លាបមិនអាចលះកុមារិកានោះទៅបាននៅក្នុងទីនោះឯងអស់មួយថ្ងៃ ក្នុងវេលាល្ងាចឃើញព្រះពោធិសត្វមកទើបប្រញាប់គេចទៅបែរមុខទៅកាន់សមុទ្ទ ។ លំដាប់នោះព្រះពោធិសត្វទើបដកដាវដេញតាមតាបសនោះទៅដោយយល់ថា បុគ្គលនេះជាសត្រូវរបស់អញ ។ តាបសសម្តែងអាការនឹងហោះឡើងក្នុងអកាស ទើបធ្លាក់ចុះទៅក្នុងសមុទ្ទ ។ ព្រះ-ពោធិសត្វគិតថា តាបសនេះនឹងមកតាមអាកាសព្រោះឈានវិនាសទើបធ្លាក់ចុះក្នុងសមុទ្ទ ឥឡូវនេះអញគួរជាទីពឹងអាស្រ័យរបស់តាបសនេះ ដូច្នេះហើយទើបឈរត្រង់ច្រាំងសមុទ្ទពោលគាថាទាំងនេះថា

លោកមក ( តាមអាកាស ) ដោយខ្លួនឯង លើទឹក
មិនបែករលកដោយអំណាចនៃឫទ្ធិ លុះទៅប្រឡូកប្រឡំដោយ
ស្រីក៏លិចចុះក្នុងសមុទ្ទធំ ។

ធម្មតាស្រីទាំងឡាយ រមែងញុំាងបុរសឲ្យវិលវល់ មាន
មាយាច្រើន ញុំាងព្រហ្មចរិយធម៌ឲ្យកម្រើក រមែងលិចចុះ
( ក្នុងអបាយ ៤ ) បណ្ឌិតបុរសដឹងច្បាស់ហើយគប្បីចៀស
វាងអំពីចម្ងាយ ។

ស្ត្រីទាំងឡាយនុ៎ះ ចូលទៅគប់រកបុរសណា ដោយសេចក្តី
ពេញចិត្តក្តី ដោយទ្រព្យក្តីតែងដុតបំផ្លាញបុរសនោះ ( ឲ្យ
វិនាស ) យ៉ាងឆាប់ដូចភ្លើង ( ដែលឆេះ ) នូវលំនៅរបស់
ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិជ្ជមានេ វារិស្មឹ** សេចក្ដីថា កាលទឹកនេះមិនកម្រើក គឺមិនបែករលកតាបសមិនពាល់ត្រូវទឹក មកដោយឫទ្ធិតាមអាកាសនោះឯង ។ បទថា **មិស្សីភាវិត្ថិយា** បានដល់ ភាវៈដែលប្រឡូកប្រឡំជាមួយស្រី ដោយអំណាចការសេពលោកធម៌ ។ បទថា **អាវដ្ដនី មហាមយា** សេចក្ដីថា ធម្មតាស្ត្រីទាំងនេះឈ្មោះថា ធ្វើបុរសឲ្យវិលវល់ ព្រោះឲ្យវិលវល់ដោយកាមគុណ ឈ្មោះថា **មហាមយា** ព្រោះប្រកបដោយមាយាស្ត្រីមិនមានទីបំផុត ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមហាហំសជាតក ) ថា

> មួយទៀតស្ត្រីទាំងនេះមានមាយាដូចជាថ្ងៃបណ្ដើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះមានអធ្យាស្រ័យដ៏រឹងរូស ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្ដីស្លាប់ ជាគុហាសម្រាប់នៅ ( របស់មច្ចុរាជ ) បុរសណាទុកចិត្តក្នុងស្ត្រីទាំងនោះ បណ្ដាបុរសទាំងឡាយ បុរសនោះឈ្មោះថា បុរសថោកទាប ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហ្មចរិយវិកោបនា** សេចក្ដីថា ញុំាងព្រហ្មចរិយៈ គឺមេថុនវិរតិព្រហ្មចរិយៈឲ្យកម្រើក ។ បទថា **សីទន្តិ** សេចក្ដីថា ធម្មតាស្ត្រីទាំងនេះឈ្មោះថា រមែងលិចចុះក្នុងអបាយទាំងឡាយព្រោះធ្វើព្រហ្មចរិយៈរបស់ពួកឥសីឲ្យកម្រើក ។ បទដ៏សេស គប្បីប្រកបដោយន័យមុននោះឯង ។

ចំណែកតាបស កាលបានស្តាប់ពាក្យរបស់ព្រះពោធិសត្វយ៉ាងនេះហើយ ឈរក្នុងកណ្តាលសមុទ្រនោះឯង ធ្វើឈានដែលវិនាសឲ្យកើតឡើងវិញហើយ ទៅកាន់លំនៅរបស់ខ្លួនតាមអាកាស ។ ព្រះពោធិសត្វគិតថា តាបសនេះជាអ្នកអប់រំមកហើយយ៉ាងនេះទៅតាមអាកាសដូចប៉ុយរកា ឯអាត្មាអញក៏គួរធ្វើឈានឲ្យកើត ហើយទៅតាមអាកាសដូចតាបសនេះ ។ ព្រះពោធិសត្វនោះកាលគិតហើយក៏ទៅកាន់អាស្រម នាំស្ត្រីនោះទៅកាន់ដែនដីមនុស្សហើយបញ្ជូនទៅដោយពាក្យថា នាងចូរទៅចុះ ស្រេចហើយក៏យាងត្រឡប់ចូលកាន់ព្រៃសាងអាស្រមក្នុងភូមិភាគដែលគួរត្រេកអរហើយបួសជាឥសី ធ្វើកសិណបរិកម្មញុំាងអភិញ្ញា និងសមាបត្តិឲ្យកើតឡើង ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុអផ្សុក បានតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា អនិត្ថិគន្ធកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចុល្លបលោភនជាតក ចប់

## មហាបនាទជាតក

[ ៣៩១ ] ( ព្រះសាស្តាត្រាស់ថា ) ព្រះរាជាអង្គនោះទ្រង់ព្រះនាម បនាទៈ មានប្រាសាទមាស មានទទឹងប្រវែងកិរិយាធ្លាក់ចុះនៃកូនសរ ១៦ ( កន្លះយោជន៍ ) ( អ្នកប្រាជ្ញទាំងឡាយ ) ពោលថា ប្រាសាទនោះកំពស់ ១ ពាន់តំណនៃកូនសរ ( ២៥ យោជន៍ ) ។

[ ៣៩២ ] ប្រាសាទនោះកំពស់ ១ ពាន់តំណនៃកូនសរ មានជាន់ ៧ បរិបូណ៌ដោយទង់ ព័ន្ធព័ទ្ធហើយដោយកែវមណីមានពណ៌ខៀវ ពួករបាំ ៦ ពាន់ចែកជា ៧ ចំណែក បានរាំលើប្រាសាទនោះ ( គ្រប់ៗថ្នាក់ ) ។

[ ៣៩៣ ] ម្នាលភទ្ទជិ អ្នកពោលហើយយ៉ាងណា ប្រាសាទនោះមានហើយក្នុងកាលនោះយ៉ាងនោះ តថាគតកើតជាព្រះឥន្ទ្រ ជាវេយ្យាវច្ចករបស់អ្នក ។

### ចប់ មហាបនាទជាតកទី ៤ ។

## អដ្ឋកថា

## មហាបនាទជាតក

[ ៣៩១-៣៩៣ ] ព្រះសាស្តាកាលគង់ត្រង់ប្រាំងស្ទឹងគង្គា ទ្រង់ប្រារព្ធអានុភាពរបស់ព្រះភទ្ទជិត្ថេរៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **បនាទោ នាមសោ រាជា** ដូច្នេះជាដើម ។

សម័យមួយ ព្រះសាស្តាទ្រង់ចាំវស្សានៅក្នុងនគរសាវត្ថី ទ្រង់ព្រះតម្រិះ

ជានឹងសង្គ្រោះភទ្ទជិកុមារ ដូច្នេះហើយចោមរោមហើយដោយពួកភិក្ខុសង្ឃ យាងចារិកដល់ភទ្ទិយនគរ គង់នៅក្នុងជាតិយាវ័នអស់ ៣ ខែ ទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់ភទ្ទជិកុមារ ។ ភទ្ទជិកុមារនោះមានយសច្រើនជាបុត្តតែមួយរបស់ភទ្ទិយសេដ្ឋីដែលមានទ្រព្យសម្បត្តិប្រមាណ ៨០ កោដិ ។ ភទ្ទជិកុមារនោះមានប្រាសាទ ៣ ខ្នង សមគួរដល់រដូវទាំង ៣ ។ ភទ្ទជិកុមារនៅក្នុងប្រាសាទនីមួយៗ ៤ ខែ កាលនៅក្នុងប្រាសាទមួយខ្នងហើយក៏ហែហមដោយស្រីរបាំទៅកាន់ប្រាសាទមួយខ្នងទៀតដោយយសធំ ។ ខណៈនោះអ្នកនគរទាំងអស់ក៏ភ្ញាក់ផ្អើលថា ពួកយើងនឹងមើលយសរបស់ភទ្ទជិកុមារ ចងចក្កនិងចក្កត្រួតលើគ្នា ចងគ្រែនិងគ្រែត្រួតលើគ្នាក្នុងរវាងប្រាសាទ ។ ព្រះសាស្តាគង់អស់ ៣ ខែ ត្រាស់ប្រាប់អ្នកនគរថា តថាគតលាទៅ ។ អ្នកនគរក្រាបទូលនិមន្តព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ស្អែកនេះសឹមទ្រង់យាងទៅចុះ ។ ក្នុងថ្ងៃទី ២ ត្រៀមមហាទានដើម្បីភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានសាងមណ្ឌបថ្វាយទានត្រង់កណ្តាលនគរ រៀបចំក្រាលអាសនៈ ហើយក្រាបទូលឲ្យទ្រង់ជ្រាបដល់កាលវេលា ។ ព្រះសាស្តា ចោមរោមដោយភិក្ខុសង្ឃយាងទៅគង់នៅក្នុងមណ្ឌបនោះ ។ មនុស្សទាំងឡាយបានថ្វាយមហាទាន ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ផ្តើមអនុមោទនាដោយព្រះសូរសៀងដ៏ពីរោះ ។ ខណៈនោះភទ្ទជិកុមារចេញអំពីប្រាសាទមួយខ្នងទៅកាន់ប្រាសាទមួយខ្នងទៀត ថ្ងៃនោះ មិនមានបុគ្គលណាមួយទៅមើលសម្បត្តិរបស់ភទ្ទជិកុមារនោះឡើយ មានតែមនុស្សរបស់ខ្លួនប៉ុណ្ណោះហែហមទៅ ។ ភទ្ទជិកុមារក៏សួរ

មនុស្សទាំងឡាយថា ក្នុងវេលាដទៃកាលយើងចេញអំពីប្រាសាទមួយខ្នងទៅកាន់ប្រាសាទមួយខ្នងទៀត អ្នកនគរទាំងអស់ភ្ញាក់ផ្អើលបងចក្កតម្រួតលើចក្កចង់គ្រែតម្រួតលើគ្រែ តែថ្ងៃនេះក្រៅអំពីមនុស្សទាំងឡាយរបស់យើងមិនមានបុគ្គលណាមួយដទៃឡើយ ព្រោះហេតុអ្វីហ្ន៎ ពួកបរិវារពោលថា បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធយាងចូលទៅអាស្រ័យនៅក្នុងនគរនេះ ទ្រង់គង់នៅអស់ ៣ ខែ ថ្ងៃនេះទ្រង់យាងទៅទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់សម្តែងធម៌ដល់មហាជន អ្នកនគរទាំងអស់នាំគ្នាស្តាប់ធម្មកថារបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ។ កទ្ទជិកុមារនោះពោលថា បើយ៉ាងនោះអ្នកទាំងឡាយចូរមកសូម្បីយើងក៏នឹងស្តាប់ធម៌ ។ ហើយប្រដាប់ដោយអាភរណៈទាំងពួងចូលទៅមួយអន្លើដោយបរិវារធំ ឈរស្តាប់ធម្មកថាខាងចុងបរិស័ទ ញុំាងកិលេសទាំងឡាយឲ្យអស់ទៅ សម្រេចអរហត្តដែលជាផលដ៏ប្រសើរ ។ ព្រះសាស្តាត្រាស់ហៅកទ្ទិយសេដ្ឋីមកហើយត្រាស់ថា មហាសេដ្ឋី បុត្តរបស់អ្នកប្រដាប់តាក់តែងហើយស្តាប់ធម្មកថាបានតាំងនៅក្នុងអរហត្ត ព្រោះហេតុនោះ ថ្ងៃនេះបុត្តរបស់អ្នកគួរបព្វជាឬគួរបរិនិព្វាន កទ្ទិយសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កិច្ចបរិនិព្វាននៃបុត្តរបស់ខ្ញុំព្រះអង្គរមែងមិនមាន សូមទ្រង់ឲ្យបុត្តរបស់ខ្ញុំព្រះអង្គនោះបព្វជាចុះ កាលឲ្យបព្វជាសូមទ្រង់នាំបុត្តរបស់ខ្ញុំព្រះអង្គនោះចូលទៅកាន់ផ្ទះរបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះចុះ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយនាំកុលបុត្តយាងទៅកាន់វិហារឲ្យបព្វជាឧបសម្បទា ។ មាតាបិតារបស់ព្រះកទ្ទជិនោះធ្វើមហាសក្ការៈ ៧ ថ្ងៃ ។ ព្រះសាស្តាគង់នៅ

ក្នុងទីនោះអស់ ៧ ថ្ងៃ ទ្រង់នាំកុលបុត្តត្រាច់ចារិកទៅដល់កោដិគាម ។ មនុស្សអ្នកកោដិគាមបានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ក្នុងវេលាស្រេចភត្តកិច្ចព្រះសាស្ដាទ្រង់ផ្ដើមអនុមោទនា ។ ក្នុងវេលាដែលទ្រង់ធ្វើអនុមោទនា កុលបុត្តទៅក្រៅស្រុកគិតថា ក្នុងវេលាព្រះសាស្ដាយាងមកប៉ុណ្ណោះ អាត្មាអញនឹងក្រោកឡើង ដូច្នេះហើយទើបអង្គុយចូលឈានត្រង់គល់ឈើមួយកន្លែងក្បែរឆ្នេរស្ទឹងគង្គា ។ កាលព្រះថេរៈដែលចាស់ៗនិមន្តមកក៏មិនក្រោកឡើងក្នុងវេលាព្រះសាស្ដាយាងមកប៉ុណ្ណោះ ទើបក្រោកឡើង ។ ពួកភិក្ខុបុថុជ្ជននាំគ្នាក្រោធថា ភទ្ទជិនេះធ្វើឫកដូចជាបួសមុន កាលព្រះមហាថេរៈនិមន្តមកសូម្បីឃើញក៏មិនក្រោកឡើង ។ អ្នកកោដិគាមនាំគ្នាចងទូកទាំងឡាយភ្ជាប់គ្នា ។ ព្រះសាស្ដាទ្រង់ប្រថាប់ឈរក្នុងទូកធំត្រាស់សួរថា ភទ្ទជិនៅឯណា ភិក្ខុទាំងឡាយក្រាបទូលថា ភទ្ទជិនេះនៅទីនេះឯង ។ ព្រះសាស្ដាត្រាស់ថា មកចុះភទ្ទជិ ចូរឡើងកាន់ទូកជាមួយតថាគត ។ ព្រះថេរៈបានហោះទៅឈរក្នុងទូកជាមួយព្រះអង្គ ។ ក្នុងវេលាដែលទូកទៅដល់កណ្ដាលស្ទឹងគង្គា ព្រះសាស្ដាត្រាស់ថា ម្នាលភទ្ទជិប្រាសាទដែលអ្នកធ្លាប់គ្រប់គ្រងក្នុងកាលនៅជាព្រះបាទមហាបនាទនៅឯណា ព្រះភទ្ទជិក្រាបទូលថា បពិត្រព្រះអង្គលិចក្នុងទីនេះ ។ ពួកភិក្ខុបុថុជ្ជននាំគ្នាពោលថា ភទ្ទជិថេរៈព្យាករអរហត្ត ។ ព្រះសាស្ដាត្រាស់ថា ម្នាលភទ្ទជិ បើយ៉ាងនោះចូរអ្នកកាត់សេចក្ដីសង្ស័យរបស់សព្រហ្មចារីទាំងឡាយ ។ ខណៈនោះព្រះថេរៈថ្វាយបង្គំព្រះសាស្ដាហើយ ទៅដោយកម្លាំងឫទ្ធិយកមេជើងថ្មៀបកំពូលប្រាសាទលើក

ប្រាសាទដែលមានកម្ពស់ ២៥ យោជន៍ឡើងហើយហោះទៅក្នុងអាកាស ។ ព្រះថេរៈហោះឡើងហើយប្រាកដដល់ជនទាំងឡាយ ដែលឈរនៅខាងក្រោមប្រាសាទហាក់បីដូចប្រាសាទធ្លាក់សង្កត់ ។ ព្រះថេរៈនោះលើកប្រាសាទឡើងអំពីទឹក ១ យោជន៍ ២ យោជន៍ ៣ យោជន៍ រហូតដល់ទៅ ២០ យោជន៍ ។ លំដាប់នោះញាតិទាំងឡាយក្នុងភពមុនរបស់ព្រះថេរៈកើតជាត្រី អណ្តើក នាគ និងកង្កែបនៅក្នុងប្រាសាទនោះឯង ព្រោះសេចក្តីលោភក្នុងប្រាសាទ កាលប្រាសាទអណ្តែតឡើងក៏ធ្លាក់ចុះទៅក្នុងទឹក ។ ព្រះសាស្តាទតឃើញសត្វទាំងនោះធ្លាក់ចុះទៅទើបត្រាស់ថា ម្នាលកទ្ទុជិ ពួកញាតិរបស់អ្នកលំបាក ។ ព្រះថេរៈបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាទើបលែងប្រាសាទ ។ ប្រាសាទក៏ត្រឡប់តាំងនៅដូចដើមនោះឯង ។ ចំណែកព្រះសាស្តាយាងឡើងអំពីស្ទឹងគង្គា ។ លំដាប់នោះជនទាំងឡាយនាំគ្នាក្រាលអាសនៈថ្វាយ ព្រះសាស្តាគង់នៅត្រង់ច្រាំងស្ទឹងគង្គានោះឯង ។ ព្រះសាស្តាគង់បញ្ចេញព្រះរស្មីត្រង់បវរពុទ្ធាសនៈដែលគេក្រាលថ្វាយដូចព្រះអាទិត្យទើបរះដូច្នោះ ។ លំដាប់នោះភិក្ខុទាំងឡាយក្រាបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ប្រាសាទនេះព្រះភទ្ទជិត្ថេរៈគ្រប់គ្រងក្នុងកាលណា ព្រះសាស្តាត្រាស់ថា ក្នុងកាលជាព្រះបាទមហាបនាទ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងនគរមិថិលាដែនវិទេហរដ្ឋ មានព្រះរាជាព្រះនាមថា សុរុចិ ។ ព្រះឱរសរបស់ព្រះអង្គក៏មានព្រះនាមថា សុរុចិ ដូចគ្នា ។ តែព្រះ

ឱរសរបស់ព្រះបាទសុរុចិនោះមានព្រះនាមថា មហាបនាទ ។ ព្រះរាជាទាំង ៣ អង្គនោះបានគ្រប់គ្រងប្រាសាទនេះ ។ បុព្វកម្មដែលនឹងបានគ្រប់គ្រងប្រាសាទនោះយ៉ាងនេះថា ជន ២ នាក់គឺ បិតានិងបុត្តបានសាងបណ្ណសាលាជាលំនៅរបស់ព្រះបច្ចេកពុទ្ធ ដោយដើមបបុសនិងដើមល្វា រឿងអតីតទាំងអស់ក្នុងជាតកនេះនឹងមានច្បាស់ក្នុងសុរុចិជាតកក្នុងបកិណ្ណកនិបាត ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ដឹងក្រៃលែងហើយទើបត្រាស់ព្រះគាថាទាំងនេះថា

ព្រះរាជាអង្គនោះទ្រង់ព្រះនាមបនាទៈ មានប្រាសាទមាស
មានទទឹងប្រវែងកិរិយាធ្លាក់ចុះនៃកូនសរ ១៦ ( កន្លះយោជន៍ )
( អ្នកប្រាជ្ញទាំងឡាយ ) ពោលថា ប្រាសាទនោះកំពស់ ១
ពាន់តំណនៃកូនសរ ( ២៥ យោជន៍ ) ។

ប្រាសាទនោះកំពស់ ១ ពាន់តំណនៃកូនសរ មានជាន់ ៧
បរិបូណ៌ដោយទង់ ព័ទ្ធព័ទ្ធហើយដោយកែវមណីមានពណ៌ខៀវ
ពួករបាំ ៦ ពាន់ចែកជា ៧ ចំណែកបានរាំលើប្រាសាទនោះ
( គ្រប់ៗថ្នាក់ ) ។

ម្នាលភទ្ទជិ អ្នកពោលហើយយ៉ាងណា ប្រាសាទនោះមាន
ហើយ ក្នុងកាលនោះយ៉ាងនោះ តថាគតកើតជាព្រះឥន្ទ្រ
ជាវេយ្យាវច្ចករបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យូបោ** បានដល់ ប្រាសាទ ។ បទថា

**តិរិយំ សោឡសុព្ភេធោ** សេចក្តីថា ដោយទទឹងប្រវែង ១៦ កូនសរ ធ្លាក់ ។ បទថា **ឧច្ចមាហុ សហស្សធា** សេចក្តីថា ដោយកម្ពស់លោក ពោលដល់កម្ពស់ប្រមាណរយៈស្ទុះទៅនៃកូនសរ ១០០០ គឺកម្ពស់ប្រមាណ ២៥ យោជន៍ ដោយការរាប់រយៈស្ទុះទៅនៃកូនសរ ១០០០ ចំណែកទទឹង របស់ប្រាសាទនោះប្រមាណកន្លះយោជន៍ ។ បទថា **សហស្សកណ្ឌា សតគេណ្ឌុ** សេចក្តីថា ប្រាសាទកម្ពស់ ១០០០ ជួរ កូនសរធ្លាក់នោះមាន ៧ ជាន់ ។ បទថា **ធជាលុ** បានដល់ ព្រមដោយទង់ ។ បទថា **ហរិតាមយោ** បានដល់ រំលេចដោយកែវមណីខៀវ ។ ចំណែកក្នុងអដ្ឋកថា បាឋៈថា **សហាលុហរិតាមយោ** ដូច្នេះក៏មាន ។ អធិប្បាយសេចក្តីនៃបាឋៈ នោះថា ប្រកបដោយទ្វារនិងបង្អួចដែលសម្រេចហើយដោយកែវមណីខៀវ ។ បានឮថា បទថា **សហ** ជាឈ្មោះរបស់សន្លុះទ្វារ និងបង្អួច ។ បទថា **គន្ធព្វា** បានដល់ ស្រីរបាំ ។ បទថា **ឆ សហស្សានិ សត្តធា** សេចក្តីថា ស្រីរបាំ ៦០០០ នាក់ បែងចែកជា ៧ ពួក រាំនៅក្នុងទីទាំង ៧ នៃ ប្រាសាទនោះដើម្បីចម្រើននូវត្រេកអរដល់ព្រះរាជា ។ អ្នករបាំទាំងនោះសូម្បី រាំនិងច្រៀងយ៉ាងនេះក៏មិនអាចឲ្យព្រះរាជាត្រេកអរ ។ គ្រានោះសក្កទេវរាជ ទ្រង់បញ្ជូនអ្នករបាំរបស់ទេវតាឲ្យទៅសម្តែងការលេងមហោស្រព ។ កាល នោះព្រះបាទមហាបនាទៈទ្រង់ត្រេកអរ ។ បទថា **យថា ភាសសិ ភទ្ទជិ** សេចក្តីថា កាលព្រះសាស្តាត្រាស់ថា ម្នាលភទ្ទជិ ប្រាសាទដែលអ្នកនៅ គ្រប់គ្រងក្នុងកាលជាព្រះបាទមហាបនាទៈនៅទីណា ព្រះភទ្ទជិត្ថេរៈក្រាបទូល

ថា បពិត្រព្រះអង្គ លិចត្រង់ទីនេះ បានពោលកាពដែលប្រាសាទនោះកើតឡើងហើយដើម្បីប្រយោជន៍ដល់ខ្លួននិងកាពដែលខ្លួនជាព្រះបាទ មហាបនាទៈក្នុងកាលនោះ ។ ព្រះសាស្តាទ្រង់កាន់យកពាក្យពោលនោះទើបត្រាស់ថា ម្នាលភទ្ទជិ អ្នកពោលដោយប្រការណា ។ ដោយបទថា **ឯវមេតំ តទា អាសិ** នេះ ព្រះសាស្តាត្រាស់ថា ម្នាលភទ្ទជិ ក្នុងកាលនោះសេចក្តីទាំងនោះបានមានហើយដូចសេចក្តីដែលអ្នកបានពោលហើយក្នុងកាលឥឡូវនេះ ក្នុងកាលនោះតថាគតបានជាសក្កទេវរាជជាស្តេចនៃទេវតា ជាវេយ្យាវច្ចៈរបស់អ្នក ។ ខណៈនោះភិក្ខុ បុថុជ្ជនទាំងឡាយបានជាអ្នកអស់សេចក្តីសង្ស័យ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទមហាបនាទៈក្នុងកាលនោះបានមកជាព្រះភទ្ទជិក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហាបនាទជាតក ចប់

# ខុរប្បជាតក

[ ៣៩៤ ] ( កូនរបស់ឈ្មួញរទេះពោលថា ) អ្នកឃើញនូវព្រួញដែលពួកចោរបាញ់ហើយដោយកម្លាំងនៃធ្នូផង នូវព្រះខាន់សំលៀងដោយប្រេងដ៏មុតដែលពួកចោរកាន់ហើយផង កាលសេចក្ដីស្លាប់ដែលគួរខ្លាចនោះចូលមកតាំងនៅចំពោះមុខហើយ ហេតុអ្វីក៏អ្នកមិនមានសេចក្ដីតក់ស្លុតសោះ ។

[ ៣៩៥ ] ( ពោធិសត្វជាមេអ្នករក្សាជង់ព្រៃពោលថា ) ខ្ញុំឃើញនូវព្រួញដែលបាញ់ហើយដោយកម្លាំងនៃធ្នូ នូវព្រះខាន់សំលៀងដោយប្រេងដ៏មុតដែលពួកចោរកាន់ហើយ កាលសេចក្ដីស្លាប់ដែលគួរខ្លាចនោះចូលមកតាំងនៅចំពោះមុខ ខ្ញុំក៏ត្រឡប់បានសេចក្ដីត្រេកអរច្រើនដ៏លើសលុប ។

[ ៣៩៦ ] ខ្ញុំនោះមានសេចក្ដីត្រេកអរបានគ្របសង្កត់នូវពួកសត្រូវ ( ព្រោះថា ) ខ្ញុំបានលះបង់ជីវិតមុនហើយព្រោះថា បុគ្គលអ្នកក្លៀវក្លាកាលធ្វើសេចក្ដីអាល័យក្នុងជីវិត គប្បីធ្វើនូវកិច្ចរបស់អ្នកក្លៀវក្លា ក្នុងកាលណាៗ មិនបានទេ ។

**ចប់ ខុរប្បជាតកទី ៥ ។**

## អដ្ឋកថា

## ខុរប្បជាតក

[ ៣៩៤-៣៩៦ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុលះសេចក្ដីព្យាយាមមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ទិស្វា ខុរប្បេ** ដូច្នេះជាដើម ។

សេចក្ដីថា ព្រះសាស្ដាត្រាស់ចំពោះភិក្ខុនោះដែលត្រូវនាំមកក្នុងធម្មសភាថា បានឮថា អ្នកលះសេចក្ដីព្យាយាមពិតឬ កាលភិក្ខុទាំងនោះក្រាបទូលថា ពិតហើយព្រះអង្គ ទើបព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខយ៉ាងនេះព្រោះហេតុអ្វីទើបលះសេចក្ដីព្យាយាមចេញ បុរាណកបណ្ឌិតទាំងឡាយរមែងធ្វើសេចក្ដីព្យាយាមសូម្បីក្នុងឋានៈមិនមែនជាគ្រឿងនាំចេញចាកទុក្ខ ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នករក្សាព្រៃមួយកន្លែង លុះចម្រើនវ័យមានបុរស ៥០០ នាក់ជាបរិវារ ជាប្រធានរបស់ជនទាំងពួងក្នុងបណ្ដាអ្នករក្សាព្រៃសម្រេចការនៅក្នុងស្រុកមួយកន្លែងត្រង់មាត់ព្រៃ ។ ប្រធានអ្នករក្សាព្រៃនោះទទួលយកថ្លៃឈ្នួលនាំពួកមនុស្សឲ្យឆ្លងព្រៃ ។ ថ្ងៃមួយកូនឈ្មួញអ្នកនគរពារាណសីមួយអន្លើដោយរទេះ ៥០០ មកដល់ស្រុកនោះហៅប្រធានដែលរក្សាព្រៃនោះមកពោលថា នែសម្លាញ់ ចូរអ្នកទទួលទ្រព្យ ១០០០ ហើយនាំយើងឲ្យឆ្លងផុតព្រៃ ។ ប្រធានអ្នករក្សាព្រៃទទួលពាក្យ ហើយកាន់

យកទ្រព្យ ១០០០ អំពីដៃរបស់ឈ្មួញនោះ កាលទទួលឈ្នួលយ៉ាងនេះ នឹងត្រូវលះជីវិតដើម្បីឈ្មួញនោះ ។ គាត់នាំកូនឈ្មួញនោះចូលព្រៃ ។ ពួកចោរ ៥០០ ក៏ក្រោកឡើងកណ្តាលព្រៃ ។ បុរសដ៏សេសគ្រាន់តែឃើញពួកចោរទាំងនោះនាំគ្នាដេកផ្កាប់មុខ ។ ប្រធានអ្នករក្សាព្រៃម្នាក់ប៉ុណ្ណោះពន្លឺសីហនាទស្រែកសន្ធាប់រត់ចូលប្រហារឲ្យពួកចោរ ៥០០ ខ្ចាត់ខ្ចាយទៅ ឲ្យឈ្មួញឆ្លងផុតកន្តារដោយសួស្តី ។ ចំណែកកូនឈ្មួញឲ្យពួករទេះស្នាក់នៅក្នុងទីឆ្ងាយអំពីផ្លូវកន្តារហើយ ឲ្យប្រធានអ្នករក្សាព្រៃបរិភោគភោជនៈមានរសដ៏ប្រសើរផ្សេងៗ ចំណែកខ្លួនឯងបរិភោគអាហារព្រឹកហើយ អង្គុយសប្បាយចរចាជាមួយប្រធានដែលរក្សាព្រៃនោះកាលសួរថា សម្លាញ់ ក្នុងវេលាដែលពួកចោរកាចសាហាវបែបនោះ ចាប់អាវុធស្ទុះចូលមក ព្រោះហេតុអ្វីសូម្បីតែសេចក្តីតក់ស្លុតក៏មិនកើតឡើងទើបពោលគាថាទី ១ ថា

អ្នកឃើញនូវព្រួញ ដែលពួកចោរបាញ់ហើយដោយកម្លាំងនៃធ្នូផង នូវព្រះខាន់សំលៀងដោយប្រេងដ៏មុតដែលពួកចោរកាន់ហើយផង កាលសេចក្តីស្លាប់ដែលគួរខ្លាចនោះ ចូលមកតាំងនៅចំពោះមុខហើយ ហេតុអ្វីក៏អ្នកមិនមានសេចក្តីតក់ស្លុតសោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធនុវេគនុន្នេ** បានដល់ បាញ់ទៅដោយកម្លាំងធ្នូ ។ បទថា **ខគ្គេ គហិតេ** បានដល់ កាន់ដាវដងក្លុកយ៉ាងខ្ជាប់ ។ បទថា **មរណេ វិរុឡ្ហេ** បានដល់ កាលសេចក្តីស្លាប់ប្រាកដ ។ បទថា

**កស្មា នុ តេ ឆាហុ** សេចក្តីថា ព្រោះហេតុអ្វីទើបសម្លាញ់មិនមានសេចក្តីតក់ស្លុត ។ បទថា **ជម្ភិតត្តំ** បានដល់ មានខ្លួនញ័របំប្រប់ ។

ប្រធានអ្នករក្សាព្រៃបានស្តាប់ពាក្យដូច្នោះ ទើបពោលគាថា ២ គាថាក្រៅអំពីនេះថា

ខ្ញុំឃើញនូវព្រួញដែលបាញ់ហើយដោយកម្លាំងនៃធ្នូ នូវព្រះខាន់សំលៀងដោយប្រេងដ៏មុតដែលពួកចោរកាន់ហើយ កាលសេចក្តីស្លាប់ដែលគួរខ្លាចនោះ ចូលមកតាំងនៅចំពោះមុខខ្ញុំ ក៏ត្រឡប់បានសេចក្តីត្រេកអរច្រើនដ៏លើសលុប ។

ខ្ញុំនោះមានសេចក្តីត្រេកអរ បានគ្របសង្កត់នូវពួកសត្រូវ ( ព្រោះថា ) ខ្ញុំបានលះបង់ជីវិតមុនហើយព្រោះថា បុគ្គលអ្នកក្លៀវក្លា កាលធ្វើសេចក្តីអាល័យក្នុងជីវិត គប្បីធ្វើនូវកិច្ចរបស់អ្នកក្លៀវក្លា ក្នុងកាលណាៗមិនបានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេទំ អលត្ថំ** គឺ ត្រឡប់បានសេចក្តីត្រេកអរនិងសោមនស្ស ។ បទថា **វិបុលំ** បានដល់ ច្រើន ។ បទថា **ឧឡារំ** បានដល់ ច្រើនក្រៃលែង ។ បទថា **អជ្ឈភវឹ** បានដល់ បរិច្ចាគជីវិតគ្របសង្កត់ហើយ ។ បទថា **បុព្វេវ មេ ជីវិតមាសិ ចត្តំ** សេចក្តីថា ព្រោះថា ខ្ញុំទទួលឈ្នួលអំពីដៃរបស់អ្នកក្នុងកាលមុននោះឯង បានលះបង់ជីវិតហើយ ។ បទថា **ន ហិ ជីវិតេ អាលយំ កុព្វមានោ** សេចក្តីថា បុគ្គលដែលក្លាហាន កាលនៅធ្វើសេចក្តីស្រឡាញ់ សេចក្តីត្រេកអរក្នុងជីវិត

នឹងគប្បីធ្វើកិច្ចរបស់អ្នកក្លាហានសូម្បីក្នុងកាលខ្លះមិនបានឡើយ ។

ប្រធានអ្នករក្សាព្រៃនោះ ធ្វើកូនឈ្នួញឲ្យដឹងថា ខ្លួនបានធ្វើកិច្ចរបស់អ្នកក្លាហានហើយ ព្រោះបានលះសេចក្តីត្រេកអរក្នុងជីវិត ដែលលះទុកក្នុងអំណាចរបស់អ្នកដទៃ បានបញ្ជូនឈ្នួញទៅហើយត្រឡប់មកកាន់ស្រុករបស់ខ្លួនវិញ ធ្វើបុណ្យទាំងឡាយមានទានជាដើមទៅតាមយថាកម្មហើយ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលលះបង់សេចក្តីព្យាយាមបានតាំងនៅក្នុងអរហត្ត ហើយទ្រង់ប្រជុំជាតកថា ប្រធានអ្នករក្សាព្រៃក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ខរបុប្បជាតក ចប់

# វាតគ្គសិន្ធវជាតក

[ ៣៩៧ ] ( កូនលាពោលថា ) អ្នកម្ដាយកើតរោគស្គមស្លៀងព្រោះតែប្ដីណា មិនពេញចិត្តនឹងកត្តព្រោះតែប្ដីណា ប្ដីនោះមកដល់ហើយ ឥឡូវនេះហេតុអ្វីបានជាអ្នកម្ដាយរត់ចេញទៅ ។

[ ៣៩៨ ] ( មេលាពោលថា ) ម្នាលកូន ម្ដាយយល់ថា ធម្មតាសន្ថវៈ ( របស់ស្ត្រី ) កើតដោយហេតុពីដំបូង ( ភ្លាម ) យសរបស់ស្ត្រីទាំងឡាយក៏សាបសូន្យ ហេតុនោះបានជាអញរត់ចេញ ។

[ ៣៩៩ ] ( ព្រះសាស្ដាទ្រង់ត្រាស់ថា ) ស្ត្រីណាមិនប្រាថ្នានូវបុរសមានយសកើតក្នុងត្រកូល ដែលគេនាំមកឲ្យស្ត្រីនោះ រមែងសោកសៅអស់កាលយូរអង្វែងដូចជាមេលា ( ដែលយំសោកស្ដាយ ) សេះសិន្ធពឈ្មោះវាតគ្គៈ ។

**ចប់ វាតគ្គសិន្ធវជាតកទី ៦ ។**

# អដ្ឋកថា

# វាតគ្គសិន្ធវជាតក

[ ៣៩៧-៣៩៩ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ក្នុងនគរសាវត្ថី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យេនាសិ កិសិយា បណ្ឌុ** ដូច្នេះជាដើម ។

បានឮថា ស្ត្រីម្នាក់ក្នុងនគរសាវត្ថីឃើញកុដុម្ពិកៈរូបស្អាតម្នាក់ មានចិត្ត

ប្រតិព័ទ្ធ ។ ភ្លើង គឺកិលេសកើតឡើងខាងក្នុងរបស់នាងដូចដុតរាងកាយទាំងមូល ។ នាងមិនបានទទួលសេចក្តីត្រេកអរផ្លូវកាយនិងផ្លូវចិត្តឡើយ ។ សូម្បីអាហារនាងក៏មិនពេញចិត្ត ដេកឱបមៅគ្រែតែម្យ៉ាង ។ លំដាប់នោះ ស្ត្រីបម្រើនិងស្ត្រីជាសម្លាញ់ បានសួរនាងថា ព្រោះហេតុអ្វីទើបនាងមានចិត្តរវើរវាយដេកឱបមៅគ្រែ នាងមិនជាសុខអ្វីឬ នាងដែលស្រីជាសម្លាញ់មិនបានពោលម្តងឬពីរដង ពោលរឿយៗទើបបានប្រាប់សេចក្តីនោះដល់ស្រីសម្លាញ់ទាំងនោះ ។ លំដាប់នោះ ស្រីសម្លាញ់ទាំងនោះក៏លួងលោមនាងឲ្យធូរចិត្តហើយពោលថា នាងដ៏ចម្រើន នាងកុំទោមនស្សឡើយពួកយើងនឹងនាំកុដុម្ពិកៈមកឲ្យហើយទៅប្រឹក្សាជាមួយកុដុម្ពិកៈ ។ កុដុម្ពិកៈនោះបដិសេធកាលពួកស្រីទាំងនោះនិយាយរឿយៗ ទើបព្រមទទួលពាក្យ ។ ស្រីទាំងនោះពោលថា ចូរអ្នកមកក្នុងថ្ងៃនោះក្នុងវេលានោះ ឲ្យកុដុម្ពិកៈទទួលពាក្យប្តេជ្ញាហើយទើបទៅប្រាប់ឲ្យស្រីនោះជ្រាប ។ ស្រីនោះបានស្តាប់ដំណឹងទើបរៀបចំបន្ទប់ដេករបស់ខ្លួន តែងខ្លួនហើយអង្គុយលើទីដេក កាលកុដុម្ពិកៈនោះមកអង្គុយក្នុងចំណែកម្ខាងនៃទីដេក ទើបគិតថា បើអញមិនធ្វើឲ្យមាំទាំចំពោះបុរសនេះ ឲ្យឱកាសក្នុងកាលឥឡូវនេះ ភាពជាធំរបស់អញក៏នឹងវិនាសទៅឈ្មោះថា ការឲ្យឱកាសក្នុងថ្ងៃដែលគេមកដល់នោះឯងមិនមែនជាហេតុដែលគួរឡើយ ថ្ងៃនេះ អញធ្វើឲ្យបុរសនេះខ្មាស ក្នុងថ្ងៃដទៃសឹមឲ្យឱកាស ។ លំដាប់នោះនាងចាប់ដៃបុរសនោះ ដែលប្រារព្ធនឹងលេងដោយការចាប់ដៃជាដើមហើយច្រានទៅមួយអន្លើដោយពាក្យថា ជៀសចេញទៅ ខ្ញុំមិនត្រូវការ

អ្នកទេ ។ កុដុម្ពិកៈនោះថយក្រោយមានចិត្តខ្មាសក្រោកឡើងទៅកាន់ផ្ទះរបស់ខ្លួនក្នុងវេលាពេលនោះឯង ។ ស្រីជាសម្លាញ់ដឹងថាស្រីនោះធ្វើយ៉ាងនោះកាលកុដុម្ពិកៈចេញទៅហើយ ទើបចូលទៅរកស្រីនោះ នាំគ្នាពោលយ៉ាងនេះថា នាងមានចិត្តប្រតិព័ទ្ធចំពោះកុដុម្ពិកៈនោះរហូតដល់មិនបរិភោគអាហារហើយដេក កាលបើដូច្នោះពួកយើងអង្វរកុដុម្ពិកៈរឿយៗហើយនាំកុដុម្ពិកៈមកឲ្យ ព្រោះហេតុអ្វីទើបមិនឲ្យឱកាសដល់កុដុម្ពិកៈ ។ នាងក៏ប្រាប់សេចក្ដីនោះឲ្យជ្រាប ។ ស្រីទាំងនោះពោលថា បើយ៉ាងនោះនាងនឹងដឹងផលក្នុងថ្ងៃខាងមុខហើយនាំគ្នាជៀសចេញទៅ ។ កុដុម្ពិកៈមិនបែរមើលទៀតឡើយ ។ ស្រីនោះកាលមិនបានកុដុម្ពិកៈនោះក៏ស្គមស្គាំង អត់អាហារដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ កុដុម្ពិកៈបានស្ដាប់ថា ស្រីនោះស្លាប់ហើយទើបកាន់ផ្កាកម្រងគ្រឿងក្រអូបនិងគ្រឿងលាបដ៏ច្រើនទៅកាន់វត្តជេតពន បូជាព្រះសាស្ដាថ្វាយបង្គំ ហើយអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ត្រូវព្រះសាស្ដាត្រាស់សួរថា ម្នាលឧបាសក ព្រោះហេតុអ្វីទើបអ្នកបាត់មុខមិនប្រាកដ ឧបាសកនោះក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាបហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គខ្មាសអស់កាលមានប្រមាណប៉ុណ្ណោះ ទើបមិនមកកាន់ទីពុទ្ធុបដ្ឋាក ។ ព្រះសាស្ដាត្រាស់ថា ម្នាលឧបាសក ស្រីនោះឲ្យហៅអ្នកមកដោយអំណាចនៃកិលេស កាលអ្នកមកហើយមិនឲ្យឱកាសធ្វើឲ្យអ្នកខ្មាសមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុននាងមានចិត្តប្រតិព័ទ្ធក្នុងបណ្ឌិតទាំងឡាយ ឲ្យហៅមកហើយ ក្នុងវេលាមកដល់មិនឲ្យឱកាស ធ្វើឲ្យលំបាកតែ

ម្យ៉ាងហើយបញ្ជូនទៅ ។ កាលកុដុម្ពិកៈនោះទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេះសិន្ធពមានឈ្មោះថា វាតគ្គសិន្ធព បានជាសេះមង្គលរបស់ព្រះបាទព្រហ្មទត្តនោះ ។ អ្នកចិញ្ចឹមសេះនាំសេះសិន្ធពនោះទៅងូតទឹកក្នុងស្ទឹងគង្គា ។ គ្រានោះសេះញីឈ្មោះថា កទ្ទលីបានឃើញសេះសិន្ធពនោះមានចិត្តប្រតិព័ទ្ធ ញាប់ញ័រដោយអំណាចនៃកិលេស មិនស៊ីស្មៅ មិនផឹកទឹក ស្គកស្គាំង ស្គមសល់តែស្បែកជណ្តប់ឆ្អឹង ។ លំដាប់នោះកូនឃើញមេស្គមស្គាំងទើបសួរថា បពិត្រអ្នកម៉ែ ព្រោះហេតុអ្វីទើបម៉ែមិនស៊ីស្មៅ មិនផឹកទឹក ស្គមស្គាំង ដេកញ័របំប្រប់នៅក្នុងទីនោះ ៗ ម៉ែមិនមានសេចក្តីសុខអ្វីឬ សេះញីនោះមិនប្រាប់ កាលត្រូវសួររឿយៗ ទើបសេះញីនោះប្រាប់សេចក្តីនោះ ។ លំដាប់នោះកូនសេះលួងលោមមេសេះឲ្យធូរស្បើយហើយពោលថា ម៉ែកុំទោមនស្សឡើយខ្ញុំនឹងនាំសេះសិន្ធពនោះមកឲ្យ ។ ក្នុងវេលាដែលសេះវាតគ្គសិន្ធពមកងូតទឹក ទើបចូលទៅរកហើយពោលថា បពិត្រលោកឪពុក មាតារបស់ខ្ញុំមានចិត្តប្រតិព័ទ្ធក្នុងលោក អត់អាហារស្គមស្គាំងនឹងស្លាប់ សូមលោកឲ្យទានជីវិតដល់មាតារបស់ខ្ញុំផងចុះ ។ វាតគ្គ-សិន្ធពពោលថា ល្អហើយបា យើងនឹងឲ្យពួកអ្នកចិញ្ចឹមសេះឲ្យយើងងូតទឹកហើយនឹងលែងដើម្បីឲ្យត្រាច់រកអាហារស៊ីត្រង់ច្រាំងស្ទឹងគង្គាមួយកន្លែង ចូរបានាំមាតាមកកាន់ប្រទេសនោះចុះ ។ កូនសេះនោះទៅនាំមាតាមកហើយទុក

ក្នុងប្រទេសនោះ ហើយបានឈរនៅក្នុងទីកំបាំងនាចំណែកម្ខាង ។ ចំណែកអ្នកចិញ្ចឹមសេះទាំងឡាយបានលែងវាតគ្គសិន្ធពទុកក្នុងទីនោះ ។ វាតគ្គសិន្ធពនោះឃើញសេះញីទើបចូលទៅរក ។ លំដាប់នោះសេះញីនោះកាលសេះវាតគ្គសន្ធព ចូលទៅត្រដុសកាយខ្លួនទើបគិតថា បើអញមិនមាំទាំឲ្យឱកាសដល់សេះនេះ ក្នុងខណៈដែលមកដល់នោះឯង កាលបើដូច្នោះយសនិងកាពជាធំរបស់អាត្មាអញនឹងវិនាសទៅ អាត្មាអញគួរធ្វើដូចជាមិនប្រាថ្នាចុះ ដូច្នេះ ហើយទើបយកជើងធាក់ចង្កាសេះសិន្ធពនោះ ហើយគេចទៅ ។ វំពេចនោះ ផ្ទេញទាំងឡាយហាក់សណ្ដកជ្រុះទៅទាំងឫស ។ វាតគ្គសិន្ធពគិតថា អញមានប្រយោជន៍អ្វីជាមួយសេះញីនេះ ជាអ្នកមានការខ្មាសគេចទៅអំពីទីនោះឯង ។ សេះញីនោះមានវិប្បដិសារីដួលចុះក្នុងទីនោះឯង ដេកសោកសៅ ។ លំដាប់នោះកូនសេះបានចូលទៅរកសេះដែលជាមាតាកាលនឹងសួរទើបពោលគាថាទី ១ ថា

អ្នកម្ដាយកើតរោគស្គមស្លៀងព្រោះតែប្ដីណា មិនពេញចិត្តនឹង
កត្តព្រោះតែប្ដីណា ប្ដីនោះមកដល់ហើយ ឥឡូវនេះហេតុអ្វី
បានជាអ្នកម្ដាយរត់ចេញទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេនាសិ** សេចក្ដីថា ព្រោះសេះណាជាហេតុឲ្យមានចិត្តប្រតិព័ទ្ធស្រឡាញ់ ។

សេះដែលជាមាតាបានស្ដាប់ពាក្យកូនទើបពោលគាថាទី ២ ថា

ម្នាលកូន ម្ដាយយល់ថា ធម្មតាសន្ធវៈ ( របស់ស្ត្រី ) កើត

ដោយហេតុពីដំបូង ( ភ្លាម ) យសរបស់ស្ត្រីទាំងឡាយក៏

សាបសូន្យ ហេតុនោះបានជាអញរត់ចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាទិកោនេវ** បានដល់ អំពីដើមនោះឯង គឺដំបូងនោះឯង ។ បទថា **សន្ថវោ** បានដល់ មិត្តសន្ថវៈដោយអំណាចការប្រកបមេថុនធម្ម ។ បទថា **យសោ ហាយតិ ឥត្ថីនំ** សេចក្តីថា នែបា ដ្បិតថា កាលស្ត្រីទាំងឡាយមិនលេងខ្លួន រមែងធ្វើនូវការជិតស្និទតាំងអំពីដំបូង យសរមែងវិនាសទៅ គឺភាពជាធំដែលនឹងគប្បីបានរមែងវិនាសទៅ ។ សេះញីនោះប្រាប់សភាពរបស់ស្ត្រីទាំងឡាយដល់កូនដោយប្រការដូច្នេះ ។

ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងទើបត្រាស់គាថាទី ៣ ថា

ស្ត្រីណាមិនប្រាថ្នានូវបុរសមានយសកើតក្នុងត្រកូល ដែលគេ

នាំមកឲ្យ ស្ត្រីនោះរមែងសោកសៅអស់កាលយូរអង្វែង ដូច

ជាមេលា ( ដែលយំសោកស្តាយ ) សេះសិន្ធព ឈ្មោះ

វាតគ្គៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យសស្សិនំ** បានដល់ ដែលបរិបូណ៌ដោយយស ។ បទថា **យា ច ឥច្ឆតិ** សេចក្តីថា ស្ត្រីណាមិនប្រាថ្នាបុរសបែបនោះ ។ បទថា **ចិររត្តាយ** បានដល់ អស់កាលដ៏យូរ អធិប្បាយថា អស់កាលដ៏យូរអង្វែង ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈតាំងនៅក្នុង

សោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា មេសេះក្នុងកាលនោះបានមកជាស្ត្រី នេះក្នុងកាលឥឡូវនេះ ចំណែកវាតគ្គសិន្ធពក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វាតគ្គសិន្ធវជាតក ចប់

# សុវណ្ណកក្កដកជាតក

[ ៤០០ ] ( ដំរីពោធិសត្វពោលថា ) ម្រឹគមានសម្បុរដូចមាស ( ក្តាម ) ជាសត្វមានភ្នែកលៀនវែង មានឆ្អឹងជាស្បែក ជាសត្វនៅក្នុងទឹក មិនមានរោម យើងត្រូវក្តាមនោះថ្ងៀបហើយទើបកំសត់ទួញយំ សូមករិយាកុំលះបង់នូវខ្ញុំដែលស្មើដោយជីវិតឡើយ ។

[ ៤០១ ] ( មេដំរីពោលថា ) បពិត្រអ្នកជាម្ចាស់ ខ្ញុំមិនលះបង់អ្នកដែលជាដំរីចែមថយកម្លាំង ក្នុងកាលនៃខ្លួនមានអាយុ ៦០ ឆ្នាំឡើយ ខ្ញុំស្រឡាញ់អ្នកក្រៃលែងជាងប្រឹថពីដែលទល់នឹងសមុទ្ទទាំង ៤ ទៅទៀត ។

[ ៤០២ ] ( មេដំរីពោលថា ) ពួកក្តាមណាដែលនៅក្នុងសមុទ្ទក្តី ក្នុងទន្លេគង្គាក្តី យមុនាក្តី អ្នកជាសត្វទឹកប្រសើរជាងក្តាមទាំងនោះ សូមអ្នកមេត្តាលែងប្តី កាលដែលខ្ញុំកំពុងទួញយំរកប្តី សូមអ្នកមេត្តាលែងប្តី ( របស់ខ្ញុំ ) មកវិញក្នុងកាលឥឡូវនេះ ។

**ចប់ សុវណ្ណកក្កដកជាតកទី ៧ ។**

# អដ្ឋកថា

# សុវណ្ណកក្កដកជាតក

[ ៤០០-៤០២ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្ត្រីម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សិង្គី មិគោ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថីមានកុដុម្ពិកៈម្នាក់នាំភរិយារបស់ខ្លួនទៅកាន់ជនបទដើម្បីទារបំណុលឲ្យអស់ កាលទារបំណុលអស់ហើយក៏ធ្វើដំណើរមកត្រូវពួកចោរចាប់ក្នុងរវាងផ្លូវ ។ ភរិយារបស់កុដុម្ពិកៈនោះជាស្រីមានរូបស្អាតគួរជ្រះថ្លា គួរត្រេកអរ ។ មេចោរប្រារព្ធនឹងសម្លាប់កុដុម្ពិកៈ ព្រោះសេចក្ដីស្រឡាញ់ក្នុងនាង តែនាងជាស្ត្រីមានសីល បរិបូណ៌ដោយអាចារមារយាទគោរពស្វាមីដូចទេវតា ។ ទើបនាងក្រាបចុះទៀបជើងរបស់មេចោរ អង្វរថា បពិត្រអ្នកជាម្ចាស់ បើអ្នកមានសេចក្ដីស្រឡាញ់ចំពោះខ្ញុំ សូមអ្នកកុំសម្លាប់ស្វាមីរបស់ខ្ញុំឡើយ បើអ្នកសម្លាប់ខ្ញុំនឹងបរិភោគថ្នាំពិសឬអត់ដង្ហើមឲ្យស្លាប់ ខ្ញុំមិនទៅជាមួយអ្នកទេ អ្នកកុំសម្លាប់ស្វាមីរបស់ខ្ញុំដោយមិនមានហេតុឡើយ ។ ហើយសូមឲ្យដោះលែងស្វាមី ។ ចំណែកស្វាមីភរិយាទាំង ២ នោះដល់ក្រុងសាវត្ថីដោយសួស្ដី ធ្វើដំណើរមកតាមផ្លូវក្រោយវិហារជេតពនគិតគ្នាថា ពួកយើងចូលក្នុងវត្ត ហើយនឹងថ្វាយបង្គំព្រះសាស្ដា ទើបចូលទៅកាន់បរិវេណព្រះគន្ធកុដិ ថ្វាយបង្គំព្រះសាស្ដាហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្ដាត្រាស់សួរជនទាំង ២ គឺស្វាមីនិងភរិយានោះថា ម្នាលឧបាសក តើអ្នកទៅណាមកណា ស្វាមីភរិយាទាំង ២ ក៏ក្រាបទូលថា ទៅជម្រះ

បំណុលព្រះអង្គ ។ កាលព្រះសាស្តាត្រាស់ថា ក្នុងរវាងផ្លូវពួកអ្នកនាំគ្នាមកដោយមិនមានជំនឹតម្ខាត់ទេឬទើបកុដុម្ពិកៈក្រាបទូលថា បពិត្រព្រះអង្គ ក្នុងរវាងផ្លូវពួកចោរចាប់ខ្ញុំព្រះអង្គទាំង ២ ក្នុងពេលនោះកិរិយារបស់ខ្ញុំព្រះអង្គនេះបានអង្វរមេចោរដែលបំណាងនឹងសម្លាប់ខ្ញុំព្រះអង្គឲ្យលែងខ្ញុំព្រះអង្គព្រោះអាស្រ័យកិរិយានេះខ្ញុំព្រះអង្គបានរួចជីវិតមក ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេដែលស្ត្រីនេះបានឲ្យជីវិតដល់អ្នកសូម្បីក្នុងកាលមុន ស្ត្រីនេះក៏បានឲ្យជីវិតដល់បណ្ឌិតទាំងឡាយដូចគ្នា កាលកុដុម្ពិកៈនោះទូលអារាធនាហើយ ទើបព្រះសាស្តាទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីមានអន្លង់ទឹកធំនៅជិតព្រៃហិមពាន្ត ។ ក្នុងអន្លង់ទឹកធំនោះមានក្តាមមាសធំអាស្រ័យនៅ ។ អន្លង់ទឹកធំនោះប្រាកដឈ្មោះថា កុឡីរទហៈ ( ប្រែថាត្រពាំងក្តាម ) ព្រោះជាលំនៅរបស់ក្តាមមាសនោះ ។ ក្តាមមាសធំនោះមានប្រមាណប៉ុនលានស្រូវ ចាប់ដំរីសម្លាប់បរិភោគ ។ ព្រោះខ្លាចក្តាមមាសនោះដំរីទាំងឡាយមិនអាចចុះអន្លង់ទឹកនោះរកអាហារបរិភោគឡើយ ។ ក្នុងកាលនោះព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃដំរីញី ព្រោះអាស្រ័យដំរីមេហ្វូងក្នុងហ្វូងដំរីដែលអាស្រ័យកុឡីរទហៈនោះ ។ លំដាប់នោះមាតារបស់ព្រះពោធិសត្វនោះគិតថានឹងរក្សាគភ៌ ដូច្នេះហើយទើបទៅកាន់ភ្នំដទៃរក្សាគភ៌រហូតដល់ប្រសូតបុត្ត ។ ព្រះពោធិសត្វនោះចម្រើនវ័យតាមលំដាប់មានបរិវារច្រើន បរិបូណ៌

ដោយកម្លាំងដល់នូវភាពជាដំរីប្រសើរដោយលម្អ ដូចគ្នានិងភ្នំអញ្ជន ។ ព្រះពោធិសត្វនោះនៅរួមជាមួយដំរីញីមួយគិតថានឹងចាប់ក្ដាមមាស ដូច្នេះហើយទើបនាំកិរិយានិងមាតារបស់ខ្លួនចូលហ្វូងដំរីនោះ ជួបជាមួយបិតាទើបពោលថា បពិត្រលោកឪពុក ខ្ញុំនឹងចាប់ក្ដាមមាសនេះ ។ លំដាប់នោះ បិតាបានហាមកូនថា បាមិនអាចឡើយ ។ ព្រះពោធិសត្វពោលនឹងបិតាដែលឃាត់រឿយៗថា លោកនឹងដឹងកម្លាំងរបស់ខ្ញុំ ។ ព្រះពោធិសត្វនោះ ក៏ឲ្យប្រជុំដំរីទាំងអស់ដែលចូលទៅអាស្រ័យអន្លង់ទឹកកុឡីរទហៈ ដើរទៅជិតអន្លង់ទឹកមួយអន្លើដោយដំរីទាំងពួងហើយសួរថា ក្ដាមមាសនោះចាប់ដំរីក្នុងវេលាចុះ ក្នុងវេលាស្វែងរកអាហារឬក្នុងវេលាឡើង បានស្ដាប់ថា ក្នុងវេលាឡើង ដូច្នេះហើយទើបពោលថា បើយ៉ាងនោះសូមពួកអ្នកចុះក្នុងអន្លង់កុឡីរទហៈរកអាហារស៊ីត្រឹមតែល្មមហើយឡើងមកមុន ខ្ញុំនឹងនៅខាងក្រោយ ។ ដំរីទាំងឡាយបានធ្វើយ៉ាងនោះ ។ ទើបក្ដាមមាសយកតង្កៀបទាំងគូ កៀបជើងទាំង ២ របស់ព្រះពោធិសត្វដែលឡើងខាងក្រោយ ទុកយ៉ាងមាំដូចជាងមាសយកអង្គឹធំចាប់ដែកដូច្នោះ ។ ដំរីញីមិនលះបង់ព្រះពោធិសត្វបានឈរនៅក្នុងទីជិតៗនោះឯង ។ ព្រះពោធិសត្វទាញ ក៏មិនអាចធ្វើឲ្យក្ដាមហើបបាន ។ ចំណែកក្ដាមមាសទាញព្រះពោធិសត្វមករកមាត់របស់ខ្លួន ។ ព្រះពោធិសត្វត្រូវមរណភ័យគំរាមក៏ស្រែកឲ្យដឹងថា ខ្ញុំត្រូវក្ដាមកៀប ។ ដំរីទាំងពួងខ្លាចមរណភ័យបន្លឺកោញ្ចនាទរាកអាចម៍ រាកនោមរត់ទៅ ។ ចំណែកដំរីញីក៏មិនអាចតាំងនៅក្នុងទីនោះផ្ដើមរត់ទៅ ។ លំដាប់នោះព្រះពោធិសត្វបានធ្វើឲ្យនាង

គិតថា ខ្លួនត្រូវក្តាមកៀបទុក ដើម្បីមិនឲ្យដំរីញីរត់ទៅទើបពោលគាថាទី ១ ថា

ម្រឹគមានសម្បុរដូចមាស ( ក្តាម ) ជាសត្វមានភ្នែកលៀនវែង មានឆ្អឹងជាស្បែក ជាសត្វនៅក្នុងទឹក មិនមានរោម យើងត្រូវក្តាមនោះថ្កៀបហើយទើបកំសត់ខ្លួញយំ សូមករិយាកុំលះបង់នូវខ្ញុំដែលស្មើដោយជីវិតឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិង្គី មិគោ** បានដល់ ម្រឹគមានពណ៌ដូចពណ៌មាស មានស្នែង អធិប្បាយថា ឈ្មោះថា **សិង្គី** ព្រោះប្រកបដោយតង្កៀបទាំង ២ ដែលញុំាងកិច្ចដែលគប្បីធ្វើដោយស្នែងឲ្យសម្រេច ។ ចំណែកកុឡីរៈគឺក្តាម លោកហៅថា **មិគោ** គឺម្រឹគក្នុងទីនេះ ព្រោះកាន់យកដោយសរុប ។ ក្នុងបទថា **អាយតចក្ខុនេត្តោ** នេះ ដែលឈ្មោះថាចក្ខុព្រោះអត្ថថា ឃើញ ដែលឈ្មោះនេត្តៈ ព្រោះអត្ថថានាំទៅ នេត្តៈពោលគឺចក្ខុរបស់ក្តាមនោះវែង ព្រោះហេតុនោះទើបឈ្មោះថាមាននេត្តៈ គឺចក្ខុវែង អធិប្បាយថា មានភ្នែកវែង ។ ឈ្មោះថា មានស្បែកជាឆ្អឹងព្រោះឆ្អឹងប៉ុណ្ណោះធ្វើកិច្ច គឺនាទីរបស់ស្បែកឲ្យសម្រេចដល់ក្តាមនោះៗ ។ បទថា **តេនាភិភូតោ** សេចក្តីថា ត្រូវម្រឹគនោះឯងគ្របសង្កត់ គឺកៀបបានដល់ ចាប់ទុកមិនឲ្យកម្រើកបាន ។ បទថា **កបណំ រុទាមិ** សេចក្តីថា ខ្ញុំជាបុគ្គលដល់នូវភាពដែលគួរករុណាខ្លួញយំ ។ បទថា **មា ហេវ មំ** សេចក្តីថា នាងកុំបោះបង់ខ្ញុំដែលជាស្វាមី ជាទីស្រឡាញ់ ស្មើនឹងខ្យល់ដង្ហើមរបស់ខ្លួនដែល

ដល់នូវសេចក្តីវិនាសបែបនេះ ។

លំដាប់នោះដំរីញីនោះទើបបែរត្រឡប់មកវិញ កាលនឹងលួងលោមព្រះពោធិសត្វនោះទើបពោលគាថាទី ២ ថា

បពិត្រអ្នកជាម្ចាស់ ខ្ញុំមិនលះបង់អ្នកដែលជាដំរីថមថយកម្លាំង
ក្នុងកាលនៃខ្លួនមានអាយុ ៦០ ឆ្នាំឡើយ ខ្ញុំស្រឡាញ់អ្នក
ក្រៃលែងជាងប្រឹថពីដែលទល់នឹងសមុទ្រទាំង ៤ ទៅទៀត
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សដ្ឋិហាយនំ** សេចក្តីថា ក្នុងវេលាមានអាយុ ៦០ ឆ្នាំ ដោយកំណើតដំរីទាំងឡាយរមែងថមថយកម្លាំង ខ្ញុំមិនលះបង់អ្នក ដែលថមថយដោយកម្លាំងយ៉ាងនេះ អ្នកដល់នូវការវិនាស អ្នកកុំខ្លាចឡើយដ្បិតថា អ្នកជាទីស្រឡាញ់ក្រៃលែងរបស់ខ្ញុំជាងប្រឹថពីនេះដែលមានមហាសមុទ្រក្នុងទិសទាំង ៤ ជាព្រំប្រទល់ ឈ្មោះថាមានមហាសមុទ្រទាំង ៤ ជាទីបំផុត ។

ដំរីញីកាលធ្វើព្រះពោធិសត្វនោះឲ្យរឹងមាំហើយ ទើបពោលថា បពិត្រអ្នកជាម្ចាស់ ឥឡូវនេះខ្ញុំកាលបានសន្ទនាប្រាស្រ័យជាមួយក្តាមមាសត្រឹមតែបន្តិចនឹងឲ្យលែងអ្នក កាលនឹងអង្វរក្តាមមាសទើបពោលគាថាទី ៣ ថា

ពួកក្តាមណាដែលនៅក្នុងសមុទ្រក្តី ក្នុងទន្លេគង្គាក្តី យមុនាក្តី
អ្នកជាសត្វទឹកប្រសើរជាងក្តាមទាំងនោះ សូមអ្នកមេត្តាលែង
ប្តី កាលដែលខ្ញុំកំពុងទួញយំរកប្តី សូមអ្នកមេត្តាលែងប្តី

( របស់ខ្ញុំ ) មកវិញក្នុងកាលឥឡូវនេះ ដូច្នេះ ។

អត្ថរបស់ពាក្យដែលជាគាថានេះថា ក្អាមពួកណាក្នុងសមុទ្ទក្តី ក្នុងស្ទឹងគង្គាក្តី ស្ទឹងយមុនាក្តី អ្នកប៉ុណ្ណោះជាអ្នកប្រសើរជាងក្អាមទាំងអស់នោះ ដោយការដល់ព្រមដោយវណ្ណៈ និងដោយភាពជាធំ ដោយហេតុនោះទើបខ្ញុំសូមអង្វរអ្នក សូមអ្នកលែងប្តីរបស់ខ្ញុំដែលកំពុងទួញយំចុះ ។

កាលដំរីញីនោះកំពុងពោលក្អាមបានកាន់យកនិមិត្តក្នុងសំឡេងស្រី ជាអ្នកមានចិត្តស្លុង ទើបលាតង្កៀបអំពីជើងដំរីដោយពុំដឹងខ្លួនថា ដំរីនេះកាលអញលែងហើយនឹងធ្វើវត្ថុឈ្មោះនេះ ។ លំដាប់នោះទើបដំរីលើកជើងជាន់ក្អាមនោះត្រង់ខ្នងស្នូក ក៏បែកទៅក្នុងរំពេចនោះឯង ។ ដំរីស្រែកឡើងដោយសេចក្តីត្រេកអរ ។ ដំរីទាំងពួងទើបប្រជុំគ្នានាំយកក្អាមទៅដាក់លើគោកជាន់ឲ្យល្អិតជាលម្អិតតូចធំ ។ តង្កៀបទាំង ២ របស់ក្អាមនោះដាច់ចេញអំពីរាងកាយខ្ចាត់ទៅក្នុងចំណែកម្ខាង ។ អន្លង់ទឹកដែលមានក្អាមនៅនោះជាប់នឹងស្ទឹងគង្គា ក្នុងវេលាដែលស្ទឹងគង្គាពេញក៏ពេញដោយទឹកក្នុងស្ទឹងគង្គា ។ កាលទឹកស្ទឹងគង្គាស្រកទឹកក្នុងអន្លង់ក៏ហូរចុះកាន់ស្ទឹងគង្គា ។ កាលនោះតង្កៀបក្អាមទាំង ២ ក៏អណ្តែតទៅក្នុងស្ទឹងគង្គា ។ ក្នុងតង្កៀបក្អាម ២ នោះតង្កៀបមួយអណ្តែតទៅកាន់មហាសមុទ្ទ ។ ព្រះរាជាបងប្អូន ១០ អង្គលេងទឹកបានតង្កៀបក្អាមមួយធ្វើសម្ភោរឈ្មោះថា អាឡិង្គៈ ។ ចំណែកតង្កៀបមួយទៀតដែលអណ្តែតទៅកាន់មហាសមុទ្ទ ពួកអសុរកាន់យកទៅហើយឲ្យធ្វើជាស្គរឈ្មោះអឡម្ពរភេរី ។ ក្នុងកាលតមកពួកអសុរទាំងនោះត្រូវសក្ក-

ទេវរាជឲ្យបាញ់ក្នុងសង្គ្រាមទើបបោលអឡម្ពុរភេរីនោះហើយរត់ទៅ ។ លំដាប់នោះសក្កទេវរាជឲ្យកាន់យកអឡម្ពុរភេរីនោះមក ដើម្បីជាប្រយោជន៍ដល់ព្រះអង្គ ។ អាចារ្យពួកខ្លះសំដៅយកស្គរនោះពោលថា ស្គរឈ្មោះអឡម្ពុរៈគ្រហឹមដូចផ្គរលាន់ដូច្នោះ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ជនទាំង ២ គឺស្វាមីភរិយាក៏តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ដំរីញីក្នុងកាលនោះបានមកជាឧបាសិកានេះក្នុងកាលឥឡូវនេះ ចំណែកដំរី ( ដែលជាស្វាមី ) ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុវណ្ណកក្កដកជាតក ចប់

## អារាមទូសកជាតក

[ ៤០៣ ] ( បុរសពោធិសត្វពោលថា ) ស្វាណាដែលគេសន្មត់ថាជាសត្វប្រសើរបំផុតជាងពួកស្វាដែលមានជាតិស្មើគ្នានេះ ប្រាជ្ញារបស់ស្វានោះមានតែត្រឹមប៉ុណ្ណេះ ពួកសត្វ ( ស្វា ) ក្រៅនេះនឹងមានប្រាជ្ញាដូចម្ដេចទៅ ។

[ ៤០៤ ] ( ហ្វូងស្វាពោលថា ) បពិត្រអ្នកដ៏ប្រសើរ ការតិះដៀលយ៉ាងនេះព្រោះតែមិនដឹង បុគ្គលមិនឃើញនូវឫសហើយគប្បីដឹងនូវដើមឈើដែលតាំងនៅស៊ប់ដូចម្ដេចកើត ។

[ ៤០៥ ] ( ពោធិសត្វពោលថា ) យើងមិនតិះដៀលពួកអ្នកដែលជាពានរអាស្រ័យនៅក្នុងព្រៃនេះទេតែថាពួកជនអ្នកដាំដើមឈើដើម្បីប្រយោជន៍ដល់ស្ដេចវិស្សសេនណា ស្ដេចវិស្សសេននោះគួរគេតិះដៀលបាន ។

**ចប់ អារាមទូសកជាតកទី ៨ ។**

## អដ្ឋកថា

## អារាមទូសកជាតក

[ ៤០៣-៤០៥ ] ព្រះសាស្ដា កាលគង់នៅក្នុងទក្ខិណាគិរីជនបទ ទ្រង់ប្រារព្ធបុត្តរបស់នាយឧទ្យានបាលម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យោមេសញ្ញ សមេតានំ** ដូច្នេះជាដើម ។

បានឮមកថា ព្រះសាស្ដាកាលចេញវស្សាហើយទ្រង់ចេញចាកវត្តជេតពនយាងចារិកទៅកាន់ទក្ខិណាគិរីជនបទ ។ កាលនោះឧបាសកម្នាក់និមន្តភិក្ខុ

សង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ក្នុងចម្ការ ឲ្យទ្រង់ឆ្អែតស្កប់ស្កល់ដោយយាគូ និងរបស់គួរទំពាទាំងឡាយទើបពោលថា បពិត្រលោកម្ចាស់ទាំងឡាយ បើលោកម្ចាស់មានបំណងត្រាច់ទៅក្នុងចម្ការ សូមនិមន្តទៅជាមួយឧទ្យានបាលនេះ ។ ហើយប្រាប់នាយឧទ្យានបាលថា អ្នកគប្បីប្រគេនផ្លែឈើតូចធំដល់លោកម្ចាស់ទាំងឡាយ ។ ភិក្ខុទាំងឡាយដើរទៅ ឃើញប្រឡោះមួយកន្លែងទើបសួរថា ទីនេះជាប្រឡោះមិនមានដើមឈើដុះឡើងព្រោះហេតុអ្វី លំដាប់នោះនាយឧទ្យានបាលក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា បានឮថា មានបុត្តរបស់នាយឧទ្យានបាលម្នាក់កាលស្រោចទឹកដើមឈើដែលដាំថ្មី គិតថានឹងស្រោចទឹកដោយយកឫសជាប្រមាណ ដូច្នេះហើយទើបដកកូនឈើមើលឫសហើយស្រោចទឹកតាមប្រមាណនៃឫស ដោយហេតុនោះទើបទីនោះជាប្រឡោះ ។ ភិក្ខុទាំងឡាយមកគាល់ព្រះសាស្តាហើយក្រាបទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនកុមារនោះក៏ជាអ្នកទម្លាយអារាមដូចគ្នា កាលភិក្ខុទាំងនោះទូលអារាធនាទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី កាលគេវាយស្គរប្រកាសការលេងមហោស្រព នាយឧទ្យានបាលគិតថានឹងលេងមហោស្រព ដូច្នេះហើយទើបប្រាប់ស្វាទាំងឡាយដែលនៅក្នុងឧទ្យានថា ឧទ្យាននេះមានឧបការៈច្រើនដល់ពួកអ្នក ខ្ញុំនឹងលេងមហោស្រព ៧ ថ្ងៃ

សូមពួកអ្នកស្រោចទឹកដើមឈើដែលដាំថ្មីអស់កាល ៧ ថ្ងៃ ។ ពួកស្វា ទទួលថា សាធុ នាយឧទ្យានបាលទើបប្រគល់ក្អមស្បែកឲ្យដល់ស្វាទាំងនោះ ហើយជៀសចេញទៅ ។ ស្វាទាំងឡាយកាលនឹងស្រោចទឹកទើបស្រោចទឹក ដើមឈើដែលដុះថ្មី ។ លំដាប់នោះស្វាមេហ្វូងបានពោលចំពោះស្វាទាំងនោះ ថា ពួកអ្នកចូររង់ចាំសិន ធម្មតាថាទឹកមិនមែនរកបានដោយងាយគ្រប់កាល ទេ ទឹកនោះគួររក្សា ពួកយើងគួរដកដើមឈើដែលដាំថ្មីដឹងប្រមាណរបស់ ឫសហើយដើមឈើដែលមានឫសវែងស្រោចទឹកឲ្យច្រើន ដើមឈើដែលមាន ឫសខ្លីស្រោចទឹកតិច ។ ស្វាទាំងនោះនាំគ្នាទទួលពាក្យថា សាធុ ។ ពួក ខ្លះដើរដកដើមឈើដែលដាំថ្មី ពួកខ្លះដាំហើយស្រោចទឹក ។ ក្នុងកាលនោះ ព្រះពោធិសត្វបានជាបុត្ររបស់ត្រកូលមួយក្នុងនគរពារាណសី ព្រះពោធិសត្វ បានទៅកាន់ឧទ្យានដោយករណីយកិច្ចឯណានីមួយ ឃើញស្វានោះធ្វើយ៉ាង នោះទើបសួរថា អ្នកណាឲ្យពួកអ្នកធ្វើយ៉ាងនេះ កាលពួកស្វាឆ្លើយថា ប្រធាន ពានរទើបពោលថា បញ្ញានៃប្រធានពានររបស់ពួកអ្នកមានប្រមាណប៉ុណ្ណេះ ចំណែកបញ្ញារបស់ពួកអ្នកដូចម្តេចទៅ ។ កាលប្រកាសសេចក្តីនោះ ទើប ពោលគាថាទី ១ ថា

ស្វាណាដែលគេសន្មត់ថាជាសត្វប្រសើរបំផុតជាងពួកស្វា ដែល
មានជាតិស្មើគ្នានេះ ប្រាជ្ញារបស់ស្វានោះមានតែត្រឹមប៉ុណ្ណេះ
ពួកសត្វ ( ស្វា ) ក្រៅនេះនឹងមានប្រាជ្ញាដូចម្តេចទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោមេសញ្ញុ សមេតានំ** សេចក្តីថា

ស្វាណាដែលបានសន្មត់ថា ប្រសើរបំផុតជាងស្វាទាំងនេះ គឺជាងស្វាទាំងអស់ដែលមានជាតិកំណើតស្មើគ្នា ។ បទថា **កិមេវ ឥតរា បជា** សេចក្ដីថា បញ្ញារបស់ស្វាដែលថោកទាបក្រៅអំពីនេះ បណ្ដាស្វាទាំងនោះ នឹងដូចម្ដេច ។

ពានរទាំងឡាយបានស្ដាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយទើបពោលគាថាទី ២ ថា

បពិត្រអ្នកដ៏ប្រសើរ ការតិះដៀលយ៉ាងនេះព្រោះតែមិនដឹង
បុគ្គលមិនឃើញនូវឫសហើយគប្បីដឹងនូវដើមឈើដែលតាំង
នៅស៊ប់ដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហ្មេ** ត្រឹមតែជាអាលបនៈ គឺពាក្យសម្រាប់ហៅ ។ ក្នុងគាថានេះមានសេចក្ដីសង្ខេបដូចតទៅនេះថា នែបុរសដ៏ចម្រើន អ្នកមិនដឹងហេតុនិងមិនមែនហេតុដោយប្រការណា មកតិះដៀលពួកយើងដោយប្រការនោះមួយរំពេច បុគ្គលណាមួយកាលមិនដកឫសហើយនឹងអាចដឹងបានយ៉ាងណាថាឈ្មោះថា ដើមឈើនេះមានឫសចាក់ចូលទៅជ្រៅឬមិនជ្រៅ ដោយហេតុនោះពួកយើងឲ្យដកឡើងហើយ ទើបស្រោចទឹកតាមប្រមាណរបស់ឫស ។

ព្រះពោធិសត្វបានស្ដាប់ដូច្នោះទើបពោលគាថាទី ៣ ថា

យើងមិនតិះដៀលពួកអ្នក ដែលជាពានរអាស្រ័យនៅក្នុងព្រៃនេះ
ទេតែជាពួកជនអ្នកដាំដើមឈើដើម្បីប្រយោជន៍ដល់ស្ដេចវិស្ស-

សេនណា ស្តេចវិស្សសេននោះ គួរគេតិះដៀលបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិស្សសេនោ ច គារយ្ហោ** សេចក្តីថា ក្នុងការដាំដើមឈើនេះ ព្រះបាទពារាណសីព្រះនាមថាវិស្សសេនៈ គប្បីត្រូវតិះដៀល ។ បទថា **យស្សត្ថា រុក្ខរោបកា** សេចក្តីថា ជនទាំងឡាយដូចពួកអ្នកជាអ្នកដាំដើមឈើដើម្បីប្រយោជន៍ដល់ព្រះរាជាអង្គណា ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ប្រធានពានរក្នុងកាលនោះ បានមកជាកុមារដែលបំផ្លាញដើមឈើក្នុងឧទ្យានក្នុងកាលឥឡូវនេះ ចំណែកបុរសជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អារាមទូសកជាតក ចប់

# សុជាតាជាតក

[ ៤០៦ ] ( ព្រះរាជាពោធិសត្វត្រាស់ថា ) ពួកជនប្រកបដោយសម្បុរ មានសំឡេងពីរោះ មានរូបជាទីស្រឡាញ់គួរមិលមើល តែជាអ្នកមានវាចារឹងរូស មិនជាទីស្រឡាញ់របស់អ្នកផងក្នុងលោកនេះនឹងលោកខាងមុខទេ ។

[ ៤០៧ ] ព្រះមាតាឃើញមេតាវ៉ៅខ្មៅនេះ ដែលមានសម្បុរអាក្រក់ ដេរដាសដោយពណ៌ពព្រុះអុចៗ តែថាជាទីស្រឡាញ់របស់សត្វច្រើនដោយសារវាចាពីរោះឬទេ ។

[ ៤០៨ ] ព្រោះហេតុនោះ បុគ្គលគប្បីជាអ្នកមានវាចាល្អិតល្អ ជាអ្នកពោលពាក្យលៃតាមប្រាជ្ញា មិនមានចិត្តរាយមាយរមែងសម្តែងនូវអត្ថនិងធម៌ ភាសិតរបស់បុគ្គលនោះទើបឈ្មោះថា ពីរោះ ។

**ចប់ សុជាតាជាតកទី ៩ ។**

## អដ្ឋកថា

## សុជាតជាតក

[ ៤០៦-៤០៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងសុជាតាប្អូនស្រីរបស់នាងវិសាខា ជីតារបស់ធនញ្ជ័យសេដ្ឋី កូនប្រសាររបស់អនាថបណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន ហិ វណ្ណេន សម្បន្នា** ដូច្នេះជាដើម ។

បានឮថា នាងសុជាតានោះចូលទៅកាន់ផ្ទះរបស់អនាថបណ្ឌិកសេដ្ឋីពេញដោយយសដ៏ធំក្រៃលែង ។ នាងសុជាតានោះគិតថា យើងជាធីតារបស់ត្រកូលធំ ដូច្នេះហើយទើបជាអ្នកប្រកាន់ខ្លួន ច្រើនទៅដោយសេចក្តីក្រោធអាក្រក់គ្រោតគ្រាត មិនធ្វើវត្តបដិបត្តិដល់ឪពុកក្មេកម្តាយក្មេកនិងស្វាមី ត្រាច់គំរាមវាយមនុស្សដែលនៅក្នុងផ្ទះ ។ ថ្ងៃមួយព្រះសាស្តាចោមរោមដោយភិក្ខុ ៥០០ យាងចូលទៅកាន់ផ្ទះរបស់អនាថបណ្ឌិកសេដ្ឋី ទ្រង់គង់ហើយ ។ ចំណែកមហាសេដ្ឋីក៏ចូលទៅអង្គុយជិតព្រះសាស្តា ស្តាប់ធម៌ ។ ខណៈនោះនាងសុជាតាធ្វើការឈ្លោះជាមួយពួកទាសៈនិងកម្មករ ។ ព្រះសាស្តាទ្រង់បញ្ឈប់ធម្មកថាត្រាស់ថា នេះសំឡេងអ្វី សេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គមានស្ត្រីដែលជាកូនប្រសារស្រីក្នុងត្រកូលម្នាក់ មិនមានការគោរព នាងមិនមានវត្តបដិបត្តិចំពោះឪពុកក្មេក ម្តាយក្មេកនិងស្វាមីមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ត្រាច់បង្កជម្លោះទាំងថ្ងៃទាំងយប់ ។ ព្រះសាស្តា ត្រាស់ថាបើយ៉ាងនោះ ចូរអ្នកហៅនាងមក ។ នាងសុជាតាមកថ្វាយបង្គំហើយបានឈរក្នុងទីបំផុតនាចំណែកម្ខាង ។ លំដាប់នោះព្រះសាស្តាត្រាស់សួរនាងថាម្នាលនាងសុជាតា ភរិយារបស់បុរសមាន ៧ ពួក នាងជាភរិយាពួកណាក្នុងភរិយា ៧ ពួកនោះ នាងសុជាតាក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនជ្រាបន័យព្រះតម្រាស់ដែលព្រះអង្គត្រាស់ដោយសង្ខេប សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់ដោយពិស្តារចុះ ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរនាងផ្ទៀងសោតៈស្តាប់ហើយត្រាស់ព្រះគាថានេះ ( ក្នុងអង្គុត្តរ

និកាយសត្តកនិបាត ) ថា

ករិយាដែលស្វាមីលោះមកដោយទ្រព្យ ស្ត្រីមានចិត្តប្រទូស្ត ( នឹងស្វាមី ) មានសេចក្តីមិនអនុគ្រោះនូវប្រយោជន៍ ជាអ្នកត្រេកត្រអាលក្នុងបុរសដទៃ មើលងាយប្តី ខ្វល់ខ្វាយដើម្បីសម្លាប់ ( ប្តី ) ស្ត្រីណាជាករិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា វធកាករិយា ។ ស្វាមីនៃស្ត្រីបាននូវទ្រព្យណាហើយតម្កល់ទុកដើម្បីធ្វើនូវសិល្បៈក្តី នូវជំនួញក្តី នូវកសិកម្មក្តី ស្ត្រីនោះប្រាថ្នាដើម្បីលួចកិបយកនូវទ្រព្យ សូម្បីបន្តិចបន្តួចអំពីទ្រព្យនោះ ស្ត្រីណាជាករិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា ចោរីករិយា ។ ស្ត្រីមិនមានសេចក្តីប្រាថ្នានឹងធ្វើនូវការងារ ជាអ្នកខ្ជិលច្រអូស ស៊ីច្រើន រឹងរូស កាចពោលនូវពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវស្វាមីដែលមានព្យាយាមប្រឹងប្រែង ស្ត្រីណាជាករិយានៃបុរសមានសភាពដូច្នេះស្ត្រីនោះហៅថា អយ្យាករិយា ។ ស្ត្រីណាមានសេចក្តីអនុគ្រោះនូវប្រយោជន៍សព្វៗកាល ចេះរក្សាប្តីដូចជាមាតារក្សាកូន ទាំងរក្សានូវទ្រព្យដែលស្វាមីនោះបានមកអំពីទីនោះៗ ស្ត្រីណាជាករិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា មាតាករិយា ។ ស្ត្រីមានសេចក្តីគោរពក្នុងស្វាមីរបស់ខ្លួនដូចប្អូនស្រីគោរពបងប្រុស មានសេចក្តីអៀនខ្មាស ប្រព្រឹត្តទៅតាម

អំណាចនៃកស្តា ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា ភគិនីភរិយា ។ ស្ត្រីណាក្នុងលោកនេះបាន ឃើញនូវប្តីហើយក៏រីករាយ ដូចជាសម្លាញ់បានឃើញសម្លាញ់ ដែលមកអស់កាលយូរ ស្រីនោះ បរិបូណ៌ដោយត្រកូលមាន សីលធម៌ ជាស្ត្រីមានវត្តប្រតិបត្តិក្នុងប្តី ស្ត្រីណាជាភរិយានៃ បុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា សខីភរិយា ។ ស្ត្រីដែលស្វាមីជេរវាយគំរាមដោយដំបង មិនមានចិត្តប្រទូស្ត វិញ ចេះអត់សង្កត់ដល់ប្តី មិនក្រោធ ប្រព្រឹត្តទៅតាមអំណាច នៃកស្តា ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា ទាសីភរិយា ដូច្នេះ ។

ម្នាលនាងសុជាតាភរិយារបស់បុរសមាន ៧ ពួកនេះឯង បណ្តាភរិយា ៧ ពួកនោះ ភរិយា ៣ ពួកទាំងនេះគឺ ភរិយាស្មើដោយអ្នកសម្លាប់ ១ ភរិយាស្មើដោយចោរ ១ ភរិយាស្មើដោយចៅហ្វាយ ១ រមែងកើតក្នុងនរក ចំណែកភរិយា ៤ ពួកខាងចុង រមែងកើតក្នុងទេវលោកជាន់និម្មានរតី ។ ( ព្រះសាស្តាកាលត្រាស់ចែកភរិយា ៧ ពួកដោយព្រះគាថាហើយទើប ត្រាស់និគមវចនៈដូច្នេះថា )

ភរិយាណាក្នុងលោកនេះដែលហៅថា វធកាក្តី ហៅថា ចោរីក្តី ហៅថា អយ្យាក្តី ភរិយាទាំងនោះមានសភាពជាស្ត្រីទ្រុស្តសីល រឹងរូស មិនមានសេចក្តីគោរព លុះបែកធ្លាយរាងកាយស្លាប់ទៅ

រមែងទៅកាន់នរក ។ កិរិយាណាក្នុងលោកនេះដែលហៅថា
មាតាក្តី ភគិនីក្តី សខីក្តី ទាសីក្តីកិរិយាទាំងនោះជាស្ត្រីសង្រួម
អស់កាលជាយូរអង្វែង ព្រោះតាំងនៅក្នុងសីលធម៌ លុះបែក
ធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់សុគតិ ដូច្នេះ ។

កាលព្រះសាស្តាទ្រង់សម្តែងកិរិយា ៧ ពួកដោយប្រការយ៉ាងនេះហើយ នាងសុជាតា បានតាំងនៅក្នុងសោតាបត្តិផល ។ កាលព្រះសាស្តាត្រាស់ថា ម្នាលនាងសុជាតាបណ្តាកិរិយាទាំង ៧ ពួកនេះ នាងជាកិរិយាពួកណា ទើបនាងសុជាតាក្រាបទូលថា ខ្ញុំម្ចាស់ សូមជាកិរិយាស្មើដោយទាសៈចុះហើយថ្វាយបង្គំសូមខមាទោសព្រះតថាគត ។ ព្រះសាស្តាទ្រង់ទូន្មាននាងសុជាតាដែលជាកូនប្រសារស្រី ដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះ ដោយប្រការដូច្នេះទ្រង់ធ្វើភត្តកិច្ចស្រេចហើយយាងទៅកាន់វត្តជេតពន កាលភិក្ខុសង្ឃសម្តែងវត្តហើយទើបយាងចូលកាន់ព្រះគន្ធកុដិ ។ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាដល់ព្រះគុណរបស់ព្រះសាស្តាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់ទូន្មាននាងសុជាតាដែលជាកូនប្រសារស្រី ដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះឲ្យតាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុនតថាគតក៏បានទូន្មាននាងសុជាតាដោយ

ឱវាទត្រឹមតែម្តងប៉ុណ្ណោះដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងព្រះឧទរ របស់អគ្គមហេសីនៃព្រះបាទព្រហ្មទត្តនោះ លុះចម្រើនវ័យហើយបានសិក្សាសិល្បៈទាំងពួងក្នុងនគរតក្កសិលា កាលព្រះរាជបិតាសោយទិវង្គតក៏បានតាំងនៅក្នុងរាជសម្បត្តិ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ដោយស្មើ ។ ព្រះមាតារបស់ព្រះពោធិសត្វនោះជាអ្នកច្រើនទៅដោយសេចក្តីក្រោធ កាចគ្រោតគ្រាត ចូលចិត្តក្នុងការជេរ ចូលចិត្តក្នុងការបរិភាស ។ ព្រះពោធិសត្វនោះប្រាថ្នានឹងថ្វាយឱវាទដល់ព្រះមាតា ទ្រង់ព្រះតម្រិះថា ការក្រាបទូលពាក្យដែលមិនមានគ្រឿងអាងយ៉ាងនេះមិនសមគួរ ដូច្នេះហើយទើបត្រាច់សម្លឹងរកឧបមាដើម្បីណែនាំព្រះមាតា ។ ថ្ងៃមួយទ្រង់បានយាងទៅកាន់ព្រះរាជឧទ្យាន ព្រះមាតាក៏បានយាងទៅមួយអន្លើដោយព្រះឱរសដូចគ្នា ។ កាលនោះសត្វត្រដេវវិចកំពុងស្រែកយំនៅក្នុងចន្លោះផ្លូវ ។ បរិស័ទរបស់ព្រះពោធិសត្វបានឮសំឡេងនោះ ទើបនាំគ្នាបិតត្រចៀកហើយពោលថា បក្សីនេះមានសំឡេងគ្រោតគ្រាត អ្នកកុំយំទៀតឡើយ ។ កាលព្រះពោធិសត្វហែហមដោយស្រីបាំ យាងទៅកាន់ព្រះរាជឧទ្យានជាមួយព្រះមាតា មានសត្វតាវៅមួយទុំនៅត្រង់ដើមសាលព្រឹក្សមួយដើមមានផ្ការីកស្គុសស្គាយ បន្លឺសំឡេងដោយសំនៀងដ៏ពីរោះ មហាជនកាន់ភាំងក្នុងសំឡេងនោះផ្គងអញ្ជលីពោលថាបក្សីនេះមានសំឡេងទន់ភ្លន់ក្រអួនក្រអៅ ចូរអ្នកយំទៀត

ចុះ ហើយអើតកន្ទៀងត្រចៀក ឈរសម្លឹងមើល ។ លំដាប់នោះព្រះពោធិសត្វទ្រង់បានជ្រាបច្បាស់នូវហេតុការណ៍ទាំង ២ នោះហើយទ្រង់ព្រះតម្រិះថា អញអាចធ្វើមាតាឲ្យយល់បានក្នុងកាលឥឡូវនេះ ដូច្នេះហើយទើបក្រាបទូលថា បពិត្រព្រះមាតា មហាជនបានឮសំឡេងសត្វត្រដេវវិចក្នុងចន្លោះផ្លូវពោលថា អ្នកកុំយំឡើយ អ្នកកុំយំឡើយ ហើយបិទត្រចៀកឈ្មោះថាវាចាដែលគ្រោតគ្រាត មិនជាទីស្រឡាញ់របស់បុគ្គលណាមួយឡើយហើយបានត្រាស់ព្រះគាថាទាំងនេះថា

ពួកជនប្រកបដោយសម្បុរ មានសំឡេងពីរោះ មានរូបជាទីស្រឡាញ់គួរមិលមើល តែជាអ្នកមានវាចារឹងរូស មិនជាទីស្រឡាញ់របស់អ្នកផងក្នុងលោកនេះនឹងលោកខាងមុខទេ ។

ព្រះមាតាឃើញមេតាវៅខ្មៅនេះ ដែលមានសម្បុរអាក្រក់ដេរដាសដោយពណ៌ពព្រះអុច ៗ តែជាជាទីស្រឡាញ់របស់សត្វច្រើនដោយសារវាចាពីរោះឬទេ ។

ព្រោះហេតុនោះបុគ្គលគប្បីជាអ្នកមានវាចាល្អិតល្អ ជាអ្នកពោលពាក្យលៃតាមប្រាជ្ញា មិនមានចិត្តរាយមាយរមែងសម្តែងនូវអត្ថនឹងធម៌ ភាសិតរបស់បុគ្គលនោះទើបឈ្មោះថា ពីរោះដូច្នេះ ។

គាថាទាំងនោះមានសេចក្តីដូចតទៅនេះថា បពិត្រព្រះមាតា សត្វទាំងនេះ

ប្រកបដោយកាយមានពណ៌ដូចផ្កាប្រយង្គុជាដើម ឈ្មោះថា **មញ្ជុកា** ព្រោះមានសំឡេងយ៉ាងពីរោះ ឈ្មោះថា **បិយទស្សនា** ព្រោះមានរូបស្អាត តែឈ្មោះថា **ខរវាចា** ព្រោះប្រកបដោយវាចាពុំរាបស្មើ ដែលប្រព្រឹត្តទៅដោយការជេរនិងការបរិភាសជាដើម ដោយហេតុ មិនជាទីស្រឡាញ់របស់មាតាបិតាទើបឈ្មោះថា មិនជាទីស្រឡាញ់នៃអ្នកផងក្នុងលោកនេះនិងលោកខាងមុខ ដូចសត្វត្រដេវវិចដែលមានវាចាគ្រោតគ្រាតក្នុងចន្លោះផ្លូវដូច្នោះ ចំណែកសត្វតាវ៉ៅមានប្រក្រតីពោលពីរោះ ប្រកបដោយវាចាផ្អែមល្ហែម សូម្បីមានរូបមិនស្អាតក៏ជាទីស្រឡាញ់របស់អ្នកផងបានដោយហេតុនោះទើបខ្ញុំសូមពោលទឹងព្រះមាតាថា ព្រះមាតាឃើញមិនមែនឬ សត្វតាវ៉ៅនេះខ្មៅ មានពណ៌មិនស្អាតពព្រុះដោយពណ៌ខ្មៅ ដែលខ្មៅក្រៃលែងជាងពណ៌កាយតែតាវ៉ៅនោះសូម្បីជាសត្វមានសម្បុរកាយមិនស្អាតយ៉ាងនេះក៏គង់ជាទីស្រឡាញ់របស់សត្វទាំងឡាយដ៏ច្រើនព្រោះមានវាចាពីរោះ ។ ព្រោះហេតុនោះសត្វទាំងឡាយមានវាចាគ្រោតគ្រាតរមែងមិនជាទីស្រឡាញ់សូម្បីមាតាបិតាក្នុងលោកដូច្នោះ បុគ្គលដែលប្រាថ្នាឲ្យជាទីស្រឡាញ់របស់ជនដ៏ច្រើនគប្បីជាអ្នកមានវាចារៀបស្មើនិងពីរោះនិងឈ្មោះថា **មន្តភាណី** ព្រោះពោលកំណត់ដោយការគិតពោលគឺបញ្ញា ឈ្មោះថា **អនុទ្ធតោ** ព្រោះពោលពាក្យល្មមប្រមាណ វៀរចាកការរាយមាយផ្តេសផ្តាស ។ បុគ្គលបែបនេះសម្តែងអត្ថនិងធម៌ ពាក្យរបស់បុគ្គលនោះឈ្មោះថាពីរោះ អាស្រ័យហេតុហើយពោលមិនធ្វើអ្នកដទៃឲ្យក្រោធអាក់អន់ ។

ព្រះពោធិសត្វសម្តែងធម៌ដល់ព្រះមាតាដោយគាថា ៣ គាថាទាំងនេះ ដោយប្រការដូច្នេះធ្វើឲ្យព្រះមាតាដឹងខ្លួនបាន ។ ចាប់តាំងអំពីនោះមកព្រះមាតាបានជាអ្នកដល់ព្រមដោយមារយាទ ។ ព្រះពោធិសត្វទ្រង់ធ្វើព្រះមាតាឲ្យអស់ព្យសន៍ដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះ ហើយស្តេចទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះមាតារបស់ព្រះបាទពារាណសីក្នុងកាលនោះ បានមកជានាងសុជាតាក្នុងកាលឥឡូវនេះ ចំណែកព្រះរាជាក្នុងកាលនោះគឺតថាគតនេះឯង ។

## អដ្ឋកថា សុជាតជាតក ចប់

## ឧលូកជាតក

[ ៤០៩ ] ( ក្អែកពោលថា ) ឮថា ពួកញាតិទាំងអស់បានលើកកោសិយៈ ( មៀម ) ឲ្យធ្វើជាធំ ប្រសិនបើពួកញាតិអនុញ្ញាតខ្ញុំសូមនិយាយនូវពាក្យមួយម៉ាត់ ។

[ ៤១០ ] ( ហ្វូងសត្វស្លាបពោលថា ) ម្នាលសម្លាញ់ យើងអនុញ្ញាតហើយ អ្នកចូរនិយាយនូវហេតុនឹងពាក្យដែលជាប់ទាក់ទងដោយបវេណីប៉ុណ្ណោះ ដ្បិតពួកបក្សីក្មេងៗដែលមានប្រាជ្ញាទ្រទ្រង់នូវសេចក្តីរុងរឿងនៅមាន ។

[ ៤១១ ] ( ក្អែកពោលថា ) សូមឲ្យអ្នកទាំងឡាយ មានសេចក្តីចម្រើន ការដែលអភិសេកមៀម មិនពេញចិត្តខ្ញុំទេ អ្នកទាំងឡាយចូរមើលមុខមៀមដែលមិនទាន់ខឹង ( បែបនេះទៅហើយ ) ចំណង់បើខឹងហើយ តើវាធ្វើមុខដូចម្តេចទៅ ។

**ចប់ ឧលូកជាតកទី ១០ ។**

**ចប់ បទុមវគ្គទី ២ ។**

**ឧទ្ទាននៃបទុមវគ្គនោះគឺ**

និយាយអំពីផ្កាឈូកដ៏ឧត្តម ១ ដំរីមានសិរី ១ សមុទ្ទធំ ១ ប្រាសាទ ១ ព្រួញដ៏ប្រសើរ ១ លាញីឈ្មោះកទ្ទលី ១ ដំរី ១ ដើមឈើ ១ វាចារឹងរូស ១ ស្តេចមៀម ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ឧល្ងកជាតក

[ ៤០៩-៤១១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការឈ្លោះគ្នារបស់ក្អែកនិងសត្វមៀម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វេហិ កិរ ញាតីហិ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះក្អែកទាំងឡាយនាំគ្នាចឹកស៊ីសត្វមៀមទាំងឡាយក្នុងពេលថ្ងៃ ។ ចំណែកសត្វមៀមទាំងឡាយចាប់តាំងអំពីព្រះអាទិត្យអស្តង្គតក៏នាំគ្នាកាត់ក្បាលរបស់សត្វក្អែកដែលដេកក្នុងទីនោះៗ ធ្វើឲ្យពួកក្អែកទាំងនោះដល់នូវការអស់ជីវិតទៅ ។ លំដាប់នោះភិក្ខុមួយរូបដែលនៅក្នុងបរិវេណមួយកន្ទែងខាងចុងវិហារជេតពនត្រូវរើសក្បាលរបស់ក្អែកដ៏ច្រើនដែលប្រឡាក់ដោយឈាមប្រមាណ ៧-៨ នាឡិ ដែលធ្លាក់ចុះអំពីដើមឈើយកទៅចោលក្នុងវេលាបោសសម្អាត ។ ទើបភិក្ខុនោះប្រាប់សេចក្តីនោះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយបានឮថា ក្នុងវេលាដែលភិក្ខុរូបនោះបោសសម្អាត ត្រូវរើសក្បាលក្អែកទាំងឡាយប្រមាណប៉ុណ្ណេះ ៗ រាល់ថ្ងៃ ។ ព្រះសាស្តាទ្រង់យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក្អែកនិងមៀមក៏បានធ្វើការឈ្លោះទាស់ទែងគ្នាមកហើយ ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ សត្វក្អែកនិងសត្វ

មៀមចងពៀរដល់គ្នានឹងគ្នាក្នុងកាលណាព្រះអង្គ ព្រះសាស្ដាទ្រង់ត្រាស់ថា ចាប់តាំងអំពីកាលដែលជាបឋមកប្បនោះឯង ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល កាលបឋមកប្បមនុស្សទាំងឡាយប្រជុំគ្នាជ្រើសរើសបុរសម្នាក់មានរូបស្អាត ដល់នូវភាពជាអ្នកប្រសើរដោយភាពល្អ បរិបូណ៌ដោយមារយាទ បរិបូណ៌ដោយអាការទាំងពួង តែងតាំងឲ្យជាព្រះរាជា ។ ចំណែកសត្វជើង ៤ ក៏ប្រជុំគ្នាតាំងរាជសីហ៍ឲ្យជាព្រះរាជា ។ ពួកត្រីក្នុងមហាសមុទ្ទក៏បានតាំងត្រីឈ្មោះអានន្ទឲ្យជាព្រះរាជា ។ លំដាប់នោះពួកបក្សីនាំគ្នាប្រជុំគ្នាត្រង់ថ្មដាមួយកន្លែងក្នុងហិមវន្តប្បទេសប្រឹក្សាគ្នាថា ក្នុងពួកមនុស្សព្រះរាជាក៏ប្រាកដ ក្នុងសត្វជើង ៤ និងត្រីទាំងឡាយក៏ប្រាកដដូចគ្នាតែក្នុងរវាងពួកយើងព្រះរាជាមិនមាន ធម្មតាថាការនៅដោយមិនមានទីពឹងរមែងមិនសមគួរសូម្បីពួកយើងក៏គួរបានព្រះរាជា ពួកយើងនឹងកំណត់សត្វមួយដែលសមគួរតាំងទុកក្នុងតំណែងព្រះរាជា ។ បក្សីទាំងឡាយពិចារណារកបក្សីបែបនោះឃើញសត្វមៀមមួយក៏ពេញចិត្តទើបពោលថា យើងពេញចិត្តក្នុងបក្សីនេះ ។ លំដាប់នោះបក្សីមួយទើបប្រកាសឡើង ៣ ដង ដើម្បីសួង់អធ្យាស្រ័យបក្សីគ្រប់គ្នា ។ កាលបក្សីនោះប្រកាស ២ ដង ក៏ស្ងប់ស្ងៀមក្នុងវេលាប្រកាសវារៈទី ៣ ក្អែកមួយក្រោកឡើងពោលថា មុននឹងអភិសេកជាព្រះរាជានេះមុខរបស់សត្វមៀមមិនទាន់ក្រោធគង់បែបនេះ កាលមៀមក្រោធមុខនឹងដូចម្តេចពួកយើងត្រូវសត្វមៀមនេះក្រោធ ក្រឡេកមើលហើយ នឹងផ្អើលក្នុងទីនោះ

មួយរំពេច ដូចអំបិលដែលដាក់ក្នុងអំបែងក្តៅដូច្នោះ ការតែងតាំងសត្វមៀម នេះឲ្យជាព្រះរាជាមិនគាប់ចិត្តខ្ញុំទេ កាលប្រកាសសេចក្តីនេះទើបពោលគាថាទី ១ ថា

ឮថា ពួកញាតិទាំងអស់បានលើកកោសិយៈ ( មៀម ) ឲ្យ
ធ្វើជាធំ ប្រសិនបើពួកញាតិអនុញ្ញាត ខ្ញុំសូមនិយាយនូវពាក្យ
មួយម៉ាត់ ដូច្នេះ ។

អត្ថនៃគាថានោះថា ខ្ញុំបានស្តាប់ការពោលប្រកាសដែលកំពុងប្រព្រឹត្តទៅ នោះទើបសូមពោលបានឮថា ពួកញាតិដែលមកប្រជុំគ្នាទាំងអស់នេះនឹងតាំងសត្វមៀមនេះឲ្យជាព្រះរាជា បើពួកញាតិអនុញ្ញាតខ្ញុំសោតខ្ញុំសូមពោលពាក្យមួយម៉ាត់ដែលគប្បីពោលក្នុងសមាគមនេះ ។

លំដាប់នោះសត្វទាំងឡាយកាលនឹងអនុញ្ញាតក្អែកនោះ ទើបពោលគាថាទី ២ ថា

ម្នាលសម្លាញ់ យើងអនុញ្ញាតហើយ អ្នកចូរនិយាយនូវហេតុ
នឹងពាក្យដែលជាប់ទាក់ទងដោយបវេណីប៉ុណ្ណោះ ដ្បិតពួកបក្សី
ក្មេងៗដែលមានប្រាជ្ញាទ្រទ្រង់នូវសេចក្តីរុងរឿងនៅមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភណ សម្ម អនុញ្ញាតោ** សេចក្តីថា ក្អែកសម្លាញ់ ពួកយើងអនុញ្ញាតអ្នកចូរនិយាយនូវពាក្យដែលគួរនិយាយចុះ ។ បទថា **អត្ថំ ធម្មញ្ច កេវលំ** សេចក្តីថា កាលបើអ្នកពោល ចូរពោលកុំឲ្យលះហេតុនិងពាក្យដែលមានតាមបវេណីឡើយ ។ បទថា **បញ្ញវន្តោ**

**ជុតិន្ធរា** សេចក្តីថា ពួកបក្សីកម្ទោះៗ ដែលសម្បូរដោយបញ្ញានិងទ្រទ្រង់នូវពន្លឺនៃញាណនិងវិជ្ជានៅមានដូចគ្នា ។

ក្អែកនោះដែលពួកបក្សីអនុញ្ញាតយ៉ាងនោះហើយទើបពោលគាថាទី ៣ ថា

សូមឲ្យអ្នកទាំងឡាយមានសេចក្តីចម្រើន ការដែលអភិសេក
មៀម មិនពេញចិត្តខ្ញុំទេ អ្នកទាំងឡាយចូរមើលមុខមៀម
ដែលមិនទាន់ខឹង ( បែបនេះទៅហើយ ) ចំណង់បើខឹង
ហើយតើវាធ្វើមុខដូចម្តេចទៅ ដូច្នេះ ។

អត្ថនៃគាថានោះថា សូមសេចក្តីចម្រើនមានដល់អ្នកទាំងឡាយ ការដែលអ្នកទាំងឡាយធ្វើអភិសេកសត្វមៀមដោយប្រកាស ៣ ដងនោះ ខ្ញុំមិនពេញចិត្ត អ្នកទាំងឡាយចូរមើលមុខរបស់សត្វមៀមនេះ ដែលចិត្តល្អនៅមិនទាន់ក្រោធក្នុងខណៈនេះ យើងមិនដឹងថា សត្វមៀមនេះក្រោធហើយនឹងធ្វើមុខដូចម្តេច ការតាំងសត្វមៀមឲ្យជាធំនេះ ទើបខ្ញុំមិនពេញចិត្តដោយប្រការទាំងពួង ។

ក្អែកនោះកាលពោលយ៉ាងនេះហើយហើរស្រែកទៅក្នុងអាកាសថា ខ្ញុំមិនពេញចិត្តទេ ខ្ញុំមិនពេញចិត្តទេ ។ ចំណែកសត្វមៀម ក៏ហើរឡើងដេញជាប់តាមសត្វក្អែកនោះទៅ ។ តាំងអំពីនោះមកទើបសត្វក្អែកនិងសត្វមៀមជាអ្នកចងពៀរដល់គ្នានឹងគ្នា ។ សត្វទាំងឡាយតាំងសុវណ្ណហង្សឲ្យជាព្រះរាជាហើយនាំគ្នាជៀសចេញទៅ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់

ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈមហាជនបានសម្រេចសោតាបន្ន ជាដើម ហើយទ្រង់ប្រជុំជាតកថា ហង្សព្រោតកដែលបានទទួលអភិសេកឲ្យ ជាព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ឧលូកជាតក ចប់**

**បទុមវគ្គ ចប់**

# ឧទបានវគ្គ

## ឧទបានទូសកជាតក

[ ៤១២ ] ( ឥសីពោធិសត្វសួរថា ) ម្នាលសម្លាញ់ ហេតុអ្វីបានជាអ្នកប្រទូស្តអណ្តូងទឹកដែលបុគ្គលធ្វើបានដោយក្ររបស់ឥសីអ្នកនៅក្នុងព្រៃប្រព្រឹត្តតបធម៌អស់រាត្រីដ៏អង្វែង ។

[ ៤១៣ ] ( ចចកពោលថា ) ពួកយើងផឹកទឹកក្នុងទីណាហើយជុះនោមបំផ្លាញ ( ទីនោះ ) នេះជាធម្មតារបស់ចចកទាំងឡាយ នេះជាធម្មតារបស់បិតានិងជីតា អ្នកមិនគួរពោលទោសចំពោះធម្មតានោះ ។

[ ៤១៤ ] ( ពោធិសត្វពោលថា ) អាការៈនេះធម្មតា របស់ពួកអ្នកណា ចំណង់បើអាការៈមិនមែនជាធម្មតានឹងប្រាកដដូចម្តេចទៅ យើងសូមកុំឲ្យជួបប្រទះនឹងអាការៈជាធម្មតាឬមិនមែនជាធម្មតារបស់ពួកនោះ ក្នុងកាលណាឡើយ ។

**ចប់ ឧទបានទូសកជាតក ទី ១ ។**

# ឧទបានទូសកវគ្គ

## អដ្ឋកថា ឧទបានទូសកជាតក

[ ៤១២-៤១៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចចកដែលទម្លាយអណ្តូងទឹកមួយក្បាល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អារញ្ញកស្ស ឥសិនោ** ដូច្នេះជាដើម ។

បានឮថា ចចកមួយប្រទូស្តអណ្តូងទឹករបស់ភិក្ខុសង្ឃដោយការបន្ទោបង់ឧច្ចារៈនិងបស្សាវៈដាក់ហើយជៀសចេញទៅ ។ ថ្ងៃមួយសាមណេរទាំងឡាយយកដុំដីគ្រវែងចចកនោះ ដែលមកជិតអណ្តូងទឹកឲ្យបានទទួលសេចក្តីលំបាក ។ ចាប់តាំងអំពីនោះមកចចកនោះសូម្បីត្រឡប់មកកាន់ទីនោះទៀត ក៏មិនសម្លឹងមើល ។ ភិក្ខុទាំងឡាយដឹងហេតុនោះទើបសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ចចកដែលទម្លាយអណ្តូងទឹក តាំងពីពួកសាមណេរធ្វើឲ្យបានទទួលសេចក្តីលំបាក សូម្បីត្រឡប់មកទៀត ក៏មិនសម្លឹងមើល ។ ព្រះសាស្តាទ្រង់យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចចកនេះប្រទូស្តអណ្តូងទឹក មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏បានជាអ្នកប្រទូស្តអណ្តូងទឹកដូចគ្នាហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលក្នុងនគរពារាណសី ព្រៃឥសិបតនៈនេះមានអណ្តូងទឹកនេះឯង ។ ក្នុងកាលនោះព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរ

ពារាណសី លុះចម្រើនវ័យហើយក៏បួសជាឥសី ចោមរោមដោយពួកឥសី សម្រេចការនៅក្នុងព្រៃឥសិបតនៈ ។ ក្នុងកាលនោះចចកមួយប្រទូស្តអណ្តូងទឹកនេះឯងហើយជៀសចេញទៅ ។ ថ្ងៃមួយតាបសទាំងឡាយព័ទ្ធចចកមួយនោះចាប់ចចកបានដោយឧបាយឯណាមួយ ទើបនាំទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វកាលនឹងចរចាប្រាស្រ័យជាមួយចចកនោះទើបពោលគាថាទី ១ ថា

ម្នាលសំឡាញ់ ហេតុអ្វីបានជាអ្នកប្រទូស្តអណ្តូងទឹក ដែលបុគ្គលធ្វើបានដោយក្ររបស់ឥសីអ្នកនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌អស់រាត្រីដ៏អង្វែង ដូច្នេះ ។

អត្ថនៃព្រះគាថានោះថា នែចចកសម្លាញ់ ហេតុអ្វី គឺដើម្បីប្រយោជន៍អ្វីទើបអ្នកបន្ទោបង់ឧច្ចារៈប្រទូស្តដោយមូត្រនិងករីសៈនូវអណ្តូងទឹក ដែលធ្វើបានដោយលំបាក គឺដែលឲ្យសម្រេចបានដោយលំបាករបស់អ្នកឈ្មោះថានៅព្រៃព្រោះភាពជាអ្នកនៅក្នុងព្រៃ ដែលបានឈ្មោះថា **ឥសិនោ** ព្រោះជាអ្នកស្វែងរកគុណ ( ធំ ) ឈ្មោះថា **តបស្សិនោ** ព្រោះអាស្រ័យតបៈអស់កាលដ៏យូរ អធិប្បាយថា ហេតុអ្វីទើបអ្នកបន្ទោបង់ គឺធ្វើមូត្រនឹងករីសៈឲ្យធ្លាក់ចុះទៅក្នុងអណ្តូងទឹកនេះ ។

ចចកបានស្តាប់ដូច្នោះទើបពោលគាថាទី ២ ថា

ពួកយើងផឹកទឹកក្នុងទីណាហើយជុះនោមបំផ្លាញ ( ទីនោះ ) នេះជាធម្មតា របស់ចចកទាំងឡាយ នេះជាធម្មតា របស់បិតា

និងជីតា អ្នកមិនគួរពោលទោសចំពោះធម្មតានោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯស ធម្មោ** បានដល់ នោះជាសភាវៈ ។ ដោយបទថា **យំ បិវិត្វា ឱហាទាមសេ** នេះលោកសម្ដែងថា នែសម្លាញ់ ពួកយើងផឹកទឹកក្នុងទីណារមែងបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះចំពោះទីនោះឯង នេះជាធម្មតារបស់ពួកយើងដែលជាចចក ។ បទថា **បិតុបិតាមហំ** សេចក្ដីថា នេះជាធម្មតារបស់មាតាបិតានិងជីដូនជីតារបស់យើងទាំងឡាយ ។ បទថា **ន តំ ឧជ្ឈាតុមរហសិ** សេចក្ដីថា លោកមិនគួរលើកទោសធម្មតា គឺសភាវៈនោះដែលមកដោយប្រពៃណីរបស់ពួកយើង គឺលោកមិនគួរក្រោធក្នុងសេចក្ដីនេះ ។

ព្រះពោធិសត្វទើបពោលគាថាទី ៣ ដល់ចចកនោះថា

អាការៈនេះធម្មតារបស់ពួកអ្នកណា ចំណង់បើអាការៈមិនមែន
ជាធម្មតានឹងប្រាកដដូចម្ដេចទៅ យើងសូមកុំឲ្យជួបប្រទះនឹង
អាការៈជាធម្មតាឬមិនមែនជាធម្មតារបស់ពួកនោះ ក្នុងកាល
ណាឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មា វោ** សេចក្ដីថា ក្នុងកាលណាៗ សូមឲ្យពួកយើងកុំបានឃើញធម្មតាឬមិនមែនធម្មតារបស់ពួកអ្នកទៀតឡើយ ។

ព្រះមហាសត្វកាលឲ្យឱវាទដល់ចចកនោះយ៉ាងនេះហើយ ទើបពោលថា អ្នកកុំត្រឡប់មកកាន់ទីនេះទៀតឡើយ ។ ចាប់តាំងអំពីនោះចចកនោះសូម្បីត្រឡប់មកទៀតក៏មិនសម្លឹងមើល ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយហើយទ្រង់ប្រជុំជាតកថា ចចកដែលប្រទូស្តអណ្តូងទឹកក្នុងកាលនោះ បានមកជាចចកក្នុងកាលឥឡូវនេះ ចំណែកតាបសដែលជាគ្រូនៃគណៈតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឧទបានទូសកជាតក ចប់

## ព្យគ្ឃជាតក

[ ៤១៥ ] ( រុក្ខទេវតាពោធិសត្វពោលថា ) សេចក្ដីក្សេមចាកយោគៈ គឺសេចក្ដីសុខកាយ សុខចិត្តរមែងសាបសូន្យទៅព្រោះប្រឡូកប្រឡំដោយបាបមិត្តណា បណ្ឌិតគប្បីញាំញីនូវបាបមិត្តនោះជាមុនហើយគប្បីរក្សា ( ខ្លួន ) ដូចបុគ្គលកាលរក្សានូវភ្នែកដូច្នោះ ។

[ ៤១៦ ] សេចក្ដីក្សេមចាកយោគៈ រមែងចម្រើនឡើងព្រោះប្រឡូកប្រឡំដោយកល្យាណមិត្តណា បណ្ឌិតគប្បីធ្វើនូវការប្រព្រឹត្តក្នុងកិច្ចទាំងពួងឲ្យស្មើនឹងខ្លួន ។

[ ៤១៧ ] ( ទេវតាពាលពោលថា ) នែខ្លានិងសីហៈ អ្នកទាំងឡាយចូរមក ចូរត្រឡប់ទៅកាន់ព្រៃធំវិញចុះ កុំឲ្យមហាជនកាប់ព្រៃរបស់យើង ព្រោះតែព្រៃមិនមានខ្លា កុំឲ្យខ្លានិងសីហៈជាសត្វមិនមានព្រៃឡើយ ។

**ចប់ ព្យគ្ឃជាតកទី ២ ។**

## អដ្ឋកថា

## ព្យគ្ឃជាតក

[ ៤១៥-៤១៧ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកោកាលិកភិក្ខុ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យេន មិត្តេន សំសគ្គា** ដូច្នេះជាដើម ។ រឿងព្រះកោកាលិកៈនិងមានច្បាស់ក្នុងតក្ការិយជាតក តេរសកនិបាត ។

ព្រះកោកាលិកៈគិតថានឹងទៅនាំព្រះសារីបុត្តនិងព្រះមោគ្គល្លានមក ដូច្នេះហើយទើបចេញអំពីកាសិករដ្ឋទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាហើយចូលទៅរកព្រះថេរៈទាំង ២ពោលថា នែអាវុសោ មនុស្សអ្នកដែនហៅរកលោកទាំងឡាយ មកចុះយើងទាំងឡាយនឹងទៅជាមួយគ្នា ។ ព្រះថេរៈទាំង ២ ពោលថា ទៅចុះលោកម្ចាស់ ពួកយើងមិនទៅទេ ។ ព្រះកោកាលិកៈនោះដែលព្រះថេរៈទាំង ២ បដិសេធហើយ ទើបត្រឡប់ទៅតែម្នាក់ឯង ។ លំដាប់នោះភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះកោកាលិកៈមិនអាចប្រព្រឹត្តទៅរួម ឬវៀរចាកព្រះសារីបុត្តនិងព្រះមោគ្គល្លាន សូម្បីនៅរួមក៏មិនបាន សូម្បីព្រាត់ប្រាសក៏មិនបាន ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងឈ្មោះអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន កោកាលិកភិក្ខុនេះមិនអាចនៅរួមឬវៀរចាកសារីបុត្តនិងមោគ្គល្លានបានឡើយ ។ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតា នៅក្នុងដងព្រៃមួយកន្លែង ។ ក្នុងទីមិនឆ្ងាយអំពីវិហាររបស់ព្រះពោធិសត្វនោះ មានរុក្ខទេវតាមួយអង្គនៅត្រង់ដើមឈើជាធំប្រចាំព្រៃ ( ស្តេចឈើ ) មួយកន្លែង ។ សីហៈនិងខ្លាធំនៅក្នុងដងព្រៃ

នោះ ។ ព្រោះខ្លាចសីហៈខ្លាធំទាំងនោះ បុគ្គលណាមួយទើបមិនអាចភ្ជួរស្រែ មិនកាត់ដើមឈើ ក្នុងដងព្រៃនោះ ។ ឈ្មោះថា បុគ្គលដែលអាចក្រឡេក មើលរមែងមិនមាន ។ ក៏សីហៈនិងខ្លាធំទាំងនោះសម្លាប់ម្រឹគទាំងឡាយមាន ប្រការផ្សេងៗ ទំពាស៊ីចោលវត្ថុដ៏សេសអំពីការទំពាស៊ីទុកក្នុងទីនោះឯង ហើយក៏ជៀសចេញទៅ ។ ដងព្រៃនោះ ក៏មានក្លិនសាកសពដែលមិនស្អាត ។ លំដាប់នោះរុក្ខទេវតាក្រៅអំពីនេះ ជាទេវតាល្ងង់ខ្លៅមិនដឹងហេតុនិងមិនមែន ហេតុ ថ្ងៃមួយបានពោលចំពោះព្រះពោធិសត្វថា សម្លាញ់ ដងព្រៃមានក្លិន សាកសពដែលមិនស្អាតដល់ពួកយើង ព្រោះអាស្រ័យសីហៈនិងខ្លាធំនេះ ខ្ញុំ នឹងដេញសីហៈនិងខ្លាធំនេះឲ្យគេចទៅ ។ ព្រះពោធិសត្វពោលថា នែសម្លាញ់ ព្រោះអាស្រ័យសីហៈនិងខ្លាធំទាំង ២ នេះទើបពួកយើងរក្សាវិមានបានកាល សីហៈនិងខ្លាធំគេចទៅហើយវិមានរបស់ពួកយើងនឹងវិនាស ព្រោះពួកមនុស្ស កាលមិនឃើញស្នាមជើងរបស់សីហៈនិងខ្លាធំទាំងឡាយ ក៏នឹងកាប់ព្រៃទាំង អស់ធ្វើឲ្យជាវាលស្រឡះហើយភ្ជួរស្រែ អ្នកកុំពេញចិត្តយ៉ាងនេះឡើយ ។ ហើយពោលគាថា ២ ជាដំបូងថា

សេចក្តីក្សេមចាកយោគៈ គឺសេចក្តីសុខកាយ សុខចិត្ត រមែងសាបសូន្យទៅ ព្រោះប្រឡូកប្រឡំដោយបាបមិត្តណា បណ្ឌិតគប្បីញាំញីនូវបាបមិត្តនោះជាមុន ហើយគប្បីរក្សា

( ៦៨ ) ដូចបុគ្គលកាលរក្សានូវភ្នែកដូច្នោះ ។

សេចក្តីក្សេមចាកយោគៈ រមែងចម្រើនឡើងព្រោះប្រឡូក

ប្រឡំដោយកល្យាណមិត្តណា បណ្ឌិតគប្បីធ្វើនូវការប្រព្រឹត្ត

ក្នុងកិច្ចទាំងពួងឲ្យស្មើនឹងខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេន មិត្តេន សំសគ្គា** បានដល់ ព្រោះហេតុនៃការប្រឡូកប្រឡំ គឺព្រោះហេតុនៃការប្រឡូកប្រឡំជាមួយបាបមិត្តណា អធិប្បាយថា ព្រោះការប្រឡូកប្រឡំ ៥ ប្រការ គឺទស្សនសំសគ្គៈ ប្រឡូកប្រឡំដោយការឃើញ សវនសំសគ្គៈ ប្រឡូកប្រឡំដោយការស្ដាប់ កាយ-សំសគ្គៈ ប្រឡូកប្រឡំដោយកាយ សមុល្លាបសំសគ្គៈ ប្រឡូកប្រឡំដោយការចរចានិងបរិភោគសំសគ្គៈ ប្រឡូកប្រឡំដោយការបរិភោគ ។ បទថា **យោគក្ខេមោ** បានដល់ សេចក្ដីសុខផ្លូវកាយនិងសេចក្ដីសុខផ្លូវចិត្ត ។ ពិតហើយសេចក្ដីសុខផ្លូវកាយនិងសេចក្ដីសុខផ្លូវចិត្តនោះ លោកបំណងយកថាជាយោគក្ខេមៈ សេចក្ដីក្សេមចាកយោគៈ តែក្នុងទីនេះព្រោះជាការក្សេមចាកយោគៈ គឺទុក្ខ ។ បទថា **វិហីយតិ** បានដល់ រមែងវិនាស ។ បទថា **បុព្វេវជ្ឈាភវន្តស្ស រក្ខេ អក្ខីវ បណ្ឌិតោ** សេចក្ដីថា បុរសដែលជាបណ្ឌិត គប្បីរក្សាលាភយសនិងជីវិតរបស់ខ្លួនដែលបាបមិត្តនោះគ្រប់គ្រង គឺដែលបាបមិត្តនោះបានគ្រប់គ្រងទុក ដោយអាការៈដែលបាបមិត្តនោះគ្រប់គ្រងលាភយសនិងជីវិតនោះមិនបាន ដូចរក្សាកែវភ្នែកទាំង ២ របស់ខ្លួនដូច្នោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **យេន** បានដល់ ព្រោះហេតុ គឺព្រោះហេតុប្រឡូកប្រឡំជាមួយកល្យាណមិត្តណា ។ បទថា **យោគក្ខេមោ បវឌ្ឍតិ** សេចក្ដីថា សេចក្ដីសុខផ្លូវកាយនិងសេចក្ដីសុខផ្លូវ

ចិត្តរមែងចម្រើន ។ បទថា **ករេយ្យត្តសមំ វុត្តឹ** សេចក្តីថា បុរសដែលជាបណ្ឌិតគប្បីធ្វើកិច្ចទាំងពួងទាំងគប្បីធ្វើឲ្យក្រៃលែងក្នុងកិច្ចទាំងពួងរបស់កល្យាណមិត្តនោះដូចធ្វើការចិញ្ចឹមជីវិតនិងការប្រើគ្រឿងឧបភោគនិងបរិភោគរបស់ខ្លួនដូច្នោះ គឺមិនគប្បីធ្វើនូវការឆ្ការរបោកទាបឡើយ ។

កាលព្រះពោធិសត្វពោលហេតុយ៉ាងនេះ ទេវតាដែលល្ងង់ខ្លៅនោះ មិនពិចារណាឡើយ ថ្ងៃមួយសម្តែងរូបដែលគួរខ្លាចធ្វើឲ្យសីហៈនិងខ្លាធំទាំងនោះជៀសចេញទៅ ។ ពួកមនុស្សមិនឃើញស្នាមជើងរបស់សីហៈនិងខ្លាធំទាំងនោះដឹងបានថា ពួកសីហៈនិងខ្លាធំនេះទៅកាន់ដងព្រៃដទៃ ដូច្នេះហើយទើបកាប់ដងព្រៃបានមួយផ្នែក ។ ទេវតាល្ងង់ខ្លៅចូលទៅរកព្រះពោធិសត្វហើយពោលថា នែសម្លាញ់ ខ្ញុំមិនធ្វើតាមពាក្យរបស់អ្នក ធ្វើសីហៈនិងខ្លាធំទាំងឡាយឲ្យជៀសចេញទៅ ឥឡូវនេះមនុស្សទាំងឡាយដឹងថា សីហៈនិងខ្លាធំទាំងនោះជៀសចេញទៅហើយទើបនាំគ្នាកាប់ព្រៃ យើងគួរធ្វើដូចម្តេច ព្រះពោធិសត្វពោលថា ឥឡូវនេះសីហៈនិងខ្លាធំទាំងនោះនៅក្នុងដងព្រៃនោះ ចូរអ្នកទៅនាំសីហៈនិងខ្លាធំទាំងនោះមក ។ រុក្ខទេវតានោះទៅកាន់ដងព្រៃនោះឈរផ្គងអញ្ជលីខាងមុខសីហៈនិងខ្លាធំទាំងនោះហើយពោលគាថាទី ៣ ថា

នែខ្លានិងសីហៈអ្នកទាំងឡាយ ចូរមក ចូរត្រឡប់ទៅកាន់ព្រៃ
ធំវិញចុះ កុំឲ្យមហាជនកាប់ព្រៃរបស់យើង ព្រោះតែព្រៃមិន
មានខ្លា កុំឲ្យខ្លានិងសីហៈជាសត្វមិនមានព្រៃឡើយ ដូច្នេះ ។

ទេវតាហៅសីហៈនិងខ្លាធំទាំង ២ នោះដោយឈ្មោះថា ខ្លាធំទើបពោល

ថា **ព្យគ្ឃា** ក្នុងគាថានោះ ។ បទថា **ឆិវត្តថ្ថា** បានដល់ សូមត្រឡប់ ។ បទថា **បច្ចុបេថ មហាវនំ** សេចក្តីថា អ្នកទាំងឡាយ សូមចូលទៅកាន់ព្រៃធំនោះ គឺសូមត្រឡប់ទៅវិញ ។ ម្យ៉ាងទៀតព្រះបាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **មា នោ វនំ ឆិន្ទិ និព្យគ្ឃំ** សេចក្តីថា ឥឡូវនេះមនុស្សទាំងឡាយកុំបានកាប់ព្រៃ ដែលជាលំនៅរបស់ពួកយើង ធ្វើឲ្យជាព្រៃប្រាសចាកសីហៈនិងខ្លាធំព្រោះមិនមានពួកលោក ។ បទថា **ព្យគ្ឃា មាហេសុ និព្វនា** សេចក្តីថា ស្តេចសីហៈនិងខ្លាធំទាំង ២ ដូចអ្នកឈ្មោះថាជាអ្នកមិនមានព្រៃ គឺកុំជាអ្នកវៀរចាកព្រៃដែលជាលំនៅព្រោះគេចទៅអំពីស្ថានទីនៅរបស់ខ្លួន ។

សីហៈនិងខ្លាធំទាំង ២ នោះត្រូវទេវតានោះអង្វរយ៉ាងនេះក៏បដិសេធថា សូមអ្នកទៅចុះ ពួកខ្ញុំមិនទៅទេ ។ ទេវតាម្នាក់ឯងប៉ុណ្ណោះត្រឡប់មកកាន់ដងព្រៃ ។ ចំណែកមនុស្សទាំងឡាយក៏កាប់ព្រៃទាំងអស់ក្នុងកាល ២-៣ ថ្ងៃនោះឯងធ្វើឲ្យជាស្រែហើយធ្វើកសិកម្ម ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយហើយទ្រង់ប្រជុំជាតកថា ទេវតាដែលមិនឈ្លាសក្នុងកាលនោះ បានមកជាកោកាលិកភិក្ខុក្នុងកាលឥឡូវនេះ សីហៈក្នុងកាលនោះ បានមកជាសារីបុត្ត ខ្លាធំក្នុងកាលនោះ បានមកជាមោគ្គល្លាន ចំណែកទេវតាដែលឈ្លាសក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា ព្យគ្ឃជាតក ចប់

## កច្ចបជាតក

[ ៤១៨ ] ( តាបសពោធិសត្វពោលថា ) បុគ្គលណាហ្ន៎ ដើរមកហាក់ដូចជាបុគ្គលអ្នកមានភត្តដួសស្រេចហើយ ឬដូចជាព្រាហ្មណ៍មានលាភពេញដៃ អ្នកដើរទៅសូមក្នុងទីណា ឬអ្នកចូរទៅរកបុគ្គលណាដែលមានសទ្ធា ។

[ ៤១៩ ] ( ពានរពោលថា ) ខ្ញុំជាស្វាឥតប្រាជ្ញាបានប៉ះពាល់នូវវត្ថុទាំងឡាយដែលគេមិនគួរប៉ះពាល់ សូមលោកម្ចាស់ដោះខ្ញុំឲ្យរួច សូមសេចក្តីចម្រើនចូរមានដល់លោក ខ្ញុំនោះបានរួចហើយនឹងទៅកាន់ភ្នំវិញ ។

[ ៤២០ ] ( ពោធិសត្វពោលថា ) ពួកអណ្តើកជាកស្សបគោត្ត ពួកស្វាជាកោណ្ឌញ្ញគោត្ត ម្នាលកស្សបៈអ្នកចូរលែងកោណ្ឌញ្ញៈ ( ស្វាទ្រុស្តសីលនេះ ) ដែលធ្វើមេថុនកម្មនឹងអ្នក ។

**ចប់ កច្ចបជាតកទី ៣ ។**

## អដ្ឋកថា

## កច្ចបជាតក

[ ៤១៨-៤២០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការស្ងប់រម្ងាប់នៃការទាស់ទែងរបស់អាមាត្យ ២ នាក់របស់ព្រះបាទកោសល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោ នុ វឌ្ឍិតភត្តោវ** ដូច្នេះជាដើម ។ រឿងដែលកើតឡើងក្នុងបច្ចុប្បន្នបានពោលទុកហើយក្នុងទុកនិបាតនោះឯង ។

ចំណែករឿងក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងកាសិករដ្ឋ លុះចម្រើនវ័យហើយរៀនសិល្បសាស្ត្រគ្រប់យ៉ាងក្នុងនគរតក្កសិលា ហើយលះកាមទាំងឡាយចេញបួសជាឥសី សាងអាស្រមបទ នៅត្រង់ច្រាំងស្ទឹងគង្គាជិតហិមវន្តប្បទេស ធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតឡើងក្នុងទីនោះ ហើយលេងឈានសម្រេចការនៅក្នុងទីនោះ ។ បានឮថា ក្នុងជាតកនេះ ព្រះពោធិសត្វជាអ្នកមានខ្ជួនជាកណ្តាលក្រៃលែង បំពេញឧបេក្ខាបារមី ។ កាលព្រះពោធិសត្វនោះអង្គុយនៅត្រង់ទ្វារបណ្ណសាលា ស្វាទ្រុស្តសីលមួយមកដល់ក៏យកអង្គជាតស៊កចូលក្នុងរន្ធត្រចៀកទាំងពីរ ។ ចំណែកព្រះពោធិសត្វក៏មិនបានហាមអង្គុយនៅដោយឧបេក្ខានោះឯង ។ ថ្ងៃមួយ អណ្តើកមួយឡើងមកអំពីទឹកដេកអាំងថ្ងៃហារមាត់ត្រង់ឆ្នេរស្ទឹងគង្គា ។ ស្វាឡេះឡោះនោះ ឃើញដូច្នោះ ទើបស៊កអង្គជាតចូលក្នុងមាត់អណ្តើកនោះ លំដាប់នោះអណ្តើកភ្ញាក់ឡើងទើបខាំអង្គជាតស្វានោះដូចដាក់ទុកក្នុងស្មុកដូច្នោះ ។ វេទនាមានកម្លាំងកើតឡើងដល់ស្វានោះ ។ ស្វាមិនអាចនឹងអត់សង្កត់វេទនាបានទើបគិតថា បុគ្គលណាហ្ន៎នឹងដោះអញចាកទុក្ខនេះ អញនឹងទៅរកបុគ្គលណាល្អ ដូច្នេះហើយទើបរឭកបានថា បុគ្គលដទៃឈ្មោះថាអាចដោះអញចាកទុក្ខនេះ វៀរលែងតាបសចេញហើយរមែងមិនមាន អញគួរនឹងទៅរកតាបសប៉ុណ្ណោះដូច្នេះហើយទើបយកដៃទាំង ២ ទ្រអណ្តើកទៅរកព្រះពោធិសត្វ ។ ព្រះពោធិសត្វកាលធ្វើការចំអកស្វាទ្រុស្តសីលនោះទើបពោលគាថាទី ១ ថា

បុគ្គលណាហ្ន៎ ដើរមកហាក់ដូចជាបុគ្គលអ្នកមានកត្តជួសស្រេច ហើយ ឬដូចជាព្រាហ្មណ៍មានលាភពេញដៃ អ្នកដើរទៅសូមក្នុងទីណា ឬអ្នកចូរទៅរកបុគ្គលណាដែលមានសទ្ធា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ នុ វទ្ធិតភត្តោវ** សេចក្តីថា អ្នកហ្ន៎ដូចបុគ្គលដែលមានកត្ត គឺនោះបុគ្គលណាហ្ន៎ដូចយកដៃទាំង ២ ផ្គងថាសដែលពេញដោយកត្ត ដែលគេជួសទុកពេញថាសមួយដើរមក ។ បទថា **បូរហត្ថោវ ព្រាហ្មណោ** សេចក្តីថា បុគ្គលណាហ្ន៎ ដូចព្រាហ្មណ៍មានលាភពេញដៃព្រោះបានរាយវេទក្នុងខែកត្តិក ។ ព្រះពោធិសត្វ សំដៅយកពានរទើបពោលដូច្នេះ ។ បទថា **កហន្នុ ភិក្ខំ អចរិ** សេចក្តីថា ពានរដ៏ចម្រើន ថ្ងៃនេះអ្នកត្រាច់ទៅរកភិក្ខាចារក្នុងទីណា ។ ដោយបទថា **កំ សទ្ធំ ឧប-សង្កមិ** នេះព្រះពោធិសត្វសម្តែងថា កត្តរបស់អ្នកមានសទ្ធា ដែលគេធ្វើឧទ្ទិសបុព្វ-បេតជនដទៃណាៗ ឬបុគ្គលដែលមានសទ្ធាណាដែលអ្នកចូលទៅរកទេយ្យធម៌នេះអ្នកបានមកអំពីណា ។

ពានរទ្រុស្តសីលបានស្តាប់ដូច្នោះទើបពោលគាថាទី ២ ថា

ខ្ញុំជាស្វាឥតប្រាជ្ញាបានប៉ះពាល់នូវវត្ថុទាំងឡាយ ដែលគេមិនគួរប៉ះពាល់ សូមលោកម្ចាស់ដោះខ្ញុំឲ្យរួច សូមសេចក្តីចម្រើនចូរមានដល់លោក ខ្ញុំនោះបានរួចហើយ នឹងទៅកាន់ភ្នំវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហំ កបិស្មិ ទុម្មេធោ** សេចក្តីថា សូម

សេចក្ដីចម្រើនចូរមានដល់លោកម្ចាស់ ខ្ញុំជាស្វាអាប់ឥតបញ្ញាមានចិត្តមិននឹងន ។ បទថា **អនាមាសានិ អាមសឹ** បានដល់ ពាល់ត្រូវឋានៈដែលមិនគួរពាល់ត្រូវ ។ បទថា **ត្វំ មំ មោចេយ្យ ភទ្ទន្តេ** សេចក្ដីថា សូមសេចក្ដីចម្រើនចូរមានដល់លោកម្ចាស់ដែលមានសេចក្ដីករុណា ការអនុគ្រោះដោះខ្ញុំឲ្យផុតចាកទុក្ខនេះ ។ បទថា **មុត្តោ គច្ឆេយ្យ បព្វតំ** សេចក្ដីថា ខ្ញុំនោះផុតចាកសេចក្ដីវិនាសនេះដោយអានុភាពរបស់លោកម្ចាស់ នឹងទៅកាន់ភ្នំមិនបង្ហាញខ្លួនក្នុងគន្លងចក្ខុរបស់លោកម្ចាស់ទៀតឡើយ ។

ព្រះពោធិសត្វព្រោះសេចក្ដីករុណាក្នុងស្វាកាលនឹងចរចាជាមួយអណ្ដើកទើបពោលគាថាទី ៣ ថា

> ពួកអណ្ដើកជាកស្សបគោត្ត ពួកស្វាជាកោណ្ឌញ្ញគោត្ត ម្នាលកស្សបៈ អ្នកចូរលែងកោណ្ឌញ្ញៈ ( ស្វាទ្រុស្ដសីលនេះ ) ដែលធ្វើមេថុនកម្មនឹងអ្នក ដូច្នេះ ។

គាថានោះមានសេចក្ដីថា ធម្មតាអណ្ដើកទាំងឡាយជាកស្សបគោត្ត ឯស្វាទាំងឡាយជាកោណ្ឌញ្ញគោត្ត កស្សបគោត្តនិងកោណ្ឌញ្ញគោត្តមានសម្ពន្ធគ្នានឹងគ្នាដោយអាវាហៈនិងវិវាហៈ គឺនាំកូនក្រមុំមកកាន់ផ្ទះកូនកំលោះ និងនាំកូនកំលោះទៅកាន់ផ្ទះកូនក្រមុំ ស្វាទ្រុស្ដនិងអ្នក ឬអ្នកនិងស្វាទ្រុស្ដសីលនេះសមគួរនឹងបានធ្វើមេថុនធម្មពោលគឺ កម្មរបស់បុគ្គលទ្រុស្ដសីល ដែលសមគួរដល់មេថុន គឺដែលដូចគ្នានឹងគោត្តធ្វើមកហើយពិតប្រាកដ ព្រោះដូច្នោះអណ្ដើកដែលជាកស្សបគោត្ត ចូរអ្នកលែងស្វាជាកោណ្ឌញ្ញគោត្តចុះ ។

អណ្ដើកបានស្ដាប់ពាក្យរបស់ព្រះពោធិសត្វ មានសេចក្ដីជ្រះថ្លាក្នុងហេតុផលទើបលែងអង្គជាតរបស់ស្វា ។ ចំណែកស្វាគ្រាន់តែរួចផុតប៉ុណ្ណោះបានថ្វាយបង្គំព្រះពោធិសត្វហើយជៀសចេញទៅ ទាំងមិនត្រឡប់សម្លឹងមើលទីនោះទៀត ។ ចំណែកអណ្ដើកថ្វាយបង្គំព្រះពោធិសត្វហើយ បានទៅកាន់លំនៅរបស់ខ្លួននោះឯង ។ សូម្បីព្រះពោធិសត្វ ក៏មិនបានវិនាសចាកឈាន មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយហើយទ្រង់ប្រជុំជាតកថា អណ្ដើកនិងស្វាក្នុងកាលនោះបានមកជាអាមាត្យទាំង ២ នាក់ក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កច្ឆបជាតក ចប់

## លោលជាតក

[ ៤២១ ] ( ព្រាបពោធិសត្វពោលថា ) កុកនេះដូចម្ដេច មានសិរជាសត្វល្អួច មានពពកជាជីតា នៃកុកអ្នកចូរមកអាយ ( ព្រោះ ) ក្អែកជាសម្លាញ់យើងជាសត្វកាច ។

[ ៤២២ ] ( ក្អែកពោលថា ) ខ្ញុំមិនមែនជាកុកមានសិរទេ ខ្ញុំជាក្អែករលោភលន់ អ្នកទើបនឹងមក ចូរមើលខ្ញុំដែលត្រូវគេដកស្លាបព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក ។

[ ៤២៣ ] ( ពោធិសត្វពោលថា ) ម្នាលសម្លាញ់ អ្នកនឹងប្រទះ ( បែបនេះ ) ម្ដងទៀតពុំខានព្រោះថាសីល ( មារយាទ ) របស់អ្នកប្រាកដដូច្នោះ គ្រឿងបរិភោគទាំងឡាយជារបស់នៃមនុស្សមិនមែនសត្វស្លាបបរិភោគបានដោយងាយឡើយ ។

**ចប់ លោលជាតកទី ៤ ។**

## អដ្ឋកថា

## លោលជាតក

[ ៤២១-៤២៣ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុល្មោភល្មោះមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កាយំ ពលាកា សិខិនី** ដូច្នេះជាដើម ។

បានឮថា ព្រះសាស្ដាកាលត្រាស់នឹងភិក្ខុនោះ ដែលត្រូវនាំមកកាន់ធម្ម-

សភាថា ម្នាលភិក្ខុ អ្នកជាបុគ្គលឡេះឡោះក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនអ្នកក៏ជាបុគ្គលឡេះឡោះមកហើយនិងបានដល់នូវការអស់ជីវិតទៅព្រោះភាពជាអ្នកឡេះឡោះ សូម្បីបុរាណកបណ្ឌិតទាំងឡាយក៏បានជាអ្នកវិនាសចាកលំនៅរបស់ខ្លួនព្រោះអាស្រ័យអ្នក ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ចុងភៅក្នុងរោងចុងភៅរបស់សេដ្ឋីក្នុងនគរពារាណសី ចងកំប្រោងសម្រាប់ជាសម្បុកសត្វទុកដើម្បីត្រូវការបុណ្យ ។ ក្នុងកាលនោះព្រះពោធិសត្វកើតក្នុងកំណើតសត្វព្រាប សម្រេចការនៅក្នុងកំប្រោងដែលជាសម្បុកនោះ ។ លំដាប់នោះក្អែកឡេះឡោះមួយហើរមកកាន់រោងចុងភៅបានឃើញត្រីនិងសាច់ប្រភេទប្លែកៗ មានប្រការផ្សេងៗត្រូវចំណង់គ្របសង្កត់គិតថា អញអាស្រ័យបុគ្គលណាហ្ន៎ ទើបនឹងបានឱកាសស៊ីត្រីនិងសាច់ ដូច្នេះហើយកាលកំពុងគិតក៏បានឃើញព្រះពោធិសត្វទើបគិតថា អាត្មាអញអាស្រ័យសត្វព្រាបនេះអាចបានឱកាស ដូច្នេះហើយក្នុងវេលាព្រះពោធិសត្វនោះទៅរកស៊ីក៏ជាប់ទៅតាមខាងក្រោយៗ ។ លំដាប់នោះព្រះពោធិសត្វពោលចំពោះក្អែកនោះថា នែក្អែកយើងមានវត្ថុដទៃជាចំណី អ្នកមានវត្ថុដទៃមួយទៀតជាចំណី ព្រោះហេតុអ្វីទើបអ្នកត្រាច់តាមខ្ញុំ ។ ក្អែកពោលថា បពិត្រលោកម្ចាស់ ខ្ញុំគាប់ចិត្តក្នុងកិរិយារបស់លោក សូម្បីខ្ញុំជាអ្នកមានចំណីមិនដូចលោកក៏ប្រាថ្នាបម្រើលោក ។ ព្រះពោធិសត្វក៏ព្រមទទួល ។ ក្អែកនោះធ្វើដូចត្រាច់ទៅរកចំណីដូចគ្នាក្នុងទីត្រាច់

ទៅរកស៊ីរួមជាមួយព្រះពោធិសត្វ បង្អែបង្អង់តាមក្រោយចឹកអាចម៍គោហើយ ទំពាស៊ីសត្វតូចៗរហូតពេញពោះ ហើយចូលទៅរកព្រះពោធិសត្វពោលថា លោកត្រាច់រកចំណីអស់កាលមានប្រមាណប៉ុណ្ណោះ ការដឹងប្រមាណក្នុងភោជនរមែងសមគួរមិនមែនឬ មកលោកយើងនឹងទៅក្នុងវេលាមិនទាន់ល្ងាចពេក ។ ព្រះពោធិសត្វបាននាំក្អែកនោះទៅកាន់លំនៅ ។ ចុងភៅគិតថា សត្វព្រាបរបស់អញនាំសម្លាញ់មក ដូច្នេះហើយ ទើបចងកំប្រោងអង្កាមទុកក្នុងទីមួយកន្លែងសម្រាប់ក្អែក ។ ចំណែកក្អែកនៅដោយទំនងនោះឯងអស់ ៤-៥ ថ្ងៃ ។ កាលថ្ងៃមួយជនទាំងឡាយនាំត្រីនិងសាច់ជាច្រើនមកឲ្យលោកសេដ្ឋី ។ ក្អែកឃើញដូច្នោះត្រូវសេចក្ដីលោភគ្របសង្កត់ដេកថ្ងូររហូតដល់ទៀបភ្លឺ កាលថ្ងៃរះឡើងព្រះពោធិសត្វពោលនឹងក្អែកថា មកសម្លាញ់ យើងនាំគ្នាទៅរកស៊ីក្អែកពោលថា លោកទៅចុះ ខ្ញុំសង្ស័យថាមានរោគព្រោះអាហារមិនរលាយ ។ ព្រះពោធិសត្វពោលថា នែសម្លាញ់ ធម្មតារោគអាហារមិនរលាយរមែងមិនមានដល់ពួកក្អែកឡើយព្រោះសូម្បីប្រទេះចង្កៀង ដែលលេបចូលទៅនៅក្នុងពោះរបស់ពួកអ្នកត្រឹមតែមួយស្របក់ ឬចំណីគ្រប់យ៉ាងគ្រាន់តែលេបទៅប៉ុណ្ណោះរមែងរលាយទៅអស់ ចូរអ្នកធ្វើតាមពាក្យរបស់ខ្ញុំ អ្នកកុំធ្វើយ៉ាងនេះព្រោះបានឃើញត្រីនិងសាច់ ។ ក្អែកពោលថា បពិត្រលោកម្ចាស់ លោកនិយាយអ្វីយ៉ាងនោះ ខ្ញុំមានសេចក្ដីសង្ស័យថា អាហារមិនរលាយពិតៗ ។ ព្រះពោធិសត្វឲ្យឱវាទក្អែកនោះថា បើយ៉ាងនោះចូរអ្នកកុំប្រមាទហើយជៀសចេញទៅ ។ ចំណែកចុងភៅរៀបចំត្រីនិងសាច់ប្រភេទផ្សេងៗ ស្រេចហើយ

កាលនឹងជម្រះញើសចេញអំពីរាងកាយទើបបានទៅឈរត្រង់ទ្វារ ។ ក្អែកគិតថា ពេលនេះជាពេលគួរទំពាស៊ីសាច់ ដូច្នេះហើយ ទើបហើរទៅទំលើចានសម្រាប់ផ្សំរស ។ ចុងភៅបានឮសំឡេងក្រឹកទើបសម្លឹងមើល ក្រឡេកឃើញក្អែកទើបចូលទៅចាប់ក្អែកមកដករោមទាំងអស់អំពីខ្លួនសល់តែសិរលើក្បាល ហើយបុកខ្ញីនិងម្រេចជាដើម ច្របល់ជាមួយតក្កៈលាបពេញខ្លួនក្អែកនោះបណ្តើរពោលបណ្តើរថា ឯងបំផ្លាញត្រីនិងសាច់របស់សេដ្ឋីពួកយើងឲ្យជារបស់សំណល់ ហើយបោះទៅក្នុងកំប្រោងដែលធ្វើជាសំបុក ។ វេទនាដ៏ពន្លឹកកើតឡើង ។ ព្រះពោធិសត្វត្រឡប់មកអំពីរកចំណីឃើញក្អែកនោះដេកថ្ងូរ កាលនឹងធ្វើការចំអកលេងទើបពោលគាថាទី ១ ថា

កុកនេះដូចម្តេច មានសិរ ជាសត្វល្អ មានពពកជាជីតា
នៃកុកអ្នកចូរមកអាយ ( ព្រោះ ) ក្អែកជាសំឡាញ់យើងជា
សត្វកាច ដូច្នេះ ។

ដោយបទថា **កាយំ ពលាកា សិខិនី** ក្នុងគាថានោះ ព្រះពោធិសត្វកាលនឹងសួរក្អែកនោះទើបពោលថា កុកនេះហេតុអ្វីទើបមានសិរ ព្រោះក្អែកនេះមានពណ៌រាងកាយសដែលលាបដោយតក្កៈយ៉ាងក្រាស់និងព្រោះសិរតាំងនៅខាងលើក្បាលរបស់ក្អែកនោះ ។ ដោយបទថា **ចោរី** នេះ ព្រះពោធិសត្វពោលថា ឈ្មោះថា ជាចោរព្រោះចូលទៅកាន់ផ្ទះរបស់ត្រកូលដែលត្រកូលមិនបានអនុញ្ញាត ឬព្រោះចូលទៅកាន់សម្បុកក្អែកដោយការមិនពេញចិត្តរបស់ក្អែក ។ បទថា **លង្ឃិ បិតាមហា** សេចក្តីថា ផ្គរលាន់ ឈ្មោះថា

**លង្ឃី** ព្រោះលោន់ពួក្នុងអាកាស ធម្មតាកុកទាំងឡាយ រមែងតាំងគភ៌ព្រោះសំឡេងផ្គរលាន់ដោយហេតុនោះ ទើបផ្គរលាន់ជាបិតារបស់កុក ( ទាំងឡាយ ) ។ ផ្គរលាន់ជាបិតារបស់កុកទាំងឡាយដោយហេតុនោះទើបលោកពោលថា **លង្ឃី បិតាមហា** ។ បទថា **ឱរំ ពលាកេ អាគច្ឆ** សេចក្តីថា នែកុក អ្នកចូរមកខាងនេះចុះ ។ ដោយបទថា **ចណ្ឌោ មេ វាយសោ សខា** នេះ ព្រះពោធិសត្វពោលថា ក្អែកសម្លាញ់របស់យើងជាម្ចាស់របស់កំប្រោងជាសត្វកាចគ្រោតគ្រាត ក្អែកនោះមកឃើញអ្នកហើយ នឹងយកចំពុះដូចចុងលំពែងចឹកធ្វើឲ្យដល់នូវសេចក្តីស្លាប់ ព្រោះដូច្នោះចូរអ្នកចុះអំពីកំប្រោងមកផ្លូវនេះ គឺប្រញាប់ចៀសចេញទៅខាងនេះដរាបណាដែលក្អែកនោះនៅមិនទាន់មក ។

ក្អែកកាលស្តាប់ពាក្យនោះទើបពោលគាថាទី ២ ថា

ខ្ញុំមិនមែនជាកុកមានសិរទេ ខ្ញុំជាក្អែករលោរលាំ អ្នកទើបនឹងមក ចូរមើលខ្ញុំ ដែលត្រូវគេដកស្លាប ព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាគតោ** សេចក្តីថា ឥឡូវនេះអ្នកមកអំពីទីរកស៊ីហើយ ចូរសម្លឹងមើលខ្ញុំដែលមានរោមជ្រុះអស់នេះចុះ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបពោលគាថាទី ៣ ថា

ម្នាលសំឡាញ់ អ្នកនឹងប្រទះ ( បែបនេះ ) ម្តងទៀតពុំខាន ព្រោះថាសីល ( មារយាទ ) របស់អ្នកប្រាកដដូច្នោះ គ្រឿង

បរិភោគទាំងឡាយ ជារបស់នៃមនុស្ស មិនមែនសត្វស្លាប
បរិភោគបានដោយងាយឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុន ចាបជ្ជសី សម្ម** សេចក្ដីថា នៃក្អែកសម្លាញ់ អ្នកនឹងបានទទួលទុក្ខបែបនេះទៀត ភាពដែលនឹងផុតចាកទុក្ខដូច្នេះ រមែងមិនមានដល់អ្នកព្រោះហេតុអ្វី ព្រោះប្រក្រតីរបស់អ្នកដូច្នេះនោះគឺជាវត្ថុដែលអាក្រក់លាមកគឺព្រោះប្រក្រតី គឺការប្រព្រឹត្តរបស់អ្នកមានសភាពដូច្នោះ ទើបសមគួរដល់ការបានទទួលតែសេចក្ដីទុក្ខប៉ុណ្ណោះ ។ បទថា **ន ហិ មានុសិកា** សេចក្ដីថា ធម្មតាមនុស្សទាំងឡាយជាអ្នកមានបុណ្យច្រើន សត្វតិរច្ឆានទាំងឡាយមិនមានបុណ្យបែបនោះ ព្រោះហេតុនោះគ្រឿងបរិភោគរបស់មនុស្សទើបបក្សីដែលជាសត្វតិរច្ឆានមិនគួរបរិភោគ ។

ឯព្រះពោធិសត្វ កាលពោលយ៉ាងនេះហើយទើបពោលថា តាំងអំពីនេះទៅខ្ញុំមិនអាចនៅក្នុងទីនេះ កាលពោលហើយក៏បានហើរទៅកាន់ទីដទៃ ។ ចំណែកក្អែកដេកថ្ងូរស្លាប់ក្នុងទីនោះឯង ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុឡេះឡោះនោះ តាំងនៅក្នុងអនាគាមិផល ហើយទ្រង់ប្រជុំជាតកថា ក្អែករលោភលន់ក្នុងកាលនោះ បានមកជាភិក្ខុឡេះឡោះក្នុងកាលឥឡូវនេះ ចំណែកសត្វព្រាបក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា លោលជាតក ចប់**

## រុចិរជាតក

[ ៤២៤ ] ( ពោធិសត្វពោលថា ) កុកនេះជាអ្វី មានសម្បុររលើប មកនៅក្នុងសំបុកក្អែក សំបុកនេះ ជារបស់ក្អែកណា ក្អែកជាសម្លាញ់របស់ខ្ញុំនោះ កាចណាស់ ។

[ ៤២៥ ] ( ក្អែកពោលថា ) ម្នាលសម្លាញ់ស្មើចិត្ត ជាសត្វមានកំណើត ២ ក្រែងអ្នកស្គាល់ខ្ញុំ ដែលជាសត្វមានពូជស្មៅជាភោជន ដែរឬ អ្នកទើបនឹងមក ចូរមើលខ្ញុំដែលគេដកស្លាប ព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក ។

[ ៤២៦ ] ( ពោធិសត្វពោលថា ) ម្នាលសម្លាញ់ អ្នកនឹងប្រទះ ( បែបនេះ ) ម្តងទៀតពុំខានព្រោះថាសីលធម៌របស់អ្នកប្រាកដដូច្នោះ គ្រឿងបរិភោគទាំងឡាយជារបស់មនុស្សមិនមែនសត្វស្លាបបរិភោគបានដោយងាយឡើយ ។

**ចប់ រុចិរជាតកទី ៥ ។**

## អដ្ឋកថា

## រុចិរជាតក

[ ៤២៤-៤២៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឡេះឡោះមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាយំ ពលាកា រុចិរា** ដូច្នេះជាដើម ។

រឿងទាំង ២ គឺរឿងបច្ចុប្បន្ននិងរឿងអតីត ដូចគ្នានឹងរឿងមុននោះឯង ។ តែគាថាផ្សេងគ្នា ។ មានគាថាជាលំដាប់ដូចតទៅនេះថា

ព្រះពោធិសត្វពោលថា

កុកនេះជាអ្វី មានសម្បុររលើប មកនៅក្នុងសំបុកក្អែក សំបុកនេះជារបស់ក្អែកណា ក្អែកជាសម្លាញ់របស់ខ្ញុំនោះកាចណាស់ដូច្នេះ ។

ក្អែកពោលគាថានេះថា

ម្នាលសម្លាញ់ស្មើចិត្ត ជាសត្វមានកំណើត ២ ក្រែងអ្នកស្គាល់ខ្ញុំដែលជាសត្វមានពូជ ស្មៅជាភោជនដែរឬ អ្នកទើបនឹងមកចូរមើលខ្ញុំ ដែលគេដកស្លាប ព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក ដូច្នេះ ។

ព្រះពោធិសត្វពោលគាថានេះថា

ម្នាលសម្លាញ់ អ្នកនឹងប្រទះ ( បែបនេះ ) ម្តងទៀតពុំខានព្រោះថា សីលធម៌របស់អ្នកប្រាកដដូច្នោះ គ្រឿងបរិភោគទាំងឡាយជារបស់មនុស្សមិនមែនសត្វស្លាបបរិភោគបានដោយងាយឡើយដូច្នេះ ។

ដោយបទថា **រុចិរា** នេះ ក្នុងគាថានោះព្រះពោធិសត្វពោលសំដៅយកភាពដែលក្អែកមានពណ៌ស ព្រោះមានរាងកាយលាបដោយតក្កៈ ។ បទថា **រុចិរា** បានដល់ មើលគួរស្រឡាញ់ អធិប្បាយថា មានពណ៌ស ។ បទថា

**កាកនីឡស្មឹ** ប្រែថា ក្នុងសម្បុករបស់ក្អែក ។ បាលីថា **កាកនិឌ្ឍស្មិ** ដូច្នេះក៏មាន ។ ក្អែកហៅសត្វព្រាបថា **ធិជ** ។ បទថា **សាមាកភោជនំ** បានដល់ មានពូជស្មៅជាអាហារ ។ ពិតហើយក្នុងទីនេះលោកកាន់យកពូជស្មៅសូម្បីទាំងអស់ដោយសព្ទថា **សាមាក** ។

សូម្បីក្នុងរឿងនេះព្រះពោធិសត្វពោលថា ឥឡូវនេះតាំងអំពីនេះទៅខ្ញុំមិនអាចនៅក្នុងទីនេះ ហើយហើរទៅកាន់ទីដទៃទៀត ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលឡេះឡោះ តាំងនៅក្នុងអនាគាមិផលហើយទ្រង់ប្រជុំជាតកថា ក្អែករលោភរលាំក្នុងកាលនោះបានមកជាភិក្ខុឡេះឡោះក្នុងកាលឥឡូវនេះ ចំណែកសត្វព្រាបក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា រុចិរជាតក ចប់

## កុរុធម្មជាតក

[ ៤២៧ ] ( ពួកព្រាហ្មណ៍ក្រាបទូលថា ) បពិត្រព្រះជនាធិបតី យើងទាំងឡាយដឹងច្បាស់នូវសទ្ធានិងសីលរបស់ព្រះអង្គ ហើយនឹងទទួលយកនូវដំរីមានសម្បុរប្រាកដស្មើដោយផ្កាអញ្ជនទៅក្នុងសំណាក់នៃព្រះបាទកាលិង្គៈ ។

[ ៤២៨ ] ( ព្រះរាជាពោធិសត្វពោលថា ) ពួកសត្វដែលយើងចិញ្ចឹមដោយបាយក្តី មិនចិញ្ចឹមក្តី សត្វណាក្នុងជីវលោកនេះដើរមកសំដៅ យើងពួកសត្វទាំងអស់នោះ យើងមិនបានឃាត់ឡើយ នេះជាពាក្យរបស់បុព្វាចារ្យ ( មាតាបិតារបស់យើង ) ។

[ ៤២៩ ] ម្នាលព្រាហ្មណ៍ទាំងឡាយ យើងឲ្យដំរីដ៏ប្រសើរនេះដែលសមគួរដល់ព្រះរាជា ជាជំនិះរបស់ព្រះរាជា មានយសប្រដាប់តាក់តែងហើយបំពាក់ហើយដោយបណ្តាញមាសដល់អ្នកទាំងឡាយ អ្នកទាំងឡាយព្រមទាំងសារថី ( ចូរនាំ ) ទៅតាមប្រាថ្នាចុះ ។

**ចប់ កុរុធម្មជាតកទី ៦ ។**

## អដ្ឋកថា

## កុរុធម្មជាតក

[ ៤២៧-៤២៩ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលសម្លាប់ហង្ស ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តវ សទ្ធញ្ច សីលញ្ច** ដូច្នេះជាដើម ។

មានសម្លាញ់ ២ នាក់ អ្នកនគរសាវត្ថីបព្វជាក្នុងសម្នាក់របស់ភិក្ខុទាំងឡាយហើយបានឧបសម្បទាដោយច្រើនត្រាច់ទៅជាមួយគ្នា ។ ថ្ងៃមួយភិក្ខុ ២ រូបជាសម្លាញ់នោះ ទៅកាន់ស្ទឹងអចិរវតីងូតទឹក អង្គុយអាំងថ្ងៃត្រង់ផ្នូកខ្សាច់ពោលពាក្យជាទីរឭកដល់គ្នានឹងគ្នា ខណៈនោះហង្ស ២ ហើរមកតាមអាកាស ។ លំដាប់នោះភិក្ខុមួយរូបចាប់ដុំក្រួសមកហើយពោលថា ខ្ញុំនឹងផ្ចាត់ភ្នែករបស់ហង្សមួយ ។ ភិក្ខុមួយអង្គទៀតពោលថា លោកមិនអាច ។ ភិក្ខុរូបនោះពោលថា ភ្នែកខាងនេះលើកទុកចុះ ខ្ញុំនឹងផ្ចាត់ភ្នែកខាងនោះ ។ ភិក្ខុមួយអង្គទៀតពោលថា សូម្បីភ្នែកខាងនោះក៏លោកមិនអាច ។ ភិក្ខុរូបនោះពោលថា បើយ៉ាងនោះលោកចាំមើល ពោលហើយក៏ចាប់ដុំក្រួសដែលមានជ្រុង ៣ មកផ្ចាត់ទៅខាងក្រោយរបស់ហង្ស ។ ហង្សបានឮសំឡេងក្រួសទើបងាកមើល ។ លំដាប់នោះភិក្ខុនោះក៏យកដុំក្រួសមួយដុំទៀតផ្ចាត់ហង្សនោះត្រង់ភ្នែកខាងក្រៅឲ្យធ្លុះមកភ្នែកខាងក្នុង ហង្សស្រែកប្រកាច់ធ្លាក់ចុះមកទៀបជើងរបស់ភិក្ខុទាំង ២ នោះ ។ ភិក្ខុទាំងឡាយដែលឈរនៅក្នុងទីនោះឃើញហើយទើបនាំគ្នាមកហើយពោលថា អាវុសោ លោកបួសក្នុងព្រះសាសនាធ្វើបាណាតិបាតឈ្មោះថា ធ្វើកម្មដែលមិនសមគួរ ។ ហើយនាំភិក្ខុដែលផ្ចាត់ហង្សនោះទៅបង្ហាញដល់ព្រះតថាគតមួយរំពេច ។ ព្រះសាស្តាទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើបាណាតិបាតពិតឬ កាលភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គទើបត្រាស់ថា ម្នាលភិក្ខុ ព្រោះហេតុអ្វីអ្នកបួសក្នុងសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខបែបនេះ បែរជាធ្វើបែប

នេះ បុរាណកបណ្ឌិតទាំងឡាយកាលព្រះពុទ្ធមិនទាន់កើតឡើងនៅសៅហ្មង ក្នុងកណ្តាលផ្ទះ គង់ធ្វើសេចក្តីវៀរស្នៀសក្នុងឋានៈទាំងឡាយសូម្បីមានប្រមាណតិច ចំណែកអ្នកបួសក្នុងសាសនាបែបនេះមិនបានធ្វើ សូម្បីត្រឹមតែសេចក្តីវៀរស្នៀស ធម្មតាកិច្ចគប្បីជាអ្នកសង្រួមកាយ វាចានិងចិត្តមិនមែនឬហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះរាជាព្រះនាមថា ធនញ្ចយកោរព្យ គ្រងរាជសម្បត្តិនៅក្នុងឥន្ទបត្ថនគរ[១]ក្នុងដែនកុរុ ព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃរបស់ព្រះអគ្គមហេសីនៃព្រះរាជានោះ ដល់នូវភាពជាអ្នកដឹងក្តីដោយលំដាប់ហើយរៀនសិល្បៈទាំងពួងក្នុងនគរតក្កសិលា ។ ព្រះបិតាទ្រង់តែងតាំងឲ្យតាំងនៅក្នុងតំណែងឧបរាជ ក្នុងកាលតមក កាលព្រះបិតាសោយទិវង្គតហើយបានតាំងនៅក្នុងរាជសម្បត្តិ ទ្រង់មិនបានធ្វើទសពិធរាជធម៌ឲ្យកម្រើក ទ្រង់ប្រព្រឹត្តក្នុងកុរុធម៌ ។ សីល ៥ ឈ្មោះថា កុរុធម៌ ។ ព្រះពោធិសត្វទ្រង់រក្សាសីល ៥ នោះឲ្យបរិសុទ្ធ ។ ព្រះមាតារបស់ព្រះពោធិសត្វ ព្រះអគ្គមហេសី ព្រះឧបរាជដែលជាព្រះអនុជ ព្រាហ្មណ៍ដែលជាបុរោហិត អាមាត្យដែលជាអ្នកវាស់ស្រែ សារថី សេដ្ឋី មហាមាត្យអ្នកវាល់ស្រូវ ឆ្មាំទ្វារ នាងវណ្ណទាសីដែលជានគរសោភិនីក៏ដូចព្រះពោធិសត្វ រួមសេចក្តីថា ជនទាំងនេះរក្សាសីល ៥ ដូចព្រះពោធិសត្វ ។

ជន ១១ នាក់គឺ ព្រះរាជា ១ ព្រះជននី ១ ព្រះអគ្គមហេសី

---

១-ក្នុងទីខ្លះជាឥន្ទបត្តនគរ ឬឥន្ទបដ្តនគរក៏មាន ។

១ ឧបរាជ ១ បុរោហិត ១ អាមាត្យអ្នកវាស់ស្រែ ១ សារថី ១ សេដ្ឋី ១ អាមាត្យអ្នកវាល់ស្រូវ ១ ឆ្មាំទ្វារ ១ និងស្រីគណិកា ១ តាំងនៅក្នុងកុរុធម៌ ដូច្នេះ ។

សូម្បីជនទាំងអស់នេះរក្សាសីល ៥ ឲ្យបរិសុទ្ធិដោយប្រការដូច្នេះ ។ ព្រះរាជាឲ្យសាងរោងទាន ៦ កន្លែង គឺ ត្រង់ទ្វារព្រះនគរទាំង ៤ ត្រង់កណ្ដាលនគរ ត្រង់ទ្វារព្រះរាជនិវេសន៍ ទ្រង់លះព្រះរាជទ្រព្យ ៦០០.០០០ រាល់ៗថ្ងៃ ទ្រង់បរិច្ចាគទានធ្វើជម្ពូទីបទាំងមូលឲ្យមានទន្ទ្គលលើកឡើងហើយ ។ កាលដែលព្រះពោធិសត្វនោះមានអធ្យាស្រ័យត្រេកអរក្នុងការបរិច្ចាគទានបានផ្សព្វផ្សាយទូទាំងជម្ពូទ្វីប ។ ក្នុងកាលនោះ ព្រះបាទកាលិង្គគ្រប់គ្រងរាជសម្បត្តិក្នុងទន្តបុរនគរក្នុងដែនកាលិង្គៈ ។ ក្នុងដែនរបស់ព្រះបាទកាលិង្គៈនោះ ភ្លៀងមិនធ្លាក់ ។ កាលភ្លៀងមិនធ្លាក់ក៏កើតនូវការអត់ឃ្លានពេញដែន ។ ព្រោះអាហារវិបត្តិ ទើបរោគកើតឡើងដល់ពួកមនុស្ស ។ ភ័យ ៣ ប្រការ គឺ ទុព្ភិក្ខភ័យ ភ័យគឺការមិនមានភ្លៀង ១ ឆាតកភ័យ ភ័យគឺការអត់ឃ្លាន ១ រោគភ័យ ភ័យគឺរោគ ១ ក៏កើតឡើង ។ មនុស្សទាំងឡាយអស់ទីពឹងដឹកដៃកូនត្រាច់ទៅ ។ អ្នកដែនទាំងអស់រួមគ្នាទៅកាន់នគរទន្តបុរៈ នាំគ្នាធ្វើសំឡេងអឺអរត្រង់ទ្វារព្រះរាជវាំង ។ ព្រះរាជាប្រថាប់ឈរផ្អែកបង្អួចទ្រង់ស្ដាប់សំឡេងនោះទើបត្រាស់សួរថា មនុស្សទាំងនេះស្រែកព្រោះហេតុអ្វីពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ ភ័យកើតឡើងពេញដែនទាំងមូល ភ្លៀងមិនធ្លាក់សន្ទូងវិនាសកើតនូវការអត់ឃ្លាន មនុស្សទាំងឡាយបរិភោគអាហារ

មិនល្អត្រូវរោគគ្របសង្កត់ អស់នូវទីពឹង អន្ទះសានាំគ្នាដឹកដៃកូនត្រាច់ទៅ បពិត្រមហារាជ សូមព្រះអង្គញុំាងភ្លៀងឲ្យធ្លាក់ចុះ ។ ព្រះរាជាត្រាស់សួរថា ព្រះរាជាអំពីបុរាណទាំងឡាយ កាលភ្លៀងមិនធ្លាក់ទ្រង់ធ្វើដូចម្ដេច ពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ ព្រះរាជាអំពីបុរាណទាំងឡាយកាលភ្លៀងមិនធ្លាក់ទ្រង់បានបរិច្ចាគទាន អធិដ្ឋានឧបោសថ សមាទានសីលហើយស្ដេចចូលកាន់បន្ទប់ដ៏មានសិរី ទ្រង់ផ្ទំលើកម្រាលដែលធ្វើដោយឈើអស់ ៧ ថ្ងៃ ក្នុងកាលនោះភ្លៀងក៏ធ្លាក់ចុះមក ។ ព្រះរាជាទ្រង់ទទួលថា សាធុ ហើយទ្រង់បានធ្វើយ៉ាងនោះ ។ សូម្បីទ្រង់ធ្វើយ៉ាងនោះភ្លៀងក៏មិនធ្លាក់ ។ ព្រះរាជាត្រាស់ចំពោះអាមាត្យទាំងឡាយថា យើងបានធ្វើកិច្ចដែលគួរធ្វើហើយ ភ្លៀងក៏នៅមិនធ្លាក់ យើងនឹងធ្វើដូចម្ដេចតទៅទៀត ។ ពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ ព្រះបាទធនញ្ជយកោរព្យក្នុងនគរឥន្ទបត្ត: មានមង្គលហត្ថីឈ្មោះថា អញ្ជនវណ្ណ: ទូលព្រះបង្គំទាំងឡាយនឹងនាំមង្គលហត្ថីនោះមក កាលបើដូច្នោះភ្លៀងក៏នឹងធ្លាក់ ។ ព្រះរាជាត្រាស់ថា ព្រះរាជាអង្គនោះទ្រង់បរិបូណ៌ដោយពលពាហន: បុគ្គលណាមួយគ្របសង្កត់បានដោយក្រ ពួកយើងនឹងនាំដំរីរបស់ព្រះរាជាអង្គនោះមកបានដូចម្ដេច ពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ មិនមានកិច្ចដែលនឹងត្រូវច្បាំងជាមួយព្រះបាទធនញ្ជយ-កោរព្យនោះឡើយ ព្រះរាជាអង្គនោះមានអធ្យាស្រ័យ ត្រេកអរក្នុងការបរិច្ចាគទាន ជាបុគ្គលត្រូវគេសូមសូម្បីព្រះសិរសាដែលប្រដាប់ហើយក៏ទ្រង់កាត់ឲ្យ សូម្បីកែវភ្នែកដែលបរិបូណ៌ដោយបសាទក៏ទ្រង់ខ្វេះឲ្យ សូម្បី

រាជសម្បត្តិទាំងអស់ក៏ទ្រង់ប្រគល់ឲ្យ ក្នុងរឿងមង្គលហត្ថីមិនចាំបាច់ពោលដល់ឡើយទូលសូមហើយទ្រង់នឹងប្រទានឲ្យពិត ។ ព្រះរាជាត្រាស់ថា នរណាអាចទៅសូមមង្គលហត្ថីនោះ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជពួកព្រាហ្មណ៍ ។ ព្រះរាជាទ្រង់ត្រាស់ឲ្យហៅពួកព្រាហ្មណ៍ ៨ នាក់មកអំពីលំនៅរបស់ព្រាហ្មណ៍ហើយទ្រង់ធ្វើសក្ការៈនិងការរាប់អានហើយ ទ្រង់បញ្ជូនទៅឲ្យសូមមង្គលហត្ថី ។ ព្រាហ្មណ៍ទាំងនោះកាន់យកស្បៀងធ្វើដំណើរ ក្លែងភេទជាមនុស្សដើរផ្លូវប្រញាប់ដើរផ្លូវទៅ ដោយស្នាក់នៅត្រឹមតែមួយរាត្រីក្នុងទីគ្រប់កន្លែង បរិភោគអាហារក្នុងរោងទានត្រង់ទ្វារព្រះនគរ ទំនុកបម្រុងរាងកាយឲ្យឆ្អែតស្កប់ស្កល់អស់ ២-៣ ថ្ងៃហើយសួរថា កាលណាព្រះរាជានឹងយាងមកកាន់រោងទាន ពួកមនុស្សប្រាប់ថា ព្រះរាជានឹងយាងមកក្នុងថ្ងៃ ១៤ ១៥ និងថ្ងៃ ៨ អស់ ៣ ថ្ងៃនៃបក្ខនីមួយ ៗ ស្អែកនេះជាថ្ងៃពេញបូរមី ១៥ កើត ព្រោះហេតុនោះព្រះរាជានឹងយាងមកក្នុងថ្ងៃស្អែកនេះ ។ ស្អែកឡើងពួកព្រាហ្មណ៍ប្រញាប់ទៅអំពីព្រឹក ឈរនៅត្រង់ទ្វារទិសខាងកើត ។ ព្រះពោធិសត្វទ្រង់ស្រង់ទឹកនិងលាបព្រះវរកាយអំពីព្រឹកទ្រង់ប្រដាប់ដោយគ្រឿងអលង្ការទាំងពួងយាងឡើងកាន់កមង្គលហត្ថីដែលប្រដាប់ហើយ យាងទៅកាន់រោងទានតាមទ្វារទិសខាងកើតដោយបរិវារធំ ទ្រង់ចុះអំពីដំរីហើយបានប្រទានអាហារដោយព្រះហស្តរបស់ព្រះអង្គដល់ពួកជន ៧-៨ នាក់ ហើយត្រាស់ថា ចូរពួកអ្នកឲ្យដោយទំនងនេះហើយទ្រង់បានឡើងដំរីទៅកាន់ទ្វារទិសខាងត្បូង ។ ពួកព្រាហ្មណ៍មិនបានឱកាសត្រង់ទ្វារទិសខាងកើត ព្រោះមានការរក្សាតឹងរឹង

ទើបបានទៅកាន់ទិសខាងត្បូងដូចគ្នា ឈរនៅត្រង់ទីខ្ពស់មិនឆ្ងាយពេកអំពីទ្វារ រង់ចាំមើលព្រះរាជាយាងមក លុះព្រះរាជាយាងមកដល់ពួកព្រាហ្មណ៍ក៏លើកដៃថ្វាយជ័យមង្គលថា បពិត្រមហារាជ សូមទ្រង់មានជ័យជម្នះចុះ ។ ព្រះរាជាទ្រង់យកកន្ទ្រពេជ្រទាញដំរីឲ្យត្រឡប់ យាងទៅជិតព្រាហ្មណ៍ទាំងនោះ ហើយត្រាស់សួរថា នែព្រាហ្មណ៍ដ៏ចម្រើន អ្នកទាំងឡាយត្រូវការអ្វី ព្រាហ្មណ៍ទាំងឡាយកាលពណ៌នាគុណរបស់ព្រះពោធិសត្វ ទើបពោលគាថាទី ១ ថា

បពិត្រព្រះជនាធិបតី យើងទាំងឡាយដឹងច្បាស់នូវសទ្ធា និង
សីលរបស់ព្រះអង្គ ហើយនឹងទទួលយកនូវដំរីមានសម្បុរ
ប្រាកដស្មើដោយផ្កាអញ្ចន់ ទៅក្នុងសំណាក់នៃព្រះបាទកាលិង្គៈ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សទ្ធំ** បានដល់ សទ្ធា គឺការជឿដោយអំណាចការជឿកម្ម និងផលនៃកម្ម ។ បទថា **សីលំ** បានដល់ សំវរសីល ( សង្រួមសីល ) អវីតិក្កមសីល ( សីលគឺការមិនកន្លងល្មើស ) ក្នុងសម័យនោះ ក្នុងប្រទេសនោះមាសហៅថា **វណ្ណំ** ។ ពាក្យនោះត្រឹមតែជាមាតិកានៃទេសនាប៉ុណ្ណោះ ។ ដោយពាក្យនេះលោកសង្គ្រោះយកមាសប្រាក់ទ្រព្យនិងធញ្ញាហារទាំងអស់ ។ បទថា **អញ្ជនវណ្ណេន** បានដល់ ដោយដំរីដ៏ប្រសើររបស់ព្រះអង្គនេះដែលមានពណ៌ដូចផ្កាអញ្ចន់ ។ បទថា **កាលិង្គស្មឹ** បានដល់ ក្នុងសម្នាក់របស់ព្រះបាទកាលិង្គៈ ។ បទថា **និជ្ឈាសេ** សេចក្តីថា ទូលព្រះបង្គំទាំងឡាយ សូមកាន់យកដោយការដោះដូរដោយទ្រព្យ ឬដោយ

របស់ដែលដាក់ទៅក្នុងផ្ទៃដោយការបរិភោគចូលទៅ ។ បទថា សេ ត្រឹមតែជានិបាត ។ លោកពោលអធិប្បាយទុកថា បពិត្រព្រះជនាធិបតី ដ្បិតថាទូលព្រះបង្គំទាំងឡាយ បានជ្រាបសទ្ធានិងសីលរបស់ព្រះអង្គ ហើយគិតថាព្រះរាជាអង្គនេះ ទ្រង់បរិបូណ៌ដោយសទ្ធានិងសីលយ៉ាងនេះ នឹងទូលសូមហើយនឹងព្រះរាជទានដំរីដ៏ប្រសើរ មានពណ៌ដូចផ្កាអញ្ចន់ ដល់ពួកយើងពិតដូច្នេះហើយទើបពោលថា យើងទាំងឡាយនឹងនាំដំរីដ៏ប្រសើរទៅកាន់សម្នាក់របស់ព្រះបាទកាលិង្គៈ ដូច្នេះហើយទើបយកទ្រព្យនិងធញ្ញាហារដ៏ច្រើនមួយអន្ទើដោយដំរីដែលមានពណ៌ដូចផ្កាអញ្ចន់នេះថាដូចជារបស់ខ្លួន គឺចាយវាយទ្រព្យនិងធញ្ញាហារដ៏ច្រើននិងដាក់ចិត្តដាក់កាយចិញ្ចឹម ។ ទូលព្រះបង្គំទាំងឡាយកាលនឹងសូមដំរីនោះយ៉ាងនេះទើបមកក្នុងទីនេះ សូមព្រះអង្គទ្រង់គុណដ៏ប្រសើរទ្រង់ជ្រាបកិច្ចដែលទ្រង់គប្បីធ្វើក្នុងរឿងដំរីនោះ ។ម្យ៉ាងទៀតទូល-ព្រះបង្គំទាំងឡាយបានជ្រាបព្រះគុណ គឺសទ្ធាគុណនិងសីលគុណរបស់ព្រះអង្គទើបគិតថា ព្រះរាជាដែលមានគុណធំក្រៃលែងសូម្បីតែជីវិតត្រូវសូមហើយក៏ប្រទានឲ្យនឹងបាច់ពោលថ្វីដល់ដំរីដ៏ប្រសើរដែលជាសត្វតិរច្ឆាន ដូច្នេះហើយទើបសូមដោះដូរ គឺប្រៀបធៀបមាសដល់ព្រះអង្គជាមួយដំរីដែលមានពណ៌ដូចផ្កាអញ្ចន់នេះ ( សូមដូរដំរីដោយមាស ) ទៅទុកក្នុងសម្នាក់របស់ព្រះបាទកាលិង្គដោយប្រការយ៉ាងនេះ ដោយហេតុនោះ ទើបទូលព្រះបង្គំទាំងឡាយមកក្នុងទីនេះ ។

ព្រះពោធិសត្វទ្រង់បានស្តាប់ដូច្នោះ ទើបទ្រង់លួងលោមឲ្យជួរចិត្តថា

ព្រាហ្មណ៍ទាំងឡាយ ប្រសិនបើអ្នកទាំងឡាយប្រើប្រាស់ទ្រព្យព្រោះដោះដូរដីរដ៏ប្រសើរនេះ ជាការចាយវាយទៅល្អហើយ កុំទោមនស្សឡើយយើងនឹងឲ្យដីរដ៏ប្រសើរដែលប្រដាប់ហើយនេះឯងដល់អ្នកទាំងឡាយ ។ ហើយបានពោលគាថា ២ ក្រៅអំពីនេះថា

ពួកសត្វដែលយើងចិញ្ចឹមដោយបាយក្តី មិនចិញ្ចឹមក្តី សត្វណាក្នុងជីវលោកនេះ ដើរមកសំដៅយើង ពួកសត្វទាំងអស់នោះយើងមិនបានឃាត់ឡើយ នេះជាពាក្យរបស់បុព្វាចារ្យ ( មាតាបិតារបស់យើង ) ។

ម្នាលព្រាហ្មណ៍ទាំងឡាយ យើងឲ្យដីរដ៏ប្រសើរនេះដែលសមគួរដល់ព្រះរាជា ជាជំនិះរបស់ព្រះរាជា មានយសប្រដាប់តាក់តែងហើយបំពាក់ហើយដោយបណ្តាញមាសដល់អ្នកទាំងឡាយ អ្នកទាំងឡាយព្រមទាំងសារថី ( ចូរនាំ ) ទៅតាមប្រាថ្នាចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អន្នភតា ច ភតា ច** សេចក្តីថា ឈ្មោះថា សត្វដែលគប្បីចិញ្ចឹមដោយបាយព្រោះសត្វដែលចូលទៅអាស្រ័យបុរសរស់នៅគប្បីចិញ្ចឹមដោយបាយមានយាគូនិងភត្តជាដើម ។ សត្វក្រៅអំពីនេះឈ្មោះថា សត្វមិនគប្បីចិញ្ចឹមព្រោះជាសត្វដែលមិនត្រូវចិញ្ចឹមយ៉ាងនោះ ។ ក្នុងទីនេះគប្បីជ្រាបការលុប **អ** អក្ខរៈដោយការភ្ជាប់បទ ។ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះឈ្មោះថា សម្តែងសត្វគ្រប់ពួកជា ២ ពួកដោយ

ការចូលទៅអាស្រ័យខ្លួន ហើយចិញ្ចឹមជីវិតនិងការមិនចូលទៅអាស្រ័យខ្លួន ហើយចិញ្ចឹមជីវិត ។ បទថា **យោធ ឧទ្ទិស្ស គច្ឆតិ** សេចក្តីថា បណ្តាសត្វទាំងនោះ សត្វពួកណាក្នុងជីវលោកនេះរមែងឧទ្ទិសបុរសណាមកដោយការប្រាថ្នាយ៉ាងណាមួយ ។ បទថា **សព្វេតេ អប្បដិក្ខិប្បា** សេចក្តីថា បើសត្វមានចំនួនច្រើនឧទ្ទិសមកយ៉ាងនោះ កាលបើដូច្នោះ បុរសនោះ ក៏មិនបដិសេធសត្វទាំងអស់នោះ អធិប្បាយថា មិនគប្បីបដិសេធយ៉ាងនេះថា ពួកអ្នកចូរជៀសចេញទៅ យើងនឹងមិនឲ្យពួកអ្នក ។ បទថា **បុព្វាចរិយវចោ ឥទំ** សេចក្តីថា មាតាបិតាហៅថាបុព្វាចារ្យ នេះជាពាក្យរបស់បុព្វាចារ្យទាំងនោះ ។ លោកសម្តែងថា មាតាបិតាឲ្យខ្ញុំសិក្សាមកយ៉ាងនេះ ។

បទថា **ឧទាមិ វោ** សេចក្តីថា ព្រោះនេះជាពាក្យរបស់បុព្វចារ្យនៃយើងទាំងឡាយ ហេតុនោះនៃព្រាហ្មណ៍ទាំងឡាយ យើងនឹងឲ្យដីរដ៏ប្រសើរនេះដល់អ្នកទាំងឡាយ ។ បទថា **រាជារហំ** បានដល់ សមគួរដល់ព្រះរាជា ។ បទថា **រាជភោគ្គំ** បានដល់ ជាគ្រឿងបរិភោគ ( ប្រើប្រាស់ ) របស់ព្រះរាជា ។ បទថា **យសស្សិនំ** បានដល់ ដល់ព្រមដោយបរិវារ អធិប្បាយថា បានឮថា មនុស្ស ៥០០ ត្រកូលមានអ្នកឃ្វាលដីរនិងព្យាបាលដីរជាដើម អាស្រ័យដីរនោះចិញ្ចឹមជីវិត យើងនឹងឲ្យដល់អ្នកទាំងឡាយព្រមទាំងមនុស្ស ៥០០ ត្រកូលនោះ ។ បទថា **អលង្កតំ** សេចក្តីថា ប្រដាប់ដោយគ្រឿងប្រដាប់ដីរប្រភេទផ្សេងៗ ។ បទថា **ហេមជាលាភិឆន្នំ** បានដល់ ប្រដាប់ដោយបណ្តាញមាស ។ បទថា **សសារថី** សេចក្តីថា យើង

នឹងឲ្យដល់ពួកអ្នកព្រមទាំងសារថី អ្នកឃ្វាលដំរីនិងហត្ថាចារ្យនោះ ព្រោះហេតុនោះពួកអ្នកមួយអន្ទើដោយសារថី គឺហ្មដំរី ចូរនាំយកដំរីនេះមួយអន្ទើដោយបរិវារទៅតាមសេចក្តីប្រាថ្នាចុះ ។

ព្រះមហាសត្វប្រថាប់លើកដំរីដ៏ប្រសើរត្រាស់ឲ្យដោយព្រះវាចាយ៉ាងនេះ ហើយយាងចុះអំពីកដំរីទ្រង់ប្រទក្សិណ ៣ ជុំ ទ្រង់ពិចារណាថា ប្រសិនបើទីដែលមិនបានប្រដាប់តាក់តែងនៅមាននឹងតាក់តែងមុនហើយសឹមឲ្យ ដូច្នេះ ហើយកាលទ្រង់មិនឃើញទីដែលមិនបានប្រដាប់តាក់តែងដំរីនោះ ទើបទ្រង់យកប្រមោយរបស់ដំរីនោះដាក់លើដៃរបស់ព្រាហ្មណ៍ទាំងឡាយ ហើយបានយកកុណ្ឌីមាសប្រួចទឹកដែលអប់ដោយផ្កានិងគ្រឿងក្រអូប ហើយព្រះរាជទានទៅ ។ ព្រាហ្មណ៍ទាំងឡាយទទួលដំរីមួយអន្ទើដោយបរិវារហើយអង្គុយលើខ្នងដំរី បានទៅកាន់ទន្តបុរនគរថ្វាយដំរីដល់ព្រះរាជា ។ ដំរីសូម្បីមកហើយភ្លៀងក៏នៅមិនធ្លាក់ ។ ទើបព្រះរាជាទ្រង់សាកសួរថា មានហេតុអ្វីហ្ន៎ ទ្រង់បានស្តាប់ថា ព្រះបាទធនញ្ជយកោរព្យទ្រង់រក្សាកុរុធម៌ ដោយហេតុនោះទើបភ្លៀងធ្លាក់ចុះក្នុងដែនរបស់ព្រះអង្គរាល់កន្លះខែឬរាល់ ១០ ថ្ងៃព្រោះអានុភាពនៃគុណ គឺសេចក្តីល្អរបស់ព្រះរាជាទើបភ្លៀងធ្លាក់ សត្វតិរច្ឆាននេះសូម្បីមានគុណតើនឹងមានប៉ុណ្ណា ដូច្នេះហើយទើបត្រាស់ថា បើយ៉ាងនោះអ្នកទាំងឡាយចូរនាំដំរីតាមដែលប្រដាប់ហើយនេះមួយអន្ទើដោយបរិវារ ទៅសងដល់ព្រះរាជាហើយចម្លងកុរុធម៌ដែលព្រះអង្គទ្រង់រក្សាដាក់ក្នុងជំបារមាសហើយនាំមក ។ ហើយទ្រង់បញ្ជូនពួកព្រាហ្មណ៍និងអាមាត្យទាំងឡាយទៅ ។ ពួក

ព្រាហ្មណ៍និងអាមាត្យទាំងនោះនាំដីរទៅថ្វាយដល់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ដីរនេះសូម្បីទៅដល់ហើយភ្លៀងក៏នៅមិនធ្លាក់ក្នុងដែនរបស់ទូលព្រះបង្គំទាំងឡាយ បានឮថា ទ្រង់រក្សាកុរុធម៌ ព្រះរាជារបស់ទូលព្រះបង្គំទាំងឡាយក៏ទ្រង់បំណាងនឹងរក្សាកុរុធម៌នោះ ទើបទ្រង់បញ្ជូនមកដោយព្រះតម្រាស់ថា ចូរអ្នកចម្លងកុរុធម៌ដាក់ក្នុងជំបារមាសនាំមក សូមទ្រង់ប្រទានកុរុធម៌នោះដល់ទូលព្រះបង្គំទាំងឡាយចុះ ។ ព្រះពោធិសត្វត្រាស់ថា បាទាំងឡាយ យើងរក្សាកុរុធម៌នោះពិតតែឥឡូវនេះយើងមានសេចក្តីរង្កៀសក្នុងកុរុធម៌នោះកុរុធម៌នោះ មិនធ្វើចិត្តរបស់យើងឲ្យត្រេកអរ ព្រោះដូច្នោះយើងមិនអាចឲ្យកុរុធម៌នោះដល់អ្នកទាំងឡាយ ។ សួរថា ព្រោះហេតុអ្វីទើបសីលនោះមិនធ្វើឲ្យព្រះរាជាត្រេកអរ ឆ្លើយថា បានឮថា ក្នុងកាលនោះព្រះរាជាទាំងឡាយមានការលេងមហោស្រពខែកត្តិករាល់ ៣ ឆ្នាំម្តង ព្រះរាជាកាលនឹងលេងមហោស្រពនោះទ្រង់ប្រដាប់ដោយគ្រឿងអលង្ការទាំងពួងកាន់យកភេទជាទេវតាឈរនៅក្នុងសម្នាក់របស់យក្សឈ្មោះថា ចិត្តរាជ ហើយបាញ់សរដែលវិចិត្រប្រដាប់ដោយផ្កាក្នុងទិសទាំង ៤ ។ ព្រះរាជាអង្គនេះកាលទ្រង់លេងមហោស្រពនោះ ទ្រង់ឈរក្នុងសម្នាក់របស់យក្ស ឈ្មោះចិត្តរាជក្បែរបឹងមួយហើយទ្រង់បាញ់សរដ៏វិចិត្រទៅក្នុងទិសទាំង ៤ ។ បណ្តាកូនសរទាំងនោះ ព្រះអង្គទ្រង់ឃើញកូនសរ ៣ ដែលបាញ់ទៅក្នុងទិសដ៏សេសតែមិនឃើញកូនសរដែលបាញ់ទៅលើផ្ទៃទឹក ។ ព្រះរាជាទ្រង់រង្កៀសថា កូនសរដែលអញបាញ់ទៅប្រហែលជាធ្លាក់ចំខ្លួនត្រីទេដឹងហ្ន៎ ។ ព្រះអង្គ

ទ្រង់ប្រារព្ធដល់ការបែកធ្លាយនៃសីលព្រោះកម្ម គឺធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះ ។ ព្រោះហេតុនោះទើបសីលមិនធ្វើព្រះរាជាឲ្យត្រេកអរ ទើបព្រះពោធិសត្វនោះត្រាស់យ៉ាងនេះថា នែបាទាំងឡាយ យើងមានសេចក្តីរង្កៀសក្នុងកុរុធម៌តែព្រះមាតារបស់យើងរក្សាទុកបានយ៉ាងល្អ ពួកអ្នកចូរកាន់យកក្នុងសម្នាក់របស់ព្រះមាតាយើងចុះ ។ ទូតទាំងឡាយក៏ក្រាបទូលថា បពិត្រមហារាជ ព្រះអង្គមិនមានចេតនាថានឹងសម្លាប់សត្វព្រោះវៀរចាកចេតនានោះទើបឈ្មោះថា មិនជាបាណាតិបាត សូមព្រះអង្គឲ្យកុរុធម៌ដែលទ្រង់រក្សា ដល់ទូលព្រះបង្គំទាំងឡាយចុះ ។ ព្រះពោធិសត្វត្រាស់ថា បើយ៉ាងនោះចូរអ្នកចម្លងយកចុះហើយឲ្យចារឹកក្នុងជំពារមាសថា **បាណោ ន ហន្តព្វោ** មិនគប្បីសម្លាប់សត្វ ១ **អទិន្នំ នាទាតព្វំ** មិនគប្បីកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ១ **កាមេសុមិច្ឆាចារោ ន ចរិតព្វោ** មិនគប្បីប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ **មុសា ន ភាសិតព្វំ** មិនគប្បីពោលពាក្យកុហក ១ **មជ្ជំបានំ ន បាតព្វំ** មិនគប្បីផឹកនូវទឹកស្រវឹង ១ ។ កាលឲ្យចារឹកហើយទើបត្រាស់ថា សូម្បីយ៉ាងនេះសីលក៏ញ៉ាំងយើងឲ្យត្រេកអរមិនបាន ពួកអ្នកចូរទៅគាល់ព្រះមាតារបស់យើងចុះ ។

ទូតទាំងឡាយថ្វាយបង្គំព្រះរាជាហើយទៅកាន់សម្នាក់របស់ព្រះមាតានោះក្រាបទូលថា បពិត្រព្រះទេវី បានឮថា ព្រះនាងរក្សាកុរុធម៌ សូមព្រះនាងប្រទានកុរុធម៌នោះ ដល់ទូលព្រះបង្គំទាំងឡាយ ។ ព្រះទេវីត្រាស់ថា នែបាទាំងឡាយ យើងរក្សាកុរុធម៌ក៏ពិតតែឥឡូវនេះយើងកើតការរង្កៀសក្នុងកុរុធម៌

នោះ កុរុធម៌នោះមិនធ្វើឲ្យយើងត្រេកអរ ព្រោះហេតុនោះទើបយើងមិនអាចឲ្យដល់បាទាំងឡាយ បានឮថា ព្រះទេវីនោះមានព្រះរាជឱរស ២ អង្គគឺព្រះរាជាដែលជាព្រះជេដ្ឋានិងឧបរាជដែលជាព្រះកនិដ្ឋា ។ កាលនោះមានព្រះរាជាមួយអង្គទ្រង់បញ្ជូនខ្លឹមចន្ទន៍ដែលមានតម្លៃ ១០០០០០ និងផ្កាមាសមានតម្លៃ ១០០០ មកថ្វាយព្រះពោធិសត្វ ។ ព្រះពោធិសត្វត្រិះរិះថានឹងបូជាព្រះមាតា ដូច្នេះហើយទើបបញ្ជូនរបស់ទាំងអស់នោះទៅថ្វាយព្រះរាជមាតា ។ ព្រះរាជមាតាទ្រង់ព្រះតម្រិះថា អញមិនលាបខ្លឹមចន្ទន៍ មិនទ្រទ្រង់ផ្កានឹងឲ្យខ្លឹមចន្ទន៍និងកម្រងផ្កានោះដល់កូនប្រសាស្រីទាំង ២ ។ លំដាប់នោះព្រះទេវីមានសេចក្តីត្រិះរិះដូច្នេះថា កូនប្រសាស្រីច្បងរបស់អញជាធំ តាំងនៅក្នុងតំណែងអគ្គមហេសី អញនឹងឲ្យកម្រងផ្កាមាសដល់កូនប្រសាស្រីច្បង ចំណែកកូនប្រសាស្រីប្អូនជាមនុស្សក្រីក្រ អញនឹងឲ្យខ្លឹមចន្ទន៍ដល់កូនប្រសាស្រីប្អូន ។ ទើបព្រះនាងប្រទានកម្រងផ្កាមាសដល់ព្រះទេវីរបស់ព្រះរាជា បានប្រទានខ្លឹមចន្ទន៍ដល់ព្រះមហេសីរបស់ឧបរាជ ។ កាលប្រទានទៅហើយព្រះរាជមាតាមានសេចក្តីរង្កៀសថា អញរក្សាកុរុធម៌ ភាពដែលស្ត្រីកូនប្រសាទាំងនោះក្រីក្រឬមិនក្រីក្រ មិនជាប្រមាណសម្រាប់អញ ការធ្វើជេដ្ឋាបចាយិកកម្ម ( ការធ្វើនូវសេចក្តីគោរពដល់ជនដែលជាច្បង ) ប៉ុណ្ណោះសមគួរដល់អញ ព្រោះភាពដែលអញមិនធ្វើជេដ្ឋាបចាយិកកម្មនោះ សីលរបស់អញនឹងបែកធ្លាយឬហ្ន៎ ។ ព្រោះហេតុនោះទើបព្រះរាជមាតាត្រាស់យ៉ាងនោះ ។ លំដាប់នោះទើបទូតទាំងឡាយក្រាបទូលព្រះរាជមាតាថា ដែលឈ្មោះថា របស់ខ្ទួន

បុគ្គលរមែងឲ្យបានតាមគាប់ចិត្ត ព្រះនាងទ្រង់ធ្វើការរង្កៀសដោយហេតុមានប្រមាណប៉ុណ្ណោះ ព្រះនាងនឹងធ្វើកម្មដ៏លាមកដទៃបានដូចម្ដេច ធម្មតាសីលរមែងមិនបែកធ្លាយ ដោយហេតុបែបនេះឡើយ សូមព្រះនាងព្រះរាជទានកុរុធម៌ដល់ទូលព្រះបង្គំទាំងឡាយចុះ ហើយកាន់យកកុរុធម៌ក្នុងសម្នាក់របស់ព្រះរាជមាតានោះចារឹកក្នុងជំបារមាស ។

ពួកទូតដែលព្រះរាជមាតាត្រាស់ថា នែបាទាំងឡាយ កាលបើយ៉ាងនោះកុរុធម៌ក៏នៅមិនធ្វើឲ្យយើងត្រេកអរបាន តែព្រះសុណិសារបស់យើងរក្សាកុរុធម៌នោះបានយ៉ាងល្អ អ្នកទាំងឡាយចូរកាន់យកក្នុងសម្នាក់របស់ព្រះសុណិសានោះចុះ ។ ទើបនាំគ្នាទៅគាល់ព្រះអគ្គមហេសីទូលសូមកុរុធម៌ដោយន័យមុននោះឯង ។ ចំណែកព្រះអគ្គមហេសីត្រាស់ដោយន័យមុនដូចគ្នាហើយត្រាស់ថា ឥឡូវនេះឈ្មោះថា សីលរមែងមិនធ្វើឲ្យយើងត្រេកអរព្រោះហេតុនោះយើងមិនអាចឲ្យពួកអ្នកបានទេ ។ បានឮថា ព្រះអគ្គមហេសីនោះថ្ងៃមួយប្រថាប់ឈរត្រង់សីហបញ្ជរទតឃើញមហាឧបរាជប្រថាប់លើខ្នងដំរីខាងក្រោយព្រះរាជាដែលកំពុងប្រទក្សិណព្រះនគរ កើតសេចក្ដីលោភឡើងព្រះនាងព្រះតម្រិះថា បើអញបានធ្វើសេចក្ដីស្និទ្ធស្នាលជាមួយមហាឧបរាជនេះសោត កាលព្រះជេដ្ឋាសោយទិវង្គតទៅមហាឧបរាជនេះបានតាំងនៅក្នុងរាជសម្បត្តិនឹងបានសង្គ្រោះអញ ។ លំដាប់នោះព្រះអគ្គមហេសីនោះមានសេចក្ដីរង្កៀសថា អញកំពុងរក្សាកុរុធម៌ទាំងជាអ្នកមានព្រះស្វាមីបែរជាសម្លឹងមើលបុរសដទៃដោយអំណាចកិលេស សីលរបស់អញគង់នឹងបែកធ្លាយ ។

ព្រោះហេតុនោះទើបអគ្គមហេសីបានត្រាស់យ៉ាងនេះ ។ លំដាប់នោះទូតទាំងឡាយក៏ក្រាបទូលអគ្គមហេសីថា បពិត្រព្រះនាង ធម្មតាការប្រព្រឹត្តកន្ទងល្មើសរមែងមិនមានដោយហេតុត្រឹមតែចិត្តប្បាទដែលកើតឡើងឡើយ ព្រះនាងធ្វើនូវសេចក្តីរង្កៀសសូម្បីដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះនាងនឹងធ្វើការកន្ទងល្មើសបានដូចម្តេច សីលរមែងមិនបែកធ្លាយដោយហេតុមានប្រមាណប៉ុណ្ណេះ សូមព្រះនាងប្រទានកុរុធម៌ដល់ទូលព្រះបង្គំទាំងឡាយចុះ ហើយកាន់យកក្នុងសម្នាក់របស់ព្រះអគ្គមហេសីនោះហើយចារឹកក្នុងជំបារមាស ។

ទូតទាំងឡាយកាលព្រះអគ្គមហេសីត្រាស់ថា បាទាំងឡាយ កាលបើយ៉ាងនោះសីលក៏មិនធ្វើយើងឲ្យត្រេកអរបានឡើយ ព្រោះមហាឧបរាជទ្រង់រក្សាបានយ៉ាងល្អ ពួកអ្នកចូរកាន់យក ក្នុងសម្នាក់របស់មហាឧបរាជនោះចុះ ទើបនាំគ្នាចូលទៅគាល់មហាឧបរាជទូលសូមកុរុធម៌ដោយន័យមុននោះឯង ។ ឧបរាជនោះកាលយាងទៅកាន់ទីបម្រើរបស់ព្រះរាជាក្នុងវេលាល្ងាច យាងទៅដោយរថដល់លានព្រះរាជវាំងហើយ បើទ្រង់បំណងនឹងសោយក្នុងសម្នាក់របស់ព្រះរាជា ហើយទ្រង់ផ្ទំនៅក្នុងទីនោះ ទ្រង់ក៏បោះខ្សែនិងជន្ទញទុកត្រង់នឹមរថ ដោយសញ្ញានោះបរិវារជនក៏ត្រឡប់ទៅ លុះពេលព្រឹកទើបឈររង់ចាំឧបរាជនោះយាងចេញមក ។ ចំណែកនាយសារថីក៏នឹងនាំរថនោះទៅ លុះពេលព្រឹកឡើងក៏នាំរថមកចតត្រង់ទ្វារព្រះរាជនិវេសន៍ ។ បើឧបរាជនោះមានបំណងនឹងយាងត្រឡប់ក្នុងខណៈនោះ ទ្រង់ដាក់ខ្សែនិងជន្ទញទុកខាងក្នុងរថហើយយាងទៅគាល់ព្រះរាជា ។ ដោយសញ្ញានោះបរិវារជនក៏ឈរត្រង់ទ្វារ

ព្រះរាជនិវេសន៍នោះឯង ដោយគិតថា ឧបរាជនឹងយាងមកក្នុងឥឡូវនេះ ។ ឧបរាជនោះទ្រង់ធ្វើយ៉ាងនោះហើយយាងចូលទៅកាន់ព្រះរាជនិវេសន៍ ។ កាលឧបរាជនោះគ្រាន់តែចូលទៅប៉ុណ្ណោះភ្លៀងក៏ធ្លាក់ចុះ ។ ព្រះរាជាត្រាស់ថា ភ្លៀងកំពុងធ្លាក់ទើបមិនឲ្យឧបរាជនោះចេញមក ។ ឧបរាជក៏សោយហើយផ្ទំក្នុងព្រះរាជនិវេសន៍នោះឯង ។ បរិវារជនគិតថា ឧបរាជនឹងយាងមកក្នុងកាលឥឡូវនេះដូច្នេះហើយទើបឈរហាលភ្លៀងរហូតដល់ភ្លឺ ។ ក្នុងថ្ងៃទី ២ មហាឧបរាជក៏ចេញមកឃើញបរិវារជនឈរហាលភ្លៀង កើតការរង្កៀសថា អញកាលរក្សាកុរុធម៌ ញុំាងមហាជនមានប្រមាណប៉ុណ្ណេះឲ្យលំបាក សីលរបស់អញប្រហែលជាបែកធ្លាយ ដោយហេតុនោះទើបឧបរាជប្រាប់ដល់ទូតទាំងនោះថា យើងរក្សាកុរុធម៌ក៏ពិតតែឥឡូវនេះយើងមានការរង្កៀស ព្រោះហេតុនោះយើងមិនអាចឲ្យដល់អ្នកទាំងឡាយបាន ។ ហើយប្រាប់រឿងនោះ ។ លំដាប់នោះទើបទូតទាំងឡាយទូលឧបរាជថា បពិត្រព្រះសម្មតិទេព ទ្រង់មិនមានការគិតថា ជនទាំងនេះចូរលំបាក ដូច្នេះកម្មដែលធ្វើដោយមិនមានចេតនា មិនចាត់ថាជាកម្មឡើយ កាលទ្រង់ធ្វើការរង្កៀស ដោយហេតុមានប្រមាណប៉ុណ្ណេះ ការកន្លងល្មើសរបស់ទ្រង់នឹងមានដូចម្ដេច ហើយទទួលយកសីលក្នុងសម្នាក់របស់ឧបរាជនោះចារឹកក្នុងជំបារមាស ។

ពួកទូតដែលឧបរាជត្រាស់ថា កាលបើយ៉ាងនោះសីលក៏មិនធ្វើឲ្យយើងត្រេកអរបាន បុរោហិតរមែងរក្សាបានល្អ ពួកអ្នកចូរកាន់យកក្នុងសម្នាក់របស់បុរោហិតនោះចុះ ទើបនាំគ្នាចូលទៅរកបុរោហិតហើយសូមកុរុធម៌ ។

ចំណែកបុរោហិតនោះថ្ងៃមួយទៅគាល់ព្រះរាជាវាំងផ្លូវបានឃើញរថមានពណ៌ស្រទន់ស្អាតដូចពន្លឺព្រះអាទិត្យទើបតែរះដែល ព្រះរាជាមួយអង្គទ្រង់បញ្ជូនមកថ្វាយព្រះរាជាអង្គនោះទើបសួរថា នេះរថរបស់នរណា បានស្តាប់ថា នាំមកថ្វាយព្រះរាជាទើបគិតថា អញក៏ចាស់ហើយ បើព្រះរាជាព្រះរាជទានរថនេះដល់អាត្មាអញសោតអាត្មាអញនឹងឡើងរថនេះត្រាច់ទៅយ៉ាងផាសុខដូច្នេះ ហើយទើបទៅគាល់ព្រះរាជា ។ ក្នុងវេលាដែលបុរោហិតនោះថ្វាយព្រះពរជ័យឈរគាល់រាជបុរសក្នុងនគរដទៃក៏ទូលថ្វាយរថដល់ព្រះរាជា ។ ព្រះរាជាទតឃើញហើយត្រាស់ថា រថរបស់យើងនេះស្អាតលើសលុប ពួកអ្នកចូរឲ្យដល់អាចារ្យរបស់យើងចុះ ។ បុរោហិតមិនប្រាថ្នាទទួលសូម្បីព្រះរាជាត្រាស់រឿយៗក៏មិនប្រាថ្នានឹងទទួលឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបានឮថា បុរោហិតនោះមានការគិតយ៉ាងនេះថា អញរក្សាកុរុធម៌ពិតៗនៅធ្វើសេចក្តីលោភក្នុងទ្រព្យរបស់អ្នកដទៃ សីលរបស់អញ គប្បីបែកធ្លាយទៅហើយ ។ ទើបបុរោហិតនោះប្រាប់រឿងនោះហើយពោលថា បាទាំងឡាយយើងមានការរង្កៀសក្នុងកុរុធម៌កុរុធម៌នោះ មិនបានញុំាងយើងឲ្យត្រេកអរឡើយព្រោះដូច្នោះយើងមិនអាចឲ្យ ។ លំដាប់នោះទូតទាំងឡាយទើបពោលនឹងបុរោហិតថា បពិត្រលោកម្ចាស់ សីលរមែងមិនបែកធ្លាយដោយហេតុត្រឹមតែកើតសេចក្តីលោភ លោកកាលធ្វើការរង្កៀសសូម្បីដោយហេតុមានប្រមាណប៉ុណ្ណេះនឹងធ្វើសេចក្តីល្មើសបានដូចម្តេច ។ ហើយទទួលយកសីលក្នុងសម្នាក់របស់បុរោហិតនោះចារឹកក្នុងជំបារមាស ។

ទូតទាំងឡាយកាលបុរោហិតពោលថា កាលបើយ៉ាងនោះ កុរុធម៌ក៏មិនញ៉ាំងយើងឲ្យត្រេកអរបានឡើយ អាមាត្យអ្នកវាស់ដីរក្សាបានល្អ ពួកអ្នកចូរទទួលយកក្នុងសម្នាក់របស់អាមាត្យនោះចុះ ។ ទើបនាំគ្នាចូលទៅរកអាមាត្យនោះហើយសូមកុរុធម៌ ។ ចំណែកអាមាត្យអ្នកវាស់ដីនោះ ថ្ងៃមួយកាលនឹងវាស់ស្រែក្នុងជនបទ ទើបយកខ្សែចងត្រង់ឈើ ឲ្យម្ចាស់របស់ស្រែចាប់ចុងម្ខាងខ្លួនឯងចាប់ចុងម្ខាង ។ ឈើដែលចងចុងខ្សែដែលអាមាត្យកាន់ដល់ត្រង់កណ្ដាលរន្ធក្ដាមមួយ ។ អាមាត្យនោះគិតថា បើអញដោតក្នុងរន្ធក្ដាម ក្ដាមក្នុងរន្ធនឹងវិនាស បើអញដោតទៅខាងមុខដីរបស់ព្រះរាជាក៏នឹងខាតបង់ បើអញដោតមកក្រោយដីរបស់កុដុម្ពិកៈក៏និងខាត អញធ្វើដូចម្ដេចល្អហ្ន៎ ។ លំដាប់នោះអាមាត្យនោះមានការគិតដូច្នេះថា ក្ដាមគួរមិនមានក្នុងរន្ធ បើមាននឹងត្រូវប្រាកដ អញនឹងដោតឈើនោះត្រង់នេះឯង ដូច្នេះហើយទើបដោតឈើនោះទៅក្នុងរន្ធ ។ ចំណែកក្ដាមក៏បញ្ចេញសំឡេងក្រឹក ។ លំដាប់នោះអាមាត្យនោះមានគំនិតដូច្នេះថា កំណាត់ឈើនឹងដោតចំស្នូកក្ដាម ក្ដាមក៏នឹងស្លាប់ ឯអញក៏រក្សាកុរុធម៌ព្រោះហេតុនោះសីលរបស់អញនឹងបែកធ្លាយ ។ អាមាត្យនោះក៏ប្រាប់រឿងនោះដល់ទូតទាំងឡាយ ហើយពោលថា ព្រោះហេតុការដូចពណ៌នាមកនេះទើបមានការរង្កៀសក្នុងកុរុធម៌ ដោយហេតុនោះយើងមិនអាចឲ្យដល់ពួកលោក ។ លំដាប់នោះទើបទូតទាំងឡាយពោលចំពោះអាមាត្យនោះថា លោកម្ចាស់ មិនមានចិត្តគិតថាក្ដាមចូរស្លាប់ ដូច្នេះកម្មដែលមិនមានចេតនានឹងសម្លាប់ មិនឈ្មោះថាជាកម្ម លោកធ្វើនូវសេចក្ដី

រន្ធៀសដោយហេតុមានប្រមាណប៉ុណ្ណោះនឹងធ្វើការល្មើសដូចម្តេចបាន ។ ហើយទទួលយកសីលក្នុងសម្នាក់របស់អាមាត្យនោះហើយចារឹកក្នុងជំពូរមាស ។

អាមាត្យនោះពោលថា កាលបើយ៉ាងនេះកុរុធម៌ក៏មិនបានធ្វើខ្ញុំឲ្យត្រេកអរបាន ឯនាយសារថីរក្សាបានយ៉ាងល្អ អ្នកទាំងឡាយចូរទទួលយកក្នុងសម្នាក់របស់នាយសារថីនោះចុះ ។ ទើបចូលទៅរកនាយសារថីនោះ ហើយសូមកុរុធម៌ ។ នាយសារថីនោះថ្ងៃមួយនាំព្រះរាជាទៅកាន់ព្រះរាជឧទ្យានដោយរាជរថ ។ ព្រះរាជាទ្រង់លេងក្នុងព្រះរាជឧទ្យាននោះអស់មួយថ្ងៃ ក្នុងវេលាល្ងាចទើបយាងចេញអំពីព្រះរាជឧទ្យានឡើងកាន់រថ ។ កាលរាជរថនោះនៅមិនទាន់ដល់ព្រះនគរភ្លៀងក៏តាំងឡើង ក្នុងវេលាដែលព្រះអាទិត្យអស់ស្តង្គត ។ ព្រោះខ្លាចថា ព្រះរាជាទទឹកភ្លៀងនាយសារថីក៏បានឲ្យសញ្ញាដោយជន្ទួញដល់សេះសិន្ធពទាំងឡាយ ។ សេះសិន្ធពទាំងឡាយទើបរត់ទៅដោយរហ័ស ។ តាំងអំពីនោះមកសេះសិន្ធពនោះដើរទៅកាន់ព្រះរាជឧទ្យានក្តី ដើរមកអំពីព្រះរាជឧទ្យានក្តីគ្រាន់តែដល់ទីនោះក៏ស្ទុះទៅដោយរហ័សទាំងទៅទាំងមក ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបានឮថា សេះសិន្ធពទាំងនោះមានការគិតដូច្នេះថា ក្នុងទីនេះគប្បីមានអន្តរាយពិត ដោយហេតុនោះនាយសារថីរបស់ពួកយើងទើបឲ្យសញ្ញាដោយជន្ទួញក្នុងកាលនោះ ។ នាយសារថីក៏មានការគិតយ៉ាងនេះថា ក្នុងកាលព្រះរាជាសើមដោយភ្លៀងឬមិនសើមដោយភ្លៀងអញនឹងមានទោសអ្វី តែអញបានឲ្យសញ្ញាដោយជន្ទួញដល់សេះសិន្ធពដែលហ្វឹកហាត់មកល្អហើយក្នុងហេតុដែលមិនសមគួរ ដោយហេតុនោះសេះសិន្ធព

ទាំងនេះសុះទាំងទៅនិងទាំងមកលំបាកដល់កាលឥឡូវនេះ ឯអាត្មាអញក៏រក្សាកុរុធម៌ ដោយហេតុនោះ សីលរបស់អញគង់នឹងបែកធ្លាយហើយ ។ នាយសារថីនោះ ទើបប្រាប់រឿងនោះឲ្យជ្រាបហើយពោលថា ព្រោះហេតុនេះទើបខ្ញុំមានការរង្កៀសក្នុងកុរុធម៌ ព្រោះហេតុនោះទើបខ្ញុំមិនអាចឲ្យដល់ពួកលោកបាន ។ លំដាប់នោះទូតទាំងឡាយទើបពោលនឹងនាយសារថីនោះថា លោកមិនមានចិត្តគិតថា សេះសិន្ធពទាំងឡាយចូរលំបាកដូច្នេះ កម្មដែលមិនមានចេតនា គឺការតាំងចិត្តមិនរាប់ថាជាកម្មឡើយ មួយទៀតលោកធ្វើការរង្កៀសដោយហេតុមានប្រមាណប៉ុណ្ណេះនឹងធ្វើការល្មើសបានដូចម្ដេច ។ ទើបទទួលយកសីលក្នុងសម្នាក់របស់នាយសារថីនោះចារឹកក្នុងជំបារមាស ។

ទូតទាំងឡាយដែលនាយសារថីពោលថា កាលបើយ៉ាងនេះសីលក៏មិនបានធ្វើឲ្យយើងត្រេកអរតែសេដ្ឋីរក្សាបានល្អ ពួកអ្នកចូរទទួលយកក្នុងសម្នាក់របស់សេដ្ឋីនោះចុះទើបចូលទៅរកសេដ្ឋីនោះហើយសូមកុរុធម៌ ។ សេដ្ឋីនោះថ្ងៃមួយទៅនាំស្រូវសាលីរបស់ខ្លួន ពិចារណាកួរស្រូវសាលីដែលចេញមកកាលត្រឡប់គិតថា អញនឹងចងកួរស្រូវសាលីឲ្យជាគុម្ពដូច្នេះហើយទើបឲ្យមនុស្សប្រមូលកួរស្រូវសាលីរួមគ្នាហើយចងជាកំនួចទុក ។ លំដាប់នោះសេដ្ឋីមានការគិតដូច្នេះថា អញត្រូវបង់ពន្ធឲ្យព្រះរាជាអំពីស្រែនេះតែអញក៏បានឲ្យមនុស្សកាន់យកកួរស្រូវសាលី ( ដែលធ្វើជាកំនួច ) មួយក្ដាប់អំពីស្រែដែលមិនទាន់បានបង់ពន្ធឲ្យព្រះរាជា ឯអញរក្សាកុរុធម៌ព្រោះហេតុនោះសីលរបស់អញគង់នឹងបែកធ្លាយហើយ ។ សេដ្ឋីនោះក៏ប្រាប់រឿងនោះដល់

ទូតទាំងឡាយហើយពោលថា ខ្ញុំមានការរង្កៀសក្នុងកុរុធម៌ដោយហេតុនេះ ព្រោះហេតុនោះខ្ញុំមិនអាចឲ្យកុរុធម៌ដល់ពួកលោកបានឡើយ ។ លំដាប់នោះ ទូតទាំងឡាយក៏ពោលនឹងសេដ្ឋីថា លោកមិនមានចេយ្យចិត្តគិតនឹងលួច វៀរចេយ្យចិត្តនោះចេញ បុគ្គលណាមួយមិនអាចបញ្ញត្តអទិន្នាទានបាន ឯលោកធ្វើនូវការរង្កៀសដោយហេតុមានប្រមាណប៉ុណ្ណោះនឹងកាន់យកទ្រព្យអ្នកដទៃបានដូចម្តេចហើយទទួលយកសីលក្នុងសម្នាក់របស់សេដ្ឋីនោះហើយចារឹកក្នុងដំបារមាស ។

ទូតទាំងឡាយដែលលោកសេដ្ឋីពោលថា កាលបើយ៉ាងនោះសីលក៏មិនបានធ្វើខ្ញុំឲ្យត្រេកអរបាន តែអាមាត្យអ្នកវាល់ស្រូវរក្សាបានល្អ ពួកលោកចូរកាន់យកក្នុងសម្នាក់របស់អាមាត្យដែលវាល់ស្រូវនោះចុះ ។ ទើបនាំគ្នាចូលទៅរកអាមាត្យអ្នកវាល់ស្រូវហើយសូមកុរុធម៌ ។ បានឮថា អាមាត្យដែលវាល់ស្រូវនោះ ថ្ងៃមួយអង្គុយត្រង់ខ្លោងទ្វារឲ្យមនុស្សវាល់ស្រូវដែលជាចំណែករបស់ព្រះរាជា ចំណែកខ្លួនឯងយកស្រូវអំពីគំនរដែលមិនទាន់បានវាល់ ( ស្រូវគហបតី ) ធ្វើជាខ្នាច់ ។ ខណៈនោះភ្លៀងក៏ធ្លាក់ ។ មហាមាត្យក៏បន្ថែមខ្នាច់ស្រូវហើយពោលថា ស្រូវដែលវាល់ហើយមានប្រមាណប៉ុណ្ណោះ ហើយកើបស្រូវដែលជាខ្នាច់ដាក់ក្នុងគំនរស្រូវដែលវាល់ហើយ ( ស្រូវព្រះរាជា ) ក៏ប្រញាប់ទៅឈរត្រង់ខ្លោងទ្វារហើយគិតថា អាត្មាអញដាក់ស្រូវដែលជាខ្នាច់ក្នុងគំនរស្រូវដែលវាល់ហើយ ឬដាក់ក្នុងគំនរស្រូវដែលមិនទាន់បានវាល់ ។ លំដាប់នោះមហាមាត្យមានគំនិតដូច្នេះថា បើអញដាក់

ក្នុងគំនរស្រូវដែលវាល់ហើយ ស្រូវរបស់ព្រះរាជាក៏នឹងចម្រើនឡើងដោយមិនមានហេតុ ស្រូវទាំងឡាយរបស់គហបតីក៏ខាតទៅ[១] ឯអាត្មាអញក៏រក្សាកុរុធម៌ ដោយហេតុនោះសីលរបស់អាត្មាអញត្រូវបែកធ្លាយហើយ ។ អាមាត្យនោះក៏ប្រាប់រឿងនោះហើយពោលថា ខ្ញុំមានការរង្កៀសក្នុងកុរុធម៌ដោយហេតុនេះ ព្រោះហេតុនោះខ្ញុំមិនអាចឲ្យដល់ពួកអ្នកបានឡើយ ។ លំដាប់នោះទូតទាំងឡាយទើបពោលចំពោះមហាមាត្យនោះថា លោកមិនមានថេយ្យ ចិត្តគិតនឹងលួច វៀរថេយ្យចិត្តនោះចេញ បុគ្គលណាមួយមិនអាចបញ្ញត្តអទិន្នាទានបាន ក៏លោកធ្វើនូវការរង្កៀសដោយហេតុមានប្រមាណប៉ុណ្ណេះនឹងកាន់យកទ្រព្យរបស់អ្នកដទៃបានដូចម្តេច ហើយទទួលយកសីលក្នុងសម្នាក់របស់មហាមាត្យដែលវាល់ស្រូវនោះចារឹកក្នុងជំបារមាស ។

ឯទូតទាំងឡាយដែលមហាមាត្យពោលថា កាលបើយ៉ាងនោះសីលក៏មិនធ្វើឲ្យយើងត្រេកអរបានតែឆ្មាំទ្វាររក្សាបានល្អ អ្នកទាំងឡាយចូរកាន់យកក្នុងសម្នាក់របស់ឆ្មាំទ្វារនោះចុះ ទើបនាំគ្នាចូលទៅរកឆ្មាំទ្វារនោះហើយសូមកុរុធម៌ ។ ចំណែកឆ្មាំទ្វារនោះ ថ្ងៃមួយ វេលាបិទទ្វារនគរបានបញ្ចេញសំឡេងប្រកាសឡើង ៣ ដង ។ កាលនោះមានបុរសក្រីក្រម្នាក់ចូលព្រៃរកឧសនិងបន្លែជាមួយប្អូនស្រីកំពុងត្រឡប់មកបានឮសំឡេងឆ្មាំទ្វារនោះប្រកាសទើបប្រញាប់

---

១-មហាមាត្យយកគ្រាប់ស្រូវរបស់គហបតីធ្វើជាខ្នាច់ដាក់គ្រាប់ស្រូវមួយរាប់ថាមួយ ដាក់គ្រាប់ស្រូវពីររាប់ថាពីរ ជាដើមកាលភ្លៀងធ្លាក់មកក៏កើបគ្រាប់ស្រូវដែលជាខ្នាច់នោះបោះទៅក្នុងពំនូកស្រូវរបស់ព្រះរាជា ហើយខ្លួនក៏ភ្លេច ទើបមានការគិតយ៉ាងនេះ ( អ្នកប្រែ ) ។

នាំប្អូនស្រីមកមួយរំពេច ។ លំដាប់នោះ ឆ្មាំទ្វារពោលនឹងបុរសក្រីក្រនោះថា អ្នកមិនដឹងថា ព្រះរាជាមាននៅក្នុងព្រះនគរនេះឬ អ្នកមិនដឹងឬថាគេនឹងបិទទ្វារព្រះនគរនេះនៅពេលល្ងាច អ្នកនាំកិរិយារបស់ខ្លួនត្រាច់ទៅក្នុងព្រៃត្រាច់លេងរីករាយអស់មួយថ្ងៃ ។ កាលបុរសក្រីក្រពោលថា នែអ្នក មិនមែនកិរិយាខ្ញុំទេ ស្រីនេះជាប្អូនស្រីរបស់ខ្ញុំ ។ ឆ្មាំទ្វារនោះក៏មានបរិវិតក្កៈដូច្នេះថា អាត្មាអញ យកប្អូនស្រីរបស់គេមកនិយាយថាជាកិរិយា ធ្វើកម្មដែលមិនមែនជាហេតុហ្ន៎ ឯអញក៏រក្សាកុរុធម៌ ដោយហេតុនោះសីលរបស់អាត្មាអញគប្បីបែកធ្លាយហើយ ។ ឆ្មាំទ្វារនោះក៏ប្រាប់រឿងនោះហើយពោលថា ខ្ញុំមានការរង្កៀសក្នុងកុរុធម៌ដោយហេតុនេះ ព្រោះហេតុនោះ ខ្ញុំមិនអាចឲ្យដល់ពួកអ្នកបានឡើយ ។ លំដាប់នោះទូតទាំងឡាយក៏ពោលចំពោះឆ្មាំទ្វារនោះថា ពាក្យនោះលោកពោលតាមការសំគាល់យ៉ាងនោះ ក្នុងសេចក្ដីនេះ ការបែកធ្លាយនៃសីលមិនមានដល់លោក លោករង្កៀសដោយហេតុមានប្រមាណប៉ុណ្ណោះ នឹងធ្វើសម្បជានមុសាវាទគឺពោលកុហកទាំងដឹងខ្លួនក្នុងកុរុធម៌បានដូចម្ដេច ហើយកាន់យកសីលក្នុងសម្នាក់របស់ឆ្មាំទ្វារនោះចារឹកក្នុងដំបារមាស ។

ទូតទាំងឡាយកាលឆ្មាំទ្វារនោះពោលថា កាលបើយ៉ាងនោះសីលក៏មិនញុំាងឲ្យខ្ញុំត្រេកអរបានតែនាងវណ្ណទាសីរក្សាបានល្អ ពួកអ្នកចូរកាន់យកក្នុងសម្នាក់របស់នាងវណ្ណទាសីនោះចុះ ទើបនាំគ្នាចូលទៅរកនាងវណ្ណទាសីនោះហើយសូមកុរុធម៌ ។ ចំណែកនាងវណ្ណទាសីក៏បដិសេធដោយន័យដែលមានខាងដើមនោះឯង ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបានឮថា

សក្កទេវរាជស្តេចទេវតាទ្រង់ព្រះតម្រិះថានឹងសាកល្បងសីលរបស់នាងដូច្នេះ ហើយទើបកាឡាខ្លួនជាមាណពមកនិយាយថា ខ្ញុំនឹងមករកហើយឲ្យទ្រព្យ ១០០០ ត្រឡប់ទៅកាន់ទេវលោកហើយមិនមកអស់កាល ៣ ឆ្នាំ ។ នាងវណ្ណទាសីនោះមិនទទួលទ្រព្យសូម្បីត្រឹមស្លាម្លូអំពីដៃបុរសដទៃអស់ ៣ ឆ្នាំ ព្រោះខ្លាចដាច់សីលរបស់ខ្លួន ។ នាងធ្លាក់ខ្លួនក្រីក្រដោយលំដាប់ទើបគិតថា កាលបើបុរសដែលឲ្យទ្រព្យ ១០០០ ដល់អាត្មាអញ ហើយជៀសចេញទៅមិនមកអស់ ៣ ឆ្នាំ អញធ្លាក់ខ្លួនក្រីក្រមិនអាចបន្តជីវិតទៅបាន ចាប់អំពីនេះទៅអញគួរប្រាប់ដល់មហាមាត្យអ្នកវិនិច្ឆ័យក្តី ហើយទទួលយកតម្លៃ ( អំពីបុរសដទៃ ) ។ ទើបនាងទៅកាន់ទីវិនិច្ឆ័យពោលថា បពិត្រលោកម្ចាស់ បុរសដែលឲ្យតម្លៃដល់ខ្ញុំហើយជៀសចេញទៅអស់ ៣ ឆ្នាំហើយ ខ្ញុំមិនដឹងថា គេស្លាប់ឬរស់ ខ្ញុំមិនអាចបន្តការចិញ្ចឹមជីវិតបាន បពិត្រលោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច មហាមាត្យអ្នកវិនិច្ឆ័យក្តីពោលថា កាលបុរសនោះមិនមកអស់កាល ៣ ឆ្នាំ នាងនឹងធ្វើអ្វី តាំងអំពីនេះទៅចូរនាងទទួលតម្លៃចុះ ។ កាលនាងវណ្ណទាសីនោះបានទទួលការវិនិច្ឆ័យក្តីហើយលុះចេញអំពីទីវិនិច្ឆ័យប៉ុណ្ណោះបុរសម្នាក់ក៏នាំកញ្ចប់ទ្រព្យ ១០០០ ចូលមកឲ្យ ។ ក្នុងខណៈដែលនាងលាដៃទទួល សក្កទេវរាជក៏បង្ហាញខ្លួនឲ្យឃើញ ។ នាងគ្រាន់តែឃើញសក្កទេវរាជនោះប៉ុណ្ណោះ ក៏ដកដៃចេញពោលថា បុរសដែលឲ្យទ្រព្យដល់ខ្ញុំ ១០០០ កាលពី ៣ ឆ្នាំមុនបានត្រឡប់មកហើយ នៃអ្នក ខ្ញុំមិនត្រូវការកហាបណៈរបស់អ្នកទេ ។ ទើបសក្កទេវរាជធ្វើកាយរបស់ព្រះអង្គឲ្យដូចដើម

ប្រថាប់ឈរក្នុងអាកាសបញ្ចេញរស្មីដូចព្រះអាទិត្យដ៏ស្រទន់ដូច្នោះ ។ អ្នកនគរទាំងអស់នាំគ្នាភ្ញាក់ផ្អើល ។ សក្កទេវរាជបានប្រទានឱវាទក្នុងកណ្តាលមហាជនថា ក្នុងទីបំផុត ៣ ឆ្នាំមកហើយយើងឲ្យទ្រព្យ ១០០០ ដើម្បីសាកល្បងនាងវណ្ណទាសីនេះ អ្នកទាំងឡាយដែលឈ្មោះថាការរក្សាសីល ចូរជាអ្នកមានសភាពបែបនេះ រក្សាចុះ ហើយទ្រង់បណ្តាលឲ្យនិវេសន៍របស់នាងវណ្ណទាសីពេញដោយរតនៈ ៧ ប្រការ ទ្រង់ទូន្មាននាងវណ្ណទាសីនោះថា នាងចូរជាអ្នកមិនប្រមាទតាំងអំពីនេះទៅ ហើយទ្រង់យាងទៅកាន់ទេវលោកនោះឯងព្រោះហេតុនេះទើបនាងវណ្ណទាសីនោះបដិសេធហាមទូតទាំងឡាយថា ខ្ញុំមិនបានដោះបេ្តជ្ញាលូកដៃទទួលតម្លៃដែលប្រុសដទៃឲ្យ ដោយហេតុនេះទើបសីលធ្វើឲ្យខ្ញុំត្រេកអរមិនបាន ព្រោះហេតុនោះ ខ្ញុំមិនអាចឲ្យដល់លោកទាំងឡាយឡើយ ។ លំដាប់នោះទូតទាំងឡាយក៏ពោលចំពោះនាងវណ្ណទាសីនោះថា សីលភេទរមែងមិនមានដោយហេតុត្រឹមតែលាដៃចេញឈ្មោះថា សីលរមែងបរិសុទ្ធក្រៃលែងដោយប្រការដូច្នេះ ហើយទទួលយកសីលក្នុងសម្នាក់របស់នាងវណ្ណទាសីនោះចារឹកក្នុងជំបារមាស ។

ទូតទាំងឡាយចារឹកសីលដែលជនទាំង ១១ នាក់នោះរក្សាក្នុងជំបារមាសដោយប្រការដូច្នេះហើយបានទៅកាន់ទន្តបុរនគរ ថ្វាយជំបារមាសដល់ព្រះបាទកាលិង្គៈ ហើយក្រាបទូលព្រឹត្តិការណ៍នោះឲ្យទ្រង់ជ្រាប ។ ព្រះរាជាកាលទ្រង់ប្រព្រឹត្តកុរុធម៌នោះទ្រង់បំពេញសីល ៥ ឲ្យបរិបូណ៌ ។ ក្នុងកាលនោះភ្លៀងក៏ធ្លាក់ចុះក្នុងកាលិង្គរដ្ឋទាំងមូលភ័យទាំង ៣ ក៏ស្ងប់រម្ងាប់ ។ ដែនក៏

មានសេចក្ដីក្រេមក្សាន្តមានកិច្ចាហារបរិបូណ៌ ។ ព្រះពោធិសត្វទ្រង់ធ្វើបុណ្យមានទានជាដើមដរាបអស់ព្រះជន្មមួយអន្លើដោយបរិវារ បានធ្វើស្ថានសួគ៌ឲ្យពេញ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ជនពួកខ្លះបានជាសោតាបន្ន ពួកខ្លះបានជាសកទាគាមី ពួកខ្លះបានជាអនាគាមី ពួកខ្លះបានជាអរហត្ត ហើយព្រះសាស្ដាទ្រង់ប្រជុំជាតកថា នាងវណ្ណទាសីស្រីគណិកាក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណាក្នុងកាលឥឡូវនេះ ឆ្មាំទ្វារក្នុងកាលនោះបានមកជាបុណ្ណភិក្ខុ រជ្ជុគាហកៈអាមាត្យដែលវាស់ដីក្នុងកាលនោះ បានមកជាកច្ចាយនៈ ទោណមាបកៈអាមាត្យដែលវាល់ស្រូវក្នុងកាលនោះ បានមកជាមោគ្គល្លាន សេដ្ឋីក្នុងកាលនោះបានមកជាសារីបុត្ត នាយសារថីក្នុងកាលនោះបានមកជាអនុរុទ្ធៈ ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាព្រះកស្សបត្ថេរៈ មហាឧបរាជក្នុងកាលនោះបានមកជានន្ទបណ្ឌិត ព្រះមហេសីក្នុងកាលនោះបានមកជារាហុលមាតា ព្រះជននីក្នុងកាលនោះបានមកជាព្រះនាងមាយាទេវី ព្រះបាទកុរុរាជពោធិសត្វក្នុងកាលនោះ គឺតថាគតនេះឯង អ្នកទាំងឡាយចូរចាំជាតកនេះដោយប្រការដូច្នេះ ។

**អដ្ឋកថា កុរុធម្មជាតក ចប់**

## រោមជាតក

[ ៤៣០ ] ( តាបសពោលថា ) ម្នាលរោមកៈ យើងនៅក្នុងគុហាក្នុំជាង ៥០ ឆ្នាំ ពួកអណ្ឌជសត្វ ( សត្វកើតអំពីពងទាំងនេះ ) មិនមានសេចក្តីរង្កៀស ជាសត្វមានចិត្តស្លូតត្រង់រមែងមកកាន់កណ្តាប់ដៃនៃយើងក្នុងកាលមុន ។

[ ៤៣១ ] ម្នាលសត្វមានអវយវៈកោង ឥឡូវនេះពួកទិជសត្វ ( សត្វកើតពីរដង ) ទាំងនោះ ( ឃើញ ) ហេតុអ្វីបានជាមានសេចក្តីខ្វល់ខ្វាយ ( គេចចេញអំពីញកភ្នំនេះ ) ទៅនៅក្នុងញកភ្នំដទៃវិញក្រែង ( ពួកបក្សីទាំងនេះ ) ទៅឃ្លាតឃ្លាយបានជាមិនស្គាល់យើងដូចជាក្នុងកាលមុន ឬក៏ពួកបក្សីទាំងនេះមិនមែនជាពួកបក្សីទាំងនោះទេ ។

[ ៤៣២ ] ( ពោធិសត្វពោលថា ) ពួកយើងស្គាល់លោកមិនមែនប្រឡំទេ លោកក៏គឺលោកហ្នឹងដដែល ពួកយើងគឺសត្វទាំងនោះមិនមែនជាសត្វដទៃទេ តែថាចិត្តរបស់លោកប្រទូស្តចំពោះពួកជននេះ ម្នាលអាជីវកៈ ព្រោះហេតុនោះបានជាពួកយើងតក់ស្លុតនឹងលោក ។

**ចប់ រោមជាតកទី ៧ ។**

# អដ្ឋកថា

## រោមជាតក

[ ៤៣០-៤៣២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការខ្នះខ្នែងដើម្បីផ្តាច់ព្រះជន្មព្រះមានព្រះភាគ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វស្សានិ បញ្ញាស សមាធិកានិ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្នមានសេចក្តីងាយយល់ទាំងអស់ហើយ ។ ចំណែករឿងអតីតមានដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាសត្វព្រាប មានសត្វព្រាបជាច្រើនហែហម សម្រេចការនៅក្នុងគុហាភ្នំមួយកន្លែងក្នុងព្រៃ ។ មានតាបសមួយរូបជាអ្នកមានសីលបរិបូណ៌ ដោយអាចារមារយាទចូលទៅអាស្រ័យបច្ចន្តគ្រាមមួយកន្លែង សាងអាស្រមបទនៅក្នុងទីមិនឆ្ងាយអំពីលំនៅរបស់សត្វព្រាបទាំងនោះ សម្រេចការនៅក្នុងបព្វតគុហា ។ ព្រះពោធិសត្វមកកាន់សម្នាក់របស់តាបសក្នុងចន្លោះៗមិនដាច់ ស្តាប់វត្ថុដែលគួរស្តាប់ ។ តាបសនៅក្នុងទីនោះអស់កាលយូរ ហើយជៀសចេញទៅ ។ កាលនោះជដិលកោងមួយរូបបានមកគង់នៅក្នុងបព្វតគុហានោះ ។ ចំណែកព្រះពោធិសត្វដែលមានសត្វព្រាបទាំងឡាយហែហម ចូលទៅរកជដិលកោងនោះ ថ្វាយបង្គំហើយធ្វើបដិសណ្ឋារៈត្រាច់ទៅក្នុងអាស្រមបទរកចំណីក្នុងទីជិតញកភ្នំក្នុងវេលាល្ងាច ទើបហើរទៅកាន់លំនៅរបស់ខ្លួន ។ តាបសកោងនៅក្នុងទីនោះអស់ ៥០ ឆ្នាំផ្សាយ ។ ថ្ងៃមួយអ្នកបច្ចន្តគ្រាមបានចម្អិនសាច់ព្រាបប្រគេនតាបសកោងនោះ ។ តាបសកោងនោះជាប់ចិត្តដោយតណ្ហា

ក្នុងរសនៃសាច់របស់សត្វព្រាបនោះទើបសួរថា នេះឈ្មោះថា សាច់អ្វី បាន ដឹងថា សាច់ព្រាប ដូច្នេះហើយទើបគិតថា សត្វព្រាបមានចំនួនច្រើនមក កាន់អាស្រមបទរបស់អញ អញសម្លាប់សត្វព្រាបទាំងនោះហើយ បរិភោគ សាច់ទើបគួរ ។ ជដិលកោងនោះទើបនាំយកអង្ករ សប្បិ ទធិ ខីរៈនិងម្រេច ជាដើមមកទុកក្នុងចំណែកម្ខាង យកជាយចីវរគ្របដំបង អង្គុយរង់ចាំសត្វព្រាប មកនៅត្រង់ទ្វារបណ្ណសាលា ។ ព្រះពោធិសត្វមានសត្វព្រាបហែហមហើរមក ឃើញកិរិយាអាក្រក់របស់ជដិលកោងនោះទើបគិតថា តាបសអាក្រក់នេះ អង្គុយដោយអាការយ៉ាងនេះខុសប្រក្រតី ប្រហែលជាបានបរិភោគសត្វដែល មានជាតិស្មើនឹងអញខ្លះហើយទេដឹង អញនឹងចាប់កំហុសតាបសកោងនោះ ដូច្នេះហើយទើបឈរនៅត្រង់ទីក្រោមខ្យល់ ហិតក្លិនខ្លួនរបស់តាបសនោះដឹង បានថា តាបសនេះបំណងនឹងសម្លាប់ពួកយើងបរិភោគ អញមិនគួរទៅកាន់ សម្នាក់របស់តាបសនោះ ដូច្នេះហើយទើបនាំព្រាបទាំងឡាយត្រឡប់មកវិញ ។ តាបសឃើញព្រាបនោះមិនមកទើបគិតថា អញគួរពោលមធុរកថា ពាក្យដ៏ ពីរោះជាមួយសត្វព្រាបទាំងនោះដូច្នេះហើយ សឹមសម្លាប់សត្វព្រាបដែលចូល មកជិតដោយការស្និទ្ធស្នាលហើយបរិភោគទើបបានពោលគាថា ២ ខាងដើម ថា

ម្នាលរោមកៈ យើងនៅក្នុងគុហាក្នុំជាង ៥០ ឆ្នាំ ពួកអណ្ឌជ
សត្វ ( សត្វកើតអំពីពងទាំងនេះ ) មិនមានសេចក្តីរង្កៀស
ជាសត្វមានចិត្តស្លូតត្រង់ រមែងមកកាន់កណ្តាប់ដៃនៃយើងក្នុង

កាលមុន ។

ម្នាលសត្វមានអវយវៈក្ងក់ ឥឡូវនេះពួកទិជសត្វ ( សត្វកើតពីរដង ) ទាំងនោះ ( ឃើញ ) ហេតុអ្វីបានជាមានសេចក្ដីខ្វល់ខ្វាយ ( គេចចេញអំពីញកភ្នំនេះ ) ទៅនៅក្នុងញកភ្នំដទៃវិញក្រែង ( ពួកបក្សីទាំងនេះ ) ទៅឃ្លាតឃ្លាបាន ជាមិនស្គាល់យើងដូចជាក្នុងកាលមុន ឬក៏ពួកបក្សីទាំងនេះមិនមែនជាពួកបក្សីទាំងនោះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមាធិកានិ** កាត់បទជា **សម អធិកានិ** ប្រែថា មានចំនួន ៥០ ឆ្នាំជាង ។ បទថា **រោមក** ប្រែថា ដែលមានរោមដុះឡើង ។ តាបសកោងហៅព្រះពោធិសត្វថា បារាវត: ព្រោះមានជើងនិងភ្នែក មានពណ៌ស្មើដោយកែវប្រពាលដែលច្នៃល្អហើយ ។ បទថា **អសង្កមានា** សេចក្ដីថា កាលយើងនៅក្នុងបព្វតគុហានេះជាង ៥០ ឆ្នាំយ៉ាងនេះ បក្សីទាំងនេះមិនបានធ្វើសេចក្ដីរង្កៀសយើងត្រឹមតែមួយថ្ងៃ ជាអ្នកមានចិត្តត្រជាក់ក្រៃលែង កាលមុនរមែងមកកាន់ហត្ថបាសរបស់យើងដោយឱកាស លូមលូកដៃដល់ ។ បទថា **តេទានិ** កាត់បទជា **តេ ឥទានិ** ប្រែថា ឥឡូវនេះបក្សីទាំងនោះ ។ តាបសកោងហៅព្រះពោធិសត្វថា **វង្កង្គ** ដែលមានអវយវៈក្ងក់ ។ បក្សីគ្រប់ប្រភេទហៅបានថា **វង្កង្គ** មានអវយវៈក្ងក់ ព្រោះក្នុងវេលាហើរធ្វើកក្ងក់ហើរទៅ ។ បទថា **កិមត្ថំ** សេចក្ដីថា ឃើញហេតុអ្វី ។ បទថា **ឧស្សុក្កា** បានដល់ ជាអ្នករអាចិត្ត ។ បទថា

**គិរិកណ្ណំ** បានដល់ ញកក្នុងទៃអំពីភ្នំ ។ បទថា **យថា បុរេ** សេចក្ដីថា កាលមុនសត្វទាំងនេះរមែងសម្គាល់យើងថាជាទីគោរព ជាទីស្រឡាញ់យ៉ាងណា ឥឡូវនេះរមែងមិនសម្គាល់យ៉ាងនោះឡើយ លោកសម្ដែងសេចក្ដីថា បក្សីទាំងនេះប្រហែលជាសម្គាល់យើងយ៉ាងនេះថា តាបសដែលធ្លាប់នៅក្នុងទីនេះអំពីមុនជាមនុស្សម្នាក់ តាបសនេះជាមនុស្សម្នាក់ទៀត គឺខុសគ្នាដោយឡែក ។ ដោយបទថា **ចិរប្បវុដ្ឋា អថវា ន តេ ឥមេ** នេះ តាបសគោងសួរថា បក្សីទាំងនេះ ព្រាត់ប្រាសទៅអស់កាលយូរ ព្រោះរយៈកាលយូរកន្លងទៅទើបបានមក ទើបចាំយើងមិនបានថា តាបសនេះក៏គឺតាបសរូបនោះឯង ឬថាបក្សីពួកណាមានចិត្តត្រជាក់ដ៏ក្រៃលែងក្នុងយើង បក្សីទាំងនោះមិនមែនបក្សីទាំងនេះ គឺជាបក្សីពួកដទៃសញ្ចរមកដោយ ហេតុនោះទើបបក្សីទាំងនេះមិនចូលមកជិតយើង ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះ ទើបបែរត្រឡប់មកឈរពោលគាថាទី ៣ ថា

> ពួកយើងស្គាល់លោកមិនមែនប្រទ្បាំទេ លោកក៏គឺលោកហ្នឹង
> ដដែល ពួកយើងគឺសត្វទាំងនោះមិនមែនជាសត្វដទៃទេ តែ
> ថាចិត្តរបស់លោកប្រទូស្តចំពោះពួកជននេះ ម្នាលអាជីវកៈ
> ព្រោះហេតុនោះបានជាពួកយើងតក់ស្លុតនឹងលោកដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន មយំ សម្មូឡ្ហា** សេចក្ដីថា ពួកយើងជាអ្នកវង្វេង គឺជាអ្នកស្រវឹង ក៏មិនមែន ។ បទថា **ចិត្តញ្ច តេ អស្មិ**

**ជនេ បទុដ្ឋំ** សេចក្ដីថា លោកគឺលោកហ្នឹងដដែល ឯខ្ញុំគឺបក្សីទាំងនោះនៅចាំលោកបាន ម្យ៉ាងទៀតចិត្តរបស់លោកប្រទូស្តក្នុងជន គឺកើតចិត្តដើម្បីនឹងសម្លាប់ពួកយើង ។ បទថា **អាជីវក** បានដល់ តាបសអាក្រក់ អ្នកបួសព្រោះហេតុត្រូវការចិញ្ចឹមជីវិត ។ បទថា **តេន តំ ឧត្តសាម** សេចក្ដីថា ព្រោះហេតុនោះ ទើបខ្ញុំតក់ស្លុតនឹងលោកមិនចូលទៅជិត ។

តាបសកោងគិតថា បក្សីទាំងនេះស្គាល់អញដូច្នេះហើយទើបគ្រវែងដំបងទៅតែខុសទើបពោលថា ចូរទៅចុះបក្សីដ៏ចម្រើន យើងជាអ្នក ( គ្រវែង ) ខុសហើយ ។ លំដាប់នោះទើបព្រះពោធិសត្វពោលនឹងតាបសកោងនោះថា ខាងដើមលោកខុសក្នុងខ្ញុំ តែលោកមិនខុសក្នុងអបាយទាំង ៤ បើលោកនៅក្នុងទីនេះតទៅ ខ្ញុំនឹងប្រាប់អ្នកស្រុកថា តាបសនេះជាចោរហើយឲ្យមកចាប់លោកទៅ លោកចូរប្រញាប់ចេញទៅ កាលគំរាមតាបសនោះហើយក៏ជៀសចេញទៅ ។ ចំណែកជដិលកោងមិនអាចនៅក្នុងទីនោះបានទៅក្នុងទីដទៃ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយហើយទ្រង់ប្រជុំជាតកថា តាបសកោងក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ តាបសដែលមានសីលដែលមកមុនក្នុងកាលនោះបានមកជាសារីបុត្ត ចំណែកប្រធានសត្វព្រាបក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា រោមជាតក ចប់

## មហិសជាតក

[ ៤៣៣ ] ( រុក្ខទេវតាពោលថា ) អ្នកអាស្រ័យហេតុដូចម្តេច ទើបអត់ទ្រាំនូវសេចក្តីលំបាកនេះនឹងស្វាមានចិត្តរហ័ស ជាសត្វប្រទូស្តមិត្ត ( ដូចជាបុគ្គលអត់ទ្រាំនឹងសេចក្តីលំបាក ) និងម្ចាស់ដែលជាអ្នកឲ្យសេចក្តីប្រាថ្នាទាំងពួង ។

[ ៤៣៤ ] អ្នកចូរវែធស្វានេះដោយស្នែង ចូរជាន់កម្ទេចដោយជើងចុះ ប្រសិនបើមិនមានអ្នកកម្ចាត់បង់ទេ ពួកពាលនឹងគប្បីរឹងរឹតបៀតបៀនឡើង ។

[ ៤៣៥ ] ( ពោធិសត្វពោលថា ) ស្វានេះកាលមើលងាយខ្ញុំបានគង់នឹងធ្វើ ( អនាចារៈ ) យ៉ាងនេះនឹងក្របីដទៃទៀត ក្របីទាំងនោះនឹងសម្លាប់វាក្នុងទីនោះ ការរួច ( ចាកសេចក្តីលំបាក ) នោះនឹងមានដល់ខ្ញុំ ។

**ចប់ មហិសជាតកទី ៨ ។**

## អដ្ឋកថា

## មហិសជាតក

[ ៤៣៣-៤៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្វាឡេះឡោះមួយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិមត្ថ-មភិសន្ធាយ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថីមានស្វាឡេះឡោះដែលគេចិញ្ចឹមមួយ ក្នុងត្រកូលមួយបានទៅកាន់រោងដំរី អង្គុយលើខ្នងដំរីដែលមានសីលមួយបន្ទោបង់

ឧច្ចារៈបស្សាវៈនិងដើរទៅដើរមកលើខ្នងដំរី ។ ដំរីក៏មិនធ្វើអ្វីព្រោះខ្លួនមានសីលដល់ព្រមដោយការអត់ធន់ ។ ថ្ងៃមួយកូនដំរីមួយបានឈរនៅក្នុងកន្លែងរបស់ដំរីនោះ ស្វាបានឡើងលើខ្នងដំរីកាចដោយសម្គាល់ថា ដំរីនេះក៏គឺដំរីនោះឯង ។ លំដាប់នោះកូនដំរីកាចនោះយកប្រមោយចាប់ស្វានោះទុកយ៉ាងខ្ជាប់ហើយបោកត្រង់ផែនដី យកជើងជាន់ឲ្យបែកទៅ ។ ប្រព្រឹត្តិការណ៍នោះបានប្រាកដដល់ពួកភិក្ខុសង្ឃ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ស្វាឡេះឡោះឡើងលើខ្នងដំរីកាចដោយសម្គាល់ថាជាដំរីមានសីល កាលបើដូច្នោះដំរីកាចនោះក៏ធ្វើឲ្យស្វាឡេះឡោះនោះដល់នូវការអស់ជីវិត ។ ព្រះសាស្តាទ្រង់យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេដែលស្វាឡេះឡោះនោះជាអ្នកមានប្រក្រតីយ៉ាងនោះ សូម្បីក្នុងកាលមុនក៏មានប្រក្រតីយ៉ាងនោះដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាក្របីនៅក្នុងហិមវន្តប្បទេស លុះចម្រើនវ័យបរិបូណ៌ដោយកម្លាំង មានរាងកាយធំ ត្រាច់ទៅតាមជើងភ្នំ ញកភ្នំ ជ្រលងភ្នំនិងព្រៃក្រាស់ឃើញដើមឈើជាទីសប្បាយមួយកន្លែង ត្រាច់រកស៊ី

ផ្អែតហើយក្នុងវេលាថ្ងៃបានមកឈរស្អាក់នៅត្រង់ដើមឈើនោះ ។ កាលនោះ មានស្វាទ្បេះទ្បោះមួយចុះអំពីដើមឈើ ហើយឡើងលើខ្នងរបស់ក្របីនោះ បន្ទោបង់ឧច្ចារៈបស្សាវៈចាប់ស្នែងទាំង ២ ហោតចាប់កន្ទុយគ្រវីទៅមក ។ ព្រះពោធិសត្វមិនបានដាក់ចិត្តដល់អនាចាររបស់ស្វាទ្បេះទ្បោះនោះ ព្រោះប្រកប ដោយខន្តិ មេត្តានិងករុណា ។ ស្វាធ្វើយ៉ាងនោះឯងរឿយៗ ។ ថ្ងៃមួយទេវតា ដែលស្ថិតនៅត្រង់ដើមឈើនោះ ឈរនៅត្រង់ដើមរបស់ដើមឈើនោះពោល ចំពោះក្របីពោធិសត្វនោះថា នែស្តេចក្របី ព្រោះហេតុអ្វីទើបអ្នកអត់សង្កត់ នូវការមើលងាយរបស់ស្វាអាក្រក់នេះ អ្នកចូរកម្ចាត់វាចេញ កាលប្រកាស សេចក្តីនោះទើបពោល ២ គាថាដំបូងថា

អ្នកអាស្រ័យហេតុដូចម្តេច ទើបអត់ទ្រាំនូវសេចក្តីលំបាក
នេះនឹងស្វាមានចិត្តរហ័ស ជាសត្វប្រទូស្តមិត្ត ( ដូចជាបុគ្គល
អត់ទ្រាំនឹងសេចក្តីលំបាក ) នឹងម្ចាស់ដែលជាអ្នកឲ្យសេចក្តី
ប្រាថ្នាទាំងពួង ។

អ្នកចូរវែធស្វានេះដោយស្នែង ចូរជាន់កម្ទេចដោយជើងចុះ
ប្រសិនបើ មិនមានអ្នកកម្ចាត់បង់ទេ ពួកពាលនឹងគប្បីរឹងរឹត
បៀតបៀនទ្បើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិមត្ថមភិសន្ធាយ** បានដល់ អាស្រ័យ ហេតុអ្វីហ្ន៎ គឺឃើញអ្វី ។ បទថា **ទុត្ថិនោ** បានដល់ ជាអ្នកច្រើនដោយការ ទ្រុស្តមិត្ត ។ បទថា **សព្វកាមទុហាស្សេវ** បានដល់ ដូចជាម្ចាស់របស់អ្នក

ឲ្យវត្ថុដែលគួរប្រាថ្នាទាំងពួង ។ បទថា **តិតិក្ខសិ** បានដល់ អត់ធន់ ។ បទថា **បធសាវ អធិដ្ឋហា** សេចក្តីថា អ្នកចូរជាន់វាដោយជើង និងវែធវា ដោយចុងស្នែងដ៏មុតដោយប្រការដែលវាស្លាប់ក្នុងទីនេះឯង ។ ដោយបទថា **ភិយ្យោ ពាលា** នេះ លោកសម្តែងថា បើអ្នកមិនហាមវា សត្វដែលល្ងង់ខ្លៅ គឺសត្វដែលមិនដឹងនឹងគប្បីសង្កត់សង្កិនញាំញីបៀតបៀនរឿយ ៗ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបពោលថា នែរុក្ខទេវតា បើខ្ញុំជាអ្នក ក្រៃលែងជាងស្វានេះដោយជាតិ គោត្តនិងវស្សាយុកាលជាដើមនឹងមិនអត់ សង្កត់ទោសរបស់ស្វានេះសោតមនោរថ គឺសេចក្តីប្រាថ្នារបស់យើងនឹងដល់ នូវសេចក្តីសម្រេចបានយ៉ាងណា ក៏ស្វានេះកាលសម្គាល់សូម្បីអ្នកដទៃថាដូច ខ្ញុំនឹងធ្វើអនាចារយ៉ាងនេះបន្ទាប់អំពីនោះស្វានឹងធ្វើយ៉ាងនេះដល់ក្របីកាចយ៉ាង ណា ក្របីកាចនោះឯងនឹងសម្លាប់ស្វានេះ ការដែលក្របីដទៃសម្លាប់ស្វានេះ ខ្ញុំនឹងផុតចាកទុក្ខនិងផុតបាណាតិបាតហើយទើបពោលគាថាទី ៣ ថា

ស្វានេះកាលមើលងាយខ្ញុំបាន គង់នឹងធ្វើ ( អនាចារៈ )
យ៉ាងនេះនឹងក្របីដទៃទៀត ក្របីទាំងនោះនឹងសម្លាប់វាក្នុងទី
នោះ ការរួច ( ចាកសេចក្តីលំបាក ) នោះនឹងមានដល់ខ្ញុំ
ដូច្នេះ ។

អស់កាលកន្លងទៅ ២-៣ ថ្ងៃ ព្រះពោធិសត្វបានទៅក្នុងទីដទៃ ។ ក្របី កាចមួយបានមកឈរត្រង់គល់ឈើនោះ ។ ស្វាអាក្រក់ក៏ឡើងលើខ្នងក្របី កាចនោះដោយសម្គាល់ថា ក្របីនេះគឺក្របីមុននោះឯង ដូច្នេះហើយទើបធ្វើ

អនាចារយ៉ាងនោះឯង ។ លំដាប់នោះក្របីកាចនោះរលាស់ស្វានោះឲ្យធ្លាក់ចុះលើផែនដី យកស្នែងវែតត្រង់បេះដូងយកជើងទាំង ៤ ជាន់ឲ្យបែកជាលម្អិតតូចធំ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយហើយទ្រង់ប្រជុំជាតកថា ក្របីកាចក្នុងកាលនោះបានមកជាដំរីកាចក្នុងកាលឥឡូវនេះ ស្វាអាក្រក់ក្នុងកាលនោះបានមកជាស្វាអាក្រក់នេះ ចំណែកស្តេចក្របីដែលមានសីលក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហឹសជាតក ចប់

## សតបត្តជាតក

[ ៤៣៦ ] ( ព្រះសាស្តាត្រាស់ថា ) មាណពសម្គាល់នូវមេចចក ក្នុងផ្លូវជាសត្វគោចរទៅក្នុងព្រៃ ប្រាថ្នានូវសេចក្តីចម្រើន តែងប្រាប់ហេតុឲ្យដឹងថាជាសត្វប្រាថ្នានូវសេចក្តីវិនាស សម្គាល់នូវសត្វចចាត ជាសត្វប្រាថ្នានូវសេចក្តីវិនាស ថាជាសត្វប្រាថ្នានូវសេចក្តីចម្រើនយ៉ាងណាមិញ ។

[ ៤៣៧ ] បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកប្រាកដដូច្នោះ ដែលជនទាំងឡាយ អ្នកប្រាថ្នានូវប្រយោជន៍ពោលពាក្យ ( ប្រៀនប្រដៅ ) ទទួលយកឆ្វេងទៅវិញក៏យ៉ាងនោះដែរ ។

[ ៤៣៨ ] មួយទៀតពួកបុគ្គលណាសរសើរនូវបុគ្គលនោះក្តី លើកតម្កើងបុគ្គលនោះព្រោះភ័យក្តី បុគ្គលនោះ រមែងសម្គាល់ពួកបុគ្គលថាជាមិត្ត ដូចមាណព ( កាលសម្គាល់ ) នូវសត្វចចាតថាជាមិត្តដូច្នោះ ។

**ចប់ សតបត្តជាតកទី ៩ ។**

## អដ្ឋកថា

## សតបត្តជាតក

[ ៤៣៦-៤៣៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកភិក្ខុឆព្វគ្គិយមានឈ្មោះថា បណ្ឌុកៈនិងលោហិតកៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា មាណវកោ បន្ថេ** ដូច្នេះជាដើម ។

បានឮថា បណ្តាភិក្ខុឆព្វគ្គិយទាំងឡាយ ឆព្វគ្គិយ ២ រូបគឺ ព្រះមេត្តិយៈ

និងព្រះភូមជកៈអាស្រ័យនគររាជគ្រឹះ ។ ឆព្វគ្គិយ ២ រូបគឺ ព្រះអស្សជិ និងព្រះបុនព្វសុកៈ ចូលទៅអាស្រ័យកីដាគិរីវិហារ ។ ចំណែកឆព្វគ្គិយ ២ រូបនេះ គឺព្រះបណ្ឌុកៈនិងព្រះលោហិតកៈចូលទៅអាស្រ័យនគរសាវត្ថីនៅក្នុងវត្តជេតពន ។ ភិក្ខុទាំង ២ រូបនោះសើរើអធិករណ៍ដែលរម្ងាប់ហើយដោយត្រូវតាមធម៌ គាំទ្រពួកភិក្ខុដែលជាសម្លាញ់ធ្លាប់ឃើញនិងសម្លាញ់ស្និទ្ធស្នាល ពោលពាក្យជាដើមថា អាវុសោទាំងឡាយ ពួកលោកជាបុគ្គលអាក្រក់ជាងភិក្ខុទាំងនេះដោយជាតិ គោត្ត សីលនិងវត្តជាដើមក៏មិនមែន បើអ្នកទាំងឡាយលះការប្រកាន់របស់ខ្លួនចេញ ភិក្ខុទាំងនេះ ក៏នឹងសង្កត់សង្កិនពួកលោកខ្លាំងឡើង ហើយបបួលមិនឲ្យលះបង់នូវការប្រគួតប្រកាន់ ។ ដោយហេតុនោះការបង្កហេតុជម្លោះនិងវិវាទក៏ប្រព្រឹត្តទៅ ។ ភិក្ខុទាំងឡាយក៏ក្រាបទូលដល់ព្រះមានព្រះភាគ ។ លំដាប់នោះព្រោះនិទាននេះព្រះមានព្រះភាគត្រាស់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់ឲ្យហៅព្រះបណ្ឌុកៈនិងព្រះលោហិតកៈមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកសើរើអធិករណ៍ដោយខ្លួនឯងទាំងមិនឲ្យភិក្ខុពួកដទៃលះបង់ការប្រកាន់ពិតឬ កាលព្រះបណ្ឌុកៈនិងព្រះលោហិតកៈទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនោះ ការធ្វើរបស់ពួកអ្នក រមែងដូចជាការធ្វើរបស់មាណពនិងសត្វចចាត ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលមួយក្នុងស្រុកមួយនាដែនកាសី លុះចម្រើនវ័យ

ហើយមិនចិញ្ចឹមជីវិតដោយកសិកម្មនិងពាណិជ្ជកម្មជាដើម តែប្រមូលពួកចោរ ៥០០ ជាប្រធាននៃចោរទាំងនោះធ្វើចោរកម្មដូចជាការប្លន់អ្នកដំណើរនិងកាត់ទីតជាដើមចិញ្ចឹមជីវិត ។ ក្នុងកាលនោះមានកុដុម្ពិកៈម្នាក់ក្នុងនគរពារាណសីឲ្យទ្រព្យ ១០០០ កហាបណៈដល់អ្នកជនបទម្នាក់ខ្ចីទៅតែមិនបានយកត្រឡប់មកវិញក៏ស្លាប់មុន ។ ក្នុងកាលតមកកិរិយារបស់កុដុម្ពិកៈនោះមានជំងឺជិតនឹងស្លាប់ទើបហៅបុត្តមកប្រាប់ថា នែបា បិតារបស់កូនឲ្យទ្រព្យ ១០០០ កហាបណៈដល់អ្នកជនបទម្នាក់ខ្ចីទៅ ( ជននោះ ) មិនទាន់បានយកមកសងក៏ស្លាប់មុន បើម៉ែស្លាប់ទៅបុរសនោះនឹងមិនឲ្យកូន កូនចូរទៅចុះកាលម៉ែនៅមានជីវិត ចូរកូននាំយកទ្រព្យ ១០០០ កហាបណៈនោះមករក្សាទុក ។ កូននោះទទួលពាក្យហើយទៅក្នុងទីនោះបាននាំកហាបណៈមក ។ លំដាប់នោះមាតារបស់បុរសនោះក៏ធ្វើកាលកិរិយាទៅព្រោះសេចក្ដីស្រឡាញ់បុត្តទើបកើតជាចចកដោយឧបបាតិកៈកំណើតនៅជិតផ្លូវមករបស់បុត្តនោះ ។ ក្នុងកាលនោះមេចោរនោះកាលប្លន់អ្នកដំណើរមួយអន្លើដោយបរិវារ ឈរនៅត្រង់ទីជិតផ្លូវនោះ ។ លំដាប់នោះចចកញីនោះកាលបុត្តមកដល់មាត់ព្រៃក៏កាយដីធ្វើសញ្ញាហាមឃាត់ ដែលជាសញ្ញាឲ្យដឹងយ៉ាងនេះថា នែបា ចូរអ្នកកុំចូលកាន់ព្រៃឡើយ ពួកចោរស្កាត់ក្នុងទីនោះ ពួកវានឹងសម្លាប់កូនហើយកាន់យកកហាបណៈទៅ ។ បុត្តនោះមិនដឹងហេតុការណ៍នោះគិតថា ចចកញីកាឡកណ្ណីនេះមករារាំងផ្លូវអញ ដូច្នេះហើយទើបចាប់ដុំដីនិងដំបងនោះដេញមាតាឲ្យជៀសចេញទៅហើយធ្វើដំណើរចូលព្រៃ ។ លំដាប់នោះសត្វចចាតមួយហើរបែរមុខ

ទៅរកចោរស្រែកថា បុរសនេះមានទ្រព្យ ១០០០ កហាបណៈនៅក្នុងដៃ ពួកអ្នកចូរសម្លាប់បុរសនេះហើយកាន់យកកហាបណៈចុះ ។ មាណពមិនដឹងហេតុដែលសត្វចចាតនោះធ្វើទើបគិតថា បក្សីនេះជាបក្សីមង្គល ឥឡូវនេះសួស្តីនឹងមានដល់អញ ដូច្នេះហើយ ទើបផ្គងអញ្ជលីពោលថា យំចុះលោកម្ចាស់ យំចុះលោកម្ចាស់ ព្រះពោធិសត្វជាអ្នកដឹងសំឡេងស្រែករបស់សត្វទាំងពួងឃើញកិរិយារបស់សត្វទាំង ២ នោះហើយគិតថា ចចកញីនេះគង់ជាមាតារបស់បុរសនេះ ដោយហេតុនោះទើបហាមព្រោះខ្លាចពួកចោរសម្លាប់បុរសនេះហើយកាន់យកកហាបណៈទៅដូច្នេះ ចំណែកសត្វចចាតគង់ជាសត្រូវ ដោយហេតុនោះទើបស្រែកប្រាប់ថា អ្នកទាំងឡាយចូរសម្លាប់បុរសនេះហើយកាន់យកកហាបណៈដូច្នេះ តែបុរសនេះមិនដឹងសេចក្តីនេះ គំរាមមាតាដែលប្រាថ្នាប្រយោជន៍ឲ្យជៀសចេញទៅ ផ្គងអញ្ជលីដល់សត្វចចាត ដែលប្រាថ្នាតែសេចក្តីវិនាសដោយយល់ថាជាអ្នកប្រាថ្នាប្រយោជន៍ដល់អញដូច្នេះ ឱហ្ន៎ បុរសនេះជាមនុស្សល្ងង់ខ្លៅ ។ ការកាន់យកទ្រព្យរបស់អ្នកដទៃនៃព្រះពោធិ-សត្វសូម្បីជាមហាបុរសយ៉ាងនេះ រមែងមានដោយអំណាចការកាន់យកបដិសន្ធិដែលមិនស្មើ ។ អាចារ្យពួកខ្លះពោលថាព្រោះទោសនៃផ្កាយនក្ខត្តឫក្សក៏មាន ។ មាណពធ្វើដំណើរមកដល់រវាងដែននៃពួកចោរ ។ ព្រះពោធិសត្វឲ្យចាប់មាណពនោះហើយសួរថា ឯងជាអ្នកស្រុកណា មាណពពោលថា ខ្ញុំជាអ្នកនគរពារាណសី ។ ព្រះពោធិសត្វសួរថា ឯងទៅណាមកណា មាណពពោលថា ទ្រព្យ ១០០០ កហាបណៈដែលគួរនឹងបានមាននៅក្នុងស្រុកមួយ

ខ្ញុំបានទៅត្រង់ស្រុកនោះហើយមក ។ ព្រះពោធិសត្វសួរថា ទ្រព្យ ១០០០ កហាបណៈនោះឯងបានមកហើយឬ មាណពពោលថា ខ្ញុំបានមកហើយ ។ ព្រះពោធិសត្វសួរថា អ្នកណាបញ្ជូនឯងទៅ មាណពពោលថា បពិត្រលោកម្ចាស់ បិតារបស់ខ្ញុំស្លាប់ហើយចំណែកមាតារបស់ខ្ញុំកំពុងឈឺធ្ងន់មាតាសម្គាល់ថា កាលយើងស្លាប់ទៅបុត្តនេះនឹងមិនបានទ្រព្យដូច្នេះហើយទើបបញ្ជូនខ្ញុំទៅ ។ ព្រះពោធិសត្វសួរថា ឥឡូវនេះឯងដឹងការប្រព្រឹត្តទៅនៃមាតារបស់ឯងដែរឬទេ មាណពពោលថា បពិត្រលោកម្ចាស់ខ្ញុំមិនដឹងទេ ។ ព្រះពោធិសត្វពោលថា មាតារបស់ឯងកាលឯងចេញមកហើយក៏ស្លាប់ ព្រោះសេចក្ដីស្រឡាញ់បុត្តទើបកើតជាចចកញីមានការខ្លាចភ័យ គឺសេចក្ដីស្លាប់របស់ឯងទើបរាំងនៅទីបំផុតចុងផ្លូវហាមឯងទុក តែឯងគំរាមចចកញីនោះ ឲ្យជៀសចេញទៅ ចំណែកសត្វចចាតជាបច្ចាមិត្តរបស់ឯង វាស្រែកប្រាប់ពួកយើងថា ពួកអ្នកចូរសម្លាប់បុរសនេះហើយកាន់យកកហាបណៈព្រោះឯងជាមនុស្សល្ងង់ខ្លៅ ឯងសម្គាល់មាតាដែលប្រាថ្នាប្រយោជន៍ថាជាអ្នកមិនប្រាថ្នាប្រយោជន៍ដល់អញ ដូច្នេះហើយទើបសម្គាល់សត្វចចាតដែលប្រាថ្នាសេចក្ដីវិនាសថាជាអ្នកប្រាថ្នាប្រយោជន៍ដល់អញវិញ ដូច្នេះឈ្មោះថាគុណដែលឯងធ្វើដល់ពួកយើងមិនមាន តែមាតារបស់ឯងមានគុណច្រើនសូម្បីដល់នូវសេចក្ដីស្លាប់ក៏ពិត ចូរឯងកាន់យកកហាបណៈទាំងឡាយទៅចុះហើយលែងមាណពនោះទៅ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ លុះ

ទ្រង់បានត្រាស់ដឹងក្រៃលែងហើយទើបបានត្រាស់ព្រះគាថាទាំងនេះថា

មាណពសម្គាល់នូវមេចចកក្នុងផ្លូវជាសត្វគោចរទៅក្នុងព្រៃ ប្រាថ្នានូវសេចក្តីចម្រើនតែងប្រាប់ហេតុឲ្យដឹងថាជាសត្វប្រាថ្នានូវសេចក្តីវិនាស សម្គាល់នូវសត្វចចាត ជាសត្វប្រាថ្នានូវសេចក្តីវិនាស ថាជាសត្វប្រាថ្នានូវសេចក្តីចម្រើន យ៉ាងណាមិញ ។

បុគ្គលខ្លះក្នុងលោកនេះជាអ្នកប្រាកដដូច្នោះ ដែលជនទាំងឡាយអ្នកប្រាថ្នានូវប្រយោជន៍ពោលពាក្យ ( ប្រៀនប្រដៅ ) ទទួលយកឆ្វេងទៅវិញក៏យ៉ាងនោះដែរ ។

មួយទៀត ពួកបុគ្គលណាសរសើរនូវបុគ្គលនោះក្តី លើកតម្កើងបុគ្គលនោះព្រោះភ័យក្តី បុគ្គលនោះ រមែងសម្គាល់ពួកបុគ្គលថាជាមិត្ត ដូចមាណព ( កាលសម្គាល់ ) នូវសត្វចចាតថាជាមិត្តដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិតេភិ** បានដល់ ដែលប្រាថ្នាប្រយោជន៍ គឺសេចក្តីចម្រើន ។ បទថា **វចនំ វុត្តោ** បានដល់ អ្នកឲ្យឱវាទនិងប្រៀនប្រដៅ ដែលនាំហិតសុខមកឲ្យ ។ បទថា **បិគ្គណ្ហាតិ វាមតោ** សេចក្តីថា បុគ្គលមិនទទួលឱវាទ កាលទទួលយកដោយគិតថា នេះមិននាំប្រយោជន៍មកឲ្យអញ នេះនាំសេចក្តីវិនាសមកឲ្យអញដូច្នេះ ឈ្មោះថាទទួលយកដោយមិនគោរព ។ បទថា **យេ ច ខោ នំ** សេចក្តីថា មួយវិញទៀត

បុគ្គលណារមែងសរសើរបុគ្គលបែបនោះ ដែលកាន់យកនូវការប្រកាន់របស់ខ្លួនថា ឈ្មោះថា បុគ្គលដែលកាន់យកអធិករណ៍យ៉ាងមាំត្រូវជាបុគ្គលដូចអ្នក ។ បទថា **ភយា ឧត្តំសយន្តិ វា** សេចក្ដីថា រមែងលើកឡើងសម្ដែងភ័យព្រោះបច្ច័យ គឺការលះបង់យ៉ាងនេះថា ព្រោះការលះសេចក្ដីប្រកាន់នេះជាបច្ច័យ ភ័យនេះនឹងកើតឡើងដល់អ្នក អ្នកកុំលះបង់ បុគ្គលនេះរមែងមិនដល់អ្នកដោយពាហុសច្ចៈត្រកូលនិងបរិវារជាដើម ។ បទថា **តញ្ហិ សោ មញ្ញតេ មិត្តំ** សេចក្ដីថា បណ្ដាជនទាំងឡាយ ដែលមានសភាពបែបនោះ បុគ្គលនោះ បុគ្គលខ្លះជាមនុស្សល្ងង់ខ្លៅរមែងសម្គាល់បុគ្គលណាមួយថាជាមិត្តព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ខ្លៅ គឺរមែងសម្គាល់ថា បុគ្គលនេះជាមិត្ត ប្រាថ្នាប្រយោជន៍ដល់យើង ។ បទថា **សតបត្តំវ មាណវោ** សេចក្ដីថា ដូចមាណពនោះសម្គាល់សត្វចចាតដែលប្រាថ្នាចំពោះសេចក្ដីវិនាសប៉ុណ្ណោះថាជាអ្នកប្រាថ្នាសេចក្ដីចម្រើន ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ខ្លៅ ចំណែកបណ្ឌិតមិនកាន់យកបុគ្គលដែលប្រចុបប្រចែងនោះថាជាមិត្ត រមែងវៀរបុគ្គលនោះចេញឲ្យឆ្ងាយនោះឯងដោយហេតុនោះទើបលោកពោលទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា

> បុគ្គលដែលជាមិត្តគិតយកតែប្រយោជន៍ខ្លួន ១ បុគ្គលដែលជាមិត្តល្អតែសម្ដី ១ បុគ្គលដែលនិយាយចាក់បណ្ដោយឲ្យគាប់ចិត្ត ១ បុគ្គលដែលជាសម្លាញ់ក្នុងផ្លូវវិនាស ១ បណ្ឌិតដឹងថា បុគ្គលទាំង ៤ ពួកនុ៎ះ មិនមែនជាមិត្តហើយគប្បីចៀស

វាងឲ្យឆ្ងាយដូចជាអ្នកដំណើរចៀសវាងផ្លូវ ដែលប្រកបដោយ
ភ័យដូច្នោះ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើប
ទ្រង់ប្រកាសសច្ចៈទាំងឡាយហើយប្រជុំជាតកថា មេចោរក្នុងកាលនោះ គឺ
តថាគតនេះឯង ។

## អដ្ឋកថា សតបត្តជាតក ចប់

## ប្ញជទូសកជាតក

[ ៤៣៩ ] ( ពោធិសត្វពោលថា ) មិគរាជ គឺស្ដេចស្វាជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ស្លឹកឈើដោយពិត ព្រោះហេតុដូច្នោះទើបបានបំផ្លាញកញ្ចប់ចោល នឹងធ្វើកញ្ចប់ដទៃឲ្យល្អជាងកញ្ចប់មុនដោយពិត ។

[ ៤៤០ ] ( ពានរពោលថា ) បិតាឬមាតារបស់ខ្ញុំ មិនមែនជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ទេ តែពួកខ្ញុំបានតែខាងបំផ្លាញនូវវត្ថុដែលគេធ្វើហើយៗប៉ុណ្ណោះ នេះជាត្រកូល ( របស់ពានរ ) តែងមានយ៉ាងនេះជាធម្មតា ។

[ ៤៤១ ] ( ពោធិសត្វពោលថា ) ធម្មតារបស់ពួកអ្នកណា ប្រាកដយ៉ាងនេះទៅហើយ ចំណង់បើមិនមែនធម្មតាតើនឹងដូចម្ដេចទៅវិញ យើងសូមកុំឲ្យជួបប្រទះនឹងអាការជាធម្មតាឬមិនមែនជាធម្មតារបស់ពួកអ្នកនោះក្នុងកាលណាឡើយ ។

**ចប់ បូជទូសកជាតកទី ១០ ។**

**ចប់ ឧទបានវគ្គទី ៣ ។**

### ឧទ្ទាននៃឧទបានវគ្គនោះគឺ

និយាយអំពីអណ្ដូងទឹកប្រសើរ ១ ខ្លាក្នុងព្រៃ ១ ស្វា ១ កុកមានសិរ ១ កុកដ៏រលើបល្អ ១ ជនាធិបតីល្អ ១ ព្រាបឈ្មោះរោមកៈ ១ ស្វាប្រទូស្ដ ១ សត្វចចាត ១ ការធ្វើកញ្ចប់ ១ ត្រូវជា ១០ ។

## អដ្ឋកថា

## ប្ជទូសកជាតក

[ ៤៣៩-៤៤១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារដែលប្រទូស្តកញ្ចប់ស្លឹកឈើម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អទ្ធា ហិ នូន មិគរាជា** ដូច្នេះជាដើម ។

បានឮថា អាមាត្យម្នាក់ក្នុងនគរសាវត្ថី បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់នៅក្នុងចម្ការកាលនឹងថ្វាយទានពោលថា ក្នុងវេលាងកត្តាហារ ភិក្ខុទាំងឡាយ ដែលប្រាថ្នាត្រាច់ទៅក្នុងសួន ក៏ចូរត្រាច់ទៅចុះ ។ ទើបភិក្ខុទាំងឡាយត្រាច់ទៅក្នុងចម្ការ ។ ក្នុងខណៈនោះអ្នករក្សាចម្ការម្នាក់ឡើងដើមឈើដែលត្រសាយត្រសុំដោយស្លឹកហើយបេះស្លឹកធំៗ ធ្វើឲ្យជាកញ្ចប់ហើយទម្លាក់ត្រង់គល់ឈើដោយគិតថា នេះកញ្ចប់ផ្កា នេះកញ្ចប់ផ្លែឈើ ។ ចំណែកទារកដែលជាបុត្តរបស់អ្នករក្សាចម្ការនោះ ក៏ហែកកញ្ចប់ស្លឹកឈើដែលអ្នករក្សាចម្ការទម្លាក់ចុះមក ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទារកនេះក៏បានជាអ្នកបំផ្លាញកញ្ចប់ស្លឹកឈើដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ម្នាក់ក្នុងនគរពារាណសី ចម្រើនវ័យហើយបាននៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយបានទៅកាន់ឧទ្យានដោយករណីយកិច្ចឯណានីមួយ ។ ពានរមួយចំនួនបាននៅក្នុងឧទ្យាននោះ ចំណែកអ្នករក្សា

ឧទ្យានធ្វើកញ្ចប់ស្លឹកឈើឲ្យធ្លាក់ចុះដោយទំនងនេះឯង ។ ពានរមេហ្វូងក៏មកហែកស្លឹកឈើ ដែលអ្នករក្សាឧទ្យានឲ្យធ្លាក់ចុះមក ។ ព្រះពោធិសត្វក៏ហៅពានរមេហ្វូងនោះមកពោលថា ឯងហែកស្លឹកឈើដែលអ្នករក្សាឧទ្យានទម្លាក់ចុះមក ប្រហែលជាមានបំណងនឹងធ្វើកញ្ចប់ស្លឹកឈើដែលគេទម្លាក់ចុះមកឲ្យជាទីជាពេញចិត្តជាងមុនពិតហើយពោលគាថាទី ១ ថា

មិគរាជ គឺស្តេចស្វាជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ស្លឹកឈើ
ដោយពិត ព្រោះហេតុដូច្នោះទើបបានបំផ្លាញកញ្ចប់ចោលនឹង
ធ្វើកញ្ចប់ដទៃឲ្យល្អជាងកញ្ចប់មុនដោយពិត ដូច្នេះ ។

ព្រះពោធិសត្វកាលសរសើរស្វាទើបពោលថា **មិគរាជា** ក្នុងគាថានោះ ។ បទថា **បុដកម្មស្ស** បានដល់ ក្នុងការធ្វើកញ្ចប់ស្លឹកឈើ ។ បទថា **កោវិទោ** បានដល់ ដែលឈ្លាស ។ ក្នុងគាថានេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ស្តេចម្រឹគនេះប្រហែលជាអ្នកឈ្លាសក្នុងបុដកម្ម ( ការធ្វើកញ្ចប់ស្លឹកឈើ ) ដោយពិត ពិតយ៉ាងនោះស្តេចម្រឹគនេះទើបទម្លាយកញ្ចប់ស្លឹកឈើដទៃដែលឧទ្យានបាលទម្លាក់ចុះមកគង់នឹងធ្វើកញ្ចប់ស្លឹកឈើដទៃឲ្យជាទីពេញចិត្តជាងនោះពិត ។

ស្វាបានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

បិតាឬមាតារបស់ខ្ញុំ មិនមែនជាសត្វឈ្លាស ក្នុងការធ្វើកញ្ចប់
ទេតែពួកខ្ញុំបានតែខាងបំផ្លាញនូវវត្ថុដែលគេធ្វើហើយៗប៉ុណ្ណោះ
នេះជាត្រកូល ( របស់ពានរ ) តែងមានយ៉ាងនេះជាធម្មតា

ដូច្នេះ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

ធម្មតារបស់ពួកអ្នកណាប្រាកដយ៉ាងនេះទៅហើយ ចំណង់បើមិនមែនធម្មតាតើនឹងដូចម្ដេចទៅវិញ យើងសូមកុំឲ្យជួបប្រទះនឹងអាការជាធម្មតា ឬមិនមែនជាធម្មតារបស់ពួកអ្នកនោះក្នុងកាលណាឡើយ ដូច្នេះ ។

ព្រះពោធិសត្វកាលពោលហើយ ទើបតិះដៀលពួកពានរហើយជៀសចេញទៅ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយហើយប្រជុំជាតកថា ពានរក្នុងកាលនោះបានមកជាទារកបំផ្លាញកញ្ចប់ស្លឹកឈើក្នុងកាលឥឡូវនេះ ចំណែកបណ្ឌិតបុរសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា បូជទូសកជាតក ចប់**

**ឧទបានវគ្គ ចប់**

# អព្ភន្តរវគ្គ

## អព្ភន្តរជាតក

[ ៤៤២ ] ( សក្កទេវរាជត្រាស់ថា ) នាងនារីមានបែបចាញ់ផ្លែបាន បរិភោគផ្លែឈើ ( ស្វាយ ) ឈ្មោះ អព្ភន្តរៈជាទិព្វហើយប្រសូត ( ព្រះរាជបុត្ត ) ជាស្ដេចចក្រពត្តិ ។

[ ៤៤៣ ] ម្នាលនាងដ៏ចម្រើន នាងជាមហេសីទាំងជាទីស្រឡាញ់របស់ព្រះរាជាជាភស្ដា ព្រះរាជានឹងនាំផ្លែស្វាយឈ្មោះអព្ភន្តរៈនេះមកដល់នាង ។

[ ៤៤៤ ] ( កូនសេកពោលថា ) បុគ្គលអ្នកក្លៀវក្លា ស៊ូលះបង់ខ្លួនប្រឹងប្រែងក្នុងប្រយោជន៍របស់បុគ្គលអ្នកចិញ្ចឹមខ្លួនរមែងបាននូវឋានៈណា ខ្ញុំបាននូវឋានៈនោះដែរ ។

**ចប់ អព្ភន្តរជាតកទី ១ ។**

# អត្តនវគ្គ

## អដ្ឋកថា អត្តន្តរជាតក

[ ៤៤២-៤៤៤ ] ព្រះសាស្តាកាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរដែលប្រគេនរសផ្លែស្វាយដល់ព្រះនាងពិម្ពាថេរី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អត្តន្តរោ ញាម ទុមោ** ដូច្នេះជាដើម ។

មែនពិត កាលព្រះសម្ពុទ្ធទ្រង់ប្រកាសធម្មចក្កដ៏សមគួរហើយគង់នៅក្នុងកូដាគារសាលាក្នុងនគរវេសាលី ព្រះនាងមហាបជាបតិគោតមីនាំសាកិយានីប្រមាណ ៥០០ ទៅសូមបព្វជ្ជាហើយបានបព្វជ្ជាឧបសម្បទា ។ ក្នុងកាលតមកភិក្ខុនី ៥០០ នោះបានស្តាប់ឱវាទរបស់ព្រះនន្ទកៈ បានសម្រេចអរហត្តកាលព្រះសាស្តា យាងចូលទៅអាស្រ័យក្រុងសាវត្ថី រាហុលមាតាព្រះតម្រិះថា ប្តីរបស់អញបួសហើយបានសម្រេចសព្វញ្ញុតញ្ញាណ កូនរបស់អញក៏បួសក្នុងសម្នាក់របស់ស្វាមីអញនោះ អញនឹងធ្វើអ្វីក្នុងកណ្តាលផ្ទះ អញបួសហើយទៅកាន់នគរសាវត្ថីនឹងឃើញព្រះសម្មាសម្ពុទ្ធមួយអន្លើដោយកូន អស់កាលជានិច្ច ដូច្នេះហើយទើបយាងចូលទៅកាន់សម្នាក់របស់ភិក្ខុនីបួសហើយបានទៅកាន់នគរសាវត្ថីមួយអន្លើដោយឧបជ្ឈាយ៍និងអាចារ្យ ឃើញព្រះសាស្តានិងកូនជាទីស្រឡាញ់ សម្រេចការនៅក្នុងសម្នាក់ភិក្ខុនីមួយកន្លែង ។ រាហុលសាមណេរបានមកសួរសុខទុក្ខមាតា ។ ថ្ងៃមួយខ្យល់ក្នុងផ្ទៃរបស់ព្រះថេរីកម្រើកឡើង កាលឱរសយាងមកដើម្បីសួរសុខទុក្ខព្រះថេរីមិនអាចចេញមកជួបបាន ។ ភិក្ខុនីដទៃៗទើបមកប្រាប់ថា ព្រះថេរីមានជំងឺ រាហុលសាមណេរ

ក៏ទៅកាន់សម្នាក់របស់មាតាហើយទូលសួរថា ព្រះនាងគួរបានថ្នាំអ្វី ព្រះមាតាតបថា នែបា កាលនៅក្នុងព្រះរាជវាំងមាតាផឹករសផ្លែស្វាយដែលផ្សំដោយរសស្ករក្រាមជាដើម រោគខ្យល់ក្នុងផ្ទៃក៏ស្ងប់រម្ងាប់ទៅ ឥឡូវនេះពួកយើងដើរបិណ្ឌបាតចិញ្ចឹមជីវិតនឹងបានរសផ្លែស្វាយនោះមកអំពីណា ។ រាហុលសាមណេរទូលថា កាលខ្ញុំបាននឹងនាំមកហើយក៏ចេញទៅ ។ ព្រះរាហុលនោះមានសម្បត្តិច្រើន គឺមានព្រះធម្មសេនាបតីជាព្រះឧបជ្ឈាយ៍ មានព្រះមហាមោគ្គល្លានជាអាចារ្យ មានព្រះអានន្ទជាព្រះបិតុលា មានព្រះសម្មាសម្ពុទ្ធជាព្រះបិតា ទោះជាដូច្នោះក៏មិនទៅកាន់សម្នាក់ជនដទៃ ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ប៉ុណ្ណោះ ថ្វាយបង្គំហើយឈរមានមុខស្រពោន ។ លំដាប់នោះព្រះថេរៈក៏ពោលនឹងរាហុលសាមណេរនោះថា នែរាហុល ហេតុអ្វីទើបអ្នកមានមុខស្រពោន រាហុលសាមណេរពោលថា បពិត្រលោកម្ចាស់ រោគខ្យល់ក្នុងផ្ទៃនៃព្រះថេរីដែលជាមាតារបស់ខ្ញុំកើតឡើង ។ ព្រះថេរៈសួរថា បានអ្វីទើបគួរ រាហុលសាមណេរប្រាប់ថា ព្រះមាតាបាននិទានឲ្យស្តាប់ថា សេចក្តីសុខនឹងមានដោយរសផ្លែស្វាយដែលផ្សំដោយស្ករក្រាម ។ ព្រះថេរៈពោលថា ណ្ហើយចុះយើងនឹងបានមក អ្នកកុំគិតថ្វីឡើយ ។ ក្នុងថ្ងៃស្អែកព្រះថេរៈនាំរាហុលសាមណេរចូលទៅកាន់នគរសាវត្ថី ឲ្យសាមណេរអង្គុយត្រង់រោងឆាន់ បានទៅកាន់ទ្វារព្រះរាជវាំង ព្រះបាទកោសលឃើញព្រះថេរៈក៏និមន្តឲ្យគង់ ។ ក្នុងខណៈនោះឯងឧទ្យានបាលនាំយកផ្លែស្វាយផ្អែម ដែលទុំទាំងចង្អោមចំនួនមួយកញ្ចប់មកថ្វាយ ព្រះរាជាទ្រង់បកសម្បកស្វាយហើយដាក់

ស្ករក្រាមចូលទៅ ច្របាច់ដោយព្រះអង្គឯង ហើយបានប្រគេនដល់ព្រះថេរៈ រហូតពេញបាត្រ ។ ព្រះថេរៈចេញអំពីរាជនិវេសន៍ទៅកាន់រោងឆាន់ ហើយបានឲ្យដល់សាមណេរដោយពោលថា ចូរអ្នកនាំរសស្វាយនេះទៅប្រគេនមាតារបស់អ្នក ។ រាហុលសាមណេរនោះបាននាំទៅប្រគេនហើយ ។ ព្រះថេរីលុះឆាន់ហើយប៉ុណ្ណោះរោគខ្យល់ក្នុងផ្ទៃក៏ស្ងប់ ។ ចំណែកព្រះរាជាទ្រង់បញ្ជូនមនុស្សទៅដោយព្រះតម្រាស់ថា ព្រះថេរៈមិនឆាន់រសផ្លែស្វាយក្នុងទីនេះ អ្នកចូរទៅមើលឲ្យដឹងថា ព្រះថេរៈឲ្យដល់នរណា ។ រាជបុរសនោះក៏ទៅជាមួយព្រះថេរៈ ជ្រាបហេតុនោះហើយ ទើបមកក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បើព្រះសាស្តានៅគ្រប់គ្រងផ្ទះនឹងបានជាស្តេចចក្រពត្តិ រាហុលសាមណេរនឹងបានជាបរិនាយករតនៈ ព្រះថេរីនឹងបានឥត្ថីរតនៈ រាជសម្បត្តិក្នុងចក្រវាឡទាំងមូលនឹងបានជារបស់ជនទាំងនេះឯង យើងគប្បីឧបដ្ឋាកជនទាំងនេះ ឥឡូវនេះ យើងមិនគួរប្រមាទក្នុងជនទាំងនេះដែលបួសហើយចូលមកអាស្រ័យយើង ។ ចាប់តាំងអំពីនោះព្រះបាទកោសលត្រាស់ឲ្យប្រគេនរសផ្លែស្វាយ ដល់ព្រះថេរីជាប្រចាំ ។ រឿងដែលព្រះសារីបុត្តត្ថេរប្រគេនរសផ្លែស្វាយដល់ព្រះនាងពិម្ពាថេរី ក៏ប្រាកដក្នុងពួកភិក្ខុសង្ឃ ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយបានឮថា ព្រះសារីបុត្តត្ថេរ បានធ្វើព្រះនាងពិម្ពាថេរីឲ្យឆ្អែតស្កប់ស្កល់ដោយរសផ្លែស្វាយ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងឈ្មោះអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា

បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្ត ឲ្យរាហុលមាតាឆ្អែតស្កប់ស្កល់ដោយរសផ្លែស្វាយ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនសារីបុត្តនេះក៏បានឲ្យមាតារបស់រាហុលនេះឆ្អែតស្កប់ស្កល់ហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធក: ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងស្រុកមួយនាដែនកាសី លុះចម្រើនវ័យហើយទៅរៀនសិល្បសាស្ត្រក្នុងនគរតក្កសិលា តម្កល់ខ្លួនក្នុងឃរាវាស អំណឹះឥតអំពីមាតាបិតាទៅក៏បួសជាឥសីធ្វើអភិញ្ញានិងសមាបត្តិឲ្យកើត រស់នៅក្នុងហិមវន្តប្បទេសមានគណៈឥសីចោមរោម ជាគ្រូរបស់គណៈក្នុងកាលយូរកន្លងទៅ ដើម្បីបរិភោគរសជូរប្រៃ ទើបចុះអំពីជើងភ្នំត្រាច់ទៅដល់នគរពារាណសីសម្រេចការនៅក្នុងព្រះរាជឧទ្យាន ។ កាលនោះភពរបស់សក្កទេវរាជក៏កម្រើករំពើកដោយតេជៈនៃសីលរបស់គណៈឥសីនោះ សក្កទេវរាជទ្រង់ពិចារណាក៏បានជ្រាបហេតុនោះទើបទ្រង់ព្រះតម្រិះថា អញនឹងបៀតបៀនធ្វើឲ្យតាបសទាំងនេះនៅមិនបាន កាលបើដូច្នោះតាបសទាំងនោះត្រូវទម្លាយទីលំនៅក៏នឹងត្រូវបែកខ្ញែកត្រាច់ទៅ នឹងមិនបានឯកគ្គតាចិត្ត កាលបើដូច្នោះសេចក្តីសុខនឹងមានដល់អញដូច្នេះទើបទ្រង់ពិចារណាថា មានឧបាយដូចម្តេចហ្ន៎ ក៏បានឃើញឧបាយនេះថា ក្នុងវេលាចន្លោះមជ្ឈិមយាម អញនឹងចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់អគ្គមហេសីនៃព្រះរាជា ឈរក្នុងអាកាសប្រាប់ដល់

ព្រះនាងថា បពិត្រព្រះនាង បើព្រះនាងបានសោយផ្លែស្វាយទុំដែលមានឈ្មោះថា អព្ពន្ទរៈនឹងបានព្រះរាជឱរស ព្រះរាជឱរសនោះនឹងបានជាស្តេចចក្រពត្តិដូច្នេះ ព្រះរាជាទ្រង់បានស្តាប់ពាក្យរបស់ព្រះទេវីហើយនឹងបញ្ជូនមនុស្សទៅកាន់ព្រះរាជឧទ្យាន ដើម្បីឲ្យយកផ្លែស្វាយទុំមក កាលបើដូច្នោះអញនឹងធ្វើឲ្យស្វាយនោះអន្តរធានទៅ រាជបុរសនឹងត្រឡប់មកក្រាបទូលព្រះរាជាថា ស្វាយក្នុងព្រះរាជឧទ្យានមិនមាន កាលព្រះរាជាត្រាស់សួរថានរណាស៊ីអស់ ពួករាជបុរសនឹងក្រាបទូលថា ពួកតាបសជាអ្នកស៊ី កាលទ្រង់ស្តាប់ដូច្នោះនឹងឲ្យវាយពួកតាបសចាប់អូសចេញទៅ កាលបើយ៉ាងនោះតាបសទាំងនោះនឹងត្រូវអញធ្វើឲ្យវិករ ។ ក្នុងចន្លោះមជ្ឈិមយាមសក្កទេវរាជក៏យាងចូលទៅកាន់បន្ទប់ដ៏មានសិរី ឈរក្នុងអាកាសបង្ហាញខ្លួនឲ្យស្គាល់ថាទ្រង់ជាទេវរាជ កាលប្រាស្រ័យជាមួយអគ្គមហេសីរបស់ព្រះរាជានោះ បានត្រាស់គាថា ២ ជាបឋមថា

នាងនារីមានបែបចាញ់ផ្ទៃបានបរិភោគផ្លែឈើ ( ស្វាយ ) ឈ្មោះអព្ពន្ទរៈជាទិព្វ ហើយប្រសូត ( ព្រះរាជបុត្ត ) ជាស្តេចចក្រពត្តិ ។

ម្នាលនាងដ៏ចម្រើន នាងជាមហេសី ទាំងជាទីស្រឡាញ់របស់ព្រះរាជាជាកស្តា ព្រះរាជានឹងនាំផ្លែស្វាយឈ្មោះអព្ពន្ទរៈនេះមកដល់នាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អព្ពន្ទរោ ណាម ទុមោ** នេះ សក្កទេវរាជ

មិនត្រាស់ថា អក្កុន្ទរះ គឺខាងក្នុងនៃគាមនិគមជនបទនិងក្នុំជាដើមឈ្មោះនោះ ត្រាស់ដល់ដើមស្វាយឈ្មោះអក្កុន្ទរះមួយដើមតែម្យ៉ាង ។ បទថា **យស្ស ទិព្យមិទំ ផលំ** សេចក្តីថា ដើមស្វាយណា មានផ្លែជាទិព្វគួរដល់ការបរិភោគរបស់ទេវតាទាំងឡាយ ។ បទថា **ឥទំ** ត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា **ទោហឡិនី** បានដល់ កើតនូវការចាញ់គភ៌ ។ បទថា **ត្វម្បិ ភទ្ទេ មហេសិសិ** សេចក្តីថា ព្រះនាងនឹងបានជាមហេសីដ៏ស្អាត ។ ចំណែកក្នុងអដ្ឋកថាមានបាលីថា **មហេសី វ** ដូច្នេះក៏មាន ។ បទថា **សា ចាបិ បតិនោ បិយា** សេចក្តីថា នឹងបានជាអគ្គមហេសីក្នុងព្រះទេវីចំនួន ១៦០០០ អង្គ និងបានជាទីគាប់ព្រះហឫទ័យរបស់ព្រះរាជស្វាមី ។ បទថា **អាហរិស្សតិ តេ រាជា ឥទំ អក្កុន្តំ ផលំ** សេចក្តីថា ព្រះរាជានឹងឲ្យនាំផ្លែស្វាយមានប្រការដូចខ្ញុំពោលហើយនេះ មកឲ្យដល់ព្រះនាងនោះ ដែលជាអគ្គមហេសីគាប់ព្រះហឫទ័យ ។ ព្រះនាងសោយផ្លែស្វាយនោះហើយនឹងបានព្រះរាជឱរសដែលកើតក្នុងព្រះឧទរហើយនឹងបានជាស្តេចចក្រពត្តិ ។

សក្កទេវរាជត្រាស់គាថា ២ នេះដោយប្រការយ៉ាងនេះហើយទ្រង់ទូន្មានព្រះទេវីថា សូមព្រះនាងកុំប្រមាទ កុំបង្អែបង្អង់គប្បីក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបក្នុងថ្ងៃស្អែកនេះ ហើយយាងទៅកាន់លំនៅរបស់ព្រះអង្គវិញ ។ ស្អែកឡើងព្រះនាងសម្តែងអាការៈធ្វើជាប្រឈួន ឲ្យសញ្ញាដល់អ្នកបម្រើទាំងឡាយហើយផ្ទំ ។ ព្រះរាជាគង់លើសីហាសនៈខាងក្រោមស្វេតច្ឆត្រដែលលើកឡើងទតស្រីស្នំទាំងឡាយមិនឃើញព្រះទេវីទើបត្រាស់សួរបាទបរិចារិកាទាំងឡាយ

ថា ព្រះទេវីទៅណា បាទបរិចារិកាទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ព្រះនាងប្រឈួន ។ ព្រះរាជាក៏យាងទៅកាន់សម្នាក់របស់ព្រះទេវី គង់ត្រង់ទីបន្ទំហើយទ្រង់ស្ទាបព្រះបិដ្ឋិត្រាស់សួរថា នែនាងដ៏ចម្រើន នាងមិនសប្បាយអ្វីឬ ព្រះទេវីទូលថា បពិត្រមហារាជ ឈ្មោះថាការមិនសប្បាយដទៃមិនមាន តែខ្ញុំម្ចាស់កើតការចាញ់គភ៌ ព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន នាងត្រូវការអ្វី ព្រះទេវីទូលថា ខ្ញុំម្ចាស់ត្រូវការផ្លែស្វាយឈ្មោះអព្ភន្តរៈ ព្រះរាជាត្រាស់ថា នែទេវី ស្វាយឈ្មោះអព្ភន្តរៈមាននៅក្នុងទីណា ព្រះទេវីទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ស្គាល់ស្វាយឈ្មោះអព្ភន្តរៈក៏ទេ តែបើខ្ញុំម្ចាស់បានផ្លែរបស់ស្វាយឈ្មោះអព្ភន្តរៈនោះទើបមានជីវិតបើមិនបានមិនមានជីវិតឡើយ ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះយើងនឹងឲ្យនាំមក នាងកុំទោមនស្សឡើយ ។ ព្រះរាជាកាលទ្រង់លួងលោមព្រះទេវីឲ្យស្បើយព្រះហឫទ័យហើយទ្រង់ក្រោកឡើងយាងទៅប្រថាប់គង់លើរាជបល្ល័ង្ក ត្រាស់ឲ្យហៅអាមាត្យទាំងឡាយមកហើយសួរថា ព្រះទេវីចាញ់គភ៌ចង់សោយផ្លែស្វាយឈ្មោះ អព្ភន្តរៈ គួរធ្វើដូចម្តេច អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ស្វាយដែលតាំងនៅត្រង់ចន្លោះស្វាយពីរដើមឈ្មោះថា ស្វាយអព្ភន្តរៈ ពួកទូលព្រះបង្គំនឹងបញ្ជូនមនុស្សទៅកាន់ព្រះរាជឧទ្យានឲ្យនាំផ្លែអំពីស្វាយ ដែលតាំងនៅក្នុងរវាងដើមស្វាយទាំងពីរមកថ្វាយដល់ព្រះទេវី ។ ព្រះរាជាត្រាស់ថា សាធុ ពួកអ្នកចូរនាំផ្លែស្វាយបែបនោះមកហើយទ្រង់បញ្ជូនរាជបុរសទៅកាន់ព្រះរាជឧទ្យាន ។ សក្កទេវរាជទ្រង់បណ្តាលឲ្យផ្លែស្វាយទាំងឡាយក្នុងព្រះរាជឧទ្យាន

អន្តរធានទៅដូចត្រូវមនុស្សបេះបរិភោគដោយអានុភាពរបស់ព្រះអគ្គ ។ រាជបុរសទាំងឡាយដែលទៅដើម្បីត្រូវការផ្លែស្វាយត្រាច់ទៅពេញព្រះរាជឧទ្យានមិនបានសូម្បីត្រឹមតែផ្លែមួយទើបត្រឡប់មកក្រាបទូលព្រះរាជាដល់ភាពដែលផ្លែស្វាយមិនមានក្នុងព្រះរាជឧទ្យាន ។ ព្រះរាជាត្រាស់សួរថា អ្នកណាស៊ីផ្លែស្វាយអស់ ពួករាជបុរសក្រាបទូលថា បពិត្រព្រះអគ្គ ពួកតាបស ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរវាយតាបសទាំងឡាយ ហើយនាំចេញទៅអំពីព្រះរាជឧទ្យាន ពួករាជបុរសទទួលព្រះរាជបញ្ជាហើយ នាំគ្នាទៅនាំតាបសទាំងឡាយចេញអំពីព្រះរាជឧទ្យាន មនោរថរបស់សក្កទេវរាជដល់ទីបំផុតហើយ ព្រះទេវីក៏នៅផ្ទំនោះឯងដោយចងព្រះហឫទ័យដើម្បីសោយផ្លែស្វាយឲ្យបាន កាលព្រះរាជាមិនឃើញឧបាយដែលគប្បីធ្វើទើបត្រាស់ឲ្យអាមាត្យនិងព្រាហ្មណ៍ទាំងឡាយប្រជុំគ្នាហើយត្រាស់សួរថា អ្នកទាំងឡាយដឹងទេថាស្វាយឈ្មោះអព្ភន្តរៈមានឬ ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ឈ្មោះថាស្វាយអព្ភន្តរៈជាគ្រឿងបរិភោគរបស់ទេវតាទាំងឡាយមានខាងក្នុងគុហាមាសក្នុងព្រៃហិមពាន្ត ពួកទូលព្រះបង្គំ បានឮតៗគ្នាយ៉ាងនេះ ព្រះរាជាត្រាស់សួរថា អ្នកណាអាចនាំយកផ្លែស្វាយអំពីព្រៃហិមពាន្តនោះមកបាន ពួកព្រាហ្មណ៍ក្រាបទូលថា បុគ្គលជាមនុស្សមិនអាចទៅក្នុងទីនោះបាន ទ្រង់គួរបញ្ជូនសុវបោតកៈ ( កូនសេក ) មួយទៅ ។ សម័យនោះក្នុងរាជត្រកូល មានកូនសេកមួយ មានខ្លួនធំប្រមាណប៉ុនដុំរទេះរបស់ពួកកុមារសម្បូរដោយកម្លាំង មានបញ្ញា ឈ្លាសក្នុងឧបាយ ព្រះរាជាក៏ឲ្យនាំសុវ-

បោតកៈនោះមកហើយត្រាស់ថា នែបាសុវបោតកៈ យើងមានឧបការៈច្រើនដល់អ្នក អ្នកបាននៅក្នុងទ្រុងមាសបរិភោគលាជលាយដោយទឹកឃ្មុំក្នុងចានមាស ផឹកទឹកដែលលាយដោយស្ករក្រាម អ្នកគួរជួយធ្វើកិច្ចមួយដល់យើង សុវបោតកៈសួរថា បពិត្រព្រះសម្មតិទេព តើកិច្ចអ្វី ព្រះរាជាត្រាស់ថា នែបា ព្រះទេវីចាញ់គភ៌ចង់សោយផ្លែស្វាយអគ្គន្ទរៈ ស្វាយនោះ មាននៅក្នុងកញ្ចនបព៌ត ( ភ្នំមាស ) ក្នុងព្រៃហិមពាន្តជាគ្រឿងបរិភោគរបស់ទេវតាទាំងឡាយ បុគ្គលដែលជាមនុស្សមិនអាចទៅក្នុងទីនោះ អ្នកគួរនាំយកផ្លែស្វាយអំពីព្រៃហិមពាន្តនោះមក ។ សុវបោតកៈក្រាបទូលថា សាធុ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំនឹងនាំមកថ្វាយ ។ លំដាប់នោះទើបព្រះរាជាឲ្យសុវបោតកៈនោះបរិភោគលាជលាយដោយទឹកឃ្មុំក្នុងចានមាស ឲ្យផឹកទឹកលាយដោយស្ករក្រាម លាបស្លាបទាំងពីររបស់សុវបោតកៈនោះដោយប្រេង ដែលចម្រាញ់មួយរយដងហើយទ្រង់បីយាងទៅប្រថាប់ឈរត្រង់បង្អួចហើយលែងទៅក្នុងអាកាស ។ ចំណែកសុវបោតកៈនោះសម្ដែងនូវការគោរពចំពោះព្រះរាជាហើយ ហើរទៅក្នុងអាកាសរំលងដែនដីមនុស្សទៅដល់សម្នាក់របស់សេកទាំងឡាយ ដែលនៅត្រង់ចន្លោះភ្នំទីមួយក្នុងព្រៃហិមពាន្ត ហើយសួរថា ស្វាយឈ្មោះអគ្គន្ទរៈមាននៅទីណា អ្នកទាំងឡាយចូរប្រាប់ទីនោះដល់ខ្ញុំ សេកទាំងឡាយពោលថា ខ្ញុំមិនស្គាល់ ពួកសេកដែលនៅក្នុងចន្លោះភ្នំទីពីរនឹងស្គាល់ ។ សុវបោតកៈនោះបានស្ដាប់ដូច្នោះទើបហើរអំពីទីនោះទៅដល់ចន្លោះភ្នំទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ក៏សួរយ៉ាងនោះ ។ សេកទាំងឡាយក្នុងចន្លោះភ្នំទី ៦ នោះពោលនឹង

សុវបោតកៈថា ពួកខ្ញុំមិនដឹង ពួកសេកក្នុងចន្លោះភ្នំទី ៧ គង់ដឹង ។ សុវ-បោតកៈនោះក៏ហើរទៅដល់ចន្លោះភ្នំទី ៧ ហើយសួរថា ស្វាយឈ្មោះអដ្ឋកៈមានក្នុងទីណា សេកទាំងនោះពោលថា មាននៅត្រង់ចន្លោះកញ្ចនបព៌ត ក្នុងទីឈ្មោះនោះ ។ សុវបោតកៈពោលថា ខ្ញុំមកដើម្បីត្រូវការផ្លែរបស់ស្វាយអដ្ឋកៈនោះ អ្នកទាំងឡាយមេត្តានាំខ្ញុំទៅក្នុងទីនោះហើយ ចូរឲ្យផ្លែស្វាយឈ្មោះអដ្ឋកៈនោះដល់ខ្ញុំចុះ ។ ពួកសេកពោលថា នែសម្លាញ់ ស្វាយអដ្ឋកៈនោះជាគ្រឿងបរិភោគរបស់ព្រះបាទវេស្សវណ្ណមហារាជ បុគ្គលណាមួយមិនអាចចូលទៅជិត ដើមស្វាយទាំងមូលព័ទ្ធដោយសំណាញ់ដែក ៧ ជាន់តាំងពីឫសឡើងទៅមានកុម្ភណ្ឌនិងអារក្សទឹក ១០០០ ថែរក្សា សត្វដែលកុម្ភណ្ឌ និងអារក្សទឹកទាំងនោះឃើញហើយនឹងមិនមានជីវិត ទីនោះដូចអវិចិមហានរក ដូចភ្លើងប្រល័យកប្ប អ្នកកុំប្រាថ្នាទៅក្នុងទីនោះឡើយ ។ សុវ-បោតកៈពោលថា បើអ្នកទាំងឡាយមិនទៅសូមប្រាប់ទីនោះដល់ខ្ញុំ ។ សេកទាំងឡាយពោលថា បើយ៉ាងនោះចូរអ្នកទៅតាមផ្លូវនោះៗ ។ សុវបោតកៈនោះកំណត់ផ្លូវបានប្រាកដប្រជាតាមដែលពួកសេកទាំងនោះប្រាប់ ទើបហើរទៅក្នុងទីនោះ មិនបង្ហាញខ្លួនក្នុងពេលថ្ងៃ ក្នុងពេលមជ្ឈិមយាម ក្នុងវេលាដែលពួកអារក្សទឹកដេកលក់ ក៏ចូលទៅជិតដើមស្វាយអដ្ឋកៈ ហើរឡើងសន្សឹមៗអំពីគល់ទៅសំណាញ់ដែកក៏ប៉ះគ្នាមានសំឡេងក្រឹកៗ ។ ពួកអារក្សទឹកទាំងនោះភ្ញាក់ឡើងឃើញសុវបោតកៈនៅខាងក្នុង ទើបចាប់ដោយចោទថាឯងជាចោរលួចស្វាយ ហើយចាត់ចែងដាក់នូវកម្មករណៈ ។ អារក្សទឹកមួយ

ពោលថា យើងនឹងយកវាដាក់ក្នុងមាត់ហើយទំពាស៊ី ។ អារក្សទឹកមួយទៀត ពោលថា យើងនឹងញិចវាដោយដៃទាំងពីរធ្វើឲ្យខ្ទេចខ្ទាត់ខ្ចាយទៅ អារក្សទឹកមួយទៀតពោលថា យើងនឹងពុះវាជាពីរចំរៀក អាំងលើរងើកភ្លើងហើយបរិភោគ ។ សុវណ្ណកក្កដកៈនោះទោះបីបានឮការចាត់ចែងដាក់កម្មករណៈរបស់អារក្សទឹកទាំងនោះក៏មិនភ័យខ្លាចឡើយ ហៅពួកអារក្សទឹកទាំងនោះមកហើយពោលថា នែអារក្សទឹកដ៏ចម្រើន ពួកអ្នកជារាជបុរសរបស់អ្នកណា ពួកអារក្សទឹកពោលថាជារាជបុរសរបស់ព្រះបាទវេស្សវណ្ណមហារាជ សុវណ្ណកក្កដកៈពោលថា ពួកអ្នកជារាជបុរសរបស់ព្រះរាជាមួយអង្គ ឯខ្ញុំក៏ជារាជបុរសរបស់ព្រះរាជាមួយអង្គដូចគ្នា ព្រះបាទពារាណសីបញ្ជូនខ្ញុំមកដើម្បីត្រូវការផ្លែស្វាយអព្ភន្តរៈ ខ្ញុំនោះបានលះជីវិតដើម្បីព្រះរាជារបស់ខ្ញុំក្នុងនគរពារាណសីនោះទើបមក បុគ្គលណាលះបង់ជីវិតដើម្បីប្រយោជន៍ដល់មាតាបិតានិងចៅហ្វាយនាយរបស់ខ្លួននោះ បុគ្គលនោះទៀងតែកើតក្នុងទេវលោកដោយពិត ព្រោះហេតុនោះខ្ញុំផុតចាកកំណើតតិរច្ឆាននេះហើយនិងកើតក្នុងទេវលោកប៉ុណ្ណោះ ហើយពោលគាថាទី ៣ ថា

> បុគ្គលអ្នកក្លៀវក្លា ស៊ូលះបង់ខ្លួនប្រឹងប្រែងក្នុងប្រយោជន៍របស់
> បុគ្គលអ្នកចិញ្ចឹមខ្លួន រមែងបាននូវឋានៈណា ខ្ញុំបាននូវឋានៈ
> នោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភត្តុរត្ថេ** សេចក្ដីថា បុគ្គលដែលចិញ្ចឹមដោយការចិញ្ចឹមដោយអាហារជាដើមហៅថា អ្នកចិញ្ចឹម ។ បុគ្គលអ្នក

ក្លាហានព្យាយាមដើម្បីប្រយោជន៍ដល់អ្នកចិញ្ចឹមទាំង ៣ នោះ គឺមាតា ១ បិតា ១ ចៅហ្វាយនាយ ១ ។ បទថា **បរក្កន្តោ** បានដល់ ដែលធ្វើនូវការប្រឹងប្រែង គឺព្យាយាម ។ បទថា **យំ ឋានមធិគច្ឆតិ** សេចក្តីថា រមែងសម្រេចដល់ហេតុនៃសេចក្តីសុខណា ជាយសក្តី លាភក្តី សគ្គសម្បត្តិក្តី ។ បទថា **សូរោ** បានដល់ អ្នកមិនខ្លាច គឺដល់ព្រមដោយសេចក្តីព្យាយាម ។ បទថា **អត្តបរិច្ចាគី** សេចក្តីថា ជាអ្នកមិនអាឡោះអាល័យ ក្នុងកាយនិងជីវិត លះបង់ខ្លួនព្រោះប្រយោជន៍របស់បុគ្គលដែលជាអ្នកចិញ្ចឹមខ្លួនទាំង ៣ នោះ ។ បទថា **លភមានោ ភវាមហំ** សេចក្តីថា បុគ្គលអ្នកក្លាហានមានសភាពបែបនោះ រមែងបានឋានៈឯណា ជាទេវសម្បត្តិក្តី មនុស្សសម្បត្តិក្តី ខ្ញុំក៏ជាអ្នកបានឋានៈនោះ ព្រោះហេតុនោះ ទើបខ្ញុំមានតែសេចក្តីរីករាយប៉ុណ្ណោះ មិនមានការតក់ស្លុតក្នុងរឿងនេះ អ្នកទាំងឡាយនឹងធ្វើខ្ញុំឲ្យតក់ស្លុតដូចម្តេចកើត ។

សុវបោតកៈនោះសម្តែងធម៌ដល់អារក្សទឹកទាំងនោះដោយគាថានេះ ដោយប្រការដូច្នេះ ពួកអារក្សទឹកទាំងនោះ ស្តាប់ធម៌របស់សុវបោតកៈនោះហើយ មានចិត្តជ្រះថ្លាពោលថា សុវបោតកៈនេះជាអ្នកតាំងនៅក្នុងធម៌ បុគ្គលណាមួយមិនអាចសម្លាប់ឲ្យស្លាប់ ពួកយើងចូរដោះលែងសុវបោតកៈនេះចុះ ពោលហើយក៏លែងសុវបោតកៈបណ្តើរពោលបណ្តើរថា សុវបោតកៈដ៏ចម្រើន អ្នកជាបុគ្គលផុតភ័យហើយ អ្នកចូរទៅអំពីដៃរបស់ពួកយើង ដោយសួស្តីចុះ សុវបោតកៈពោលថា អ្នកទាំងឡាយកុំធ្វើការមករបស់ខ្ញុំឲ្យសោះសូន្យ ឥត

ប្រយោជន៍ឡើយ ចូរឲ្យផ្លែស្វាយមួយដល់ខ្ញុំចុះ ។ អារក្សទឹកទាំងឡាយពោលថា នែសុវបោតកៈ ឈ្មោះថា ការឲ្យផ្លែស្វាយដល់អ្នកមួយមិនមែនជាភារៈរបស់ពួកយើង ដ្បិតថា ស្វាយលើដើមនេះព្រះបាទវេស្សវណរាប់ទុកកាលបាត់ទៅសូម្បីត្រឹមមួយផ្លែ ជីវិតរបស់យើងមិនមានព្រោះកាលព្រះបាទវេស្សវណខឹងក្រោធសម្លឹងតែម្តង ពួកយើងក៏នឹងដូចជាគ្រាប់ល្ងដែលដាក់លើអំបែងក្តៅ កុម្ភណ្ឌរាប់ពាន់ក៏ខ្ទាត់ខ្ទាយទៅ ដោយហេតុនោះទើបខ្ញុំមិនអាចឲ្យដល់អ្នក តែពួកខ្ញុំនឹងប្រាប់ទីកន្លែងដែលអាចរកបាន ។ សុវបោតកៈពោលថា បុគ្គលណាម្នាក់អាចឲ្យបាន អ្នកទាំងឡាយចូរប្រាប់ទីដែលបានចុះ ។ អារក្សទឹកទាំងនោះប្រាប់ថា ត្រង់ចន្លោះនៃកញ្ចនបព៌តនេះមានតាបសឈ្មោះជោតិរស លោកបូជាភ្លើងនៅក្នុងបណ្ណសាលាដែលមានឈ្មោះថា កញ្ចនបត្តិ លោកជាកុលុបកៈ គឺអ្នកបួសប្រចាំត្រកូលរបស់ព្រះបាទវេស្សវណ ព្រះបាទវេស្សវណបញ្ជូនផ្លែស្វាយទៅប្រគេនជាប្រចាំមួយថ្ងៃ ៤ ផ្លែ ចូរអ្នកទៅកាន់សម្នាក់របស់ឥសីនោះចុះ សុវបោតកៈទទួលថា សាធុ ហើយហើរទៅកាន់សម្នាក់របស់តាបសនោះថ្វាយបង្គំហើយទំក្នុងទីសមគួរនាចំណែកម្ខាង លំដាប់នោះទើបតាបសសួរសុវបោតកៈនោះថា អ្នកមកអំពីណា សុវបោតកៈប្រាប់ថា ខ្ញុំមកអំពីសម្នាក់របស់ព្រះបាទពារាណសី តាបសសួរថា មកដើម្បីអ្វី សុវបោតកៈប្រាប់ថា ព្រះទេវីរបស់ព្រះរាជានៃខ្ញុំកើតនូវការចាញ់គភ៌ ចង់សោយផ្លែស្វាយទុំឈ្មោះអព្ភន្តរៈទើបខ្ញុំមកដើម្បីត្រូវការផ្លែស្វាយអព្ភន្តរៈនោះ តែពួកអារក្សទឹកឲ្យស្វាយទុំឈ្មោះអព្ភន្តរៈដល់ខ្ញុំដោយខ្លួនឯងមិនបាន ទើប

បញ្ជូនមកកាន់សម្នាក់របស់លោកម្ចាស់ តាបសពោលថា បើយ៉ាងនោះ ចូរអ្នកអង្គុយរង់ចាំសិនទើបបាន ។ លំដាប់នោះព្រះបាទវេស្សវ័ណបញ្ជូនផ្លែស្វាយ ៤ មកប្រគេនតាបសនោះ ។ តាបសនោះឆាន់ ២ ផ្លែអំពី ៤ ផ្លែនោះ បានឲ្យសុវបោតកៈបរិភោគ ១ ផ្លែ កាលសុវបោតកៈនោះបរិភោគផ្លែស្វាយនោះហើយ ទើបតាបសយកស្វាយមួយទៀតដាក់ក្នុងសំប្រុកពាក់ត្រង់កសុវបោតកៈហើយពោលថា ចូរអ្នកទៅក្នុងកាលឥឡូវនេះចុះ ហើយក៏បញ្ជូនសុវបោតកៈនោះទៅ សុវបោតកៈនោះបាននាំផ្លែស្វាយនោះមកថ្វាយព្រះទេវី ។ ព្រះទេវីសោយផ្លែស្វាយនោះហើយក៏ញ៉ាំងការចាញ់គភ៌ឲ្យស្ងប់រម្ងាប់បាន ។ ព្រះរាជាទ្រង់សោមនស្សដែលមានការបានផ្លែស្វាយអព្ភន្តរៈនោះមកជាហេតុ តែព្រះរាជទេវីនោះមិនមានព្រះរាជឱរសឡើយ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះទេវីក្នុងកាលនោះបានមកជារាហុលមាតាក្នុងកាលឥឡូវនេះ សុវបោតកៈក្នុងកាលនោះ បានមកជាអានន្ទ តាបសអ្នកឲ្យស្វាយក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកតាបសដែលនៅក្នុងព្រះរាជឧទ្យានក្នុងកាលនោះ គឺ តថាគតអរហត្តសម្មាសម្ពុទ្ធ នេះឯង ។

## អដ្ឋកថា អព្ភន្តរជាតក ចប់

# សេយ្យជាតក

[ ៤៤៥ ] ( ព្រះរាជាពោធិសត្វត្រាស់ថា ) បុគ្គលណាគប់រកនូវបុគ្គលប្រសើរ ( បុគ្គលនោះ ) ជាអ្នកមានចំណែកប្រសើរ ជាអ្នកប្រសើរបំផុត ខ្ញុំបានធ្វើនូវការជាប់តជាមួយនឹងស្តេចជាចោរម្នាក់ ( ដោយមេត្តាភាវនា ) បានដោះអ្នកទាំងឡាយ ១០០ នាក់ដែលត្រូវគេសម្លាប់ ( ឲ្យរួចបាន ) ។

[ ៤៤៦ ] ព្រោះហេតុនោះ បុគ្គលម្នាក់ឯងធ្វើនូវការជាប់តជាមួយនឹងលោកទាំងមូល ( ដោយមេត្តាភាវនា ) លុះទម្លាយខន្ធទៅ គប្បីបានឋានសួគ៌ អ្នកទាំងឡាយដែលនៅក្នុងដែនកាសី ចូរស្តាប់នូវពាក្យរបស់យើងនេះចុះ ។

[ ៤៤៧ ] ( ព្រះសាស្តាត្រាស់ថា ) ព្រះរាជាជាធំ ព្រះនាមកំសៈ ព្រះអង្គគ្រប់គ្រងក្រុងពារាណសីបានត្រាស់ដូច្នេះហើយ ទ្រង់ដាក់ធ្នូនិងព្រួញចោលហើយទើបចូលទៅកាន់ការសង្រួម គឺបព្វជ្ជា ។

**ចប់ សេយ្យជាតកទី ២ ។**

# អដ្ឋកថា

# សេយ្យជាតក

[ ៤៤៥-៤៤៧ ] ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាមាត្យរបស់ព្រះបាទកោសលម្នាក់ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្ដើមថា **សេយ្យំសោ សេយ្យសោ ហោតិ** ដូច្នេះជាដើម ។

បានឮថា អាមាត្យនោះមានឧបការៈច្រើនដល់ព្រះរាជា ជាអ្នកចាត់ចែងរាជកិច្ចទាំងពួងឲ្យសម្រេច ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អាមាត្យនេះមានឧបការៈច្រើនដល់អញ ដូច្នេះហើយបានប្រទានយសធំដល់អាមាត្យនោះ ។ អាមាត្យពួកដទៃ អត់ធន់នឹងអាមាត្យនោះមិនបាន ក៏ញុះញង់ព្រះរាជាបំបែកអាមាត្យនោះ ។ ព្រះរាជាទ្រង់ជឿពាក្យរបស់អាមាត្យទាំងនោះ មិនបានពិចារណាទោស ឲ្យចងអាមាត្យដែលជាអ្នកមានសីលនោះ ដែលជាអ្នកមិនមានទោសដោយចំណង គឺច្រវាក់ហើយឃុំឃាំងក្នុងគុក ។ អាមាត្យនោះម្នាក់ឯងនៅក្នុងគុកនោះអាស្រ័យសីលសម្បត្តិបាននូវឯកគ្គតាចិត្តក្នុងអារម្មណ៍តែមួយ ពិចារណាសង្ខារទាំងឡាយក៏បានសម្រេចសោតាបត្តិផល ។ ក្នុងកាលតមកព្រះរាជាទ្រង់ជ្រាបថា អាមាត្យនោះមិនមានទោស ទើបត្រាស់ឲ្យដោះចំណង គឺច្រវាក់ហើយបានព្រះរាជទានយសធំជាងមុន ។ អាមាត្យនោះគិតថានឹងថ្វាយបង្គំព្រះសាស្ដា ដូច្នេះហើយទើបកាន់យកផ្កាកម្រងនិងគ្រឿងក្រអូបជាដើមជាច្រើនទៅកាន់វិហារបូជាព្រះតថាគត ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្ដាកាលទ្រង់ធ្វើបដិសណ្ឋារៈជាមួយអាមាត្យនោះ ទើបត្រាស់ថា តថាគតបានឮថា រាជទណ្ឌដែលមិនមាន

ប្រយោជន៍កើតឡើងដល់អ្នកឬ អាមាត្យក្រាបទូលថា បពិត្រព្រះអង្គ រាជទណ្ឌមិនមានប្រយោជន៍កើតឡើងហើយ តែខ្ញុំព្រះអង្គ បានធ្វើប្រយោជន៍អំពីវត្ថុដែលឥតប្រយោជន៍នោះ ខ្ញុំព្រះអង្គនោះ អង្គុយក្នុងគុកហើយធ្វើសោតាបត្តិ-ផលឲ្យកើតឡើង ។ ព្រះសាស្ដាត្រាស់ថា ម្នាលឧបាសកមិនមែនតែអ្នកប៉ុណ្ណោះ ដែលនាំយកប្រយោជន៍មកអំពីវត្ថុដែលមិនជាប្រយោជន៍ សូម្បីបោរាណកបណ្ឌិតទាំងឡាយក៏នាំយកវត្ថុដែលជាប្រយោជន៍មកអំពីវត្ថុ ដែលឥតប្រយោជន៍ដល់ខ្លួនដូចគ្នា ។ កាលអាមាត្យនោះទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងព្រះឧទរអគ្គមហេសីព្រះបាទព្រហ្មទត្តនោះ ចម្រើនវ័យហើយរៀនសិល្បសាស្ត្រទាំងពួងក្នុងនគរតក្កសិលា កាលព្រះរាជបិតាសោយទិវង្គតហើយតាំងនៅក្នុងរាជសម្បត្តិ ទ្រង់មិនបានញុំាងទសពិធរាជធម៌ឲ្យកម្រើក គ្រងរាជសម្បត្តិដោយធម៌ស្មើ បំពេញទាន រក្សាសីល ៥ ធ្វើនូវឧបោសថកម្ម ។ លំដាប់នោះអាមាត្យម្នាក់របស់ព្រះអង្គ ប្រទូស្តខាងក្នុងព្រះរាជវាំង ( ប្រទូស្តស្រីស្នំ ) រាជាបរិវារដែលជាបាទបរិចារិកាជាដើមដឹងហើយ ទើបក្រាបទូលដល់ព្រះរាជាថា អាមាត្យឈ្មោះនោះ ប្រទូស្តខាងក្នុងព្រះរាជាវាំង ព្រះរាជាទ្រង់សង្កេតពិនិត្យហើយ ទ្រង់ជ្រាបបានតាមសេចក្ដីពិត បញ្ជាឲ្យអាមាត្យនោះចូលគាល់ហើយត្រាស់ថា ចាប់តាំងអំពីនេះទៅអ្នកកុំមកឧបដ្ឋាកយើងឡើយហើយ ទ្រង់ដកយស ។ អាមាត្យនោះ ទៅឧបដ្ឋាកព្រះរាជា

សាមន្តរាជអង្គដទៃ រឿងទាំងពួងបានពោលទុកក្នុងមហាសីលវជាតកខាងដើម នោះឯង ។ ក្នុងជាតកនេះ ព្រះរាជានោះទ្រង់សាកល្បងអស់វារៈ ៣ ដង ទើបជឿពាក្យរបស់អាមាត្យនោះ ទ្រង់ព្រះតម្រិះថានឹងដណ្តើមយករាជសម្បត្តិ ក្នុងនគរពារាណសី ដូច្នេះហើយមួយអន្លើដោយបរិវារធំលើកទ័ពមកដល់ រាជសីមារបស់ព្រះបាទពារាណសី ។ ទាហានធំរបស់ព្រះបាទពារាណសី ប្រមាណ ៧០០ នាក់ ដឹងព្រឹត្តិការណ៍នោះហើយក្រាបទូលថា បពិត្រព្រះ សម្មតិទេព បានឮថា ព្រះរាជាអង្គនោះគិតថានឹងដណ្តើមរាជសម្បត្តិក្នុងនគរ ពារាណសី ដូច្នេះហើយទើបវាយជនបទចូលមក ពួកទូលព្រះបង្គំនឹងទៅ កាន់ជនបទនោះឯង ហើយចាប់ព្រះរាជាអង្គនោះមក ។ ព្រះបាទពារាណសី ត្រាស់ថា យើងមិនមានការធ្វើកម្មដោយរាជសម្បត្តិ ដោយការបៀតបៀន អ្នកដទៃ ពួកអ្នកកុំធ្វើអ្វីដល់ព្រះរាជានោះឡើយ ។ ព្រះរាជាដែលជាចោរ ព័ទ្ធព្រះនគរទុក ។ អាមាត្យទាំងឡាយចូលទៅគាល់ព្រះរាជាទៀតក្រាបទូល ថា បពិត្រព្រះសម្មតិទេព សូមទ្រង់កុំធ្វើយ៉ាងនេះ ពួកទូលព្រះបង្គំនឹងចាប់ ស្តេចចោរនោះ ។ ព្រះរាជាត្រាស់ថា កុំធ្វើអ្វីដល់ព្រះរាជានោះឡើយ ចូរ បើកទ្វារនគរទាំងអស់ ទ្រង់ចោមរោមដោយពួកអាមាត្យប្រថាប់គង់លើបល្ល័ង្ក ក្នុងផ្ទៃប្រាសាទ ។ ព្រះរាជាដែលជាចោរវាយពួកមនុស្សត្រង់ទ្វារទាំង ៤ ចូលនគរបានហើយឡើងកាន់ប្រាសាទឲ្យចាប់ព្រះរាជា ដែលចោមរោមដោយ អាមាត្យ ចងដោយច្រវាក់ហើយឲ្យឃុំឃាំងក្នុងគុក ។ ព្រះរាជាប្រថាប់គង់ ក្នុងគុកនោះឯងទ្រង់ផ្សាយមេត្តាទៅកាន់ស្តេចចោរ ទ្រង់ញ៉ាំងឈានមានមេត្តា

ឲ្យកើតឡើងដល់ស្តេចចោរនោះ ។ ដោយអានុភាពនៃមេត្តារបស់ព្រះបាទពារាណសីនោះ ការក្តៅក្រហាយក៏កើតឡើងក្នុងកាយរបស់ព្រះរាជាដែលជាចោរ ។ សរីរៈកាយទាំងមូលរបស់ស្តេចចោរនោះហាក់បីដូចត្រូវគប់ភ្លើងក្នុងយមលោកដុតរោល ។ ស្តេចចោរនោះត្រូវទុក្ខជំគ្របសង្កត់ ទើបត្រាស់សួរថា តើមានហេតុអ្វីហ្ន៎ អាមាត្យទាំងឡាយក្រាបទូលថា ទ្រង់ឲ្យឃុំឃាំងព្រះរាជាដែលជាអ្នកមានសីលក្នុងគុក ដោយហេតុនោះទើបទុក្ខនេះកើតឡើងដល់ព្រះអង្គ ។ ស្តេចចោរនោះក៏យាងទៅសូមខមាទោសព្រះពោធិសត្វថា រាជសម្បត្តិរបស់ព្រះអង្គចូរជារបស់ព្រះអង្គវិញចុះ ហើយទ្រង់ប្រគល់រាជសម្បត្តិដល់ព្រះបាទពារាណសីវិញហើយទូលថា តាំងអំពីនេះទៅសត្រូវរបស់ព្រះអង្គ ចូរជាភារៈរបស់ខ្ញុំ ឲ្យដាក់អាជ្ញាដល់អាមាត្យដែលប្រទូស្តហើយយាងទៅកាន់នគររបស់ព្រះអង្គ ។ ព្រះពោធិសត្វគង់លើបល្ល័ង្កដែលលើកស្វេតច្ឆត្រឡើងហើយក្នុងផ្ទៃប្រាសាទ កាលទ្រង់ប្រាស្រ័យពួកអាមាត្យដែលអង្គុយចោមរោមទើបត្រាស់គាថា ២ ជាបឋមថា

បុគ្គលណាគប់រកនូវបុគ្គលប្រសើរ ( បុគ្គលនោះ ) ជាអ្នកមានចំណែកប្រសើរ ជាអ្នកប្រសើរបំផុត ខ្ញុំបានធ្វើនូវការជាប់តជាមួយនឹងស្តេចជាចោរម្នាក់ ( ដោយមេត្តាភាវនា ) បានដោះអ្នកទាំងឡាយ ១០០ នាក់ដែលត្រូវគេសម្លាប់ ( ឲ្យរួចបាន ) ។

ព្រោះហេតុនោះ បុគ្គលម្នាក់ឯងធ្វើនូវការជាប់តជាមួយនឹង

លោកទាំងមូល ( ដោយមេត្តាភាវនា ) លុះទម្លាយខន្ធទៅ
គប្បីបានឋានសួគ៌ អ្នកទាំងឡាយដែលនៅក្នុងដែនកាសីចូរ
ស្តាប់នូវពាក្យរបស់យើងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សេយ្យំសោ សេយ្យសោ ហោតិ យោ សេយ្យមុបសេវតិ** សេចក្តីថា បុគ្គលឈ្មោះថាជាអ្នកមានចំណែកដ៏ប្រសើរ ព្រោះមានចំណែក គឺកោដ្ឋាសដ៏ប្រសើរពោលគឺ ធម៌ដ៏ឧត្តមដែលមិនមានទោសបានដល់ បុគ្គលអាស្រ័យកុសលធម៌ ។ បុគ្គលណាសេពកុសលធម្មភាវនាដ៏ប្រសើរនោះ ឬបុគ្គលដ៏ប្រសើរត្រេកអរក្រៃលែងក្នុងកុសលធម៌ដ៏ប្រសើរនោះរឿយៗ បុគ្គលនោះជាអ្នកមានចំណែកដ៏ប្រសើរ គឺជាបុគ្គលគួរសរសើរជាងនិងជាបុគ្គលក្រៃលែងជាង ។ បទថា **ឯកេន សន្ធឹ កត្វាន សតំ វជ្ឈេ អមោចយឹ** នេះ គប្បីជ្រាបដូច្នេះថា កាលយើងសេពមេត្តាភាវនាដ៏ប្រសើរ បានធ្វើនូវការជាប់ត គឺបន្តមេត្តាភាវនាជាមួយស្តេចចោរតែម្នាក់ដោយមេត្តាភាវនានោះបានដោះអ្នកទាំងឡាយ ដែលត្រូវសម្លាប់រាប់រយនាក់ ។ ក្នុងគាថាទី ២ មានសេចក្តីដូចតទៅនេះថា ព្រោះហេតុដែលយើងធ្វើនូវការជាប់តដោយមេត្តាភាវនាដោយភាពតែមួយជាមួយស្តេចចោរ ទើបដោះអ្នកទាំងឡាយដែលត្រូវសម្លាប់បានរាប់រយនាក់ព្រោះហេតុនោះគប្បីជ្រាបសេចក្តីនោះថា ព្រោះបុគ្គលមួយធ្វើការជាប់តជាមួយលោកទាំងពួង ដោយមេត្តាភាវនា លះលោកទៅហើយនឹងចូលដល់ស្ថានសួគ៌ក្នុងលោកខាងមុខព្រោះមេត្តាភាវនាដែលជាឧបចារឈាន ឲ្យបដិសន្ធិក្នុងកាមាវចរភព មេត្តាភាវនា

ដែលជាអប្បនាឈាន រមែងឲ្យបដិសន្ធិក្នុងព្រហ្មលោក ។ អ្នកទាំងឡាយ ដែលជាអ្នកកាសិករដ្ឋ ចូរស្តាប់ពាក្យរបស់យើងនេះទុក ។ ព្រះមហាសត្វ ពណ៌នាគុណរបស់ការនាដែលប្រកបដោយមេត្តាដល់មហាជនយ៉ាងនេះហើយ ទ្រង់លះស្វេតច្ឆត្រក្នុងនគរពារាណសីដែលមានទំហំ ១២ យោជន៍យាងចូល ព្រៃហិមពាន្តបួសជាឥសី ។

ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងហើយទើបត្រាស់គាថាទី ៣ ថា

ព្រះរាជាជាធំព្រះនាមកំសៈ ព្រះអង្គគ្រប់គ្រងក្រុងពារាណសី
បានត្រាស់ដូច្នេះហើយ ទ្រង់ដាក់ធ្នូនិងព្រួញចោលហើយទើប
ចូលទៅកាន់ការសង្រួម គឺបព្វជ្ជា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហារាជា** បានដល់ ព្រះរាជាធំ ។ បទថា **កំសោ** ជាព្រះនាមរបស់ព្រះរាជាដែលជាធំនោះ ។ បទថា **ពារាណសិគ្គ-ហោ** បានដល់ ដែលគ្រប់គ្រងនគរពារាណសីព្រោះកាន់យកនគរពារាណសី គ្រប់គ្រង ។ ព្រះរាជាត្រាស់ព្រះតម្រាស់នេះហើយទ្រង់ដាក់ គឺលះបង់នូវធ្នូ និងព្រួញចូលដល់ការសង្រួមក្នុងសីល គឺបួស កាលបួសហើយក៏ញ៉ាំងឈាន ឲ្យកើតឡើង ជាអ្នកមានឈានមិនសាបសូន្យទើបកើតក្នុងព្រហ្មលោក ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ ប្រជុំជាតកថា ព្រះរាជាដែលជាចោរក្នុងកាលនោះបានមកជាអានន្ទក្នុងកាល ឥឡូវនេះ ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាសេយ្យជាតក ចប់**

# វឌ្ឍកីសូករជាតក

[ ៤៤៨ ] ( ជដិលមានចិត្តកោងពោលថា ) កាលពីដើមអ្នករីបជាន់នូវជ្រូកទាំងឡាយក្នុងប្រទេសនេះ តែងសម្លាប់ជ្រូកដ៏ប្រសើរៗបាន ម្នាលខ្លា ឥឡូវនេះអ្នកនោះត្រឡប់មកម្នាក់ឯងសញ្ជប់សញ្ជឹង ម្នាលខ្លា ថ្ងៃនេះកម្លាំងកាយរបស់អ្នកគ្មានទេឬ ។

[ ៤៤៩ ] ( ខ្លាពោលថា ) កាលពីដើមជ្រូកទាំងនេះជាច្រើនត្រូវភ័យបៀតបៀនហើយក៏ស្វែងរកទីជ្រកកោន ហើយក៏បោលទៅកាន់ទិសតូចទិសធំ ឥឡូវនេះជ្រូកទាំងនេះស្ថិតនៅក្នុងទីណាដែលខ្ញុំបៀតបៀនមិនបាន ជ្រូកទាំងនោះក៏មកជួបជុំគ្នានៅក្នុងទីនោះជាមួយគ្នា ។

[ ៤៥០ ] ( រុក្ខទេវតាពោលថា ) យើងសូមថ្វាយបង្គំពួកជ្រូកដែលមកជួបជុំគ្នា ( ក្នុងទីនេះ ) យើងបានឃើញនូវមិត្តភាព ( របស់អ្នកទាំងឡាយ ) ដ៏អស្ចារ្យដោយខ្លួនឯង ទើបពោលព្រោះថា ពួកម្រឹគមានខ្នាយបានឈ្នះនូវខ្លារូបចាក ( មរណភ័យ ) ដោយសេចក្តីព្រមព្រៀងក្នុងពួកជ្រូកមានខ្នាយជាកម្លាំង ។

**ចប់ វឌ្ឍកីសូករជាតក ទី ៣ ។**

# អដ្ឋកថា

# វឌ្ឍកីសូករជាតក

[ ៤៤៨-៤៥០ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធនុគ្គហតិស្សត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វរំ វរំ ត្វំ** ដូច្នេះជាដើម ។

បានឮថា ព្រះបាទមហាកោសលជាព្រះបិតារបស់ព្រះបាទបសេនទិកោ-សលបានព្រះរាជទាននាងកោសលទេវីរាជធីតាដល់ព្រះបាទពិម្ពិសារ បានព្រះរាជទានកាសិកគ្រាមដែលជាស្រុកមានចំណូលកើតឡើង ១ សែន ឲ្យជាថ្លៃលម្អិតសម្រាប់ងូតដល់ព្រះរាជធីតានោះ ។ តែកាលព្រះបាទអជាតសត្តុផ្តាច់ព្រះជន្មបិតា នាងកោសលទេវី ( វេទេហី ) ត្រូវសេចក្តីសោកគ្របសង្កត់ក៏សោយព្រះទិវង្គត ( តាមព្រះស្វាមី ) ។ លំដាប់នោះព្រះបាទបសេនទិកោសលទ្រង់ព្រះតម្រិះថា ព្រះបាទអជាតសត្តុផ្តាច់ព្រះជន្មបិតា ចំណែកព្រះភគនីរបស់អញកាលស្វាមីសោយទិវង្គតហើយ ព្រោះសេចក្តីសោក ក៏សោយព្រះវិលាល័យ អញនឹងមិនឲ្យកាសិកគ្រាមដល់ចោរបិតុឃាដ ( ចោរសម្លាប់ឪពុក ) កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏មិនឲ្យកាសិកគ្រាមនោះដល់ព្រះបាទអជាតសត្តុ ។ ព្រោះអាស្រ័យស្រុកនោះឯងព្រះរាជាទាំងពីរអង្គនោះមានការច្បាំងគ្នារឿយៗមក ។ ព្រះបាទអជាតសត្តុទ្រង់នៅក្មេងរឹងប៉ឹងមានសមត្ថភាព ចំណែកព្រះបាទបសេនទិកោសលទ្រង់ជរាភាពហើយ ទ្រង់ក៏ច្បាំងចាញ់រឿយៗ ។ មនុស្សរបស់ព្រះបាទមហាកោសលក៏ចាញ់ដោយច្រើន ។ លំដាប់នោះព្រះរាជាត្រាស់សួរអាមាត្យថា ពួកយើងចាញ់ព្រះបាទ

អជាតសត្តុរឿយៗគួរធ្វើដូចម្តេចល្អ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាភិក្ខុទាំងឡាយរមែងជាអ្នកឈ្លាសក្នុងការគិត គួរស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយក្នុងវត្តជេតពន ។ ព្រះរាជាទ្រង់បង្គាប់ចារបុរសទាំងឡាយថា បើយ៉ាងនោះអ្នកទាំងឡាយចូរស្តាប់ពាក្យសន្ទនារបស់ភិក្ខុទាំងឡាយក្នុងវេលានោះ តាំងអំពីនោះមកចារបុរសទាំងនោះ បានធ្វើយ៉ាងនោះ ក្នុងកាលនោះព្រះថេរៈចាស់ ២ អង្គ គឺព្រះទត្តត្ថេរនិងព្រះធនុគ្គហតិស្សត្ថេរនៅក្នុងបណ្ណសាលាខាងចុងវិហារ ។ បណ្តាព្រះថេរៈ ២ អង្គនោះព្រះធនុគ្គ-ហតិស្សត្ថេរសឹងលក់ទាំងក្នុងបឋមយាមនិងមជ្ឈិមយាមហើយភ្ញាក់ក្នុងបច្ឆិម-យាម អង្គុយគោះរងើកភ្លើងឲ្យភ្លឺហើយពោលថា អាវុសោទត្តត្ថេរ លោកដេកឬអង្គុយ ព្រះទត្តត្ថេរពោលថា ខ្ញុំមិនទាន់ដេក លោកម្ចាស់មានការអ្វី ព្រះធនុគ្គហតិស្សត្ថេរពោលថា ក្រោកឡើងអង្គុយសិនចុះ ។ ព្រះធនុគ្គហតិ-ស្សត្ថេរក្រោកឡើងអង្គុយហើយពោលថា អាវុសោទត្តត្ថេរ ព្រះបាទកោសលពោះកំប៉ោងនេះល្ងង់ខ្លៅ ធ្វើព្រះក្រយាហារដែលសោយក្នុងថាសឲ្យខាតទទេមិនចេះក្បួនច្បាំងណាមួយទើបទ្រង់ចាញ់ហើយចាញ់ទៀត ព្រះទត្តត្ថេរសួរថា បើយ៉ាងនោះគួរធ្វើដូចម្តេច ។ ខណៈនោះចារបុរសទាំងនោះបានឈរស្តាប់ពាក្យរបស់ព្រះថេរៈទាំង ២ អង្គនោះ ។ ព្រះធនុគ្គហតិស្សត្ថេរវិភាគការច្បាំងថា អាវុសោ ឈ្មោះថាការច្បាំងមានក្បួនទ័ព ៣ ប្រការ គឺបទុម-ព្យូហៈក្បួនទ័ពដូចផ្កាឈូក ១ ចក្កព្យូហៈក្បួនទ័ពដូចកង់រថ ១ សកដព្យូហៈក្បួនទ័ពដូចរទេះ ១ បើព្រះបាទបសេនទិកោសលមានបំណងចង់ចាប់ព្រះ

បាទអជាតសត្តុគួរបង្កប់ទ័ពទុកត្រង់ចន្លោះភ្នំទាំង ២ ឈ្មោះនោះបង្ហាញកម្លាំងទ័ពខាងមុខឲ្យដឹងថា ទន់ខ្សោយកុំឲ្យព្រះបាទអជាតសត្តុដឹង កាលទ្រង់ដេញចូលមក ទ័ពសងខាងផ្លូវដែលបង្កប់ត្រង់ចន្លោះភ្នំទាំង ២ គប្បីស្រែកហ៊ោឡើងវាយកាត់មកអំពីខាងក្រោយ ក៏អាចចាប់ព្រះបាទអជាតសត្តុបានដូចចាប់ត្រីដែលចូលខាងក្នុងសំណាញ់និងដូចចាប់កូនចាបដែលនៅក្នុងកណ្ដាប់ដៃដូច្នោះ ។ ពួកចារបុរសក៏ក្រាបទូលសេចក្ដីនោះដល់ព្រះរាជា ព្រះរាជាបានស្ដាប់ដូច្នោះទើបត្រាស់ឲ្យវាយស្គរសង្គ្រាមភេរី ហើយយាងទៅរៀបចំក្បួនទ័ពសកដព្យូហៈ ចាប់ព្រះបាទអជាតសត្តុទាំងរស់ បានប្រទានរាជធីតារបស់ព្រះអង្គព្រះនាមថា វជិរកុមារីដល់ព្រះភាគិនេយ្យ ( ព្រះបាទអជាតសត្តុ ) ហើយបានប្រទានកាសិកគ្រាមឲ្យជាថ្លៃសម្រាប់ស្រពស្រង់ ដល់ព្រះរាជធីតានោះហើយបញ្ជូនទៅ ។ ការប្រព្រឹត្តទៅនោះបានប្រាកដទៅក្នុងពួកភិក្ខុសង្ឃ ។ សម័យមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយបានឮថា ព្រះបាទកោសលទ្រង់ឈ្នះព្រះបាទអជាតសត្តុ ព្រោះការគិតរបស់ព្រះធនុគ្គហតិស្សត្ថេរ ព្រះសាស្ដាទ្រង់យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងឈ្មោះអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនព្រះធនុគ្គហតិស្សត្ថេរ ក៏ជាអ្នកឈ្លាសក្នុងការគិតក្នុងរឿងចម្បាំងមកហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅ

នេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតាក្នុងដងព្រៃ ។ ក្នុងកាលនោះជាងឈើម្នាក់ចេញអំពីស្រុក ជាងឈើក្នុងនគរពារាណសី ទៅកាន់ព្រៃដើម្បីត្រូវការឈើ ឃើញកូនជ្រូកធ្លាក់រណ្ដៅ ទើបនាំយកទៅផ្ទះចិញ្ចឹមទុក កូនជ្រូកនោះដល់នូវការធំធាត់ មានរាងកាយធំ មានខ្នាយកោងជាសត្វដល់ព្រមដោយមារយាទ ព្រោះជាងឈើនាំមកចិញ្ចឹមទុកទើបប្រាកដឈ្មោះថា វឌ្ឍកីសូករៈ ។ វឌ្ឍកី-សូករៈនោះក្នុងពេលជាងឈើចាំងឈើក៏យកមាត់ប្រមៀលឈើឲ្យ យកមាត់ពាំកាំបិត ប៉ូវថៅ ពន្លាកនិងញញួរមកឲ្យ ជួយទាញខ្សែបន្ទាត់ឲ្យ ។ លំដាប់នោះជាងឈើនោះក៏នាំវឌ្ឍកីសូករៈនោះទៅលែងក្នុងព្រៃព្រោះខ្លាចបុគ្គលណាមួយសម្លាប់បរិភោគ ។ ចំណែកវឌ្ឍកីសូករៈនោះចូលព្រៃពិនិត្យមើលទីកន្លែងដែលជាផាសុក មិនមានភ័យបានឃើញញកភ្នំធំក្នុងរវាងភ្នំមួយកន្លែងបរិបូណ៌ដោយមើមដំឡូងនិងឫសឈើជាទីកន្លែងគួរផាសុក ដេរដាសដោយជ្រូកច្រើនរយ ។ ជ្រូកទាំងនោះឃើញវឌ្ឍកីសូករៈនោះហើយ ទើបមកកាន់សម្នាក់របស់វឌ្ឍកីសូករៈនោះ ។ ចំណែកវឌ្ឍកីសូករៈនោះក៏ពោលនិងជ្រូកទាំងនោះថា ខ្ញុំដើររកពួកអ្នកនោះឯង ឥឡូវនេះខ្ញុំបានជួបពួកអ្នកហើយ ម្យ៉ាងទៀតទីនេះជាទីកន្លែងគួរត្រេកអរ ឥឡូវនេះខ្ញុំនិងនៅទីនេះឯង ។ ជ្រូកទាំងឡាយពោលថា ពិតណាស់ក្នុងទីនេះជាស្ថានទីដែលគួររីករាយ តែមានអន្តរាយ ។ វឌ្ឍកីសូករៈពោលថា ខ្ញុំបានឃើញអ្នកទាំងឡាយហើយក៏បាន

ដឹងដល់សេចក្តីនោះ កាលអ្នកទាំងឡាយនៅក្នុងទីដែលសម្បូរដោយគោចរ យ៉ាងនេះសាច់និងឈាមក្នុងរាងកាយរបស់ពួកអ្នកក៏មិនមាន ពួកអ្នកមានភ័យអ្វីក្នុងទីនេះ ។ ជ្រូកទាំងឡាយពោលថា មានខ្លាធំមួយមកអំពីព្រលឹម ចាប់ជ្រូកណាមួយដែលវាឃើញយកទៅ វឌ្ឍកីសូករៈសួរថា ខ្លាធំនោះចាប់យករាល់ថ្ងៃឬវៀរថ្ងៃខ្លះ ជ្រូកទាំងឡាយពោលថា ចាប់យកជាប្រចាំរាល់ថ្ងៃ វឌ្ឍកីសូករៈសួរថា ខ្លានោះមានប៉ុន្មាន ជ្រូកទាំងឡាយពោលថាមាន ១ ។ វឌ្ឍកីសូករៈពោលថា ពួកអ្នកមានប្រមាណប៉ុណ្ណេះមិនអាចច្បាំងនឹងខ្លាមួយបានឬ ជ្រូកទាំងឡាយពោលថា មិនអាច វឌ្ឍកីសូករៈពោលថា ខ្ញុំនឹងចាប់ខ្លានោះ សូមពួកអ្នកធ្វើតាមពាក្យខ្ញុំ ខ្លានោះនៅឯណា ជ្រូកទាំងឡាយពោលថា នៅត្រង់ភ្នំនោះ ។ វឌ្ឍកីសូករៈនោះក្នុងរាត្រីនោះឯងបានរៀបចំជ្រូកទាំងឡាយ កាលនឹងរៀបចំការច្បាំងទើបពោលថា ឈ្មោះថាការច្បាំងមាន ៣ យ៉ាង គឺបទុមព្យូហៈ ១ ចក្កព្យូហៈ ១ សកដព្យូហៈ ១ ហើយរៀបចំតាមក្បួនបទុមព្យូហៈ ។ វឌ្ឍកីសូករៈ ស្គាល់ទីជ័យភូមិ ព្រោះហេតុនោះទើបគិតថា គួរចាត់ការច្បាំងក្នុងទីនេះ ដូច្នេះហើយទើបដាក់ជ្រូកដែលជាលំដាប់មេបាដែលមានកូនតូច ទុកត្រង់កណ្តាលរបស់ជ្រូកទាំងនោះ ដាក់ជ្រូកញីជំទង់ជុំវិញជ្រូកលំដាប់មេបាដែលមានកូនតូចទាំងនោះ ដាក់ជ្រូកឈ្មោលជំទង់ជុំវិញជ្រូកញីជំទង់នោះ ដាក់ជ្រូកពេញកម្លាំងជុំវិញជ្រូកឈ្មោលជំទង់នោះ ដាក់ជ្រូកដែលមានខ្នាយវែងជុំវិញជ្រូកដែលពេញកម្លាំងទាំងនោះ ហើយដាក់ជ្រូកដែលសម្បូរដោយកម្លាំងអាចប្រយុទ្ធបានអំពីខាងក្រៅ រៀបចំ

ឲ្យជាពួកៗ ក្នុងទីនោះៗ មួយពួក ១០ ខ្លះ ២០ ខ្លះ ៣០ ខ្លះព័ទ្ធជុំវិញពួកជ្រូកដែលមានខ្នាយវែងទាំងនោះ វឌ្ឍកីសូករៈនោះឲ្យជីករណ្តៅមូលទុកមួយរណ្តៅខាងមុខទីដែលខ្លួនឈរនិងឲ្យជីករណ្តៅមួយទៀត ទុកខាងក្រោយទីដែលខ្លួនឈរ ឲ្យមានសណ្ឋានដូចចង្អេរអុំអង្ករជម្រាលទៅតាមលំដាប់ ដូចគ្នានឹងញកក្ន័ ។ កាលវឌ្ឍកីសូករៈនោះនាំជ្រូកអ្នកប្រយុទ្ធប្រមាណ ៦០ ឬ ៧០ ក្បាលត្រាច់ចាត់ចែងការងារក្នុងទីនោះៗ មួយអន្លើដោយពាក្យថា ពួកអ្នកកុំខ្លាចឡើយរហូតដល់ថ្ងៃរះ ។ ចំណែកខ្លាធំក្រោកឡើងដឹងថាបានវេលា ក៏ទៅឈរលើក្ន័ ដែលតាំងនៅក្នុងទីចំពោះមុខជ្រូកទាំងនោះ សម្លឹងមើលជ្រូកទាំងឡាយ ។ វឌ្ឍកីសូករៈ បានឲ្យសញ្ញាដល់ជ្រូកទាំងនោះថា ពួកអ្នកចូរបើកភ្នែកសម្លឹងតទៅរកវា ។ ជ្រូកទាំងនោះក៏សម្លឹងត ។ ខ្លាហាមាត់ដកដង្ហើម ជ្រូកទាំងឡាយក៏បានធ្វើយ៉ាងនោះដូចគ្នា ។ ខ្លាបន្ទោបង់បស្សាវៈ ពួកជ្រូកក៏បន្ទោបង់បស្សាវៈដែរ ។ កាលខ្លានោះធ្វើកិរិយាអាការយ៉ាងណាៗ ជ្រូកទាំងឡាយក៏ធ្វើអាការៈយ៉ាងនោះៗ ។ ខ្លាគិតថា កាលមុនក្នុងកាលដែលអញសម្លឹងមើល ជ្រូកទាំងឡាយនាំគ្នារត់ទៅ ថ្ងៃនេះជ្រូកមិនរត់បែរជាធ្វើជាសត្រូវតបនឹងអញធ្វើត្រាប់កិរិយាអាការៈដែលអញធ្វើ ត្រង់ផ្ទៃដីដែលជាប្រធាននោះមានជ្រូកមួយឈរបញ្ជាជ្រូកទាំងនោះ ថ្ងៃនេះជ័យជម្នះមិនប្រាកដដល់អញទៅហើយ ។ ខ្លាគិតដូច្នេះហើយទើបត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។ ម្យ៉ាងទៀតមានជដិលកោងម្នាក់អ្នកចាំស៊ីសាច់ដែលខ្លានោះពាំយកមក ហើយជដិលកោងនោះឃើញខ្លាត្រឡប់មកទទេ កាលប្រាស្រ័យជាមួយខ្លានោះទើប

ពោលគាថាទី ១ ថា

កាលពីដើមអ្នករីបជាន់នូវជ្រូកទាំងឡាយក្នុងប្រទេសនេះ តែង
សម្លាប់ជ្រូកដ៏ប្រសើរៗបាន ម្នាលខ្លា ឥឡូវនេះអ្នកនោះ
ត្រឡប់មកម្នាក់ឯងសញ្ជប់សញ្ជឹង ម្នាលខ្លា ថ្ងៃនេះកម្លាំងកាយ
របស់អ្នកគ្មានទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វរំ វរំ ត្វំ និហានំ បុរេ ចរិ អស្មឹ បទេសេ អភិភុយ្យ សូករេ** សេចក្តីថា នែខ្លាដ៏ចម្រើន កាលមុនអ្នកញាំញី ជ្រូកទាំងពួងក្នុងប្រទេសនេះ បណ្តាជ្រូកទាំងនេះ អ្នកត្រាច់សម្លាប់ជ្រូកធំៗ គឺជ្រូកធាត់ៗ បានដល់ ជ្រូកដែលមានសាច់បរិបូណ៌ ។ បទថា **សោធានិ ឯកោ ព្យគ្ឃ បគម្ហ ឈាយសិ** សេចក្តីថា ឥឡូវនេះ អ្នកមិនចាប់ជ្រូកដទៃ ម្នាក់ឯងប៉ុណ្ណោះស្ងប់សៅដើរមក ។ បទថា **ពលន្នុ តេ ព្យគ្ឃ ន ចជ្ជ វិជ្ជតិ** សេចក្តីថា នែខ្លាដ៏ចម្រើន ថ្ងៃនេះកម្លាំងកាយរបស់អ្នកមិនមានទេឬ ។

ខ្លាបានស្តាប់ដូច្នោះទើបពោលគាថាទី ២ ថា

កាលពីដើមជ្រូកទាំងនេះជាច្រើនត្រូវភ័យបៀតបៀនហើយ ក៏
ស្វែងរកទីជ្រកកោនហើយក៏បោលទៅកាន់ទិសតូចទិសធំ ឥឡូវ
នេះជ្រូកទាំងនេះស្ថិតនៅក្នុងទីណា ដែលខ្ញុំបៀតបៀនមិនបាន
ជ្រូកទាំងនោះក៏មកជួបជុំគ្នានៅក្នុងទីនោះជាមួយគ្នា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អស្សុ តា** ត្រឹមតែជានិបាត ឯអត្ថជាយសង្ខេបមានដូចតទៅនេះថា កាលមុន ជ្រូកទាំងនេះឃើញខ្ញុំហើយ ត្រូវការ

ខ្លាចបៀតបៀន ស្វែងរកទីពួនទីសម្ងំរៀង ៗ ខ្លួន ។ បទថា **បុថូ** សេចក្តីថា ជាអ្នកលះពួក គឺបែកខ្ញែកគ្នាទៅម្នាក់មួយផ្លូវ ។ បទថា **ឆិសោឆិសំ** គឺ បែរមុខគេចទៅកាន់ទិសនោះៗឥឡូវនេះជ្រូកទាំងអស់នោះមកប្រជុំគ្នាបន្លឺសំឡេងក្នុងទីជ័យភូមិ ។ បទថា **យត្ថដ្ឋិតា ឧប្បសហាដ្ឋិមេ មយា** សេចក្តីថា ជ្រូកទាំងនេះតាំងនៅក្នុងទីជ័យភូមិដែលខ្ញុំញ៉ាំញីបានដោយលំបាក ។

ជដិលកោងកាលញ៉ាំងឧស្សាហៈឲ្យកើតដល់ខ្លានោះទើបពោលថា ទៅចុះកុំខ្លាចឡើយ កាលអ្នកបន្លឺសំឡេងរត់ចូលទៅជ្រូកទាំងអស់ខ្លាចនឹងនាំគ្នាបែកខ្ញែករត់ទៅ ។ កាលជដិលកោងនោះ ធ្វើឲ្យកើតឧស្សាហៈខ្លាធំ ក៏មានចិត្តក្លាហានត្រឡប់ទៅឈរលើភ្នំទៀត វឌ្ឍកីសូករៈឈរក្នុងចន្លោះរណ្តៅទាំង ២ ចំណែកជ្រូកទាំងឡាយ ពោលថា បពិត្រលោកម្ចាស់ មហាចោរមកទៀតហើយ ។ វឌ្ឍកីសូករៈពោលថា កុំខ្លាច កុំខ្លាច ខ្ញុំនឹងចាប់វាឥឡូវនេះឯង ។ ខ្លាធំបន្លឺសំឡេងហើយលោតទៅអំពីខាងលើវឌ្ឍកីសូករៈ ។ ក្នុងវេលាដែលខ្លានោះធ្លាក់ចុះមកលើខ្លួន វឌ្ឍកីសូករៈក៏ប្រមៀលខ្លួនគេចទៅក្នុងរណ្តៅដែលជីកខាងមុខ ដោយចំណែកខាងក្រោយរបស់ខ្លា ។ ខ្លាមិនអាចទប់នូវសន្ទុះបាន ក៏ជ្រុលទៅខាងលើធ្លាក់ចុះទៅមាត់រណ្តៅដែលចង្អៀតដែលជ្រូកជីកទុកមានសណ្ឋានដូចមាត់ចង្អេររាងកាយខ្លាដូចគរដោយគំនរដូច្នោះ ។ វឌ្ឍកីសូករៈស្ទុះឡើងអំពីរណ្តៅ ប្រញាប់រត់ទៅរហ័សដូចផ្លេកបន្ទោរ យកខ្នាយវៃចខ្លាធំត្រង់ចន្លោះភ្លៅ មុតរហូតដល់តម្រងបស្សាវៈ យកខ្នាយខ្វេះសាច់ដែលធ្វាញ់ ៥ យ៉ាងចេញមក រុំជុំវិញក្បាលរបស់ខ្លាធំ ហើយលើកឡើងបោះចេញទៅ

ខាងក្រៅរណ្តៅពោលថា អ្នកទាំងឡាយចូរចាប់បច្ចាមិត្តរបស់ពួកអ្នក ។ ពួកជ្រូកដែលមកមុនក៏បានស៊ីសាច់ខ្លាធំ ពួកជ្រូកដែលមកឯក្រោយពោលថា ឈ្មោះថា សាច់ខ្លាដូចម្តេចហ្ន៎ ទើបដើរហិតមាត់របស់ជ្រូកទាំងនោះ ។ ជ្រូកទាំងឡាយក៏មិនទាំគ្នាត្រេកអរ ។ វឌ្ឍកីសូករៈឃើញអាការៈរបស់ជ្រូកទាំងនោះទើបពោលថា ព្រោះហេតុអ្វី ទើបពួកអ្នកមិនត្រេកអរ ជ្រូកទាំងឡាយពោលថា បពិត្រលោកម្ចាស់ ប្រយោជន៍អ្វីដោយខ្លាមួយដែលត្រូវសម្លាប់ ជដិលកោងអាចនាំយកខ្លាដទៃមកបានទៀតមាន ។ វឌ្ឍកីសូករៈសួរថា ជដិលកោងនោះគឺនរណា ពួកជ្រូកពោលថា តាបសទ្រុស្តសីលម្នាក់ ។ វឌ្ឍកី-សូករៈពោលថា សូម្បីខ្លាធំគង់យើងសម្លាប់បាន តាបសទ្រុស្តសីលនោះមិនល្មមសម្រាប់ខ្ញុំ មកចុះអ្នកទាំងឡាយ ពួកយើងនឹងចាប់តាបសទ្រុស្តសីលនោះ ពោលហើយក៏ទៅព្រមជាមួយពួកជ្រូក ។ ចំណែកតាបសកោងកាលខ្លាយឺតយូរក៏គិតថា ពួកជ្រូកចាប់ខ្លាបានហើយទេដឹងហ្ន៎ ដូច្នេះហើយទើបដើរប្រាសផ្លូវមកបានឃើញជ្រូកទាំងឡាយកំពុងមក កាន់យកបរិក្ខាររបស់ខ្លួនរត់ទៅត្រូវជ្រូកទាំងនោះដេញតាមទើបទម្លាក់បរិក្ខារទាំងឡាយ ប្រញាប់ឡើងដើមល្វាដោយរហ័ស ជ្រូកទាំងឡាយពោលថា បពិត្រលោកម្ចាស់ ឥឡូវនេះតាបសអាក្រក់នេះឡើងដើមឈើទៅហើយ ។ វឌ្ឍកីសូករៈសួរថា ដើមនេះឈ្មោះដើមអ្វី ជ្រូកទាំងឡាយប្រាប់ថា ដើមល្វា ។ វឌ្ឍកីសូករៈនោះចាត់ចែងថា ជ្រូកញីចូរទៅនាំទឹកមក កូនជ្រូកចូរជីក ជ្រូកដែលមានចង្កូមចូរកាត់ឫស ចំណែកជ្រូកដែលសេសសល់ព័ទ្ធដើមល្វារក្សាទុក ។ កាលជ្រូកទាំង

នោះធ្វើយ៉ាងនោះ ខ្លួនឯងក៏គាស់ឫសកែវរបស់ដើមល្វាឲ្យដើមល្វាដួលចុះដូច យកប៉ូវថៅកាប់ដូច្នោះ ។ ពួកជ្រូកដែលឈរចោមរោមក៏ធ្វើជដិលកោងដែល ធ្លាក់ចុះមកលើផែនដីឲ្យជាកំណាត់តូចធំហើយទំពាស៊ីរហូតដល់ឆ្អឹង អញ្ជើញ វឌ្ឍកីសូករៈ ឲ្យអង្គុយលើដើមល្វានោះឯង ហើយឲ្យយកស័ង្ខបរិក្ខាររបស់ ជដិលជងទឹកមកអភិសេក តែងតាំងឲ្យជាព្រះរាជា និងតែងតាំងជ្រូកញីមួយ ឲ្យជាអគ្គមហេសីរបស់វឌ្ឍកីសូករៈនោះ ។ បានឮថា ចាប់តាំងអំពីនោះមក អាមាត្យរាជសេវកៈទាំងឡាយយាងព្រះរាជាឲ្យគង់លើឧទុម្ពរភទ្ទបីឋៈ ( តាំង ដើមល្វា ) ហើយអភិសេកដោយស័ង្ខ ៣ ប្រភេទជាប់ជាតំណាមកដល់សព្វ ថ្ងៃនេះ ។ ទេវតាដែលស្ថិតនៅក្នុងដងព្រៃនោះ ឃើញនូវភាពអស្ចារ្យនោះ បង្ហាញមុខដល់ជ្រូកទាំងឡាយត្រង់ប្រគាបឈើពោលគាថាទី ៣ ថា

> យើងសូមថ្វាយបង្គំពួកជ្រូកដែលមកជួបជុំគ្នា ( ក្នុងទីនេះ )
> យើងបានឃើញនូវមិត្តភាព ( របស់អ្នកទាំងឡាយ ) ដ៏
> អស្ចារ្យដោយខ្លួនឯង ទើបពោលព្រោះថា ពួកម្រឹគមានខ្នាយ
> បានឈ្នះនូវខ្លា រួចចាក ( មរណភ័យ ) ដោយសេចក្តីព្រម
> ព្រៀងក្នុងពួកជ្រូកមានខ្នាយជាកម្លាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆមត្ថុ សង្ឃាន** សេចក្តីថា ការធ្វើនមស្ការ របស់ខ្ញុំនេះ ចូរមានដល់ជ្រូកទាំងឡាយដែលមកប្រជុំគ្នា ។ បទថា **ឥស្សា សយំ សខ្យ វទាមិ អត្ថុតំ** សេចក្តីថា ខ្ញុំបានឃើញនូវភាពជាសម្លាញ់ គឺមិត្តភាពដែលមិនធ្លាប់មានក្នុងកាលមុន ឈ្មោះថាមិនធ្លាប់មាននេះទើប

ពោល ។ បទថា **ព្យគ្ឃំ មិគា យត្ថ ជិឃឹសុ ធាឋិនោ** សេចក្ដីថា ឈ្មោះថា ម្រឹគ គឺជ្រូកទាំងឡាយដែលមានខ្នាយឈ្នះនូវខ្លាធំដោយសាមគ្គីណា ។ ម្យ៉ាងទៀត បាលីក៏ដូចគ្នា ។ បទថា **សាមគ្គិយា ធាឋពលេសុ មុច្ចរេ** សេចក្ដីថា សាមគ្គី គឺភាពជាអ្នកមានអធ្យាស្រ័យតែមួយក្នុងពួកជ្រូកដែលមានខ្នាយជាកម្លាំងនេះឯណា ដោយសាមគ្គីក្នុងពួកជ្រូកនោះ ជ្រូកដែលមានខ្នាយជាកម្លាំងទាំងនោះចាប់សត្រូវបានទើបផុតចាកមរណភ័យក្នុងថ្ងៃនេះ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា វឌ្ឍកីសូករៈក្នុងកាលនោះបានមកជាធនុគ្គហតិស្សត្ថេរក្នុងកាលឥឡូវនេះ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វឌ្ឍកីសូករជាតក ចប់

## សិរីជាតក

[ ៤៥១ ] ( ព្រះសាស្តាត្រាស់ថា ) ពួកបុគ្គលឥតបុណ្យ ខ្វល់ខ្វាយប្រមូលទ្រព្យណាដ៏ច្រើន ចំណែកខាងបុគ្គលអ្នកមានបុណ្យទោះមានសិល្បៈក្តី មិនមានសិល្បៈក្តី ក៏រមែងបានបរិភោគនូវទ្រព្យទាំងនោះ ។

[ ៤៥២ ] ភោគៈទាំងឡាយច្រើន រមែងកន្លងនូវពួកបុគ្គលឥតបុណ្យកើតឡើងសម្រាប់បុគ្គលអ្នកមានបុណ្យធ្វើហើយក្នុងទីទាំងពួង សូម្បីក្នុងទីមិនមែនជាកន្លែងសម្រាប់កើត ។

[ ៤៥៣ ] មាន់ឈ្មោលក្តី កែវមណីក្តី ឈើច្រត់ក្តី នាងបុញ្ញលក្ខណាទេវីជាប្រពន្ធ ( របស់សេដ្ឋី ) ក្តី រមែងកើតឡើងដល់អនាថបិណ្ឌិកសេដ្ឋីអ្នកមិនមានបាប ជាអ្នកមានបុញ្ញធ្វើហើយ ។

**ចប់ សិរីជាតកទី ៤ ។**

## អដ្ឋកថា

## សិរីជាតក

[ ៤៥១-៤៥៣ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ចោរលួចសិរីម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យំ ឧស្សុក្កា សង្ឃរន្តិ** ដូច្នេះជាដើម ។

ក្នុងជាតកនេះរឿងបច្ចុប្បន្នមានពិស្តារហើយ ក្នុងខទិរង្គារជាតកខាងដើមនោះឯង តែក្នុងទីនេះទេវតាដែលជាមិច្ឆាទិដ្ឋិដែលអាស្រ័យនៅត្រង់ខ្លោងទ្វារ

ទីមួយក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីនោះ កាលធ្វើទណ្ឌកម្មដល់ខ្លួនឯងទើប នាំយកប្រាក់ ៥៤ កោដិមកដាក់ពេញជង្រុកបានជាសម្លាញ់ជាមួយសេដ្ឋី ។ លំដាប់នោះសេដ្ឋីបាននាំទេវតានោះទៅកាន់សម្នាក់របស់ព្រះសាស្តា ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ទេវតានោះ ។ ទេវតានោះកាលបានស្តាប់ធម៌ហើយបាន ជាព្រះសោតាបន្ន ។ តាំងអំពីនោះមកយសរបស់សេដ្ឋីក៏ដូចដើម ។ កាលនោះ មានព្រាហ្មណ៍អ្នកស្គាល់លក្ខណៈសិរីអ្នកនគរសាវត្ថីម្នាក់គិតថា អានាថ-បិណ្ឌិកសេដ្ឋីជាបុគ្គលក្រីក្រហើយត្រឡប់បានជាធំវិញ ណ្ហើយចុះអញធ្វើហាក់ដូចត្រូវការនឹងទៅសួរសុខទុក្ខលោកសេដ្ឋីនោះហើយលួចយកសិរីអំពីផ្ទះសេដ្ឋីនោះមក ។ ព្រាហ្មណ៍នោះទៅកាន់ផ្ទះលោកសេដ្ឋី កាលសេដ្ឋីធ្វើសក្ការៈនឹងការរាប់អានហើយ កាលកំពុងពោលពាក្យដែលជាគ្រឿងឲ្យរឭកដល់គ្នានឹងគ្នា ទើបសេដ្ឋីពោលថា អ្នកមករកខ្ញុំដើម្បីត្រូវការអ្វី ក៏ពិនិត្យមើលថាសិរីប្រតិស្ឋានទៅក្នុងទីណាហ្ន៎ ។ ចំណែកសេដ្ឋីមានមាន់សសុទ្ធមានចំណែកប្រៀបដូចស័ង្ខដែលខាត់ហើយទុកក្នុងទ្រុងមាស ។ សិរីប្រតិស្ឋានត្រង់សិររបស់មាន់នោះ ។ ព្រាហ្មណ៍ពិនិត្យមើលដឹងថាសិរីប្រតិស្ឋានត្រង់មាន់នោះ ទើបពោលថា លោកសេដ្ឋីខ្ញុំបង្រៀនមន្តពួកមាណព ៥០០ ព្រោះអាស្រ័យមាន់មួយរងាវមិនត្រូវកាលពួកមាណពនឹងខ្ញុំលំបាក បានឮថា មាន់នេះរងាវត្រូវកាល ខ្ញុំមកដើម្បីត្រូវការមាន់នេះ សូមលោកឲ្យមាន់នេះដល់ខ្ញុំចុះ ។ សេដ្ឋីពោលថា នែព្រាហ្មណ៍ សូមលោកចាប់យកចុះ ខ្ញុំឲ្យមាន់នេះដល់លោក ។ ក្នុងខណៈដែលសេដ្ឋីពោលថា ឲ្យប៉ុណ្ណោះ សិរីក៏ឃ្លៀតចាកសិរមាន់នោះទៅ

ប្រតិស្ឋានត្រង់កែវមណីដែលទុកលើក្បាលដំណេក ។ ព្រាហ្មណ៍ដឹងថា សិរី ទៅប្រតិស្ឋានត្រង់កែវមណីទើបសូមកែវមណីនោះ ។ ក្នុងខណៈដែលសេដ្ឋី ពោលថា សូមប្រើកែវមណីក៏ខ្ញុំឲ្យ សិរីក៏ឃ្លៀតចាកកែវមណីទៅប្រតិស្ឋានត្រង់ ឈើប្រត់ដែលទុកលើក្បាលដំណេក ព្រាហ្មណ៍ដឹងថា សិរីទៅប្រតិស្ឋានត្រង់ ឈើប្រត់នោះទើបសូមឈើប្រត់ ក្នុងខណៈដែលសេដ្ឋីពោលថា ចូរកាន់យក ចុះ សិរីក៏ឃ្លៀតចាកឈើប្រត់ទៅប្រតិស្ឋាន ត្រង់សីសៈរបស់ភរិយាធំរបស់ សេដ្ឋីឈ្មោះ បុញ្ញលក្ខណាទេវី ។ ចោរព្រាហ្មណ៍អ្នកលួចសិរីដឹងថា សិរី ទៅប្រតិស្ឋានត្រង់ភរិយាធំរបស់សេដ្ឋីទើបគិតថា អញមិនអាចសូមភរិយាធំ នេះដែលជាទ្រព្យសេដ្ឋីលះបង់មិនបានដូច្នេះ ទើបពោលពាក្យនេះនឹងលោក សេដ្ឋីថា លោកសេដ្ឋី ខ្ញុំមកដោយតាំងចិត្តថានឹងលួចសិរីក្នុងផ្ទះរបស់លោក ទៅ សិរីបានប្រតិស្ឋានត្រង់សិរមាន់របស់លោក កាលលោកឲ្យមាន់នេះ ដល់ខ្ញុំ សិរីក៏ឃ្លៀតចាកមាន់នោះទៅប្រតិស្ឋានត្រង់កែវមណី កាលលោកឲ្យ កែវមណី សិរីក៏ទៅប្រតិស្ឋានត្រង់ឈើប្រត់ កាលលោកឲ្យឈើប្រត់ សិរី ក៏ឃ្លៀតចាកឈើប្រត់ទៅប្រតិស្ឋានត្រង់ក្បាលរបស់នាង បុញ្ញលក្ខណាទេវី ខ្ញុំគិតថាទ្រព្យនេះ ( ភរិយា ) ជាទ្រព្យលះបង់មិនបានដូច្នេះហើយទើបមិន អាចលួចសិរីរបស់លោកបាន របស់លោកចូរជារបស់លោកនោះឯង ។ កាល ពោលហើយ ក៏ក្រោកចាកអាសនៈជៀសចេញទៅ ។ អានាថបិណ្ឌិកសេដ្ឋី គិតថានឹងក្រាបទូលហេតុការណ៍នេះដល់ព្រះមានព្រះភាគ ដូច្នេះហើយ ទើប ទៅកាន់វិហារបូជាព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងចំណែក

ម្នាង ក្រាបទូលរឿងទាំងអស់នោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់បានស្តាប់ដូច្នោះទើបត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេដែលសិរីរបស់អ្នកដទៃទៅក្នុងទីដទៃ សូម្បីក្នុងកាលមុនសិរីដែលបុគ្គលមានបុណ្យតិចឲ្យកើតឡើង ក៏ទៅទៀបបាទមូលរបស់បុគ្គលមានបុណ្យ ( ច្រើន ) ប៉ុណ្ណោះ កាលអនាថបិណ្ឌិកសេដ្ឋីទូលអារាធនាហើយទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងកាសិករដ្ឋ លុះចម្រើនវ័យហើយបានរៀនសិប្បៈទាំងពួងក្នុងនគរតក្កសិលា នៅគ្រប់គ្រងផ្ទះ មានចិត្តសង្វេគព្រោះមាតាបិតាធ្វើកាលកិរិយាទៅ ទើបចេញបួសជាឥសីនៅក្នុងហិមវន្តប្បទេស ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ញ៉ាំងកាលវេលាឲ្យកន្លងទៅអស់កាលយូរបានទៅកាន់ជនបទដើម្បីបរិភោគរសជូរប្រៃ នៅក្នុងព្រះរាជឧទ្យានរបស់ព្រះបាទពារាណសី ស្អែកឡើងត្រាច់ភិក្ខាចារបានទៅកាន់ទ្វារផ្ទះរបស់ហត្ថាចារ្យ ។ ហត្ថាចារ្យនោះជ្រះថ្លាក្នុងអាចារៈនិងវិហារធម៌របស់តាបសនោះទើបប្រគេនភិក្ខាហារនិមន្តឲ្យនៅក្នុងព្រះរាជឧទ្យានប្រតិបត្តិជានិច្ច ។ ក្នុងកាលនោះអ្នករកឧសចិញ្ចឹមជីវិតម្នាក់ នាំឧសមកអំពីព្រៃមិនអាចមកទាន់ទ្វារនគរបានតាមកាលក្នុងវេលាល្ងាចទើបធ្វើបាច់ឧសឲ្យជាខ្នើយ ហើយដេកត្រង់សាលាមួយកន្លែង ។ មានមាន់ជាច្រើនដែលអ្នកស្រុកលែងត្រង់សាលានាំគ្នាដេកត្រង់ដើមឈើមួយដើមមិនឆ្ងាយអំពីបុរសអ្នករកឧសនោះ ។ ក្នុងវេលាទៀប

ក្តីមាន់ដែលដេកលើមាន់ទាំងនោះបន្ទោបង់ដាក់មាន់ដែលដេកខាងក្រោម កាលមាន់ដែលដេកខាងក្រោមសួរថា អ្នកណាជុះអាចម៍ដាក់អញ ទើបពោលថាខ្ញុំ កាលមាន់ខាងក្រោមពោលថា ព្រោះហេតុអ្វី ទើបពោលថា មិនបានពិចារណា ហើយក៏បន្ទោបង់ដាក់ម្តងទៀត ។ ពេលនោះមាន់ទាំងពីរក៏ខឹងដល់គ្នានឹងគ្នាធ្វើនូវជម្លោះថា កម្លាំងរបស់អ្នកមានឬ កម្លាំងរបស់អ្នកមានឬ ។ លំដាប់នោះមាន់ដែលដេកខាងក្រោមពោលថា អ្នកណាសម្លាប់ខ្ញុំហើយស៊ីសាច់ដែលឆ្អិនដោយរងើកភ្លើងនឹងបានទ្រព្យ ១០០០ កហាបណៈទាំងព្រឹក ។ មាន់ដែលដេកខាងលើពោលថា នែអ្នកដ៏ចម្រើន អ្នកកុំអួតអានុភាពមានប្រមាណប៉ុណ្ណោះដ្បិតថា អ្នកណាបានស៊ីសាច់ចំឡូករបស់ខ្ញុំ នឹងបានជាស្តេចអ្នកណាស៊ីសាច់ខាងក្រៅ បើជាបុរសនឹងបានតំណែងសេនាបតី បើជាស្ត្រីនឹងបានតំណែងជាអគ្គមហេសី ឯអ្នកស៊ីសាច់ជាប់ឆ្អឹងរបស់ខ្ញុំ បើជាគ្រហស្ថនឹងបានជានាយឃ្លាំង បើជាអ្នកបួសនិងបានជារាជកុលុបកៈ ។ បុរសអ្នករកឧសបានស្តាប់ពាក្យរបស់មាន់ទាំងពីរនោះហើយគិតថា បើអញបានសោយរាជសម្បត្តិហើយកិច្ចដោយទ្រព្យ ១០០០ មិនមាន ដូច្នេះហើយទើបលបៗឡើងទៅចាប់មាន់ដែលដេកខាងលើសម្លាប់ហើយខ្ចប់ទុកគិតថា អញនឹងបានជាព្រះរាជាទើបដើរទៅ លុះទ្វារនគរបើកក៏ចូលនគរ រៀបចំបោចរោមមាន់លាងទឹកឲ្យស្អាតហើយឲ្យដល់ភរិយាប្រាប់ថា ចូរនាងចម្អិនសាច់មាន់នេះឲ្យល្អ ។ ភរិយាចាត់ចែងសាច់និងបាយស្រេចហើយបង្អោនចូលទៅឲ្យដល់ស្វាមីថា សូមអ្នកបរិភោគចុះ ស្វាមីពោលថា នែនាងដ៏ចម្រើនសាច់នេះមានអានុភាពច្រើន

ខ្ញុំបរិភោគសាច់នេះហើយនឹងបានជាព្រះរាជា ឯនាងនឹងបានជាអគ្គមហេសី ។ ស្វាមីភរិយាទាំងពីរកាន់យកបាយនិងសាច់នោះទៅកាន់ឆ្នេរស្ទឹងគង្គា គិតថាងូត ហើយនឹងបរិភោគ ទើបដាក់ភាជនៈអាហារត្រង់មាត់ច្រាំងហើយចុះទៅងូតទឹក ។ ខណៈនោះ ទឹកត្រូវខ្យល់បក់ឡើងមកបាននាំយកភាជនៈភត្តាហារអណ្តែតទៅ ។ ភាជនៈអាហារនោះត្រូវខ្យល់បក់មកមហាមាត្យដែលជាហត្ថាចារ្យម្នាក់ កំពុងឲ្យដំរីងូតទឹកក្នុងស្ទឹងខាងក្រោមឃើញភាជនៈនោះទើបឲ្យលើកឡើង ឲ្យបើកមើលសួរថា មានអ្វី ពួកបរិវារប្រាប់ថា ភត្តាហារនិងសាច់មាន់ ។

មហាមាត្យនោះក៏ឲ្យបិទភាជនភត្តាហារនោះហើយឲ្យបោះត្រាបញ្ជូនទៅឲ្យភរិយាថា នាងកុំបើកសាច់និងបាយទម្រាំខ្ញុំមក ។ ចំណែកអ្នករកឧសពោះប៉ោងព្រោះទឹកលាយដីខ្សាច់ចូលមាត់ ទើបជៀសចេញទៅ ។ លំដាប់នោះតាបសមានចក្ខុទិព្វដែលជាកុលុបកៈរបស់នាយហត្ថាចារ្យនោះគិតថា ញោមឧបដ្ឋាករបស់អញមិនទាន់រួចផុតជាភាពហត្ថាចារ្យ កាលណាហ្ន៎ ទើបបានសម្បត្តិ ដូច្នេះហើយ ទើបពិចារណាដោយទិព្វចក្ខុឃើញបុរសនោះ ដឹងហេតុការណ៍នោះ ទើបរៀសរវៃទៅកាន់ផ្ទះបុរសនោះមុន ហើយអង្គុយក្នុងនិវេសន៍របស់នាយហត្ថាចារ្យ ។ ហត្ថាចារ្យមកដល់ថ្វាយបង្គំតាបសនោះ ហើយអង្គុយនាចំណែកម្ខាង ឲ្យនាំភាជនភត្តាហារនោះមកពោលថា លោកទាំងឡាយ ចូរអង្គាសលោកម្ចាស់ដោយសាច់និងបាយ ។ តាបសទទួលតែបាយមិនទទួលសាច់ដែលគេប្រគេនពោលថា អាត្មានឹងចាត់ចែងសាច់នេះ កាលនាយហត្ថាចារ្យពោលថា សូមលោកម្ចាស់ចាត់ចែងចុះ ទើបធ្វើឲ្យជា

ចំណែកៗ បណ្តាសាច់ចំឡុកជាដើមហើយឲ្យសាច់ចំឡុកដល់នាយហត្ថាចារ្យ ឲ្យសាច់ខាងក្រៅដល់កិរិយារបស់ហត្ថាចារ្យនោះ ខ្លួនឯងបរិភោគសាច់ជាប់ឆ្អឹង ។ ក្នុងវេលាស្រេចភត្តកិច្ចតាបសនោះកាលនឹងទៅក៏ពោលថា ក្នុងថ្ងៃទី ៣ អំពីថ្ងៃនេះ អ្នកនឹងបានជាព្រះរាជា ចូរកុំប្រមាទហើយជៀសចេញទៅ ។ ក្នុងថ្ងៃទី ៣ ស្តេចសាមន្តរាជលើកទ័ពមកព័ទ្ធនគរពារាណសី ។ ព្រះបាទពារាណសី ឲ្យនាយហត្ថាចារ្យតែងខ្លួនជាព្រះរាជាហើយត្រាស់ថា ចូរអ្នកជិះដំរីច្បាំង ចំណែកទ្រង់ក្លែងភេទដែលមិនមានអ្នកណាស្គាល់ត្រាច់ទៅក្នុងពួកសេនា ត្រូវបាញ់ដោយព្រួញមួយដ៏មានកម្លាំង ទើបសោយទិវង្គតក្នុងខណៈនោះឯង ។ នាយហត្ថាចារ្យដឹងថា ព្រះរាជាសោយទិវង្គត ទើបឲ្យជញ្ជូនកហាបណៈជាច្រើនឲ្យត្រាច់វាយស្គរប្រកាសថា អ្នកណាត្រូវការទ្រព្យចូរជាអ្នកជួរមុខហើយច្បាំងចុះ ។ ពលនិកាយក៏ផ្តាច់ព្រះជន្មព្រះរាជាដែលជាសត្រូវបានក្នុងកាលមិនយូរឡើយ ។ អាមាត្យទាំងឡាយថ្វាយព្រះភ្លើងព្រះសពរបស់ព្រះរាជាហើយប្រឹក្សាគ្នាថា យើងនឹងតែងតាំងអ្នកណាឲ្យជាព្រះរាជា ទើបសម្រេចថា កាលព្រះរាជានៅមានព្រះជន្មបានព្រះរាជទានភេទរបស់ព្រះអង្គដល់ហត្ថាចារ្យ ហត្ថាចារ្យនេះឯងធ្វើនូវចម្បាំងការពាររាជសម្បត្តិបាន យើងទាំងឡាយនឹងឲ្យរាជសម្បត្តិដល់ហត្ថាចារ្យនេះ ហើយអភិសេកហត្ថាចារ្យនោះក្នុងរាជសម្បត្តិទាំងបានធ្វើកិរិយារបស់ហត្ថាចារ្យនោះឲ្យជាអគ្គមហេសី ។ ព្រះពោធិសត្វបានជារាជកុលុបកៈ ។

ព្រះសាស្តាកាលទ្រង់នាំយករឿងក្នុងអតីតនេះមកហើយ ទ្រង់ត្រាស់ដឹង

ក្រៃលែងហើយបានត្រាស់គាថា ២ ថា

ពួកបុគ្គលឥតបុណ្យ ខ្វល់ខ្វាយប្រមូលទ្រព្យណាដ៏ច្រើន ចំណែកខាងបុគ្គលអ្នកមានបុណ្យទោះមានសិល្បៈក្តី មិនមានសិល្បៈក្តី ក៏រមែងបានបរិភោគនូវទ្រព្យទាំងនោះ ។

ភោគៈទាំងឡាយច្រើនរមែងកន្លងនូវពួកបុគ្គលឥតបុណ្យ កើតឡើងសម្រាប់បុគ្គលអ្នកមានបុណ្យធ្វើហើយក្នុងទីទាំងពួង សូម្បីក្នុងទីមិនមែនជាកន្លែងសម្រាប់កើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំឧស្សុក្កា** សេចក្តីថា បុគ្គលដែលមិនមានបុណ្យដល់នូវការខ្វល់ខ្វាយ គឺកើតឆន្ទៈដើម្បីប្រមូលទ្រព្យណារមែងប្រមូលទ្រព្យទុកជាច្រើនដោយការងារ ។ បាលីថា **យេ ឧស្សុក្កា** ដូច្នេះក៏មាន ។ អធិប្បាយថា បុរសពួកណា ខ្វល់ខ្វាយក្នុងការប្រមូលទ្រព្យមានសិប្បៈដូចជាសិប្បៈដំរីជាដើមឬមិនមានសិប្បៈក្តី ធ្វើនូវការងារដោយហោចដោយការស៊ីឈ្នួលប្រមូលទ្រព្យជាច្រើនទុក ។ បទថា **លភន្តិ តានិ បុញ្ញវេ** សេចក្តីថា បុរសដទៃដែលមានបុណ្យ កាលបរិភោគផលបុណ្យរបស់ខ្លួន សូម្បីមិនធ្វើការងារណាមួយក៏រមែងបានប្រើប្រាស់ទ្រព្យទាំងឡាយដែលហៅថាទ្រព្យច្រើនទាំងនោះ ។ បទថា **អតិច្ចញ្ញេវ ចាណិនោ** បានដល់ កន្លងនូវសត្វទាំងឡាយដទៃ ឯវ អក្ខរៈក្នុងបទថា **អតិច្ចញ្ញេវ** នេះ គប្បីប្រកបចូលជាមួយបទដំបូងមានអត្ថថា កន្លងនូវពួកសត្វដែលមិនបានធ្វើបុណ្យទុករមែងកើតឡើងក្នុងទីទាំងពួងនោះឯងដល់បុគ្គលដែលបានធ្វើបុណ្យទុក ។ បទថា

**អបិ ឆាយតនេសុបិ** សេចក្តីថា ដោយពិតភោគៈទាំងឡាយជាច្រើនទាំងដែលជាទ្រព្យមានវិញ្ញាណនិងទ្រព្យដែលមិនមានវិញ្ញាណ រមែងកើតឡើងក្នុងទីដែលមិនមែនជាអាយតនៈ ( ប្រភពកើត ) គឺរតនៈទាំងឡាយរមែងកើតឡើងក្នុងទីដែលមិនមែនជាប្រភពកើតនៃរតនៈមាសជាដើម រមែងកើតឡើងក្នុងទីដែលមិនមែនជាប្រភពកើតនៃមាសជាដើម ដំរីជាដើម រមែងកើតឡើងក្នុងទីដែលមិនមែនជាប្រភពកើតនៃដំរីជាដើម ។ ពិតហើយក្នុងកាលដែលកែវមុក្តានិងកែវមណីជាដើម កើតឡើងក្នុងទីដែលមិនមែនជាអាយតនៈនោះគប្បីសម្តែងរឿងរបស់ព្រះបាទទុដ្ឋគាមិនីអភ័យមហារាជ ( មានក្នុងអដ្ឋកថាព្រះវិន័យក្បាលទី ១ ) ។

ព្រះសាស្តាកាលទ្រង់ត្រាស់គាថានេះហើយ ទើបត្រាស់បន្តថា ម្នាលគហបតីឈ្មោះថា អាយតនៈ ( ប្រភពកើត ) ដទៃដូចគ្នានឹងបុណ្យរបស់សត្វទាំងនេះរមែងមិនមានព្រោះថា រតនៈទាំងឡាយរមែងកើតឡើងដល់បុគ្គលអ្នកមានបុណ្យសូម្បីក្នុងទីដែលមិនមែនជាប្រភពកើតទាំងឡាយ ហើយទ្រង់សម្តែងព្រះធម្មទេសនានេះ ( ក្នុងខុទ្ទនិកាយខុទ្ទកបាឋ ) ថា

កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងដល់
ទេវតានិងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ
ប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះៗ រមែងបាន
ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពជាអ្នកមានសម្បុរ
ផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី

មានយសបរិវារ ផលទាំងអស់រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតាក្នុងទេវនិកាយទាំងឡាយ ផលទាំងអស់រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាមដោយឧបាយ ដែលត្រូវជាអ្នកស្ទាត់ក្នុងវិជ្ជានិងវិមុត្តិឥដ្ឋផលទាំងអស់បានដោយកំណាប់ទ្រព្យ គឺបុណ្យនោះ ។ បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញាណនិងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ បុញ្ញសម្បទានោះឲ្យសម្រេចប្រយោជន៍ដ៏ធំដោយប្រការដូច្នេះ ព្រោះហេតុនោះអ្នកប្រាជ្ញទាំងឡាយជាធីរជនទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ដូច្នេះ ។

ឥឡូវនេះដើម្បីទ្រង់សម្តែងរតនៈទាំងឡាយ ដែលជាទីប្រតិស្ឋាននៃសិរីរបស់អនាថបិណ្ឌិកសេដ្ឋីទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **កុក្កុដោ** ដូច្នេះ ដូចមានគាថាព័ន្ធថា

មាន់ឈ្មោលក្តី កែវមណីក្តី ឈើប្រត់ក្តី នាងបុញ្ញលក្ខណា
ទេវីជាប្រពន្ធ ( របស់សេដ្ឋី ) ក្តី រមែងកើតឡើងដល់
អនាថបិណ្ឌិកសេដ្ឋី អ្នកមិនមានបាប ជាអ្នកមានបុញ្ញធ្វើហើយ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧណ្ហោ** ក្នុងគាថានោះ លោកសំដៅយក ឈើប្រត់ ។ បទថា **ឋិយោ** បានដល់ នាងបុញ្ញលក្ខណាទេវីដែលជាភរិយា របស់សេដ្ឋី ។ ពាក្យដ៏សេសក្នុងគាថានេះងាយយល់ហើយ ។ ព្រះសាស្តា កាលត្រាស់ព្រះគាថានេះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ តាបសដែលជាកុលុបកៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សិរីជាតក ចប់**

## មណិសូករជាតក

[ ៤៥៤ ] ( ពួកជ្រូកពោលថា ) យើងខ្ញុំប្រមាណ ៣០ នាក់ នៅក្នុងមណិគុហា ៧ ឆ្នាំ យើងខ្ញុំប្រឹក្សាគ្នាថា យើងខ្ញុំកម្ចាត់បង់នូវពន្លឺនៃកែវមណីដូច្នេះ ។

[ ៤៥៥ ] យើងខ្ញុំដដុសកែវមណីដរាបណា កែវមណីរឹងរឹតតែភ្លឺថ្លាឡើង ឥឡូវនេះយើងខ្ញុំសូមសួរនូវហេតុនោះថា លោកយល់នូវកិច្ចដូចម្ដេចក្នុងរឿងនេះ ។

[ ៤៥៦ ] ( ពោធិសត្វពោលថា ) កែវមណីនេះដូចជាកែវពៃទូរ្យ មិនមែនកញ្ចក់ ជាកែវស្អាតឥតមន្ទិល អ្នកណាមួយមិនអាចដើម្បីកម្ចាត់បង់ពន្លឺនៃកែវមណីនុ៎ះឲ្យស្អាប់សម្បុរបាន នែជ្រូកទាំងឡាយ ពួកអ្នកចូរចៀសចេញទៅ ។

**ចប់ មណិសូករជាតកទី ៥ ។**

## អដ្ឋកថា

## មណិសូករជាតក

[ ៤៥៤-៤៥៦ ] ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសមាគមនៃនាងសុន្ទរី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ទរិយា សត្ត វស្សានិ** ដូច្នេះជាដើម ។

សម័យនោះឯងព្រះមានព្រះភាគដែលទេវតានិងមនុស្សធ្វើសក្ការៈគោរព

រាប់អាន បូជា រឿងមានមកហើយក្នុងគម្ពីរខទានឯណោះ សេចក្ដីសង្ខេបមានដូច្នេះថា

បានឮថា កាលលាភសក្ការៈដូចជំនន់ទឹកធំ ៥ ខ្សែកើតឡើងដល់ព្រះមានព្រះភាគនិងភិក្ខុសង្ឃ ពួកតិរ្ថិយសាបសូន្យចាកលាភសក្ការៈ ជាអ្នកអាប់រស្មីដូចអំពិលអំពែកក្នុងវេលាព្រះអាទិត្យរះ ទើបមកប្រជុំប្រឹក្សាគ្នាថា ចាប់តាំងអំពីព្រះសមណគោតមកើតឡើងហើយ ពួកយើងសាបសូន្យចាកលាភសក្ការៈ បុគ្គលណាមួយមិនដឹងភាពដែលពួកយើងមាន ព្រះសមណគោតមដល់នូវភាពជាកំពូលដោយលាភ ពួកយើងរួមដៃជាមួយអ្នកណាល្អហ្ន៎ ដើម្បីញ៉ាំងទោសមិនមែនគុណឲ្យកើតឡើងដល់សមណគោតម ធ្វើលាភសក្ការៈរបស់សមណគោតមនោះឲ្យអន្តរធានទៅ ។ លំដាប់នោះពួកតិរ្ថិយទាំងនោះមានគំនិតថា ពួកយើងរួមដៃជាមួយនាងសុន្ទរីនឹងអាចធ្វើបាន ។ ថ្ងៃមួយពួកតិរ្ថិយទាំងនោះមិនពោលនឹងនាងសុន្ទរីដែលចូលទៅកាន់អារាមរបស់តិរ្ថិយថ្វាយបង្គំហើយឈរ ។ នាងសុន្ទរីនោះពោលរឿយៗ ក៏មិនបានទូវចម្លើយទើបសួរថា បពិត្រលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយត្រូវបុគ្គលណាមួយបៀតបៀនឬ ពួកតិរ្ថិយពោលថា នែប្អូនស្រី នាងមិនឃើញទេឬ ព្រះសមណគោតមត្រាច់បៀតបៀនពួកយើងធ្វើឲ្យវិនាសលាភសក្ការៈ ។ នាងសុន្ទរីនោះពោលយ៉ាងនេះថា ក្នុងរឿងនេះ ខ្ញុំគួរធ្វើដូចម្ដេច តិរ្ថិយទាំងឡាយពោលថា នែប្អូនស្រី នាងមានរូបស្អាតដល់នូវភាពជាអ្នកប្រសើរដោយលម្អ ចូរនាងលើកទោសមិនមែនគុណដល់ព្រះសមណគោតម ឲ្យមហាជន

ជឿពាក្យរបស់នាងហើយធ្វើឲ្យវិនាសលាភសក្ការៈ ។ នាងសុន្ទរីនោះទទួលពាក្យថា សាធុ ទើបថ្វាយបង្គំហើយជៀសចេញទៅ ។ ចាប់តាំងអំពីនោះមកនាងក៏កាន់ផ្កាគ្រឿងក្រអូប គ្រឿងលាប កប្បូរនិងគ្រឿងហឹរជាដើមហើយបែរមុខទៅកាន់វត្តជេតពន ក្នុងពេលល្ងាចក្នុងកាលដែលមហាជនស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយនឹងត្រូវសួរថា នាងទៅណា ក៏ពោលថា ទៅកាន់សម្នាក់របស់ព្រះគោតម ដ្បិតថាខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតម ហើយក៏ទៅក្នុងអារាមរបស់តិរ្ថិយមួយកន្លែង លុះព្រឹកឡើងក៏ឈានចុះកាន់ផ្លូវដែលទៅវត្តជេតពនបែរមុខទៅកាន់ព្រះនគរ កាលត្រូវសួរថា នែនាងសុន្ទរី នាងមកអំពីណា ទើបពោលថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតមឲ្យព្រះសមណគោតមត្រេកអរដោយកិលេសហើយទើបមក ។ លុះកន្លងទៅ ២-៣ ថ្ងៃ ពួកតិរ្ថិយឲ្យកហាបណៈដល់ពួកអ្នកលេង ហើយពោលថា ពួកអ្នកចូរសម្លាប់នាងសុន្ទរីហើយកប់ក្នុងគំនរសំរាម ( គំនរផ្កា ) ក្បែរៗព្រះគន្ធកុដិរបស់ព្រះសមណគោតមហើយចូរមក ។ ពួកអ្នកលេងទាំងនោះបានធ្វើយ៉ាងនេះ ។ លំដាប់នោះ ពួកអន្យតិរ្ថិយនាំគ្នាធ្វើកោលាហលថាយើងទាំងឡាយមិនឃើញនាងសុន្ទរីទើបក្រាបទូលព្រះរាជា ព្រះរាជាត្រាស់សួរថា អ្នកទាំងឡាយមានសេចក្តីរង្កៀសសង្ស័យក្នុងទីណា ទើបក្រាបទូលថា សព្វថ្ងៃនេះនាងសុន្ទរីនៅវត្តជេតពន ទូលព្រះបង្គំទាំងឡាយមិនដឹងការប្រព្រឹត្តទៅរបស់នាងក្នុងវត្តជេតពននោះ ។ ព្រះរាជាទ្រង់អនុញ្ញាតថា បើយ៉ាងនោះពួកអ្នកចូរពិនិត្យ ទើបនាំមនុស្សដែលជាឧបដ្ឋាករបស់ខ្លួនទៅកាន់

វត្ថុជេតពនស្វែងរកឃើញនាងសុន្ទរីក្នុងគំនរសំរាមផ្កា ទើបឲ្យលើកសពនាងសុន្ទរីឡើងដាក់លើគ្រែតូច ហើយចូលទៅកាន់ព្រះនគរក្រាបទូលព្រះរាជាថា ពួកសាវករបស់សមណគោតមគិតថានឹងបិទបាំងកម្មអាក្រក់ដែលព្រះសាស្តារបស់ខ្លួនធ្វើដូច្នេះហើយទើបសម្លាប់នាងសុន្ទរីកប់ក្នុងគំនរសំរាមផ្កា ព្រះរាជាត្រាស់ថា បើដូច្នោះអ្នកទាំងឡាយចូរប្រកាសឲ្យពេញព្រះនគរ ។ តិរ្ថិយទាំងឡាយនោះត្រាច់ប្រកាសតាមផ្លូវពេញព្រះនគរដោយន័យជាដើមថា អ្នកទាំងឡាយចូរមើលកម្មរបស់ពួកសមណសក្យបុត្ត ហើយត្រឡប់មកកាន់ទ្វារព្រះរាជនិវេសន៍វិញ ។ ព្រះរាជាត្រាស់ឲ្យលើកសរីរៈរបស់នាងសុន្ទរីដាក់លើគ្រែតូចក្នុងព្រៃខ្មោចហើយឲ្យរក្សាទុក ។ អ្នកនគរសាវត្ថីវៀរព្រះអរិយសាវកជនដ៏សេសដោយច្រើនពោលពាក្យជាដើមថា អ្នកទាំងឡាយ ចូរមើលការធ្វើរបស់ពួកសមណសក្យបុត្ត ហើយត្រាច់ជេរភិក្ខុទាំងឡាយខាងក្នុងនគរនិងខាងក្រៅនគរ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះតថាគត ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះអ្នកទាំងឡាយចូរចោទតបពួកមនុស្សទាំងនោះយ៉ាងនេះហើយត្រាស់គាថា ( ក្នុងខុទ្ទកនិកាយឧទាន ) ថា

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ ( អំពើអាក្រក់ )
ហើយនិយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅ
កាន់នរក ជនទាំង ២ នាក់ដែលមានអំពើទាបថោក ( ស្មើគ្នា )
នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា ( ដោយ
គតិ ) ក្នុងលោកខាងមុខទៀត ដូច្នេះ ។

ព្រះរាជាទ្រង់បញ្ជូនពួករាជបុរសទៅថា ពួកអ្នកចូរដឹងថា នាងសុន្ទរី ត្រូវអ្នកដទៃសម្លាប់ ។ លំដាប់នោះពួកអ្នកលេងទាំងនោះផឹកស្រាដោយកហាបណៈទាំងនោះ ធ្វើនូវជម្លោះដល់គ្នានឹងគ្នា ។ ក្នុងអ្នកលេងទាំងនោះ អ្នកលេងម្នាក់ពោលយ៉ាងនេះថា ឯងសម្លាប់នាងសុន្ទរីដោយការប្រហារត្រឹមតែម្តងប៉ុណ្ណោះ ហើយកប់ក្នុងគំនរសំរាមផ្កា ទើបផឹកស្រាដោយកហាបណៈដែលបានអំពីការសម្លាប់នាងសុន្ទរីនោះ ។ ពួករាជបុរស ក៏ចាប់អ្នកលេងទាំងនោះបង្ហាញដល់ព្រះរាជា ។ លំដាប់នោះព្រះរាជាទ្រង់ត្រាស់សួរអ្នកលេងទាំងនោះថា ពួកអ្នកសម្លាប់ឬ ពួកអ្នកលេងក្រាបទូលថា ករុណាថ្លៃវិសេស ព្រះរាជាត្រាស់សួរថា អ្នកណាប្រើឲ្យសម្លាប់ អ្នកលេងទាំងនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកតិរ្ថិយប្រើឲ្យសម្លាប់ ។ ព្រះរាជាត្រាស់ឲ្យហៅពួកតិរ្ថិយមក ហើយត្រាស់ថា ពួកអ្នកចូរសែងនាងសុន្ទរីត្រាច់ទៅពេញនគរពោលយ៉ាងនេះថា នាងសុន្ទរី ពួកយើងបំណងនឹងលើកទោសព្រះសមណគោតមទើបឲ្យសម្លាប់ ទោសនៃសាវកទាំងឡាយរបស់ព្រះសមណ-គោតមមិនមានឡើយ ជាទោសរបស់យើងទាំងឡាយ ពួកតិរ្ថិយទាំងនោះបានធ្វើយ៉ាងនោះតាមព្រះរាជបញ្ជា ។ ក្នុងកាលនោះមហាជនល្ងង់ខ្លៅក៏ជឿ ។ ចំណែកពួកតិរ្ថិយត្រូវជាក់ទោសក្នុងបទសម្លាប់មនុស្ស ។ ចាប់តាំងអំពីនោះ ព្រះសម្ពុទ្ធមានលាភសក្ការៈក្រៃលែងឡើង ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ពួកតិរ្ថិយគិតថានឹងញុំាងសេចក្តីសៅហ្មងឲ្យកើតដល់ព្រះពុទ្ធដូច្នេះ ខ្លួនឯងបែរជាសៅហ្មង ម្យ៉ាងទៀត

លាភសក្ការៈធំបែរជាកើតឡើងដល់ព្រះសម្ពុទ្ធ ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នា ដោយរឿងឈ្មោះអ្វី ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿង ឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយមិនអាច ធ្វើសេចក្តីសៅហ្មងឲ្យកើតឡើងដល់ព្រះពុទ្ធ ឈ្មោះថា ការធ្វើសេចក្តីសៅ ហ្មងដល់ព្រះពុទ្ធក៏ដូចគ្នានឹងធ្វើសេចក្តីសៅហ្មងដល់កែវមណីជាតិ ( ដូច្នោះ ដែរ ) ក្នុងកាលមុនជ្រូកទាំងឡាយសូម្បីព្យាយាមដោយបំណងថានឹងធ្វើកែវ មណីជាតិ គឺកែវមណីដោយកំណើតឲ្យសៅហ្មង ក៏មិនអាចធ្វើឲ្យសៅហ្មង បាន កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទាន មកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងស្រុកមួយកន្លែង លុះចម្រើនវ័យ ហើយឃើញទោសក្នុងកាមទាំងឡាយ ក៏ចេញចាកផ្ទះ ឆ្លងភ្នំជួរទី ៣ ក្នុង ហិមវន្តប្បទេស បួសជាតាបសនៅក្នុងបណ្ណសាលា ។ មានគុហាកែវមណី នៅក្នុងទីមិនឆ្ងាយអំពីបណ្ណសាលានោះជ្រូកប្រមាណ ៣០ ក្បាល នៅក្នុង គុហាកែវមណីនោះ ។ មានរាជសីមួយត្រាច់ទៅក្នុងទីមិនឆ្ងាយអំពីគុហានោះ ស្រមោលរបស់រាជសីនោះ រមែងប្រាកដត្រង់កែវមណី ។ ជ្រូកទាំងឡាយ ឃើញរាជសីហ៍ភិតភ័យតក់ក្រមា ទើបមានសាច់និងឈាមតិច ។ ជ្រូកទាំង នោះគិតគ្នាថា ព្រោះកែវមណីនេះថ្លាទើបស្រមោលនេះប្រាកដ ពួកយើងចូរ

ធ្វើកែវមណីនេះឲ្យសៅហ្មងមិនមានពន្លឺ ដូច្នេះហើយទើបទៅកាន់ស្រះមួយកន្លែងក្នុងទីមិនឆ្ងាយ នាំនៀលក្នុងកក់ហើយមកត្រដុសត្រង់កែវមណីនោះ ។ កែវមណីនោះត្រូវរោមជ្រូកទាំងឡាយពាល់ត្រូវ ក៏រឹងរឹតជាឡើងហាក់បីដូចផ្កាយសុក្រាកាសដ៏បរិសុទ្ធ ។ ជ្រូកទាំងឡាយមើលមិនឃើញឧបាយទើបគិតគ្នាថា នឹងសួរឧបាយជាគ្រឿងធ្វើកែវមណីនេះឲ្យប្រាសចាកពណ៌ជាមួយតាបសទើបចូលទៅរកព្រះពោធិសត្វធ្វើគារវៈ ហើយឈរក្នុងចំណែកម្ខាងពោលគាថា ២ ជាបឋមថា

យើងខ្ញុំប្រមាណ ៣០ នាក់នៅក្នុងមណិគុហាអស់ ៧ ឆ្នាំ
យើងខ្ញុំប្រឹក្សាគ្នាថា យើងខ្ញុំកម្ចាត់បង់នូវពន្លឺនៃកែវមណីដូច្នេះ ។
យើងខ្ញុំដដុសកែវមណីដរាបណា កែវមណីរឹងរឹតតែភ្លឺចុះ
ឡើង ឥឡូវនេះយើងខ្ញុំសូមសួរនូវហេតុនោះថា លោកយល់
នូវកិច្ចដូចម្តេចក្នុងរឿងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧរិយា** បានដល់ ក្នុងគុហាកែវមណី ។ បទថា **វសាមសេ** បានដល់ រមែងអាស្រ័យនៅ ។ បទថា **ហាញាម** សេចក្តីថា ពួកខ្ញុំនឹងកម្ចាត់ គឺសូម្បីពួកខ្ញុំក៏មិនធ្វើឲ្យអស់ពណ៌ ។ បទថា **ឥទញ្ចទានិ បុច្ឆាម** សេចក្តីថា ឥឡូវនេះពួកខ្ញុំសូមសួរដល់សេចក្តីនេះថា ព្រោះហេតុអ្វីកែវមណីដែលពួកខ្ញុំធ្វើឲ្យសៅហ្មង ប្រែទៅជាផូរផង់ ។ បទថា **កឹ កិច្ចំ ឥធ មញ្ញសិ** សេចក្តីថា ក្នុងរឿងនេះ លោកម្ចាស់សម្គាល់កិច្ចនេះថាដូចម្តេច ។

លំដាប់នោះព្រះពោធិសត្វកាលប្រាប់ដល់ជ្រូកទាំងនោះ ទើបពោលគាថាទី ៣ ថា

កែវមណីនេះដូចជាកែវពៃទូរ្យ មិនមែនកញ្ចក់ ជាកែវស្អាត ឥតមន្ទិល អ្នកណាមួយមិនអាចដើម្បីកម្ចាត់បង់ពន្លឺនៃកែវមណីនុ៎ះឲ្យស្អាប់សម្បុរបាន នៃជ្រូកទាំងឡាយ ពួកអ្នកចូរចៀសចេញទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អកាចោ** បានដល់ មិនគ្រោតគ្រាត ។ បទថា **សុភោ** បានដល់ ស្អាត ។ បទថា **សិរី** ប្រែថា រស្មី ។ បទថា **អបក្កមថ** សេចក្ដីថា បុគ្គលណាមួយ មិនអាចធ្វើពន្លឺរបស់កែវមណីនេះឲ្យវិនាសទៅបានឡើយ អ្នកទាំងឡាយ ចូរបោះបង់គុហាកែវមណីនេះទៅរស់នៅក្នុងទីដទៃចុះ ។

ជ្រូកទាំងនោះបានស្ដាប់ពាក្យរបស់ព្រះពោធិសត្វក៏ធ្វើយ៉ាងនោះ ។ ព្រះពោធិសត្វធ្វើឈានឲ្យកើតឡើងហើយក្នុងវេលាអស់អាយុមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា តាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មណិសូករជាតក ចប់

## សាលុកជាតក

[ ៤៥៧ ] ( គោឈ្មោះមហាលោហិតពោធិសត្វពោលថា ) អ្នកកុំប្រាថ្នា ( នូវអាហារ ) របស់ជ្រូកឈ្មោះសាលុកៈឡើយ ( ដ្បិតជ្រូកនេះ ) បរិភោគបាយជាគ្រឿងក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយបរិភោគនូវអង្កាមចុះ ការបរិភោគនូវអង្កាមនេះឯងហើយ ជាលក្ខណៈនៃហេតុឲ្យអាយុវែង ។

[ ៤៥៨ ] បុរសអ្នករៀបការនោះជាសេវកៈ ( ប្រកបដោយបរិសទ្យ ) ជាភ្ញៀវមកប្រជុំក្នុងទីនេះ ក្នុងកាលឥឡូវនេះអ្នកនឹងឃើញជ្រូកឈ្មោះសាលុកៈដេកស្ងៀមត្រូវគេសម្លាប់ក្នុងចន្លោះនៃអង្រែមិនខាន ។

[ ៤៥៩ ] ( ព្រះសាស្តាត្រាស់ថា ) គោចាស់ ( ទាំង ២ ) ឃើញជ្រូកដេកស្ងៀមត្រូវគេសម្លាប់ក្នុងចន្លោះនៃអង្រែដែលគេកាច់ ហើយក៏គិតថាអង្កាមជាអាហារដ៏ប្រសើររបស់យើង ។

**ចប់ សាលុកជាតកទី ៦ ។**

## អដ្ឋកថា

## សាលុកជាតក

[ ៤៥៧-៤៥៩ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារិកា ( ក្រមុំចាស់ ) ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មា សាលុកស្ស បិហាយិ** ដូច្នេះជា

ដើម ។

រឿងការលួងលោមរបស់កុមារិកានោះនឹងមានជាក់ច្បាស់ក្នុងចុល្លនារទ-កស្សបជាតកតែក្នុងទីនេះព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថាអ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ពិតមែន ព្រះសាស្ដាត្រាស់សួរថា អ្នកណាធ្វើឲ្យអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ថុល្លកុមារិកា ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ថុល្លកុមារិកាជាអ្នកធ្វើនូវសេចក្ដីវិនាសឲ្យដល់អ្នកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេសូម្បីក្នុងកាលមុនអ្នកក៏បានជាសម្ពន្ធត្ថរិកផ្ករបស់បរិស័ទដែលមកក្នុងថ្ងៃវិវាហៈរបស់ថុល្លកុមា-រិកានេះដូចគ្នា កាលភិក្ខុទាំងឡាយក្រាបទូលអារាធនាហើយទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីព្រះពោធិសត្វកើតជាគោឈ្មោះ មហាលោហិត ចំណែកប្អូនប្រុសរបស់ព្រះពោធិសត្វនោះជាគោឈ្មោះចុល្លលោហិត គោទាំងពីរនោះធ្វើការងារក្នុងត្រកូលមួយក្នុងស្រុក ។ ត្រកូលនោះមានកុមារិកាម្នាក់កំពុងចម្រើនវ័យត្រកូលដទៃបានសូម ( ដណ្ដឹង ) កុមារិកានោះ ។ កាលនោះត្រកូលនោះគិតថា ក្នុងកាលវិវាហៈមង្គលនឹងមានសម្ពន្ធត្ថរិកផ្គ ដូច្នេះហើយទើបប្រតិបត្តិជ្រូកឈ្មោះសាលុកៈដោយបបរនិងភត្ត ឲ្យជ្រូកសាលុកៈនោះដេកក្រោមគ្រែ ។ ថ្ងៃមួយគោចុល្លលោហិតពោលនឹងបងប្រុសថា បពិត្របង ពួកយើងធ្វើការក្នុងត្រកូលនេះ ត្រកូលនេះ អាស្រ័យពួកយើងចិញ្ចឹមជីវិត កាលបើយ៉ាងនោះ

មនុស្សទាំងនេះ ឲ្យតែស្មៅនិងចំបើងដល់ពួកយើង តែឲ្យជ្រូកនេះដោយបបរ និងកត្តនិងឲ្យដេកក្រោមគ្រែ ជ្រូកនេះធ្វើអ្វីដល់មនុស្សទាំងនេះ ។ គោមហាលោហិតពោលថា នែបា ឯងកុំប្រាថ្នាបបរនិងកត្តរបស់ជ្រូកនេះឡើយ ក្នុងថ្ងៃវិវាហមង្គលរបស់កុមារិកានេះ គេបំណងនឹងធ្វើជ្រូកនេះឲ្យជាសម្ភារគ្គិកង្គ ទើបចិញ្ចឹមជ្រូកនេះដោយបបរនិងកត្តដើម្បីធ្វើសាច់ឲ្យឡើងជាដុំៗ ២-៣ ថ្ងៃទៀតអ្នកនឹងឃើញជ្រូកនោះត្រូវគេអូសចេញអំពីក្រោមគ្រែសម្លាប់ហើយពន្លះសាច់ជាដុំតូចដុំធំធ្វើឲ្យជាអាហារសម្រាប់លៀងភ្ញៀវហើយពោលគាថា ២ ថា

អ្នកកុំប្រាថ្នា ( នូវអាហារ ) របស់ជ្រូកឈ្មោះសាលុកៈ
ឡើយ ( ដ្បិតជ្រូកនេះ ) បរិភោគបាយជាគ្រឿងក្តៅក្រហាយ
អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយបរិភោគនូវអង្កាមចុះ
ការបរិភោគនូវអង្កាមនេះឯងហើយ ជាលក្ខណៈនៃហេតុឲ្យ
អាយុវែង ។

បុរសអ្នករៀបការនោះជាសេវកៈ ( ប្រកបដោយបរិសទ្យ )
ជាភ្ញៀវមកប្រជុំក្នុងទីនេះ ក្នុងកាលឥឡូវនេះអ្នកនឹងឃើញជ្រូក
ឈ្មោះសាលុកៈដេកស្ងៀម ត្រូវគេសម្លាប់ក្នុងចន្លោះនៃអង្រែ
មិនខាន ដូច្នេះ ។

ក្នុងគាថានោះមានសេចក្តីសង្ខេបដូចតទៅនេះថា នែបា អ្នកកុំប្រាថ្នាភាវៈដូចសាលុកសូករឡើយព្រោះថា ជ្រូកសាលុកៈនេះបរិភោគអាហារដែលក្តៅក្រហាយ គឺភោជនជាគ្រឿងសម្លាប់ខ្លួនដែលបរិភោគហើយមិនយូរប៉ុន្មាននឹង

ដល់នូវសេចក្តីស្លាប់ តែអ្នកចូរជាបុគ្គលមានសេចក្តីប្រាថ្នាតិចមិនជាប់ជំពាក់ទំពាស៊ីអង្កាមលាយចំបើងនេះដែលខ្លួនបានហើយចុះ នេះជាលក្ខណៈគឺជានិមិត្តឲ្យដឹងដល់ភាពជាអ្នកមានអាយុវែង ឥឡូវនេះ គឺពីរបីថ្ងៃទៀតប៉ុណ្ណោះ រាជបុរសដែលមកក្នុងពិធីវិវាហមង្គលនោះឈ្មោះថា អាមាត្យរាជសេវកៈព្រោះប្រកបដោយរាជបរិវារជាច្រើនដែលជាភ្ញៀវមកក្នុងទីនេះ កាលនោះឯង អ្នកនឹងបានឃើញជ្រូកសាលុកៈនេះត្រូវវាយដោយអង្រែ ព្រោះប្រកបដោយចំណែកខាងលើដូចអង្រែដេកស្លាប់ ។

ក្នុងកាលតមក ២-៣ ថ្ងៃប៉ុណ្ណោះ កាលភ្ញៀវក្នុងពិធីវិវាហមង្គលនាំគ្នាមកហើយម្ចាស់ការទាំងឡាយបានសម្លាប់ជ្រូកសាលុកៈធ្វើជាសម្ភារឧត្តរិកង្គ ។ គោទាំងពីរឃើញនូវវិបត្តិនោះរបស់ជ្រូកសាលុកៈនោះ ទើបប្រឹក្សាគ្នាថា អង្កាមប៉ុណ្ណោះជារបស់ប្រសើរសម្រាប់ពួកយើង ។ ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងហើយទើបទ្រង់ត្រាស់គាថាទី ៣ ដែលកើតអំពីរឿងនោះថា

> គោចាស់ ( ទាំង២ ) ឃើញជ្រូកដេកស្ងៀម ត្រូវគេសម្លាប់
> ក្នុងចន្លោះនៃអង្រែដែលគេកាច់ហើយក៏គិតថា អង្កាមជាអាហារ
> ដ៏ប្រសើររបស់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភុសាមិវ** សេចក្តីថា អង្កាមប៉ុណ្ណោះជាអាហារប្រសើរ គឺឧត្តមរបស់យើង ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល

ហើយទ្រង់ប្រជុំជាតកថា ចុល្លកុមារិកាក្នុងកាលនោះ បានមកជាចុល្លកុមារិកាក្នុងកាលឥឡូវនេះ ជ្រូកសាលុកៈក្នុងកាលនោះបានមកជាភិក្ខុអផ្សុក គោចុល្ល-លោហិតក្នុងកាលនោះ បានមកជាអានន្ទ ចំណែកគោមហាលោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សាលូកជាតក ចប់

# លាភគរហិកជាតក

[ ៤៦០ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) បុគ្គលមិនធ្មត រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិននិយាយញុះញង់ រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិនមែនអ្នករបាំ រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមានសំដីក្រអឺមក្រអៀម រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ នេះជាពាក្យប្រៀនប្រដៅរបស់អ្នក ។

[ ៤៦១ ] ( កូនសិស្សពោលថា ) បពិត្រព្រាហ្មណ៍ ខ្ញុំសូមតិះដៀលនូវការបានយសនិងការបានទ្រព្យព្រោះតែប្រព្រឹត្តចិញ្ចឹមជីវិត ដោយធ្វើខ្លួនឲ្យលិចលង់ ( ដោយកិច្ចមានកិរិយាសម្លាប់គេជាដើម ) ឬដោយការប្រព្រឹត្តនូវទុច្ចរិត ។

[ ៤៦២ ] បុគ្គលសូវធ្វើជាអ្នកបួសកាន់បាត្រ ( ដើរសូមគេ ) ( ព្រោះថា ) ការប្រព្រឹត្តចិញ្ចឹមជីវិតនេះឯងប្រសើរបំផុតជាងកិរិយាស្វែងរកចិញ្ចឹមជីវិតដោយអធម៌ ។

**ចប់ លាភគរហិកជាតកទី ៧ ។**

# អដ្ឋកថា

# លាភគរហិកជាតក

[ ៤៦០-៤៦២ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នានុម្មត្តោ** ដូច្នេះជាដើម ។

បានឮថា សទ្ធិវិហារិករបស់ព្រះថេរៈចូលទៅរកព្រះថេរៈថ្វាយបង្គំហើយ អង្គុយក្នុងចំណែកម្ខាងហើយសួរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់បដិបទាដែលឲ្យលាភកើតដល់ខ្ញុំ ភិក្ខុធ្វើដូចម្តេចទើបបានបច្ច័យមានចីវរជាដើម ។ លំដាប់នោះទើបព្រះថេរៈប្រាប់បដិបទាដែលឲ្យកើតលាភដល់សទ្ធិវិហារិកនោះដូច្នេះថា អាវុសោ លាភសក្ការៈរមែងកើតដល់ភិក្ខុដែលប្រកបដោយអង្គ ៤ គឺ គប្បីលះបង់នូវហិរិឱត្តប្បៈក្នុងខ្លួន លះបង់សមណសញ្ញា មិនឆ្កួតធ្វើខ្លួនឲ្យដូចមនុស្សឆ្កួត ១ គប្បីពោលពាក្យញុះញង់ ១ គប្បីធ្វើដូចជាអ្នករបាំ ១ គប្បីជាបុគ្គលក្រអឺមក្រអៀម ១ ។ សទ្ធិវិហារិកនោះតិះដៀលបដិបទានោះហើយក្រោកឡើងជៀសចេញទៅ ព្រះថេរៈចូលទៅគាល់ព្រះសាស្តាថ្វាយបង្គំហើយ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ភិក្ខុនោះតិះដៀលលាភក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនសូម្បីក្នុងកាលមុនក៏បានតិះដៀលហើយដូចគ្នា កាលព្រះថេរៈក្រាបទូលអារាធនាទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយក្នុងកាលមាន

អាយុ ១៦ ឆ្នាំ ក៏រៀនចប់ត្រៃវេទនឹងសិល្បសាស្ត្រ ១៨ ប្រការ បានជាអាចារ្យទិសាបាមោក្ខបង្រៀនសិប្បៈដល់មាណព ៥០០ ។ ក្នុងចំនួនមាណពទាំងនោះមានមាណពម្នាក់ដល់ព្រមដោយសីលាចារវត្ត ថ្ងៃមួយចូលទៅរកអាចារ្យហើយសួរបដិបទាដែលជាគ្រឿងឲ្យកើតលាភថា លាភកើតឡើងដល់សត្វទាំងនេះបានដូចម្ដេច អាចារ្យពោលថា នែបា លាភកើតឡើងដល់សត្វទាំងនេះដោយហេតុ ៤ ប្រការ ហើយពោលគាថាទី ១ ថា

> បុគ្គលមិនឆ្កួត រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិននិយាយញុះញង់រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិនមែនអ្នករបាំ រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមានសំដីក្រអឺមក្រអៀម រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ នេះជាពាក្យប្រៀនប្រដៅរបស់អ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នានុម្មត្តោ** កាត់បទជា **ន អនុម្មត្តោ** ប្រែថា មិនមែនជាមនុស្សឆ្កួតធ្វើដូចមនុស្សឆ្កួត លោកពោលអធិប្បាយទុកថា ឈ្មោះថា មនុស្សឆ្កួតឃើញស្ត្រីឃើញបុរសហើយដណ្ដើមយកសំពត់និងគ្រឿងប្រដាប់ជាដើមរបស់ជនទាំងនោះ កាន់យកសាច់ត្រីនិងនំជាដើមអំពីទីនោះៗដោយកម្លាំងបាយយកមកទំពាស៊ីយ៉ាងណា បុគ្គលណាជាគ្រហស្ថលះបង់ហិរិឱត្តប្បៈដែលមានសមុដ្ឋានខាងក្នុងនិងខាងក្រៅមិនអើពើ ដើម្បីកុសលនិងអកុសល មិនខ្លាចភ័យក្នុងនរកត្រូវចំណង់គ្របសង្កត់ ត្រូវតណ្ហារឹតរុំចិត្ត

ស្រវឹងក្នុងកាមទាំងឡាយ ធ្វើកម្មដ៏ក្តៅផ្សាមានកាត់ជញ្ជាំងជាដើម បើជាបព្វជិត ក៏លះបង់ហិរិឱត្តប្បៈ មិនអើពើក្នុងកុសលនិងអកុសល មិនខ្លាចភ័យក្នុងនរក ញាំញីសិក្ខាបទដែលព្រះលោកនាថបញ្ញត្តិទុក ត្រូវចំណង់គ្របសង្កត់ តណ្ហារួបរឹតចិត្ត អាស្រ័យត្រឹមតែសំពត់ចីវរជាដើម លះបង់ភាពជាសមណៈរបស់ខ្លួន ជាបុគ្គលប្រមាទស្រវឹងធ្វើនូវវេជ្ជកម្មនិងទូតកម្មជាដើមអាស្រ័យការស្វែងរកមិនប្រសើរ មានការឲ្យឫស្សីជាដើមចិញ្ចឹមជីវិតក៏ដូច្នោះដូចគ្នា បុគ្គលនេះទោះមិនធ្លូត ក៏ឈ្មោះថាធ្លូត ព្រោះដូចមនុស្សធ្លូត លាភរមែងកើតឡើងដល់គ្រហស្ថ ឬបព្វជិតបែបនេះដោយឆាប់រួសរាន់ ចំណែកបុគ្គលណាមិនជាមនុស្សធ្លូតយ៉ាងនោះមានការខ្មាស មានសេចក្តីវៀរវៀស បុគ្គលនេះរមែងមិនបានលាភក្នុងពួកគណៈដែលជាអ្នកវង្វេងមិនមែនបណ្ឌិត ព្រោះហេតុនោះបុគ្គលដែលត្រូវការលាភគប្បីធ្វើដូចមនុស្សធ្លូត ។

បទថា **ឆាបិសុណោ** នេះគប្បីជ្រាបសេចក្តីយ៉ាងនេះថា ចំណែកបុគ្គលណាជាអ្នកញុះញង់នាំនូវការញុះញង់ចូលទៅក្នុងរាជត្រកូលថា បុគ្គលនោះធ្វើកម្មឈ្មោះនេះ បុគ្គលនោះដណ្តើមយសរបស់អ្នកដទៃកាន់យកមកដើម្បីខ្លួនឯង ។ ចំណែកព្រះរាជាទាំងឡាយក៏គិតថា បុគ្គលនេះស្រឡាញ់ក្នុងពួកយើងដូច្នេះហើយទើបតាំងបុគ្គលនោះទុកក្នុងតំណែងខ្ពង់ខ្ពស់ ចំណែកអាមាត្យជាដើមរមែងសម្គាល់វត្ថុដែលគប្បីឲ្យដល់បុគ្គលនោះ ព្រោះខ្លាចថាបុគ្គលនេះធ្វើពួកយើងឲ្យប្រេះឆាក្នុងរាជត្រកូល លាភរមែងកើតដល់អ្នកញុះញង់មួយរំពេចដោយប្រការយ៉ាងនេះ ចំណែកបុគ្គលណាមិនញុះញង់ បុគ្គល

នោះរមែងមិនបានលាភក្នុងពួកជនដែលវង្វេង ។

បទថា **ឆាតជោ** សេចក្តីថា គប្បីជាអ្នកធ្វើលាភឲ្យកើតឡើងដូចអ្នករាំច្រៀង អធិប្បាយថា អ្នករាំច្រៀងទាំងឡាយលះបង់ហិរិឱត្តប្បៈ ធ្វើនូវការរាំច្រៀងនិងប្រគំ សន្សំទ្រព្យយ៉ាងណាបុគ្គលត្រូវការលាភក៏ដូចគ្នាត្រូវលះបង់ហិរិឱត្តប្បៈធ្វើជាសម្លាញ់របស់ស្ត្រី បុរស ក្មេងប្រុស ក្មេងស្រីទាំងឡាយដើរសម្តែងនូវការលេងមានប្រការផ្សេងៗ ចំណែកបុគ្គលណាមិនធ្វើដូចអ្នករបាំយ៉ាងនេះ បុគ្គលនោះរមែងមិនបានលាភក្នុងពួកបុគ្គលវង្វេង ។

បទថា **ឆាកុត្តុហាលោ** សេចក្តីថា បុគ្គលមានវាចាភ្ញាក់ផ្អើលឈ្មោះថា កុត្តុហាលបុគ្គល ។ ពិតហើយព្រះរាជាទាំងឡាយចោមរោមដោយពួកអាមាត្យត្រាស់សួរអាមាត្យទាំងឡាយថា យើងបានឮមកថា ក្នុងទីឈ្មោះនោះមនុស្សត្រូវសម្លាប់ ត្រូវប្លន់ កូនប្រពន្ធរបស់អ្នកដទៃត្រូវរំលោភបំពាន ដូច្នេះនេះជាកម្មរបស់អ្នកណាក្នុងពួកអាមាត្យទាំងនោះ កាលអាមាត្យដ៏សេសមិនពោលពាក្យណាមួយ បុគ្គលណាក្រោកឡើងក្រាបទូលថា បុគ្គលឈ្មោះនោះធ្វើ បុគ្គលនេះឈ្មោះថា កុត្តុហាលបុគ្គល ។ ព្រះរាជាទាំងឡាយក៏បញ្ជូនរាជបុរសទាំងនោះទៅស៊ើបអង្កេតហាមប្រាមតាមពាក្យរបស់អាមាត្យទាំងនោះ រមែងប្រទានយសធំដល់អាមាត្យទាំងនោះដោយទ្រង់ព្រះតម្រិះថា ព្រោះអាស្រ័យបុគ្គលនេះទើបស្រុកទេសរបស់យើងប្រាសចាកចោរ ។ ចំណែកជនដ៏សេសក៏ឲ្យទ្រព្យដល់បុគ្គលនោះដូចគ្នា ព្រោះខ្លាចបុគ្គលនេះកាលត្រូវរាជបុរសសួរក៏ពោលផ្តេសផ្តាស ( ទម្លាក់កំហុសឲ្យខ្លួន ) លាភរមែងកើតដល់បុគ្គល

ភ្ញាក់ផ្អើលដោយប្រការយ៉ាងនេះ ។ ចំណែកបុគ្គលដែលមិនភ្ញាក់ផ្អើលរមែង មិនបានលាភក្នុងពួកជនដែលវង្វេង ។ បទថា **ឯសា តេ អនុសាសនី** សេចក្ដីថា នេះជាឱវាទក្នុងរឿងការបានលាភរបស់អ្នកអំពីសម្នាក់របស់យើង ។

អន្តេវាសិកបានស្ដាប់គាថារបស់អាចារ្យហើយ កាលតិះដៀលលាភទើប ពោលគាថា ២ ថា

បពិត្រព្រាហ្មណ៍ ខ្ញុំសូមតិះដៀលនូវការបានយសនិងការ បានទ្រព្យ ព្រោះតែប្រព្រឹត្តចិញ្ចឹមជីវិតដោយធ្វើខ្លួនឲ្យលិច លង់ ( ដោយកិច្ចមានកិរិយាសម្លាប់គេជាដើម ) ឬដោយការ ប្រព្រឹត្តនូវទុច្ចរិត ។

បុគ្គលសូវធ្វើជាអ្នកបួស កាន់បាត្រ ( ដើរសូមគេ ) ( ព្រោះថា ) ការប្រព្រឹត្តចិញ្ចឹមជីវិតនេះឯងប្រសើរបំផុតជាង កិរិយាស្វែងរកចិញ្ចឹមជីវិតដោយអធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យា វុត្តិ** បានដល់ ការប្រព្រឹត្តចិញ្ចឹមជីវិត ឯណា ។ បទថា **វិនិបាតេន** គឺ ដោយការធ្វើខ្លួនឲ្យវិនាសទៅ ។ បទថា **អធម្មចរិយាយ វា** បានដល់ ដោយការប្រព្រឹត្តមិនប្រកបដោយធម៌ និង ដោយការធ្វើដែលមិនស្មើ អភិប្រាយថា ការប្រព្រឹត្តឯណាដោយធ្វើខ្លួនឲ្យ វិនាសដោយការត្រូវសម្លាប់ ត្រូវចងនិងត្រូវតិះដៀលជាដើម និងដោយ ប្រព្រឹត្តមិនជាធម៌ដូចខ្ញុំតិះដៀល គឺនិន្ទាមើលងាយនូវការប្រព្រឹត្តនោះនិងការ បានយសនិងទ្រព្យទាំងពួង ខ្ញុំមិនត្រូវការ ការប្រព្រឹត្តចិញ្ចឹមជីវិតនោះទេ ។

បទថា **បត្តមាធាយ** បានដល់ កាន់ភាជនៈសម្រាប់ភិក្ខា ។ បទថា **អនាគារោ បរិព្វជេ** សេចក្ដីថា គប្បីជាបព្វជិតមិនមានផ្ទះត្រាច់ទៅនិងជាសប្បុរស មិនប្រព្រឹត្តធម៌ដោយកាយទុច្ចរិតជាដើម ព្រោះហេតុអ្វី ដោយពាក្យថា ការប្រព្រឹត្តចិញ្ចឹមជីវិតនេះឯង ប្រសើរបំផុតជាងកិរិយាស្វែងរកចិញ្ចឹមជីវិតដោយអធម៌នេះ លោកសម្ដែងថា ការដែលបព្វជិតមានបាត្រក្នុងដៃត្រាច់ភិក្ខាចារក្នុងត្រកូលដទៃៗប៉ុណ្ណោះ ប្រសើរជាងការស្វែងរកដោយអធម៌ គឺប្រសើរជាងមួយរយដង មួយពាន់ដង ។

មាណពកាលពណ៌នាគុណរបស់បព្វជ្ជាយ៉ាងនេះហើយ ទើបចេញបួសជាឥសីស្វែងរកភិក្ខាដោយធម៌ ញ៉ាំងសមាបត្តិទាំងឡាយឲ្យកើតឡើង មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា មាណពក្នុងកាលនោះ បានមកជាភិក្ខុតិះដៀលលាភក្នុងកាលឥឡូវនោះ ចំណែកអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា លាភគរហិកជាតក ចប់**

## មច្ឆទានជាតក

[ ៤៦៣ ] ( ពោធិសត្វពោលថា ) ត្រីទាំងឡាយថ្លៃ ១០០០ កហាបណៈ លើសដោយ ( ៧ មាសក ) មិនមានអ្នកណាមួយជឿនូវហេតុនេះ តែថា ( មក ) ដល់អញក្នុងទីនេះនៅតែថ្លៃ ៧ មាសកអញគប្បីទិញនូវពួកត្រីនោះ ។

[ ៤៦៤ ] ( នទីទេវតាពោលថា ) អ្នកបានឲ្យភោជនដល់ពួកត្រី ហើយផ្សាយចំណែកផលដល់ខ្ញុំ ខ្ញុំរឭកនូវទក្ខិណានោះជាសេចក្តីគោរពដែលអ្នកធ្វើហើយ ( ទើបរក្សាទ្រព្យនេះទុកឲ្យអ្នក ) ។

[ ៤៦៥ ] សេចក្តីចម្រើនមិនមានដល់បុគ្គលអ្នកមានចិត្តប្រទូស្តឡើយមួយទៀតបុគ្គលណាធ្វើអំពើអាក្រក់បោកប្រាសទ្រព្យសម្បត្តិដែលជាកេរ្តិ៍មត៌ករបស់បិតានិងបងប្អូនឯង ពួកទេវតាក៏មិនបូជាបុគ្គលនោះឡើយ ។

**ចប់ មច្ឆទានជាតកទី ៨ ។**

## អដ្ឋកថា

## មច្ឆទានជាតក

[ ៤៦៣-៤៦៥ ] ព្រះសាស្តាកាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញកោងម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អគ្ឃន្តិ មច្ឆា** ដូច្នេះជាដើម ។ រឿងនេះបានពោលទុកហើយខាងដើមនោះឯង ។

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលកុដុម្ពិកៈ លុះដឹងក្តីហើយក៏រួបរួមទ្រព្យសម្បត្តិ

ទុក ។ ព្រះពោធិសត្វនោះមានប្អូនប្រុសម្នាក់ ក្នុងកាលតមកកាលបិតារបស់ជនទាំងពីរនោះធ្វើកាលកិរិយាទៅហើយ ថ្ងៃមួយបងប្អូនទាំងពីរនោះគិតគ្នាថា ពួកយើងនឹងជម្រះបំណុលដែលជារបស់បិតាឲ្យស្រេចបាច់ ដូច្នេះហើយទើបទៅកាន់ស្រុកមួយបានទ្រព្យ ១០០០ កហាបណៈហើយត្រឡប់មកបរិភោគបាយសំណុំហើយរង់ចាំទូកត្រង់កំពង់ ។ ព្រះពោធិសត្វបានឲ្យអាហារដែលសេសសល់ដល់ត្រីទាំងឡាយក្នុងស្ទឹងគង្គាហើយឲ្យចំណែកបុណ្យដល់ទេវតាដែលថែរក្សាស្ទឹង ទេវតាលុះអនុមោទនាចំណែកបុណ្យប៉ុណ្ណោះក៏ចម្រើនដោយយសដ៏ជាទិព្វ ពិចារណាដល់ការចម្រើននៃយសរបស់ខ្លួន ក៏បានដឹងដោយហេតុនោះ ចំណែកព្រះពោធិសត្វ លាតសំពត់ដណ្តប់លើផ្ទៃខ្សាច់ដេកលក់ទៅ ។ ចំណែកប្អូនប្រុសរបស់ព្រះពោធិសត្វនោះ មានប្រក្រតី គឺមាននិស្ស័យជាចោរទើបធ្វើកញ្ចប់ក្រួសមួយកញ្ចប់ឲ្យដូចកញ្ចប់កហាបណៈហើយទុកកញ្ចប់ទាំងពីរជាមួយគ្នា ព្រោះបំណងមិនឲ្យកហាបណៈទាំងនោះដល់ព្រះពោធិសត្វកាន់យកតែម្នាក់ឯង ។ កាលបងប្អូនទាំងពីរនោះឡើងទូកទៅដល់កណ្តាលស្ទឹងគង្គាប្អូនប្រុសធ្វើទូកឲ្យឃ្លោងហើយគិតថា អញនឹងបោះកញ្ចប់ក្រួសទៅក្នុងទឹក ដូច្នេះត្រឡប់ជាបោះកញ្ចប់ទ្រព្យ ១០០០ កហាបណៈទៅហើយពោលថា បពិត្របងកញ្ចប់ទ្រព្យ ១០០០ កហាបណៈធ្លាក់ទឹកទៅហើយយើងនឹងធ្វើដូចម្តេច ព្រះពោធិសត្វពោលថា បើកញ្ចប់ទ្រព្យធ្លាក់ទឹកទៅហើយ ពួកយើងនឹងធ្វើអ្វីកើត កុំគិតថ្វីឡើយ ។ ទេវតាប្រចាំស្ទឹងគិតថា អញអនុមោទនាចំណែកបុណ្យដែលបុរសនេះឲ្យ ទើបចម្រើនដោយយសទិព្វ

អញនឹងរក្សាទ្រព្យដែលជារបស់បុរសនេះទុក ដូច្នេះហើយ ទើបបណ្ដាលឲ្យត្រីមាត់ធំមួយលេបកញ្ចប់ទ្រព្យនោះទុកដោយអានុភាពរបស់ខ្លួនហើយធ្វើការរក្សា ។ ចំណែកប្អូនប្រុសដែលមាននិស្ស័យជាចោរនោះ ទៅដល់ផ្ទះហើយគិតថា អញបញ្ឆោតបងប្រុសបានហើយ ទើបស្រាយបង្វិចឃើញតែដុំក្រួសមានហទយៈស្រពាប់ស្រពោនដេកឱបមែគ្រែ ។ ក្នុងកាលនោះពួកអ្នកប្រមង់បានបង់សំណាញ់ដើម្បីចាប់ត្រី ។ ត្រីនោះបានចូលទៅជាប់សំណាញ់ដោយអានុភាពរបស់ទេវតា ។ ពួកអ្នកប្រមង់ចាប់ត្រីនោះបានហើយទើបចូលទៅកាន់នគរដើម្បីលក់ត្រី មនុស្សទាំងឡាយឃើញត្រីធំទើបសួរតម្លៃ អ្នកប្រមង់ពោលថា ចូរឲ្យទ្រព្យ ១០០០ កហាបណៈនិង ៧ មាសកៈហើយកាន់យកចុះ ។ មហាជនធ្វើនូវការសើចចំអកថា ឱត្រីតម្លៃ ១០០០ យើងមិនធ្លាប់ឃើញឡើយ ។ អ្នកប្រមង់កាន់យកត្រីទៅកាន់ទ្វារផ្ទះរបស់ព្រះពោធិសត្វពោលថា លោកចូរកាន់យក ( ទិញ ) ត្រីនេះ ព្រះពោធិសត្វសួរថា ត្រីនេះតម្លៃប៉ុន្មាន អ្នកប្រមង់ពោលថា ចូរឲ្យ ៧ មាសកៈហើយកាន់យកចុះ ព្រះពោធិសត្វសួរថា កាលអ្នកលក់ឲ្យអ្នកដទៃលក់ដូចម្ដេច អ្នកប្រមង់ពោលថា លក់ឲ្យអ្នកដទៃ ១០០០ កហាបណៈនិង ៧ មាសកៈ តែអ្នកចូរឲ្យ ៧ មាសកៈ ហើយកាន់យកចុះ ។ ព្រះពោធិសត្វឲ្យអ្នកប្រមង់ ៧ មាសកៈ ហើយបញ្ជូនត្រីទៅឲ្យដល់ភរិយា ភរិយាវះពោះត្រីឃើញកញ្ចប់ទ្រព្យ ១០០០ កហាបណៈទើបប្រាប់ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វពិនិត្យមើលកញ្ចប់ទ្រព្យនោះឃើញត្រារបស់ខ្លួនក៏ដឹងថាជារបស់ខ្លួន ទើបគិតថា ឥឡូវនេះអ្នក

ប្រមង់ទាំងនេះកាលឲ្យ ( លក់ ) ត្រីនេះដល់អ្នកដទៃ ក៏លក់ ១០០០ កហាបណៈនិង ៧ មាសកៈ តែលុះមកដល់អញមិននិយាយដល់ ១០០០ ឡើយ បានឲ្យកាន់យក ( លក់ ) ត្រឹម ៧ មាសកៈប៉ុណ្ណោះ ព្រោះកហាបណៈ ១០០០ នោះជារបស់អញ អញមិនអាចឲ្យបុគ្គលណាមួយដែលមិនដឹងហេតុនេះជឿបាន ដូច្នេះហើយទើបពោលគាថាទី ១ ថា

> ត្រីទាំងឡាយថ្លៃ ១០០០ កហាបណៈ លើសដោយ ( ៧ មាសក ) មិនមានអ្នកណាមួយ ជឿនូវហេតុនេះ តែថា ( មក ) ដល់អញក្នុងទីនេះ នៅតែថ្លៃ ៧ មាសក អញគប្បីទិញនូវពួកត្រីនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អធិកំ** សេចក្ដីថា អ្នកប្រមង់ត្រូវអ្នកដទៃសួរក៏ពោលថា ត្រីមានតម្លៃ ១០០០ កហាបណៈនិង ៧ មាសកៈ ។ បទថា **ន សោ អត្ថិ យោ ឥមំ សទ្ទហេយ្យ** សេចក្ដីថា មនុស្សដែលមិនដឹងហេតុនេះដោយប្រចក្សនិងជឿពាក្យរបស់អញមិនមាន ឬបុគ្គលដែលជឿពាក្យនេះថា ត្រីមានតម្លៃប្រមាណប៉ុណ្ណោះរមែងមិនមាន ព្រោះហេតុនោះឯងទើបមនុស្សដទៃមិនកាន់យកត្រីទាំងនោះ ។ បទថា **មយ្ហញ្ច អស្សុ** សេចក្ដីថា ម្យ៉ាងទៀតអាត្មាអញក៏មាន ៧ មាសកៈប៉ុណ្ណោះ ។ បទថា **មច្ឆុទ្ទានំ** បានដល់ ចង្កោមត្រីព្រោះថា គេដោតត្រីដទៃៗជាមួយត្រីនោះ លោកសំដៅយកចង្កោមត្រីទាំងនោះទើបពោលថា **មច្ឆុទ្ទានំ** ( ពួកត្រី ) ដូច្នេះ ។ បទថា **កិណេយ្យំ** បានដល់ ខ្ញុំទិញ អធិប្បាយថា ខ្ញុំឲ្យ ៧ មាសកៈ

ប៉ុណ្ណោះកាន់យកត្រីមានប្រមាណប៉ុណ្ណោះបាន ។

ព្រះពោធិសត្វកាលពោលយ៉ាងនេះហើយ ទើបគិតយ៉ាងនេះថា ព្រោះអាស្រ័យអ្វីហ្ន៎ ទើបអញបានកហាបណៈទាំងនេះ ។ ខណៈនោះទេវតាប្រចាំស្ទឹងបង្ហាញខ្លួនឲ្យប្រាកដឈរក្នុងអាកាសពោលថា ខ្ញុំជាទេវតាប្រចាំស្ទឹងគង្គា អ្នកឲ្យអាហារចំណែកលើសដល់ត្រីទាំងឡាយ ហើយឲ្យចំណែកបុណ្យដល់ខ្ញុំដោយហេតុនោះទើបខ្ញុំរក្សាទ្រព្យរបស់អ្នកទុក កាលសម្តែងអត្ថឲ្យជាក់ច្បាស់ទើបពោលថា

អ្នកបានឲ្យភោជនដល់ពួកត្រី ហើយផ្សាយចំណែកផលដល់ខ្ញុំ
ខ្ញុំរឭកនូវទក្ខិណានោះ ជាសេចក្តីគោរព ដែលអ្នកធ្វើហើយ
( ទើបរក្សាទ្រព្យនេះទុកឲ្យអ្នក ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទក្ខិណំ** សេចក្តីថា ការឲ្យចំណែកបុណ្យឈ្មោះថា ទក្ខិណាក្នុងទីនេះ ។ បទថា **កតំ អបចិតឹ តយា** សេចក្តីថា ខ្ញុំរឭកដល់ការគោរពដែលអ្នកធ្វើដល់ខ្ញុំនោះ ទើបរក្សាទ្រព្យរបស់អ្នកទុក ។

ទេវតាប្រចាំស្ទឹងកាលពោលគាថានេះហើយ ទើបប្រាប់ការវៀចវេរដែលប្អូនប្រុសធ្វើទាំងអស់ដល់ព្រះពោធិសត្វនោះ ហើយពោលថា ឥឡូវនេះប្អូនរបស់អ្នកមានហទយៈស្វិតស្រពោនកំពុងដេកឈ្មោះថា សេចក្តីចម្រើនរមែងមិនកើតដល់បុគ្គលដែលមានចិត្តប្រទូស្ត ខ្ញុំគិតថា ទ្រព្យរបស់អ្នកកុំបីវិនាសឡើយ ដូច្នេះហើយទើបនាំទ្រព្យនោះមកឲ្យអ្នក អ្នកកុំឲ្យទ្រព្យនេះដល់ប្អូនប្រុសរបស់អ្នកដែលជាចោរឡើយ ចូរកាន់យកតែម្នាក់ឯងទាំងអស់ចុះហើយ

ពោលគាថាទី ៣ ថា

សេចក្ដីចម្រើនមិនមានដល់បុគ្គលអ្នកមានចិត្តប្រទូស្តឡើយ
មួយទៀត បុគ្គលណាធ្វើអំពើអាក្រក់បោកប្រាស់ទ្រព្យសម្បត្តិ
ដែលជាកេរ្តិ៍មត៌ករបស់បិតា និងបងប្អូនឯង ពួកទេវតាក៏មិន
បូជាបុគ្គលនោះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ជាតិ ហោតិ** សេចក្ដីថា ឈ្មោះថា សេចក្ដីចម្រើនក្នុងលោកនេះ ឬលោកខាងមុខ រមែងមិនមានដល់បុគ្គលបែបនោះ ។ បទថា **ន ចាបិ នំ** សេចក្ដីថា ទេវតាទាំងឡាយ ដែលរក្សាសម្បត្តិរបស់ព្រះពោធិសត្វរមែងមិនបូជាបុគ្គលនោះ ។

លំដាប់នោះទេវតាដែលមិនបំណងឲ្យកហាបណៈដល់ចោរទ្រុស្តមិត្តទើបពោលយ៉ាងនោះ ។ ចំណែកព្រះពោធិសត្វគិតថា អញមិនអាចធ្វើយ៉ាងនោះ ទើបបញ្ជូនទ្រព្យចំនួន ៥០០ ឲ្យដល់ប្អូនប្រុសដែលជាចោរនោះ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ឈ្មួញតាំងនៅក្នុងសោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា ប្អូនប្រុសក្នុងកាលនោះបានមកជាឈ្មួញកោងក្នុងកាលឥឡូវនេះ ចំណែកបងប្រុសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មច្ចុទានជាតក ចប់**

## ឆាឆាជន្ទជាតក

[ ៤៦៦ ] ( ព្រាហ្មណ៍បុរោហិតពោលថា ) បពិត្រមហារាជ យើងខ្ញុំទាំងឡាយមានចំណង់ផ្សេងៗគ្នា នៅក្នុងផ្ទះជាមួយគ្នា ចំណែកខ្ញុំព្រះអង្គចង់បានស្រុកសួយ នាងព្រាហ្មណីជាប្រពន្ធចង់បានគោ ១០០ ។

[ ៤៦៧ ] កូនប្រុស ( របស់ខ្ញុំព្រះអង្គ ) ចង់បានរថទឹមដោយសេះអាជានេយ្យ នាងកញ្ញា ( កូនប្រុសស្រី ) ចង់បានកុណ្ឌលកែវមណី ចំណែកខាងនាងបុណ្ណកាទាសីថោកទាបចង់បានត្បាល់ ( មួយអន្ទើដោយចង្អេរនិងអង្រែ ) ។

[ ៤៦៨ ] ( ព្រះរាជាត្រាស់ថា ) អ្នកទាំងឡាយ ចូរឲ្យស្រុកសួយដល់ព្រាហ្មណ៍ ចូរឲ្យគោ ១០០ ដល់នាងព្រាហ្មណី ចូរឲ្យរថទឹមដោយសេះអាជានេយ្យដល់បុត្ត ( របស់ព្រាហ្មណ៍ ) ចូរឲ្យកុណ្ឌលកែវមណីដល់នាងកញ្ញាមួយទៀត អ្នកទាំងឡាយចូរចាត់ចែងរកត្បាល់ ( ព្រមទាំងចង្អេរនិងអង្រែ ) ឲ្យនាងបុណ្ណកាទាសីថោកទាបនោះផង ។

**ចប់ នានាឆន្ទជាតក ទី ៩ ។**

# អដ្ឋកថា

## ឆាឆាជន្នជាតក

[ ៤៦៦-៤៦៨ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបានពរ ៨ ប្រការរបស់ព្រះអានន្ទត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆាឆាជន្នា មហារាជ** ដូច្នេះជាដើម ។

រឿងនេះមានជាក់ច្បាស់ក្នុងជុណ្ហជាតកឯកាទសកនិបាត ។

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃរបស់អគ្គមហេសីព្រះបាទព្រហ្មទត្តអង្គនោះ លុះចម្រើនវ័យហើយ រៀនសិល្បសាស្ត្រទាំងពួងក្នុងនគរតក្កសិលា កាលព្រះរាជបិតាសោយទិវង្គតក៏បានសោយរាជសម្បត្តិ ។ ព្រះពោធិសត្វមានបុរោហិតរបស់ព្រះរាជបិតាត្រូវដកអំពីតំណែង ។ បុរោហិតនោះក្លាយជាមនុស្សក្រីក្រអាស្រ័យនៅក្នុងផ្ទះមនុស្សជរាម្នាក់ ។ ថ្ងៃមួយព្រះពោធិសត្វក្លែងភេទមិនឲ្យអ្នកណាស្គាល់យាងទៅពិនិត្យព្រះនគរក្នុងពេលរាត្រី ។ ពួកចោរដែលធ្វើចោរកម្មនាំគ្នាផឹកស្រាក្នុងតៀមស្រាមួយកន្លែង យកក្អមដាក់ស្រាទុកមួយក្អមកាន់យកទៅផ្ទះរបស់ខ្លួន ក្នុងរវាងផ្លូវបានឃើញព្រះពោធិសត្វទើបពោលថា នែឯងជានរណាហើយវាយដណ្តើមយកសំពត់ឲ្យព្រះពោធិសត្វលើកក្អមស្រានោះទូលដើរទៅ ចំណែកព្រាហ្មណ៍នោះខណៈនោះចេញទៅឈរក្នុងរវាងផ្លូវពិនិត្យមើលផ្កាយនក្ខត្តឫក្សដឹងថា ព្រះរាជាធ្លាក់ក្នុងកណ្តាប់ដៃរបស់ពួកសត្រូវទើបហៅព្រាហ្មណី ។ ព្រាហ្មណីនោះពោលថា តើអ្នកមានរឿងអ្វី ហើយប្រញាប់មកកាន់សម្នាក់របស់ព្រាហ្មណ៍នោះ ។ លំដាប់នោះព្រាហ្មណ៍ពោល

នឹងព្រាហ្មណីនោះថា នែនាងដ៏ចម្រើន ព្រះរាជារបស់យើងធ្លាក់នៅក្នុងអំណាចរបស់សត្រូវ ព្រាហ្មណីពោលថា ការងារអ្វីរបស់លោក ពួកព្រាហ្មណ៍ដែលមានយសក្នុងរាជសម្នាក់គេនឹងដឹង ។ ព្រះរាជាទ្រង់ស្តាប់សំឡេងរបស់ព្រាហ្មណ៍ បានយាងទៅបន្តិច ទើបត្រាស់នឹងពួកអ្នកលេងថា បពិត្រលោកម្ចាស់ ខ្ញុំជាមនុស្សក្រីក្រលោកយកសំពត់ខ្ញុំទៅហើយ ចូរដោះលែងខ្ញុំចុះ ។ ព្រះរាជាត្រាស់រឿយៗ ពួកអ្នកលេងទាំងនោះ ក៏លែងព្រះរាជាទៅដោយសេចក្តីអាណិត ។ ព្រះរាជាទ្រង់កំណត់ផ្ទះរបស់អ្នកលេងទាំងនោះហើយ ទើបយាងត្រឡប់ ។ លំដាប់នោះបុរោហិតដែលជាព្រាហ្មណ៍ចាស់ក៏ពោលថា នែនាងដ៏ចម្រើន ព្រះរាជារបស់ពួកយើង ផុតអំពីកណ្តាប់ដៃរបស់សត្រូវហើយ ។ ព្រះរាជាបានស្តាប់ពាក្យនោះហើយទ្រង់កំណត់ផ្ទះរបស់បុរោហិតនោះទុក ទ្រង់យាងឡើងកាន់ប្រាសាទ ។ កាលរាត្រីអស់ហើយ ព្រះរាជាត្រាស់ឲ្យហៅព្រាហ្មណ៍ទាំងឡាយមកត្រាស់សួរថា លោកអាចារ្យ ក្នុងពេលយប់លោកទាំងឡាយបានឃើញផ្កាយនក្ខត្តឫក្សខ្លះដែរឬ ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំបានឃើញហើយ ។ ព្រះរាជាត្រាស់សួរថា នក្ខត្តឫក្សល្អដែរឬទេ ព្រាហ្មណ៍ក្រាបទូលថា ល្អព្រះអង្គ ព្រះរាជាត្រាស់សួរថា គ្រោះកាចណាមួយមិនមានទេឬ ព្រាហ្មណ៍ក្រាបទូលថា មិនមានទេព្រះអង្គ ។ ព្រះរាជាត្រាស់ឲ្យហៅបុរោហិតអំពីបុរាណមកដោយត្រាស់ថា អ្នកចូរទៅហៅព្រាហ្មណ៍អំពីស្រុកឈ្មោះនេះមក ហើយត្រាស់សួរថា លោកអាចារ្យក្នុងពេលយប់ លោកឃើញផ្កាយនក្ខត្តឫក្សដែរឬទេ បុរោហិតក្រាប

ទូលថា បពិត្រព្រះសម្មតិទេព ឃើញ ។ ព្រះរាជាត្រាស់សួរថា គ្រោះកាចណាមួយមិនមានទេឬ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ កាលពីរាត្រីទ្រង់ធ្លាក់ក្នុងអំណាចរបស់សត្រូវ តែមួយស្របក់ប៉ុណ្ណោះ ក៏រួចផុតបាន ។ ព្រះរាជាត្រាស់ថា ធម្មតាអ្នកស្គាល់ផ្កាយនក្ខត្តឫក្សត្រូវជាបុគ្គលបែបនេះឯង កាលត្រាស់ហើយឲ្យដកពួកព្រាហ្មណ៍ដ៏សេសក្រៅអំពីនោះចេញហើយត្រាស់ថា នែព្រាហ្មណ៍ ខ្ញុំជ្រះថ្លាក្នុងលោកសូមលោកទទួលយកពរចុះ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំប្រឹក្សាជាមួយបុត្តនិងភរិយាហើយនឹងទទួលយក ។ ព្រះរាជាត្រាស់ថា សូមអ្នកប្រឹក្សាហើយសឹមមក ។ ព្រាហ្មណ៍នោះទៅហើយហៅព្រាហ្មណី កូនប្រុស កូនប្រសារស្រីនិងទាសីមកហើយសួរថា ព្រះរាជាប្រទានពរដល់យើង យើងនឹងទទួលយកអ្វី ព្រាហ្មណីពោលថា សូមលោកនាំគោទឹកដោះមកឲ្យខ្ញុំ ១០០ ។ កូនប្រុសឈ្មោះឆត្តមាណពពោលថា សូមលោកឪពុកនាំរថដែលទឹមដោយសេះសិន្ធព ៤ មានពណ៌ដូចផ្កាកោមុទមកឲ្យខ្ញុំ ។ កូនប្រសារស្រីពោលថា សូមលោកឪពុកនាំយកគ្រឿងប្រដាប់ មានកុណ្ឌលកែវមណីជាដើមមកឲ្យខ្ញុំ ។ ទាសីឈ្មោះបុណ្ណាពោលថា សូមលោកម្ចាស់ យកត្បាល់អង្រែនិងចង្អេរមកឲ្យខ្ញុំ ។ ចំណែកព្រាហ្មណ៍ត្រូវការស្រុកសួយទើបទៅកាន់រាជសម្នាក់ កាលព្រះរាជាត្រាស់សួរថា លោកសួរបុត្តនិងភរិយាហើយឬ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំសួរហើយតែឆន្ទៈមិនដូចគ្នា ហើយពោលគាថា ២ ថា

បពិត្រមហារាជ យើងខ្ញុំទាំងឡាយ មានចំណង់ផ្សេងៗគ្នា នៅក្នុងផ្ទះជាមួយគ្នា ចំណែកខ្ញុំព្រះអង្គចង់បានស្រុកសួយ នាងព្រាហ្មណីជាប្រពន្ធចង់បានគោ ១០០ ។

កូនប្រុស ( របស់ខ្ញុំព្រះអង្គ ) ចង់បានរថទឹមដោយសេះអាជានេយ្យ នាងកញ្ញា ( កូនប្រសាស្រី ) ចង់បានកុណ្ឌលកែវមណី ចំណែកខាងនាងបុណ្ណកាទាសីថោកទាបចង់បានត្បាល់ ( មួយអន្ទើដោយចង្អេរនិងអង្រែ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥច្ឆេ** បានដល់ រមែងប្រាថ្នា ។ បទថា **គវំ សតំ** បានដល់ មេគោទឹកដោះ ១០០ ។ បទថា **កញ្ញា** សំដៅដល់កូនប្រសាស្រី ។ បទថា **យា ចេសា** សេចក្តីថា ទាសីឈ្មោះ បុណ្ណកាក្នុងផ្ទះរបស់ទូលព្រះបង្គំនោះ នាងជាស្រីទន់ទាបគួរករុណាប្រាថ្នា គឺត្រូវការត្បាល់ ចង្អេរនិងអង្រែ ( ប៉ុណ្ណោះ ) ។

ព្រះរាជាត្រាស់ថា ពួកអ្នកចូរឲ្យវត្ថុដែលត្រូវការហើយដល់មនុស្សទាំងនោះ ហើយត្រាស់គាថានេះថា

អ្នកទាំងឡាយ ចូរឲ្យស្រុកសួយដល់ព្រាហ្មណ៍ ចូរឲ្យគោ ១០០ ដល់នាងព្រាហ្មណី ចូរឲ្យរថទឹមដោយសេះអាជានេយ្យ ដល់បុត្ត ( របស់ព្រាហ្មណ៍ ) ចូរឲ្យកុណ្ឌលកែវមណីដល់នាងកញ្ញាមួយទៀត អ្នកទាំងឡាយ ចូរចាត់ចែងរកត្បាល់ ( ព្រមទាំងចង្អេរនិងអង្រែ ) ឲ្យនាងបុណ្ណកាទាសីថោកទាប

នោះផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យញ្ចេតំ** សេចក្ដីថា អ្នកទាំងឡាយចូរញ៉ាំងទាសីដែលមានឈ្មោះថា បុណ្ណកាដែលគួរឲ្យអាណិតនោះឲ្យបាន គឺឲ្យបានទទួលត្បាល់ អង្រែនិងចង្អេរ ។

ព្រះរាជាបានព្រះរាជទានវត្ថុដែលព្រាហ្មណ៍ប្រាថ្នានិងយសធំដទៃ ដោយប្រការដូច្នេះហើយត្រាស់ថា ចាប់តាំងអំពីនេះទៅចូរលោកខ្វល់ខ្វាយក្នុងកិច្ចដែលគប្បីធ្វើដល់ខ្ញុំ ហើយទ្រង់តាំងព្រាហ្មណ៍ទុកក្នុងសម្នាក់របស់ព្រះអង្គ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា នានាឆន្ទជាតក ចប់

# សីលវីមំសជាតក

[ ៤៦៩ ] ( ព្រាហ្មណ៍ពោធិសត្វពោលថា ) ឮថា សីលជាគុណជាត ល្អ សីលជាគុណជាតប្រសើរបំផុតក្នុងលោក អ្នកចូរមើលចុះពស់មានពិស ដ៏ពន្លឹកមិនបៀតបៀន ( ហ្នពស់ ) ដោយយល់ថា អ្នកមានសីល ។

[ ៤៧០ ] បុគ្គលប្រព្រឹត្តស្មើតាមការប្រព្រឹត្តរបស់ព្រះអរិយៈ ទើប បណ្ឌិតហៅថា អ្នកមានសីល ដោយសីលណាយើងនឹងសមាទាននូវសីល នោះ ដែលបណ្ឌិតយល់ព្រមហើយថា សីលនេះជារបស់ក្សេម ( ចាកភ័យ ) ក្នុងលោក ។

[ ៤៧១ ]ម្យ៉ាងទៀតបុគ្គលអ្នកមានសីលជាទីស្រឡាញ់នៃពួកញាតិ ផង រមែងរុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយក៏ទៅកើតក្នុងសុគតិ ភព ។

**ចប់ សីលវីមំសជាតក ទី ១០ ។**

**ចប់ អព្ភន្តរវគ្គទី ៤ ។**

## ឧទ្ទាននៃអត្ថន្នវគ្គនោះគឺ

និយាយអំពីផ្លែឈើអត្ថន្នរៈ ១ ព្រះរាជាព្រះនាមកំសៈ ១ ជ្រូកដ៏ប្រសើរនិងម្រឹគគីឌ្នា ១ កែវមណី ១ ជ្រូកនៅក្នុងគុហាកែវមណី ១ ជ្រូកឈ្មោះសាលុកៈ ១ ការប្រៀនប្រដៅ ១ ត្រីដ៏ប្រសើរ ១ កុណ្ឌលកែវមណី ១ សីល ១ ត្រូវជា ១០ ។

# អដ្ឋកថា
# សីលវីមំសជាតក

[ ៤៦៩-៤៧១ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកសាកល្បងសីលម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើថា **សីលំ កិរេវ កល្យាណំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ននិងអតីតបានឲ្យពិស្តារហើយក្នុងសីលវីមំសជាតកឯកនិបាតខាងដើមនោះឯង តែក្នុងទីនេះមានរឿងថា កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី បុរោហិតអ្នកដល់ព្រមដោយសីលរបស់ព្រះអង្គគិតថានឹងសាកល្បងសីលរបស់ខ្លួន ដូច្នេះហើយ ទើបចាប់យកកហាបណៈម្តងមួយៗអស់កាលពីរថ្ងៃអំពីបន្ទះក្តារសម្រាប់រាប់ប្រាក់ ។ ក្នុងថ្ងៃទីបីពួករាជបុរសចាប់ព្រាហ្មណ៍នោះដោយចោទថាជាចោរ នាំទៅកាន់សម្នាក់របស់ព្រះរាជា ។ ក្នុងរវាងផ្លូវព្រាហ្មណ៍នោះបានឃើញអាលម្ពាយកំពុងលេងជាមួយពស់ លំដាប់នោះព្រះរាជាឃើញត្រាស់សួរព្រាហ្មណ៍នោះថា ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនេះ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រោះទូលបង្គំបំណងនឹងសាកល្បងសីលរបស់ខ្លួនហើយពោលគាថាទាំងនេះថា

ឮថា សីលជាគុណជាតល្អ សីលជាគុណជាតប្រសើរបំផុតក្នុងលោក អ្នកចូរមើលចុះពស់មានពិសដ៏ពន្លឹកមិនបៀតបៀន ( ហ្មពស់ ) ដោយយល់ថាអ្នកមានសីល ។

បុគ្គលប្រព្រឹត្តស្មើតាមការប្រព្រឹត្តរបស់ព្រះអរិយៈ ទើប

បណ្ឌិតហៅថា អ្នកមានសីល ដោយសីលណាយើងនឹង
សមាទានទូវសីលនោះដែលបណ្ឌិតយល់ព្រមហើយថា សីល
នេះជារបស់ក្សេម ( ចាកភ័យ ) ក្នុងលោក ។

ម្យ៉ាងទៀត បុគ្គលអ្នកមានសីលជាទីស្រឡាញ់នៃពួកញាតិ
ផង រមែងរុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយក៏
ទៅកើតក្នុងសុគតិភព ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សីលំ** បានដល់ អាចារៈនិងមារយាទ ។ សព្ទថា **កិរ** ត្រឹមតែជានិបាតចុះក្នុងអត្ថថា បានឮ បានស្ដាប់ ។ បទថា **កល្យាណំ** បានដល់ ស្អាត អធិប្បាយថា បណ្ឌិតទាំងឡាយពោលយ៉ាង នេះថា បានឮថា សីលប៉ុណ្ណោះស្អាត ។ ព្រាហ្មណ៍ពោលដល់ខ្លួនដោយ ពាក្យថា **បស្ស** ( អ្នកចូរមើល ) ។ បទថា **ន ហាញ្ញតិ** សេចក្ដីថា មិនបៀតបៀនអ្នកដទៃដោយខ្លួនឯង ទាំងមិនប្រើឲ្យអ្នកដទៃបៀតបៀនអ្នក ដទៃ ។ បទថា **សមាទិស្សំ** បានដល់ នឹងសមាទាន ។ បទថា **អនុមតំ សិវំ** សេចក្ដីថា បណ្ឌិតទាំងឡាយធានាហើយថាជាដែនក្សេម គឺមិនមាន ភ័យ ។ បទថា **យេន វុច្ចតិ** សេចក្ដីថា ខ្ញុំនឹងសមាទានសីល ដែលជា ហេតុឲ្យគេហៅបុគ្គលអ្នកមានសីល ប្រព្រឹត្តដោយអើពើចំពោះបដិបទារបស់ ព្រះអរិយទាំងឡាយមានព្រះពុទ្ធជាដើមថា អរិយវុត្តិសមាចារ ( អ្នកមាន សមាចារដែលជាគ្រឿងប្រព្រឹត្តដ៏ប្រសើរ ) ។ បទថា **វិរោចតិ** សេចក្ដីថា រមែងរុងរឿងដូចគំនរភ្លើងលើកំពូលភ្នំ ។

ព្រះពោធិសត្វកាលប្រកាសគុណរបស់សីលដោយគាថា ៣ យ៉ាងនេះ ហើយទើបសម្ដែងធម៌ដល់ព្រះរាជាហើយក្រាបទូលថា បពិត្រមហារាជ ក្នុងផ្ទះរបស់ទូលព្រះបង្គំមានទ្រព្យច្រើន ជារបស់មាតាបិតាធ្វើឲ្យកើតដោយខ្លួនឯងផង ជាទ្រព្យដែលទ្រង់ព្រះរាជទានផងទីបំផុតដោយជុំវិញ គឺការសម្រេចមិនប្រាកដ ទូលព្រះបង្គំកាលសាកល្បងសីលទើបចាប់យកកហាបណៈអំពីបន្ទះក្ដារសម្រាប់រាប់ទៅ ឥឡូវនេះ ទូលព្រះបង្គំជ្រាបហើយថាក្នុងលោកនេះ ជាតិ គោត្តត្រកូលនិងប្រទេសជាភាវៈថោកថយ សីលប៉ុណ្ណោះប្រសើរ ទូលព្រះបង្គំនឹងបួសសូមទ្រង់អនុញ្ញាតឲ្យទូលព្រះបង្គំបួសចុះ ហើយទូលសូមឲ្យទ្រង់អនុញ្ញាតការបួស ព្រះរាជាទ្រង់អង្វរហើយអង្វរទៀត ក៏នៅតែចេញចាកផ្ទះចូលទៅកាន់ព្រៃហិមពាន្តបួសជាឥសីញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើត ហើយជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍បុរោហិតអ្នកសាកល្បងសីលក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សីលវីមំសជាតក ចប់**

**អត្តនវគ្គ ចប់**

# កុម្ភវគ្គ

## ភទ្រឃដភេទកជាតក

[ ៤៧២ ] ( ព្រះសាស្តាត្រាស់ថា ) អ្នកលេងបាននូវឆ្នាំងកំណាប់ដែលឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយរក្សាឆ្នាំងនោះដរាបណា អ្នកលេងនោះក៏ដល់នូវសេចក្តីសុខដរាបនោះ ។

[ ៤៧៣ ] ក្នុងកាលណាអ្នកលេងស្រវឹងផង គឃ្លើនផងបានបំបែកឆ្នាំងព្រោះសេចក្តីប្រមាទ ក្នុងកាលនោះ បុគ្គលពាលទៅជាអ្នកអាក្រាតផង ជាអ្នកស្លៀកកំណាត់សំពត់កន្ទបផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។

[ ៤៧៤ ] បុគ្គលឥតប្រាជ្ញា បាននូវទ្រព្យយ៉ាងនេះហើយ ជាអ្នកមានសេចក្តីប្រមាទប្រើប្រាស់ រមែងក្តៅក្រហាយក្នុងកាលខាងក្រោយ ដូចជាអ្នកលេង ( ដែលក្តៅក្រហាយស្តាយក្រោយ ) ព្រោះតែបំបែកឆ្នាំងចោល ។

**ចប់ ភទ្រឃដភេទកជាតកទី ១ ។**

# កុម្ភវគ្គ

## អដ្ឋកថា ភទ្រឃដភេទជាតក

[ ៤៧២-៤៧៤ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វកាមទទំ កុម្ភំ** ដូច្នេះជាដើម ។

បានឮថា ក្មួយរបស់អនាថបិណ្ឌិកសេដ្ឋីនោះបំផ្លាញប្រាក់ ៤០ កោដិ ដែលជារបស់មាតាបិតាឲ្យវិនាសទៅ ដោយការផឹកស្រា ហើយទើបបានទៅកាន់សម្នាក់របស់សេដ្ឋី សេដ្ឋីក៏បានឲ្យទ្រព្យដល់បុរសនោះ ១០០០ ដោយប្រាប់ថា ចូរធ្វើការជួញដូរ ។ បុរសនោះក៏ធ្វើទ្រព្យទាំង ១០០០ ឲ្យវិនាស ហើយក៏មកទៀត ។ សេដ្ឋីក៏ឲ្យទ្រព្យ ៥០០ បុរសនោះធ្វើទ្រព្យ ៥០០ ឲ្យវិនាសហើយត្រឡប់មកសូមទៀត ។ សេដ្ឋីក៏ឲ្យសំពត់សាដកសាច់គ្រោតគ្រាត ២ ផ្ទាំង បុរសនោះក៏ធ្វើសំពត់សាដកទាំង ២ ផ្ទាំងនោះឲ្យវិនាស ហើយមករកទៀត ។ សេដ្ឋីឲ្យអ្នកបម្រើចាប់ត្រង់កអូសចេញទៅ ។ បុរសនោះក្លាយជាមនុស្សអនាថាអាស្រ័យជញ្ជាំងផ្ទះរបស់អ្នកដទៃ ស្លាប់ទៅ ជនទាំងឡាយក៏អូសបុរសនោះទៅចោលខាងក្រៅស្រុក អនាថបិណ្ឌិកសេដ្ឋីទៅកាន់វិហារ ក្រាបទូលការប្រព្រឹត្តរបស់ក្មួយប្រុសនោះទាំងអស់ឲ្យព្រះតថាគតទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ក្នុងកាលមុនតថាគតសូម្បីឲ្យថ្នាំងដែលសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក៏មិនអាចធ្វើបុគ្គលឲ្យឆ្អែតស្កប់ស្កល់បាន អ្នកធ្វើបុគ្គលនោះឲ្យឆ្អែតបានដូចម្តេច កាលអនាថបិណ្ឌិកសេដ្ឋីទូលអារាធនា ហើយទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី កាលបិតាអនិច្ចកម្មទៅ ក៏បានតំណែងសេដ្ឋី ។ ក្នុងផ្ទះរបស់សេដ្ឋីនោះមានទ្រព្យកប់ទុកប្រមាណ ៤០ កោដិ ។ម្យ៉ាងទៀតព្រះពោធិសត្វនោះ មានបុត្តតែមួយប៉ុណ្ណោះ ។ ព្រះពោធិសត្វធ្វើ

បុណ្យមានទានជាដើម ធ្វើកាលកិរិយាហើយ កើតជាសក្កទេវរាជ ។ កាលនោះបុត្តរបស់សេដ្ឋីនោះមិនចាត់ចែងទានវត្តណាមួយតែឲ្យសាងមណ្ឌបដែលមហាជនចោមរោមអង្គុយរាំនិងផឹកសុរា ។ គាត់ឲ្យទ្រព្យម្តងមួយពាន់ៗដល់អ្នករាំនិងអ្នកច្រៀងជាដើម ដល់នូវភាពជាអ្នកលេងស្រី លេងស្រានិងជាអ្នកស៊ីសាច់ជាដើម ជាអ្នកត្រូវការតែមហោស្រពថា អ្នកទាំងឡាយចូរច្រៀង អ្នកទាំងឡាយចូររាំ អ្នកទាំងឡាយចូរប្រគំ ជាអ្នកស្រវឹងហើយត្រាច់ទៅមិនយូរប៉ុន្មានបានបំផ្លាញទ្រព្យ ៤០ កោដិនិងគ្រឿងឧបភោគបរិភោគឲ្យវិនាសក្លាយជាមនុស្សទុគ៌តអនាថាស្លៀកសំពត់កន្ទបត្រាច់ទៅ ។ សក្កទេវរាជទ្រង់ពិចារណាទ្រង់ជ្រាបថា កូនរបស់អញដល់នូវសេចក្តីលំបាក ទើបយាងមកព្រោះសេចក្តីស្រឡាញ់ក្នុងបុត្តបានឲ្យឆ្នាំងដែលសម្រេចតាមសេចក្តីប្រាថ្នាសព្វយ៉ាងទូន្មានថា នែបា ចូរបារក្សាឆ្នាំងនេះកុំឲ្យបែក កាលបើបានៅមានឆ្នាំងនេះឈ្មោះថា ការអស់ទៅនៃទ្រព្យមិនមានឡើយ ចូរបាកុំប្រមាទហើយត្រឡប់ទៅកាន់ទេវលោក ។ ចាប់តាំងអំពីនោះបុរសនោះក៏ត្រាច់ផឹកសុរាថ្ងៃមួយគាត់ស្រវឹងបោះឆ្នាំងនោះទៅក្នុងអាកាសហើយទទួលដោយដៃហើយក៏ភ្លាត់ធ្លាក់ទៅ ឆ្នាំងធ្លាក់លើផែនដីក៏បែកទៅ ។ តាំងអំពីនោះមកបុរសនោះក៏ត្រឡប់ជាមនុស្សទុគ៌តស្លៀកកន្ទប មានដៃកាន់អំបែងដើរសូមបាយអាស្រ័យជញ្ជាំងផ្ទះអ្នកដទៃរហូតដល់ស្លាប់ទៅ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា

អ្នកលេងបាននូវផ្ទាំងកំណាប់ ដែលឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ហើយរក្សាផ្ទាំងនោះដរាបណា អ្នកលេងនោះក៏ដល់នូវសេចក្ដីសុខដរាបនោះ ។

ក្នុងកាលណាអ្នកលេងស្រវឹងផង គឃ្លើនផងបានបំបែកផ្ទាំងព្រោះសេចក្ដីប្រមាទ ក្នុងកាលនោះបុគ្គលពាលទៅជាអ្នកអាក្រាតផង ជាអ្នកស្លៀកកំណាត់សំពត់កន្ទបផង រមែងក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ។

បុគ្គលឥតប្រាជ្ញាបាននូវទ្រព្យយ៉ាងនេះហើយជាអ្នកមានសេចក្ដីប្រមាទប្រើប្រាស់រមែងក្ដៅក្រហាយក្នុងកាលខាងក្រោយ ដូចជាអ្នកលេង ( ដែលក្ដៅក្រហាយស្ដាយក្រោយ ) ព្រោះតែបំបែកផ្ទាំងចោល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វកាមទទំ** បានដល់ ផ្ទាំងដែលអាចឲ្យនូវវត្ថុដែលគួរប្រាថ្នាទាំងពួង ។ បទថា **កុម្ភំ** ជាវេវចនៈរបស់ពាក្យថា **កុម្ភ** នោះឯង ។ បទថា **យាវ** បានដល់ អស់កាលដរាបណា ។ បទថា **អនុបាលេតិ** សេចក្ដីថា បុគ្គលណាមួយបាននូវផ្ទាំងបែបនេះរក្សាទុកដរាបណា បុគ្គលនោះរមែងបាននូវសេចក្ដីសុខដរាបនោះ ។ បទថា **មត្តោ ច ទិត្តោ ច** សេចក្ដីថា ឈ្មោះថា **មត្ត** ព្រោះស្រវឹងស្រា ឈ្មោះថា **ទិត្ត** ព្រោះក្អេងក្អាង ។ បទថា **បមាទា កុម្ភមព្ភិទា** បានដល់ បំបែកនូវផ្ទាំងព្រោះសេចក្ដីប្រមាទ ។ បទថា **នគ្គោ ច ចោឡោ ច** សេចក្ដីថា ជួន

កាលជាមនុស្សអាក្រាត ជួនកាលជាមនុស្សស្លៀកកន្ទប ព្រោះជាមនុស្សស្លៀកសំពត់ចាស់ ។ បទថា **ឯវមេវ** ប្រែថា យ៉ាងនោះឯង ។ បទថា **បមត្តោ** បានដល់ ដោយការប្រមាទ ។ បទថា **តប្បតិ** បានដល់ រមែងសោកស្តាយ ។

ព្រះសាស្តាកាលទ្រង់ត្រាស់ព្រះគាថានេះហើយ ទ្រង់ប្រជុំជាតកថា អ្នកលេងបំបែកឆ្នាំងដែលនាំមកនូវសេចក្តីចម្រើន ក្នុងកាលនោះបានមកជាក្មួយសេដ្ឋីក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ភទ្រឃដភេទកជាតក ចប់

## សុបត្តជាតក

[ ៤៧៥ ] ( ក្អែកពោលថា ) បពិត្រមហារាជ ស្តេចក្អែកឈ្មោះសុបត្តៈនៅអាស្រ័យក្បែរក្រុងពារាណសីមានក្អែក ៨ ម៉ឺនជាបរិវារ ។

[ ៤៧៦ ] នាងសុបស្សាជាកិរិយារបស់ស្តេចក្អែកនោះមានសេចក្តីចាញ់ផ្ទៃចង់បរិភោគនូវក្រយាស្ងោយមានថ្លៃច្រើន ដែលនាយពិសេសចំអិនដើម្បីថ្វាយព្រះរាជា ក្នុងរោងសម្រាប់ចំអិនក្រយាស្ងោយ ។

[ ៤៧៧ ] ឯខ្ញុំព្រះអង្គជារាជទូតរបស់ស្តេចក្អែកទាំងនោះ ត្រូវស្តេចបញ្ជូនមក បានជាមកក្នុងទីនេះ ខ្ញុំព្រះអង្គធ្វើនូវសេចក្តីគោរពចំពោះម្ចាស់ហើយ បានធ្វើឲ្យមានរបួសត្រង់ច្រមុះ ( របស់នាយពិសេស ) ។

**ចប់ សុបត្តជាតកទី ២ ។**

## អដ្ឋកថា

## សុបត្តជាតក

[ ៤៧៥-៤៧៧ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកត្តបាយស្រូវសាលីដែលលាយដោយសប្បិក្នុងរសេត្រីធ្លិនក្រហមដែលព្រះសារីបុត្តត្ថេរប្រគេនដល់ព្រះនាងពិម្ពាទេវី ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ពារាណស្យំ មហារាជ** ដូច្នេះជាដើម ។ រឿងនេះដូចគ្នានឹងរឿងក្នុងអព្ភន្តរជាតកដែលពោលទុកហើយខាងដើមនោះឯង ។

ក្នុងកាលនោះរោគខ្យល់ក្នុងផ្ទៃរបស់ព្រះថេរីកើតឡើង ។ ព្រះរាហុលកទ្

ក៏ប្រាប់ដល់ព្រះថេរៈ ព្រះថេរៈឲ្យព្រះរាហុលកុមារអង្គុយក្នុងរោងឆាន់ហើយទៅកាន់រាជនិវេសន៍របស់ព្រះបាទកោសលនាំយកកត្តនៃបាយ ស្រូវសាលីលាយដោយសប្បិក្នុងរសត្រីឆ្អិនក្រហម ហើយបានឲ្យដល់ព្រះរាហុលកុមារនោះ ។ ព្រះរាហុលកុមារបាននាំទៅប្រគេនព្រះថេរីដែលជាមាតា គ្រាន់តែព្រះថេរីឆាន់ប៉ុណ្ណោះរោគខ្យល់ក្នុងផ្ទៃក៏ស្ងប់រម្ងាប់ ។ ព្រះរាជាទ្រង់បញ្ជូនពួករាជបុរសឲ្យទៅសើបមើល តាំងអំពីនោះមកបានថ្វាយកត្តបែបនោះដល់ព្រះថេរី ( រហូតមក ) ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះធម្មសេនាបតីញុំាំងព្រះថេរីឲ្យឆ្អែតស្កប់ស្កល់ដោយភោជនបែបនេះ ។ ព្រះសាស្ដាទ្រង់យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងឈ្មោះអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តឲ្យវត្ថុដែលរាហុលមាតាប្រាថ្នាតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេសូម្បីក្នុងកាលមុនក៏បានឲ្យហើយដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតក្អែក លុះចម្រើនវ័យហើយបានជាធំជាងក្អែក ៨ មុឺន ជាស្ដេចក្អែកឈ្មោះថា សុបត្តៈ ។ ចំណែកអគ្គមហេសីរបស់ស្ដេចក្អែកសុបត្តៈឈ្មោះថា សុបស្សា ។ សេនាបតីឈ្មោះ សុមុខៈ ។ ស្ដេចក្អែកសុបត្តៈនោះចោមរោមដោយក្អែក ៨ មុឺន អាស្រ័យនៅក្នុងនគរពារាណសី ។

ថ្ងៃមួយស្តេចក្អែកសុបត្តៈនាំនាងសុបស្សាទៅរកអាហារ ហើរលើរោងចុងភៅរបស់ព្រះបាទពារាណសី ចុងភៅចម្អិនភោជនដែលមានត្រីនិងសាច់ផ្សេងៗ ជាគ្រឿងប្រកបបើកកាជនៈបន្តិចឲ្យកម្តៅចេញទៅ ។ នាងសុបស្សាបានទូវក្លិនត្រីនិងសាច់មានបំណងចង់បរិភោគភោជនរបស់ព្រះរាជា មួយថ្ងៃនោះមិននិយាយអ្វីឡើយ ក្នុងថ្ងៃទីពីរកាលស្តេចក្អែកសុបត្តៈពោលថា នែនាងដ៏ចម្រើនមកពួកយើងនឹងទៅរកស៊ី ទើបពោលថា សូមអ្នកទៅចុះ ខ្ញុំមានការចាញ់គភ៌ម្យ៉ាង កាលស្តេចក្អែកសុបត្តៈពោលថា នាងចាញ់គភ៌ដូចម្តេច ទើបពោលថា ខ្ញុំចង់បរិភោគភោជនរបស់ព្រះបាទពារាណសីតែមិនអាចបានភោជននោះ បពិត្រអ្នកដ៏ប្រសើរ ព្រោះហេតុនោះខ្ញុំនឹងអស់ជីវិត ។ ព្រះពោធិសត្វកំពុងអង្គុយគិតគាប់ជួនសុមុខសេនាបតីមកសួរថា បពិត្រមហារាជ ទ្រង់មិនសប្បាយចិត្តព្រោះហេតុអ្វី ព្រះពោធិសត្វក៏ប្រាប់សេចក្តីនោះ ។ សេនាបតីក៏ទូលឲ្យព្រះរាជានិងអគ្គមហេសីនោះធូរស្រាលចិត្តថា បពិត្រមហារាជ សូមទ្រង់កុំក្តៅក្រហាយចិត្តឡើយហើយទូលបន្តទៀតថា ថ្ងៃនេះសូមទ្រង់ទាំងពីរនៅក្នុងទីនេះឯង ខ្ញុំនឹងទៅនាំកត្តនោះមកហើយជៀសចេញទៅ ។ សេនាបតីនោះឲ្យពួកក្អែកប្រជុំគ្នាហើយប្រាប់ហេតុនោះឲ្យដឹងហើយពោលថា មកចុះអ្នកទាំងឡាយ ពួកយើងនឹងទៅនាំកត្តមកទើបហើរចូលទៅកាន់នគរពារាណសីមួយអន្លើដោយក្អែកទាំងឡាយ បែងចែកក្អែកជាពួកៗទុកក្នុងទីមិនឆ្ងាយអំពីរោងចុងភៅដើម្បីត្រូវការរក្សាក្នុងទីនោះៗ ចំណែកខ្លួនឯងទំត្រង់ដំបូលរោងចុងភៅមួយអន្លើដោយក្អែកអ្នកចម្បាំង ៨ កាលកំពុងរង់ចាំពេលវេលាដែលចុង

ភៅនាំព្រះក្រយាហារទៅថ្វាយព្រះរាជាក្អែក សេនាបតីបានពោលនឹងក្អែកទាំងនោះថា កាលចុងភៅនាំព្រះក្រយាហាររបស់ព្រះរាជាទៅ ខ្ញុំនឹងធ្វើភាជនៈឲ្យធ្លាក់ចុះ កាលភាជនៈធ្លាក់ចុះហើយជីវិតរបស់ខ្ញុំក៏មិនមានអ្នកទាំងឡាយ ៤ ចូរពាំកត្តឲ្យពេញមាត់ ៤ ទៀតចូរពាំត្រីនិងសាច់ហើយនាំទៅថ្វាយស្តេចក្អែកមួយអន្លើដោយមហេសីបរិភោគ កាលព្រះរាជាសួរថា សេនាបតីទៅណា ពួកអ្នកគប្បីប្រាប់ថា ខ្ញុំនឹងមកខាងក្រោយដូច្នេះ ។ លំដាប់នោះចុងភៅរៀបចំភោជនរបស់ព្រះរាជាស្រេចហើយទើបរែកភាជនៈទៅដោយអម្រែកចូលទៅកាន់រាជត្រកូល ។ ក្នុងវេលាដែលចុងភៅទៅដល់លានព្រះរាជវាំង ក្អែកសេនាបតីក៏ឲ្យសញ្ញាដល់ក្អែកទាំងឡាយ ហើយខ្លួនឯងបោះពួយទំគ្រង់ទ្រូងរបស់អ្នករែកកត្ត ខ្ទាំដោយក្រចកយកចំពុះដែលដូចគ្នានឹងចុងលំពែងចឹកចុងច្រមុះរបស់អ្នករែកកត្តនោះ ហើរឡើងយកស្លាបទាំងពីរបិទមាត់របស់បុរសនោះ ។ ព្រះរាជាទ្រង់យាងលើប្រាសាទទតតាមបង្អួចឃើញកិរិយារបស់ក្អែកនោះទើបទ្រង់ត្រាស់ដល់អ្នករែកកត្តថា នែកត្តការកៈដ៏ចម្រើន ចូរអ្នកចោលភាជនៈទាំងឡាយចាប់ក្អែកប៉ុណ្ណោះ ។ អ្នករែកកត្តក៏ទម្លាក់ភាជនៈទាំងឡាយហើយចាប់ក្អែកទុកយ៉ាងណែន ។ ព្រះរាជាត្រាស់ថា ចូរមកផ្លូវនេះ ។ ខណៈនោះក្អែកទាំងនោះមកស៊ីកត្តរហូតគ្រប់គ្រាន់ដល់ខ្លួនហើយបានពាំយកចំណែកដ៏សេសទៅដោយទំនងដែលពោលហើយនោះឯង ។ លំដាប់នោះពួកក្អែកដ៏សេសក៏នាំគ្នាមកស៊ីចំណែកដែលសេសសល់ ។ ចំណែកក្អែកទាំង ៨ នោះហើរទៅឲ្យស្តេចក្អែកមួយអន្លើដោយបជាបតីបរិភោគកត្តនោះ ។ ការបាញ់

គភ៌របស់នាងសុបស្សាក៏ស្ងប់រម្ងាប់ទៅ ។ អ្នករែកភត្តនាំក្អែកចូលទៅថ្វាយព្រះរាជា ។ លំដាប់នោះព្រះរាជាបានត្រាស់សួរក្អែកនោះថា នែក្អែកដ៏ចម្រើន អ្នកមិនខ្មាសយើងថែមទាំងចឹកប្រមុះរបស់ភត្តាហារកៈឲ្យដាច់ទៀតផង ធ្វើភាជនភត្តឲ្យបែកផង មិនរក្សាជីវិតខ្លួនឯងផង ព្រោះហេតុអ្វីទើបអ្នកធ្វើកម្មបែបនេះ ។ ក្អែកក្រាបទូលថា បពិត្រមហារាជ ព្រះរាជារបស់ទូលព្រះបង្គំអាស្រ័យនគរពារាណសី ទូលព្រះបង្គំជាសេនាបតីរបស់ព្រះរាជានោះ អគ្គ-មហេសីឈ្មោះថា សុបស្សារបស់ព្រះរាជានោះចាញ់គភ៌ បំណងនឹងបរិភោគភោជនរបស់ព្រះអង្គ ទើបព្រះរាជាប្រាប់ការចាញ់គភ៌របស់អគ្គមហេសីនោះដល់ទូលព្រះបង្គំ ទើបទូលព្រះបង្គំលះបង់ជីវិតដើម្បីព្រះរាជានោះហើយមកឥឡូវនេះ ទូលព្រះបង្គំបានបញ្ជូនភោជនទៅឲ្យដល់អគ្គមហេសីរបស់ស្តេចក្អែកនោះ មនោរថរបស់ទូលព្រះបង្គំដល់ទីបំផុតហើយ ដោយហេតុនេះទើបទូលព្រះបង្គំធ្វើកម្មមានសភាពបែបនេះ កាលសម្តែងអត្ថនោះឲ្យជាក់ច្បាស់ ទើបពោលគាថាទាំងនេះថា

បពិត្រមហារាជ ស្តេចក្អែកឈ្មោះសុបត្តៈនៅអាស្រ័យក្បែរ
ក្រុងពារាណសីមានក្អែក ៨ ម៉ឺនជាបរិវារ ។

នាងសុបស្សាជាភរិយារបស់ស្តេចក្អែកនោះមានសេចក្តី
ចាញ់ផ្ទៃ ចង់បរិភោគនូវក្រយាស្ងោយមានថ្លៃច្រើនដែលនាយ
ពិសេសចំអិនដើម្បីថ្វាយព្រះរាជាក្នុងរោងសម្រាប់ចំអិនក្រយា
ស្ងោយ ។

ឯខ្ញុំព្រះអង្គជារាជទូតរបស់ស្តេចក្អែកទាំងនោះ ត្រូវស្តេចបញ្ជូនមកបានជាមកក្នុងទីនេះ ខ្ញុំព្រះអង្គធ្វើនូវសេចក្តីគោរពចំពោះម្ចាស់ ហើយបានធ្វើឲ្យមានរបួសត្រង់ច្រមុះ ( របស់នាយពិសេស ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពារាណស្យំ** បានដល់ ក្នុងនគរពារាណសី ។ បទថា **និវាសកោ** បានដល់ ជាអ្នកនៅប្រចាំ ។ បទថា **បក្កំ** បានដល់ ចាត់ចែងហើយដោយប្រការផ្សេងៗ ។ អាចារ្យពួកខ្លះស្វាធ្យាយថា **សិទ្ធំ** ប្រែថា សម្រេចហើយដូច្នេះក៏មាន ។ បទថា **បច្ចគ្ឃំ** បានដល់ដែលក្តៅក្រៃលែងមិនបានគ្របទុក ។ ម្យ៉ាងទៀតឈ្មោះថា **បច្ចគ្ឃ** ព្រោះប្រភេទរបស់ត្រីនិងសាច់ទាំងឡាយ ត្រីនិងសាច់ដែលគេឲ្យឆ្អិនតែម្យ៉ាងមានតម្លៃច្រើនដូច្នេះក៏មាន ។ បទថា **តេសាហំ បហិតោ ទូតោ រញ្ញោ ចម្ហិ ឥធាគតោ** សេចក្តីថា ទូលព្រះបង្គំជាទូត គឺជាអ្នកធ្វើតាមពាក្យប្រដៅរបស់ស្តេចក្អែកទាំងពីរនោះទាំងស្តេចក្អែកក៏បញ្ជូនមក ព្រោះហេតុនោះទើបមកក្នុងទីនេះ ។ បទថា **ភត្តុ អបចិតឹ កុម្មិ** សេចក្តីថា ទូលព្រះបង្គំនោះបានមកយ៉ាងនេះហើយរមែងធ្វើនូវការគោរព គឺធ្វើសក្ការៈនិងការរាប់អានដល់ម្ចាស់របស់ខ្លួន ។ បទថា **ឆាសាយមការំ វណំ** សេចក្តីថា បពិត្រមហារាជព្រោះហេតុនេះទើបទូលព្រះបង្គំ មិនកោតក្រែងចំពោះព្រះអង្គនិងមិនស្តាយជីវិតរបស់ខ្លួន បានយកចំពុះចឹកច្រមុះអ្នកកែកភត្តឲ្យរបួសដើម្បីឲ្យភាជនភត្តាហារធ្លាក់ចុះទៅ ទូលព្រះបង្គំបានធ្វើនូវការស្រឡាញ់ចំពោះព្រះរាជា របស់ទូល-

ព្រះបង្គំហើយ ឥឡូវនេះសូមទ្រង់ដាក់អាជ្ញាដល់ទូលព្រះបង្គំតាមព្រះបំណង ចុះ ។

ព្រះរាជាបានស្តាប់ពាក្យរបស់ក្អែកនោះហើយទ្រង់ព្រះតម្រិះថា ពួកយើងជាមនុស្សឲ្យយសធំដល់មនុស្ស ក៏មិនអាចធ្វើសេចក្តីសប្បាយដល់យើងបាន ទោះបីឲ្យស្រុកជាដើម ក៏នៅមិនបានបុគ្គលដែលលះបង់ជីវិតឲ្យដល់យើង សត្វនេះជាក្អែកគង់លះជីវិតដល់ព្រះរាជារបស់ខ្លួនបាន រាប់ថាជាសប្បុរសដ៏កំពូលមានសំឡេងពីរោះជាធម្មកថិក ដូច្នេះហើយ ទើបទ្រង់ជ្រះថ្លាក្នុងគុណទាំងឡាយរបស់ក្អែកនោះ ទ្រង់បូជាក្អែកនោះដោយស្វេតច្ឆត្រ ។ ក្អែកនោះក៏បូជាព្រះរាជានោះឯងដោយស្វេតច្ឆត្ររបស់ខ្លួនដែលបាន ហើយពោលគុណទាំងឡាយរបស់ព្រះពោធិសត្វ ។ ព្រះរាជាត្រាស់ឲ្យហៅព្រះពោធិសត្វនោះមកហើយទ្រង់ស្តាប់ធម៌ ទ្រង់បានតាំងភត្តាហារតាមទំនងគ្រឿងសោយរបស់ព្រះអង្គដើម្បីស្តេចក្អែកនិងបជាបតីទាំងពីរនោះ ទ្រង់ឲ្យដាំបាយអំពីអង្ករមួយអម្ពណៈ ( ស្នូកស្វាយ ) រាល់ៗ ថ្ងៃដើម្បីក្អែកដ៏សេស ក្រៅអំពីនេះទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ប្រទានអភ័យដល់សត្វទាំងពួង ទ្រង់រក្សាសីល ៥ ជានិច្ច ម្យ៉ាងទៀតឱវាទរបស់ស្តេចក្អែកឈ្មោះ សុបត្តៈ ប្រព្រឹត្តទៅអស់ ៧០០ ឆ្នាំ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាព្រះអានន្ទក្នុងកាលឥឡូវនេះ ក្អែកសេនាបតីក្នុងកាលនោះបានមកជាសារីបុត្ត ក្អែកសុបស្សាក្នុងកាល

នោះបានមកជារាហុលមាតា ចំណែកក្អែកសុបត្តៈក្នុងកាលនោះ គឺតថាគត នេះឯង ។

## អដ្ឋកថា សុបត្តជាតក ចប់

## កាយនិព្វិន្ទជាតក

[ ៤៧៨ ] ( តាបសពោធិសត្វពោលថា ) កាលអញត្រូវព្យាធិរោគណាមួយប៉ះពាល់ហើយដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំងក្លា ដែលរោគកំពុងបៀតបៀនរាងកាយនេះដ៏នឹងរីងស្ងួតយ៉ាងឆាប់ដូចជាផ្កាឈើដែលគេដោតលើអាចម៍ដីដ៏ក្តៅ ( ក៏ស្ងួតដូច្នោះ ) ។

[ ៤៧៩ ] ( រាងកាយនេះ ) មិនជាទីគាប់ចិត្តតែជនពាលពោលថាជាទីគាប់ចិត្ត មិនស្អាតទេ តែជនពាលសន្មតថាជារបស់ស្អាត រាងកាយដ៏ពេញប្រៀបដោយសាកសពផ្សេងៗមានសភាពជាទីគាប់ចិត្តនៃជនពាល ។

[ ៤៨០ ] យើងគួរតិះដៀលនូវកាយស្អុយនេះ ជារបស់ឈឺជានិច្ចគួរខ្ពើមរអើម មិនស្អាត មានព្យាធិជាធម្មតាដែលពួកសត្វប្រមាទជ្រប់ជាប់ញ៉ាំងផ្លូវនៃសុគតិកពឲ្យវិនាសសាបសូន្យ ។

**ចប់ កាយនិព្វិន្ទជាតក ទី ៣ ។**

## អដ្ឋកថា
## កាយនិព្វិន្ទជាតក

[ ៤៧៨-៤៨០ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុរសម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ផុដ្ឋស្ស មេ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានបុរសម្នាក់ជាអ្នកក្តៅក្រហាយដោយរោគ

ស្គមលឿន គ្រូពេទ្យមិនអាចព្យាបាល ។ បុត្តនិងភរិយារបស់គាត់ ក៏គិតថា អ្នកណាហ្ន៎ អាចបដិបត្តិបុរសនេះបាន ។ បុរសនោះមានការគិតដូច្នេះថា បើអញសះជាអំពីរោគនេះអញនឹងបួស ។ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ប៉ុណ្ណោះបុរសនោះក៏ជូរស្បើយបន្តិចបន្តួចរហូតជាបុគ្គលមិនមានរោគ ទើបទៅកាន់វត្តជេតពនទូលសូមបួសជាមួយព្រះសាស្តា ។ កុលបុត្តនោះបានបព្វជ្ជានិងឧបសម្បទាក្នុងសម្នាក់របស់ព្រះសាស្តាហើយមិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បុរសអ្នកមានរោគស្គមលឿនឈ្មោះនោះគិតថា បើអញសះជាអំពីរោគនេះអញនឹងបួស ដូច្នេះកាលសះជារោគហើយក៏បួសសម្រេចអរហត្ត ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែបុរសនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនបណ្ឌិតទាំងឡាយក៏ពោលយ៉ាងនេះ កាលសះជារោគស្គមលឿនហើយក៏បួសបានធ្វើនូវសេចក្តីចម្រើនដល់ខ្លួនដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយ បានរួបរួមទ្រព្យសម្បត្តិ ព្រះពោធិសត្វនោះក៏កើតរោគស្គមលឿន ។ គ្រូពេទ្យមិនអាច

ព្យាបាលបាន ។ បុត្តកិរិយាបានទទួលនូវការក្តៅក្រហាយ ។ ព្រះពោធិសត្វគិតថា អញជាសះស្បើយរោគនេះហើយនឹងបួស ដូច្នេះហើយបានជាអ្នកជាសះស្បើយរហូតជាអ្នកមិនមានរោគ ទើបចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសីធ្វើសមាបត្តិនិងអភិញ្ញាឲ្យកើតឡើង នៅដោយសេចក្តីសុខក្នុងឈានគិតថា អញមិនបានសេចក្តីសុខបែបនេះអស់កាលមានប្រមាណប៉ុណ្ណោះ ដូច្នេះហើយកាលបន្លឺឧទានទើបពោលគាថាទាំងនេះថា

កាលអញត្រូវព្យាធិរោគណាមួយប៉ះពាល់ហើយ ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំងក្លា ដែលរោគកំពុងបៀតបៀនរាងកាយនេះដ៏នឹងរីងស្ងួតយ៉ាងឆាប់ដូចជាផ្កាឈើដែលគេដោតលើអាចម៍ដីដ៏ក្តៅ ( ក៏ស្ងួតដូច្នោះ ) ។

( រាងកាយនេះ ) មិនជាទីគាប់ចិត្តតែជនពាលពោលថាជាទីគាប់ចិត្ត មិនស្អាតទេតែជនពាលសន្មតថាជារបស់ស្អាតរាងកាយដ៏ពេញប្រៀបដោយសាកសពផ្សេងៗមានសភាពជាទីគាប់ចិត្តនៃជនពាល ។

យើងគួរតិះដៀលនូវកាយស្អុយនេះ ជារបស់ឈឺជានិច្ចគួរខ្ពើមរអើម មិនស្អាត មានព្យាធិជាធម្មតាដែលពួកសត្វប្រមាទជ្រប់ជាប់ ញុំាំងផ្លូវនៃសុគតិភពឲ្យវិនាសសាបសូន្យដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អញ្ញតរេន** បានដល់ ព្យាធិ គឺរោគស្គម

លឿងឯណាមួយក្នុងបណ្ដាភោគ ៩៨ ប្រភេទ ។ បទថា **រោគេឆ** បាន ដល់ ដែលបានឈ្មោះថារោគយ៉ាងនេះព្រោះមានការចាក់ដោតជាសភាវៈ ។ បទថា **រុប្បតោ** បានដល់ បៀតបៀន គឺគ្របសង្កត់ ។ បទថា **បំសុនិ អាតបេ កតំ** សេចក្ដីថា រមែងរីងស្ងួតទៅ ដូចផ្កាដែលខ្ចីដែលបុគ្គលទុក ក្នុងទីក្ដៅ គឺត្រង់ដីខ្សាច់ដ៏ក្ដៅដូច្នោះ ។ បទថា **អជញ្ញំ ជញ្ញសង្ខាតំ** បាន ដល់ ជារបស់បដិកូលមិនគួរពេញចិត្តតែដល់នូវការរាប់ថាជាទីពេញចិត្តរបស់ បុគ្គលពាល ។ បទថា **ឆាឆាកុណបបរិបូរំ** បានដល់ បរិបូណ៌ដោយ សាកសព ៣២ ប្រការមានសក់ជាដើម ។ បទថា **ជញ្ញរូបំ អបស្សតោ** សេចក្ដីថា រមែងប្រាកដជាទីពេញចិត្ត គឺជារបស់ល្អមានសភាវៈជាគ្រឿង បរិភោគប្រើប្រាស់សម្រាប់បុគ្គលដែលជាអន្ធពាលបុថុជ្ជន ដែលជាអ្នកមិន ឃើញ គឺភាវៈដែលមិនស្អាតដែលលោកប្រកាសដោយន័យជាដើមថា ពពឹក ភ្នែកចេញអំពីភ្នែកជាដើមដូច្នេះ ។ រមែងមិនប្រាកដដល់បុគ្គលពាលទាំង ឡាយ ។ បទថា **អាតុរំ** គឺ ឈឺថ្កាត់ជានិច្ច ។ បទថា **អធិមុច្ឆិតា** បានដល់ ងប់ជ្រប់យ៉ាងក្រៃលែងដោយការវង្វេងព្រោះកិលេស ។ បទថា **បជា** បានដល់ បុថុជ្ជនល្ងង់ខ្លៅ ។ បទថា **ហាបេន្តិ មគ្គំ សុគតូប បត្តិយា** សេចក្ដីថា ពួកសត្វទាំងឡាយជាអ្នកជាប់ជំពាក់ក្នុងកាយស្អុយនេះ ធ្វើផ្លូវអបាយឲ្យពេញ ធ្វើផ្លូវដើម្បីចូលដល់សុគតិមានទេវតានិងមនុស្សឲ្យ វិនាស ។

ព្រះមហាសត្វ កំណត់ពិចារណាភាវៈដែលមិនស្អាតនិងភាវៈដែលក្ដៅ

ក្រហាយជានិច្ចដោយប្រការផ្សេងៗដោយប្រការដូច្នោះនៀយណាយក្នុងកាយ ចម្រើនព្រហ្មវិហារ ៤ ដរាបដល់អស់ជីវិត បានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ មហាជនបានសម្រេចសោតាបត្តិផលជាដើម ហើយទ្រង់ប្រជុំជាតកថា តាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កាយនិព្វិន្ទជាតក ចប់

## ជម្ពុខាទកជាតក

[ ៤៨១ ] ( ចចកពោលថា ) អ្នកណានេះមានសំឡេងគ្រលួច ពីរោះឧត្តមជាងពួកសត្វដែលមានសំឡេង ទំលើមែកព្រីងហើយយំពីរោះដូចជាសំឡេងនៃកូនក្ងោក ។

[ ៤៨២ ] ( ក្អែកពោលថា ) កុលបុត្តចេះសរសើរកុលបុត្ត ( ដូចគ្នា ) ម្នាលសម្លាញ់ មានសម្បុរដូចជាសម្បុរនៃកូនខ្លា ខ្ញុំសូមជូន ( ផ្លែព្រីង ) ដល់អ្នក ចូរអ្នកពិសាចុះ ។

[ ៤៨៣ ] ( រុក្ខទេវតាពោលថា ) យូរណាស់ហើយយើងទើបតែឃើញនូវក្អែកជាសត្វស៊ីនូវកម្អួតផង នូវចចកជាសត្វស៊ីនូវសាកសពផង ជាសត្វពោលពាក្យកុហក មកជួបគ្នាហើយសរសើរគ្នាទៅវិញទៅមក ។

**ចប់ ជម្ពុខាទកជាតកទី ៤ ។**

## អដ្ឋកថា

## ជម្ពុខាទកជាតក

[ ៤៨១-៤៨៣ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុនិងកោកាលិកភិក្ខុ ទើបទ្រង់ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោយំ ពិន្ទុស្សរោ វគ្គុ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះទេវទត្តភិក្ខុសាបសូន្យលាភសក្ការៈ កោកាលិកភិក្ខុក៏ចូលទៅកាន់ត្រកូលទាំងឡាយ ពោលគុណរបស់ទេវទត្តថា ព្រះថេរៈ

ឈ្មោះថាទេវទត្ត កើតក្នុងវង្សព្រះបាទឱក្កាករាជដោយបន្តវង្សមកអំពីព្រះបាទមហាសម្មតរាជ ចម្រើនក្នុងខត្តិយវង្សដែលមិនលាយឡំ ( ដោយជាតិវង្សដទៃ ) ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកបានឈាន មានសំដីពីរោះ ជាធម្មកថិក អ្នកទាំងឡាយចូរឲ្យ ចូរធ្វើ ( សក្ការៈជាដើម ) ដល់ព្រះថេរៈចុះ ។ ចំណែកទេវទត្តភិក្ខុក៏ពោលគុណរបស់កោកាលិកភិក្ខុថា កោកាលិកភិក្ខុចេញបួសអំពីត្រកូលព្រាហ្មណ៍ដែលមានកេរ្តិ៍ឈ្មោះ ជាពហុស្សូត ជាធម្មកថិក អ្នកទាំងឡាយចូរឲ្យ ចូរធ្វើ ( សក្ការៈជាដើម ) ដល់កោកាលិកភិក្ខុចុះ ។ ទេវទត្តនិងកោកាលិកៈនោះពោលគុណដល់គ្នានឹងគ្នា ត្រាច់ឆាន់ក្នុងផ្ទះនៃត្រកូលទាំងឡាយដោយប្រការដូច្នេះ ។ សម័យថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តនិងកោកាលិកភិក្ខុពោលពាក្យពណ៌នាគុណដែលមិនមានពិតដល់គ្នានឹងគ្នាហើយត្រាច់ឆាន់អាហារ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងឈ្មោះអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេដែលទេវទត្តនិងកោកាលិកនោះពណ៌នាគុណដែលមិនពិត ( ដល់គ្នានឹងគ្នា ) ហើយបរិភោគភត្តាហារ សូម្បីក្នុងកាលមុនទេវទត្តនិងកោកាលិកក៏បរិភោគហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វ កើតជារុក្ខទេវតាក្នុងព្រៃព្រីងមួយកន្លែង ។ ក្នុងព្រៃព្រីងនោះ មានក្អែកមួយទំត្រង់មែកព្រីង ស៊ីផ្លែព្រីងទុំៗ ។ កាលនោះមានចចកមួយដើរ មកសម្លឹងមើលលើ ឃើញក្អែកហើយគិតថា ណ្ហើយចុះ អញពោលគុណ ដែលមិនពិតរបស់ក្អែកនេះនឹងបានស៊ីផ្លែព្រីងទុំ ដូច្នេះហើយ កាលនឹងពោល គុណរបស់ក្អែកនោះទើបពោលគាថាទី ១ ថា

អ្នកណានេះមានសំឡេងគ្រលួច ពីរោះឧត្តមជាងពួកសត្វដែល មានសំឡេង ទំលើមែកព្រីងហើយយំពីរោះដូចជាសំឡេងនៃ កូនក្ងោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពិន្ទុស្សរោ** សេចក្តីថា ប្រកបដោយសំឡេង គ្រលួច គឺទន់ពីរោះមូលដ៏ឧត្តម ។ បទថា **វគ្គុ** បានដល់ មានសំឡេង ផ្អែមល្ហែម ។ បទថា **អច្ចុតោ** បានដល់ មិនឃ្លាត គឺទំមួយកន្លែង ។ ដោយបទថា **មោរច្ឆាចោរ កុជ្ជតិ** នេះចចកពោលថា នោះឈ្មោះអ្វីបន្លឺ សំឡេងជាទីត្រេកអរនៃចិត្តដូចក្ងោកជំទង់ដូច្នោះ ។

លំដាប់នោះក្អែកកាលសរសើរតបដល់ចចកនោះ ទើបពោលគាថាទី ២ ថា

កុលបុត្តចេះសរសើរកុលបុត្ត ( ដូចគ្នា ) ម្នាលសម្លាញ់ មានសម្បុរដូចជាសម្បុរនៃកូនខ្លា ខ្ញុំសូមជូន ( ផ្លែព្រីង ) ដល់អ្នក ចូរអ្នកពិសាចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្យគ្ឃច្ឆាបសទិសវណ្ណ** សេចក្តីថា អ្នក រមែងប្រាកដដល់ខ្ញុំ មានពណ៌សម្បុរស្មើនឹងកូនខ្លាធំ អ្នកជាបុគ្គលមានពណ៌

សម្បុរដូចគ្នានឹងកូនខ្លាធំដ៏ចម្រើន ដោយហេតុនោះ ទើបខ្ញុំពោលនឹងអ្នក ។ បទថា **ភុញ្ជ សម្ម ធនាមិ តេ** សេចក្តីថា នែសម្លាញ់ អ្នកចូរបរិភោគផ្លែព្រីងទុំរហូតគ្រប់គ្រាន់ដល់សេចក្តីត្រូវការចុះ ខ្ញុំឲ្យអ្នក ។

កាលពោលយ៉ាងនោះហើយ ក្អែកក៏អង្រួនមែកព្រីងឲ្យផ្លែទាំងឡាយជ្រុះទៅ ។ កាលនោះទេវតាដែលអាស្រ័យនៅត្រង់ដើមព្រីងឃើញក្អែកនិងចចកនោះពោលគុណដែលមិនមានពិតដល់គ្នានឹងគ្នាស៊ីផ្លែព្រីងទុំ ទើបពោលគាថាទី ៣ ថា

យូរណាស់ហើយយើងទើបតែឃើញនូវក្អែក ជាសត្វស៊ីនូវកម្អួត
ផង នូវចចកជាសត្វស៊ីនូវសាកសពផង ជាសត្វពោលពាក្យ
កុហកមកជួបគ្នា ហើយសរសើរគ្នាទៅវិញទៅមក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វន្តាទំ** បានដល់ ក្អែកជាអ្នកស៊ីអាហារដែលអ្នកដទៃក្អួតចេញមក ។ បទថា **កុណបាទនញ្ច** បានដល់ ចចកជាអ្នកស៊ីសាកសព ។

ទេវតានោះកាលពោលគាថានេះហើយទើបសម្តែងរូបារម្មណ៍ដែលគួរខ្លាចឲ្យក្អែកនិងចចកគេចទៅអំពីទីនោះ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ក្អែកក្នុងកាលនោះបានមកជាកោកាលិកៈ ចំណែកទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ជម្ពុខាទកជាតក ចប់**

## អន្ធជាតក

[ ៤៨៤ ] ( ក្អែកពោលថា ) ករបស់អ្នកដូចជាកនៃគោឧសភ ការមិតពត់របស់អ្នកដូចជាការមិតពត់នៃសត្វសីហៈ បពិត្រមិគរាជ ខ្ញុំសូមថ្វាយបង្គំអ្នក ធ្វើម្តេចយើងនឹងបាននូវសាច់តិចតួច ។

[ ៤៨៥ ] ( ចចកពោលថា ) កុលបុត្តចេះសរសើរនូវកុលបុត្តដូចគ្នា ម្នាលក្អែកមានផ្នួតកដូចជាក្ងោក អ្នកចូរចុះអំពីដើមល្ហុងនេះមក ។

[ ៤៨៦ ] ( រុក្ខទេវតាពោលថា ) ចចកជាសត្វថោកទាបជាងម្រឹគទាំងឡាយ ឯក្អែកជាសត្វថោកទាបជាងបក្សីទាំងឡាយដែរ ដើមល្ហុងជាឈើថោកទាបជាងឈើទាំងឡាយ ពួកថោកទាបទាំង ៣ មកជួបប្រទះគ្នា ។

**ចប់ អន្ធជាតកទី ៥ ។**

## អដ្ឋកថា

## អន្ធជាតក

[ ៤៨៤-៤៨៦ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជនទាំងពីរ គឺទេវទត្តនិងកោកាលិកៈនោះឯង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧសភស្សេវ តេ ខន្ធោ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្នដូចគ្នានឹងរឿងមុននោះឯង ឯរឿងក្នុងអតីតមានដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វកើតជារុក្ខទេវតាត្រង់ដើមល្ហុងខ្វែរក្នុងបរិវេណស្រុកមួយកន្លែង ។ ក្នុងកាលនោះ អ្នកស្រុកអួសគោចាស់ដែលស្លាប់ក្នុងស្រុកនោះ ទៅចោលត្រង់ព្រៃល្ហុងខ្វែរក្បែរទ្វារស្រុក មានចចកមួយមកស៊ីសាច់គោស្លាប់នោះ ។ មានក្អែកមួយហើរមកទំត្រង់ដើមល្ហុងខ្វែរឃើញដូច្នោះទើបគិតថា ណ្ហើយចុះ អញគប្បីពោលគុណដែលមិនពិតរបស់ចចកនេះនឹងបានស៊ីសាច់ ដូច្នេះហើយទើបពោលគាថាទី ១ ថា

កររបស់អ្នកដូចជាកនៃគោឧសភ ការមិតពត់របស់អ្នកដូចជា
ការមិតពត់នៃសត្វសីហៈ បពិត្រមិគរាជ ខ្ញុំសូមថ្វាយបង្គំអ្នក
ធ្វើម្ដេចយើងនឹងបានទូវសាច់តិចតួច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥមោ ត្យត្ថុ** កាត់បទជា **ឥមោ តេ អត្ថុ** ប្រែថា សូមថ្វាយបង្គំដល់លោក ចចកបានស្ដាប់ដូច្នោះទើបពោលគាថាទី ២ ថា

កុលបុត្តចេះសរសើរនូវកុលបុត្តដូចគ្នា ម្នាលក្អែកមានផ្នួត**ក**
ដូចជាក្ងោក អ្នកចូរចុះអំពីដើមល្ហុងនេះមក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱរោ បរិយាហិ** នេះ ចចកពោលថា សូមអ្នកចុះអំពីដើមល្ហុងខ្វែរ គឺមកអំពីដើមល្ហុងខ្វែរនេះរហូតដល់ខ្ញុំ ហើយបរិភោគសាច់ ។ រុក្ខទេវតាឃើញកិរិយារបស់សត្វទាំង ២ នោះទើបពោលគាថាទី ៣ ថា

ចចកជាសត្វថោកទាបជាងម្រឹគទាំងឡាយ ឯក្អែកជាសត្វថោក

ទាបជាងបក្សីទាំងឡាយដែរ ដើមល្អុងជាឈើថោកទាបជាងឈើទាំងឡាយ ពួកថោកទាបទាំង ៣ មកជួបប្រទះគ្នាដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អន្តោ** បានដល់ ថោកទាប គឺអាក្រក់ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ក្អែកក្នុងកាលនោះបានមកជាកោកាលិកៈ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា អន្តជាតក ចប់**

## សមុទ្ទជាតក

[ ៤៨៧ ] ( សមុទ្ទទេវតាពោលថា ) អ្នកណានេះហ្ន៎ ស្ទុះទៅមក ដោយជុំវិញក្នុងសមុទ្ទមានទឹកប្រៃ ហាមឃាត់នូវពួកត្រីនិងពួកមករលំបាកក្នុង រលកទឹក ។

[ ៤៨៨ ] ( ក្អែកសមុទ្ទពោលថា ) ខ្ញុំជាសត្វស្ទាប ជាសត្វផឹកទឹក មិនមានជាទីបំផុត ល្បីល្បាញទៅគ្រប់ទិសថាជាសត្វមិនចេះឆ្អែត ប្រាថ្នាដើម្បី ផឹកនូវទឹកសមុទ្ទ គឺសាគរដែលជាម្ចាស់នៃទន្លេ ។

[ ៤៨៩ ] ( សមុទ្ទទេវតាពោលថា ) សមុទ្ទធំនោះជួនកាលក៏នាចទៅ ជួនកាលក៏ជោរឡើង ទីបំផុតនៃទឹកសមុទ្ទនោះដែលសកលលោកផឹកហើយ មិនប្រាកដទេ ឬថាសាគរអ្នកណាមួយក៏មិនអាចផឹកទឹកឲ្យអស់បានឡើយ ។

**ចប់ សមុទ្ទជាតកទី ៦ ។**

## អដ្ឋកថា

## សមុទ្ទជាតក

[ ៤៨៧-៤៨៩ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ ប្រារព្ធព្រះឧបនន្ទត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោ នាយំ** ដូច្នេះជាដើម ។

បានឮថា ព្រះឧបនន្ទនោះបរិភោគច្រើន មានសេចក្តីល្មោភច្រើន បុគ្គល ណាមួយមិនអាចឲ្យព្រះឧបនន្ទនោះឆ្អែតដោយបច្ច័យដែលពេញដោយរទេះ ។

ក្នុងថ្ងៃជិតចូលវស្សាព្រះឧបនន្ទនោះចូលវស្សាក្នុងវិហារ ២-៣ កន្លែងដាក់ស្បែកជើងទុកក្នុងវិហារមួយ ដាក់កុណ្ឌីទឹកទុកក្នុងវិហារមួយ ដាក់ឈើច្រត់ទុកក្នុងវិហារមួយ ខ្លួនឯងនៅក្នុងវិហារមួយ ។ ថ្ងៃមួយទៅកាន់វិហារក្នុងជនបទឃើញភិក្ខុទាំងឡាយមានបរិក្ខារប្រណីត ទើបពោលអរិយវង្សកថាពណ៌នាដល់ភាពជាវង្សរបស់ព្រះអរិយៈ ឲ្យភិក្ខុទាំងនោះកាន់យកសំពត់បង្សុកូល ហើយកាន់យកចីវររបស់ភិក្ខុទាំងនោះ ឲ្យភិក្ខុទាំងនោះកាន់យកបាត្រដី ខ្លួនឯងកាន់យកបាត្រដែលគាប់ចិត្តនិងភាជនៈមានថាសជាដើម ដាក់ពេញយានតូចហើយមកកាន់វត្តជេតពន ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះឧបនន្ទសក្យបុត្តបរិភោគច្រើនប្រាថ្នាច្រើន សម្តែងបដិបទាដល់ភិក្ខុពួកដទៃ ហើយកាន់យកសមណបរិក្ខារផ្ទុកពេញរទេះតូច ( នាំ ) មក ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទពោលអរិយវង្សកថាដល់អ្នកដទៃហើយធ្វើកម្មមិនសមគួរព្រោះគួរតែខ្លួនជាអ្នកប្រាថ្នាតិចសិនហើយសឹមពោលអរិយវង្សកថាដល់អ្នកដទៃក្នុងកាលឯក្រោយហើយទ្រង់សម្តែងគាថាក្នុងធម្មបទដូច្នេះថា

**អត្តានមេវ បឋមំ    បតិរូបេ និវេសយេ**
**អថញ្ញមនុសាសេយ្យ    ន កិលិស្សេយ្យ បណ្ឌិតោ ។**

បណ្ឌិតគួរតម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជាមុនសិន ហើយ
សឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ ( ធ្វើយ៉ាងនេះ ) នឹង
មិនលំបាកឡើយ ។

កាលត្រាស់ហើយទើបទ្រង់តិះដៀលព្រះឧបនន្ទថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទជាអ្នកប្រាជ្ញាច្រើន តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏សម្គាល់ទឹកក្នុងមហាសមុទ្រថា ខ្លួនគួររក្សា ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាទេវតារក្សាសមុទ្រ ។ កាលនោះមានក្អែកទឹកមួយហើរទៅអំពីខាងលើសមុទ្រស្រែកហាមត្រីនិងហ្វូងបក្សីថា អ្នកទាំងឡាយ ចូរផឹកទឹកក្នុងសមុទ្រតែល្មមប្រមាណ សូមជួយគ្នារក្សាទឹកផឹកផងចុះ ។ សមុទ្ទទេវតាឃើញដូច្នោះទើបពោលគាថាទី ១ ថា

អ្នកណានេះហ្ន៎ ស្ទុះទៅមកដោយជុំវិញក្នុងសមុទ្រមានទឹកប្រៃ
ហាមឃាត់នូវពួកត្រីនិងពួកមករលំបាកក្នុងរលកទឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ ឆ្វាយំ** កាត់បទជា **កោ នុ អយំ** ប្រែថា នេះអ្នកណាហ្ន៎ ។ ក្អែកទឹកបានស្តាប់ដូច្នោះទើបពោលគាថាទី ២ ថា

ខ្ញុំជាសត្វស្វាប ជាសត្វផឹកទឹកមិនមានជាទីបំផុត ល្បីល្បាញ
ទៅគ្រប់ទិសថាជាសត្វមិនចេះឆ្អែត ប្រាថ្នាដើម្បីផឹកនូវទឹកសមុទ្រ
គឺសាគរដែលជាម្ចាស់នៃទន្លេ ដូច្នេះ ។

អត្ថនៃគាថានោះថា ខ្ញុំប្រាថ្នានឹងផឹកទឹកក្នុងសាគរដែលមិនមានទីបំផុត ដោយហេតុនោះទើបខ្ញុំជាបក្សីឈ្មោះថា **អនន្តបាយី** ។ ម្យ៉ាងទៀតខ្ញុំដែលបុគ្គលបានឮ បានស្តាប់ប្រាកដហើយថា ឈ្មោះថា **អតិត្តោ** ព្រោះប្រកបដោយចំណង់ដែលមិនពេញ ខ្ញុំនោះប្រាថ្នានឹងផឹកទឹកសមុទ្រនេះទាំងអស់ដែលឈ្មោះថា **សាគរំ** ព្រោះជាប្រភពកើតនៃរតនៈដ៏វិចិត្រនិងព្រោះព្រះបាទសាគរជាអ្នកជីក ឈ្មោះថា **សរិតប្បតឹ** ព្រោះជាធំជាងស្រះទាំងឡាយ ។ សមុទ្ទទេវតាបានស្តាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

សមុទ្ទធំនោះជួនកាលក៏នាចទៅ ជួនកាលក៏ជោរឡើង ទីបំផុតនៃទឹកសមុទ្រនោះ ដែលសកលលោកផឹកហើយមិនប្រាកដទេ

ឬថាសាគរ អ្នកណាមួយក៏មិនអាចផឹកទឹកឲ្យអស់បានឡើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ អយំ ហាយតី ចេវ** សេចក្តីថា ទឹកសមុទ្ទរមែងនាចក្នុងវេលាទឹកស្រកនិងរមែងជោរក្នុងវេលាទឹកជន់ ។ បទថា **នាស្ស នាយតិ** សេចក្តីថា បើសត្វលោកទាំងអស់ផឹកទឹកសមុទ្ទនោះ ទោះជាយ៉ាងនោះសមុទ្ទនោះក៏មិនប្រាកដជាស្រក សូម្បីសត្វលោកផឹកទឹកមានប្រមាណប៉ុណ្ណេះអំពីទឹកនេះ ។ បទថា **អបេយ្យោ កិរ** សេចក្តីថា បានឮថា សាគរនេះបុគ្គលណាមួយមិនអាចផឹកឲ្យអស់បាន ។

សមុទ្ទទេវតាកាលពោលយ៉ាងនេះហើយ សម្តែងរូបារម្មណ៍ដែលគួរខ្លាចឲ្យក្អែកសមុទ្ទនោះគេចទៅ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ក្អែកសមុទ្ទក្នុងកាលនោះបានមកជាឧបនន្ទក្នុងកាលឥឡូវនេះ ចំណែកសមុទ្ទទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សមុទ្ទជាតក ចប់**

# កាមវិលាបជាតក

[ ៤៩០ ] ( បុរសម្នាក់ពោលថា ) ម្នាលសត្វស្ទាប អ្នកទៅក្នុងទីខ្ពស់ ទៅដោយស្លាបបាន ទៅតាមអាកាសបាន សូមអ្នកប្រាប់ ( ប្រពន្ធខ្ញុំ ) ដែលមានភ្លៅស្រលួតដូចដើមចេក ប្រពន្ធរបស់ខ្ញុំនោះ នឹងរឭកខ្ញុំអស់កាលយូរ ។

[ ៤៩១ ] ប្រពន្ធខ្ញុំនោះមិនដឹងនូវដាវនិងលំពែងនេះឯងដែលគេដោតចុះហើយ វាជាស្រីឆ្នាស់តែងធ្វើនូវសេចក្តីក្រោធ ការក្រោធរបស់វានោះរមែងក្តៅក្រហាយដល់ខ្ញុំ ( ឯដាវនិងលំពែងដែលគេដោត ) ក្នុងទីនេះមិនមែនក្តៅក្រហាយដល់ខ្ញុំទេ ។

[ ៤៩២ ] ច្បូកដូចជាផ្កាឧប្បលនិងក្រោះនោះ ចិញ្ចៀនមាស សំពត់មានសាច់ដ៏ទន់ដែលជននាំមកអំពីដែនកាសី ខ្ញុំដាក់លើក្បាលដំណេក ( ប្រពន្ធខ្ញុំ ) ជាស្រីត្រូវការនឹងទ្រព្យ ចូរយកចិញ្ចឹមជីវិតឲ្យស្កប់ស្កល់ចុះ ។

**ចប់ កាមវិលាបជាតក ទី ៧ ។**

## អដ្ឋកថា

## កាមវិលាបជាតក

[ ៤៩០-៤៩២ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ករិយាចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧច្ចេ សកុណ ឌេមាន** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នបានពោលទុកហើយក្នុងបុប្ផរត្តជាតក ។ រឿងក្នុងអតីតនឹងមានជាក់ច្បាស់ក្នុងឥន្ទ្រិយជាតក តែក្នុងទីនេះរាជបុរសទាំងឡាយធ្វើឲ្យបុរសនេះតក់ស្លុតដោយដោតនឹងឈើអណ្តោតទាំងរស់ ។ បុរសនោះអង្គុយលើឈើអណ្តោតឃើញក្អែកមួយហើរមកតាមអាកាស មិនអើពើដល់វេទនាដ៏ខ្លាំងក្លាបែបនោះ កាលហៅក្អែកនោះមកដើម្បីបញ្ជូនដំណឹងដល់ភរិយាជាទីស្រឡាញ់ទើបពោលគាថាទាំងនេះថា

ម្នាលសត្វស្លាប អ្នកទៅក្នុងទីខ្ពស់ទៅដោយស្លាបបាន ទៅតាមអាកាសបាន សូមអ្នកប្រាប់ ( ប្រពន្ធខ្ញុំ ) ដែលមានភ្លៅស្រលូតដូចដើមចេក ប្រពន្ធរបស់ខ្ញុំនោះនឹងរឭកខ្ញុំអស់កាលយូរ ។

ប្រពន្ធខ្ញុំនោះមិនដឹងនូវដាវនិងលំពែងនេះឯងដែលគេដោតចុះហើយ វាជាស្រីឆ្នាសតែងធ្វើនូវសេចក្តីក្រោធ ការក្រោធរបស់វានោះ រមែងក្តៅក្រហាយដល់ខ្ញុំ ( ឯដាវនិងលំពែងដែលគេដោត ) ក្នុងទីនេះមិនមែនក្តៅក្រហាយដល់ខ្ញុំទេ ។

ច្បូកដូចជាផ្កាឧប្បលនិងក្រោះនោះ ចិញ្ចៀនមាស សំពត់មានសាច់ដ៏ទន់ដែលជនទាំមកអំពីដែនកាសី ខ្ញុំដាក់លើក្បាលដំណេក ( ប្រពន្ធខ្ញុំ ) ជាស្រីត្រូវការនឹងទ្រព្យ ចូរយកចិញ្ចឹមជីវិតឲ្យស្កប់ស្កល់ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខេមាណ** បានដល់ ហើរទៅ គឺត្រាច់ទៅ ។

បុរសនោះហៅក្អែកនោះថា **បត្តយាន** ព្រោះមានស្លាបជាយាន ហៅថា **វិហង្គម** ព្រោះទៅក្នុងវេហាបានក៏ដូចគ្នា ។ ពិតហើយក្អែកនោះឈ្មោះថា **បត្តយាន** ព្រោះធ្វើការទៅដោយស្លាបទាំងឡាយឈ្មោះថា **វិហង្គម** ព្រោះទៅតាមអាកាស ។ បទថា **វជ្ជាសិ** បានដល់ អ្នកគប្បីប្រាប់ ។ បទថា **វាម្ភុរុំ** បានដល់ ដែលមានភ្លៅស្រលូនដូចដើមចេក អ្នកគប្បីប្រាប់ថា ខ្ញុំអង្គុយលើលំពែង ។ បទថា **ចិរំ ខោ សា ករិស្សតិ** សេចក្តីថា នាងកាលមិនជ្រាបដំណឹងពេលនេះ នឹងធ្វើនូវការរង់ចាំការមករបស់ខ្ញុំអស់កាលយូរ គឺនាងនឹងគិតយ៉ាងនេះថា ស្វាមីដែលជាទីស្រឡាញ់ទៅយូរហើយមិនទាន់មក ។ បទថា **អសី សត្តិញ្ច** បានដល់ ដាវនិងលំពែងនេះ បុរសនោះពោលសំដៅយកចំពោះឈើអណ្តាតប៉ុណ្ណោះ ព្រោះស្មើដោយដាវនិងលំពែង ។ ពិតហើយឈើអណ្តាតនោះគេដាក់ គឺដោតទុកដើម្បីដោតផ្កាលបុរសនោះ ។ បទថា **ចណ្ឌី** បានដល់ ជាអ្នកច្រើនដោយសេចក្តីក្រោធ ។ បទថា **កាហាតិ កោធំ** សេចក្តីថា នាងនឹងធ្វើការក្រោធចំពោះខ្ញុំថា វង់តែយឺតយូរ ។ បទថា **តំ មេ តប្បតិ** សេចក្តីថា សេចក្តីក្រោធរបស់នាងនោះរមែងធ្វើខ្ញុំឲ្យក្តៅក្រហាយ ។ បទថា **នោ ឥធ** នេះបុរសនោះសម្តែងថា ឯលំពែងនេះមិនធ្វើឲ្យខ្ញុំក្តៅក្រហាយក្នុងទីនេះឡើយ ។ ដោយពាក្យថា **ឯស ឧប្បលសន្នាហោ** ជាដើម បុរសនោះប្រាប់ដល់វត្ថុរបស់ខ្លួនដែលទុកលើក្បាលដំណេកក្នុងផ្ទះ ។ បណ្តាបទទាំងនោះបទថា **ឧប្បលសន្នាហោ** បានដល់ ច្បូកផងក្រោះផង ឈ្មោះថា ឧប្បលសន្នាហៈ អធិប្បាយថា ច្បូកមួយ

ប្រភេទដូចគ្នានឹងផ្កាឈូកនិងក្រោះ ។ បទថា **និក្ខញ្ច** បានដល់ ចិញ្ចៀន ដែលធ្វើដោយមាសមានត្បូង ៥ ។ ដោយបទថា **កាសិកញ្ច មុទុំ វត្ថំ** នេះ បុរសនោះពោលសំដៅយកគូសំពត់សាដក ដែលធ្វើក្នុងដែនកាសីមាន សាច់ទន់ ។ បានឮថា ទ្រព្យមានប្រមាណប៉ុណ្ណេះដែលបុរសនោះរក្សាទុក លើក្បាលដំណេក ។ បទថា **តប្បេតុ ធនកាមិយា** សេចក្ដីថា ភរិយា ជាទីស្រឡាញ់របស់ខ្ញុំនោះ មានសេចក្ដីត្រូវការទ្រព្យ ចូរកាន់យកទ្រព្យទាំង អស់នេះ ចូរឆ្អែតស្កប់ស្កល់បរិបូណ៌ គឺចូរត្រេកអរដោយទ្រព្យនេះ ។ បុរស នោះខ្សឹកខ្សួលយ៉ាងនេះហើយក៏ស្លាប់ទៅកើតក្នុងនរក ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើប ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុង សោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ភរិយាក្នុងកាលនោះ បានមកជា ភរិយាក្នុងកាលឥឡូវនេះ ទេវបុត្តអ្នកឃើញហេតុការណ៍នោះ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កាមវិលាបជាតក ចប់

## ឧទុម្ពរជាតក

[ ៤៩៣ ] ( ស្វាធំពោលថា ) ពួកដើមល្វាផង ដើមជ្រៃផង ដើមខ្វិតផងទាំងនេះឯងសុទ្ធតែមានផ្លែទុំ អ្នកចូរមកហើយចេញទៅបរិភោគ ( នូវផ្លែឈើទាំងនោះ ) អ្នកស្លាប់ដោយសេចក្ដីឃ្លានដូចម្ដេចកើត ។

[ ៤៩៤ ] ( ស្វាតូចពោលថា ) បុគ្គលណាគោរពក្រោតក្រែងចាស់ព្រឹទ្ធាចារ្យ បុគ្គលនោះបានឈ្មោះថា ឆ្អែតស្កប់ស្កល់ហើយយ៉ាងនេះ ដូចជាក្នុងថ្ងៃនេះខ្ញុំបានបរិភោគផ្លែឈើទុំឆ្អែតស្កប់ស្កល់ហើយ ។

[ ៤៩៥ ] ( ស្វាធំពោលថា ) ស្វាដែលកើតក្នុងព្រៃគប្បីបញ្ឆោតនូវស្វាដែលកើតក្នុងព្រៃដូចគ្នា ព្រោះហេតុណាហេតុនោះស្វាដែលនៅក្មេង ( ដូចជាអ្នក ) មិនគប្បីជឿបានទេ ស្វាចាស់គ្រាំគ្រា ( ដូចយើង ) ក៏មិនគប្បីជឿបានដែរ ។

**ចប់ ឧទុម្ពរជាតកទី ៨ ។**

## អដ្ឋកថា

## ឧទុម្ពរជាតក

[ ៤៩៣-៤៩៥ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឧទុម្ពរា ចិមេ បក្កា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះសាងវិហារក្នុងបច្ចន្តគាមមួយកន្លែង ។ វិហារនោះ

គួរជាទីត្រេកអរតាំងនៅលើផ្ទាំងថ្ម ។ ស្ថានទីបោសសម្អាតដូចបារាំ មានទឹកប្រើប្រាស់សុខស្រួល ។ គោចរគ្រាមក៏មិនឆ្ងាយ ។ មនុស្សទាំងឡាយស្រឡាញ់រាប់អាននាំគ្នាប្រគេនភិក្ខា ។ ក្នុងកាលនោះ ភិក្ខុមួយអង្គចារិកទៅដល់វិហារនោះ ។ ភិក្ខុម្ចាស់កន្លែងធ្វើអាគន្តុកវត្តដល់ភិក្ខុនោះ ស្អែកឡើងបាននាំភិក្ខុនោះចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយប្រគេនភិក្ខាដ៏ប្រណីតដល់ភិក្ខុទាំងនោះ ហើយនិមន្តឲ្យឆាន់ក្នុងថ្ងៃស្អែក ។ អាគន្តុកភិក្ខុឆាន់បានពីរបីថ្ងៃទើបគិតថា អញនឹងបោកបញ្ឆោតភិក្ខុម្ចាស់អាវាសនេះដោយឧបាយណាមួយអូសទាញចេញទៅហើយដណ្តើមវិហារនេះ ។ លំដាប់នោះអាគន្តុកភិក្ខុបានសួរអាវាសភិក្ខុដែលមកកាន់ទីបម្រើព្រះថេរៈថា អាវុសោលោកមិនបម្រើព្រះពុទ្ធទេឬ អាវាសិកភិក្ខុពោលថា ឈ្មោះថា អ្នកបដិបត្តិមើលថែវិហារនេះមិនមាន ដោយហេតុនោះទើបខ្ញុំមិនធ្លាប់ទៅ ( ឧបដ្ឋាកព្រះសម្ពុទ្ធ ) អាគន្តុកភិក្ខុពោលថា ខ្ញុំនឹងមើលវិហារនេះទម្រាំលោកទៅគាល់ព្រះសម្ពុទ្ធហើយត្រឡប់មក ។ ភិក្ខុម្ចាស់អាវាសពោលថា សាធុលោកម្ចាស់ហើយពោលនឹងមនុស្សទាំងឡាយថា អ្នកទាំងឡាយ កុំប្រមាទក្នុងព្រះថេរៈទម្រាំអាត្មាត្រឡប់មក ហើយជៀសចេញទៅ ។ ចាប់តាំងអំពីនោះមកអាគន្តុកភិក្ខុក៏ពោលថា ភិក្ខុម្ចាស់អាវាសមានទោសនេះមួយ មានទោសនេះមួយ ហើយញុះញង់មនុស្សទាំងឡាយនោះឲ្យប្រេះឆា ( ជាមួយអាវាសិកភិក្ខុ ) ។ ចំណែកភិក្ខុម្ចាស់អាវាសថ្វាយបង្គំព្រះសាស្តាហើយត្រឡប់មក ។ លំដាប់នោះអាគន្តុកភិក្ខុនោះមិនឲ្យសេនាសនៈ ។ ទើបភិក្ខុម្ចាស់អាវាសនៅ

ក្នុងទីមួយកន្លែង ស្អែកឡើងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត មនុស្សទាំងឡាយក៏មិនធ្វើសូម្បីត្រឹមតែសាមីចិកម្ម ។ ភិក្ខុម្ចាស់អាវាសក្តៅក្រហាយចិត្តទើបទៅកាន់វត្តជេតពនប្រាប់ហេតុនោះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏អង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ភិក្ខុឈ្មោះនោះអូសភិក្ខុឈ្មោះនោះចេញចាកវិហារ ហើយខ្លួនឯងនៅក្នុងវិហារនោះ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងឈ្មោះអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនអាគន្តុកភិក្ខុនេះក៏អូសអាវាសិកភិក្ខុនេះចេញចាកលំនៅមកហើយដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីព្រះពោធិសត្វកើតជារុក្ខទេវតាក្នុងព្រៃ ។ ក្នុងរដូវភ្លៀង ភ្លៀងធ្លាក់ជោកជាំអស់កាល ៧ សប្តាហ៍ ។ ក្នុងកាលនោះមានស្វាតូចមុខក្រហមមួយនៅក្នុងញកថ្មមួយកន្លែង ដែលមិនសើមដោយភ្លៀង ។ ថ្ងៃមួយអង្គុយជាសុខក្នុងទីដែលមិនសើមត្រង់ញកភ្នំ ។ លំដាប់នោះស្វាធំខ្មៅមួយត្រូវរងាបៀតបៀនដើរមកឃើញស្វាតូចនោះអង្គុយយ៉ាងនោះទើបគិតថា អញនឹងនាំស្វានេះចេញទៅដោយឧបាយហើយនៅក្នុងទីនេះឯងដូច្នេះ ទើបធ្វើពោះឲ្យធំ សម្តែងអាការៈឆ្អែតស្កប់ស្កល់ទៅឈរខាងមុខស្វាតូចនោះហើយពោលគាថាទី ១ ថា

ពួកដើមល្វាផង ដើមជ្រៃផង ដើមខ្វិតផងទាំងនេះឯងសុទ្ធតែ
មានផ្លែទុំ អ្នកចូរមកហើយចេញទៅបរិភោគ ( នូវផ្លែឈើទាំង
នោះ ) អ្នកស្លាប់ដោយសេចក្ដីឃ្លានដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កបិត្ថនា** បានដល់ផ្លែល្មៀប[១]។ បទថា **ឃសា និក្ខម** សេចក្ដីថា ដើមល្វាជាដើមទាំងនេះវិចិត្រហើយព្រោះពេញដោយផ្លែ ឯខ្ញុំក៏ទំពាស៊ីរហូតឆ្អែតហើយទើបមក អ្នកក៏ចូរទៅស៊ីចុះ ។

ស្វាតូចបានស្ដាប់ពាក្យរបស់ស្វាធំនោះហើយក៏ជឿ បំណងនឹងទំពាស៊ីផ្លែឈើតូចធំទាំងឡាយទើបចេញទៅហើយត្រាច់ទៅក្នុងទីនោះៗ កាលមិនបានផ្លែឈើណាមួយទើបត្រឡប់មកវិញ ឃើញស្វាធំនោះចូលទៅអង្គុយក្នុងញកថ្មរបស់ខ្លួនគិតថា អញនឹងបោកស្វាធំនេះដូច្នេះទើបឈរខាងមុខស្វាធំហើយពោលគាថា ទី ២ ថា

បុគ្គលណាគោរពក្រោតក្រែងចាស់ព្រឹទ្ធាចារ្យ បុគ្គលនោះបាន
ឈ្មោះថា ឆ្អែតស្កប់ស្កល់ហើយយ៉ាងនេះ ដូចជាក្នុងថ្ងៃនេះ
ខ្ញុំបានបរិភោគផ្លែឈើទុំឆ្អែតស្កប់ស្កល់ហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុមបក្កានិ មាសិតោ** សេចក្ដីថា ខ្ញុំទំពាស៊ីផ្លែឈើមានផ្លែល្វាជាដើមរហូតឆ្អែតស្កប់ស្កល់ហើយ ។ ស្វាធំបានស្ដាប់ដូច្នោះទើបពោលគាថាទី ៣ ថា

ស្វាដែលកើតក្នុងព្រៃគប្បីបញ្ឆោតនូវស្វាដែលកើតក្នុងព្រៃដូច

---

១-បិកដខ្មែរជា ផ្លែខ្វិត ។

គ្នាព្រោះហេតុណា ហេតុនោះស្វាដែលនៅក្មេង ( ដូចជាអ្នក )
មិនគប្បីជឿបានទេ ស្វាចាស់គ្រាំគ្រា ( ដូចយើង ) ក៏មិន
គប្បីជឿបានដែរ ដូច្នេះ ។

អត្ថនៃគាថានោះថា ស្វាដែលកើតក្នុងព្រៃគប្បីបោកបញ្ឆោតស្វាដែលកើតក្នុងព្រៃព្រោះហេតុឯណាស្វាក្មេងដូចអ្នកក៏គប្បីជឿ ព្រោះហេតុនោះស្វាចាស់ គឺស្វាចាស់ដូចយើងមិនគប្បីជឿ គឺមិនគប្បីជឿស្វាក្មេងដូចអ្នកដែលពោលអស់ ៧ ដង ក្នុងហិមវន្តប្បទេសមានផ្លែឈើទាំងឡាយដែលសើមដោយទឹកភ្លៀងជ្រុះហើយទីនេះមិនមានកន្លែងសម្រាប់អ្នកទេ អ្នកចូរទៅចុះ ។ ស្វាតូចនោះក៏ជៀសចេញទៅ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ស្វាតូចក្នុងកាលនោះបានមកជាភិក្ខុម្ចាស់អាវាសក្នុងកាលឥឡូវនេះ ស្វាធំក្នុងកាលនោះបានមកជាអាគន្តុកភិក្ខុ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ឧទុម្ពរជាតក ចប់**

# កោមារិយបុត្តជាតក

[ ៤៩៦ ] ( ពួកតាបសពោលថា ) ម្នាលស្វា កាលពីដើមអ្នកឯង លោតលេងជិតអាស្រមក្នុងសំណាក់នៃយើងអ្នកមានសីល អ្នកចូរធ្វើ ( នូវអាការទាំងឡាយមានញាក់មុខជាដើម ) ដែលជាល្បែងរបស់ស្វា យើងមិនត្រេកអរនឹងសីលវត្តនោះទេ ។

[ ៤៩៧ ] ( ស្វាពោលថា ) សេចក្តីបរិសុទ្ធដ៏ក្រៃលែងរបស់តាបសឈ្មោះកោមារិយបុត្តជាពហូសូត ខ្ញុំបានឮហើយ ឥឡូវនេះលោកកុំសម្គាល់ខ្ញុំដូចមុនឡើយ នៃអាវុសោ ( ឥឡូវនេះ ) ពួកយើងជាអ្នកប្រកបក្នុងឈាន ។

[ ៤៩៨ ] ( តាបសពោលថា ) ប្រសិនបើបុគ្គលគប្បីព្រោះនូវពូជលើថ្មទោះភ្លៀងបង្អុរចុះក៏ដោយ ឯពូជនោះមិនគប្បីលូតលាស់បានឡើយ សេចក្តីបរិសុទ្ធដ៏ក្រៃលែងនោះអ្នកបានឮហើយ នៃស្វា អ្នកឆ្ងាយអំពីឈានក្រៃពេកណាស់ ។

**ចប់ កោមារិយបុត្តជាតកទី ៩ ។**

# អដ្ឋកថា

# កោមារិយបុត្តជាតក

[ ៤៩៦-៤៩៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធភិក្ខុទាំងឡាយដែលច្រើនដោយការលេងជាប្រក្រតី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បុរេ តុវំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុទាំងនោះកាលព្រះសាស្តាគង់នៅក្នុងប្រាសាទជាន់លើក៏នាំគ្នានិយាយដល់រឿងដែលខ្លួនបានឃើញនិងបានឮមកជាដើម ធ្វើនូវការគ្គាំគ្គងនិងការក្អាកក្អាយក្នុងប្រាសាទជាន់ក្រោម ។ ព្រះសាស្តាហៅព្រះមហាមោគ្គ-ល្លានមកហើយត្រាស់ថា អ្នកចូរធ្វើភិក្ខុទាំងនេះឲ្យសង្វេគ ។ ព្រះថេរៈហោះឡើងទៅក្នុងអាកាស ហើយយកចុងមេជើងគ្ពុះកំពូលប្រាសាទធ្វើឲ្យប្រាសាទញាប់ញ័ររហូតដល់ទឹកទ្រផែនដីជាទីបំផុត ។ ភិក្ខុទាំងនោះភ័យខ្លាចស្លាប់ ក៏**ចេញទៅឈរខាងក្រៅ ។ ភាពដែលភិក្ខុទាំងនោះ ជាអ្នកមានប្រក្រតីជាអ្នក**លេងនោះកើតប្រាកដទៅក្នុងពួកភិក្ខុទាំងឡាយ ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុមួយពួកបួសក្នុងសាសនាដែលជាធម្មជាតិនាំចេញចាកទុក្ខបែបនេះ នៅនាំគ្នាត្រាច់លេងជាប្រក្រតី មិនធ្វើវិបស្សនាកម្មដ្ឋានថា អនិច្ចំ ទុក្ខំ អនត្តា ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះក៏ជាអ្នកលេងឃ្លើសឃ្លងជាប្រក្រតីដូចគ្នា

ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងស្រុកមួយកន្លែង ជនទាំងឡាយស្គាល់កុមារនោះបានដោយឈ្មោះថា កោមារិយបុត្ត ។ ក្នុងកាលតមក កោមារិយបុត្តនោះចេញបួសជាឥសីនៅក្នុងហិមវន្តប្បទេស ។ ក្នុងកាលនោះមានតាបសដែលច្រើនដោយការលេងពួកដទៃ សាងអាស្រមនៅក្នុងហិមវន្តប្បទេស កិច្ចត្រឹមតែកសិណបរិកម្មក៏មិនមានដល់តាបសទាំងនោះ ។ តាបសទាំងនោះនាំផ្លែឈើតូចធំមកអំពីព្រៃទំពាស៊ីសើចលេង ញុំាងកាលវេលាឲ្យដោយការលេងមានប្រការផ្សេងៗ ។ ក្នុងសម្នាក់របស់តាបសទាំងនោះមានស្វាមួយ ។ ស្វានោះក៏ច្រើនទៅដោយការលេងគ្នាំគ្នងដូចគ្នា ញាក់មុខញាក់មាត់ធ្វើវិការៈផ្សេងៗសម្តែងការលេងមានប្រការផ្សេងៗដូចតាបសទាំងឡាយដែរ ។ តាបសទាំងនោះនៅក្នុងទីនោះអស់កាលយូរទើបនាំគ្នាទៅកាន់ដែនដីមនុស្សដើម្បីសេពសេជូរប្រៃ ។ ចាប់តាំងអំពីតាបសទាំងនោះទៅហើយព្រះពោធិសត្វក៏មកកាន់ទីនោះ ហើយសម្រេចការនៅអាស្រ័យ ។ ស្វាក៏សម្តែងការលេងដល់ព្រះពោធិសត្វដូចសម្តែងដល់តាបសទាំងនោះ ។ ព្រះពោធិសត្វក៏ផ្ទាត់ម្រាមដៃហើយឲ្យឱវាទដល់ស្វានោះថា ធម្មតាអ្នកនៅក្នុងសម្នាក់របស់បព្វជិតដែលមានការសិក្សាល្អហើយ គួរតែដល់ព្រមដោយអាចារៈនិងមារយាទសង្រួមកាយជាដើមប្រកបការខ្វល់ខ្វាយក្នុងឈាន ។ ចាប់តាំងអំពីនោះស្វានោះបានជាសត្វមានសីលដល់ព្រមដោយអាចារៈនិងមារយាទ ។ ព្រះពោធិ-

សត្វបានចេញអំពីទីនោះទៅកាន់ទីដទៃ ។ លំដាប់នោះតាបសដែលជាអ្នកលេង ទាំងនោះបរិភោគរសផ្លូវប្រែហើយក៏ត្រឡប់មកកាន់ទីនោះ ។ ស្វាមិនសម្តែងការលេងដល់តាបសទាំងនោះដូចសព្វមួយដងឡើយ ។ លំដាប់នោះតាបសនោះកាលសួរស្វានោះថា អាវុសោ ក្នុងកាលមុនបាបានធ្វើការលេងខាងមុខពួកយើង ឥឡូវនេះព្រោះហេតុអ្វីទើបមិនធ្វើហើយពោលគាថាទី ១ ថា

ម្នាលស្វា កាលពីដើមអ្នកឯងលោតលេងជិតអាស្រមក្នុងសំណាក់នៃយើងអ្នកមានសីល អ្នកចូរធ្វើ ( នូវអាការទាំងឡាយមានញាក់មុខជាដើម ) ដែលជាល្បែងរបស់ស្វា យើងមិនត្រេកអរនឹងសីលវត្តនោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលវតំ សកាសេ** បានដល់ ក្នុងអាស្រមដែលជាសម្នាក់របស់យើងទាំងឡាយ ដែលជាអ្នកឃ្មើសឃ្មងក្នុងការលេងជាប្រក្រតី ។ បទថា **ឱក្កន្ទិកំ** បានដល់ លោតលេងដូចមិគជាតិ ។ បទថា **ករោហរេ** បានដល់ ចូរធ្វើ ។ សព្ទថា **អរេ** ជាអាលបនៈ គឺពាក្យសម្រាប់ហៅ ។ បទថា **មកដិយានិ** បានដល់ ធ្វើមាត់អេចអូចជាដើមពោលគឺ លេងដោយមាត់ ។ បទថា **ន តំ មយំ សីលវតំ រមាម** សេចក្តីថា សីលនិងវត្ត គឺការផ្តាំផ្តងរបស់អ្នកក្នុងកាលមុននោះ ឥឡូវនេះពួកយើងមិនត្រេកអរ គឺមិនត្រេកអរក្រៃលែង អ្នកមិនធ្វើឲ្យពួកយើងត្រេកអរ តើមានហេតុអ្វីហ្ន៎ ។

ស្វាបានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

សេចក្ដីបរិសុទ្ធដ៏ក្រៃលែងរបស់តាបសឈ្មោះ កោមារិយបុត្ត ជាពហុស្សុត ខ្ញុំបានឮហើយ ឥឡូវនេះលោកកុំសម្គាល់ខ្ញុំដូចមុនឡើយ នែអាវុសោ ( ឥឡូវនេះ ) ពួកយើងជាអ្នកប្រកបក្នុងឈាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មយ្ហំ** ជាចតុត្ថីវិភត្តិប្រើក្នុងអត្ថតតិយាវិភត្តិ ។ បទថា **វិសុទ្ធិ** បានដល់ ការបរិសុទ្ធដោយឈាន ។ បទថា **ពហុស្សុតស្ស** បានដល់ ឈ្មោះថា **ពហុស្សុតស្ស** ព្រោះបានស្ដាប់និងព្រោះបានដឹងច្បាស់ក្នុងកសិណបរិកម្មជាច្រើននិងសមាបត្តិ ៨ ។ បទថា **តុវំ** នេះ ស្វាកាលហៅតាបសមួយរូបក្នុងបណ្ដាតាបសទាំងនោះទើបសម្ដែងថា ឥឡូវនេះលោកម្ចាស់កុំសម្គាល់ខ្ញុំថាដូចកាលមុន ខ្ញុំមិនដូចកាលមុនទេខ្ញុំបានអាចារ្យហើយ ។

តាបសបានស្ដាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

ប្រសិនបើបុគ្គលគប្បីព្រោះនូវពូជលើថ្ម ទោះភ្លៀងបង្អុរចុះក៏ដោយ ឯពូជនោះមិនគប្បីលូតលាស់បានឡើយ សេចក្ដីបរិសុទ្ធដ៏ក្រៃលែងនោះអ្នកបានឮហើយ នែស្វា អ្នកឆ្ងាយអំពីឈានភូមិណាស់ ដូច្នេះ ។

អត្ថនៃគាថានោះថា បើបុគ្គលគប្បីព្រោះពូជ ៥ ប្រការលើផ្ទាំងថ្ម ទោះបីភ្លៀងធ្លាក់ចុះល្អពូជនោះក៏ដុះឡើងមិនបាន ព្រោះផ្ទាំងថ្មនោះមិនមែនជាស្រែយ៉ាងណាការបរិសុទ្ធនៃឈានជាន់ខ្ពស់ដែលអ្នកបានស្ដាប់មក ក៏ដូច្នោះដូចគ្នានែស្វា ព្រោះអ្នកកើតក្នុងកំណើតតិរច្ឆានទើបអ្នកឆ្ងាយចាកឈានភូមិ គឺអ្នក

មិនអាចធ្វើឈានឲ្យកើតឡើងបាន ។ តាបសទាំងនោះតិះដៀលស្វាដោយប្រការដូច្នេះ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ពួកតាបសអ្នកឃើសឃ្នងក្នុងការលេងជាប្រក្រតី ក្នុងកាលនោះ បានមកជាភិក្ខុទាំងនេះក្នុងកាលឥឡូវនេះ ចំណែកកោមារិយបុត្តក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កោមារិយបុត្តជាតក ចប់

## ពកជាតក

[ ៤៩៩ ] ( ព្រះសុគតទ្រង់ត្រាស់ថា ) កុកកាលរស់នៅមានសាច់និងឈាមជាភោជនព្រោះសម្លាប់តែសត្វដទៃ ( ហើយអួតថា ) សមាទាននូវវត្តរក្សាឧបោសថ ។

[ ៥០០ ] សក្កទេវរាជបានដឹងច្បាស់នូវវត្តរបស់កុកនោះ ហើយចូលមកដោយ ( ក្លែងខ្លួន ) ជារូបពពែ កុកមានតបះទៅប្រាសហើយ ជាសត្វផឹកនូវឈាម ( នៃសត្វដទៃ ) បានស្ទុះចូលទៅ ( ដើម្បីចឹកពពែស៊ី ) ហើយក៏ទម្លាយបង់នូវតបះដែលខ្លួនសមាទានហើយ ។

[ ៥០១ ] បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានកម្លាំងថយក្នុងការសមាទានឈ្មោះថា ធ្វើខ្លួនឲ្យរហ័សដូចជាកុក ( ដែលទម្លាយនូវតបះរបស់ខ្លួន ) ព្រោះហេតុតែពពែក៏យ៉ាងនោះឯង ។

**ចប់ ពកជាតកទី ១០ ។**

**ចប់ កុម្ភវគ្គទី ៥ ។**

### ឧទ្ទាននៃកុម្ភវគ្គនោះគឺ

និយាយអំពីឆ្នាំងដ៏ប្រសើរ ១ ស្តេចក្អែកឈ្មោះសុបត្តៈ ១ រូបកាយដែលសន្មត់ថាស្អាត ១ ក្អែកមានសំឡេងក្រឡៅ ១ ចចកមានកដូចឧសភៈ ១ សមុទ្ទជាម្ចាស់នៃទន្លេ ១ ប្រពន្ធឆ្លាស ១ ស្វាចាស់ ១ ល្បែងរបស់ស្វា ១ កុក ១ ត្រូវជា ១០ ។

**ឧទ្ទាននៃវគ្គគឺ**

និយាយអំពីសង្កប្បវគ្គ ១ បទុមវគ្គ ១ ឧទបានវគ្គជាគម្រប់បី ១ អព្ភន្តរវគ្គ ១ កុម្ភវគ្គ ១ ( ទាំងអស់នេះ ) រួមបញ្ចូលក្នុងតិកនិបាត ។

**ចប់ តិកនិបាត ។**

## អដ្ឋកថា

## ពកជាតក

[ ៤៩៩-៥០១ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសន្ថ័តចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **បរទាណាយាតេ** ដូច្នេះជាដើម ។

រឿងនេះក៏បានពោលមកហើយដោយពិស្ដារក្នុងព្រះវិន័យនោះឯង ។ ក្នុងទីនេះមានសេចក្ដីសង្ខេបដូចតទៅនេះថា

ព្រះឧបសេនមានវស្សា ២ មួយអន្លើដោយសទ្ធិវិហារិកដែលមានវស្សា ១ នាំគ្នាចូលទៅគាល់ព្រះសាស្ដាត្រូវព្រះសាស្ដាទ្រង់តិះដៀល ទើបត្រឡប់ហើយជៀសចេញទៅ ផ្ដើមបំពេញវិបស្សនាសម្រេចអរហត្តហើយប្រកបដោយគុណមានការប្រាថ្នាតិចជាដើម សមាទានធុតង្គៈ ១៣ ដឹកនាំបរិស័ទឲ្យជាអ្នកទ្រទ្រង់ធុតង្គ ១៣ ផងដែរ ។ កាលព្រះមានព្រះភាគទ្រង់ពួនសម្ងំអស់ត្រៃមាស មួយអន្លើដោយបរិស័ទចូលទៅគាល់ព្រះសាស្ដាព្រោះអាស្រ័យបរិស័ទនោះឯងទើបបានទទួលការតិះដៀលជាលើកដំបូងតែព្រោះប្រព្រឹត្តតាមកតិកាដែលប្រកបដោយធម៌ទើបបានទទួលសាធុការក្នុងលើកទី ២ ជាបុគ្គលដែលព្រះសាស្ដាទ្រង់ធ្វើសេចក្ដីអនុគ្រោះថា ចាប់តាំងអំពីនេះទៅ ភិក្ខុទាំងឡាយដែលទ្រទ្រង់ធុតង្គសូមចូលមកគាល់តថាគតតាមសប្បាយចុះ ហើយទើបចេញទៅប្រាប់សេចក្ដីនោះដល់ភិក្ខុទាំងឡាយ ។ តាំងអំពីនោះមកភិក្ខុទាំងឡាយ ក៏នាំគ្នាទ្រទ្រង់ធុតង្គចូលទៅគាល់ព្រះសាស្ដា កាលព្រះសាស្ដា

យានចេញអំពីទីសម្ងំក៏នាំគ្នាបោលសំពត់បង្សុកូលក្នុងទីនោះៗ កាន់យកតែបាត្រនិងចីវររបស់ខ្លួនប៉ុណ្ណោះ ។ ព្រះសាស្តាត្រាច់ចារិកទៅកាន់សេនាសនៈមួយអន្លើដោយភិក្ខុជាច្រើន ទតឃើញសំពត់បង្សុកូលរាត់រាយក្នុងទីនោះៗទើបត្រាស់សួរ ទ្រង់បានស្តាប់សេចក្តីនោះហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយការសមាទានវត្តរបស់ភិក្ខុទាំងនេះជារបស់មិនឋិតថេរ ដូចគ្នានឹងឧបោសថកម្មរបស់ខ្លែងព្រៃ[១] ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិជាសក្កទេវរាជ ។ គ្រានោះមានខ្លែងព្រៃមួយ ដែលនៅត្រង់ខ្នងថ្មជាក្បែរច្រាំងស្ទឹងគង្គា តមកជំនន់ទឹកជំនន់ស្ទឹងគង្គាហូរមកលិចទីជុំវិញថ្មដានោះ ខ្លែងព្រៃក៏ឡើងទៅដេកលើខ្នងថ្មដា ។ ទីស្វែងរកអាហារនិងផ្លូវដែលទៅស្វែងរកអាហាររបស់ខ្លែងព្រៃនោះមិនមានឡើយ សូម្បីទឹកស្ទឹងក៏នៅប្រៀបប្រាំងនោះឯង ។ ខ្លែងព្រៃគិតថា អញមិនមានទីស្វែងរកអាហារនិងផ្លូវដែលត្រូវស្វែងរកអាហារ ឧបោសថកម្មជារបស់ប្រសើរ ជាងការដេករបស់អញដែលទំនេរ ដូច្នេះហើយទើបអធិដ្ឋានឧបោសថដោយចិត្តនោះឯង សមាទានសីលដេក ។ ក្នុងកាលនោះ សក្កទេវរាជទ្រង់ពិចារណាមើលទ្រង់ជ្រាបការសមាទានដែលទន់ខ្សោយរបស់ខ្លែងព្រៃនោះ ទ្រង់ព្រះតម្រិះថា អញនឹងសាកល្បងខ្លែងព្រៃនេះ ដូច្នេះទើបជំណែងខ្លួនជាពពែ មកឈរបង្ហាញខ្លួនឲ្យ

---

[១]-បាលីបិដកជា ពក ទើបលោកប្រែថា កុក ឯបាលីអដ្ឋកថាជា វក ដែលប្រែថា ខ្លែងព្រៃ ឯក្នុងគាថាខាងក្រោមក៏យើងកាន់យកពាក្យថា វក គឺខ្លែងព្រៃនេះ បណ្ឌិតគប្បីជ្រាប ។

ឃើញក្នុងទីមិនឆ្ងាយអំពីខ្លែងព្រៃនោះ ។ ខ្លែងព្រៃឃើញពពែនោះហើយគិតថា អញនឹងដឹងក្នុងការរក្សាឧបោសថកម្មក្នុងថ្ងៃដទៃ ដូច្នេះហើយទើបក្រោកឡើងស្ទុះចូលទៅដើម្បីសង្គ្រប់ពពែនោះបរិភោគ ។ ចំណែកពពែរត់ទៅក្នុងទិសផ្សេងៗមិនឲ្យខ្លែងព្រៃនោះខាំខ្លួនបាន ។ ខ្លែងព្រៃមិនអាចខាំពពែបានក៏ត្រឡប់មកដេកលើខ្នងថ្មដានោះឯងទៀត ដោយគិតថា ឧបោសថកម្មរបស់អញមិនទាន់បែកធ្លាយទេ ។ សក្កទេវរាជទ្រង់ប្រថាប់ឈរក្នុងអាកាសដោយអានុភាពរបស់ទ្រង់ទ្រង់តិះដៀលខ្លែងព្រៃនោះថា ប្រយោជន៍អ្វីដោយឧបោសថកម្មរបស់បុគ្គលដែលមានអធ្យាស្រ័យទន់ខ្សោយដូចអ្នក អ្នកមិនដឹងថាយើងជាសក្កទេវរាជទើបបំណងនឹងស៊ីសាច់ពពែ កាលទ្រង់តិះដៀលហើយក៏យាងទៅកាន់ទេវលោកមួយរំពេច ។

មានអភិសម្ពុទ្ធគាថា ៣ ថា

ខ្លែងព្រៃកាលរស់នៅមានសាច់និងឈាមជាភោជន ព្រោះសម្លាប់តែសត្វដទៃ ( ហើយអួតថា ) សមាទាននូវវត្តរក្សាឧបោសថ ។

សក្កទេវរាជបានដឹងច្បាស់នូវវត្តរបស់ខ្លែងព្រៃនោះ ហើយចូលមកដោយ ( ក្លែងខ្លួន ) ជារូបពពែ ខ្លែងព្រៃមានតបៈទៅប្រាសហើយជាសត្វផឹកនូវឈាម ( នៃសត្វដទៃ ) បានស្ទុះចូលទៅ ( ដើម្បីខាំពពែស៊ី ) ហើយក៏ទម្លាយបង់នូវតបៈដែលខ្លួនសមាទានហើយ ។

បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានកម្លាំងថយក្នុងការសមាទានឈ្មោះថា ធ្វើខ្លួនឲ្យរហ័សដូចជាខ្លែព្រៃ ( ដែលទម្លាយនូវតបៈរបស់ខ្លួន ) ព្រោះហេតុតែពពែក៏យ៉ាងនោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧបបជ្ជិ ឧបោសថំ** បានដល់ ចូលទៅរក្សាឧបោសថ ។ បទថា **វតញ្ញាយ** សេចក្ដីថា សក្កទេវរាជទ្រង់ជ្រាបវត្តដ៏ទុព្វលរបស់ខ្លែព្រៃនោះ ។ បទថា **វិតតចោ អជ្ឈប្បត្តោ** សេចក្ដីថា ជាបុគ្គលប្រាសចាកតបៈ ស្ទុះចូលទៅ អធិប្បាយថា ស្ទុះចូលទៅដើម្បីស៊ីពពែនោះ ។ បទថា **លោហិតចោ** ប្រែថា ជាសត្វផឹកឈាមជាប្រក្រតី ។ បទថា **តបំ** សេចក្ដីថា ខ្លែព្រៃទម្លាយតបៈដែលខ្លួនសមាទានហើយនោះ ។

ព្រះសាស្ដាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់សមោធានជាតកថា សក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វកជាតក ចប់**

**កុម្ភវគ្គ ចប់**

**តិកនិបាត ចប់**

# ក្បាលទី ៤៦

## សុត្តន្តបិដក ចាលីប្រែ -៥៨

### សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ


ភជោភាទជាតក .......... .......... .......... .......... .......... .......... ..... ២

អដ្ឋកថា ភជោភាទជាតក .......... .......... .......... .......... .......... .......... ..... ៣

សិគាលជាតក ......... .......... .......... .......... .......... .......... ... ១១

អដ្ឋកថា សិគាលជាតក .......... .......... .......... .......... .......... .......... ១១

សូករជាតក ............... .......... .......... .......... ............. .... ១៨

អដ្ឋកថា សូករជាតក .......... .......... .......... .......... .......... ............ ១៨

ឧរគជាតក .......... .......... .......... .......... .......... ............ ២៣

អដ្ឋកថា ឧរគជាតក .......... .......... .......... .......... .......... ............ ២៣

ភគ្គជាតក .......... .......... .......... .......... .......... ............ ២៩

អដ្ឋកថា ភគ្គជាតក .......... .......... .......... .......... .......... ............ ២៩

អលីនចិត្តជាតក .......... .......... .......... .......... .......... ........... ៣៥

អដ្ឋកថា អលីនចិត្តជាតក .......... .......... .......... .......... .......... ............ ៣៥

គុណជាតក .......... .......... .......... .......... .......... .......... ៤៥

អដ្ឋកថា គុណជាតក .......... .......... .......... .......... .......... .......... ៤៥

សុហនុជាតក .......... .......... .......... .......... .......... .......... ៥៥

អដ្ឋកថា សុហនុជាតក .......... .......... .......... .......... .......... .......... ៥៥

មោរជាតក .......... .......... .......... .......... .......... ......... ៦១

អដ្ឋកថា មោរជាតក .......... .......... .......... .......... .......... ......... ៦២

វិនីលកជាតក .......... .......... .......... .......... .......... ..... ៧១

អដ្ឋកថា វិនីលកជាតក .......... .......... .......... .......... .......... ..... ៧២


## សន្ថវវគ្គ


ឥន្ទសមានគោត្តជាតក .......... .......... .......... .......... .......... .... ៧៦

អដ្ឋកថា ឥន្ទសមានគោត្តជាតក .......... .......... .......... .......... .......... .... ៧៦

សន្ថវជាតក .......... .......... .......... .......... .......... .... ៨១

អដ្ឋកថា សន្ថវជាតក .......... .......... .......... .......... .......... .... ៨១

សុសីមជាតក .......... .......... .......... .......... .......... ..... ៨៥

អដ្ឋកថា សុសីមជាតក .......... .......... .......... .......... .......... ..... ៨៥

គិជ្ឈជាតក .......... .......... .......... .......... .......... .... ៩៤

អដ្ឋកថា គិជ្ឈជាតក .......... .......... .......... .......... .......... .... ៩៤

នកុលជាតក .......... .......... .......... .......... .......... .... ៩៩

អដ្ឋកថា នកុលជាតក .......... .......... .......... .......... .......... .... ៩៩

ឧបសាឡ្ហកជាតក .......... .......... .......... .......... .............. ១០៣

អដ្ឋកថា ឧបសាឡ្ហកជាតក .......... .......... .......... .......... .............. ១០៣

សមិទ្ធិជាតក .......... .......... .......... .......... .............. ១០៨

អដ្ឋកថា សមិទ្ធិជាតក .......... .......... .......... .......... .............. ១០៨

សកុណគ្ឃិជាតក .......... .......... .......... .......... .............. ១១៣

អដ្ឋកថា សកុណគ្ឃិជាតក .......... .......... .......... .......... .............. ១១៣

អរកជាតក .......... .......... .......... .......... .............. ១១៨

អដ្ឋកថា អរកជាតក .......... .......... .......... .......... .............. ១១៨

កកណ្ដកជាតក .......... .......... .......... .......... ............ ១២៣

អដ្ឋកថា កកណ្ដកជាតក .......... .......... .......... .......... .......... ....... ១២៤

# កល្យាណធម្មវគ្គ


កល្យាណធម្មជាតក .......... .......... .......... .......... ................. ១២៥

អដ្ឋកថា កល្យាណធម្មជាតក .......... .......... .......... .......... ................. ១២៦

ទទ្ទរជាតក .......... .......... .......... .......... ................. ១៣១

អដ្ឋកថា ទទ្ទរជាតក .......... .......... .......... .......... ................. ១៣១

មក្កដជាតក .......... .......... .......... .......... ................. ១៣៦

អដ្ឋកថា មក្កដជាតក .......... .......... .......... .......... ................. ១៣៦

ទុតិយមក្កដជាតក .......... .......... .......... .......... ................. ១៤០

អដ្ឋកថា ទុតិយមក្កដជាតក .......... .......... .......... .......... ................. ១៤០

អាទិច្ចុបដ្ឋានជាតក .......... .......... .......... .......... ................. ១៤៤

អដ្ឋកថា អាទិច្ចុបដ្ឋានជាតក .......... .......... .......... .......... ................. ១៤៤

កឡាយមុដ្ឋិជាតក .......... .......... .......... .......... ................ ១៤៨

អដ្ឋកថា កឡាយមុដ្ឋិជាតក .......... .......... .......... .......... ................ ១៤៨

តិន្ទុកជាតក .......... .......... .......... .......... ................ ១៥៣

អដ្ឋកថា តិន្ទុកជាតក .......... .......... .......... .......... ................ ១៥៣

កច្ឆបជាតក .......... .......... .......... .......... ................ ១៥៨

អដ្ឋកថា កច្ឆបជាតក .......... .......... .......... .......... ................ ១៥៨

សតធម្មជាតក .......... .......... .......... .......... ................ ១៦៣

អដ្ឋកថា សតធម្មជាតក .......... .......... .......... .......... ................ ១៦៣

ទុទ្ទទជាតក .......... .......... .......... .......... ............... ១៦៩

អដ្ឋកថា ទុទ្ទទជាតក .......... .......... .......... .......... ............... ១៧០


# អសទិសវគ្គ


អសទិសជាតក .......... .......... .......... .......... ................. ១៧៤

អដ្ឋកថា អសទិសជាតក .......... .......... .......... .......... ................. ១៧៥

សង្គាមាវចរជាតក .......... .......... .......... .......... ................. ១៨៣

អដ្ឋកថា សង្គាមាវចរជាតក .......... .......... .......... .......... ................. ១៨៣

វាលោទកជាតក .......... .......... .......... .......... ................. ១៩០

អដ្ឋកថា វាលោទកជាតក .......... .......... .......... .......... ................. ១៩០

គិរិទត្តជាតក .......... .......... .......... .......... ................. ១៩៥

អដ្ឋកថា គិរិទត្តជាតក .......... .......... .......... .......... ................. ១៩៥

អនភិរតិជាតក .......... .......... .......... .......... ................. ១៩៩

អដ្ឋកថា អនភិរតិជាតក .......... .......... .......... .......... ................. ១៩៩

ទធិវាហនជាតក .......... .......... .......... .......... ................. ២០៣

អដ្ឋកថា ទធិវាហនជាតក .......... .......... .......... .......... ................. ២០៣

ចតុមដ្ឋជាតក .......... .......... .......... .......... ................. ២១២

អដ្ឋកថា ចតុមដ្ឋជាតក .......... .......... .......... .......... .......... ..... ២១២

សីហកោត្ថុកជាតក .......... .......... .......... .......... ................. ២១៦

អដ្ឋកថា សីហកោត្ថុកជាតក .......... .......... .......... .......... ................. ២១៦

សីហចម្មជាតក .......... .......... .......... .......... ................. ២១៩

អដ្ឋកថា សីហចម្មជាតក .......... .......... .......... .......... ................. ២១៩

សីលានិសំសជាតក .......... .......... .......... .......... ................. ២២២

អដ្ឋកថា សីលានិសំសជាតក .......... .......... .......... .......... ................. ២២៣

## រុហកវគ្គ

រុហកជាតក .......... .......... .......... .......... ................. ២២៧

អដ្ឋកថា រុហកជាតក .......... .......... .......... .......... ................. ២២៨

សិរិកាឡកណ្ណិជាតក .......... .......... .......... .......... ................. ២៣២

អដ្ឋកថា សិរីកាឡកណ្ណិជាតក .......... .......... .......... .......... ................ ២៣២
ចុល្លបទុមជាតក .......... .......... .......... .......... ................ ២៣៣
អដ្ឋកថា ចូឡបទុមជាតក .......... .......... .......... .......... ................ ២៣៣
មណិចោរជាតក .......... .......... .......... .......... ................ ២៤៣
អដ្ឋកថា មណិចោរជាតក .......... .......... .......... .......... ................ ២៤៣
បព្វតូបត្ថរជាតក .......... .......... .......... .......... ................ ២៥០
អដ្ឋកថា បព្វតូបត្ថរជាតក .......... .......... .......... .......... ................ ២៥០
វលាហកជាតក .......... .......... .......... .......... ................ ២៥៥
អដ្ឋកថា វលាហកជាតក .......... .......... .......... .......... ................ ២៥៥
មិត្តាមិត្តជាតក .......... .......... .......... .......... ................ ២៦១
អដ្ឋកថា មិត្តាមិត្តជាតក .......... .......... .......... .......... ................ ២៦១
រាធជាតក .......... .......... .......... .......... ................ ២៦៥
អដ្ឋកថា រាធជាតក .......... .......... .......... .......... ................ ២៦៥
គហបតិជាតក .......... .......... .......... .......... ................ ២៦៩
អដ្ឋកថា គហបតិជាតក .......... .......... .......... .......... ................ ២៦៩
សាធុសីលជាតក .......... .......... .......... .......... ................ ២៧៤
អដ្ឋកថា សាធុសីលជាតក .......... .......... .......... .......... ................ ២៧៥

## ឆត្ថនិបាតវគ្គ

ពន្ធនាគារជាតក .......... .......... .......... .......... ................ ២៧៩
អដ្ឋកថា ពន្ធនាគារជាតក .......... .......... .......... .......... ................ ២៨០
កេឡិសីលជាតក .......... .......... .......... .......... .......... ........ ២៨៥
អដ្ឋកថា កេឡិសីលជាតក .......... .......... .......... .......... .......... ........ ២៨៥
ខន្ធបរិត្តជាតក .......... .......... .......... .......... .......... ........ ២៩១

អដ្ឋកថា ខទូបរិត្តជាតក .......... .......... .......... .......... .......... ........ ២៩២
វីរកជាតក .......... .......... .......... .......... .......... ......... ៣០១
អដ្ឋកថា វីរកជាតក .......... .......... .......... .......... .......... .......... ៣០១
គង្គេយ្យជាតក .......... .......... .......... .......... .......... ........ ៣០៥
អដ្ឋកថា គង្គេយ្យជាតក .......... .......... .......... .......... .......... ........ ៣០៥
កុរុង្គមិគជាតក .......... .......... .......... .......... .......... ......... ៣០៩
អដ្ឋកថា កុរុង្គមិគជាតក .......... .......... .......... .......... .......... ......... ៣០៩
អស្សកជាតក .......... .......... .......... .......... .......... ......... ៣១៤
អដ្ឋកថា អស្សកជាតក .......... .......... .......... .......... .......... ......... ៣១៤
សុំសុមារជាតក .......... .......... .......... .......... .......... ......... ៣២០
អដ្ឋកថា សុំសុមារជាតក .......... .......... .......... .......... .......... ......... ៣២០
កក្ករជាតក .......... .......... .......... .......... .......... .......... ៣២៤
អដ្ឋកថា កក្ករជាតក .......... .......... .......... .......... .......... ....... ៣២៤
កន្ទគលកជាតក .......... .......... .......... .......... .......... ........ ៣២៧
អដ្ឋកថា កន្ទគលកជាតក .......... .......... .......... .......... .......... ........ ៣២៨

## ពីរណាត្ថម្ភកវគ្គ

សោមទត្តជាតក .......... .......... .......... .......... .......... ........ ៣៣២
អដ្ឋកថា សោមទត្តជាតក .......... .......... .......... .......... .......... ........ ៣៣២
ឧច្ឆិដ្ឋភត្តជាតក .......... .......... .......... .......... .......... ....... ៣៣៧
អដ្ឋកថា ឧច្ឆិដ្ឋភត្តជាតក .......... .......... .......... .......... .......... ......... ៣៣៧
ភរុរាជជាតក .......... .......... .......... .......... .......... ........ ៣៤១
អដ្ឋកថា ភរុរាជជាតក .......... .......... .......... .......... .......... ........ ៣៤១
បុណ្ណនទីជាតក .......... .......... .......... .......... .......... ......... ៣៤៤

អដ្ឋកថា បុណ្ណនទីជាតក .......... .......... .......... .......... .......... ......... ៣៤៨

កច្ឆបជាតក .......... .......... .......... .......... .......... ......... ៣៥៣

អដ្ឋកថា កច្ឆបជាតក .......... .......... .......... .......... .......... ......... ៣៥៣

មច្ឆជាតក .......... .......... .......... .......... .......... .......... ៣៥៨

អដ្ឋកថា មច្ឆជាតក .......... .......... .......... .......... .......... .......... ៣៥៨

សេគ្គុជាតក .......... .......... .......... .......... .......... ......... ៣៦២

អដ្ឋកថា សេគ្គុជាតក .......... .......... .......... .......... .......... .......... ៣៦២

កូដវាណិជជាតក .......... .......... .......... .......... .......... ......... ៣៦៥

អដ្ឋកថា កូដវាណិជជាតក .......... .......... .......... .......... .......... ........ ៣៦៥

គរហិតជាតក .......... .......... .......... .......... .......... ......... ៣៧១

អដ្ឋកថា គរហិតជាតក .......... .......... .......... .......... .......... ......... ៣៧១

ធម្មទ្ធជជាតក .......... .......... .......... .......... .......... ......... ៣៧៦

អដ្ឋកថា ធម្មទ្ធជជាតក .......... .......... .......... .......... .......... ......... ៣៧៧

## កាសាវវគ្គ

កាសាវជាតក .......... .......... .......... .......... .......... ......... ៣៩៥

អដ្ឋកថា កាសាវជាតក .......... .......... .......... .......... .......... ........ ៣៩៦

ចុល្លនន្ទិយជាតក .......... .......... .......... .......... .......... ......... ៤០១

អដ្ឋកថា ចុល្លនន្ទិយជាតក ......... .......... .......... .......... .......... .......... ៤០១

បុដកត្តជាតក .......... .......... .......... .......... ................ ៤០៧

អដ្ឋកថា បុដកត្តជាតក ........... .......... .......... .......... ................ ៤០៧

កុម្ភីលជាតក ........... .......... .......... .......... .............. ៤១៤

អដ្ឋកថា កុម្ភីលជាតក ........... .......... .......... .......... .............. ៤១៤

ខន្តិវណ្ណនជាតក ........... .......... .......... .......... .............. ៤១៦

អដ្ឋកថា ខន្តិវណ្ណនជាតក ......... .......... .......... .......... .................. ៤១៦
កោសិយជាតក .......... .......... .......... .......... ............... ៤១៩
អដ្ឋកថា កោសិយជាតក .......... .......... .......... .......... ............... ៤១៩
គូថបាណកជាតក .......... .......... .......... .......... .............. ៤២៣
អដ្ឋកថា គូថបាណកជាតក .......... .......... .......... .......... .......... .. ៤២៣
កាមនីតជាតក .......... .......... .......... .......... .............. ៤២៨
អដ្ឋកថា កាមនីតជាតក .......... .......... .......... .......... ............... ៤២៨
បលាយិជាតក .......... .......... .......... .......... .............. ៤៣៥
អដ្ឋកថា បលាយិជាតក .......... .......... .......... .......... .............. ៤៣៥
ទុតិយបលាយិជាតក .......... .......... .......... .......... .......... .. ៤៣៩
អដ្ឋកថា ទុតិយបលាយិជាតក .......... .......... .......... .......... .............. ៤៤១

## ឧបាហនវគ្គ

ឧបាហនជាតក .......... .......... .......... .......... .............. ៤៤៥
អដ្ឋកថា ឧបាហនជាតក .......... .......... .......... .......... .............. ៤៤៥
វីណាថូណជាតក .......... .......... .......... .......... .............. ៤៥១
អដ្ឋកថា វីណាថូណជាតក .......... .......... .......... .......... .............. ៤៥១
វិកណ្ណកជាតក .......... .......... .......... .......... ............... ៤៥៥
អដ្ឋកថា វិកណ្ណកជាតក .......... .......... .......... .......... .......... .......... ៤៥៥
អសិតាភុជាតក .......... .......... .......... .......... .......... .......... ៤៦០
អដ្ឋកថា អសិតាភុជាតក .......... .......... .......... .......... .......... .......... ៤៦០
វច្ឆនខជាតក .......... .......... .......... .......... .......... .......... ៤៦៥
អដ្ឋកថា វច្ឆនខជាតក .......... .......... .......... .......... .......... ......... ៤៦៥
ពកជាតក .......... .......... .......... .......... .......... .......... ៤៧០

អដ្ឋកថា ពកជាតក .......... .......... .......... .......... .......... ......... ៤៧០

សាកេតជាតក .......... .......... .......... .......... .......... ........ ៤៧៣

អដ្ឋកថា សាកេតជាតក .......... .......... .......... .......... .......... ........ ៤៧៣

ឯកបទជាតក .......... .......... .......... .......... .......... ....... ៤៧៦

អដ្ឋកថា ឯកបទជាតក .......... .......... .......... .......... .......... ........ ៤៧៦

ហរិតមាតជាតក .......... .......... .......... .......... ........... ....... ៤៨០

អដ្ឋកថា ហរិតមាតជាតក .......... .......... .......... .......... ........... ..... ៤៨០

មហាបិង្គលជាតក .......... .......... .......... .......... .......... ........ ៤៨៤

អដ្ឋកថា មហាបិង្គលជាតក .......... .......... .......... .......... ........... ....... ៤៨៦

## សិគាលវគ្គ

សព្វទាឋិជាតក .......... .......... .......... .......... .......... ........ ៤៩១

អដ្ឋកថា សព្វទាឋិជាតក .......... .......... .......... .......... ........... ....... ៤៩១

សុនខជាតក .......... .......... .......... .......... .......... ........ ៤៩៧

អដ្ឋកថា សុនខជាតក .......... .......... .......... .......... ........... ..... ៤៩៧

គុត្តិលជាតក .......... .......... .......... .......... ........... ..... ៥០១

អដ្ឋកថា គុត្តិលជាតក .......... .......... .......... .......... ........... ..... ៥០១

វិគតិច្ឆជាតក .......... .......... .......... .......... ................ ៥១៥

អដ្ឋកថា វិគតិច្ឆជាតក .......... .......... .......... .......... ................ ៥១៥

មូលបរិយាយជាតក .......... .......... .......... .......... ................ ៥១៩

អដ្ឋកថា មូលបរិយាយជាតក .......... .......... .......... .......... ................ ៥១៩

ពាលោវាទជាតក .......... .......... .......... .......... ................ ៥២៤

អដ្ឋកថា ពាលោវាទជាតក .......... .......... .......... .......... ................ ៥២៤

បាទញ្ជលិជាតក .......... .......... .......... .......... ................ ៥២៨

អដ្ឋកថា បាទញ្ជលិជាតក .......... .......... .......... .......... ................ ៥២៨
កឹស្សុកោបមជាតក .......... .......... .......... .......... ................ ៥៣២
អដ្ឋកថា កឹស្សុកោបមជាតក .......... .......... .......... .......... ................ ៥៣២
សាលកជាតក .......... .......... .......... .......... ................ ៥៣៦
អដ្ឋកថា សាលកជាតក .......... .......... .......... .......... ................ ៥៣៦
កបិជាតក .......... .......... .......... .......... ................ ៥៤០
អដ្ឋកថា កបិជាតក .......... .......... .......... .......... ................ ៥៤២

# តិកនិបាតជាតក

## សង្កប្បវគ្គ

សង្កប្បរាគជាតក .......... .......... .......... .......... ................ ៥៤៦
អដ្ឋកថា សង្កប្បរាគជាតក .......... .......... .......... .......... ................ ៥៤៧
តិលមុដ្ឋិជាតក .......... .......... .......... .......... ................ ៥៥៧
អដ្ឋកថា តិលមុដ្ឋិជាតក .......... .......... .......... .......... ................ ៥៥៧
មណិកណ្ឋជាតក .......... .......... .......... .......... ................ ៥៦៨
អដ្ឋកថា មណិកណ្ឋជាតក .......... .......... .......... .......... ............. ៥៦៨
កុណ្ឌកកុច្ឆិសិន្ធវជាតក .......... .......... .......... .......... ............. ៥៧៦
អដ្ឋកថា កុណ្ឌកកុច្ឆិសិន្ធវជាតក .......... .......... .......... .......... ........... ៥៧៦
សុកជាតក .......... .......... .......... .......... ............. ៥៨៦
អដ្ឋកថា សុកជាតក .......... .......... .......... .......... ............. ៥៨៦
ជរូទបានជាតក .......... .......... .......... .......... ............. ៥៩២
អដ្ឋកថា ជរូទបានជាតក .......... .......... .......... .......... ............. ៥៩២
គាមណិចន្ទជាតក .......... .......... .......... .......... ............. ៥៩៧
អដ្ឋកថា គាមណិចន្ទជាតក .......... .......... .......... .......... ............. ៥៩៧

មន្ទាតុរាជជាតក .......... .......... .......... .......... ............ ៦២០

អដ្ឋកថា មន្ទាតុរាជជាតក .... .......... .......... .......... ............ ៦២០

តិរិតិវច្ឆជាតក .......... .......... .......... .......... ........... ៦២៨

អដ្ឋកថា តិរិតិវច្ឆជាតក ......... .......... .......... .......... ........... ៦២៩

ទូតជាតក .......... .......... .......... .......... ........... ៦៣៧

អដ្ឋកថា ទូតជាតក .......... .......... .......... .......... ........... ៦៣៩

## បទុមវគ្គ

បទុមជាតក .......... .......... .......... .......... ............. ៦៤៣

អដ្ឋកថា បទុមជាតក .......... .......... .......... .......... ............ ៦៤៤

មុទុបាណិជាតក .......... .......... .......... .......... ............. ៦៤៨

អដ្ឋកថា មុទុបាណិជាតក .......... .......... .......... .......... ............. ៦៤៨

ចុល្លបលោភនជាតក .......... .......... .......... .......... ............. ៦៥៧

អដ្ឋកថា ចុល្លបលោភនជាតក ......... .......... .......... .......... ............. ៦៥៧

មហាបនាទជាតក .......... .......... .......... .......... ................ ៦៦៤

អដ្ឋកថា មហាបនាទជាតក .......... .......... .......... .......... ............... ៦៦៤

ខុរប្បជាតក .......... .......... .......... .......... ................ ៦៧២

អដ្ឋកថា ខុរប្បជាតក .......... .......... .......... .......... ................ ៦៧៣

វាតគ្គសិន្ធវជាតក .......... .......... .......... .......... ............... ៦៧៧

អដ្ឋកថា វាតគ្គសិន្ធវជាតក .......... .......... .......... .......... ................ ៦៧៧

សុវណ្ណកក្កដកជាតក .......... .......... .......... .......... ................ ៦៨៤

អដ្ឋកថា សុវណ្ណកក្កដកជាតក .......... .......... .......... .......... ................ ៦៨៥

អារាមទូសកជាតក .......... .......... .......... .......... ................ ៦៩២

អដ្ឋកថា អារាមទូសកជាតក .......... .......... .......... .......... ................ ៦៩២

សុជាតាជាតក .......... .......... .......... .......... ................ ៦៩៧
អដ្ឋកថា សុជាតជាតក .......... .......... .......... .......... ................ ៦៩៧
ឧលូកជាតក .......... .......... .......... .......... ................ ៧០៦
អដ្ឋកថា ឧលូកជាតក .......... .......... .......... .......... ................ ៧០៧

## ឧទបានវគ្គ

ឧទបានទូសកជាតក .......... .......... .......... .......... ................ ៧១២
អដ្ឋកថា ឧទបានទូសកជាតក .......... .......... .......... .......... ................ ៧១៣
ព្យគ្ឃជាតក .......... .......... .......... .......... ................ ៧១៧
អដ្ឋកថា ព្យគ្ឃជាតក .......... .......... .......... .......... ................ ៧១៧
កច្ឆបជាតក .......... .......... .......... .......... ................ ៧២៣
អដ្ឋកថា កច្ឆបជាតក .......... .......... .......... .......... ................ ៧២៣
លោលជាតក .......... .......... .......... .......... ................ ៧២៨
អដ្ឋកថា លោលជាតក .......... .......... .......... .......... .......... ........ ៧២៨
រុចិរជាតក .......... .......... .......... .......... .......... .......... ៧៣៤
អដ្ឋកថា រុចិរជាតក .......... .......... .......... .......... .......... .......... ៧៣៤
កុរុធម្មជាតក .......... .......... .......... .......... .......... ........ ៧៣៧
អដ្ឋកថា កុរុធម្មជាតក .......... .......... .......... .......... .......... ........ ៧៣៧
រោមជាតក .......... .......... .......... .......... .......... ........ ៧៦៤
អដ្ឋកថា រោមជាតក .......... .......... .......... .......... .......... ....... ៧៦៥
មហិសជាតក .......... .......... .......... .......... .......... ........ ៧៧០
អដ្ឋកថា មហិសជាតក .......... .......... .......... .......... .......... ........ ៧៧០
សតបត្តជាតក .......... .......... .......... .......... .......... ........ ៧៧៥
អដ្ឋកថា សតបត្តជាតក .......... .......... .......... .......... .......... ........ ៧៧៥

បូជទូសកជាតក .......... .......... .......... .......... .......... ........ ៧៨៣
អដ្ឋកថា បូជទូសកជាតក .......... .......... .......... .......... .......... ........ ៧៨៤

# អព្ភន្តរវគ្គ

អព្ភន្តរជាតក .......... .......... .......... .......... .......... ........ ៧៨៧
អដ្ឋកថា អព្ភន្តរជាតក .......... .......... .......... .......... .......... ........ ៧៨៨
សេយ្យជាតក .......... .......... .......... .......... .......... ........ ៨០២
អដ្ឋកថា សេយ្យជាតក .......... .......... .......... .......... .......... ........ ៨០៣
វឌ្ឍកីសូករជាតក .......... .......... .......... .......... .......... ........ ៨០៩
អដ្ឋកថា វឌ្ឍកីសូករជាតក .......... .......... .......... .......... .......... ........ ៨១០
សិរីជាតក .......... .......... .......... .......... .......... ....... ៨២១
អដ្ឋកថា សិរីជាតក .......... .......... .......... .......... .......... ....... ៨២១
មណិសូករជាតក .......... .......... .......... .......... ............. ៨៣២
អដ្ឋកថា មណិសូករជាតក .......... .......... .......... .......... ............. ៨៣២
សាលុកជាតក .......... .......... .......... .......... ............. ៨៤០
អដ្ឋកថា សាលុកជាតក .......... .......... .......... .......... ............. ៨៤០
លាភគរហិកជាតក .......... .......... .......... .......... ............. ៨៤៥
អដ្ឋកថា លាភគរហិកជាតក ........ .......... .......... ............ .............. ៨៤៦
មច្ឆទានជាតក .......... .......... .......... .......... ............. ៨៥២
អដ្ឋកថា មច្ឆទានជាតក .......... .......... .......... .......... .............. ៨៥២
នានាឆន្ទជាតក .......... .......... .......... .......... ............... ៨៥៨
អដ្ឋកថា នានាឆន្ទជាតក .......... .......... .......... .......... .............. ៨៥៩
សីលវីមំសជាតក .......... .......... .......... .......... .............. ៨៦៤
អដ្ឋកថា សីលវីមំសជាតក ............. ......... .......... .......... .............. ៨៦៦

# កុម្ភវគ្គ


កទ្រយជភេទកជាតក .......... .......... .......... .......... ............... ៨៦៩

អដ្ឋកថា កទ្រយជភេទជាតក ............... .......... ........... .............. ៨៦៩

សុបត្តជាតក .......... .......... .......... .......... ............... ៨៧៤

អដ្ឋកថា សុបត្តជាតក .......... .......... .......... .......... .............. ៨៧៤

កាយនិព្វិន្ទជាតក .......... .......... .......... .......... .............. ៨៨២

អដ្ឋកថា កាយនិព្វិន្ទជាតក .......... .......... .......... .......... .............. ៨៨២

ជម្ពុខាទកជាតក .......... .......... .......... .......... ............. ៨៨៧

អដ្ឋកថា ជម្ពុខាទកជាតក .......... .......... .......... .......... .............. ៨៨៧

អន្តជាតក .......... .......... .......... .......... ............. ៨៩១

អដ្ឋកថា អន្តជាតក .......... .......... .......... .......... .......... .... ៨៩១

សមុទ្ទជាតក .......... .......... .......... .......... .......... .... ៨៩៤

អដ្ឋកថា សមុទ្ទជាតក .......... .......... .......... .......... .......... .... ៨៩៤

កាមវិលាបជាតក .......... .......... .......... .......... .......... .... ៨៩៩

អដ្ឋកថា កាមវិលាបជាតក .......... .......... .......... .......... .......... .... ៨៩៩

ឧទុម្ពរជាតក .......... .......... .......... .......... .......... .... ៩០៣

អដ្ឋកថា ឧទុម្ពរជាតក .......... .......... .......... .......... .......... .... ៩០៣

កោមារិយបុត្តជាតក .......... .......... .......... .......... .......... ..... ៩០៨

អដ្ឋកថា កោមារិយបុត្តជាតក ...... .......... .......... .......... .......... ..... ៩០៩

ពកជាតក .......... .......... .......... .......... .......... ..... ៩១៤

អដ្ឋកថា ពកជាតក ......... .......... .......... .......... .......... ..... ៩១៦